# ក្បួនពិធីអភិបូជា
# តាមក្រុងរ៉ូម

MISSALE ROMANUM

# អារម្ភកថា

តាំងពីព្រះសហគមន៍បានចូលមកប្រទេសកម្ពុជា ការងារបកប្រែ ជាការចាំបាច់ពីព្រោះគ្រីស្តបរិស័ទត្រូវការសៀវភៅសម្រាប់អប់រំជំនឿ។ ក្រោយមក យោងតាមស្មារតីរបស់មហាសន្និបាតវ៉ាទីកង់ទី២ លោកអភិបាល អ៊ីវ រ៉ាមូស (Yves Ramousse) បានណែនាំព្រះសហគមន៍ឲ្យកែប្រែរបៀបប្រារព្ធពិធីបុណ្យស្របតាមប្រពៃណីខ្មែរ។ ជាពិសេសលោកសុំឲ្យគេបកប្រែក្បួនពិធីអភិបូជាពីភាសាឡាតាំងមកជាភាសាខ្មែរ។ ក្រសួងពិធីបុណ្យនៃសន្តអាសនៈបានអនុញ្ញាតឲ្យប្រើឯកសារថ្មីនេះ ជាបណ្ដោះអាសន្ន នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៦៥។ បន្ទាប់មកទៀត លោកបូជាចារ្យ ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ (François Ponchaud) ប្រធានមណ្ឌលវប្បធម៌កាតូលិកកម្ពុជា បានជួយកែសម្រួលអត្ថបទទាំងនោះ តាម កាលៈទេសៈ ដូចជានៅពេលជនភៀសខ្លួនខ្មែរ ធ្វើមាតុភូមិនិវត្តន៍ពីជំរំតាមព្រំដែន កម្ពុជា-ថៃ មក កម្ពុជាវិញជាដើម។

នៅឆ្នាំ២០០៦ ក្រុមលោកអភិបាលព្រះសហគមន៍នៅកម្ពុជា បានបង្កើតឲ្យមានគណៈកម្មាធិការពិធីបុណ្យអន្តរភូមិភាគជាផ្លូវការ ដើម្បីកែសម្រួលក្បួនពិធីបុណ្យឲ្យស្របតាមឯកសារចុងក្រោយរបស់ក្រុងរ៉ូម (Missale Romanum) ដោយទទួលគំនិត និងយោបល់ពីមនុស្សជាច្រើន។ លោកអភិបាល អេមីល ដេតម្ប (Emile Destombes) ជាប្រធានគណៈកម្មាធិការនេះ មានសមាជិកមកពីភូមិភាគទាំងបី ជាអ្នកឯកទេស ដូចជា ទេវវិទ្យា គម្ពីរវិទ្យា ភាសាឡាតាំង និងភាសាខ្មែរៈ

១. លោកអភិបាល អេមីល ដេតម្ប (Emile Destombes) ប្រធាន (២០០៦-២០១០)។
២. លោកអភិបាល អង់តូនីសាមី ស៊ូសៃរាជ្យ (Antonysamy Susairaj) បន្តតំណែងជាប្រធាននៃគណៈកម្មាធិការពិធីបុណ្យអន្តរភូមិភាគ បន្ទាប់ពីលោកអភិបាល អេមីល ដេតម្ប ចូលនិវត្តន៍
៣. លោកបូជាចារ្យ សេរ៉ាល វ៉ូហ្សាំង (Gérald Vogin) ជា លេខាធិការ
៤. លោកបូជាចារ្យ វ៉ាំងសង់ សេនេឆាល់ (Vincent Sénéchal) ឯកទេសខាងគម្ពីរវិទ្យា និងភាសាក្រិក
៥. លោកបូជាចារ្យ តូនី វែនដ្រាមីន (Antonio Vendramin) ឯកទេសភាសាឡាតាំង

៦. លោកបូជាចារ្យ ប៉ូល រឿងឆ័ត្រសិរី (Roeung Chatsirey) ឯកទេសភាសាថៃ

៧.លោកបូជាចារ្យ ទម្លាប់ សុផល (Tonlop Sophal) សម្រួលខាងភាសាខ្មែរ

៨.លោកបូជាចារ្យ អ៊ែនរីកូ ហ្វីដានហ្សា (Enrico Fidanza) ឯកទេសភាសាឡាតាំង

៩.លោកបូជាចារ្យ ហ្វ្រង់កូ ឡេញ៉ានី (Franco Legnani) ឯកទេសភាសាឡាតាំង

១០. លោកបូជាចារ្យ ហ៊ាន់ (Juan Jesus Solorzano) បកប្រែសេចក្ដីណែនាំរបស់សន្និបាតវ៉ាទីកង់ទី២។

១១. លោកបូជាចារ្យ ហ្វារនើ ដាមីញ៉ាំង (Damien Fahrner) បកប្រែសេចក្ដីណែនាំរបស់មហាសន្និបាតវ៉ាទីកង់ទី២។

១២.បងស្រី អ៊ីយឿង ម៉ារីអង់ (Y Yoeung Marie-Ange) ឯកទេសភាសាឡាតាំង

១៣.បងស្រី អាង សង្វាត (Ang Sangvath) សម្រួលខាងភាសាខ្មែរ

១៤.អ្នកស្រី សាឡៃ សង្ឃឹម (Salay Sangkhum) សម្រួលខាងភាសាខ្មែរ

១៥.អ្នកស្រី ប៉ុល ខាំថង (Pol Kamthang) សម្រួលខាងភាសាខ្មែរ

១៦.លោក លី សុវណ្ណា (Ly Sovanna) សម្រួលខាងភាសាខ្មែរ

១៧.លោក ដួង សាវង់ (Duong Savong) សម្រួលខាងភាសាខ្មែរ

១៨.លោក យ៉ាន សុគុន្ធ (Yan Sokun) សម្រួលខាងភាសាខ្មែរ

១៩.កញ្ញា សំ អានីត្តា (Sam Anita) វាយកុំព្យូទ័រ ។

អស់រយៈពេល ១០ឆ្នាំ គណៈកម្មាធិការបកប្រែបានជួបជុំគ្នា ២ ឬ ៣ថ្ងៃ ជារៀងរាល់ខែ។ គណៈកម្មាធិការយើងបានសុំយោបល់ពីលោកបូជាចារ្យ និងបងប្អូនគ្រីស្តបរិស័ទឯទៀតៗ ហើយបានទទួលយោបល់ និងសំណើរបស់បងប្អូនទាំងនោះ តាមតែអាច ធ្វើបាន។

ក្នុងសៀវភៅក្បួនពិធីអភិបូជាថ្មីនេះ យើងខ្ញុំមិនទាន់ឯកភាពនូវពាក្យពេចន៍មួយចំនួន ដូចជាពាក្យ "មានព្រះជន្មរស់ឡើងវិញ" ឬ "មានព្រះជន្មថ្មីដ៏រុងរឿង" "គម្រោងការដ៏អស្ចារ្យ" ឬ "ការអាថ៌កំបាំងដ៏អស្ចារ្យ" ។ល។ ដូច្នេះ យើងបានសម្រុះ សម្រួលតាមសភាពការណ៍ និងអត្ថន័យនៃបរិបទ។ រយៈពេលកន្លងមកនេះ មាន សមាជិកនៃគណៈកម្មាធិការយើងចំនួនពីរនាក់បានចែកឋានទៅឯព្រះអង្គ គឺលោក អភិបាល អេមីល ដេតម្ប និងអ្នកស្រី ប៉ុល ខាំថង។ យើងមិនអាចភ្លេចគុណសម្បត្តិ របស់អ្នកទាំងពីរទេ ហើយយើងក៏ជឿថា អ្នកទាំងពីរនៅតែអង្វរព្រះជាម្ចាស់ឲ្យ គណៈកម្មាធិការរបស់យើងអាចសម្រេចការងារនេះបាន។

*ជាទីបញ្ចប់ យើងសូមឲ្យអស់លោកអ្នកដែលប្រើសៀវភៅ ក្បួនអភិបូជាថ្មីនេះចាប់អារម្មណ៍មើលកំណត់សម្គាល់នៅចុងទំព័រ ដែលរំឭកអំពីរបៀបថ្វាយអភិបូជា តាមវប្បធម៌ខ្មែរ ជាពិសេស កាយវិការរបស់លោកបូជាចារ្យដែលបានទទួលការ អនុញ្ញាតពីសន្តអាសនៈ ដូចជា ការប្រណម្យដៃពេលអធិដ្ឋាន ការក្រាបថ្វាយបង្គំ និងការអង្គុយបត់ជើងលើកន្ទេលជាដើម។*

*សូមព្រះជាម្ចាស់ប្រទានពរដល់ព្រះសហគមន៍យើងខ្ញុំផង។*

*ភ្នំពេញ, ថ្ងៃទី ០៩ ធ្នូ ២០១៦*

*លោកបូជាចារ្យ សេប៉ាល វ៉ូហ្សាំង*

# លិខិតស្នើសុំច្បាប់អនុញ្ញាតពីក្រសួងពិធីបុណ្យនៃសន្តអាសនៈ

# ស្តីអំពីក្បួនពិធីអភិបូជាថ្មីជាភាសាខ្មែរ

To
His Eminence Cardinal,
Congregation for Divine Worship and the Discipline of the Sacraments
Vatican, Rome, Italy

His Eminence Cardinal,
Hereby I am forwarding this New Khmer Missal from Cambodia, for your approval and guidance. This new translation of Missale Romanum in Khmer language is the fruit of the work of Liturgical Commission that is represented by all the three Eccl. Circumscriptions of Cambodia, namely
Apostolic Vicariate of Phnom Penh
Apostolic Prefecture of Battambang
Apostolic Prefecture of Kompong Cham.
This team of translation consists of priests and laity, with members who are competent in different fields such as study of Bible, liturgy, and languages such as Latin, French, English, Khmer, and a deep sense of awareness of the Catholic faithful who will benefit by this Missal, so as to be able to participate in the divine liturgy, with a deep sense of prayer and with a sense of the presence of God through every moment of the Liturgy.

This translation work has been going on since 10 years with regular sessions of two to three days every month all these years. We thank God for the cooperation of the members of this translation team, and the frequent feedback received from both priests, religious and laity so as to improve the choice of words that express as closely as possible the Latin Original both in words and spirit.

While entrusting this new translation in Khmer to your guidance and approval, we continue to offer our prayers for your sacred Congregation that is vital to inspire and edify us to benefit more and more from our Eucharistic Sacrifices.

With loving prayers and awaiting your prayers,

BISHOP-IN-CHARGE

Yours in Our Lord,
Fr. S. Antony Samy, Mep, 27th Jan 2017
Mgr.S.Antonysamy, Mep
Apostolic Prefect of Kompong Cham
In charge of Liturgical Commission of Cambodia

Hereby I also include the support of the two other ordinaries of Cambodia

+ Olivier Schmitthaeusler

Bishop Olivier Schmitthaeusler, Mep
Apostolic Vicar
Phnom Penh

+E.Figaredo SJ

Mgr. Enrique Figaredo, Sj
Apostolic Prefect
Battambang

# ធម្មនុញ្ញព្រះសហគមន៍

## ក្បួនពិធីអភិបូជាក្រុងរ៉ូម
## តាមក្រឹត្យអនុញ្ញាតរបស់មហាសន្និបាតវ៉ាទីកង់ទី២

**CONSTITUTIO APOSTOLICA**

MISSALE ROMANUM
EX DECRETO CONCILII CECUMENICI VATICANI II
INSTURATUM PROMULGATUR

*ខ្ញុំប៉ូលជាអភិបាលព្រះសហគមន៍*

*ជាអ្នកបម្រើរបស់ព្រះជាម្ចាស់*

*សូមប្រកាសធម្មនុញ្ញនេះ ដើម្បីជួយឲ្យបងប្អូនចងចាំរហូតតរៀងទៅ*

នៅឆ្នាំ១៥៧០ សម្ដេចប៉ាប ភីយ៉ូសទី៥ (Pius V) ជាបុព្វបុរសរបស់យើងបានប្រកាសឲ្យប្រើក្បួនពិធីអភិបូជាតាមច្បាប់នៃមហាសន្និបាតត្រែន (Trente) [1] ហើយអស់លោក ក៏បានទទួលនូវផលផ្លែដ៏ល្អមកពីមហាសន្និបាត ដោយប្រកាសឲ្យប្រើក្បួនពិធីនោះតាមព្រះសហគមន៍ទាំងអស់។ រយៈពេលបួនសតវត្សកន្លងមក មិនត្រឹមតែផ្ដល់ឲ្យអស់លោកបូជាចារ្យប្រើក្បួនពិធីតាមច្បាប់ឡាតាំង សម្រាប់ពិធីអរព្រះគុណដ៏វិសុទ្ធ ប៉ុន្តែ ត្រូវតែគោរពប្រតិបត្តិតាមព្រះគម្ពីរដំណឹងល្អមុនគេ ស្ទើរតែទូទាំងពិភពលោក។ ម៉្យាងទៀតក្នុងក្បួនពិធីនោះ សម្រាប់សន្តបុគ្គល និងគ្រីស្តបរិស័ទជាច្រើនបានទទួលផលផ្លែខាងវិញ្ញាណ ដោយគោរពស្រឡាញ់ឆ្ពោះទៅរកព្រះជាម្ចាស់របស់ខ្លួន ខាងអានព្រះគម្ពីរដ៏វិសុទ្ធ ឬខាងអធិដ្ឋានដែលបានរៀបចំឡើងវិញនូវក្បួនពិធីនោះ គឺជាសេចក្ដីបំព្រួញនៃខ្លឹមសាររបស់សម្ដេចប៉ាប ហ្គ្រេហ្គ័រ ជាជនដ៏ឧត្ដុង្គឧត្ដម (Saint Gregory the Great)។

[1] Cf. Apost. Const. Quo primun, July 13, 1570.

សម្តេចប៉ាប ភីយ៉ូស ទី៧ (Pius XII) ជាបុព្វបុរសរបស់យើងយល់ថា តាំងពីមានការរីកចម្រើន និងបានប្រកាសក្នុងចំណោមគ្រីស្តបរិស័ទ ក្បួនពិធីបុណ្យចាប់ផ្តើមរៀបចំឡើងវិញបានល្អ ជាសញ្ញាសម្គាល់បង្ហាញថា វត្តមានរបស់ព្រះជាម្ចាស់ និងព្រះវិញ្ញាណដ៏វិសុទ្ធថែរក្សាណែនាំដល់ព្រះសហគមន៍។[2] ដូច្នេះ ត្រូវពិនិត្យពិច័យក្បួននេះ និងបន្ថែមខ្លឹមសារខ្លះៗនៃក្បួនពិធីអភិបូជាក្រុងរ៉ូម។ ការចាប់ផ្តើមនូវការងារពិនិត្យ កែសម្រួលឡើងវិញនេះ គឺបន្តពីសម្តេចប៉ាប ភីយ៉ូស ទី៧ (Pius XII) ដែលជាបុព្វបុរស របស់យើងបានកែឡើងវិញនូវក្បួនពិធីរាត្រីបុណ្យចម្លង និងរបៀបប្រារព្ធពិធីសប្តាហ៍ ពិសិដ្ឋ[3] ជាដំណាក់កាលដំបូងដែលទើបបង្កើតនូវក្បួនពិធីអភិបូជាក្រុងរ៉ូម តាមគំនិត សម័យបច្ចុប្បន្ន។

ថ្មីៗនេះ ធម្មនុញ្ញមហាសន្និបាតសកលនៃវ៉ាទីកង់ទី២ បានប្រកាសឲ្យប្រើក្បួនពិធីដ៏ពិសិដ្ឋតាមម្រូវការដើម្បីកែសម្រួល និងគោរពប្រណិប័តន៍ តាមការចាត់តាំងមូលដ្ឋានគ្រឹះទូទៅសម្រាប់កែបន្ថែមបន្ថយពីក្បួនអភិបូជាក្រុងរ៉ូម៖ ក្នុងការប្រកាសអត្ថបទ និងក្បួនពិធីនានា គួរតែព្រាងសេចក្តីដែលគេបានបង្ហាញពីអត្ថន័យយ៉ាងច្បាស់ថា សេចក្តីទាំងប៉ុន្មាននៅក្នុងពិធីបុណ្យនោះ គឺជាអ្វីដែលបរិសុទ្ធ" [4] និងចាត់ចែងឲ្យមានរបៀបរៀបរយ គឺ "ត្រូវពិនិត្យកែឡើងវិញនូវក្បួនពិធីអភិបូជាក្នុងរបៀបមួយដែលមាននៅក្នុងច្បាប់ដើម និងគោលបំណងនៃផ្នែកនីមួយៗក្នុងអភិបូជា មានតួនាទីពិសេសដូចជាការ តភ្ជាប់គ្នាទៅវិញទៅមករវាងនឹងគ្រីស្តបរិស័ទ អាចបង្ហាញឲ្យឃើញយ៉ាងច្បាស់បន្ថែមទៀត ហើយអ្នកគោរពប្រណិប័តន៍ព្រះជាម្ចាស់ ងាយស្រួលចូលរួមយ៉ាងសកម្ម និងបំពេញដោយចិត្តស្មោះ។[5] នៅក្នុងបទបញ្ញត្តិនោះ "ត្រូវយកព្រះគម្ពីរទុកជាទ្រព្យដ៏ មានតម្លៃ គឺជាការបើកឱកាសឲ្យគ្រីស្តបរិស័ទមានគំនិតច្រើនជាងពីមុន ដើម្បីឲ្យអ្នកជឿទទួល ព្រះបន្ទូលព្រះជាម្ចាស់ទុកជាអាហារ"។[6] នៅទីបំផុត ការចាត់តាំងនោះ ត្រូវ "ជាក្បួន ពិធីថ្មីសម្រាប់ថ្វាយអភិបូជារួម គឺដើម្បីឲ្យមានគ្រោងការ ហើយបញ្ចូលគ្នាទៅក្នុងក្បួន ពិធីរបស់លោកអភិបាល និងចូលទៅក្នុងក្បួនពិធីអភិបូជាក្រុងរ៉ូម"។[7]

[2] Cf. Pius XII, Discourse to the participants of the First International Congress of Pastoral Liturgy at Assisi, May 22, 1956: A.A.S. 48 (1956) 112.
[3] Cf. Sacred Congregation of Rites, Decree Dominicae Resurrectionis, February 9, 1951: A.A.S. 43 (1951) 128ff.; Decree Maxima Redemptionis nostrae mysteria, November 16, 1955: A.A.S. 47 (1955) 838ff.
[4] Vatican Council, Const. on the Sacred Liturgy, Sacrosanctum Concilium, art. 21: A.A.S. 56 (1964) 106.
[5] Ibid., art. 50: A.A.S. 56 (1964) 114.
[6] Ibid., art. 51: A.A.S. 56 (1964) 114.
[7] Ibid., art. 58: A.A.S. 56 (1964) 115.

ទោះជាយ៉ាងណាក៏ដោយ កុំនឹកស្មានថា ជាការរៀបចំឡើងវិញ នូវក្បួនពិធី អភិបូជាក្រុងរ៉ូមបានចាត់តាំងគ្មានព្រាងទុក។ ដំណើរការដែលបំពេញក្បួនពិធីបុណ្យ បានសម្រេច ជាលទ្ធផលនៃការរិះគិត និងបទពិសោធអស់រយៈពេលបួនសតវត្សកន្លង មកដោយគ្មានការសង្ស័យពីរបៀបដែលបានចាត់ចែងនោះ។ បន្ទាប់ពីមហាសន្និបាតរបស់លោកអភិបាលព្រះហគមន៍ត្រែន (Trent) តាមការសិក្សា "គេបានចាប់ផ្ដើមរក ឯកសារពីបុរាណដែលនៅកន្លែងផ្សេងៗមកពន្យល់ ដូចជាបណ្ណាល័យវ៉ាទីកង់ និង ប្រមូលតាមព្រះសហគមន៍ប្រពៃណីខាងកើត" ដូចជាបុព្វបុរសរបស់យើង សម្ដេចប៉ាប ភីយ៉ូស ទី៥ (Pius V) បានបង្ហាញឲ្យឃើញក្នុងធម្មនុញ្ញព្រះសហគមន៍ស្រាប់ Quo Primum បានជួយយ៉ាងខ្លាំងសម្រាប់ការពិនិត្យកែឡើងវិញនូវក្បួនពិធីក្រុងរ៉ូម។ ចាប់តាំងពីពេល នោះមកទោះជាយ៉ាងណា ឯកសារដើមអំពីក្បួនពិធីបុណ្យបុរាណជាច្រើនទៀត ត្រូវ បានរកឃើញ និងបោះពុម្ព ហើយនៅពេលជាមួយគ្នានោះដែរ រូបមន្តក្បួនពិធីបុណ្យ នៃព្រះសហគមន៍ខាងកើតដែលបានទទួលស្គាល់ថា ល្អប្រសើរជាងគេ។ មនុស្សមួយ ចំនួនធំមានបំណងចង់ឲ្យឯកសារបុរាណនោះ ជាទ្រព្យសម្បត្តិ ទាំងគោលលទ្ធិ និង ទាំងខាងវិញ្ញាណ អាចនឹងមិនលាក់នៅក្នុងទីងងឹតនៃបណ្ណាល័យនោះ តែផ្ទុយទៅវិញ អាចនឹងនាំចូលនៅក្នុងពន្លឺ ដើម្បីបំភ្លឺចិត្តគំនិត ព្រមទាំងជំរុញទឹកចិត្តគ្រីស្ដបរិស័ទ និង ចិញ្ចឹមគេខាងវិញ្ញាណ។

ឥឡូវនេះ សូមឲ្យយើងបង្ហាញនៅក្នុងរបៀបយ៉ាងទូលាយ ជាសមាសភាពថ្មីនៃក្បួនពិធីអភិបូជាក្រុងរ៉ូម។ ជាបឋម នៅក្នុងអារម្ភកថា ដែលជាសៀវភៅប្រើសម្រាប់សេចក្ដីណែនាំទូទៅពីក្បួនពិធីអភិបូជា ជាបទបញ្ជាថ្មីមួយ បានកំណត់ចេញមកទុកឲ្យប្រារព្ធពិធីអរព្រះគុណដ៏វិសុទ្ធ អំពីក្បួនពិធី និងពីមុខងារនិមួយៗរបស់អ្នកចូលរួម ព្រមទាំងសម្ភារៈពិសិដ្ឋសម្រាប់រៀបចំចាត់ចែងក្នុងព្រះវិហារ ឬនៅទីសក្ការបូជា។

គោលដៅសំខាន់ជាងគេ គឺការកែសៀវភៅចេញថ្មីដែលទាក់ទងនឹងធម៌អរព្រះគុណព្រះជាម្ចាស់។ ប្រសិនបើ នៅក្នុងក្បួនពិធីក្រុងរ៉ូម ជាផ្នែកទីមួយនៃពាក្យអធិដ្ឋានធម៌ប្រារព្ធ បានរក្សានូវបទបញ្ញត្តិផ្សេងគ្នាតាំងពីយូរសតវត្សមកហើយនោះ ផ្ទុយពីផ្នែកទីពីរដែលយើងហៅថា "ក្បួនច្បាប់នៃកិច្ចការសក្ការបូជា" (Canon Actionis) មិនអាច

ទទួលយកការផ្លាស់ប្តូរបានឲ្យត្រូវតាមច្បាប់ តាំងពីអំឡុងពេលសតវត្សទី៤ និងទី៥ ដែលផ្ទុយពីរបៀបរបបពិធីបុណ្យប្រពៃណីភាគខាងកើត ដែលអនុញ្ញាតឲ្យមានភាពផ្លាស់ប្តូរជារឿយៗនៅក្នុងការប្រើពាក្យកំណាព្យច្រើន (Anaphora)។ ទោះបីជាយ៉ាងណានៅក្នុងបញ្ហានេះ មានតែផ្នែកមួយដែលនៅស្ថិតស្ថេរនៅឡើយ គឺពាក្យធម៌អរព្រះគុណព្រះជាម្ចាស់ ដោយមានធម៌ប្រារព្ធមួយចំនួនធំធ្វើឲ្យមានខ្លឹមសារ យើងបានពិចារណាសម្រេចដាក់បន្ថែមពាក្យអធិដ្ឋានថ្មីចំនួនបីទៀតក្នុងក្បួនពិធីនេះ ដែលបានទទួលពីប្រពៃណីបុរាណនៃព្រះសហគមន៍រ៉ូម៉ាំង ឬរៀបចំតែងជាថ្មីផងដែរ។ នៅក្នុងរបៀបអធិដ្ឋានផ្សេងៗគ្នានេះ ជាទស្សនៈមួយជួយឲ្យគ្រីស្តបរិស័ទសញ្ជឹងគិតពីការអាថ៌កំបាំងនៃការសង្គ្រោះរបស់ព្រះជាម្ចាស់ ដើម្បីផ្តល់ឲ្យគ្រីស្តបរិស័ទប្រាថ្នាលើកតម្កើង និង អរព្រះគុណព្រះជាម្ចាស់។ ទោះបីជាយ៉ាងណាក៏ដោយ ករណីកិច្ចណែនាំគ្រីស្តបរិស័ទ និងការចាត់តាំងដើម្បីជួយសម្រួលក្នុងការប្រារព្ធពិធី ដែលមានបូជាចារ្យច្រើននាក់ចូលរួម គួរឲ្យយើងចាត់ចែងព្រះបន្ទូលរបស់ព្រះអម្ចាស់ ដូចគ្នានឹងក្បួនរបស់សាសនក្រឹត្យ។ ដូច្នេះ នៅក្នុងពាក្យអធិដ្ឋាននីមួយៗនៃធម៌អរព្រះគុណព្រះជាម្ចាស់ ជាព្រះបន្ទូលដែលយើងបានប្រកាស គឺប្រសិទ្ធពរលើនំតង្វាយពេលព្រះយេស៊ូជប់លៀងចុងក្រោយជាមួយក្រុមសាវ័កថា៖ **"សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា** (ACCÍPITE ET MANDUCÁTE EX HOC OMNES: HOC EST ENIM CORPUS MEUM, QUOD PRO VOBIS TRADÉTUR.)។ ប្រសិទ្ធពរលើពែងព្រះលោហិត៖ **"សូមអ្នក រាល់គ្នាយកពែងនេះ ហើយពិសាចុះ នេះជាលោហិតរបស់ខ្ញុំដែលចងសម្ពន្ធមេត្រីថ្មី និងគង់វង្ស អស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរដើម្បីលើកលែងទោសអ្នករាល់គ្នា និងមនុស្សច្រើនឥត គណនាឲ្យរួចពីបាប សូមអ្នករាល់គ្នាធ្វើដូច្នេះដើម្បីនឹករឭកដល់ខ្ញុំ"**។ (ACCÍPTE ET BÍBITE EX EO OMNES: HIC EST ENIM CALIX SÁNGUINIS MEI NOVI ET ÆTÉRNI TESTAMÉNTI, QUI PRO VOBIS ET PRO MULTIS EFFUNDÉTUR IN REMISSIÓNEM PECCATÓRUM. HOC FÁCITE IN MEAM COMMEMORATIÓNEM.) រីឯពាក្យ "នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ" (MYSTÉRIUM FIDEI) ស្រង់ចេញពីអត្ថបទនៃព្រះបន្ទូលរបស់ព្រះគ្រីស្តជាអម្ចាស់ ហើយពោលផ្តើមដោយលោកបូជាចារ្យជាអ្នកបម្រើ ប្រកាសខ្លាំងៗណែនាំដល់អស់អ្នកជឿ។ ទាក់ទងនឹងក្បួនពិធីអភិបូជានេះ "ជាក្បួនពិធីដែលសាមញ្ញ ទោះជាត្រូវរក្សានូវខ្លឹមសារនៃពិធីទាំងនោះ"។[8]

[8] Ibid., art. 50: A.A.S. 56 (1964) 114.

យើងក៏បានលុបចោលនូវអ្វីដែលមានចែងពីរដងផងដែរ គឺបន្ថែមទៅតាមដំណើរការប្រវត្តិសាស្រ្ត ឬមិនសូវមានប្រយោជន៍ប៉ុន្មាន"។[9] នៅក្នុងក្បួនពិធីនៃពាក្យថ្វាយតង្វាយខាងលើ គឺនំ និងស្រាតង្វាយ ហើយនៅក្នុងពិធីទាំងអស់នោះ ជាពិធីកាច់នំព្រះកាយ ហើយក៏ជាពិធីទទួលព្រះកាយ និងព្រះលោហិត។

ម្យ៉ាងទៀត បានយកសេចក្តីខ្លះដែលបាត់បង់តាមប្រវត្តិសាស្រ្តឲ្យមានឡើងវិញ[10] ដូចជា ធម្មទេសនា[11] ពាក្យអធិដ្ឋានធម្មតា ឬពាក្យអធិដ្ឋានសម្រាប់អស់អ្នកជឿ។[12] ពិធីទទួលសារភាព ឬពិធីផ្សះផ្សាមនុស្សលោកជាមួយព្រះជាម្ចាស់ និងជាមួយអស់ បងប្អូនគ្រីស្តបរិស័ទ ព្រមទាំងរៀបចំកន្ទែងសមរម្យតាមការចែងបញ្ជាក់ណែនាំខាង ដើមនៅពេលចាប់ផ្តើមថ្វាយអភិបូជា។

តាមការបញ្ជាក់នូវបទបញ្ញត្តិរបស់មហាសន្និបាតវ៉ាទីកង់ទី២ "ចែកផ្នែកសំខាន់ៗនៃអត្ថបទព្រះគម្ពីរដែលប្រជាជននឹងត្រូវអាន ត្រូវរៀបចំកំណត់ទុកក្នុងរយៈពេលប៉ុន្មានឆ្នាំ"[13] ហើយសម្រាប់ការអានអត្ថបទគម្ពីរប្រចាំថ្ងៃអាទិត្យ ត្រូវបែងចែកក្នុងរយៈពេល ៣ ឆ្នាំ។ លើសពីនេះទៀត ថ្វាយអភិបូជាសម្រាប់ថ្ងៃអាទិត្យ និងថ្ងៃបុណ្យ ត្រូវអានលិខិតរបស់គ្រីស្តទូត និងអត្ថបទព្រះគម្ពីរដំណឹងល្អ បន្ទាប់មក ត្រូវបន្តអានអត្ថបទព្រះគម្ពីរសម្ពន្ធមេត្រីចាស់ ឬកណ្ឌកិច្ចការគ្រីស្តទូតនៅក្នុងរដូវបុណ្យចម្លង។ ធ្វើរបៀបនេះ គឺជាថាមភាពជួយឲ្យគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះ ដែលបង្ហាញចេញពីអត្ថបទព្រះគម្ពីរវិវរណៈត្រូវបន្ថែមន័យលេចធ្លោកាន់តែច្បាស់។ ការជ្រើសរើសអានអត្ថបទព្រះគម្ពីរទាំងនេះយ៉ាងទូលំទូលាយ ជាផ្នែកមួយសំខាន់ជាងគេអំពីធម៌វិន័យដ៏ពិសិដ្ឋដើម្បីផ្តល់ឲ្យដល់អស់អ្នកជឿនៅក្នុងថ្ងៃបុណ្យ គឺគ្រីស្តបរិស័ទបានទទួលសេចក្តីជាច្រើនមកពីការអានសៀវភៅដ៏វិសុទ្ធពេញលក្ខណៈនៅថ្ងៃផ្សេងទៀត។

យើងរៀបចំរបៀបទាំងអស់នេះ ដើម្បីធ្វើឲ្យគ្រីស្តបរិស័ទស្រេកឃ្លានចង់ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់[14] ដោយមានការណែនាំពីព្រះវិញ្ញាណដ៏វិសុទ្ធ និងដឹកនាំប្រជារាស្រ្តនៃសម្ពន្ធមេត្រីថ្មីឲ្យមានការរួបរួមគ្នាជាធ្លុងតែមួយក្នុងព្រះសហគមន៍។

---

[9] Ibid.
[10] Cf. Ibid.
[11] Cf. Ibid., art. 52: A.A.S. 56 (1964) 114.
[12] Cf. Ibid., art. 53: A.A.S. 56 (1964) 114.
[13] Ibid., art. 51: A.A.S. 56 (1964) 114.
[14] Cf. Amos 8: 11.

យើងជឿជាក់ថា ទាំងលោកបូជាចារ្យ ទាំងគ្រីស្តបរិស័ទ និងត្រៀមខ្លួនដើម្បីចូលរួមក្នុងពិធីជប់លៀងរបស់ព្រះអម្ចាស់ ដោយទឹកសញ្ចឹងគិតដល់ព្រះគម្ពីរដ៏វិសុទ្ធ ហើយនៅពេលនោះ យើងក៏ទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាអាហារចិញ្ចឹមពួកគេពីមួយថ្ងៃទៅមួយថ្ងៃកាន់តែច្រើនៗ ហេតុនេះ តាមពាក្យផ្តាំផ្ញើរបស់មហាសន្និបាតវ៉ាទីកង់ទី២ អត្ថបទព្រះគម្ពីរដ៏វិសុទ្ធនឹងទៅជាប្រភពនៃជីវិតខាងវិញ្ញាណ និងជាឧបករណ៍សម្រាប់ដាស់តឿនពីតម្លៃលទ្ធិគ្រីស្តសាសនា ហើយជាមធ្យោបាយដ៏ល្អសម្រាប់ការអប់រំជំនឿ និងខ្លឹមសារទេវវិទ្យា។

នៅក្នុងការពិនិត្យកែឡើងវិញ នៃក្បួនពិធីបុណ្យក្រុងរ៉ូមនេះ បុព្វបទដែលបន្ថែមក្នុងការផ្លាស់ប្តូរចំណែកទាំងបីដូចរៀបរាប់ខាងលើ គឺធម៌អរព្រះគុណដ៏វិសុទ្ធ ក្បួនពិធីអភិបូជា និងអានអត្ថបទព្រះគម្ពីរប្រចាំថ្ងៃ នៅផ្នែកផ្សេងទៀតក៏បានពិនិត្យដោយហ្មត់ចត់ និងកែតម្រូវគួរឲ្យកត់សម្គាល់ជាច្រើនដូចជា៖ ពាក្យអធិដ្ឋានតាមរដូវផ្សេងៗ ពិធីបុណ្យគោរពសន្តបុគ្គលទាំងឡាយ ពាក្យអធិដ្ឋានរួមសម្រាប់សន្តបុគ្គល អភិបូជាតាមក្បួនពិធីផ្សេងៗ និងអភិបូជាតាមប្រាថ្នា។ នៅក្នុងការផ្លាស់ប្តូរទាំងអស់នេះ ជាពិសេសការយកចិត្តទុកដាក់នូវពាក្យអធិដ្ឋាន មិនត្រឹមតែមានចំនួនទាំងនោះកើនឡើងទេ តែអត្ថបទថ្មីនេះ អាចល្អប្រសើរជាមុន ហើយស៊ីគ្នានឹងតម្រូវការបច្ចុប្បន្ន ប៉ុន្តែអត្ថបទអស់ទាំងនោះក៏បានធ្វើឡើងវិញ ភាគច្រើននៅលើទីបន្ទាល់នៃកុស្តុតាងជាក់ស្តែងពី ឯកសារបុរាណ។ តាមទំនៀមទម្លាប់រ៉ូម៉ាំងនៃក្បួនពិធីបុណ្យតាមរដូវផ្សេងៗ គឺរដូវរង់ចាំ រដូវអបអរសាទរបុណ្យព្រះយេស៊ូប្រសូត្រ រដូវសែសិបថ្ងៃ និងរដូវបុណ្យចម្លង បាន រៀបចំពាក្យអធិដ្ឋានផ្តល់ជូនជាស្រាប់។

ទោះបីអត្ថបទចម្រៀងប្រចាំពិធីបុណ្យក្រុងរ៉ូម (Gradual Romanum) មិនបានកែតម្រូវក៏ដោយ ក៏យើងយកទំនុកតម្កើងក្នុងពិធីអភិបូជាមានជាស្រាប់ ដើម្បីជួយឲ្យគ្រីស្តបរិស័ទចូលរួមពិធីបុណ្យងាយស្រួល ដូចសន្តអូគូស្តាំង និងសន្តឡេអូជនដ៏ប្រសើរឧត្តមបានចែងជារឿយៗក្នុងការកែសម្រួលឡើងវិញ ដូចជាពាក្យអធិដ្ឋានពេលចូល និងពាក្យអធិដ្ឋានមុនពេលទទួលព្រះកាយព្រះគ្រីស្ត ត្រូវផ្លាស់ប្តូរដើម្បីសម្របសម្រួលដល់អ្នកអានក្នុងពិធីអភិបូជា។

នៅទីបញ្ចប់ យើងមានបំណងប្រកាសជំរុញឲ្យប្រើក្បួនច្បាប់ទាំងអស់ ដែលបាន ចែងនៅក្នុងក្បួនពិធីអភិបូជាក្រុងរ៉ូមថ្មី ប្រកាសជាផ្លូវការឲ្យប្រើក្បួនពិធីអភិបូជាក្រុងរ៉ូម និងបោះពុម្ពផ្សាយ ដែលបុព្វជិកការីរបស់យើង សម្តេចប៉ាប ភីយ៉ូសទី៥ (Pius V) បាន តាំងក្បួនពិធីបុណ្យនេះ ជាឧបករណ៍ទុកសម្រាប់ជាមធ្យោបាយឲ្យគ្រីស្តបរិស័ទប្រើក្បួន នេះពេញមួយឆ្នាំ ដើម្បីរួបរួមគ្នា និងធ្វើជាសក្ខីភាពនៃការថ្វាយបង្គំព្រះជាម្ចាស់ ដោយ ត្រឹមត្រូវនៅក្នុងព្រះសហគមន៍។ រីឯអ្វីដែលនៅសល់ក្នុងក្បួនពិធីអភិបូជាថ្មី គឺអាស្រ័យ លើការចាត់តាំងរបស់មហាសន្និបាតវ៉ាទីកង់ទី២ អនុញ្ញាតឲ្យ "កែសម្រួលពិធីផ្សេងៗ តាមរបៀបត្រឹមត្រូវ"[15] យ៉ាងណាក៏ដោយ យើងសង្ឃឹមថា សៀវភៅអភិបូជានោះ នឹង ទទួលបាននូវភាពត្រឹមត្រូវពិតប្រាកដទុកជាឧបករណ៍ និងជាសាក្សី ដើម្បីបញ្ជាក់យ៉ាង ច្បាស់ថា៖ យើងប្រើក្បួនពិធីនេះ ព្រមព្រៀងរួមគ្នាក្នុងព្រះសហគមន៍។ ដូច្នេះ នៅក្នុង ការប្រើភាសាផ្សេងៗក៏សំខាន់ណាស់ដែរ គឺមានតែពាក្យអធិដ្ឋានមួយគត់នឹងលើកឡើង ជាមួយតង្វាយ ដែលព្រះបិតាគាប់ព្រះហឫទ័យលើកព្រះយេស៊ូឡើងទៅស្ថានបរមសុខ តាមរយៈព្រះយេស៊ូគ្រីស្តជាមហាបូជាចារ្យរបស់យើងក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។

យើងបានចាត់តាំងឲ្យអនុវត្តនៃបញ្ញាត្តិធម្មនុញ្ញនេះ ចាប់ពីថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ នេះ ត្រូវជាថ្ងៃអាទិត្យទី១ ក្នុងរដូវរង់ចាំ។

យើងសង្ឃឹមថា បទបញ្ញាត្តិ និងសេចក្តីបង្គាប់របស់យើងទាំងប៉ុន្មាននេះ អាចនឹង ប្រកាន់ខ្ជាប់ ហើយមានប្រសិទ្ធិភាពនៅក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគត ដោយ គ្មានឧបសគ្គ ថ្វីបើវិសាលភាពចាំបាច់ ជាធម្មនុញ្ញព្រះសហគមន៍ និងបទបញ្ញត្តិដែល ចេញពីបុព្វជិការីរបស់យើងបានប្រកាសមុនៗ ហើយជាសេចក្តីបង្គាប់ផ្សេងទៀតបាន លើកមកនិយាយនៅក្នុងក្បួនច្បាប់ព្រះសហគមន៍ ដែលសមនឹងទទួលបានដោយផ្ទាល់ និងត្រូវបដិបត្តិតាមច្បាប់។

ទីក្រុងរ៉ូម នៅព្រះវិហារសន្តសិលា

ថ្ងៃព្រហស្បតិ៍ពិសិដ្ឋ ទី៣ ខែមេសា ឆ្នាំ១៩៦៩

**ពីខ្ញុំជាសម្តេចប៉ាប ប៉ូលទី ៦**

---

[15] II Vatican Council, Const. on the Sacred Liturgy, Sacrosanctum Consilium, art. 38: A.A.S. 56 (1964).

# សេចក្ដីណែនាំ

# របស់មហាសន្និបាតវ៉ាទីកង់ទី២

# ស្ដីពី

# ក្បួនពិធីអភិបូជាក្រុងរ៉ូម

INSTITUTIO GENERALIS
MISSALIS ROMANI

# សេចក្ដីផ្ដើម

PROŒMIUM

១. ខណៈដែលព្រះគ្រីស្ដជាអម្ចាស់ បានធ្វើពិធីជប់លៀងនៃបុណ្យចម្លងជាមួយក្រុមសាវ័កព្រះអង្គសព្វព្រះហឫទ័យថ្វាយព្រះកាយ និងព្រះលោហិតរបស់ព្រះអង្គ ដោយបង្គាប់ឲ្យគេរៀបចំបន្ទប់មួយយ៉ាងធំជាស្រេច។ "ចូររៀបចំម្ហូបអាហារសម្រាប់បុណ្យចម្លងនៅក្នុងបន្ទប់នេះចុះ" (លក.២២,១២)។ តាមពិតព្រះសហគមន៍ទទួលទុកព្រះបញ្ជានេះ ជារបស់ខ្លួនផ្ទាល់ដែលត្រូវអនុវត្ត ដើម្បីណែនាំគ្រីស្ដបរិស័ទឲ្យយកចិត្តទុកដាក់រៀបចំចិត្តគំនិត រួមទាំងទីកន្លែងក្បួនពិធី និងអត្ថបទសម្រាប់ប្រារព្ធពិធីអរព្រះគុណដ៏វិសុទ្ធ។ ក្បួនច្បាប់បច្ចុប្បន្ននេះ មានចែងទុកក្នុងបញ្ញត្តិរបស់មហាសន្និបាតវ៉ាទីកង់ទី២ ព្រមទាំងសៀវភៅក្បួនពិធីអភិបូជាថ្មី ដែលស្របតាមក្បួនពិធីប្រពៃណីរ៉ូម៉ាំងផងដែរ។ បញ្ជាក់ជាថ្មីម្ដងទៀត ព្រះសហគមន៍ត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងអំពីជំនឿ និងសេចក្ដីស្រឡាញ់ដែលមិនចេះប្រែប្រួល ចំពោះគម្រោងការដ៏អស្ចារ្យដែលជាកំពូលនៃធម៌អរព្រះគុណដ៏វិសុទ្ធ។ ហើយផ្ដល់សក្ខីភាពបញ្ជូនបន្តដល់ព្រះសហគមន៍ និងស្របទៅតាមវប្បធម៌ប្រពៃណីសព្វថ្ងៃ ទោះបីជាត្រូវមានការកែសម្រួលច្បាប់ថ្មីមួយចំនួនខ្លះក៏ដោយ។

## សក្ខីភាពអំពីជំនឿដែលមិនចេះប្រែប្រួល

២. លោកបូជាចារ្យ ជាសភាវៈនៃសក្ការបូជាសម្រាប់ថ្វាយអភិបូជា ដែលក្រុមប្រឹក្សានៃមហាសន្និបាតត្រែន (Trent) ការពារយ៉ាងម៉ឺងម៉ាត់ ព្រោះធ្វើយ៉ាងឲ្យស្របគ្នានឹងប្រពៃណីរបស់ព្រះសហគមន៍ទូទៅ[16] ដូច្នេះ មហាសន្និបាតវ៉ាទីកង់ទី២ បានប្រកាសយ៉ាងច្បាស់អំពីពាក្យអភិបូជានៅក្នុងពិធីជប់លៀងចុងក្រោយរបស់ព្រះសង្គ្រោះ ដែលបានតែងតាំងសក្ការបូជាដើម្បីអរព្រះគុណព្រះជាម្ចាស់ គឺព្រះកាយ និងព្រះលោកហិតរបស់ព្រះអង្គ ដែលបានបូជាព្រះជន្មនៅលើឈើឆ្កាង ហើយនឹកចាំរហូតដល់ពេលព្រះអង្គយាងមកវិញ ព្រះអង្គក៏ផ្ញើទុកឲ្យព្រះសហគមន៍ជាភរិយាដ៏ជាទីស្រឡាញ់នឹករឭកដល់ព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ។[17]

មហាសន្និបាតរបស់លោកអភិបាល បានបញ្ជាក់យ៉ាងម៉ឺងម៉ាត់នៅក្នុងក្បួនអភិបូជា ដោយបង្រៀនព្រះសហគមន៍ពីរបៀបប្រើក្បួនពិធីនេះ ម្យ៉ាងទៀត ជាគោលលទ្ធិដែលលេចធ្លោជាងគេនៅក្នុងឃ្លាប្រយោគដើម្បីឲ្យអ្នកជឿតាម គេបានកត់សម្គាល់បញ្ចូលរួចជាស្រេច ហើយបញ្ជាក់យ៉ាងច្បាស់ និងសង្ខេបក្បួនពិធីអត្ថសញ្ញាផ្សេងៗរួមគ្នា ដែលមាននៅក្នុងសម័យបុរាណនោះហៅថា (Leonine) ជាការនឹករឭកដល់យញ្ញបូជានេះ គឺជាពិធីប្រារព្ធនូវព្រះរាជកិច្ចនៃព្រះសង្គ្រោះរបស់យើងដែលបានបំពេញ[18] នៅក្នុងខ្លឹមសារ និងសេចក្ដីពន្យល់យ៉ាងច្បាស់ក្នុងពាក្យអធិដ្ឋានធម៌អរព្រះគុណដ៏វិសុទ្ធ។ ពីព្រោះពាក្យអធិដ្ឋានទាំងនោះលោកបូជាចារ្យត្រូវជ្រើសរើសធម៌

[16] Ecumenical Council of Trent, Session 22, Doctrina de ss. Missae sacrificio, 17 September 1562: Enchiridion Symbolorum, H. Denzinger and A. Schönmetzer, editors (edition XXXIII, Freiburg: Herder, 1965; hereafter, Denz-Schön), 1738-1759.

[17] Second Vatican Ecumenical Council, Constitution on the Sacred Liturgy, Sacrosanctum Concilium, no. 47; cf. Second Vatican Ecumenical Council, Decree on the Ministry and Life of Priests, Presbyterorum ordinis, nos. 2, 4, 5.

[18] Evening Mass of the Lord's Supper, prayer over the offerings. Cf. Sacramentarium Veronense, L.C. Mohlberg et al., editors, (3rd edition, Rome, 1978), section I, no. 93.

នឹករឭកទូលអង្វរទៅព្រះជាម្ចាស់ ក្នុងនាមប្រជាជនទាំងអស់ លោកអរព្រះគុណព្រះអង្គ ហើយថ្វាយសក្ការបូជាដ៏ពិសិដ្ឋ និងថ្វាយនូវការរស់នៅរបស់ព្រះសហគមន៍ ព្រមទាំងជាអ្នកថ្វាយយញ្ញបូជា និងជាតង្វាយដែលគាប់ព្រះហឫទ័យព្រះបិតា[19] ហើយលោកបូជាចារ្យពោលពាក្យអធិដ្ឋានថា សូមព្រះបិតាមេត្តាប្រោសប្រទានឲ្យព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ដប្រោសឲ្យមនុស្សលោកបានទទួលការសង្គ្រោះពីយញ្ញបូជាដ៏ល្អប្រសើរនេះ។[20]

ហេតុនេះ នៅក្នុងក្បួនពិធីអភិបូជាថ្មី ជាក្បួនអធិដ្ឋានរបស់ព្រះសហគមន៍ (lex orandi) ដែលស្របតាមជំនឿនៃព្រះសហគមន៍ (lex credendi) ដែលប្រៀនប្រដៅយើងថា ព្រះឈើឆ្កាងរបស់ព្រះអម្ចាស់ជាយញ្ញបូជា ហើយបន្តអគ្គសញ្ញាដែលរំឭកនៅក្នុងអភិបូជានេះ ដូចដែលព្រះគ្រីស្ដជាអម្ចាស់បានតែងតាំងនៅពេលព្រះអង្គជប់លៀងចុងក្រោយ ហើយបានបញ្ជាទៅក្រុមសាវ័កទាំងមានព្រះបន្ទូលថា៖ "សូមធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ" គឺមានតែម្ដង ហើយពោលក្នុងពេលដដែលខុសគ្នា តែនៅក្នុងរបៀបថ្វាយតង្វាយ ក៏ជាហេតុផលមួយដែលពិធីថ្វាយអភិបូជា គឺជាពិធីលើកតម្កើងព្រះជាម្ចាស់ ពិធីអរព្រះគុណដ៏វិសុទ្ធ ពិធីថ្វាយតង្វាយ និងពិធីផ្សះផ្សាមនុស្សលោកឲ្យជានានឹងព្រះជាម្ចាស់។

៣. ម៉្យាងទៀត គម្រោងការអស្ចារ្យនៃវត្តមានរបស់ព្រះអម្ចាស់ តាមរយៈព្រះកាយ និងព្រះលោហិតព្រះគ្រីស្ដ បានបញ្ជាក់បន្ថែមដោយមហាសន្និបាតវ៉ាទីកង់ទី២[21] និងយល់ព្រមពីក្រុមណែនាំព្រះសហគមន៍ឯទៀតៗបានបង្ហាត់បង្រៀន[22] នៅក្នុងសុភនិច្ឆ័យដូចគ្នានេះដែរ គឺដូចគ្នានឹងឯកសារនៃគោលលទ្ធិរបស់មហាសន្និបាតនៅត្រែនបានដាក់ស្នើ និងប្រកាសនៅក្នុងពិធីអភិបូជាថា ត្រូវតែជឿទុកចិត្តលើព្រះជាម្ចាស់[23] មិនត្រឹមតែព្រះបន្ទូលរបស់ព្រះគ្រីស្ដប៉ុណ្ណោះទេ គឺប្រសិទ្ធនំ និងស្រាតង្វាយឲ្យទៅជាព្រះកាយ និងព្រះលោហិតព្រះគ្រីស្ដ ជាវត្តមានរបស់ព្រះអង្គដែលបានបំពេញតាមរយៈការផ្លាស់ប្ដូរធាតុ គឺនំ និងស្រា ត្រឡប់ទៅជាព្រះកាយ និងព្រះលោហិតរបស់ព្រះយេស៊ូ ប៉ុន្តែក៏ជាការត្រៀមខ្លួនផងដែរ ផ្នែកខាងវិញ្ញាណ និងផ្នែកខាងក្រៅ ដោយបង្ហាញនូវសេចក្ដីគោរពរាប់អានយ៉ាងថ្លៃថ្នូរ ព្រមទាំងថ្វាយបង្គំព្រះជាម្ចាស់ដោយខិតខំទទួលនូវអ្វីដែលបានពីការចូលរួមក្នុងអភិបូជា។ នេះជាមូលហេតុដែលគ្រីស្ដបរិស័ទក្រាបប្រណិប័តន៍អគ្គសញ្ញាដ៏អស្ចារ្យ តាមរយៈការថ្វាយបង្គំព្រះជាម្ចាស់ក្នុងរបៀបពិសេសនៅថ្ងៃព្រហស្បតិ៍នៃពិធីជប់លៀងរបស់ព្រះអម្ចាស់ក្នុងសប្ដាហ៍ពិសិដ្ឋ និង នៅថ្ងៃបុណ្យយ៉ាងឱឡារិកនៃបុណ្យព្រះកាយ និងព្រះលោហិតព្រះគ្រីស្ដ។

៤. យើងអាចយល់ច្បាស់អំពីមុខងារ ជាអ្នកបម្រើនៃអគ្គសញ្ញាតែងតាំងជាបូជាចារ្យរបស់លោកអភិបាល និងលោកបូជាចារ្យដែលថ្វាយអភិបូជាក្នុងព្រះនាមព្រះគ្រីស្ដ និងជាអធិបតីក្នុងការជួបជុំគ្នាក្នុងព្រះសហគមន៍ ដោយបង្ហាញពីមុខងារពិសេសរបស់លោក។ ធម៌ប្រារព្ធ

[19] Cf. Eucharistic Prayer III.
[20] Cf. Eucharistic Prayer IV.
[21] CoNC. Œcum. VAT. II, Const. de sacra Liturgia, Sacrosanctum Concilium, nn.7, 47; Decr. de Presbyterorum ministerio et vita, Presbyterorum ordinis, nn. 5, 18.
[22] Cf. Pius XII, Litt. Enc. Humani generis, diei 12 augusti 1950: A.A.S. 42 (1950) pp.570-571; Paulus VI, Litt. Enc. Mysterium Fidei, diei 3 septembris 1965: A.A.S. 57 (1965) pp. 762-769, Sollemnis profession fidei, diei 30 iunii 1968, nn. 3f, 9: A.A.S. 59 (1967) pp. 543, 547.
[23] Cf. Cong. Œcum. Trid., Sessio XIII, II octobris 1551: Denz. Schönrm. 1635-1661.

សម្រាប់ថ្វាយអភិបូជា ការប្រសិទ្ធពរលើប្រេងគ្រីស្មានៅថ្ងៃព្រហស្បតិ៍ សប្តាហ៍ពិសិដ្ឋ គឺជាថ្ងៃនឹករឭកពីការតែងតាំងមុខងារជាបូជាចារ្យដែលបានប្រកាស គឺពន្យល់ពីអត្ថន័យនៃមុខងារតាមរបៀបដ៏ល្អប្រសើរ។ ធម៌ប្រារព្ធបានបង្ហាញពីលក្ខណៈ និងអំណាចរបស់ព្រះគ្រីស្ត ជាមហាបូជាចារ្យនៃសម្ពន្ធមេត្រីថ្មី។

៥. មុខងារបម្រើព្រះជាម្ចាស់ជាអគ្គសញ្ញាតែងតាំងជាបូជាចារ្យ គឺបង្ហាញពីរបៀបសាមញ្ញនៃឋានៈជាបូជាចារ្យ ដែលគ្រីស្តបរិស័ទទាំងឡាយបានទទួលដោយអគ្គសញ្ញាជ្រមុជទឹក។ គ្រីស្តបរិស័ទដែលពលិកម្មទាំងកម្លាំងកាយចិត្ត ដោយបំពេញនូវមុខងាររបស់លោកអភិបាល និងលោកបូជាចារ្យដែលបានបូជាក្នុងសក្ការបូជារបស់ព្រះគ្រីស្ត និងជាស្ពានមេត្រីតែមួយគត់របស់យើង។[24] អភិបូជា គឺជាសកម្មភាពនៃពិធីបុណ្យរបស់ព្រះសហគមន៍ទាំងមូល ហើយនៅក្នុងពិធីនេះ ម្នាក់ៗត្រូវបំពេញមុខងាររបស់ខ្លួនដែលទទួលក្នុងព្រះសហគមន៍។ ហេតុនេះត្រូវយកចិត្តទុកដាក់លើផ្នែកខ្លះនៃពិធីអភិបូជា ដែលជួនកាលយើងមិនសូវអើពើ។ ព្រះសហគមន៍ជាក្រុមមនុស្សដែលព្រះជាម្ចាស់បានសង្គ្រោះដោយព្រះលោហិតព្រះគ្រីស្ត ហើយរួបរួមគ្នាដោយសារព្រះអម្ចាស់ ព្រមទាំងទទួលព្រះបន្ទូលព្រះអង្គទុកជាអាហារ ជាប្រជារាស្ត្រដែលព្រះអង្គបានត្រាស់ហៅ ឲ្យប្រមូលផ្តុំគ្នាអធិដ្ឋានទូលអង្វរព្រះអង្គសម្រាប់មនុស្សលោក និងអរព្រះគុណព្រះគ្រីស្ត តាមគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គជាព្រះសង្គ្រោះ។ ដូច្នេះ យើងទាំងអស់គ្នានឹងក្លាយទៅជាផ្លូងតែមួយ ក្នុងព្រះកាយ និងព្រះលោហិតរបស់ព្រះយេស៊ូគ្រីស្ត ជាជនដ៏វិសុទ្ធតាំងពីកំណើត ព្រោះភាពដ៏វិសុទ្ធនេះ បានរីកចម្រើនលូតលាស់ដោយការរួបរួមគ្នាយ៉ាងសកម្ម និងជាផលផ្លែដ៏ល្អប្រសើរចូលក្នុងគម្រោងការដ៏អស្ចារ្យនៃពិធីអភិបូជា។[25]

**សាក្សីអំពីការបញ្ជូនបន្តដែលឥតចេះប្រែប្រួល**

៦. នៅពេលកំណត់ចេញការណែនាំឲ្យប្រើក្បួនពិធីអភិបូជា ត្រូវពិនិត្យមើលឡើងវិញ គឺធ្វើតាមរបៀបរបស់មហាសន្និបាតវ៉ាទីកង់ទី២ ប្រើពាក្យឲ្យដូចសម្តេចប៉ាប ភីយ៉ូស ទី៥ (Pius V) បានប្រកាសក្នុងធម្មនុញ្ញ Quo primum នៃមហាសន្និបាតត្រែន នៅឆ្នាំ១៥៧០ ត្រូវយកពិធីខ្លះមកវិញ "តាមរបៀបច្បាប់ដើមនៃក្រុមលោកឪពុកដែលជាបុព្វបុរសដ៏វិសុទ្ធ"។[26] ទោះបីជាមានភាពខុសគ្នា៤០០សតវត្សយ៉ាងណា ក៏យើងអាចយល់ថា ក្បួនពិធីអភិបូជារ៉ូម៉ាំងទាំងនោះនៅតែប្រើពាក្យដដែល ហើយកាន់យករបៀបនៃការគោរពប្រពៃណីតែមួយ។ ម្យ៉ាងទៀតប្រសិនបើ នៅក្នុងក្បួនពិធីនៃច្បាប់ប្រពៃណីទាំងពីរចំណុចដែលបានបញ្ជាក់ខាងលើ គឺវាមានសារៈសំខាន់ណាស់ក្នុងការបញ្ជូនបន្ត និងសុខចិត្តបំពេញក្បួនពិធីអភិបូជាចាស់ជាកំពូលនៃពិធីដែលបានសម្រេចផ្តល់ក្បួនពិធីបុណ្យថ្មីនេះ នៅសម័យក្រោយទៀត។

៧. ពិតណាស់នៅក្នុងគ្រាលំបាក ព្រះសហគមន៍កាតូលិកសម័យដើម គេធ្វើបូជាយញ្ញក្នុងពេលថ្វាយអភិបូជា ជាសក្ការបូជារបស់ព្រះយេស៊ូគ្រីស្ត ជាមុខងារអ្នកបម្រើ ជាបូជាចារ្យដែលទទួលអគ្គសញ្ញាតែងតាំង ហើយជាវត្តមានរបស់ព្រះយេស៊ូគ្រីស្ត ក្នុងព្រះកាយ និង

---

[24] Cf. Second Vatican Ecumenical Council, Decree on the Ministry and Life of Priests, *Presbyterorum ordinis*,
[25] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 11.
[26] Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 50.

ព្រះលោហិត ជាប្រភេទធម៌អរព្រះគុណព្រះជាម្ចាស់ ដែលគេសង្ស័យថា មិនទាន់គ្រប់គ្រាន់ សម្ដេចប៉ាប ភីយ៉ូស ទី៥ (Pius V) បានយកចិត្តទុកដាក់ជាពិសេស ដោយការពារច្បាប់ប្រពៃណីថ្មីនេះបន្ថែមទៀត បន្ទាប់មក ភាពអយុត្តិធម៌ដែលអ្នកខ្លះប្រឆាំងមិនព្រមទទួលស្គាល់ មានការកែប្រែក្បួនពិធីបុណ្យមិនសូវច្រើនប៉ុន្មានទេ។ តាមពិត ពិធីអភិបូជានៅឆ្នាំ១៥៧០ មិនសូវខុសគ្នាពីក្បួនពិធីដែលបោះពុម្ពលើកទីមួយនៅឆ្នាំ១៤៧៤ ដែលបានបែរមកចាប់យកប្រើក្បួនអភិបូជានៅសម័យសម្ដេចប៉ាប អិនណូសង់ ទី៣ (Innocent III)។ ម៉្យាងទៀត នៅក្នុងបណ្ណាល័យវ៉ាទីកង់ មានសៀវភៅដែលសរសេរដៃគ្រប់គ្រាន់ពីអ្នកនិពន្ធបុរាណ ទោះបី ជាអស់លោកបានផ្ដល់សម្ភារៈ ដែលជាអត្ថបទជាច្រើនសម្រាប់ជួយកែតម្រូវពាក្យពេចន៍ខ្លះ ក៏ដោយ ក៏គ្មានមធ្យោបាយណា ដែលអាចធ្វើឲ្យការស្វែងរកបន្ដចូលទៅក្នុង "អ្នកនិពន្ធសម័យបុរាណ និងយល់ព្រម" ដើម្បីជួយជ្រោមជ្រែងបន្ថែមទៀតនូវសេចក្ដីអត្ថាធិប្បាយពីក្បួនពិធីបុណ្យនៅមជ្ឈិមសម័យ។

៨. សព្វថ្ងៃនេះ យ៉ាងណាក៏ដោយ ការសិក្សាស្រាវជ្រាវបានបំភ្លឺពីរបៀបដើមរបស់បុព្វបុរសដ៏វិសុទ្ធដែលពិនិត្យមើលឡើងវិញនូវក្បួនពិធីអភិបូជារបស់ សម្ដេចប៉ាប ភីយ៉ូស ទី៥ (Pius V) បានធ្វើតាម។ ពីព្រោះ គេបានបោះពុម្ពផ្សាយជាលើកដំបូងនៅឆ្នាំ១៥៧១ សម្រាប់ក្បួនពិធីអគ្គសញ្ញាដែលហៅថា (Gregorian)។ គេបានបោះពុម្ពក្បួនបុរាណរ៉ូម៉ាំងផ្សេងទៀត និងចែកចាយក្បួនអគ្គសញ្ញាអាំប្រូស (Ambrosian) ព្រមទាំងសៀវភៅពិធីបុណ្យខ្លះៗពីប្រពៃណី ហ៊ីសជានីក និងហ្គាឡីកេន (Hispanic and Gallican) ដែលមានពាក្យអធិដ្ឋានដ៏ល្អប្រសើរ ដែលគេមិនធ្លាប់ស្គាល់។ ការបោះពុម្ពសៀវភៅបុរាណទាំងនេះ នាំឲ្យគេរកឃើញនូវរបៀបអធិដ្ឋានជាច្រើនដែលជាគុណតម្លៃនៃពន្លឺខាងវិញ្ញាណដែលគេមិនធ្លាប់ស្គាល់កាលពីសម័យមុន។

នៅក្នុងរបៀបដដែល ច្បាប់ប្រពៃណីនៃសតវត្សដើមដំបូង បានរកឃើញក្បួនពិធីនៃប្រពៃណីទិសខាងកើត និងខាងលិចមុនគេ។ ឥឡូវនេះ គឺគេយល់ដឹងប្រសើរជាងមុនដោយសារតែគេរកឃើញនូវឯកសារក្បួនពិធីបុណ្យជាច្រើន។

លើសពីនេះទៅទៀត ការសិក្សានៃបុព្វបុរសដ៏វិសុទ្ធបានបន្តឲ្យមានដំណើរការទៅមុខ និងបំភ្លឺឲ្យយល់ច្បាស់ជាងពីទេវវិទ្យារបស់សន្តអ៊ីរ៉ាណូស សន្តអាំប្រូស និងសន្តក្រីវាលជាអភិបាលក្រុងយេរូសាឡឹម និងសន្តយ៉ូហានគ្រីសូស្តូម អំពីគម្រោងការដ៏អស្ចារ្យនៃពិធីអភិបូជា។

៩. ហេតុនេះ គោលការណ៍របស់សន្តអាសនៈមិនតម្រូវតែរក្សារបៀបដើមប៉ុណ្ណោះទេ គឺត្រូវថែរក្សាសេចក្ដីដែលទទួលពីបុព្វបុរសរបស់យើង ព្រមទាំងការសិក្សាយល់ដឹងពីអតីតកាលនៃប្រវត្តិសាស្ត្ររបស់ព្រះសហគមន៍ និងរបៀបដែលគេប្រកាសជំនឿតាមអរិយធម៌ផ្សេងៗ ដូចជា អ៊ីស្រាអែល ក្រិក និងឡាតាំង។ របៀបផ្សេងៗពីគ្នានេះ បង្ហាញឲ្យយើងឃើញថា ព្រះវិញ្ញាណដ៏វិសុទ្ធជួយបំភ្លឺប្រជាជនដ៏វិសុទ្ធរបស់ព្រះអង្គ ដើម្បីថែរក្សាការពារជំនឿតែមួយ ទោះបី មានពាក្យអធិដ្ឋានផ្សេងពីគ្នាក៏ដោយ។

## ការរៀបចំកែសម្រួលឲ្យស្របតាមស្ថានភាពថ្មី

១០. ក្បួនពិធីថ្មីនេះ គោរពតាមច្បាប់នៃអធិដ្ឋាន (lex orandi) ដែលជាទម្លាប់របស់ព្រះសហគមន៍ប្រពៃណីរ៉ូម៉ាំង ហើយទទួលការគោរពលទ្ធិនៃជំនឿពីមហាសន្និបាតខ្លះៗ ព្រមទាំងដើរមួយជំហានទៅមុខទៀត ក្នុងដំណើរការនៃច្បាប់ប្រពៃណីខាងពិធីបុណ្យ។

ដោយលោកឪពុកនៃមហាសន្និបាតវ៉ាទីកង់ទីពីរ បានបញ្ជាក់បន្ថែមទៀតនូវគោលសំខាន់ក្នុងសេចក្តីប្រកាសរបស់មហាសន្និបាតត្រែន ដែលគេនិយាយពីភាពខុសគ្នាកន្លងមក នៅក្នុងប្រវត្តិសាស្ត្រពិភពលោក ហើយសម្រាប់ហេតុផលនោះ អាចនាំយកសំណើរ និងការវាស់វែងទៅមុខទៀត ចំពោះការទំនាក់ទំនងនឹងជីវិតអ្នកណែនាំដែលមិនអាចជឿនលឿនទៅមុខជាងបួនសតវត្សមុន។

១១. មហាសន្និបាតត្រែន បានទទួលស្គាល់ពីអត្ថប្រយោជន៍ជាច្រើននៃការអប់រំជំនឿមាននៅក្នុងក្បួនពិធីអភិបូជា ប៉ុន្តែគេមិនបានទាញយកនូវផលវិបាកទាំងអស់របស់ខ្លួនចំពោះការអនុវត្តជាក់ស្តែង។ តាមពិត ក្រុមផ្សេងៗបានស្នើសុំការអនុញ្ញាតជាច្រើនដងដើម្បីឲ្យប្រើភាសាប្រចាំភូមិភាគនៅក្នុងពិធីអរព្រះគុណព្រះជាម្ចាស់។ ដើម្បីឲ្យការស្នើសុំមហាសន្និបាតបានពន្យល់ពីស្ថានភាពនៅសម័យនោះ ជាបញ្ហានៃកាតព្វកិច្ចមួយដើម្បីឆ្លើយតប ដោយទាមទារជាថ្មីម្តងទៀតទៅលើការបង្ហាត់បង្រៀនសម្រាប់ព្រះសហគមន៍ ដូចដែលគេធ្លាប់បានប្រគល់ឲ្យបញ្ជូនបន្ត បើយោងតាមពិធីអរព្រះគុណព្រះជាម្ចាស់ គឺស្ថិតនៅក្នុងដើមដំបូងអង្គស់ ជាសកម្មភាពរបស់ព្រះគ្រីស្តផ្ទាល់ព្រះអង្គដែលមានប្រសិទ្ធភាព ហេតុដូច្នេះ មិនអាស្រ័យលើរបៀបដែលគ្រីស្តបរិស័ទចូលរួមទេ។ នេះជាមូលហេតុដែលមហាសន្និបាតបានបញ្ជាក់យ៉ាងម៉ឺងម៉ាត់ដូចដែលបានគ្រោងទុកថា ទោះជាអភិបូជាមានការណែនាំសម្រាប់អស់អ្នកជឿយ៉ាងណាក៏ដោយ ក៏ក្រុមលោកឪពុកដែលប្រារព្ធពិធីនោះមិនឃើញថា ការប្រើភាសាប្រចាំ ភូមិភាគជាចំណុចមួយដ៏ចាំបាច់ទេ។[27] រួចហើយ មហាសន្និបាតរបស់លោកអភិបាល បានប្រកាសជាកិត្តិយសដល់អស់អ្នកដែលប្រកាន់រិះគន់យ៉ាងខ្លាំងថា "ក្បួនពិធីរបស់ព្រះសហគមន៍រ៉ូម៉ាំងជាផ្នែកមួយនៃសាសនគ្រីត្យក្រុងរ៉ូម និងថ្វាយពាក្យសន្យាចំពោះព្រះជាម្ចាស់ គឺប្រកាសជាផ្លូវការ នៅក្នុងធម៌ប្រសិទ្ធិព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ដែលត្រូវនិយាយខ្សឹបៗ ឬធម៌លើកលែងទោស ដែលត្រូវថ្វាយអភិបូជាដោយប្រើតែភាសាប្រចាំភូមិភាគ។ យ៉ាងណាក៏ដោយក្នុងពេលដដែលមហាសន្និបាតបានហាមឃាត់មិនឲ្យប្រើភាសាប្រចាំតំបន់ក្នុងអភិបូជា នេះជាការចាត់ចែង ហើយម្យ៉ាងទៀត គង្វាលជាដួងព្រលឹងនៃអ្នកណែនាំដាក់ឲ្យសមតាមការអប់រំជំនឿគ្រីស្តបរិស័ទនៅក្នុងកន្លែងរបស់ខ្លួន "កុំបណ្តោយឲ្យហ្វូងចៀមរបស់ព្រះគ្រីស្តស្រេកឃ្លាន ...មហាសន្និបាតគ្រីស្តបរិស័ទបានដាក់សំណើទៅលោកបូជាចារ្យ និងអស់អ្នកដែលទទួលបន្ទុកណែនាំដល់គ្រីស្តបរិស័ទយកចិត្តទុកដាក់នូវអាហារខាងវិញ្ញាណរបស់គេជារឿយៗ

[27] Ecumenical Council of Trent, Session 22, *Doctrina de ss. Missae sacrificio*, 17 September 1562, chapter 8: Denz-Schön, 1749.

នៅក្នុងពេលថ្វាយអភិបូជា មិនថាចំពោះខ្លួនឯងផ្ទាល់ ឬអ្នកដទៃ ត្រូវពន្យល់គេនូវអ្វីៗដែលបានអានក្នុងអភិបូជា ហើយអធិប្បាយអំពីគម្រោងការដ៏អស្ចារ្យនៃពិធីអភិបូជានេះ ជាពិសេសនៅថ្ងៃអាទិត្យ និងថ្ងៃបុណ្យ។[28]

១២. ហេតុនេះ មហាសន្និបាតវ៉ាទីកង់ទី២ បានរិះគិតពីរបៀបដែលព្រះសហគមន៍ទាមទារឲ្យកែសម្រួលនៅសម័យនោះ ដោយពិនិត្យមើលលក្ខណៈពិសេសនៃពិធីបុណ្យខាងការអប់រំគ្រីស្តបរិស័ទ ដូចមហាសន្និបាតត្រែនបានធ្វើ[29] សព្វថ្ងៃនេះ ព្រះសហគមន៍បដិសេធមិនទទួលស្គាល់ក្បួនអភិបូជាដែលប្រារព្ធជាភាសាឡាតាំង តាមច្បាប់របស់មហាសន្និបាតបានអនុញ្ញាតថាមានប្រសិទ្ធភាព និងត្រឹមត្រូវតាមច្បាប់ ក្រុមប្រឹក្សាក៏បានទទួលស្គាល់ថា ការប្រើភាសាប្រចាំតំបន់ពិតជាមានប្រយោជន៍យ៉ាងខ្លាំង សម្រាប់បងបងប្អូនគ្រីស្តបរិស័ទ។[30] ភាពខ្នះខ្នែងជាមួយនឹងសេចក្តីសម្រេចនេះ បានទទួលនៅគ្រប់ទីកន្លែងប្រសើរលើសលប់ដោយអំណររីករាយអស់ពីដួងចិត្ត នៅក្រោមការដឹកនាំរបស់លោកអភិបាលភូមិភាគ និងលោកអភិបាលព្រះសហគមន៍ក្រុងរ៉ូមនៃសន្តអាសនៈ ចំពោះការអនុញ្ញាតឲ្យប្រារព្ធគ្រប់ពិធីបុណ្យជាភាសាប្រចាំតំបន់តាមមណ្ឌលសកម្មភាព ដើម្បីជួយឲ្យគ្រីស្តបរិស័ទចូលរួម និងយល់កាន់តែច្បាស់ពីគម្រោងការដ៏អស្ចារ្យនៃអភិបូជានេះ។

១៣. ដោយសារប្រើភាសាប្រចាំតំបន់ក្នុងពិធីបុណ្យមានសារៈសំខាន់សម្រាប់អប់រំជំនឿ និងបង្ហាញពីអត្ថន័យដ៏អាថ៌កំបាំងនៃពិធីបុណ្យ មហាសន្និបាតវ៉ាទីកង់ទី២ បានចាត់ចែងឲ្យមានក្រឹត្យវិន័យខ្លះពីមហាសន្និបាតត្រែនដែលមិនទាន់អនុវត្តបាននៅគ្រប់ទីកន្លែង ដូចជាឲ្យមានអប់រំជំនឿឡើងវិញ ធម្មទេសនានៅថ្ងៃអាទិត្យ និងថ្ងៃបុណ្យផ្សេងៗ[31] ព្រមទាំងអនុញ្ញាតឲ្យពន្យល់សេចក្តីខ្លះៗដែលចាំបាច់ពេលកំពុងប្រារព្ធពិធី។[32]

មហាសន្និបាតវ៉ាទីកង់ទី២ បានជំរុញឲ្យគ្រីស្តបរិស័ទទទួលព្រះកាយ និងព្រះលោហិតបន្ទាប់ពីលោកបូជាចារ្យធ្វើពិធីប្រសិទ្ធពរលើនំ និងស្រាតង្វាយនោះ[33] មហាសន្និបាតវ៉ាទីកង់ទី២ មានគោលបំណងផ្ញើលិខិតទៅលោកឪពុកនៅត្រែន ថាធ្វើយ៉ាងណា ដើម្បីឲ្យគ្រីស្តបរិស័ទចូលរួមថ្វាយអភិបូជា មិនគ្រាន់តែទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត តាមបំណងប្រាថ្នាក្នុងចិត្តតែប៉ុណ្ណោះទេ គឺទទួលអគ្គសញ្ញាព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ត។[34]

១៤. ដោយការយកចិត្តទុកដាក់អំពីការណែនាំគ្រីស្តបរិស័ទ មហាសន្និបាតវ៉ាទីកង់ទី២ បានឲ្យក្រឹត្យវិន័យសាជាថ្មីទៀត ចំពោះអ្វីដែលមហាសន្និបាតត្រែនបានសម្រេច អំពីការទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។ តាមពិតសព្វថ្ងៃនេះ គោលការណ៍នៃលទ្ធិនៅមានប្រសិទ្ធភាពពេញលេញក្នុងពិធីអរព្រះគុណដ៏វិសុទ្ធ ដែលជាវត្តមានព្រះយេស៊ូគ្រីស្តនៅក្នុងនំ

---

[28] Ecumenical Council of Trent, Session 22, *Doctrina de ss. Missae sacrificio*, 17 September 1562, chapter 8: Denz-Schön, 1749.
[29] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 33
[30] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 36.
[31] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 52.
[32] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 35:3.
[33] Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 55.
[34] Ecumenical Council of Trent, Session 22, *Doctrina de ss. Missae sacrificio*, 17 September 1562, chapter 6: Denz-Schön, 1747.

ព្រះកាយ និងព្រះលោហិត ពេលយើងរួមគ្នាថ្វាយអភិបូជា ដូច្នេះ មហាសន្និបាតបានអនុញ្ញាតឲ្យគ្រីស្តបរិស័ទទទួលអគ្គសញ្ញាព្រះកាយ និងព្រះលោហិតក្នុងឱកាសពិសេស គឺទទួលទាំងព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ធ្វើរបៀបនេះ ជួយឲ្យគ្រីស្តបរិស័ទដែលចូលរួមស៊ីជម្រៅ និងយល់ពីគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។[35]

១៥. ធ្វើដូច្នេះ មុខងារបម្រើព្រះសហគមន៍មានរបៀបក្នុងការថែរក្សា ដូចជា "របៀបចាស់" ទុកជាគ្រូបាធ្យាយនៃសេចក្តីពិត គឺជាការបញ្ជូនបន្តឲ្យអ្នកជឿនៃទំនៀមទម្លាប់ ក្នុងពេលតែមួយដើម្បីបំពេញកាតព្វកិច្ចនៃការពិនិត្យមើលដោយប្រុងប្រយ័ត្ននូវ "របៀបថ្មី" (មថ ១៣,៥២)។ ស្របនឹងសេចក្តីនេះ នៅក្នុងក្បួនអភិបូជាថ្មី មានពាក្យអធិដ្ឋានខ្លះជាពាក្យទូលអង្វរព្រះជាម្ចាស់សម្រាប់សេចក្តីត្រូវការរបស់យើងក្នុងពេលបច្ចុប្បន្ន។ តាមរបៀបខាងលើ ក្បួនពិធីអភិបូជាទាំងស្រុង និងអភិបូជាសម្រាប់សេចក្តីត្រូវការផ្សេងៗ មានពាក្យអធិដ្ឋានច្រើនមកពីសម័យបុរាណដែលមានស្រាប់នៅក្នុងក្បួនចាស់ៗនៃពិធីបុណ្យរ៉ូម៉ាំង យើងមិនបានផ្លាស់ប្តូរទេ ប៉ុន្តែមានពាក្យខ្លះបានកែសម្រួលតាមសេចក្តីត្រូវការ និងធ្វើឲ្យទាន់សម័យ។ រីឯពាក្យអធិដ្ឋានសម្រាប់ព្រះសហគមន៍ និងប្រជាជន ជាពាក្យអង្វរសូមព្រះអង្គប្រោសឲ្យការងាររបស់មនុស្សបានវិសុទ្ធ និងប្រោសឲ្យប្រជាជនចូលរួមជាធ្លុងតែមួយ ព្រមទាំងសេចក្តីត្រូវការក្នុងសម័យបច្ចុប្បន្ននេះ គឺអស់លោកបានសរសេរសាជាថ្មីទៀតនូវឯកសា និងតាមគំនិតរបស់មហាសន្និបាត។ ស្របតាមស្ថានភាពសម័យបច្ចុប្បន្ន ពេលព្រះសហគមន៍យកឯកសារបុរាណដែលយើងគោរពដូចជាទ្រព្យសម្បត្តិរបស់ព្រះសហគមន៍ ហើយបើសិន ត្រូវការផ្លាស់ប្តូរពាក្យខ្លះៗ ឬសេចក្តីខ្លះពីទម្លាប់បុរាណនោះ ដូចជា ពាក្យវាយតម្លៃទ្រព្យសម្បត្តិលោកីយ៍ វិន័យព្រះសហគមន៍ និងការតមទាំងប៉ុន្មានដែលប្រព្រឹត្តតាមផ្លូវកាយ អស់លោកត្រូវយកចិត្តទុកដាក់ កុំចោល ឯកសារបុរាណទាំងនោះ ឬផ្លាស់ប្តូរអត្ថន័យតាមរបៀបដែលមិនគួរសម។

នៅក្នុងរបៀបចុងក្រោយ ក្បួនពិធីបុណ្យនៃក្រុមប្រឹក្សាត្រែន ពិតជាបានបញ្ចប់ និងដោយសុក្រឹត្យភាពនៅក្នុងចំណុចជាច្រើន ដោយមហាសន្និបាតវ៉ាទីកង់ទីពីរនោះ យកបទបញ្ញានៃក្បួនពិធីបុណ្យដែលមានប្រសិទ្ធភាព អត្ថន័យច្បាស់ និងល្អជាង។ ហេតុដូច្នេះ មហាសន្និបាតបានបញ្ចប់កិច្ចការរបស់ព្រះសហគមន៍អស់រយៈពេល៤០០ឆ្នាំចុងក្រោយ ហើយជាពិសេស កិច្ចប្រឹងប្រែងរបស់សម្តេចប៉ាប ភីយ៉ូសទី១០ (Pius X) និងសម្តេចប៉ាបឯទៀតៗដែលលោកមានបំណងចង់ឲ្យគ្រីស្តបរិស័ទចូលរួមយ៉ាងសកម្ម។

---

[35] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, Sacrosanctum Concilium, no. 55.

## ជំពូកទី ១

## សារៈសំខាន់ និងមុខងារកំពូលនៃពិធីអរព្រះគុណដ៏វិសុទ្ធ

១៦. ពិធីអភិបូជា គឺជាសកម្មភាពរបស់ព្រះគ្រីស្ត និងព្រះសហគមន៍ ហើយជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់នៃមុខងាររបស់លោកបូជាចារ្យ ជាសក្ការបូជានៃដួងជីវិតរបស់គ្រីស្តបរិស័ទម្នាក់ៗក្នុងព្រះសហគមន៍ទាំងក្នុងតំបន់ និងទូទាំងសកលលោក។[36] ពីព្រោះអភិបូជា ជាបុណ្យដ៏កំពូលនៃសកម្មភាពព្រះជាម្ចាស់ដែលប្រោសឲ្យពិភពលោកបានវិសុទ្ធក្នុងអង្គព្រះគ្រីស្ត និងថ្វាយបង្គំគោរពបូជា ដែលមនុស្សគ្រប់ជាតិសាសន៍ថ្វាយឆ្ពោះទៅព្រះបិតា ក្រាបថ្វាយបង្គំព្រះអង្គ តាមរយៈព្រះគ្រីស្តជាព្រះបុត្រារបស់ព្រះជាម្ចាស់ រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ។[37] ម្យ៉ាងទៀត នៅក្នុងអភិបូជា មានវដ្ដកាលនៃពិធីបុណ្យពេញមួយឆ្នាំដែលជួយឲ្យនឹករឭកដល់គម្រោងការដ៏អស្ចារ្យនៃព្រះសង្គ្រោះ គឺត្រូវប្រារព្ធពិធីតាមរបៀបមួយចំនួនដែលបានបង្កើតសព្វថ្ងៃនេះ។[38] អភិបូជា ជាប្រភព និងជាគោលដៅនៃពិធីបុណ្យទាំងអស់ ជាសកម្មភាពទាំងប៉ុន្មានដែលបានចាត់ចែងក្នុងព្រះសហគមន៍សម្រាប់ជីវិតជាគ្រីស្តបរិស័ទ។[39]

១៧. ដូច្នេះ លក្ខណៈសំខាន់បំផុតនៃការប្រារព្ធពិធីអភិបូជា ឬពិធីជប់លៀងរបស់ព្រះអម្ចាស់ដែលបានចាត់តាំងនោះ អ្នកបម្រើពិធីបុណ្យ និងអស់អ្នកជឿដែលចូលរួម ត្រូវរៀបចំទៅតាមផ្នែកនៃមុខងារម្នាក់ៗដោយសមរម្យ អាចនឹងទាក់ទាញចិត្តគ្រីស្តបរិស័ទជាច្រើនទៀត[40] ទាំងនោះគឺជាផលផ្លែដែលទទួលបានពីព្រះគ្រីស្តជាអម្ចាស់ តែងតាំងសក្ការបូជានៃព្រះកាយ និងព្រះលោហិតរបស់ព្រះអង្គ ហើយប្រគល់ឲ្យព្រះសហគមន៍ជាភរិយាដ៏ជាទីស្រឡាញ់របស់ព្រះអង្គរំឭកពីព្រះអម្ចាស់សោយទុក្ខលំបាក និងមានព្រះជន្មរស់ឡើងវិញ។[41]

១៨. ប្រសិនបើមានបំណងឲ្យពិធីនេះសមរម្យ ត្រូវរៀបចំតែងលម្អដោយមានលក្ខណៈធម្មជាតិហើយត្រូវយល់ពីកាលៈទេសៈផ្សេងទៀតនៃការជួបជុំគ្នាក្នុងពិធីបុណ្យ នៅក្នុងរបៀបដែលនាំឲ្យមានការរំពឹងទុកថា គ្រីស្តបរិស័ទចូលរួមយ៉ាងសកម្ម អស់ពីដួងចិត្ត អស់ពីស្មារតី និងប្រកបដោយជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់ គឺតាមរបៀបដែលព្រះសហគមន៍ប្រាថ្នាទៅតាមរបៀបសមរម្យ ថ្លៃថ្នូរ នេះជាសិទ្ធ និងជាកាតព្វកិច្ចរបស់គ្រីស្តបរិស័ទដែលទទួលអគ្គសញ្ញាជ្រមុជទឹក។[42]

១៩. ទោះបីជាពិធីខ្លះមិនមានឱកាសអាចប្រព្រឹត្តទៅបានដើម្បីប្រឈមមុខ និងអ្នកចូលរួមយ៉ាងសកម្មរបស់គ្រីស្តបរិស័ទ ត្រូវបង្ហាញគេឲ្យយល់ច្បាស់ពីលក្ខណៈនៃការប្រារព្ធពិធីបុណ្យ[43]

[36] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 41; Dogmatic Constitution on the Church, *Lumen gentium*, no. 11; Decree on the Ministry and Life of Priests, *Presbyterorum ordinis*, nos. 2, 5, 6; Decree on the Pastoral Office of Bishops, *Christus Dominus*, 28 October 1965 , no. 30; Second Vatican Ecumenical Council, Decree on Ecumenism, *Unitatis redintegratio*, 21 November 1964, no. 15; Sacred Congregation of Rites, Instruction *Eucharisticum mysterium*, On the worship of the Eucharist, 25 May 1967, nos. 3e, 6: AAS 59 (1967), pp. 542, 544-545.
[37] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 10.
[38] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 102.
[39] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 10; cf. Decree on the Ministry and Life of Priests, *Presbyterorum ordinis*, no. 5.
[40] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, nos. 14, 19, 26, 28, 30.
[41] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 47.
[42] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 14.
[43] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 41.

ការប្រារព្ធពិធីអរព្រះគុណព្រះជាម្ចាស់ តែងតែផ្ដល់នូវប្រសិទ្ធភាពខ្ពស់ ជាបុណ្យកំពូល និងជាសកម្មភាពរបស់ព្រះគ្រីស្ដ ហើយជាកាតព្វកិច្ចដ៏សំខាន់របស់ព្រះសហគមន៍ នៅក្នុងមុខងារបម្រើដែលលោកបូជាចារ្យបំពេញយ៉ាងសកម្ម ហើយដើរតួនាទីដើម្បីសង្គ្រោះមនុស្សលោក។

ហេតុនេះ លោកបូជាចារ្យត្រូវផ្ដល់អនុសាសន៍ដើម្បីប្រារព្ធពិធីអរព្រះគុណដ៏វិសុទ្ធ តាមតែលោកអាចធ្វើបាន ទោះជាមានថ្វាយអភិបូជារៀងរាល់ថ្ងៃ។[44]

២០. កន្លងមក ទោះបីជាយ៉ាងណាក៏ដោយ ការប្រារព្ធពិធីអរព្រះគុណព្រះជាម្ចាស់ ក៏ដូចជាពិធីបុណ្យទាំងឡាយ ត្រូវអនុវត្តន៍ដោយមធ្យោបាយនូវសញ្ញាសម្គាល់ឯទៀតៗដែលបង្ហាញពីជំនឿដ៏រឹងមាំទុកជាអាហារ[45] ដូច្នេះ ត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការប្រកាន់យកក្បួនច្បាប់ ព្រមទាំងស្នើសុំនូវចំណុចសំខាន់ៗដែលព្រះសហគមន៍បានរៀបចំ និងជ្រើសរើស ទីកន្លែងដែលផ្ដល់ឲ្យបងប្អូនទៅតាមកាលៈទេសៈ ដើម្បីជួយជំរុញឲ្យគ្រីស្ដបរិស័ទកាន់តែមានប្រសិទ្ធភាពចូលរួមយ៉ាងសកម្ម ហើយថែមទាំងជួយឲ្យគ្រីស្ដបរិស័ទ ងាយនឹងឆ្លើយតបនូវសេចក្ដីត្រូវការខាងផ្លូវវិញ្ញាណ។

២១. សេចក្ដីណែនាំនេះ មានគោលដៅពីរ ទីមួយ ការរៀបចំចាត់ចែងពិធីអភិបូជាទូទៅនៃពិធីអរព្រះគុណព្រះជាម្ចាស់ និងទីពីរ សេចក្ដីសម្រេចក្នុងការពន្យល់អំពីក្បួនច្បាប់នៃទម្រង់នីមួយៗដែលត្រូវរៀបចំសម្រាប់ថ្វាយអភិបូជា។[46]

២២. អភិបូជាមានសារៈសំខាន់ខ្លាំងណាស់ ជាពិសេសនៅក្នុងព្រះសហគមន៍តាមភូមិភាគ។ ពីព្រោះលោកអភិបាលព្រះសហគមន៍ភូមិភាគ ជាអ្នកទទួលខុសត្រូវ និងជាអ្នកបម្រើ មើលថែរក្សានូវគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ក្នុងព្រះសហគមន៍ លោកយកចិត្តទុកដាក់ជួយជំរុញ សម្រុះសម្រួល គាំទ្រ និងណែនាំជីវិតគ្រីស្ដបរិស័ទខាងផ្លូវវិញ្ញាណឲ្យស្របតាមក្បួនពិធីខាងគ្រីស្ដសាសនា។[47] ពិធីអភិបូជា គឺនៅក្រោមអធិបតីភាពរបស់លោកអភិបាល ជាពិសេស ថ្វាយអភិបូជា ដោយមានលោកបូជាចារ្យ លោកឧបដ្ឋាក និងគ្រីស្ដបរិស័ទឯទៀតៗចូលរួម ជាការបង្ហាញឲ្យឃើញពីអាថ៌កំបាំងនៃព្រះសហគមន៍។ ហេតុនេះ ការប្រារព្ធពិធីអភិបូជាយ៉ាងឱឡារិក គួរយកគំរូក្បួនពិធីតាមរបៀបដ៏ល្អប្រសើរសម្រាប់ភូមិភាគទាំងអស់។

ហេតុនេះហើយ លោកអភិបាល គួរតែធ្វើតាមការកំណត់ថា លោកបូជាចារ្យ លោកឧបដ្ឋាក ព្រមទាំងគ្រីស្ដបរិស័ទត្រូវយល់យ៉ាងច្បាស់ពីសេចក្ដីសំខាន់នៃក្បួនពិធី និងអត្ថន័យនៅក្នុងអត្ថបទនៃពិធីបុណ្យផ្សេងៗ ធ្វើដូច្នេះ អាចនាំអ្នកទាំងអស់ចូលរួមយ៉ាងសកម្ម និងទទួលបានផលផ្លែយ៉ាងបរិបូរណ៍ពីអភិបូជា។ ដើម្បីឲ្យដល់គោលដៅ លោកអភិបាលគួរតែមានការប្រុងប្រយ័ត្នក្នុងការអះអាងថា មុខងារបម្រើពិធីបុណ្យទាំងអស់នេះ បានប្រារព្ធឡើង

---

[44] Cf. Second Vatican Ecumenical Council, Decree on the Ministry and Life of Priests, *Presbyterorum ordinis*, no. 13; *Codex Iuris Canonici* , can. 904.
[45] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 59.
[46] Special celebrations of Mass should observe the guidelines established for them: For Masses with special groups, cf. Sacred Congregation for Divine Worship, Instruction *Actio pastoralis*, on Masses with special groups, 15 May 1969: AAS 61 (1969), pp. 806-811; for Masses with children, cf. Sacred Congregation for Divine Worship, *Directory for Masses with Children*, 1 November 1973: AAS 66 (1974), pp. 30-46; for the manner of joining the Hours of the Office with the Mass, cf. Sacred Congregation for Divine Worship, General Instruction of the Liturgy of the Hours, *editio typica*, 11 April 1971, *editio typica altera*, 7 April 1985, nos. 93-98; for the manner of joining certain blessings and the crowning of an image of the Blessed Virgin Mary with the Mass, cf. The Roman Ritual, *Book of Blessings*, *editio typica*, 1984, Introduction, no. 28; *Order of Crowning an Image of the Blessed Virgin Mary, editio typica*, 1981, nos. 10 and 14.
[47] Cf. Second Vatican Ecumenical Council, Decree on the Pastoral Office of Bishops, *Christus Dominus*, no. 15; cf. also Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 41.

ល្អប្រសើរ និងធ្វើឲ្យមានសោភ័ណភាពនៅទីសក្ការបូជា ដូចជាមានលក្ខណៈសិល្បៈ រួមទាំងមានភ្លេងតន្ត្រីដើម្បីជួយផ្ដល់ឲ្យពិធីនោះកាន់តែប្រសើរឡើងតាមតែអាចធ្វើបាន។

២៣. ម្យ៉ាងទៀត នៅក្នុងការចាត់ចែងប្រារព្ធពិធី អាចស្របគ្នាច្រើនជាងសេចក្ដីបង្គាប់ដែលបានបំពេញ និងជំរុញស្មារតីឲ្យប្រារព្ធពិធីបុណ្យដ៏ពិសិដ្ឋនេះ ហើយនៅក្នុងការចាត់ចែងនោះផងដែរ មណ្ឌលសកម្មភាពខ្លះមានប្រសិទ្ធភាពកាន់តែប្រសើរឡើង ពិតមែនហើយ អស់លោកត្រូវយកចិត្តទុកដាក់រៀបចំ កែតម្រូវតាមសេចក្ដីណែនាំទូទៅ និងសៀវភៅក្បួនពិធី អភិបូជានេះ។

២៤. លោកបូជាចារ្យដែលយកលំនាំតាមពិធីនេះ ភាគច្រើនជ្រើសរើសយក ក្បួនពិធីដែលបានកំណត់រួចមកហើយ ដូចជា អត្ថបទព្រះគម្ពីរ បទចម្រៀង ការអាន ពាក្យអធិដ្ឋាន សេចក្ដីអត្ថាធិប្បាយ កាយវិការដែលឆ្លើយតបនឹងសេចក្ដីត្រូវការ ព្រមទាំងរបៀបត្រៀមខ្លួននិងវប្បធម៌ប្រពៃណីរបស់អ្នកចូលរួម ដែលលោកបូជាចារ្យបានប្រារព្ធពិធីឆ្លងនោះ។ ទោះជាយ៉ាងណា លោកបូជាចារ្យត្រូវតែចងចាំថា លោកជាអ្នកបម្រើពិធីបុណ្យដ៏សក្ការៈ ដូច្នេះលោកមិនអាចធ្វើការសម្រេចចិត្ត ដោយខ្លួនឯង លុបចោល ឬបន្ថែមទៅលើការផ្លាស់ប្ដូរចំណុចណាមួយនៅក្នុងក្បួនពិធីអភិបូជាឡើយ។[48]

២៥. លើសពីនេះទៅទៀត នៅក្នុងអភិបូជាត្រូវមានកន្លែងត្រឹមត្រូវ គឺបង្ហាញប្រាប់ពីលំនាំមួយចំនួនដែលបានអនុញ្ញាតអំពីធម្មនុញ្ញពិធីបុណ្យដ៏សក្ការៈ មានទាក់ទងនឹងលោកអភិបាលនីមួយៗប្រចាំភូមិភាគ ឬអង្គប្រជុំរបស់លោកអភិបាល[49] (សូមមើលលេខ ៣៨៧, ៣៨៨, ៣៩៣)។

២៦. សម្រាប់សេចក្ដីផ្សេងៗ និងការផ្លាស់ប្ដូរទៅតាមអត្ថន័យដ៏ជ្រាលជ្រៅដែលបានពិនិត្យពិច័យពីទំនៀមទម្លាប់ និងវប្បធម៌របស់ប្រជាជនតាមតំបន់ ចំពោះការណែនាំដែលមាននៅក្នុងមាត្រាទី៤០ បានអនុញ្ញាតឲ្យគោរពបទបញ្ញាធម្មនុញ្ញនៃពិធីបុណ្យដ៏សក្ការៈនេះ ពីព្រោះជាហេតុដែលមានអត្ថប្រយោជន៍ ឬជាការចាំបាច់ជៀសមិនរួច ក្បួនច្បាប់ទាំងអស់នោះ ត្រូវបានកំណត់នៅក្នុងសេចក្ដីណែនាំរបស់មហាសន្និបាត ស្ដីអំពីពិធីបុណ្យក្រុងរ៉ូម និងការសម្របក្បួនពិធីព្រះសហគមន៍រួមនឹងប្រពៃណីខ្មែរ[50] ហើយត្រូវប្រតិបត្តិតាមឯកសារយោងខាងក្រោមលេខ៣៩៥-៣៩៩។

[48] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 22.
[49] Cf. also Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, nos 38, 40; Paul VI, Apostolic Constitution *Missale Romanum*, above.
[50] Congregation for Divine Worship and the Discipline of the Sacraments, Instruction *Varietates legitimae*, 25 January 1994 : AAS 87 (1995), pp. 288-314.

# ជំពូកទី ២

## រចនាសម្ព័ន្ធនៃអភិបូជា និងផ្នែកផ្សេងជាគោលការណ៍សំខាន់ៗ

### I. រចនាសម្ព័ន្ធទូទៅនៃពិធីអភិបូជា

២៧. ពេលថ្វាយអភិបូជា ឬពិធីជប់លៀងរបស់ព្រះអម្ចាស់ គឺព្រះជាម្ចាស់បានត្រាស់ហៅប្រជារាស្ត្ររបស់ព្រះអង្គឲ្យរួបរួមគ្នា ដោយមានលោកបូជាចារ្យធ្វើជាអធិបតី ហើយថ្វាយអភិបូជាក្នុងព្រះនាមព្រះគ្រីស្ត ដើម្បីនឹករឭកដល់ព្រះអម្ចាស់ ឬពិធីអរព្រះគុណព្រះជាម្ចាស់។[51] ដូច្នេះនៅក្នុងរបៀបដ៏ប្រសើរនេះ ត្រូវអនុវត្តទៅជួបជុំគ្នាក្នុងព្រះវិហារនៅតាមតំបន់របស់ខ្លួន ដូចព្រះគ្រីស្តមានព្រះបន្ទូលសន្យាថា៖ "កាលណាមានពីរ ឬបីនាក់ ជួបជុំគ្នាក្នុងនាមខ្ញុំ នោះខ្ញុំស្ថិតនៅជាមួយអ្នករាល់គ្នាដែរ" (មថ១៨, ២០)។ ពីព្រោះ ក្នុងថ្វាយអភិបូជា គឺជាការថ្វាយយញ្ញបូជានៃឈើឆ្កាងដែលនៅឋិតថេរជានិច្ច[52] ព្រះគ្រីស្ត គឺពិតជាមានវត្តមានគង់នៅក្នុងអស់អ្នកដែលជួបជុំគ្នាក្នុងនាមព្រះអង្គ គង់នៅក្នុងសកម្មភាពនៃអ្នកបម្រើពិធីបុណ្យ និងនៅក្នុងព្រះបន្ទូលរបស់ព្រះអង្គ ព្រមទាំងខ្លឹមសារនៃសេចក្តីពិត និងនិមិត្តរូបនំនិងស្រាតង្វាយក្នុងពេលថ្វាយអភិបូជា។[53]

២៨. ពិធីអភិបូជាចែកជាពីរភាគធំៗគឺ៖ ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់ និងពិធីអរព្រះគុណដ៏វិសុទ្ធ ធម៌ទាំងពីរនេះមានការទាក់ទងគ្នាយ៉ាងជ្រាលជ្រៅ ហើយជាសកម្មភាពថ្វាយបង្គំព្រះជាម្ចាស់តែមួយ។[54] ពីព្រោះ នៅក្នុងពេលថ្វាយអភិបូជា គឺប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ពីតុព្រះបន្ទូល និងនៅតុនៃព្រះកាយព្រះលោហិតព្រះគ្រីស្ត ហើយគ្រីស្តបរិស័ទក៏ទទួលបានការណែនាំ និងធ្វើឲ្យគេមានកម្លាំងឡើងវិញដែលមកពីអាហារខាងវិញ្ញាណ។[55] ក្បួនពិធីទាំងនោះ ក៏មានការចាប់ផ្តើមពិធី និងពិធីបញ្ចប់ផងដែរ។

### II. គោលការណ៍សំខាន់ៗពីភាពខុសគ្នានៃពិធីអភិបូជា

#### អានអត្ថបទព្រះគម្ពីរ និងសេចក្តីអត្ថាធិប្បាយ

២៩. ពេលគេអានព្រះគម្ពីរក្នុងព្រះវិហារ ព្រះជាម្ចាស់មានព្រះបន្ទូលទៅប្រជារាស្ត្ររបស់ព្រះអង្គ និងវត្តមានរបស់ព្រះគ្រីស្តជាព្រះបន្ទូលព្រះអង្គ ដែលបានប្រកាសដំណឹងល្អរបស់ព្រះអង្គផ្ទាល់។

ហេតុដូច្នេះហើយ អង្គប្រជុំត្រូវស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយគោរព ពីព្រោះព្រះបន្ទូលនេះ ជាគោលការណ៍ដ៏សំខាន់បំផុតនៅក្នុងពិធីបុណ្យ។ ទោះបីយ៉ាងណា ក្នុងពេលអានព្រះគម្ពីរ គឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលព្រះបិតាមានព្រះបន្ទូលទៅប្រជារាស្ត្រ

---

[51] Cf. Second Vatican Ecumenical Council, Decree on the Ministry and Life of Priests, *Presbyterorum ordinis*, no. 5; Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 33.
[52] Cf. Ecumenical Council of Trent, Session 22, *Doctrina de ss. Missae sacrificio*, 17 September 1562, chapter 1: Denz-Schön, 1740; Paul VI, Solemn Profession of Faith, 30 June 1968, no. 24: AAS 60 (1968), p. 442.
[53] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 7; Paul VI, Encyclical Letter *Mysterium fidei*, On the doctrine and worship of the Eucharist, 3 September 1965: AAS 57 (1965), p. 764; Sacred Congregation of Rites, Instruction *Eucharisticum mysterium*, On the worship of the Eucharist, 25 May 1967, no. 9: AAS 59 (1967), p. 547.
[54] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 56; Sacred Congregation of Rites, Instruction Eucharisticum mysterium, On the worship of the Eucharist, 25 May 1967, no. 3: AAS 59 (1967), p. 542.
[55] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, nos. 48, 51; Second Vatican Ecumenical Council, Dogmatic Constitution on Divine Revelation, *Dei Verbum*, 18 November 1965, no. 21; Decree on the Ministry and Life of Priests, *Presbyterorum ordinis*, no. 4.

ទាំងអស់របស់ព្រះអង្គក្នុងគ្រប់សម័យកាល ហើយពួកគេអាចយល់ដឹងបានច្បាស់នូវសេចក្តីទាំងប៉ុន្មានដែលបានអត្ថាធិប្បាយ ព្រមទាំងទទួលបានផលផ្លែជាច្រើនពីព្រះបន្ទូលនោះ ដោយជួយជំរុញឲ្យព្រះបន្ទូលមានជីវិតរស់រវើក តាមការសន្ទនាអំពីអត្ថន័យព្រះគម្ពីរ (ធម្មទេសនា) ដែលជាផ្នែកមួយនៃសកម្មភាពពិធីបុណ្យ។[56]

## ពាក្យអធិដ្ឋាន និងផ្នែកផ្សេងទៀតដែលលោកបូជាចារ្យត្រូវប្រព្រឹត្ត

៣០. ក្នុងចំណោមកិច្ចការនៃអភិបូជាដែលលោកបូជាចារ្យត្រូវប្រព្រឹត្ត មានកន្លែងមួយដែលសំខាន់ជាង គឺធម៌អរព្រះគុណព្រះជាម្ចាស់ ដែលជាកំពូលនៃការប្រារព្ធអភិបូជា។ បន្ទាប់មកមានថ្លែងព្រះបន្ទូល ពាក្យអធិដ្ឋានសរុប ពាក្យថ្វាយតង្វាយ និងពាក្យអរព្រះគុណ។ ពាក្យអធិដ្ឋានទាំងនេះ លោកបូជាចារ្យធ្វើជាអធិបតីភាពក្នុងព្រះនាមព្រះគ្រីស្ត ទូលអង្វរថ្វាយទៅព្រះបិតាក្នុងនាមប្រជារាស្ត្រដ៏វិសុទ្ធ និងមនុស្សទាំងអស់សព្វថ្ងៃនេះ។[57] ហេតុនេះ គេហៅពាក្យអធិដ្ឋានទាំងនោះដោយត្រឹមត្រូវថា "ប្រធាននៃការអធិដ្ឋាន"។

៣១. ដូចគ្នានេះដែរ លោកបូជាចារ្យមានមុខងារណែនាំគ្រីស្តបរិស័ទ ជាបន្ទុករបស់លោកក្នុងការប្រមែប្រមូលអង្គប្រជុំ ដើម្បីផ្តល់ការពន្យល់នូវចំណុចមួយចំនួន ដែលបានព្យាករនៅក្នុងក្បួនពិធីផ្ទាល់។ ការប្រារព្ធពិធីនេះ លោកជាអធិបតីអាចកែសម្រួលចំណុចខ្លះ តាមពាក្យណែនាំពណ៌ក្រហមដើម្បីជួយអ្នកចូលរួមបានយល់ដឹងស្របគ្នានឹងរបៀបនោះ។ យ៉ាងណាក៏ដោយ លោកបូជាចារ្យត្រូវយកចិត្តទុកដាក់ ដើម្បីប្រមូលអារម្មណ៍ក្នុងការពន្យល់អត្ថបទ និងបង្ហាញពីអត្ថន័យដែលមានខ្លឹមសារនៅក្នុងអភិបូជា។ លោកបូជាចារ្យជាអធិបតីផងដែរ ត្រូវចាត់ចែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយលោកប្រទានពរចុងក្រោយនៃពិធីបញ្ចប់។ បន្ទាប់មកលោកលាតដៃពោលពាក្យយ៉ាងខ្លី ដល់អស់អ្នកជឿណែនាំ អំពីអត្ថន័យនៅថ្ងៃ អភិបូជា (គោរពស្វាគមន៍មុន រួចហើយពិធីសូមទទួលសារភាព) ចំពោះពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់ (ត្រូវអានអត្ថបទមុន) ហើយបន្តទៅពិធីអរព្រះគុណព្រះជាម្ចាស់ ក្នុងធ្វើពិធីបញ្ចប់លោកអាចបែរមុខទៅរកអង្គប្រជុំ ពន្យល់ពីសកម្មភាព នៃពិធីបុណ្យដែល ទើបបានប្រព្រឹត្ត មុនចាត់ឲ្យទៅ។

៣២. ដោយសារលោកជា "អធិបតី" ត្រូវអានខ្លឹមសារនោះ ដោយនិយាយបញ្ចេញសំឡេងខ្លាំងៗ និងច្បាស់លាស់ ហើយអង្គប្រជុំទាំងមូលប្រុងស្មារតីតាំងចិត្តស្តាប់។[58] ដូច្នេះ ខណៈពេលដែលលោកបូជាចារ្យកំពុងពោលពាក្យនោះ លោកមិនគួរពោលពាក្យអធិដ្ឋានផ្សេង ឬចម្រៀង ព្រមទាំងសំឡេងអកហ្គ ឬឧបករណ៍តន្ត្រីទេ គួរស្ងាត់ស្ងៀមបន្តិច។

[56] Cf. II Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, nos. 7, 33, 52
[57] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 33.
[58] Cf. Sacred Congregation of Rites, Instruction *Musicam sacram*, On music in the Liturgy, 5 March 1967 , no. 14: AAS 59 (1967), p. 304.

៣៣. លោកបូជាចារ្យជាអធិបតី ពោលពាក្យអធិដ្ឋានក្នុងនាមព្រះសហគមន៍ និងអង្គប្រជុំឲ្យទៅជាធ្លុងតែមួយ លោកក៏ត្រូវអធិដ្ឋានសម្រាប់ខ្លួនឯងផងដែរ ដោយទូលអង្វរព្រះអង្គប្រោសលោកឲ្យយកចិត្តទុកដាក់ប្រព្រឹត្តនូវមុខងារជាអ្នកបម្រើព្រះជាម្ចាស់ ដោយភក្តីភាព និងរស់នៅសមនឹងឋានៈជាគង្វាលដ៏ល្អ។ លោកឱនលំទោនពោលពាក្យអធិដ្ឋាន មុនប្រកាសព្រះបន្ទូលដំណឹងល្អ ក្នុងពិធីរៀបចំតង្វាយ ព្រមទាំងមុន និងក្រោយទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត គឺលោកបូជាចារ្យពោលខ្សឹបៗដោយស្ងៀមស្ងាត់។

**ក្បួនផ្សេងៗក្នុងការប្រារព្ធអភិបូជា**

៣៤. ព្រោះថាប្រារព្ធពិធីអភិបូជា មានលក្ខណៈ "រួបរួមគ្នាជាសហគមន៍"[59] ដូច្នេះ ការសន្ទនារវាងលោកបូជាចារ្យ និងគ្រីស្តបរិស័ទជួបជុំគ្នា ព្រមទាំងពោលពាក្យដែលមានសារៈសំខាន់អបអរសាទរ [60] នេះមិនមែនគ្រាន់តែសញ្ញាសម្គាល់ខាងក្រៅនៃការប្រារព្ធពិធីទេ តែជាការបង្ហាញញ៉ាំងឲ្យមានការប្តូរចិត្តគំនិតគ្នារទៅវិញទៅមករវាងលោកបូជាចារ្យ និងគ្រីស្តបរិស័ទ។

៣៥. ពាក្យអបអរសាទរ ពាក្យឆ្លើយតបនឹងគ្រីស្តបរិស័ទ និងពាក្យស្វាគមន៍របស់លោកបូជាចារ្យ ព្រមទាំងពាក្យអធិដ្ឋាន គឺជារបៀបដែលគ្រីស្តបរិស័ទចូលរួមយ៉ាងសកម្មក្នុងអភិបូជា ធ្វើដូច្នេះសកម្មភាពរបស់ព្រះសហគមន៍ទាំងមូល អាចមើលឃើញយ៉ាងច្បាស់ពីការរួមគ្នា និងលើកតម្កើង[61]។

៣៦. នៅផ្នែកផ្សេងទៀត គឺមានអត្ថប្រយោជន៍បំផុតសម្រាប់ការបញ្ចេញយោបល់ និងជួយជំរុញឲ្យអ្នកចូលរួមសកម្មយ៉ាងខ្ជាប់ខ្ជួន ហើយការប្រជុំទាំងមូលមានការចែករំលែកពីគ្នាទៅវិញទៅមក ជាពិសេសនៅក្នុងពិធីសូមទទួលសារភាព ពិធីប្រកាសជំនឿ ពាក្យអង្វរសកល និងពាក្យអធិដ្ឋានរបស់ព្រះអម្ចាស់ "ធម៌ ឱ ព្រះបិតា"។

៣៧. សេចក្តីចុងក្រោយ ក្នុងចំណោមក្បួនផ្សេងទៀតមានដូចខាងក្រោម៖

ក. មានក្បួនខ្លះដែលជាផ្នែកមួយនៃពិធី ដូចជា៖ "ធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់" ស្មូតទំនុកតម្កើង "អាលេលូយ៉ា" ពាក្យអបអរសាទរមុនប្រកាសព្រះបន្ទូលដំណឹងល្អ ពាក្យបន្ទរ "ព្រះដ៏វិសុទ្ធ" បទចម្រៀងក្រោយពិធីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។

ខ. ម្យ៉ាងទៀត ក្បួនផ្សេងដែលជួយក្នុងពិធីខ្លះៗ ដូចជា បទចម្រៀងពេលចូល ពេលថ្វាយតង្វាយ នៅពេលពិធីកាច់នំព្រះកាយ ពាក្យបន្ទរ "ឱ កូនចៀមរបស់ព្រះជាម្ចាស់..." និងពិធីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។

**របៀបនៃការប្រកាសអត្ថបទផ្សេងៗ**

៣៨. ក្នុងពេលប្រកាសអត្ថបទព្រះគម្ពីរត្រូវមានសំឡេងខ្លាំង និងច្បាស់ ទោះជាលោកបូជាចារ្យលោកឧបដ្ឋាក ឬអ្នកប្រកាសព្រះបន្ទូល ឬអ្នកឯទៀត គួរតែបញ្ចេញសំឡេងឲ្យស៊ីគ្នាទៅនឹង

---

[59] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, nos. 26-27; Sacred Congregation of Rites, Instruction Eucharisticum mysterium, On the worship of the Eucharist, 25 May 1967, no. 3d: AAS 59 (1967), p. 542.
[60] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 30.
[61] Cf. Sacred Congregation of Rites, Instruction *Musicam sacram*, On music in the Liturgy, 5 March 1967, no. 16a: AAS 59 (1967), p. 305.

អត្ថបទព្រះគម្ពីរដែលអង្គប្រជុំឆ្លើយ គឺជាការអធិដ្ឋាន សេចក្តីពន្យល់ ពាក្យអបអរសាទរ ស្មូត ទំនុកតម្កើង ឬបទចម្រៀង ទាំងនោះអាស្រ័យទៅលើការប្រតិបត្តិរបស់អ្នកប្រកាសព្រះបន្ទូល។ គួរច្រៀងបន្តគ្នាស្របទៅតាមការប្រារព្ធពិធី និងពិធីបុណ្យយ៉ាងឱឡារិកសម្រាប់ការប្រជុំនេះ។ ត្រូវយកចិត្តទុកដាក់អំពីភាសា និងវប្បធម៌របស់ប្រជាជន ដែលមានចរិតលក្ខណៈខុសគ្នានៅតំបន់នោះ។

ហេតុនេះហើយ បានជានៅក្នុងពាក្យណែនាំពណ៌ក្រហម និងនៅក្នុងក្បួនច្បាប់ខាងក្រោមនេះ មានពាក្យដូចជា "និយាយ" និង "ប្រកាស" គឺត្រូវឲ្យគេយល់ទាំងការច្រៀង ឬការសូត្រត្រូវទាក់ទងជាមួយនឹងគោលការណ៍ដែលបានថែងពន្យល់នៅខាងលើ។

## សារៈសំខាន់នៃការច្រៀង

៣៩. ជំនឿគ្រីស្តបរិស័ទដែលរួបរួមគ្នាបានរង់ចាំព្រះអម្ចាស់យាងមក គឺជាគ្រីស្តទូតប៉ូលដែលបានបង្រៀនគេឲ្យច្រៀងអរព្រះគុណព្រះជាម្ចាស់ក្នុងចិត្តរួមជាមួយគ្នា ដោយប្រើទំនុកតម្កើង បទកោតសរសើរ និងបទចម្រៀងមកពីព្រះវិញ្ញាណ (កូឡូស៣. ១៦)។ ចម្រៀងជាសញ្ញានៃអំណរសប្បាយរីករាយអស់ពីបេះដូង និងដោយចិត្តស្មោះ (កឋ.៤៦)។ ហេតុដូច្នេះហើយបានជាសន្តអូគូស្តាំងថ្លែងដោយផ្ទាល់ថា ការច្រៀង គឺជាសកម្មភាពរបស់មនុស្សដែលមានសេចក្តីស្រឡាញ់[62] ហើយមានសុភាសិតបុរាណមួយពោលថា "អ្នកណាច្រៀងបានល្អ ពីរោះ ស្មើនឹងអធិដ្ឋានពីរដង"។

៤០. ដូច្នេះ សំខាន់បំផុតត្រូវយកចិត្តទុកដាក់ ជាប់ចិត្តនឹងការច្រៀងបម្រើក្នុងពេលប្រារព្ធពិធីអភិបូជា ដោយគិតពិចារណាពីវប្បធម៌របស់ប្រជាជន និងសមត្ថភាពនៃការជួបជុំគ្នាសម្រាប់ពិធីបុណ្យនីមួយៗនៅតំបន់នោះ។ បើជាការចាំបាច់ដែលជៀសមិនរួចគ្រប់ពេល (ឧទាហរណ៍ អភិបូជាប្រចាំសប្តាហ៍) គ្រប់អត្ថបទត្រូវប្រកាសតាមគោលការណ៍ ដើម្បីច្រៀងនៅថ្ងៃអាទិត្យ គួរតែមានការយកចិត្តទុកដាក់គ្រប់បទចម្រៀងដោយអ្នកបម្រើពិធីបុណ្យ ហើយអង្គប្រជុំមិនត្រូវអវត្តមាននៅពេលថ្វាយអភិបូជាឡើយ ត្រូវតែមានមុខជានិច្ចនៅថ្ងៃអាទិត្យ និងថ្ងៃបុណ្យខានមិនបាន។

ទោះបីយ៉ាងណាក៏ដោយ ក្នុងការជ្រើសរើសផ្នែកខ្លះនៃបទចម្រៀង ត្រូវគិតដល់ចំណង់ចំណូលចិត្ត និងសេចក្តីស្រឡាញ់ ដើម្បីផ្តល់ឲ្យអ្នកដែលសំខាន់ជាងគេ និងជាពិសេស អ្នកដែលត្រូវច្រៀងនេះឯង គឺលោកបូជាចារ្យ លោកឧបដ្ឋាក ឬអ្នកប្រកាសព្រះបន្ទូល ព្រមទាំងមានអង្គប្រជុំឆ្លើយ ឬលោកបូជាចារ្យ និងគ្រីស្តបរិស័ទច្រៀងជាមួយគ្នា។[63]

៤១. ចម្រៀង និងបទភ្លេង គួរតែធ្វើតាមរបៀបលោកគ្រេហ្គ័រ ដែលមានកន្លែងកិត្តិយសជារបៀបពិធីបុណ្យរ៉ូម៉ាំង។ ប្រភេទតន្ត្រីដ៏សក្ការៈផ្សេងទៀត នៅក្នុងបទភ្លេងដែលមានទំនុកលាយ

[62] Saint Augustine of Hippo, *Sermo* 336, 1: *Patrologiae cursus completus: Series latina*, J. P. Migne, editor, Paris, 1844-1855, 38, 1472.
[63] Cf. Sacred Congregation of Rites, Instruction *Musicam sacram*, On music in the Liturgy, 5 March 1967, nos. 7, 16: AAS 59 (1967), pp. 302, 305.

ច្រើន ជាពិសេស គឺមិនអាចចោលភ្លេងរបៀបនោះបានឡើយ ព្រោះធ្វើឲ្យយើងមានស្មារតីសកម្មចំពោះពិធីបុណ្យ និងជួយជំរុញគ្រីស្តបរិស័ទឲ្យចូលរួមទាំងអស់គ្នាដោយចិត្តស្មោះ។[64]

ព្រោះថា សព្វថ្ងៃនេះអស់អ្នកជឿមានឱកាសជាច្រើនដើម្បីទៅប្រទេសផ្សេងៗ ដូច្នេះគួរអប់រំគេឲ្យចេះពីរបៀបច្រៀងជាមួយគ្នា យ៉ាងហោចណាស់បទខ្លះតាមរបៀបសាមញ្ញក្នុងការរៀបចំសម្រាប់ពិធីអភិបូជាក្នុងភាសាឡាតាំង ជាពិសេស ធម៌ប្រកាសជំនឿ និងពាក្យអធិដ្ឋានរបស់ព្រះអម្ចាស់ "ធម៌ ឱ ព្រះបិតា"។[65]

## អាកប្បកិរិយា និងឥរិយាបថ

៤២. កាយវិការ និងឥរិយាបថរបស់លោកបូជាចារ្យ លោកឧបដ្ឋាក អ្នកបម្រើពិធីបុណ្យ ព្រមទាំង គ្រីស្តបរិស័ទជួយឲ្យពិធីទាំងមូល មានសោភណភាព សាមញ្ញសមរម្យ ដែលបង្ហាញច្បាស់ពីអត្ថន័យពិធីបុណ្យផ្សេងៗ និងជួយគ្រីស្តបរិស័ទឲ្យចូលរួមយ៉ាងសកម្ម។[66] ដូច្នេះ ត្រូវយកចិត្តទុកដាក់អំពីសេចក្តីណែនាំ ហើយប្រព្រឹត្តតាមក្បួនពិធីនៃប្រពៃណីរ៉ូម៉ាំង និងស្វែងយល់ពីអ្វីដែលជួយឲ្យជីវិតខាងវិញ្ញាណមានប្រយោជន៍ដល់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ជាជាងការទោរទន់លម្អៀងទៅរកតែអ្វីដែលខ្លួនឯងពេញចិត្ត ឬជ្រើសរើសដោយបំពាន។

អាកប្បកិរិយាដ៏សាមញ្ញ ជាផ្នែកមួយដែលត្រូវប្រតិបត្តិ គឺជាសញ្ញានៃការរួបរួមគ្នា ជាសមាជិករួមជំនឿតែមួយក្នុងព្រះសហគមន៍ ដើម្បីប្រមែប្រមូលគ្រីស្តបរិស័ទឲ្យចូលរួមក្នុងពិធីបុណ្យដ៏សក្ការៈនេះ ពេលគ្រីស្តបរិស័ទមានឥរិយាបថរួមគ្នាតែមួយ និងបង្ហាញនូវបំណងប្រាថ្នារបស់គេអស់ពីដួងចិត្ត នឹងជួយខាងផ្លូវចិត្តអស់អ្នកដែលចូលរួមថ្វាយអភិបូជាផងដែរ។

៤៣. ពេលច្រៀងបទចូល អង្គប្រជុំក្រោកឈរ ឬពេលលោកបូជាចារ្យហែទៅដល់តុសក្ការបូជា រហូតចប់ពាក្យអធិដ្ឋានសរុប។ អង្គប្រជុំក្រោកឈរពេលច្រៀង "អាលេលូយ៉ា" មុនប្រកាសព្រះបន្ទូលដំណឹងល្អ។ អង្គប្រជុំក្រោកឈរពេលសូត្រធម៌កាសជំនឿ និងពាក្យអធិដ្ឋានអង្វរសកល។ ពាក្យអញ្ជើញ "សូមបងប្អូនតាំងចិត្តអធិដ្ឋាន" (Orate, fratres) មុនពាក្យថ្វាយតង្វាយ រហូតដល់ពិធីបញ្ចប់អភិបូជា លើកលែងតែ៖

អង្គប្រជុំគួរតែអង្គុយស្តាប់អត្ថបទព្រះគម្ពីរ មុននឹងសូត្រទំនុកតម្កើងឆ្លើយឆ្លងគ្នា បន្ទាប់មក ស្តាប់ព្រះបន្ទូលដំណឹងល្អ និងស្តាប់ធម្មទេសនា នៅក្នុងពិធីរៀបចំតង្វាយ ហើយតាមកាលៈទេសៈរៀបចំខ្លួនរក្សាភាពស្ងៀមស្ងាត់ក្នុងពេលអង្គុយ ឬលុតជង្គង់ ក្រោយពីទទួល ព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។

អង្គប្រជុំទាំងមូលអង្គុយបត់ជើងលើកន្ទេល ឬលុតជង្គង់ បន្ទាប់ពីប្រសិទ្ធពរលើនំ និងស្រាតង្វាយ លើកលែងតែមានបញ្ហាសុខភាពរារាំង ឬមូលហេតុមកពីកន្លែងចង្អៀតដោយ

---

[64] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 116; cf. also Sacred Congregation of Rites, Instruction *Musicam sacram*, On music in the Liturgy, 5 March 1967, no. 30.

[65] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 54; Sacred Congregation of Rites, Instruction *Inter Oecumenici,* on the orderly carrying out of the Constitution on the Sacred Liturgy, 26 September 1964, no. 59: AAS 56 (1964), p. 891; Sacred Congregation of Rites, Instruction *Musicam sacram*, On music in the Liturgy, 5 March 1967, no. 47: AAS 59 (1967), p. 314.

[66] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, nos. 30, 34; cf. also Sacred Congregation of Rites, Instruction *Musicam sacram*, On music in the Liturgy, 5 March 1967, no. 21.

សារមានចំនួនមនុស្សច្រើន ឬមានហេតុផលផ្សេងទៀត។ ទោះបីយ៉ាងណាក៏ដោយ ចំពោះអ្នកដែលមិនលុតជង្គង់អាចឱនកាយគោរព ពេលលោកបូជាចារ្យបន្ទន់ជង្គង់ប្រសិទ្ធព្រះកាយ និងព្រះលោហិត។

សម្រាប់ក្រុមសន្និសិទរបស់លោកអភិបាល បានអនុញ្ញាតតាមក្នុងក្បួនច្បាប់ដើម្បីសម្របខ្លួនទៅតាមកាយវិការ និងឥរិយាបថដែលរៀបរាប់នៅក្នុងពិធីអភិបូជា ឲ្យសមនឹងវប្បធម៌ និងប្រពៃណីរបស់ប្រជាជននៅតំបន់នោះ។[67] យ៉ាងណាក៏ដោយ ត្រូវយកចិត្តទុកដាក់អះអាងថា ការយកលំនាំតាមឲ្យដូចគ្នាទៅនឹងអត្ថន័យ ហើយលក្ខណៈតួអក្សរនៃផ្នែកនីមួយៗត្រូវគ្នាក្នុងពិធីថ្វាយអភិបូជា។ អង្គប្រជុំត្រូវទម្លាប់លុតជង្គង់ ពេលដល់គ្រង់កន្លែងគេច្រៀង "ព្រះដ៏វិសុទ្ធ" រហូតចប់ពិធីអរព្រះគុណដ៏វិសុទ្ធ និងមុនទទួលព្រះកាយព្រះគ្រីស្ត នៅពេលលោកបូជាចារ្យពោលថា "នេះជាកូនចៀមរបស់ព្រះជាម្ចាស់" (Ecce Agnus Dei) កាយវិការនេះ គួរឲ្យកោតសរសើរ និងរក្សាទុកប្រតិបត្តិតាមដើម្បីចងចាំរហូត។

ពីព្រោះ លក្ខណៈនៃឥរិយាបថ និងកាយវិការមួយសមរម្យនៅក្នុងពេលប្រារព្ធពិធី ហើយដូចគ្នានេះដែរ អស់អ្នកជឿគួរតែប្រព្រឹត្តតាមសេចក្តីណែនាំនៃក្បួនពិធី ដែលលោកបូជាចារ្យ លោកឧបដ្ឋាក ឬអ្នកបម្រើពិធីបុណ្យផ្តល់ឲ្យ ទៅតាមអ្វីដែលបានចុះនៅក្នុងក្បួនពិធីអភិបូជា។

៤៤. អាកប្បកិរិយាក៏បង្ហាញពីសកម្មភាពនៅក្នុងចំណោមក្បួនហែដែរ តាមរយៈលោកបូជាចារ្យ លោកឧបដ្ឋាក និងអ្នកបម្រើពិធីបុណ្យ ដែលដើរឆ្ពោះទៅតុសក្ការបូជា លោកឧបដ្ឋាកហែសៀវភៅព្រះគម្ពីរដំណឹងល្អទៅតុព្រះបន្ទូល មុនប្រកាសព្រះបន្ទូលដំណឹងល្អ រីឯគ្រីស្តបរិស័ទហែតង្វាយ ហើយបន្តពិធីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។ ពិតជាការគួរណាស់ដែលគ្រីស្តបរិស័ទគោរពតាមកិច្ចការ និងការដើរដង្ហែបែបនេះ ព្រមទាំងមានបទចម្រៀងប្រចាំពិធីនោះ ដូចដែលបានចុះនៅក្នុងក្បួនពិធីនីមួយៗ។

## ភាពស្ងៀមស្ងាត់

៤៥. ភាពស្ងៀមស្ងាត់ក៏ជាប់ទាក់ទងនឹងព្រះជាម្ចាស់ ជាផ្នែកមួយនៃពិធីបុណ្យដែលត្រូវប្រតិបត្តិតាមគ្រប់ពេល។[68] ភាពស្ងៀមស្ងាត់ អាស្រ័យទៅលើពិធីនីមួយៗដែលមានកើតឡើងផ្សេង។ ពិធីសូមទទួលសារភាព និងបន្ទាប់ពីលោកបូជាចារ្យអញ្ជើញគ្រីស្តបរិស័ទឲ្យតាំងចិត្តអធិដ្ឋាន បន្ទាប់មកស្តាប់ព្រះបន្ទូល ឬធម្មទេសនា អង្គប្រជុំត្រូវសញ្ជឹង គិតអំពីអ្វីដែលគេបានស្តាប់។ ក្រោយពីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត អង្គប្រជុំកោតសរសើរ និងអធិដ្ឋានអស់ពីដួងចិត្ត។ មុន និងក្រោយពិធី ត្រូវតែរក្សាស្ងៀមស្ងាត់នៅក្នុងព្រះវិហារ នៅបន្ទប់លោកផ្លាស់

[67] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 40; Congregation for Divine Worship and the Discipline of the Sacraments, Instruction *Varietates legitimae*, 25 January 1994, no. 41: AAS 87 (1995), p. 304.

[68] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 30; Sacred Congregation of Rites, Instruction *Musicam sacram*, On music in the Liturgy, 5 March 1967, no. 17: AAS 59 (1967), p. 305.

ប្តូរសម្លៀកបំពាក់ និងកន្លែងជិតៗ ដើម្បីជួយឲ្យម្នាក់ៗត្រៀមខ្លួនចូលរួមក្នុងពិធីនោះដោយសេចក្តីស្រឡាញ់។

## III. ផ្នែកនីមួយៗនៃពិធីអភិបូជា

### ក. ពិធីប្រារព្ធ

៤៦. ពិធីប្រារព្ធ គឺមុនពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់ ពេលចូលទទួលស្វាគមន៍ ពិធីសូមទទួលសារភាព ចម្រៀង ឬពាក្យទូលអង្វរព្រះយេស៊ូគ្រីស្តជាអម្ចាស់ ឱ ព្រះអម្ចាស់អើយ! សូមអាណិតអាសូរ ធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ពាក្យអធិដ្ឋានសរុប។ ពិធីនេះមានលក្ខណៈផ្នែកដើមបុព្វកថា និងការត្រៀមខ្លួន។ គោលដៅគឺ ជួយឲ្យគ្រីស្តបរិស័ទរួបរួមគ្នាជាធ្លុងតែមួយ និងត្រៀមខ្លួនស្ដាប់ព្រះបន្ទូលព្រះជាម្ចាស់ និងថ្វាយអភិបូជាដោយសមរម្យ។ តាមក្បួនសៀវភៅពិធីបុណ្យ មានពិធីខ្លះដែលលាយឡំនឹងពិធីអភិបូជា ដូច្នេះ ជួនកាលត្រូវចោលពិធីប្រារព្ធ ឬប្រព្រឹត្តពិធីនោះតាមរបៀបពិសេស។

### ក្បួនដង្ហែចូលព្រះវិហារ

៤៧. ក្រោយពីគ្រីស្តបរិស័ទរួបរួមគ្នា គេចាប់ផ្ដើមបទចម្រៀងពេលចូល ពេលលោកបូជាចារ្យហែចូលវិហារជាមួយលោកឧបដ្ឋាក និងអ្នកបម្រើពិធីបុណ្យ។ គោលដៅនៃបទចម្រៀង គឺបង្កើតពិធីជួយឲ្យបងប្អូនរួបរួមគ្នា និងប្រមូលអារម្មណ៍ក្នុងគម្រោងការដ៏អស្ចារ្យនៃពិធីបុណ្យ ឬពិធីតាមរដូវ ដោយមានអ្នកបម្រើពិធីបុណ្យហែរួមជាមួយលោកបូជាចារ្យ។

៤៨. ចម្រៀងពេលចូល ក្រុមចម្រៀង និងគ្រីស្តបរិស័ទ ឬប្រធានអ្នកចម្រៀង ឬតែគ្រីស្តបរិស័ទ ឬតែក្រុមអ្នកចម្រៀង។ ក្នុងចំណោមបទចម្រៀងទាំងនោះ អាចជ្រើសរើស៖ ពាក្យបន្ទរពីក្បួនពិធី ឬទំនុកតម្កើងពី (Gradual Romanum) ឬបទមួយពីសៀវភៅបទចម្រៀងដែលមានអត្ថន័យ និងទទួលការអនុញ្ញាតពីលោកអភិបាលប្រចាំតំបន់ ឬលោកអភិបាលភូមិភាគ។[69] ប្រសិនបើគ្មានបទចម្រៀងពេលចូលទេ អង្គប្រជុំ ឬអ្នកប្រកាសព្រះបន្ទូល ឬលោកបូជាចារ្យសូត្រពាក្យបន្ទរពីក្បួនពិធីនោះ (សូមមើលលេខ ៣១)។

### គោរពគុសក្ការបូជា និងជម្រាបសួរស្វាគមន៍អង្គប្រជុំចូលរួម

៤៩. ពេលលោកបូជាចារ្យ លោកឧបដ្ឋាក និងអ្នកបម្រើពិធីបុណ្យហែដល់កន្លែងទីសក្ការបូជា លោកគោរពគុសក្ការបូជាដោយឱនកាយ។ លោកបូជាចារ្យ និងលោកឧបដ្ឋាកថើបគុសក្ការបូជាជាសញ្ញាបង្ហាញពីការគោរព។ តាមកាលៈទេសៈ លោកបូជាចារ្យអាចប្រើកំញាន ឬធូប ដើម្បីគោរពព្រះឈើឆ្កាង និងគុសក្ការបូជា។

៥០. ចម្រៀងពេលចូលចប់ លោកបូជាចារ្យឈរនៅកន្លែងកៅអីរបស់លោក ហើយរួមជាមួយអង្គប្រជុំគូសសញ្ញាព្រះឈើឆ្កាង។ ក្រោយមក តាមរយៈការស្វាគមន៍ លោកបង្ហាញវត្តមានរបស់ព្រះជាម្ចាស់គង់នៅជាមួយគ្រីស្តបរិស័ទដែលរួបរួមគ្នាក្នុងព្រះសហគមន៍។ ពាក្យស្វាគមន៍ និងអង្គប្រជុំឆ្លើយ គឺបង្ហាញពីគម្រោងការដ៏អស្ចារ្យនៃការរួបរួមគ្នារបស់គ្រីស្តបរិស័ទ។

ក្រោយពីស្វាគមន៍អង្គប្រជុំ លោកបូជាចារ្យ លោកឧបដ្ឋាក ឬអ្នកបម្រើពិធីបុណ្យពន្យល់គ្រីស្តបរិស័ទអំពីអត្ថន័យអភិបូជាប្រចាំថ្ងៃ។

[69] Cf. John Paul II, Apostolic Letter *Dies Domini*, 31 May 1998 , no. 50: AAS 90 (1998), p. 745.

### ពិធីសូមទទួលសារភាព

៥១. បន្ទាប់មក លោកបូជាចារ្យអញ្ជើញអង្គប្រជុំចូលរួមពិធីសូមទទួលសារភាព ដោយស្ងៀមស្ងាត់បន្តិច អង្គប្រជុំប្រព្រឹត្តពិធីនោះតាមរូបមន្តដែលមានស្រាប់។ ទីបញ្ចប់នៃពិធីនេះ គឺពាក្យលើកលែងទោសរបស់លោកបូជាចារ្យ ដែលគ្មានប្រសិទ្ធិភាពដូចអគ្គសញ្ញាលើកលែងទោស។ នៅថ្ងៃអាទិត្យ ជាពិសេសរដូវបុណ្យចម្លង លោកបូជាចារ្យអាចធ្វើពិធីលើកលែងទោសដោយបាចទឹកព្រះពរ ដើម្បីនឹករឭកដល់អគ្គសញ្ញាជ្រមុជទឹក។[70]

### ពាក្យអង្វរព្រះយេស៊ូជាអម្ចាស់៖ ឱ ព្រះអម្ចាស់អើយ ! សូមអាណិតអាសូរ

៥២. ក្រោយពិធីសូមទទួលសារភាព ច្រៀង "ឱ ព្រះអម្ចាស់អើយ! សូមអាណិតអាសូរ"។ លើកលែងតែបានបញ្ចូលចម្រៀងនោះក្នុងពិធីផ្ទាល់។ ជាបទចម្រៀងមួយដើម្បីអង្វរព្រះជាម្ចាស់ សូមអាណិតអាសូរ ដូច្នេះអង្គប្រជុំរួមគ្នាច្រៀង គឺគ្រីស្តបរិស័ទ និងក្រុមអ្នកចម្រៀង។ តាមច្បាប់ត្រូវច្រៀងឃ្លានីមួយៗពីរដង។ យ៉ាងណាក៏អាចច្រៀងឃ្លានីមួយៗច្រើនជាងពីរដងទៀត ដោយលក្ខណៈភាសា ភ្លេង ឬតាមកាលៈទេសៈ។ ចូលពិធីសូមទទួលសារភាព ត្រូវសូត្រឃ្លាមួយមុនច្រៀងបន្ទរ ពេលច្រៀង "ឱ ព្រះអម្ចាស់អើយ! សូមអាណិតអាសូរ" ។

### ធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់

៥៣. ធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ជាធម៌សម័យបុរាណបំផុត និងជាធម៌ដ៏សក្ការៈដែលព្រះសហគមន៍ច្រៀងថ្វាយព្រះជាម្ចាស់ រួបរួមគ្នាក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ លើកតម្កើងសិរីរុងរឿង និងទូលអង្វរព្រះជាម្ចាស់ ជាព្រះបិតា និងព្រះបុត្រាជាកូនចៀមដ៏វិសុទ្ធ។ មិនអាចជ្រើសរើសបទផ្សេងមកជំនួសធម៌នេះបានទេ។ លោកបូជាចារ្យច្រៀងបទនេះ ឬអ្នកចម្រៀងច្រៀងម្នាក់ឯង ឬច្រៀងជាក្រុម ឬអង្គប្រជុំច្រៀងរួមជាមួយក្រុមចម្រៀង។ ប្រសិនបើមិនអាចច្រៀងបានទេ គួរសូត្រទាំងអស់គ្នា ឬសូត្រចែកជាពីរក្រុមដោយឆ្លងឆ្លើយគ្នា។ ត្រូវប្រកាសធម៌នេះ នៅថ្ងៃអាទិត្យក្រៅពីរដូវរង់ចាំ និងរដូវសែសិបថ្ងៃ និងពិធីយ៉ាងឱឡារិកផងដែរ។

### ពាក្យអធិដ្ឋានសរុប

៥៤. លោកបូជាចារ្យអញ្ជើញអង្គប្រជុំឲ្យតាំងចិត្តអធិដ្ឋាន។ អង្គប្រជុំរក្សាភាពស្ងៀមស្ងាត់បន្តិចដើម្បីយកចិត្តទុកដាក់អំពីវត្តមានរបស់ព្រះជាម្ចាស់ និងទូលអង្វរព្រះអង្គរៀងៗខ្លួន។ លោកបូជាចារ្យពោលពាក្យអធិដ្ឋានសរុបដែលបញ្ជាក់អំពីពិធីប្រចាំថ្ងៃដែរ។ តាមប្រពៃណីបុរាណនៃព្រះសហគមន៍ ពាក្យអធិដ្ឋានពេលចូល ជាពាក្យអង្វរព្រះបិតា តាមរយៈព្រះគ្រីស្តក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ[71] ហើយបញ្ចប់ពាក្យអធិដ្ឋាននេះ ដោយមានរូបមន្តអង្វរព្រះត្រៃឯកដូចតទៅ៖

- ប្រសិនបើពាក្យអធិដ្ឋានទៅកាន់ព្រះបិតា៖ "ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់ ជាព្រះបុត្រាដែលសោយរាជ្យរួមជាមួយព្រះអង្គ និងព្រះវិញ្ញាណដ៏វិសុទ្ធអស់កល្បជាអង្វែងតរៀងទៅ"។

[70] Cf. below, pp. 1249-1252.
[71] Cf. Tertullian, *Adversus Marcionem*, IV, 9: *Corpus Christianorum, Series latina*, Turnhout, Belgium, 1953- (hereafter, CCSL), 1, p. 560. PL 2, 376A; Origen, *Disputatio cum Heracleida*, no. 4, 24: *Sources chrétiennes*, H. deLubac et al., ed. (Paris, 1941-), p. 62; *Statuta Concilii Hipponensis Breviata*, 21: CCSL 149, p. 39.

- ប្រសិនបើពាក្យអធិដ្ឋានទៅកាន់ព្រះបិតា ហើយមានចែងអំពីព្រះគ្រីស្តនៅខាងចុង "ដែលសោយរាជ្យរួមជាមួយព្រះអង្គ និងព្រះវិញ្ញាណដ៏វិសុទ្ធអស់កល្បជាអង្វែងតរៀងទៅ"។
- ប្រសិនបើពាក្យអធិដ្ឋានទៅកាន់ព្រះបុត្រា៖ ដែលសោយរាជ្យរួមជាមួយព្រះបិតា និងព្រះវិញ្ញាណដ៏វិសុទ្ធអស់កល្បជាអង្វែងតរៀងទៅ។

អង្គប្រជុំចូលរួមក្នុងពាក្យអធិដ្ឋាននេះ ហើយយកពាក្យអធិដ្ឋានទាំងនោះ ជាពាក្យអធិដ្ឋានខ្លួនឯងដោយប្រកាសថា "អាម៉ែន"។

ពេលថ្វាយអភិបូជា មានពាក្យអធិដ្ឋានសរុបតែមួយគត់។

## ខ. ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់

៥៥. ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់ មានអានអត្ថបទព្រះគម្ពីរ និងស្មូតបទចម្រៀង រួមជាមួយ ហើយមានធម្មទេសនា ប្រកាសជំនឿ និងពាក្យអង្វរសកល។ ព្រះបិតាមានព្រះបន្ទូលទៅកាន់អង្គប្រជុំតាមរយៈអត្ថបទព្រះគម្ពីរ សេចក្ដីអធិប្បាយរបស់លោកបូជាចារ្យក្នុងធម្មទេសនា [72] និងជួយឲ្យគ្រីស្តបរិស័ទបើកចិត្តចំពោះគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះ ហើយប្រោសប្រទានអាហារខាងវិញ្ញាណឲ្យយើង។ ព្រះគ្រីស្តគង់នៅជាមួយបងប្អូនតាមរយៈព្រះបន្ទូលព្រះអង្គ។[73] អង្គប្រជុំទទួលព្រះបន្ទូលព្រះអង្គក្នុងដួងចិត្ត ដោយការច្រៀង និងដោយភាពស្ងៀមស្ងាត់ ហើយបញ្ជាក់សាជាថ្មីទៀតថា ជាប់នឹងព្រះបន្ទូលនោះដោយប្រកាសជំនឿ។ ក្រោយពីបានទទួលអាហារខាងវិញ្ញាណ អង្គប្រជុំអង្វរព្រះជាម្ចាស់សម្រាប់ព្រះសហគមន៍ និងការសង្គ្រោះពិភពលោកទាំងមូលតាមរយៈពាក្យអង្វរសកល។

### ភាពស្ងៀមស្ងាត់ជាសក្ការបូជា

៥៦. ត្រូវប្រព្រឹត្តពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់តាមរបៀបសញ្ជឹងគិត ដូច្នេះ គួរជៀសវាងឱកាសណាដែលគ្រីស្តបរិស័ទមិនសូវយកចិត្តទុកដាក់ សូមជួយឲ្យគេសញ្ជឹងគិត។ ក្នុងពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់គួរតែរក្សាភាពស្ងៀមស្ងាត់ ដើម្បីទទួលព្រះវិញ្ញាណដ៏វិសុទ្ធ អង្គប្រជុំទុកព្រះបន្ទូលព្រះជាម្ចាស់ក្នុងដួងចិត្ត ហើយត្រៀមខ្លួនដើម្បីអធិដ្ឋាន។ ភាពស្ងៀមស្ងាត់នោះ មុនពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់ ក្រោយអានអត្ថបទទីមួយ និងអត្ថបទទីពីរ និងក្រោយធម្មទេសនា។[74]

### អានអត្ថបទព្រះគម្ពីរ

៥៧. ក្នុងពេលអានអត្ថបទព្រះគម្ពីរ "ត្រូវបើកព្រះគម្ពីរចំហ ព្រោះជាកំណប់ដ៏ថ្លៃថ្នូរសម្រាប់គ្រីស្តបរិស័ទទទួលទុកជាអាហារពីតុព្រះបន្ទូលឲ្យបានច្រើនជាងពីមុន"។[75] ដូច្នេះ ជាការគួរណាស់ដែលត្រូវគោរពរបៀបការអានអត្ថបទព្រះគម្ពីរ ដែលជាពន្លឺបំភ្លឺប្រវត្តិសាស្ត្រពីការសង្គ្រោះនោះ ដោយឯកភាពរវាងសម្ពន្ធមេត្រីចាស់ និងសម្ពន្ធមេត្រីថ្មី។ ដូច្នេះហើយ បើសិនជាយកអត្ថបទផ្សេងជំនួសព្រះគម្ពីរដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះខុសច្បាប់ពិធីបុណ្យ។[76]

---

[72] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 33.
[73] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 7.
[74] Cf. The Roman Missal, *Lectionary for Mass, editio typica altera*, 1981, Introduction, no. 28.
[75] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 51.
[76] Cf. John Paul II, Apostolic Letter *Vicesimus quintus annus*, 4 December 1988 , no. 13: AAS 81 (1989), p. 910.

៥៨. ពេលថ្វាយអភិបូជា ត្រូវមានអង្គប្រជុំចូលរួម ហើយប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ពីតុព្រះបន្ទូល។

៥៩. តាមប្រពៃណីព្រះសហគមន៍ មុខងារប្រកាសព្រះបន្ទូលព្រះជាម្ចាស់ មានលក្ខណៈជាអ្នកបម្រើពិធីបុណ្យ មិនមែនជាមុខងាររបស់អ្នកជាអធិបតី។ ដូច្នេះ អ្នកបម្រើពិធីបុណ្យត្រូវអានអត្ថបទព្រះគម្ពីរ ហើយលោកឧបដ្ឋាក ឬលោកបូជាចារ្យខុសពីលោកដែលធ្វើជាអធិបតី ដែលប្រកាសព្រះបន្ទូលដំណឹងល្អ។ ប្រសិនបើគ្មានអ្នកបម្រើពិធីបុណ្យប្រកាសព្រះបន្ទូលលោកបូជាចារ្យដែលធ្វើជាអធិបតីត្រូវអានអត្ថបទទាំងអស់។ ក្រោយពីអត្ថបទនីមួយៗ អ្នកដែលបានអានថ្លែងពាក្យអបអរសាទរ ហើយគ្រីស្តបរិស័ទឆ្លើយដោយគោរពព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលគេបានទទួលដោយជំនឿ និងចិត្តប្រកបដោយអំណរគុណ។

៦០. ប្រកាសដំណឹងល្អគឺជាកំពូលនៃពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់។ ការប្រៀនប្រដៅនៃពិធីបុណ្យឲ្យយើងគោរពយ៉ាងជ្រាលជ្រៅ ដោយមានសញ្ញាសម្គាល់ខ្លះបញ្ជាក់កិត្តិយសនេះ ដូចជាអ្នកបម្រើពិធីបុណ្យប្រកាសដំណឹងល្អ ត្រៀមខ្លួនទទួលព្រះពរ ឬការអធិដ្ឋាន អង្គប្រជុំក្រោកឈរឡើងដើម្បីស្តាប់ពាក្យអបអរសាទព្រះគម្ពីរដំណឹងល្អ ទទួលស្គាល់ និងប្រកាសវត្តមានព្រះគ្រីស្តដែលមានព្រះនូលដល់គេ ឬគោរពហែសៀវភៅព្រះបន្ទូលដំណឹងល្អ។

## ស្នូតបន្ទរទំនុកតម្កើង

៦១. បន្ទាប់ពីអានអត្ថបទទីមួយ សូត្របទទំនុកតម្កើង។ សារៈសំខាន់ក្នុងពិធីបុណ្យ គឺអ្នកណែនាំជួយគ្រីស្តបរិស័ទឲ្យសញ្ជឹងគិតពីព្រះបន្ទូលព្រះជាម្ចាស់។

ការស្នូតទំនុកតម្កើងត្រូវទាក់ទងនឹងអត្ថបទនីមួយៗ ហើយត្រូវយកពីសៀវភៅអត្ថបទគម្ពីរដែលត្រូវប្រកាសក្នុងពិធីបុណ្យផ្សេងៗ។ បើអង្គប្រជុំស្នូតទំនុកតម្កើង ច្រៀងឆ្លើយឆ្លងគ្នា ពិតជាការល្អណាស់។ ដូច្នេះ អ្នកស្នូតទំនុកតម្កើង ឬច្រៀងម្នាក់ឯង គឺស្នូតទំនុកតម្កើងពីតុព្រះបន្ទូល ឬពីកន្លែងផ្សេង។ បព្វជិត បព្វជិតាទាំងអស់អង្គុយ ហើយស្តាប់ តាមធម្មតាត្រូវចូលរួមច្រៀងបន្ទរ លុះត្រាតែស្នូតទំនុកតម្កើងទាំងនោះគ្មានពាក្យឆ្លើយ។ ទោះជាយ៉ាងណា ត្រូវរៀបចំឲ្យអង្គប្រជុំអាចចូលរួមស្នូតទំនុកតម្កើងច្រៀងឆ្លើយឆ្លងបានងាយស្រួល អត្ថបទដែលឆ្លើយបន្ទរនឹងទំនុកតម្កើងត្រូវជ្រើសរើសទៅតាមរដូវបុណ្យប្រចាំឆ្នាំ ឬពិធីបុណ្យផ្សេងៗនៃបុណ្យគោរពសន្តបុគ្គល។ ទាំងនេះ អាចប្រើអត្ថបទអានជំនួសច្រៀងបន្ទរទំនុកតម្កើងក៏បាន។ ប្រសិនបើមិនមានស្នូតបន្ទរ គួរតែសូត្រតាមរបៀបដែលជួយឲ្យគ្រីស្តបរិស័ទសញ្ជឹងគិតពីព្រះបន្ទូលព្រះជាម្ចាស់។

ជំនួសឲ្យការស្នូតទំនុកតម្កើងដែលយកពីសៀវភៅអត្ថបទគម្ពីរក្នុងពិធីបុណ្យផ្សេងៗ អាចច្រៀងទំនុកតម្កើងឆ្លើយឆ្លងយ៉ាងរហឹមបែបប្រពៃណីរ៉ូម៉ាំង (Graduale Romanum) ឬអាលេលូយ៉ាដូចបានរៀបរាប់ក្នុងសៀវភៅទាំងនេះ។

### ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ

៦២. បន្ទាប់ពីអានអត្ថបទព្រះគម្ពីរមុនហើយភ្លាម ច្រៀង អាលេលូយ៉ា ឬសូត្រពាក្យអបអរសាទរផ្សេងទៀតតាមពាក្យណែនាំប្រចាំពិធីបុណ្យតាមរដូវ។ ពាក្យអបអរសាទរនេះ ជាពិធីមួយ ឬសកម្មភាពមួយដែរ ពីព្រោះនាំឲ្យអង្គប្រជុំចូលរួមអធិដ្ឋានតាមរយៈពាក្យអបអរសាទរនេះ និងទទួលស្វាគមន៍ព្រះអម្ចាស់ដែលមានព្រះបន្ទូលមកគេ ហើយប្រកាសជំនឿរបស់គេ។ អង្គប្រជុំក្រោកឈរឡើង និងច្រៀងរួមជាមួយក្រុមចម្រៀង ឬច្រៀងម្នាក់ឯង។

ក) ច្រៀង "អាលេលូយ៉ា" លើកលែងតែរដូវសែសិបថ្ងៃ។ យកពាក្យអបអរសាទរព្រះគម្ពីរដំណឹងល្អ ពីក្រាំង ឬសៀវភៅអត្ថបទគម្ពីរដែលត្រូវប្រកាសក្នុងពិធីផ្សេងៗ (Graduale) ។

ខ) ក្នុងរដូវសែសិបថ្ងៃជំនួសឲ្យ "អាលេលូយ៉ា" ច្រៀងមួយវគ្គមុនប្រកាសព្រះបន្ទូលដំណឹងល្អ អាចស្មូតទំនុកតម្កើងមួយដកស្រង់ពីសៀវភៅអត្ថបទគម្ពីរដែលត្រូវប្រកាសក្នុងពិធីផ្សេងៗ។

៦៣. មានតែអត្ថបទទីមួយដែលអានមុនព្រះបន្ទូលដំណឹងល្អ ៖

ក) ក្នុងរដូវបុណ្យច្រៀង "អាលេលូយ៉ា" អាចប្រើទំនុកតម្កើងអាលេលូយ៉ា ឬទំនុកតម្កើងឆ្លងឆ្លើយក្រោយមកច្រៀង "អាលេលូយ៉ា"។

ខ) រដូវបុណ្យមិនអាចច្រៀង "អាលេលូយ៉ា" អាចប្រើទំនុកតម្កើង និងពាក្យអបអរសាទរពីសៀវភៅអត្ថបទគម្ពីរក្នុងពិធីផ្សេងៗ ឬទំនុកតម្កើង មុនប្រកាសព្រះបន្ទូលដំណឹងល្អ។

គ) ប្រសិនបើមិនអាចច្រៀងបានទេ អាចចោល "អាលេលូយ៉ា" មុនប្រកាសព្រះបន្ទូលដំណឹងល្អ។

៦៤. ជាលំដាប់តម្រូវឲ្យច្រៀងតៗគ្នា លើកលែងតែថ្ងៃអាទិត្យបុណ្យចម្លង និងថ្ងៃបុណ្យលើកតម្កើងព្រះយេស៊ូចាត់ព្រះវិញ្ញាណយាងមក (ថ្ងៃបុណ្យទី៥០) អាចច្រៀង អាលេលូយ៉ា មុនតាមចិត្ត។

### ធម្មទេសនា

៦៥. ធម្មទេសនា គឺជាផ្នែកមួយនៃពិធីបុណ្យដែលគាំទ្រយ៉ាងខ្លាំង[77] ពីព្រោះ ជួយពង្រឹងជីវិតខាងផ្លូវវិញ្ញាណ។ ធម្មទេសនា ជាអធិប្បាយពន្យល់អត្ថបទព្រះគម្ពីរជាប្រចាំ ឬអត្ថបទប្រចាំពិធីបុណ្យនៅពេលអភិបូជា ហើយត្រូវយកចិត្តទុកដាក់ពីគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ និងសេចក្ដីត្រូវការរបស់គ្រីស្តបរិស័ទក្នុងព្រះសហគមន៍ដែរ។[78]

៦៦. ជាធម្មតា លោកបូជាចារ្យដែលជាអធិបតីនៃអភិបូជាត្រូវសម្ដែងធម្មទេសនា តែលោកអាចឲ្យម្នាក់ទៀត ជាលោកឧបដ្ឋាកដែលចូលរួមថ្វាយអភិបូជាសម្ដែងធម្មទេសនាបានដែរ ប៉ុន្តែមិនអាចឲ្យគ្រីស្តបរិស័ទធ្វើធម្មទេសនាជាដាច់ខាត។[79] ក្នុងករណីពិសេស លោកអាចអនុញ្ញាតសម្ដែងធម្មទេសនាឲ្យលោកអភិបាល ឬលោកបូជាចារ្យដែលអង្គុយជាមួយគ្រីស្តបរិស័ទចូលរួមថ្វាយអភិបូជា មិនអាចចូលរួមជាមួយដើម្បីប្រារព្ធពិធីឡើយ។

រៀងរាល់ថ្ងៃអាទិត្យ និងថ្ងៃបុណ្យខានមិនបាន រាល់អភិបូជាដែលមានគ្រីស្តបរិស័ទចូលរួមត្រូវតែមានធម្មទេសនា។ មិនអាចចោលធម្មទេសនាបានទេ លុះត្រាតែមានមូលហេតុធំដុំ។

---

[77] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 52; *Codex Iuris Canonici*, can. 767 § 1.
[78] Cf. Sacred Congregation of Rites, Instruction *Inter Oecumenici*, on the orderly carrying out of the Constitution on the Sacred Liturgy, 26 September 1964, no. 54: AAS 56 (1964), p. 890.
[79] Cf. *Codex Iuris Canonici*, can. 767 ' 1; Pontifical Commission for the Authentic Interpretation of the Code of Canon Law, response to *dubium* regarding can. 767 § 1: AAS 79 (1987), p. 1249; Interdicasterial Instruction on certain questions regarding the collaboration of the non-ordained faithful in the sacred ministry of priests, *Ecclesiae de mysterio*, 15 August 1997 , art. 3: AAS 89 (1997), p. 864.

គួរធ្វើធម្មទេសនារាល់ថ្ងៃសម្រាប់រដូវអបអរសាទរព្រះអម្ចាស់យាងមក រដូវសែសិបថ្ងៃ រដូវបុណ្យចម្លង និងពិធីបុណ្យផ្សេងៗ ដែលមានគ្រីស្តបរិស័ទជាច្រើនចូលរួមថ្វាយអភិបូជា។[80]

ក្រោយពីធម្មទេសនា គួរតាំងចិត្តអធិដ្ឋានដោយស្ងៀមស្ងាត់។

## ការប្រកាសជំនឿ

៦៧. គោលបំណងនៃធម៌ប្រកាសជំនឿ គឺនាំឲ្យគ្រីស្តបរិស័ទទាំងអស់ចូលរួមយ៉ាងសកម្មក្នុងគម្រោងការដ៏អស្ចារ្យនៃអភិបូជា ឆ្លើយតបនឹងអត្ថបទព្រះគម្ពីរ ដែលគេស្តាប់លោកបូជាចារ្យអធិប្បាយក្នុងធម្មទេសនា ដើម្បីឲ្យគេចងចាំ និងប្រកាសពីគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ និងបន្តជំនឿរបស់យើងតាមគំរូនៃក្បួនពិធីបុណ្យ។

៦៨. ធម៌ជឿត្រូវតែច្រៀង ឬសូត្រដោយលោកបូជាចារ្យ និងអង្គប្រជុំរាល់ថ្ងៃអាទិត្យ និងក្នុងពិធីបុណ្យយ៉ាងឱឡារិក។ គួរប្រកាសជំនឿរាល់ពេលថ្វាយអភិបូជាក្នុងពិធីឱឡារិកជាប្រចាំ។

បើសិនប្រកាសជំនឿដោយច្រៀង លោកបូជាចារ្យត្រូវចាប់ផ្ដើម ឬក្រុមចម្រៀង ឬច្រៀងម្នាក់ឯង ឬអង្គប្រជុំត្រូវច្រៀងឆ្លងឆ្លើយជាមួយនឹងក្រុមចម្រៀង។ បើមិនមានចម្រៀងទេ អង្គប្រជុំសូត្រធម៌ប្រកាសជំនឿ ដោយចែកជាពីរក្រុមបន្ទរឆ្លងឆ្លើយគ្នា។

## ពាក្យអង្វរសកល

៦៩. ពាក្យអង្វរសកល ជារបៀបមួយដើម្បីឲ្យគ្រីស្តបរិស័ទឆ្លើយតបនឹងព្រះបន្ទូលព្រះជាម្ចាស់ដែលទើបនឹងទទួល ហើយសូមអង្វរព្រះជាម្ចាស់សម្រាប់សង្គ្រោះមនុស្សលោក ស្របនឹងលក្ខណៈជាបូជាចារ្យដែលគេបានទទួលពីអគ្គសញ្ញាជ្រមុជទឹក។ ពាក្យអង្វរសកល ត្រូវមានរាល់ពេលថ្វាយអភិបូជាដោយមានគ្រីស្តបរិស័ទចូលរួម ដើម្បីទូលអង្វរព្រះជាម្ចាស់សម្រាប់ព្រះសហគមន៍ទាំងមូល សម្រាប់អាជ្ញាធរ និងបងប្អូនទាំងឡាយដែលរងទុក្ខលំបាក និងទូលអង្វរព្រះអង្គដើម្បីសង្គ្រោះដល់ពិភពលោកទាំងមូល។[81]

៧០. គោលបំណងពាក្យទូលអង្វរសកលមានរបៀបដូចខាងក្រោម ៖

ក)សម្រាប់សេចក្ដីត្រូវការរបស់ព្រះសហគមន៍

ខ)សម្រាប់អាជ្ញាធរ និងការសង្គ្រោះដល់ពិភពលោកទាំងមូល

គ)សម្រាប់បងប្អូនដែលរងទុក្ខលំបាក

ឃ)សម្រាប់សហគមន៍ប្រចាំតំបន់ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងពិធីបុណ្យពិសេសដូចជា៖ អគ្គសញ្ញាលាបថ្ងាស អគ្គសញ្ញាអាពាហ៍ពិពាហ៍ ឬពិធីបុណ្យបញ្ចុះសព គួរមានពាក្យអង្វរខ្លះដែលស្របតាមក្បួនពិធីនោះ។

៧១. លោកបូជាចារ្យដែលជាអធិបតីក្នុងអភិបូជា ផ្ដើមបង្ហាញពាក្យណែនាំយ៉ាងខ្លី ដោយអញ្ជើញគ្រីស្តបរិស័ទអធិដ្ឋានអង្វរសកល ហើយបញ្ចប់ពិធីនោះដោយពាក្យអធិដ្ឋានដែរ។ គួររៀបចំពាក្យអធិដ្ឋានមុនតាមក្រុម ទាំងសម្ដែងមនោសញ្ចេតនា និងការគោរព កុំប្រើពាក្យវែងពេក

[80] Cf. Sacred Congregation of Rites, Instruction *Inter Oecumenici*, on the orderly carrying out of the Constitution on the Sacred Liturgy, 26 September 1964, no. 53: AAS 56 (1964), p. 890.
[81] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 53.

ត្រូវអធិដ្ឋានសម្រាប់ព្រះសហគមន៍ទាំងមូល មិនមែនអធិដ្ឋានអង្វរសម្រាប់តែម្នាក់ប៉ុណ្ណោះទេ។ លោកឧបដ្ឋាក អ្នកបម្រើពិធីបុណ្យ ឬគ្រីស្តបរិស័ទម្នាក់ឡើងទៅតុព្រះបន្ទូលពោលពាក្យអង្វរសកល ឬកន្លែងមួយផ្សេងទៀត។[82] អង្គប្រជុំនៅឈរ ហើយឆ្លើយតបនូវពាក្យអង្វរនីមួយៗ ឬនៅស្ងៀមស្ងាត់បន្តិច។

### គ. ពិធីអរព្រះគុណដ៏វិសុទ្ធ

៧២. នៅពិធីជប់លៀងចុងក្រោយរបស់ព្រះយេស៊ូ ព្រះអង្គបានតែងតាំងពិធីអភិបូជាដែលជារបៀបលោកបូជាចារ្យជាតំណាងរបស់ព្រះយេស៊ូ នឹករឭកសាជាថ្មីក្នុងព្រះសហគមន៍ពីសក្ការបូជានៃព្រះឈើឆ្កាងដែលព្រះអង្គបានប្រព្រឹត្ត និងប្រទានឲ្យក្រុមសាវ័ក ដើម្បីនឹករឭកដល់ព្រះអង្គ។[83]

ពីព្រោះព្រះយេស៊ូយកនំព្រះកាយ និងពែងព្រះលោហិត អរព្រះគុណព្រះបិតា កាច់នំប៉័ងហើយប្រទានឲ្យក្រុមសាវ័កដោយមានព្រះបន្ទូលថា៖ "សូមអ្នករាល់គ្នាយកពិសាចុះ! នេះជារូបកាយរបស់ខ្ញុំ នេះជាលោហិតរបស់ខ្ញុំ! សូមធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ"។ ដូច្នេះហើយព្រះសហគមន៍បានរៀបចំពិធីអរព្រះគុណព្រះជាម្ចាស់ ដោយផ្នែកនីមួយៗត្រូវនឹងព្រះបន្ទូល និងសកម្មភាពរបស់ព្រះយេស៊ូ ៖

ក) ពេលរៀបចំនំ និងស្រាតង្វាយ គេយកមកតុសក្ការបូជា ហើយនំ និងស្រាតង្វាយជាមួយទឹក គឺជាធាតុដែលព្រះយេស៊ូបានប្រើដែរ។

ខ) ធម៌អរព្រះគុណដ៏វិសុទ្ធ គឺជាពាក្យអរព្រះគុណព្រះបិតាដែលបានសង្គ្រោះ ហើយនំ និងស្រាតង្វាយក្លាយទៅជាព្រះកាយ និងព្រះលោហិតរបស់ព្រះយេស៊ូគ្រីស្ត។

គ) ដោយកាច់នំតង្វាយ និងពិធីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ទោះបីមានអង្គប្រជុំច្រើនយ៉ាងណា ក៏ទទួលព្រះកាយព្រះគ្រីស្ត ពីនំព្រះកាយ និងពីពែងព្រះលោហិតតែមួយ ដូចក្រុមគ្រីស្តទូតពីដើមបានទទួលពីព្រះហស្តរបស់ព្រះគ្រីស្ត។

### ការរៀបចំនំ និងស្រាតង្វាយ

៧៣. ពេលចាប់ផ្ដើមពិធីអរព្រះគុណព្រះជាម្ចាស់ លោកយកនំ និងស្រាតង្វាយដែលដាក់លើតុសក្ការបូជា មកប្រសិទ្ធឲ្យទៅជាព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។

មុនដំបូង រៀបចំតុសក្ការបូជា ដែលជាតុរបស់ព្រះអម្ចាស់ក្នុងពិធីអរព្រះគុណព្រះជាម្ចាស់[84] រៀបចំដាក់កម្រាលពិសិដ្ឋ កន្សែងជូត ពែងពិសិដ្ឋ សៀវភៅក្បួនពិធីបុណ្យ និងពែងពិសិដ្ឋ លើតុសក្ការបូជា (លុះត្រាតែការរៀបចំតាមជំនឿសាសនា តុតូចសម្រាប់នំ និងស្រាតង្វាយ)។

ពិធីថ្វាយតង្វាយ គឺយកនំ និងស្រាតង្វាយឆ្ពោះទៅតុសក្ការបូជា។ ជាការប្រព្រឹត្តរបស់អ្នកជឿលើកតម្កើងព្រះជាម្ចាស់ ដោយយកនំ និងស្រាតង្វាយមកថ្វាយ។ លោកបូជាចារ្យ ឬ

[82] Cf. Sacred Congregation of Rites, Instruction *Inter Oecumenici*, on the orderly carrying out of the Constitution on the Sacred Liturgy, 26 September 1964, no. 56: AAS 56 (1964), p. 890.

[83] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 47; Sacred Congregation of Rites, Instruction Eucharisticum mysterium, On the worship of the Eucharist, 25 May 1967, no. 3a, b: AAS 59 (1967), pp. 540-541.

[84] Cf. Sacred Congregation of Rites, Instruction *Inter Oecumenici*, on the orderly carrying out of the Constitution on the Sacred Liturgy, 26 September 1964, no. 91: AAS 56 (1964), p. 898; Sacred Congregation of Rites, Instruction Eucharisticum mysterium, On the worship of the Eucharist, 25 May 1967, no. 24: AAS 59 (1967), p. 554.

លោកឧបដ្ឋាកទទួលនំ និងស្រាតង្វាយ យកមកដាក់លើតុសក្ការបូជា។ ទោះបីសព្វថ្ងៃគ្រីស្តបរិស័ទមិនយកនំ និងស្រាពីផ្ទះរបស់ខ្លួនក៏ពិធីថ្វាយអភិបូជានៅតែមានអត្ថន័យក្នុងជីវិតខាងវិញ្ញាណ។

បើគ្រីស្តបរិស័ទយកប្រាក់ដាក់ជាតង្វាយ ឬតង្វាយផ្សេងៗសម្រាប់អ្នកក្រីក្រ ជាការប្រសើរណាស់។ ត្រូវរៀបចំតង្វាយនៅកន្លែងមួយសមរម្យ តែមិនមែននៅលើតុសក្ការបូជាទេ។

៧៤. មានបទចម្រៀងថ្វាយតង្វាយ ក្នុងពេលហែនំ និងស្រាតង្វាយមកដល់តុសក្ការបូជា (សូមមើលលេខ ៣៧ ខ) ច្រៀងរហូតដល់លោករៀបចំនំ និងស្រាតង្វាយលើតុសក្ការបូជា។ ក្បួនច្បាប់ពីរបៀបនៃការច្រៀងដូចគ្នានឹងបទចម្រៀងពេលចូល (សូមមើលលេខ ៤៨)។ គួរតែច្រៀងអមដំណើរពិធីថ្វាយតង្វាយរហូត ទោះបីគ្មាន ពិធីហែនំ និងស្រាតង្វាយក៏ដោយ។

៧៥. នំ និងស្រាតង្វាយលើតុសក្ការបូជា លោកបូជាចារ្យសូត្រពាក្យអធិដ្ឋានដែលមានស្រាប់។ លោកអាចប្រើកំញានប្រសិទ្ធពរលើនំ និងស្រាតង្វាយ គោរពព្រះឈើឆ្កាង និងតុសក្ការបូជាដែលជាសញ្ញាបញ្ជាក់ថា តង្វាយ និងពាក្យអធិដ្ឋានរបស់ព្រះសហគមន៍ឆ្ពោះទៅកាន់ព្រះបិតាដូចផ្សែងកំញាន ឬធូបនោះដែរ។ ក្រោយមក លោកឧបដ្ឋាក ឬអ្នកបម្រើពិធីបុណ្យប្រើកំញានគោរពលោកបូជាចារ្យ និងអង្គប្រជុំ ជាករណីកិច្ចនៃអត្តសញ្ញាជ្រមុជទឹកដែលលោកបានទទួល។

៧៦. បន្ទាប់មក លោកបូជាចារ្យលាងដៃនៅក្បែរតុសក្ការបូជា។ ក្បួនពិធីនេះ ស្របតាមពាក្យអធិដ្ឋានរបស់លោកបូជាចារ្យ សូមព្រះជាម្ចាស់ជម្រះភាពខាងក្នុងរបស់លោក។

### ពាក្យថ្វាយតង្វាយ

៧៧. នំ និងស្រាតង្វាយនៅលើតុសក្ការបូជា រួមទាំងមានសៀវភៅក្បួនពិធីបុណ្យផ្សេងៗរួចជាស្រេច លោកបូជាចារ្យអញ្ជើញអង្គប្រជុំឲ្យចូលរួមអធិដ្ឋាន ហើយពោលពាក្យថ្វាយតង្វាយប្រសិទ្ធពរលើនំ និងស្រាតង្វាយ ដើម្បីត្រៀមរៀបចំធម៌អរព្រះគុណដ៏វិសុទ្ធ។

នៅក្នុងអភិបូជា មានពាក្យអធិដ្ឋានតែមួយគត់ដែលប្រសិទ្ធពរលើនំ និងស្រាតង្វាយ។ ពាក្យអធិដ្ឋាននោះ បញ្ចប់ដោយពាក្យខ្លីដូចជា៖ តាមរយៈព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ។ បើពាក្យអធិដ្ឋានបញ្ចប់ ដោយព្រះបុត្រាមានព្រះបន្ទូល ត្រូវបន្ថែម ដែលគង់នៅ និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ។ អង្គប្រជុំចូលរួមនឹងពាក្យអធិដ្ឋាន ដោយឆ្លើយថា៖ អាម៉ែន។

### ធម៌អរព្រះគុណដ៏វិសុទ្ធ

៧៨. គឺជាខ្លឹមសារដ៏កំពូលនៃពិធីអភិបូជា។ ធម៌អរព្រះគុណដ៏វិសុទ្ធ ជាពាក្យអរព្រះគុណ ព្រះជាម្ចាស់ និងធ្វើឲ្យបានវិសុទ្ធ។ លោកបូជាចារ្យអញ្ជើញអង្គប្រជុំឲ្យលើកចិត្តថ្វាយព្រះអង្គ ដោយអរព្រះគុណព្រះជាម្ចាស់រួមជាមួយគ្នា ដើម្បីអធិដ្ឋានក្នុងនាមព្រះសហគមន៍ទាំងមូលឆ្ពោះទៅកាន់ព្រះបិតា តាមរយៈព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ពាក្យអធិដ្ឋាននេះ មានន័យថា ព្រះសហគមន៍រួមគ្នាប្រកាសពីកិច្ចការដ៏អស្ចារ្យរបស់ព្រះបិតា តាមរយៈព្រះយេស៊ូគ្រីស្ត និងព្រះវិញ្ញាណដ៏វិសុទ្ធ។ អង្គប្រជុំត្រូវយកចិត្តទុកដាក់ស្តាប់ធម៌អរព្រះគុណដ៏វិសុទ្ធដោយស្ងៀមស្ងាត់។

៧៩. ផ្នែកនីមួយៗនៃធម៌អរព្រះគុណដ៏វិសុទ្ធមាន៖

ក)ពាក្យអរព្រះគុណ (ជាពិសេសនៅធម៌ប្រារព្ធ) លោកបូជាចារ្យក្នុងនាមព្រះសហគមន៍ទាំងមូលកោតសរសើរព្រះបិតា អរព្រះគុណព្រះអង្គជាព្រះសង្គ្រោះរបស់យើង ឬមានការប្រែប្រួលទៅតាមពិធីបុណ្យប្រចាំថ្ងៃ ឬតាមរដូវបុណ្យផ្សេងៗ។

ខ)ពាក្យអបអរសាទរ៖ ព្រះសហគមន៍ទាំងមូល ចូលរួមជាមួយអស់ទេវទូតនៅស្ថានបរមសុខច្រៀង ព្រះដ៏វិសុទ្ធ (Sanctus)។ លោកបូជាចារ្យ និងអង្គប្រជុំត្រូវប្រកាសពាក្យសាទរនេះ។

គ)ពាក្យអង្វរព្រះវិញ្ញាណ៖ ជាពាក្យអធិដ្ឋានសម្រាប់ព្រះសហគមន៍អង្វរព្រះជាម្ចាស់ ប្រោសប្រទានព្រះវិញ្ញាណយាងមកលើតង្វាយដែលប្រសិទ្ធឲ្យទៅជាព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ហើយអង្វរព្រះអង្គប្រោសឲ្យអស់អ្នកដែលចូលរួមទទួលព្រះកាយ និងព្រះលោហិត ព្រះគ្រីស្តទទួលបានការសង្គ្រោះ។

ឃ)ពាក្យនឹករឭកការតែងតាំង និងពិធីប្រសិទ្ធពរ៖ ទៅតាមព្រះបន្ទូល និងសកម្មភាពរបស់ព្រះគ្រីស្តដែលបានបូជាព្រះជន្មផ្ទាល់ក្នុងពេលជប់លៀងចុងក្រោយ ដោយថ្វាយព្រះកាយ និងព្រះលោហិតរបស់ព្រះអង្គ តាមរយៈនំ និងស្រាដែលព្រះអង្គប្រទានឲ្យក្រុមគ្រីស្តទូតពិសា ហើយបញ្ជាឲ្យក្រុមគ្រីស្តទូតធ្វើដូច្នេះ ដើម្បីបន្តគម្រោងការដ៏អស្ចារ្យនេះ។

ង) ធម៌នឹករឭក៖ ជាធម៌ដែលព្រះសហគមន៍អនុវត្តតាមដំបូន្មានរបស់ព្រះគ្រីស្តជាព្រះអម្ចាស់ តាមរយៈក្រុម គ្រីស្តទូត ជាពិសេស នឹករឭកដល់ព្រះគ្រីស្តដែលរងទុក្ខលំបាក និងមានព្រះជន្មរស់ឡើង វិញប្រកបដោយសិរីរុងរឿង ហើយយាងឡើងស្ថានបរមសុខ។

ច) ការថ្វាយតង្វាយ៖ ពាក្យនេះ ដែលរំឭកដល់ព្រះសហគមន៍យ៉ាងខ្លាំង ជាពិសេសអស់បងប្អូនដែលចូលរួមថ្វាយអភិបូជា តង្វាយដ៏វិសុទ្ធតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ គឺជាកូនចៀមបូជាយញ្ញថ្វាយទៅព្រះបិតា។ គោលបំណងព្រះសហគមន៍ គឺនាំឲ្យគ្រីស្តបរិស័ទ ថ្វាយតែតង្វាយប៉ុណ្ណោះទេ គឺបូជាយញ្ញដូចព្រះអង្គបានបង្រៀន[85] តាមរយៈព្រះគ្រីស្តជាស្ពានមេត្រី ដើម្បីឲ្យព្រះជាម្ចាស់បំពេញអ្វីៗទាំងអស់ក្នុងមនុស្ស ជាស្ពាពរនៅថ្ងៃចុងក្រោយបំផុត។[86]

ឆ)ពាក្យអង្វរសកល៖ ត្រូវបង្ហាញថា យើងថ្វាយអភិបូជាដោយរួមជាមួយព្រះសហគមន៍ ទាំងមូលទាំងនៅលើផែនដី ទាំងនៅស្ថានបរមសុខ ហើយតង្វាយដែលបានមកសម្រាប់ព្រះសហគមន៍ និងបងប្អូនទាំងអស់ ទាំងនៅរស់ ទាំងស្លាប់ ឲ្យរួចផុតពីបាប និងទទួលការសង្គ្រោះមកពីព្រះកាយ និងព្រះលោហិតគ្រីស្ត។

ជ)ជាចុងក្រោយ ពាក្យលើកតម្កើងសិរីរុងរឿងព្រះគ្រីស្ត៖ ជាពាក្យដែលព្រះសហគមន៍កោតសរសើរ ព្រះជាម្ចាស់ ហើយអង្គប្រជុំបញ្ចប់ដោយពោលពាក្យថា៖ "អាម៉ែន"។

[85] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 48; Sacred Congregation of Rites, Instruction Eucharisticum mysterium, On the worship of the Eucharist, 25 May 1967, no. 12: AAS 59 (1967), pp. 548-549.

[86] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 48; Decree on the Ministry and Life of Priests, *Presbyterorum ordinis*, no. 5; Sacred Congregation of Rites, Instruction *Eucharisticum mysterium*, On the worship of the Eucharist, 25 May 1967, no. 12: AAS 59 (1967), pp. 548-549.

## ពិធីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត

៨០. ពិធីអភិបូជាជប់លៀងនៃបុណ្យចម្លង។ មុននឹងទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត តាមព្រះដំបូន្មានរបស់ព្រះអង្គ គ្រីស្តបរិស័ទទាំងអស់យកចិត្តទុកដាក់សម្រុះសម្រួល ធ្វើកាយវិការមួយដែលបង្ហាញពីការអត់ទោសឲ្យគ្នាទៅវិញទៅមក នេះជាអត្ថន័យនៃពិធីជប់លៀងរបស់ព្រះអម្ចាស់ និងពិធីផ្សេងៗរហូតដល់ពិធីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។

## ពាក្យអធិដ្ឋានរបស់ព្រះអម្ចាស់ (ធម៌ ឱ ព្រះបិតា)

៨១. នៅក្នុងពាក្យអធិដ្ឋានរបស់ព្រះអម្ចាស់ ជាពាក្យទូលអង្វរសូមប្រទានអាហារប្រចាំថ្ងៃ គឺសំខាន់បំផុតសម្រាប់គ្រីស្តបរិស័ទដែលទទួលព្រះកាយព្រះគ្រីស្តជាអាហារ និងទូលអង្វរព្រះអង្គឲ្យលើកលែងទោសជម្រះបាប ដូច្នេះ អាហារដ៏វិសុទ្ធនេះ នឹងបានទៅដល់ជនដ៏វិសុទ្ធរបស់ព្រះអង្គដែរ។ លោកបូជាចារ្យប្រកាសជាការអញ្ជើញក្នុងពេលអធិដ្ឋាន ហើយគ្រីស្តបរិស័ទទាំងអស់ពោលពាក្យអធិដ្ឋានរួមជាមួយលោក ក្រោយមក លោកបូជាចារ្យតែម្នាក់ដែលបន្តពាក្យអធិដ្ឋាន ហើយអង្គប្រជុំបញ្ចប់ដោយពាក្យសរសើរតម្កើងសិរីរុងរឿងព្រះគ្រីស្ត។ ការបន្តពាក្យអធិដ្ឋានរបស់ព្រះអម្ចាស់លាតសន្ធឹងឡើងនាពេលចុងក្រោយ ដើម្បីទូលអង្វរព្រះជាម្ចាស់ដ៏មានឫទ្ធានុភាព សូមសង្គ្រោះព្រះសហគមន៍ទាំងមូលឲ្យរួចផុតពីអំណាចនៃអំពើអាក្រក់។

ការអញ្ជើញនេះ ជាការអធិដ្ឋានខ្លួនឯងផ្ទាល់ ហើយអង្គប្រជុំ បន្តការអធិដ្ឋានរបស់ព្រះអម្ចាស់ដោយច្រៀងសរសើរតម្កើងសិរីរុងរឿងព្រះគ្រីស្តបន្លឺសំឡេងខ្លាំងៗ។

## ពិធីជូនសេចក្តីសុខសាន្ត

៨២. តាមក្បួនពិធីជូនសេចក្តីសុខសាន្ត ព្រះសហគមន៍សូមអង្វរព្រះជាម្ចាស់ប្រទានសន្តិភាព និងឯកភាពក្នុងព្រះសហគមន៍ក្នុងទូទាំងពិភពលោក ហើយគ្រីស្តបរិស័ទបង្ហាញកាយវិការគោរពគ្នាទៅវិញទៅមក ឯកភាព ជាសញ្ញាពីសេចក្តីសុខសាន្តរបស់គេ មុនទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។ ក្រុមលោកអភិបាលប្រចាំតំបន់ត្រូវជ្រើសរើសសញ្ញា ឬរបៀបណាមួយឲ្យគ្រីស្តបរិស័ទជូនសេចក្តីសុខសាន្តតាមវប្បធម៌ ប្រពៃណីរបស់គេ។ គួរជូនសេចក្តីសុខសាន្តឲ្យគ្រីស្តបរិស័ទដែលនៅក្បែរខ្លួន។

## ពិធីកាច់នំពង្វាយ

៨៣. លោកបូជាចារ្យកាច់នំប៉័ងដែលជាពិធីប្រសិទ្ធព្រះកាយ ហើយលោកឧបដ្ឋាកអាចជួយក្នុងពិធីនេះបាន។ នៅសម័យគ្រីស្តទូតពិធីថ្វាយអភិបូជាគេធ្លាប់ហៅ៖ ពិធីកាច់នំប៉័ង តាមកាយវិការរបស់ព្រះយេស៊ូជប់លៀងចុងក្រោយជាមួយក្រុមសាវ័ក។ កាយវិការនេះ មានន័យថា គ្រីស្តបរិស័ទក្លាយទៅជារូបកាយតែមួយ (១ករ ១០.១៧) ដោយទទួលនំប៉័ងដែលផ្តល់ជីវិត គឺព្រះកាយព្រះគ្រីស្តដែលសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ ដើម្បីសង្គ្រោះមនុស្សលោក។ ក្រោយពីជូនសេចក្តីសុខសាន្តឲ្យគ្នាទៅវិញទៅមក ត្រូវមានពិធីកាច់នំប៉័ងជាដាច់ខាត

ទោះជាពិធីនោះមានរយៈពេលខ្លីក៏ដោយ។ មានតែលោកបូជាចារ្យ និងលោកឧបដ្ឋាកដែលអាចប្រារព្ធពិធីនេះបាន។

លោកបូជាចារ្យ កាច់នំលើថានព្រះកាយ ហើយយកបំណែកតូចមួយដាក់ក្នុងពែងព្រះលោហិត ដើម្បីបង្ហាញឯកភាពនៃព្រះកាយ និងព្រះលោហិតព្រះគ្រីស្តក្នុងការសង្គ្រោះ គឺព្រះកាយព្រះយេស៊ូគ្រីស្តដែលមានព្រះជន្មគង់នៅក្នុងសិរីរុងរឿង។ តាមពាក្យទូលអង្វរនេះ ក្រុមចម្រៀងត្រូវច្រៀងបទ "កូនចៀមរបស់ព្រះជាម្ចាស់" (Agnus Dei) ជាធម្មតាអង្គប្រជុំឆ្លើយ ឬក៏ត្រូវសូត្រឲ្យខ្លាំងៗ។ បទចម្រៀងនេះ កំដរពិធីកាច់នំព្រះកាយ ដូច្នេះ ត្រូវច្រៀងច្រើនដងរហូតដល់បញ្ចប់ពិធីនេះ។ ពាក្យចុងក្រោយនៃបទចម្រៀងនេះ គឺ "សូមប្រទានសេចក្តីសុខសាន្តឲ្យយើងខ្ញុំ" (dona nobis pacem)។

### ទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត

៨៤. លោកបូជាចារ្យអធិដ្ឋានដោយខ្សឹបៗ សូមអង្វរព្រះជាម្ចាស់សម្រាប់ទទួលផលផ្លែល្អពីព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។ គ្រីស្តបរិស័ទអង្វរព្រះជាម្ចាស់ដោយអធិដ្ឋានស្ងៀមស្ងាត់។ លោកបូជាចារ្យបង្ហាញនំព្រះកាយឲ្យគ្រីស្តបរិស័ទឃើញ ដោយកាន់នំព្រះកាយលើថានពិសិដ្ឋ ឬលើពែងព្រះលោហិត លោកអញ្ជើញគ្រីស្តបរិស័ទទាំងអស់ចូលរួមក្នុងពិធីជប់លៀងរបស់ព្រះគ្រីស្ត និងបង្ហាញពីកាយវិការមួយប្រកបដោយភាពសុភាពរាបសារ ហើយអង្គប្រជុំប្រកាសសេចក្តីមួយដែលដកស្រង់ពីព្រះគម្ពីរដំណឹងល្អ។

៨៥. ជាការគួរណាស់ បើសិនជាគ្រីស្តបរិស័ទអាចទទួលនំព្រះកាយ និងព្រះលោហិត ដូចលោកបូជាចារ្យដែលប្រសិទ្ធក្នុងអភិបូជា ទៅជាព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត (សូមមើលលេខ ២៨៣) ដូច្នេះ សញ្ញាសម្គាល់ជួយឲ្យយល់ច្បាស់ថា យើងទាំងអស់គ្នាចូលរួមក្នុងសក្ការបូជាដែលបានប្រារព្ធនេះ។[87]

៨៦. ពេលលោកបូជាចារ្យកំពុងទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត គ្រីស្តបរិស័ទចាប់ផ្តើមច្រៀង។ គោលដៅនៃបទចម្រៀងនេះ គឺបង្ហាញតាមរយៈសំឡេងតែមួយ នៃការរួបរួមគ្នាក្នុងអង្គព្រះគ្រីស្តរបស់អ្នកទទួលអគ្គសញ្ញា ម្យ៉ាងទៀត គឺបង្ហាញអំណរសប្បាយអស់ពីដួងចិត្ត និងបង្ហាញយ៉ាងច្បាស់ពី "លក្ខណៈរួម" នៃពិធីហែរ និងទទួលព្រះកាយព្រះគ្រីស្ត។ ត្រូវច្រៀងរហូតដល់ចប់ពិធីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។[88] ប្រសិនបើមានបទចម្រៀងផ្សេងទៀត គួរបញ្ចប់បទចម្រៀងបន្ទាប់ពី ពិធីទទួលព្រះកាយព្រះគ្រីស្តរួចតាមរបៀបត្រឹមត្រូវ។ ចូរប្រយ័ត្នត្រូវឲ្យក្រុមច្រៀងទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្តតាមរបៀបស្រួលបួល។

៨៧. សម្រាប់ពិធីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត អាចជ្រើសរើសពាក្យបន្ទរ និងទំនុកតម្កើងពី Graduale Romanum ឬពាក្យបន្ទរទំនុកតម្កើងពី Graduale Simplex ឬបទចម្រៀង

[87] Cf. Sacred Congregation of Rites, Instruction *Eucharisticum mysterium*, On the worship of the Eucharist, 25 May 1967, nos. 31, 32; Sacred Congregation for the Discipline of the Sacraments, Instruction *Immensae caritatis*, 29 January 1973, no. 2: AAS 65 (1973), pp. 267-268.
[88] Cf. Sacred Congregation for the Sacraments and Divine Worship, Instruction *Inaestimabile donum*, 3 April 1980, no. 17: AAS 72 (1980), p. 338.

ពីបញ្ជីផ្សេងដែលទទួលសេចក្ដីអនុញ្ញាតពីក្រុមលោកអភិបាលប្រចាំតំបន់។ បទចម្រៀងនោះ ក្រុមចម្រៀង ឬគ្រីស្ដបរិស័ទច្រៀងរួមជាមួយ។

ប្រសិនបើគ្មានបទចម្រៀងទេ អង្គប្រជុំ សូត្រពាក្យបន្ទរដែលមានក្នុងក្បួនពិធីបុណ្យ ឬលោកបូជាចារ្យសូត្រម្នាក់ឯង ក្រោយមក ទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ដ ហើយជូនព្រះកាយ និងព្រះលោហិតព្រះគ្រីស្ដដល់គ្រីស្ដបរិស័ទ។

៨៨. ក្រោយពីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ដរួច លោកបូជាចារ្យ និងគ្រីស្ដបរិស័ទអធិដ្ឋានរៀងខ្លួនៗ ឬអង្គប្រជុំរួមគ្នាច្រៀងបទកោតសរសើរ ឬទំនុកតម្កើង ប្រសិនជាអាចធ្វើបាន។

៨៩. ទីបញ្ចប់នៃពិធីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ដ លោកបូជាចារ្យសូត្រពាក្យអធិដ្ឋានដើម្បីទូលអង្វរព្រះអង្គ សូមប្រោសប្រទានផលផ្លែនៃពិធីដែលគេបានប្រារព្ធ។

ពេលថ្វាយអភិបូជា មានពាក្យអធិដ្ឋានតែមួយប៉ុណ្ណោះ ក្រោយពីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ដ ដោយពោលពាក្យបញ្ចប់យ៉ាងខ្លី ៖

- ប្រសិនបើពាក្យអធិដ្ឋានទៅកាន់ព្រះបិតា៖ "ដោយរួមជាមួយព្រះយេស៊ូគ្រីស្ដជាអម្ចាស់"។
- បើសិនប្រើពាក្យអធិដ្ឋានទៅកាន់ព្រះបិតា មានថែងអំពីព្រះគ្រីស្ដនៅខាងចុង "ដែលគង់នៅ និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ"។
- បើពាក្យអធិដ្ឋានទៅកាន់ព្រះគ្រីស្ដ៖ "ដែលគង់នៅ និងសោយរាជ្យអស់កល្បជាអង្វែង តរៀងទៅ"។

គ្រីស្ដបរិស័ទយកពាក្យអធិដ្ឋាននោះ មកអធិដ្ឋានខ្លួនឯងដោយប្រកាសថា អាម៉ែន។

### ឃ) ពិធីបញ្ចប់

៩០. ពិធីបញ្ចប់មាន ៖

ក)សេចក្ដីប្រកាស គួរសង្ខេបបើមានការចាំបាច់។

ខ)ពាក្យជំរាបសួររបស់លោកបូជាចារ្យ និងការប្រទានពរ ដែលមានកំណត់ជាស្រេច ហើយបង្ហាញនូវការអធិដ្ឋានដល់អង្គប្រជុំ ឬធ្វើតាមក្បួនពិធីនៃការប្រទានពរយ៉ាងឱឡារិក។

គ)ពិធីចាត់បងប្អូនឲ្យទៅរបស់លោកបូជាចារ្យ ឬលោកឧបដ្ឋាក ដើម្បីឲ្យបងប្អូនទៅប្រព្រឹត្តការងារល្អ ដោយកោតសរសើរព្រះជាម្ចាស់។

ឃ)លោកបូជាចារ្យ លោកឧបដ្ឋាក ព្រមទាំងអ្នកបម្រើពិធីបុណ្យ ថើបគុសក្ការបូជា និងឱនកាយគោរពគុសក្ការបូជា។

# ជំពូកទី ៣

## ភារកិច្ចរបស់អ្នកបម្រើពិធីបុណ្យក្នុងអភិបូជា

៩១. អភិបូជា គឺជាសកម្មភាពរបស់ព្រះគ្រីស្ត និងជាសកម្មភាពចូលរួមរបស់ព្រះសហគមន៍ជាប្រជារាស្ត្ររបស់ព្រះអង្គក្រោមការណែនាំរបស់លោកអភិបាល។ ដូច្នេះ ព្រះកាយជាកម្មសិទ្ធិរបស់ព្រះសហគមន៍ ហើយមានប្រសិទ្ធភាពលើគ្រីស្តបរិស័ទម្នាក់ៗតាមរបៀបផ្សេងពីគ្នា ដោយទទួលមុខងារ និងចូលរួមក្នុងការរៀបចំពិធី។[89] តាមរបៀបនេះ គ្រីស្តបរិស័ទដែលព្រះអង្គបានជ្រើសរើស ជាក្រុមបូជាចារ្យរបស់ព្រះមហាក្សត្រ ជាជាតិសាសន៍ដ៏វិសុទ្ធ ជាប្រជារាស្ត្រដែលព្រះជាម្ចាស់យកមកធ្វើជាកម្មសិទ្ធិផ្ទាល់របស់ព្រះអង្គ ដើម្បីបង្ហាញពីឯកភាព និងឋានានុក្រមរបស់ខ្លួន។[90] ហេតុដូច្នេះ ទោះជាអ្នកបម្រើពិធីបុណ្យ ឬអស់អ្នកជឿដែលមានភារកិច្ចបំពេញមុខងារទាំងនោះ ទទួលអគ្គសញ្ញាតែងតាំងឲ្យបំពេញនូវមុខងារទាំងស្រុងតែម្នាក់ឯង។[91]

## I. ភារកិច្ចនៃអគ្គសញ្ញាតែងតាំងជាអ្នកបម្រើ

៩២. តាមច្បាប់រាល់ពេលថ្វាយអភិបូជា គឺត្រូវមានលោកអភិបាលជាអធិបតីភាព ឬតាមរយៈលោកបូជាចារ្យម្នាក់ក៏អាចជួយលោកជាអធិបតីក្នុងអភិបូជានោះក៏បាន។[92] ពេលលោកអភិបាលថ្វាយអភិបូជាដោយមានគ្រីស្តបរិស័ទច្រើននាក់ចូលរួម ហើយពិតជាប្រសើរណាស់ បើលោកបូជាចារ្យឯទៀតចូលរួមថ្វាយអភិបូជារួមជាមួយលោកជាអធិបតី។ ធ្វើដូច្នេះ មិនមែនដើម្បីបន្ថែមភាពឱឡារិកនៅខាងក្រៅទេ គឺដើម្បីបង្ហាញពីគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គដល់ព្រះសហគមន៍នូវ "អគ្គសញ្ញានៃការរួបរួមគ្នា"។[93] បើលោកអភិបាលមិនថ្វាយអភិបូជា លោកចាត់តាំងម្នាក់ទៀតឲ្យប្រារព្ធពិធីនេះ អនុញ្ញាតឲ្យលោកបូជាចារ្យម្នាក់ថ្វាយអភិបូជា ជាការគួរណាស់ លោកអភិបាលជាអធិបតី ធ្វើពិធីលើកតម្កើងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយពាក់ឈើឆ្កាងលើអាវលោកអភិបាល កន្សែងបង់កពិសិដ្ឋ និងអាវធំលើអាវសវែង ហើយគួរឲ្យលោកប្រទានពរពេលពិធីបញ្ចប់អភិបូជា។[94]

៩៣. លោកបូជាចារ្យ មានសិទ្ធិថ្វាយអភិបូជាក្នុងនាមព្រះគ្រីស្តនៅក្នុងព្រះសហគមន៍ ជាអគ្គសញ្ញាតែងតាំងដែលព្រះគ្រីស្តបានបូជាព្រះជន្មផ្ទាល់ [95] លោកណែនាំប្រជារាស្ត្រព្រះអង្គដែលរួបរួមគ្នាអធិដ្ឋាន និងប្រកាសដំណឹងល្អពីការសង្គ្រោះរបស់ព្រះអម្ចាស់ឲ្យគេស្តាប់ ព្រមទាំងរួបរួមគ្រីស្តបរិស័ទឲ្យថ្វាយតង្វាយទៅព្រះបិតា តាមរយៈព្រះគ្រីស្តក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ និងឲ្យបងប្អូនចូលរួមទទួល "នំប៉័ង" ដែលប្រោសប្រទានជីវិតអស់កល្បជានិច្ច។ ពេលលោកថ្វាយអភិបូជា លោកត្រូវបម្រើព្រះជាម្ចាស់ បម្រើបងប្អូនដោយសេចក្តីថ្លៃថ្នូរ និងបន្ទាបខ្លួនដោយខិតខំថ្លែងព្រះបន្ទូលរបស់ព្រះអង្គនៅពេលដែលព្រះអង្គតែងតាំងអភិបូជានេះ។ លោកបង្ហាញពីវត្តមានរបស់ព្រះគ្រីស្តដែលគង់នៅជាមួយ។

[89] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 26.
[90] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 14.
[91] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 28.
[92] Cf. Second Vatican Ecumenical Council, Dogmatic Constitution on the Church, *Lumen gentium*, nos. 26, 28; Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 42.
[93] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 26.
[94] Cf. *Caeremoniale Episcoporum, editio typica*, 1984, nos. 175-186.
[95] Cf. Second Vatican Ecumenical Council, Dogmatic Constitution on the Church, *Lumen gentium*, no. 28; Decree on the Ministry and Life of Priests, *Presbyterorum ordinis*, no. 2.

៩៤. ក្រោយពីលោកបូជាចារ្យ មានលោកឧបដ្ឋាក ដោយអគ្គសញ្ញាតែងតាំងដែលគាត់បានទទួល កន្លែងពិសេសក្នុងចំណោមអ្នកបម្រើនៃពិធីអភិបូជា។ តាំងពីសម័យក្រុមគ្រីស្តទូត គេទទួលស្គាល់កិត្តិយសនៃការតែងតាំងជាឧបដ្ឋាក។[96] ពេលប្រារព្ធពិធីអភិបូជា លោកឧបដ្ឋាកមានមុខងារច្បាស់លាស់ គឺប្រកាសដំណឹងល្អ ធម្មទេសនាយូរៗម្តង អធិដ្ឋានអង្វរសកលជួយលោកបូជាចារ្យរៀបចំតុសក្ការបូជា ជូនព្រះកាយដល់គ្រីស្តបរិស័ទ ជាពិសេសពេលគ្រីស្តបរិស័ទទទួលព្រះកាយ និងព្រះលោហិត ព្រមទាំងណែនាំពីកាយវិការ និងឥរិយាបថរបស់ គ្រីស្តបរិស័ទពេលថ្វាយអភិបូជា។

៩៥. ពេលថ្វាយអភិបូជា គ្រីស្តបរិស័ទចូលរួមជាប្រជាជនដ៏វិសុទ្ធ ជាប្រជារាស្ត្ររបស់ព្រះអង្គ ដើម្បីអរព្រះគុណព្រះជាម្ចាស់ និងថ្វាយទៅព្រះអង្គ "យញ្ញបូជាដ៏ល្អប្រសើរ គឺអភិបូជា" មិនមែនតែតាមរបៀបលោកបូជាចារ្យទេ ប៉ុន្តែរួមជាមួយលោក។ ធ្វើដូច្នេះ គ្រីស្តបរិស័ទម្នាក់ៗថ្វាយខ្លួនទៅព្រះជាម្ចាស់។[97] គ្រីស្តបរិស័ទខិតខំបង្ហាញថា គេចង់ថ្វាយខ្លួនទៅព្រះជាម្ចាស់ ដោយសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ និងសេចក្តីស្រឡាញ់ចំពោះគ្រីស្តបរិស័ទ ដែលចូលរួមថ្វាយអភិបូជា។ ដូច្នេះ គ្រីស្តបរិស័ទត្រូវជៀសវាងបង្ហាញភាពបុគ្គលនិយម ឬភាពបាក់បែកគ្នា ដោយរំឭកគ្នាទៅវិញទៅមកថា យើងមានព្រះបិតាតែមួយ ដូច្នេះហើយយើងជាបងប្អូន។

៩៦. ពិតប្រាកដមែន គេជារូបកាយតែមួយ ដោយស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ចូលរួមអធិដ្ឋាន និងច្រៀង ជាពិសេសថ្វាយអភិបូជាតែមួយ និងចូលរួមទទួលព្រះកាយតែមួយពីតុសក្ការបូជារបស់ព្រះអម្ចាស់។ គេបង្ហាញការរួបរួមគ្នានេះ ដោយធ្វើកាយវិការ និងឥរិយាបថរបស់បងប្អូនតាមរបៀបដ៏ល្អប្រសើរ។

៩៧. គ្រីស្តបរិស័ទមិនត្រូវបដិសេធជាអ្នកបម្រើប្រជាជនដ៏វិសុទ្ធរបស់ព្រះអង្គ ពេលដែលគេសូមឲ្យទទួលមុខងារមួយ ឬបម្រើព្រះសហគមន៍ក្នុងពិធីមួយ។

## III. បេសសកកម្មរបស់អ្នកបម្រើពិធីបុណ្យ

### ការចាត់តាំងអ្នកបម្រើតុសក្ការបូជា និងអ្នកប្រកាសព្រះបន្ទូល

៩៨. អ្នកបម្រើតុសក្ការបូជា ទទួលការចាត់តាំងឲ្យជួយលោកបូជាចារ្យ និងលោកឧបដ្ឋាក។ ជាពិសេសត្រូវរៀបចំតុសក្ការបូជា ចានពិសិដ្ឋ នំតង្វាយ និងពែងព្រះលោហិត ស្រាតង្វាយ ហើយតាមសេចក្តីត្រូវការ ក្នុងករណីពិសេស អាចជូនព្រះកាយព្រះគ្រីស្តដល់គ្រីស្តបរិស័ទ។[98] អ្នកបម្រើតុសក្ការបូជា មានមុខងាររបស់គាត់ (សូមមើលលេខ ១៨៧/១៩៣) ដែលគាត់ត្រូវប្រព្រឹត្តផ្ទាល់ខ្លួន។

---

[96] Cf. Paul VI, Apostolic Letter *Sacrum diaconatus ordinem*, 18 June 1967: AAS 59 (1967), pp. 697-704; The Roman Pontifical, *Rites of Ordination of a Bishop, of Priests, and of Deacons, editio typica altera*, 1989, no. 173.

[97] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 48; Sacred Congregation of Rites, *Instruction Eucharisticum mysterium*, On the worship of the Eucharist, 25 May 1967, no. 12: AAS 59 (1967), pp. 548-549.

[98] Cf. *Codex Iuris Canonici*, can. 910 ' 2; cf. also Interdicasterial Instruction on certain questions regarding the collaboration of the non-ordained faithful in the sacred ministry of priests, *Ecclesiae de mysterio*, 15 August 1997, art. 8: AAS 89 (1997), p. 871.

៩៩. អ្នកប្រកាសព្រះបន្ទូល ទទួលការតែងតាំងដើម្បីប្រកាសអត្ថបទព្រះគម្ពីរ លើកលែងតែអត្ថបទព្រះគម្ពីរដំណឹងល្អ។ គាត់អាចអានពាក្យអង្វរសកល ហើយតាមសេចក្ដីត្រូវការប្រកាសទំនុកតម្កើងក្រោយអត្ថបទទីមួយ។ ពេលប្រារព្ធពិធីអភិបូជា អ្នកប្រកាសព្រះបន្ទូលមានមុខងាររបស់គាត់ (សូមមើលលេខ ១៩៤-១៩៨) ដែលគាត់ត្រូវប្រព្រឹត្តផ្ទាល់ខ្លួន។

## មុខងារផ្សេងៗនៃពិធីបុណ្យ

១០០. ពេលគ្មានអ្នកបម្រើគុសក្ការបូជា គ្រីស្តបរិស័ទអាចបម្រើគុសក្ការបូជា ជួយលោកបូជាចារ្យ និងលោកឧបដ្ឋាក។ គេអាចហែដោយកាន់ព្រះឈើឆ្កាង ទៀន ចង្ក្រានកំញាន នំ និងស្រាតង្វាយជាមួយទឹក។ ក្នុងករណីពិសេស អាចជូនព្រះកាយព្រះគ្រីស្តដល់គ្រីស្តបរិស័ទ។[99]

១០១. បើគ្មានអ្នកប្រកាសព្រះបន្ទូល លោកអាចផ្តល់សិទ្ធិឲ្យគ្រីស្តបរិស័ទម្នាក់ឡើងប្រកាស ព្រះបន្ទូល។ លោកត្រូវយកចិត្តទុកដាក់ប្រកាសព្រះបន្ទូល ហើយត្រូវទទួលការអប់រំពីមុខងារនេះ។ ធ្វើដូច្នេះ ជួយឲ្យគ្រីស្តបរិស័ទកាន់តែមានចិត្តស្រឡាញ់ព្រះបន្ទូលរបស់ព្រះជាម្ចាស់រាល់ពេលស្តាប់ព្រះគម្ពីរ។[100]

១០២. មានអ្នកបម្រើម្នាក់ ដែលត្រូវសូត្រទំនុកតម្កើង ឬបទចម្រៀងផ្សេង ក្រោយពីអត្ថបទទីមួយ។ ដើម្បីបំពេញភារកិច្ចនេះបានត្រឹមត្រូវ អ្នកសូត្រទំនុកតម្កើង ត្រូវមានទេពកោសល្យជាអ្នកចម្រៀង ព្រមទាំងនិយាយច្បាស់ និងពីរោះ។

១០៣. ការបង្ហាត់គ្រីស្តបរិស័ទឲ្យចេះច្រៀង (schola cantorum) ឬក្រុមចម្រៀង មានមុខងារច្បាស់លាស់ក្នុងពិធីបុណ្យ ដោយច្រៀងតាមរបៀបត្រឹមត្រូវ និងជួយឲ្យគ្រីស្តបរិស័ទឯទៀតៗចូលរួមយ៉ាងសកម្ម ដោយច្រៀងជាមួយគ្នា។[101] បទបញ្ញានេះសម្រាប់ក្រុមអ្នកចម្រៀងដូចគ្នាសម្រាប់តន្ត្រីឯទៀតៗ ជាពិសេសអ្នកលេងអកហ្គ។

១០៤. គួរមានប្រធានក្រុមចម្រៀង ឬអ្នកណែនាំចង្វាក់ ដើម្បីជួយគ្រីស្តបរិស័ទពេលកំពុងច្រៀង។ ពេលគ្មានក្រុមចម្រៀង គួរមានម្នាក់ណែនាំបទចម្រៀងផ្សេងៗ ដើម្បីជួយគ្រីស្តបរិស័ទចូលរួមច្រៀងជាមួយគ្នា។[102]

១០៥. មុខងារពិធីបុណ្យមានបែងចែកដូចជា ៖

ក) អ្នកថែរក្សាកន្លែងសក្ការបូជា រៀបចំសៀវភៅក្បួនពិធីបុណ្យ សម្លៀកបំពាក់ពិសិដ្ឋ និងអ្វីៗដែលត្រូវការសម្រាប់ថ្វាយអភិបូជា។

ខ) ពិធីករពន្យល់ ដាស់តឿនគ្រីស្តបរិស័ទឲ្យយល់ច្បាស់ ហើយចូលរួមយ៉ាងសកម្ម។ ពិធីករត្រូវរៀបចំសេចក្ដីពន្យល់តាមរបៀបត្រឹមត្រូវ និងច្បាស់លាស់ ត្រូវអាន និងពន្យល់ ដោយឈរនៅខាងមុខគ្រីស្តបរិស័ទ នៅកន្លែងផ្សេងពីគុព្រះបន្ទូល។

គ) អ្នករៃលុយតង្វាយពីគ្រីស្តបរិស័ទ។

[99] Cf. Sacred Congregation for the Discipline of the Sacraments, Instruction *Immensae caritatis*, 29 January 1973, no. 1: AAS 65 (1973), pp. 265-266; *Codex Iuris Canonici*, can. 230 § 3.
[100] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 24.
[101] Cf. Sacred Congregation of Rites, Instruction *Musicam sacram*, On music in the Liturgy, 5 March 1967, no. 19: AAS 59 (1967), p. 306.
[102] Cf. Sacred Congregation of Rites, Instruction *Musicam sacram*, On music in the Liturgy, 5 March 1967, no. 21: AAS 59 (1967), pp. 306-307.

ឃ)នៅតំបន់ខ្លះ មានអ្នកទទួលស្វាគមន៍រង់ចាំគ្រីស្តបរិស័ទនៅខាងមុខទ្វារធំ ហើយណែនាំគេដល់កន្លែងអង្គុយ។

១០៦. នៅវិសាលវិហារ និងព្រះវិហារធំ គួរមានអ្នកណែនាំពិធីបុណ្យដើម្បីជួយរៀបចំពិធី និងជួយណែនាំអ្នកបម្រើពិធីបុណ្យ និងគ្រីស្តបរិស័ទឲ្យគេប្រារព្ធពិធីប្រកបដោយសេចក្តីថ្លៃថ្នូរ របៀបត្រឹមត្រូវ និងសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់។

១០៧. មុខងារផ្សេងៗនៃពិធីបុណ្យ លោកបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍ប្រចាំតំបន់អាចជ្រើសរើសគ្រីស្តបរិស័ទ ដើម្បីជួយជាបណ្តោះអាសន្នក្នុងមុខងារជាអ្នកបម្រើ ដែលមិនមែនជាមុខងាររបស់លោកបូជាចារ្យ ឬលោកឧបដ្ឋាក (សូមមើលលេខ ១០០-១០៦)។[103] ដូច្នេះមុខងារអ្នកបម្រើតុសក្ការបូជាសម្រាប់ជួយលោកបូជាចារ្យ ត្រូវគោរពប្រតិបត្តិតាមក្បួនច្បាប់ដែលលោកអភិបាលភូមិភាគបានចាត់តាំង។

## IV. ការចាត់ចែងមុខងារនៃពិធីបុណ្យ និងការរៀបចំប្រារព្ធពិធី

១០៨. ត្រូវមានលោកបូជាចារ្យតែម្នាក់ធ្វើជាអធិបតីក្នុងពិធីនានានៃអភិបូជា លើកលែងតែផ្នែករបស់លោកអភិបាល ពេលលោកចូលរួម (សូមមើលលេខ ៩២)។

១០៩. បើសិនជាមានអ្នកបម្រើខ្លះ ដែលអាចបំពេញមុខងារនៃពិធីបុណ្យ គេអាចចែកមុខងារខ្លះៗឲ្យអ្នកទាំងនោះ។ ឧទាហរណ៍ លោកឧបដ្ឋាកម្នាក់អាចច្រៀង ឬស្មូតម្នាក់ទៀត បម្រើតុសក្ការបូជា។ ប្រសិនបើមានគ្នាច្រើន អ្នកបម្រើប្រកាសព្រះបន្ទូលអាចចែកគ្នាអានអត្ថបទព្រះគម្ពីរ។ មុខងារផ្សេងៗ ក៏អាចធ្វើដូចគ្នាដែរ។ ប៉ុន្តែគេមិនអាចចែកមុខងារតែមួយបានទេ ឧទាហរណ៍ មានពីរ ឬបីនាក់ ជាអ្នកប្រកាសព្រះបន្ទូល មិនអាចអានអត្ថបទតែមួយ ដោយម្នាក់ចាប់ផ្តើម និងម្នាក់ទៀតបន្តនោះទេ។ ប៉ុន្តែមានករណីលើកលែង គឺពេលប្រកាសអត្ថបទស្តីពីទុក្ខលំបាករបស់ព្រះយេស៊ូ។

១១០. ក្នុងអភិបូជា បើមានអ្នកបម្រើតែម្នាក់ អ្នកបម្រើនោះអាចបំពេញមុខងារផ្សេងៗបាន។

១១១. គួរតែធ្វើឲ្យពិធីទាំងនោះមានភាពសប្បាយរីករាយ និងយកចិត្តទុកដាក់ដល់អស់អ្នកដែលចូលរួមជាប់ចិត្តនឹងការរៀបចំពិធីបុណ្យនីមួយៗដោយសមរម្យ ក្នុងពេលថ្វាយអភិបូជា ត្រូវមានបទភ្លេងឲ្យស្របតាមក្បួនពិធីណែនាំព្រះសហគមន៍ និងសៀវភៅផ្សេងៗនៃក្បួនពិធីបុណ្យ។ ការរៀបចំត្រូវសួរយោបល់ពីលោកបូជាចារ្យទទួលខុសត្រូវ និងគ្រីស្តបរិស័ទ។ លោកបូជាចារ្យដែលជាអធិបតី មានសិទ្ធិរៀបចំនូវអ្វីដែលស្ថិតនៅក្រោមអធិបតីភាពរបស់លោក។[104]

[103] Cf. Pontifical Commission for interpreting legal texts, response to *dubium* regarding can. 230 § 2: AAS 86 (1994), p. 541.
[104] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 22.

# ជំពូកទី ៤

## របៀបផ្សេងៗនៃការប្រារព្ធពិធីអភិបូជា

១១២. តាមព្រះសហគមន៍ប្រចាំភូមិភាគ អភិបូជាត្រូវស្ថិតក្រោមអធិបតីភាពរបស់លោកអភិបាល ដោយមានលោកបូជាចារ្យ លោកឧបដ្ឋាក និងអ្នកបម្រើពិធីបុណ្យ[105] ព្រមទាំងជនដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ចូលរួមយ៉ាងសកម្ម ធ្វើរបៀបនោះ បង្ហាញគ្រប់លក្ខណៈរបស់ព្រះសហគមន៍។

ពេលប្រារព្ធពិធីអភិបូជាក្រោមអធិបតីភាពរបស់លោកអភិបាល ត្រូវគោរពបទបញ្ជានៃក្បួនពិធីរបស់លោកអភិបាល (Caereminiale Episcoprum)។[106]

១១៣. ត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំង ចំពោះពិធីអភិបូជាដែលមានគ្រីស្តបរិស័ទចូលរួម ជាពិសេសពេលថ្វាយអភិបូជាតាមព្រះសហគមន៍ប្រចាំភូមិភាគ ព្រោះព្រះសហគមន៍នីមួយៗ ជាតំណាងនៃសហគមន៍ទាំងមូលដែលជួបជុំគ្នានៅកន្លែងមួយ ជាពិសេស ភិបូជាប្រចាំថ្ងៃអាទិត្យ។[107]

១១៤. អភិបូជាសម្រាប់ក្រុមគ្រួសារបព្វជិត បព្វជិតា ឬអភិបូជាប្រចាំថ្ងៃសម្រាប់អារាម មានរបៀបពិសេស ទោះបីគ្មានពិធីពិសេស។ យ៉ាងណាក៏ជាការគួរណាស់ បើសិនជាគេច្រៀង ហើយសមាជិកទាំងអស់គ្នា ចូលរួមយ៉ាងសកម្ម ទោះបីគេជាបព្វជិត បព្វជិតា។ ក្នុងពិធី អភិបូជានេះ ម្នាក់ៗគួរបំពេញមុខងាររបស់ខ្លួនជាអ្នក បម្រើដោយការចាត់តាំង ឬដោយការតែងតាំងជាអគ្គសញ្ញា។ លោកបូជាចារ្យដែលមិនត្រូវទៅថ្វាយអភិបូជាជាមួយគ្រីស្តបរិស័ទនៅក្រៅអារាម គួរចូលរួមថ្វាយអភិបូជាក្នុងក្រុមគ្រួសាររបស់លោក។ ម្យ៉ាងទៀត លោកបូជាចារ្យដែលត្រូវទៅថ្វាយអភិបូជានៅកន្លែងផ្សេង គួរចូលរួមថ្វាយអភិបូជាក្នុងក្រុមគ្រួសាររបស់ខ្លួនដែរ។[108] លោកបូជាចារ្យដែលចូលរួមថ្វាយអភិបូជា គួរចូលរួមថ្វាយដោយមានសម្លៀកបំពាក់ត្រឹមត្រូវ លើកលែងតែមានករណីពិសេស។

## I. ពិធីអភិបូជាដោយមានគ្រីស្តបរិស័ទចូលរួម

១១៥. ជាការគួរណាស់ បើមានបទចម្រៀងក្នុងពិធីអភិបូជារបៀបនេះ ជាពិសេសនៅថ្ងៃអាទិត្យ និងថ្ងៃបុណ្យខានមិនបាន គួរមានអ្នកបម្រើពិធីបុណ្យច្រើននាក់។[109] ប៉ុន្តែគេអាចប្រារព្ធពិធីដោយគ្មានបទចម្រៀង និងមានអ្នកបម្រើតែម្នាក់។

១១៦. បើមានលោកឧបដ្ឋាកចូលរួមថ្វាយអភិបូជា លោកត្រូវបំពេញមុខងាររបស់ខ្លួន។ ម្យ៉ាងទៀតត្រូវទុកដូចជាច្បាប់ពេលប្រារព្ធពិធីអភិបូជា គួរមានអ្នកបម្រើគុសក្ការបូជា អ្នកប្រកាសព្រះបន្ទូល និងអ្នកចម្រៀង ដើម្បីជួយលោកបូជាចារ្យ។ ក្បួនពិធីដែលបានរៀបរាប់ដូចខាងក្រោមនេះ បង្ហាញថា គួរឲ្យមានអ្នកបម្រើពិធីបុណ្យច្រើននាក់។

---

[105] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 41.
[106] Cf. *Caeremoniale Episcoporum, editio typica*, 1984, nos. 119-186.
[107] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 42; Dogmatic Constitution on the Church, *Lumen gentium*, no. 28; Decree on the Ministry and Life of Priests, *Presbyterorum ordinis*, no. 5; Sacred Congregation of Rites, Instruction *Eucharisticum mysterium*, On the worship of the Eucharist, 25 May 1967, no. 26: AAS 59 (1967), p. 555.
[108] Cf. Sacred Congregation of Rites, Instruction *Eucharisticum mysterium*, On the worship of the Eucharist, 25 May 1967, no. 47: AAS 59 (1967), p. 565.
[109] Cf. Sacred Congregation of Rites, Instruction *Eucharisticum mysterium*, On the worship of the Eucharist, 25 May 1967, no. 26: AAS 59 (1967), p. 555; Sacred Congregation of Rites, Instruction *Musicam sacram*, On music in the Liturgy, 5 March 1967, nos. 16, 27: AAS 59 (1967), pp. 305, 308.

### សម្ភារៈដែលត្រូវរៀបចំមុន

១១៧. ត្រូវក្រាលក្រណាត់ពណ៌សលើតុសក្ការបូជា។ ត្រូវមានទៀននៅលើតុសក្ការបូជា ឬនៅជិត។ យ៉ាងតិចត្រូវមានពីរ បួន ឬប្រាំមួយដើម ជាពិសេស សម្រាប់អភិបូជាប្រចាំថ្ងៃអាទិត្យ និងថ្ងៃបុណ្យខានមិនបាន។ ពិធីក្រោមអធិបតីភាពរបស់លោកអភិបាលប្រចាំភូមិភាគ ត្រូវមានទៀនប្រាំពីរដើម។ លើតុសក្ការបូជា ឬនៅជិត ត្រូវមានព្រះឈើឆ្កាងដែលមានភ្ជាប់រូបព្រះ យេស៊ូ។ ពេលចូលអាចហែទៀន និងព្រះឈើឆ្កាងជាមួយគ្នា។ ប្រសិនបើមិនមានហែ សៀវភៅព្រះគម្ពីរដំណឹងល្អទេ (ខុសពីសៀវភៅអត្ថបទទីមួយ និងទីពីរ) ក្នុងពេលហែត្រូវ ដាក់សៀវភៅព្រះគម្ពីរនេះ នៅលើតុសក្ការបូជា។

១១៨. លើសពីនេះត្រូវរៀបចំ ៖

ក)ត្រូវមានសៀវភៅក្បួនពិធីបុណ្យជិតកៅអីលោកបូជាចារ្យ និងសៀវភៅចម្រៀង បើត្រូវការ។

ខ)ត្រូវដាក់សៀវភៅអត្ថបទព្រះគម្ពីរលើតុព្រះបន្ទូល។

គ)នៅលើតុតង្វាយ ត្រូវមានពែងព្រះលោហិត កម្រាលពិសិដ្ឋ និងកន្សែងជូតពែងព្រះលោហិត គម្របពែងព្រះលោហិត ចានព្រះកាយ ក្លងតម្កល់ព្រះកាយបើសិនជាត្រូវការ នំតង្វាយសម្រាប់លោកបូជាចារ្យ លោកឧបដ្ឋាក អ្នកបម្រើពិធីបុណ្យ និងគ្រីស្តបរិស័ទដែលទទួលព្រះកាយព្រះគ្រីស្ត។ ត្រូវរៀបចំពែងស្រាតង្វាយ និងពែងទឹក លើកលែងតែគ្រីស្តបរិស័ទយកសម្ភារៈទាំងនេះ ពេលហែតង្វាយ។ ត្រូវរៀបចំផ្តិលទឹកព្រះពរ បើសិនជាមានពិធីបាចទឹកព្រះពរ ចានទ្រ និងសម្ភារៈឯទៀតៗដែលត្រូវការសម្រាប់ពិធីលាងដៃរបស់លោកបូជាចារ្យ (ផ្តិលលាងដៃ កន្សែងជូតសម្អាត)។

គួរមានទម្លាប់ល្អប្រសើរ គឺត្រូវយកក្រណាត់ពណ៌ស ឬពណ៌តាមរដូវពិធីបុណ្យគ្របលើពែងព្រះលោហិត។

១១៩. នៅបន្ទប់លោកបូជាចារ្យផ្លាស់ប្តូរសម្លៀកបំពាក់ ត្រូវរៀបចំសម្លៀកបំពាក់ពិសិដ្ឋ សម្រាប់លោកបូជាចារ្យ លោកឧបដ្ឋាក និងអ្នកបម្រើពិធីបុណ្យ (សូមមើលលេខ ៣៣៧-៣៤១)។

ក)សម្រាប់លោកបូជាចារ្យ អាវសវែង កន្សែងបង់កពិសិដ្ឋ អាវពិសិដ្ឋ។

ខ)សម្រាប់លោកឧបដ្ឋាក អាវសវែង កន្សែងបង់កពិសិដ្ឋ អាវពិសិដ្ឋសម្រាប់លោកឧបដ្ឋាក។ ដោយមានមូលហេតុត្រឹមត្រូវ ឬដោយសារពិធីមិនសូវឱឡារិក លោកឧបដ្ឋាកមិនពាក់អាវពិសិដ្ឋក៏បាន ។

គ)សម្រាប់អ្នកបម្រើពិធីបុណ្យ អាវវែងពណ៌ស ឬខោអាវផ្សេងដែលបានទទួលសេចក្តីអនុញ្ញាត។[110]

អ្នកបម្រើពិធីបុណ្យទាំងអស់ពាក់អាវវែងពណ៌ស ត្រូវមានខ្សែចងចង្កេះ លើកលែងតែករណីដែលអាវវែងពណ៌សខ្លះ វាមិនត្រូវការខ្សែចងចង្កេះ។

[110] Cf. Interdicasterial Instruction on certain questions regarding the collaboration of the non- ordained faithful in the sacred ministry of priests, *Ecclesiae de mysterio*, 15 August 1997, art. 6: AAS 89 (1997), p. 869.

បើសិនជាមានពិធីហែពេលចូល ត្រូវរៀបចំសៀវភៅព្រះគម្ពីរដំណឹងល្អនៅថ្ងៃអាទិត្យ និងថ្ងៃបុណ្យពិសេស។ ត្រូវរៀបចំចង្រ្កានកំញាន ចានដាក់កំញាន និងកំញាន ប្រសិនបើចង់ប្រើ។ ព្រះឈើឆ្កាងសម្រាប់ហែពេលចូល និងទៀនដែលកំពុងឆេះ។

### ៨) ពិធីអភិបូជាដោយគ្មានលោកឧបដ្ឋាក

### ពិធីប្រារព្ធ

១២០. ពេលគ្រីស្តបរិស័ទចូលក្នុងព្រះវិហារហើយ លោកបូជាចារ្យ និងអ្នកបម្រើពិធីបុណ្យដែលស្លៀកសម្លៀកបំពាក់ពិសិដ្ឋ ហែចូលដល់គុសក្ការបូជាតាមរបៀបដូចតទៅ៖

ក)អ្នកបម្រើកាន់ចង្រ្កានកំញាន ដោយមានកំញានកំពុងឆេះ បើសិនជាប្រើកំញាន។

ខ)អ្នកបម្រើគុសក្ការបូជា ឬអ្នកបម្រើពិធីបុណ្យដែលកាន់ព្រះឈើឆ្កាង និងអ្នកបម្រើដែលកាន់ទៀន។

គ)អ្នកបម្រើគុសក្ការបូជា និងអ្នកបម្រើឯទៀតៗ។

ឃ)អ្នកប្រកាសព្រះបន្ទូល កាន់សៀវភៅអត្ថបទព្រះគម្ពីរដំណឹងល្អ ដោយលើកឡើងខ្ពស់បន្តិច (ប៉ុន្តែមិនអាចយកសៀវភៅព្រះគម្ពីរផ្សេង)។

ង)លោកបូជាចារ្យដែលធ្វើជាអធិបតីនៃពិធីអភិបូជា។ បើសិនជាប្រើកំញាន មុនពេលហែចូល លោកបូជាចារ្យដាក់កំញានក្នុងចង្រ្កានកំញាន ក្រោយមក ប្រទានពរដោយគូសសញ្ញាឈើឆ្កាង ប៉ុន្តែគ្មានប្រសាសន៍ទេ។

១២១. ពេលកំពុងហែទៅដល់គុសក្ការបូជា អង្គប្រជុំច្រៀងបទចម្រៀងពេលចូល (សូមមើលលេខ ៤៧-៤៨)។

១២២. ពេលទៅដល់គុសក្ការបូជា លោកបូជាចារ្យ និងអ្នកបម្រើឱនកាយគោរព។ លោកយកព្រះឈើឆ្កាងដែលមានភ្ជាប់រូបព្រះយេស៊ូ (ដែលហែក្នុងពេលចូល) តម្កល់នៅជិតគុសក្ការបូជា។ បើមានព្រះឈើឆ្កាងស្រាប់ក្នុងព្រះវិហារ ត្រូវទុកព្រះឈើឆ្កាងដែលហែមក នៅកន្លែងផ្សេង។ គួរតែដាក់ជើងទៀននៅលើគុសក្ការបូជា ឬនៅជិត។ ត្រូវដាក់សៀវភៅព្រះគម្ពីរដំណឹងល្អ នៅលើគុសក្ការបូជា។

១២៣. ក្រោយមក លោកបូជាចារ្យថើបគុសក្ការបូជាដើម្បីបង្ហាញការគោរព។ បើសិនជាប្រើកំញាន លោកបូជាចារ្យគោរពព្រះឈើឆ្កាងដោយបក់ផ្សែងកំញាន ក្រោយមកលោកឱនគោរពគុសក្ការបូជា ហើយដើរព័ទ្ធជុំវិញគុដោយបក់ផ្សែងកំញាន។

១២៤. រួចហើយ លោកបូជាចារ្យដើរទៅកន្លែងអង្គុយរបស់លោក។ ពេលច្រៀងបទចូលចប់ លោកបូជាចារ្យ និងអង្គប្រជុំ នៅឈរគូសសញ្ញាឈើឆ្កាង។ លោកបូជាចារ្យពោលថា៖ ក្នុងព្រះនាមព្រះបិតា និងព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ អង្គប្រជុំឆ្លើយ៖ អាម៉ែន។

លោកឈរនៅខាងមុខអង្គប្រជុំ ហើយលាតដៃស្វាគមន៍គ្រីស្តបរិស័ទ ដោយពោលពាក្យដែលមានស្រាប់ក្នុងក្បួនពិធី។ លោកបូជាចារ្យ ឬអ្នកបម្រើពិធីបុណ្យណែនាំអភិបូជាប្រចាំថ្ងៃនោះដល់អង្គប្រជុំ។

១២៥. ពិធីសូមទទួលសារភាព បន្ទាប់មក ច្រៀង ឬសូត្រ ឱ ព្រះអម្ចាស់អើយ! សូមអាណិតអាសូរ (Kyrie) ដោយធ្វើតាមពាក្យណែនាំពណ៌ក្រហម (សូមមើលលេខ ៥២)។

១២៦. ច្រៀង ឬសូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (បើត្រូវសូត្រ) (សូមមើលលេខ ៥៣។

១២៧. លោកបូជាចារ្យលើកដៃប្រណម្យ ហើយអញ្ជើញអង្គប្រជុំអធិដ្ឋាន៖ សូមបងប្អូនតាំងចិត្តអធិដ្ឋាន អង្គប្រជុំអធិដ្ឋានរួមជាមួយលោកបូជាចារ្យ ដោយរក្សាភាពស្ងៀមស្ងាត់មួយរយៈខ្លី។ ហើយលោកបូជាចារ្យលាតដៃ ពោលពាក្យអធិដ្ឋានសរុប។ ទីបញ្ចប់អង្គប្រជុំឆ្លើយ៖ អាម៉ែន។

### ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់

១២៨. ក្រោយពីពាក្យអធិដ្ឋានសរុប អង្គប្រជុំអង្គុយចុះ។ លោកបូជាចារ្យអាចពន្យល់អត្ថន័យនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ប្រចាំថ្ងៃនោះ។ ក្រោយមក អ្នកប្រកាសព្រះបន្ទូលដើរសំដៅទៅគុព្រះបន្ទូល ហើយប្រកាសអត្ថបទទីមួយ ក្នុងសៀវភៅអត្ថបទព្រះគម្ពីរសម្រាប់អភិបូជា។ អានអត្ថបទរួចហើយ អ្នកប្រកាសព្រះបន្ទូលពោលថា៖ "នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់" អង្គប្រជុំឆ្លើយ៖ "សូមអរព្រះគុណព្រះជាម្ចាស់"។ បន្ទាប់មកស្ងៀមស្ងាត់បន្តិច ដើម្បីជួយឲ្យគ្រីស្តបរិស័ទសញ្ជឹងគិតអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលគេបានស្ដាប់។

១២៩. ក្រោយមក អ្នកស្មូតទំនុកតម្កើង ឬអ្នកប្រកាសព្រះបន្ទូល សូត្រទំនុកតម្កើង ហើយអង្គប្រជុំឆ្លើយដោយស្មូត ឬសូត្របន្ទរ។

១៣០. បើសិនជាមានអត្ថបទទីពីរ អ្នកប្រកាសព្រះបន្ទូលអានអត្ថបទត្រង់គុព្រះបន្ទូល។ អង្គប្រជុំស្ដាប់ បន្ទាប់មកឆ្លើយ (សូមមើលលេខ ១២៨)។ ក្រោយមកស្ងៀមស្ងាត់បន្តិចដើម្បីជួយឲ្យគ្រីស្តបរិស័ទសញ្ជឹងគិត អំពីព្រះបន្ទូលដែលគេបានស្ដាប់។

១៣១. បន្ទាប់មក អង្គប្រជុំក្រោកឈរឡើងច្រៀងអាលេលូយ៉ា ឬបទចម្រៀងផ្សេងតាមរដូវពិធីបុណ្យ (សូមមើលលេខ ៦២-៦៤)។

១៣២. បើសិនជាដុតកំញាន ពេលច្រៀង "អាលេលូយ៉ា" ឬបទចម្រៀងផ្សេង លោកបូជាចារ្យដាក់កំញានក្នុងចង្រ្កានកំញាន ហើយប្រទានពរ។ លោកលើកដៃប្រណម្យឱនកាយខាងមុខគុសក្ការបូជា ដោយពោលខ្សឹបៗថា៖ បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ! សូមមេត្តាជម្រះចិត្តគំនិត និងបបូរមាត់ខ្ញុំ ដើម្បីប្រកាសព្រះបន្ទូលដំណឹងល្អដោយសមរម្យ (Munda cor meum)។

១៣៣. បើសិនជាសៀវភៅព្រះបន្ទូលដំណឹងល្អនៅលើតុសក្ការបូជា លោកបូជាចារ្យត្រូវយកមកកាន់ដោយលើកឡើងបន្តិច ហើយដើរទៅតុព្រះបន្ទូល ដោយមានអ្នកបម្រើពិធីបុណ្យដែលកាន់ចង្ក្រានកំញាន និងទៀនដើរពីមុខ។ អង្គប្រជុំបែរខ្លួនទៅរកតុព្រះបន្ទូលជាសញ្ញាបញ្ជាក់អំពីការគោរព ព្រះបន្ទូលដំណឹងល្អរបស់ព្រះយេស៊ូគ្រីស្ត។

១៣៤. នៅតុព្រះបន្ទូល លោកបូជាចារ្យបើកសៀវភៅ ហើយលើកដៃប្រណម្យទាំងពោលថា៖ "សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន" អង្គប្រជុំឆ្លើយ "ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង"។ លោកក៏ពោលបន្តថា៖ "សូមថ្លែងព្រះគម្ពីរដំណឹងល្អ" ដោយយកមេដៃគូសសញ្ញាឈើឆ្កាងលើសៀវភៅ លើថ្ងាស លើមាត់ លើទ្រូងរបស់លោក។ អង្គប្រជុំក៏ធ្វើដូចគ្នាដែរ ដោយប្រកាសថា "សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអម្ចាស់"។ បើសិនជាប្រើកំញានលោកបក់ផ្សែងកំញានទៅរកសៀវភៅព្រះគម្ពីរដំណឹងល្អ (សូមមើលលេខ ២៧៦-២៧៧)។ ក្រោយមក លោកប្រកាសព្រះបន្ទូលដំណឹងល្អ ហើយនៅចុងបញ្ចប់ពោលថា "នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់"។ អង្គប្រជុំឆ្លើយ "សូមកោតសរសើរព្រះអម្ចាស់យេស៊ូគ្រីស្ត"។ លោកបូជាចារ្យថើបសៀវភៅ ពោលខ្សឹបៗថា "សូមឲ្យព្រះបន្ទូលដំណឹងល្អនេះ..." (Per evangelica dicta)។

១៣៥. បើគ្មានអ្នកប្រកាសព្រះបន្ទូល លោកបូជាចារ្យផ្ទាល់ប្រកាសអត្ថបទទាំងអស់ និងទំនុកតម្កើងដោយឈរនៅត្រង់តុព្រះបន្ទូល។ ប្រសិនបើប្រើកំញាន នៅត្រង់តុព្រះបន្ទូល លោកបូជាចារ្យដាក់កំញានខ្លះក្នុងចង្ក្រានកំញានប្រទានពរ ឱនកាយពោលថា៖ "សូមមេត្តាជម្រះចិត្តគំនិតរបស់ខ្ញុំ" (Munda cor meum)។

១៣៦. លោកបូជាចារ្យធ្វើធម្មទេសនា នៅកន្លែងអង្គុយ ឬនៅតុព្រះបន្ទូល ឬនៅកន្លែងផ្សេងទៀត។ គួរស្ងៀមស្ងាត់មួយរយៈខ្លីក្រោយពីធម្មទេសនាចប់។

១៣៧. លោកបូជាចារ្យរួមជាមួយអង្គប្រជុំឈរឡើងដើម្បីប្រកាសជំនឿ (សូមមើលលេខ ៦៨)។ ពេលដល់ត្រង់ពាក្យ "ព្រះអង្គមានកំណើតជាមនុស្ស ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ..." (et incarnates est) អង្គប្រជុំឱនកាយបន្តិច។ ប៉ុន្តែថ្ងៃបុណ្យយ៉ាងឱឡារិក បុណ្យរំលឹកពីទេវទូតជូនដំណឹងអំពីកំណើតព្រះអម្ចាស់យេស៊ូ អង្គប្រជុំត្រូវលុតជង្គង់។

១៣៨. សូត្រធម៌ប្រកាសជំនឿចប់ លោកបូជាចារ្យឈរលើកដៃប្រណម្យ ហើយអញ្ជើញអង្គប្រជុំអធិដ្ឋានពាក្យអង្វរសកល។ ក្រោយមកអ្នកចម្រៀង អ្នកប្រកាសព្រះបន្ទូល ឬម្នាក់ផ្សេងទៀតអធិដ្ឋានពាក្យទូលអង្វរសកលនៅត្រង់តុព្រះបន្ទូល ឬកន្លែងគួរសមផ្សេងទៀត នៅខាងមុខអង្គប្រជុំដោយពោលពាក្យបន្ទរជាមួយគ្នា។ ក្រោយពីអធិដ្ឋានពាក្យអង្វរសកល លោកបូជាចារ្យលាតដៃ ហើយអធិដ្ឋានបញ្ចប់។

### ពិធីអរព្រះគុណដ៏វិសុទ្ធ

១៣៩. ពេលអធិដ្ឋានពាក្យអង្វរសកលចប់ អង្គប្រជុំអង្គុយចុះ ហើយចាប់ផ្តើមច្រៀងចម្រៀងថ្វាយតង្វាយ (សូមមើលលេខ ៧៤)។ អ្នកបម្រើគុសក្ការបូជា ឬអ្នកបម្រើពិធីបុណ្យរៀបចំកម្រាលពិសិដ្ឋ កន្សែងជូតពែងព្រះលោហិត ពែងព្រះលោហិត គម្របពែងព្រះលោហិត និងសៀវភៅក្បួនពិធីបុណ្យដាក់នៅលើគុសក្ការបូជា។

១៤០. ក្នុងពិធីថ្វាយតង្វាយគួរចូលរួមក្នុងពិធីថ្វាយតង្វាយ ដោយនំតង្វាយ និងស្រាសម្រាប់ពិធីអភិបូជា ឬអំណោយផ្សេងៗទៀត សម្រាប់ជួយព្រះសហគមន៍ និងអ្នកក្រីក្រ។ លោកបូជាចារ្យ (ដោយមានអ្នកបម្រើគុសក្ការបូជា និងអ្នកបម្រើពិធីបុណ្យមកជួយផង) ទទួលតង្វាយពីគ្រីស្តបរិស័ទ។ លោកដែលជាធិបតីក្នុងពិធីអភិបូជាទទួលនំ និងស្រាតង្វាយសម្រាប់ពិធីអភិបូជា ហើយលោកដាក់តង្វាយនេះលើគុសក្ការបូជា។ រីឯតង្វាយឯទៀតៗ គេដាក់នៅកន្លែងផ្សេងដែលគួរសម (សូមមើលលេខ ៧៣)។

១៤១. នៅលើគុសក្ការបូជា លោកបូជាចារ្យទទួលចានព្រះកាយជាមួយនំតង្វាយ។ លោកកាន់នំតង្វាយលើចានព្រះកាយ ដៃទាំងពីរលើកឡើងពោលខ្សឹបៗថា "បពិត្រព្រះអម្ចាស់ជាព្រះបិតា សូមព្រះអង្គប្រោសប្រទាន..." (Benedictus es, Domine) ក្រោយមក លោកដាក់ចានព្រះកាយ និងនំតង្វាយលើកម្រាលពិសិដ្ឋ។

១៤២. បន្ទាប់មក អ្នកបម្រើពិធីបុណ្យយកពែងព្រះលោហិតជូនលោកបូជាចារ្យ លោកចាក់ស្រាតង្វាយ និងចាក់ទឹកបន្តិច ចូលក្នុងពែងព្រះលោហិត ដោយពោលខ្សឹបៗថា "ដូចទឹកលាយជាមួយស្រានេះ..." (Per huius aquae)។ លោកលើកពែងព្រះលោហិតឡើងដៃទាំងពីរពោលខ្សឹបៗថា "បពិត្រព្រះបិតាជាអម្ចាស់ សូមព្រះអង្គប្រោសឲ្យ..." (Benedictus es, Domine)។ ក្រោយមកលោកដាក់ពែងព្រះលោហិតលើកម្រាលពិសិដ្ឋ និងយកគម្របពែងពិសិដ្ឋគ្របពីលើ។ បើសិនជាគ្មានបទចម្រៀងថ្វាយតង្វាយ គេមិនលេងអកហ្គ ហើយលោកបូជាចារ្យពោលពាក្យខាងលើដោយសំឡេងខ្លាំងៗ។ អង្គប្រជុំឆ្លើយ "សូមសរសើរតម្កើងព្រះអង្គអស់កល្បជាអង្វែងតរៀងទៅ"។

១៤៣. ក្រោយពីដាក់ពែងព្រះលោហិតលើគុសក្ការបូជា លោកបូជាចារ្យលំទោនកាយ ហើយពោលខ្សឹបៗថា "ឱ ព្រះអម្ចាស់អើយ! សូមទទួលអង្វរព្រះអង្គ សូមឲ្យព្រះវិញ្ញាណដ៏វិសុទ្ធ..." (In spiritu humilitatis)។

១៤៤. ប្រសិនបើប្រើកំញាន លោកដាក់កំញានក្នុងចង្រ្កានកំញាន ហើយប្រទានពរ រួចបក់ផ្សែងកំញានពីលើតង្វាយ ឈើឆ្កាង និងគុសក្ការបូជា។ អ្នកបម្រើពិធីបុណ្យម្នាក់បក់ផ្សែងកំញានតម្រង់ទៅរកលោកបូជាចារ្យ និងគ្រីស្តបរិស័ទ។

១៤៥. បន្ទាប់មក អធិដ្ឋាន "ឱ ព្រះអម្ចាស់អើយ! យើងខ្ញុំទូលអង្វរព្រះអង្គ សូមឲ្យព្រះវិញ្ញាណដ៏វិសុទ្ធ..." (In spiritu humilitatis) ឬក្រោយពីបក់ផ្សែងកំញាន លោកបូជាចារ្យលាងដៃនៅចំហៀងតុសក្ការបូជា។ ពេលអ្នកបម្រើពិធីបុណ្យចាក់ទឹក លោកពោលខ្សឹបៗថា "ឱ ព្រះអម្ចាស់អើយ! សូមលុបលាងកំហុសរបស់ខ្ញុំ (Lava me, Domine)។

១៤៦. លោកបូជាចារ្យត្រឡប់មកឈរនៅក្រោយតុសក្ការបូជា បែរមុខទៅរកអង្គប្រជុំ លោកលាតដៃប្រណម្យទាំងពោលថា "សូមបងប្អូនតាំងចិត្តអធិដ្ឋាន" (Orate, fraters)។ អង្គប្រជុំក្រោកឈរឡើងហើយឆ្លើយថា "សូមព្រះអម្ចាស់ទទួលសក្ការបូជានេះ..."។ ក្រោយមក លោកបូជាចារ្យលាតដៃដោយពោលពាក្យថ្វាយតង្វាយ។ អង្គប្រជុំឆ្លើយ "អាម៉ែន"។

១៤៧. បន្ទាប់មក លោកបូជាចារ្យចាប់ផ្តើមសូត្រធម៌អរព្រះគុណដ៏វិសុទ្ធ។ តាមពាក្យណែនាំពណ៌ក្រហម (សូមមើលលេខ ៣៦៥) លោកជ្រើសរើសធម៌អរព្រះគុណដ៏វិសុទ្ធ ដែលមានស្រាប់ក្នុងក្បួនពិធីបុណ្យ ឬមួយណាដែលបានទទួលសេចក្តីអនុញ្ញាតពីសន្តអាសនៈ។ មានតែលោកបូជាចារ្យប៉ុណ្ណោះ អាចសូត្រធម៌អរព្រះគុណដ៏វិសុទ្ធ តាមអគ្គសញ្ញាតែងតាំងរបស់លោក។ ចំណែកឯអង្គប្រជុំវិញ ចូលរួមជាមួយលោកដោយជំនឿ និងស្ងៀមស្ងាត់ ព្រមទាំងឆ្លើយបន្ទរក្នុងធម៌អរព្រះគុណដ៏វិសុទ្ធ គឺឆ្លើយនៅក្នុងធម៌ប្រារព្ធជាពាក្យកោតសរសើរ "ព្រះដ៏វិសុទ្ធ" ពាក្យអបអរសាទរ ក្រោយពីពិធីប្រសិទ្ធលើនំ និងស្រាតង្វាយ ពាក្យ "អាម៉ែន" ក្រោយមក ពាក្យលើកតម្កើងដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត... ព្រមទាំងពាក្យអបអរសាទរឯទៀតៗដែលបានទទួលសេចក្តីអនុញ្ញាតពីមហាសន្និបាតលោកអភិបាល ដែលសន្តអាសនៈបានទទួលស្គាល់។

ជាការគួរណាស់ បើលោកបូជាចារ្យច្រៀង ផ្នែកខ្លះនៃធម៌អរព្រះគុណដ៏វិសុទ្ធដែលមានអក្សរភ្លេងស្រាប់។

១៤៨. ពេលលោកបូជាចារ្យផ្តើមសូត្រធម៌អរព្រះគុណដ៏វិសុទ្ធ លោកលាតដៃ ច្រៀង ឬពោលថា "សូមព្រះអម្ចាស់គង់ជាមួយបងប្អូន"។ អង្គប្រជុំឆ្លើយ "ហើយគង់នៅជាមួយវិញ្ញារបស់លោកផង"។ លោកលាតដៃពោលបន្ត "សូមលើកចិត្តថ្វាយព្រះអង្គ"។ អង្គប្រជុំឆ្លើយ "យើងលើកចិត្តថ្វាយព្រះអង្គហើយ"។ លោកលាតដៃពោលបន្ត "សូមអរព្រះគុណព្រះអម្ចាស់" ហើយអង្គប្រជុំឆ្លើយ "ពិតជាការគួរណាស់ហើយប្រពៃផង"។ បន្ទាប់មក លោកបូជាចារ្យលាតដៃប្រណម្យបន្តសូត្រធម៌ប្រារព្ធ។ នៅទីបញ្ចប់នៃធម៌ប្រារព្ធ លោកលើកដៃប្រណម្យ រួមជាមួយអង្គប្រជុំច្រៀង ឬសូត្រពាក្យកោតសរសើរ ព្រះដ៏វិសុទ្ធ (សូមមើលលេខ ៧៩ ខ)។

១៤៩. លោកបូជាចារ្យបន្តធម៌អរព្រះគុណដ៏វិសុទ្ធ តាមពាក្យណែនាំពណ៌ក្រហម។ បើសិនជាលោកអភិបាលជាអធិបតី បន្ទាប់ពីពាក្យអធិដ្ឋានឲ្យសម្តេចប៉ាបព្រះនាម...លោកបន្ថែម "ហើយខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គ.."។ ប្រសិនបើ លោកអភិបាលថ្វាយអភិបូជានៅកន្លែងផ្សេង

ក្រៅពីភូមិភាគរបស់លោក ក្រោយពីពាក្យសម្តេចប៉ាបព្រះនាម..លោកបន្ថែម "ខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គ និងលោក...ជាលោកអភិបាលនៃភូមិភាគនេះ"។ ត្រូវអធិដ្ឋានឲ្យលោកអភិបាលភូមិភាគ ឬលោកណាម្នាក់ ដែលតាមច្បាប់មានឋានៈស្មើនឹងលោក។ ត្រូវប្រើពាក្យនេះ "រួមជាមួយសម្តេចប៉ាបព្រះនាម ... លោកនាម... ជាអភិបាលព្រះសហគមន៍" អាចហៅឈ្មោះលោកអភិបាលជំនួសបាន ប៉ុន្តែមិនចាំបាច់ហៅឈ្មោះលោកអភិបាលផ្សេងៗ ដែលចូលរួមថ្វាយអភិបូជានោះទេ។ ពេលណាដែលត្រូវហៅឈ្មោះលោកអភិបាលដែលមានចំនួនច្រើនត្រូវប្រើពាក្យ "លោកនាម...ជាអភិបាលព្រះសហគមន៍យើងខ្ញុំ និងលោកអភិបាលទាំងអស់"។ ត្រូវរៀបរាប់តាមលំដាប់លំដោយ ដូចមានចែងនៅក្នុងក្បួន។

១៥០. មុនពិធីប្រសិទ្ធលើនំ និងស្រាតង្វាយ អ្នកបម្រើម្នាក់គោះកណ្តឹងជាសញ្ញាសម្គាល់ សម្រាប់គ្រីស្តបរិស័ទ។ តាមទម្លាប់កន្លែងខ្លះ អ្នកបម្រើក៏គោះកណ្តឹងទៀត ពេលលោកបូជាចារ្យលើកបង្ហាញព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។ បើសិនជាប្រើកំញាន ពេលលោកបូជាចារ្យលើកបង្ហាញព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត (ក្រោយពីពិធីប្រសិទ្ធលើនំ និងស្រាតង្វាយ) អ្នកបម្រើគោរពដោយបក់ផ្សែងកំញាន។

១៥១. បន្ទាប់ពីប្រសិទ្ធពរលើនំ និងស្រាតង្វាយ លោកបូជាចារ្យពោលថា "នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ" គ្រីស្តបរិស័ទច្រៀង ឬសូត្រតាមក្បួនពិធីមួយដែលមានស្រាប់ហើយ។

ទីបញ្ចប់នៃធម៌អរព្រះគុណដ៏វិសុទ្ធ លោកបូជាចារ្យយកចានដែលមានព្រះកាយ និងពែងដែលមានព្រះលោហិត ហើយលើកឡើងដោយដៃទាំងពីរ ទាំងច្រៀង ឬសូត្រពាក្យកោតសរសើរ "គឺដោយព្រះគ្រីស្ត..."។ ចុងបញ្ចប់អង្គប្រជុំឆ្លើយ "អាម៉ែន"។ ក្រោយមក លោកបូជាចារ្យដាក់ចានព្រះកាយ និងពែងព្រះលោហិតលើកម្រាលពិសិដ្ឋ។

១៥២. ក្រោយពីធម៌អរព្រះគុណដ៏វិសុទ្ធ លោកបូជាចារ្យលើកដៃប្រណម្យ ហើយពោលពាក្យផ្តើមនៃធម៌ ឱ ព្រះបិតា។ លោកលាតដៃហើយសូត្រធម៌ ឱព្រះបិតាជាមួយគ្រីស្តបរិស័ទ។

១៥៣. បន្ទាប់ពីចប់ពាក្យអធិដ្ឋានរបស់ព្រះអម្ចាស់ លោកបូជាចារ្យលាតដៃប្រណម្យ ទាំងពោលថា បពិត្រព្រះអម្ចាស់! សូមប្រោសយើងខ្ញុំឲ្យរួចពីសេចក្តីអាក្រក់គ្រប់យ៉ាង (Libera nos) នៅពេលចប់ អង្គប្រជុំឆ្លើយ "ដ្បិតព្រះអង្គគ្រងរាជ្យ..."។

១៥៤. ក្រោយមក លោកបូជាចារ្យលាតដៃ ហើយពោលពាក្យអធិដ្ឋាន "ឱព្រះអម្ចាស់យេស៊ូគ្រីស្តអើយ! ព្រះអង្គមានព្រះបន្ទូលទៅកាន់ក្រុមគ្រីស្តទូតថា..." (Domine Iesu Christe, qui dixisti)។ ក្រោយពីពាក្យអធិដ្ឋាននេះ លោកលាតដៃ ហើយលើកដៃប្រណម្យទាំងពោលថា "សូមឲ្យសេចក្តីសុខសាន្តរបស់ព្រះអម្ចាស់គង់នៅជាមួយបងប្អូន"។ អង្គប្រជុំឆ្លើយ "ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង"។ បន្ទាប់មក ជាការគួរសម លោកបូជាចារ្យអញ្ជើញអង្គប្រជុំ "សូមបងប្អូនជូនសេចក្តីសុខសាន្តចំពោះគ្នាទៅវិញទៅមក"។

លោកបូជាចារ្យអាចជូនសេចក្តីសុខសាន្តដល់អ្នកបម្រើ ដែលស្ថិតនៅទីសក្ការបូជា ដោយមិនចាំបាច់ទៅកន្លែងផ្សេងៗនាំឲ្យរំខានពិធីនេះ។ តាមការសម្រេចរបស់លោកអភិបាល អង្គប្រជុំធ្វើកាយវិការមួយតាមប្រពៃណីក្នុងស្រុក ដើម្បីជូនសេចក្តីសុខសាន្ត ឯកភាព និងធម៌មេត្តា ករុណា។ ពេលអង្គប្រជុំបង្ហាញសញ្ញានៃសេចក្តីសុខសាន្តរវាងគ្នានឹងគ្នា ដោយម្នាក់ពោលថា "សូមឲ្យសេចក្តីសុខសាន្តរបស់ព្រះអម្ចាស់គង់នៅជាមួយបងប្អូន" ម្នាក់ទៀតឆ្លើយថា "អាម៉ែន"។

១៥៥. លោកបូជាចារ្យកាច់នំព្រះកាយពីលើចានព្រះកាយ យកចំណែកតូចមួយដាក់ក្នុងពែងព្រះលោហិត ទាំងពោលខ្សឹបៗថា "សូមឲ្យព្រះកាយ និងព្រះលោហិត..." (Haec commixtio)។ ក្នុងពេលដដែលនោះ អង្គប្រជុំច្រៀង ឬសូត្រ "ឱ កូនចៀមរបស់ព្រះជាម្ចាស់..." (Agnus Dei) (សូមមើលលេខ ៨៣)។

១៥៦. ក្រោយមក លោកបូជាចារ្យប្រណម្យដៃពោលខ្សឹបៗថា "បពិត្រព្រះអម្ចាស់យេស៊ូគ្រីស្ត! ជាព្រះបុត្រានៃព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ..." (Domine Iesu Christe, Fili Dei vivi) ឬ "បពិត្រព្រះអម្ចាស់យេស៊ូគ្រីស្ត! សូមប្រោសខ្ញុំដែលទទួលព្រះកាយ និងព្រះលោហិតរបស់ព្រះអង្គ" (Perceptio Corporis et Sanguinis tui)។

១៥៧. ពេលបញ្ចប់ពាក្យអធិដ្ឋាន លោកបូជាចារ្យលុតជង្គង់យកព្រះកាយដែលទើបបានប្រសិទ្ធពរក្នុងពិធីអភិបូជា ហើយលើកឡើងបន្តិចពីចានព្រះកាយ ឬពែងព្រះលោហិត នៅចំពោះមុខអង្គប្រជុំពោលថា "នេះជាកូនចៀមរបស់ព្រះជាម្ចាស់..." (Ecce Agnus Dei)។ រួមជាមួយអង្គប្រជុំលោកពោលថា "បពិត្រព្រះអម្ចាស់! ខ្ញុំមិនសមនឹងទទួលព្រះអង្គ..." ។

១៥៨. លោកបូជាចារ្យបែរមុខទៅរកតុសក្ការបូជា ទាំងពោលខ្សឹបៗថា "សូមព្រះកាយព្រះគ្រីស្តរក្សាខ្ញុំទុកក្នុងជីវិតអស់កល្បជានិច្ច" (Corpus Christi custodiat me in vitam aeternam) រួចលោកទទួលព្រះកាយព្រះគ្រីស្តដោយគោរព។ បន្ទាប់មក លោកកាន់ពែងព្រះលោហិតទាំងពោលខ្សឹបៗថា "សូមព្រះលោហិតព្រះគ្រីស្តរក្សាខ្ញុំទុកក្នុងជីវិតអស់កល្បជានិច្ច" (Sanguis Christi custodiat me in vitam aeternam) រួចលោកទទួលព្រះលោហិតព្រះគ្រីស្តដោយគោរព។

១៥៩. ពេលលោកកំពុងទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត អង្គប្រជុំចាប់ផ្តើមច្រៀងចម្រៀងទទួលព្រះកាយ (សូមមើលលេខ ៨៦)។

១៦០. លោកបូជាចារ្យកាន់ចានព្រះកាយ ឬក្លុងព្រះកាយរួចដើរទៅកាន់អ្នកទទួលព្រះកាយព្រះគ្រីស្ត។ តាមធម្មតា អង្គប្រជុំដើរទៅទទួលព្រះកាយព្រះគ្រីស្ត។

អង្គប្រជុំមិនអាចយកព្រះកាយ ឬកាន់ពែងព្រះលោហិតព្រះគ្រីស្តដោយខ្លួនឯងបានទេ ហើយក៏មិនអាចជូនព្រះកាយព្រះគ្រីស្តឲ្យគ្នាទៅវិញទៅមកបានដែរ។ អង្គប្រជុំទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ដោយឈរ ឬលុតជង្គង់។ យ៉ាងណាក៏ដោយត្រូវធ្វើកាយវិការមួយបង្ហាញពីការគោរពចំពោះព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។

១៦១. បើទទួលតែព្រះកាយព្រះគ្រីស្ត លោកបូជាចារ្យលើកព្រះកាយឡើងបន្តិច បង្ហាញឲ្យអ្នកទទួលព្រះកាយព្រះគ្រីស្តមើលឃើញ ទាំងពោលថា "ព្រះកាយព្រះគ្រីស្ត"។ អ្នកទទួលអគ្គសញ្ញាឆ្លើយថា "អាម៉ែន" ហើយទទួលព្រះកាយលើអណ្តាត ឬក្នុងដៃរបស់ខ្លួន។ ពេលទទួលព្រះកាយនិងព្រះលោហិតគ្រីស្តរួចហើយ ត្រូវបរិភោគអាហារដ៏សក្ការៈនេះភ្លាម តាមច្បាប់ពិធីបុណ្យអនុញ្ញាត។

បើសិនជាទទួលអគ្គសញ្ញាទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ត្រូវធ្វើដូចសេចក្តីពន្យល់លេខ ២៨៤-២៨៧។

១៦២. បើសិនជាមានលោកបូជាចារ្យម្នាក់ទៀត ដែលចូលរួមថ្វាយអភិបូជា លោកអាចជួយជូនព្រះកាយព្រះគ្រីស្តដល់គ្រីស្តបរិស័ទ។ បើសិនជាគ្មានលោកបូជាចារ្យផ្សេងទៀតទេ ហើយមានគ្រីស្តបរិស័ទច្រើនដែលមកទទួលអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត លោកបូជាចារ្យអាចហៅអ្នកបម្រើពិធីបុណ្យជួយលោក ដូចជាអ្នកបម្រើដែលទទួលការចាត់តាំង អ្នកបម្រើតុសក្ការបូជា ឬគ្រីស្តបរិស័ទដែលបានជ្រើសរើសជាមុន។[111] បើមានសេចក្តីត្រូវការចាំបាច់ លោកបូជាចារ្យអាចហៅគ្រីស្តបរិស័ទឯទៀតៗ ដើម្បីជួយលោកក្នុងឱកាសតែមួយនោះ។[112] អ្នកបម្រើទាំងនេះមិនអាចមកទីសក្ការបូជាមុនលោកបូជាចារ្យ ទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្តនោះទេ ពីព្រោះត្រូវទទួលចានព្រះកាយ ឬពែងដែលមានព្រះលោហិតពីលោកបូជាចារ្យ។

១៦៣. បន្ទាប់ពីគ្រីស្តបរិស័ទបានទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្តហើយ លោកបូជាចារ្យពិសាព្រះលោហិតព្រះគ្រីស្តទាំងអស់ដែលនៅសល់។ រីឯព្រះកាយព្រះគ្រីស្តដែលនៅសល់លោកបូជាចារ្យអាចពិសាទាំងអស់ ឬទុកព្រះកាយព្រះគ្រីស្តក្នុងព្រះពន្លា។ ពេលលោកបូជាចារ្យត្រឡប់មកតុសក្ការបូជាវិញ លោកប្រមូលកម្ទេចពីចានព្រះកាយ និងក្លងព្រះកាយចូលពែងព្រះលោហិត។ ពេលសម្អាតពែងព្រះលោហិត លោកពោលខ្សឹបៗថា "បពិត្រព្រះអម្ចាស់! សូមឲ្យយើងខ្ញុំទទួលដោយចិត្តបរិសុទ្ធនូវអ្វីដែលយើងខ្ញុំបានទទួលតាមមាត់..." (Quod ore sumpsimus)។ ក្រោយមក លោកយកកន្សែងជូតពែងព្រះលោហិត សម្អាតពែងព្រះលោហិត។ បើលោកសម្អាតចានព្រះកាយ និងពែងព្រះលោហិតលើតុសក្ការបូជា អ្នកបម្រើពិធីបុណ្យត្រូវដាក់ចានព្រះកាយ និងពែងព្រះលោហិតលើតុតង្វាយ។ ប្រសិនបើមានចានព្រះកាយ និងពែងព្រះលោហិតច្រើនដែលត្រូវសម្អាត លោកអាចទុកលើតុសក្ការបូជា ឬលើតុតង្វាយដោយយកកម្រាលពិសិដ្ឋគ្របពីលើ ហើយសម្អាតពេលអភិបូជាចប់។

១៦៤. រួចហើយ លោកបូជាចារ្យអាចត្រឡប់ទៅអង្គុយនៅកន្លែងចាប់ផ្តើមពិធីវិញ។ តាម កាលៈទេសៈ គ្រីស្តបរិស័ទអាចរក្សាភាពស្ងៀមស្ងាត់មួយរយៈខ្លី ឬស្មូតទំនុកតម្កើង ឬច្រៀងបទកោតសរសើរ ឬច្រៀងបទផ្សេងៗទៀត (សូមមើលលេខ ៨៨)។

[111] Cf. Sacred Congregation for the Sacraments and Divine Worship, Instruction *Inaestimabile donum*, 3 April 1980, no. 10: AAS 72 (1980), p. 336; Interdicasterial Instruction on certain questions regarding the collaboration of the non-ordained faithful in the sacred ministry of priests, *Ecclesiae de mysterio*, 15 August 1997, art. 8: AAS 89 (1997), p. 871.
[112] Cf. *below*, Appendix, Order of Commissioning a Minister to Distribute Holy Communion on a Single Occasion, p. 1253.

១៦៥. នៅមុខអង្គប្រជុំ ត្រង់កន្លែងចាប់ផ្ដើមពិធី ឬកន្លែងតុសក្ការបូជា លោកបូជាចារ្យលើកដៃប្រណម្យ ហើយពោលថា "សូមបងប្អូនតាំងចិត្តអធិដ្ឋាន" (Oremus)។ លោកលាតដៃ ពោលពាក្យអរព្រះគុណព្រះជាម្ចាស់។ គួររក្សាភាពស្ងៀមស្ងាត់មួយរយៈខ្លី មុនពាក្យអរព្រះគុណ។ ក្រោយពីពាក្យអរព្រះគុណ អង្គប្រជុំឆ្លើយ "អាម៉ែន"។

### ពិធីបញ្ចប់

១៦៦. ពេលពាក្យអរព្រះគុណចប់ មានសេចក្ដីប្រកាសខ្លីពីព័ត៌មានផ្សេងៗបើសិនជាមាន។

១៦៧. លោកបូជាចារ្យលាតដៃប្រណម្យ ពោលថា "សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន"។ អង្គប្រជុំឆ្លើយ "ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង"។ លោកដាក់ដៃឆ្វេងលើទ្រូង លើកដៃស្ដាំឡើងពោលថា "សូមព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ប្រទានព្រះពរដល់អស់បងប្អូន" ហើយលោកគូសសញ្ញាឈើឆ្កាងលើគ្រីស្តបរិស័ទទាំងអស់គ្នា ដោយពោលថា "ក្នុងព្រះនាម ព្រះបិតា និងព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ"។ អង្គប្រជុំឆ្លើយ "អាម៉ែន"។

មានថ្ងៃខ្លះ ឬឱកាសខ្លះដែលមានពិធីពិសេស លោកបូជាចារ្យអាចបន្ថែមពាក្យអធិដ្ឋានតាមពាក្យណែនាំពណ៌ក្រហម មុនពេលប្រទានពរបញ្ចប់។ បើលោកអភិបាលធ្វើជាអធិបតី លោកប្រទានពរលើគ្រីស្តបរិស័ទ ដោយគូសសញ្ញាឈើឆ្កាង៣ដងលើគ្រីស្តបរិស័ទ។[113]

១៦៨. ភ្លាមនោះ លោកលើកដៃប្រណម្យទាំងពោលថា "អភិបូជាចប់ហើយ ព្រះជាម្ចាស់ចាត់បងប្អូនឲ្យទៅ" (Ite, Missa est) អង្គប្រជុំឆ្លើយ "សូមអរព្រះគុណព្រះជាម្ចាស់"។

១៦៩. បន្ទាប់មក លោកបូជាចារ្យគោរពដោយថើបតុសក្ការបូជា។ ហើយបន្ទាប់ពីឱនកាយនៅមុខតុសក្ការបូជា លោកបូជាចារ្យរួមជាមួយអ្នកបម្រើពិធីចាកចេញ។

១៧០. បើសិនជានៅក្នុងពិធីបញ្ចប់នៃអភិបូជាមានសកម្មភាពពិធីបុណ្យមួយទៀត នោះពាក្យស្វាគមន៍ ពាក្យប្រទានពរត្រូវលប់ចោល ហើយមិនត្រូវបញ្ចូល។

### ខ.ពិធីអភិបូជាដោយមានលោកឧបដ្ឋាក

១៧១. ពេលលោកឧបដ្ឋាកចូលរួមថ្វាយអភិបូជា លោកត្រូវបំពេញមុខងាររបស់ខ្លួន ដោយពាក់អាវពិសិដ្ឋ។ តួនាទីលោកឧបដ្ឋាកគឺ៖

ក )ត្រូវជួយលោកបូជាចារ្យ និងស្ថិតនៅក្បែរលោក។

ខ )បម្រើតុសក្ការបូជាទាំងគោរពពែងព្រះលោហិត និងសៀវភៅក្បួនពិធីបុណ្យ។

គ )ប្រកាសព្រះបន្ទូលដំណឹងល្អ។ បើសិនជាលោកបូជាចារ្យអនុញ្ញាត លោកឧបដ្ឋាកអាច សម្ដែងធម្មទេសនា ( សូមមើលលេខ ៦៦ )។

ឃ )ណែនាំគ្រីស្តបរិស័ទដោយពន្យល់អំពីពិធីប្រចាំថ្ងៃ ហើយអធិដ្ឋានពាក្យអង្វរសកល។

ង )ជួយលោកបូជាចារ្យជូនព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យគ្រីស្តបរិស័ទ។ សម្អាតចានព្រះកាយ និងពែងព្រះលោហិត។

ច )ត្រូវបំពេញមុខងាររបស់អ្នកបម្រើពិធីបុណ្យ បើសិនជាគេអវត្តមាន។

[113] 113 Cf. Cérémonial des éveques, n. 1118-1121

## ពិធីប្រារព្ធ

១៧២. លោកឧបដ្ឋាកដើរខាងមុនលោកបូជាចារ្យទៅកាន់តុសក្ការបូជា ដោយលើកសៀវភៅព្រះគម្ពីរដំណឹងល្អឡើងបន្តិច ឬដើរនៅជិតលោកបូជាចារ្យក៏បានដែរ។

១៧៣. ពេលលោកឧបដ្ឋាកទៅដល់តុសក្ការបូជា បើសិនជាលោកកាន់សៀវភៅព្រះគម្ពីរដំណឹងល្អ លោកមិនឱនកាយខាងមុខតុសក្ការបូជាទេ គឺលោកដើរហូតដល់តុសក្ការបូជាតែម្តង។ លោកដាក់សៀវភៅព្រះគម្ពីរដំណឹងល្អលើតុសក្ការបូជា ក្រោយមក លោកគោរពដោយថើបតុសក្ការបូជា។ ប៉ុន្តែ បើលោកមិនកាន់សៀវភៅព្រះគម្ពីរដំណឹងល្អ លោកត្រូវឱនកាយជាមួយលោកបូជាចារ្យនៅខាងមុខតុសក្ការបូជា ហើយលោកគោរពដោយថើបតុសក្ការបូជាជាមួយលោកបូជាចារ្យ។ ចុងក្រោយ បើសិនជាប្រើកំញាន លោកជួយលោកបូជាចារ្យដាក់កំញានក្នុងចង្រ្កានកំញាន និងដុតកំញាន គោរពព្រះឈើឆ្កាង និងតុសក្ការបូជា។

១៧៤. ក្រោយមក រួមជាមួយលោកបូជាចារ្យ លោកឧបដ្ឋាកដើរទៅកាន់កន្លែងចាប់ផ្តើមពិធី ហើយអង្គុយនៅជិតលោកបូជាចារ្យ និងជួយលោកតាមសេចក្តីត្រូវការ។

## ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់

១៧៥. បើមានប្រើកំញាន លោកឧបដ្ឋាកជួយលោកបូជាចារ្យ ដាក់កំញានក្នុងចង្រ្កានកំញាន អង្គប្រជុំច្រៀង "អាលេលូយ៉ា" ឬបទចម្រៀងផ្សេង។ ក្រោយមក លោកឱនកាយនៅមុខលោកបូជាចារ្យ ហើយសូមលោកបូជាចារ្យប្រទានពរដល់លោក ទាំងពោលខ្សឹបៗថា "សូមលោកប្រទានពរឲ្យខ្ញុំ"។ លោកបូជាចារ្យប្រទានពរដល់លោកឧបដ្ឋាក ដោយពោលថា "សូមព្រះអម្ចាស់គង់សណ្ឋិតនៅក្នុងចិត្ត.."។ លោកឧបដ្ឋាកគូសសញ្ញាឈើឆ្កាងលើខ្លួន ហើយឆ្លើយថា "អាម៉ែន"។ លោកឱនកាយនៅមុខតុសក្ការបូជា លោកយកព្រះគម្ពីរដំណឹងល្អពីតុសក្ការបូជា ហើយដើរទៅកាន់តុព្រះបន្ទូលដោយលើកព្រះគម្ពីរដំណឹងល្អឡើងបន្តិច។ អ្នកបម្រើពិធីបុណ្យអមដំណើរលោក ដោយកាន់កំញាន និងទៀន។ លោកឧបដ្ឋាកលើកដៃប្រណម្យពោលថា "សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន" បន្ទាប់មក លោកពោលថា "សូមថ្លែងព្រះគម្ពីរដំណឹងល្អ" លោកគូសសញ្ញាឈើឆ្កាងលើសៀវភៅ ដោយប្រើមេដៃ ក្រោយមកលោកគូសសញ្ញាឈើឆ្កាងលើថ្ងាស បបូរមាត់ និងលើដើមទ្រូងរបស់លោក។ លោកបក់ផ្សែងកំញានទៅរកព្រះគម្ពីរដំណឹងល្អ ហើយប្រកាសព្រះបន្ទូល។ ពេលប្រកាសព្រះបន្ទូលចប់ហើយ លោកពោលថា "នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់" អង្គប្រជុំឆ្លើយ "សូមកោតសរសើរព្រះអម្ចាស់យេស៊ូគ្រីស្ត"។ លោកថើបព្រះគម្ពីរដំណឹងល្អ ដោយពោលថា "សូមឲ្យព្រះបន្ទូលដំណឹងល្អនេះ" (Per evangelica dicta) ហើយត្រឡប់ទៅអង្គុយនៅកន្លែងជិតលោកបូជាចារ្យ។ ពេលលោកអភិបាលធ្វើជាអធិបតី លោកឧបដ្ឋាកជូនសៀវភៅព្រះគម្ពីរដំណឹងល្អឲ្យលោកអភិបាលថើប ឬលោកថើបព្រះគម្ពីរដំណឹងល្អដោយខ្លួនឯង ទាំងពោលថា "សូមឲ្យព្រះបន្ទូលដំណឹងល្អនេះ" Per evangelica dicta។

ពេលប្រារព្ធពិធីយ៉ាងឱឡារិក តាមកាលៈទេសៈ លោកអភិបាលប្រើព្រះគម្ពីរដំណឹងល្អប្រទានពរដល់គ្រីស្តបរិស័ទចុងក្រោយ លោកឧបដ្ឋាកតម្កល់ព្រះគម្ពីរដំណឹងល្អនៅកន្លែងសមរម្យ។

១៧៦. ប្រសិនបើគ្មាននរណាអានអត្ថបទផ្សេងទៀត លោកឧបដ្ឋាកអាចអានបាន។

១៧៧. ក្រោយពីពាក្យផ្ដើមរបស់លោកបូជាចារ្យ តាមធម្មតា លោកឧបដ្ឋាកជាអ្នកប្រកាសពាក្យអង្វរសកលនៅត្រង់គុព្រះបន្ទូល។

**ពិធីអរព្រះគុណដ៏វិសុទ្ធ**

១៧៨. ក្រោយពីពាក្យអង្វរសកល លោកបូជាចារ្យអង្គុយនៅកន្លែងរបស់គាត់ ហើយលោកឧបដ្ឋាករៀបចំតុសក្ការបូជាដោយមានអ្នកបម្រើតុសក្ការបូជាជួយគាត់។ ប៉ុន្តែជាមុខងាររបស់លោកឧបដ្ឋាក រៀបចំចានព្រះកាយ និងពែងព្រះលោហិត។ គាត់ក៏ជួយលោកបូជាចារ្យទទួលតង្វាយផ្សេងៗរបស់គ្រីស្តបរិស័ទ។ គាត់ជូនលោកបូជាចារ្យ ចានពិសិដ្ឋជាមួយនំតង្វាយ។ គាត់ចាក់ស្រាតង្វាយ និងចាក់ទឹកបន្តិចចូលក្នុងពែងព្រះលោហិត ដោយពោលខ្សឹបៗថា "ដូចទឹកលាយជាមួយស្រានេះ" ហើយជូនពែងពិសិដ្ឋទៅលោកបូជាចារ្យ។ គាត់អាចរៀបចំពែងព្រះលោហិតលើតុតង្វាយក៏បានដែរ។ បើប្រើកំញាន លោកឧបដ្ឋាកជួយលោកបូជាចារ្យគោរពតង្វាយ ព្រះឈើឆ្កាង និងតុសក្ការបូជាជាមួយកំញាន។ ក្រោយមក លោកឧបដ្ឋាក ឬអ្នកបម្រើតុសក្ការបូជា ប្រើកំញានគោរព លោកបូជាចារ្យ និងគ្រីស្តបរិស័ទ។

១៧៩. ពេលធម៌អរព្រះគុណដ៏វិសុទ្ធ លោកឧបដ្ឋាកអង្គុយនៅជិតលោកបូជាចារ្យ ប៉ុន្តែនៅខាងក្រោយបន្តិច ដូច្នេះ បើលោកបូជាចារ្យត្រូវការលោកឧបដ្ឋាក លោកអាចជួយជាមួយ ពែងព្រះលោហិត ឬជាមួយសៀវភៅក្បួនពិធីបាន។ ធម្មតាលោកឧបដ្ឋាកលុតជង្គង់តាំងពីពាក្យអង្វរព្រះវិញ្ញាណរហូតដល់លោកបូជាចារ្យ បង្ហាញពែងដែលមានព្រះលោហិតព្រះគ្រីស្ត។ បើមានលោកឧបដ្ឋាកច្រើនចូលរួម ម្នាក់ដាក់កំញានក្នុងចង្រ្កានកំញាន និងគោរពនំព្រះកាយ និងពែងដែលមានព្រះលោហិតព្រះគ្រីស្ត ពេលលោកបូជាចារ្យបង្ហាញទាំងពីរឲ្យអង្គប្រជុំឃើញ។

១៨០. ចុងក្រោយនៃធម៌អរព្រះគុណដ៏វិសុទ្ធ៖ ឱព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ! លោកឧបដ្ឋាកឈរនៅជិតលោកបូជាចារ្យ ដោយលើកពែងដែលមានព្រះលោហិតព្រះគ្រីស្តឡើងបន្តិច រីឯលោកបូជាចារ្យវិញកាន់ចាននំព្រះកាយឡើងបន្តិច រហូតដល់អង្គប្រជុំឆ្លើយ អាម៉ែន។

១៨១. ក្រោយពីលោកបូជាចារ្យបានសូត្រពាក្យអធិដ្ឋាននៃសេចក្ដីសុខសាន្ត ហើយលោកពោលថា៖ សូមឲ្យសេចក្ដីសុខសាន្តរបស់ព្រះអម្ចាស់គង់នៅជាមួយបងប្អូន (Pax Domini sit semper vobiscum) ហើយអង្គប្រជុំឆ្លើយ៖ ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង (Et cum spiritu tuo) បើសិនជាការគួរសម លោកឧបដ្ឋាក អញ្ជើញគ្រីស្តបរិស័ទទាំងអស់ ជូនសញ្ញានៃសេចក្ដីសុខ

សាន្តចំពោះគ្នាទៅវិញទៅមក។ ខាងមុខគ្រីស្តបរិស័ទ លោកលើកដៃប្រណម្យទាំងពោលថា សូមបងប្អូនជូនសេចក្តីសុខសាន្ត ចំពោះគ្នាទៅវិញទៅមក (Offerte vobis pacem)។ ក្រោយមក លោកទទួលសញ្ញានៃសេចក្តីសុខសាន្តពីលោកបូជាចារ្យ ហើយលោកឧបដ្ឋាកជូនសញ្ញានោះ ដល់អ្នកបម្រើពិធីបុណ្យដែលនៅជិតគាត់។

១៨២. ក្រោយពីលោកបូជាចារ្យទទួលនំព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត លោកឧបដ្ឋាក ក៏ទទួលពីលោកបូជាចារ្យដែរ ហើយជួយលោកបូជាចារ្យជូនព្រះកាយព្រះគ្រីស្តដល់គ្រីស្តបរិស័ទ។ បើគ្រីស្តបរិស័ទទទួលទាំងព្រះកាយ ទាំងព្រះលោហិតព្រះគ្រីស្ត លោកឧបដ្ឋាកកាន់ពែងព្រះលោហិត ហើយអង្គប្រជុំទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត លោកឧបដ្ឋាកនៅ តុសក្ការបូជា ពិសាព្រះលោហិតដែលនៅសល់ក្នុងពែងព្រះលោហិត។ តាមកាលៈទេសៈ លោកបូជាចារ្យ ឬលោកឧបដ្ឋាកឯទៀតៗអាចជួយពិសាព្រះលោហិត ដែលនៅសល់។

១៨៣. ក្រោយពីអង្គប្រជុំទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត លោកឧបដ្ឋាកត្រឡប់មក តុសក្ការបូជា ជាមួយលោកបូជាចារ្យ ហើយប្រមូលកម្ទេចនំព្រះកាយ បើសិនជាមាន។ ក្រោយមកយកពែងព្រះលោហិតទៅដាក់លើតុតង្វាយដើម្បីសម្អាត។ រីឯលោកបូជាចារ្យវិញ លោកក៏ទៅអង្គុយនៅកន្លែងរបស់លោក។ លោកឧបដ្ឋាកទុកពែងព្រះលោហិតលើតុសក្ការបូជា ឬលើតុតង្វាយដោយគ្របជាមួយកម្រាលពិសិដ្ឋ ហើយសម្អាតពេលអភិបូជារួច។

**ពិធីបញ្ចប់**

១៨៤. ក្រោយពីពាក្យអធិដ្ឋាន លោកឧបដ្ឋាកអាចអានពត៌មានផ្សេងៗបើសិនជាមាន ហើយ បើសិនជាលោកបូជាចារ្យគ្មានបំណងចង់អានពត៌មាននោះខ្លួនឯងទេ។

១៨៥. ប្រសិនជាមានពាក្យអធិដ្ឋានលើអង្គប្រជុំ ឬមានការប្រទានពរយ៉ាងឱឡារិក លោកឧបដ្ឋាក ណែនាំគ្រីស្តបរិស័ទ "សូមឱនកាយទូលអង្វរព្រះជាម្ចាស់ប្រទានពរដល់បងប្អូន"។ ក្រោយពី លោកបូជាចារ្យប្រទានពរ លោកឧបដ្ឋាកលើកដៃប្រណម្យពោលថា "អភិបូជាចប់ហើយ ព្រះជាម្ចាស់ចាត់បងប្អូនឲ្យទៅ" (Ite, missa est)។

១៨៦. ក្រោយមក លោកបូជាចារ្យរួមជាមួយលោកឧបដ្ឋាក ថើបគោរពតុសក្ការបូជា ឱនកាយ ហើយដង្ហែចេញទៅទ្វារចូល។

**គ) មុខងាររបស់អ្នកបម្រើតុសក្ការបូជា**

១៨៧. មុខងារអ្នកបម្រើតុសក្ការបូជាមានច្រើនយ៉ាង ហើយជួនកាលត្រូវប្រព្រឹត្តមុខងារផ្សេងពីគ្នាក្នុងពេលតែមួយ។ ដូច្នេះ ត្រូវចែករំលែកមុខងារនេះ ក្នុងចំណោមអ្នកបម្រើតុសក្ការបូជាផ្សេងៗ។ ប្រសិនបើមានអ្នកបម្រើតុសក្ការបូជាតែមួយ លោកត្រូវការបំពេញមុខងារដែលសំខាន់ជាង ហើយមុខងារផ្សេងៗអាចចែករំលែក ក្នុងចំណោមអ្នកបម្រើផ្សេងទៀត។

## ពិធីប្រារព្ធ

១៨៨. ពេលហែទៅកាន់ទីសក្ការបូជា អ្នកបម្រើតុសក្ការបូជាកាន់ព្រះឈើឆ្កាង ដោយដើរនៅ ចំកណ្ដាលអ្នកបម្រើពីរនាក់ ដែលកាន់ទៀនកំពុងឆេះ។ ពេលទៅដល់តុសក្ការបូជា អ្នកបម្រើ តុសក្ការបូជា តម្កល់ព្រះឈើឆ្កាងនៅជិតតុសក្ការបូជា ដូច្នេះហើយ ក្លាយទៅជាព្រះឈើឆ្កាងនៃតុសក្ការបូជា។ ឬត្រូវតម្កល់ព្រះឈើឆ្កាងនៅកន្លែងកិត្តិយសមួយ។ ក្រោយមកលោកទៅអង្គុយនៅកន្លែងរបស់លោកនៅទីសក្ការបូជា។

១៨៩. អ្នកបម្រើតុសក្ការបូជាត្រូវការត្រៀមខ្លួនរហូត ដើម្បីជួយលោកឧបដ្ឋាក ឬលោកបូជាចារ្យ ដោយកាន់សៀវភៅក្បួនពិធី ឬជួយតាមរបៀបផ្សេងៗដែលលោកត្រូវការ។ ដូច្នេះហើយ អ្នកបម្រើតុសក្ការបូជា ត្រូវការអង្គុយនៅកន្លែងដែលស្រួលសម្រាប់បម្រើមុខងាររបស់គាត់ ឬស្រួលទៅកន្លែង លោកបូជាចារ្យអង្គុយ ឬស្រួលទៅដល់តុសក្ការបូជា។

## ពិធីអរព្រះគុណដ៏វិសុទ្ធ

១៩០. ពេលគ្មានលោកឧបដ្ឋាកចូលរួមថ្វាយអភិបូជា បន្ទាប់ពីពាក្យអង្វរសកល លោកបូជាចារ្យនៅកន្លែងរបស់លោក ហើយអ្នកបម្រើតុសក្ការបូជា រៀបចំកម្រាលពិសិដ្ឋ កន្សែងជូតពែងព្រះលោហិត និងគម្របពែងព្រះលោហិត និងសៀវភៅក្បួនពិធីលើតុសក្ការបូជា។ ក្រោយមកបើជាការចាំបាច់ អ្នកបម្រើតុសក្ការបូជាអាចជួយលោកបូជាចារ្យទទួលតង្វាយពីគ្រីស្តបរិស័ទ និងជូននំ និងស្រាតង្វាយទៅឲ្យលោកបូជាចារ្យ។ បើមានប្រើកំញាន អ្នកបម្រើតុសក្ការបូជាជូនចង្ក្រានកំញានឲ្យលោកបូជាចារ្យ និងជួយពេលណាដែលលោកបូជាចារ្យគោរពតង្វាយ ព្រះឈើឆ្កាង និងតុសក្ការបូជា ជាមួយផ្សែងកំញាន។ ក្រោយមក អ្នកបម្រើតុសក្ការបូជាគោរពលោកបូជាចារ្យ និងអង្គប្រជុំជាមួយផ្សែងកំញាន។

១៩១. អ្នកទទួលការចាត់តាំងបម្រើតុសក្ការបូជា បើមានការចាំបាច់ អាចជួយលោកបូជាចារ្យជូនព្រះកាយ និងព្រះលោហិតព្រះគ្រីស្តដល់គ្រីស្តបរិស័ទ។[114] បើអង្គប្រជុំទទួលទាំងព្រះកាយទាំងព្រះលោហិតព្រះគ្រីស្ត ហើយគ្មានលោកឧបដ្ឋាកចូលរួមអភិបូជា អ្នកបម្រើតុសក្ការបូជាអាចជូនពែងដែលមានព្រះលោហិតព្រះគ្រីស្តដល់គ្រីស្តបរិស័ទ បើសិនជាអង្គប្រជុំទទួលទាំងព្រះកាយ ទាំងព្រះលោហិតព្រះគ្រីស្ត ដោយជ្រលក់ព្រះកាយក្នុងព្រះលោហិតព្រះគ្រីស្ត។

១៩២. អ្នកទទួលការចាត់តាំងជាអ្នកបម្រើតុសក្ការបូជា អាចជួយលោកបូជារ្យ ឬលោកឧបដ្ឋាកសម្អាត និងរៀបចំចានព្រះកាយ និងពែងព្រះលោហិត។ ពេលគ្មានលោកឧបដ្ឋាកចូលរួមអភិបូជា អ្នកបម្រើដែលទទួលការចាត់តាំងជាអ្នកបម្រើតុសក្ការបូជា យកចានព្រះកាយ និង ពែងព្រះលោហិតទៅតុតង្វាយ ហើយជូតសម្អាត និងរៀបចំតាមរបៀបត្រឹមត្រូវ។

[114] Cf. *Caeremoniale Episcoporum, editio typica*, 1984, nos. 1118-1121. Cf. Paul VI, Apostolic Letter *Ministeria quaedam*, 15 August 1972: AAS 64 (1972), p. 106

១៩៣. ក្រោយពីពិធីអភិបូជា អ្នកបម្រើតុសក្ការបូជា និងអ្នកបម្រើឯទៀតៗ ដង្ហែត្រឡប់ទៅបន្ទប់លោកផ្លាស់ប្តូរសម្លៀកបំពាក់ រួមជាមួយលោកឧបដ្ឋាកនិងលោកបូជាចារ្យ តាមរបៀបដែលគេបានដង្ហែចូលពិធីដែរ។

### ឃ) មុខងាររបស់អ្នកប្រកាសព្រះបន្ទូល

#### ពិធីប្រារព្ធ

១៩៤. ក្នុងពេលហែឆ្ពោះទៅតុសក្ការបូជា ហើយគ្មានលោកឧបដ្ឋាកចូលរួមថ្វាយអភិបូជា អ្នកប្រកាសព្រះបន្ទូលត្រូវស្លៀកពាក់ត្រឹមត្រូវ ហែនៅខាងមុខលោកបូជាចារ្យ កាន់សៀវភៅព្រះគម្ពីរដំណឹងល្អលើកឡើងបន្តិច។ បើលោកមិនកាន់ព្រះគម្ពីរដំណឹងល្អទេ លោកហែជាមួយ អ្នកបម្រើឯទៀតៗ។

១៩៥. ពេលដល់តុសក្ការបូជា អ្នកប្រកាសព្រះបន្ទូលឱនកាយគោរពតុសក្ការបូជារួមជាមួយអ្នកបម្រើពិធីបុណ្យ។ ប៉ុន្តែបើសិនជាគាត់កាន់ព្រះគម្ពីរដំណឹងល្អ លោកដើរដល់តុ សក្ការបូជា ហើយតម្កល់សៀវភៅនេះលើតុសក្ការបូជា។ ក្រោយមក លោកទៅអង្គុយជាមួយ អ្នកបម្រើពិធីបុណ្យនៅកន្លែងរបស់គាត់នៅទីសក្ការបូជា។

#### ពិធីលើកតម្កើងព្រះបន្ទូលរបស់ព្រះជាម្ចាស់

១៩៦. អ្នកប្រកាសព្រះបន្ទូលទៅដល់តុព្រះបន្ទូល ហើយអានអត្ថបទដែលមានមុនប្រកាសព្រះបន្ទូលដំណឹងល្អ។ បើសិនជាគ្មានអ្នកបម្រើសូត្រទំនុកតម្កើង គាត់អាចសូត្រទំនុកតម្កើងក្រោយពីអត្ថបទទីមួយ។

១៩៧. ពេលគ្មានលោកឧបដ្ឋាកចូលរួមពិធីអភិបូជា អ្នកប្រកាសព្រះបន្ទូល អាចអានពាក្យអង្វរសកលពីតុព្រះបន្ទូល។

១៩៨. បើសិនជាគ្មានបទចម្រៀងពេលចូល ឬពេលទទួលព្រះកាយព្រះគ្រីស្ត ហើយបើសិនជាគ្រីស្តបរិស័ទមិនប្រកាសពាក្យបន្ទរពីសៀវភៅក្បួនពិធីទេ ដូច្នេះ អ្នកប្រកាសព្រះបន្ទូលអាចអានពាក្យបន្ទរនោះបានដែរ។ (សូមមើលលេខ ៤៨.៨៧)

## II. ពិធីអភិបូជាដោយមានលោកបូជាចារ្យចូលរួមច្រើននាក់

១៩៩. ក្បួនពិធីសម្រាប់តែងតាំងលោកអភិបាល ឬលោកបូជាចារ្យ និងពិធីប្រទានពរលើប្រធានក្រុមបព្វជិត និងពិធីអភិបូជាប្រទានពរលើប្រេងគ្រីស្មា មានក្បួនពិធីអភិបូជាស្រាប់ដោយមានលោកបូជាចារ្យច្រើននាក់ចូលរួម។ ពិធីរបៀបនេះ បង្ហាញយ៉ាងច្បាស់ពីការ រួបរួមគ្នាក្នុងក្រុមបូជាចារ្យ និងប្រជារាស្ត្ររបស់ព្រះអង្គ។ ដូចគ្នានេះដែរគួរមានពិធីអភិបូជា ដោយមានលោកបូជាចារ្យច្រើននាក់ចូលរួម ៖

ក)ពិធីអភិបូជាពេលរសៀល នៅថ្ងៃព្រះយេស៊ូជប់លៀងក្រុមសាវ័កចុងក្រោយ។

ខ)ពិធីអភិបូជាពេលមានមហាសន្និបាត ប្រជុំក្រុមលោកអភិបាល ឬប្រជុំលោកអភិបាលជាមួយលោកបូជាចារ្យប្រចាំភូមិភាគ។

គ)ពិធីអភិបូជាក្នុងវត្តអារាម ពិធីអភិបូជាសំខាន់ជាងគេក្នុងព្រះវិហារមួយ ឬព្រះវិហារតូចនៃបូជនីយដ្ឋាន។

ឃ)ពិធីអភិបូជានៃប្រជុំលោកបូជាចារ្យប្រចាំភូមិភាគ ឬក្រុមបព្វជិត[115] លោកបូជាចារ្យម្នាក់មានសិទ្ធិថ្វាយអភិបូជាតែម្នាក់ឯង ប៉ុន្តែនៅពេលវេលានិងកន្លែងខុសគ្នា។ យ៉ាងណាក៏ដោយសម្រាប់ពិធីអភិបូជានៅថ្ងៃព្រហស្បតិ៍ពិសិដ្ឋ និងពិធីអភិបូជាយប់បុណ្យចម្លង លោកបូជាចារ្យមិនអាចថ្វាយអភិបូជាតែម្នាក់ឯងបានទេ។

២០០. ពេលមានលោកបូជាចារ្យមកសួរសុខទុក្ខព្រះសហគមន៍មួយ គួរទទួលលោកចូលរួមថ្វាយអភិបូជា លុះត្រាតែលោកបង្ហាញថា លោកជាលោកបូជាចារ្យដែលគ្មានបញ្ហាជាមួយព្រះសហគមន៍ឬភូមិភាគដែលលោកបម្រើទេ។

២០១. តាមកាលៈទេសៈ កាលណាមានលោកបូជាចារ្យជំនួយច្រើន គេអាចប្រារព្ធពិធីអភិបូជាដោយមានលោកបូជាចារ្យគ្នាច្រើនចូលរួមតាមពេលវេលាផ្សេងៗនៅថ្ងៃដដែល ក៏ប៉ុន្តែត្រូវប្រារព្ធពិធីនោះនៅកន្លែងផ្សេងពីគ្នា។[116]

២០២. លោកអភិបាលភូមិភាគនីមួយៗ ត្រូវបង្កើតច្បាប់ស្របនឹងព្រះសហគមន៍សកល សម្រាប់ពិធីអភិបូជាដោយមានលោកបូជាចារ្យគ្នាច្រើនចូលរួម។

២០៣. ត្រូវចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះអភិបូជា ក្នុងពេលមានលោកបូជាចារ្យប្រចាំភូមិភាគចូលរួមជាមួយលោកអភិបាលនៅវិសាលវិហារ ជាពិសេស នៅក្នុងថ្ងៃបុណ្យយ៉ាងឱឡារិកនៃក្បួនពិធីបុណ្យសម្រាប់មួយឆ្នាំ ពិធីតែងតាំងលោកអភិបាល ឬលោកអភិបាលរង អភិបូជាប្រសិទ្ធពរលើប្រេងគ្រីស្មា ពិធីអភិបូជាពេលល្ងាច ថ្ងៃព្រហស្បតិ៍ពិសិដ្ឋនៃពិធីជប់លៀងរបស់ព្រះអម្ចាស់ ពេលប្រារព្ធពិធីសម្រាប់សន្តឧបការីនៃប្រពៃណីព្រះសហគមន៍ ឬលោកអភិបាលប្រចាំភូមិភាគ ថ្ងៃបុណ្យខួបនៃលោកអភិបាលព្រះសហគមន៍ និងចុងក្រោយ គឺនៅក្នុងឱកាសនៃការសន្និបាត ឬនៅពេលលោកអភិបាលចុះទៅសួរសុខទុក្ខ។

តាមរបៀបដដែល អភិបូជាដែលមានលោកបូជាចារ្យច្រើននាក់ចូលរួម កាលណាដែលមានប្រជុំលោកបូជាចារ្យជាមួយលោកអភិបាល ក្រុមរបស់លោកមានសំណាក់ធម៌ ឬប្រជុំផ្សេងៗ។ ក្នុងករណីទាំងនោះ បង្ហាញពីឯកភាពនៃក្រុមលោកបូជាចារ្យ និងព្រះសហគមន៍មានការប្រព្រឹត្តជារៀងរាល់ថ្ងៃកាន់តែច្បាស់។[117]

[115] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 57; *Codex Iuris Canonici*, can. 902.
[116] Cf. Sacred Congregation of Rites, Instruction *Eucharisticum mysterium*, On the worship of the Eucharist, 25 May 1967, no. 47: AAS 59 (1967), p. 566.
[117] Cf. Sacred Congregation of Rites, Instruction *Eucharisticum mysterium*, On the worship of the Eucharist, 25 May 1967, no. 47: AAS 59 (1967), p. 565.

២០៤. តាមកាលៈទេសៈ ដើម្បីប្រារព្ធពិធីបុណ្យមួយដែលមានអត្ថន័យសម្រាប់ពិធីនេះ អាចចូលរួមថ្វាយអភិបូជាច្រើនជាងមួយដងក្នុងមួយថ្ងៃ ឬដោយករណីពិសេស ដូចតទៅ ៖

ក)លោកបូជាចារ្យដែលថ្វាយអភិបូជា ឬបានចូលរួមថ្វាយអភិបូជាប្រសិទ្ធិពរលើប្រេងគ្រីស្មានៅព្រហស្បត៍ពិសិដ្ឋ អាចថ្វាយអភិបូជា ឬចូលរួមថ្វាយអភិបូជាពេលរសៀល ពិធីជប់លៀងរបស់ព្រះយេស៊ូជាមួយក្រុមសាវ័ក។

ខ)លោកបូជាចារ្យដែលថ្វាយអភិបូជា ឬចូលរួមថ្វាយអភិបូជាពេលយប់បុណ្យចម្លង អាចថ្វាយអភិបូជា ឬចូលរួមថ្វាយអភិបូជានៅថ្ងៃអាទិត្យបុណ្យចម្លង។

គ)ថ្ងៃលើកតម្កើងព្រះយេស៊ូប្រសូត លោកបូជាចារ្យថ្វាយអភិបូជា ឬចូលរួមថ្វាយអភិបូជា ៣ដង តាមពេលវេលាត្រឹមត្រូវនៃពិធីនីមួយៗ។

ឃ)នៅថ្ងៃពិធីគោរពសន្តបុគ្គលទាំងឡាយ លោកបូជាចារ្យថ្វាយអភិបូជា ឬអាចចូលរួមថ្វាយអភិបូជា៣ដង តាមពេលវេលាផ្សេងៗពីគ្នា ហើយដោយគោរពបទបញ្ញាសម្រាប់ករណីថ្វាយអភិបូជា២ ឬ ៣ដង ក្នុងមួយថ្ងៃ។[118]

ង)លោកបូជាចារ្យចូលរួមថ្វាយអភិបូជា ជាមួយលោកអភិបាល ឬក្នុងមហាសន្និបាតរបស់លោកអភិបាល ឬការទៅសួរសុខទុក្ខតាមព្រះសហគមន៍ ឬប្រជុំលោកបូជាចារ្យប្រចាំភូមិភាគ ឬបព្វជិត អាចថ្វាយអភិបូជាសម្រាប់គ្រីស្តបរិស័ទតាមព្រះសហគមន៍បានដែរ។ អភិបូជាដែលមានលោកបូជាចារ្យច្រើនចូលរួម ជារបៀបណាក៏ដោយ គឺត្រូវគោរពតាមក្បួនច្បាប់។

២០៥. ត្រូវគោរពចំណុចខាងក្រោមនេះ (សូមមើលលេខ ១១២-១១៨) លើកលែងតែករណីដែលត្រូវគោរព ទោះបីតាមករណីពិសេសក៏ដោយ។

២០៦. មិនអាចទទួលលោកបូជាចារ្យឲ្យចូលរួមថ្វាយអភិបូជាក្រោយពីចាប់ផ្តើមពិធីរួចហើយ។

២០៧. នៅទីសក្ការបូជាត្រូវរៀបចំ ៖

ក)កៅអី និងសៀវភៅគ្រប់គ្រាន់សម្រាប់លោកបូជាចារ្យដែលចូលរួម។

ខ)លើតុតង្វាយ ត្រូវមានពែងលោហិតធំល្មម ឬពែងព្រះលោហិតចំនួនច្រើនល្មម សម្រាប់លោកបូជាចារ្យដែលចូលរួមថ្វាយអភិបូជា។

២០៨. បើសិនជាគ្មានលោកឧបដ្ឋាកចូលរួមពិធីអភិបូជាទេ នោះត្រូវមានលោកបូជាចារ្យម្នាក់បំពេញមុខងាររបស់លោកឧបដ្ឋាក។ បើគ្មានអ្នកបម្រើពិធីបុណ្យ គួរជ្រើសរើសគ្រីស្តបរិស័ទម្នាក់ឲ្យបំពេញមុខងារនោះ ឬលោកបូជាចារ្យដែលចូលរួមអាចបំពេញមុខងារទាំងនោះបានដែរ។

២០៩. នៅកន្លែងលោកបូជាចារ្យផ្លាស់ប្តូរសម្លៀកបំពាក់ ឬកន្លែងផ្សេងសមរម្យ ជាសម្លៀកបំពាក់ពិសិដ្ឋដែលលោកពាក់ពេលថ្វាយអភិបូជា។ បើមានមូលហេតុផ្សេង (ឧទាហរណ៍ ចំនួនលោកបូជាចារ្យចូលរួមច្រើន ឬគ្មានសម្លៀកបំពាក់ពិសិដ្ឋគ្រប់គ្រាន់) លោកអាចពាក់អាវសវែង និងកន្សែងបង់កពិសិដ្ឋបាន (លើកលែងតែលោកធ្វើជាអធិបតី)។

[118] Cf. Benedict XV, Apostolic Constitution *Incruentum altaris sacrificium*, 10 August 1915: AAS 7 (1915), pp. 401-404.

## ពិធីប្រារព្ធ

២១០. ពេលរៀបចំអ្វីទាំងអស់ហើយ តាមធម្មតាក្បួនហែក្នុងព្រះវិហារទៅដល់គុសក្ការបូជា។ លោកបូជាចារ្យដែលចូលរួមថ្វាយអភិបូជាដើរខាងមុខលោកបូជាចារ្យដែលធ្វើជាអធិបតី។

២១១. ទៅដល់គុសក្ការបូជា លោកបូជាចារ្យធ្វើជាអធិបតី និងលោកបូជាចារ្យដែលចូលរួមថ្វាយអភិបូជាឱនកាយគោរព និងថើបគុសក្ការបូជា ក្រោយមក ទៅអង្គុយនៅកន្លែងរៀងៗខ្លួន។ បើសិនជាប្រើកំញាន លោកបូជាចារ្យគោរពព្រះឈើឆ្កាង និងគុសក្ការបូជាជាមួយកំញាន ក្រោយមក ទៅអង្គុយនៅកន្លែងរបស់ខ្លួន។

## ពិធីលើកតម្កើងព្រះបន្ទូលរបស់ព្រះជាម្ចាស់

២១២. សម្រាប់ពិធីលើកតម្កើងព្រះបន្ទូលរបស់ព្រះជាម្ចាស់ លោកបូជាចារ្យដែលចូលរួមថ្វាយអភិបូជាចាំនៅកន្លែងដដែល អង្គុយ ឬឈរឡើង តាមលោកបូជាចារ្យដែលធ្វើជាអធិបតី។ ក្រោយពីចាប់ផ្តើមច្រៀងបទអាលេលូយ៉ា ទាំងអស់គ្នាឈរឡើង លើកលែងតែលោកអភិបាលដែលត្រូវបញ្ចូលកំញានក្នុងចង្រ្កានកំញានដោយស្ងៀមស្ងាត់។ ក្រោយមក លោកអភិបាលប្រទានពរដល់លោកឧបដ្ឋាក។ បើសិនជាគ្មានលោកឧបដ្ឋាក លោកអភិបាលប្រទានពរ ដល់លោកបូជាចារ្យដែលប្រកាសព្រះបន្ទូលដំណឹងល្អ។ ប្រសិនបើ លោកដែលធ្វើជាអធិបតី ជាលោកបូជាចារ្យធ្វើដូចគ្នា ប៉ុន្តែបើគ្មានលោកឧបដ្ឋាក លោកបូជាចារ្យដែលប្រកាសព្រះបន្ទូលដំណឹងល្អ មិនត្រូវការ សូមលោកបូជាចារ្យដែលធ្វើជាអធិបតីប្រទានពរដល់លោកទេ។

២១៣. លោកជាអធិបតីពិធី ឬលោកដែលចូលរួមថ្វាយអភិបូជាអាចសម្តែងធម្មទេសនាបាន។

## ពិធីអរព្រះគុណដ៏វិសុទ្ធ

២១៤. លោកដែលធ្វើជាអធិបតីពិធី រៀបចំពិធីថ្វាយតង្វាយ (សូមមើលលេខ ១៣៩-១៤៦) លោកផ្សេងៗដែលចូលរួមថ្វាយអភិបូជា រង់ចាំនៅកន្លែងរបស់លោក។

២១៥. លោកធ្វើជាអធិបតីពិធី ពោលពាក្យអធិដ្ឋានថ្វាយតង្វាយរួចហើយ លោកបូជាចារ្យផ្សេងៗដែលចូលរួមថ្វាយអភិបូជា មកឈរក្បែរគុសក្ការបូជា តាមរបៀបដែលមិនរាំងស្ទះក្នុងពិធី ហើយគ្រីស្តបរិស័ទ អាចមើលឃើញសកម្មភាពទីសក្ការបូជានៃពិធីបុណ្យដែលកំពុងប្រារព្ធ។ មិនត្រូវរាំងស្ទះផ្លូវរបស់លោកឧបដ្ឋាកដែលមានមុខងារនៅគុសក្ការបូជា ដោយជួយជាមួយពែងព្រះលោហិត និងសៀវភៅក្បួនពិធី។ លោកឧបដ្ឋាកឈរក្បែរលោកធ្វើជាអធិបតី ប៉ុន្តែនៅខាងក្រោយបន្តិចពីក្រុមលោកបូជាចារ្យចូលរួមថ្វាយអភិបូជា។

## របៀបពោលធម៌អរព្រះគុណដ៏វិសុទ្ធ

២១៦. លោកជាអធិបតី ច្រៀង ឬសូត្រធម៌ប្រារព្ធម្នាក់ឯង រីឯពាក្យកោតសរសើរព្រះដ៏វិសុទ្ធ គឺច្រៀង ឬសូត្រទាំងអស់គ្នា ទាំងលោកបូជាចារ្យចូលរួមថ្វាយអភិបូជា ទាំងអង្គប្រជុំ និងក្រុមច្រៀង។

២១៧. ក្រោយពីពាក្យកោតសរសើរដ៏វិសុទ្ធ លោកបូជាចារ្យដែលចូលរួមថ្វាយអភិបូជា សូត្រធម៌អរព្រះគុណដ៏វិសុទ្ធ ដូចពន្យល់ខាងក្រោមនេះ លើកលែងតែមានពាក្យណែនាំផ្សេង។ មានតែលោកធ្វើជាអធិបតីពិធីដែលធ្វើកាយវិការ។

២១៨. លោកបូជាចារ្យដែលចូលរួមថ្វាយអភិបូជា ត្រូវសូត្រផ្នែករួម ជាពិសេសពាក្យនៃពិធីប្រសិទ្ធលើនំប៉័ង និងស្រាតង្វាយ ដោយសម្លេងទាបហើយតាមការណែនាំរបស់លោកដែលធ្វើជាអធិបតី ដើម្បីឲ្យគ្រីស្តបរិស័ទអាចស្តាប់សម្លេងយ៉ាងច្បាស់។ បើសិនជាលោកទាំងអស់ច្រៀងផ្នែករួម ជាការគួរណាស់ ហើយល្អជាងរបៀបសូត្រ។

**ធម៌អរព្រះគុណដ៏វិសុទ្ធ ទី១ ធម៌អរព្រះគុណដ៏វិសុទ្ធបុរាណពីក្រុងរ៉ូម**

២១៩. ក្នុងធម៌អរព្រះគុណដ៏វិសុទ្ធទី១ ឬធម៌បុរាណតាមសាសនក្រឹត្យក្រុងរ៉ូម លោកបូជាចារ្យជាអធិបតីលាតដៃ ហើយពោលម្នាក់ឯងថា "បពិត្រព្រះបិតាដ៏មានព្រះហឫទ័យសប្បុរសយ៉ាងក្រៃលែង... " (Te igitur)។

២២០. ជាការគួរណាស់ដែល បុណ្យរំឭក (Memento) ពោលពាក្យអធិដ្ឋានដល់អ្នកនៅរស់ និង "អស់អ្នកដែលរួបរួមគ្នានៅទីនេះជាមួយព្រះសហគមន៍ទាំងមូល" (Communicantes) គឺចាត់ចែងម្នាក់ឲ្យទៅជាមួយ ឬម្នាក់ផ្សេងទៀតជាលោកបូជាចារ្យដែលប្រារព្ធពិធីប្រកាសពាក្យអធិដ្ឋានម្នាក់ឯង ដោយលាតដៃ និងបន្លឺសំឡេងខ្លាំងៗ។

២២១. គឺលោកជាអធិបតីលាតដៃ ដោយពោលពាក្យអធិដ្ឋានបន្តថា ហេតុនេះហើយបានជា "យើងខ្ញុំសូមទូលអង្វរព្រះអម្ចាស់..." (Hanc igitur)។

២២២. ចាប់ពី "ឱ ព្រះជាម្ចាស់អើយ! យើងខ្ញុំសូមទូលអង្វរព្រះអង្គ សូមទ្រង់សព្វព្រះហឫទ័យ" (Quam oblationem) រហូតដល់ "បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ យើងខ្ញុំសូមឱនកាយទូលអង្វរព្រះអង្គ" លោកបូជាចារ្យដែលធ្វើជាអធិបតី ធ្វើកាយវិការម្នាក់ឯង ហើយលោកបូជាចារ្យឯទៀតចូលរួមជាមួយគ្នាតាមរបៀបដូចខាងក្រោម៖

ក)"ឱ ព្រះជាម្ចាស់អើយ! យើងខ្ញុំសូមទូលអង្វរព្រះអង្គ សូមទ្រង់សព្វព្រះហឫទ័យ និងប្រទានពរលើតង្វាយនេះ" (Quam oblationem) លោកទ្រាបដៃទាំងពីរលើតង្វាយ។

ខ)នៅមុនថ្ងៃព្រះយេស៊ូសោយទុក្ខលំបាក និងនៅពេលចុងក្រោយនៃពិធីជប់លៀងព្រះអង្គធ្វើតាមរបៀបដដែល (Simili modo) លោកលើកដៃប្រណម្យ។

គ)ពេលព្រះអង្គមានព្រះបន្ទូល លោកទាំងអស់លាតដៃទៅលើនំព្រះកាយ និងពែងព្រះលោហិត។ លោកទាំងអស់គោរពមើលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ហើយឱនកាយបន្តិច។

ឃ)ពាក្យអធិដ្ឋាន "ឱ ព្រះអម្ចាស់អើយ! យើងខ្ញុំជាអ្នកបម្រើព្រះអង្គ រួមជាមួយប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គ នាំគ្នានឹករឭក..." (Unde et memores) "សូមព្រះអង្គសព្វព្រះហឫទ័យទតមើល..." (Supra quae) លោកលាតដៃប្រណម្យ។

ង)ចាប់ពី "បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ យើងខ្ញុំសូមឱនកាយទូលអង្វរព្រះអង្គ" (Supplices) រហូតដល់ "សូមប្រោសយើងខ្ញុំដែលទទួលព្រះកាយ និងព្រះលោហិតដ៏វិសុទ្ធរបស់ព្រះបុត្រាពីតុសក្ការបូជានេះ" លោកឱនកាយលើកដៃប្រណម្យ។ ក្រោយមក លោកក្រោកឈរ ហើយគូសសញ្ញាឈើឆ្កាងទាំងពោលថា៖ "បានពោរពេញដោយព្រះហឫទ័យប្រណីសន្ដោស និងព្រះពរយ៉ាងបរិបូរណ៍" (omni benedictione et gratia repleamur)។

២២៣. លោកបូជាចារ្យម្នាក់ដែលចូលរួមថ្វាយអភិបូជា លាតដៃហើយអធិដ្ឋានឲ្យអស់អ្នកដែលបានលាចាកលោកនេះទៅហើយ (Memento) ហើយសម្រាប់យើងដែរ "ទោះបីយើងខ្ញុំជាអ្នកបាបក៏ដោយ" (Nobis quoque peccatoribus)។

២២៤. ពេលសូត្រពាក្យ "ទោះបីយើងខ្ញុំជាអ្នកបាបក៏ដោយ..." (Nobis quoque peccatoribus) អស់លោកដែលចូលរួមថ្វាយអភិបូជាគក់ទ្រូង។

២២៥. លោកជាអធិបតីពោលពាក្យ "គឺដោយសារព្រះគ្រីស្ដនេះហើយ បានជាព្រះអង្គនៅតែបង្កើតអ្វីៗដ៏ល្អទាំងអស់នេះ ប្រោសឲ្យបានវិសុទ្ធ ឲ្យមានជីវិត និងប្រទានពរ ហើយប្រគល់ឲ្យយើងខ្ញុំ" (Per quem haec omnia) ។

**ធម៌អរព្រះគុណដ៏វិសុទ្ធ ទី២**

២២៦. នៅក្នុងធម៌អរព្រះគុណដ៏វិសុទ្ធ ទី២ នៅផ្នែក "ឱ ព្រះអម្ចាស់អើយ! ព្រះអង្គពិតជាព្រះដ៏វិសុទ្ធមែន" លោកជាអធិបតីលាតដៃប្រណម្យ ដោយពោលម្នាក់ឯង។

២២៧. ចាប់ពី "សូមព្រះអង្គប្រោសព្រះវិញ្ញាណរបស់ព្រះអង្គដូចទឹកសន្សើម មកញ៉ាំងតង្វាយទាំងនេះឲ្យបានវិសុទ្ធ" រហូតដល់ "យើងខ្ញុំសូមឱនកាយទូលអង្វរ សូមព្រះអង្គប្រោសប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ..." លោកទាំងអស់សូត្រតាមរបៀបដូចខាងក្រោម៖

ក)ពាក្យអង្វរ "សូមព្រះអង្គប្រោសព្រះវិញ្ញាណរបស់ព្រះអង្គ..." លោកទ្រាបដៃទៅដល់តង្វាយ។

ខ)ពាក្យ "នៅគ្រាដែលព្រះយេស៊ូគ្រីស្ដសព្វព្រះហឫទ័យ ឲ្យគេបញ្ជូនព្រះអង្គទៅសោយទុក្ខលំបាក" លោកលើកដៃប្រណម្យ។

គ)បើសិនជាការគួរសម ពេលកំពុងនិយាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ លោកម្នាក់ៗលាតដៃស្ដាំលើនំព្រះកាយ និងពែងព្រះលោហិត ហើយលោកទាំងអស់មើលទៅនំព្រះកាយ និងព្រះលោហិត ព្រមទាំងឱនកាយបន្តិច។

ឃ) ពាក្យ "ក្នុងពេលដែលយើងខ្ញុំនឹករឭក ដល់ព្រះបុត្រាសោយទិវង្គត... និង យើងខ្ញុំសូមឱនកាយទូលអង្វរ" លោកទាំងអស់លាតដៃប្រណម។

២២៨. លោកបូជាចារ្យម្នាក់លាតដៃទូលអង្វរសម្រាប់បងប្អូននៅរស់ "សូមព្រះអម្ចាស់មេត្តានឹកដល់ព្រះសហគមន៍របស់ព្រះអង្គ" និងសម្រាប់បងប្អូនដែលបានទទួលមរណភាពទៅហើយ "សូមព្រះអង្គនឹកដល់អស់បងប្អូនយើងខ្ញុំ..." គឺចាត់ចែងម្នាក់ឲ្យទៅជាមួយ ឬម្នាក់ផ្សេងទៀតជាលោកបូជាចារ្យដែលប្រារព្ធពិធីប្រកាសពាក្យអធិដ្ឋានម្នាក់ឯង ដោយលាតដៃនិងបន្លឺសំឡេងខ្លាំងៗ។

## ធម៌អរព្រះគុណដ៏វិសុទ្ធ ទី៣

២២៩. នៅក្នុងធម៌អរព្រះគុណដ៏វិសុទ្ធ ទី៣ ត្រង់ពាក្យ "ឱ ព្រះអម្ចាស់អើយ ព្រះអង្គពិតជាព្រះដ៏វិសុទ្ធមែន..." លោកជាអធិបតីលាតដៃប្រណម។

២៣០. ក្នុងពាក្យ "ឱ ព្រះអម្ចាស់អើយ! ហេតុនេះហើយ បានជាយើងខ្ញុំសូមឱនកាយទូលអង្វរព្រះអង្គ សូមចាត់ព្រះវិញ្ញាណរបស់ព្រះអង្គ មកប្រសិទ្ធិពរលើតង្វាយដែលយើងខ្ញុំលើកថ្វាយ..." រហូតដល់ "សូមព្រះអង្គមេត្តាទតមើលតង្វាយ..." លោកទាំងអស់សូត្រតាមរបៀបនៅខាងក្រោម៖

ក)ពាក្យ "ឱ ព្រះអម្ចាស់អើយ! ហេតុនេះហើយ បានជាយើងខ្ញុំសូមឱនកាយទូលអង្វរព្រះអង្គ" លោកប្រណមដៃ ហើយទ្រាបដៃទាំងពីរទៅលើតង្វាយ។

ខ)ពាក្យ "នៅរាត្រីដែលគេបញ្ជូនព្រះយេស៊ូទៅសោយទុក្ខលំបាក..." និង "នៅពេលចុងក្រោយនៃពិធីជប់លៀង..." លោកលាតដៃប្រណម្យ។

គ) ពោលព្រះបន្ទូលរបស់ព្រះអម្ចាស់ លោកម្នាក់ៗលាតដៃស្តាំលើនំព្រះកាយ និងពែងព្រះលោហិត។ លោកទាំងអស់ត្រូវមើលព្រះកាយ និងព្រះលោហិត ឱនកាយគោរពបន្តិច។

ឃ)ពាក្យ "ឱ ព្រះអម្ចាស់អើយ! យើងខ្ញុំនឹករឭក..." និង "សូមព្រះអង្គមេត្តាទតមើល..." លោកលាតដៃប្រណម្យ។

២៣១. លោកបូជាចារ្យម្នាក់ដែលចូលរួមថ្វាយអភិបូជា ត្រូវលាតដៃប្រណម្យពោលពាក្យអង្វរ "សូមព្រះអង្គប្រោសយើងខ្ញុំឲ្យទៅជាតង្វាយគង់វង្សអស់កល្បជានិច្ច..." ហើយ "សូមព្រះអង្គមេត្តាដល់អស់បងប្អូនយើងខ្ញុំដែលទទួលមរណភាព"។

## ធម៌អរព្រះគុណដ៏វិសុទ្ធ ទី៤

២៣២. នៅក្នុងធម៌អរព្រះគុណដ៏វិសុទ្ធ ទី៤ លោកជាអធិបតីលាតដៃប្រណម្យពោលថា "បពិត្រព្រះបិតាដ៏វិសុទ្ធ! យើងខ្ញុំសូមប្រកាសថា ព្រះអង្គជាព្រះដ៏ប្រសើរឧត្តម..." រហូតដល់ "ព្រះអង្គបានបង្កើតអ្វីៗសព្វសារពើទាំងអស់..."។

២៣៣. ចាប់ពី "ឱ ព្រះអម្ចាស់អើយ! យើងខ្ញុំសូមអង្វរព្រះអង្គ..." រហូតដល់ "ឱ ព្រះអម្ចាស់អើយ! សូមព្រះអង្គសព្វព្រះហឫទ័យទតមើលសក្ការបូជា..." លោកដែលចូលរួមថ្វាយអភិបូជាទាំងអស់សូត្រតាមរបៀបដូចខាងក្រោម៖

ក)ពាក្យអង្វរ "ឱ ព្រះអម្ចាស់អើយ! ហេតុដូចនេះហើយ បានជាយើងខ្ញុំសូមអង្វរព្រះអង្គសូមប្រោសឲ្យព្រះវិញ្ញាណដ៏វិសុទ្ធ..." លោកប្រណម្យដៃ ហើយទ្រាបដៃទាំងពីរលើតង្វាយ។

ខ)ពាក្យ "បពិត្រព្រះបិតាដ៏វិសុទ្ធ! ដល់ពេលកំណត់ដែលព្រះបុត្រាបានទទួលសិរីរុងរឿងពីព្រះបិតា ដោយទ្រង់ស្រឡាញ់សាវ័ក..." និង "បន្ទាប់មក ព្រះអង្គធ្វើតាមរបៀបដដែល..." លោកលើកដៃប្រណម្យ។

គ)ត្រូវពោលព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយលាតដៃស្តាំលើនំព្រះកាយ និងពែងព្រះលោហិត ព្រមទាំងសម្លឹងមើលព្រះកាយ និងព្រះលោហិត ហើយឱនកាយបន្តិចគោរព។

ឃ)លោកលាតដៃប្រណម ត្រង់ពាក្យ "ឱ ព្រះអម្ចាស់អើយ! ហេតុនេះហើយ បានជាយើងខ្ញុំរួមគ្នានៅពេលនេះ ធ្វើពិធី..." និង "ឱ ព្រះអម្ចាស់អើយ! សូមព្រះអង្គសព្វព្រះហឫទ័យទតមើលសក្ការបូជា..." ។

២៣៤. លោកបូជាចារ្យដែលចូលរួមថ្វាយអភិបូជា ត្រូវលាតដៃប្រណម្យពេលពោលពាក្យអង្វរខ្លាំងៗថា៖ "បពិត្រព្រះអម្ចាស់! សូមព្រះអង្គប្រោសប្រណីដល់អស់បងប្អូន..." និង "ឱ ព្រះបិតាដ៏មានព្រះហឫទ័យមេត្តាអើយ! សូមព្រះអង្គប្រោសឲ្យយើងខ្ញុំទាំងអស់គ្នា ដែលជាបុត្រធីតាព្រះអង្គ..."។

២៣៥. សម្រាប់ធម៌អរព្រះគុណដ៏វិសុទ្ធផ្សេងៗ ដែលបានទទួលការអនុញ្ញាតពីសន្តអាសនៈត្រូវធ្វើតាមបទបញ្ជានោះ។

២៣៦. លោកបូជាចារ្យជាអធិបតី ពោលពាក្យកោតសរសើរខ្លីចុងក្រោយ គឺលោកសូត្រម្នាក់ម្តងៗ "ឱ ព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ!" នៃធម៌អរព្រះគុណដ៏វិសុទ្ធ បើសិនអស់លោកបូជាចារ្យចូលរួមសូត្របាន ប៉ុន្តែគ្រីស្តបរិស័ទមិនអាចចូលរួមបានទេ។

### ពិធីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត

២៣៧. លោកជាអធិបតី សូត្រធម៌ឱព្រះបិតា ដោយលើកដៃប្រណម្យ។ លោកទាំងអស់លាតដៃព្រមគ្នា ហើយសូត្រ ឬច្រៀង។

២៣៨. លោកជាអធិបតីលាតដៃពោលពាក្យ "ឱព្រះអម្ចាស់អើយ! សូមប្រោសយើងខ្ញុំឲ្យរួចពី..." (Libera nos)។ លោកទាំងអស់ រួមនឹងគ្រីស្តបរិស័ទពោលពាក្យ "ដ្បិតព្រះអង្គគ្រងរាជ្យ..." ។

២៣៩. ក្រោយពីលោកឧបដ្ឋាក ឬបើសិនជាគ្មានឧបដ្ឋាកទេ លោកបូជាចារ្យម្នាក់ ពោលពាក្យអញ្ជើញ "សូមបងប្អូនជូនសេចក្តីសុខសាន្ត..." (Offerte vobis pacem pacem) អង្គប្រជុំបង្ហាញសញ្ញានៃសេចក្តីសុខសាន្តរវាងគ្នានិងគ្នា។ លោកបូជាចារ្យចូលរួមថ្វាយអភិបូជា ដែលនៅជិតលោកជាអធិបតីបង្ហាញសញ្ញានៃសេចក្តីសុខសាន្តឲ្យលោកជាអធិបតីមុនលោកឧបដ្ឋាក។

២៤០. ពេលកំពុងច្រៀង ឬសូត្រ "ឱកូនចៀមរបស់ព្រះជាម្ចាស់..." (Agnus Dei) លោកឧបដ្ឋាក ឬលោកបូជាចារ្យដែលចូលរួមថ្វាយអភិបូជាជួយកាច់នំព្រះកាយសម្រាប់លោក និងអង្គប្រជុំ។

២៤១. បន្ទាប់ពីកាច់នំព្រះកាយ ហើយយកបំណែកតូចមួយដាក់ក្នុងពែងព្រះលោហិត លោកជាអធិបតីលើកដៃប្រណម្យ ហើយពោលខ្សឹបៗថា "បពិត្រព្រះអម្ចាស់យេស៊ូគ្រីស្ត! ជាព្រះបុត្រានៃព្រះជាម្ចាស់..." (Domine Iesu Christe Fili Dei vivi) ឬពាក្យ "បពិត្រព្រះអម្ចាស់យេស៊ូគ្រីស្ត! សូមឲ្យយើងខ្ញុំដែលទទួលព្រះកាយ និងព្រះលោហិតរបស់ព្រះអង្គ..." (Perceptio Corporis et Sanguinis)។

២៤២. មុនពេលអធិដ្ឋានទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត លោកជាអធិបតីលុតជង្គង់ ហើយថយក្រោយបន្តិច។ ក្រោយមកលោកទាំងអស់ មកដល់តុសក្ការបូជាលុតជង្គង់ ថយក្រោយបន្តិច និងយកព្រះកាយព្រះគ្រីស្តពីតុសក្ការបូជា រួចហើយត្រឡប់ទៅដល់កន្លែងផ្ទាល់ខ្លួនវិញ ដោយកាន់ព្រះកាយព្រះគ្រីស្តក្នុងដៃស្តាំ និងដៃឆ្វេងទ្រនៅខាងក្រោម។ លោកដែលចូលរួមថ្វាយអភិបូជាអាចរង់ចាំនៅកន្លែងផ្ទាល់ខ្លួន ហើយយកព្រះកាយព្រះគ្រីស្តពីចានព្រះកាយដែលលោកជាអធិបតីជូនឲ្យ ឬលោកម្នាក់ដែលចូលរួមថ្វាយអភិបូជាជូនតៗគ្នា។

២៤៣. លោកជាអធិបតីលើកព្រះកាយព្រះគ្រីស្តឡើង ហើយពោលពាក្យ "នេះជាកូនចៀមរបស់ព្រះជាម្ចាស់..." ទាំងអស់គ្នាបន្តពាក្យអធិដ្ឋាន "ឱព្រះអម្ចាស់អើយ! ខ្ញុំមិនសម..."។

២៤៤. លោកធ្វើជាអធិបតីពោលថា៖ "សូមព្រះកាយព្រះគ្រីស្តរក្សាខ្ញុំទុកក្នុងជីវិតអស់កល្បជានិច្ច" (Corpus Christi custodiat me ad vitam aeternam) ហើយទទួលព្រះកាយព្រះគ្រីស្ត។ ក្រោយមកលោកទាំងអស់ ដែលចូលរួមថ្វាយអភិបូជាធ្វើដូចគ្នាដែរ។ បន្ទាប់មកលោកឧបដ្ឋាកទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្តពីលោកធ្វើជាអធិបតី។

២៤៥. គេអាចទទួលព្រះលោហិតព្រះគ្រីស្ត និងពិសាពីពែងព្រះលោហិត ដោយជ្រលក់ ឬដោយបំពង់តូចមួយ ឬដោយស្លាបព្រា។

២៤៦. បើសិនជាលោកផឹកពីពែងពិសិដ្ឋត្រូវធ្វើដូចតទៅ៖

ក)លោកជាអធិបតីយកពែងព្រះលោហិតព្រះគ្រីស្តទាំងពោលថា៖ "សូមព្រះលោហិតព្រះគ្រីស្តរក្សាខ្ញុំទុកក្នុងជីវិតអស់កល្បជានិច្ច" (Sanguis Christi custodiat me in vitam aeternam)។ លោកទទួលព្រះលោហិតព្រះគ្រីស្ត ហើយជូនពែងព្រះលោហិតទៅលោកឧបដ្ឋាក ឬលោកបូជាចារ្យម្នាក់ទៀត។ ក្រោយមក លោកជូនព្រះកាយព្រះគ្រីស្តដល់គ្រីស្តបរិស័ទ (សូមមើលលេខ ១៦០-១៦២)។ លោកដែលចូលរួមថ្វាយអភិបូជាទៅដល់តុសក្ការបូជាម្តងម្នាក់ៗ (បើសិនមានពែងព្រះលោហិតពីរ ដូច្នេះទៅពីរនាក់ៗ) លោកលុតជង្គង់ទទួលព្រះលោហិតព្រះគ្រីស្តជូតពែងព្រះលោហិត និងត្រឡប់ទៅកន្លែងរបស់គាត់វិញ។

ខ)លោកជាអធិបតីទទួលព្រះលោហិតព្រះគ្រីស្តនៅតុសក្ការបូជា។ លោកបូជាចារ្យចូលរួមអាចទទួលព្រះលោហិតព្រះគ្រីស្តនៅកន្លែងផ្ទាល់ខ្លួន ដោយមានលោកឧបដ្ឋាក ឬលោកម្នាក់ជូនព្រះលោហិតព្រះគ្រីស្តបន្តទៅលោកម្នាក់ទៀត។ ក្រោយពីលោកម្នាក់ៗទទួលព្រះលោហិតព្រះគ្រីស្ត លោកខ្លួនឯង ឬលោកម្នាក់ដែលជូនពែងព្រះលោហិត ត្រូវជូតពែងព្រះលោហិត។

២៤៧. លោកឧបដ្ឋាកទទួលព្រះលោហិតព្រះគ្រីស្តដែលនៅសល់ បើសល់ច្រើន លោកផ្សេងៗអាចជួយបាន។ លោកឧបដ្ឋាក យកពែងពិសិដ្ឋទៅដល់តុតង្វាយ ហើយអ្នកបម្រើតុសក្ការបូជាជូតពែងព្រះលោហិត និងរៀបចំទុកនៅកន្លែងត្រឹមត្រូវ (សូមមើលលេខ ១៨៣)។

២៤៨. លោកបូជាចារ្យដែលចូលរួមអាចទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត នៅតុសក្ការបូជា។ ក្នុងករណីលោកជាអធិបតីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត តាមរបៀបធម្មតា (សូមមើលលេខ ១៥៨) យ៉ាងណាក៏ដោយ ត្រូវជ្រើសរើសរបៀបមួយ ដើម្បីទទួលព្រះលោហិតព្រះគ្រីស្ត ហើយអស់លោកដែលចូលរួមត្រូវធ្វើតាម។ ក្រោយពី លោកអធិបតីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត លោកដាក់ពែងព្រះលោហិតលើ កន្សែងពិសិដ្ឋនៅមួយចំហៀងលើតុសក្ការបូជា។ លោកដែលចូលរួមថ្វាយអភិបូជា មកដល់កណ្តាលតុសក្ការបូជា លុតជង្គង់ទទួលព្រះកាយព្រះគ្រីស្ត ទៅដល់ចំហៀងនៃតុសក្ការបូជាដែលបានដាក់ពែងព្រះលោហិត ហើយទទួលព្រះលោហិតព្រះគ្រីស្តតាមរបៀបដែលគេបានជ្រើសរើសដូចបាននិយាយនៅខាងលើនេះ។ លោកឧបដ្ឋាកទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ហើយសម្អាតពែងព្រះលោហិត តាមរបៀបដែលបានពន្យល់រួចហើយ។

២៤៩. បើសិនជាលោកដែលចូលរួមថ្វាយអភិបូជាទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត តាមរបៀបជ្រលក់ លោកជាអធិបតីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ត្រូវយកចិត្តទុកដាក់រក្សាទុកព្រះលោហិតព្រះគ្រីស្តគ្រប់គ្រាន់សម្រាប់អស់លោកដែលចូលរួមថ្វាយអភិបូជា។ ក្រោយមក លោកឧបដ្ឋាក ឬលោកម្នាក់ទៀត រៀបចំពែងព្រះលោហិតនៅកណ្តាល ឬនៅចំហៀងនៃតុសក្ការបូជា លើកន្សែងពិសិដ្ឋមួយ ជាមួយចានព្រះកាយដែលមានព្រះកាយព្រះគ្រីស្ត។

លោកដែលចូលរួមថ្វាយអភិបូជា ទៅដល់តុសក្ការបូជា លុតជង្គង់យកព្រះកាយព្រះគ្រីស្តជ្រលក់ក្នុងព្រះលោហិតព្រះគ្រីស្ត ក្រោយមក យកកន្សែងពិសិដ្ឋជូតពែងព្រះលោហិត ក្រោមចង្កាលោក ហើយទទួលព្រះកាយព្រះគ្រីស្តដែលបានជ្រលក់ក្នុងព្រះលោហិតព្រះគ្រីស្ត។ រួចទៅអង្គុយនៅកន្លែងដើមវិញ។

លោកឧបដ្ឋាកទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត តាមរបៀបដដែល ក្រោយពីពាក្យ "ព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត" (Corpus et Sanguis Christi) លោកឆ្លើយ អាម៉ែន។ លោកឧបដ្ឋាកទទួលព្រះលោហិតព្រះគ្រីស្តដែលនៅសល់ បើនៅសល់ច្រើនលោកផ្សេងៗអាចជួយបាន។ លោកឧបដ្ឋាកយកពែងពិសិដ្ឋទៅដល់តុតង្វាយ ហើយលោក ឬអ្នកបម្រើតុសក្ការបូជាជូតពែងព្រះលោហិត និងរៀបចំទុកនៅកន្លែងត្រឹមត្រូវ។

**ពិធីបញ្ចប់**

២៥០. លោកអធិបតីប្រារព្ធពិធីចប់ ដូចបានពន្យល់ហើយ (សូមមើលលេខ ១៦៦-១៦៨) រីឯលោកបូជាចារ្យដែលចូលរួមថ្វាយអភិបូជា ចាំនៅកន្លែងរបស់លោក។

២៥១. មុនចាកចេញពីតុសក្ការបូជា លោកដែលចូលរួមអភិបូជាឱនកាយខាងមុខតុសក្ការបូជា។ លោកអធិបតី និងលោកឧបដ្ឋាកថើបគោរពតុសក្ការបូជា។

## III. ពិធីអភិបូជាដែលមានលោកបូជាចារ្យតែម្នាក់ និងអ្នកបម្រើម្នាក់

២៥២. សម្រាប់ពិធីអភិបូជាដែលមានតែលោកបូជាចារ្យម្នាក់ និងអ្នកបម្រើម្នាក់ត្រូវប្រព្រឹត្តដូចពិធីអភិបូជាដែលមានគ្រីស្តបរិស័ទចូលរួម (សូមមើលលេខ ១២០-១៦៩)។ អ្នកបម្រើឆ្លើយផ្នែករបស់គ្រីស្តបរិស័ទ។

២៥៣. បើអ្នកបម្រើនោះជាលោកឧបដ្ឋាក គាត់ប្រព្រឹត្តមុខងាររបស់គាត់ (សូមមើលលេខ ១៧១-១៨៦) ព្រមទាំងត្រូវការឆ្លើយផ្នែកនៃគ្រីស្តបរិស័ទ។

២៥៤. មិនគួរថ្វាយអភិបូជាដោយគ្មានអ្នកចូលរួមទេ យ៉ាងតិចអ្នកបម្រើម្នាក់ ឬគ្រីស្តបរិស័ទម្នាក់។ បើសិនជាគ្មានគ្រីស្តបរិស័ទចូលរួមទេ មិនត្រូវការពាក្យស្វាគមន៍ ពាក្យផ្ដើម ឬពាក្យពន្យល់ ហើយប្រទានពរចុងក្រោយទេ។

២៥៥. មុនចាប់ផ្ដើមថ្វាយអភិបូជា ត្រូវរៀបចំចាន និងពែងពិសិដ្ឋនៅតុតង្វាយ ឬនៅលើតុសក្ការបូជាខាងស្ដាំដៃ។

### ពិធីប្រារព្ធ

២៥៦. លោកបូជាចារ្យទៅដល់តុសក្ការបូជា ឱនកាយគោរពជាមួយអ្នកបម្រើ ហើយថើបគោរពតុសក្ការបូជា រួចទៅកន្លែងអង្គុយ។ លោកអាចចាំនៅតុសក្ការបូជា និងត្រៀមរៀបចំសៀវភៅក្បួនពិធីបុណ្យលើតុសក្ការបូជា។ លោកបូជាចារ្យ ឬអ្នកបម្រើប្រកាសពាក្យបន្ទរពេលចូល។

២៥៧. លោកបូជាចារ្យឈរឡើង គូសសញ្ញាឈើឆ្កាង ទាំងពោលថា "ក្នុងព្រះនាមព្រះបិតា..." (In nomine Patris)។ លោកស្វាគមន៍អ្នកបម្រើដោយប្រើរូបមន្តស្វាគមន៍មួយ។

២៥៨. ពិធីសូមទទួលសារភាពរួច ធ្វើតាមពាក្យណែនាំពណ៌ក្រហម សូត្រធម៌លើកតម្កើង សិរីរុងរឿងរបស់ព្រះជាម្ចាស់។

២៥៩. ក្រោយមក លោកលើកដៃប្រណម្យទាំងពោលថា៖ "សូមបងប្អូនតាំងចិត្តអធិដ្ឋាន"។ លោកសូត្រពាក្យអធិដ្ឋានពេលចូល។ ទីបញ្ចប់នៃពាក្យអធិដ្ឋាន អ្នកបម្រើប្រកាស អាម៉ែន។

### ពិធីលើកតម្កើងព្រះបន្ទូលរបស់ព្រះជាម្ចាស់

២៦០. បើសិនជាធ្វើបាន គួរប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ពីតុព្រះបន្ទូល ឬបញ្ឈរព្រះគម្ពីរ។

២៦១. បន្ទាប់ពីពាក្យអធិដ្ឋានសរុប អ្នកបម្រើពិធីបុណ្យអានអត្ថបទទីមួយ និងស្មូតទំនុកតម្កើង ហើយអានអត្ថបទទីពីរ បើសិនជាមាន រួចច្រៀងបន្ទរ អាលេលូយ៉ា ឬបទចម្រៀងផ្សេង។

២៦២. ក្រោយមក បូជាចារ្យឱនកាយ ទាំងពោលថា "សូមព្រះអម្ចាស់គង់សណ្ឋិតនៅក្នុងចិត្ត" (Munda cor meum) ហើយប្រកាសព្រះបន្ទូលដំណឹងល្អ។ ពេលចប់លោកពោលថា "នេះជា ព្រះបន្ទូលដំណឹងល្អរបស់ព្រះជាម្ចាស់" ហើយអ្នកបម្រើពិធីបុណ្យឆ្លើយ "សូមកោតសរសើរ ព្រះអម្ចាស់យេស៊ូគ្រីស្ត"។ លោកបូជាចារ្យថើបព្រះគម្ពីរ ដោយពោលខ្សឹបៗថា "សូមឲ្យព្រះបន្ទូលដំណឹងល្អនេះជម្រះយើងខ្ញុំឲ្យរួចពីបាប" (Per evangelica dicta)។

២៦៣. លោកបូជាចារ្យ និងអ្នកបម្រើពិធីបុណ្យសូត្រធម៌ប្រកាសជំនឿ ដោយអនុវត្តតាមពាក្យណែនាំពណ៌ក្រហម។

២៦៤. រួចហើយពាក្យអង្វរដែលត្រូវមាន។ លោកបូជាចារ្យពោលពាក្យដើម និងពាក្យចុងក្រោយ ហើយអ្នកបម្រើអានពាក្យអង្វរ។

**ពិធីអរព្រះគុណព្រះជាម្ចាស់**

២៦៥. នៅក្នុងពិធីអរព្រះគុណដ៏វិសុទ្ធ គ្រប់យ៉ាងត្រូវធ្វើដូចពិធីអភិបូជាដែលមានគ្រីស្តបរិស័ទចូលរួម លើកលែងតែមានករណីផ្សេង។

២៦៦. បន្ទាប់ពិធីអបអរសាទរចប់ ត្រូវបន្ថែមពាក្យអធិដ្ឋានរបស់ព្រះអម្ចាស់ ដោយលោកបូជាចារ្យពោលថា "ឱ ព្រះអម្ចាស់យេស៊ូគ្រីស្តអើយ! ព្រះអង្គមានព្រះបន្ទូលទៅកាន់ក្រុមគ្រីស្តទូតថា" (Domine Iesu Christe, qui dixisti)។ ក្រោយមក បន្ថែម "សូមឲ្យសេចក្តីសុខសាន្តរបស់ព្រះអម្ចាស់គង់នៅជាមួយបងប្អូន" អ្នកបម្រើឆ្លើយថា "ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង"។ លោកបូជាចារ្យបង្ហាញសញ្ញានៃសេចក្តីសុខសាន្តដល់អ្នកបម្រើពិធីបុណ្យ។

២៦៧. បន្ទាប់មក លោកបូជាចារ្យរួមនឹងអ្នកបម្រើពិធីបុណ្យសូត្រ "ឱ កូនចៀមរបស់ព្រះជាម្ចាស់" (Agnus Dei) លោកបូជាចារ្យកាច់នំព្រះកាយលើចានព្រះកាយ ហើយយកបំណែកតូចមួយដាក់ក្នុងពែងព្រះលោហិត ទាំងពោលខ្សឹបៗថា "សូមឲ្យព្រះកាយព្រះគ្រីស្ត រក្សាខ្ញុំទុកក្នុងជីវិតអស់កល្បជានិច្ច" (Haec commixtio)។

២៦៨. ក្រោយពីកាច់នំព្រះកាយហើយ លោកយកបំណែកតូចមួយដាក់ក្នុងពែងព្រះលោហិត ដោយពោលខ្សឹបៗថា "ឱ ព្រះអម្ចាស់យេស៊ូគ្រីស្ត! ជាព្រះបុត្រានៃព្រះជាម្ចាស់" (Domine Iesu Christe, Fili Dei vivi) ឬ "បពិត្រព្រះអម្ចាស់យេស៊ូគ្រីស្ត! សូមប្រោសឲ្យខ្ញុំដែលទទួលព្រះកាយ និងព្រះលោហិត" (Perceptio Corporis et Sanguinis tui)។ លោកបូជាចារ្យលុតជង្គង់យកនំព្រះកាយ បើមានអ្នកបម្រើពិធីបុណ្យទទួលព្រះកាយព្រះគ្រីស្ត លោកបែរទៅរកអ្នកបម្រើ ហើយកាន់ព្រះកាយព្រះគ្រីស្តលើចានពិសិដ្ឋ លើកឡើងបន្តិច ទាំងពោលថា៖ "នេះជាកូនចៀមរបស់ព្រះជាម្ចាស់" រួមជាមួយអ្នកបម្រើពោលបន្តថា "បពិត្រព្រះអម្ចាស់! ខ្ញុំមិនសមនឹងទទួល..."។ ពេលនោះ នៅមុខតុសក្ការបូជា លោកបូជាចារ្យទទួលព្រះកាយព្រះគ្រីស្ត។ យ៉ាងណាក៏ដោយ បើអ្នកបម្រើពិធីបុណ្យមិនទទួលព្រះកាយព្រះគ្រីស្ត ក្រោយមក លោកបូជាចារ្យលុតជង្គង់យកព្រះកាយព្រះគ្រីស្ត ហើយទៅខាងមុខតុសក្ការបូជាពោលខ្សឹបៗថា "បពិត្រព្រះអម្ចាស់! ខ្ញុំមិនសមនឹងទទួល..." (Domine, non sum dignus) និង "សូមឲ្យព្រះលោហិតព្រះគ្រីស្ត រក្សាខ្ញុំទុកក្នុងជីវិតអស់កល្បជានិច្ច" (Corpus Christi custodiat me in vitam aeternam) ហើយទទួលព្រះកាយព្រះគ្រីស្ត។ ក្រោយមក លោកយកពែងព្រះលោហិត ហើយពោលខ្សឹបៗថា "សូមព្រះលោហិតព្រះគ្រីស្ត រក្សាខ្ញុំទុកក្នុងជីវិតអស់កល្បជានិច្ច" (Sanguis Christi custodiat me in vitam aeternam) ហើយទទួលព្រះលោហិតព្រះគ្រីស្ត។

២៦៩. អ្នកបម្រើពិធីបុណ្យទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្តមុន ត្រូវប្រកាសពាក្យបន្ទរនៃពិធីទទួលព្រះកាយព្រះគ្រីស្ត ដោយអ្នកបម្រើពិធីបុណ្យ ឬលោកបូជាចារ្យផ្ទាល់។

២៧០. លោកបូជាចារ្យជូតពែងព្រះលោហិតនៅតុតង្វាយ ឬនៅលើតុសក្ការបូជា។ ក្រោយមកដាក់ពែងព្រះលោហិតនៅលើតុសក្ការបូជា។

២៧១. ក្រោយពីជូតពែងព្រះលោហិត លោកបូជាចារ្យនៅស្ងៀមស្ងាត់ ហើយពោលពាក្យអធិដ្ឋាន ក្រោយពីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។

**ពិធីបញ្ចប់**

២៧២. ពិធីបញ្ចប់ ដូចគ្នានឹងពេលថ្វាយអភិបូជាដែលមានគ្រីស្តបរិស័ទចូលរួម លើកលែងតែពាក្យអភិបូជាចប់ហើយ ព្រះជាម្ចាស់ចាត់បងប្អូនឲ្យទៅ គឺលុបចោល (Ite, missa est)។ លោកបូជាចារ្យគោរពថើបតុសក្ការបូជាតាមរបៀបធម្មតា បន្ទាប់មក លោកឱនកាយគោរពជាមួយអ្នកបម្រើពិធីបុណ្យ ហើយចាកចេញទៅ។

## IV. ក្បួនទូទៅមួយចំនួនពីរបៀបថ្វាយអភិបូជា

**គោរពតុសក្ការបូជា និងព្រះគម្ពីរដំណឹងល្អ**

២៧៣. តាមប្រពៃណីថើបគោរពតុសក្ការបូជា និងសៀវភៅព្រះគម្ពីរដំណឹងល្អ គឺជារបៀបមួយដើម្បីបង្ហាញពីការគោរពថ្វាយបង្គំ ទោះបីជាយ៉ាងណាក៏ដោយ លោកអភិបាលត្រូវរកសញ្ញាសម្គាល់ណាមួយជំនួសការថើបនេះដើម្បីបង្ហាញពីការគោរព ពីព្រោះ នៅកន្លែងខ្លះមិនមានប្រពៃណីទម្លាប់ថើបរបៀបនេះ ដែលមហាសន្និបាតរបស់លោកអភិបាល បានទទួលសេចក្តីអនុញ្ញាតពីសន្តអាសនៈ។

**ការលុតជង្គង់ និងឱនកាយ**

២៧៤. ការលុតជង្គង់បន្ទាបខាងស្តាំរហូតដល់ដី មានន័យថា៖ ការគោរពលើកតម្កើងថ្វាយបង្គំដូច្នេះហើយ ត្រូវទុកសញ្ញានេះសម្រាប់អគ្គសញ្ញាព្រះកាយព្រះលោហិតព្រះគ្រីស្ត និងពិធីគោរពព្រះឈើឆ្កាងនៅថ្ងៃសុក្រពិសិដ្ឋ រហូតដល់ថ្ងៃសៅរ៍ពិសិដ្ឋ ចាប់ផ្តើមរាត្រីបុណ្យចម្លង។

ពេលកំពុងថ្វាយអភិបូជា លោកបូជាចារ្យត្រូវលុតជង្គង់បីដង គឺពេលបង្ហាញព្រះកាយព្រះគ្រីស្ត ពេលបង្ហាញពែងព្រះលោហិតព្រះគ្រីស្ត និងមុនទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។ លក្ខណៈពិសេសណាមួយដែលមានលោកបូជាចារ្យផ្សេងៗចូលរួមថ្វាយអភិបូជាត្រូវធ្វើតាមពាក្យណែនាំនៅខាងលើនេះ (សូមមើលលេខ ២១០-២៥១)។

ប្រសិនបើ មានព្រះពន្លានៅទីសក្ការបូជា លោកបូជាចារ្យ លោកឧបដ្ឋាក និងអ្នកបម្រើពិធីបុណ្យត្រូវលុតជង្គង់ពេលទៅនៅជិត ឬចាកចេញពីតុសក្ការបូជាមិនត្រូវលុតជង្គង់ពេលគេកំពុងធ្វើពិធីអភិបូជា។ ក្រៅពីនេះ គ្រីស្តបរិស័ទត្រូវការលុតជង្គង់ លើកលែងតែករណីដែលគេកំពុងដង្ហែ។ អ្នកបម្រើដែលហែកាន់ឈើឆ្កាង ឬទៀន មិនត្រូវការលុតជង្គង់ទេ ប៉ុន្តែត្រូវការឱនក្បាលគោរព។

២៧៥. ការឱនកាយ ឬឱនក្បាល បង្ហាញពីការគោរព និងជាកិត្តិយសចំពោះមនុស្ស ឬជាសញ្ញាសម្គាល់របស់គេ។ ការគោរពឱនកាយមានពីរប្រភេទ៖ ការគោរពឱនក្បាល និងការគោរពឱនកាយ។

ក)ការឱនក្បាល គឺគោរពដល់ព្រះនាមទាំងបី ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា ព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះនាមព្រះយេស៊ូ ព្រះនាមនៃព្រះនាងព្រហ្មចារិនីម៉ារី និងក្នុងពេលថ្វាយអភិបូជាដែលនឹករឭកដល់សន្តៈឬសន្តីនោះ។

ខ)ការឱនកាយគោរពខាងមុខតុសក្ការបូជា ក្នុងពេលដែលពោលពាក្យអធិដ្ឋាន "សូមព្រះអម្ចាស់លាងជម្រះចិត្តគំនិតរបស់ខ្ញុំ" (Munda cor meum) និង "សូមប្រោសប្រទានឲ្យយើងខ្ញុំមានចិត្តសុភាពរាបសា" (In spiritu humilitatis)។ នៅក្នុងពាក្យធម៌ប្រកាសជំនឿ "ព្រះអង្គមានកំណើតជាមនុស្សដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ" (et incarnates est)។ នៅក្នុងសាសនក្រឹត្យក្រុងរ៉ូមធម៌អរព្រះគុណដ៏វិសុទ្ធទី១ នៅត្រង់ "បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ! យើងខ្ញុំសូមឱនកាយទូលអង្វរព្រះអង្គ" (Supplices te rogamus)។ តាមរបៀបដូចគ្នា លោកឧបដ្ឋាកឱនកាយពេលទូលអង្វរសូមប្រទានពរមុនប្រកាសព្រះបន្ទូលដំណឹងល្អ។ លើសពីនេះទៅទៀត លោកបូជាចារ្យឱនកាយបន្តិច ពេលលោកប្រកាសព្រះបន្ទូលរបស់ព្រះអម្ចាស់នៅពេលប្រសិទ្ធពរលើនំ និងស្រាតង្វាយ។

### ការអុជធូប ឬដុតកំញាន

២៧៦. ការអុជធូប ឬដុតកំញាន ជារបៀបមួយដើម្បីបង្ហាញពីការគោរព និងអធិដ្ឋាន ដូចយើងបានអានក្នុងព្រះគម្ពីរ (សូមមើលទំនុកតម្កើងលេខ ១៤០ (១៤១),២ វវ ៨.៣)។

ធូប ឬកំញាន អាចប្រើតាមសេចក្តីត្រូវការក្នុងពេលថ្វាយអភិបូជា៖

ក)នៅពេលហែចូល។

ខ)នៅពេលចាប់ផ្តើមពិធីអភិបូជា ដុតធូប ឬកំញានដើម្បីគោរពព្រះឈើឆ្កាង និងតុសក្ការបូជា។

គ)ក្នុងពេលដង្ហែព្រះគម្ពីរដំណឹងល្អ និងប្រកាសព្រះបន្ទូលដំណឹងល្អ។

ឃ)បន្ទាប់ពីរៀបចំនំ និងស្រាតង្វាយ នៅលើតុសក្ការបូជា មានដុតកំញាន ឬធូបដើម្បីថ្វាយតង្វាយ ព្រះឈើឆ្កាង និងគោរពតុសក្ការបូជា ព្រមទាំងលោកបូជាចារ្យ និងគ្រីស្តបរិស័ទ។

ង)នៅពេលលោកលើកបង្ហាញនំព្រះកាយ និងពែងព្រះលោហិតព្រះគ្រីស្ត ក្រោយពេលពិធីប្រសិទ្ធពរព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។

២៧៧. លោកបូជាចារ្យ រៀបចំធូប ឬកំញានក្នុងចង្ក្រានកំញាន ប្រទានពរគូសសញ្ញាឈើឆ្កាងដោយមិនពោលពាក្យអ្វីទាំងអស់។

មុន និងក្រោយ អុជធូប ឬបក់ផ្សែងកំញាន ត្រូវឱនកាយខាងមុខអង្គប្រជុំ ឬវត្ថុសក្ការបូជាដែលយើងគោរព លើកលែងតែ តុសក្ការបូជា និងតង្វាយសម្រាប់ថ្វាយអភិបូជា។

ត្រូវគោរពបក់ផ្សែងកំញានបីដង ទៅលើព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត អដ្ឋិធាតុនៃព្រះឈើឆ្កាង រូបព្រះយេស៊ូដែលបានរៀបចំសម្រាប់ថ្វាយបង្គំ តង្វាយសម្រាប់ថ្វាយអភិបូជា ព្រះឈើឆ្កាងជាប់នឹងតុសក្ការបូជា សៀវភៅព្រះគម្ពីរដំណឹងល្អ ទៀនព្រះជ័យ លោកបូជាចារ្យ និងគ្រីស្តបរិស័ទ។ ត្រូវគោរពដោយបក់ផ្សែងកំញានពីរដងសម្រាប់អដ្ឋិធាតុ និងរូបរបស់សន្តៈសន្តីដែលបានរៀបចំដើម្បីកោតសរសើរ។ យ៉ាងណាក៏ត្រូវការបក់ផ្សែងកំញាន ក្រោយបានបក់ផ្សែងកំញានគោរពនៅមុខតុសក្ការបូជា។ ត្រូវបក់ផ្សែងកំញានគោរពនៅមុខតុសក្ការបូជាតាមរបៀបនេះ ៖

ក)បើសិនជាតុសក្ការបូជាមិនជាប់នឹងជញ្ជាំងទេ លោកដើរជុំវិញហើយបក់ផ្សែងកំញានមួយៗ។

ខ)បើសិនជាតុសក្ការបូជាជាប់នឹងជញ្ជាំង លោកដើរទៅខាងស្តាំដៃ ហើយបក់ផ្សែងកំញានមួយៗ ក្រោយមក ទៅខាងឆ្វេងដៃហើយបក់ផ្សែងកំញានមួយៗ។ បើសិនជាព្រះឈើ ឆ្កាងនៅលើ ឬនៅជិតតុសក្ការបូជា លោកបូជាចារ្យបក់ផ្សែងកំញានទៅលើព្រះឈើឆ្កាង នោះមុនបក់ផ្សែងកំញានទៅដល់តុសក្ការបូជា។ បើសិនជាព្រះឈើឆ្កាងនៅកន្លែងផ្សេង លោកបក់ផ្សែងកំញាន ពេលដើរទៅខាងមុខព្រះឈើឆ្កាងនោះ។ លោកបូជាចារ្យបក់ផ្សែងកំញាន ទៅលើតង្វាយបីដង ឬគូសសញ្ញាឈើឆ្កាងលើតង្វាយ ក្រោយមក បក់ផ្សែងកំញានទៅលើព្រះឈើឆ្កាង និងតុសក្ការបូជា។

### ពិធីជម្រះឲ្យបានស្អាតបរិសុទ្ធ

២៧៨. គ្រប់ពេលដែលបំណែកតូចនៃនំព្រះកាយជាប់និងម្រាមដៃ ជាពិសេស ក្រោយពីពិធីកាច់នំព្រះកាយ ឬជូនព្រះកាយព្រះគ្រីស្តដល់គ្រីស្តបរិស័ទ លោកបូជាចារ្យត្រូវជូតម្រាមដៃលើចានព្រះកាយ ឬបើសិនជាចាំបាច់លាងម្រាមដៃ។ ដូចគ្នាដែរ លោកបូជាចារ្យ ត្រូវប្រមូលបំណែកតូចនៃនំព្រះកាយ ដែលធ្លាក់ខាងក្រៅចានព្រះកាយ។

២៧៩. លោកបូជាចារ្យ លោកឧបដ្ឋាក ឬអ្នកបម្រើតុសក្ការបូជាជម្រះចានព្រះកាយ និងពែងព្រះលោហិត (គួរធ្វើពិធីជម្រះលើតុតង្វាយ) ក្រោយពីពិធីទទួលព្រះកាយនិងព្រះលោហិតព្រះគ្រីស្ត ឬក្រោយពីពិធីអភិបូជា។ ត្រូវជម្រះពែងព្រះលោហិតជាមួយទឹក ឬជាមួយទឹកស្រាដែលអ្នកធ្វើពិធីជម្រះត្រូវពិសាទាំងអស់។ លោកជម្រះចានព្រះកាយជាមួយកន្សែងជូតពែងព្រះលោហិត។ ត្រូវដឹងថា ត្រូវពិសាព្រះលោហិតព្រះគ្រីស្តដែលនៅសល់ទាំងអស់ ក្រោយពីពិធីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។

២៨០. បើសិនជានំព្រះកាយមួយ ឬបំណែកតូចមួយបានធ្លាក់ត្រូវរើសយកមកវិញ។ បើសិនព្រះលោហិតព្រះគ្រីស្តធ្លាក់ ត្រូវលាងកន្លែងនោះជាមួយទឹក ហើយទឹកនោះយកទៅបន្ទប់លោកផ្លាស់ប្តូរសម្លៀកបំពាក់ sacrarium ។

## ពិធីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត

២៨១. ជាការល្អណាស់ បើសិនជាគ្រីស្តបរិស័ទអាចទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត (មានន័យថា ទទួលនំព្រះកាយ និងព្រះលោហិត) ពីព្រោះរបៀបនេះបញ្ជាក់ច្បាស់ជាសញ្ញារបស់ព្រះយេស៊ូដែលបានបូជាព្រះជន្ម និងចងសម្ព័ន្ធមេត្រីថ្មីអស់កល្បជានិច្ច។[119]

២៨២. លោកគង្វាល គួរអប់រំអស់អ្នកដែលចូលរួមថ្វាយអភិបូជា ដើម្បីឲ្យគេអាចយល់ការអប់រំរបស់ព្រះសហគមន៍កាតូលិក តាមរបៀបអប់រំនៃមហាសន្និបាតត្រែនតូ។ ជាពិសេស ត្រូវអប់រំឲ្យគេយល់ច្បាស់ថា គ្រីស្តបរិស័ទទទួលនំព្រះកាយតែមួយ ឬព្រះលោហិតតែមួយដូចគ្នានឹងទទួលទាំងព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត គឺគេទទួលព្រះអំណោយទានទាំងអស់ដែលយើងត្រូវការសម្រាប់ការសង្គ្រោះ។[120] ត្រូវអប់រំថា ព្រះសហគមន៍ទទួលខុសត្រូវលើអគ្គសញ្ញានៅលើលោកនេះ មានអំណាចផ្លាស់ប្តូរចំណុចខ្លះៗ (ពីខ្លឹមសារនៃអគ្គសញ្ញា) តាមកាលៈទេសៈសម័យកាល និងទីកន្លែងដើម្បីបន្ថែមការគោរពចំពោះអគ្គសញ្ញា និងមានប្រយោជន៍ខាងវិញ្ញាណ។[121] ម្យ៉ាងទៀត គួរជំរុញឲ្យគ្រីស្តបរិស័ទចូលរួមយ៉ាងសកម្មក្នុងអភិបូជានេះ ដែលបង្ហាញច្បាស់ពីសក្ការបូជារបស់ព្រះយេស៊ូគ្រីស្ត។

២៨៣. ក្រៅពីករណីដែលមានក្នុងសៀវភៅក្បួនពិធីបុណ្យ គ្រីស្តបរិស័ទអាចទទួលទាំងព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ក្នុងករណីដូចតទៅ៖

ក)លោកបូជាចារ្យដែលមិនអាចថ្វាយអភិបូជា ឬចូលរួមថ្វាយអភិបូជា។

ខ)លោកឧបដ្ឋាក និងអ្នកបម្រើឯទៀតៗដែលមានមុខងារពិសេសពេលថ្វាយអភិបូជា។

គ.)អភិបូជាសម្រាប់សមាជិកក្រុមគ្រួសារ ឬអភិបូជាសម្រាប់និស្សិតទេវវិទ្យាល័យ ឬអស់អ្នកដែលចូលរួមក្នុងសំណាក់ធម៌ ឬអង្គប្រជុំណែនាំគ្រីស្តបរិស័ទ។ លោកអភិបាលប្រចាំភូមិភាគត្រូវដាក់បទបញ្ញាសម្រាប់ពិធីទទួលព្រះកាយព្រះគ្រីស្ត ដោយទទួលទាំងព្រះកាយ និងព្រះលោហិតព្រះគ្រីស្តដែលត្រូវគោរពក្នុងភូមិភាគ ព្រមទាំងតាមផ្ទះបព្វជិតបព្វជិតា និងពិធីអភិបូជាជាមួយក្រុមតូចៗ។ លោកអភិបាលអាចអនុញ្ញាតលោកបូជាចារ្យដែលទទួលខុសត្រូវក្នុងព្រះសហគមន៍ប្រចាំតំបន់ឲ្យលោកជូនទាំងព្រះកាយ និងព្រះលោហិតព្រះគ្រីស្តដល់អង្គប្រជុំ លុះត្រាតែគ្រីស្តបរិស័ទទទួលការអប់រំអំពីរបៀបត្រឹមត្រូវដើម្បីទទួលទាំងព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត គ្មានហានិភ័យបាត់បង់កិត្តិយស សេចក្តីថ្លៃថ្នូររបស់អគ្គសញ្ញាការគោរពពិធីនេះ ឬបង្កើតសភាពមិនសូវស្រួល ដោយសារចំនួនមនុស្សច្រើនពេក។

២៨៤. ពេលណាដែលគ្រីស្តបរិស័ទទទួលទាំងព្រះកាយនិងព្រះលោហិតព្រះគ្រីស្ត

[119] Cf. Sacred Congregation of Rites, Instruction *Eucharisticum mysterium*, On the worship of the Eucharist, 25 May 1967, no. 32: AAS 59 (1967), p. 558.
[120] Cf. Council of Trent, session 21, *Doctrina de communione sub utraque specie et parvulorum*, 16 July 1562, chapters 1-3: Denz-Schön, 1725-1729.
[121] Cf. Council of Trent, session 21, *Doctrina de communione sub utraque specie et parvulorum*, chapter 2: Denz-Schön, 1728.

ក)លោកឧបដ្ឋាក (បើសិនជាគ្មានលោកឧបដ្ឋាក លោកបូជាចារ្យ ឬអ្នកបម្រើតុសក្ការបូជា ឬអ្នកបម្រើពិសេសជូនព្រះកាយព្រះគ្រីស្ត ឬគ្រីស្តបរិស័ទដែលទទួលមុខងារយ៉ាងពិសេសសម្រាប់ពិធីអភិបូជាថ្ងៃនោះ) កាន់ពែងព្រះលោហិតព្រះគ្រីស្ត។

ខ)លោកបូជាចារ្យ ឬលោកឧបដ្ឋាក ឬអ្នកបម្រើតុសក្ការបូជាទៅដល់តុសក្ការបូជា ហើយទទួលព្រះលោហិតព្រះគ្រីស្តដែលនៅសល់ ក្រោយមកជូតពែងព្រះលោហិតជាមួយកន្សែងជូតពែងព្រះលោហិត ហើយទុកចានព្រះកាយ និងពែងព្រះលោហិតតាមរបៀបត្រឹមត្រូវ។ បើសិនជាមានគ្រីស្តបរិស័ទម្នាក់មិនចង់ទទួលទាំងព្រះកាយ និងព្រះលោហិត ព្រះគ្រីស្តទេ លោកអាចទទួលតែព្រះកាយព្រះគ្រីស្តក៏បានដែរ។

២៨៥. សម្រាប់គ្រីស្តបរិស័ទដែលទទួលទាំងព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត គួររៀបចំមុនៈ

ក)បើសិនជាគ្រីស្តបរិស័ទទទួលព្រះលោហិតព្រះគ្រីស្ត ដោយផឹកពីពែងព្រះលោហិត គួររៀបចំពែងព្រះលោហិតច្រើន ឬពែងព្រះលោហិតមួយធំល្មម។ យ៉ាងណា ត្រូវយកចិត្តទុកដាក់អំពីចំនួនព្រះលោហិតព្រះគ្រីស្តដែលត្រូវការ ពីព្រោះពិធីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្តរួចហើយ ត្រូវទទួលព្រះលោហិតទាំងអស់ដែលនៅសល់។

ខ)បើសិនជាទទួលទាំងព្រះកាយ និងព្រះលោហិតព្រះគ្រីស្តតាមរបៀបជ្រលក់ (intinction) ដូច្នេះ ត្រូវយកចិត្តទុកដាក់អំពីនំប៉័ងតង្វាយ ដោយជៀសវាងកុំឲ្យរៀបចំនំតង្វាយតូចពេក ឬស្តើងពេក ផ្ទុយទៅវិញ ក្រាស់ជាងធម្មតា ដូច្នេះ ក្រោយពីបានជ្រលក់ព្រះកាយក្នុងព្រះលោហិតព្រះគ្រីស្ត គ្រីស្តបរិស័ទអាចទទួលទាំងព្រះកាយ និងព្រះលោហិតព្រះគ្រីស្តយ៉ាងងាយស្រួល។

២៨៦. ក្រោយពីបានទទួលព្រះកាយព្រះគ្រីស្ត គ្រីស្តបរិស័ទទៅខាងមុខអ្នកបម្រើដែលកាន់ពែងព្រះលោហិតព្រះគ្រីស្ត។ អ្នកបម្រើពោលថា៖ ព្រះលោហិតព្រះគ្រីស្ត។ អង្គប្រជុំឆ្លើយថា៖ អាម៉ែន! អ្នកបម្រើជូនពែងព្រះលោហិត។ គ្រីស្តបរិស័ទទួលពែងព្រះលោហិត ក្រោយមកទទួលព្រះលោហិតព្រះគ្រីស្តតែបន្តិចប៉ុណ្ណោះ ហើយជូនពែងព្រះលោហិតដល់អ្នកបម្រើវិញ រួចចាកចេញទៅ។ អ្នកបម្រើជូតមាត់ពែងព្រះលោហិត ជាមួយកន្សែងជូតពែងព្រះលោហិត។

២៨៧. បើគ្រីស្តបរិស័ទទទួលទាំងព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត តាមរបៀបជ្រលក់ (intinction) គេទៅដល់លោកបូជាចារ្យដោយកាន់ចានព្រះកាយខាងក្រោមចង្កា។ លោកបូជាចារ្យកាន់ចានព្រះកាយព្រះគ្រីស្ត អ្នកបម្រើផ្សេងទៀតកាន់ពែងព្រះលោហិត។ លោកបូជាចារ្យយកនំព្រះកាយមួយជ្រលក់ក្នុងព្រះលោហិតព្រះគ្រីស្ត បង្ហាញឲ្យគ្រីស្តបរិស័ទឃើញ ដោយពោលថា៖ ព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត (Corpus et Sanguis Christi)។ អង្គប្រជុំឆ្លើយថា៖ អាម៉ែន។ គ្រីស្តបរិស័ទទទួលទាំងព្រះកាយ និងព្រះលោហិតព្រះគ្រីស្តក្នុងមាត់របស់គាត់ ហើយចេញទៅកន្លែងរបស់គាត់វិញ។

## ជំពូកទី ៥

## ការរៀបចំព្រះវិហារ និងគ្រឿងសង្ហារិមសម្រាប់ពិធីអភិបូជា

### I. គោលការណ៍ទូទៅ

២៨៨. ជាការធម្មតា សម្រាប់ប្រារព្ធពិធីអភិបូជា ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ចូលរួមនៅព្រះវិហារ។ ប្រសិនបើគ្មានព្រះវិហារ ឬក៏ព្រះវិហារតូចពេក គេរួបរួមគ្នានៅកន្លែងផ្សេង ដែលគួរសមនឹងពិធីដ៏អស្ចារ្យដ៏រុងរឿងនេះ។ ដូច្នេះហើយ ត្រូវរៀបចំព្រះវិហារ និងកន្លែងផ្សេង ដើម្បីប្រារព្ធសកម្មភាពនៃសក្ការបូជា និងដើម្បីជួយឲ្យគ្រីស្តបរិស័ទចូលរួមយ៉ាងសកម្ម។ អគារជាដ៏សក្ការៈ និងអ្វីផ្សេងៗដែលត្រូវការសម្រាប់ប្រារព្ធសកម្មភាពជាទីសក្ការបូជា ត្រូវឲ្យបានស្អាត និងជាសញ្ញាសម្គាល់នូវពិភពសក្ការៈនៅស្ថានបរមសុខ។[122]

២៨៩. ដូច្នេះហើយ គ្រប់ពេលវេលាព្រះសហគមន៍ធ្លាប់រកជំនួយពីសិល្បៈ និងទទួលវប្បធម៌សិល្បៈដែលមកពីគ្រប់ជាតិគ្រប់ទីកន្លែង។[123] តាមពិត ដូចព្រះសហគមន៍ខំប្រឹងរក្សាទុកទ្រព្យសម្បត្តិសិល្បៈដែលបានទទួលតាំងពីសម័យបុរាណ[124] ខំប្រឹងគាំទ្រសិល្បៈថ្មីៗដែលសមនឹងសម័យបច្ចុប្បន្នកាលនេះ។[125] ដោយសារហេតុនេះ ក្នុងការជ្រើសរើសអ្នកសិល្បៈ និងស្នាដៃសិល្បៈ ដើម្បីប្រើប្រាស់នៅព្រះវិហារ ត្រូវមានល័ក្ខខ័ណ្ឌមួយគឺ ត្រូវតែបង្ហាញនៃ ភាពសិល្បៈល្អប្រសើរ ហើយដែលត្រូវបង្កើនជំនឿ និងសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់ ព្រមទាំងបញ្ជាក់យ៉ាងច្បាស់គោលដៅដែលមាន។[126]

២៩០. សម្រាប់ព្រះវិហារទាំងអស់ គួរមានពិធីឆ្លងព្រះវិហារ ឬយ៉ាងតិចពិធីប្រទានពរ។ រីឯវិសាលវិហារវិញ ត្រូវមានពិធីឆ្លងព្រះវិហារយ៉ាងឱឡារិក។

២៩១. ដើម្បីសាងសង់ ឬជួសជុលសាជាថ្មីនូវអគារដ៏សក្ការៈ ត្រូវសួរយោបល់របស់គណៈកម្មការពិធីបុណ្យ និងសិល្បៈជាទីសក្ការៈ។ លោកអភិបាលភូមិភាគ គួរសួរយោបល់គណៈ កម្មការនេះដែរ ពេលលោកត្រូវការបង្កើតបទបញ្ជាអំពីការសាងសង់ រៀបចំប្លង់សម្រាប់អគារថ្មី និងការសម្រេចសំខាន់ៗអំពីរឿងនេះ។[127]

២៩២. ភាពស្អាត និងភាពថ្លៃថ្នូរនៃព្រះវិហារ ត្រូវគួរសមនឹងភាពសាមញ្ញ មិនមែនដោយអំនួត។ ពេលជ្រើសរើសវត្ថុធាតុនៃសម្ភារៈ និងគ្រឿងសង្ហារិម ត្រូវគោរពគុណភាពនៃវត្ថុធាតុនោះ គោលដៅអប់រំអ្នកជឿ និងភាពថ្លៃថ្នូរនៃទីសក្ការៈ។

---

[122] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, nos. 122-124; Decree on the Ministry and Life of Priests, *Presbyterorum ordinis*, no. 5; Sacred Congregation of Rites, Instruction *Inter Oecumenici*, on the orderly carrying out of the Constitution on the Sacred Liturgy, 26 September 1964, no. 90: AAS 56 (1964), p. 897; Sacred Congregation of Rites, Instruction Eucharisticum mysterium, On the worship of the Eucharist, 25 May 1967, no. 24: AAS 59 (1967), p. 554; *Codex Iuris Canonici*, can. 932 § 1.

[123] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 123.

[124] Cf. Sacred Congregation of Rites, Instruction Eucharisticum mysterium, On the worship of the Eucharist, 25 May 1967, no. 24: AAS 59 (1967), p. 554.

[125] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, nos. 123, 129; Sacred Congregation of Rites, Instruction *Inter Oecumenici*, on the orderly carrying out of the Constitution on the Sacred Liturgy, 26 September 1964, no. 13c: AAS 56 (1964), p. 880.

[126] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 123.

[127] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 126; Sacred Congregation of Rites, Instruction *Inter Oecumenici*, on the orderly carrying out of the Constitution on the Sacred Liturgy, 26 September 1964, no. 91: AAS 56 (1964), p. 898.

២៩៣. ការរៀបចំអគារសក្ការបូជា និងបរិវេណជុំវិញ ដែលឆ្លើយតបនឹងសេចក្តីត្រូវការនាសម័យបច្ចុប្បន្ននេះ ត្រូវយកចិត្តទុកដាក់ មិនមែនតែអំពីគោលការណ៍ដែលទាក់ទងនឹងសកម្មភាពប៉ុណ្ណោះ គឺអំពីចំណុចខ្លះដែលជួយឲ្យគ្រីស្តបរិស័ទមានភាពងាយស្រួលក្នុងការចូលរួម។

២៩៤. ប្រជារាស្រ្តរបស់ព្រះជាម្ចាស់ ដែលចូលរួមថ្វាយអភិបូជាមានរបៀប និងរចនាសម្ព័ន្ធតាមលំដាប់ថ្នាក់ត្រឹមត្រូវ ដែលពិធីបុណ្យបង្ហាញតាមផ្នែកពិធីមុខងារបម្រើ និងសកម្មភាពនៅទីសក្ការៈផ្សេងៗ។ របៀបរៀបចំអគារដ៏សក្ការៈត្រូវជួយបង្ហាញរូបភាពនៃព្រះសហគមន៍ដែលរួបរួមគ្នា ត្រូវជួយឲ្យអស់អ្នកដែលចូលរួមមានកន្លែងរបស់ខ្លួន និងមានភាពងាយស្រួលក្នុងការបំពេញសកម្មភាពផ្ទាល់ខ្លួន។ គ្រីស្តបរិស័ទ និងក្រុមអ្នកច្រៀង គួរមានកន្លែងត្រឹមត្រូវដែលជួយឲ្យចូលរួមយ៉ាងសកម្ម។[128] លោកបូជាចារ្យដែលធ្វើជាអធិបតី លោកឧបដ្ឋាក និងអ្នកបម្រើពិធីបុណ្យមានកន្លែងត្រឹមត្រូវ នៅទីសក្ការបូជាគួររៀបចំកន្លែងមួយសម្រាប់អស់លោកបូជាចារ្យដែលចូលរួមថ្វាយអភិបូជា។ ប្រសិនបើចំនួនបូជាចារ្យច្រើនពេក គួររៀបចំកន្លែងផ្សេងសម្រាប់លោក យ៉ាងណាក៏ត្រូវការរៀបចំនៅជិតតុសក្ការបូជា។ គោលការណ៍ទាំងអស់នេះ ទោះបីបង្ហាញរចនាសម្ព័ន្ធតាមលំដាប់ថ្នាក់ និងមុខងារផ្សេងពីគ្នា យ៉ាងណាក៏ត្រូវបង្ហាញឯកភាពនៃប្រជារាស្រ្តរបស់ព្រះជាម្ចាស់។ ពិតប្រាកដមែន ភាពស្អាតនៃអគារដ៏សក្ការៈ គ្រឿងសង្ហារិម និងសម្ភារផ្សេងៗត្រូវបង្ហាញពីសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ និងភាពដ៏វិសុទ្ធនៃពិធីដែលគ្រីស្តបរិស័ទប្រារព្ធនៅកន្លែងនោះ។

## II. ការរៀបចំទីសក្ការបូជាសម្រាប់អភិបូជា

២៩៥. ទីសក្ការបូជា ជាកន្លែងដែលដាក់តុសក្ការបូជា កន្លែងដែលមានតុព្រះបន្ទូល និងកន្លែងលោកបូជាចារ្យ លោកឧបដ្ឋាក និងអ្នកបម្រើឯទៀតៗប្រព្រឹត្តមុខងាររបស់គេ។ ត្រូវមានសញ្ញាសម្គាល់ដែលជួយឲ្យស្គាល់យ៉ាងច្បាស់ ពោលគឺ៖ រៀបចំទីសក្ការៈខ្ពស់ជាងបន្តិច ឬដោយគម្រោងពិសេស ឬដោយតុបតែងយ៉ាងពិសេស។ ត្រូវជាកន្លែងធំល្មមដើម្បីប្រារព្ធពិធីអភិបូជាដោយភាពងាយស្រួល ហើយដែលគ្រីស្តបរិស័ទអាចមើលឃើញដែរ។[129]

### តុសក្ការបូជា និងគ្រឿងដ៏សក្ការៈសម្រាប់តុសក្ការបូជា

២៩៦. លើតុសក្ការបូជា យើងបំពេញជាថ្មី (តាមរបៀបអគ្គសញ្ញា) ព្រះយេស៊ូលីឈើឆ្កាង។ តុសក្ការបូជា គឺជាតុរបស់ព្រះអម្ចាស់ដែលប្រជារាស្រ្តរបស់ព្រះអង្គមកចូលរួមថ្វាយអភិបូជា។ ជាមជ្ឈដ្ឋាននៃពិធីអរព្រះគុណដែលយើងប្រារព្ធ ពេលណាដែលយើងថ្វាយអភិបូជា។

២៩៧. ត្រូវថ្វាយអភិបូជាលើតុសក្ការបូជានៅទីសក្ការៈ។ ពេលថ្វាយអភិបូជានៅកន្លែងផ្សេង អាចប្រើតុមួយធម្មតា ដោយមានកម្រាលតុ កម្រាលពិសិដ្ឋ ព្រះឈើឆ្កាង និងទៀន។

[128] Cf. Sacred Congregation of Rites, Instruction *Inter Oecumenici*, on the orderly carrying out of the Constitution on the Sacred Liturgy, 26 September 1964, nos. 97-98: AAS 56 (1964), p. 899.
[129] Cf. Sacred Congregation of Rites, Instruction *Inter Oecumenici*, on the orderly carrying out of the Constitution on the Sacred Liturgy, 26 September 1964, no. 91: AAS 56 (1964), p. 898.

២៩៨. ព្រះវិហារនីមួយៗ គួរមានតុសក្ការបូជាដែលជាប់នឹងព្រះវិហារ ជាសញ្ញាសម្គាល់អំពីព្រះយេស៊ូគ្រីស្ត "ជាសិលាដ៏មានជីវិត" (១សល ២: ៤; អភ២: ២០)។ នៅកន្លែងផ្សេងដែលគេចូលរួមថ្វាយអភិបូជាអាចមានតុសក្ការបូជាចល័តដែលមិនជាប់នឹងព្រះវិហារ។ យើងហៅតុសក្ការបូជាជាប់នឹងព្រះវិហារ ពេលតុសក្ការបូជានោះជាប់ មិនអាចធ្វើចលនា ឬយើងមិនអាចយកដាក់នៅកន្លែងផ្សេង។ បើសិនជាយើងអាចយកទៅដាក់នៅកន្លែងផ្សេង យើងហៅតុសក្ការបូជាចល័ត។

២៩៩. គួរសាងសង់តុសក្ការបូជាដាច់ឡែកពីជញ្ជាំង ដូច្នេះលោកអាចដើរជុំវិញ ហើយថ្វាយអភិបូជានៅមុខប្រជាជនដែលជារបៀបល្អជាង។ ត្រូវរៀបចំតុសក្ការបូជានៅពាក់កណ្ដាលទីសក្ការៈ ដើម្បីធ្វើឲ្យគ្រីស្តបរិស័ទយកចិត្តទុកដាក់អំពីតុសក្ការបូជានេះ។[130] តុសក្ការបូជាគួរជាប់នឹងព្រះវិហារ និងគួរធ្វើពិធីថ្វាយទៅព្រះជាម្ចាស់។

៣០០. តុសក្ការបូជា ត្រូវធ្វើពិធីថ្វាយទៅព្រះជាម្ចាស់ ទោះបីជាប់នឹងព្រះវិហារ ឬចល័ត។ ពិធីថ្វាយតុសក្ការបូជានោះ មានក្នុងក្បួនពិធីលោកអភិបាល។ សម្រាប់តុសក្ការបូជាចល័ត អាចធ្វើតែពិធីប្រសិទ្ធិពរប៉ុណ្ណោះ។

៣០១. ដើម្បីគោរពប្រពៃណីរបស់ព្រះសហគមន៍ និងនិមិត្តសញ្ញានៃតុសក្ការបូជាត្រូវសាងសង់ជាប់នឹងព្រះវិហារអំពីថ្មធម្មជាតិ។ សម្រាប់គ្រឹះ និងអ្វីៗដែលត្រូវទ្រតុសក្ការបូជាគេអាចប្រើប្រាស់ធាតុផ្សេងដែលល្អ និងរឹងមាំ។ គេអាចសាងសង់តុសក្ការៈចល័ត អំពីធាតុដែលគួរសមនឹងភាពថ្លៃថ្នូរនៃពិធីបុណ្យ តាមប្រពៃណី និងទំនៀមទម្លាប់តាមតំបន់ផ្សេងៗ។

៣០២. គួរគោរពនិងរក្សាទុកទំនៀមទម្លាប់របស់ព្រះសហគមន៍ បញ្ចុះក្រោមតុសក្ការបូជាអដ្ឋិធាតុសន្តៈសន្តីទោះបី អដ្ឋិធាតុនោះ មិនមែនរបស់មរណសាក្សី។ យ៉ាងណាក៏ត្រូវពិនិត្យឲ្យដឹងច្បាស់ យថាភាពនៃអដ្ឋិធាតុដែលមាន។

៣០៣. ពេលសាងសង់ព្រះវិហារថ្មី គួរមានតុសក្ការៈតែមួយ ជាសញ្ញាសម្គាល់បញ្ជាក់ថា ព្រះសហគមន៍មានព្រះគ្រីស្តតែមួយ និងអភិបូជាតែមួយ។ ពេលមានព្រះវិហារចាស់ ដែលមានតុសក្ការបូជាជាប់នៅកន្លែងដែលមិនសូវជួយឲ្យគ្រីស្តបរិស័ទចូលរួម ប៉ុន្តែគេមិនអាចដូរកន្លែងបានដោយសារបង្គួចសិល្បៈ និងសោភណភាពនៃវិហារនោះ ដូច្នេះហើយ គេអាចសាងសង់តុសក្ការបូជាមួយទៀត ជាលក្ខណៈសិល្បៈនៅទីសក្ការៈ ដែលត្រូវធ្វើពិធីថ្វាយទៅព្រះជាម្ចាស់។ ត្រូវប្រព្រឹត្តសកម្មភាពជាទីសក្ការៈតែលើតុសក្ការបូជាថ្មីនេះ។ មិនត្រូវតុបតែងតុសក្ការបូជាចាស់ទេ ជៀសវាងកុំឲ្យគ្រីស្តបរិស័ទយល់ច្រឡំ។

---

[130] Cf. Sacred Congregation of Rites, Instruction *Inter Oecumenici*, on the orderly carrying out of the Constitution on the Sacred Liturgy, 26 September 1964, no. 91: AAS 56 (1964), p. 898.

៣០៤. ដើម្បីគោរពពិធីនឹករឭកដល់ព្រះអម្ចាស់ ពិធីជប់លៀងព្រះកាយ និងព្រះលោហិត ព្រះគ្រីស្ត គួរមានកម្រាលពណ៌ស ដែលសមនឹងតុសក្ការបូជា។ អាចថែមកម្រាលមួយទៀតលើកម្រាលពណ៌សនោះ ដែលមានពណ៌ផ្សេងតាមពិធីបុណ្យប្រចាំថ្ងៃ ឬពណ៌ល្អ តាមទម្លាប់នៅកន្លែងនោះ។ យ៉ាងណាក៏ត្រូវតែមានកម្រាលពណ៌ស មុនកម្រាលឯទៀតៗ។

៣០៥. ពេលតុបតែងតុសក្ការបូជា ត្រូវរក្សាភាពសាមញ្ញ។ ក្នុងរដូវរង់ចាំ ត្រូវរៀបចំផ្កាតាមរបៀបដែលសមរម្យតាមអត្ថន័យនៃពិធីបុណ្យ ដែលបង្ហាញពីអំណរសប្បាយនៃពិធីបុណ្យព្រះយេស៊ូប្រសូត។ ក្នុងរដូវអប់រំពិសេស ហាមតុបតែងផ្កានៅតុសក្ការបូជា។ លើកលែងតែថ្ងៃអាទិត្យ ទី ៤ ក្នុងរដូវអប់រំពិសេស (Laetare Sunday) ថ្ងៃបុណ្យយ៉ាងឱឡារិក និងពិធីផ្សេងៗ។ គ្រប់ពេលរៀបចំផ្កា ត្រូវរក្សាភាពសាមញ្ញ ហើយរៀបចំផ្កា នៅជុំវិញតុសក្ការបូជា មិនមែនលើតុសក្ការបូជាទេ។

៣០៦. លើតុសក្ការបូជា ត្រូវដាក់តែអ្វីដែលត្រូវការសម្រាប់អភិបូជា គឺតាំងពីចាប់ផ្តើម រហូតដល់ប្រកាសដំណឹងល្អ មានតែព្រះគម្ពីរដំណឹងល្អ។ តាំងពីពិធីថ្វាយតង្វាយរហូតដល់ពិធីជម្រះចានព្រះកាយ និងពែងព្រះលោហិត ត្រូវមានតែ ពែងព្រះលោហិត និងចានព្រះកាយ ក្លងពិសិដ្ឋតម្កល់ព្រះកាយ បើត្រូវការកម្រាលពិសិដ្ឋ កន្សែងជូតពែងព្រះលោហិត គម្របពែងព្រះលោហិត និងសៀវភៅក្បួនពិធីបុណ្យ។ បើត្រូវការមីក្រូ ត្រូវរៀបចំវាតាមរបៀបដែលមិនរំខាន មិនបិទបាំងគ្រឿងសក្ការបូជាដែលសំខាន់។

៣០៧. ត្រូវដាក់ទៀន តែពេលប្រារព្ធពិធីបុណ្យនូវគ្រប់សកម្មភាព សូមមើលលេខ ១១៧) នៅជុំវិញ ឬលើតុសក្ការបូជាត្រូវរៀបឲ្យសមទៅនឹងតុសក្ការបូជា និងទីសក្ការបូជា តាមរបៀបដែលមិនបិទបាំងតុសក្ការបូជា នាំឲ្យគ្រីស្តបរិស័ទមើលមិនឃើញ សកម្មភាពដែលប្រព្រឹត្តលើតុសក្ការបូជា ឬគ្រឿងសក្ការបូជាដែលមាននៅលើតុសក្ការបូជាប៉ុណ្ណោះ។

៣០៨. លើតុសក្ការបូជា ឬនៅជិត ត្រូវមានឈើឆ្កាង ដែលមានរូបភាពព្រះយេស៊ូលីឈើឆ្កាង ហើយគ្រីស្តបរិស័ទអាចមើលឃើញបាន។ ព្រះឈើឆ្កាងរំឭកគ្រីស្តបរិស័ទអំពីទុក្ខលំបាករបស់ព្រះយេស៊ូដែលសង្គ្រោះយើង ហើយគួរទុកព្រះឈើឆ្កាង នៅជិតតុសក្ការបូជា ទោះបីគ្មានសកម្មភាពនៃពិធីបុណ្យ។

### តុព្រះបន្ទូល

៣០៩. ដោយភាពថ្លៃថ្នូរនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រះវិហារគួរមានកន្លែងមួយដ៏ល្អ ដើម្បីប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយជាកន្លែងដែលគ្រីស្តបរិស័ទទាំងអស់គ្នាត្រូវយកចិត្តទុកដាក់ ពេលប្រារព្ធពិធី លើកតម្កើងព្រះបន្ទូលរបស់ព្រះជាម្ចាស់។[131] ជាការគួរណាស់បើតុព្រះបន្ទូលនោះ ជាប់នឹងព្រះវិហារ មិនមែនជាតុចល័តដើម្បីប្រកាសព្រះបន្ទូល។ ត្រូវដាក់

[131] Cf. Sacred Congregation of Rites, Instruction *Inter Oecumenici*, on the orderly carrying out of the Constitution on the Sacred Liturgy, 26 September 1964, no. 92: AAS 56 (1964), p. 899.

គុព្រះបន្ទូលជាប់នោះ នៅកន្លែងដែលគួរសមនឹងប្លង់នៃព្រះវិហារ ដូច្នេះហើយ គ្រីស្តបរិស័ទទាំងអស់អាចមើលនឹងស្តាប់ឮ សេចក្តីដែលអ្នកបម្រើដែលបានទទួលការតែងតាំង និងអ្នកបម្រើប្រកាសព្រះបន្ទូលប្រកាស។ ត្រូវប្រកាសពីគុព្រះបន្ទូល អត្ថបទប្រចាំពិធី ទំនុកតម្កើង និងលើកតម្កើងសិរីរុងរឿងរបស់ព្រះគ្រីស្ត ដែលមានព្រះជន្មថ្មីដ៏រុងរឿងតែប៉ុណ្ណោះ។ អាចប្រើបានសម្រាប់ថ្លែងធម្មទេសនា និងអធិដ្ឋានពាក្យអង្វរសកល។ ដោយភាពថ្លៃថ្នូរនៃគុព្រះបន្ទូល មានតែអ្នកបម្រើប្រកាសព្រះបន្ទូលដែលអាចឡើងទៅកន្លែងនោះ។ មុនចាប់ផ្តើមប្រើគុព្រះបន្ទូលថ្មី គួរធ្វើពិធីប្រទានពរ តាមពិធីដែលមានក្នុងក្បួនពិធីរ៉ូម៉ាំង។[132]

### កៅអីសម្រាប់លោកបូជាចារ្យជាអធិបតី និងកៅអីផ្សេង

៣១០. កៅអីរបស់លោកបូជាចារ្យជាអធិបតី ត្រូវបង្ហាញមុខងាររបស់លោក គឺធ្វើអធិបតីនៃពិធី និងណែនាំពាក្យអធិដ្ឋាន។ ដូច្នេះ កន្លែងល្អជាង គឺនៅទីសក្ការបូជាខាងមុខគ្រីស្តបរិស័ទ លើកលែងតែប្លង់នៃព្រះវិហារ ឬកាលៈទេសៈផ្សេងមិនអាចឲ្យរៀបចំរបៀបនោះបាន។ ឧទាហរណ៍ បើសិនជាឆ្ងាយពីគ្រីស្តបរិស័ទ ឬបើសិនជាព្រះពន្លានៅពាក់កណ្តាល ក្រោយពីតុសក្ការបូជា។ យ៉ាងណា ត្រូវជៀសវាង បង្ហាញឲ្យគេឃើញដូចជាព្រះបល្ល័ង្កមួយ។[133] មុនចាប់ផ្តើមប្រើកៅអីនោះ គួរធ្វើពិធីប្រទានពរ តាមពិធីដែលមានក្នុងក្បួនពិធីរ៉ូម៉ាំង។[134] ដូចគ្នាដែរ ត្រូវរៀបចំកៅអីសម្រាប់លោកបូជាចារ្យដែលចូលរួមថ្វាយអភិបូជា និងសម្រាប់លោកបូជាចារ្យដែលចូលរួមក្នុងក្រុមច្រៀង ប៉ុន្តែមិនចូលរួមថ្វាយអភិបូជា។ កៅអីរបស់លោកឧបដ្ឋាក គឺនៅជិតលោកធ្វើជាអធិបតី។ ត្រូវរៀបចំកៅអីសម្រាប់អ្នកបម្រើងទៀតៗ តាមរបៀបដែលគេអាចឃើញច្បាស់ថា ខុសគ្នាពីកៅអីរបស់លោក និងតាមរបៀបដែលជួយឲ្យគេប្រព្រឹត្តមុខងាររបស់គេក្នុងពិធីបុណ្យ។[135]

## III. របៀបរៀបចំព្រះវិហារ

### កន្លែងសម្រាប់គ្រីស្តបរិស័ទ

៣១១. ត្រូវរៀបចំកន្លែងសម្រាប់គ្រីស្តបរិស័ទតាមរបៀបស្រួលបួល ដូច្នេះ គេអាចចូលរួមយ៉ាងសកម្ម ដោយមើលឃើញច្បាស់ និងដោយចូលរួមតាមផ្លូវវិញ្ញាណ។ គួរមានជើងម៉ា ឬកៅអីសម្រាប់គេ។ យ៉ាងណា ត្រូវចោលទម្លាប់មិនល្អ គឺទុកកៅអីខ្លះសម្រាប់ពួកអភិជនក្នុងព្រះវិហារ។[136] ម្យ៉ាងទៀត ត្រូវរៀបចំជើងម៉ា ឬកៅអី ដោយជួយឲ្យគ្រីស្តបរិស័ទងាយស្រួល ក្នុងផ្លាស់ប្តូរឥរិយាបថ តាមផ្នែកផ្សេងៗនៃពិធី ហើយងាយស្រួលដើម្បីទៅទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។ ត្រូវយកចិត្តទុកដាក់ដើម្បីជួយឲ្យគ្រីស្តបរិស័ទមើលឃើញ និងស្តាប់ឮយ៉ាងច្បាស់ លោកបូជាចារ្យ លោកឧបដ្ឋាក និងអ្នកបម្រើប្រកាសព្រះបន្ទូល។

[132] Cf. The Roman Ritual, Book of Blessings, *editio typica*, 1984, Order for a Blessing on the Occasion of the Installation of a New Ambo, nos. 900-918.
[133] Cf. Sacred Congregation of Rites, Instruction *Inter Oecumenici*, on the orderly carrying out of the Constitution on the Sacred Liturgy, 26 September 1964, no 92: AAS 56 (1964), p. 898.
[134] Cf. The Roman Ritual, Book of Blessings, *editio typica*, 1984, Order for a Blessing on the Occasion of the Installation of a New Cathedra or Presidential Chair, nos. 880-899.
[135] Cf. Sacred Congregation of Rites, Instruction *Inter Oecumenici*, on the orderly carrying out of the Constitution on the Sacred Liturgy, 26 September 1964, no. 92: AAS 56 (1964), p. 898.
[136] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 32.

### កន្លែងសម្រាប់ក្រុមចម្រៀង និងឧបករណ៍តន្ត្រី

៣១២. កន្លែងក្រុមអ្នកច្រៀងនោះ ត្រូវគួរសមនឹងប្លង់នៃព្រះវិហារ ហើយត្រូវបង្ហាញយ៉ាងច្បាស់ថា៖ ក្រុមនេះគឺជាក្រុមមួយនៃគ្រីស្តបរិស័ទដែលចូលរួមថ្វាយអភិបូជា ហើយមានមុខងារមួយពិសេសក្នុងពិធីបុណ្យ។ កន្លែងនោះ ត្រូវជួយអ្នកច្រៀងប្រព្រឹត្តមុខងាររបស់គេយ៉ាងងាយស្រួល និងចូលរួមពិធីអភិបូជាយ៉ាងសកម្ម។[137]

៣១៣. ការប្រើអកហ្គ័ និងឧបករណ៍តន្ត្រីផ្សេងទៀត តាមច្បាប់អនុញ្ញាតត្រូវមានកន្លែងសមរម្យ ដើម្បីជួយទាំងក្រុមចម្រៀង ទាំងគ្រីស្តបរិស័ទ អាចងាយស្រួលស្តាប់ភ្លេងនៅពេលច្រៀង។ មុនប្រើអកហ្គ័ គួរធ្វើពិធីប្រទានពរ តាមពិធីដែលមានក្នុងក្បួនពិធីរ៉ូម៉ាំង។[138] ក្នុងរដូវរង់ចាំ ត្រូវប្រើអកហ្គ័ និងឧបករណ៍តន្ត្រីផ្សេងៗតាមរបៀបគួរសម រដូវពិធីបុណ្យមានន័យថា មិនអាចបង្ហាញយ៉ាងពេញលេញអំណរសប្បាយនៃពិធីបុណ្យព្រះយេស៊ូប្រសូត។

ក្នុងរដូវអប់រំពិសេស អាចប្រើអកហ្គ័ និងឧបករណ៍តន្ត្រីសម្រាប់ជួយឲ្យច្រៀងតែប៉ុណ្ណោះ។ លើកលែងតែ (ថ្ងៃអាទិត្យទីបួននៃរដូវអប់រំពិសេស)(Laetare) បុណ្យយ៉ាងឱឡារិក និងបុណ្យផ្សេងៗ។

### ព្រះពន្លា ជាកន្លែងទុកព្រះកាយព្រះគ្រីស្ត

៣១៤. តាមប្លង់នៃព្រះវិហារនីមួយៗ និងទំនៀមទម្លាប់ប្រពៃណីដែលត្រឹមត្រូវតាមច្បាប់ក្នុងស្រុក ត្រូវរក្សាទុកព្រះកាយព្រះគ្រីស្តដាក់តម្កល់ក្នុងព្រះពន្លា ជាកន្លែងដែលស័ក្តិសិទ្ធិបំផុតក្នុងព្រះវិហារ គឺបង្ហាញឲ្យឃើញថា មានការចាប់អារម្មណ៍ខ្លាំង ដោយតុបតែងជារបស់មានតម្លៃ និងជាកន្លែងសមរម្យសម្រាប់ជួយគេក្នុងការអធិដ្ឋាន។[139]

ព្រះពន្លា ជាទូតាំងគ្រឿងសក្ការបូជាត្រូវមានតែមួយជាប់នឹងព្រះវិហារដែលមិនអាចដោះចេញបាន ត្រូវសាងសង់ដោយធាតុរឹងមាំដែលមិនអាចមើលធ្លុះ ត្រូវចាក់សោរការពារដោយសុវត្ថិភាព[140] ម្យ៉ាងទៀត ព្រះពន្លាជាទីសក្ការៈដែលគោរពមុនចាប់ផ្តើមធ្វើពិធីបុណ្យតាមរបៀបក្បួនពិធីប្រពៃណីរ៉ូម៉ាំង។[141]

៣១៥. ដោយគោរពអត្ថន័យនៃសញ្ញានេះ ព្រះពន្លាជាកន្លែងរក្សាទុកព្រះកាយព្រះគ្រីស្ត ដូច្នេះមិនអាចដាក់ព្រះពន្លាលើតុសក្ការបូជាដែលប្រើប្រាស់សម្រាប់ថ្វាយអភិបូជា។[142]

ហេតុនេះ ត្រូវគោរពយោបល់របស់លោកអភិបាលប្រចាំភូមិភាគដែលបានរៀបចំព្រះពន្លា៖

ក)ទីសក្ការបូជា ដាច់ឡែកពីតុសក្ការបូជាសម្រាប់ថ្វាយអភិបូជា ឬលើតុសក្ការបូជាចាស់ដែលមិនប្រើសម្រាប់ថ្វាយអភិបូជា(សូមមើលលេខ ៣០៣)

ខ)នៅព្រះវិហារតូចដែលមានគ្រីស្តបរិស័ទអធិដ្ឋាន[143] ជាប់នឹងព្រះវិហារធំ ហើយគ្រីស្តបរិស័ទអាចមើលឃើញបាន។

---

[137] Cf. Sacred Congregation of Rites, Instruction *Musicam sacram*, On music in the Liturgy, 5 March 1967, no. 23: AAS 59 (1967), p. 307.
[138] Cf. The Roman Ritual, Book of Blessings, *editio typica*, 1984, Order for the Blessing of an Organ, nos. 1052-1067.
[139] Cf. Sacred Congregation of Rites, Instruction Eucharisticum mysterium, On the worship of the Eucharist, 25 May 1967, no. 54: AAS 59 (1967), p. 568; cf. also Sacred Congregation of Rites, Instruction *Inter Oecumenici*, on the orderly carrying out of the Constitution on the Sacred Liturgy, 26 September 1964, no. 95: AAS 56 (1964), p. 898.
[140] Cf. Sacred Congregation of Rites, Instruction Eucharisticum mysterium, On the worship of the Eucharist, 25 May 1967. no. 52: AAS 59 (1967), p. 568; Sacred Congregation of Rites, Instruction *Inter Oecumenici*, on the orderly carrying out of the Constitution on the Sacred Liturgy, 26 September 1964, no. 95: AAS 56 (1964), p. 898; Sacred Congregation for the Sacraments, Instruction *Nullo umquam tempore*, 28 May 1938, no. 4: AAS 30 (1938), pp. 199-200; The Roman Ritual, *Holy Communion and Worship of the Eucharist outside Mass*, *editio typica*, 1973, nos. 10-11; *Codex Iuris Canonici*, can. 938 § 3.
[141] Cf. The Roman Ritual, Book of Blessings, *editio typica*, 1984, Order for a Blessing on the Occasion of the Installation of a New Tabernacle, nos. 919-929.
[142] Cf. Sacred Congregation of Rites, Instruction *Eucharisticum mysterium*, On the worship of the Eucharist, 25 May 1967. no. 55: AAS 59 (1967), p. 569.

៣១៦. តាមប្រពៃណីគួរមានចង្កៀងមួយជាមួយប្រេង ឬក្រមួន បំភ្លឺព្រះពន្លា ដើម្បីបង្ហាញសេចក្តីថ្លៃថ្នូរ និងកិត្តិយសនៃវត្តមានព្រះគ្រីស្ត។[144]

៣១៧. នៅក្នុងរបៀបទាំងនេះ មិនអាចបំភ្លេចចោលនូវអ្វីៗដែលច្បាប់កំណត់ គឺត្រូវដាក់តម្កល់ព្រះកាយព្រះគ្រីស្តក្នុងព្រះពន្លា។[145]

## រូបភាពដ៏សក្ការៈ

៣១៨. តាមពិធីបុណ្យលើផែនដីនេះ ព្រះសហគមន៍ចូលរួមក្នុងពិធីបុណ្យទីក្រុងយេរូសាឡឹម នៃស្ថានបរមសុខដែលជាគោលដៅនៃដំណើរជីវិតរបស់យើង ហើយដែលជាកន្លែងព្រះយេស៊ូគង់នៅខាងស្តាំព្រះបិតា។ ដោយគោរពសន្តៈសន្តី ព្រះសហគមន៍សង្ឃឹមថា នៅថ្ងៃណាមួយនឹងចូលរួមជាមួយគេនៅស្ថានបរមសុខ។[146] ដូច្នេះហើយ តាមប្រពៃណីបុរាណនៃព្រះសហគមន៍គួរមានរូបភាពរបស់ព្រះយេស៊ូ ព្រះនាងម៉ារី និងសន្តៈសន្តី នៅអគារជាទីសក្ការបូជាដើម្បីឲ្យគ្រីស្តបរិស័ទគោរពរូបភាពនោះ[147] និងជួយឲ្យគ្រីស្តបរិស័ទចូលរួមក្នុងគម្រោងការដ៏អស្ចារ្យ និងអាថ៌កំបាំងនៃជំនឿ។ យ៉ាងណា ត្រូវប្រយ័ត្នកុំឲ្យមានរូបភាពច្រើនពេក នាំឲ្យគ្រីស្តបរិស័ទបែកអារម្មណ៍ ហើយមិនអាចផ្ចង់ស្មារតីនឹងពិធីដែលកំពុងប្រព្រឹត្ត[148]។ គួរមានរូបភាពតែមួយនៃសន្តៈសន្តីម្នាក់។ និយាយរួម ពេលរៀបចំតុបតែងព្រះវិហារមួយ ត្រូវយកចិត្តទុកដាក់អំពីជំនឿ និងប្រពៃណីនៃព្រះសហគមន៍តំបន់នោះ សោភណភាព និងសេចក្តីថ្លៃថ្នូរផង។

---

[143] Cf. Sacred Congregation of Rites, Instruction *Eucharisticum mysterium*, On the worship of the Eucharist, 25 May 1967, no. 53: AAS 59 (1967), p. 568; The Roman Ritual, *Holy Communion and Worship of the Eucharist outside Mass*, *editio typica*, 1973, no. 9; *Codex Iuris Canonici* can. 938 § 2; John Paul II, Apostolic Letter *Dominicae Cenae*, 24 February 1980, no. 3: AAS 72 (1980), pp. 117-119.

[144] Cf. *Codex Iuris Canonici*, can. 940; Sacred Congregation of Rites, Instruction *Eucharisticum mysterium*, On the worship of the Eucharist, 25 May 1967, no. 57: AAS 59 (1967), p. 569; The Roman Ritual, *Holy Communion and Worship of the Eucharist outside Mass*, *editio typica*, 1973, no. 11.

[145] Cf. particularly in Sacred Congregation for the Sacraments, Instruction *Nullo umquam tempore*, 28 May 1938: AAS 30 (1938), pp. 198-207; *Codex Iuris Canonici*, cann. 934-944.

[146] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 8.

[147] Cf. The Roman Pontifical: *Order of the Dedication of a Church and an Altar*, *editio typica*, 1984, Chapter 4, no. 10; The Roman Ritual, Book of Blessings, *editio typica*, 1984, Order for the Blessing of Images for Public Veneration by the Faithful, nos. 984-1031.

[148] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 125.

# ជំពូកទី ៦

## លក្ខណៈផ្សេងៗនៃពិធីអភិបូជា

### I. នំ និងស្រាតង្វាយសម្រាប់អភិបូជា

៣១៩. ធ្វើតាមគំរូរបស់ព្រះយេស៊ូ ព្រះសហគមន៍តាំងពីដើមបានប្រើនំប៉័ង និងស្រាជាមួយទឹក ដើម្បីធ្វើពិធីជប់លៀងរបស់ព្រះអម្ចាស់។

៣២០. នំប៉័ងសម្រាប់ថ្វាយអភិបូជា ត្រូវធ្វើពីស្រូវសាលី ដុតមិនសូវយូរប៉ុន្មាន ហើយតាមប្រពៃណីបុរាណនៃព្រះសហគមន៍ឡាតាំង ត្រូវជានំប៉័ងឥតមេ។

៣២១. តាមអត្ថន័យនៃពិធីនេះ នំ និងស្រាតង្វាយត្រូវជាម្ហូបត្រឹមត្រូវ។ ដូច្នេះ លោកបូជាចារ្យនិងអាចកាច់នំតង្វាយសម្រាប់ថ្វាយអភិបូជា ទោះបីឥតមេ និងដុតតាមរបៀបធម្មតា ហើយចែកឲ្យគ្រីស្ដបរិស័ទ។ យ៉ាងណាក៏ត្រូវមាននំប៉័ងតូច ពេលមានគ្រីស្ដបរិស័ទចំនួនច្រើន ដែលទទួលព្រះកាយព្រះគ្រីស្ដ ឬដោយកាលៈទេសៈតាមការណែនាំគ្រីស្ដបរិស័ទ។ សកម្មភាពកាច់នំព្រះកាយ (កាលពីដើមគេហៅពិធីអភិបូជាគឺ ពិធីកាច់នំប៉័ង) នឹងបង្ហាញយ៉ាងច្បាស់អំពីកម្លាំងនៃសញ្ញាឯកភាព និងការចូលរួមគ្នាក្នុងនំប៉័ងតែមួយ និងសញ្ញាអំពីមេត្តាករុណាដោយសារគេចែកនំប៉័ងតែមួយ ក្នុងចំណោមបងប្អូនទាំងអស់។

៣២២. សម្រាប់ការថ្វាយអភិបូជា ត្រូវការស្រាទំពាំងបាយជូរ (លក២២ : ១៨) ធម្មជាតិ ហើយមិនត្រូវលាយនឹងធាតុផ្សេងទេ។

៣២៣. ត្រូវប្រយ័ត្ន និងថែរក្សាការពារនំប៉័ង និងស្រាសម្រាប់ថ្វាយអភិបូជា។ ជៀសវាងឲ្យស្រាក្លាយទៅជាទឹកខ្មេះ និងនំប៉័ង ខូច ឬ រឹងពេក ដែលយើងមិនអាចកាច់បាន។

៣២៤. ក្រោយពីប្រសិទ្ធព្រះពរ ឬពេលលោកទទួលព្រះលោហិតព្រះគ្រីស្ដ លោកបូជាចារ្យត្រូវដឹងថា ក្នុងពែងព្រះលោហិតមានតែទឹក គ្មានព្រះលោហិតព្រះគ្រីស្ដទេ លោកត្រូវចាក់ទឹកនោះចោល ហើយដាក់ស្រាតង្វាយ និងទឹក រួចលោកធ្វើពិធីប្រសិទ្ធព្រះពរ។ លោកពោលតែផ្នែកនៃធម៌អរព្រះគុណដ៏វិសុទ្ធ ដែលទាក់ទងនឹងព្រះកាយ និងលោហិតព្រះគ្រីស្ដ ដោយមិនបាច់ធ្វើពិធីប្រសិទ្ធលើនំតង្វាយ។

### II. គ្រឿងសង្ឃារិមដ៏សក្ការៈ

៣២៥. ពេលសាងសង់ព្រះវិហារថ្មី ហើយរៀបចំគ្រឿងសង្ឃារិម ព្រះសហគមន៍ទទួលស្គាល់សិល្បៈប្រចាំតំបន់ និងទទួលស្គាល់ការកែសម្រួលដែលស្របតាមប្រពៃណី និងអរិយធម៌នៃប្រជាជនផ្សេងៗលុះត្រាតែគ្រឿងសង្ឃារិមនោះស្របនឹងគោលដៅដ៏សក្ការៈនៃគ្រឿងនោះ។[149]

ក្នុងរឿងនេះ ត្រូវគោរពភាពសាមញ្ញដែលជាគូដ៏ល្អនៃសិល្បៈដ៏ពិតប្រាកដ។

[149] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 128.

៣២៦. ការជ្រើសរើសគ្រឿងសង្ហារិមដ៏សក្ការៈដែលប្រឌិត ត្រូវប្រើតាមប្រពៃណីព្រះសហគមន៍ អាចទទួលគ្រឿងប្រឌិតថ្មី បើសិនជាតាមបទដ្ឋានសម័យបច្ចុប្បន្នមានភាពថ្លៃថ្នូរ គុណភាពល្អ រឹងមាំ ប្រើបានយូរ ហើយសមនឹងប្រើប្រាស់លើគុសក្ការបូជា។

## III. សម្ភារៈប្រើប្រាស់លើតុសក្ការបូជា

៣២៧. ក្នុងចំណោមសម្ភារៈទាំងប៉ុន្មានដែលត្រូវរៀបចំសម្រាប់ថ្វាយអភិបូជា មានចានព្រះកាយ និងពែងព្រះលោហិតដែលមានសារៈសំខាន់ និងកិត្តិយសពិសេស សម្រាប់ថ្វាយនំ និងស្រាតង្វាយក្នុងពេលប្រសិទ្ធពិធី ដោយសារចានព្រះកាយ និងពែងព្រះលោហិត គ្រីស្តបរិស័ទទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។

៣២៨. សម្ភារៈប្រើប្រាស់លើតុសក្ការបូជា គួរធ្វើពីលោហធាតុមានតម្លៃ។ ប្រសិនបើគេធ្វើពីលោហធាតុដែលច្រេះស៊ី ឬថោកជាងមាស ជាទូទៅគេត្រូវស្រោបមាសពីខាងក្រៅ។

៣២៩. យោងតាមយោបល់របស់មហាសន្និបាត លោកអភិបាលបានសម្រេចរបស់អាចច្នៃប្រឌិតចានព្រះកាយនិងពែងព្រះលោហិតពីគ្រឿងប្រណីត រឹងមាំ ដែលប្រជាជនរាប់ដូចគ្រឿងដែលមានតម្លៃ ដូចជាឈើខ្មៅ ឬឈើឯទៀតៗដែលរឹងមាំ លុះត្រាតែអាចប្រើគ្រឿងប្រឌិតនោះក្នុងសកម្មភាពជាទីសក្ការបូជា និងមិនងាយបែក ឬខូច។ ត្រូវគោរពសម្ភារៈ សម្រាប់សក្ការបូជានេះ ជាគ្រឿងដ៏សក្ការៈទាំងអស់ដែលប្រើប្រាស់សម្រាប់តម្កល់នំព្រះកាយ ដូចជា ចានពិសិដ្ឋ ក្លងពិសិដ្ឋតម្កល់ព្រះកាយជើងតម្កល់ព្រះកាយ។

៣៣០. រីឯពែងព្រះលោហិតវិញ និងសម្ភារៈសម្រាប់សក្ការបូជាផ្សេងទៀត ដែលត្រូវប្រើដើម្បីតម្កល់ព្រះលោហិតព្រះគ្រីស្ត ត្រូវទុកខាងក្នុងដោយគ្រឿងប្រឌិតដែលមិនអាចជ្រាបបានទេ។ រីឯគ្រឹះរបស់វាវិញ អាចប្រើគ្រឿងប្រឌិតរឹងមាំផ្សេងៗបានដែរ។

៣៣១. សម្រាប់ពិធីប្រសិទ្ធិនំព្រះកាយ អាចប្រើចានពិសិដ្ឋធំ ដែលមាននំព្រះកាយសម្រាប់លោកបូជាចារ្យ លោកឧបដ្ឋាក អ្នកបម្រើឯទៀតៗ និងគ្រីស្តបរិស័ទ។

៣៣២. រីឯសម្ភារៈប្រើប្រាស់លើតុសក្ការបូជាវិញ អ្នកអាចប្រឌិតតាមបែបសិល្បៈនៃប្រពៃណីតំបន់នីមួយៗ លុះត្រាតែមានគោលដៅច្បាស់ គឺប្រើក្នុងសកម្មភាពជាទីសក្ការបូជា ដែលអាចឃើញច្បាស់ថា ខុសពីចានដែលប្រើរាល់ថ្ងៃ។

៣៣៣. ដើម្បីធ្វើពិធីប្រទានពរលើសម្ភារៈប្រើប្រាស់លើតុសក្ការបូជាត្រូវធ្វើតាមក្បួនពិធី ដែលមានស្រាប់ហើយ។[150]

៣៣៤. គួរទម្លាប់ទុកអាគារដែលមានបន្ទប់លោកផ្លាស់ប្តូរសម្លៀកបំពាក់ sacrarium ដែលមានទឹកលាងជម្រះសម្ភារៈប្រើប្រាស់លើតុសក្ការបូជា និងក្រណាត់ពិសិដ្ឋ (សូមមើលលេខ ២៨០)។

[150] Cf. The Roman Pontifical: *Order of the Dedication of a Church and an Altar*, *editio typica*, 1984, Chapter 7, Order of the Blessing of a Chalice and a Paten; The Roman Ritual, Book of Blessings, *editio typica*, 1984, Order for the Blessing of Articles for Liturgical Use, nos. 1068- 1084.

## IV. សម្លៀកបំពាក់ពិសិដ្ឋ

៣៣៥. នៅក្នុងព្រះវិហារ ជាព្រះកាយព្រះគ្រីស្ត បងប្អូនខ្លះមានមុខងារផ្សេងៗពីគ្នា។ សម្លៀកបំពាក់ពិសិដ្ឋជាសញ្ញាសម្គាល់ខាងក្រៅ ដែលជួយឲ្យស្គាល់ពីមុខងារផ្សេងៗរបស់អ្នកបម្រើ។ ម្យ៉ាងទៀត សម្លៀកបំពាក់ពិសិដ្ឋត្រូវជួយបន្ថែមសោភ័ណភាពនៃសកម្មភាពដ៏សក្ការៈដែរ។ ជាការគួរណាស់ បើធ្វើពិធីប្រទានពរដល់សម្លៀកបំពាក់ដ៏សក្ការៈរបស់លោកបូជាចារ្យ និងលោកឧបដ្ឋាក ព្រមទាំងសម្លៀកបំពាក់របស់អ្នកបម្រើពិធីបុណ្យតាមពិធីដែលមានស្រាប់ក្នុងក្បួនពិធីរ៉ូម៉ាំង។[151]

៣៣៦. សម្លៀកបំពាក់ដ៏ពិសិដ្ឋរបស់អ្នកបម្រើដែលទទួលការតែងតាំង ជាអគ្គសញ្ញា និងជាអ្នកបម្រើដោយការតែងតាំង ព្រមទាំងអាវសវែងដែលប្រើខ្សែពិសិដ្ឋចងចង្កេះ លើកលែងតែអាវសដែលជាប់ចង្កេះមិនត្រូវការខ្សែពិសិដ្ឋចងទេ។ តាមធម្មតាមិនគួរប្រើអាវសបាំងសម្លៀកបំពាក់ដល់កទេ គួរប្រើខ្សែពិសិដ្ឋចងចង្កេះ ។ ពេលពាក់អាវពិសិដ្ឋ ឬអាវពិសិដ្ឋលោកឧបដ្ឋាក ឬតាមក្បួនពិធីអាចពាក់តែកន្សែងបង់កពិសិដ្ឋ មិនចាំបាច់ពាក់អាវពិសិដ្ឋ ឬអាវពិសិដ្ឋលោកឧបដ្ឋាក មិនអាចយក surplice ជំនួសអាវសទេ ទោះបីអាវសលើ cassock ។

៣៣៧. សម្លៀកបំពាក់ពិសិដ្ឋរបស់លោកបូជាចារ្យ ពេលថ្វាយអភិបូជា និងសកម្មភាពនៃពិធីបុណ្យផ្សេងៗ ដែលទាក់ទងនឹងពិធីអភិបូជា (លើកលែងតែមានពាក្យណែនាំផ្សេង) គឺជាអាវពិសិដ្ឋលើអាវស និងកន្សែងបង់កពិសិដ្ឋ។

៣៣៨. សម្លៀកបំពាក់ពិសិដ្ឋសម្រាប់លោកឧបដ្ឋាក គឺជាអាវពិសិដ្ឋលោកឧបដ្ឋាក ដែលគេពាក់លើអាវស និងកន្សែងបង់កពិសិដ្ឋ។ សម្រាប់ពិធីមិនឱឡារិក មិនចាំបាច់ពាក់អាវពិសិដ្ឋលោកឧបដ្ឋាកទេ។

៣៣៩. អ្នកបម្រើចែកព្រះកាយ អ្នកបម្រើតុសក្ការបូជា អ្នកប្រកាសព្រះបន្ទូល និងអ្នកបម្រើពិធីបុណ្យ អាចពាក់អាវសវែង ឬ សម្លៀកបំពាក់ផ្សេង ដែលគួរសមនឹងពិធី។

៣៤០. លោកបូជាចារ្យពាក់កន្សែងបង់កពិសិដ្ឋ ព័ទ្ធករបស់លោក ហើយចងចុះក្រោម។ លោកឧបដ្ឋាក ពាក់កន្សែងបង់កពិសិដ្ឋដោយពាក់ធៀងលើស្មាខាងឆ្វេង។

៣៤១. លោកបូជាចារ្យពាក់ cope ពេលហែ ឬសម្រាប់សកម្មភាពនៃពិធីបុណ្យផ្សេងៗ តាមពាក្យណែនាំពណ៌ក្រហមនៃក្បួនពិធីនីមួយៗ។

៣៤២. ទាក់ទងនឹងសម្លៀកបំពាក់ពិសិដ្ឋ មហាសន្និបាតរបស់លោកអភិបាលអាចសម្រេចិត្ត និងស្នើសុំទៅសន្តអាសនៈដើម្បីសូមការអនុញ្ញាតនូវរាល់សេចក្តីត្រូវការទៅតាមតំបន់នីមួយៗ។[152]

[151] Cf. The Roman Ritual, Book of Blessings, *editio typica*, 1984, Order for the Blessing of Articles for Liturgical Use, no 1070.
[152] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 128.

៣៤៣. សូមប្រើប្រាស់គ្រឿងប្រណិតដែលធ្លាប់ប្រើតាមប្រពៃណីព្រះសហគមន៍ ព្រមទាំងគ្រឿងប្រណិតធម្មជាតិ ឬផលិតផលក្នុង ដើម្បីធ្វើសម្លៀកបំពាក់ពិសិដ្ឋ។ លោកអភិបាលប្រចាំភូមិភាគត្រូវសម្រេចអំពីរឿងនេះ។[153]

៣៤៤. ជាការគួរណាស់ បើសោភណភាពនៃសម្លៀកបំពាក់ពិសិដ្ឋមកពីគ្រឿងប្រណិត និងគំនូរប៉ាក់ មិនប្រើគ្រឿងតុបតែងថ្លៃពេក។ គួរតុបតែងសម្លៀកបំពាក់ពិសិដ្ឋដោយគូរគំនូរអំពីសញ្ញាសម្គាល់ជាទីសក្ការបូជាមិនចាំបាច់ប្រើអ្វីដែលមិនគួរសម។

៣៤៥. ពណ៌ផ្សេងៗនៃសម្លៀកបំពាក់ពិសិដ្ឋ គឺបង្ហាញពីលក្ខណៈខាងក្រៅនៃគម្រោងការដ៏អស្ចារ្យ ដែលកំពុងប្រព្រឹត្ត និងបង្ហាញចលនានៃជីវិតតាមចលនានៃឆ្នាំប្រចាំពិធីបុណ្យ។

៣៤៦. ត្រូវប្រើពណ៌នៃសម្លៀកបំពាក់ពិសិដ្ឋដូចតទៅៈ

ក) ពណ៌ស រដូវបុណ្យចម្លង និងអបអរសាទរព្រះយេស៊ូប្រសូត ពិធីកោតសរសើរព្រះអម្ចាស់យេស៊ូគ្រីស្ត (លើកលែងតែពិធីលើកតម្កើងទុក្ខលំបាកព្រះយេស៊ូ) ពិធីកោតសរសើរព្រះនាងម៉ារី ទេវទូត សន្តៈសន្តី (ដែលមិនមែនមរណសាក្សី) គោរពសន្តបុគ្គល និងឧទ្ទិសដល់មរណបុគ្គលទាំងអស់ ពិធីកំណើតសន្តយ៉ូហានបាទីស្ត (២៤ មិថុនា) ពិធីសន្តយ៉ូហានជាគ្រីស្តទូតជាអ្នកនិពន្ធគម្ពីរ (២៧ ធ្នូ) សន្តសីលា (២២ កុម្ភៈ) ពិធីសន្តប៉ូលប្រែចិត្តជឿលើព្រះយេស៊ូ (២៥ មករា)។

ខ) ពណ៌ក្រហម ថ្ងៃអាទិត្យសប្តាហ៍ពិសិដ្ឋ លើកតម្កើងទុក្ខលំបាកព្រះយេស៊ូនៅថ្ងៃសុក្រពិសិដ្ឋ បុណ្យព្រះវិញ្ញាណយាងមក បុណ្យគ្រីស្តទូត និងអ្នកនិពន្ធគម្ពីរ ពិធីបុណ្យសន្តៈសន្តី និងជាមរណសាក្សី។

គ) ពណ៌បៃតង ប្រើក្នុងរដូវធម្មតា ឬអធិដ្ឋានតាមពេលកំណត់ក្នុងរដូវធម្មតា។

ឃ) ពណ៌ស្វាយ ព្រះគ្រីស្តយាងមក (រដូវរង់ចាំ) រដូវអប់រំពិសេស (រដូវសែសិបថ្ងៃ)។ ពិធីអភិបូជា និងពិធីអធិដ្ឋានតាមពេលកំណត់អង្វរព្រះជាម្ចាស់ឲ្យអ្នកដែលទទួលមរណភាព។

ង) អាចប្រើពណ៌ខ្មៅ (នៅតាមកន្លែងដែលមានទំនៀមទម្លាប់) សម្រាប់ពិធីបញ្ចុះសព ពិធីអភិបូជា ឬអធិដ្ឋានតាមពេលកំណត់សម្រាប់អ្នកដែលទទួលមរណភាព។

ច) តាមទំនៀមទម្លាប់កន្លែងខ្លះៗ ប្រើពណ៌ផ្កាឈូក នៅថ្ងៃអាទិត្យទី៣ រដូវរង់ចាំ និងថ្ងៃអាទិត្យទី៤ ក្នុងរដូវអប់រំពិសេស ។

ជ) ត្រូវប្រើសម្លៀកបំពាក់ពិសិដ្ឋ (ទោះបីពណ៌ខុសគ្នា) ជាពិសេស ក្នុងពិធីយ៉ាងឱឡារិក។

៣៤៧. អភិបូជាសម្រាប់ពិធីផ្សេងៗតាមពណ៌ប្រចាំឆ្នាំ (ពណ៌សបង្ហាញពីអំណរសប្បាយ)។ សម្រាប់ពិធីអភិបូជាតាមសេចក្តីត្រូវការផ្សេងៗប្រើពណ៌ប្រចាំថ្ងៃ ឬតាមរដូវនៃពិធីបុណ្យ ឬពណ៌ស្វាយ (បើសិនជាពិធីសម្រុះសម្រួល)។ ឧទាហរណ៍ ពិធីអភិបូជា លេខ៣១ នៅពេលមានសង្គ្រាម ឬជម្លោះ។ លេខ៣៣ នៅពេលមានទុរ្ភិក្ស។ លេខ៣៨ អង្វរព្រះជាម្ចាស់លើកលែងទោស។ សម្រាប់ពិធីអភិបូជាតាមបំណងពិសេស ពណ៌ដែលគួរសម ឬពណ៌ប្រចាំថ្ងៃ ឬប្រចាំរដូវពិធីបុណ្យ។

---

[153] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 128.

## V. សម្ភារផ្សេងៗដែលត្រូវការនៅក្នុងព្រះវិហារ

៣៤៨. ក្រៅពីសម្ភារៈពិសិដ្ឋ និងសម្លៀកបំពាក់ពិសិដ្ឋ ដែលត្រូវប្រើប្រាស់គ្រឿងប្រណិតពិសេស ត្រូវការប្រើប្រាស់គ្រឿងប្រណិតដ៏ល្អនិងសមរម្យ សម្រាប់គ្រឿងសង្ហារិមខ្លះ ដែលគេត្រូវប្រើសម្រាប់ពិធីបុណ្យ[154] ឬប្រើនៅព្រះវិហារ។

៣៤៩. ត្រូវយកចិត្តទុកដាក់អំពីសៀវភៅក្បួនពិធីបុណ្យ ជាពិសេសសៀវភៅព្រះគម្ពីរដំណឹងល្អ និងសៀវភៅអត្ថបទព្រះគម្ពីរ ដែលប្រើសម្រាប់ប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ត្រូវគោរពសៀវភៅនោះ និងឲ្យកិត្តិយស ត្រូវមានសកម្មភាពក្នុងពិធីបុណ្យដែលជានិមិត្តរូបនៃពិភពសក្ការបូជា ដូច្នេះត្រូវមានកិត្តិយស សេចក្ដីថ្លៃថ្នូរ និងសោភ័ណភាព។

៣៥០. ត្រូវយកចិត្តទុកដាក់នឹងអ្វីៗទាំងអស់ដែលទាក់ទងនឹងតុសក្ការបូជា និងពិធីអភិបូជា។ ឧទាហរណ៍ ព្រះឈើឆ្កាងដាក់លើតុសក្ការបូជា និងព្រះឈើឆ្កាងដែលប្រើសម្រាប់ពិធីដង្ហែ។

៣៥១. ត្រូវយកចិត្តទុកដាក់អំពីសម្ភារៈ ទោះបីមិនសូវសំខាន់ក៏ដោយ ជាលក្ខណៈសិល្បៈ ភាពសាមញ្ញ រួមនឹងភាពស្រស់ប្រណិត។

[154] For blessing objects that are designed for liturgical use in churches, cf. The Roman Ritual, Book of Blessings, *editio typica*, 1984, part III.

## ជំពូកទី ៧

## ជម្រើសនៃអភិបូជា និងផ្នែកនីមួយៗ

៣៥២. មណ្ឌលសកម្មភាពដែលមានប្រសិទ្ធិភាពណែនាំគ្រីស្តបរិស័ទថ្វាយអភិបូជា នឹងជួយឲ្យបងប្អូនដែលចូលរួមក្នុងពិធីយ៉ាងខ្លាំង បើនៅក្នុងខ្លឹមសារអានអត្ថបទព្រះគម្ពីរ ពាក្យអធិដ្ឋាន បទចម្រៀង អាចស្របទៅតាមវប្បធម៌ប្រពៃណី និងជាសេចក្តីត្រូវការខាងជីវិតផ្លូវវិញ្ញាណ។ ដើម្បីទៅដល់ទិសដៅនេះ ត្រូវប្រើតាមរបៀបត្រឹមត្រូវ ជម្រើសទាំងប៉ុន្មានដែលយើងមាននៅខាងក្រោមនេះ។

ដូច្នេះ នៅក្នុងពេលរៀបចំថ្វាយអភិបូជា ត្រូវគិតដល់សេចក្តីត្រូវការរបស់គ្រីស្តបរិស័ទក្នុងព្រះសហគមន៍នោះ មិនមែនគិតអំពីអ្វីៗដែលខ្លួនចូលចិត្ត។ លោកត្រូវជ្រើសរើសចំណែកខាងគ្រីស្តបរិស័ទដែលចូលរួមក្នុងពិធី។ ដោយមានជម្រើសច្រើនសម្រាប់ផ្នែកនីមួយៗនៃអភិបូជា ត្រូវឲ្យលោកឧបដ្ឋាកប្រកាសព្រះបន្ទូល ស្មូត្រទំនុកតម្កើង អ្នកណែនាំចង្វាក់ភ្លេង និងអ្នកអត្ថាធិប្បាយ ហើយក្រុមចម្រៀងដឹងច្បាស់នូវជម្រើសណាមួយដែលត្រូវជ្រើសរើសសម្រាប់អភិបូជា ជៀសវាងការមិនបានត្រៀមទុកជាមុន។ ការព្រមព្រៀងក្នុងការរៀបចំពិធីអភិបូជាជួយគ្រីស្តបរិស័ទឲ្យតាំងចិត្ត និងចូលរួមថ្វាយអភិបូជាយ៉ាងសកម្ម។

### I. ការជ្រើសរើសនៃពិធីអភិបូជា

៣៥៣. ថ្ងៃបុណ្យយ៉ាងឱឡារិក លោកបូជាចារ្យត្រូវតែធ្វើតាមប្រតិទិននៃព្រះសហគមន៍ ដែលលោកថ្វាយអភិបូជា។

៣៥៤. នៅថ្ងៃអាទិត្យ ជាថ្ងៃអាទិត្យក្នុងរដូវរង់ចាំ បុណ្យព្រះយេស៊ូប្រសូត រដូវសែសិបថ្ងៃ និងបុណ្យចម្លង នៅថ្ងៃបុណ្យ និងនៅថ្ងៃបុណ្យរំឭក ៖

ក) បើថ្វាយអភិបូជាដោយមានគ្រីស្តបរិស័ទ គួរប្រព្រឹត្តតាមប្រតិទិននៃព្រះសហគមន៍ ដែលលោកថ្វាយអភិបូជា

ខ) បើថ្វាយអភិបូជាមានអ្នកបម្រើពិធីបុណ្យតែមួយនាក់ លោកបូជាចារ្យអាចជ្រើសរើសប្រតិទិនព្រះសហគមន៍ដែលលោកថ្វាយអភិបូជា ឬប្រតិទិនរបស់ព្រះសហគមន៍ផ្ទាល់។

៣៥៥. ចំពោះពិធីបុណ្យរំឭកដែលខានមិនបាន ៖

ក) នៅថ្ងៃអាទិត្យក្នុងរដូវរង់ចាំ ចាប់ពីថ្ងៃទី១៧ រហូតដល់ថ្ងៃទី២៤ ខែធ្នូ នៅថ្ងៃអាទិត្យក្រោយបុណ្យព្រះអម្ចាស់យេស៊ូប្រសូត និងថ្ងៃអាទិត្យក្នុងរដូវសែសិបថ្ងៃ លើកលែងតែថ្ងៃពុធបុណ្យរោយផេះ និងសប្តាហ៍ពិសិដ្ឋ អត្ថបទព្រះគម្ពីរត្រូវប្រារព្ធពិធីអភិបូជាតាមក្បួនពិធីបុណ្យដែលមានស្រាប់ ប៉ុន្តែអាចប្រើពាក្យអធិដ្ឋានសរុប យកពីបុណ្យរំឭកដែលបញ្ចូលក្នុងប្រតិទិនត្រូវនឹងថ្ងៃនោះ លើកលែងតែថ្ងៃពុធបុណ្យរោយផេះ និងក្នុងសប្តាហ៍ពិសិដ្ឋ។ ថ្ងៃអាទិត្យធម្មតាក្នុងរដូវបុណ្យចម្លងអាចប្រារព្ធបុណ្យរំឭកសន្តៈសន្តីបាន។

ខ)នៅថ្ងៃអាទិត្យក្នុងរដូវរង់ចាំ មុនថ្ងៃទី១៧ ធ្នូ សប្ដាហ៍បុណ្យព្រះយេស៊ូប្រសូត ពីថ្ងៃទី២ខែមករា និងថ្ងៃអាទិត្យនៃរដូវបុណ្យចម្លង អាចជ្រើសរើសពិធីអភិបូជាប្រចាំថ្ងៃ ឬបុណ្យរំឭកសន្តៈសន្តី តាមប្រតិទិនព្រះសហគមន៍។

គ)ថ្ងៃអាទិត្យក្នុងរដូវធម្មតា អាចជ្រើសរើសអភិបូជាប្រចាំសប្ដាហ៍ ឬបុណ្យរំឭកដែលប្រារព្ធនៅថ្ងៃនោះ ឬថ្វាយអភិបូជាសម្រាប់បុណ្យរំឭកដែលខានមិនបាន ឬអភិបូជាសម្រាប់សន្តបុគ្គលខ្លះដែលមានឈ្មោះនៅក្នុងបញ្ជីថ្ងៃនោះ ឬអភិបូជាតាមសេចក្ដីត្រូវការផ្សេងៗ ឬអភិបូជាសម្រាប់ការបួងសួងពិសេស។

បើលោកថ្វាយអភិបូជាជាមួយគ្រីស្តបរិស័ទ ត្រូវយកចិត្តទុកដាក់កុំចោលអត្ថបទព្រះគម្ពីរប្រចាំថ្ងៃជាញឹកញាប់ ពីព្រោះ ព្រះគម្ពីរជាទ្រព្យដ៏ថ្លៃថ្នូរ ដែលអស់អ្នកជឿទទួលពីតុព្រះបន្ទូលឲ្យបានច្រើនជាងមុន។[155] ដោយមានមូលហេតុដូចគ្នា គួរជៀសវាងប្រើពិធីអភិបូជាសម្រាប់អ្នកដែលទទួលមរណភាពឲ្យញឹកញាប់ ដោយសារយើងថ្វាយគ្រប់អភិបូជាសម្រាប់បងប្អូនដែលនៅរស់ និងបងប្អូនដែលទទួលមរណភាព ហើយធម៌អរព្រះគុណដ៏វិសុទ្ធក៏មានពាក្យអង្វរព្រះជាម្ចាស់សម្រាប់បងប្អូនដែលបានលាចាកលោកនេះទៅហើយ។

ទោះជាយ៉ាងណា នៅថ្ងៃបុណ្យរំឭកដែលខានមិនបាន គឺសម្រាប់បុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារី ឬបុណ្យសន្តបុគ្គលដ៏ជាស្រឡាញ់ចំពោះអ្នកជឿដែលគោរពប្រណិបត្តិន៍ លោកបូជាចារ្យគួរថ្វាយអភិបូជា ដោយប្រើពិធីរបៀបនោះតាមបំណងប្រាថ្នារបស់គ្រីស្តបរិស័ទ។ ពេលជ្រើសរើសពិធីបុណ្យរំឭកតាមប្រតិទិនប្រចាំតំបន់ ប្រចាំក្រុមបព្វជិតបព្វជិតា ឬពីប្រតិទិនទូទៅ ដូច្នេះ ប្រតិទិនទីមួយមានអទិភាពលើប្រតិទិនទូទៅ។

## II. ជម្រើសនៃអត្ថបទផ្សេងៗសម្រាប់ពិធីអភិបូជា

៣៥៦. ជ្រើសរើសអត្ថបទគម្ពីរសម្រាប់ផ្នែកផ្សេងៗនៃពិធីអភិបូជា ទោះជាសម្រាប់រដូវប្រចាំឆ្នាំ ឬសម្រាប់បុណ្យសន្តបុគ្គល ក៏ត្រូវធ្វើតាមក្បួនពិធីបុណ្យមានស្រាប់។

### អត្ថបទព្រះគម្ពីរ

៣៥៧. មាន៣អត្ថបទព្រះគម្ពីរសម្រាប់ថ្ងៃអាទិត្យ និងពិធីយ៉ាងឱឡារិក ដូចជា ព្យាការីមួយ គ្រីស្តទូតមួយ ដំណឹងល្អមួយ។ តាមអត្ថបទនេះ គ្រីស្តបរិស័ទទទួលស្គាល់ប្រវត្តិសាស្ត្រនៃការសង្គ្រោះតាមគម្រោងការរបស់ព្រះបិតា។ ដោយអានអត្ថបទទាំងបីឲ្យត្រឹមត្រូវតាមប្រពៃណីនៃព្រះសហគមន៍ ក្នុងរដូវបុណ្យចម្លងជំនួសអត្ថបទពីសម្ព័ន្ធមេត្រីចាស់ ត្រូវអានអត្ថបទពីកណ្ឌកិច្ចការគ្រីស្តទូត។ សម្រាប់ពិធីផ្សេងៗ មានអត្ថបទព្រះគម្ពីរពីរ។ ហើយបើមានពិធីមួយដែលគេប្រារព្ធតាមរបៀបពិធីយ៉ាងឱឡារិក ត្រូវបន្ថែមអត្ថបទមួយពីអត្ថបទប្រចាំពិធីនោះ។ អាចអានអត្ថបទប្រចាំថ្ងៃសម្រាប់បុណ្យរំឭកដល់សន្តៈសន្តី លើកលែងតែអត្ថបទប្រចាំពិធីនោះ

[155] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 51.

តម្រូវឲ្យអាន។ ជួនកាលបុណ្យរំឭកសន្តៈសន្តី មានអត្ថបទពិសេសដែលជួយឲ្យនឹកដល់ជីវិតរបស់សន្តៈសន្តី ឬបេសកកម្មរបស់គាត់ មិនបង្ខំឲ្យអានអត្ថបទនោះ លុះត្រាតែមានសេចក្តីត្រូវការពីអ្នកណែនាំគ្រីស្តបរិស័ទ។

៣៥៨. នៅក្នុងសៀវភៅអត្ថបទគម្ពីរប្រចាំសប្តាហ៍ អានអត្ថបទសម្រាប់ថ្ងៃនីមួយៗពេញមួយឆ្នាំដែលគួរប្រើតាមរបៀបត្រឹមត្រូវ លើកលែងតែថ្ងៃដែលត្រូវនឹងពិធីយ៉ាងឱឡារិក ឬបុណ្យរំឭកសន្តៈសន្តីដែលមានក្នុងអត្ថបទគម្ពីរសម្ព័ន្ធមេត្រីថ្មីស្រាប់ គឺអត្ថបទដែលនិយាយអំពីសន្តបុគ្គលនោះ។ ពេលបន្តអានអត្ថបទប្រចាំសប្តាហ៍ ត្រូវផ្អាកដោយសារមានពិធីបុណ្យយ៉ាងឱឡារិក ឬពិធីផ្សេង លោកមានជម្រើសក្នុងចំណោមអត្ថបទដែលលោកមានសម្រាប់ពិធី និងអត្ថបទប្រចាំថ្ងៃ។ សម្រាប់អភិបូជាជាមួយក្រុមពិសេស លោកបូជាចារ្យមានជម្រើស លុះត្រាតែលោកជ្រើសរើសសៀវភៅអត្ថបទព្រះគម្ពីរដែលបានទទួលសេចក្តីអនុញ្ញាតត្រឹមត្រូវ។

៣៥៩. ម្យ៉ាងទៀត សៀវភៅអត្ថបទព្រះគម្ពីរមានអត្ថបទខ្លះៗ ពិធីអភិបូជាសម្រាប់ពិធីផ្សេងៗដែលមានពិធីអគ្គសញ្ញា ឬអនុសញ្ញា ឬពិធីអភិបូជាតាមសេចក្តីត្រូវការផ្សេងៗ។ គេបានរៀបចំអត្ថបទព្រះគម្ពីរតាមរបៀបនេះ ដើម្បីជួយឲ្យគ្រីស្តបរិស័ទចូលរួមយ៉ាងសកម្ម យល់កាន់តែច្បាស់ពីគម្រោងការដ៏អស្ចារ្យនៃពិធីបុណ្យ និងស្រឡាញ់ព្រះបន្ទូលរបស់ព្រះជាម្ចាស់កាន់តែខ្លាំងឡើង។ ដូច្នេះ ដើម្បីជ្រើសរើសអត្ថបទព្រះគម្ពីរត្រូវការគិតដល់សេចក្តីត្រូវការខាងការណែនាំគ្រីស្តបរិស័ទ និងដោយគិតដល់ក្រុមអត្ថបទជម្រើសដែលមានក្នុងសៀវភៅអត្ថបទ។

៣៦០. ជួនកាលមានរបៀបវែងជាង ឬខ្លីជាងសម្រាប់អត្ថបទតែមួយ លោកត្រូវការជ្រើសរើសមួយដោយគិតដល់សេចក្តីត្រូវការខាងណែនាំគ្រីស្តបរិស័ទដោយសួរខ្លួនឯង តើគ្រីស្តបរិស័ទអាចយល់អត្ថបទដែលវែងជាង នៅពេលលោកពន្យល់ក្នុងធម្មទេសនា។[156]

៣៦១. ពេលជ្រើសរើសអត្ថបទព្រះគម្ពីរ ត្រូវយកចិត្តទុកដាក់ដល់សេចក្តីត្រូវការរបស់គ្រីស្តបរិស័ទដែលចូលរួមក្នុងពិធីនោះ ដោយជ្រើសរើសមួយណាដែលស្រួលជាង ឬមួយណាដែលសមនឹងអ្នកចូលរួម និងយល់ដល់សេចក្តីត្រូវការណែនាំគ្រីស្តបរិស័ទ។[157] ជួនកាលត្រូវអានអត្ថបទមួយ ប៉ុន្មានថ្ងៃក្រោយទៀត ឧទាហរណ៍ នៅថ្ងៃអាទិត្យក្រោយថ្ងៃប្រចាំសប្តាហ៍ ឬជួនកាលយើងគិតថា អ្នកចូលរួមពិធីនោះ មិនសូវស្រួលស្តាប់អត្ថបទមួយនោះ។ យ៉ាងណា ត្រូវប្រយ័ត្នកុំឲ្យចោលអត្ថបទខ្លះៗរហូត។

៣៦២. ម្យ៉ាងទៀត លោកអភិបាលប្រចាំតំបន់ អាចជ្រើសរើសអត្ថបទខ្លះសម្រាប់ពិធីពិសេស លុះត្រាតែដកស្រង់អត្ថបទនោះ ពីសៀវភៅដែលបានទទួលសេចក្តីអនុញ្ញាតពីសន្តអសនៈ។

[156] The Roman Missal, Lectionary for Mass, *editio typica altera*, 1981, Introduction, no. 80
[157] The Roman Missal, Lectionary for Mass, *editio typica altera*, 1981, Introduction, no. 81.

## ពាក្យអធិដ្ឋាន

៣៦៣. សម្រាប់ពិធីអភិបូជា ត្រូវប្រើពាក្យអធិដ្ឋានដែលមានស្រាប់សម្រាប់ពិធីអភិបូជានោះ លើកលែងតែមានករណីពិសេស។ ថ្ងៃពិធីនឹករឭកសន្តៈសន្តីត្រូវប្រើពាក្យអធិដ្ឋានពេលចូលដែលមានហើយ បើគ្មានទេ យកពាក្យអធិដ្ឋានមួយពីអត្ថបទធម្មតាសន្តៈសន្តី។ ប្រសិនជាគ្មានពាក្យថ្វាយតង្វាយ និងពាក្យអរព្រះគុណ ត្រូវយកពាក្យអធិដ្ឋានធម្មតានៃសន្តៈសន្តី ឬពាក្យអធិដ្ឋានប្រចាំថ្ងៃតាមរដូវពិធីបុណ្យ។ សម្រាប់ថ្ងៃធម្មតាប្រចាំសប្ដាហ៍អាចប្រើពាក្យអធិដ្ឋានពីថ្ងៃអាទិត្យមុន ឬថ្ងៃអាទិត្យផ្សេង។ លោកអាចប្រើពាក្យអធិដ្ឋានតាមសេចក្ដីត្រូវការផ្សេងៗ និងពាក្យអធិដ្ឋានសរុបដែលមានក្នុងក្បួនពិធី។ បើធ្វើដូច្នេះ មានពាក្យអធិដ្ឋានយ៉ាងច្រើន នាំឲ្យជីវិតខាងផ្លូវវិញ្ញាណរបស់គ្រីស្តបរិស័ទលូតលាស់។ សម្រាប់រដូវពិសេសតាមឆ្នាំពិធីបុណ្យមានពាក្យអធិដ្ឋានប្រចាំថ្ងៃស្រាប់ហើយ។

## ធម៌អរព្រះគុណដ៏វិសុទ្ធ

៣៦៤. មានធម៌ប្រារព្ធជាច្រើនក្នុងសៀវភៅក្បួនពិធីបុណ្យ មូលហេតុដោយមានបំណងចង់ប្រមូល ដើម្បីអរព្រះគុណព្រះជាម្ចាស់ និងជួយយើងឲ្យយល់ច្បាស់ពីគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះ។

៣៦៥. ដើម្បីជ្រើសរើសធម៌អរព្រះគុណដ៏វិសុទ្ធពីក្បួនពិធី ត្រូវធ្វើតាមបទបញ្ញាខាងក្រោម៖

ក)ធម៌អរព្រះគុណដ៏វិសុទ្ធទី១ ឬជាធម៌តាមសាសនក្រឹត្យក្រុងរ៉ូមដែលប្រើតាមធម្មតា ដោយច្រៀង ឬសូត្រ ជាពិសេស ពេលមានអត្ថបទស្រាប់ "ដោយរួមជាមួយព្រះសហគមន៍ទាំងមូល" ឬអភិបូជាដែលមានរបៀបអធិដ្ឋានស្រាប់ "បពិត្រព្រះអម្ចាស់! សូមទទួលតង្វាយនេះ" ឬបុណ្យរំឭកគ្រីស្តទូត ឬសន្តៈសន្តី គួរប្រើធម៌អរព្រះគុណដ៏វិសុទ្ធ រាល់ថ្ងៃអាទិត្យ លុះត្រាតែការណែរបស់នាំគ្រីស្តបរិស័ទសម្រេចឲ្យប្រើធម៌អរព្រះគុណដ៏វិសុទ្ធទី៣។

ខ)ធម៌អរព្រះគុណដ៏វិសុទ្ធទី២ ប្រើនៅថ្ងៃធម្មតាប្រចាំសប្ដាហ៍ ឬតាមកាលៈទេសៈពិសេស។ គេអាចប្រើធម៌ប្រារព្ធផ្សេងៗ ជាពិសេសធម៌ប្រារព្ធដែលបញ្ជាក់យ៉ាងសង្ខេបប្រវត្តិសាស្ត្រនៃកាសង្គ្រោះ ដូចជា ធម៌ប្រារព្ធពិធីទូទៅ ទោះបីធម៌អរព្រះគុណដ៏វិសុទ្ធទី២នេះមានធម៌ប្រារព្ធស្រាប់។ ពេលថ្វាយអភិបូជា អង្វរព្រះជាម្ចាស់សម្រាប់ម្នាក់ដែលបានលាចាកលោកនេះទៅហើយ ត្រូវប្រើរូបមន្តនៅកន្លែងដែលមានស្រាប់ គឺ "សូមព្រះអង្គនឹកដល់អស់បងប្អូនយើងខ្ញុំ"។

គ)ធម៌អរព្រះគុណដ៏វិសុទ្ធទី៣ ប្រើជាមួយធម៌ប្រារព្ធផ្សេងៗ ជាពិសេសនៅថ្ងៃអាទិត្យ និងថ្ងៃបុណ្យផ្សេងៗ។ បើប្រើធម៌នេះ ជាពិធីអភិបូជាសម្រាប់អង្វរព្រះជាម្ចាស់ឲ្យម្នាក់ដែលបានលាចាកលោកនេះទៅហើយ គួរប្រើរូបមន្តពិសេសសម្រាប់អ្នកស្លាប់ក្រោយពី "អស់បុត្រធីតាព្រះអង្គដែលខ្ចាត់ខ្ចាយ" ។

ឃ) ធម៌អរព្រះគុណដ៏វិសុទ្ធទី៤ (មានធម៌ប្រារព្ធស្រាប់ដែលមិនអាចផ្លាស់ប្តូរបានទេ) ហើយបញ្ជាក់យ៉ាងសង្ខេបប្រវត្តិសាស្ត្រនៃការសង្គ្រោះ។ គួរប្រើថ្ងៃណាដែលពិធីអភិបូជាគ្មានធម៌ប្រារព្ធស្រាប់ និងថ្ងៃអាទិត្យរដូវធម្មតា។ ដោយគម្រោងនៃធម៌នេះ មិនអាចបញ្ចូលរូបមន្តពិធីអភិបូជាអង្វរព្រះជាម្ចាស់ សម្រាប់ម្នាក់ដែលលាចាកលោកនេះទៅហើយ។

### បទចម្រៀង

៣៦៦. មិនអាចផ្លាស់ប្តូរបទចម្រៀងដែលមានស្រាប់ហើយ សម្រាប់ពិធីអភិបូជាក្នុងក្បួនពិធី។ ឧបមាថា "ឱ កូនចៀមរបស់ព្រះជាម្ចាស់!" (Agnus Dei)។

៣៦៧. ត្រូវគោរពបទបញ្ជាដែលមានហើយ (សូមមើលលេខ ៤០-៤១, ៤៧-៤៨, ៦១-៦៤, ៧៤, ៨៦-៨៨) សម្រាប់បទចម្រៀងចន្លោះអត្ថបទ ព្រមទាំងបទចម្រៀងពេលចូល ថ្វាយតង្វាយ និងទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។

# ជំពូកទី ៨

## ពិធីអភិបូជាតាមកាលៈទេសៈផ្សេង និងពិធីអភិបូជាអង្វរព្រះជាម្ចាស់សម្រាប់ម្នាក់ដែលបានលាចាកលោកនេះទៅហើយ

### I. ពិធីអភិបូជាតាមសេចក្តីត្រូវការផ្សេងៗ

៣៦៨. ដោយសារពិធីបុណ្យជាអគ្គសញ្ញា និងជាព្រឹត្តិការណ៍ដ៏សំខាន់នីមួយៗនៃជីវិតអ្នកជឿគ្រីស្តបរិស័ទត្រូវត្រៀមខ្លួនតាមរបៀបល្អ គឺទទួលព្រះអំណោយទានហូរចេញពីគម្រោងការដ៏អស្ចារ្យនៃបុណ្យចម្លង[158] ហើយដោយសារអភិបូជា គឺជាអគ្គសញ្ញា ក្បួនពិធីបុណ្យមានរបៀបនៃពិធីអភិបូជា និងពាក្យអធិដ្ឋានផ្សេងៗ ដែលអាចប្រើប្រាស់តាមព្រឹត្តិការណ៍ផ្សេងៗសម្រាប់ជីវិតគ្រីស្តបរិស័ទ និងតាមសេចក្តីត្រូវការក្នុងពិភពលោក និងព្រះសហគមន៍ទាំងមូលក្នុងពិភពលោក។

៣៦៩. ដោយសារមានជម្រើសយ៉ាងច្រើន គួរប្រើពិធីអភិបូជាតាមសេចក្តីត្រូវការផ្សេងៗ ពេលមានសេចក្តីត្រូវការចាំបាច់។

៣៧០. សម្រាប់ពិធីអភិបូជាតាមសេចក្តីត្រូវការផ្សេងៗ អាចប្រើអត្ថបទព្រះគម្ពីរប្រចាំថ្ងៃ និងបទចម្រៀងចន្លោះអត្ថបទ បើសិនជាការគួរសមនឹងពិធីដែលប្រារព្ធ លើកលែងតែករណីដែលបញ្ជាក់យ៉ាងច្បាស់។

៣៧១. ក្នុងចំណោមពិធីអភិបូជានេះ មានអភិបូជាសម្រាប់ពិធីផ្សេងៗ អភិបូជាតាមសេចក្តីត្រូវការផ្សេងៗ និងអភិបូជាតាមបំណងពិសេស។

៣៧២. អភិបូជាសម្រាប់ពិធីផ្សេងៗ ទាក់ទងនឹងពិធីអគ្គសញ្ញា និងអនុសញ្ញា។ តាមបទបញ្ជាដែលមានក្នុងសៀវភៅក្បួនពិធី ហាមប្រារព្ធពិធីអភិបូជានេះ នៅថ្ងៃអាទិត្យរដូវរង់ចាំព្រះអម្ចាស់យាងមក រដូវសែសិបថ្ងៃ រដូវបុណ្យចម្លង ថ្ងៃពិធីយ៉ាងឱឡារិក សប្តាហ៍បុណ្យចម្លង ថ្ងៃអាទិត្យនៃបុណ្យចម្លង បុណ្យគោរពសន្តបុគ្គល និងឧទ្ទិសដល់មរណបុគ្គលទាំងអស់ ថ្ងៃពិធីបុណ្យរោយផេះ ថ្ងៃនីមួយៗនៃសប្តាហ៍ពិសិដ្ឋ។

៣៧៣. ត្រូវប្រារព្ធអភិបូជាតាមសេចក្តីត្រូវការផ្សេងៗ ឬតាមកាលៈទេសៈផ្សេងៗ នៅពេលដែលមានករណីពិសេស ឬតាមពេលដែលបានកំណត់ហើយ។

៣៧៤. តាមករណីពិសេស ឬជាប្រយោជន៍តាមការណែនាំគ្រីស្តបរិស័ទ និងតាមសេចក្តីអនុញ្ញាតរបស់លោកអភិបាលប្រចាំភូមិភាគ អាចប្រារព្ធពិធីទាំងនេះ លើកលែងតែថ្ងៃបុណ្យយ៉ាងឱឡារិក ថ្ងៃអាទិត្យក្នុងរដូវរង់ចាំ រដូវសែសិបថ្ងៃ រដូវបុណ្យចម្លង សប្តាហ៍បុណ្យចម្លង បុណ្យគោរពសន្តបុគ្គល និងឧទ្ទិសដល់មរណបុគ្គលទាំងអស់ ថ្ងៃនីមួយៗនៃសប្តាហ៍ពិសិដ្ឋ។

---

[158] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 61.

៣៧៥. នៅថ្ងៃប្រចាំអាទិត្យរដូវធម្មតា ទោះបីមានបុណ្យរំឭក អាចប្រារព្ធពិធីអភិបូជាតាមបំណងពិសេស ដោយនឹកដល់គម្រោងការដ៏អស្ចារ្យរបស់ព្រះអម្ចាស់ ឬថ្ងៃគោរពព្រះនាងព្រហ្មចារិនីម៉ារី ឬពពួកទេវទូត ឬសន្តបុគ្គលទាំងឡាយ។ យ៉ាងណា មិនអាចប្រារព្ធអភិបូជាតាមបំណងពិសេស ដោយថ្វាយអភិបូជានៃគម្រោងការដ៏អស្ចារ្យរបស់ព្រះអម្ចាស់ ឬព្រះនាងព្រហ្មចារិនីម៉ារី លើកលែងតែបុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារីគ្មានជំពាក់បាបកម្ម ដោយសារពិធីនោះ ជាផ្នែកមួយដ៏សំខាន់នៃពិធីបុណ្យប្រចាំឆ្នាំ។

៣៧៦. ហាមប្រារព្ធអភិបូជាតាមសេចក្តីត្រូវការផ្សេងៗ និងតាមបំណងពិសេស នៅថ្ងៃបុណ្យរំឭកគ្រប់ប្រភេទដែលត្រូវនឹងសប្តាហ៍ក្នុងរដូវរង់ចាំរហូតដល់ថ្ងៃទី១៦ ខែធ្នូ និងសប្តាហ៍ព្រះយេស៊ូប្រសូត ចាប់ពីថ្ងៃទី២ ខែមករា និងថ្ងៃប្រចាំសប្តាហ៍នៃរដូវបុណ្យចម្លង ក្រោយពីសប្តាហ៍នៃបុណ្យចម្លង បើចាំបាច់ ឬសមនឹងសេចក្តីត្រូវការតាមការណែនាំគ្រីស្តបរិស័ទ លោកបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍ប្រចាំតំបន់ ឬលោកបូជាចារ្យជាអធិបតី អាចប្រារព្ធពិធីរបៀបនេះបានដែរ សម្រាប់អភិបូជាដែលមានគ្រីស្តបរិស័ទចូលរួម។

៣៧៧. នៅថ្ងៃអាទិត្យក្នុងរដូវធម្មតា មានបុណ្យរំឭកមួយប្រភេទគួរប្រារព្ធ ឬពាក្យអធិដ្ឋានតាមពេលកំណត់ប្រចាំថ្ងៃ អាចប្រារព្ធអភិបូជាតាមកាលៈទេសៈផ្សេងៗ ប៉ុន្តែមិនអាចប្រារព្ធអភិបូជាតាមពិធីផ្សេងៗទេ។

៣៧៨. គួរប្រារព្ធពិធីអភិបូជាគោរពព្រះនាងម៉ារីនៅថ្ងៃសៅរ៍ ពីព្រោះក្នុងពិធីបុណ្យនៃព្រះសហគមន៍គោរពព្រះមាតារបស់ព្រះសង្គ្រោះយើង ខ្លាំងជាងគោរពសន្តៈសន្តីឯទៀតៗ។[159]

## II. ពិធីអភិបូជាអង្វរព្រះជាម្ចាស់ឲ្យវិញ្ញាណក្ខន្ធមនុស្សស្លាប់ទៅហើយ

៣៧៩. ព្រះសហគមន៍ថ្វាយអភិបូជាអង្វរព្រះជាម្ចាស់ឲ្យវិញ្ញាណក្ខន្ធមនុស្សស្លាប់ ដោយសារគ្រីស្តបរិស័ទទាំងឡាយចូលរួមក្នុងព្រះកាយព្រះគ្រីស្ត ដូច្នេះ អង្វរព្រះជាម្ចាស់ឲ្យអ្នកខ្លះនឹងជួយគាំទ្រ និងផ្តល់សេចក្តីសង្ឃឹមដល់អ្នកនោះដែរ។

៣៨០. ក្នុងចំណោមអភិបូជាអង្វរព្រះជាម្ចាស់ឲ្យវិញ្ញាណក្ខន្ធមនុស្សស្លាប់ ពិធីអភិបូជាបញ្ចុះសពមានកន្លែងពិសេស អាចប្រារព្ធអភិបូជានេះ នៅថ្ងៃណាក៏បានដែរ លើកលែងតែ ថ្ងៃបុណ្យយ៉ាងឱឡារិក ថ្ងៃបុណ្យខានមិនបាន ថ្ងៃព្រហស្បតិ៍ពិសិដ្ឋ ត្រៃទិវានៃបុណ្យចម្លង ថ្ងៃអាទិត្យក្នុងរដូវរង់ចាំ និងរដូវសែសិបថ្ងៃ។ សូមមើលច្បាប់ព្រះសហគមន៍ផ្សេងៗ។[160]

៣៨១. អាចប្រារព្ធអភិបូជាអង្វរព្រះជាម្ចាស់ឲ្យវិញ្ញាណក្ខន្ធមនុស្សស្លាប់ នៅថ្ងៃទទួលព័ត៌មានអំពីមនុស្សដែលបានស្លាប់ ថ្ងៃបញ្ចុះសព បុណ្យខួបមួយរយថ្ងៃ ទោះបី នៅក្នុងសប្តាហ៍ព្រះយេស៊ូប្រសូត បុណ្យរំឭកគ្រប់ប្រភេទត្រូវតែប្រារព្ធនៅថ្ងៃបុណ្យប្រចាំសប្តាហ៍ លើកលែងតែថ្ងៃពិធីរោយផេះ

[159] Cf. Second Vatican Ecumenical Council, Dogmatic Constitution on the Church, *Lumen gentium*, no. 54; Paul VI, Apostolic Exhortation *Marialis cultus*, 2 February 1974, no. 9: AAS 66 (1974), pp. 122-123.
[160] Cf. particularly *Codex Iuris Canonici*, can. 1176-1185; The Roman Ritual, *Order of Christian Funerals, editio typica*, 1969.

ឬសប្ដាហ៍ពិសិដ្ឋ។ អាចប្រារព្ធអភិបូជាអង្វរព្រះជាម្ចាស់ឲ្យវិញ្ញាណក្ខន្ធមនុស្សស្លាប់ នៅថ្ងៃអាទិត្យក្នុងរដូវធម្មតា និងថ្ងៃបុណ្យរំឭក។

៣៨២. ពេលថ្វាយអភិបូជាបញ្ចុះសព ត្រូវមានធម្មទេសនា ប៉ុន្ដែត្រូវប្រយ័ត្នកុំឲ្យប្រើធម្មទេសនាដើម្បីមានកោតសរសើរព្រះជាម្ចាស់ឲ្យអ្នកស្លាប់បានច្រើន។

៣៨៣. គ្រីស្ដបរិស័ទ ជាពិសេសបងប្អូនរបស់អ្នកស្លាប់ គួរចូលរួមថ្វាយអភិបូជាបញ្ចុះសព ហើយទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ដ។

៣៨៤. បើថ្វាយអភិបូជាបញ្ចុះសព ជាប់នឹងពិធីបញ្ចុះសព ក្រោយពីពាក្យអធិដ្ឋានទទួលព្រះកាយនិងព្រះលោហិតព្រះគ្រីស្ដ ចោលពិធីបញ្ចប់ ហើយប្រារព្ធពិធីរំកិលសព។ អាចប្រារព្ធពិធីនេះលុះត្រាតែមានសពអ្នកស្លាប់នៅព្រះវិហារ។

៣៨៥. ពេលរៀបចំអភិបូជាសម្រាប់បញ្ចុះសព ឬផ្នែកផ្សេងៗនៃពិធី ដូចជា ពាក្យអធិដ្ឋានអត្ថបទព្រះគម្ពីរ ពាក្យអង្វរសកល ត្រូវយកចិត្តទុកដាក់អំពីអ្នកដែលបានស្លាប់ ក្រុមគ្រួសារ និងគ្រីស្ដបរិស័ទផ្សេងៗដែលចូលរួមពិធី។ លោកបូជាចារ្យត្រូវយកចិត្តទុកដាក់ពីអ្នកចូលរួមពិធី ឬចូលរួមស្ដាប់ព្រះបន្ទូលដំណឹងល្អ ជាពិសេសអស់អ្នកដែលមិនមែនជាគ្រីស្ដបរិស័ទ ឬគ្រីស្ដបរិស័ទដែលមិនសូវចូលរួមថ្វាយអភិបូជា ឬអ្នករស់នៅដោយបោះបង់ចោលជំនឿយូរ។ ពីព្រោះលោកបូជាចារ្យជាគង្វាល និងត្រូវប្រកាសដំណឹងល្អសម្រាប់បងប្អូនទាំងអស់គ្នា។

## ជំពូកទី ៩
## ការកែសម្រួលដែលនៅក្រោមអំណាចលោកអភិបាល ឬក្រុមលោកអភិបាលប្រចាំភូមិភាគ

៣៨៦. ក្បួនពិធីរ៉ូម៉ាំងថ្មីនេះ បានប្រព្រឹត្តស្របតាមក្រឹត្យរបស់មហាសន្និបាតវ៉ាទីកង់ទី២ បានយកចិត្តទុកដាក់ឲ្យគ្រីស្តបរិស័ទចូលរួមយ៉ាងពេញលេញ ដោយដឹងខ្លួន យល់ពីអត្ថន័យ និងយ៉ាងសកម្មទៀត ស្របតាមលក្ខណៈផ្ទាល់នៃពិធីបុណ្យផង លក្ខណៈនៃគ្រីស្តបរិស័ទ ដោយអគ្គសញ្ញាជ្រមុជទឹក មានសិទ្ធិ និងកាតព្វកិច្ចនេះ។[161] ក្នុងក្បួនពិធីនេះ ក្នុងការចាត់ចែងពិធីអភិបូជាមានការកែសម្រួលខ្លះ ដើម្បីជួយឲ្យពិធីបុណ្យស្របនឹងក្បួនពិធី និងខ្លឹមសារនៃពិធីបុណ្យ ហើយលោកអភិបាលភូមិភាគ និងលោកអភិបាលប្រចាំតំបន់ត្រូវពិនិត្យមើល។

៣៨៧. លោកអភិបាលប្រចាំភូមិភាគ ត្រូវចាត់លោកអភិបាល ទុកជាមហាបូជាចារ្យនៃហ្វូងចៀមរបស់លោក។ ក្នុងភូមិភាគ ការរួមរស់ក្នុងអង្គព្រះគ្រីស្តជាតួនាទីរបស់គ្រីស្តបរិស័ទអាស្រ័យលើលោកផងដែរ[162] ត្រូវគាំទ្រនូវការបង្កើតក្បួនច្បាប់ និងពិនិត្យមើលជីវិតខាងពិធីបុណ្យក្នុងភូមិភាគរបស់លោក។ លោកទទួលខុសត្រូវពីក្បួនពិធីនៃអភិបូជា ដោយមានលោកបូជាចារ្យចំនួនច្រើនចូលរួម (សូមមើលលេខ ២០២-៣៧៤) និងបទបញ្ជាសម្រាប់អ្នកបម្រើពិធីបុណ្យដែលជួយលោកបូជាចារ្យនៅតុសក្ការបូជា (សូមមើលលេខ ១០៧) ពិធីទទួលព្រះកាយព្រះគ្រីស្ត ដោយទទួលទាំងព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត (សូមមើលលេខ ២៨៣) និងរបៀបសាងសង់ព្រះវិហារ (សូមមើលលេខ ២៩១)។ ជាពិសេស លោកទទួលខុសត្រូវជួយឲ្យលោកបូជាចារ្យ លោកឧបដ្ឋាក និងគ្រីស្តបរិស័ទទាំងអស់ស្រឡាញ់ និងយល់ពីខ្លឹមសារនៃពិធីបុណ្យ។

៣៨៨. លោកអភិបាលប្រចាំភូមិភាគ ត្រូវកែសម្រួលចំណុចដែលពន្យល់នៅខាងក្រោម តាមច្បាប់ព្រះសហគមន៍។

៣៨៩. លោកអភិបាលប្រចាំតំបន់ រៀបចំបកប្រែជាភាសាប្រចាំតំបន់ដែលគេទទួលខុសត្រូវ និងផ្តល់សេចក្តីអនុញ្ញាតនៃក្បួនពិធីនេះ ពេលទទួលសេចក្តីអនុញ្ញាតពីសន្តអាសនៈ។[163] ត្រូវបោះពុម្ពក្បួនពិធីរ៉ូម៉ាំងទាំងអស់នេះ ជាភាសាឡាតាំង ឬភាសាប្រចាំតំបន់។

៣៩០. អាស្រ័យលើលោកអភិបាលប្រចាំភូមិភាគ សម្រេចអំពីការកែសម្រួលដូចបានពន្យល់ក្នុងក្បួនពិធីនេះ ហើយបញ្ចូលការកែសម្រួលក្បួនពិធី ក្រោយដែលបានទទួលសេចក្តីអនុញ្ញាតពីសន្តអាសនៈ។ ត្រូវសម្រេចអំពីៈ

ក)កាយវិការ និងឥរិយាបថរបស់គ្រីស្តបរិស័ទ (សូមមើលលេខ ៤៣)

[161] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 14.
[162] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 41.
[163] Cf. *Codex Iuris Canonici*, can. 838 § 3.

ខ)កាយវិការគោរពគុសក្ការបូជា និងសៀវភៅព្រះគម្ពីរដំណឹងល្អ (សូមមើលលេខ ២៧៣)
គ)សៀវភៅបទចម្រៀងនៃពិធី ពេលចូល ថ្វាយតង្វាយ ទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត (សូមមើលលេខ ៣៨, ៧៤, ៨៧)
ឃ)អត្ថបទព្រះគម្ពីរ ដែលត្រូវប្រើនៅពេលកាលៈទេសៈពិសេស (សូមមើលលេខ ៣៦២)។
ង)កាយវិការជូនសេចក្តីសុខសាន្ត (សូមមើលលេខ ៨២)។
ច)របៀបទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត (សូមមើលលេខ ១៦០, ២៨៣)
ឆ)គ្រឿងប្រណិតសម្រាប់គុសក្ការបូជា និងគ្រឿងសង្ហារិមពិសិដ្ឋ និងគ្រឿងប្រណិតរបៀបនៃពណ៌សម្លៀកបំពាក់ពិសិដ្ឋ (សូមមើលលេខ ៣០១-៣២៦, ៣២៩-៣៣៩, ៣៤២-៣៤៦) អាចបញ្ចូលក្នុងក្បួនពិធីនេះ សៀវភៅណែនាំពិធី ឬពាក្យណែនាំគ្រីស្តបរិស័ទ ដែលក្រុមលោកអភិបាលប្រចាំភូមិភាគ ដោយគិតថា សេចក្តីអនុញ្ញាតពីសន្តអាសនៈអាចជួយបាន។

៣៩១. អាស្រ័យលើលោកអភិបាលប្រចាំភូមិភាគយកចិត្តទុកដាក់ និងទទួលខុសត្រូវលើការបកប្រែអត្ថបទព្រះគម្ពីរដែលត្រូវប្រើសម្រាប់ថ្វាយអភិបូជា។ ព្រោះអត្ថបទដែលប្រកាសក្នុងពិធីបុណ្យ និងពន្យល់តាមពិធីបកស្រាយ ព្រមទាំងទំនុកតម្កើងដែលស្មូតសុទ្ធតែដកស្រង់ចេញពីព្រះគម្ពីរ។ ពាក្យអធិដ្ឋានផ្សេងៗ ពាក្យអង្វរ និងបទចម្រៀងក្នុងពិធីបុណ្យក៏សុទ្ធសឹងតែយោងគំនិត និងកម្លាំងពីព្រះគម្ពីរដែរ។ កាយវិការ និងនិមិត្តរូបផ្សេងៗ ក៏ទទួលអត្ថន័យពីព្រះគម្ពីរថែមទៀតផង។[164] ត្រូវការប្រើភាសាដែលប្រជាជនអាចយល់តាមរបៀបស្រួលបួល ប៉ុន្តែភាសាដែលគួរសមនឹងពិធីបុណ្យ។

៣៩២. លោកអភិបាលប្រចាំតំបន់ត្រូវបកប្រែ និងរៀបចំអត្ថបទផ្សេងៗ ដោយគោរពរចនាសម្ព័ន្ធនៃភាសា និងអត្ថន័យដើមពីភាសាឡាតាំង។ ត្រូវយកចិត្តទុកដាក់ដល់ប្រភេទអក្សរសាស្ត្រក្នុងអភិបូជា ដូចជា ពាក្យអធិដ្ឋានរបស់អ្នកធ្វើជាអធិបតី ពាក្យផ្តើម ពាក្យប្រកាស ពាក្យឆ្លើយ ពាក្យអង្វរ។ល។ គោលដៅទីមួយនៃការបកប្រែអត្ថបទទាំងនោះ មិនមែនដើម្បីសញ្ជឹងគិតទេ គឺដើម្បីប្រកាស និងចម្រៀងដែលច្រៀងក្នុងពិធីបុណ្យ។ ត្រូវប្រើភាសាដែលងាយស្រួលយល់សម្រាប់គ្រីស្តបរិស័ទនៅតំបន់នីមួយៗ ប៉ុន្តែភាសាដែលមានគុណភាពល្អ តាមអក្សរសាស្ត្រ និងគួរសមនឹងពិធីយ៉ាងណា ក៏គ្រីស្តបរិស័ទត្រូវទទួលអប់រំ អំពីពាក្យពេចន៍ដែលក្នុងព្រះគម្ពីរមានអត្ថន័យពិសេសសម្រាប់គ្រីស្តបរិស័ទ។ តាមតំបន់ដែលប្រើភាសាដដែល គួរប្រើពាក្យពេចន៍ដូចគ្នាក្នុងសៀវភៅដែលប្រើសម្រាប់ពិធីបុណ្យ ជាពិសេស អត្ថបទព្រះគម្ពីរ និងក្បួនពិធី[165]

[164] Cf. II Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 24.
[165] Cf. II Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 36 § 3.

៣៩៣. ដោយសារបទចម្រៀងមានសារៈសំខាន់ក្នុងរចនាសម្ព័ន្ធនៃពិធីបុណ្យ[166] ត្រូវផ្ញើសៀវភៅបទចម្រៀងសម្រាប់គ្រីស្តបរិស័ទ និងពាក្យដែលត្រូវឆ្លើយ និងប្រកាសក្នុងពិធីអភិបូជា និងពិធីបុណ្យផ្សេងៗប្រចាំឆ្នាំឲ្យក្រុមលោកអភិបាលពិនិត្យមើលមុនបោះពុម្ព។

៣៩៤. ភូមិភាគនីមួយៗត្រូវមានប្រតិទិន និងពិធីអភិបូជាប្រចាំភូមិភាគ។ ក្រុមលោកអភិបាលប្រចាំតំបន់វិញ ត្រូវរៀបចំប្រតិទិនសម្រាប់ប្រទេស ឬសម្រាប់តំបន់ធំជាង ដោយរួមជាមួយក្រុមលោកអភិបាលប្រចាំតំបន់ផ្សេង តែសម្រាប់ប្រតិទិនធំនេះត្រូវមានការអនុញ្ញាតពីសន្តអាសនៈ។[167] ហេតុនេះហើយបានជាថ្ងៃរបស់ព្រះអម្ចាស់ ជាថ្ងៃគោរពថ្វាយបង្គំដ៏សំខាន់ជាងគេ។ ត្រូវដាស់តឿនគ្រីស្តបរិស័ទឲ្យគោរពថ្ងៃរបស់ព្រះអម្ចាស់ ទៅជាថ្ងៃប្រកបដោយអំណរសប្បាយ និងសម្រាកពីការងារ។ បុណ្យឯទៀតៗគ្មានអាទិភាពលើថ្ងៃអាទិត្យទេ លើកលែងតែបុណ្យយ៉ាងឧឡារិក ពីព្រោះថ្ងៃអាទិត្យជាគ្រឹះ និងជាស្នូលនៃពិធីគោរពប្រណិប័តន៍ប្រចាំឆ្នាំ។[168] ត្រូវយកចិត្តទុកដាក់អំពីរបៀបមហាសន្និបាតវ៉ាទីកង់ទី២ បានចែងពិធីបុណ្យប្រចាំឆ្នាំ កុំយករបៀបផ្សេងមានអាទិភាពជាង។ ពេលបោះពុម្ពក្បួនពិធី គួរដាក់ពិធីប្រចាំប្រទេស ឬតំបន់ធំនៅកន្លែងគួរសមរួមជាមួយពិធីឯទៀតៗ។ រីឯពិធីប្រចាំតំបន់តូច ឬព្រះសហគមន៍ប្រចាំតំបន់ត្រូវដាក់ក្នុងសេចក្តីបន្ថែម។[169]

៣៩៥. ត្រូវកែសម្រួលថែមទៀត តាមវប្បធម៌ និងប្រពៃណី ដើម្បីជួយឲ្យគ្រីស្តបរិស័ទចូលរួមយ៉ាងសកម្ម ជាពិសេស កន្លែងចាប់ផ្តើមប្រកាសដំណឹងល្អ ក្រុមលោកអភិបាលប្រចាំភូមិភាគត្រូវសូមសេចក្តីអនុញ្ញាតពីសន្តអាសនៈ។[170] ត្រូវគោរពបទបញ្ជាដែលមានក្នុងឯកសារណែនាំអំពីពិធីបុណ្យរ៉ូម៉ាំង និងកែសម្រួលតាមអរិយធម៌ប្រចាំតំបន់។[171] ដើម្បីប្រព្រឹត្តតាមការកែសម្រួលនោះ ត្រូវមាន៖

ក)ការពន្យល់យ៉ាងល្អិតល្អន់ក្នុងឯកសារសំណើ ហើយផ្ញើទៅសន្តអាសនៈ។ ដូច្នេះ ក្រោយពីបានទទួលសេចក្តីអនុញ្ញាតរួចហើយ គេអាចចាប់ផ្តើមអនុវត្តតាម។ ក្រោយពីទទួលសេចក្តីអនុញ្ញាត លោកចាប់ផ្តើមប្រើបណ្តោះអាសន្ននៅតំបន់ខ្លះ ហើយដោយកំណត់ពេលវេលាយ៉ាងច្បាស់។ ក្រោយពីប្រើបណ្តោះអាសន្នរួចហើយ ក្រុមលោកអភិបាលប្រចាំតំបន់ត្រូវសម្រេចបន្តអនុវត្តតាម ឬមិនបន្ត។ បើសិនជាបន្តអនុវត្តតាមការកែសម្រួលនោះ ត្រូវផ្ញើដល់សន្តអាសនៈនូវឯកសារសំណើថ្មីល្អជាង និងច្បាស់ជាង ហើយរង់ចាំសេចក្តីសម្រេចនោះ។[172]

៣៩៦. មុនបន្តអនុវត្តតាមការកែសម្រួលនោះ ជាពិសេស ករណីដែលសំខាន់ជាង ត្រូវយកចិត្តទុកដាក់អំពីការបង្ហាត់តាមរបៀបត្រឹមត្រូវដល់ក្រុមលោកបូជាចារ្យ និងគ្រីស្តបរិស័ទជួយឲ្យយល់ច្បាស់ពីការកែសម្រួល និងបង្កើតបទបញ្ជាខាងការណែនាំគ្រីស្តបរិស័ទ ដើម្បីជួយរក្សាទុកខ្លឹមសារនៃពិធីបុណ្យ។

---

[166] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, Sacrosanctum Concilium, no. 112
[167] Cf. *General Norms for the Liturgical Year and the Calendar* , nos. 48-51, *below*, p. 99; Sacred Congregation for Divine Worship, Instruction *Calendaria particularia*, 24 June 1970, nos. 4, 8: AAS 62 (1970), pp. 652-653.
[168] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 106.
[169] Cf. *General Norms for the Liturgical Year and Calendar*, no. 46, *below*, p. 98; cf. also Sacred Congregation for Divine Worship, Instruction *Calendaria particularia*, 24 June 1970, no. 38: AAS 62 (1970), p. 660.
[170] Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, nos. 37-40.
[171] Cf. Congregation for Divine Worship and the Discipline of the Sacraments, Instruction *Varietates legitimae*, 25 January 1994, nos. 54, 62-69: AAS 87 (1995), pp. 308-309, 311-313.
[172] Cf. Congregation for Divine Worship and the Discipline of the Sacraments, Instruction *Varietates legitimae*, 25 January 1994, nos. 66-68: AAS 87 (1995), p. 313.

៣៩៧.ម្យ៉ាងទៀត ត្រូវគោរពគោលការណ៍ ដែលព្រះសហគមន៍នីមួយៗ (ប្រចាំតំបន់ ឬប្រចាំប្រទេស) ត្រូវឯកភាពនឹងព្រះសហគមន៍សកល មិនមែនតែអំពីលទ្ធិនៃសាសនាព្រះគ្រីស្ត និងអត្តសញ្ញា គឺអំពីទម្លាប់សកល និងការបញ្ជូនបន្ត តាំងពីសម័យគ្រីស្តទូតថែមទៀត។ ត្រូវ ថែរក្សាការបញ្ជូនបន្តនេះ មិនមែនតែដើម្បីជៀសវាងអំពើខុសឆ្គង គឺដើម្បីបន្តជំនឿរបស់យើងទាំងស្រុង ពីព្រោះព្រះសហគមន៍គោរពទម្លាប់ច្បាប់សម្រាប់អធិដ្ឋាន ស្របនឹងច្បាប់នៃ ជំនឿ។[173] ពិធីបុណ្យប្រពៃណីរ៉ូម៉ាំង គឺជាផ្នែកដ៏ថ្លៃថ្លាមួយនៃទ្រព្យសម្បត្តិខាងពិធីបុណ្យរបស់ព្រះសហគមន៍កាតូលិក ហើយដែលមានប្រយោជន៍ដល់ព្រះសហគមន៍ទាំងមូល ដូច្នេះបើបាត់ទ្រព្យសម្បត្តិនេះ ព្រះសហគមន៍នឹងរបួសយ៉ាងធ្ងន់។ តាំងពីដើមដល់បច្ចុប្បន្ន ពិធីបុណ្យប្រពៃណីរ៉ូម៉ាំង បានរក្សាទុកមិនមែនតែរបៀបពិធីបុណ្យនៅទីក្រុងរ៉ូមប៉ុណ្ណោះទេ គឺបានទទួលតាមរបៀបដ៏ល្អប្រសើរ របៀបប្រើប្រាស់ និងសកម្មភាពផ្សេងៗ តាមទម្លាប់ និងប្រពៃណីរបស់ប្រជាជន និងព្រះសហគមន៍ទិសខាងកើត ទិសខាងលិច រហូតបានទទួលអត្តសញ្ញាណសកល។ សព្វថ្ងៃនេះ យើងមើលអត្តសញ្ញាណ និងឯកភាពនៃពិធីប្រពៃណីរ៉ូម៉ាំងនេះ ក្នុងសៀវភៅក្បួនពិធីបុណ្យដែលបានបោះពុម្ព ក្រោមការអនុញ្ញាតរបស់លោកអភិបាលក្រុងរ៉ូម ព្រមទាំងសៀវភៅក្បួនពិធីបុណ្យដែលក្រុមលោកអភិបាលប្រចាំភូមិភាគបានបកប្រែ និងរៀបចំ ហើយដែលបានទទួលការអនុញ្ញាតពីសន្តអាសនៈ។[174]

៣៩៨. ត្រូវគោរពបទបញ្ជាដែលព្រះសហគមន៍មានពីមហាសន្និបាតវ៉ាទីកង់ទី២ គឺត្រូវកែសម្រួលជាថ្មីនូវក្បួនពិធីបុណ្យ លុះត្រាតែមានប្រយោជន៍ដល់ព្រះសហគមន៍ពិតប្រាកដ។ ហើយក៏ត្រូវជានាអះអាងយ៉ាងច្បាស់ថា របៀបធ្វើពិធីបែបថ្មីៗនោះ ហូរចេញមកពីរបៀបពិធីដែលធ្លាប់ធ្វើពីមុនមក ហាក់ដូចជាកើតចេញពីពិធីចាស់នោះវិញ។ ប្រសិនបើអាចធ្វើបាន ត្រូវជៀសវាងកុំឲ្យមានពិធីប្លែកៗពីគ្នាខ្លាំងពេក ក្នុងតំបន់ដែលនៅក្បែរគ្នា។[175] ជាពិសេស ពេលកែសម្រួលស្របតាមអរិយធម៌ប្រចាំតំបន់។[176] ត្រូវការទុកពេលវេលាវែងសម្រាប់ដំណើរការកែសម្រួលនេះ ក្រែងលោមានគ្រោះថ្នាក់ដល់ការបញ្ជូនបន្តត្រឹមត្រូវនៃពិធីបុណ្យ ដោយប្រញាប់ប្រញាល់ និងខ្វះការរិះគិតពិចារណា។ ចុងក្រោយត្រូវបញ្ជាក់ថា គោលដៅនៃការកែសម្រួលស្របតាមអរិយធម៌ប្រចាំតំបន់ មិនមែនបង្កើតពិធីបុណ្យប្រពៃណីផ្សេងៗទៀតទេ ផ្ទុយទៅវិញ គឺប្រឈមមុខនឹងសេចក្តីត្រូវការរបស់ព្រះសហគមន៍ប្រចាំភូមិភាគ ដោយយកចិត្តទុកដាក់ជៀសវាងការកែសម្រួលក្បួនពិធីបុណ្យ ឬសៀវភៅផ្សេងសម្រាប់ពិធីបុណ្យ ចេញឆ្ងាយពីពិធីបុណ្យប្រពៃណីរ៉ូម៉ាំង។[177]

៣៩៩. ដូច្នេះ ត្រូវតែរក្សាទុកក្បួនពិធីរ៉ូម៉ាំង ជាឧបករណ៍ និងជាសញ្ញាសម្គាល់ដ៏អស្ចារ្យមួយអំពីឯកភាពនៃពិធីបុណ្យប្រពៃណីរ៉ូម៉ាំង[178] ទោះបីជាភាសាផ្សេងពីគ្នា ក៏បានកែសម្រួលខ្លះជាភាសាតាមតំបន់នានាដែរ។[179]

---

173 Cf. Congregation for Divine Worship and the Discipline of the Sacraments, Instruction *Varietates legitimae*, 25 January 1994, nos. 26-27: AAS 87 (1995), pp. 298-299.
174 Cf. John Paul II, Apostolic Letter *Vicesimus Quintus Annus*, 4 December 1988, no. 16: AAS 81 (1989), p. 912; Congregation for Divine Worship and the Discipline of the Sacraments, Instruction *Varietates legitimae*, 25 January 1994, nos. 2, 36: AAS 87 (1995), pp. 288, 302.
175 Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 23.
176 Cf. Congregation for Divine Worship and the Discipline of the Sacraments, Instruction *Varietates legitimae*, 25 January 1994, no. 46: AAS 87 (1995), p. 306.
177 Cf. Congregation for Divine Worship and the Discipline of the Sacraments, Instruction *Varietates legitimae*, 25 January 1994, no. 36: AAS 87 (1995), p. 302.
178 Cf. Second Vatican Ecumenical Council, Constitution on the Sacred Liturgy, *Sacrosanctum Concilium*, no. 38; Paul VI, Apostolic Constitution *Missale Romanum*, *above*, p. 14.
179 Cf. Congregation for Divine Worship and the Discipline of the Sacraments, Instruction *Varietates legitimae*, 25 January 1994, no. 54: AAS 87 (1995), pp. 308-309.

# ពាក្យអធិដ្ឋានតាមរដូវផ្សេងៗ

PROPRIUM DE TEMPORE

# រដូវរង់ចាំ

# TEMPUS ADVENTUS

# ថ្ងៃអាទិត្យទី ១ ក្នុងរដូវរង់ចាំ

DOMINICA I ADVENTUS

មិនសូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !

ព្រះអង្គមានព្រះបន្ទូលសន្យាថា

នឹងប្រែផ្ទៃមេឃ និងផែនដីឲ្យបានថ្មីល្អឥតខ្ចោះ ។

សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំយកចិត្តទុកដាក់

នឹងសញ្ញាសម្គាល់ដែលបង្ហាញពីព្រះបុត្រាព្រះអង្គកំពុងយាងមក ។

សូមប្រោសឲ្យយើងខ្ញុំមានសេចក្ដីក្លាហាន និងប្រុងស្មារតីជានិច្ច ក្នុងការកសាង

ពិភពលោកថ្មីស្របតាមព្រះហឫទ័យព្រះអង្គ ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់យើងខ្ញុំ ! ព្រះអង្គបានប្រទានអ្វីៗទាំងអស់ឲ្យយើងខ្ញុំប្រើប្រាស់ ។

យើងខ្ញុំសូមយកប្រាក់ ធូប ផ្កា នំ និងស្រាមកថ្វាយព្រះអង្គ ។

សូមព្រះអង្គមេត្តាទទួលតង្វាយទាំងនេះ ដោយអនុគ្រោះ រួមនឹងសក្ការបូជារបស់

ព្រះគ្រីស្ដ ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ ទំព័រ ៤១៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់យើងខ្ញុំអើយ !

ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ដឲ្យយើងខ្ញុំ

ដែលកំពុងធ្វើដំណើរក្នុងលោកដ៏មិនទៀងទាត់នេះ ។

សូមព្រះអង្គមេត្តាប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកណែនាំយើងខ្ញុំ

ឲ្យជាប់ចិត្តស្រឡាញ់ព្រះអង្គកាន់តែខ្លាំងឡើងៗគ្រប់កាលៈទេសៈទាំងអស់ ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរយ៉ាងឱឡារិក (Latin p. 606) ។

# ថ្ងៃចន្ទ

Feria secunda

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់យើងខ្ញុំអើយ !
តាំងពីដើម ព្រះអង្គសព្វព្រះហឫទ័យសង្គ្រោះមនុស្សលោក ។
សូមព្រះអង្គមេត្តាជាស់តឿនចិត្តគំនិតយើងខ្ញុំ
ឲ្យយកចិត្តទុកដាក់ទទួលព្រះបុត្រាព្រះអង្គដែលកំពុងយាងមក ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំព្យាយាមអធិដ្ឋាន
ព្រមទាំងប្រុងស្មារតីនៅថ្ងៃដែលព្រះគ្រីស្តគោះទ្វារ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
ព្រះអង្គប្រទានអ្វីៗទាំងអស់ឲ្យយើងខ្ញុំ
ក្រៅពីព្រះអំណោយទានរបស់ព្រះអង្គ
យើងខ្ញុំគ្មានអ្វីយកមកលើកថ្វាយព្រះអង្គឡើយ ។
សូមព្រះអង្គមេត្តាទទួលតង្វាយទាំងនេះដោយអនុគ្រោះ
ហើយប្រទានពរឲ្យយើងខ្ញុំដែលរួមជាមួយព្រះគ្រីស្តក្នុងអភិបូជានេះ
បានរួមជាមួយព្រះអង្គអស់កល្បជានិច្ច ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ ទំព័រ ៤១៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គសព្វព្រះហឫទ័យត្រាស់ហៅយើងខ្ញុំឲ្យមកជួបជុំគ្នានៅពេលនេះ ។ សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំចេះស្រឡាញ់ព្រះអង្គ ក្នុងគ្រប់កិច្ចការដែលយើងខ្ញុំប្រព្រឹត្តនៅពេលបច្ចុប្បន្ននេះ ។ សូមប្រោសឲ្យយើងខ្ញុំស្រឡាញ់ព្រះអង្គជានិច្ច និងនៅលោកខាងមុខផង ។

# ថ្ងៃអង្គារ

Feria tertia

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គជាទីពឹង និងជាខែលការពារយើងខ្ញុំជានិច្ច ។ សូមព្រះអង្គសណ្ដាប់ពាក្យអង្វររបស់យើងខ្ញុំ
ដែលកំពុងជួបប្រទះទុក្ខលំបាកគ្រប់យ៉ាងក្នុងលោកនេះ ។ សូមព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គគង់នៅជាមួយយើងខ្ញុំ ហើយប្រទានពរឲ្យយើងខ្ញុំមានចិត្តក្លាហាន និងជៀសផុតពីអំពើបាបនានា ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់យើងខ្ញុំអើយ !
សូមព្រះអង្គសណ្ដាប់ពាក្យអង្វររបស់យើងខ្ញុំ និងទទួលតង្វាយដ៏ស្លូតស្មើងរបស់យើងខ្ញុំដោយអនុគ្រោះ ។
យើងខ្ញុំពុំអាចពឹងផ្អែកលើអំពើល្អរបស់យើងខ្ញុំបានឡើយ សូមព្រះអង្គប្រណីសន្ដោសដល់យើងខ្ញុំ និងយាងមកសង្គ្រោះយើងខ្ញុំផង ។

ធម៌ប្រារព្ធទី ១ ក្នុងរជូវរង់ចាំ ទំព័រ ៤១៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ដែលប្រោសប្រណីឲ្យយើងខ្ញុំ
ទទួលព្រះកាយព្រះគ្រីស្ដក្នុងអភិបូជានេះ ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតយើងខ្ញុំឲ្យយល់ពីអត្ថន័យដ៏ពិតប្រាកដ
នៃព្រឹត្តិការណ៍ទាំងអស់ដែលកើតឡើងនៅក្នុងលោកនេះ
ដោយជាប់ចិត្តនឹងសម្បត្តិនៃស្ថានបរមសុខផង ។

# ថ្ងៃពុធ

Feria quarta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតាយើងខ្ញុំ !
ព្រះអង្គត្រាស់ហៅយើងខ្ញុំឲ្យមកជួបជុំគ្នានៅទីនេះ
ដើម្បីរង់ចាំព្រះបុត្រាយាងមក ។
សូមព្រះអង្គមេត្តាតម្រង់ចិត្តគំនិតរបស់យើងខ្ញុំឲ្យបានស្អាតបរិសុទ្ធ
ហើយទទួលយើងខ្ញុំឲ្យចូលរួមជាមួយព្រះគ្រីស្តដែលយាងមក ។
នៅពេលនោះ សូមព្រះអង្គមេត្តាអាណិតអាសូរយើងខ្ញុំផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ជាព្រះបិតាដ៏សប្បុរសអើយ !
ព្រះអង្គប្រោសប្រណីដល់ព្រះសហគមន៍ឲ្យថ្វាយសក្ការបូជានេះជានិច្ច ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយព្រះយេស៊ូគ្រីស្តដែលសង្គ្រោះយើងខ្ញុំ ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ ទំព័រ ៤១៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាជាអម្ចាស់ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្តឲ្យយើងខ្ញុំ ។
សូមព្រះអង្គមេត្តាការពារយើងខ្ញុំ
កុំឲ្យបាញ់ការល្បួងទៅតាមកិលេសតណ្ហាឡើយ តែសូមព្រះអង្គរៀបចំចិត្តគំនិតរបស់យើងខ្ញុំ
ដើម្បីទទួលព្រះគ្រីស្តដែលយាងមក ។

# ថ្ងៃព្រហស្បតិ៍

Feria quinta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំសូមលើកតម្កើងព្រះអង្គ
ដែលជាទីពឹងដ៏មាំមួនការពារយើងខ្ញុំជានិច្ច ។
សូមព្រះអង្គបង្ហាញឫទ្ធានុភាពរបស់ព្រះអង្គ និងគាំទ្រយើងខ្ញុំ
ហើយសង្គ្រោះយើងខ្ញុំ នៅពេលខាងមុខនេះ
សូមកុំឲ្យអំពើបាបរបស់យើងខ្ញុំរារាំងផ្លូវព្រះអង្គឡើយ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់យើងខ្ញុំអើយ !
ព្រះអង្គសព្វព្រះហឫទ័យប្រទានព្រះបន្ទូលព្រះអង្គឲ្យយើងខ្ញុំ ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
និងពង្រឹងជំនឿយើងខ្ញុំឲ្យមាំមួនជានិច្ច ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ ទំព័រ ៤១៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយព្រះគ្រីស្ត
ដើម្បីឲ្យយើងខ្ញុំបានរួមដំណើរជាមួយព្រះយេស៊ូក្នុងពិភពលោកនេះ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំគោរពបម្រើព្រះអង្គ ដោយមិនគ្រាន់តែពោលពាក្យសម្ដីប៉ុណ្ណោះទេ
គឺដោយប្រព្រឹត្តកិច្ចការទាំងអស់ស្របតាមព្រះហឫទ័យព្រះអង្គជានិច្ច ។

# ថ្ងៃសុក្រ

Feria sexta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
មានតែព្រះអង្គទេ ដែលសង្គ្រោះមនុស្សលោក
ឲ្យរួចផុតពីអំពើអាក្រក់គ្រប់បែបយ៉ាង ។
សូមព្រះអង្គមេត្តាសម្ដែងឫទ្ធានុភាពដ៏អស្ចារ្យរបស់ព្រះអង្គ
មកប្រែចិត្តគំនិតរបស់យើងខ្ញុំ ឲ្យកាន់កិរិយាមារយាទល្អត្រឹមត្រូវបរិសុទ្ធ
និងបានគាប់ព្រះហឫទ័យព្រះអង្គផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះបិតាជាអម្ចាស់យើងខ្ញុំអើយ !
ព្រះអង្គបាត់ព្រះយេស៊ូឲ្យធ្វើជាពន្លឺ ដើម្បីបំភ្លឺជីវិតយើងខ្ញុំសព្វថ្ងៃនេះ ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
ដែលជឿសង្ឃឹមលើព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គដោយអនុគ្រោះ ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ ទំព័រ ៤១៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាជាអម្ចាស់ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះបន្ទូល
និងព្រះកាយព្រះគ្រីស្ដឲ្យយើងខ្ញុំទុកជាអាហារផ្ដល់ជីវិត ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿរបស់យើងខ្ញុំ ឲ្យទទួលស្គាល់វត្តមានរបស់ព្រះអង្គក្នុង
ពិភពលោកនេះ ។

# ថ្ងៃសៅរ៍

Sabbato

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់អើយ !
ព្រះអង្គបានចាត់ព្រះបុត្រាយាងមករំដោះមនុស្សលោកឲ្យរួចពីបាប ។
យើងខ្ញុំសូមអង្វរព្រះអង្គដោយស្មោះអស់ពីចិត្ត
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យមានសេរីភាពដ៏ពេញលេញ
ដើម្បីស្រឡាញ់ព្រះអង្គផង ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គអាណិតអាសូរមនុស្សមានជំងឺគ្រប់បែបយ៉ាង ព្រះអង្គក៏យាងមកធ្វើជាគង្វាលនៃប្រជារាស្ត្ររបស់ព្រះអង្គដែរ ។
យើងខ្ញុំសូមថ្វាយភាពទន់ខ្សោយរបស់យើងខ្ញុំទៅក្នុងព្រះហស្ដរបស់ព្រះអង្គ
សូមព្រះអង្គមេត្តាទទួលយកដោយអនុគ្រោះ និងប្រទានកម្លាំងឲ្យយើងខ្ញុំ ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ ទំព័រ ៤១៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាម្ចាស់ដ៏សប្បុរស !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយ
និងព្រះលោហិតរបស់ព្រះគ្រីស្ដទុកជាអាហារសម្រាប់យើងខ្ញុំ ។
ព្រះអង្គបានចាត់ព្រះយេស៊ូឲ្យយាងមកថែរក្សាការពារ និងណែនាំយើងខ្ញុំ
សូមព្រះអង្គមេត្តាពង្រឹងជំនឿរបស់យើងខ្ញុំឲ្យសុខចិត្តប្រកាសដំណឹងល្អ អំពីការសង្គ្រោះរបស់ព្រះអង្គ និងជួយសម្រាលទុក្ខដល់អស់អ្នកដែលវេទនា ។

# ថ្ងៃអាទិត្យទី ២ ក្នុងរដូវរង់ចាំ

DOMINICA II ADVENTUS

មិនសូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការអើយ !
ព្រះអង្គសព្វព្រះហឫទ័យចាត់ព្យាការីយ៉ូហានបាទីស្ត
ឲ្យមករៀបចំផ្លូវថ្វាយព្រះបុត្រាព្រះអង្គ ។ សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតយើងខ្ញុំ
ឲ្យយកចិត្តទុកដាក់ រៀបចំផ្លូវថ្វាយព្រះគ្រីស្តដែលកំពុងយាងមក
និងប្រោសឲ្យយើងខ្ញុំចេះកសាងពិភពលោកប្រកបដោយយុត្តិធម៌ ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់ដ៏មានធម៌មេត្តាករុណាក្រៃលែងអើយ !
ក្នុងពេលយើងខ្ញុំនាំគ្នាធ្វើពិធីនឹករឭកព្រះបុត្រាបូជាព្រះជន្ម
ព្រះអង្គបានប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកគង់នៅជាមួយយើងខ្ញុំ ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមនឹងសក្ការបូជារបស់ព្រះគ្រីស្ត ដែលមានព្រះជន្មគង់នៅ
និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ ទំព័រ ៤១៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
ព្រះអង្គសព្វព្រះហឫទ័យប្រទានព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ត
ឲ្យយើងខ្ញុំទុកជាអាហារផ្តល់ជីវិត ។
សូមព្រះអង្គមេត្តាកែប្រែចិត្តគំនិតយើងខ្ញុំឲ្យយកចិត្តទុកដាក់
កសាងសន្តិភាពជារៀងរាល់ថ្ងៃនៅកន្លែងដែលយើងខ្ញុំរស់នៅ
ដោយប្រោសឲ្យយើងខ្ញុំដែលស្អប់គ្នា បានជានានឹងគ្នាវិញ ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរយ៉ាងឱឡារិក (Latin p. 606) ។

# ថ្ងៃចន្ទ

Feria secunda

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គមានព្រះហឫទ័យមេត្តាករុណាដ៏លើសលប់ចំពោះមនុស្សលោក ។
សូមព្រះអង្គមេត្តាទទួលពាក្យអង្វររបស់យើងខ្ញុំ ។
សូមព្រះអង្គតម្រង់ចិត្តគំនិតយើងខ្ញុំឲ្យមានឆន្ទៈបរិសុទ្ធទៀងត្រង់
សុខចិត្តរួមស្លាប់រួមរស់ជាមួយព្រះបុត្រាដែលប្រសូតជាមនុស្សដូចយើងខ្ញុំផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គលើកលែងទោសឲ្យមនុស្សលោកដោយសារព្រះយេស៊ូគ្រីស្ត ។
យើងខ្ញុំគ្មានអ្វីតបស្នងព្រះគុណព្រះអង្គឡើយ ក្រៅពីកាយ វាចា និងចិត្ត
សូមព្រះអង្គមេត្តាជម្រះចិត្តគំនិតយើងខ្ញុំឲ្យបានស្អាតបរិសុទ្ធ
និងគាប់ព្រះហឫទ័យព្រះអង្គផង ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ ទំព័រ ៤១៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គប្រោសយើងខ្ញុំឲ្យរួចពីបាប ដោយសារព្រះកាយ
និងព្រះលោហិតរបស់ព្រះគ្រីស្ត យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ។
សូមព្រះអង្គប្រោសប្រណីយើងខ្ញុំឲ្យចេះអត់ទោស
ដល់អស់អ្នកដែលប្រព្រឹត្តខុសនឹងយើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំបានរួមរស់ជាមួយព្រះអង្គ ។

# ថ្ងៃអង្គារ

Feria tertia

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់យើងខ្ញុំអើយ !
ព្រះអង្គមានព្រះបន្ទូលសន្យាថា នឹងចាត់ព្រះគ្រីស្ត
ឲ្យយាងមកសង្គ្រោះមនុស្សគ្រប់ជាតិសាសន៍ ។
ព្រះគ្រីស្តបានយាងមកតាមព្រះបន្ទូលសន្យារបស់ព្រះអង្គមែន
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំប្រុងស្មារតីទទួលព្រះគ្រីស្តដែលកំពុងយាងមក ។
សូមប្រោសឲ្យយើងខ្ញុំយកចិត្តទុកដាក់ប្រកាសអំពីការសង្គ្រោះនេះ នៅកន្លែងដែលយើងខ្ញុំរស់នៅ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
យើងខ្ញុំគ្មានអ្វីតបស្នងព្រះគុណព្រះអង្គទេ
ក្រៅពីយកនំ និងស្រានេះមកថ្វាយព្រះអង្គទុកជាតង្វាយ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំបានចូលរួមជាមួយព្រះយេស៊ូ
និងអរព្រះគុណព្រះអង្គក្នុងអភិបូជាដ៏ប្រសើរនេះ ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ ទំព័រ ៤១៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គសព្វព្រះហឫទ័យប្រោសឲ្យយើងខ្ញុំបានចូលរួមជាមួយព្រះយេស៊ូគ្រីស្ត ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំឲ្យយល់អំពី
ព្រះហឫទ័យមេត្តាករុណាដ៏លើសលប់របស់ព្រះអង្គចំពោះមនុស្សលោក ។
សូមប្រោសឲ្យយើងខ្ញុំយកចិត្តទុកដាក់បង្ហាញធម៌មេត្តាករុណានេះ
ជាពិសេស ដល់អ្នកជិតខាងដែលកើតទុក្ខលំបាក ។

# ថ្ងៃពុធ

Feria quarta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គប្រគល់ភារកិច្ចឲ្យយើងខ្ញុំរៀបចំផ្លូវថ្វាយព្រះបុត្រា ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតយើងខ្ញុំ ឲ្យមានសេចក្ដីសង្ឃឹមជានិច្ច ព្រមទាំងយកចិត្តទុកដាក់កសាងពិភពលោកថ្មីប្រកបដោយយុត្តិធម៌ និង ភាតរភាពថ្វាយព្រះអង្គ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គចាត់ព្រះបុត្រាឲ្យយាងមកប្រទានធម្មវិន័យថ្មីដល់យើងខ្ញុំ ។ សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះយេស៊ូគ្រីស្ត ដែលមានព្រះជន្មគង់នៅ និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ ទំព័រ ៤១៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គបានប្រទានកម្លាំងថ្មីឲ្យយើងខ្ញុំ ដោយប្រទានព្រះកាយ
និងព្រះលោហិតរបស់ព្រះគ្រីស្តទុកជាអាហារដែលផ្ដល់ជីវិត ។
សូមព្រះអង្គមេត្តាប្រែចិត្តគំនិតយើងខ្ញុំឲ្យហ៊ានធ្វើជាសាក្សីអំពី
ព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គដល់មនុស្សលោកសព្វថ្ងៃនេះ ។

# ថ្ងៃព្រហស្បតិ៍

Feria quinta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការអើយ !
ព្រះអង្គបាត់ព្រះបុត្រាឲ្យយាងមកសង្គ្រោះយើងខ្ញុំ ។
សូមព្រះអង្គមេត្តាកែប្រែចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យស្ម័គ្រចិត្តរៀបចំផ្លូវថ្វាយព្រះគ្រីស្តដែលកំពុងយាងមក ។
សូមប្រោសឲ្យយើងខ្ញុំយកចិត្តទុកដាក់បម្រើព្រះអង្គ
ដោយសេចក្ដីស្រឡាញ់ និងជួយដល់អ្នកកម្សត់ទុគ៌ត ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះបិតាជាអម្ចាស់ !
ព្រះអង្គបានប្រៀនប្រដៅយើងខ្ញុំ តាមរយៈព្យាការីទាំងឡាយ ។
ក្រៅពីព្រះយេស៊ូ គ្មាននរណាអាចគាប់ព្រះហឫទ័យព្រះអង្គបានឡើយ
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជាដ៏វិសុទ្ធរបស់ព្រះយេស៊ូគ្រីស្តដែលបានបូជាព្រះជន្ម ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ ទំព័រ ៤១៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ជាព្រះបិតា !
ព្រះអង្គបានប្រទានព្រះបន្ទូល និងព្រះកាយព្រះគ្រីស្តក្នុងអភិបូជានេះ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានចិត្តជួយដល់អ្នកកើតទុក្ខ
ដើម្បីបង្ហាញពីព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គឲ្យគេស្គាល់ ។

# ថ្ងៃសុក្រ

Feria sexta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គបានសង្គ្រោះយើងខ្ញុំដោយសារព្រះយេស៊ូគ្រីស្ត ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតយើងខ្ញុំឲ្យប្រុងស្មារតី
ក្នុងពេលយើងខ្ញុំទទួលព្រះគ្រីស្តយាងមក ។
សូមប្រោសឲ្យយើងខ្ញុំឃើញព្រះភក្ត្រព្រះអង្គក្នុងមនុស្សគ្រប់ៗរូប
ដែលយើងខ្ញុំជួបជារៀងរាល់ថ្ងៃ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់ដ៏សប្បុរសអើយ !
ព្រះអង្គដាស់តឿនយើងខ្ញុំឲ្យប្រុងស្មារតីជានិច្ច ។
យើងខ្ញុំសូមថ្វាយ កាយ វាចា ចិត្តរបស់យើងខ្ញុំ
ទុកជាតង្វាយរួមជាមួយសក្ការបូជារបស់ព្រះយេស៊ូគ្រីស្ត សូមព្រះអង្គមេត្តាទទួល
ដោយអនុគ្រោះ ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ ទំព័រ ៤១៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះបន្ទូល និងព្រះកាយព្រះគ្រីស្តក្នុង
អភិបូជានេះ ។
សូមព្រះអង្គបំភ្លឺចិត្តគំនិតយើងខ្ញុំឲ្យមើលឃើញ
សញ្ញាសម្គាល់របស់ព្រះអង្គដែលត្រាស់ហៅយើងខ្ញុំសព្វថ្ងៃនេះ ។

# ថ្ងៃសៅរ៍

Sabbato

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គចាត់ព្រះបុត្រារបស់ព្រះអង្គឲ្យយាងមកបំភ្លឺមនុស្សលោក ។ ព្រះបុត្រាយាងមកប្រកបដោយសិរីរុងរឿងយ៉ាងអស្ចារ្យ
ទ្រង់នឹងបំបាត់ភាពងងឹត និងសេចក្តីអាក្រក់គ្រប់យ៉ាង ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំធ្វើជាបុត្រធីតាដ៏វិសុទ្ធរបស់ព្រះអង្គផង ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គសព្វព្រះហឫទ័យប្រៀនប្រដៅយើងខ្ញុំតាមរយៈព្យាការីទាំងឡាយ ។
ក្នុងអភិបូជានេះ យើងខ្ញុំនាំគ្នានឹករឭកដល់ព្រះបុត្រាព្រះអង្គ
ដែលបូជាព្រះជន្មដោយព្រះហឫទ័យស្រឡាញ់ ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមនឹងសក្ការបូជារបស់ព្រះគ្រីស្ត ដែលមានព្រះជន្មគង់នៅ
និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ ទំព័រ ៤១៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលសព្វព្រះហឫទ័យឲ្យយើងខ្ញុំ
ចូលរួមជាមួយព្រះយេស៊ូក្នុងអភិបូជានេះ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំកាន់កិរិយាត្រឹមត្រូវ
និងចេះយកចិត្តទុកដាក់ជួយដល់អ្នកកម្សត់ទុគ៌ត
ដើម្បីរៀបចំផ្លូវថ្វាយព្រះគ្រីស្តដែលកំពុងយាងមក ។

# ថ្ងៃអាទិត្យទី ៣ ក្នុងរដូវរង់ចាំ

DOMINICA III ADVENTUS

មិនសូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាដ៏សប្បុរសយ៉ាងក្រៃលែងអើយ !
ព្រះអង្គបានចាត់ព្រះគ្រីស្តឲ្យយាងមកផ្តល់សេចក្តីសុខគ្រប់យ៉ាង
និងប្រោសមនុស្សលោកឲ្យបានរួចពីបាប ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតយើងខ្ញុំឲ្យជឿថា ព្រះយេស៊ូពិតជាព្រះគ្រីស្ត
ដែលកំពុងយាងមករំដោះយើងខ្ញុំ ឲ្យរួចពីសេចក្តីអាក្រក់គ្រប់យ៉ាងមែន ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ពេលណាយើងខ្ញុំនាំគ្នាថ្វាយអភិបូជានេះ យើងខ្ញុំនឹករឭកដល់ព្រះបុត្រា
ដែលបានបូជាព្រះជន្ម ដើម្បីសង្គ្រោះមនុស្សលោក ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះគ្រីស្តដែលមានព្រះជន្មគង់នៅ និងសោយរាជ្យអស់
កល្បជាអង្វែងតរៀងទៅ ។

ធម៌ប្រារព្ធទី ១ និង ទី២ ក្នុងរដូវរង់ចាំ ទំព័រ ៤១៤ និង ៤១៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គសព្វព្រះហឫទ័យប្រទានព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ត
ឲ្យយើងខ្ញុំទុកជាអាហារផ្តល់ជីវិត ។
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលចាត់ព្រះគ្រីស្តយាងមកប្រោសយើងខ្ញុំ
ឲ្យមើលឃើញ និងជឿថា ព្រះអង្គមានព្រះជន្មរស់ឡើងវិញមែន ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតយើងខ្ញុំឲ្យទទួលព្រះអំណោយទានរបស់ព្រះអង្គ
ដោយចិត្តស្មោះ និងប្រព្រឹត្តតាមព្រះអំណោយទានទាំងនោះជានិច្ច ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរយ៉ាងឱឡារិក (Latin p. 606) ។

# ថ្ងៃចន្ទ

Feria secunda

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
យើងខ្ញុំសូមលើកតម្កើងព្រះអង្គ
ដែលមានព្រះហឫទ័យមេត្តាករុណាដ៏លើសលប់ចំពោះមនុស្សលោក ។
ព្រះអង្គចាត់ព្រះបុត្រាឲ្យយាងមកបំភ្លឺមនុស្សលោក
សូមព្រះអង្គមេត្តាពង្រឹងជំនឿ សេចក្ដីសង្ឃឹម
និងសេចក្ដីស្រឡាញ់របស់យើងខ្ញុំផង ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គណែនាំយើងខ្ញុំតាមរបៀបផ្សេងៗដើម្បីឲ្យស្គាល់ព្រះអង្គ ។ សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះគ្រីស្តដែលមានព្រះជន្មគង់នៅជានិច្ច ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ ទំព័រ ៤១៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
ព្រះអង្គចាត់ព្យាការីជាច្រើនឲ្យមកប្រៀនប្រដៅយើងខ្ញុំក្នុងព្រះនាមព្រះអង្គ ។
សូមព្រះអង្គមេត្តាកែប្រែចិត្តគំនិតយើងខ្ញុំ ឲ្យទទួលស្គាល់ព្រះបន្ទូលព្រះអង្គតាមរយៈអស់អ្នកដែលនិយាយមកយើងខ្ញុំក្នុងព្រះនាមព្រះអង្គសព្វថ្ងៃ ហើយសូមពង្រឹងជំនឿរបស់យើងខ្ញុំផង ។

# ថ្ងៃអង្គារ

Feria tertia

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់យើងខ្ញុំអើយ !
ព្រះអង្គប្រោសឲ្យយើងខ្ញុំកើតជាថ្មី
និងរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូជាព្រះបុត្រាព្រះអង្គ ។
សូមព្រះអង្គមេត្តាសង្គ្រោះយើងខ្ញុំឲ្យជៀសផុតពីសៅហ្មងទាំងឡាយ ។
សូមប្រោសឲ្យយើងខ្ញុំកាន់កិរិយាថ្លៃថ្នូរសមជាបុត្រធីតារបស់ព្រះអង្គ
ដើម្បីរៀបចំផ្លូវទទួលព្រះបុត្រាដែលកំពុងយាងមក ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គចាត់ព្រះបុត្រាឲ្យយាងមកសង្គ្រោះមនុស្សលោក ។
យើងខ្ញុំគ្មានអ្វីយកមកថ្វាយតបស្នងព្រះគុណព្រះអង្គទេ ក្រៅពីផ្ញើជីវិតទាំងស្រុង ទៅលើធម៌មេត្តាករុណារបស់ព្រះអង្គ ។ សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យចូលរួម ជាមួយព្រះយេស៊ូ
ដែលបានបូជាព្រះជន្មដើម្បីសង្គ្រោះមនុស្សលោកផង ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ ទំព័រ ៤១៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់ដ៏មានព្រះហឫទ័យមេត្តាករុណាអើយ !
ព្រះអង្គមានព្រះហឫទ័យស្រឡាញ់មនុស្សលោកខ្លាំងណាស់ ។
ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្តឲ្យយើងខ្ញុំ ។
សូមព្រះអង្គប្រោសឲ្យមនុស្សគ្រប់ជាតិសាសន៍
ចេះបង្ហាញពីធម៌មេត្តាករុណាដ៏អស្ចារ្យនេះ
ឲ្យមនុស្សសម័យឥឡូវឃើញផង ។

# ថ្ងៃពុធ

Feria quarta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការអើយ !
យើងខ្ញុំសូមកោតសរសើរព្រះអង្គដែលចាត់ព្រះបុត្រា
ឲ្យយាងមកសង្គ្រោះមនុស្សលោក ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ យកចិត្តទុកដាក់រៀបចំផ្លូវថ្វាយព្រះអង្គ
ដោយខិតខំធ្វើកិច្ចការដែលបង្ហាញពីធម៌មេត្តាករុណារបស់ព្រះអង្គ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គចាត់ព្រះបុត្រាឲ្យយាងមកបង្ហាញពីធម៌មេត្តាករុណាដ៏លើសលប់
ចំពោះមនុស្សតូចតាច និងអ្នកដែលកើតទុក្ខព្រួយគ្រប់យ៉ាង ។
សូមព្រះអង្គទទួលកិច្ចការទាំងប៉ុន្មាន
ដែលយើងខ្ញុំបានប្រព្រឹត្តចំពោះអ្នកកើតទុក្ខព្រួយ
ធ្វើជាតង្វាយរួមជាមួយសក្ការបូជារបស់ព្រះយេស៊ូគ្រីស្ត ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ ទំព័រ ៤១៨ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាបិតា !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយ
និងព្រះលោហិតរបស់ព្រះគ្រីស្តឲ្យយើងខ្ញុំទុកជាអាហារ ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យយកចិត្តទុកដាក់ប្រព្រឹត្តកិច្ចការ
ដែលបង្ហាញពីធម៌មេត្តាករុណារបស់ព្រះអង្គចំពោះមនុស្សលោកសព្វថ្ងៃ ជា
ពិសេស ចំពោះអ្នកកម្សត់ទុគ៌ត ។

# ថ្ងៃព្រហស្បតិ៍

Feria quinta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ជាព្រះសង្គ្រោះអើយ !
ព្រះអង្គប្រោសយើងខ្ញុំឲ្យស្គាល់ និងបម្រើព្រះអង្គ ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យទទួលព្រះគ្រីស្តដែលកំពុងយាងមកសង្គ្រោះយើងខ្ញុំ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គមានគម្រោងការដ៏អស្ចារ្យសង្គ្រោះអស់អ្នក
ដែលផ្ញើជីវិតទាំងស្រុងលើព្រះអង្គ ។
សូមព្រះអង្គទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំទុកជាតង្វាយ
គាប់ព្រះហឫទ័យព្រះអង្គ រួមជាមួយសក្ការបូជារបស់ព្រះគ្រីស្ត ។

ធម៌ប្រារព្ធទី ១ ក្នុងរជ្ជវង់ចាំ ទំព័រ ៤១៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ដែលប្រទានព្រះកាយព្រះគ្រីស្តឲ្យយើងខ្ញុំ ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ ឲ្យស្គាល់ពីគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ
សូមប្រោសឲ្យយើងខ្ញុំមានចិត្តទូលំទូលាយដល់អស់បងប្អូនឯទៀតផង ។

# ថ្ងៃសុក្រ

Feria sexta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គយាងមករកយើងខ្ញុំ មុនយើងខ្ញុំចាប់ផ្ដើមរកព្រះអង្គទៅទៀត
ព្រះអង្គមិនប្រកាន់ជាតិសាសន៍ ឬអ្នកបាបណាឡើយ ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតយើងខ្ញុំ
ឲ្យទទួលស្គាល់ព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គកាន់តែច្បាស់ឡើងៗ
និងចេះបង្ហាញពីសេចក្តីស្រឡាញ់នេះ
ដល់អស់អ្នកដែលរស់នៅក្បែរយើងខ្ញុំផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាម្ចាស់ដ៏សប្បុរសអើយ !
ព្រះអង្គចាត់ព្រះបុត្រាឲ្យយាងមកសង្គ្រោះយើងខ្ញុំ ។
សូមព្រះអង្គមេត្តាទទួលជំនឿរបស់យើងខ្ញុំទុកជាតង្វាយ ដោយអនុគ្រោះ
ហើយសូមបំភ្លឺយើងខ្ញុំឲ្យយល់ពីគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គផង ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ ទំព័រ ៤១៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយព្រះគ្រីស្តឲ្យយើងខ្ញុំ ។
សូមព្រះអង្គមេត្តាកែប្រែចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យហ៊ានរួមស្លាប់រួមរស់ជាមួយព្រះគ្រីស្តគ្រប់ពេលវេលា
ដើម្បីឲ្យយើងខ្ញុំអាចធ្វើជាសាក្សីអំពីព្រះអង្គក្នុងពិភពលោកនេះ ។

# ថ្ងៃអាទិត្យទី ៤ ក្នុងរដូវរង់ចាំ

DOMINICA IV ADVENTUS

មិនសូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !

ព្រះអង្គបង្ហាញធម៌មេត្តាករុណាដ៏លើសលប់ឲ្យមនុស្សលោកស្គាល់ ដោយប្រោសឲ្យស្ត្រីព្រហ្មចារីម្នាក់ អាចបង្កើតព្រះបុត្រារបស់ព្រះអង្គបាន ។ សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំមានជំនឿមាំមួន

ដូចព្រះនាងម៉ារី និងលោកយ៉ូសែប ។

សូមព្រះអង្គបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំឲ្យយល់ពីទីសម្គាល់នានា

ដែលបង្ហាញថា ព្រះអង្គគង់នៅជាមួយយើងខ្ញុំសព្វថ្ងៃនេះ ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាម្ចាស់យើងខ្ញុំអើយ ! ព្រះអង្គប្រោសនាងម៉ារីឲ្យមានគភ៌ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ។

សូមព្រះអង្គមេត្តាប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកញ៉ាំងតង្វាយទាំងនេះឲ្យទៅជាព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ត ។ សូមប្រោសយើងខ្ញុំឲ្យចូលរួមក្នុងសក្ការបូជារបស់ព្រះយេស៊ូគ្រីស្ត

ដែលមានព្រះជន្មគង់នៅ និងសោយរាជ្យអស់កល្បជានិច្ចផង ។

ធម៌ប្រារព្ធទី ២ ក្នុងរដូវរង់ចាំ ទំព័រ ៤១៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !

ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំទុកជាអាហារ ។

សូមព្រះអង្គមេត្តាចាត់ព្រះវិញ្ញាណដ៏វិសុទ្ធ យាងមកគង់ក្នុងចិត្តយើងខ្ញុំ

ដូចព្រះអង្គបានគង់នៅក្នុងព្រះនាងម៉ារីកាលពីដើម

ហើយសូមប្រោសឲ្យយើងខ្ញុំបានគាប់ព្រះហឫទ័យព្រះអង្គជានិច្ច ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរយ៉ាងឱឡារិក (Latin p. 606) ។

# អាទិត្យចុងក្រោយនៃរដូវរង់ចាំ

IN FERIIS ADVENTUS

ពីថ្ងៃទី១៧ ដល់ ២៤ធ្នូ

a die 17 ad diem 24 decembris

## ថ្ងៃទី ១៧ ធ្នូ

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
យើងខ្ញុំសូមលើកតម្កើងព្រះអង្គដែលជាព្រះបង្កើតមេឃ និងដី
ព្រមទាំងលោះមនុស្សលោកឲ្យរួចពីបាប ។
ព្រះអង្គប្រទានព្រះបន្ទូល ដែលមានព្រះជន្មគង់នៅតាំងពីដើមរៀងមក
ឲ្យប្រសូតជាមនុស្ស ដោយសារព្រះនាងព្រហ្មចារីម៉ារី ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យរៀបចំខ្លួនទទួលព្រះបុត្រាដែលកំពុងយាងមក ។

ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យព្រះបុត្រាយាងមកចូលរួមជាមួយយើងខ្ញុំជាមនុស្ស ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំទុកជាតង្វាយ
រួមជាមួយព្រះបុត្រាដែលបូជាព្រះជន្មថ្វាយព្រះអង្គក្នុងនាមយើងខ្ញុំទាំងអស់គ្នា ។

ធម៌ប្រារព្ធទី ២ ក្នុងរដូវរង់ចាំ ទំព័រ ៤១៦ ។

ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គប្រទានព្រះកាយព្រះគ្រីស្តឲ្យយើងខ្ញុំ ។
សូមព្រះអង្គមេត្តាបាត់ព្រះវិញ្ញាណដ៏វិសុទ្ធមកគង់ជាមួយយើងខ្ញុំ
ឲ្យមានចិត្តស្រឡាញ់ព្រះអង្គកាន់តែខ្លាំងឡើងៗ និងប្រព្រឹត្តតែអំពើណាដែលគាប់
ព្រះហឫទ័យព្រះអង្គជានិច្ច ។

# ថ្ងៃទី ១៨ ធ្នូ

Die 18 decembris

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គសព្វព្រះហឫទ័យសង្គ្រោះមនុស្សលោកឲ្យរួចពីបាប ។
សូមព្រះអង្គមេត្តារំដោះយើងខ្ញុំឲ្យមានសេរីភាពដ៏ពិតប្រាកដខាងផ្លូវចិត្ត
និងតម្រង់ចិត្តគំនិតរបស់យើងខ្ញុំ ដើម្បីរៀបចំខ្លួនធ្វើពិធីលើកតម្កើង
ព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គដែលប្រសូតមកជាមនុស្ស ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
ព្រះអង្គចាត់ព្រះបុត្រាឲ្យយាងមកប្រសូតជាមនុស្សដែលរមែងតែស្លាប់ ។
ឥឡូវនេះ ព្រះបុត្រាអង្វរព្រះអង្គក្នុងនាមយើងខ្ញុំ
និងថ្វាយសក្ការបូជាដែលគាប់ព្រះហឫទ័យព្រះអង្គ ។ សូមព្រះអង្គមេត្តាប្រទាន
ព្រះជន្មរបស់ព្រះអង្គឲ្យយើងខ្ញុំ
រួមជាមួយព្រះបុត្រាដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

ធម៌ប្រារព្ធទី ២ ក្នុងរដូវរង់ចាំ ទំព័រ ៤១៦ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់ដ៏សប្បុរសអើយ !
ព្រះអង្គមានព្រះហឫទ័យស្រឡាញ់មនុស្សលោកខ្លាំងណាស់
រហូតដល់ចាត់ព្រះបុត្រាដ៏ជាទីស្រឡាញ់ឲ្យយាងមកសង្គ្រោះយើងខ្ញុំ ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿរបស់យើងខ្ញុំឲ្យកាន់តែមាំមួនឡើង
ហើយប្រោសយើងខ្ញុំឲ្យចេះបម្រើអ្នកដទៃសមជាបុត្រធីតារបស់ព្រះអង្គ ។

# ថ្ងៃទី ១៩ ធ្នូ

Die 19 decembris

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ! ព្រះអង្គសម្តែងសិរីរុងរឿងដ៏អស្ចារ្យរបស់ព្រះអង្គ ដោយប្រោសឲ្យស្ត្រីព្រហ្មចារីម្នាក់អាចបង្កើតកូនបាន ។ សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតយើងខ្ញុំឲ្យមានជំនឿកាន់តែមាំមួនឡើងៗ និងសុខចិត្តធ្វើតាមព្រះហឫទ័យព្រះអង្គដោយចិត្តស្រឡាញ់ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះបិតាជាអម្ចាស់អើយ ! ព្រះអង្គសង្គ្រោះប្រជារាស្ត្ររបស់ព្រះអង្គតាមរបៀបអស្ចារ្យ ។ ក្រៅពីផ្ញើជីវិតទាំងស្រុងទៅលើព្រះអង្គ យើងខ្ញុំគ្មានអ្វីតបស្នងព្រះគុណព្រះអង្គឡើយ ។

សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះគ្រីស្តក្នុងអភិបូជានេះ ។

ធម៌ប្រារព្ធទី ២ ក្នុងរដូវរង់ចាំ ទំព័រ ៤១៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ ! ព្រះអង្គប្រទានព្រះអំណោយទានដ៏ច្រើនឥតគណនាឲ្យយើងខ្ញុំ ។

សូមព្រះអង្គមេត្តាប្រែចិត្តគំនិតរបស់យើងខ្ញុំឲ្យយល់កាន់តែច្បាស់
ពីព្រះអំណោយទានដ៏អស្ចារ្យរបស់ព្រះអង្គចំពោះមនុស្សលោក ។

# ថ្ងៃទី ២០ ធ្នូ

Die 20 decembris

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាអម្ចាស់ ! ព្រះអង្គបាត់ព្រះបន្ទូលព្រះអង្គឲ្យយាងមកប្រសូតជាមនុស្ស ។
នៅពេលនោះ នាងព្រហ្មចារិនីម៉ារីបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ និងត្រឡប់ទៅជាព្រះវិហាររបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត ។ សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតយើងខ្ញុំឲ្យស្គាល់ពីព្រះហឫទ័យរបស់ព្រះអង្គ និងប្រោសឲ្យយើងខ្ញុំប្រព្រឹត្តតាមគំរូរបស់ព្រះនាងម៉ារី ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា ! ព្រះអង្គបាត់ព្រះបុត្រាឲ្យប្រសូតមកជាមនុស្សដូចយើងខ្ញុំ
ហើយអង្វរព្រះអង្គក្នុងនាមយើងខ្ញុំទាំងអស់គ្នា ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះគ្រីស្ត
ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

ធម៌ប្រារព្ធទី ២ ក្នុងរដូវរង់ចាំ ទំព័រ ៤១៦ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់យើងខ្ញុំអើយ !
ព្រះអង្គបានប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត
ឲ្យយើងខ្ញុំទុកជាអាហារដែលផ្តល់ជីវិត ។
សូមព្រះអង្គមេត្តាថែរក្សាការពារ
និងប្រទានសេចក្តីសុខសាន្តឲ្យយើងខ្ញុំជានិច្ច ។

# ថ្ងៃទី ២១ ធ្នូ

Die 21 decembris

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់ដ៏មានព្រះហឫទ័យមេត្តាអើយ ! ព្រះអង្គសណ្ដាប់ពាក្យទូលអង្វររបស់យើងខ្ញុំ
ដោយបាត់ព្រះបុត្រាឲ្យយាងមករួមរស់ជាមួយមនុស្សលោក
ទាំងប្រទានកិត្តិយសដ៏ថ្លៃថ្លាឲ្យយើងខ្ញុំ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំទទួលសិរីរុងរឿងរបស់ព្រះអង្គ
នៅថ្ងៃព្រះគ្រីស្តយាងមក ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គតែងតែប្រទានសុភមង្គលដល់អស់អ្នកជឿសង្ឃឹមលើព្រះអង្គ ។
ក្រៅពីជំនឿ យើងខ្ញុំគ្មានអ្វីយកមកថ្វាយព្រះអង្គឡើយ ។ សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ ដោយអនុគ្រោះ
រួមជាមួយសក្ការបូជារបស់ព្រះយេស៊ូគ្រីស្តដែលជាព្រះសង្គ្រោះ ។

ធម៌ប្រារព្ធទី ២ ក្នុងរដូវរង់ចាំ ទំព័រ ៤១៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ !
ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំ ។ សូមព្រះអង្គមេត្តាថែរក្សាការពារប្រជារាស្ត្ររបស់ព្រះអង្គទាំងផ្លូវកាយ
ទាំងផ្លូវចិត្ត ឲ្យចេះបម្រើព្រះអង្គ និងបម្រើអ្នកដទៃផង ។

# ថ្ងៃទី ២២ ធ្នូ

Die 22 decembris

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គមិនបណ្ដោយឲ្យមនុស្សលោកវិនាសអន្តរាយឡើយ
គឺព្រះអង្គសព្វព្រះហឫទ័យឲ្យមនុស្សមានជីវិត
ដោយសារព្រះបុត្រាតែមួយរបស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាប្រោសឲ្យអស់អ្នកដែលជឿសង្ឃឹម
និងគោរពថ្វាយបង្គំព្រះបុត្រា បានទទួលការសង្គ្រោះពីព្រះអង្គជានិច្ច ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គស្រឡាញ់មនុស្សលោកខ្លាំងណាស់
រហូតដល់ចាត់ព្រះបុត្រាព្រះអង្គឲ្យយាងមករួមរស់ជាមួយយើងខ្ញុំ ។
យើងខ្ញុំសូមផ្ញើជីវិតទាំងស្រុង ទៅលើព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ
សូមព្រះអង្គមេត្តាជម្រះចិត្តគំនិតរបស់យើងខ្ញុំ ក្នុងអភិបូជានេះ ។

ធម៌ប្រារព្ធទី ២ ក្នុងរដូវរង់ចាំ ទំព័រ ៤១៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គមានព្រះហឫទ័យស្មោះត្រង់ជានិច្ច ហើយព្រះអង្គបានសង្គ្រោះប្រជារាស្ត្រ
របស់ព្រះអង្គតាមព្រះបន្ទូលសន្យា ។ សូមព្រះអង្គមេត្តាពង្រឹងជំនឿរបស់យើងខ្ញុំ
និងប្រោសឲ្យយើងខ្ញុំបានទទួលសុភមង្គលដ៏ពេញលេញ តាមព្រះបន្ទូលសន្យានេះ ។

# ថ្ងៃទី ២៣ ធ្នូ

Die 23 decembris

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការអើយ ! ព្រះអង្គបានចាត់ព្រះបុត្រាឲ្យយាងមកប្រសូតជាមនុស្សដូចយើងខ្ញុំ
ដោយបង្ហាញពីព្រះហឫទ័យមេត្តាករុណាចំពោះអ្នកតូចតាច និងអ្នកក្រីក្រ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំប្រែចិត្តគំនិត
ដើម្បីទទួលកិត្តិយសដ៏ថ្លៃថ្លាជាបុត្រធីតារបស់ព្រះអង្គ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គចាត់ព្រះបុត្រាឲ្យយាងមកសង្គ្រោះយើងខ្ញុំ ។
ក្នុងអភិបូជានេះ យើងខ្ញុំនាំគ្នានឹករឭកដល់សក្ការបូជាដ៏ប្រសើរបំផុត ដែលព្រះបុត្រាបានថ្វាយទៅព្រះបិតា ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យរៀបចំចិត្តគំនិត ដើម្បីទទួលព្រះបុត្រាដែលយាងមកជារៀងរាល់ថ្ងៃ ។

ធម៌ប្រារព្ធទី ២ ក្នុងរដូវរង់ចាំ ទំព័រ ៤១៦ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់ដ៏សប្បុរសអើយ !
ព្រះអង្គប្រទានឲ្យយើងខ្ញុំចូលរួមជាមួយព្រះយេស៊ូក្នុងអភិបូជានេះ ។ សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យប្រុងស្មារតីរៀបចំផ្លូវ
ទទួលព្រះបុត្រាដែលកំពុងយាងមក ។

# ថ្ងៃទី ២៤ ធ្នូ

# អភិបូជាពេលព្រឹក

Ad Missam matutinam

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះយេស៊ូជាអម្ចាស់ !
ព្រះអង្គយាងមកសង្គ្រោះយើងខ្ញុំយ៉ាងប្រញាប់ ដោយមិនបង្អង់ឡើយ ។ សូមព្រះអង្គលើកទឹកចិត្តដល់យើងខ្ញុំ
ដែលជឿសង្ឃឹមលើព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ
សូមព្រះអង្គពង្រឹងជំនឿ និងសង្គ្រោះយើងខ្ញុំផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់ដ៏ជាទីស្រឡាញ់អើយ !
ព្រះអង្គសង្គ្រោះយើងខ្ញុំ ដោយសារព្រះយេស៊ូជាពន្លឺបំភ្លឺមនុស្សលោក ។ សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះយេស៊ូ
ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

ធម៌ប្រារព្ធទី ២ ក្នុងរដូវរង់ចាំ ទំព័រ ៤១៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គចាត់ព្រះបុត្រាឲ្យយាងមកប្រសូតជាមនុស្សតាមរបៀបអស្ចារ្យ ។ សូមព្រះអង្គបំភ្លឺចិត្តគំនិតយើងខ្ញុំ ឲ្យយល់ពីព្រះអំណោយទានដ៏វិសេសបំផុត
ដែលព្រះអង្គបានប្រទាន ។

# រដូវបុណ្យព្រះយេស៊ូប្រសូត

TEMPUS NATIVITATIS

សម្រាប់ថ្ងៃទី ២៥ ធ្នូ

Die 25 decembris

# បុណ្យព្រះអម្ចាស់យេស៊ូប្រសូត

IN NATIVITATE DOMINI

( បុណ្យឱឡារិក )

Sollemnitas

# អភិបូជានៅពេលយប់

Ad Missam in nocte

លោកបូជាចារ្យធ្វើពិធីប្រារព្ធបុណ្យព្រះអម្ចាស់យេស៊ូប្រសូតនៅយប់ថ្ងៃទី ២៤ ធ្នូ ឬ លោកអាចប្រារព្ធពិធីអភិបូជាទាំងបីពេល តាមការគួរ ។

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
នៅរាត្រីនេះ ព្រះអង្គសព្វព្រះហឫទ័យបាត់ព្រះបុត្រា
ឲ្យយាងមកបំភ្លឺមនុស្សគ្រប់ជាតិគ្រប់សាសន៍ ។
សូមព្រះអង្គមេត្តាប្រោសឲ្យមនុស្សទាំងអស់មានជំនឿមាំមួន
និងស្គាល់ពីព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ
ដើម្បីឲ្យពន្លឺរបស់ព្រះអម្ចាស់បំភ្លឺពិភពលោកសព្វថ្ងៃនេះ ។

សូត្រធម៌ប្រកាសជំនឿ
ដល់ "ព្រះអង្គមានកំណើតជាមនុស្សដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ" អង្គប្រជុំឱនកាយបន្តិច ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ ! ព្រះអង្គស្រឡាញ់មនុស្សលោកខ្លាំងណាស់ ។
យើងខ្ញុំសូមយកប្រាក់ ធូប ផ្កា ទៀន នំ និងស្រាមកថ្វាយព្រះអង្គ ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ ដោយអនុគ្រោះ
រួមជាមួយសក្ការបូជារបស់ព្រះយេស៊ូគ្រីស្ត ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

ធម៌ប្រារព្ធទី១ ទី២ ឬ ទី៣ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត ទំព័រ ៤១៨-៤២២ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
ព្រះអង្គប្រោសយើងខ្ញុំឲ្យស្គាល់ព្រះគ្រីស្តជាពន្លឺ ដែលបំភ្លឺពិភពលោកទាំងមូល ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿ និងសេចក្តីសង្ឃឹមរបស់យើងខ្ញុំ
ឲ្យកាន់តែរឹងមាំឡើងដើម្បីបំភ្លឺដល់អស់អ្នកដែលយើងខ្ញុំជួបជារៀងរាល់ថ្ងៃ ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរយ៉ាងឱឡារិក (Latin p. 606) ។

# អភិបូជានៅពេលព្រឹកព្រលឹម

Ad Missam in aurora

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គបានចាត់ព្រះបុត្រាឲ្យយាងមកបំភ្លឺមនុស្សលោក ។
សូមព្រះអង្គមេត្តាប្រោសឲ្យមនុស្សទាំងអស់
យល់ពីព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ
ដើម្បីឲ្យពន្លឺរបស់ព្រះអម្ចាស់បំភ្លឺដល់អស់អ្នកដែលមិនស្គាល់ព្រះអង្គ ។

សូត្រធម៌ប្រកាសជំនឿ
ដល់ "ព្រះអង្គមានកំណើតជាមនុស្សដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ" អង្គប្រជុំឱនកាយបន្តិច ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់ដ៏សប្បុរសអើយ !
ព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គឲ្យយាងមកសង្គ្រោះយើងខ្ញុំ ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះយេស៊ូគ្រីស្ត
ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

ធម៌ប្រារព្ធទី១ ទី២ ឬ ទី៣ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត ទំព័រ ៤១៨-៤២២ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ប្រកបដោយធម៌មេត្តាករុណា ! ព្រះអង្គប្រោសយើងខ្ញុំឲ្យ
ស្គាល់ព្រះគ្រីស្តជាពន្លឺ ដែលបំភ្លឺពិភពលោកទាំងមូល ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿ និងសេចក្តីសង្ឃឹមរបស់យើងខ្ញុំ
ឲ្យកាន់តែរឹងមាំឡើង ដើម្បីបំភ្លឺដល់អស់អ្នកដែលយើងខ្ញុំជួបជារៀងរាល់ថ្ងៃ ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរយ៉ាងឱឡារិក (Latin p. 606-607) ។

# អភិបូជានៅពេលថ្ងៃ

Ad Missam in die

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់អើយ !
ដោយសារព្រះបុត្រាប្រសូតជាមនុស្ស
ព្រះអង្គប្រោសឲ្យយើងខ្ញុំមានកិត្តិយសយ៉ាងអស្ចារ្យ
ក្នុងឋានៈជាបុត្រធីតា និងជារូបតំណាងរបស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ
មកបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំឲ្យទទួលស្គាល់ឋានៈរបស់ខ្លួន
និងប្រតិបត្តិយ៉ាងសមរម្យជាបុត្រធីតារបស់ព្រះអង្គ ។

សូត្រធម៌ប្រកាសជំនឿ
ដល់ "ព្រះអង្គមានកំណើតជាមនុស្សដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ" អង្គប្រជុំឱនកាយបន្តិច ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់ដ៏មានធម៌មេត្តាករុណាអើយ !
អ្វីៗសព្វសារពើសុទ្ធតែកើតមកពីព្រះបន្ទូលព្រះអង្គ ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តដែលយើងខ្ញុំលើកថ្វាយនៅថ្ងៃនេះ
រួមជាមួយនឹងសក្ការបូជារបស់ព្រះយេស៊ូគ្រីស្ត ដើម្បីអរព្រះគុណព្រះអង្គ ។

ធម៌ប្រារព្ធទី១ ទី២ ឬ ទី៣ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត ទំព័រ ៤១៨-៤២២ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះបុត្រាតែមួយព្រះអង្គ
ប្រសូតមកជាមនុស្សដើម្បីសង្គ្រោះមនុស្សលោក ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំជឿសង្ឃឹមលើព្រះអង្គ និងចេះស្រឡាញ់អស់បង
ប្អូនឯទៀតៗដូចព្រះអង្គបានស្រឡាញ់យើងខ្ញុំដែរ ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរយ៉ាងឱឡារិក (Latin p. 606) ។

ថ្ងៃអាទិត្យក្រោយបុណ្យព្រះអម្ចាស់យេស៊ូប្រសូត

# បុណ្យគ្រួសារដ៏វិសុទ្ធរបស់ព្រះយេស៊ូ

S. FAMILIÆ IESU, MARIÆ ET IOSEPH

(បុណ្យ)

គេធ្វើបុណ្យនេះ នៅថ្ងៃអាទិត្យក្រោយបុណ្យព្រះអម្ចាស់យេស៊ូប្រសូត ឬ ថ្ងៃទី ៣០ ធ្នូ ។

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យប្រទានគំរូដ៏អស្ចារ្យនៃគ្រួសារដ៏វិសុទ្ធដល់យើងខ្ញុំ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំយកតម្រាប់តាម
របៀបរស់នៅរបស់គ្រួសារព្រះយេស៊ូ ដោយមានចិត្តស្រឡាញ់
ហើយថ្ងៃណាមួយ សូមឲ្យយើងខ្ញុំមានអំណរសប្បាយអស់កល្បជានិច្ច
ក្នុងគ្រួសារតែមួយរបស់ព្រះអង្គ ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះអង្គប្រោសឲ្យយើងខ្ញុំចូលរួមក្នុងសក្ការបូជារបស់ព្រះបុត្រា
ដែលផ្សះផ្សាមនុស្សលោកជាមួយព្រះអង្គ ។
តាមរយៈពាក្យទូលអង្វររបស់ព្រះនាងព្រហ្មចារិនី ជាមាតារបស់ព្រះជាម្ចាស់
រួមជាមួយសន្តយ៉ូសែប សូមព្រះអង្គប្រទានការប្រោសប្រណី
និងសេចក្ដីសុខសាន្តដល់គ្រួសាររបស់យើងខ្ញុំ ។

ធម៌ប្រារព្ធទី ១ ទី២ ឬ ទី៣ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត ទំព័រ ៤១៨-៤២២ ។

ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏សប្បុរស !

ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្តដល់យើងខ្ញុំ ។

សូមព្រះអង្គប្រោសឲ្យយើងខ្ញុំយកគំរូតាមគ្រួសារដ៏វិសុទ្ធ ។

បន្ទាប់ពីបានរងទុក្ខលំបាកក្នុងលោកនេះ សូមប្រោសឲ្យយើងខ្ញុំទៅជាសមាជិកនៃគ្រួសារដ៏វិសុទ្ធអស់កល្បជានិច្ចផង ។

# ថ្ងៃទី ២៩ ធ្នូ
# ថ្ងៃទី ៥ ក្នុងសប្ដាហ៍ព្រះអម្ចាស់យេស៊ូប្រសូត

De V die infra octavam Nativitatis Domini

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ! ព្រះអង្គមានព្រះហឫទ័យដ៏ទូលំទូលាយ ប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គ
ឲ្យយាងមកធ្វើជាពន្លឺដើម្បីបំបាត់ភាពងងឹតចេញពីពិភពលោក ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿយើងខ្ញុំ និងប្រទានសេចក្ដីសុខសាន្តដល់យើងខ្ញុំ
ហើយសូមប្រោសឲ្យយើងខ្ញុំអាចមើលឃើញព្រះអង្គក្នុងព្រះបុត្រាផង ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គបាត់ព្រះបុត្រាឲ្យយាងមកធ្វើជាតង្វាយពិសេសរបស់យើងខ្ញុំ ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះយេស៊ូគ្រីស្ត ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

ធម៌ប្រារព្ធទី១ ទី២ ឬ ទី៣ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត ទំព័រ ៤១៨-៤២២ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយ
និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំទុកជាអាហារផ្ដល់ជីវិត ។
សូមព្រះអង្គគាំទ្រ និងណែនាំយើងខ្ញុំឲ្យស្គាល់ព្រះបុត្រាកាន់តែច្បាស់
ហើយគង់នៅជាមួយយើងខ្ញុំជានិច្ច ។

# ថ្ងៃទី ៣០ ធ្នូ
# ថ្ងៃទី ៦ ក្នុងសប្ដាហ៍ព្រះអម្ចាស់យេស៊ូប្រសូត

De VI die infra octavam Nativitatis Domini

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គចាត់ព្រះបុត្រាតែមួយរបស់ព្រះអង្គឲ្យប្រសូតមកជាមនុស្សដូចយើងខ្ញុំ ។
យើងខ្ញុំសូមកោតសរសើរព្រះអង្គ ចំពោះគម្រោងការដ៏អស្ចារ្យនេះ ។
សូមព្រះអង្គមេត្តាលោះយើងខ្ញុំឲ្យរួចពីបាបនានា
ហើយប្រទានឲ្យយើងខ្ញុំមានសេរីភាពដ៏ពិតប្រាកដ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់យើងខ្ញុំអើយ !
ព្រះអង្គបានចាត់ព្រះយេស៊ូឲ្យយាងមកប្រសូតជាមនុស្សដូចយើងខ្ញុំ ។ សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ ដោយអនុគ្រោះ
រួមជាមួយសក្ការបូជារបស់ព្រះគ្រីស្តដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

ធម៌ប្រារព្ធទី១ ទី២ ឬ ទី៣ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត ទំព័រ ៤១៨-៤២២ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
ពេលណាយើងខ្ញុំទទួលព្រះកាយព្រះគ្រីស្ត
ពេលនោះព្រះអង្គប្រទានកម្លាំងដល់យើងខ្ញុំ ។
ព្រះអំណោយទានរបស់ព្រះអង្គនាំឲ្យយើងខ្ញុំសមនឹងទទួលការសង្គ្រោះ ។

# ថ្ងៃទី ៣១ ធ្នូ
# ថ្ងៃទី ៧ ក្នុងសប្ដាហ៍ព្រះអម្ចាស់យេស៊ូប្រសូត

De VII die infra octavam Nativitatis Domini

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ និងគង់នៅអស់កល្បជានិច្ច !
ព្រះអង្គសព្វព្រះហឫទ័យឲ្យព្រះបុត្រាដែលប្រសូតជាមនុស្ស ទាក់ទាញយើងខ្ញុំឲ្យបែរចិត្តស្វែងរកព្រះអង្គ
ហើយក៏ប្រោសឲ្យយើងខ្ញុំទៅជាបុត្រធីតារបស់ព្រះអង្គដែរ ។
សូមព្រះអង្គមេត្តារាប់បញ្ចូលយើងខ្ញុំក្នុងព្រះកាយព្រះគ្រីស្ត
ដែលយាងមកបង្រួបបង្រួមមនុស្សលោកទាំងអស់ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះបិតាជាអម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យមនុស្សលោកអាចបម្រើព្រះអង្គដោយចិត្តស្មោះ ព្រមទាំងឲ្យគេអាចកសាងសន្តិភាពបាន ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះគ្រីស្តដែលបង្រួបបង្រួមយើងខ្ញុំជាធ្លុងតែមួយ ។

ធម៌ប្រារព្ធទី១ ទី២ ឬ ទី៣ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត ទំព័រ ៤១៨-៤២២ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គតែងតែជួយការពារយើងខ្ញុំគ្រប់ពេលវេលា ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ ចេះប្រើសម្បត្តិលោកីយ៍ដ៏មិនទៀងទាត់នេះ
ដោយភ្ជាប់ចិត្តនឹងសម្បត្តិសួគ៌ដែលស្ថិតស្ថេរអស់កល្បជានិច្ច ។

# ថ្ងៃទី ១ មករា

In octava Nativitatis Domini

# បុណ្យគោរពព្រះនាងម៉ារី ជាមាតារបស់ព្រះជាម្ចាស់

SOLLEMNITAS SANCTÆ DEI GENETRICIS MARIÆ

(បុណ្យឱឡារិក)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាអម្ចាស់ !
ព្រះអង្គប្រោសឲ្យព្រះនាងព្រហ្មចារិនីម៉ារី
បង្កើតព្រះបុត្រាព្រះអង្គដើម្បីសង្គ្រោះមនុស្សលោក ។
តាមរយៈពាក្យទូលអង្វររបស់ព្រះនាង សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ
សមនឹងទទួលព្រះអម្ចាស់យេស៊ូគ្រីស្ត ជាព្រះបុត្រាដែលជាប្រភពនៃជីវិតថ្មី ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
ព្រះអង្គជាប្រភពនៃព្រះអំណោយទានគ្រប់យ៉ាង ។
សូមព្រះអង្គមេត្តាកែប្រែចិត្តគំនិតយើងខ្ញុំឲ្យសុខចិត្តរួមស្លាប់រួមរស់
ជាមួយព្រះយេស៊ូដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

ធម៌ប្រារព្ធទី ១ បុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារី ទំព័រ ៤៧៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់យើងខ្ញុំអើយ !
ព្រះអង្គបានប្រទានព្រះកាយព្រះគ្រីស្តឲ្យយើងខ្ញុំ ។
ថ្ងៃនេះ យើងខ្ញុំនាំគ្នាលើកតម្កើងព្រះនាងព្រហ្មចារិនីម៉ារី
ជាមាតានៃព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ និងជាមាតានៃព្រះសហគមន៍ ។
សូមព្រះអង្គមេត្តាថែរក្សាការពារដល់អស់គ្រីស្តបរិស័ទ
ទូទាំងសកលលោកបានប្រកបដោយសេចក្តីសុខសាន្ត ។

# ថ្ងៃអាទិត្យទី ២ ក្រោយបុណ្យព្រះយេស៊ូប្រសូត

DOMINICA II POST NATIVITATEM

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការអើយ !
ព្រះអង្គសព្វព្រះហឫទ័យបង្កើតពិភពលោកថ្មី
ដោយប្រទានព្រះបុត្រាមកប្រសូតជាមនុស្សពីស្ត្រីព្រហ្មចារីម្នាក់ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំទទួលព្រះបុត្រា
ដែលយាងមករំដោះយើងខ្ញុំឲ្យរួចពីបាបនានាផង ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យយើងខ្ញុំបានចូលរួមជាមួយព្រះយេស៊ូគ្រីស្ត ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះគ្រីស្តដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

ធម៌ប្រារព្ធទី១ ទី២ ឬ ទី៣ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត ទំព័រ ៤១៨-៤២២ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ពេលទទួលព្រះកាយព្រះគ្រីស្ត ព្រះអង្គយាងមករកយើងខ្ញុំ ។
មានតែព្រះអង្គទេ ដែលជម្រះចិត្តគំនិតរបស់យើងខ្ញុំ ឲ្យទទួលព្រះកាយព្រះគ្រីស្ត
យ៉ាងសមសួន ។ សូមព្រះអង្គមេត្តាតម្រង់ចិត្តយើងខ្ញុំឲ្យរស់នៅជាគ្រីស្តបរិស័ទ
ទៀងត្រង់
ស័ក្តិសមនឹងព្រះកាយដែលយើងខ្ញុំបានទទួលនៅពេលនេះផង ។

ថ្ងៃទី ៦ មករា

# បុណ្យព្រះយេស៊ូសម្ដែងព្រះអង្គ

IN EPIPHANIA DOMINI

បុណ្យឱឡារិក

Sollemnitas

# អភិបូជានៅពេលថ្ងៃ

Ad Missam in die

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គបាត់ព្រះបុត្រាឲ្យយាងមកបំភ្លឺមនុស្សគ្រប់ជាតិគ្រប់សាសន៍
ដើម្បីស្គាល់ព្រះអង្គ និងឲ្យស្គាល់ពីតម្លៃដ៏ខ្ពង់ខ្ពស់នៃជីវិតរបស់ខ្លួន ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យខិតខំស្វែងរកសេចក្ដីពិត និងពង្រឹងជំនឿរបស់យើងខ្ញុំជានិច្ច ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
ពីដើម ពួកហោរាចារ្យយកមាស កំញាន និងជ័រល្វីងទេស
មកថ្វាយព្រះបុត្រាព្រះអង្គ យើងខ្ញុំសូមយកប្រាក់ ធូប ផ្កា ទៀន នំ និងស្រា
ដែលជានិមិត្តរូបនៃជីវិតរបស់យើងខ្ញុំ លើកថ្វាយព្រះអង្គ ។
សូមព្រះអង្គមេត្តាទទួលតង្វាយរបស់យើងខ្ញុំរួមជាមួយសក្ការបូជារបស់ព្រះគ្រីស្ត
ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

ធម៌ប្រារព្ធ ក្នុងបុណ្យព្រះយេស៊ូសម្ដែងព្រះអង្គ ទំព័រ ៤២៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គណែនាំយើងខ្ញុំឲ្យស្គាល់ព្រះគ្រីស្ត ដែលជាពន្លឺបំភ្លឺមនុស្សលោក ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំទទួលស្គាល់វត្តមានរបស់ព្រះអង្គ
ក្នុងពិភពលោកនេះ ហើយសូមពង្រឹងជំនឿយើងខ្ញុំ
និងសេចក្ដីសង្ឃឹមរបស់យើងខ្ញុំជានិច្ច ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរយ៉ាងឱឡារិក (Latin p. 608) ។

# សប្ដាហ៍ក្នុងរដូវបុណ្យព្រះយេស៊ូប្រសូត

IN FERIIS TEMPORIS NATIVITATIS

ពីថ្ងៃទី ២ មករា រហូតដល់ថ្ងៃសៅរ៍មុនបុណ្យព្រះអម្ចាស់យេស៊ូទទួលពិធីជ្រមុជទឹក

## ថ្ងៃចន្ទ

Feria secunda

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !

ព្រះអង្គសព្វព្រះហឫទ័យចាត់ព្រះបុត្រាមកធ្វើជាពន្លឺបំភ្លឺមនុស្សលោក ។ សូមព្រះអង្គមេត្តាណែនាំយើងខ្ញុំដែលស្ថិតក្នុងលោកដ៏ងងឹតនេះ
បានទៅដល់ពន្លឺដ៏ត្រចះត្រចង់នៃព្រះរាជ្យព្រះអង្គនៅថ្ងៃណាមួយផង ។

### ពាក្យថ្វាយតង្វាយ

ឱ ព្រះជាម្ចាស់អើយ !

ព្រះអង្គបានប្រទាននូវអ្វីៗទាំងអស់ដែលយើងខ្ញុំត្រូវការក្នុងលោកនេះ ។
យើងខ្ញុំសូមយកនំប៉័ង និងស្រានេះ មកថ្វាយព្រះអង្គ
ទុកជាតំណាងនៃព្រះអំណោយទានដ៏អស្ចារ្យរបស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាទទួលតង្វាយទាំងនេះ ពីយើងខ្ញុំដោយអនុគ្រោះ ។

ធម៌ប្រារព្ធទី១ ទី២ ឬ ទី៣ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត ទំព័រ ៤១៨-៤២២ ។
ឬ ធម៌ប្រារព្ធ បុណ្យព្រះយេស៊ូសម្ដែងព្រះអង្គ ទំព័រ ៤២៤ ។

### ពាក្យអរព្រះគុណ

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គ
ដែលប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត
ព្រមទាំងព្រះបន្ទូលរបស់ព្រះអង្គ ទុកជាអាហារដែលផ្ដល់កម្លាំងឲ្យយើងខ្ញុំ ។

# ថ្ងៃអង្គារ

Feria tertia

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ចអើយ !
ព្រះបុត្រាចាប់កំណើតជាមនុស្ស ដោយប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំកែប្រែចិត្តគំនិត និងប្រព្រឹត្តរាល់កិច្ចការ
ដើម្បីគាប់ព្រះហឫទ័យព្រះអង្គជានិច្ច ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គប្រោសប្រទានអ្វីៗទាំងអស់ ដែលយើងខ្ញុំត្រូវការក្នុងលោកនេះ ។
យើងខ្ញុំសូមយកនំប៉័ង និងស្រានេះមកថ្វាយ
ទុកជាតំណាងនៃព្រះអំណោយទានរបស់ព្រះអង្គ ។
សូមព្រះមេត្តាទទួលតង្វាយទាំងនេះ ពីយើងខ្ញុំដោយអនុគ្រោះ ។

ធម៌ប្រារព្ធទី១ ទី២ ឬ ទី៣ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត ទំព័រ ៤១៨-៤២២ ។
ឬ ធម៌ប្រារព្ធ បុណ្យព្រះយេស៊ូសម្ដែងព្រះអង្គ ទំព័រ ៤២៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រោសប្រទានព្រះបន្ទូល និងព្រះកាយព្រះគ្រីស្តឲ្យយើងខ្ញុំ
ទុកជាអាហារពិសេសក្នុងអភិបូជានេះ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានជំនឿមាំមួន
ដើម្បីចូលរួមជាមួយព្រះយេស៊ូគ្រីស្តដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

# ថ្ងៃពុធ

Feria quarta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គជាពន្លឺដែលបំភ្លឺមនុស្សគ្រប់ជាតិគ្រប់សាសន៍
និងមានព្រះហឫទ័យមេត្តាករុណាចំពោះមនុស្សគ្រប់ៗរូប ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំបានស្គាល់ព្រះអង្គ ហើយសូមឲ្យប្រជាជាតិនានា
នៅលើផែនដីបានប្រកបដោយសេចក្ដីសុខសាន្ត ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាម្ចាស់អើយ !
មានតែព្រះអង្គទេដែលប្រោសឲ្យមនុស្ស
អាចបម្រើព្រះអង្គដោយចិត្តស្មោះ និងបេះកសាងសន្តិភាព ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះគ្រីស្ដដែលយើងខ្ញុំលើកថ្វាយនៅពេលនេះ ។

ធម៌ប្រារព្ធទី១ ទី២ ឬ ទី៣ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត ទំព័រ ៤១៨-៤២២ ។
ឬ ធម៌ប្រារព្ធ បុណ្យព្រះយេស៊ូសម្ដែងព្រះអង្គ ទំព័រ ៤២៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
នៅពេលប្រជារាស្ត្ររបស់ព្រះអង្គធ្វើដំណើរនៅនាលោកនេះ
ព្រះអង្គតែងតែណែនាំពួកគេ ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿយើងខ្ញុំ និងបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យនឹកដល់ព្រះអង្គដែលគង់នៅជាមួយយើងខ្ញុំជានិច្ច ។

# ថ្ងៃព្រហស្បតិ៍

Feria quinta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ដោយសារព្រះបុត្រាដ៏ជាទីស្រឡាញ់ប្រសូតជាមនុស្ស ពន្លឺដ៏ត្រចះត្រចង់របស់ព្រះអង្គបានបំភ្លឺដល់មនុស្សគ្រប់ជាតិសាសន៍ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ
ទទួលសិរីរុងរឿងរបស់ព្រះគ្រីស្តដែលជាពន្លឺមិនចេះរលត់ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គបានប្រទានព្រះអំណោយទានគ្រប់បែបយ៉ាងដល់យើងខ្ញុំ ។
សូមព្រះអង្គទទួលនំប៉័ង និងស្រានេះ
ទុកជាតង្វាយដែលមកពីការងាររបស់យើងខ្ញុំ ដោយអនុគ្រោះ ។

ធម៌ប្រារព្ធទី១ ទី២ ឬ ទី៣ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត ទំព័រ ៤១៨-៤២២ ។
ឬ ធម៌ប្រារព្ធ បុណ្យព្រះយេស៊ូសម្ដែងព្រះអង្គ ទំព័រ ៤២៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គប្រោសឲ្យយើងខ្ញុំបានចូលរួមជាមួយព្រះយេស៊ូគ្រីស្ត ក្នុងអភិបូជានេះ ។
សូមព្រះអង្គមេត្តាជួយយើងខ្ញុំឲ្យមានកម្លាំងចិត្ត និងកាន់កិរិយាមារយាទត្រឹមត្រូវជារៀងរាល់ថ្ងៃ ។

# ថ្ងៃសុក្រ

Feria sexta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គសព្វព្រះហឫទ័យបង្ហាញឲ្យមនុស្សលោកដឹងថា ព្រះសង្គ្រោះបានប្រសូតមកហើយ
ព្រះអង្គកំពុងបំពេញកិច្ចការក្នុងពិភពលោកសព្វថ្ងៃនេះ ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ ឲ្យយល់ពីសញ្ញាសម្គាល់នៃព្រះរាជ្យរបស់ព្រះអង្គ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គមានព្រះហឫទ័យស្រឡាញ់មនុស្សលោកខ្លាំងណាស់
រហូតដល់ប្រទានព្រះបុត្រាឲ្យមកលោះបាបរបស់យើងខ្ញុំ ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
ទុកជាតង្វាយរួមជាមួយសក្ការបូជារបស់ព្រះគ្រីស្ត ដោយអនុគ្រោះ ។

ធម៌ប្រារព្ធទី១ ទី២ ឬ ទី៣ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត ទំព័រ ៤១៨-៤២២ ។
ឬ ធម៌ប្រារព្ធ បុណ្យព្រះយេស៊ូសម្តែងព្រះអង្គ ទំព័រ ៤២៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាម្ចាស់អើយ !
មានតែព្រះអង្គទេ ដែលប្រោសឲ្យយើងខ្ញុំបានទទួលព្រះកាយព្រះគ្រីស្ត ។
សូមព្រះអង្គមេត្តាតម្រង់ចិត្តគំនិតរបស់យើងខ្ញុំឲ្យរស់នៅយ៉ាងទៀងត្រង់ ។
សូមប្រោសឲ្យយើងខ្ញុំបានរួចពីសេចក្តីអាក្រក់នានា
ដែលរារាំងផ្លូវមិនឲ្យទទួលជីវិតដ៏ពេញលក្ខណៈ ។

# ថ្ងៃសៅរ៍

Sabbato

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ
ហើយមានព្រះជន្មគង់នៅអស់កល្បជានិច្ច !
ព្រះអង្គមានព្រះហឫទ័យស្រឡាញ់មនុស្សលោកខ្លាំងណាស់
ដោយប្រោសយើងខ្ញុំឲ្យទៅជាបុត្រធីតារបស់ព្រះអង្គ ។ សូមព្រះអង្គប្រោសឲ្យ
យើងខ្ញុំរួបរួមគ្នាជាធ្លុងតែមួយ
និងស្រឡាញ់អ្នកដទៃដូចស្រឡាញ់ខ្លួនឯង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គបានប្រោសឲ្យយើងខ្ញុំមានចិត្តស្មោះ និងចេះកសាងសន្តិភាព ។
សូមព្រះអង្គមេត្តាទទួលសក្ការបូជាដែលយើងខ្ញុំលើកថ្វាយនៅពេលនេះ
និងប្រោសឲ្យយើងខ្ញុំមានចិត្តស្អាតបរិសុទ្ធ
ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ។

ធម៌ប្រារព្ធទី១ ទី២ ឬ ទី៣ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត ទំព័រ ៤១៨-៤២២ ។
ឬ ធម៌ប្រារព្ធ បុណ្យព្រះយេស៊ូសម្តែងព្រះអង្គ ទំព័រ ៤២៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
នៅពេលប្រជារាស្ត្ររបស់ព្រះអង្គធ្វើដំណើរនៅនាលោកនេះ
ព្រះអង្គតែងតែណែនាំពួកគេ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំចេះប្រើសម្បត្តិលោកីយ៍ដ៏មិនទៀងទាត់នេះ
ដោយភ្ជាប់ចិត្តនឹងសម្បត្តិសួគ៌ដែលនៅស្ថិតស្ថេរអស់កល្បជានិច្ច ។

ថ្ងៃអាទិត្យ ឬ ថ្ងៃចន្ទក្រោយបុណ្យព្រះយេស៊ូសម្ដែងព្រះអង្គ

# បុណ្យព្រះអម្ចាស់យេស៊ូទទួលពិធីជ្រមុជទឹក

IN BAPTISMATE DOMINI

(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ពេលព្រះយេស៊ូទទួលពិធីជ្រមុជទឹក
ព្រះអង្គសម្ដែងឲ្យមនុស្សលោកស្គាល់ឋានៈរបស់ព្រះគ្រីស្ត
ជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់អស់អ្នកដែលទទួលពិធីជ្រមុជទឹក
ដោយព្រះវិញ្ញាណដ៏វិសុទ្ធ ឲ្យបន្តបេសកកម្មរបស់ព្រះយេស៊ូក្នុងពិភពលោកនេះ ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាម្ចាស់អើយ !
ពេលព្រះយេស៊ូទទួលពិធីជ្រមុជទឹក ផ្ទៃមេឃបើកចំហ
ដើម្បីឲ្យមនុស្សលោកគាល់ព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកញ៉ាំងតង្វាយទាំងនេះ រួមនឹងសក្ការបូជារបស់ព្រះគ្រីស្ត
ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

ធម៌ប្រារព្ធ បុណ្យព្រះអម្ចាស់យេស៊ូទទួលពិធីជ្រមុជទឹក ទំព័រ ១៦២ ។

ប.  សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ.  ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប.  សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ.  យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប.  សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ.  ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់ និងមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។
យើងខ្ញុំសូមថ្លែងអំណរព្រះគុណព្រះអង្គ  ព្រោះពេលព្រះយេស៊ូទទួលពិធីជ្រមុជទឹកក្នុងទន្លេយ័រដាន់
ព្រះអង្គមានព្រះបន្ទូលបញ្ជាក់ថា  ព្រះយេស៊ូពិតជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ។
ព្រះវិញ្ញាណអភិសេកព្រះយេស៊ូតែងតាំងជាព្រះគ្រីស្ត និងជាអ្នកបម្រើរបស់ព្រះអង្គ ដើម្បីនាំដំណឹងល្អទៅប្រកាសឲ្យអ្នកក្រីក្រ ។
ឥឡូវនេះ ព្រះអង្គក៏ប្រោសយើងខ្ញុំឲ្យកើតជាថ្មីដោយសារទឹក និងព្រះវិញ្ញាណ ដើម្បីធ្វើជាបុត្រធីតារបស់ព្រះអង្គដែរ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត ដែលមានអំណាចនៅស្ថានបរមសុខ  លើកតម្កើងឫទ្ធានុភាពដ៏អស្ចារ្យរបស់ព្រះអង្គ ជានិច្ចនៅលើផែនដីនេះ ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ លើពិភពលោកទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់ដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះអង្គសព្វព្រះហឫទ័យប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំ ។
សូមព្រះអង្គបាត់ព្រះវិញ្ញាណដ៏វិសុទ្ធ មកណែនាំអស់អ្នកជឿសង្ឃឹមលើព្រះអង្គ
ឲ្យយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលព្រះអង្គគ្រប់ពេលវេលា ។

# ពាក្យអធិដ្ឋានក្នុងរដូវសែសិបថ្ងៃ

## TEMPUS QUADRAGESIMÆ

# ថ្ងៃពុធ រោយផេះ

FERIA QUARTA CINERUM

ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !

ព្រះអង្គត្រាស់ហៅយើងខ្ញុំជាគ្រីស្តបរិស័ទឲ្យវិលត្រឡប់មករកព្រះអង្គវិញ ។

សូមព្រះអង្គប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ យាងមកកែប្រែចិត្តគំនិតយើងខ្ញុំ

និងប្រោសឲ្យយើងខ្ញុំមានកម្លាំងអាចរំងាប់កិលេសតណ្ហាគ្រប់បែបយ៉ាង ។

## ពិធីរោយផេះ និងសូមព្រះពរពីព្រះជាម្ចាស់

Benedictio et imposition cinerum

ក្រោយពេលធម្មទេសនា លោកបូជាចារ្យប្រណម្យដៃ ដោយពោលថា ៖

ឱ ព្រះបិតាយើងខ្ញុំអើយ !

ព្រះអង្គសព្វព្រះហឫទ័យលើកលែងទោស

ឲ្យអស់អ្នកដែលដាក់ខ្លួន និងយល់ព្រមកែប្រែចិត្តគំនិត ។

(លោកបូជាចារ្យទ្រាបដៃអធិដ្ឋានដោយស្ងាត់ស្ងៀម) ហើយលោកពោលបន្ត ៖

សូមព្រះជាម្ចាស់មេត្តាទទួលពាក្យអង្វររបស់យើងខ្ញុំ

ព្រមទាំងប្រទានពរឲ្យយើងខ្ញុំ ✠ ដែលហៀបនឹងរោយផេះលើខ្លួន ។

សូមព្រះអង្គជម្រះចិត្តគំនិតរបស់យើងខ្ញុំ

ដើម្បីឲ្យយើងខ្ញុំបានចូលរួមជាមួយព្រះបុត្រា

ដែលសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញផង ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

(លោកបូជាចារ្យ ប្រោះទឹកព្រះពរលើផេះ ដោយស្ងាត់ស្ងៀម)

ក្នុងពេលរោយផេះ លោកបូជាចារ្យពោលថា ៖

**ចូរប្រែចិត្តគំនិត ហើយជឿដំណឹងល្អចុះ ។**

ឬ

**ចូរនឹកថា អ្នកកើតពីដី ហើយត្រឡប់ទៅដីវិញ ។**

រោយដេះហើយ លោកបូជាចារ្យលាងដៃ បន្ទាប់មក មានពាក្យអង្វរសកល ។

មិនសូត្រធម៌ប្រកាសជំនឿ ។

# ពិធីអរព្រះគុណព្រះជាម្ចាស់

Liturgia eucharistica

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
ចូលក្នុងរដូវសែសិបថ្ងៃនេះ យើងខ្ញុំសូមថ្វាយ កាយ វាចា ចិត្ត
រួមជាមួយសក្ការបូជារបស់ព្រះយេស៊ូគ្រីស្ត
ដែលសោយទុក្ខលំបាក និងមានព្រះជន្មរស់ឡើងវិញ ។
សូមព្រះអង្គកែប្រែចិត្តគំនិតយើងខ្ញុំឲ្យមានចិត្តស្រឡាញ់ព្រះអង្គ និងអ្នកដទៃយ៉ាងពិតប្រាកដ ។

ធម៌ប្រារព្ធទី ៣ និងទី ៤ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៣៣១-៣៣៣ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតរបស់គ្រីស្តឲ្យយើងខ្ញុំ ។
សូមព្រះអង្គមេត្តាប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកបំភ្លឺចិត្តគំនិតយើងខ្ញុំ ឲ្យចេះយកចិត្តទុកដាក់ប្រតិបត្តិតាមធម៌មេត្តាករុណារបស់ព្រះអង្គ
ដើម្បីឲ្យយើងខ្ញុំបានគាប់ព្រះហឫទ័យព្រះអង្គ និងបានជាសះស្បើយ ។

# ថ្ងៃព្រហស្បតិ៍ ក្រោយបុណ្យរោយផេះ

Feria quinta post Cineres

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ
ហើយប្រណីសន្ដោសដល់យើងខ្ញុំក្នុងពេលបំពេញកិច្ចការនានា
ព្រមទាំងជួយយើងខ្ញុំឲ្យសម្រេចកិច្ចការទាំងនោះ
តាមព្រះហឫទ័យព្រះអង្គ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ដ៏មានធម៌មេត្តាករុណាអើយ !
ព្រះអង្គសព្វព្រះហឫទ័យលើកលែងទោសឲ្យមនុស្សគ្រប់ជាតិសាសន៍ ។
សូមព្រះអង្គមេត្តាទទួលតង្វាយដែលមកពីការងាររបស់យើងខ្ញុំនៅថ្ងៃនេះ
បានចូលរួមជាមួយសក្ការបូជារបស់ព្រះគ្រីស្ត
ដែលមានព្រះជន្មគង់នៅជានិច្ចផង ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គ
ដែលប្រោសឲ្យយើងខ្ញុំទៅជាជនដ៏វិសុទ្ធ ដោយចូលរួមជាមួយព្រះបុត្រាជាព្រះសង្គ្រោះ ។
សូមព្រះអង្គមេត្តាលើកលែងទោសឲ្យយើងខ្ញុំ
និងសង្គ្រោះយើងខ្ញុំឲ្យរួចពីបាបនានា ។

# ថ្ងៃសុក្រ ក្រោយបុណ្យរោយផេះ

Feria sexta post Cineres

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !
ក្នុងរដូវសែសិបថ្ងៃនេះ សូមព្រះអង្គថែរក្សាការពារ
និងគាំទ្រយើងខ្ញុំដែលជាមនុស្សទន់ខ្សោយ ។
សូមប្រោសឲ្យយើងខ្ញុំមានកម្លាំងពលំ
អាចរំងាប់កិលេសតណ្ហារបស់ខ្លួន និងមានចិត្តស្រឡាញ់ព្រះអង្គជានិច្ច ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
យើងខ្ញុំសូមចូលរួមក្នុងសក្ការបូជារបស់ព្រះយេស៊ូនៅថ្ងៃនេះ
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបានគាប់ព្រះហឫទ័យព្រះអង្គ
ដោយយកចិត្តទុកដាក់លះបង់ប្រយោជន៍របស់ខ្លួន ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានឲ្យយើងខ្ញុំ
បានទទួលព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ត ។
សូមព្រះអង្គមេត្តាជម្រះចិត្តគំនិតរបស់យើងខ្ញុំឲ្យរួចផុតពីបាប
និងប្រោសឲ្យយើងខ្ញុំបានជាសះស្បើយ ។

# ថ្ងៃសៅរ៍ ក្រោយបុណ្យរោយផេះ

Sabbato post Cineres

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ
និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច ! ព្រះអង្គអាណិតអាសូរយើងខ្ញុំជាអ្នកបាប
សូមព្រះអង្គមេត្តាថែរក្សាការពារ និងគាំទ្រយើងខ្ញុំ ដោយឫទ្ធានុភាពដ៏ខ្លាំងក្លា
របស់ព្រះអង្គជានិច្ចផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គបានលើកលែងទោស និងជម្រះចិត្តគំនិតរបស់យើងខ្ញុំ
ដោយឫទ្ធានុភាពដ៏អស្ចារ្យរបស់ព្រះអង្គ ។
នៅពេលនេះ យើងខ្ញុំសូមថ្វាយសក្ការបូជារួមជាមួយព្រះយេស៊ូគ្រីស្ត
សូមព្រះអង្គសព្វព្រះហឫទ័យទទួលដោយអនុគ្រោះ ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់ប្រកបដោយព្រះបេស្គាអើយ ! យើងខ្ញុំសូមអរព្រះគុណព្រះអង្គ
ដែលប្រទានព្រះកាយ
និងព្រះលោហិតរបស់ព្រះគ្រីស្តឲ្យយើងខ្ញុំមានកម្លាំង ។
សូមព្រះអង្គមេត្តាណែនាំ និងបង្ហាញផ្លូវឲ្យយើងខ្ញុំ ធ្វើដំណើរឆ្ពោះទៅកាន់ព្រះអង្គ
ឯស្ថានបរមសុខ ។

# ថ្ងៃអាទិត្យទី ១ ក្នុងរដូវសែសិបថ្ងៃ

DOMINICA I IN QUADRAGESIMA

មិនសូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គសព្វព្រះហឫទ័យប្រទានជីវិតឲ្យមនុស្សលោក
និងប្រោសឲ្យគេមានសុភមង្គលយ៉ាងពេញលេញ ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំឲ្យចេះស្រឡាញ់ និងបម្រើព្រះអង្គ
ដើម្បីយើងខ្ញុំអាចស្គាល់មាគ៌ាឆ្ពោះទៅកាន់ព្រះអង្គឯស្ថានបរមសុខ ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គពិតជាម្ចាស់ជីវិតរបស់យើងខ្ញុំ ហើយប្រទានអ្វីៗទាំងអស់លើផែនដីឲ្យយើងខ្ញុំប្រើប្រាស់ ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំទុកជាតង្វាយ
រួមជាមួយនឹងសក្ការបូជារបស់ព្រះគ្រីស្ត
ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

ធម៌ប្រារព្ធ លើកតម្កើងព្រះអម្ចាស់សោយទុក្ខលំបាក ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ ជាព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់
ហើយមានព្រះជន្មអស់កល្បជានិច្ច !
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់ ។
ព្រះគ្រីស្តបានតមអាហារអស់រយៈពេលសែសិបថ្ងៃ
ហើយព្រះអង្គទុកការតមនេះ ជាគំរូសម្រាប់យើងខ្ញុំប្រព្រឹត្តក្នុងរដូវត្រណម ។
ព្រះអង្គបានឈ្នះល្បិចកលរបស់សត្វពស់ និងប្រៀនប្រដៅឲ្យយើងខ្ញុំកម្ចាត់មេម្យៅនៃអំពើអាក្រក់
ដូច្នេះ យើងខ្ញុំអាចចូលរួមក្នុងគម្រោងការដ៏អស្ចារ្យនៃបុណ្យចម្លងដោយសមរម្យ
និងចូលរួមក្នុងពិធីបុណ្យចម្លងអស់កល្បជានិច្ចនៅថ្ងៃណាមួយ ។

ហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយទេវទូត
និងសន្តបុគ្គលទាំងឡាយ សូមអរព្រះគុណព្រះអង្គ
ដោយប្រកាសទាំងអំណរសប្បាយក្រៃលែងថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ លើពិភពលោកទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ... ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្តឲ្យយើងខ្ញុំ ។
តាមរយៈព្រះយេស៊ូគ្រីស្ត យើងខ្ញុំទទួលជីវិតថ្មី មានជំនឿ
និងមានសេចក្តីសង្ឃឹមយ៉ាងមាំមួន ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំស្គាល់ព្រះគ្រីស្ត
ដែលជាព្រះបន្ទូលរបស់ព្រះអង្គ កាន់តែច្បាស់ឡើងៗ ។

# ថ្ងៃចន្ទ

Feria secunda

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់ជាព្រះសង្គ្រោះយើងខ្ញុំអើយ !
ព្រះអង្គប្រទានឲ្យយើងខ្ញុំមានប្រាជ្ញាយល់ដឹងពីអត្ថន័យនៃព្រះបន្ទូល ។
សូមព្រះអង្គមេត្តាកែប្រែចិត្តគំនិតយើងខ្ញុំឲ្យវិលត្រឡប់មករកព្រះអង្គវិញ
ហើយប្រោសយើងខ្ញុំឲ្យចេះស្រឡាញ់អ្នកដទៃដូចស្រឡាញ់ខ្លួនឯង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យលើកលែងទោស និងការពារយើងខ្ញុំគ្រប់ពេលវេលា ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំទុកជាតង្វាយ
រួមជាមួយសក្ការបូជារបស់ព្រះគ្រីស្តដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំ ។
សូមព្រះអង្គមេត្តាការពារយើងខ្ញុំទាំងផ្លូវកាយ ទាំងផ្លូវចិត្ត
ហើយសង្គ្រោះយើងខ្ញុំឲ្យមានអំណរសប្បាយជានិច្ច ។

# ថ្ងៃអង្គារ

Feria tertia

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាប្រភពនៃជីវិត !
ព្រះអង្គទតមើលប្រជារាស្ត្ររបស់ព្រះអង្គ
ព្រមទាំងប្រោសឲ្យពួកគេតមអាហារដើម្បីជម្រះចិត្តគំនិត ។
សូមប្រោសឲ្យយើងខ្ញុំប្រាថ្នាស្វែងរកព្រះអង្គ និងប្រព្រឹត្តតាមព្រះហឫទ័យព្រះអង្គជានិច្ច ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គប្រទានអ្វីៗគ្រប់យ៉ាងឲ្យយើងខ្ញុំសម្រាប់ចិញ្ចឹមជីវិត ។
សូមព្រះអង្គមេត្តាទទួលតង្វាយដែលយើងខ្ញុំលើកថ្វាយដោយអនុគ្រោះ ។
សូមព្រះអង្គសព្វព្រះហឫទ័យញ៉ាំងតង្វាយទាំងនេះ ឲ្យទៅជាព្រះកាយ
និងព្រះលោហិតរបស់ព្រះគ្រីស្ត ដែលផ្តល់ជីវិតអស់កល្បជានិច្ចដល់យើងខ្ញុំ ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំក្នុងអភិបូជានេះ ។
ដោយអគ្គសញ្ញានេះ សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំរួបរួមគ្នា
ដើម្បីមានកម្លាំងរំងាប់កិលេសតណ្ហា ព្រមទាំងយកចិត្តទុកដាក់ស្វែងរកសម្បត្តិនៅស្ថានបរមសុខ ។

# ថ្ងៃពុធ

Feria quarta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ !
ព្រះអង្គទតមើលប្រជារាស្ត្ររបស់ព្រះអង្គដោយព្រះហឫទ័យស្រឡាញ់ ។ សូមព្រះអង្គមេត្តាកែប្រែចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យលះបង់ចោលប្រយោជន៍ផ្ទាល់ខ្លួន ហើយប្រព្រឹត្តអំពើល្អចំពោះអ្នកដទៃ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យយើងខ្ញុំបានជាសះស្បើយ និងមានជីវិតដ៏ប្រសើរតាមរយៈអគ្គសញ្ញានានា ។
សូមព្រះអង្គមេត្តាញ៉ាំងនំប៉័ង និងស្រានេះ
ឲ្យទៅជាព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ត ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាម្ចាស់ដ៏សប្បុរសអើយ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានអគ្គសញ្ញានានា
ទុកជាកម្លាំងប្រចាំជីវិតរបស់យើងខ្ញុំ ។
សូមព្រះអង្គមេត្តាលោះយើងខ្ញុំឲ្យរួចពីបាបនានា
ដើម្បីទទួលព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ត
ទុកជាអាហារដែលផ្តល់ជីវិតអស់កល្បជានិច្ច ។

# ថ្ងៃព្រហស្បតិ៍

Feria quinta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គបំភ្លឺចិត្តគំនិតយើងខ្ញុំឲ្យស្វែងរកសេចក្ដីសុចរិត
និងប្រព្រឹត្តអំពើល្អតាមសេចក្ដីដែលយើងខ្ញុំប្រាថ្នា ។
ប្រសិនបើព្រះអង្គមិនជួយយើងខ្ញុំទេ យើងខ្ញុំក៏រស់នៅមិនបានដែរ
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំបេះស្រឡាញ់អ្នកដទៃ
និងប្រព្រឹត្តកិច្ចការទាំងអស់ ឲ្យបានគាប់ព្រះហឫទ័យព្រះអង្គផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ដ៏មានធម៌មេត្តាករុណាអើយ !
ព្រះអង្គប្រោសឲ្យយើងខ្ញុំប្រែចិត្តគំនិតបែរមករកព្រះអង្គវិញ ។ សូមព្រះអង្គមេត្តា
ទទួលកាយ វាចា ចិត្ត និងពាក្យទូលអង្វររបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះគ្រីស្ត ដោយអនុគ្រោះ ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់ជាព្រះបិតាយើងខ្ញុំអើយ !
ព្រះអង្គប្រោសប្រទានឲ្យយើងខ្ញុំថ្វាយអភិបូជាដ៏វិសុទ្ធនេះ
ដើម្បីឲ្យយើងខ្ញុំបានរួចពីបាប និងមានជីវិតយ៉ាងពេញលេញ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបានជាសះស្បើយ
នៅពេលនេះ និងរហូតតទៅទៀត ។

# ថ្ងៃសុក្រ

Feria sexta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !

ព្រះអង្គប្រោសឲ្យយើងខ្ញុំរៀបចំខ្លួនសម្រាប់បុណ្យចម្លងខាងមុខនេះ ដើម្បីរំឭកដល់ព្រះយេស៊ូសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ ។

តាមរយៈការតមខាងផ្លូវកាយ សូមព្រះអង្គមេត្តាជួយឲ្យយើងខ្ញុំបង្កើតផលផ្លែល្អខាងផ្លូវចិត្ត ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !

ព្រះអង្គមានព្រះហឫទ័យសង្គ្រោះយើងខ្ញុំឲ្យរួចផុតពីបាបនានា ។

សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ

រួមជាមួយសក្ការបូជារបស់ព្រះគ្រីស្តដែលមានព្រះជន្មគង់នៅជានិច្ច

ហើយប្រោសឲ្យយើងខ្ញុំបានជាសះស្បើយ ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !

ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្តឲ្យយើងខ្ញុំ ។

សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំមានចិត្តគំនិតថ្មី

និងលាងជម្រះយើងខ្ញុំឲ្យរួចផុតពីបាបចាស់ ដើម្បីយើងខ្ញុំបានទទួលការសង្គ្រោះពីព្រះអង្គផង ។

# ថ្ងៃសៅរ៍

Sabbato

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដែលគង់នៅអស់កល្បជានិច្ច !
ព្រះអង្គស្រឡាញ់មនុស្សលោកខ្លាំងណាស់ ។
សូមព្រះអង្គបង្វែរចិត្តគំនិតរបស់យើងខ្ញុំឲ្យបែរមករកព្រះអង្គវិញ ដោយប្រោសឲ្យយើងខ្ញុំស្រឡាញ់ និងហ៊ានថ្វាយជីវិតទាំងស្រុង
ដើម្បីបម្រើព្រះអង្គក្នុងគ្រប់កិច្ចការទាំងអស់ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
សក្ការបូជារបស់ព្រះគ្រីស្ត ប្រោសយើងខ្ញុំឲ្យជាសះស្បើយ ។
សូមព្រះអង្គមេត្តាជួយពង្រឹងជំនឿរបស់យើងខ្ញុំ
ឲ្យហ៊ានរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូគ្រីស្ត
ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ចផង ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គបានប្រទានព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ត
ឲ្យយើងខ្ញុំទុកជាអាហារផ្តល់កម្លាំង ។
សូមព្រះអង្គមេត្តាថែរក្សាការពារ និងប្រោសឲ្យយើងខ្ញុំ
ទៅជាប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គ ។

# ថ្ងៃអាទិត្យទី ២ ក្នុងរដូវសែសិបថ្ងៃ

DOMINICA II QUADRAGESIMA

មិនសូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែងអើយ !
ព្រះអង្គបាត់ព្រះបុត្រាដ៏ជាទីស្រឡាញ់ ឲ្យធ្វើជាព្រះបន្ទូលក្នុងលោកនេះ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំយកចិត្តទុកដាក់
ស្តាប់សេចក្តីដែលព្រះអង្គមានព្រះបន្ទូលមកយើងខ្ញុំតាមរយៈអ្នកដទៃ
និងតាមរយៈព្រឹត្តិការណ៍នានាប្រចាំជីវិតយើងខ្ញុំ ។
សូមប្រោសឲ្យយើងខ្ញុំមានជំនឿមាំមួន ដើម្បីស្គាល់សិរីរុងរឿងរបស់ព្រះគ្រីស្ត
ដែលមានព្រះជន្មគង់នៅ ជាមួយយើងខ្ញុំសព្វថ្ងៃនេះផង ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
កាលពីដើម លោកអប្រាហាំបានយកកូនដ៏ជាទីស្រឡាញ់មកថ្វាយព្រះអង្គ ។
សូមព្រះអង្គមេត្តាទទួលនំ និងស្រានេះ ព្រមទាំងកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះគ្រីស្ត ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

ធម៌ប្រារព្ធ ព្រះអម្ចាស់បញ្ចេញរស្មីពណ្ណរាយ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ព្រះអង្គសព្វព្រះហឫទ័យប្រទានពេលវេលាដ៏ពិសិដ្ឋដល់បុត្រធីតារបស់ព្រះអង្គ
ដើម្បីឲ្យពួកគេជម្រះចិត្តគំនិតបានស្អាតបរិសុទ្ធឡើងវិញ ។
ព្រះអង្គក៏សព្វព្រះហឫទ័យឲ្យពួកគេរំងាប់កិលេសតណ្ហា
ដោយប្រើប្រាស់ទ្រព្យសម្បត្តិនៃពិភពលោកដ៏មិនទៀងទាត់នេះ
ដើម្បីផ្ចង់ចិត្តទៅរកសម្បត្តិនៅស្ថានបរមសុខ ដែលស្ថិតស្ថេរអស់កល្បជានិច្ច ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ សូមកោតសរសើរព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ លើពិភពលោកទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ...

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់ដ៏សប្បុរសអើយ !
ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្តដល់យើងខ្ញុំ ។
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំ ឲ្យស្គាល់ពីគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ
ហើយបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំឲ្យរស់នៅសមជាបុត្រធីតារបស់ព្រះអង្គជានិច្ច ។

# ថ្ងៃចន្ទ

Feria secunda

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គបង្ហាញឲ្យយើងខ្ញុំបេះលត់ដំរូបកាយ ដើម្បីកែប្រែចិត្តគំនិត ។
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យរួចផុតពីអំពើបាបនានា
ហើយរស់នៅស្របតាមសេចក្ដីស្រឡាញ់របស់ព្រះអង្គជានិច្ច ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គត្រាស់ហៅយើងខ្ញុំឲ្យគោរពបម្រើព្រះអង្គ និងថ្វាយអភិបូជានេះ ។
សូមព្រះអង្គមេត្តាថែរក្សាការពារយើងខ្ញុំ ឲ្យជៀសផុតពីអំពើអាក្រក់គ្រប់យ៉ាង
ហើយព្រះសណ្ដាប់ពាក្យទូលអង្វររបស់យើងខ្ញុំ ដោយអនុគ្រោះ ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ដឲ្យយើងខ្ញុំទុកជាអាហារផ្ដល់ជីវិត ។
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យបានជាសះស្បើយ និងប្រែចិត្តរបស់យើងខ្ញុំឲ្យស្វែងរកសម្បត្តិនៅស្ថានបរមសុខ ។

# ថ្ងៃអង្គារ

Feria tertia

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែងអើយ !
ព្រះអង្គថែរក្សាព្រះសហគមន៍របស់ព្រះអង្គជានិច្ច ដោយណែនាំយើងខ្ញុំមិនឲ្យវង្វេងពីមាគ៌ារបស់ព្រះអង្គឡើយ ។
សូមព្រះអង្គគាំទ្រយើងខ្ញុំឲ្យជៀសផុតពីសេចក្ដីអាក្រក់គ្រប់យ៉ាង និងតម្រង់ចិត្តយើងខ្ញុំឲ្យបែរឆ្ពោះទៅរកព្រះអង្គជាព្រះសង្គ្រោះ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យយញ្ញបូជានេះ ផ្ដល់សេចក្ដីសុខសាន្តដល់យើងខ្ញុំ
និងជម្រះចិត្តយើងខ្ញុំឲ្យស្អាតបរិសុទ្ធ រួចពីសេចក្ដីអាក្រក់គ្រប់យ៉ាង ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះគ្រីស្ត ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់ដ៏មានធម៌មេត្តាករុណាដ៏លើសលប់អើយ !
ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតព្រះយេស៊ូគ្រីស្តឲ្យយើងខ្ញុំ ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យមានជំនឿមាំមួនលើព្រះអង្គ
ដោយរស់នៅស្របតាមព្រះហឫទ័យព្រះអង្គជានិច្ច ។

# ថ្ងៃពុធ

Feria quarta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !

ព្រះអង្គគាំទ្រព្រះសហគមន៍ឲ្យទៅជាមហាគ្រួសារតែមួយ ។ សូមព្រះអង្គប្រទានពរជ័យឲ្យយើងខ្ញុំតាមសេចក្តីត្រូវការសព្វថ្ងៃនេះ ហើយសូមកែប្រែចិត្តគំនិតយើងខ្ញុំឲ្យប្រព្រឹត្តតាមព្រះហឫទ័យព្រះអង្គជានិច្ច ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !

ព្រះអង្គស្រឡាញ់មនុស្សលោកខ្លាំងណាស់ ។

សូមព្រះអង្គមេត្តាទទួលតង្វាយទាំងនេះ ដោយអនុគ្រោះ

និងប្រោសឲ្យយើងខ្ញុំបានរួចពីបាប ព្រមទាំងមានសេរីភាព

ដោយជាប់ចិត្តនឹងព្រះអង្គជានិច្ច ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់ជាព្រះបិតាយើងខ្ញុំអើយ !

ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតព្រះយេស៊ូគ្រីស្តឲ្យយើងខ្ញុំ

ទុកជាអាហារផ្តល់កម្លាំង ។

សូមព្រះអង្គមេត្តាពង្រឹងជំនឿ និងសេចក្តីសង្ឃឹមដល់យើងខ្ញុំផង ។

# ថ្ងៃព្រហស្បតិ៍

Feria quinta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គស្រឡាញ់មនុស្សដែលមានចិត្តបរិសុទ្ធ
ហើយក៏ប្រោសអ្នកបាបឲ្យមានចិត្តបរិសុទ្ធដែរ ។
សូមព្រះអង្គបំភ្លឺចិត្តគំនិតយើងខ្ញុំឲ្យមានជំនឿមាំមួន
ដើម្បីបំពេញការងាររបស់ខ្លួន ក្រោមការណែនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គស្រឡាញ់មនុស្សលោកខ្លាំងណាស់ ។
ក្នុងរដូវសែសិបថ្ងៃនេះ សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
ខិតខំជម្រះចិត្តគំនិតយ៉ាងពិតប្រាកដ ដើម្បីគាប់ព្រះហឫទ័យព្រះអង្គ ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះបិតាជាអម្ចាស់អើយ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គ
ដែលប្រទានព្រះកាយ និងព្រះលោហិតព្រះយេស៊ូគ្រីស្តឲ្យយើងខ្ញុំ
ទុកជាអាហារផ្តល់កម្លាំង ។
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យចេះរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូ
ដែលគង់នៅជាមួយយើងខ្ញុំក្នុងគ្រប់កាលៈទេសៈ ។

# ថ្ងៃសុក្រ

Feria sexta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យយើងខ្ញុំប្រែចិត្តគំនិត និងប្រព្រឹត្តអំពើល្អ ។
សូមព្រះអង្គមេត្តាជម្រះយើងខ្ញុំឲ្យបានស្អាតបរិសុទ្ធ  និងមានចិត្តស្មោះត្រង់
ដើម្បីចូលរួមជាមួយព្រះគ្រីស្តនៅស្ថានបរមសុខ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាម្ចាស់អើយ !
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំចេះបម្រើព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
ដើម្បីថ្វាយអភិបូជានេះដោយសមរម្យ ។
សូមប្រោសឲ្យយើងខ្ញុំរស់នៅដោយប្រព្រឹត្តតាមព្រះហឫទ័យព្រះអង្គជានិច្ច ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតរបស់ព្រះយេស៊ូគ្រីស្ត
ដែលជាអគ្គសញ្ញានៃការសង្គ្រោះអស់កល្បជានិច្ចដល់យើងខ្ញុំ ។
សូមប្រោសឲ្យយើងខ្ញុំដើរឆ្ពោះទៅរកព្រះអង្គ
ដើម្បីទទួលការសង្គ្រោះតាមព្រះបន្ទូលសន្យារបស់ព្រះអង្គ ។

# ថ្ងៃសៅរ៍

Sabbato

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់ដ៏មានធម៌មេត្តាករុណាអើយ !
ព្រះអង្គប្រោសឲ្យយើងខ្ញុំបានជាសះស្បើយ ហើយព្រះអង្គក៏ប្រទានសម្បត្តិនៃស្ថានបរមសុខឲ្យយើងខ្ញុំដែរ ។ សូមព្រះអង្គមេត្តាអាណិតអាសូរថែរក្សាយើងខ្ញុំគ្រប់ពេលវេលា និងណែនាំយើងខ្ញុំទៅកាន់ពន្លឺដ៏ភ្លឺស្វាងរបស់ព្រះយេស៊ូគ្រីស្តជានិច្ច ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
សូមឲ្យព្រះអំណោយទានដ៏សក្ការៈនេះ លោះយើងខ្ញុំដើម្បីទទួលបានផលផ្លែល្អ
គឺការពារយើងខ្ញុំឲ្យរួចផុតពីកិលេសតណ្ហា
និងណែនាំយើងខ្ញុំឆ្ពោះទៅកាន់ការសង្គ្រោះ ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយ
និងព្រះលោហិតរបស់ព្រះយេស៊ូគ្រីស្តឲ្យយើងខ្ញុំទុកជាអាហារប្រចាំជីវិត ។
សូមព្រះអង្គប្រោសឲ្យកម្លាំងនៃអគ្គសញ្ញានានា ជ្រាបចូលក្នុងចិត្តរបស់យើងខ្ញុំ
ដើម្បីជាចលករជំរុញឲ្យយើងខ្ញុំមានជំនឿមាំមួន ។

# ថ្ងៃអាទិត្យទី ៣ ក្នុងរដូវសែសិបថ្ងៃ

DOMINICA III IN QUADRAGESIMA

មិនសូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យប្រទានព្រះជន្មផ្ទាល់របស់ព្រះអង្គ ឲ្យអស់អ្នកដែលផ្ញើជីវិតទៅលើព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ ។
សូមព្រះអង្គប្រទានព្រះអំណោយទានដ៏អស្ចារ្យនេះ
ដល់អស់បងប្អូនយើងខ្ញុំដែលត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក
ក្នុងឱកាសបុណ្យចម្លងខាងមុខ ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រទានធម្មវិន័យឲ្យយើងខ្ញុំប្រតិបត្តិតាម ហើយព្រះអង្គក៏សន្យាថា
នឹងប្រទានព្រះវិញ្ញាណនៃសេចក្ដីស្រឡាញ់
ដល់អស់អ្នកដែលជឿសង្ឃឹមលើព្រះអង្គ ។
យើងខ្ញុំសូមថ្វាយកាយ វាចា ចិត្ត និងជំនឿរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះគ្រីស្ត ។
សូមព្រះអង្គមេត្តាទទួលដោយអនុគ្រោះ ។

ធម៌ប្រារព្ធ៖ ស្ត្រីជាសាសន៍សាម៉ារី ឬ ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។
ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។
ប. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ ជាព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់
ហើយមានព្រះជន្មគង់អស់កល្បជានិច្ច !
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។
នៅពេលព្រះអង្គសុំទឹកពីស្ត្រីសាសន៍សាម៉ារី
ព្រះអង្គមានបំណងឲ្យនាងសម្តែងជំនឿ
ដ្បិតព្រះអង្គបានបង្កាត់ភ្លើងនៃសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់
នៅក្នុងចិត្តរបស់នាង ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ សូមកោតសរសើរព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ លើពិភពលោកទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ...

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់យើងខ្ញុំអើយ !
ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតព្រះបុត្រាឲ្យយើងខ្ញុំទុកជាអាហារ ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿ និងបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំឲ្យស្គាល់
ធម៌មេត្តាករុណារបស់ព្រះអង្គនៅគ្រប់កាលៈទេសៈក្នុងជីវិតប្រចាំថ្ងៃនេះ ។

# ថ្ងៃចន្ទ

Feria secunda

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !
ប្រសិនបើព្រះអង្គមិនជួយការពារទេនោះ ព្រះសហគមន៍គ្មានសេចក្តីសុខសាន្តឡើយ ។
សូមព្រះអង្គមេត្តាសម្តែងធម៌មេត្តាករុណារបស់ព្រះអង្គចំពោះយើងខ្ញុំ ដោយជម្រះឲ្យយើងខ្ញុំបានស្អាតបរិសុទ្ធ ព្រមទាំងថែរក្សា និងណែនាំព្រះសហគមន៍របស់ព្រះអង្គគ្រប់ពេលវេលា ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ដ៏សប្បុរស !
យើងខ្ញុំជាអ្នកបម្រើព្រះអង្គ សូមលើកតង្វាយនេះដើម្បីលើកតម្កើងព្រះអង្គ ។
សូមព្រះអង្គមេត្តាទទួលតង្វាយទាំងនេះដោយអនុគ្រោះ
រួមជាមួយសក្ការបូជារបស់ព្រះគ្រីស្តដែលជាព្រះសង្គ្រោះយើងខ្ញុំ ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គ
ដែលប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំក្នុងអភិបូជានេះ ។
សូមព្រះអង្គមេត្តាបង្រួបបង្រួមយើងខ្ញុំជាធ្លុងតែមួយក្នុងអង្គព្រះគ្រីស្ត
ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

# ថ្ងៃអង្គារ

Feria tertia

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ដ៏មានព្រះហឫទ័យស្មោះត្រង់ជានិច្ចអើយ !
ព្រះអង្គសម្តែងធម៌មេត្តាករុណាចំពោះយើងខ្ញុំ
និងជួយឧបត្ថម្ភយើងខ្ញុំឲ្យស្ម័គ្រចិត្តបម្រើព្រះអង្គជារៀងរាល់ថ្ងៃ ។
សូមព្រះអង្គថែរក្សាការពារយើងខ្ញុំ
ឲ្យជៀសផុតពីមហន្តរាយគ្រប់បែបយ៉ាង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការអើយ !
ព្រះអង្គទាក់ទាញចិត្តយើងខ្ញុំឲ្យស្វែងរកព្រះអង្គ
ដោយចាត់ព្រះយេស៊ូឲ្យយាងមកសង្គ្រោះយើងខ្ញុំ ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
ហើយប្រោសឲ្យយើងខ្ញុំបានជាសះស្បើយ ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គតែងតែថែរក្សាការពារយើងខ្ញុំគ្រប់ពេលវេលា ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំចេះស្រឡាញ់ព្រះអង្គ
និងរួមរស់ជាមួយព្រះគ្រីស្តកាន់តែជិតស្និទ្ធឡើងៗ ។

# ថ្ងៃពុធ

Feria quarta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់យើងខ្ញុំអើយ !
ក្នុងរដូវសែសិបថ្ងៃនេះ ព្រះអង្គចិញ្ចឹមយើងខ្ញុំដោយព្រះបន្ទូលរបស់ព្រះអង្គ
និងបង្រៀនយើងខ្ញុំឲ្យចេះរួមរស់ជាមួយព្រះគ្រីស្ត ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបម្រើព្រះអង្គដោយចិត្តស្មោះ
និងរួមគ្នាអធិដ្ឋានជានិច្ច ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ដ៏សប្បុរសអើយ !
ព្រះអង្គតែងតែថែរក្សាការពារយើងខ្ញុំឲ្យរួចពីអន្តរាយគ្រប់បែបយ៉ាង ។
ក្នុងអភិបូជានេះ សូមព្រះអង្គមេត្តាទទួលតង្វាយរបស់យើងខ្ញុំ
រួមជាមួយពាក្យទូលអង្វររបស់ប្រជារាស្ត្រព្រះអង្គ ដោយអនុគ្រោះ ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតអើយ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយ និងព្រះលោហិតព្រះយេស៊ូគ្រីស្តឲ្យយើងខ្ញុំទុកជាអាហារផ្តល់កម្លាំង ។
សូមព្រះអង្គមេត្តាជម្រះចិត្តគំនិតយើងខ្ញុំឲ្យស្អាតបរិសុទ្ធផុតពីសៅហ្មងនានា
និងប្រោសឲ្យយើងខ្ញុំយល់ពីគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គផង ។

# ថ្ងៃព្រហស្បតិ៍

Feria quinta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
ព្រះអង្គប្រោសយើងខ្ញុំឲ្យរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូគ្រីស្ត
ដែលសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ ។
សូមព្រះអង្គមេត្តាបំភ្លឺយើងខ្ញុំឲ្យយកចិត្តទុកដាក់រៀបចំចិត្តគំនិត
សម្រាប់ពិធីបុណ្យចម្លងនៅពេលខាងមុខនេះ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់យើងខ្ញុំ !
ព្រះអង្គសព្វព្រះហឫទ័យជម្រះចិត្តគំនិតយើងខ្ញុំ
ឲ្យរួចផុតពីអំពើអាក្រក់គ្រប់បែបយ៉ាង ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំចេះស្រឡាញ់បងប្អូនឯទៀតៗ ហើយជាប់ចិត្តនឹង
សម្បត្តិដ៏ពេញលក្ខណៈនៅស្ថានបរមសុខ ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់ដ៏សប្បុរសអើយ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយ និងព្រះលោហិតព្រះយេស៊ូ
គ្រីស្តឲ្យយើងខ្ញុំទុកជាអាហារ ។
សូមព្រះអង្គមេត្តាជួយឧបត្ថម្ភយើងខ្ញុំ
និងប្រោសឲ្យយើងខ្ញុំចេះបង្ហាញពីការសង្គ្រោះរបស់ព្រះអង្គ
ក្នុងគ្រប់កិច្ចការដែលយើងខ្ញុំប្រព្រឹត្ត ។

# ថ្ងៃសុក្រ

Feria sexta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ដ៏មានព្រះហឫទ័យសប្បុរសយ៉ាងក្រៃលែងអើយ !
ព្រះអង្គបង្ហូរធម៌មេត្តាករុណារបស់ព្រះអង្គមកក្នុងចិត្តយើងខ្ញុំ ។ សូមព្រះអង្គប្រោសយើងខ្ញុំឲ្យចេះរំងាប់កិលេសតណ្ហា
ដោយស្តាប់ និងប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះអង្គ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ !
ព្រះអង្គសព្វព្រះហឫទ័យនាំការសង្គ្រោះមកឲ្យយើងខ្ញុំ ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
និងញ៉ាំងតង្វាយទាំងនេះ ឲ្យទៅជាសក្ការបូជាដែលគាប់ព្រះហឫទ័យព្រះអង្គ ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គបានបង្ហាញឫទ្ធានុភាពដ៏អស្ចារ្យរបស់ព្រះអង្គ
ឲ្យយើងខ្ញុំទទួលការសង្គ្រោះរបស់ព្រះគ្រីស្តយ៉ាងបរិបូណ៌ ។ សូមព្រះអង្គប្រោសឲ្យយើងខ្ញុំចេះរួមរស់ជាមួយព្រះបុត្រាព្រះអង្គ
ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

# ថ្ងៃសៅរ៍

Sabbato

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យយើងខ្ញុំប្រារព្ធពិធីផ្សេងៗ ក្នុងរដូវសែសិបថ្ងៃនេះ
ដើម្បីកែប្រែចិត្តគំនិត ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំខិតខំរួមរស់ជាមួយព្រះយេស៊ូ
ដែលសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតអើយ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យយើងខ្ញុំមានចិត្តស្អាតបរិសុទ្ធ
ដើម្បីចូលរួមក្នុងអភិបូជានេះ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំហ៊ានប្រកាសថា អ្វីៗទាំងអស់សុទ្ធតែមកពីព្រះអង្គ ។
សូមឲ្យសក្ការបូជាដែលយើងខ្ញុំថ្វាយនៅថ្ងៃនេះ បានគាប់ព្រះហឫទ័យព្រះអង្គ ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាម្ចាស់ដ៏មានធម៌មេត្តាករុណាអើយ !
ព្រះអង្គប្រទានព្រះអំណោយទានយ៉ាងបរិបូណ៌ឲ្យយើងខ្ញុំ ។
សូមព្រះអង្គពង្រឹងជំនឿ និងសេចក្ដីសង្ឃឹមរបស់យើងខ្ញុំ
ដើម្បីឲ្យយើងខ្ញុំគោរពថ្វាយបង្គំព្រះអង្គជានិច្ច ។

# ថ្ងៃអាទិត្យទី ៤ ក្នុងរដូវសែសិបថ្ងៃ

DOMINICA IV IN QUADRAGESIMA

មិនសូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់ដ៏មានធម៌មេត្តាករុណាអើយ !
ព្រះអង្គចាត់ព្រះបុត្រាឲ្យយាងមកផ្សះផ្សាមនុស្សលោកនឹងព្រះអង្គ ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿ និងបំភ្លឺចិត្តគំនិតគ្រីស្តបរិស័ទទាំងអស់
ឲ្យស្គាល់ពីព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គគ្រប់ពេលវេលា
ជាពិសេស អស់អ្នកដែលត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក
ក្នុងឱកាសបុណ្យចម្លងខាងមុខនេះ ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់យើងខ្ញុំអើយ !
ព្រះអង្គមានព្រះហឫទ័យមេត្តាករុណាចំពោះយើងខ្ញុំជាអ្នកបាប ។
យើងខ្ញុំគ្មានអ្វីតបស្នងព្រះគុណព្រះអង្គ ក្រៅពីផ្ញើជីវិតទាំងស្រុង
ទៅលើព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គឡើយ ។
សូមព្រះអង្គទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះយេស៊ូគ្រីស្តដែលមានព្រះជន្មគង់នៅជានិច្ច ។

លោកអាចជ្រើសរើស ធម៌ប្រារព្ធទី ១ ទី២ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

ធម៌ប្រារព្ធ បុរសម្នាក់ដែលខ្វាក់ភ្នែកពីកំណើត

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។
ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។
ប. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ជាព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្ដជាអម្ចាស់យើងខ្ញុំ ។

ដោយសារគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ ព្រះបុត្រាបានចាប់កំណើតជាមនុស្ស
ដើម្បីណែនាំមនុស្សជាតិដែលដើរក្នុងសេចក្ដីងងឹត ឲ្យចូលក្នុងពន្លឺនៃជំនឿ ។
ព្រះអង្គបានយកទឹកនៃជីវិតថ្មីមកលាងជម្រះអស់អ្នក
ដែលកើតក្នុងទាសភាពនៃបាបចាស់ ដើម្បីឲ្យគេទៅជាបុត្រធីតារបស់ព្រះអង្គវិញ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្ដបុគ្គលទាំងឡាយ សូមកោតសរសើរព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ លើពិភពលោកទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ...

ពាក្យអរព្រះគុណ
ឱ ព្រះបិតាជាអម្ចាស់អើយ !
ព្រះអង្គពិតជាពន្លឺដែលបំភ្លឺមនុស្សគ្រប់ជាតិគ្រប់សាសន៍ ។
សូមព្រះអង្គមេត្ដាពង្រឹងជំនឿរបស់យើងខ្ញុំ
ដែលទើបទទួលព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ដ
ឲ្យកាន់តែយល់ពីធម៌មេត្ដាករុណា និងស្រឡាញ់អ្នកដទៃតាមរបៀបព្រះអង្គ ។

# ថ្ងៃចន្ទ

Feria secunda

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គប្រទានអគ្គសញ្ញានានា ដើម្បីកសាងពិភពលោកថ្មី ។
សូមព្រះអង្គជួយឧបត្ថម្ភឲ្យព្រះសហគមន៍កាន់តែរីកចម្រើនឡើង ហើយប្រោសឲ្យយើងខ្ញុំចេះចែករំលែកសម្បត្តិនៃស្ថានបរមសុខ
ដល់មនុស្សលោកសព្វថ្ងៃនេះផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់យើងខ្ញុំអើយ !
ព្រះអង្គប្រទានព្រះជន្មរបស់ព្រះអង្គដើម្បីសង្គ្រោះយើងខ្ញុំ ។
សូមព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយដែលយើងខ្ញុំលើកថ្វាយនៅថ្ងៃនេះ
ហើយសូមជម្រះចិត្តយើងខ្ញុំឲ្យផុតពីភាពសៅហ្មងនានា ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំទុកជាអាហារចិញ្ចឹមជីវិត ។
សូមព្រះអង្គមេត្តាណែនាំយើងខ្ញុំឆ្ពោះទៅកាន់សុភមង្គលអស់កល្បជានិច្ច ។

# ថ្ងៃអង្គារ

Feria tertia

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ដ៏មានធម៌មេត្តាករុណាអើយ !
ព្រះអង្គសង្គ្រោះមនុស្សលោក ដោយសារព្រះយេស៊ូជាព្រះបុត្រាព្រះអង្គ
ដែលសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ ។
ក្នុងរដូវសែសិបថ្ងៃនេះ សូមប្រោសឲ្យយើងខ្ញុំហ៊ានប្រកាសដំណឹងល្អ
ដល់មនុស្សលោកថា ព្រះអង្គពិតជាព្រះសង្គ្រោះមែន ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គប្រទានអាហារគ្រប់យ៉ាងសម្រាប់ចិញ្ចឹមជីវិត ។ យើងខ្ញុំសូមយកអាហារខ្លះ
មកថ្វាយ ដើម្បីអរព្រះគុណព្រះអង្គ ។
សូមព្រះអង្គមេត្តាញ៉ាំងនំប៉័ង និងស្រានេះ
ឲ្យទៅជាព្រះកាយ និងព្រះលោហិតព្រះយេស៊ូគ្រីស្ត ។
សូមប្រោសឲ្យយើងខ្ញុំបានជាសះស្បើយ និងមានជីវិតជាអនន្ត ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតព្រះយេស៊ូគ្រីស្តឲ្យយើងខ្ញុំ
ទុកជាអាហារផ្តល់ជីវិត ។
សូមព្រះអង្គមេត្តាជម្រះចិត្តគំនិតរបស់យើងខ្ញុំ
នៅពេលឥឡូវនេះ ហើយជាដរាបតរៀងទៅ ។

# ថ្ងៃពុធ

Feria quarta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់អើយ !
ព្រះអង្គប្រទានរង្វាន់ដល់អស់អ្នកសុចរិត
ហើយព្រះអង្គលើកលែងទោសដល់អ្នកបាបដែលកែប្រែចិត្តគំនិត ។
សូមព្រះអង្គមានព្រះហឫទ័យមេត្តាករុណាចំពោះអស់អ្នកដែលទូលអង្វរព្រះអង្គ ។
ពេលយើងខ្ញុំសារភាពថា យើងខ្ញុំជាអ្នកបាប
សូមព្រះអង្គមេត្តាលើកលែងទោសឲ្យយើងខ្ញុំរួចផុតពីបាបផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គមេត្តាទទួលសក្ការបូជានេះ ដោយអនុគ្រោះ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបោះបង់បោលរបៀបរស់នៅចាស់ ហើយប្រែចិត្តមក
រួមរស់ជាមួយព្រះយេស៊ូ ដែលមានព្រះជន្មគង់នៅ
និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅផង ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គតែងតាំងអគ្គសញ្ញាព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត
សូមព្រះអង្គមេត្តាកុំបណ្តោយឲ្យយើងខ្ញុំមានទោស ព្រោះយើងខ្ញុំប្រព្រឹត្តមិនសម
រម្យចំពោះព្រះកាយ
តែផ្ទុយទៅវិញ សូមប្រោសឲ្យយើងខ្ញុំបានជាសះស្បើយ
ដោយសារបានទទួលព្រះកាយនេះ ។

# ថ្ងៃព្រហស្បតិ៍

Feria quinta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ដ៏មានព្រះហឫទ័យសប្បុរសអើយ !
សូមព្រះអង្គប្រណីសន្ដោសយើងខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គ ដែលបានខិតខំផ្ចង់ខ្លួន និងព្យាយាមធ្វើអំពើល្អ
ដើម្បីប្រព្រឹត្តតាមវិន័យរបស់ព្រះអង្គ
ហើយត្រៀមខ្លួនប្រារព្ធពិធីបុណ្យចម្លងខាងមុខនេះ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គជ្រាបថា យើងខ្ញុំជាមនុស្សទន់ខ្សោយ
សូមឫទ្ធានុភាពនៃសក្ការបូជារបស់ព្រះយេស៊ូ
ប្រោសឲ្យយើងខ្ញុំរួចផុតពីសេចក្ដីអាក្រក់នានា
និងជួយការពារយើងខ្ញុំជានិច្ច ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្ដឲ្យយើងខ្ញុំ ។
សូមព្រះអង្គមេត្ដាជម្រះចិត្តគំនិតរបស់យើងខ្ញុំ ឲ្យរួចពីសេចក្ដីអាក្រក់គ្រប់បែបយ៉ាង ។

# ថ្ងៃសុក្រ

Feria sexta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យជួយឧបត្ថម្ភយើងខ្ញុំជាមនុស្សទន់ខ្សោយ ។
ដោយសារជំនួយនេះ សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំបានជាសះស្បើយ
និងមានអំណរសប្បាយ ហើយរស់នៅតាមរបៀបសុចរិត ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការអើយ !
ព្រះយេស៊ូបានបូជាព្រះជន្ម ដើម្បីប្រទានព្រះជន្មនេះឲ្យយើងខ្ញុំ ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះយេស៊ូគ្រីស្តគ្រប់ពេលវេលាផង ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំទុកជាអាហារ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំលះបង់ចិត្តរឹងមានះបោល ដើម្បីទទួលចិត្តថ្មីដ៏វិសុទ្ធវិញ ។

# ថ្ងៃសៅរ៍

Feria Sabbato

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ប្រកបដោយធម៌មេត្តាករុណាអើយ !
ប្រសិនបើ ព្រះអង្គមិនប្រោសប្រណីដល់យើងខ្ញុំទេនោះ
យើងខ្ញុំពុំអាចគាប់ព្រះហឫទ័យព្រះអង្គបានឡើយ ។
សូមព្រះអង្គមេត្តាតម្រង់ចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យបែរឆ្ពោះទៅរកព្រះអង្គជានិច្ច ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់យើងខ្ញុំអើយ !
សូមព្រះអង្គមេត្តាទទួលតង្វាយរបស់យើងខ្ញុំដោយអនុគ្រោះ ។ នៅពេលយើងខ្ញុំឃ្លាតឆ្ងាយពីព្រះអង្គ សូមព្រះអង្គមេត្តាអាណិតអាសូរ
តម្រង់ចិត្តគំនិតរបស់យើងខ្ញុំឲ្យវិលមករកព្រះអង្គវិញ ។

ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់ដ៏សប្បុរសអើយ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត
ទុកជាអាហារ ។
សូមព្រះអង្គមេត្តាជម្រះចិត្តគំនិតរបស់យើងខ្ញុំ
ព្រមទាំងផ្ដល់កម្លាំងឲ្យយើងខ្ញុំប្រព្រឹត្តតែកិច្ចការ
ដែលគាប់ព្រះហឫទ័យព្រះអង្គ ។

# ថ្ងៃអាទិត្យទី ៥ ក្នុងរដូវសែសិបថ្ងៃ

DOMINICA V IN QUADRAGESIMA

មិនសូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាអម្ចាស់យើងខ្ញុំ !
សូមព្រះអង្គជួយយើងខ្ញុំឲ្យប្រាថ្នា
ដើរតាមផ្លូវនៃធម៌មេត្តាករុណារបស់ព្រះបុត្រាព្រះអង្គ
ដែលស្រឡាញ់មនុស្សលោករហូតដល់សោយទិវង្គត ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គមិនសព្វព្រះហឫទ័យឲ្យមនុស្សបាបវិនាសអន្តរាយឡើយ
តែព្រះអង្គប្រោសឲ្យគេកែប្រែចិត្តគំនិត និងទទួលជីវិតថ្មី ។
សូមព្រះអង្គទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះយេស៊ូគ្រីស្ត ដែលមានព្រះជន្មគង់នៅ
និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ ។

លោកអាចប្រើ ធម៌ប្រារព្ធ ក្នុងរដូវសែសិបថ្ងៃ ទំព័រ ៤២៨-៤៣៤ ។

ធម៌ប្រារព្ធ ៖ លោកឡាសារ

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។
ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។
ប. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មរស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

កាលពីដើម ក្នុងសភាពជាមនុស្ស ព្រះអង្គព្រះកន្សែង
សោកស្តាយលោកឡាសារជាមិត្តសម្លាញ់ តែក្នុងសភាពជាព្រះដ៏វិសុទ្ធ
ទ្រង់ប្រោសឲ្យលោកបានក្រោកចេញពីផ្នូរ ។
ឥឡូវព្រះអង្គនៅតែមានព្រះហឫទ័យអាណិតអាសូរមនុស្សលោក
ហើយណែនាំយើងខ្ញុំទៅកាន់ជីវិតថ្មី ដោយព្រះអំណោយទានរបស់ព្រះអង្គ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ សូមកោតសរសើរព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ លើពិភពលោកទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ...

## ពាក្យអរព្រះគុណ

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្តឲ្យយើងខ្ញុំ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំរួបរួមគ្នាជាធ្លុងតែមួយក្នុងអង្គព្រះគ្រីស្ត ។

# ថ្ងៃចន្ទ

Feria secunda

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់ដ៏សប្បុរសអើយ !
ព្រះអង្គសព្វព្រះហឫទ័យត្រាស់ហៅមនុស្សឲ្យស្គាល់ និងស្រឡាញ់ព្រះអង្គ ។
សូមព្រះអង្គប្រោសប្រណីដល់យើងខ្ញុំ
ជាពិសេស បងប្អូនដែលត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក
ក្នុងបុណ្យចម្លងខាងមុខនេះ ឲ្យមានជីវិតថ្មីរួមជាមួយព្រះយេស៊ូគ្រីស្តជានិច្ច ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំសូមថ្វាយអភិបូជានេះ
ដើម្បីកោតសរសើរ និងអរព្រះគុណព្រះអង្គ ។
សូមព្រះអង្គមេត្តាទទួលយើងខ្ញុំដែលបានផ្តន្ទាខ្លួន ដើម្បីជម្រះចិត្តគំនិតឲ្យបានស្អាតបរិសុទ្ធ ។

ធម៌ប្រារព្ធទី ១ លើកតម្កើងព្រះអម្ចាស់សោយទុក្ខលំបាក ទំព័រ ៤៣៦ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់យើងខ្ញុំអើយ !
ព្រះអង្គបានប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំ
ទុកជាអាហារផ្តល់កម្លាំង ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានចិត្តរីករាយដើរតាមព្រះយេស៊ូគ្រីស្ត
ដែលមានព្រះជន្មគង់នៅ និងសោយរាជ្យរួមជាមួយព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

# ថ្ងៃអង្គារ

Feria tertia

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់យើងខ្ញុំអើយ !
មានតែព្រះអង្គទេ ដែលអាចប្រោសឲ្យមនុស្សទៅជាបុត្រធីតារបស់ព្រះអង្គ
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានចិត្តខ្ជាប់ខ្ជួន ប្រាថ្នាធ្វើតាមព្រះហឫទ័យព្រះអង្គ
ជានិច្ច ។
សូមប្រោសឲ្យប្រជារាស្ត្រដែលបម្រើព្រះអង្គកាន់តែរីកចម្រើនឡើងផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំសូមថ្វាយសក្ការបូជា ដែលផ្សះផ្សាយើងខ្ញុំជាមួយព្រះអង្គ
សូមព្រះអង្គមេត្តារំដោះយើងខ្ញុំឲ្យរួចផុតពីបាបនានា
និងជំរុញយើងខ្ញុំឲ្យបម្រើព្រះអង្គដោយចិត្តស្មោះ ។

ធម៌ប្រារព្ធទី ១ លើកតម្កើងព្រះអម្ចាស់សោយទុក្ខលំបាក ទំព័រ ៤៣៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយ
និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំ ទុកជាអាហារផ្តល់ជីវិត ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានចិត្តស្មោះ
រួមរស់ជាមួយព្រះគ្រីស្តនៅស្ថានបរមសុខ ។

# ថ្ងៃពុធ

Feria quarta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់ដ៏មានធម៌មេត្តាករុណាអើយ !
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់បុត្រធីតាព្រះអង្គ
ដែលមានចិត្តសោកស្ដាយចំពោះអំពើបាបរបស់ខ្លួន ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យស្ម័គ្រចិត្តបម្រើព្រះអង្គជារៀងរហូតផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គប្រទានអ្វីៗសព្វសារពើឲ្យយើងខ្ញុំសម្រាប់ចិញ្ចឹមជីវិត ។ យើងខ្ញុំសូមយកតង្វាយខ្លះមកថ្វាយព្រះអង្គ
ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ និងអរព្រះគុណព្រះអង្គ ។
សូមព្រះអង្គមេត្តាទទួលតង្វាយទាំងនេះ ដោយអនុគ្រោះ ។

ធម៌ប្រារព្ធទី ១ លើកតម្កើងព្រះអម្ចាស់សោយទុក្ខលំបាក ទំព័រ ៤៣៦ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
មានតែព្រះអង្គទេដែលប្រោសឲ្យយើងខ្ញុំបានជាសះស្បើយ សូមព្រះអង្គមេត្តាដកឫសនៃសេចក្ដីអាក្រក់គ្រប់យ៉ាង ចេញពីចិត្តគំនិតយើងខ្ញុំ
សូមការពារយើងខ្ញុំ និងប្រទានកម្លាំងឲ្យយើងខ្ញុំជានិច្ច ។

# ថ្ងៃព្រហស្បតិ៍

Feria quinta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតអើយ !
សូមព្រះអង្គមេត្តាសណ្តាប់ពាក្យទូលអង្វររបស់យើងខ្ញុំ
ហើយថែរក្សាការពារយើងខ្ញុំ ដែលពឹងផ្អែកលើធម៌មេត្តាករុណារបស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាលើកលែងទោសយើងខ្ញុំឲ្យរួចពីបាបនានា
ដើម្បីឲ្យយើងខ្ញុំរស់នៅស្របតាមព្រះហឫទ័យព្រះអង្គផង ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះយេស៊ូបានបូជាព្រះជន្មដើម្បីលើកលែងទោសយើងខ្ញុំឲ្យរួចពីបាប ។
សូមព្រះអង្គមេត្តាទទួលតង្វាយរបស់យើងខ្ញុំដោយអនុគ្រោះ
រួមជាមួយសក្ការបូជារបស់ព្រះយេស៊ូគ្រីស្ត ជាព្រះសង្គ្រោះមនុស្សលោក ។

ធម៌ប្រារព្ធទី ១ លើកតម្កើងព្រះអម្ចាស់សោយទុក្ខលំបាក ទំព័រ ៤៣៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ដ៏មានធម៌មេត្តាករុណា !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គ
ដែលប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំ
ទុកជាអាហារផ្តល់ជីវិតអស់កល្បជានិច្ច ។

# ថ្ងៃសុក្រ

Feria sexta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គលើកលែងទោសឲ្យយើងខ្ញុំជាប្រជារាស្ត្រដ៏ទន់ខ្សោយ ដែលស្ថិតនៅក្រោមអំណាចនៃតណ្ហានៅឡើយ ។ សូមព្រះអង្គមេត្តារំដោះយើងខ្ញុំឲ្យមានសេរីភាពយ៉ាងពិតប្រាកដ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាម្ចាស់ដ៏សប្បុរសអើយ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យយើងខ្ញុំគោរពបម្រើព្រះអង្គនៅទីនេះ ។ សូមព្រះអង្គប្រោសឲ្យយើងខ្ញុំចូលរួមក្នុងសក្ការបូជារបស់ព្រះយេស៊ូគ្រីស្ត ដែលបានបូជាព្រះជន្ម និងសង្គ្រោះយើងខ្ញុំផង ។

ធម៌ប្រារព្ធទី ១ លើកតម្កើងព្រះអម្ចាស់សោយទុក្ខលំបាក ទំព័រ ៤៣៦ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំទុកជាអាហារផ្តល់ជីវិត ។
សូមព្រះអង្គមេត្តាការពារយើងខ្ញុំឲ្យផុតពីអន្តរាយនានា ។

# ថ្ងៃសៅរ៍

Sabbato

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យសង្គ្រោះមនុស្សលោកគ្រប់ពេលវេលា ។
សូមព្រះអង្គមេត្តាថែរក្សាការពារយើងខ្ញុំ ជាបុត្រធីតារបស់ព្រះអង្គ
ហើយសូមបន្តណែនាំបងប្អូនដែលត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹកផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ដ៏មានព្រះជន្មគង់នៅអស់កល្បជានិច្ចអើយ !
ព្រះអង្គប្រទានជីវិតថ្មីឲ្យអស់អ្នកដែលមានជំនឿ
ហើយទទួលអគ្គសញ្ញាជ្រមុជទឹក ។
សូមព្រះអង្គមេត្តាទទួលតង្វាយ និងពាក្យអង្វររបស់យើងខ្ញុំដោយអនុគ្រោះ ។
សូមទ្រង់លើកលែងទោសឲ្យយើងខ្ញុំដែលជឿសង្ឃឹមលើព្រះអង្គ ។

ធម៌ប្រារព្ធទី ១ លើកតម្កើងព្រះអម្ចាស់សោយទុក្ខលំបាក ទំព័រ ៤៣៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏ខ្ពង់ខ្ពស់បំផុត !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលបានប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំ ទុកជាអាហារផ្តល់ជីវិត ។
សូមព្រះអង្គមេត្តាប្រទានព្រះជន្មផ្ទាល់របស់ព្រះអង្គឲ្យយើងខ្ញុំផង ។

# សប្ដាហ៍ពិសិដ្ឋ

HEBDOMADA SANCTA

# ថ្ងៃអាទិត្យបុណ្យហែស្លឹក
# លើកតម្កើងព្រះអម្ចាស់រងទុក្ខលំបាក

DOMINICA IN PALMIS DE PASSIONE DOMINI

នៅថ្ងៃអាទិត្យនេះ យើងនាំគ្នារំឭកព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹមក្នុងឋានៈជា «ព្រះគ្រីស្ត» គឺជាស្ដេចមួយអង្គដែលប្រទានសុភមង្គលដ៏ពេញលេញឲ្យមនុស្សលោកតាមព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ ។ ដោយយើងអានគម្ពីរស្ដីអំពីព្រះយេស៊ូរងទុក្ខលំបាក យើងសន្មតហៅថ្ងៃអាទិត្យនេះថា «ថ្ងៃអាទិត្យលើកតម្កើងព្រះយេស៊ូរងទុក្ខលំបាក» ។ នៅថ្ងៃនេះ មានពិធីហែស្លឹក បន្ទាប់មកថ្វាយអភិបូជា ។

## ព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម

Commemoratio ingressus Domini in Ierusalem

គ្រីស្តបរិស័ទជួបជុំគ្នានៅខាងក្រៅព្រះវិហារ ដោយកាន់ធាងទន្សែ (ស្លឹក) រៀងៗខ្លួន ។ លោកបូជាចារ្យ ជាអធិបតីពាក់អាវពណ៌ក្រហមអញ្ជើញមកដល់ ។ នៅពេលអង្គប្រជុំច្រៀងចប់ លោកបូជាចារ្យពោលថា ៖

**ក្នុងព្រះនាមព្រះបិតា និងព្រះបុត្រា ≅ និងព្រះវិញ្ញាណដ៏វិសុទ្ធ ។**

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

លោកបូជាចារ្យពន្យល់យ៉ាងខ្លីអំពីអត្ថន័យពិធី ហើយប្រណម្យដៃពោលថា ៖

បពិត្រព្រះបិតាប្រកបដោយធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះអង្គសព្វព្រះហឫទ័យឲ្យយើងខ្ញុំអបអរសាទរទទួលព្រះយេស៊ូ
ដែលយាងមករកយើងខ្ញុំក្នុងនាមព្រះអង្គ ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿរបស់យើងខ្ញុំនៅពេលកើតទុក្ខលំបាក
ហើយប្រោសឲ្យយើងខ្ញុំសុខចិត្តបូជាជីវិតតាមព្រះយេស៊ូគ្រីស្ត ដែលមានព្រះជន្មរស់ឡើងវិញ និងសោយរាជ្យជាមួយព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

លោកបូជាចារ្យប្រោះទឹកព្រះពរលើអង្គប្រជុំទាំងមូល បន្ទាប់មក លោកប្រកាសព្រះបន្ទូលដំណឹងល្អស្ដីអំពីព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម ។

## ឆ្នាំ «ក»

### ✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមលោកម៉ាថាយ ២១,១-១១

ព្រះយេស៊ូយាងមកជាមួយពួកសាវ័កជិតដល់ក្រុងយេរូសាឡឹមហើយ។ កាលមកដល់ភូមិ បេតផាសេ ដែលនៅចង្កេះភ្នំដើមអូលីវ ព្រះអង្គចាត់សាវ័កពីររូបឲ្យទៅមុន ទាំងមានព្រះបន្ទូលថា៖ «ចូរទៅភូមិដែលនៅមុខអ្នករាល់គ្នា។ ពេលទៅដល់ភ្លាម អ្នកនឹងឃើញមេលាមួយដែលគេចងនៅទីនោះ ហើយមានកូនវានៅជាមួយដែរ។ ចូរស្រាយវាដឹកមកឲ្យខ្ញុំ។ ប្រសិនបើមាននរណា សួរ ចូរប្រាប់គេថា ព្រះអម្ចាស់ត្រូវការវា តែព្រះអង្គនឹងឲ្យគេដឹកមកវិញភ្លាមជាមិនខាន»។ ព្រឹត្តិការណ៍នេះ កើតឡើងស្របនឹងសេចក្ដីដែលមានចែងទុកតាមរយៈព្យាការីថា៖ «ចូរប្រាប់ប្រជាជនក្រុងស៊ីយ៉ូនថា៖ មើលហ្ន៎! ព្រះមហាក្សត្ររបស់អ្នកយាងមករកអ្នកហើយ។ ទ្រង់មានព្រះហឫទ័យស្លូតបូត ទ្រង់គង់លើខ្នងលា ហើយគង់លើខ្នងកូនលាផងដែរ»។ សាវ័កទាំងពីរនាំគ្នាចេញទៅធ្វើតាមបញ្ជារបស់ព្រះយេស៊ូ ដឹកមេលា និងកូនវាមក។ គេយកអាវក្រាលពីលើខ្នងលា និងលើខ្នងកូនលាផង ហើយព្រះយេស៊ូឡើងគង់លើខ្នងវា។ នៅពេលនោះមានបណ្ដាជនជាច្រើន នាំគ្នាយកអាវរបស់ខ្លួនក្រាលតាមផ្លូវ ហើយអ្នកខ្លះទៀត កាច់ធាងទន្សែយកមកក្រាលលើផ្លូវដែរ។ មហាជនដែលដើរហែហមព្រះយេស៊ូពីមុខពីក្រោយ នាំគ្នាស្រែកឡើងថា៖ «ជយោ! ព្រះរាជវង្សរបស់ព្រះបាទដាវីឌ! សូមព្រះជាម្ចាស់ប្រទានពរ ដល់ព្រះអង្គដែលយាងមកក្នុងព្រះនាមព្រះជាអម្ចាស់! ជយោ! ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត!»។ កាលព្រះយេស៊ូយាងទៅដល់ក្រុងយេរូសាឡឹម ប្រជាជននៅក្នុងទីក្រុងទាំងមូលនាំគ្នាជ្រួលច្របល់សួរថា៖ «តើលោកនោះជានរណា?»។ មហាជនឆ្លើយថា៖ «លោកជាព្យាការីយេស៊ូមកពីភូមិណាសារ៉ែត ក្នុងស្រុកកាលីឡេ»។

ឆ្នាំ «ខ»

## ✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមលោកម៉ាកុស ១១,១-១០

ព្រះយេស៊ូយាងមកជាមួយសាវ័កជិតដល់ក្រុងយេរូសាឡឹមហើយ។ លុះមកដល់ជិតភូមិបេតផាសេ និងភូមិបេថានី ដែលនៅចង្កេះភ្នំដើមអូលីវ ព្រះអង្គចាត់សាវ័កពីររូបឲ្យទៅមុន ដោយមានព្រះបន្ទូលថា៖ «ចូរទៅភូមិនៅមុខអ្នករាល់គ្នា ពេលទៅដល់ភ្លាម អ្នកនឹងឃើញកូនលាមួយដែលគេចងទុក ពុំទាន់ដែលមាននរណាជិះនៅឡើយទេ ចូរស្រាយវាដឹកមក។ ប្រសិនបើមានគេសួរថា "ហេតុអ្វីបានជាអ្នកស្រាយវា?" ចូរឆ្លើយប្រាប់គេថា "ព្រះអម្ចាស់ត្រូវការវា តែព្រះអង្គនឹងឲ្យគេដឹកមកវិញភ្លាមជាមិនខាន"»។ សាវ័កទាំងពីររូបចេញដំណើរទៅឃើញ កូនលាមួយដែលគេចងទុកនៅមាត់ទ្វារខាងក្រៅផ្ទះក្បែរផ្លូវ ហើយក៏ស្រាយវា។ មានអ្នកខ្លះនៅទីនោះ សួរអ្នកទាំងពីរថា៖ «តើអ្នកធ្វើអ្វីហ្នឹង ហេតុអ្វីបានជាអ្នកស្រាយកូនលានេះ?»។ សាវ័កទាំងពីរឆ្លើយទៅគេតាមពាក្យដែលព្រះយេស៊ូបានបង្គាប់មក គេក៏ឲ្យដឹកចេញទៅ។ សាវ័កទាំង ពីរដឹកវាយកមកថ្វាយព្រះយេស៊ូ ហើយយកអាវរបស់ខ្លួនក្រាលពីលើខ្នងកូនលា ព្រះអង្គក៏ឡើង គង់លើខ្នងកូនលានោះ។ មានមនុស្សម្នាជាច្រើននាំគ្នាយកអាវរបស់ខ្លួនក្រាលតាមផ្លូវ ហើយខ្លះទៀតយកស្លឹកឈើពីចម្ការមករាយលើផ្លូវដែរ។ អស់អ្នកដែលដើរហែហមព្រះយេស៊ូពីមុខពីក្រោយនាំគ្នាស្រែកឡើងថា៖ «ជយោ! សូមព្រះជាម្ចាស់ប្រទានពរដល់ព្រះអង្គដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ សូមព្រះជាម្ចាស់ប្រទានពរដល់ព្រះរាជ្យដែលកំពុងតែមកដល់ គឺព្រះរាជ្យរបស់ព្រះបាទដាវីឌជាបិតារបស់យើង! ជយោ! ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត!»។

ឬ

## ✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមលោកយ៉ូហាន ១២,១២-១៦

បណ្ដាជនច្រើនកុះករចូលរួមធ្វើបុណ្យចម្លង។ កាលគេឮដំណឹងថា ព្រះយេស៊ូយាងជិតដល់ក្រុងយេរូសាឡឹម គេនាំគ្នាកាច់ធាងទន្សែកាន់មកទទួលព្រះអង្គទាំងស្រែកថា៖ "ជយោ! សូមព្រះជាម្ចាស់ប្រទានពរដល់ព្រះអង្គដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ គឺព្រះមហាក្សត្ររបស់ជនជាតិអ៊ីស្រាអែល!"។ ព្រះយេស៊ូរកបានកូនលាមួយ ហើយព្រះអង្គគង់លើខ្នងវា ស្របតាម សេចក្ដីដែលមានចែងទុកមកថា៖ "ប្រជាជនក្រុងស៊ីយ៉ូនអើយ! កុំភ័យខ្លាចអី! មើលហ្ន៎! ព្រះមហាក្សត្ររបស់អ្នកយាងមកដល់ហើយ ព្រះអង្គគង់លើខ្នងកូនលា"។ នៅពេលនោះ ក្រុមសាវ័កពុំបានយល់ហេតុការណ៍ទាំងនេះភ្លាមៗទេ។ លុះដល់ព្រះយេស៊ូ ទទួលសិរីរុងរឿងហើយ ទើបគេនឹកឃើញថា ហេតុការណ៍ទាំងនេះ មានចែងទុកអំពីព្រះអង្គ ហើយមហាជនក៏បានធ្វើកិច្ចការទាំងប៉ុន្មានថ្វាយព្រះអង្គស្របតាមគម្ពីរដែរ។

ឆ្នាំ «គ»

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមលោកលូកា** ១៩,២៨-៤០

កាលព្រះយេស៊ូមានព្រះបន្ទូលដូច្នោះហើយ ព្រះអង្គក៏យាងនាំមុខបណ្ដាជនឡើងទៅក្រុងយេរូសាឡឹម។ លុះព្រះអង្គយាងជិតដល់ភូមិបេតផាសេ និងភូមិបេតថានី ដែលនៅចង្កេះភ្នំដើមអូលីវ ព្រះអង្គចាត់សាវ័កពីររូបឲ្យទៅមុន ដោយមានព្រះបន្ទូលថា៖ «ចូរទៅភូមិខាងមុខនោះ ពេលអ្នកទៅដល់ អ្នកនឹងឃើញកូនលាមួយដែលគេចងនៅ ទីនោះ ពុំទាន់មាននរណាជិះនៅឡើយទេ ចូរស្រាយវាដឹកមក។ ប្រសិនបើមានគេសួរថា "ហេតុអ្វីបានជាអ្នកស្រាយវា?" ចូរឆ្លើយទៅគេថា "ព្រះអម្ចាស់ត្រូវការវា"»។ សាវ័កទាំងពីរក៏ចេញទៅ ហើយឃើញដូចព្រះយេស៊ូមានព្រះបន្ទូលប្រាប់គេមែន។ ពេលគេកំពុងស្រាយ កូនលា ម្ចាស់វាសួរថា៖ «ហេតុអ្វីបានជាអ្នកស្រាយលានេះ?» សាវ័កឆ្លើយថា៖ «ព្រះអម្ចាស់ត្រូវការវា»។ បន្ទាប់មក អ្នកទាំងពីរដឹកកូនលាយកមកថ្វាយព្រះយេស៊ូ ហើយក្រាលអាវធំរបស់ខ្លួនលើខ្នងវា ថ្វាយព្រះអង្គគង់។ នៅពេលព្រះអង្គយាងទៅមុខ មនុស្សម្នាយកអាវធំរបស់ខ្លួនមកក្រាលតាមផ្លូវ។ កាលព្រះយេស៊ូយាងតាមផ្លូវដែលចុះពីភ្នំដើមអូលីវ មកជិតដល់ក្រុងយេរូសាឡឹម មានសាវ័កច្រើនកុះករអរសប្បាយនាំគ្នាបន្លឺសំឡេងសរសើរតម្កើងព្រះជាម្ចាស់អំពីការអស្ចារ្យទាំងប៉ុន្មានដែលគេបានឃើញ។ គេពោលថា៖ «សូមព្រះជាម្ចាស់ប្រទានពរដល់ព្រះមហាក្សត្រដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់! សូមសន្តិភាពកើតពីស្ថានបរមសុខមក សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត!»។ មានអ្នកខាងគណៈផារីស៊ីខ្លះ ដែលនៅក្នុងចំណោមបណ្ដាជនទូលព្រះយេស៊ូថា៖ «លោកគ្រូសូមឃាត់សិស្សរបស់លោកឲ្យនៅស្ងៀមផង!»។ ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នា ដឹងថា ប្រសិនបើអ្នកទាំងនេះនៅស្ងៀម ដុំថ្មមុខជាស្រែកជំនួសគេវិញមិនខាន»។

រួចមានធម្មទេសនាយ៉ាងខ្លី ។ លោកបូជាចារ្យនាំអង្គប្រជុំហែស្លឹកចូលព្រះវិហារ ។

ទំនុកតម្កើង ២៤ (២៣), ៤៧ (៤៦)

# អភិបូជា

AD MISSAM

លោកបូជាចារ្យគោរពតុសក្ការបូជា ហើយពោលថា ៖

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គសព្វព្រះហឫទ័យរងទុក្ខលំបាក និងសោយទិវង្គតយ៉ាងសែនអាម៉ាស់ ដើម្បីសង្គ្រោះមនុស្សលោកឲ្យរួចពីបាប ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យយល់ពីគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ
ហើយសូមប្រោសឲ្យយើងខ្ញុំសុខចិត្តធ្វើតាមព្រះយេស៊ូជានិច្ចផង ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
នៅពេលព្រះបុត្រាព្រះអង្គរងទុក្ខលំបាក និងសោយទិវង្គត
ព្រះអង្គសម្ដែងសេចក្ដីស្រឡាញ់ចំពោះព្រះបិតាក្នុងនាមយើងខ្ញុំទាំងអស់គ្នា ។
សូមព្រះអង្គទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះយេស៊ូគ្រីស្តដែលមានព្រះជន្មគង់នៅ និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ ។

ធម៌ប្រារព្ធ ៖ លើកតម្កើងព្រះអម្ចាស់រងទុក្ខលំបាក

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ដោយសារព្រះបុត្រារងទុក្ខលំបាក ដើម្បីប្រទានការសង្គ្រោះដល់ពិភពលោកទាំងមូល
ទ្រង់ប្រកាសអំពីឫទ្ធានុភាពរបស់ព្រះអង្គ ។
អំណាចដ៏អស្ចារ្យនៃឈើឆ្កាង
សម្ដែងការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ចំពោះមនុស្សលោក
និងសម្ដែងឫទ្ធានុភាពរបស់ព្រះគ្រីស្ត ដែលជាប់នៅលើឈើឆ្កាង ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ សូមអរព្រះគុណព្រះអង្គ
ដោយប្រកាសទាំងអំណរសប្បាយក្រៃលែងថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !

ពាក្យអរព្រះគុណ
ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
ព្រះបុត្រាព្រះអង្គបានបូជាព្រះជន្ម
ដោយសម្ដែងសេចក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅចំពោះមនុស្សលោក យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿ និងសេចក្ដីស្រឡាញ់របស់យើងខ្ញុំ
ឲ្យសុខចិត្តបូជាជីវិតរួមជាមួយព្រះយេស៊ូ
ដោយមានសង្ឃឹមថា នឹងទទួលសិរីរុងរឿងរួមជាមួយព្រះអង្គ ។

# ថ្ងៃចន្ទ ក្នុងសប្ដាហ៍ពិសិដ្ឋ

FERIA II HEBDOMADÆ SANCTÆ

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំនាំគ្នារំឭកដល់ព្រះយេស៊ូជាព្រះបុត្រាព្រះអង្គ
រងទុក្ខលំបាកដើម្បីសង្គ្រោះមនុស្សលោក ។ សូមព្រះអង្គមេត្តាលើកលែងទោសឲ្យយើងខ្ញុំ
ដែលជាមនុស្សទន់ខ្សោយ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យព្រះបុត្រាបូជាព្រះជន្ម
ដើម្បីរំដោះមនុស្សលោកឲ្យរួចពីបាប ។
សូមព្រះអង្គទទួលតង្វាយរួមជាមួយសក្ការបូជានេះ ហើយប្រោសឲ្យយើងខ្ញុំបានរួមរស់ជាមួយព្រះគ្រីស្ត
និងបង្កើតផលដែលនៅស្ថិតស្ថេរជានិច្ច ។

ធម៌ប្រារព្ធទី ២ លើកតម្កើងព្រះអម្ចាស់រងទុក្ខលំបាក ទំព័រ ៤៣៨ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
នៅក្នុងអភិបូជានេះ ព្រះអង្គប្រទានព្រះកាយ
និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំបានវិសុទ្ធ ។
សូមព្រះអង្គមេត្តាគង់នៅជាមួយប្រជារាស្ត្ររបស់ព្រះអង្គ
ហើយប្រោសឲ្យយើងខ្ញុំរស់នៅក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គជាដរាប ។

# ថ្ងៃអង្គារ ក្នុងសប្ដាហ៍ពិសិដ្ឋ

FERIA III HEBDOMADÆ SANCTÆ

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ
ហើយមានព្រះជន្មគង់នៅអស់កល្បជានិច្ច !
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យយល់អត្ថន័យដ៏ជ្រៅបំផុតនៃទុក្ខលំបាករបស់ព្រះយេស៊ូ ។
សូមប្រោសឲ្យយើងខ្ញុំសុខចិត្តរួមស្លាប់រួមរស់ជាមួយព្រះគ្រីស្ដជានិច្ច ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់យើងខ្ញុំអើយ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យមហាគ្រួសារព្រះអង្គ រួមគ្នាថ្វាយសក្ការបូជានេះ
សូមព្រះអង្គមេត្តាទទួលដោយអនុគ្រោះ ។
យើងខ្ញុំចូលរួមជាមួយព្រះគ្រីស្ដដែលបូជាព្រះជន្មយ៉ាងណា
សូមប្រោសឲ្យយើងខ្ញុំរួមរស់ជាមួយព្រះគ្រីស្ដនៅស្ថានបរមសុខយ៉ាងនោះដែរ ។

ធម៌ប្រារព្ធទី ២ លើកតម្កើងព្រះអម្ចាស់រងទុក្ខលំបាក ទំព័រ ៤៣៨ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គ
ដែលប្រទានអគ្គសញ្ញានៃការសង្គ្រោះឲ្យយើងខ្ញុំទុកជាអាហារផ្ដល់ជីវិត ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ
បានចូលរួមក្នុងជីវិតអស់កល្បជានិច្ចរបស់ព្រះអង្គ ។

# ថ្ងៃពុធ ក្នុងសប្ដាហ៍ពិសិដ្ឋ

FERIA IV HEBDOMADÆ SANCTÆ

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់អើយ !
ព្រះបុត្រាសព្វព្រះហឫទ័យសោយទិវង្គតនៅលើឈើឆ្កាង
ដើម្បីរំដោះយើងខ្ញុំឲ្យរួចពីអំណាចរបស់មារ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបានចូលរួមក្នុងសិរីរុងរឿងរបស់ព្រះគ្រីស្ត
ដែលមានព្រះជន្មរស់ឡើងវិញ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
ព្រះបុត្រាសព្វព្រះហឫទ័យរងទុក្ខលំបាក និងសោយទិវង្គត
ដើម្បីប្រទានជីវិតអស់កល្បជានិច្ចឲ្យយើងខ្ញុំ ។
យើងខ្ញុំសូមថ្វាយកាយ វាចា ចិត្តរួមជាមួយសក្ការបូជារបស់ព្រះគ្រីស្ត
ដែលជាគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាទទួលតង្វាយទាំងនេះដោយអនុគ្រោះ ។

ធម៌ប្រារព្ធទី ២ លើកតម្កើងព្រះអម្ចាស់រងទុក្ខលំបាក ទំព័រ ៤៣៨ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះយេស៊ូបូជាព្រះជន្មផ្ទាល់របស់ព្រះអង្គដើម្បីសង្គ្រោះយើងខ្ញុំ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំមានជំនឿមាំមួនលើព្រះបុត្រា
និងសុខចិត្តរួមស្លាប់រួមរស់ជាមួយព្រះអង្គ
ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

# ថ្ងៃព្រហស្បតិ៍ ក្នុងសប្តាហ៍ពិសិដ្ឋ

FERIA V HEBDOMADÆ SANCTÆ

មានពិធីប្រសិទ្ធពរលើប្រេង និងពិធីជប់លៀងសាវ័ក ។ ក្នុងសប្តាហ៍ពិសិដ្ឋ លោកអភិបាលព្រះសហគមន៍តែងតែធ្វើពិធីប្រសិទ្ធពរលើប្រេងសម្រាប់ពិធីបុណ្យនានាក្នុងរយៈពេលមួយឆ្នាំ ។ សហគមន៍គ្រីស្តបរិស័ទបានយកប្រេងនេះ ទុកជានិមិត្តរូបនៃព្រះវិញ្ញាណដែលជាព្រះអំណោយទានពិសេសរបស់ព្រះជាម្ចាស់ គឺព្រះអង្គជ្រាបចូលក្នុងចិត្តគំនិត ព្រមទាំងប្រទានកម្លាំង និងអំណរសប្បាយដល់អស់អ្នកជឿ ។ នៅក្នុងពិធីជប់លៀងសាវ័ក ព្រះយេស៊ូយកនំប៉័ង និងស្រាមកបែងចែកឲ្យសាវ័កបរិភោគ ទុកជាសញ្ញាសម្គាល់បញ្ជាក់ថា ព្រះអង្គសព្វព្រះហឫទ័យបូជាព្រះជន្មផ្ទាល់របស់ព្រះអង្គ ដោយគ្មាននរណាបង្ខំ ។ ព្រះយេស៊ូមានធម៌មេត្តាករុណាហួសពីការស្មានរបស់មនុស្ស ។

១. តាមប្រពៃណីព្រះសហគមន៍ពីបុរាណនៅថ្ងៃនេះ មិនអនុញ្ញាតឲ្យលោកបូជាចារ្យថ្វាយអភិបូជាដោយគ្មានគ្រីស្តបរិស័ទចូលរួម ។

# អភិបូជាប្រសិទ្ធពរលើប្រេង

**Ad Missam chrismatis**

២. ថ្ងៃព្រហស្បតិ៍ពិសិដ្ឋពេលព្រឹក លោកអភិបាលព្រះសហគមន៍រួមជាមួយអស់លោកបូជាចារ្យប្រសិទ្ធពរលើប្រេងទាំងបីក្នុងអភិបូជានេះ ។

៣. គេអាចជ្រើសរើសថ្ងៃណាមួយជៀងជិតបុណ្យចម្លង ដើម្បីសម្រួលដល់អស់លោកបូជាចារ្យអាចមកចូលរួមបាន ។

៤. អភិបូជានេះ បង្ហាញអំពីការរួបរួមគ្នាជាធ្លុងតែមួយរវាងលោកអភិបាលព្រះសហគមន៍ និងអស់លោកបូជាចារ្យ ។

៥. តាមប្រពៃណីព្រះសហគមន៍ ពេលប្រសិទ្ធពរលើព្រះកាយរួចហើយ លោកអភិបាលព្រះសហគមន៍ប្រសិទ្ធពរលើប្រេងសម្រាប់លាបឲ្យអ្នកជំងឺ ។ ពេលចែកព្រះកាយរួចហើយ លោកប្រសិទ្ធពរលើប្រេងគ្រីស្មា និងប្រេងសម្រាប់លាបឲ្យអ្នករៀបចំខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក ។ ប៉ុន្តែតាមសេចក្តីត្រូវការរបស់ព្រះសហគមន៍ លោកអភិបាលអាចប្រសិទ្ធពរ លើប្រេងទាំងបីបន្ទាប់ពី ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់ ។

៦. អភិបូជានេះ សូមសូត្រ ឬច្រៀងធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ។

៧. ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាម្ចាស់អើយ !
ព្រះអង្គបានអភិសេកព្រះបុត្រាដោយព្រះវិញ្ញាណរបស់ព្រះអង្គ
ហើយតែងតាំងជាព្រះគ្រីស្ត និងជាព្រះអម្ចាស់ ។
ព្រះអង្គក៏បានអភិសេកយើងខ្ញុំក្នុងអង្គព្រះគ្រីស្តដែរ
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំចេះផ្តល់សក្ខីភាពនៃការសង្គ្រោះ
ក្នុងពិភពលោកសព្វថ្ងៃនេះផង ។

៨. បន្ទាប់ពីអានអត្ថបទគម្ពីរដំណឹងល្អ លោកអភិបាលធ្វើធម្មទេសនា យោងតាមអត្ថបទគម្ពីរដែលទើបនឹងអាន ។ លោកមានប្រសាសន៍ទៅកាន់អង្គប្រជុំ និងក្រុមបូជាចារ្យរំឭកអំពីពិធីតែងតាំងជាបូជាចារ្យ ។ លោកអភិបាលដាស់តឿនបូជាចារ្យឲ្យបំពេញបេសកកម្មដោយមានចិត្តជឿជាក់ ហើយលោកអញ្ជើញពួកគេឲ្យប្រកាសពាក្យសច្ចាឡើងវិញនៅមុខអង្គប្រជុំ ។

# ពិធីប្រកាសពាក្យសច្ចាសាជាថ្មីរបស់អស់លោកបូជាចារ្យ

Renovatio promissionum sacerdotalium

៩. លោកអភិបាលអញ្ជើញលោកបូជាចារ្យទាំងអស់ ប្រកាសពាក្យសច្ចារបស់ខ្លួនឡើងវិញ ។

បងប្អូនជាទីស្រឡាញ់ !
នៅថ្ងៃដែលយើងខ្ញុំនឹករឭកដល់ព្រះយេស៊ូត្រាស់ហៅពួកសាវ័ក និងត្រាស់ហៅយើងខ្ញុំម្នាក់ៗឲ្យចូលរួមជាមួយព្រះអង្គជាមហាបូជាចារ្យ តើបងប្អូនចង់ប្រកាសពាក្យសច្ចាប្រណិធានរបស់ខ្លួនសាជាថ្មី
នៅចំពោះមុខលោកអភិបាល និងចំពោះមុខប្រជារាស្ត្រព្រះជាម្ចាស់ ឬទេ?

លោកបូជាចារ្យឆ្លើយ ៖ បាទ ! ខ្ញុំចង់

នៅថ្ងៃដែលបងប្អូនតែងតាំងជាបូជាចារ្យដើម្បីបម្រើព្រះសហគមន៍ បងប្អូនបានទទួលមុខដំណែងមួយដ៏សំខាន់ពីព្រះជាម្ចាស់ ។ តើបងប្អូនចង់រួមស្លាប់រួមរស់ជាមួយព្រះយេស៊ូ ជាព្រះអម្ចាស់ឲ្យអស់ពីចិត្ត
ដោយលះបង់ប្រយោជន៍ផ្ទាល់ខ្លួន និងប្រកាន់យ៉ាងស្មោះត្រង់តាមពាក្យសច្ចា
ព្រមទាំងបំពេញបេសកកម្មរបស់បងប្អូនក្នុងព្រះសហគមន៍ ឬទេ?

លោកបូជាចារ្យឆ្លើយ ៖ បាទ ! ខ្ញុំចង់

យើងបម្រើគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ តាមរយៈព្រះបន្ទូលព្រះអង្គ ដោយថ្វាយអភិបូជា និងធ្វើពិធីបុណ្យផ្សេងៗ ។ តើបងប្អូនចង់បំពេញកិច្ចការរបស់ព្រះជាម្ចាស់តាមព្រះគ្រីស្តជាគង្វាលដ៏ប្រពៃ ឬទេ?

លោកបូជាចារ្យឆ្លើយ ៖ បាទ! ខ្ញុំចង់

លោកអភិបាលពោលមកកាន់គ្រីស្តបរិស័ទ

សូមបងប្អូនជាគ្រីស្តបរិស័ទជួយអង្វរព្រះជាម្ចាស់ ដើម្បីផ្តល់ជាប្រយោជន៍ដល់អស់លោកបូជាចារ្យ ។ សូមអង្វរព្រះអង្គចាក់បង្ហូរព្រះអំណោយទានលើលោកយ៉ាង បរិបូណ៌ ដើម្បីជួយអស់លោកឲ្យចេះបម្រើព្រះជាអម្ចាស់ដោយស្មោះត្រង់ និងណែនាំបងប្អូនទៅដល់ប្រភពនៃការសង្គ្រោះ ។

អង្គប្រជុំឆ្លើយ ៖ សូមព្រះអង្គមេត្តាប្រោសស្តាប់យើងខ្ញុំ ។

សូមបងប្អូនអង្វរព្រះជាម្ចាស់សម្រាប់ខ្ញុំ និងអស់លោកអភិបាល ។
ទោះបីយើងខ្ញុំមិនសមទទួលបន្ទុកនេះក៏ដោយ តែសូមព្រះជាម្ចាស់ជួយឲ្យយើងខ្ញុំចេះបំពេញមុខងារនេះដោយស្ម័គ្រចិត្ត និងមានភក្តីភាពក្នុងនាមព្រះគ្រីស្តជាមហាបូជាចារ្យ
ជាគង្វាលដ៏សប្បុរស ជាបរមគ្រូ និងជាអ្នកបម្រើមនុស្សទាំងឡាយ ។

អង្គប្រជុំឆ្លើយ ៖ សូមព្រះអង្គមេត្តាប្រោសស្តាប់យើងខ្ញុំ ។

សូមព្រះជាម្ចាស់ប្រមូល និងថែរក្សាយើងខ្ញុំក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ ។
សូមព្រះអង្គណែនាំទាំងលោកបូជាចារ្យ ទាំងប្រជារាស្ត្ររបស់ព្រះអង្គ
ឲ្យមានជីវិតអស់កល្បជានិច្ច ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

# ពិធីប្រសិទ្ធពរលើប្រេង[១៨០]

អ្នកពោល៖ ក្នុងសប្តាហ៍ពិសិដ្ឋ លោកអភិបាលព្រះសហគមន៍តែងធ្វើពិធីប្រសិទ្ធពរលើប្រេងសម្រាប់ពិធីបុណ្យនានាក្នុងរយៈពេលមួយឆ្នាំ ។ សហគមន៍គ្រីស្តបរិស័ទបានយកប្រេងទុកជានិមិត្តរូបនៃព្រះវិញ្ញាណដែលជាព្រះអំណោយទានពិសេសរបស់ព្រះជាម្ចាស់ គឺព្រះអង្គជ្រាបចូលក្នុងចិត្តគំនិត ព្រមទាំងប្រទានកម្លាំង និងអំណរសប្បាយដល់អស់អ្នកជឿ ។

**ប្រេងពិសិដ្ឋមាន ៣ យ៉ាង ៖**

១-ប្រេងអ្នកជំងឺ ជាប្រេងសម្រាប់លាបឲ្យអ្នកជំងឺ (oleum infirmorum : OI) ។

២-ប្រេងអ្នកស្វែងយល់ ជាប្រេងសម្រាប់លាបឲ្យអ្នកដែលកំពុងរៀបចំខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក (oleum sanctum : OS) ។

៣-ប្រេងគ្រីស្មា ជាប្រេងសម្រាប់លាបឲ្យអ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹក និងទទួលអគ្គសញ្ញាលាបថ្ងាស ព្រមទាំងសម្រាប់លាបឲ្យលោកបូជាចារ្យដែលលោកអភិបាលទើបនឹងតែងតាំងឡើង (sanctum chrisma : SC) ។

## ប្រសិទ្ធពរលើប្រេងអ្នកជំងឺ

ឱ ព្រះបិតាជាអម្ចាស់យើងខ្ញុំអើយ !
មានតែព្រះអង្គទេ ដែលលើកទឹកចិត្តមនុស្សនៅពេលកើតទុក្ខព្រួយ
ដោយព្រះអង្គសព្វព្រះហឫទ័យចាត់ព្រះបុត្រា
ឲ្យយាងមកព្យាបាលជំងឺរោគារបស់យើងខ្ញុំ ។
សូមព្រះអង្គមេត្តាព្រះសណ្តាប់ពាក្យអង្វររបស់យើងខ្ញុំ ដែលទូលទៅព្រះអង្គដោយជំនឿ ។
សូមចាត់ព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះដ៏ជួយការពារមកប្រសិទ្ធពរលើប្រេង
ដែលព្រះអង្គបានបង្កើតសម្រាប់ប្រោសឲ្យរាងកាយយើងខ្ញុំមាំមួន ។
ដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ប្រេងនេះបានទៅជាឱសថពិសិដ្ឋ
ដើម្បីសម្រាលការឈឺចាប់ទាំងកាយ ទាំងវិញ្ញាណរបស់បងប្អូន
ដែលទទួលអគ្គសញ្ញាលាបប្រេងផ្តល់កម្លាំង ។

[១៨០] ពិធីនេះ ស្រង់ពីសៀវភៅក្បួនពិធីរបស់លោកអភិបាល ។

សូមព្រះអង្គប្រោសឲ្យបងប្អូនទាំងនោះ បានរួចផុតពីជំងឺ និងពីបាបនានា ។
សូមព្រះអង្គមេត្តាសព្វព្រះហឫទ័យឲ្យប្រេងនេះ
បានទៅជាឧបករណ៍សម្រាប់ព្រះអង្គប្រើប្រាស់
ដើម្បីប្រទានព្រះអំណោយទានផ្សេងៗឲ្យយើងខ្ញុំ
ក្នុងព្រះនាមព្រះយេស៊ូគ្រីស្ដជាព្រះអម្ចាស់យើងខ្ញុំ
ដែលសោយរាជ្យរួមជាមួយព្រះអង្គ អស់កល្បជាអង្វែងតរៀងទៅ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

## ប្រសិទ្ធពរលើប្រេងអ្នកស្វែងយល់

បពិត្រព្រះជាអម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គតែងតែថែរក្សាប្រជារាស្ត្ររបស់ព្រះអង្គជានិច្ច
និងប្រោសប្រទានឲ្យគេមានកម្លាំងពលំ ។
ព្រះអង្គបានបង្កើតប្រេងជានិមិត្តរូបនៃភាពអង់អាចក្លាហាន សូមព្រះអង្គមេត្តាចាត់ព្រះវិញ្ញាណដ៏វិសុទ្ធមកប្រសិទ្ធពរលើប្រេងនេះ
ឲ្យបានពិសិដ្ឋសម្រាប់លាបលើបងប្អូនយើងខ្ញុំ
ដែលស្ម័គ្រចិត្តដើរតាមព្រះយេស៊ូគ្រីស្ដជាព្រះអម្ចាស់ ។
សូមព្រះអង្គប្រទានឲ្យបងប្អូនមានប្រាជ្ញាឈ្លាសវៃ មានកម្លាំងអង់អាចក្លាហាន
និងប្រោសឲ្យពួកគេយល់កាន់តែច្បាស់ពីព្រះបន្ទូលដំណឹងល្អរបស់ព្រះអង្គ ព្រមទាំងឲ្យពួកគេមានកម្លាំងប្រឆាំងនឹងអំពើអាក្រក់នានា
ដែលជាឧបសគ្គក្នុងជីវិតជាគ្រីស្ដបរិស័ទ ។
សូមព្រះអង្គមេត្តាប្រោសឲ្យពួកគេបានសក្តិសមជាបុត្រធីតារបស់ព្រះអង្គ
និងមានអំណរសប្បាយដែលបានកើតជាថ្មី ដោយរស់នៅរួបរួមគ្នាក្នុងព្រះសហគមន៍របស់ព្រះអង្គ ។
យើងខ្ញុំសូមអង្វរព្រះអង្គដោយរួមជាមួយព្រះយេស៊ូគ្រីស្ដ និងជាព្រះអម្ចាស់ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

# ប្រសិទ្ធពរលើប្រេងគ្រីស្មា

ជាប្រេងសម្រាប់លាបឲ្យអ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹក និងទទួលអគ្គសញ្ញាលាបថ្ងាស ព្រម ទាំងសម្រាប់លាបលើដៃរបស់លោកបូជាចារ្យ ដែលលោកអភិបាលទើបនឹងតែងតាំងឡើង ។

លោកអភិបាលផ្លុំលើដបប្រេងគ្រីស្មា ៖

ឱ ព្រះជាម្ចាស់ដ៏មានធម៌មេត្តាករុណាអើយ !
ព្រះអង្គតែងតាំងអគ្គសញ្ញានានាដើម្បីផ្តល់ជីវិតឲ្យយើងខ្ញុំ ។
យើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដែលមានព្រះហឫទ័យមេត្តាករុណាដ៏លើសលប់ ។
ក្នុងសម្ពន្ធមេត្រីចាស់ ព្រះអង្គសម្តែងឲ្យឃើញច្បាស់នូវឫទ្ធិបារមីនៃប្រេងពិសិដ្ឋ ។
នៅពេលកំណត់មកដល់ ព្រះយេស៊ូទទួលពិធីជ្រមុជទឹកនៅទន្លេយ័រដាន់
ព្រះអង្គបានបញ្ជូនព្រះវិញ្ញាណដ៏ត្រចះត្រចង់ក្នុងអង្គព្រះគ្រីស្ត ហើយប្រកាសថា
ព្រះយេស៊ូជាព្រះបុត្រាដ៏ជាទីស្រឡាញ់តែមួយគត់របស់ព្រះអង្គ ។
ព្រះអង្គសម្តែងឲ្យយើងខ្ញុំដឹងថា ទ្រង់ចាត់ព្រះយេស៊ូជាអ្នកស្រុកណាសារ៉ែត
ឲ្យមកប្រកាសដំណឹងល្អដល់អ្នកក្រីក្រ ។
ព្រះយេស៊ូជាមហាបូជាចារ្យដែលរំដោះបាបមនុស្សលោក ដោយព្រះលោហិតព្រះ
អង្គផ្ទាល់
ព្រះយេស៊ូជាគង្វាលដ៏សប្បុរសដឹកនាំហ្វូងចៀមឆ្ពោះទៅកាន់ប្រភពនៃជីវិត ។

អាស្រ័យហេតុនេះហើយ ព្រះយេស៊ូជាព្រះបុត្រាព្រះអង្គ
និងជាព្រះអម្ចាស់យើងខ្ញុំបានសង្គ្រោះមនុស្សលោក ។
ក្នុងព្រឹត្តិការណ៍នៃបុណ្យចម្លង ព្រះអង្គប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ
និងព្រះអំណោយទានយ៉ាងបរិបូណ៌ដល់ព្រះសហគមន៍របស់ព្រះអង្គ ដើម្បីបំពេញ
បេសកកម្មនៃការសង្គ្រោះក្នុងពិភពលោកនេះ ។
ដោយសារឫទ្ធានុភាពនៃប្រេងពិសិដ្ឋនេះ ព្រះអង្គប្រោសឲ្យមនុស្សលោក
បានប្រកបដោយព្រះពរយ៉ាងបរិបូណ៌ ។

យើងខ្ញុំដែលជាបុត្រធីតារបស់ព្រះអង្គបានកើតជាថ្មី
ដោយទឹកនៃអគ្គសញ្ញាជ្រមុជទឹក និងទទួលព្រះវិញ្ញាណដ៏វិសុទ្ធ
ដែលប្រោសឲ្យយើងខ្ញុំមានលក្ខណៈប្រសើរ
ហើយអនុវត្តតាមព្រះយេស៊ូគ្រីស្ត
ជាព្រះបុត្រាព្រះអង្គដោយចូលរួមក្នុងបេសកកម្មជាព្យាការី
ជាបូជាចារ្យ និងជាព្រះមហាក្សត្រ ។

លោកអភិបាលអញ្ជើញអស់លោកបូជាចារ្យ ឲ្យទ្រាប់ដៃលើដបប្រេង ។
បពិត្រព្រះបិតាជាអម្ចាស់ !
ដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ
យើងខ្ញុំសូមអង្វរព្រះអង្គមេត្តាប្រោសឲ្យប្រេង
ដែលលាយចូលគ្នានឹងគ្រឿងក្រអូបនេះ បានទៅជាអគ្គសញ្ញា
បង្ហាញពីព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ ។

សូមព្រះអង្គប្រោសឲ្យអស់បងប្អូនដែលទទួលប្រេងនេះ
បានពោរពេញដោយព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធ
ដើម្បីឲ្យជីវិតរស់នៅរបស់ពួកគេបានប្រកបដោយសេចក្ដីសុខសាន្ត
និងបង្ហាញពីភាពដ៏វិសុទ្ធរបស់ព្រះអង្គ ។
សូមប្រោសឲ្យព្រះសហគមន៍របស់ព្រះអង្គរីកចម្រើនឡើង
ក្នុងពន្លឺរបស់ព្រះអង្គរហូតតរៀងទៅ ។

យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្ត
ជាព្រះបុត្រាព្រះអង្គ និងជាព្រះអម្ចាស់យើងខ្ញុំ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

១០. អត់មានសូត្រធម៌ប្រកាសជំនឿ ។

### ១១. ពាក្យថ្វាយតង្វាយ

ឱ ព្រះបិតាជាអម្ចាស់យើងខ្ញុំអើយ !
ដោយឫទ្ធានុភាពនៃសក្ការបូជារបស់ព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ
បានបូជាព្រះជន្មផ្ទាល់ ដើម្បីលុបបំបាត់សេចក្តីអាក្រក់គ្រប់យ៉ាង
ព្រមទាំងប្រទានជីវិតថ្មី និងផ្តល់ការសង្គ្រោះឲ្យយើងខ្ញុំ
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំចូលរួមក្នុងសក្ការបូជារបស់ព្រះយេស៊ូ
ជាព្រះបុត្រាព្រះអង្គ និងជាអម្ចាស់យើងខ្ញុំ ។

### ១២. ធម៌ប្រារព្ធ

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ ហើយមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

យើងខ្ញុំសូមលើកតម្កើងព្រះអង្គ ដែលបានចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធ
មកអភិសេកព្រះបុត្រា តែងតាំងជាមហាបូជាចារ្យតែមួយនៃសម្ពន្ធមេត្រីថ្មី
ដែលគង់នៅស្ថិតស្ថេរអស់កល្បជានិច្ច ។

ព្រះអង្គសព្វព្រះហឫទ័យឲ្យមានបូជាចារ្យនៅក្នុងព្រះសហគមន៍
ដើម្បីបន្តមុខងាររបស់ព្រះបុត្រាជាមហាបូជាចារ្យតែមួយ ។
ព្រះគ្រីស្តប្រទានឲ្យប្រជារាស្ត្រទាំងអស់ដែលព្រះអង្គបានរំដោះ មានកិត្តិយសជាបូជាចារ្យរួមគ្នាគ្រងរាជ្យលើពិភពលោកទាំងមូល ។
ព្រះគ្រីស្តជារៀមច្បង ព្រះអង្គស្រឡាញ់បងប្អូន ហើយបានជ្រើសរើសអស់លោកបូជាចារ្យឲ្យរួមចំណែកក្នុងមុខងាររបស់ព្រះអង្គដោយពិធីទ្រាប់ដៃ ។

ក្នុងនាមព្រះគ្រីស្ត អស់លោកបូជាចារ្យថ្វាយសក្ការបូជាតែមួយ
ដែលសង្គ្រោះមនុស្សលោកក្នុងពិធីជប់លៀងបុណ្យចម្លង ។ អស់លោកបូជាចារ្យត្រូវតែបម្រើប្រជារាស្ត្រព្រះអង្គ ព្រមទាំងចែកព្រះបន្ទូលរបស់ព្រះអង្គធ្វើជាអាហារ
និងផ្តល់ជីវិតដល់ប្រជារាស្ត្រព្រះអង្គតាមរយៈអគ្គសញ្ញានានា ។
អស់លោកនឹងទៅជាសាក្សីដ៏ពិតប្រាកដអំពីជំនឿ និងអំពីសេចក្តីស្រឡាញ់
ដោយសុខចិត្តបូជាជីវិតថ្វាយព្រះអង្គតាមព្រះគ្រីស្ត
ដើម្បីជាប្រយោជន៍ដល់អស់បងប្អូន ។

អាស្រ័យហេតុនេះ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយប្រកាសថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ លើពិភពលោកទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ
ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

១៣. ពាក្យបន្ទរ ពេលទទួលព្រះកាយ (ទំនុកតម្កើង ៨៩ (៨៨), ២)

ខ្ញុំនឹងច្រៀងសរសើរព្រះហឫទ័យមេត្តាករុណារបស់ព្រះអម្ចាស់រហូតតទៅ ។
ខ្ញុំនឹងប្រកាសអំពីព្រះហឫទ័យស្មោះស្ម័គ្ររបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

១៤. ពាក្យអរព្រះគុណ

បពិត្រព្រះបិតាជាអម្ចាស់ !
យើងខ្ញុំបានទទួលអគ្គសញ្ញាដែលផ្ដល់ជីវិតយ៉ាងបរិបូណ៌ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ
បានពោរពេញដោយក្លិនពិដោរដ៏ក្រអូបរបស់ព្រះគ្រីស្តផង ។

១៥.លោកបូជាចារ្យ អាចធ្វើពិធីទទួលប្រេងពិសិដ្ឋតាមព្រះសហគមន៍នីមួយៗ មុនពេលប្រារព្ធអភិបូជាជប់លៀងចុងក្រោយរបស់ព្រះអម្ចាស់ ឬនៅពេលណាមួយផ្សេងទៀតដែលសមស្រប ។

# ត្រៃទិវានៃបុណ្យចម្លង

SACRUM TRIDUUM PASCHALE

# ថ្ងៃព្រហស្បតិ៍ពិសិដ្ឋ

# ព្រះអម្ចាស់ជប់លៀងសាវ័ក

FERIA V IN CENA DOMINI

# អភិបូជានៅពេលល្ងាច

Ad Missam vespertinam

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាអម្ចាស់ !

នៅយប់នេះ ព្រះបុត្រាសព្វព្រះហឫទ័យបូជាព្រះជន្មព្រះអង្គ
ដើម្បីឲ្យព្រះសហគមន៍បេះរួមគ្នាថ្វាយសក្ការបូជានៃសម្ពន្ធមេត្រី ដែលនៅស្ថិតស្ថេរ
អស់កល្បជានិច្ច និងប្រទានជីវិតថ្មីឲ្យយើងខ្ញុំ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំមានចិត្តស្រឡាញ់ព្រះអង្គ
និងបេះស្រឡាញ់អ្នកដទៃ ដូចព្រះយេស៊ូបានស្រឡាញ់យើងខ្ញុំដែរ ។

## ពិធីលាងជើង

**Loto pedum**

មិនសូត្រធម៌ប្រកាសជំនឿ ។

# ពិធីអរព្រះគុណដ៏វិសុទ្ធ

**Liturgia eucharistica**

១៥. ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់ !

យើងខ្ញុំរួមគ្នាថ្វាយអភិបូជានេះ

ដើម្បីនឹករឭកដល់ព្រះយេស៊ូដែលបានបូជាព្រះជន្មសម្រាប់យើងខ្ញុំ ។

សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ

រួមជាមួយសក្ការបូជារបស់ព្រះបុត្រាដែលជាព្រះសង្គ្រោះ ។

១៦. ធម៌ប្រារព្ធទី ១ បុណ្យព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ទំព័រ ៤៦៨ ។
(ព្រះគ្រីស្តជាអគ្គសញ្ញា និងជាយញ្ញបូជា)

១៨. លោកបូជាចារ្យលាតដៃ ដោយពោលថា ៖

ឱ ព្រះបិតាប្រកបដោយព្រះហឫទ័យសប្បុរសយ៉ាងក្រៃលែងអើយ !

យើងខ្ញុំសូមអង្វរព្រះអង្គតាមរយៈព្រះយេស៊ូគ្រីស្ត

ជាព្រះបុត្រាព្រះអង្គ និងជាអម្ចាស់យើងខ្ញុំ ។

លោកបូជាចារ្យប្រណម្យដៃ ។

សូមព្រះអង្គមេត្តាទទួល

លោកបូជាចារ្យធ្វើសញ្ញាឈើឆ្កាងលើនំ និងស្រាតង្វាយ ទាំងពោលថា ៖

ហើយប្រទានព្រះពរ ≅ លើអំណោយ តង្វាយ និងសក្ការបូជាដ៏វិសុទ្ធនេះ ។

យើងខ្ញុំសូមថ្វាយតង្វាយទាំងនេះ

លោកបូជាចារ្យលាតដៃ ហើយពោលបន្តថា ៖

ជាដំបូង ដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍កាតូលិក ។

សូមព្រះអង្គមេត្តាប្រទានសេចក្តីសុខសាន្ត ដល់ព្រះសហគមន៍នៅលើផែនដីទាំងមូល ។

សូមព្រះអង្គថែរក្សាការពារ ណែនាំ និងបង្រួបបង្រួមព្រះសហគមន៍ជាធ្លុងតែមួយ

រួមជាមួយអ្នកបម្រើរបស់ព្រះអង្គ សម្តេចប៉ាបយើងខ្ញុំ (នាម...)

និងលោក (ឈ្មោះ...) ជាអភិបាលព្រះសហគមន៍យើងខ្ញុំ

ព្រមទាំងអស់លោកអភិបាល ដែលថែរក្សាសេចក្តីពិត

និងជំនឿកាតូលិក ដែលបន្តមកពីក្រុមគ្រីស្តទូត ។

១៩. ធម៌អង្វរសម្រាប់មនុស្សទាំងឡាយ ។

សូមព្រះជាអម្ចាស់ប្រោសប្រណី ដល់អស់អ្នកបម្រើរបស់ព្រះអង្គ (ឈ្មោះ...)

លោកបូជាចារ្យប្រណម្យដៃ ហើយស្ងៀមស្ងាត់បន្តិចដោយនឹកដល់អ្នកនោះ ។ បន្ទាប់មក លោកលាតដៃ ហើយពោលបន្តថា ៖

និងអស់អ្នកដែលរួបរួមគ្នានៅទីនេះ មានតែព្រះអង្គទេដែលជ្រាបថា
បងប្អូនទាំងនេះ មានជំនឿ និងចិត្តភក្ដីយ៉ាងណាចំពោះព្រះអង្គ ។
យើងខ្ញុំសូមថ្វាយអភិបូជានេះ សម្រាប់បងប្អូនទាំងនោះ
ហើយបងប្អូនក៏ថ្វាយអភិបូជាសម្រាប់ខ្លួនគេ និងញាតិមិត្តរបស់គេដែរ ។
បងប្អូនសង្ឃឹមថា ព្រះអង្គរំដោះពួកគេឲ្យរួចពីបាប
ឲ្យមានសុខភាពល្អ និងឲ្យបាកផុតពីអន្តរាយគ្រប់បែបយ៉ាង
ហេតុនេះ គេអាចបំពេញតាមពាក្យសន្យាចំពោះព្រះអង្គ
ជាព្រះជាម្ចាស់ដ៏ពិតប្រាកដ និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

២០. ពាក្យអង្វរបន្ត ៖

យើងខ្ញុំទាំងអស់គ្នា រួមជាមួយព្រះសហគមន៍ទាំងមូល
អបអរសាទរថ្ងៃដ៏វិសុទ្ធបំផុត ជាថ្ងៃដែលព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ
សព្វព្រះហឫទ័យឲ្យគេបញ្ជូនទៅសោយទុក្ខលំបាក ។
យើងខ្ញុំទាំងអស់គ្នាសូមគោរព
ជាបឋម ព្រះនាងព្រហ្មចារិនីម៉ារី ពោរពេញដោយសិរីរុងរឿង
ជាព្រះមាតាព្រះយេស៊ូគ្រីស្តជាព្រះជាម្ចាស់ និងជាព្រះអម្ចាស់យើងខ្ញុំ
បន្ទាប់មក សន្តយ៉ូសែប ជាស្វាមីរបស់ព្រះនាង
គ្រីស្តទូត និងមរណសាក្សី
សន្តសិលា និងសន្តប៉ូល, សន្តអន់ដ្រេ,
(សន្តយ៉ាកុប, សន្តយ៉ូហាន,
សន្តថូម៉ាស, សន្តភីលីព,
សន្តបារថូឡូមេ, សន្តម៉ាថាយ,
សន្តស៊ីម៉ូន និងសន្តយូដា,
សន្តលីណូ, សន្តក្លេ, សន្តក្លេម៉ង់,

សន្តស៊ីក្សទុស, សន្តក័រណើ, សន្តស៊ីព្រីយ៉ាំង,
សន្តឡូរ៉ង, សន្តគ្រីសូហ្គូន,
សន្តយ៉ូហាន និងសន្តប៉ូល,
សន្តកូស្មា និងសន្តដាមីយ៉ាំង) និងសន្តបុគ្គលទាំងឡាយ ។
ដោយពាក្យអង្វររបស់សន្តបុគ្គលទាំងអស់នោះ
សូមព្រះអង្គមេត្តាជួយការពារយើងខ្ញុំគ្រប់ពេលវេលា និងគ្រប់ទិសទី
(ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)

២១. លោកបូជាចារ្យលាតដៃ ដោយពោលបន្តថា ៖
បពិត្រព្រះអម្ចាស់ !
សូមទទួលតង្វាយនេះ ពីគ្រួសារទាំងមូលរបស់ព្រះអង្គ
ដែលកំពុងនឹករឭកថ្ងៃព្រះយេស៊ូគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ
សព្វព្រះហឫទ័យប្រទានអគ្គសញ្ញាព្រះកាយ និងព្រះលោហិត
ដល់សាវ័ករបស់ព្រះអង្គ ទុកសម្រាប់ប្រព្រឹត្តតាម ។
សូមប្រទានសេចក្តីសុខសាន្តរបស់ព្រះអង្គ ដល់យើងខ្ញុំជារៀងរាល់ថ្ងៃ ។
សូមរំដោះយើងខ្ញុំ ឲ្យរួចពីទោសអស់កល្បជានិច្ច
ហើយសូមទទួលយើងខ្ញុំចូលក្នុងចំណោមអស់អ្នក ដែលព្រះអង្គបានជ្រើសរើស ។

លោកបូជាចារ្យលើកដៃប្រណម្យ

(ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)

២២. លោកបូជាចារ្យទ្រាប់ដៃទាំងពីរលើតង្វាយ ទាំងពោលថា ៖
បពិត្រព្រះអម្ចាស់ !
សូមព្រះអង្គមេត្តាទទួល និងប្រទានពរលើតង្វាយនេះ
ឲ្យបានវិសុទ្ធ និងជាទីគាប់ព្រះហឫទ័យព្រះអង្គ ។
សូមប្រោសឲ្យតង្វាយនេះ បានទៅជាព្រះកាយ
និងព្រះលោហិតព្រះអម្ចាស់យេស៊ូគ្រីស្ត
ជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ដើម្បីជាប្រយោជន៍ដល់យើងខ្ញុំ ។

លោកបូជាចារ្យលើកដៃប្រណម្យ

២៣. លោកបូជាចារ្យពោលពាក្យនីមួយៗឲ្យបានច្បាស់ ត្រូវតាមអត្ថន័យនៃព្រះបន្ទូលនេះ ។
នៅថ្ងៃ មុនព្រះយេស៊ូសោយទុក្ខលំបាក

លោកបូជាចារ្យលើកនំប៉័ងឡើងបន្តិចពីតុសក្ការបូជា ដោយពោលបន្តថា ៖
ព្រះអង្គយកនំប៉័ងមកកាន់ក្នុងព្រះហស្តដ៏វិសុទ្ធជាទីគោរព

លោកបូជាចារ្យ ងើបមុខឡើងបន្តិច
ព្រះអង្គងើបព្រះភ័ក្ត្រទតទៅលើមេឃ
ឆ្ពោះទៅកាន់ព្រះជាម្ចាស់
ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ
ព្រះអង្គអរព្រះគុណ និងសរសើរតម្កើង
ហើយកាច់ប្រទានឲ្យក្រុមសាវ័ក ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យ ឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពិសាចុះ**
**នេះជារូបកាយរបស់ខ្ញុំ**
**ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។**

លោកបូជាចារ្យលើកព្រះកាយឡើង បង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់គោរព ។

២៤. លោកបូជាចារ្យពោលបន្ត ៖
នៅពេលចុងក្រោយនៃពិធីជប់លៀង ព្រះអង្គធ្វើតាមរបៀបដដែល

លោកបូជាចារ្យយកពែងមកកាន់ លើកបន្តិចពីតុសក្ការបូជា ដោយពោលបន្ត៖
ព្រះអង្គកាន់ពែងដ៏ប្រសើរនេះ
ក្នុងព្រះហស្តដ៏វិសុទ្ធជាទីគោរព
អរព្រះគុណ និងសរសើរតម្កើងម្តងទៀត
ហើយប្រទានឲ្យក្រុមសាវ័ក ទាំងមានព្រះបន្ទូលថា៖

លោកបូជាចារ្យ ឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ**
**នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ព័នមេត្រីថ្មី**
**និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ**
**ដើម្បីលើកលែងទោសអ្នករាល់គ្នា**
**និងមនុស្សច្រើនឥតគណនាឲ្យរួចពីបាប។**
**សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ។**

លោកបូជាចារ្យលើកពែងព្រះលោហិតឡើងបង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់គោរព ។

២៥. លោកបូជាចារ្យ ច្រៀង ឬពោលថា ៖
នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

អង្គប្រជុំឆ្លើយ ៖ ឱ ព្រះជាអម្ចាស់អើយ !
យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

ឬ
ឱ ព្រះជាអម្ចាស់អើយ !
រៀងរាល់ពេលយើងខ្ញុំពិសានំប៉័ង និងពិសាពីពែងនេះ
យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

ឬ
ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !
ព្រះអង្គសោយទិវង្គតលើឈើឆ្កាង និងមានព្រះជន្មរស់ឡើងវិញ
ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។

២៦. លោកបូជាចារ្យលាតដៃ ដោយពោលបន្ត ៖

បពិត្រព្រះបិតាជាអម្ចាស់ !

យើងខ្ញុំជាអ្នកបម្រើព្រះអង្គ រួមជាមួយប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គ

នាំគ្នានឹករឭកដល់ព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ និងជាព្រះអម្ចាស់យើងខ្ញុំ

គឺព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញពីស្ថានក្រោម

ហើយព្រះអង្គយាងឡើងស្ថានបរមសុខយ៉ាងរុងរឿង ។

ក្នុងចំណោមអ្វីៗដែលព្រះអង្គបានប្រទាន យើងខ្ញុំសូមថ្វាយព្រះអង្គនូវ

សក្ការបូជាដ៏បរិសុទ្ធ

សក្ការបូជាដ៏ពិសិដ្ឋ

សក្ការបូជាដ៏និម្មល ជាព្រះកាយដែលផ្តល់ជីវិតអស់កល្បជានិច្ច

និងព្រះលោហិត ដែលផ្តល់ការសង្គ្រោះជានិរន្តរ៍ ។

២៧. កាលពីដើម ព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយរបស់លោកអាបិល

ជាមនុស្សសុចរិត និងយញ្ញបូជារបស់លោកអប្រាហាំ

ជាបុព្វបុរសយើងខ្ញុំ ព្រមទាំងយញ្ញបូជារបស់ស្តេចមែលគីសេដែក

ជាមហាបូជាចារ្យរបស់ព្រះអង្គយ៉ាងណា

សូមព្រះអង្គមេត្តាទទួលសក្ការបូជានេះ

ទុកជាយញ្ញបូជាដ៏ពិសិដ្ឋ និងជាសក្ការបូជាដ៏និម្មលយ៉ាងនោះផង ។

២៨. លោកបូជាចារ្យឱនកាយបន្តិច ប្រណម្យដៃ ហើយពោលបន្ត ៖

ឱ ព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !

យើងខ្ញុំសូមឱនកាយអង្វរព្រះអង្គ

សូមមេត្តាឲ្យទេវទូតដ៏ពិសិដ្ឋនាំយកសក្ការបូជានេះ

ទៅថ្វាយព្រះអង្គនៅលើតុសក្ការៈឯស្ថានបរមសុខ

នៅចំពោះព្រះភ័ក្ត្រនៃព្រះដ៏ខ្ពង់ខ្ពស់បំផុត ។

សូមឲ្យយើងខ្ញុំដែលទទួលព្រះកាយ

និងព្រះលោហិតដ៏វិសុទ្ធរបស់ព្រះបុត្រាពីតុសក្ការបូជានេះ

លោកបូជាចារ្យឈរឡើង និងគូសសញ្ញាឈើឆ្កាងលើខ្លួន ហើយពោលថា ៖

បានពោរពេញដោយព្រះហឫទ័យប្រណីសន្តោស និងព្រះពរយ៉ាងបរិបូរណ៍ ។

លោកបូជាចារ្យលើកដៃប្រណម្យ

(ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)

២៩. ពាក្យអង្វរសម្រាប់មរណបុគ្គល លោកបូជាចារ្យលាតដៃ ហើយពោលថា ៖

សូមព្រះអម្ចាស់មេត្តានឹកដល់អ្នកបម្រើព្រះអង្គ នាម... និងនាម...
ដែលបានដៅដោយសញ្ញានៃជំនឿ
ពួកគាត់បានលាចាកលោកនេះមុនយើងខ្ញុំ និងកំពុងសម្រាកយ៉ាងសុខសាន្ត ។

លោកបូជាចារ្យប្រណម្យដៃ ហើយអធិដ្ឋានយ៉ាងខ្លីសម្រាប់មរណបុគ្គលទាំងនោះ ។ បន្ទាប់មកលោកលាតដៃ ដោយពោលបន្តថា ៖

សូមព្រះជាអម្ចាស់មេត្តាប្រោសប្រទានបុគ្គលទាំងនោះ
និងអស់អ្នកដែលសម្រាកក្នុងអង្គព្រះគ្រីស្ត
បានត្រជាក់ត្រជុំ ពោរពេញដោយពន្លឺ និងសេចក្តីសុខសាន្ត ។

លោកបូជាចារ្យលើកដៃប្រណម្យ

(ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)

៣០. លោកបូជាចារ្យ គក់ទ្រូង ហើយពោលបន្ត ៖

ទោះបីយើងខ្ញុំជាអ្នកបាបក៏ដោយ ក៏យើងខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គ

លោកបូជាចារ្យលាតដៃ ហើយពោលបន្តថា ៖

ដែលជឿសង្ឃឹមលើព្រះហឫទ័យមេត្តាករុណាដ៏លើសលប់របស់ព្រះអង្គដែរ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ
បានចូលរួមក្នុងសហភាពជាមួយគ្រីស្តទូត និងមរណសាក្សី
ជាមួយសន្តយ៉ូហានបាទីស្ត, សន្តស្ទេផាន
សន្តម៉ាធីយ៉ា, សន្តបារណាបាស
(សន្តអ៊ីញ៉ាស, សន្តអាឡិចសង់
សន្តម៉ាសេឡាំង និងសិលា
សន្តីភេលីស៊ីតា និងពែពេទូអា
សន្តីអាហ្គាត, សន្តីលូស៊ី

សន្តីអាព្រៀស, សន្តីសេស៊ីល
សន្តីអាណាស្តាស៊ី) និងសន្តបុគ្គលទាំងឡាយផង ។
យើងខ្ញុំសូមទទូចអង្វរព្រះអង្គ
សូមឲ្យយើងខ្ញុំបានចូលរួមក្នុងសហភាពរបស់ជនដ៏វិសុទ្ធទាំងនេះ ។
សូមព្រះអង្គកុំរាប់អំពើល្អរបស់យើងខ្ញុំឡើយ
តែសូមលើកលែងទោសឲ្យយើងខ្ញុំវិញ

លោកបូជាចារ្យលើកដៃប្រណម្យ៖
ដោយសារព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។

៣១. លោកបូជាចារ្យពោលបន្ត ៖
គឺដោយសារព្រះគ្រីស្តនេះហើយ
បានជាព្រះអង្គនៅតែបង្កើតអ្វីៗដ៏ល្អទាំងអស់នេះ
ប្រោសឲ្យបានវិសុទ្ធ ឲ្យមានជីវិត និងប្រទានពរ ហើយប្រគល់ឲ្យយើងខ្ញុំ ។

៣២. លោកបូជាចារ្យលើកបានព្រះកាយ និងពែងព្រះលោហិតក្នុងដៃទាំងពីរ ហើយពោលថា ៖
ឱ ព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង បានជាយើងខ្ញុំ
សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ អស់កល្បជាអង្វែងតរៀងទៅ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៥៥៥ ។

ពាក្យអរព្រះគុណ
បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំបានទទួលជីវិតថ្មីពីព្រះអង្គក្នុងពិធីជប់លៀងរបស់ព្រះបុត្រា ។
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យមានអំណរសប្បាយ យ៉ាងស្កប់ស្កល់នៅថ្ងៃណាមួយឯស្ថានបរមសុខ ។

# ថ្ងៃសុក្រពិសិដ្ឋ

FERIA VI IN PASSIONE DOMINI

(ព្រះយេស៊ូសោយទុក្ខលំបាក)

១. តាមប្រពៃណីព្រះសហគមន៍ដើមដំបូង ព្រះសហគមន៍មិនប្រារព្ធអគ្គសញ្ញាផ្សេងៗនៅថ្ងៃនេះ និងថ្ងៃបន្ទាប់ លើកលែងតែអគ្គសញ្ញាលើកលែងទោស និងអគ្គសញ្ញាលាបប្រេងឲ្យអ្នកជំងឺ ។

២. នៅថ្ងៃនេះ គ្រីស្តបរិស័ទអាចទទួលព្រះកាយព្រះគ្រីស្ត តែនៅក្នុងពិធីលើកតម្កើងព្រះយេស៊ូសោយទុក្ខលំបាកប៉ុណ្ណោះ ។ ប៉ុន្តែ អ្នកជំងឺដែលមិនអាចចូលរួមក្នុងពិធីបុណ្យនេះ អាចទទួលព្រះកាយព្រះ គ្រីស្តបាននៅគ្រប់ពេលវេលា ។

៣. សូមរក្សាតុសក្ការបូជាឲ្យនៅទំនេរ ដោយមិនក្រាលក្រណាត់ គ្មានទៀន ឬឈើឆ្កាង ។

# ពិធីលើកតម្កើងព្រះយេស៊ូសោយទុក្ខលំបាក

Celebratio Passionis Domini

៤. នៅថ្ងៃនេះ ព្រះសហគមន៍ប្រារព្ធពិធីលើកតម្កើងព្រះយេស៊ូសោយទុក្ខលំបាកនៅវេលាម៉ោង៣រសៀល (លើកលែងតែមានសេចក្តីត្រូវការពិសេស អាចពន្យាពេលប្រារព្ធពិធីក្រោយម៉ោង៣រសៀលបាន) ដោយចែកពិធីជា៣ភាគ ទីមួយ លើកតម្កើងព្រះបន្ទូលព្រះអង្គ ទីពីរ គោរពព្រះឈើឆ្កាង និងទីបី ទទួលព្រះកាយព្រះគ្រីស្ត ។

៥. បូជាចារ្យ និងលោកឧបដ្ឋាក (ប្រសិនបើមានឧបដ្ឋាក) ពាក់អាវកាស៊ូឡា (អាវធំសម្រាប់អភិបូជា) ពណ៌ក្រហម ទៅកាន់តុសក្ការបូជាដោយស្ងៀមស្ងាត់ ហើយឱនកាយគោរពតុសក្ការបូជា ។ បន្ទាប់មកលោកក្រាបចុះដល់កន្ទេល អធិដ្ឋានស្ងៀមស្ងាត់មួយរយៈ ។ អង្គប្រជុំលុតជង្គង់[181] ។

៦. បន្ទាប់មក លោកបូជាចារ្យ និងអ្នកបម្រើពិធីបុណ្យ ដើរឆ្ពោះទៅកាន់កៅអី ហើយបែរមុខទៅអង្គប្រជុំ ។ អង្គប្រជុំក្រោកឈរឡើង[182] ។ លោកបូជាចារ្យលាតដៃ ហើយពោលពាក្យអធិដ្ឋាន (មិនប្រើពាក្យអញ្ជើញ សូមបងប្អូនតាំងចិត្តអធិដ្ឋាន) ។

[181] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ ស្តីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ អង្គប្រជុំទាំងមូលអង្គុយបត់ជើងលើកដៃប្រណម្យ»នកüaldl;kenÞl ។

[182] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ ស្តីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ អង្គប្រជុំទាំងមូលអង្គុយបត់ជើងលើកenÞl ។

គ្រីស្តបរិស័ទនៅស្ងៀមបន្តិច ស្មឹងស្មាធិ៍ រួចលោកបូជាចារ្យពោលថា ៖
បពិត្រព្រះបិតាដែលស្រឡាញ់មនុស្សលោកហួសពន់ប្រមាណ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យព្រះបុត្រាព្រះអង្គសោយទិវង្គត
ដើម្បីរំដោះមនុស្សលោកឲ្យរួចពីបាប ។
សូមព្រះអង្គបំភ្លឺយើងខ្ញុំឲ្យដើរជាមួយព្រះគ្រីស្ត
ដែលរងទុក្ខលំបាកលើឈើឆ្កាង ហើយប្រោសយើងខ្ញុំឲ្យបានវិសុទ្ធ
ស្របតាមគម្រោងការដ៏អស្ចារ្យនៃបុណ្យចម្លងនេះ ។

អង្គប្រជុំឆ្លើយ៖ អាម៉ែន ។

## ភាគទី មួយ

# ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់

LITURGIA VERBI

៧. អត្ថបទទី១ អេសាយ ៥២,១៣-៥៣,១២ និងទំនុកតម្កើង ៣១ (៣០) ២.៦.១២-១៧.២៥ ។

៨. អត្ថបទទី២ ហេប្រឺ ៤,១៤-១៦,៥,៧-៩ ហើយច្រៀងចម្រៀងអបអរសាទរព្រះគម្ពីរដំណឹងល្អ ។

៩. ព្រះគម្ពីរដំណឹងល្អអំពីទុក្ខលំបាកព្រះយេស៊ូ យ៉ូហាន ១៨,១-១៩,៤២ ។

១០.បន្ទាប់ពីអានព្រះគម្ពីរដំណឹងល្អ លោកបូជាចារ្យទេសនាយ៉ាងខ្លី ។ នៅចុងបញ្ចប់ធម្មទេសនា លោកអញ្ជើញគ្រីស្តបរិស័ទឲ្យអធិដ្ឋានស្ងៀមស្ងាត់មួយរយៈ ។

# ពិធីអង្វរព្រះជាម្ចាស់សម្រាប់សកលលោក

Oratio universalis

១១. ពិធីអបអរសាទរព្រះបន្ទូលព្រះជាម្ចាស់ បន្តដោយមានពាក្យអង្វរសកលយ៉ាងឱឡារិក ។ លោកឧបដ្ឋាក (បើសិនជាមានឧបដ្ឋាក) ឬគ្រីស្តបរិស័ទម្នាក់ឈរនៅកន្លែងបញ្ជូរព្រះគម្ពីរ ហើយច្រៀង ឬសូត្រពាក្យអញ្ជើញឲ្យបូជាចារ្យអង្វរព្រះអង្គ ។ អង្គប្រជុំនៅស្ងៀមស្ងាត់មួយរយៈ លោកបូជាចារ្យឈរនៅអាសនៈ ឬតុសក្ការបូជា ច្រៀង ឬសូត្រពាក្យអធិដ្ឋាន ។ អង្គប្រជុំលុតជង្គង់ ឬឈរ[183] នៅពេលលោកបូជាចារ្យពោលពាក្យអធិដ្ឋាន ។

១២. មុនលោកបូជាចារ្យពោលពាក្យអធិដ្ឋាន លោកឧបដ្ឋាក ឬគ្រីស្តបរិស័ទម្នាក់ អញ្ជើញអង្គប្រជុំដោយពោលថា សូមបងប្អូនក្រោកឈរឡើង ឬលុតជង្គង់[184] ។

១៣. ក្រៅពីពាក្យអង្វរទាំងដប់ លោកអភិបាលព្រះសហគមន៍អាចបន្ថែមពាក្យអធិដ្ឋានតាមសេចក្តីត្រូវការ ។

## ១. ពាក្យអង្វរព្រះជាម្ចាស់សម្រាប់ព្រះសហគមន៍

បងប្អូនជាទីស្រឡាញ់ !

សូមបងប្អូននាំគ្នាអង្វរព្រះជាម្ចាស់ប្រទានពរដល់ព្រះសហគមន៍ និងជួយការពារព្រះសហគមន៍ក្នុងពិភពលោកទាំងមូល ជាពិសេសនៅប្រទេសកម្ពុជាយើង ។ សូមឲ្យព្រះសហគមន៍បានប្រកបដោយសេចក្តីសុខសាន្ត និងសូមឲ្យគ្រីស្តបរិស័ទគ្រប់និកាយបេះរួបរួមគ្នាដោយមានចិត្តថ្លើមតែមួយ ។

សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !

ព្រះអង្គប្រោសឲ្យមនុស្សលោកទាំងអស់ស្គាល់ព្រះអង្គដោយសារព្រះគ្រីស្ត ។

សូមព្រះអង្គប្រោសឲ្យព្រះសហគមន៍ក្នុងពិភពលោកទាំងមូល

ដែលកើតមកពីធម៌មេត្តាករុណារបស់ព្រះអង្គ មានជំនឿតែមួយ ។

---

183 យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ ស្តីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ អង្គប្រជុំទាំងមូលអង្គុយបត់ជើងលើកenÞlelIkédRbNm ។

184 យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ ស្តីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ អង្គប្រជុំទាំងមូលអង្គុយបត់ជើងលើកenÞlelIkédRbNm ។

យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

អង្គប្រជុំឆ្លើយ៖ អាម៉ែន ។

២.ពាក្យអង្វរព្រះជាម្ចាស់សម្រាប់សម្តេចប៉ាប

សូមបងប្អូននាំគ្នាអង្វរព្រះជាម្ចាស់ប្រទានពរដល់សម្តេចប៉ាបយើងខ្ញុំ (នាម)...
ដែលទទួលមុខតំណែងណែនាំព្រះសហគមន៍
សូមឲ្យលោកមានសុខភាពល្អ និងបំពេញមុខងារបានយ៉ាងល្អប្រសើរ ។

សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ
ហើយមានព្រះជន្មគង់នៅអស់កល្បជានិច្ច !
ព្រះអង្គណែនាំព្រឹត្តិការណ៍ទាំងអស់ដែលកើតក្នុងពិភពលោក
តាមព្រះប្រាជ្ញាញាណរបស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាថែរក្សាការពារសម្តេចប៉ាបដែលព្រះអង្គបានជ្រើសរើស
សូមឲ្យលោកមានសុខភាពល្អ និងណែនាំព្រះសហគមន៍ដោយមានជំនឿមាំមួន ។
យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

អង្គប្រជុំឆ្លើយ៖ អាម៉ែន ។

៣.ពាក្យអង្វរព្រះជាម្ចាស់សម្រាប់អស់លោកអភិបាល និងបូជាចារ្យទាំងអស់

សូមបងប្អូននាំគ្នាអង្វរព្រះជាម្ចាស់ ប្រទានពរដល់លោកអភិបាលព្រះសហគមន៍យើងខ្ញុំ (នាម)... ដល់អស់លោកអភិបាល អស់លោកបូជាចារ្យ អស់លោកឧបដ្ឋាក និងអស់បងប្អូនដែលបំពេញមុខងារក្នុងព្រះសហគមន៍ ព្រមទាំងប្រជារាស្ត្រទាំងមូលរបស់ព្រះអង្គ ។

សូមបងប្អូនតាំងចិត្តអធិដ្ឋាន

ឱ ព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការអើយ !
ព្រះវិញ្ញាណដ៏វិសុទ្ធតែងតែបំភ្លឺ និងណែនាំព្រះសហគមន៍ទាំងមូល
ដែលជាព្រះកាយព្រះគ្រីស្ត ។
សូមព្រះអង្គមេត្តាថែរក្សាការពារអស់បងប្អូនយើងខ្ញុំទាំងប៉ុន្មាន

ដែលបំពេញមុខងារពិសេសក្នុងព្រះសហគមន៍ឲ្យយកចិត្តទុកដាក់បម្រើព្រះអង្គ ដោយចិត្តស្មោះ និងប្រព្រឹត្តតាមព្រះអំណោយទានរបស់ព្រះអង្គជានិច្ច ។ យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

អង្គប្រជុំឆ្លើយ៖ អាម៉ែន ។

៤. ពាក្យអង្វរព្រះជាម្ចាស់សម្រាប់អស់អ្នកដែលទទួលការអប់រំខាងជំនឿ

សូមបងប្អូននាំគ្នាអង្វរព្រះជាម្ចាស់ប្រទានពរដល់អស់បងប្អូន ដែលកំពុងទទួលការអប់រំខាងជំនឿ មុននឹងទទួលអគ្គសញ្ញាជ្រមុជទឹក ។ សូមអង្វរព្រះអង្គបំភ្លឺចិត្តគំនិតបងប្អូនទាំងនោះ ហើយទទួលគេក្នុងព្រះកាយព្រះគ្រីស្ត ។

សូមបងប្អូនតាំងចិត្តអធិដ្ឋាន

ឱ ព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការអើយ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យព្រះសហគមន៍ទៅជាប្រភពនៃជីវិត និងបង្កើតបុត្រធីតាព្រះអង្គ ឲ្យមានចំនួនកាន់តែច្រើនឡើងៗជាលំដាប់ ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតបងប្អូនដែលកំពុងស្វែងរកព្រះអង្គ ហើយប្រោសឲ្យបងប្អូនទាំងនោះ មានជំនឿកាន់តែមាំមួន
ដោយប្រោសឲ្យគេមានជីវិតថ្មី និងបានចូលរួមក្នុងចំណោមបុត្រធីតាព្រះអង្គ ។

អង្គប្រជុំឆ្លើយ៖ អាម៉ែន ។

៥. ពាក្យអង្វរព្រះជាម្ចាស់សម្រាប់បងប្អូនដែលជឿសង្ឃឹមលើព្រះគ្រីស្ត

សូមបងប្អូននាំគ្នាអង្វរព្រះជាម្ចាស់ប្រោសឲ្យអស់បងប្អូនដែលជឿសង្ឃឹមលើព្រះយេស៊ូគ្រីស្ត បានចូលរួមក្នុងព្រះសហគមន៍តែមួយ ។

សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ហើយមានព្រះជន្មគង់នៅជានិច្ច !
មានតែព្រះអង្គទេដែលអាចប្រមែប្រមូលបុត្រធីតារបស់ព្រះអង្គ
ដែលបាក់បែកគ្នាឲ្យចូលរួមគ្នាទៅជាគ្រួសារតែមួយបាន ។
សូមព្រះអង្គមេត្តាអាណិតអាសូរដល់ព្រះសហគមន៍

និងប្រោសឲ្យអស់អ្នកដែលបានទទួលអគ្គសញ្ញាជ្រមុជទឹក មានចិត្តស្រឡាញ់គ្នាទៅវិញទៅមក ដោយមានជំនឿតែមួយផង ។
យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ ។
អង្គប្រជុំឆ្លើយ៖ អាម៉ែន ។

៦. ពាក្យអង្វរព្រះជាម្ចាស់សម្រាប់ប្រជាជនអ៊ីស្រាអែល

សូមបងប្អូននាំគ្នាអង្វរព្រះជាម្ចាស់ប្រទានពរដល់ប្រជាជនអ៊ីស្រាអែល ដែលបានទទួលព្រះបន្ទូលព្រះអង្គមុនគេ ។
សូមប្រោសឲ្យប្រជាជននេះ ស្រឡាញ់ព្រះជាម្ចាស់កាន់តែខ្លាំងឡើងៗ ។

សូមបងប្អូនតាំងចិត្តអធិដ្ឋាន

ឱ ព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការអើយ !
កាលពីដើមព្រះអង្គជ្រើសរើសលោកអប្រាហាំ និងពូជពង្សរបស់លោកឲ្យទៅជាប្រជារាស្ត្រផ្ទាល់របស់ព្រះអង្គ ។ សូមព្រះអង្គប្រោសឲ្យប្រជារាស្ត្រនៃសម្ពន្ធមេត្រីនេះ ទទួលការសង្គ្រោះជាស្ថាពរ ។
យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ ។
អង្គប្រជុំឆ្លើយ៖ អាម៉ែន ។

៧. ពាក្យអង្វរព្រះជាម្ចាស់សម្រាប់អស់អ្នកដែលមិនជឿលើព្រះគ្រីស្ត

សូមបងប្អូននាំគ្នាអង្វរព្រះជាម្ចាស់ប្រទានពរដល់មនុស្សដែលមិនជឿលើព្រះគ្រីស្ត ។
សូមព្រះអង្គមេត្តាជួយបង្ហាញផ្លូវឲ្យពួកគេទៅរកការសង្គ្រោះផង ។

សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គបំភ្លឺមនុស្សគ្រប់ៗរូបដែលមិនជឿលើព្រះគ្រីស្ត
ឲ្យស្វែងរកព្រះអង្គដោយចិត្តស្មោះ ដើម្បីឃើញសេចក្តីពិត ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានចិត្តសប្បុរសចំពោះគ្នាទៅវិញទៅមក និងធ្វើជាសាក្សីពីធម៌មេត្តាករុណារបស់ព្រះអង្គ ។

យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

អង្គប្រជុំឆ្លើយ៖ អាម៉ែន ។

៨. ពាក្យអង្វរព្រះជាម្ចាស់សម្រាប់អស់អ្នកដែលមិនជឿលើព្រះណាមួយ

សូមបងប្អូននាំគ្នាអង្វរព្រះជាម្ចាស់ប្រទានពរដល់អស់អ្នក
ដែលមិនជឿលើព្រះណាមួយ
សូមឲ្យពួកគេរកឃើញព្រះជាម្ចាស់ដោយស្តាប់តាមមនសិការរបស់ខ្លួន ។

សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គបានបង្កើតមនុស្សលោកឲ្យគេប្រាថ្នាស្វែងរកព្រះអង្គ
ហើយនៅពេលរកឃើញព្រះអង្គ គេមានសេចក្តីសុខសាន្ត ។
ទោះបី មនុស្សត្រូវជួបឧបសគ្គយ៉ាងណាក៏ដោយ ព្រះអង្គនៅតែប្រោសគេ
ឲ្យចាប់អារម្មណ៍ពីធម៌មេត្តាករុណារបស់ព្រះអង្គជានិច្ច ។

អង្គប្រជុំឆ្លើយ៖ អាម៉ែន ។

៩. ពាក្យអង្វរព្រះជាម្ចាស់សម្រាប់អស់អ្នកដែលដឹកនាំប្រទេស

សូមបងប្អូននាំគ្នាអង្វរព្រះជាម្ចាស់ប្រទានពរដល់អស់លោក
ដែលដឹកនាំប្រទេសនានា និងអស់អ្នកដែលទទួលខុសត្រូវកិច្ចការសាធារណៈ ។
សូមព្រះអង្គបំភ្លឺចិត្តគំនិតរបស់អស់លោកទាំងនោះ
ឲ្យយកចិត្តទុកដាក់ កសាងពិភពលោកប្រកបដោយយុត្តិធម៌ និងសេរីភាព ។

សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គឈ្វេងយល់ចិត្តគំនិតមនុស្សទាំងអស់
និងតែងតែការពារសិទ្ធិសេរីភាពខាងជំនឿរបស់ប្រជារាស្ត្រព្រះអង្គ ។ សូមព្រះអង្គ
មេត្តាប្រោសឲ្យអស់លោកអ្នក ដែលកាន់អំណាចក្នុងប្រទេសនានា
ខិតខំស្វែងរកប្រយោជន៍រួម ខិតខំស្វែងរកសន្តិភាព
និងស្វែងរកសេចក្តីសុខសាន្តនៅលើផែនដីទាំងមូល ។

យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

អង្គប្រជុំឆ្លើយ៖ អាម៉ែន ។

១០. ពាក្យអង្វរព្រះជាម្ចាស់សម្រាប់អស់អ្នកដែលរងទុក្ខវេទនា

សូមបងប្អូននាំគ្នាអង្វរព្រះជាម្ចាស់អាណិតអាសូរដល់អស់អ្នកដែលកើតទុក្ខ សូមកម្ចាត់សេចក្តីអាក្រក់គ្រប់យ៉ាងចេញពីពិភពលោក កុំឲ្យមានទុរ្ភិក្ស កុំឲ្យមានជំងឺរាតត្បាត ។ សូមព្រះអង្គរំដោះមនុស្សជាប់ជាឈ្លើយ មនុស្សជាប់គុកឲ្យមានសេរីភាព និងជួយការពារដល់អ្នកធ្វើដំណើរឲ្យមានសុវត្ថិភាពតាមផ្លូវ ។ សូមប្រោសឲ្យជនភៀសខ្លួន និងជនដែលត្រូវគេនិរទេសបានវិលត្រឡប់ទៅមាតុភូមិវិញ ។ សូមប្រោសឲ្យអ្នកជំងឺបានជាសះស្បើយ និងឲ្យអ្នកដែលជិតផុតដង្ហើមទទួលការសង្គ្រោះ ។

សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ហើយមានព្រះជន្មគង់នៅអស់កល្បជានិច្ច !
ព្រះអង្គតែងតែសម្រាលទុក្ខដល់អស់អ្នកដែលមានអាសន្ន ។
សូមព្រះអង្គអាណិតអាសូរដល់អស់បងប្អូន ដែលកំពុងកើតទុក្ខគ្រប់បែបយ៉ាង
បានរួចផុតពីក្តីវេទនាទាំងនោះ ហើយមានអំណរសប្បាយផង ។

អង្គប្រជុំឆ្លើយ៖ អាម៉ែន ។

### ភាគទី ពីរ

## ពិធីថ្វាយបង្គំព្រះឈើឆ្កាង

ADORATIO SANCTÆ CRUCIS

១៤. បន្ទាប់ពីពាក្យអង្វរសកលយ៉ាងឱឡារិក មានប្រារព្ធពិធីថ្វាយបង្គំព្រះឈើឆ្កាង ។ ឈើឆ្កាងត្រូវបង្ហាញតាមរបៀបពីរ ទីមួយ បូជាចារ្យបង្ហាញឈើឆ្កាងដោយយកក្រណាត់ចេញម្តងមួយៗ ទីពីរ បូជាចារ្យបង្ហាញឈើឆ្កាងដោយមិនប្រើក្រណាត់ ។

# បង្ហាញព្រះឈើឆ្កាង

OSTENSIO SANCTÆ CRUCIS

របៀបទីមួយ

១៥. លោកឧបដ្ឋាក (បើសិនមានលោកឧបដ្ឋាក) ឬអ្នកបម្រើពិធីបុណ្យម្នាក់ទៅបន្ទប់សម្ភារពិធីបុណ្យ យកព្រះឈើឆ្កាងដែលគ្របក្រណាត់ពណ៌ស្វាយ ហែចូលក្នុងព្រះវិហារ ឈរចំកណ្ដាល ហើយអ្នកជំនួយពិធីបុណ្យកាន់ទៀនដែលឆេះដើរអមសងខាងលោក ។ លោកបូជាចារ្យមកឈរនៅមុខអាសនៈទទួលឈើឆ្កាងពីលោកឧបដ្ឋាក ហើយបែរទៅរកអង្គប្រជុំ បង្ហាញព្រះឈើឆ្កាង ហើយទាញក្រណាត់ចេញពីដៃម្ខាង លើកនៅមុខអង្គប្រជុំដោយពោលថា នេះជាឈើដែល... អង្គប្រជុំលុតជង្គង់គោរពឈើឆ្កាងដោយស្ងៀមស្ងាត់ ។ លោកបូជាចារ្យធ្វើរបៀបនេះបីដង ។

នេះជាឈើដែលគេឆ្កាងព្រះយេស៊ូគ្រីស្ត
គេបានធ្វើគុតព្រះសង្គ្រោះមនុស្សលោក នៅលើឈើនេះ ។

អង្គប្រជុំឆ្លើយ៖ យើងខ្ញុំសូមក្រាបថ្វាយបង្គំព្រះឈើឆ្កាង ។

១៦. របៀបទីពីរ មិនប្រើក្រណាត់គ្រប់លើឈើឆ្កាងទេ ។

# ថ្វាយបង្គំព្រះឈើឆ្កាង

ADORATIO SANCTÆ CRUCIS

១៧. ក្រោយមក លោកបូជាចារ្យយកឈើឆ្កាងដាក់ខាងមុខតុសក្ការបូជា ឬកន្លែងមួយដែលត្រឹមត្រូវ ដោយមានទៀនអមសងខាង ។

១៨. ជាបឋម លោកបូជាចារ្យពាក់អាវកាស៊ូឡា (អាវធំសម្រាប់អភិបូជា) លុតជង្គង់ថ្វាយបង្គំព្រះឈើឆ្កាង ។ បន្ទាប់មក អ្នកបម្រើពិធីបុណ្យ និងអង្គប្រជុំមកថ្វាយបង្គំព្រះឈើឆ្កាង ដោយបញ្ចេញកាយវិការផ្សេងៗ មានឱនក្បាល ក្រាបថ្វាយបង្គំ ថើបជាដើមតាមចិត្តចង់ ។

១៩. ត្រូវប្រើឈើឆ្កាងតែមួយគត់ សម្រាប់ពិធីថ្វាយបង្គំព្រះឈើឆ្កាង ។ ក្នុងករណីមានអង្គប្រជុំច្រើនពេក បូជាចារ្យលើកព្រះឈើឆ្កាង និងអញ្ជើញអង្គប្រជុំឲ្យឱនកាយថ្វាយបង្គំព្រះឈើឆ្កាងរួមជាមួយគ្នាដោយស្ងៀមស្ងាត់មួយរយៈ ។

២០. នៅពេលអង្គប្រជុំថ្វាយបង្គំព្រះឈើឆ្កាង មានច្រៀងចម្រៀង យើងខ្ញុំសូមក្រាបថ្វាយបង្គំព្រះឈើឆ្កាង និងបទចម្រៀងផ្សេងៗដែលបង្ហាញពីព្រះហឫទ័យទុក្ខសោករបស់ព្រះអង្គព្រោះតែអ្នកជឿបានឃ្លាតឆ្ងាយពីព្រះអង្គ ឬអាចសូត្របទផ្សេងៗស្ដីអំពីធម៌មេត្តាករុណារបស់ព្រះ ជា

ម្ចាស់ចំពោះមនុស្សលោក ឬម្នាក់អាចអានឃ្លាខ្លះដកស្រង់ពីព្យាការីអេសាយ ៥២-៥៣ ព្រម
ទាំងនីកសញ្ញើងផង ។

២១. បន្ទាប់ពីថ្វាយបង្គំព្រះឈើឆ្កាង លោកឧបដ្ឋាក ឬអ្នកបម្រើពិធីបុណ្យម្នាក់ យកព្រះឈើឆ្កាងដាក់លើតុសក្ការបូជា ដោយមានទៀនឆេះអមសងខាង ។

### ភាគទី បី

## ពិធីទទួលព្រះកាយព្រះគ្រីស្ត

SACRA COMMUNIO

២២. មានក្រណាត់សមួយក្រាលលើតុសក្ការបូជា ដោយមានកន្សែងព្រះកាយនៅចំកណ្ដាល និងសៀវភៅអភិបូជាមានជាស្រាប់ ។ បន្ទាប់មក លោកបូជាចារ្យ យកកន្សែងសជណ្ដប់លើអាវធំសម្រាប់អភិបូជា ដើរឆ្ពោះទៅយកព្រះកាយពីទូព្រះពន្លាមកដាក់លើតុសក្ការបូជា ដោយមានអ្នកជំនួយពិធីបុណ្យកាន់ទៀនអមសងខាង ។

២៣. លោកបូជាចារ្យលើកដៃប្រណមដោយពោលថា ៖

តាមដំបូន្មានរបស់ព្រះយេស៊ូជាព្រះសង្គ្រោះ
និងតាមការប្រៀនប្រដៅរបស់ព្រះអង្គ យើងខ្ញុំហ៊ានទូលថា ៖

លោកបូជាចារ្យលាតដៃ ហើយរួមជាមួយអង្គប្រជុំសូត្របន្តថា ៖

**ឱ ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ !**
**សូមសម្តែងព្រះបារមីឲ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ**
**សូមឲ្យព្រះរាជ្យព្រះអង្គបានមកដល់**
**សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គ បានសម្រេចនៅលើផែនដី**
**ដូចនៅស្ថានបរមសុខដែរ។**
**សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ។**
**សូមអត់ទោសឲ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោសឲ្យអស់អ្នក**
**ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ។**
**សូមកុំបណ្តោយឲ្យយើងខ្ញុំ ចាញ់ការល្បួងឡើយ។**
**តែសូមរំដោះយើងខ្ញុំ ឲ្យរួចពីមារកំណាច។**

២៤ លោកបូជាចារ្យលាតដៃ ហើយពោលម្នាក់ឯងថា ៖
ឱ ព្រះជាអម្ចាស់អើយ !
សូមប្រោសយើងខ្ញុំឲ្យរួចពីសេចក្ដីអាក្រក់គ្រប់យ៉ាង
សូមឲ្យយើងខ្ញុំបានប្រកបដោយសេចក្ដីសុខសាន្តក្នុងពេលរស់នៅសព្វថ្ងៃ ។
ដោយសារធម៌មេត្តាករុណារបស់ព្រះអង្គ
សូមឲ្យយើងខ្ញុំរួចពីបាបជានិច្ច និងផុតពីទុក្ខលំបាកទាំងឡាយ ។
យើងខ្ញុំទន្ទឹងរង់ចាំសុភមង្គលតាមសេចក្ដីសង្ឃឹមរបស់យើង
គឺជាថ្ងៃដែលព្រះយេស៊ូគ្រីស្ដជាព្រះសង្គ្រោះទ្រង់យាងមក ។

អង្គប្រជុំប្រកាសដោយខ្លាំងៗថា ៖
ដ្បិតព្រះអង្គគ្រងរាជ្យ ទ្រង់មានឫទ្ធានុភាព
និងសិរីរុងរឿងអស់កល្បជាអង្វែងតរៀងទៅ ។

២៥. លោកបូជាចារ្យលើកដៃប្រណម្យ ទាំងពោលខ្សឹបៗថា ៖
បពិត្រព្រះអម្ចាស់យេស៊ូគ្រីស្ដ !
សូមឲ្យខ្ញុំដែលទទួលព្រះកាយ និងព្រះលោហិតរបស់ព្រះអង្គ
មិនមានទោស និងមិនទទួលទណ្ឌកម្មឡើយ
ផ្ទុយទៅវិញ តាមព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ
សូមឲ្យព្រះកាយ និងព្រះលោហិតទៅជាឱសថការពារ
និងព្យាបាលវិញ្ញាណព្រមទាំងរូបកាយរបស់ខ្ញុំ ។

២៦. លោកបូជាចារ្យលុតជង្គង់ យកព្រះកាយ ហើយលើកបន្តិចពីលើចានព្រះកាយបង្ហាញអង្គប្រជុំ ព្រមទាំងពោលច្បាស់ៗថា ៖
នេះជាកូនចៀមរបស់ព្រះជាម្ចាស់
នេះជាព្រះអង្គដែលដកបាបនៃពិភពលោក ។
អ្នកណាដែលព្រះជាម្ចាស់បានត្រាស់ហៅ
ឲ្យមកចូលរួមក្នុងពិធីជប់លៀងរបស់កូនចៀម
អ្នកនោះពិតជាមានសុភមង្គលហើយ ។

លោកបូជាចារ្យ រួមជាមួយអង្គប្រជុំ ពោលបន្តថា ៖

ឱ ព្រះជាអម្ចាស់អើយ !
ខ្ញុំមិនសមនឹងទទួលព្រះអង្គក្នុងផ្ទះខ្ញុំទេ
តែសូមព្រះអង្គមានព្រះបន្ទូលតែមួយព្រះឱស្ឋមក
នោះព្រលឹងខ្ញុំនឹងជាសះស្បើយ ។

២៧. លោកបូជាចារ្យបែរមុខទៅរកតុសក្ការបូជា ទាំងពោលខ្សឹបៗថា ៖
សូមព្រះកាយព្រះគ្រីស្តរក្សាខ្ញុំទុកក្នុងជីវិតអស់កល្បជានិច្ច ។

២៨. លោកបូជាចារ្យកាន់ចានព្រះកាយ ឬក្លង/ប្រអប់តម្កល់ព្រះកាយ រួចដើរទៅកាន់អ្នកទទួលព្រះកាយ ។ ក្នុងពេលទទួលព្រះកាយ គេអាចសូត្រទំនុកតម្កើងលេខ ២២ (២១) ឬអាចច្រៀងចម្រៀងផ្សេងដែលត្រូវនឹងពិធីបុណ្យ ។

២៩. បន្ទាប់ពីចែកព្រះកាយរួចហើយ លោកបូជាចារ្យយកចានព្រះកាយ ទៅដាក់ក្នុងព្រះពន្លាដែលនៅជ្រុងក្រៅពីព្រះវិហារ ។

៣០. បន្ទាប់មកលោកបូជាចារ្យពោលថា សូមបងប្អូនតាំងចិត្តអធិដ្ឋាន និងស្ងៀមស្ងាត់បន្តិច ហើយពោលបន្តពាក្យអរព្រះគុណ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏មានធម៌មេត្តាករុណា !
ព្រះអង្គប្រោសឲ្យយើងខ្ញុំមានជីវិតថ្មីរួមជាមួយព្រះយេស៊ូគ្រីស្ត
ដែលសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំដែលចូលរួមក្នុងអាថ៌កំបាំងដ៏អស្ចារ្យនេះ
នៅតែបន្តស្ម័គ្រចិត្តបូជាជីវិតតាមព្រះគ្រីស្ត ។

អង្គប្រជុំឆ្លើយ៖ អាម៉ែន ។

៣១. លោកឧបដ្ឋាក (បើសិនមានលោកឧបដ្ឋាក) ឬបូជាចារ្យ អញ្ជើញអង្គប្រជុំដោយពោលថា សូមបងប្អូនឱនកាយទទួលព្រះពរ ។ លោកបូជាចារ្យពោលពាក្យជូនពរបញ្ចប់ ។

## ពាក្យជូនពរបញ្ចប់

បពិត្រព្រះបិតាជាអម្ចាស់ !
ព្រះអង្គបានប្រទានព្រះពរយ៉ាងបរិបូណ៌មកលើប្រជារាស្ត្ររបស់ព្រះអង្គ ។

យើងខ្ញុំនាំគ្នាធ្វើពិធីលើកតម្កើងព្រះបុត្រាព្រះអង្គសោយទិវង្គត សូមព្រះអង្គមេត្តាលើកលែងទោសរំដោះបាប និងពង្រឹងជំនឿរបស់យើងខ្ញុំ ដោយមានសង្ឃឹមថា នឹងរស់ឡើងវិញដូចព្រះបុត្រាដែរ ។

អង្គប្រជុំឆ្លើយ៖ អាម៉ែន ។

៣២. អង្គប្រជុំទាំងអស់ លុតជង្គង់[185]គោរពឈើឆ្កាង ហើយបាកចេញដោយស្ងៀមស្ងាត់ ។

៣៣. ក្រោយពេលបញ្ចប់ពិធីបុណ្យ ត្រូវយកក្រណាត់ចេញពីតុសក្ការបូជា ប៉ុន្តែរក្សាទុកឈើឆ្កាង និងទៀនពីរ ឬបួនដើម ។

៣៤. ចំពោះអស់អ្នកដែលបានចូលរួមក្នុងពិធីបុណ្យនេះ មិនបាច់អធិដ្ឋានពេលល្ងាចទេ ។

[185] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ ស្ដីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ អង្គប្រជុំទាំងមូលអង្គុយបត់ជើងលើកដៃប្រណម្យ»នកüaldl;kenÞl ។

# ថ្ងៃសៅរ៍ពិសិដ្ឋ

SABBATO SANCTO

១. នៅថ្ងៃសៅរ៍ពិសិដ្ឋនេះ ព្រះសហគមន៍ចាំនៅមុខផ្នូរព្រះគ្រីស្តដោយអធិដ្ឋាន និងតមអាហារ ទាំងសញ្ជឹងគិតពីព្រះគ្រីស្តដែលរងទុក្ខលំបាក សោយទិវង្គត និងយាងចុះទៅស្ថានក្រោម ហើយព្រះសហគមន៍ក៏ទន្ទឹងរង់ចាំព្រះអង្គមានព្រះជន្មរស់ឡើងវិញដែរ ។

២. ថ្ងៃនេះព្រះសហគមន៍ មិនប្រារព្ធអភិបូជាទេ តុសក្ការបូជាក្នុងព្រះវិហារនៅទំនេរ រហូតដល់រាត្រីបុណ្យចម្លងនៅយប់ថ្ងៃសៅរ៍ ។ នោះគឺជាពេលដែលយើងរង់ចាំបុណ្យចម្លង ដោយមានអំណរសប្បាយ បន្តដល់ថ្ងៃទីហាសិប ។

៣. នៅថ្ងៃនេះ មានតែអ្នកជំងឺប៉ុណ្ណោះដែលអាចទទួលព្រះកាយព្រះគ្រីស្តបាន ។

# រដូវបុណ្យចម្លង

# ថ្ងៃអាទិត្យបុណ្យចម្លង

# ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ

DOMINICA PASCHÆ

IN RESURRECTIONE DOMINI

# រាត្រីបុណ្យចម្លង
# ព្រះយេស៊ូមានជ័យជម្នះលើសេចក្ដីស្លាប់

VIGILIA PASCHALIS IN NOCTE SANCTA

១. តាមប្រពៃណីពីបុរាណ ព្រះសហគមន៍អធិដ្ឋានពេលយប់នេះដោយរង់ចាំព្រះគ្រីស្ត (សេរីភាព ១២,៤២) ។ តាមអត្ថបទព្រះគម្ពីរ លូកា ១២,៣៥-៣៧ ព្រះសហគមន៍ប្រៀបដូចជាអ្នកបម្រើដែលកាន់ចង្កៀងនៅឆេះ និងរង់ចាំម្ចាស់ត្រឡប់មកវិញ ។ នៅពេលម្ចាស់ត្រឡប់មកដល់ឃើញអ្នកបម្រើនៅរង់ចាំលោក នោះលោកនឹងឲ្យគេអង្គុយបរិភោគរួមតុជាមួយ ។

២. បុណ្យចម្លងនៅរាត្រីនេះ ជាបុណ្យកំពូលឱឡារិកជាងគេ ។ ព្រះសហគមន៍នីមួយៗប្រារព្ធពិធីបុណ្យនេះបានតែម្ដងទេ ។

**ពិធីបុណ្យក្នុងរាត្រីនេះ ចែកជាបួនភាគ ៖**

ក. ម្នាក់ៗកាន់ទៀនឆេះនៃបុណ្យចម្លង ហើយរួមគ្នាប្រកាសយ៉ាងឱឡារិកថា ព្រះគ្រីស្តមានព្រះជន្មរស់ឡើងវិញ ។

ខ. តាមរយៈពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់ ព្រះសហគមន៍សញ្ជឹងគិតពីការអស្ចារ្យ ដែលព្រះអម្ចាស់បានធ្វើសម្រាប់ប្រជារាស្ត្រព្រះអង្គ តាំងពីកំណើតពិភពលោក ដោយជឿជាក់លើព្រះបន្ទូលសន្យារបស់ព្រះអង្គ ។

គ. ពិធីនេះបន្តរហូតដល់ពេលជិតភ្លឺ ជាពេលព្រះសហគមន៍ធ្វើអគ្គសញ្ញាជ្រមុជទឹកឲ្យគ្រីស្តបរិស័ទថ្មី ។

ឃ. ព្រះសហគមន៍ចូលរួមតុសក្ការបូជា ដែលព្រះអម្ចាស់បានរៀបចំទុកសម្រាប់ប្រជារាស្ត្រព្រះអង្គ ។ គ្រីស្តបរិស័ទទទួលព្រះកាយព្រះគ្រីស្ត គឺជាការនឹករឭកដល់ព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ ហើយរង់ចាំដល់ពេលព្រះអង្គយាងមក ។

៣. ពិធីរាត្រីបុណ្យចម្លង ចាប់ផ្ដើមនៅពេលអធ្រាត្រ ហើយបញ្ចប់មុនពេលថ្ងៃរះនៅថ្ងៃអាទិត្យ ។

៤. ទោះបីអភិបូជានេះ ប្រារព្ធមុនម៉ោងដប់ពីរក៏ដោយ គេនៅតែចាត់ទុកជាអភិបូជាថ្ងៃអាទិត្យបុណ្យចម្លង ។

៥. គ្រីស្តបរិស័ទដែលទទួលព្រះកាយព្រះគ្រីស្តក្នុងអភិបូជា នៅរាត្រីបុណ្យចម្លង គេក៏អាចទទួលព្រះកាយក្នុងអភិបូជាពេលថ្ងៃដែរ ។ លោកបូជាចារ្យដែលថ្វាយអភិបូជានៅរាត្រីបុណ្យចម្លងលោកក៏អាចថ្វាយអភិបូជាពេលថ្ងៃដែរ ។ លោកបូជាចារ្យដែលចូលរួមក្នុងពិធីរាត្រីបុណ្យចម្លង លោកមិនចាំបាច់អានអត្ថបទរបស់ខ្លួនប្រចាំថ្ងៃ ។

៦. ជាធម្មតា លោកឧបដ្ឋាកម្នាក់ធ្វើជាជំនួយការរបស់លោកបូជាចារ្យនៅក្នុងពិធីបុណ្យនេះ ។ ប្រសិនបើគ្មានឧបដ្ឋាកទេ លោកបូជាចារ្យម្នាក់អាចជំនួសធ្វើជាជំនួយការរបស់លោកបូជាចារ្យជាអធិបតី ។ លោកបូជាចារ្យព្រមទាំងឧបដ្ឋាក ប្រើអាវធំអភិបូជាពណ៌ស ។

៧. អស់អ្នកដែលចូលរួមក្នុងពិធីរាត្រីបុណ្យចម្លង ត្រូវរៀបចំទៀនរៀងៗខ្លួន ។ នៅពេលចាប់ផ្ដើមពិធី ត្រូវបិទភ្លើងទាំងអស់ក្នុងព្រះវិហារ ។

## ភាគទី មួយ

# ពិធីគោរពព្រះគ្រីស្ដជាពន្លឺបំភ្លឺមនុស្សលោក

SOLLEMNE INITIUM VIGILIÆ SEU LUCERNARIUM

# ពិធីប្រទានពរលើភ្លើង និងរៀបចំទៀន

Benedictio ignis et præparatio cerei

៨. ត្រូវរៀបចំគប់ភ្លើងនៅកន្លែងមួយសមរម្យខាងក្រៅព្រះវិហារ ។ ពេលព្រះសហគមន៍ជួបជុំគ្នានៅទីនោះ លោកបូជាចារ្យ និងអស់អ្នកបម្រើពិធីបុណ្យនាំគ្នាទៅកន្លែងគប់ភ្លើង ។ អ្នកបម្រើពិធីបុណ្យម្នាក់កាន់ទៀនបុណ្យចម្លង ។ ក្នុងក្បួនដង្ហែរមិនចាំបាច់មានឈើឆ្កាង និងទៀនតូចៗទេ ។ កន្លែងណាដែលមិនអាចរៀបចំភ្លើងគប់បានទេ ត្រូវចាប់ផ្ដើមពិធីតាំងពីលេខ១៣ តទៅ ។

៩. លោកបូជាចារ្យ និងអស់អ្នកជឿគូសសញ្ញាឈើឆ្កាងលើខ្លួននៅពេលដែលលោកបូជាចារ្យពោលថា៖ ក្នុងព្រះនាមព្រះបិតា និងព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។ លោកបូជាចារ្យស្វាគមន៍អង្គប្រជុំដូចធម្មតា ។

បងប្អូនជាទីស្រឡាញ់ក្នុងអង្គព្រះគ្រីស្ដ !

នៅរាត្រីដ៏វិសុទ្ធនេះ ព្រះយេស៊ូគ្រីស្ដជាព្រះអម្ចាស់យើងខ្ញុំបានឆ្លងផុតពីសេចក្ដីស្លាប់ឲ្យមានព្រះជន្មរស់ឡើងវិញ ។ ព្រះសហគមន៍អញ្ជើញអស់បុត្រធីតាព្រះអង្គនៅទូទាំងពិភពលោកឲ្យមកជួបជុំគ្នាដើម្បីអធិដ្ឋាន ។ នេះជាយប់នៃបុណ្យចម្លងរបស់ព្រះជាអម្ចាស់ ពេលយើងខ្ញុំនឹករឭកពីការសោយទិវង្គត និងព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ តាមគម្រោងការដ៏អស្ចារ្យរបស់ព្រះបិតា យើងខ្ញុំមានទំនុកចិត្តថា បានចូលរួមក្នុងភាពជោគជ័យរបស់ព្រះអង្គលើសេចក្ដីស្លាប់ ហើយរស់នៅជាមួយព្រះអង្គអស់កល្បជានិច្ច ។

១០. បន្ទាប់មក លោកបូជាចារ្យទ្រទាប់ដៃប្រទានពរលើភ្លើង ហើយពោលថា ៖

សូមបងប្អូនតាំងចិត្តអធិដ្ឋាន ៖

ឱ ព្រះបិតាជាអម្ចាស់យើងខ្ញុំអើយ !
ព្រះអង្គប្រោសព្រះយេស៊ូឲ្យមានព្រះជន្មរស់ឡើងវិញ
និងបញ្ចេញរស្មីនៃសិរីរុងរឿងរបស់ព្រះអង្គ ក្នុងភាពងងឹតនៃពិភពលោក
ដូចអណ្ដាតភ្លើងដែលភ្លឺនៅកណ្ដាលយប់អន្ធការ ។
សូមព្រះជាម្ចាស់ ✠ ប្រទានពរលើភ្លើងថ្មីនេះ
ដើម្បីបំភ្លឺចិត្តគំនិតយើងខ្ញុំឲ្យស្គាល់ឋានៈរបស់ខ្លួនជាបុត្រធីតាព្រះអង្គ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំយកចិត្តទុកដាក់ស្វែងរកព្រះគ្រីស្ត
ដើម្បីឲ្យថ្ងៃណាមួយ យើងខ្ញុំបានចូលរួមជាមួយព្រះអង្គនៅស្ថានបរមសុខ ។

អង្គប្រជុំឆ្លើយ៖ អាម៉ែន ។

១១. បន្ទាប់ពីប្រទានពរលើភ្លើងថ្មីហើយ អ្នកបម្រើពិធីបុណ្យម្នាក់យកទៀននៃបុណ្យចម្លងប្រគល់ទៅលោកបូជាចារ្យ ។ លោកបូជាចារ្យប្រើម្ជុលគូសសញ្ញាឈើឆ្កាងលើទៀន ។ ក្រោយមកលោកគូសអក្សរ A (Alpha) ខាងលើឈើឆ្កាង និង Ω (Omega) ខាងក្រោមឈើឆ្កាងនិងលេខឆ្នាំបច្ចុប្បន្ននៅសងខាងឈើឆ្កាងដោយពោលថា ៖

ក. ព្រះគ្រីស្តម្សិលមិញ និងថ្ងៃនេះ ។ (លោកគូសបន្ទាត់បញ្ឈរ)
ខ. ដើមកំណើត និងទីបញ្ចប់នៃជីវិត (លោកគូសបន្ទាត់ផ្ដេក)
គ. អាលហ្វា (លោកគូសអក្សរ A ខាងលើឈើឆ្កាង)
ឃ.អូមេហ្កា (លោកគូសអក្សរ Ω ខាងក្រោមឈើឆ្កាង)
ង. ពេលវេលារបស់ព្រះអង្គ (លោកគូសលេខទីមួយនៃឆ្នាំបច្ចុប្បន្ន)
ច. និងគ្រប់ជំនាន់របស់ព្រះអង្គ (លោកគូសលេខទីពីរនៃឆ្នាំបច្ចុប្បន្ន)
ឆ. ឫទ្ធានុភាព និងសិរីរុងរឿងរបស់ព្រះអង្គ (លោកគូសលេខទីបីនៃឆ្នាំបច្ចុប្បន្ន)
ជ. អស់កល្បជាអង្វែងតរៀងទៅ ។ អាម៉ែន ។ (លោកគូសលេខទីបួននៃឆ្នាំបច្ចុប្បន្ន)

A

| | |
|---|---|
| 2 | 0 |
| 2 | 1 |

Ω

១២. បន្ទាប់មក លោកបូជាចារ្យដាក់បញ្ចូលគ្រាប់កំញាន ៥គ្រាប់ ដោតលើទៀនជ័យ ដែលមានទ្រង់ទ្រាយជាសញ្ញាឈើឆ្កាង ហើយពោលថា ៖

១. តាមរយៈរបួសរបស់ព្រះអង្គ

២. ដែលពោរពេញដោយសិរីរុងរឿង

៣. ព្រះអង្គការពារយើងខ្ញុំ

៤. និងថែរក្សាទំនុកបម្រុងយើងខ្ញុំ

៥. ព្រះគ្រីស្តជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។

1

4 2 5

3

១៣. ប្រសិនបើ គ្មានកន្លែងសមរម្យសម្រាប់រៀបចំគប់ភ្លើង គ្រីស្តបរិស័ទជួបជុំគ្នានៅក្នុងព្រះវិហារ ។ លោកបូជាចារ្យឈរនៅត្រង់ទ្វារចូលព្រះវិហារ ហើយលោកគូសសញ្ញាឈើឆ្កាងលើទៀន ដូចរៀបរាប់ខាងលើ ។

១៤. បន្ទាប់មក លោកបូជាចារ្យអុជទៀនជ័យពីភ្លើងថ្មី ហើយពោលថា ៖

សូមឲ្យពន្លឺព្រះគ្រីស្តពោរពេញដោយសិរីរុងរឿង
កំចាត់ភាពងងឹតចេញពីចិត្តគំនិតរបស់យើងខ្ញុំ ។

## ក្បួនហែ

Processio

១៥. បន្ទាប់ពីអុជទៀនរួចហើយ លោកបូជាចារ្យដាក់កំញានក្នុងប្រដាប់ដុតកំញានដែលមានភ្លើងឆេះ ។ អ្នកកាន់ប្រដាប់ដុតកំញានទៅមុនគេ បន្ទាប់មកលោកឧបដ្ឋាក (ឬលោកបូជាចារ្យជាអធិបតី) លើកទៀនជ័យឡើង ហើយច្រៀងថា ៖

ព្រះពន្លឺព្រះគ្រីស្ត

អង្គប្រជុំឆ្លើយ ៖ សូមអរព្រះគុណព្រះជាម្ចាស់ ។

លោកបូជាចារ្យ បន្តភ្លើងទៀនទៅឲ្យគ្រីស្តបរិស័ទ ។

១៦. លោកឧបដ្ឋាកដង្ហែរហូតដល់ចំកណ្តាលព្រះវិហារ លោកលើកទៀនជ័យឡើងហើយច្រៀងថា៖

ព្រះពន្លឺព្រះគ្រីស្ត

អង្គប្រជុំឆ្លើយ ៖ សូមអរព្រះគុណព្រះជាម្ចាស់ ។

គ្រីស្តបរិស័ទអុជទៀនរបស់ខ្លួន បន្តពីទៀនជ័យរៀងៗខ្លួន ។

១៧. លោកឧបដ្ឋាកដង្ហែ រហូតដល់តុសក្ការបូជា លោកបែរមុខទៅរកគ្រីស្តបរិស័ទ លើកទៀនជ័យឡើង ហើយច្រៀងថា ៖

ព្រះពន្លឺព្រះគ្រីស្ត

អង្គប្រជុំឆ្លើយ ៖ សូមអរព្រះគុណព្រះជាម្ចាស់ ។

ក្រោយមក លោកឧបដ្ឋាក ដាក់ទៀនជ័យលើជើងតម្កល់ទៀននៅក្បែរតុអានព្រះបន្ទូល ។ បន្ទាប់មកបំភ្លឺភ្លើងក្នុងព្រះវិហារទាំងមូល លើកលែងតែទៀនតូចៗនៅលើតុសក្ការបូជា គេមិនអុជទេ ។

## ការប្រកាសយ៉ាងឱឡារិកនៃបុណ្យចម្លង

Præconium paschale

១៨. មកដល់តុសក្ការបូជា លោកបូជាចារ្យដើរសំដៅទៅកន្លែងអង្គុយរបស់លោក ។ អ្នកបម្រើតុសក្ការបូជា យកប្រដាប់ដុតកំញានជូនលោកបូជាចារ្យដាក់កំញានបន្ថែម ។ លោកឧបដ្ឋាកទៅទទួលព្រះពរពីលោកដោយពោលថា ៖

សូមលោកប្រទានពរមកខ្ញុំផង ។

លោកបូជាចារ្យពោលខ្សឹបៗថា ៖

សូមព្រះអម្ចាស់គង់ក្នុងដួងចិត្ត និងលើមាត់លោក
ដើម្បីលោកអាចប្រកាសបទចម្រៀងនៃបុណ្យចម្លងដោយសមរម្យ ក្នុងព្រះនាមព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ ។

លោកឧបដ្ឋាកឆ្លើយ ៖ អាម៉ែន ។

១៩. បន្ទាប់ពីបក់ផ្សែងកំញានលើសៀវភៅបទចម្រៀងនៃបុណ្យចម្លង និងលើទៀនជ័យ លោកឧបដ្ឋាកប្រកាសយ៉ាងឱឡារិក ពេលនោះ គ្រីស្តបរិស័ទឈរ[186] កាន់ទៀនឆេះ ។

លោកបូជាចារ្យ ឬលោកឧបដ្ឋាកលើកតម្កើងសិរីរុងរឿងរបស់ព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ ដោយច្រៀងបទនេះ ឬបទដែលមានអត្ថន័យប្រហាក់ប្រហែលគ្នា ។

ចូរពួកទេវទូតទាំងឡាយនៅស្ថានបរមសុខ ត្រេកអរសប្បាយរីករាយឡើង
ចូរនាំគ្នាផ្គុំស្នែងអបអរជ័យជម្នះរបស់ព្រះមហាក្សត្រដ៏មានឫទ្ធានុភាព ។

[186] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ ស្តីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ អង្គប្រជុំទាំងមូលអង្គុយបត់ជើងលើកenÞl ។

ចូរផែនដីទាំងមូលសប្បាយរីករាយឡើង ពន្លឺដ៏ចិញ្ចែងចិញ្ចាចរបស់ព្រះមហាក្សត្របានបញ្ចាំងសិរីរុងរឿងលើអ្នកហើយ ។
ចូរពិភពលោកទាំងមូលរីករាយឡើង
ពន្លឺបានកម្ចាត់កម្ចាយភាពងងឹតចេញពីពិភពលោកយើងនេះហើយ ។
ចូរព្រះសហគមន៍ជាមាតារបស់យើងខ្ញុំរីករាយឡើង ពន្លឺបានបញ្ចេញរស្មីពណ្ណរាយលើអ្នកហើយ ។
ចូរព្រះវិហារពោរពេញដោយអំណរសប្បាយដ៏គគ្រឹកគគ្រេង ។

(ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។)

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ពិតជាការគួរណាស់ហើយប្រពៃផង
យើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ជាព្រះដែលមនុស្សលោកមើលពុំឃើញ ។
យើងខ្ញុំក៏សូមលើកតម្កើងព្រះយេស៊ូគ្រីស្ត
ជាព្រះបុត្រាតែមួយរបស់ព្រះអង្គ ហើយជាព្រះអម្ចាស់យើងខ្ញុំ ។
ព្រះអង្គលោះបំណុលពីព្រះបិតាជំនួសលោកអដាំ បានជាប្រយោជន៍ដល់យើងខ្ញុំ ។
ព្រះអង្គបានបង្ហូរព្រះលោហិតដើម្បីលាងបាបដើមដំបូងរបស់យើងខ្ញុំ ។
យើងខ្ញុំនាំគ្នាអបអរសាទរបុណ្យចម្លង
ដើម្បីនឹករឭកដល់កូនចៀមតែមួយដ៏ពិតប្រាកដដែលត្រូវគេសម្លាប់ ។
គ្រីស្តបរិស័ទទទួលការសង្គ្រោះដោយសារព្រះលោហិតកូនចៀមនេះ ដូចប្រជាជនអ៊ីស្រាអែលទទួលការសង្គ្រោះ

ដោយសារឈាមរបស់កូនចៀមដែលគេលាបនៅលើក្លោងទ្វារផ្ទះ ។
នៅរាត្រីនេះ ព្រះអង្គបានដឹកនាំជូនតារបស់យើងខ្ញុំ
គឺកូនចៅអ៊ីស្រាអែល ចេញផុតពីភាពជាទាសករនៅស្រុកអេហ្ស៊ីប
ហើយនាំពួកគេដើរឆ្លងកាត់សមុទ្រក្រហម ។

នៅរាត្រីនេះ ព្រះអង្គប្រើដុំភ្លើងលុបបំបាត់ភាពងងឹតនៃអំពើបាប ។
នៅរាត្រីនេះ ក្នុងពិភពលោកទាំងមូល
ព្រះអង្គញែកអ្នកជឿលើព្រះគ្រីស្តចេញពីអំពើអាក្រក់របស់លោកីយ
និងចេញពីភាពងងឹតនៃអំពើបាប ហើយទ្រង់ដឹកនាំពួកគេ
ដោយព្រះហឫទ័យប្រណីសន្តោស ព្រមទាំងប្រទានឲ្យពួកគេបានវិសុទ្ធ ។
នៅរាត្រីនេះ ព្រះគ្រីស្តបំបាក់ខ្នោះឃ្នាងនៃសេចក្តីស្លាប់
ហើយក្រោកពីស្ថានក្រោមប្រកបដោយជ័យជម្នះ ។

ឱ ព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យថ្លាក់ថ្លមដ៏អស្ចារ្យអើយ !
ព្រះអង្គមានព្រះហឫទ័យអាណិតអាសូរ
និងមេត្តាករុណាចំពោះយើងខ្ញុំហួសពីការស្មាន ។
ព្រះអង្គបានលះបង់ព្រះបុត្រាដើម្បីលោះយើងខ្ញុំចេញពីទាសភាព ។
ពិតមែនហើយ អំពើបាបរបស់លោកអដាំមានប្រយោជន៍ណាស់ !
ដ្បិតព្រះគ្រីស្តសោយទិវង្គតដើម្បីបំផ្លាញអំពើបាបនោះ ។
នៅរាត្រីនេះ ឫទ្ធានុភាពដ៏វិសុទ្ធរបស់ព្រះអង្គកម្ចាត់កម្ចាយសេចក្តីអាក្រក់
លាងជម្រះអំពើបាប និងលើកលែងទោសអ្នកបាបឲ្យបានសុចរិត
ហើយផ្តល់អំណរសប្បាយដល់អ្នកមានទុក្ខព្រួយ ។
ពិតហើយ រាត្រីនេះមានសុភមង្គលមែន !
ដ្បិតស្ថានបរមសុខ និងផែនដីរួបរួមគ្នា
ហើយព្រះជាម្ចាស់ និងមនុស្សលោកជ្សាភ្ជាប់គ្នា ។
ឱ ព្រះបិតាដ៏វិសុទ្ធអើយ !

នៅរាត្រីនៃការប្រណីសន្ដោសនេះ សូមព្រះអង្គមេត្តាទទួលនូវទៀនព្រះជ័យពីដៃអ្នកបម្រើរបស់ព្រះអង្គ ។ យើងខ្ញុំសូមយកទៀននេះ ដែលធ្វើពីក្រមួនឃ្មុំលើកថ្វាយទៅព្រះអង្គ
ទុកជាសក្ការបូជាអរព្រះគុណនៅពេលល្ងាច
និងជាតង្វាយដ៏ប្រសើរឧត្តម្ភពីព្រះសហគមន៍ដ៏វិសុទ្ធរបស់ព្រះអង្គ ។

ឱ ព្រះជាអម្ចាស់យើងខ្ញុំអើយ !
សូមព្រះអង្គប្រោសឲ្យទៀននេះឆេះជារៀងរហូត
ដើម្បីបំភ្លឺភាពងងឹតក្នុងរាត្រីនេះ និងលើកតម្កើងព្រះនាមព្រះអង្គ ។
សូមឲ្យទៀនព្រះជ័យនេះ បញ្ចេញក្លិនពិដោរវិរីកសាយភាយសព្វទិសទី
និងសូមឲ្យពន្លឺទៀននេះចូលរួមជាមួយពន្លឺនៃហ្វូងតារានៅស្ថានបរមសុខ ។
សូមឲ្យពន្លឺនេះនៅតែភ្លឺរហូតដល់ផ្កាយព្រឹករះ ជាផ្កាយដែលមិនចេះលិច
គឺព្រះគ្រីស្តជាព្រះបុត្រាដែលមានព្រះជន្មរស់ឡើងវិញ ហើយចេញពីស្ថានមនុស្សស្លាប់ ។
សូមឲ្យពន្លឺនៃសេចក្តីសុខសាន្តរបស់ព្រះអង្គបំភ្លឺមនុស្សលោក ។
យើងខ្ញុំសូមកោតសរសើរព្រះអង្គដែលមានព្រះជន្មគង់នៅ និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

## ភាគទី ពីរ

# ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់

LITURGIA VERBI

២០. ក្នុងរាត្រីបុណ្យចម្លង ដែលជាបុណ្យកំពូល មានអត្ថបទព្រះគម្ពីរចំនួនប្រាំបួន គឺមានប្រាំពីរអត្ថបទមកពីសម្ពន្ធមេត្រីចាស់ ហើយមានពីរអត្ថបទមកពីសម្ពន្ធមេត្រីថ្មី (ដកស្រង់ពីលិខិតរបស់គ្រីស្តទូត និងគម្ពីរដំណឹងល្អ) ។ បើសិនជាអាចធ្វើបាន គួរអានអត្ថបទព្រះគម្ពីរទាំងអស់ ដើម្បីរក្សាលក្ខណៈបុណ្យដែលត្រូវការពេលវេលាវែង ។

២១. ទោះជាយ៉ាងណាក៏ដោយ ក្នុងកាលៈទេសៈដែលព្រះសហគមន៍មានការលំបាក យើងអាចបន្ថយចំនួនអត្ថបទពីសម្ពន្ធមេត្រីចាស់ដែលត្រូវអាន ក៏ប៉ុន្តែសូមយល់ថា ពិធីលើកតម្កើងព្រះបន្ទូល ជាពិធីគ្រឹះដ៏សំខានបំផុតក្នុងរាត្រីបុណ្យចម្លង ។ យើងត្រូវរក្សាទុកយ៉ាងតិចបី អត្ថបទពីសម្ពន្ធមេត្រីចាស់ គឺអត្ថបទគម្ពីរពីធម្មវិន័យ និងគម្ពីរព្យាការី រួមនឹងទំនុកតម្កើងដែលត្រូវសូត្រ ។ ដាច់ខាតត្រូវតែអានអត្ថបទគម្ពីរដំណើរឆ្ពោះទៅកាន់សេរីភាព ជំពូកទី១៤ រួមជាមួយនឹងបទចម្រៀងរបស់លោកម៉ូសេ ។

២២. បន្ទាប់ពីពន្លត់ភ្លើងទៀន អង្គប្រជុំអង្គុយចុះ ។ មុនពេលចាប់ផ្តើមអានអត្ថបទព្រះគម្ពីរ លោកបូជាចារ្យណែនាំអង្គប្រជុំដោយពោលពាក្យដូចខាងក្រោម ឬប្រហាក់ប្រហែលថា៖

បងប្អូនជាទីស្រឡាញ់ !

ឥឡូវនេះ យើងចាប់ផ្តើមរាត្រីនៃបុណ្យចម្លងយ៉ាងឱឡារិក

ចូរយើងផ្ទៀងត្រចៀកស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់

ចូរយើងត្រិះរិះអំពីរបៀបដែលព្រះជាម្ចាស់

បានសង្គ្រោះប្រជាជនរបស់ព្រះអង្គកាលពីដើម

ហើយចុងក្រោយបំផុត បានចាត់ព្រះបុត្រាដើម្បីសង្គ្រោះយើងខ្ញុំ ។

ចូរយើងអង្វរព្រះជាម្ចាស់ សូមប្រោសឲ្យកិច្ចការសង្គ្រោះមនុស្សលោក

បានគ្រប់លក្ខណៈក្នុងបុណ្យចម្លងនេះ ។

២៣. ក្រោយមក អ្នកអានប្រកាសព្រះបន្ទូលជាបន្តបន្ទាប់ អមជាមួយទំនុកតម្កើង ។ បន្ទាប់មកអង្គប្រជុំក្រោកឈរ [១៨៧] ហើយលោកបូជាចារ្យពោលថា៖ សូមបងប្អូនតាំងចិត្តអធិដ្ឋាន ។ ក្រោយ

---

១៨៧ យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ ស្តីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ អង្គប្រជុំទាំងមូលអង្គុយបត់ជើងលើកន្ទេល ។

មក អង្គប្រជុំនៅស្ងាត់ស្ងៀម លោកក៏អានពាក្យអធិដ្ឋានដែលត្រូវនឹងអត្ថបទគម្ពីរ ទើបបានប្រកាស ។ ជំនួសឲ្យការសូត្រទំនុកតម្កើង អង្គប្រជុំអាចរក្សាភាពស្ងៀមស្ងាត់មួយសន្ទុះ ។

## ពាក្យអធិដ្ឋានបន្ទាប់ពីបានអានអត្ថបទគម្ពីរ

Orationes post lectiones

២៤. បន្ទាប់ពីបានអានអត្ថបទទី ១ (កណ ១,១-២,២ ឬ ១,១.២៦-៣១ក) និងទំនុកតម្កើងលេខ ១០៤ (១០៣) ឬ ៣៣ (៣២)) ។

សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គប្រព្រឹត្តអ្វីៗទាំងអស់ ដោយព្រះប្រាជ្ញាញាណដ៏ប្រសើរបំផុត ។
ព្រះអង្គប្រទានឲ្យយើងខ្ញុំមានលក្ខណៈដ៏ប្រសើរដូចព្រះអង្គ ។
ព្រះអង្គក៏ប្រោសឲ្យយើងខ្ញុំទៅជាបុត្រធីតារបស់ព្រះអង្គ
ដោយព្រះគ្រីស្តជាព្រះបុត្រាបានបូជាព្រះជន្ម
ទុកជាសក្ការបូជានៃបុណ្យចម្លង ។
ព្រះអង្គមានព្រះជន្មគង់នៅ និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

២៥. បន្ទាប់ពីបានអានអត្ថបទទី២ (កណ ២២,១-១៨ ឬ ២២,១-២. ៩ក. ១០-១៣. ១៥-១៨) និងទំនុកតម្កើងលេខ ១៦ (១៥) ។

សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះជាម្ចាស់ដ៏វិសុទ្ធបំផុត !
ព្រះអង្គពិតជាព្រះបិតារបស់អស់អ្នកជឿសង្ឃឹមលើព្រះអង្គ ។
ព្រះអង្គសព្វព្រះហឫទ័យឲ្យមនុស្សទាំងអស់ ទៅជាបុត្រធីតារបស់ព្រះអង្គ
តាមព្រះបន្ទូលដែលព្រះអង្គសន្យាជាមួយលោកអប្រាហាំ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំទៅជាប្រជារាស្ត្ររបស់ព្រះអង្គ ដែលរស់យ៉ាង
សមរម្យតាមឋានៈរបស់យើងខ្ញុំ ។
យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

២៦.បន្ទាប់ពីបានអានអត្ថបទទី៣ (ដំណើរឆ្លងកាត់សមុទ្រក្រហមៈ ដណ ១៤,១៥-១៥,១) និង បទចម្រៀងរបស់លោកម៉ូសេ (ដណ ១៥) ។

សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
កាលពីដើម ព្រះអង្គបានសង្គ្រោះប្រជាជនអ៊ីស្រាអែល
ឲ្យរួចពីកណ្តាប់ដៃខ្មាំងសត្រូវ ។
សព្វថ្ងៃព្រះអង្គក៏សង្គ្រោះមនុស្សគ្រប់ជាតិសាសន៍
ដោយប្រទានជីវិតថ្មីឲ្យអស់អ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹក ។ សូមព្រះអង្គ
មេត្តាប្រោសឲ្យមនុស្សទាំងអស់
ទៅជាពូជពង្សរបស់លោកអប្រាហាំ
និងមានកិត្តិយសជាបុត្រធីតារបស់ព្រះអង្គ ។
យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

២៧.បន្ទាប់ពីបានអានអត្ថបទទី៤ (អស ៥៤,៥-១៤) និងទំនុកតម្កើងលេខ ៣០ (២៩) ។

សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
សូមព្រះអង្គមេត្តាបង្កើនចំនួនបុត្រធីតារបស់ព្រះអង្គ
តាមព្រះបន្ទូលដែលព្រះអង្គសន្យាជាមួយបុព្វបុរស ។
សូមសម្ដែងធម៌មេត្តាករុណារបស់ព្រះអង្គឲ្យព្រះសហគមន៍
និងឲ្យមនុស្សគ្រប់ជាតិសាសន៍ជឿសង្ឃឹមលើព្រះអង្គ ។
យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់ ។
អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

២៨.បន្ទាប់ពីបានអានអត្ថបទទី៥ (អស ៥៥,១-១១) និងបទចម្រៀងរបស់លោកអេសាយ (អស ១២) ។
សូមបងប្អូនតាំងចិត្តអធិដ្ឋាន
ឱ ព្រះបិតាដ៏វិសុទ្ធ ហើយមានព្រះជន្មគង់នៅអស់កល្បជានិច្ចអើយ !
មានតែព្រះអង្គទេ ដែលអាចបំពេញសេចក្ដីសង្ឃឹមរបស់មនុស្សលោកបាន ។
ព្រះអង្គបានប្រទានដំណឹងអំពីការសង្គ្រោះ តាមរយៈអស់លោកព្យាការី ។
សូមព្រះអង្គមេត្តាទាក់ទាញចិត្តគំនិតនៃបុត្រធីតារបស់ព្រះអង្គ ឲ្យមានបំណង
ប្រព្រឹត្តតែកិច្ចការដែលគាប់ព្រះហឫទ័យព្រះអង្គ ។
យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់ ។
អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

២៩.បន្ទាប់ពីបានអានអត្ថបទទី៦ (បរ ៣,៩-១៥.៣១-៤,៤) និងទំនុកតម្កើងលេខ ១៩ (១៨) ។
សូមបងប្អូនតាំងចិត្តអធិដ្ឋាន
បពិត្រព្រះបិតាជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គតែងតែត្រាស់ហៅមនុស្សគ្រប់ជាតិសាសន៍
ឲ្យចូលរួមក្នុងព្រះសហគមន៍កាន់តែច្រើនឡើងៗ ។
សូមព្រះអង្គមេត្តាការពារថែរក្សាអស់អ្នក
ដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកឲ្យមានជំនឿកាន់តែមាំមួន ។
យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់ ។
អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

៣០. បន្ទាប់ពីបានអានអត្ថបទទី៧ (បិត្តគំនិតថ្មី និងវិញ្ញាណថ្មី អគ ៣៦,១៦-២៨) និងទំនុកតម្កើង លេខ ៤២ (៤១)-៤៣ (៤២) ។

សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះអម្ចាស់ជាព្រះបិតា !

ព្រះអង្គបង្រៀនយើងខ្ញុំតាមរយៈព្រះគម្ពីរសម្ពន្ធមេត្រីចាស់ និងថ្មី

ហើយនាំយើងខ្ញុំចូលក្នុងគម្រោងការដ៏អស្ចារ្យនៃបុណ្យចម្លង ។

សូមឲ្យយើងខ្ញុំយល់ពីទំហំនៃធម៌មេត្តាករុណារបស់ព្រះអង្គ

ដើម្បីឲ្យអំណោយទានដែលយើងខ្ញុំទទួលក្នុងយប់នេះ បង្ហាញពីអំណោយទាន

ដែលយើងខ្ញុំសង្ឃឹមនឹងទទួលក្នុងលោកខាងមុខ ។

យើងខ្ញុំសូមទូលអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

៣១. បន្ទាប់ពីអានអត្ថបទចុងក្រោយនៃគម្ពីរសម្ព័ន្ធមេត្រីចាស់ សូត្រទំនុកតម្កើង និងពោលពាក្យអធិដ្ឋាន គេអុជទៀននៅលើតុសក្ការបូជា ហើយលោកបូជាចារ្យណែនាំអង្គប្រជុំច្រៀង "ធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់" ។ នៅពេលនោះ គេអាចវាយជួងតាមទម្លាប់ទីកន្លែងនីមួយៗ ។

៣២. នៅពេលច្រៀងចប់ លោកបូជាចារ្យពោលពាក្យអធិដ្ឋានតាមធម្មតា ។

សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះបិតាដ៏សប្បុរស !

ព្រះអង្គប្រទានឲ្យសិរីរុងរឿងរបស់ព្រះអម្ចាស់

ដែលមានព្រះជន្មរស់ឡើងវិញ បំភ្លឺយប់ដ៏សក្ការៈនេះ ។

សូមឲ្យយើងខ្ញុំជាព្រះសហគមន៍កាន់តែស្គាល់ឋានៈរបស់ខ្លួនជាបុត្រធីតា

ដើម្បីយើងខ្ញុំបម្រើព្រះអង្គឲ្យអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ។

យើងខ្ញុំសូមអង្វរព្រះអង្គតាមរយៈព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់

ជាព្រះបុត្រាព្រះអង្គដែលមានព្រះជន្មគង់នៅ ហើយសោយរាជ្យរួមជាមួយព្រះបិតា

និងព្រះវិញ្ញាណដ៏វិសុទ្ធអស់កល្បជាអង្វែងតរៀងទៅ ។

៣៣. បន្ទាប់មក អានអត្ថបទមួយដកស្រង់ពីលិខិតរបស់គ្រីស្តទូត ។

៣៤. ក្រោយពីអានលិខិតរបស់គ្រីស្តទូត អង្គប្រជុំក្រោកឈរ[188] ។ លោកបូជាចារ្យ ឬអ្នកណែនាំបទចម្រៀង ច្រៀង **អាលេលូយ៉ា** បីដង ឲ្យកាន់តែខ្លាំងឡើង បន្តិចម្តងៗ ។ អង្គប្រជុំច្រៀងតាម ។ ក្រោយមក ស្មូតទំនុកតម្កើង លេខ ១១៨ (១១៧) អង្គប្រជុំច្រៀងបន្ទរ **អាលេលូយ៉ា** ។

៣៥. តាមធម្មតាលោកបូជាចារ្យ ដាក់កំញានក្នុងប្រដាប់ដុតកំញាន ហើយប្រទានពរដល់លោកឧបដ្ឋាក ។ ពេលនោះ គេមិនចាំបាច់ឈរកាន់ទៀនអមសងខាងព្រះគម្ពីរទេ គឺគ្រាន់តែបក់ផ្សែងកំញានប៉ុណ្ណោះ ។

៣៦. បន្ទាប់ពីអានព្រះបន្ទូលដំណឹងល្អ ដាច់ខាតត្រូវតែមានធម្មទេសនា ទោះបីជាខ្លីក៏ដោយ ។

## ភាគទី បី

# ក្បួនពិធីជ្រមុជទឹក

LITURGIA BAPTISMALIS

៣៧. បន្ទាប់ពីធម្មទេសនា ក្បួនពិធីជ្រមុជទឹកចាប់ផ្តើម ។ លោកបូជាចារ្យ និងអ្នកបម្រើពិធីបុណ្យដើរទៅកន្លែងធ្វើពិធីជ្រមុជទឹក ប្រសិនបើ ជាកន្លែងដែលគ្រីស្តបរិស័ទមិនអាចមើលឃើញនោះ គេអាចប្រើផ្តិលធំដាក់ទឹកនៅទីសក្ការបូជា ។

៣៨. គេអញ្ជើញអ្នកត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹកទៅខាងមុខ ហើយឪពុកធម៌ ម្តាយធម៌បង្ហាញពួកគេនៅចំពោះមុខព្រះសហគមន៍ ។ ប្រសិនបើមានកូនតូចៗ ឪពុកម្តាយបង្កើត និងឪពុកម្តាយធម៌នាំពួកគេទៅខាងមុខ ។

៣៩. ក្រោយមក បើសិនមានការដង្ហែរទៅកន្លែងជ្រមុជទឹក នោះអ្នកកាន់ទៀនជ័យដើរមុខគេ ហើយអស់អ្នកដែលត្រៀមទទួលអគ្គសញ្ញាជ្រមុជទឹករួមជាមួយឪពុកធម៌ ម្តាយធម៌ រួចអ្នកបម្រើពិធីបុណ្យ លោកឧបដ្ឋាក និងលោកបូជាចារ្យដើរតាមក្រោយ ។ នៅពេលនោះ គេស្មូតពាក្យអង្វរសន្តបុគ្គលទាំងឡាយ (ល.៤៣) ។ ពេលស្មូតចប់ លោកបូជាចារ្យធ្វើការណែនាំ (ល.៤០) ។

៤០. បើសិនជា ពិធីជ្រមុជទឹកប្រារព្ធនៅទីសក្ការបូជា លោកបូជាចារ្យធ្វើការណែនាំភ្លាម ដោយពោលពាក្យដូចខាងក្រោម ឬពាក្យប្រហាក់ប្រហែល ។

[188] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ ស្តីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ អង្គប្រជុំទាំងមូលអង្គុយបត់ជើងលើកន្ទេល ។

ពេលមានអ្នកត្រៀមទទួលអគ្គសញ្ញាជ្រមុជទឹក ៖

បងប្អូនជាទីស្រឡាញ់ !
សូមបងប្អូនរួមចិត្តគំនិតអង្វរព្រះបិតាមេត្តាប្រទានពរដល់អស់បងប្អូន
ដែលត្រៀមទទួលអគ្គសញ្ញាជ្រមុជទឹកនៅពេលនេះ ។
សូមព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ មេត្តាថែរក្សាបងប្អូនទាំងនោះ
នៅពេលពួកគេកំពុងដើរឆ្ពោះទៅកាន់ប្រភពទឹកដែលផ្តល់ជីវិតថ្មី ។

ពេលគ្មានអ្នកត្រៀមទទួលអគ្គសញ្ញាជ្រមុជទឹក ៖

បងប្អូនជាទីស្រឡាញ់ !
សូមអង្វរព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ប្រទានព្រះពរលើអាងជ្រមុជទឹកនេះ
សូមឲ្យអស់អ្នកដែលនឹងកើតជាថ្មី
បានចូលរួមក្នុងចំណោមបុត្រធីតារបស់ព្រះអង្គ ក្នុងអង្គព្រះគ្រីស្ត ។

៤១. អ្នកចម្រៀងពីរនាក់សូត្រពាក្យអង្វរសន្តបុគ្គលទាំងឡាយ អង្គប្រជុំទាំងមូលក្រោកឈរ[189] ទាំងអស់គ្នា (ពីព្រោះជាពេលបុណ្យចម្លង) ហើយឆ្លើយបន្ទរ ។ ប្រសិនជាមានក្បួនហែ វែងឆ្ពោះទៅអាងជ្រមុជទឹក សូមសូត្រពាក្យអង្វរសន្តបុគ្គលទាំងឡាយក្នុងពេលហែក្បួន ។ ក្បួនដង្ហែចាប់ផ្តើមដោយមានទៀនព្រះជ័យនាំមុខ ហើយអស់អ្នកដែលត្រៀមទទួលអគ្គសញ្ញា ជ្រមុជទឹកដើរតាមពីក្រោយរួមជាមួយឪពុកធម៌ ម្តាយធម៌ អ្នកបម្រើពិធីបុណ្យ លោកឧបដ្ឋាក និងលោកបូជាចារ្យ ។ បន្ទាប់ពីក្បួនហែនេះ លោកបូជាចារ្យពោលពាក្យណែនាំខ្លះៗ មុនធ្វើព្រះពរលើទឹក ។

៤២. បើសិនជាគ្មានអ្នកណាទទួលពិធីជ្រមុជទឹក ហើយបើសិនជាគ្មានការប្រទានពរលើអាងជ្រមុជទឹកទេ សូមកុំសូត្រពាក្យអង្វរសន្តបុគ្គលទាំងឡាយ ។ សូមប្រារព្ធពិធីប្រទានពរលើទឹកតែម្តង (លេ.៥៤) ។

៤៣. នៅក្នុងពាក្យអង្វរសន្តបុគ្គលទាំងឡាយ គេអាចបន្ថែមឈ្មោះសន្តបុគ្គលខ្លះៗ ដូចជាសន្តបុគ្គលជាឧបការជនព្រះវិហារ និងព្រះសហគមន៍ ព្រមទាំងឈ្មោះសន្ត សន្តី របស់អ្នកដែលត្រូវទទួលអគ្គសញ្ញាជ្រមុជទឹក ។

[189] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ ស្តីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ អង្គប្រជុំទាំងមូលអង្គុយបត់ជើងលើកដៃប្រណម្យ»នកüaldl;kenÞl ។

ឱ ព្រះអម្ចាស់អើយ សូមអាណិតអាសូរ !

អង្គប្រជុំឆ្លើយ ៖ **ឱ ព្រះអម្ចាស់អើយ សូមអាណិតអាសូរ ។**

ឱ ព្រះគ្រីស្តអើយ សូមអាណិតអាសូរ !

អង្គប្រជុំឆ្លើយ ៖ **ឱ ព្រះគ្រីស្តអើយ សូមអាណិតអាសូរ ។**

ឱ ព្រះអម្ចាស់អើយ សូមអាណិតអាសូរ !

អង្គប្រជុំឆ្លើយ ៖ **ឱ ព្រះអម្ចាស់អើយ សូមអាណិតអាសូរ ។**

-ព្រះនាងម៉ារី ជាព្រះមាតាព្រះយេស៊ូគ្រីស្ត

-អស់សន្ត សន្តីទេវទូតទាំងឡាយ

អង្គប្រជុំឆ្លើយ ៖ **សូមជួយអង្វរព្រះអម្ចាស់ឲ្យយើងខ្ញុំ** (ឃ្លាខាងក្រោមឆ្លើយដូចគ្នាដែរ)

-សន្តទេវទូតមីកាអែល

-សន្តយ៉ូសែប

-សន្តអង់ទ្រេ

-សន្តីម៉ារី ជាអ្នកស្រុកម៉ាដាឡា

-សន្តអ៊ីញ៉ាស ជាអភិបាលក្រុងអន់ទីយ៉ូក

-សន្តីពែរប៉េទូអា និងសន្តីហ្វេលីស៊ីតា

-សន្តក្រេគ័រ

-សន្តអាថាណាស

-សន្តម៉ាតាំង

-សន្តហ្វ្រង់ស្វ័រ និងសន្តដូនីមីកូ

-សន្តយ៉ូហាន ម៉ារី (វីយ៉ានេ)

-សន្តីតេរេសាគោរពព្រះយេស៊ូកុមារ

-សន្តហ្វ្រង់ស្វ័រនៅឡាសាល

-សន្តយ៉ូហាន-បាទីស្ត

-សន្តសិលា និងសន្តប៉ូល

-សន្តយ៉ូហាន

-សន្តស្ទេផាន

-សន្តឡូរ៉ង់

-សន្តីអាញ៉េស

-សន្តអូគុស្តាំង

-សន្តបាស៊ីល

-សន្តបេណេឌិក្ត

-សន្តហ្វ្រង់ស្វ័រ (សាវីយេ)

-សន្តីកាថារីណា នៅក្រុងស៊ីយេណា

-សន្តីតេរេសានៅក្រុងអាវីឡា

-សន្តយ៉ូហានបូស្កូ

-សន្តប៉ូល មីគី និងសហការី ជាមរណសាក្សី នៅប្រទេសជប៉ុន ។
-សន្តអន់ដ្រេ គីម និងសហការី ជាមរណសាក្សីនៅប្រទេសកូរ៉េ ។
-សន្តកាព្រីអែល និងសន្តអូគុស្តាំង សៅរ៉ែង ព្រមទាំងសហការី
ជាមរណសាក្សីនៅប្រទេសចិន ។
-សន្តអន់ដ្រេយ៉ូងឡាក និងសហការី ជាមរណសាក្សីនៅប្រទេសវៀតណាម ។
-សន្តីអាញ៉េសភីឡា និងសន្តភីលីពស៊ីផង ព្រមទាំងសហការី
ជាមរណសាក្សីនៅប្រទេសថៃ ។

អស់មរណសាក្សីនៅប្រទេសកម្ពុជាដែលមិនទាន់ទទួលការអនុញ្ញាតពីបូរីរ៉ាំទីកង់៖
-លោកយ៉ូសែប ឆ្មារសាឡាស ជាអភិបាលព្រះសហគមន៍ភ្នំពេញពីដើម។
-លោកប៉ូលទេពអ៊ឹមសុត្ថា ជាអភិបាលព្រះសហគមន៍បាត់ដំបងពីដើម។
-លោកយ៉ូសែប ឆ្មារ សាឡឹម, លោកម៉ាសែល ទ្រឿង សំរើន, លោកប៉ែរណា ឈួន សារ ជាបូជាចារ្យ និងអស់លោកអ្នកបួស ដែលបានបូជាជីវិតថ្វាយព្រះគ្រីស្ត នៅប្រទេសកម្ពុជា។

-អស់សន្ត សន្តីទាំងឡាយរបស់ព្រះជាអម្ចាស់ ។
-សូមព្រះយេស៊ូប្រោសប្រណីយើងខ្ញុំ

អង្គប្រជុំឆ្លើយ ៖ **សូមព្រះអម្ចាស់ជួយរំដោះយើងខ្ញុំ។** (ឃ្លាខាងក្រោមឆ្លើយដូចគ្នាដែរ)

-ឲ្យបាកផុតពីអន្តរាយគ្រប់បែបយ៉ាង ។
-ឲ្យបាកផុតពីបាបគ្រប់ជំពូក ។
-ឲ្យបាកផុតពីសេចក្តីស្លាប់អស់កល្បជានិច្ច ។
-ដោយព្រះគុណបុណ្យព្រះបុត្រាបានចាប់កំណើតជាមនុស្ស
-ដោយព្រះគុណព្រះយេស៊ូបានសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
-ដោយព្រះអំណោយដ៏ថ្លៃថ្លារបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ។

-យើងខ្ញុំជាអ្នកបាប

អង្គប្រជុំឆ្លើយ ៖ **សូមទ្រង់មេត្តាព្រះសណ្ដាប់យើងខ្ញុំ។**

-សូមព្រះអម្ចាស់មេត្តាប្រោសអស់បងប្អូន
ដែលព្រះអង្គជ្រើសរើសឲ្យទទួលអគ្គសញ្ញាជ្រមុជទឹកនៅពេលនេះ
បានរស់នៅដោយមានព្រះជន្មព្រះអង្គជាប់ក្នុងខ្លួនជានិច្ច ។

អង្គប្រជុំឆ្លើយ ៖ **សូមទ្រង់មេត្តាព្រះសណ្ដាប់យើងខ្ញុំ។**

-សូមព្រះយេស៊ូជាព្រះបុត្រានៃព្រះជាម្ចាស់ដែលគង់នៅជាដរាប ។

អង្គប្រជុំឆ្លើយ ៖ **សូមទ្រង់មេត្តាព្រះសណ្ដាប់យើងខ្ញុំ។**

-ឱ ព្រះគ្រីស្តអើយ សូមព្រះសណ្ដាប់យើងខ្ញុំ !

អង្គប្រជុំឆ្លើយ ៖ **ឱ ព្រះគ្រីស្តអើយ សូមព្រះសណ្ដាប់យើងខ្ញុំ។**

-ឱ ព្រះគ្រីស្តអើយ សូមទទួលពាក្យអង្វរយើងខ្ញុំ !

អង្គប្រជុំឆ្លើយ ៖ **ឱ ព្រះគ្រីស្តអើយ សូមទទួលពាក្យអង្វរយើងខ្ញុំ។**

ប្រសិនបើ មានអ្នកត្រៀមទទួលអគ្គសញ្ញាជ្រមុជទឹក លោកបូជាចារ្យលាតដៃ ដោយពោលពាក្យអធិដ្ឋានថា ៖

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ហើយមានព្រះជន្មគង់នៅជានិច្ច ! ព្រះអង្គគង់នៅជាមួយយើងខ្ញុំ តាមរយៈអគ្គសញ្ញានៃធម៌មេត្តាករុណារបស់ព្រះអង្គ ។
សូមព្រះអង្គប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ
ដល់អស់បងប្អូនដែលហៀបនឹងកើតជាថ្មីពីប្រភពទឹក ។
សូមឲ្យកាយវិការដែលយើងខ្ញុំប្រព្រឹត្តបានសក្ដិសិទ្ធិ
ដោយសារឫទ្ធានុភាពរបស់ព្រះអង្គ ។
យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

# ពិធីប្រទានពរលើទឹក

Benedictio aquæ baptismalis

៤៤ និង ៤៦ លោកបូជាចារ្យលាតដៃប្រទានពរលើទឹក ដោយពោលពាក្យអធិដ្ឋានថា ៖

បពិត្រព្រះជាម្ចាស់ !
ព្រះអង្គប្រើអគ្គសញ្ញាផ្សេងៗ ដើម្បីបង្ហាញការអស្ចារ្យនៃឫទ្ធានុភាពរបស់ព្រះអង្គ
ហើយទ្រង់ប្រើទឹកជានិមិត្តរូបនៃការសង្គ្រោះមនុស្សលោកតាំងពីដើមរៀងមក ។
កាលដើមដំបូងបង្អស់ ព្រះវិញ្ញាណរបស់ព្រះអង្គវេរាលើទឹក
ដើម្បីឲ្យទឹកបានស័ក្តិសិទ្ធិអាចផ្តល់ជីវិតថ្មីដល់បុត្រធីតារបស់ព្រះអង្គ ។
ក្រោយមក ទឹកជន់លិចផែនដី ជាទីសម្គាល់អំពីអគ្គសញ្ញាជ្រមុជទឹក
ព្រោះទឹកបានបំផ្លាញអំពើអាក្រក់របស់មនុស្ស
ហើយធ្វើឲ្យមនុស្សលោកកើតជាថ្មី និងសុចរិត ។

ក្រោយមក ព្រះអង្គប្រោសឲ្យជនជាតិអ៊ីស្រាអែលដើរឆ្លងកាត់សមុទ្រក្រហម
ដើម្បីឲ្យប្រជាជននេះ រួចពីកណ្តាប់ដៃខ្មាំងសត្រូវ
ដែលជានិមិត្តរូបនៃបុត្រធីតារបស់ព្រះអង្គបានរួចផុតពីអំណាចរបស់មារ ។
នៅពេលព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ
ទទួលពិធីជ្រមុជទឹកនៅក្នុងទន្លេយ័រដាន់ពីលោកយ៉ូហាន
ពេលនោះ ព្រះវិញ្ញាណដ៏វិសុទ្ធអភិសេកព្រះអង្គ ។
ក្រោយមកទៀត ពេលព្រះយេស៊ូនៅលើឈើឆ្កាង
ទ្រង់បណ្តោយឲ្យព្រះលោហិត និងទឹកហូរចេញពីមុខរបួសត្រង់ឆ្អឹងជំនីរ ។
លុះព្រះគ្រីស្តមានព្រះជន្មរស់ឡើងវិញ
ព្រះអង្គមានព្រះបន្ទូលទៅក្រុមសាវ័កថា ៖
«ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ឲ្យធ្វើជាសាវ័ក
ហើយធ្វើពិធីជ្រមុជទឹកឲ្យគេ
ក្នុងនាមព្រះបិតា និងព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ» ។

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ឥឡូវនេះ សូមព្រះអង្គមេត្តាប្រទានពរដល់ព្រះសហគមន៍ព្រះអង្គ
ដោយប្រោសឲ្យទឹកនេះ ទៅជាប្រភពនៃជីវិតថ្មីដុសឡើងសម្រាប់ព្រះសហគមន៍ ។
សូមព្រះវិញ្ញាណប្រោសឲ្យមនុស្សបានកើតជាថ្មីដោយសារទឹកនេះ ហើយលាងជម្រះអស់អ្នកជឿឲ្យបានស្អាតបរិសុទ្ធ និងផុតពីភាពសៅហ្មងគ្រប់យ៉ាង ដើម្បីឲ្យបានទៅជាបុត្រធីតារបស់ព្រះអង្គ ។

នៅពេលនេះ លោកបូជាចារ្យអាចយកទៀនព្រះជ័យដាក់ក្នុងទឹក មួយដង ឬបីដង ហើយពោលបន្តថា ៖

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
សូមប្រោសឲ្យព្រះវិញ្ញាណដ៏មានឫទ្ធានុភាពយាងមកគង់លើទឹកនេះ

លោកបូជាចារ្យកាន់ទៀនព្រះជ័យដាក់ក្នុងទឹក ហើយពោលបន្ត ៖

ដើម្បីឲ្យអស់អ្នកដែលជ្រមុជក្នុងទឹក បានរួមស្លាប់ជាមួយព្រះគ្រីស្ត
ហើយកើតជាថ្មីរួមរស់ជាមួយព្រះអង្គជានិច្ច ។
យើងខ្ញុំសូមទូលអង្វរព្រះអង្គដែលមានព្រះជន្មគង់នៅ សោយរាជ្យរួមជាមួយព្រះបិតា និងព្រះវិញ្ញាណដ៏វិសុទ្ធអស់កល្បជាអង្វែងតរៀងទៅ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

៤៥ និង ៤៧. ក្រោយមក គេយកទៀនព្រះជ័យចេញពីទឹក ហើយអង្គប្រជុំប្រកាសសាទរថា ៖
ឱ ប្រភពទឹកទាំងឡាយអើយ ចូរនាំគ្នាសសើរតម្កើងព្រះអម្ចាស់ !
សូមសូត្រ និងលើកតម្កើងព្រះអង្គអស់កល្បជាអង្វែងតរៀងទៅ ។

៤៨. បន្ទាប់មក លោកបូជាចារ្យនៅឈរ ហើយសួរសំណួរទៅកាន់អ្នកត្រៀមទទួលអគ្គសញ្ញាជ្រមុជទឹកតាមក្បួនពិធីបុណ្យជ្រមុជទឹក ដើម្បីឲ្យពួកគេប្រកាសពីការលះបង់អំពើអាក្រក់ ។ ក្នុងករណីបេក្ខជននៅជាកុមារ លោកបូជាចារ្យសួរឪពុកម្ដាយ ឬឪពុកម្ដាយធម៌ ។

ប្រសិនបើ អ្នកស្វែងយល់មិនទាន់ទទួលការលាបប្រេង (OS) ពួកគេត្រូវទទួលនៅពេលនេះ ។

៤៩. ក្រោយមក លោកបូជាចារ្យសួរអ្នកត្រៀមទទួលអគ្គសញ្ញាជ្រមុជទឹក ម្នាក់ៗ អំពីជំនឿរបស់ខ្លួន ។ ប្រសិនបើមានកុមារទទួលអគ្គសញ្ញាជ្រមុជទឹក លោកបូជាចារ្យសូមឲ្យឪពុកម្ដាយ និងឪពុកម្ដាយធម៌ រួមគ្នាប្រកាសជំនឿលើព្រះត្រៃឯក ដូចមានចែងនៅក្នុងក្បួនពិធី ។ ប្រសិនបើមានអ្នកទទួលអគ្គសញ្ញាជ្រមុជទឹកច្រើននាក់ ក្រោយពីលោកបូជាចារ្យបានទទួលចម្លើយពីបេក្ខជន លោកក៏សួរសំណួរដដែលទៅកាន់អង្គប្រជុំផងដែរ ។

៥០. ពេលប្រកាសជំនឿរួចហើយ លោកបូជាចារ្យធ្វើអគ្គសញ្ញាជ្រមុជទឹកជូនអស់អ្នកដែលព្រះជាម្ចាស់បានជ្រើសរើស ទាំងមនុស្សពេញវ័យ ទាំងកុមារ ។

៥១. បន្ទាប់ពីជ្រមុជទឹក លោកបូជាចារ្យលាបប្រេងគ្រីស្មាឲ្យកុមារ ។ លោកបំពាក់អាវសឲ្យអ្នកពេញវ័យ និងកុមារ ។ ក្រោយមក លោកបូជាចារ្យ ឬលោកឧបដ្ឋាកទទួលទៀនព្រះជ័យពីដៃអ្នកបម្រើពិធីបុណ្យ ហើយចម្លងពន្លឺទៀនឲ្យអ្នកដែលទើបទទួលអគ្គសញ្ញាជ្រមុជទឹក ។ ចំពោះកុមារ គេមិនធ្វើពិធី «អេផាថា» (ប្រែថា ចូរបើកឡើង) ។

៥២. ក្រោយមក ទាំងអស់គ្នាដង្ហែត្រឡប់ទៅកាន់ទីសក្ការបូជា ទាំងកាន់ទៀនឆេះរៀងៗខ្លួន ដោយច្រៀងថា Vidi aquam មានន័យថា (ខ្ញុំបានឃើញទឹក...) ឬច្រៀងបទមួយផ្សេងទៀត (លេខ ៥៦) ។

៥៣. ប្រសិនបើមានអ្នកពេញវ័យទទួលអគ្គសញ្ញាជ្រមុជទឹក លោកអភិបាល ឬក្នុងករណីអវត្តមានលោកបូជាចារ្យធ្វើពិធីលាបថ្វាសឲ្យគេនៅទីសក្ការបូជាតាមក្បួនពិធី ។

## ប្រទានពរលើទឹក

Benedictio aquæ

៥៤. ប្រសិនបើ គ្មានអ្នកត្រៀមទទួលអគ្គសញ្ញាជ្រមុជទឹក នោះលោកបូជាចារ្យប្រទានពរលើទឹកដោយពោលថា ៖

បងប្អូនជាទីស្រឡាញ់ !

សូមបងប្អូនអង្វរព្រះជាអម្ចាស់ប្រទានពរលើទឹកដែលប្រោះលើយើងខ្ញុំ
ដើម្បីរំឭកពីអគ្គសញ្ញាជ្រមុជទឹកដែលយើងខ្ញុំបានទទួល ។
សូមព្រះអង្គលាងជម្រះយើងខ្ញុំជាថ្មី ដើម្បីឲ្យយើងខ្ញុំភ្ជាប់ចិត្តជាមួយព្រះវិញ្ញាណដ៏វិសុទ្ធកាន់តែខ្លាំងឡើងៗ ។

បន្ទាប់ពីនៅស្ងៀមស្ងាត់បន្តិច លោកលាតដៃដោយអធិដ្ឋានថា ៖

បពិត្រព្រះជាអម្ចាស់យើងខ្ញុំ !

សូមព្រះអង្គគង់នៅជាមួយយើងខ្ញុំពេញមួយយប់នេះ ។

សូមព្រះអង្គប្រទានពរលើទឹកនេះទុកជាប្រយោជន៍

ឲ្យយើងខ្ញុំនឹករឭកដល់ស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះអង្គ ហើយរិតតែប្រសើរជាងនេះទៅទៀត

គឺនឹកដល់ការសង្គ្រោះដែលមកពីព្រះអង្គ ។

ទឹកជាអំណោយទានរបស់ព្រះអង្គដែលធ្វើឲ្យដីបង្កើតផលផ្លែល្អ ហើយទឹកក៏ផ្តល់ភាពត្រជាក់ត្រជុំ

និងលាងជម្រះរូបកាយយើងខ្ញុំឲ្យបានស្អាត ។

ព្រះអង្គក៏ប្រើទឹកនេះ ជាសញ្ញាសម្គាល់នៃព្រះហឫទ័យមេត្តាករុណា

ដោយសារទឹក ទ្រង់បានរំដោះប្រជារាស្ត្រព្រះអង្គឲ្យរួចពីទាសភាព

និងបំបាត់ភាពស្រេកឃ្លានរបស់ពួកគេនៅវាលរហោស្ថាន ។

តាមរយៈទឹកនេះ ព្យាការីទាំងឡាយបានប្រកាសពីសម្ពន្ធមេត្រីថ្មី

ដែលព្រះអង្គចងជាមួយមនុស្សជាតិ ។

ពេលព្រះគ្រីស្តជ្រមុជក្នុងទឹកទន្លេយ័រដាន់ ទឹកនេះក៏បានវិសុទ្ធ

ហើយប្រោសយើងខ្ញុំជាមនុស្សអាក្រក់ឲ្យមានជីវិតល្អដូចដើមវិញ ។

ដូច្នេះ ទឹកនេះរំឭកពីអគ្គសញ្ញាជ្រមុជទឹកដែលយើងខ្ញុំបានទទួល ។

សូមព្រះអង្គប្រទានឲ្យយើងខ្ញុំមានអំណរសប្បាយជាមួយអស់បងប្អូន

ដែលទើបទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងបុណ្យចម្លងនេះផង ។ យើងខ្ញុំសូមអង្វរព្រះអង្គ តាមរយៈព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

# ពិធីលះបង់ចោលមារ និងពិធីប្រកាសជំនឿ

Renovatio promissionum baptismalium

៥៥. នៅពេលពិធីជ្រមុជទឹក (និង អគ្គសញ្ញាលាបថ្ងាស) ឬពិធីបាចទឹកព្រះពរចប់សព្វគ្រប់ហើយ អង្គប្រជុំក្រោកឈរ[១៩០]កាន់ទៀនដែលឆេះដើម្បីប្រកាសសាឡើងវិញនូវពាក្យសន្យាដែលគេបានធ្វើក្នុងពិធីជ្រមុជទឹក លើកលែងតែ គេបានប្រកាសរួចហើយ (សូមអានលេខ ៤៩) ។

លោកបូជាចារ្យពោលទៅកាន់អង្គប្រជុំថា ៖

បងប្អូនជាទីស្រឡាញ់ !
តាមគម្រោងការដ៏អស្ចារ្យនៃបុណ្យចម្លង
អគ្គសញ្ញាជ្រមុជទឹក នាំឲ្យយើងកប់ក្នុងផ្នូររួមជាមួយព្រះគ្រីស្ត
ដើម្បីឲ្យយើងដើរជាមួយព្រះអង្គក្នុងជីវិតថ្មី ។
ឥឡូវនេះរដូវសែសិបថ្ងៃចប់ហើយ ចូរប្រកាសជាថ្មីនូវពាក្យដែលយើងបានសន្យា
ក្នុងឱកាសទទួលអគ្គសញ្ញាជ្រមុជទឹក ថាយើងបោះបង់ចោលមារ
ព្រមទាំងសន្យាថា បម្រើព្រះជាម្ចាស់ក្នុងព្រះសហគមន៍កាតូលិកដ៏វិសុទ្ធ ។
ដូច្នេះហើយ ខ្ញុំសូមសួរទៅបងប្អូនថា ៖

លោកបូជាចារ្យ ៖ តើបងប្អូនសុខចិត្តលះបង់មារសាតាំងដែរឬទេ?

អង្គប្រជុំឆ្លើយ ៖ ខ្ញុំសុខចិត្ត

លោកបូជាចារ្យ ៖
តើបងប្អូនសុខចិត្តឈប់បម្រើកិច្ចការរបស់មារសាតាំងដែរឬទេ?

អង្គប្រជុំឆ្លើយ ៖ ខ្ញុំសុខចិត្ត

លោកបូជាចារ្យ ៖
តើបងប្អូនសុខចិត្តបដិសេធល្បិចកលរបស់មារសាតាំងដែរឬទេ?

អង្គប្រជុំឆ្លើយ ៖ ខ្ញុំសុខចិត្ត

[១៩០] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ ស្តីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ អង្គប្រជុំទាំងមូលអង្គុយបត់ជើងលើកន្ទេល ។

ឬ

លោកបូជាចារ្យ ៖ តើបងប្អូនសុខចិត្តលះបង់បោលអំពើបាប
ដើម្បីរស់នៅដោយមានសេរីភាពជាបុត្រធិតារបស់ព្រះជាម្ចាស់ដែរឬទេ?

អង្គប្រជុំឆ្លើយ ៖ ខ្ញុំសុខចិត្ត

លោកបូជាចារ្យ ៖ តើបងប្អូនសុខចិត្តលះបង់បោលការល្បួងរបស់មារ
ដើម្បីកុំឲ្យធ្លាក់ខ្លួនជាខ្ញុំបម្រើរបស់មារដែរឬទេ?

អង្គប្រជុំឆ្លើយ ៖ ខ្ញុំសុខចិត្ត

លោកបូជាចារ្យ ៖ តើបងប្អូនសុខចិត្តលះបង់បោលមារសាតាំង
ជាមេ និងជាម្ចាស់នៃអំពើបាបដែរឬទេ?

អង្គប្រជុំឆ្លើយ ៖ ខ្ញុំសុខចិត្ត

ប្រសិនបើមានសេចក្ដីត្រូវការ ក្រុមលោកអភិបាលអាចសម្រួលសំណួរទីពីរខាងលើតាមកាលៈទេសៈ ។

ក្រោយមក លោកបូជាចារ្យសួរបន្តថា ៖

តើបងប្អូនជឿលើព្រះជាម្ចាស់ ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ
ជាព្រះបង្កើតមេឃ និងដី ដែរឬទេ?

អង្គប្រជុំឆ្លើយ ៖ ខ្ញុំជឿ

លោកបូជាចារ្យ ៖ តើបងប្អូនជឿលើព្រះយេស៊ូគ្រីស្ត
ជាព្រះបុត្រាតែមួយនៃព្រះបិតា ជាព្រះអម្ចាស់យើងខ្ញុំ
ជឿថា ព្រះអង្គបានប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី
ទ្រង់បានសោយទិវង្គត ព្រះសពព្រះអង្គត្រូវគេបញ្ចុះ
ជឿថា ព្រះអង្គមានព្រះជន្មរស់ឡើងវិញ ពីចំណោមមនុស្សស្លាប់
និងគង់ខាងស្ដាំព្រះបិតា ដែរឬទេ?

អង្គប្រជុំឆ្លើយ ៖ ខ្ញុំជឿ

លោកបូជាចារ្យ ៖ តើបងប្អូនជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ
ជឿលើព្រះសហគមន៍កាតូលិកដ៏វិសុទ្ធ និងសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ
ជឿថា មានការលើកលែងទោសមនុស្សឲ្យរួចពីបាប
ហើយរូបកាយមនុស្សនឹងរស់ឡើងវិញ
ព្រមទាំងមានជីវិតរស់នៅអស់កល្បជានិច្ច ដែរឬទេ?
អង្គប្រជុំឆ្លើយ ៖ ខ្ញុំជឿ

រួចហើយ លោកបូជាចារ្យពោលបន្តថា ៖
បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ
ជាព្រះបិតារបស់ព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់យើងខ្ញុំ
ព្រះអង្គប្រោសឲ្យយើងខ្ញុំមានជីវិតថ្មីដោយសារទឹក និងដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ
ហើយព្រះអង្គលើកលែងទោសឲ្យយើងខ្ញុំបានរួចពីបាប ។
សូមព្រះអង្គមេត្តាថែរក្សាយើងខ្ញុំដោយព្រះហឫទ័យប្រណីសណ្តោស
ដើម្បីទទួលជីវិតរស់នៅអស់កល្បជានិច្ច
ក្នុងអង្គព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់យើងខ្ញុំ ។
អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

៥៦. លោកបូជាចារ្យបាចទឹកព្រះពរលើអង្គប្រជុំ ក្នុងពេលគេកំពុងច្រៀង ៖
បទចម្រៀង
ខ្ញុំបានឃើញទឹកខ្វាយចេញពីខាងស្តាំព្រះវិហារ អាលេលូយ៉ា...
យើងអាចច្រៀងបទមួយផ្សេងទៀតដែលមានអត្ថន័យដូចគ្នា ។

៥៧. អ្នកទើបទទួលអគ្គសញ្ញាជ្រមុជទឹក (ពន្លកថ្មី) វិលត្រឡប់ទៅអង្គុយជាមួយគ្រីស្តបរិស័ទ ។ ប្រសិនបើធ្វើពិធីប្រទានពរលើអាងជ្រមុជទឹកហើយ ទឹកព្រះពរដែលនៅសល់ពីធ្វើអគ្គសញ្ញាជ្រមុជទឹកត្រូវយកទៅចាក់ក្នុងអាងជ្រមុជទឹកវិញ ។ ប្រសិនបើគ្មានពិធីប្រទានពរលើអាង ជ្រមុជទឹកទេ ទឹកព្រះពរដែលនៅសល់ត្រូវទុកនៅកន្លែងមួយសមរម្យ ។

៥៨. បន្ទាប់ពីបាចទឹកព្រះពរហើយ គ្មានការប្រកាសជំនឿទេ ។ លោកបូជាចារ្យត្រឡប់ទៅអង្គុយនៅកន្លែងដើមវិញ ហើយចាប់ផ្តើមពាក្យអង្វរសាកល ដោយមានពន្លកថ្មីចូលរួមជាលើកដំបូង ។

## ភាគទី បួន

# ពិធីអរព្រះគុណដ៏វិសុទ្ធ

LITURGIA EUCHARISTICA

៥៩. លោកបូជាចារ្យទៅកាន់តុសក្ការបូជា ហើយចាប់ផ្ដើមពិធីអរព្រះគុណដ៏វិសុទ្ធដូចធម្មតា ។

៦០. គួរឲ្យអ្នកទើបទទួលជ្រមុជទឹកចូលរួមហែតង្វាយ ដោយកាន់នំប៉័ង និងស្រា ។ ប្រសិនបើអ្នកទើបជ្រមុជទឹកជាកុមារ គួរឲ្យឪពុកម្ដាយ ឬឪពុកម្ដាយធម៌កាន់តង្វាយជំនួសវិញ ។

៦១. ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ !
សូមព្រះអង្គទទួលពាក្យអង្វររបស់យើងខ្ញុំ
រួមជាមួយតង្វាយ និងសក្ការបូជាដែលយើងខ្ញុំថ្វាយ ។
ក្នុងគម្រោងការដ៏អស្ចារ្យនៃបុណ្យចម្លង ព្រះអង្គបានចាប់ផ្ដើមប្រោសយើងខ្ញុំ
ឲ្យជាសះស្បើយដោយសារឫទ្ធានុភាពរបស់ព្រះអង្គ
សូមព្រះអង្គនាំយើងខ្ញុំឆ្ពោះទៅកាន់ជីវិតអស់កល្បជានិច្ចផង ។
យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្ដជាព្រះអម្ចាស់ ។

៦២. ធម៌ប្រារព្ធទី១នៃបុណ្យចម្លង៖ អាថ៌កំបាំងដ៏អស្ចារ្យនៃបុណ្យចម្លង (...នៅរាត្រីដ៏ពិសិដ្ឋនេះ...) សូមអាននៅទំព័រ... ។

៦៣. នៅរាល់ពាក្យអធិដ្ឋានអរព្រះគុណដ៏វិសុទ្ធ យើងត្រូវអង្វរព្រះអង្គឲ្យអ្នកទើបទទួលអគ្គសញ្ញាជ្រមុជទឹក និងឪពុកម្ដាយធម៌របស់គេ តាមរបៀបក្បួនពិធីអភិបូជាក្រុងរ៉ូម និងក្បួនពិធីផ្សេងៗក្រុងរ៉ូម ។

៦៤. មុននឹងពោលថា នេះជាកូនចៀមរបស់ព្រះជាម្ចាស់... (Ecce Agnus Dei) លោកបូជាចារ្យពន្យល់ជាសង្ខេបទៅកាន់អ្នកទើបទទួលអគ្គសញ្ញាជ្រមុជទឹក អំពីការទទួលព្រះកាយព្រះគ្រីស្ដលើកដំបូងរបស់ពួកគេ និងអំពីភាពដ៏ឧត្ដុង្គឧត្ដមនៃការអាថ៌កំបាំងដ៏អស្ចារ្យ គឺព្រះកាយ ព្រះគ្រីស្ដដែលជាកំពូលនៃដំណើរការអប់រំជំនឿ និងជាស្នូលនៃការរស់នៅជាគ្រីស្ដបរិស័ទ ។

៦៥. គួរឲ្យអ្នកទើបទទួលអគ្គសញ្ញាជ្រមុជទឹក ទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត រួមជាមួយឪពុកម្ដាយធម៌ ឪពុកម្ដាយ និងស្វាមីភរិយាកាតូលិក ព្រមទាំងអ្នកអប់រំជំនឿរបស់គេ ។ បើមានការអនុញ្ញាតពីលោកអភិបាលព្រះសហគមន៍ គ្រីស្តបរិស័ទអាចទទួលទាំងព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ។

៦៦. ពាក្យបន្ទរពេលទទួលព្រះកាយព្រះគ្រីស្ត ១កូរិនថូស ៥.៧-៨

ព្រះគ្រីស្តធ្វើជាយញ្ញបូជារបស់យើងខ្ញុំ ក្នុងឱកាសបុណ្យចម្លងរួចស្រេចទៅហើយ ។
ហេតុនេះ ចូរយើងធ្វើពិធីជប់លៀងបុណ្យចម្លង
ដោយប្រើនំបុ័ងឥតមេ ជាសញ្ញានៃចិត្តស្មោះត្រង់ និងសេចក្តីពិត អាលេលូយ៉ា ។

ទំនុកតម្កើង ១១៨ (១១៧) គួរសូត្រយ៉ាងឱឡារិក ។

៦៧. ពាក្យអរព្រះគុណព្រះជាម្ចាស់ក្រោយពីទទួលព្រះកាយព្រះគ្រីស្ត

ឱ ព្រះអម្ចាស់អើយ !
សូមចាក់បង្ហូរព្រះវិញ្ញាណនៃសេចក្តីស្រឡាញ់របស់ព្រះអង្គលើយើងខ្ញុំ ។
សូមប្រោសឲ្យយើងខ្ញុំដែលព្រះអង្គបានចិញ្ចឹមដោយព្រះកាយព្រះគ្រីស្ត
មានចិត្តថ្លើមតែមួយក្នុងព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ។
យើងខ្ញុំសូមអង្វរព្រះអង្គ តាមរយៈព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់ ។

៦៨. ការប្រទានពរយ៉ាងឱឡារិក

សូមព្រះដ៏មានឫទ្ធានុភាពសព្វប្រការ
ប្រទានព្រះពរដល់អស់បងប្អូននៅក្នុងថ្ងៃបុណ្យចម្លងដ៏ឱឡារិកនេះ
ហើយសូមព្រះអង្គការពារអស់បងប្អូនឲ្យរួចផុតពីបាបនានា
ដោយព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

សូមព្រះអង្គប្រទានរង្វាន់អមតៈដែលជាជីវិតអស់កល្បជានិច្ចដល់បងប្អូន ក្នុងអង្គព្រះបុត្រាតែមួយដែលមានព្រះជន្មរស់ឡើងវិញ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

ថ្ងៃដែលព្រះអង្គសោយទុក្ខលំបាកបានចប់ហើយ សូមឲ្យបងប្អូនដែលប្រារព្ធបុណ្យចម្លងដោយចិត្តរីករាយ ចូលរួមបុណ្យនៅស្ថានបរមសុខជាមួយព្រះគ្រីស្ត ដែលជួយឲ្យបងប្អូនមានអំណរសប្បាយអស់កល្បជានិច្ច ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

សូមព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ
ប្រទានព្រះពរ និងគង់នៅជាមួយបងប្អូនអស់កល្បជានិច្ច ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

តាមកាលៈទេសៈ លោកបូជាចារ្យអាចប្រើរបៀបប្រទានពរចុងក្រោយតាមក្បួនពិធីទទួលអគ្គសញ្ញាជ្រមុជទឹករបស់មនុស្សពេញវ័យ ឬកុមារ ។

៦៩. ប្រសិនបើគ្មានលោកឧបដ្ឋាក លោកបូជាចារ្យច្រៀង ឬពោលថា ៖

អភិបូជាចប់ហើយ ព្រះជាម្ចាស់ចាត់បងប្អូនឲ្យទៅ
អាលេលូយ៉ា អាលេលូយ៉ា ។

អង្គប្រជុំឆ្លើយ ៖ សូមអរព្រះគុណព្រះជាម្ចាស់
អាលេលូយ៉ា អាលេលូយ៉ា ។

គេប្រើរបៀបខាងលើនេះ ក្នុងរយៈពេល ៨ថ្ងៃ នៃសប្ដាហ៍បុណ្យចម្លង ។

៧០. រាល់ពេលប្រារព្ធពិធីបុណ្យផ្សេងៗក្នុងរដូវបុណ្យចម្លង សូមអុជទៀនព្រះជ័យ ។

# អភិបូជានៅពេលថ្ងៃ

Ad Missam in die

៧១. ពាក្យបន្ទរពេលចូល ស្រង់ពាក្យខ្លះពីទំនុកតម្កើងលេខ ១៣៩ (១៣៨) ១៨.៥-៦

កាលណាទូលបង្គំភ្ញាក់ឡើង
ទូលបង្គំនៅជាមួយនឹងព្រះអង្គនៅឡើយ អាលេលូយ៉ា ។
ព្រះអង្គបានដាក់ព្រះហស្តលើទូលបង្គំ អាលេលូយ៉ា ។
អស្ចារ្យមែន ចំពោះព្រះប្រាជ្ញាញាណរបស់ព្រះអង្គ អាលេលូយ៉ា ។

ឬ លូកា ២៤.៣៤, វវ ១,៦

ព្រះអម្ចាស់មានព្រះជន្មរស់ឡើងវិញពិតប្រាកដមែន អាលេលូយ៉ា ។
សូមលើកតម្កើងសិរីរុងរឿង និងព្រះចេស្ដារបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ អាលេលូយ៉ា អាលេលូយ៉ា ។

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

៧២. ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
នៅថ្ងៃនេះ ព្រះអង្គប្រោសព្រះបុត្រាតែមួយឲ្យមានជ័យជម្នះលើសេចក្ដីស្លាប់
និងបើកផ្លូវឲ្យយើងខ្ញុំឆ្ពោះទៅកាន់ភាពអស់កល្បជានិច្ច ។
ពេលប្រារព្ធពិធីបុណ្យព្រះអម្ចាស់មានព្រះជន្មរស់ឡើងវិញយ៉ាងឱឡារិកនេះ
សូមព្រះអង្គប្រោសប្រណីឲ្យយើងខ្ញុំរស់ឡើងវិញក្នុងពន្លឺនៃជីវិតថ្មី
ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ។
យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះអម្ចាស់យេស៊ូគ្រីស្ត
ជាព្រះបុត្រាដែលមានព្រះជន្មគង់នៅ ព្រមទាំងសោយរាជ្យរួមជាមួយព្រះអង្គ
និងព្រះវិញ្ញាណដ៏វិសុទ្ធអស់កល្បជាអង្វែងតរៀងទៅ ។

សូត្រធម៌ប្រកាសជំនឿ ។

## ៧៣. ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ !
យើងខ្ញុំមានចិត្តរីករាយនាឱកាសបុណ្យចម្លងដ៏សែនសប្បាយនេះ
យើងខ្ញុំសូមថ្វាយសក្ការបូជា
ដែលធ្វើឲ្យព្រះសហគមន៍របស់ព្រះអង្គកើតជាថ្មី និងទទួលកម្លាំងយ៉ាងអស្ចារ្យ ។
យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់ ។

៧៤. ធម៌ប្រារព្ធទី១ ក្នុងរដូវបុណ្យចម្លង ៖ អាថ៌កំបាំងដ៏អស្ចារ្យនៃបុណ្យចម្លង ទំព័រ ៤៣៨ ។ ក្នុងធម៌ប្រារព្ធទី១ យើងនឹងប្រើពាក្យដូចតទៅ ៖ នៅរាត្រីដ៏ពិសិដ្ឋនេះ/នៅថ្ងៃដ៏ពិសិដ្ឋនេះ/នៅពេលនេះ ។ ពេលយើងប្រើធម៌អរព្រះគុណដ៏វិសុទ្ធទី១ តាមសាសនក្រឹត្យក្រុងរ៉ូម សូមជ្រើសរើសពាក្យអធិដ្ឋានអង្វរសម្រាប់មនុស្សទាំងឡាយដែលត្រូវនឹងបុណ្យចម្លង (លេខ ៨៦ ក្នុង ក្បួនពិធីអភិបូជា) ។ ពេលអធិដ្ឋានបន្ត សូមជ្រើសរើសពាក្យអធិដ្ឋានដែលត្រូវនឹងបុណ្យចម្លង (លេខ ៨៧ ក្នុងក្បួនពិធីអភិបូជា) ។

## ៧៥. ពាក្យបន្ទរពេលទទួលព្រះកាយព្រះគ្រីស្ត

១កូរិនថូស ៥,៧-៨

ព្រះគ្រីស្តជាយញ្ញបូជារបស់យើងខ្ញុំ
ក្នុងឱកាសបុណ្យចម្លងរួចស្រេចទៅហើយ អាលេលូយ៉ា ។
ហេតុនេះ ចូរយើងធ្វើពិធីជប់លៀងបុណ្យចម្លង ដោយប្រើនំបុ័ងឥតមេ
ជាសញ្ញានៃចិត្តស្មោះត្រង់ និងសេចក្តីពិត អាលេលូយ៉ា អាលេលូយ៉ា ។

## ៧៦ ពាក្យអធិដ្ឋានក្រោយពេលទទួលព្រះកាយព្រះគ្រីស្ត

ឱ ព្រះជាម្ចាស់អើយ !
សូមទ្រង់ទតមកព្រះសហគមន៍របស់ព្រះអង្គ
ដោយព្រះហឫទ័យស្រឡាញ់ និងប្រណីសណ្តោសដែលមិនចេះរីងស្ងួត ។
សូមឲ្យព្រះសហគមន៍ទទួលកម្លាំងពីអាថ៌កំបាំងដ៏អស្ចារ្យនៃបុណ្យចម្លង
និងចូលក្នុងសិរីរុងរឿងរបស់ព្រះគ្រីស្តជាព្រះអម្ចាស់យើងខ្ញុំដែលមានព្រះជន្មរស់ឡើងវិញ ។

៧៧. ពេលប្រទានព្រះពរនៅបញ្ចប់អភិបូជា លោកបូជាចារ្យអាចប្រើពាក្យប្រទានពរយ៉ាងឱឡារិក ឲ្យបានសមរម្យសម្រាប់ពិធីអភិបូជានារាត្រីបុណ្យចម្លង (ទំព័រ ២៨៦ លេខ ៦៨) ។

៧៨. នៅពេលបាត់អង្គប្រជុំឲ្យទៅ លោកបូជាចារ្យអាចច្រៀង (ដូចលេខ ៦៩) ឬពោលថា ៖

អភិបូជាចប់ហើយ ព្រះជាម្ចាស់បាត់បងប្អូនឲ្យទៅ
អាលេលូយ៉ា អាលេលូយ៉ា ។

ឬ

សូមអស់បងប្អូនអញ្ជើញឲ្យបានសុខសាន្ត អាលេលូយ៉ា អាលេលូយ៉ា

អង្គប្រជុំឆ្លើយ ៖ សូមអរព្រះគុណព្រះជាម្ចាស់ អាលេលូយ៉ា អាលេលូយ៉ា ។

# ថ្ងៃចន្ទ នៃសប្ដាហ៍បុណ្យចម្លង

FERIA II INFRA OCTAVAM PASCHÆ

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ជារៀងរាល់ឆ្នាំ ព្រះអង្គពង្រីកព្រះសហគមន៍របស់ព្រះអង្គ
ដោយមានអ្នកថ្មីៗជឿទៅលើព្រះគ្រីស្ត ហើយទទួលអគ្គសញ្ញាជ្រមុជទឹក ។
សូមព្រះអង្គមេត្តាប្រោសឲ្យបុត្រធីតារបស់ព្រះអង្គ
រស់នៅស្របតាមអគ្គសញ្ញាដែលខ្លួនបានទទួលនោះ និងមានជំនឿកាន់តែមាំមួនឡើង ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ !
យើងខ្ញុំគ្មានអ្វីលើកថ្វាយព្រះអង្គក្រៅពីកាយ វាចា ចិត្ត
សូមព្រះអង្គមេត្តាទទួលដោយអនុគ្រោះ ។
យើងខ្ញុំបានទទួលជីវិតថ្មីដោយសារជំនឿលើព្រះអង្គ និងអគ្គសញ្ញាជ្រមុជទឹក
សូមប្រោសឲ្យយើងខ្ញុំបានចូលរួមជាមួយព្រះបុត្រា
ដែលសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
ហើយគង់នៅអស់កល្បជាអង្វែងតរៀងទៅ ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៣៨ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ដែលបានប្រទានជីវិតថ្មីឲ្យយើងខ្ញុំ ។
ព្រះអង្គប្រោសឲ្យព្រះយេស៊ូទទួលព្រះជន្មផ្ទាល់របស់ព្រះអង្គ
ហើយទ្រង់ក៏បានប្រោសឲ្យយើងខ្ញុំទៅជាបុត្រធីតារបស់ព្រះអង្គដែរ
សូមព្រះអង្គមេត្តាពង្រឹងជំនឿ និងសេចក្ដីសង្ឃឹមរបស់យើងខ្ញុំជានិច្ច ។

# ថ្ងៃអង្គារ នៃសប្ដាហ៍បុណ្យចម្លង

FERIA III INFRA OCTAVAM PASCHÆ

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រោសឲ្យយើងខ្ញុំជាសះស្បើយនៅពេលបុណ្យចម្លងនេះ ដោយចាក់បង្ហូរព្រះពរ និងព្រះអំណោយទាន គឺជីវិតថ្មីដល់យើងខ្ញុំ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានសេរីភាពពេញទី
ដើម្បីឲ្យថ្ងៃណាមួយយើងខ្ញុំមានអំណរយ៉ាងពេញលេញ ចូលរួមជាមួយព្រះអង្គនៅស្ថានបរមសុខ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
សូមព្រះអង្គមេត្តាទទួលតង្វាយពីព្រះសហគមន៍ដោយអនុគ្រោះ ។
សូមទ្រង់ព្រះមេត្តាការពារយើងខ្ញុំ
និងបង្វែរចិត្តរបស់យើងខ្ញុំឲ្យភ្ជាប់ចិត្តនឹងព្រះអង្គជានិច្ច ។

ធម៌ប្រារព្ធទី ១ ក្នុងរង្វង់បុណ្យចម្លង ទំព័រ ៤៣៨ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គសព្វព្រះហឫទ័យប្រោសឲ្យយើងខ្ញុំ
ដែលទទួលអគ្គសញ្ញាជ្រមុជទឹកបានទៅជាបុត្រធីតារបស់ព្រះអង្គ ។
សូមប្រោសឲ្យយើងខ្ញុំមានចិត្តប្រាថ្នាសុភមង្គលអស់កល្បជានិច្ច ។

# ថ្ងៃពុធ នៃសប្ដាហ៍បុណ្យចម្លង

FERIA IV INFRA OCTAVAM PASCHÆ

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានធម៌មេត្ដាករុណាយ៉ាងក្រៃលែង !
ព្រះអង្គប្រទានសុភមង្គលមកយើងខ្ញុំ
តាមរយៈបុណ្យចម្លងជារៀងរាល់ឆ្នាំ ។
សូមព្រះអង្គប្រោសប្រណីយើងខ្ញុំឲ្យរស់នៅដោយសុចរិត និងមានអំណរសប្បាយ
អស់កល្បជានិច្ច ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
សូមព្រះអង្គមេត្ដាទទួលសក្ការបូជា
ដែលលោះបាបមនុស្សលោកដោយអនុគ្រោះ ។ សូមព្រះអង្គសព្វព្រះហឫទ័យឲ្យ
យើងខ្ញុំ
បានទទួលការសង្គ្រោះទាំងផ្លូវកាយ និងផ្លូវចិត្ត ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៣៨ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
គ្រប់ពេលយើងខ្ញុំទទួលព្រះកាយព្រះគ្រីស្ដ
ដោយចិត្តគោរពយ៉ាងជ្រាលជ្រៅ
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យទទួលកម្លាំង
ដើម្បីលាងជម្រះរបៀបរស់នៅចាស់ ហើយបែរមករករបៀបរស់នៅថ្មីវិញ ។

# ថ្ងៃព្រហស្បតិ៍ នៃសប្ដាហ៍បុណ្យចម្លង

FERIA V INFRA OCTAVAM PASCHÆ

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ! ព្រះអង្គសព្វព្រះហឫទ័យប្រមែប្រមូលមនុស្សគ្រប់ជាតិសាសន៍ ឲ្យរួបរួមគ្នាក្នុងមហាគ្រួសារតែមួយ ។ សូមព្រះអង្គមេត្តាប្រោសឲ្យអស់អ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹក មានចិត្តថ្លើមតែមួយ មានជំនឿតែមួយ និងសេចក្ដីស្រឡាញ់តែមួយ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
សូមព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយ
ដែលយើងខ្ញុំថ្វាយដោយចិត្តរីករាយ
និងសូមផ្ដល់កម្លាំងឲ្យអស់អ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹក ។
សូមព្រះអង្គមេត្តាជួយយើងខ្ញុំ
ឲ្យមានសេចក្ដីសង្ឃឹមលើព្រះអង្គដែលគង់នៅស្ថានបរមសុខ ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៣៨ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
សូមព្រះអង្គព្រះសណ្ដាប់ពាក្យអង្វររបស់យើងខ្ញុំ
ព្រះអង្គបានលោះយើងខ្ញុំ ដោយភាពជីវិតសុទ្ធបំផុតរបស់ព្រះអង្គ ។
សូមព្រះអង្គផ្ដល់កម្លាំងមកយើងខ្ញុំក្នុងពេលឥឡូវនេះ
ហើយជាក់ច្បាស់ថាយើងខ្ញុំនឹងមានសុភមង្គលអស់កល្បជានិច្ច ។

# ថ្ងៃសុក្រ នៃសប្ដាហ៍បុណ្យចម្លង

FERIA VI INFRA OCTAVAM PASCHÆ

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ
ហើយដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច !
ព្រះអង្គបានប្រទានការអាថ៌កំបាំងដ៏អស្ចារ្យនៃបុណ្យចម្លងដល់យើងខ្ញុំ
ដើម្បីសម្រុះសម្រួលជាមួយមនុស្សលោកក្នុងសម្ពន្ធមេត្រីរបស់ព្រះអង្គ ។
សូមព្រះអង្គមេត្តារៀបចំចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យយើងខ្ញុំប្រព្រឹត្តគ្រប់កិច្ចការស្របតាមជំនឿ ដែលយើងខ្ញុំប្រកាស ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
តាមរយៈតង្វាយនៃបុណ្យចម្លង សូមព្រះអង្គពង្រឹងទំនាក់ទំនងដ៏ល្អប្រសើររវាងយើងខ្ញុំ និងព្រះអង្គ ។
សូមព្រះអង្គបង្វែរចិត្តយើងខ្ញុំចេញពីបំណងប្រាថ្នាលោកីយ៍
ឲ្យផ្ចង់ចិត្តទៅរកសម្បត្តិនៃស្ថានបរមសុខវិញ ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៣៨ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
សូមព្រះអង្គថែរក្សាអស់អ្នកដែលព្រះអង្គបានសង្គ្រោះ
ដោយព្រះហឫទ័យដ៏សប្បុរសរបស់ព្រះអង្គ
គឺអស់អ្នកដែលព្រះអង្គបានលោះ ដោយសារព្រះបុត្រាសោយទុក្ខលំបាក ។
ហេតុនេះ សូមព្រះអង្គប្រោសឲ្យពួកគេមានអំណរសប្បាយ
ក្នុងអង្គព្រះបុត្រាដែលមានព្រះជន្មរស់ឡើងវិញ ។

# ថ្ងៃសៅរ៍ នៃសប្ដាហ៍បុណ្យចម្លង

SABBATO INFRA OCTAVAM PASCHÆ

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ដោយអគ្គសញ្ញាជ្រមុជទឹក
ព្រះអង្គសព្វព្រះហឫទ័យឲ្យបុត្រធីតារបស់ព្រះអង្គ
កើនចំនួនឡើងជាលំដាប់ ។
សូមទ្រង់ព្រះមេត្តាថែរក្សាបុត្រធីតាដែលទើបនឹងកើតថ្មីនេះ
បានទទួលជីវិតអស់កល្បជានិច្ចរួមជាមួយព្រះគ្រីស្ត ។

ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
សូមប្រោសប្រណីឲ្យយើងខ្ញុំទទួលអំណរសប្បាយ
ដែលមកពីអាថ៌កំបាំងដ៏អស្ចារ្យនៃបុណ្យចម្លងនេះ
ហើយសូមប្រទានឲ្យយើងខ្ញុំមានកម្លាំងឥតឈប់ឈរ
ដែលបណ្ដាលឲ្យយើងខ្ញុំមានក្ដីអំណរជានិច្ច ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៣៨ ។

ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
សូមព្រះអង្គមេត្តាទតមកប្រជារាស្ត្ររបស់ព្រះអង្គ ។
ព្រះអង្គសព្វព្រះហឫទ័យឲ្យយើងខ្ញុំទទួលជីវិតថ្មី
ដោយចូលរួមក្នុងអាថ៌កំបាំងដ៏អស្ចារ្យអស់កល្បជានិច្ច
សូមប្រទានឲ្យរូបកាយរបស់យើងខ្ញុំរស់ឡើងវិញ និងទទួលសិរីរុងរឿង ។

# ថ្ងៃអាទិត្យទី ២ ក្នុងរដូវបុណ្យចម្លង

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែងហួសពីការស្មាន !
សូមព្រះអង្គមេត្តាពង្រឹងជំនឿរបស់យើងខ្ញុំ កុំឲ្យមានចិត្តសង្ស័យឡើយ ។
សូមប្រោសឲ្យយើងខ្ញុំយល់កាន់តែច្បាស់អំពីអគ្គសញ្ញាជ្រមុជទឹក
ដែលជម្រះយើងខ្ញុំឲ្យមានជីវិតថ្មីក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ។
សូមរំដោះយើងខ្ញុំឲ្យរួចពីបាប ដោយសារព្រះលោហិតរបស់ព្រះអង្គ ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
សូមព្រះអង្គមេត្តាទទួលតង្វាយពីយើងខ្ញុំជាបុត្រធីតា
ដែលកើតជាថ្មីរួមជាមួយព្រះគ្រីស្ត ។
យើងខ្ញុំសូមថ្វាយកាយ វាចា ចិត្តរួមនឹងសក្ការបូជារបស់ព្រះយេស៊ូ
ជាព្រះបុត្រាព្រះអង្គដែលមានព្រះជន្មគង់នៅ
និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ ។

ធម៌ប្រារព្ធទី ១ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៣៨ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គប្រោសឲ្យយើងខ្ញុំទទួលជីវិតថ្មី ដោយជឿលើព្រះបុត្រា
ដែលសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ ។
សូមព្រះអង្គមេត្តាចាត់ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកប្រែចិត្តគំនិតយើងខ្ញុំ
ឲ្យរស់នៅស្របតាមឋានៈរបស់ខ្លួនជាបុត្រធីតាព្រះអង្គ ។

# ថ្ងៃចន្ទ

Feria secunda

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ
ហើយមានព្រះជន្មគង់នៅជានិច្ច !
ព្រះអង្គប្រោសឲ្យយើងខ្ញុំហៅព្រះអង្គថា «ព្រះបិតា» ។
សូមព្រះអង្គមេត្តាប្រទានឲ្យយើងខ្ញុំ
មានចិត្តគំនិតស្របតាមឋានៈខ្លួនជាបុត្រធីតាព្រះអង្គ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះបិតាដ៏ជាចៅហ្វាយ !
ព្រះអង្គបានបង្កើតផ្ទៃមេឃ ផែនដី សមុទ្រ
និងអ្វីៗសព្វសារពើទាំងអស់ ដោយសារព្រះបន្ទូលព្រះអង្គ ។
សូមព្រះអង្គមេត្តាទទួលតង្វាយ
ដែលយើងខ្ញុំជាអ្នកបម្រើលើកថ្វាយរួមជាមួយព្រះយេស៊ូគ្រីស្ត
ជាព្រះបុត្រាព្រះអង្គ និងជាអម្ចាស់យើងខ្ញុំ ។
ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៤៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាប្រកបដោយធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះអង្គបានប្រទានជីវិតថ្មីឲ្យយើងខ្ញុំ
ដោយសារអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញានានា ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំប្រព្រឹត្តស្របតាមជីវិតថ្មីដ៏ប្រសើរនេះ ។

# ថ្ងៃអង្គារ

Feria tertia

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំជាព្រះសហគមន៍
ផ្តល់សក្ខីភាពអំពីព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យទទួលព្រះអំណោយទាន
តាមព្រះបន្ទូលសន្យារបស់ព្រះអង្គផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់ !
ព្រះអង្គបានប្រោសឲ្យយើងខ្ញុំកើតជាថ្មី ពីទឹក
និងពីព្រះវិញ្ញាណដ៏វិសុទ្ធ ។
យើងខ្ញុំសូមថ្វាយកាយ វាចា ចិត្ត
រួមជាមួយព្រះយេស៊ូដែលបានបូជាព្រះជន្ម ។
សូមព្រះអង្គមេត្តាទទួលតង្វាយរបស់យើងខ្ញុំដោយអនុគ្រោះ ។
ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៤៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គបានប្រទានជីវិតថ្មីដល់យើងខ្ញុំជាបុត្រធីតារបស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាបំភ្លឺឲ្យព្រះសហគមន៍
យកចិត្តទុកដាក់កសាងពិភពលោកថ្មី ប្រកបដោយយុត្តិធម៌
និងភាតរភាព ដូចសាវ័កពីដើម ។

# ថ្ងៃពុធ

Feria quarta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាអម្ចាស់ !
ជារៀងរាល់ឆ្នាំ ព្រះសហគមន៍នាំគ្នាគិតសញ្ជឹងអំពីព្រះអង្គ
ដែលប្រោសឲ្យព្រះយេស៊ូក្រោកឡើង ពីចំណោមមនុស្សស្លាប់ ។
ព្រះអង្គប្រោសឲ្យយើងខ្ញុំមានកិត្តិយស មានចិត្តសង្ឃឹម និងមានជីវិតថ្មី
សូមព្រះអង្គមេត្តាពង្រឹងជំនឿ និងសេចក្ដីស្រឡាញ់របស់យើងខ្ញុំជានិច្ច ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គស្រឡាញ់មនុស្សលោកខ្លាំងណាស់
រហូតដល់បាត់ព្រះបុត្រាតែមួយរបស់ព្រះអង្គឲ្យយាងមក ដើម្បីឲ្យអស់អ្នកជឿ
សង្ឃឹមលើព្រះបុត្រាទទួលព្រះជន្មផ្ទាល់របស់ព្រះអង្គ ។
សូមព្រះអង្គទទួលយើងខ្ញុំដែលផ្ញើជីវិតទៅលើព្រះអង្គ ក្នុងអភិបូជានេះ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៤៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
កាលពីដើមព្រះអង្គបានប្រោសប្រទានឲ្យសាវ័ក
ដែលជាមនុស្សកំសាក ហ៊ានពុះពារឧបសគ្គនានា
ដើម្បីប្រកាសព្រះបន្ទូលដែលផ្ដល់ជីវិតឲ្យមនុស្សលោក ។ សូមព្រះអង្គមេត្តា
ប្រទានឲ្យយើងខ្ញុំមានចិត្តក្លាហាន ហ៊ានធ្វើជាសាក្សីពីជំនឿរបស់យើងខ្ញុំគ្រប់ពេល
វេលា ។

# ថ្ងៃព្រហស្បតិ៍

Feria quinta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះអង្គបានលើកព្រះយេស៊ូឡើងជាព្រះអម្ចាស់ និងជាព្រះសង្គ្រោះរបស់មនុស្សលោក ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ បំពេញកិច្ចការរាល់ថ្ងៃរួមជាមួយព្រះយេស៊ូ ដែលមានព្រះជន្មគង់នៅជាមួយព្រះបិតា និងព្រះវិញ្ញាណដ៏វិសុទ្ធ អស់កល្បជាអង្វែងតរៀងទៅ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះបិតា !
ព្រះអង្គស្រឡាញ់ព្រះបុត្រាខ្លាំងណាស់
ហើយបានប្រគល់អ្វីៗទាំងអស់ ឲ្យនៅក្រោមអំណាចរបស់ព្រះបុត្រា ។
សូមព្រះអង្គមេត្តាទទួលតង្វាយ និងពាក្យអធិដ្ឋានរបស់យើងខ្ញុំ
ទុកជាសក្ការបូជាដែលគាប់ព្រះហឫទ័យព្រះអង្គ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៤៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដែលស្រឡាញ់មនុស្សលោកហួសប្រមាណ !
ព្រះអង្គប្រទានជីវិតអស់កល្បជានិច្ច ឲ្យអស់អ្នកដែលជឿសង្ឃឹមលើព្រះយេស៊ូ ជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿរបស់យើងខ្ញុំ ឲ្យរស់នៅស្របតាមព្រះបន្ទូលព្រះអង្គ ។

# ថ្ងៃសុក្រ

Feria sexta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដែលស្រឡាញ់មនុស្សលោកយ៉ាងក្រៃលែង !
ព្រះអង្គសព្វព្រះហឫទ័យឲ្យព្រះបុត្រាសោយទិវង្គតលើឈើឆ្កាង ដើម្បីឲ្យយើងខ្ញុំបានរួចពីបាប ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបានរួមរស់ជាមួយព្រះយេស៊ូ
ដែលមានព្រះជន្មរស់ឡើងវិញ ហើយសោយរាជ្យជាមួយព្រះបិតា
និងព្រះវិញ្ញាណដ៏វិសុទ្ធ អស់កល្បជាអង្វែងតរៀងទៅ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះបិតាជាអម្ចាស់ !
កាលពីដើម ព្រះបុត្រាយកនំប៉័ងប្រាំដុំ
និងត្រីពីរកន្ទុយរបស់ក្មេងម្នាក់មកចិញ្ចឹមមនុស្សរាប់ពាន់នាក់ ។ សូមព្រះអង្គមេត្តាទទួលតង្វាយដ៏ស្ដួចស្ដើងរបស់យើងខ្ញុំ
ឲ្យទៅជាព្រះកាយព្រះគ្រីស្ដ
ដើម្បីចិញ្ចឹមយើងខ្ញុំជាអ្នកជឿសង្ឃឹមលើព្រះអង្គ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៤៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាម្ចាស់ដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះអង្គប្រទានព្រះបន្ទូល និងព្រះកាយព្រះគ្រីស្ដ
ឲ្យយើងខ្ញុំទុកជាអាហារដ៏ប្រសើរ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំយកចិត្តទុកដាក់
ស្វែងរកព្រះរាជ្យរបស់ព្រះអង្គឲ្យអស់ពីសមត្ថភាព អស់ពីប្រាជ្ញា
និងរស់នៅក្នុងលោកនេះស្របតាមជំនឿរបស់យើងខ្ញុំ ។

# ថ្ងៃសៅរ៍

Sabbato

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាប្រកបដោយព្រះប្រាជ្ញាញាណ !
ព្រះអង្គណែនាំព្រះសហគមន៍ស្របតាមព្រះហឫទ័យព្រះអង្គ ។
សូមព្រះអង្គមេត្តាជួយយើងខ្ញុំឲ្យដោះស្រាយបញ្ហានៃព្រះសហគមន៍សព្វថ្ងៃ ក្រោមពន្លឺនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីឲ្យព្រះបន្ទូលព្រះអង្គ
បានឮសុសសាយពាសពេញក្នុងពិភពលោក ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
សូមព្រះអង្គណែនាំព្រះសហគមន៍ឲ្យពុះពារគ្រប់ឧបសគ្គ ។
សូមព្រះអង្គមេត្តាចាត់ព្រះវិញ្ញាណដ៏វិសុទ្ធ
ឲ្យយាងមកផ្ដល់សេចក្ដីសុខសាន្ដដ៏ពិតប្រាកដដល់ព្រះសហគមន៍ ដែលជាព្រះកាយព្រះគ្រីស្ដ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតាយើងខ្ញុំ !
ព្រះអង្គបានប្រទានព្រះបន្ទូល
និងព្រះកាយព្រះគ្រីស្ដទុកជាអាហារសម្រាប់យើងខ្ញុំ ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿរបស់យើងខ្ញុំឲ្យជឿជាក់ថា
ព្រះបុត្រាព្រះអង្គគង់នៅជាមួយយើងខ្ញុំ
និងណែនាំព្រះសហគមន៍ជានិច្ច ។

# ថ្ងៃអាទិត្យទី ៣ ក្នុងរដូវបុណ្យចម្លង

DOMINICA III PASCHÆ

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ជាព្រះបិតា !

ព្រះអង្គប្រោសឲ្យព្រះយេស៊ូទទួលព្រះជន្មផ្ទាល់របស់ព្រះអង្គ ហើយទ្រង់ក៏ប្រោសឲ្យយើងខ្ញុំ មានកិត្តិយសជាបុត្រធីតារបស់ព្រះអង្គដែរ ។

សូមព្រះអង្គមេត្តាពង្រឹងជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់របស់យើងខ្ញុំឲ្យរស់នៅតាមឋានៈដ៏ថ្លៃថ្នូររបស់ខ្លួនជានិច្ច ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !

សូមព្រះអង្គមេត្តាទទួលតង្វាយពីព្រះសហគមន៍ រួមនឹងសក្ការបូជារបស់ព្រះយេស៊ូគ្រីស្ដដែលសោយទិវង្គត ។

សូមព្រះអង្គប្រោសប្រទានឲ្យយើងខ្ញុំរួមរស់ជាមួយព្រះយេស៊ូគ្រីស្ដ ដែលមានព្រះជន្មគង់នៅឯស្ថានបរមសុខ អស់កល្បជាអង្វែងតរៀងទៅ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏មានព្រះហឫទ័យសប្បុរស !

ព្រះអង្គបានប្រោសឲ្យយើងខ្ញុំទទួលជីវិតថ្មី ដោយសារជំនឿ និងដោយសារអគ្គសញ្ញានានា ។

សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ ឲ្យសុខចិត្តរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូគ្រីស្ដគ្រប់ពេលវេលា ហើយណែនាំយើងខ្ញុំឲ្យទទួលសិរីរុងរឿងរួមជាមួយព្រះអង្គផង ។

# ថ្ងៃចន្ទ

Feria secunda

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
កាលពីដើមព្រះអង្គគាប់ព្រះហឫទ័យនឹងលោកស្ទេផាន
ដែលមានប្រាជ្ញាមកពីព្រះវិញ្ញាណ ។
សូមព្រះអង្គមេត្តាប្រទានឲ្យយើងខ្ញុំមានប្រាជ្ញាវាងវៃ
ហ៊ានធ្វើជាសាក្សីរបស់ព្រះយេស៊ូគ្រីស្តក្នុងលោកនេះ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះយេស៊ូគ្រីស្តបានប្រទានអាហារដ៏ពិតប្រាកដ ដែលផ្តល់ជីវិតអស់កល្បជានិច្ច
ដល់យើងខ្ញុំ ។
យើងខ្ញុំគ្មានអ្វីលើកថ្វាយព្រះអង្គក្រៅពីជំនឿលើព្រះបុត្រា
ដែលយាងមកសង្គ្រោះមនុស្សលោក ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រទានអាហារដ៏ពិតប្រាកដ ដែលស្ថិតនៅអស់កល្បជានិច្ច ។
សូមព្រះអង្គមេត្តាចិញ្ចឹមជំនឿរបស់យើងខ្ញុំឲ្យផ្ញើជីវិតទាំងស្រុងលើព្រះយេស៊ូ
និងប្រោសឲ្យយើងខ្ញុំមានចិត្តក្លាហាន
បំពេញកិច្ចការប្រចាំថ្ងៃដែលគាប់ព្រះហឫទ័យព្រះអង្គ ។

# ថ្ងៃអង្គារ

Feria tertia

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
កាលពីដើមព្រះអង្គបានប្រទានឲ្យលោកស្ទេផាន
ធ្វើជាសាក្សីអំពីសេចក្តីពិតរហូតដល់បូជាជីវិតដូចព្រះយេស៊ូ ។ សូមព្រះអង្គមេត្តាប្រោសប្រទានដល់យើងខ្ញុំជាគ្រីស្តបរិស័ទ ដែលកើតជាថ្មីដោយទឹក និងព្រះវិញ្ញាណដ៏វិសុទ្ធ មានជំនឿមាំមួន
និងមានសេចក្តីក្លាហានប៉ានបញ្ជាក់ជំនឿរបស់ខ្លួន ដូចលោកស្ទេផាន ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គតែងតែប្រទានអាហារសម្រាប់ចិញ្ចឹមជីវិតយើងខ្ញុំ ។
យើងខ្ញុំសូមយកអាហារខ្លះមកថ្វាយព្រះអង្គ
សូមព្រះអង្គមេត្តាទទួលតង្វាយនេះ ឲ្យទៅជាព្រះកាយព្រះគ្រីស្ត
ដែលជាអាហារដ៏ពិតប្រាកដចុះមកពីស្ថានបរមសុខ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

ឱ ព្រះបិតាដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះអង្គប្រទានព្រះកាយព្រះគ្រីស្ត
ដែលជាអាហារដ៏ពិតប្រាកដចុះពីស្ថានបរមសុខ ។
សូមព្រះអង្គមេត្តាឲ្យយើងខ្ញុំស្រេកឃ្លានអាហារនេះជាដរាប ។

# ថ្ងៃពុធ

Feria quarta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គណែនាំ និងគាំទ្រព្រះសហគមន៍ឲ្យរីកចម្រើនលូតលាស់ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំមានចិត្តសង្ឃឹមជានិច្ចនៅគ្រាលំបាក
ដើម្បីរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូ
ដែលសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតារបស់ព្រះយេស៊ូគ្រីស្ត !
ព្រះអង្គមានព្រះហឫទ័យសប្បុរសយ៉ាងក្រៃលែង ដោយប្រទានព្រះជន្មផ្ទាល់របស់ព្រះអង្គ
ដល់អស់អ្នកដែលជឿសង្ឃឹមលើព្រះបុត្រា ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យសុខចិត្តថ្វាយខ្លួនទៅព្រះអង្គ ដោយរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាម្ចាស់ដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ដ្បិតព្រះអង្គបានប្រទានឲ្យយើងខ្ញុំ
មានជំនឿលើព្រះយេស៊ូជាព្រះបុត្រាព្រះអង្គ ។
ព្រះយេស៊ូមិនបោះបង់បោលអ្នកណាដែលរត់មករកព្រះអង្គឡើយ
ហេតុនេះ សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំមានជំនឿកាន់តែមាំមួន
និងប្រព្រឹត្តតាមជំនឿនេះជានិច្ច ។

# ថ្ងៃព្រហស្បតិ៍

Feria quinta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ
ហើយមានព្រះជន្មគង់នៅអស់កល្បជានិច្ច !
ព្រះអង្គប្រោសមនុស្សគ្រប់ជាតិសាសន៍ឲ្យស្គាល់ព្រះអង្គ
ដោយមិនរើសមុខនរណាឡើយ ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យយកចិត្តទុកដាក់ស្ដាប់ព្រះបន្ទូលព្រះអង្គ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះបិតាប្រកបដោយព្រះប្រាជ្ញាញាណ !
ព្រះអង្គទាក់ទាញចិត្តមនុស្សទាំងអស់ឲ្យស្គាល់ព្រះអង្គ ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យរស់នៅស្របតាមអគ្គសញ្ញាដែលយើងខ្ញុំនាំគ្នាប្រារព្ធនៅពេលនេះ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះយេស៊ូបានប្រទានព្រះបន្ទូល និងព្រះកាយផ្ទាល់របស់ព្រះអង្គឲ្យយើងខ្ញុំ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ យកចិត្តទុកដាក់ស្ដាប់ព្រះបន្ទូលព្រះអង្គ
ដើម្បីនៅថ្ងៃណាមួយ យើងខ្ញុំនឹងឃើញព្រះបិតានៅស្ថានបរមសុខ
រួមជាមួយព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។

# ថ្ងៃសុក្រ

Feria sexta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គសព្វព្រះហឫទ័យត្រាស់ហៅលោកសូល
ដែលមានចិត្តរឹងរូសឲ្យកែប្រែចិត្តគំនិត
ហើយព្រះអង្គក៏ប្រោសយើងខ្ញុំឲ្យជឿលើព្រះគ្រីស្តដែរ ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យស្មោះត្រង់ចិត្តរស់នៅតាមរបៀបថ្មី ស្របតាមគម្រោងការរបស់ព្រះអង្គ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះបិតាដែលមានព្រះជន្មគង់នៅ !
ព្រះយេស៊ូប្រទានព្រះកាយ និងព្រះលោហិតព្រះអង្គ
ទុកជាអាហារដែលផ្ដល់ជីវិត ដើម្បីសង្គ្រោះយើងខ្ញុំ ។
សូមព្រះអង្គទទួលតង្វាយ និងជំនឿរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះយេស៊ូ ជាព្រះគ្រីស្ត និងជាអម្ចាស់យើងខ្ញុំ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !
ក្នុងអភិបូជានេះ ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំ សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំស្ថិតនៅក្នុងព្រះបុត្រា និងឲ្យព្រះបុត្រាស្ថិតនៅក្នុងយើងខ្ញុំជានិច្ច ។ សូមប្រទានឲ្យយើងខ្ញុំមានចិត្តស្រឡាញ់ព្រះអង្គ និងអ្នកដទៃដូចព្រះយេស៊ូ ។

# ថ្ងៃសៅរ៍

Sabbato

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គបានសម្តែងឫទ្ធានុភាពដ៏អស្ចារ្យ
ដោយប្រោសឲ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ។ ព្រះអង្គក៏ប្រោសឲ្យសាវ័កអាចប្រព្រឹត្តការអស្ចារ្យបាន ក្នុងនាមព្រះយេស៊ូដែរ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំមានជំនឿមាំមួន និងបង្ហាញពីឫទ្ធានុភាពរបស់ព្រះអង្គសព្វថ្ងៃនេះផង ។

ពាក្យថ្វាយតង្វាយ

បពិត្រព្រះបិតារបស់ព្រះយេស៊ូគ្រីស្តជាអម្ចាស់ !
យើងខ្ញុំជឿថា ព្រះគ្រីស្តជាព្រះបន្ទូលដែលផ្តល់ជីវិតអស់កល្បជានិច្ច
ព្រះអង្គក៏ជាព្រះដ៏វិសុទ្ធដែលមកពីព្រះបិតាដែរ ។ សូមព្រះអង្គមេត្តាពង្រឹងជំនឿរបស់យើងខ្ញុំ
ឲ្យសុខចិត្តរួមស្លាប់រួមរស់ជាមួយព្រះគ្រីស្ត
ដូចយើងខ្ញុំបានប្រកាសក្នុងអភិបូជានេះ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

ពាក្យអរព្រះគុណ

បពិត្រព្រះបិតាប្រកបដោយធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ក្នុងអភិបូជានេះ ព្រះអង្គទាក់ទាញចិត្តយើងខ្ញុំឆ្ពោះទៅរកព្រះគ្រីស្ត
ដែលជាព្រះបន្ទូលផ្តល់ជីវិតអស់កល្បជានិច្ច ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿរបស់យើងខ្ញុំ
ដែលបានទទួលព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ត
ហើយសូមឲ្យយើងខ្ញុំជាប់ចិត្តនឹងព្រះគ្រីស្តជានិច្ចផង ។

# ថ្ងៃអាទិត្យទី ៤ ក្នុងរដូវបុណ្យចម្លង

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ និងមានព្រះជន្មគង់នៅជានិច្ច !
ព្រះអង្គតែងតាំងព្រះយេស៊ូជាគង្វាលដ៏ប្រសើរ
ដែលប្រមែប្រមូលមនុស្សគ្រប់ជាតិសាសន៍ទៅជាមហាគ្រួសារតែមួយ ។
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យយកចិត្តទុកដាក់ស្ដាប់ព្រះសូរសៀងព្រះអង្គ និង
បម្រើអ្នកដទៃតាមគង្វាលដ៏ប្រសើរនេះ ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ជារៀងរាល់ឆ្នាំ ព្រះអង្គសព្វព្រះហឫទ័យឲ្យយើងខ្ញុំ
នឹករឭកអំពីរបៀបព្រះគ្រីស្ដសង្គ្រោះយើងខ្ញុំ ។
យើងខ្ញុំសូមថ្វាយ កាយ វាចា ចិត្ត រួមជាមួយព្រះយេស៊ូដែលបានបូជាព្រះជន្ម
សូមព្រះអង្គមេត្តាទទួលតង្វាយរបស់យើងខ្ញុំដោយអនុគ្រោះ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ ហើយដែលជាគង្វាលដ៏សប្បុរស !
ព្រះអង្គសង្គ្រោះយើងខ្ញុំដោយព្រះបុត្រាបូជាព្រះជន្ម ។
សូមព្រះអង្គមេត្តាណែនាំយើងខ្ញុំជាព្រះសហគមន៍ ឲ្យស្គាល់ធម៌មេត្តាករុណាដ៏លើស
លប់របស់ព្រះអង្គផង ។

# ថ្ងៃចន្ទ

Feria secunda

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានធម៌មេត្តាករុណា !
ព្រះបុត្រារបស់ព្រះអង្គ សោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
ដើម្បីសង្គ្រោះមនុស្សលោកឲ្យរួចពីបាប ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំជាព្រះសហគមន៍
ប្រកាសពីការសង្គ្រោះនេះដល់អ្នកដទៃ ។
សូមព្រះអង្គប្រមែប្រមូលមនុស្សទាំងអស់ឲ្យទៅជាមហាគ្រួសារតែមួយ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាម្ចាស់យើងខ្ញុំ !
ព្រះអង្គតែងតាំងព្រះយេស៊ូជាគង្វាលរបស់អស់អ្នកជឿសង្ឃឹមលើព្រះអង្គ ។
ព្រះយេស៊ូជាទ្វារសម្រាប់ឲ្យយើងខ្ញុំចូលទៅកាន់ព្រះបិតា ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្ត ដែលយើងខ្ញុំលើកថ្វាយ
រួមជាមួយព្រះយេស៊ូជាព្រះបុត្រាដែលមានព្រះជន្មគង់នៅ
និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាប្រកបដោយធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះយេស៊ូជាទ្វារសម្រាប់ឲ្យយើងខ្ញុំចូលឆ្ពោះទៅកាន់ព្រះបិតា ។
ក្នុងអភិបូជានេះ យើងខ្ញុំសូមចូលរួមជាមួយព្រះយេស៊ូជាគង្វាលដ៏សប្បុរស
ដែលសោយទិវង្គតដើម្បីលោះបាបរបស់យើងខ្ញុំ ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿរបស់យើងខ្ញុំឲ្យយកចិត្តទុកដាក់
ណែនាំមនុស្សទាំងអស់ទៅជាមហាគ្រួសារតែមួយរបស់ព្រះអង្គ ។

# ថ្ងៃអង្គារ

Feria tertia

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះអង្គប្រោសឲ្យព្រះសហគមន៍លូតលាស់ជាលំដាប់
ដោយសារឫទ្ធានុភាពរបស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាប្រទានឲ្យអស់អ្នកដែលមានឈ្មោះជាគ្រីស្តបរិស័ទ
យកចិត្តទុកដាក់រស់នៅឲ្យសមរម្យនឹងឋានៈរបស់ខ្លួន ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គមានអំណាចលើសអ្វីៗទាំងអស់
ហើយព្រះអង្គក៏បានចាត់ព្រះយេស៊ូឲ្យយាងមក
ប្រទានជីវិតអស់កល្បជានិច្ចដល់អស់អ្នកជឿ ។ សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ
ព្យាយាមស្តាប់ព្រះសូរសៀងរបស់ព្រះគ្រីស្ត និងប្រព្រឹត្តតាមផង ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គប្រោសឲ្យយើងខ្ញុំរួបរួមជាមួយព្រះគ្រីស្ត
រីឯព្រះគ្រីស្តនៅក្នុងព្រះបិតាជាអង្គតែមួយ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ រួមរស់ជាមួយព្រះអង្គជានិច្ច
ដោយគ្មានអ្វីអាចឆក់យកយើងខ្ញុំពីព្រះហស្តព្រះអង្គបានឡើយ ។ សូមប្រទានឲ្យ
យើងខ្ញុំជាប់ចិត្តនឹងព្រះអង្គ ក្នុងគ្រប់កិច្ចការប្រចាំជីវិត ។

# ថ្ងៃពុធ

Feria quarta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គសព្វព្រះហឫទ័យឲ្យមនុស្សគ្រប់ជាតិសាសន៍ជឿសង្ឃឹមលើព្រះអង្គ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំជាគ្រីស្តបរិស័ទ
យកចិត្តទុកដាក់ប្រកាសដំណឹងល្អអំពីព្រះអង្គ
ក្នុងគ្រប់កាលៈទេសៈប្រចាំជីវិតយើងខ្ញុំ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់យើងខ្ញុំ !
សូមព្រះអង្គទទួលតង្វាយរបស់យើងខ្ញុំដោយអនុគ្រោះ ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិត និងពង្រឹងជំនឿរបស់យើងខ្ញុំ
ឲ្យប្រព្រឹត្តតាមជំនឿនេះក្នុងគ្រប់កិច្ចការប្រចាំជីវិត ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាម្ចាស់ដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះអង្គប្រោសឲ្យយើងខ្ញុំទទួលជីវិតថ្មី
ដោយអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត ។
សូមព្រះអង្គមេត្តាតម្រង់ចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យរស់នៅស្របតាមឋានៈរបស់ខ្លួន
ជាបុត្រធីតារបស់ព្រះអង្គគ្រប់ពេលវេលា ។

# ថ្ងៃព្រហស្បតិ៍

Feria quinta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាដ៏មានធម៌មេត្តាករុណា !
ព្រះអង្គបាត់ព្រះយេស៊ូជាព្រះគ្រីស្តឲ្យយាងមកស្របតាមព្រះបន្ទូលសន្យា
ដើម្បីប្រោសមនុស្សលោកឲ្យក្រោកឡើង និងមានកិត្តិយសជាបុត្រធីតាព្រះអង្គ ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យយល់កាន់តែច្បាស់នូវព្រះអំណោយទានដ៏ថ្លៃថ្លានេះ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ទោះបីព្រះយេស៊ូជាព្រះបុត្រាក៏ដោយ
ក៏ព្រះអង្គសព្វព្រះហឫទ័យយកឋានៈជាអ្នកបម្រើ រហូតដល់លាងជើងក្រុមសាវ័ក ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ ស្ម័គ្រចិត្តលះបង់ប្រយោជន៍ផ្ទាល់ខ្លួន
និងបម្រើអស់អ្នកដែលនៅជាមួយយើងខ្ញុំសព្វថ្ងៃនេះ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គស្រឡាញ់មនុស្សលោកខ្លាំងណាស់
រហូតដល់បាត់ព្រះបុត្រាឲ្យយាងមកបម្រើយើងខ្ញុំ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ ដែលទទួលព្រះកាយព្រះគ្រីស្តក្នុងអភិបូជានេះ
បេះអរព្រះគុណព្រះបិតា ដោយបម្រើអ្នកដទៃ ។

# ថ្ងៃសុក្រ

Feria sexta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រោសឲ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ
តាមព្រះបន្ទូលសន្យាជាមួយបុព្វបុរសរបស់យើងខ្ញុំ ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យយល់ពីគម្រោងការដ៏អស្ចារ្យនេះ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាម្ចាស់យើងខ្ញុំ !
ព្រះយេស៊ូជាផ្លូវ ជាសេចក្តីពិត និងជាជីវិត
ព្រះអង្គបង្ហាញមាគ៌ាឲ្យយើងខ្ញុំឆ្ពោះទៅកាន់ព្រះបិតា ។
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យស្ម័គ្រចិត្តបូជាជីវិតរួមជាមួយព្រះយេស៊ូ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតា !
ព្រះអង្គប្រោសឲ្យយើងខ្ញុំចូលរួមយ៉ាងជិតស្និទ្ធ
ក្នុងសក្ការបូជារបស់ព្រះយេស៊ូជាព្រះបុត្រាព្រះអង្គ ។ សូមព្រះអង្គមេត្តាពង្រឹងជំនឿរបស់យើងខ្ញុំ កុំឲ្យរន្ធត់ចិត្តឡើយ ។
សូមឲ្យយើងខ្ញុំរួមរស់ជាមួយព្រះគ្រីស្តក្នុងគ្រប់កិច្ចការប្រចាំជីវិត ដើម្បីឲ្យថ្ងៃណាមួយ យើងខ្ញុំបានរស់នៅក្នុងព្រះដំណាក់របស់ព្រះអង្គ ។

# ថ្ងៃសៅរ៍

Sabbato

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាប្រកបដោយធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះអង្គសព្វព្រះហឫទ័យឲ្យមនុស្សគ្រប់ជាតិសាសន៍
បានស្គាល់ព្រះអង្គ និងទទួលជីវិតអស់កល្បជានិច្ច ។
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំជាគ្រីស្តបរិស័ទ
ឲ្យមានចិត្តក្លាហានពុះពារឧបសគ្គនានា
ដើម្បីនាំព្រះបន្ទូលរបស់ព្រះអង្គដល់មនុស្សសម័យឥឡូវនេះ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់យើងខ្ញុំ !
សូមព្រះអង្គមេត្តាទទួលសក្ការបូជារបស់យើងខ្ញុំដោយអនុគ្រោះ ។
សូមប្រោសយើងខ្ញុំឲ្យសុខចិត្តរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូ
ជាព្រះបុត្រាដែលស្ថិតនៅក្នុងព្រះបិតា ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
ព្រះយេស៊ូបានសម្តែងព្រះអង្គឲ្យយើងខ្ញុំស្គាល់ និងឃើញថែមទៀត ។
ឥឡូវនេះ ព្រះយេស៊ូយាងឆ្លងទៅព្រះបិតាវិញ ហើយអង្វរព្រះអង្គឲ្យយើងខ្ញុំ
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំដែលជឿសង្ឃឹមលើព្រះគ្រីស្ត
ឲ្យប្រព្រឹត្តនូវរាល់កិច្ចការរបស់ព្រះអង្គក្នុងលោកនេះ ។

# ថ្ងៃអាទិត្យទី ៥ ក្នុងរដូវបុណ្យចម្លង

DOMINICA V PASCHÆ

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ជាព្រះបិតាយើងខ្ញុំ !

ព្រះអង្គសព្វព្រះហឫទ័យចាត់ព្រះបុត្រាឲ្យយាងមកណែនាំ និងប្រមូលមនុស្សគ្រប់ជាតិសាសន៍ ធ្វើជាមហាគ្រួសារតែមួយ ។

សូមព្រះអង្គមេត្តាប្រែចិត្តគំនិតរបស់យើងខ្ញុំឲ្យស្រឡាញ់ព្រះអង្គ និងស្រឡាញ់បងប្អូនយ៉ាងស្មោះតាមគំរូព្រះយេស៊ូ ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !

ព្រះអង្គប្រោសឲ្យព្រះយេស៊ូធ្វើជាមហាបូជាចារ្យ ដែលបូជាព្រះជន្មផ្ទាល់របស់ព្រះអង្គ សម្រាប់មនុស្សលោកទាំងមូល ។

សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ

រួមជាមួយសក្ការបូជារបស់ព្រះយេស៊ូគ្រីស្ត ដែលមានព្រះជន្មគង់នៅ

និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាម្ចាស់ដ៏សប្បុរស !

ព្រះអង្គបានប្រទានព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ត

ឲ្យយើងខ្ញុំទទួលទុកជាអាហារ ។

សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំដែលទទួលជីវិតថ្មីពីព្រះអង្គ

បានរស់នៅយ៉ាងសមរម្យនឹងជីវិតថ្មីនេះ ។

# ថ្ងៃចន្ទ

Feria secunda

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាអម្ចាស់ !
ព្រះអង្គជាប្រភពនៃជីវិតគ្រប់បែបយ៉ាង
ហើយប្រទានសញ្ញាសម្គាល់នានាឲ្យមនុស្សលោកបានស្គាល់ព្រះអង្គ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំជាប់ចិត្តនឹងព្រះអង្គជានិច្ច
កុំឲ្យយើងខ្ញុំយកទ្រព្យសម្បត្តិ ការភ្លើតភ្លើន
ឬព្រះក្លែងក្លាយមកគោរពឡើយ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់ដ៏សប្បុរស !
សូមប្រោសឲ្យយើងខ្ញុំ ស្រឡាញ់ព្រះអង្គកាន់តែខ្លាំងឡើងៗ
ដោយប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ។ សូមព្រះអង្គមេត្តាគង់នៅក្នុងចិត្តរបស់យើងខ្ញុំគ្រប់ពេលវេលា ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រោសឲ្យយើងខ្ញុំចូលរួមយ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូ
ព្រះអង្គបាត់ព្រះវិញ្ញាណដ៏វិសុទ្ធ មកបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ ។
សូមព្រះអង្គមេត្តាជួយការពារយើងខ្ញុំ និងប្រោសប្រទានឲ្យយើងខ្ញុំ
មានកម្លាំងក្លាហានប្រព្រឹត្តតាមព្រះបន្ទូលព្រះអង្គជានិច្ច ។

# ថ្ងៃអង្គារ

Feria tertia

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !

ព្រះអង្គប្រោសព្រះយេស៊ូឲ្យទទួលសិរីរុងរឿង និងប្រទានឲ្យយើងខ្ញុំទទួលព្រះជន្ម ផ្ទាល់របស់ព្រះអង្គ ។

សូមព្រះអង្គមេត្តាលើកទឹកចិត្តយើងខ្ញុំឲ្យមានសេចក្ដីសង្ឃឹម សេចក្ដីក្លាហាន ដើម្បីពុះពារឧបសគ្គនានានៅក្នុងជីវិតផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះបិតាដ៏សប្បុរស !

ក្នុងអភិបូជានេះ ព្រះសហគមន៍សូមនឹករឭកដល់ព្រះយេស៊ូ ដែលសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញប្រកបដោយសិរីរុងរឿង ។

សូមព្រះអង្គទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ រួមជាមួយព្រះយេស៊ូគ្រីស្តដែលមានព្រះជន្មគង់នៅ និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាជាអម្ចាស់ !

ព្រះអង្គប្រោសប្រទានព្រះកាយ និងព្រះលោហិតព្រះយេស៊ូគ្រីស្តឲ្យយើងខ្ញុំ ។

សូមព្រះអង្គមេត្តាជួយការពារយើងខ្ញុំ កុំឲ្យចាញ់ការល្បួងនៃចៅហ្វាយលោកីយ៍នេះ

និងប្រោសឲ្យយើងខ្ញុំធ្វើតាមព្រះហឫទ័យព្រះអង្គគ្រប់ពេលវេលា ។

# ថ្ងៃពុធ

Feria quarta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គបានបង្កើតមនុស្សឲ្យមានលក្ខណៈដ៏ប្រសើរដូចព្រះអង្គ ។ ព្រះអង្គប្រោសព្រះយេស៊ូឲ្យទទួលសិរីរុងរឿង ព្រះអង្គក៏បើកផ្លូវឲ្យយើងខ្ញុំស្គាល់ព្រះអង្គដែរ ។ សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតមនុស្សគ្រប់ជាតិសាសន៍
ឲ្យស្គាល់ និងគោរពថ្វាយបង្គំព្រះអង្គតាមប្រពៃណីរៀងៗខ្លួន ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ក្នុងអភិបូជានេះ ព្រះសហគមន៍ចូលរួមជាមួយព្រះបុត្រាព្រះអង្គ
ដែលសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ ។
សូមព្រះអង្គមេត្តាលើកទឹកចិត្ត និងជម្រះឲ្យយើងខ្ញុំបានស្អាតបរិសុទ្ធ
ហើយជាប់ចិត្តជាមួយព្រះយេស៊ូគ្រីស្តជានិច្ច ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រទានព្រះបន្ទូល និងព្រះកាយរបស់ព្រះគ្រីស្តឲ្យយើងខ្ញុំ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំស្ថិតនៅជាប់នឹងព្រះគ្រីស្តជានិច្ច ដើម្បីឲ្យយើងខ្ញុំអាចបង្កើតផលផ្លែយ៉ាងបរិបូណ៌ ។

# ថ្ងៃព្រហស្បតិ៍

Feria quinta

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាដ៏មានធម៌មេត្តាករុណាដ៏លើសលប់ !
ព្រះអង្គសង្គ្រោះអស់អ្នកដែលផ្ញើជីវិតលើព្រះអង្គ
ដោយផ្ដល់សេរីភាពដ៏ពិតប្រាកដដល់គេ ។
សូមព្រះអង្គមេត្តាប្រោសឲ្យព្រះសហគមន៍របស់ព្រះអង្គបេះគោរព និងការពារសេរីភាពនេះ ព្រមទាំងណែនាំឲ្យមនុស្សគ្រប់ជាតិសាសន៍
ចូលរួមជាមហាគ្រួសារតែមួយ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គសព្វព្រះហឫទ័យឲ្យយើងខ្ញុំចូលរួមជាមួយព្រះយេស៊ូ
ដែលសម្ដែងសេចក្ដីស្រឡាញ់យ៉ាងលើសលប់រហូតដល់បូជាព្រះជន្ម ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
រួមជាមួយព្រះយេស៊ូដែលជាព្រះបុត្រាព្រះអង្គផង ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គស្រឡាញ់យើងខ្ញុំខ្លាំងណាស់
រហូតដល់ប្រទានព្រះបុត្រារបស់ព្រះអង្គមកយើងខ្ញុំ ។
សូមព្រះអង្គមេត្តាពង្រឹងសេចក្ដីស្រឡាញ់របស់យើងខ្ញុំ
ដើម្បីឲ្យយើងខ្ញុំមានអំណរសប្បាយប្រតិបត្តិតាមវិន័យរបស់ព្រះអង្គ ។

# ថ្ងៃសុក្រ

Feria sexta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គលើកព្រះយេស៊ូឲ្យទទួលសិរីរុងរឿង ហើយទ្រង់បានប្រោសឲ្យមនុស្សគ្រប់ជាតិសាសន៍
ទៅជាបុត្រធីតារបស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំទៅជាសញ្ញាសម្គាល់
នៃគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គនៅលើផែនដី ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
យើងខ្ញុំសូមលើកតម្កើងព្រះយេស៊ូគ្រីស្ត
ដែលមានព្រះហឫទ័យស្រឡាញ់រហូតដល់បូជាព្រះជន្ម ។ សូមព្រះអង្គមេត្តាទទួលយើងខ្ញុំរួមជាមួយព្រះយេស៊ូគ្រីស្ត
ជាព្រះសង្គ្រោះមនុស្សលោក ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះយេស៊ូសម្តែងឲ្យយើងខ្ញុំដឹងពី
សេចក្តីស្រឡាញ់ដ៏លើសលប់របស់ព្រះបិតាចំពោះមនុស្សលោក ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ ចេះស្រឡាញ់គ្នាទៅវិញទៅមក
ដូចព្រះយេស៊ូបានស្រឡាញ់យើងខ្ញុំដែរ ។

# ថ្ងៃសៅរ៍

Sabbato

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គសព្វព្រះហឫទ័យប្រទានជីវិតថ្មីឲ្យយើងខ្ញុំ
ដោយសារជំនឿ និងប្រោសឲ្យយើងខ្ញុំទៅជាបុត្រធីតារបស់ព្រះអង្គ ។
សូមព្រះអង្គប្រទានឲ្យយើងខ្ញុំមានសេចក្ដីក្លាហាន
នាំដំណឹងល្អនេះដល់មនុស្សលោកសព្វថ្ងៃផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះបិតាយើងខ្ញុំ !
ក្នុងអភិបូជានេះ យើងខ្ញុំសូមចូលរួមជាមួយព្រះយេស៊ូដើម្បីលើកតម្កើងព្រះអង្គ
ដែលមានព្រះហឫទ័យស្រឡាញ់មនុស្សលោកជានិច្ច ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តដែលយើងខ្ញុំថ្វាយ
ក្នុងនាមមនុស្សលោក ទុកជាតង្វាយគាប់ព្រះហឫទ័យព្រះអង្គ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គសព្វព្រះហឫទ័យបាត់យើងខ្ញុំឲ្យទៅក្នុងពិភពលោកនេះ
ដើម្បីចេះស្រឡាញ់អ្នកដែលស្អប់យើងខ្ញុំ ។
សូមព្រះអង្គមេត្តាលើកទឹកចិត្តយើងខ្ញុំឲ្យប្រព្រឹត្តល្អ
ដល់អស់អ្នកដែលបៀតបៀនយើងខ្ញុំ ។

# ថ្ងៃអាទិត្យទី ៦ ក្នុងរដូវបុណ្យចម្លង

DOMINICA VI PASCHÆ

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាប្រកបដោយធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះអង្គសព្វព្រះហឫទ័យបង្រួបបង្រួមមនុស្សលោក
ដែលបាក់បែកគ្នាឲ្យចូលរួមជាមហាគ្រួសារតែមួយ ។ សូមព្រះអង្គមេត្តាប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកណែនាំយើងខ្ញុំ
ឲ្យរស់នៅសមនឹងឋានៈរបស់ខ្លួនជាបុត្រធីតារបស់ព្រះអង្គ ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា!
យើងខ្ញុំសូមលើកកាយ វាចា ចិត្តថ្វាយព្រះអង្គ
រួមជាមួយព្រះយេស៊ូដែលបូជាព្រះជន្ម ។
សូមព្រះអង្គមេត្តាចាត់ព្រះវិញ្ញាណដ៏វិសុទ្ធមកញ៉ាំងតង្វាយនេះ
ឲ្យទៅជាព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ត ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គប្រោសឲ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ
ហើយទ្រង់ក៏ប្រទានជីវិតថ្មីឲ្យយើងខ្ញុំដែរ ។
សូមព្រះអង្គមេត្តាបង្ហាញសេចក្ដីពិតមកណែនាំយើងខ្ញុំ
ឲ្យរស់នៅតាមគំរូរបស់ព្រះយេស៊ូផង ។

# ថ្ងៃចន្ទ

Feria secunda

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាប្រកបដោយធម៌មេត្តាករុណាដ៏លើសលប់ !
ព្រះអង្គសព្វព្រះហឫទ័យបំភ្លឺមនុស្សលោក
ឲ្យយកចិត្តទុកដាក់ស្ដាប់ព្រះបន្ទូល និងជឿសង្ឃឹមលើព្រះគ្រីស្ដ ។
សូមព្រះអង្គមេត្តាចាត់ព្រះវិញ្ញាណដ៏វិសុទ្ធ
យាងមកទាក់ទាញចិត្តមនុស្សលោកសព្វថ្ងៃនេះ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
នៅក្នុងអភិបូជានេះ យើងខ្ញុំសូមចូលរួមជាមួយព្រះយេស៊ូ
ជាព្រះបុត្រាដែលបូជាព្រះជន្ម ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំដោយអនុគ្រោះ
ទុកជាតង្វាយដែលគាប់ព្រះហឫទ័យព្រះអង្គ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ដ៏មានធម៌មេត្តាករុណា !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះបុត្រាឲ្យយើងខ្ញុំ ។
សូមព្រះអង្គមេត្តាចាត់ព្រះវិញ្ញាណដ៏វិសុទ្ធ
យាងមកសម្ដែងសេចក្ដីពិតឲ្យយើងខ្ញុំបានធ្វើជាសាក្សីពីព្រះយេស៊ូ ។

# ថ្ងៃអង្គារ

Feria tertia

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រទានសេរីភាព និងអំណរសប្បាយដ៏ពិតប្រាកដ
ដល់អស់អ្នកជឿសង្ឃឹមលើព្រះអង្គ ។
សូមព្រះអង្គមេត្តាលើកទឹកចិត្តយើងខ្ញុំ
ឲ្យមានសេចក្តីសង្ឃឹមជានិច្ច នៅពេលយើងខ្ញុំជួបឧបសគ្គនានា ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
នៅពេលនេះ ព្រះសហគមន៍នឹករឭកដល់ព្រះយេស៊ូ
ជាព្រះបុត្រាដែលមានជ័យជម្នះលើមារ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំចូលរួមជាមួយព្រះគ្រីស្ត ដែលឈ្នះលើសេចក្តីអាក្រក់គ្រប់បែបយ៉ាង ។

ធម៌ប្រារព្ធ ក្នុងរជូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រទានព្រះបន្ទូល និងព្រះកាយព្រះគ្រីស្តឲ្យយើងខ្ញុំ
ទុកជាអាហារដែលផ្តល់ជីវិត ។
សូមព្រះអង្គមេត្តាប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ
មកបំភ្លឺយើងខ្ញុំឲ្យចេះស្រឡាញ់ ដូចព្រះគ្រីស្តស្រឡាញ់មនុស្សលោក ។

# ថ្ងៃពុធ

Feria quarta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាអម្ចាស់នៃស្ថានបរមសុខ !
ព្រះអង្គលាក់គម្រោងការដ៏អស្ចារ្យមិនឲ្យអ្នកប្រាជ្ញយល់
តែព្រះអង្គបានសម្តែងឲ្យអ្នកតូចតាចយល់វិញ ។ សូមព្រះអង្គមេត្តាប្រោសឲ្យយើង
ខ្ញុំស្គាល់ព្រះអង្គកាន់តែច្បាស់ឡើងៗ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គចាត់ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកណែនាំយើងខ្ញុំ
ឲ្យស្គាល់សេចក្តីពិតគ្រប់ជំពូក ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យយល់ពីធម៌មេត្តាករុណាដ៏លើសលប់របស់ព្រះអង្គ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

ឱ ព្រះបិតាជាអម្ចាស់ !
ព្រះអង្គបានប្រទានព្រះបន្ទូល
និងព្រះកាយព្រះគ្រីស្តទុកជាអាហារសម្រាប់យើងខ្ញុំ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំមានកម្លាំងកាយ កម្លាំងចិត្ត
ធ្វើដំណើរក្នុងលោកនេះឆ្ពោះទៅព្រះបិតា ។

# ថ្ងៃព្រហស្បតិ៍

Feria quinta

តាមធម្មតាថ្ងៃនេះ ជាថ្ងៃបុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ ក៏ប៉ុន្តែនៅប្រទេសកម្ពុជា និងប្រទេសមួយចំនួនទៀត បានប្រារព្ធបុណ្យនេះនៅថ្ងៃអាទិត្យបន្ទាប់ ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះអង្គសព្វព្រះហឫទ័យត្រាស់ហៅមនុស្សគ្រប់ជាតិសាសន៍
ឲ្យស្គាល់ព្រះអង្គដោយមិនរើសមុខនរណាឡើយ ។
សូមព្រះអង្គមេត្តាបំភ្លឺឲ្យយើងខ្ញុំចេះទទួលអស់អ្នក
ដែលជឿសង្ឃឹមលើព្រះគ្រីស្តទុកជាបងប្អូន ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះបិតាជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គគង់នៅជាមួយយើងខ្ញុំតាមរយៈអគ្គសញ្ញានានា ។
សូមព្រះអង្គប្រោសឲ្យនំ និងស្រា ដែលយើងខ្ញុំលើកថ្វាយនៅពេលនេះ
បានទៅជាព្រះកាយ និងព្រះលោហិតព្រះយេស៊ូគ្រីស្តសម្រាប់យើងខ្ញុំ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាជាអម្ចាស់ !
ព្រះអង្គបានតាំងព្រះសហគមន៍ជាសញ្ញាសម្គាល់
នៃព្រះរាជ្យព្រះអង្គក្នុងពិភពលោកនេះ ។
សូមព្រះអង្គពង្រឹងជំនឿរបស់យើងខ្ញុំ
ឲ្យចេះបង្ហាញវត្តមានព្រះគ្រីស្តដល់បងប្អូនឯទៀតៗផង ។

# ថ្ងៃសុក្រ

Feria sexta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រោសឲ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ
ហើយទ្រង់ក៏បានប្រទានជីវិតថ្មីឲ្យយើងខ្ញុំ ។
សូមព្រះអង្គប្រទានឲ្យយើងខ្ញុំបានទទួលសិរីរុងរឿងនៅថ្ងៃណាមួយ
រួមជាមួយព្រះគ្រីស្តជាព្រះសង្គ្រោះយើងខ្ញុំ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ពេលនេះ ព្រះសហគមន៍នឹករឭកពីទុក្ខលំបាករបស់ព្រះយេស៊ូ
ដែលបានបូជាព្រះជន្មដើម្បីបង្កើតពិភពលោកថ្មី ។
សូមព្រះអង្គមេត្តាទទួលទុក្ខលំបាករបស់យើងខ្ញុំ និងទុក្ខលំបាករបស់មនុស្សលោក
រួមជាមួយសក្ការបូជារបស់ព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រោសឲ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ
ហើយប្រទានអាហារដែលផ្តល់ជីវិតដល់យើងខ្ញុំ ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿយើងខ្ញុំ
ឲ្យឈ្នះទុក្ខលំបាកទាំងឡាយដែលយើងខ្ញុំបានជួបប្រទះ ។

# ថ្ងៃសៅរ៍
# អភិបូជានៅពេលព្រឹក

Ad Missam matutinam

អភិបូជានេះប្រារព្ធនៅពេលព្រឹកថ្ងៃសៅរ៍ មុនបុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ (បុណ្យឱឡារិក) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គអប់រំចិត្តគំនិតយើងខ្ញុំឲ្យចេះធ្វើអំពើល្អអស់មួយជីវិត
ដោយរួមជាមួយព្រះគ្រីស្តជាព្រះបុត្រាព្រះអង្គ ។
សូមព្រះអង្គប្រោសប្រណីឲ្យយើងខ្ញុំភ្ជាប់ចិត្តនឹងគម្រោងដ៏អស្ចារ្យនៃបុណ្យចម្លង
ដែលនាំឲ្យជីវិតយើងខ្ញុំកាន់តែប្រសើរទៅៗ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ជាព្រះបិតា !
ព្រះអង្គទទួលតង្វាយរបស់យើងខ្ញុំទុកជាយញ្ញបូជា ដែលគាប់ព្រះហឫទ័យព្រះអង្គ ។
សូមប្រោសឲ្យជីវិតយើងខ្ញុំទៅជាតង្វាយអស់កល្បជានិច្ច
នៅចំពោះព្រះភ័ក្ត្រព្រះអង្គ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ទំព័រ ៤៤០-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រទានព្រះអំណោយទានដ៏អស្ចារ្យដល់យើងខ្ញុំពីសក្ការបូជានេះ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំចេះស្រឡាញ់គ្នាទៅវិញទៅមក
ដូចព្រះបុត្រាបានបង្រៀនយើងខ្ញុំ
ដើម្បីធ្វើជាសញ្ញាសម្គាល់នៃសេចក្តីស្រឡាញ់របស់ព្រះអង្គ ។

# បុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ

## IN ASCENSIONE DOMINI

(បុណ្យឱឡារិក)

Sollemnitas

# អភិបូជានៅពេលល្ងាច

Ad Missam in Vigilia

អភិបូជានេះប្រារព្ធនៅពេលល្ងាចថ្ងៃសៅរ៍ មុនបុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ (បុណ្យឱឡារិក) ។

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ជាព្រះបិតា !

ព្រះបុត្រាយាងឡើងស្ថានបរមសុខ នៅពេលក្រុមសាវ័កកំពុងតែសម្លឹងមើល ។

សូមព្រះអង្គប្រទានឲ្យយើងខ្ញុំមានកិត្តិយសដ៏ខ្ពស់ ដោយប្រោសឲ្យព្រះយេស៊ូគង់នៅជាមួយយើងខ្ញុំ

ក្នុងពេលដែលយើងខ្ញុំរស់នៅលើផែនដីនេះ និងនៅពេលយើងខ្ញុំនៅស្ថានបរមសុខ ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះបិតាជាអម្ចាស់ !

ព្រះយេស៊ូជាព្រះបុត្រាតែមួយព្រះអង្គគត់ ដែលជាមហាបូជាចារ្យរបស់យើងខ្ញុំ

ព្រះអង្គមានព្រះជន្មអស់កល្បជានិច្ច និងគង់នៅខាងស្ដាំព្រះបិតា

ដើម្បីទូលអង្វរឲ្យយើងខ្ញុំ ។

សូមព្រះអង្គប្រោសឲ្យយើងខ្ញុំហ៊ានទៅរកព្រះភ័ក្ត្រព្រះអង្គ

ដោយទុកចិត្តលើព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ ។

ធម៌ប្រារព្ធទី១ ឬទី២ បុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ ទំព័រ ៤៤៨-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !

ព្រះអង្គបានប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត

ដើម្បីបំភ្លឺឲ្យយើងខ្ញុំប្រាថ្នាតាំងទីលំនៅឯស្ថានបរមសុខ ។ សូមព្រះអង្គមេត្តាជំរុញឲ្យយើងខ្ញុំដើរឆ្ពោះទៅកាន់ស្ថានបរមសុខ

តាមព្រះគ្រីស្តដែលបានបើកផ្លូវនៅថ្ងៃនេះ ។

# អភិបូជានៅពេលថ្ងៃ

Ad Missam in Die

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
នៅថ្ងៃនេះ យើងខ្ញុំមានអំណរសប្បាយ
ដោយព្រះគ្រីស្តជាព្រះសង្គ្រោះយាងឡើងស្ថានបរមសុខ
ដើម្បីរៀបចំកន្លែងឲ្យយើងខ្ញុំ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំរស់នៅក្នុងលោកនេះ ដោយភ្ជាប់ចិត្តឯស្ថានបរមសុខ ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ជាព្រះបិតា !
នៅថ្ងៃនេះ យើងខ្ញុំសូមថ្វាយតង្វាយដើម្បីលើកតម្កើងព្រះបុត្រា
ដែលយាងឡើងស្ថានបរមសុខ និងគង់ខាងស្ដាំព្រះអង្គ ។
សូមព្រះអង្គមេត្តាទទួលតង្វាយនេះ
ហើយប្រោសឲ្យយើងខ្ញុំរួមរស់ជាមួយព្រះគ្រីស្ត
ឯស្ថានបរមសុខនៅថ្ងៃណាមួយផង ។

ធម៌ប្រារព្ធទី១ ឬទី២ បុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ ទំព័រ ៤៤៨-៤៥០ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពដែលគង់នៅអស់កល្បជានិច្ច !
ព្រះអង្គប្រោសឲ្យប្រជារាស្ត្រព្រះអង្គ នឹករឭកដល់គម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ ។
សូមព្រះអង្គពង្រឹងសេចក្ដីសង្ឃឹមរបស់យើងខ្ញុំ
ឲ្យខិតខំព្យាយាមរួមចិត្តគំនិតជាមួយព្រះអង្គផង ។

# ថ្ងៃចន្ទ

Feria secunda

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !

ព្រះអង្គប្រោសប្រទានឲ្យយើងខ្ញុំទៅជាបុត្រធីតារបស់ព្រះអង្គ សូមព្រះអង្គមេត្តាចាត់ព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅជាមួយយើងខ្ញុំយ៉ាងបរិបូណ៌ ដើម្បីបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំឲ្យស្គាល់ព្រះហឫទ័យព្រះអង្គ និងប្រព្រឹត្តតាមក្នុងគ្រប់កិច្ចការប្រចាំជីវិតរបស់យើងខ្ញុំ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !

សូមឲ្យសក្ការបូជាដ៏ល្អឥតខ្ចោះរបស់ព្រះបុត្រាព្រះអង្គ

ជម្រះចិត្តគំនិតយើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំបានទទួលព្រះអំណោយទានពីព្រះអង្គ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ឬ បុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ ទំព័រ ៤៥០ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់ជាព្រះបិតា !

ព្រះអង្គបានប្រោសយើងខ្ញុំឲ្យចូលរួម

ក្នុងគម្រោងការដ៏អស្ចារ្យនៃស្ថានបរមសុខ ។

សូមព្រះអង្គគង់នៅជាមួយយើងខ្ញុំជាប្រជារាស្ត្ររបស់ព្រះអង្គ

ហើយជួយយើងខ្ញុំឲ្យចាកចេញពីរបៀបរស់នៅចាស់ និងចូលក្នុងជីវិតថ្មី ។

# ថ្ងៃអង្គារ

Feria tertia

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
តាំងពីដើមរៀងមក ព្រះអង្គបាត់គ្រីស្តទូតឲ្យទៅប្រកាសដំណឹងល្អ
ស្តីអំពីព្រះគ្រីស្ត ដែលមានព្រះជន្មរស់ឡើងវិញរហូតមកដល់សព្វថ្ងៃនេះ ។
សូមព្រះអង្គមេត្តាប្រទានព្រះវិញ្ញាណដ៏វិសុទ្ធយាងមកណែនាំយើងខ្ញុំ ឲ្យចេះប្រកាស
ដំណឹងល្អនេះដូចគ្រីស្តទូតពីដើមផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់ដ៏វិសុទ្ធ !
ព្រះយេស៊ូគង់នៅជាមួយព្រះអង្គ ហើយទ្រង់ក៏គង់នៅជាមួយយើងខ្ញុំដែរ ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
និងណែនាំយើងខ្ញុំឲ្យឆ្ពោះទៅកាន់សិរីរុងនៃស្ថានបរមសុខ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ឬ បុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ ទំព័រ ៤៤៨ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ព្រះយេស៊ូបានបូជាព្រះជន្មផ្ទាល់របស់ព្រះអង្គសម្រាប់មនុស្សលោក ។ ក្នុងអភិបូជា
នេះ ព្រះអង្គបានប្រទានព្រះបន្ទូល និងព្រះកាយព្រះគ្រីស្ត
ឲ្យយើងខ្ញុំទុកជាអាហារដែលផ្តល់ជីវិត
សូមព្រះអង្គមេត្តាជួយយើងខ្ញុំដែលរស់នៅក្នុងលោកនេះនៅឡើយ
ឲ្យប្រព្រឹត្តតាមព្រះបន្ទូលព្រះអង្គដោយចិត្តស្មោះ ។

# ថ្ងៃពុធ

Feria quarta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះវិញ្ញាណយាងមកប្រមែប្រមូលយើងទាំងអស់គ្នាជាគ្រួសារតែមួយ
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យស្រឡាញ់ព្រះអង្គអស់ពីដួងចិត្ត
និងរួមរស់ជាមួយគ្នាជាធ្លុងតែមួយដោយចិត្តស្មោះ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះបិតាដ៏ជាទីស្រឡាញ់ !
យើងខ្ញុំជឿថា ព្រះយេស៊ូបានបូជាព្រះជន្មថ្វាយព្រះអង្គ
ដើម្បីឲ្យយើងខ្ញុំទៅជាប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំបានវិសុទ្ធដោយសារសេចក្ដីពិត ដោយបង្រួម
យើងខ្ញុំក្នុងសក្ការបូជារបស់ព្រះយេស៊ូគ្រីស្ត ដែលមានព្រះជន្មគង់នៅ និងសោយ
រាជ្យអស់កល្បជាអង្វែងតរៀងទៅ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ឬ បុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ ទំព័រ ៤៤៨ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ក្នុងអភិបូជានេះ ព្រះអង្គប្រោសឲ្យយើងខ្ញុំរួបរួមគ្នាជាធ្លុងតែមួយ ។
សូមព្រះអង្គមេត្តាថែរក្សាយើងខ្ញុំទាំងអស់គ្នាជាគ្រីស្តបរិស័ទ
ទាំងគ្រប់និកាយឲ្យគោរពគ្នាទៅវិញទៅមក
និងយកចិត្តទុកដាក់រួបរួមគ្នាក្នុងព្រះនាមព្រះយេស៊ូគ្រីស្ត ។

# ថ្ងៃព្រហស្បតិ៍

Feria quinta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏សប្បុរស !
សូមព្រះអង្គមេត្តាប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ
យាងមកកែប្រែចិត្តគំនិតរបស់យើងខ្ញុំ ឲ្យស្ម័គ្រចិត្តធ្វើតាមព្រះបំណងព្រះអង្គ
និងបានគាប់ព្រះហឫទ័យព្រះអង្គគ្រប់ពេលវេលា ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ជាព្រះបិតាដ៏សប្បុរស !
ព្រះអង្គបានប្រោសនំប៉័ង និងស្រានេះ
ឲ្យទៅជាព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ។
សូមព្រះអង្គទទួលកាយ វាចា ចិត្តរបស់យើងខ្ញុំ
ទុកជាតង្វាយដែលគាប់ព្រះហឫទ័យព្រះអង្គផង ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ឬ បុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ ទំព័រ ៤៤៨ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ពេលយើងខ្ញុំទទួលព្រះកាយព្រះគ្រីស្ត
យើងខ្ញុំរួបរួមយ៉ាងជិតស្និទ្ធជាមួយព្រះអង្គ ។
សូមទ្រង់ព្រះមេត្តាប្រោសឲ្យគ្រីស្តបរិស័ទទាំងអស់ចេះរួបរួមគ្នាជាធ្លុងតែមួយ
ដើម្បីឲ្យមនុស្សលោកសព្វថ្ងៃនេះជឿថា
ព្រះអង្គពិតជាបានចាត់ព្រះយេស៊ូឲ្យយាងមកសង្គ្រោះមនុស្សលោកមែន ។

# ថ្ងៃសុក្រ

Feria sexta

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាប្រកបដោយធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះអង្គលើកតម្កើងព្រះយេស៊ូឲ្យមានសិរីរុងរឿងរួមជាមួយព្រះអង្គ ។
ព្រះអង្គចាត់ព្រះវិញ្ញាណដ៏វិសុទ្ធមកបំភ្លឺចិត្តរបស់យើងខ្ញុំឲ្យមានជំនឿមាំមួន និង
បើកផ្លូវឲ្យយើងខ្ញុំចូលទៅក្នុងជីវិតអស់កល្បជានិច្ច ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះបិតាដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះយេស៊ូលើកលែងទោសឲ្យលោកសិលាដែលក្បត់ព្រះអង្គ ព្រមទាំងផ្ញើមុខងារ
ឲ្យលោកណែនាំព្រះសហគមន៍ ។
ក្នុងអភិបូជានេះ សូមព្រះអង្គមេត្តាប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ
ឲ្យយើងខ្ញុំមានចិត្តស្រឡាញ់ព្រះអង្គស្មោះអស់ពីចិត្ត ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ឬ បុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ ទំព័រ ៤៤៨ ។

## ពាក្យអរព្រះគុណ

ឱ ព្រះបិតាដ៏ជាទីស្រឡាញ់ !
ព្រះអង្គប្រទានព្រះកាយព្រះគ្រីស្តទុកជាអាហារដែលផ្តល់កម្លាំង
នៅពេលយើងខ្ញុំកំពុងធ្វើដំណើរនៅនាលោកនេះ ។ សូមព្រះអង្គមេត្តាចាត់ព្រះ
វិញ្ញាណដ៏វិសុទ្ធយាងមក
បង្ហាញផ្លូវឲ្យយើងខ្ញុំដើរតាមព្រះអង្គ ។

# ថ្ងៃសៅរ៍
# អភិបូជានៅពេលព្រឹក

Ad Missam matutinam

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំទើបបានប្រារព្ធពិធីបុណ្យចម្លង ។
សូមព្រះអង្គប្រោសប្រទានឲ្យយើងខ្ញុំថែរក្សាអំណោយទាន
ដែលមកពីព្រះអង្គក្នុងជីវិតប្រចាំថ្ងៃរបស់យើងខ្ញុំ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះបិតាយើងខ្ញុំ !
ព្រះអង្គបានចាត់ព្រះវិញ្ញាណដ៏វិសុទ្ធ
ឲ្យយាងមកលើកលែងទោស និងរៀបចំចិត្តគំនិតយើងខ្ញុំ
ដើម្បីទទួលអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត ។
សូមព្រះអង្គមេត្តាប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ
មកគង់នៅជាមួយយើងខ្ញុំជារៀងរហូត ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យចម្លង ឬ បុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ ទំព័រ ៤៤៨ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់ជាប្រភពនៃជីវិតគ្រប់យ៉ាង !
ព្រះអង្គប្រោសឲ្យយើងខ្ញុំទទួលអគ្គសញ្ញាជ្រមុជទឹក និងព្រះកាយព្រះគ្រីស្ត
សូមឲ្យយើងខ្ញុំបាកចេញពីរបៀបរស់នៅចាស់ ដើម្បីទទួលរបៀបរស់នៅថ្មី
ស្របតាមឋានៈរបស់ខ្លួន ជាបុត្រធីតារបស់ព្រះអង្គ ។

# បុណ្យលើកតម្កើងព្រះវិញ្ញាណយាងមក

## DOMINICA PENTECOSTES

(បុណ្យឱឡារិក)

Sollemnitas

# អភិបូជានៅពេលល្ងាច

Ad Missam in Vigilia

អភិបូជានៅពេលល្ងាចថ្ងៃសៅរ៍នេះ អាចប្រារព្ធបានមុន ឬក្រោយអធិដ្ឋានពេលល្ងាចតាមពេលកំណត់ (សប្ដាហ៍ទីមួយ) ។ ព្រះសហគមន៍ដែលថ្វាយអភិបូជាពេលល្ងាចតាមរបៀបវែង អាចធ្វើតាមឧបសម្ព័ន្ធក្បួនពិធីអភិបូជាក្រុងរ៉ូម ទំព័រ ១២៧១ (Missale Romanum, Editio Typica Tertia, 2008, Supplementum Ad Missam in Vigilia Pentecostes, p. 1271) ។

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
អស់រយៈពេលហាសិបថ្ងៃ ព្រះអង្គប្រោសឲ្យយើងខ្ញុំជួបជុំគ្នាអបអរសាទរ
បុណ្យចម្លងដែលជាគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ ។
សូមព្រះអង្គបង្រួបបង្រួមមនុស្សគ្រប់ជាតិសាសន៍ដែលបែកខ្ញែកគ្នា
ឲ្យទៅជាមហាគ្រួសារតែមួយ និងសូមប្រោសឲ្យប្រជាជន
ដែលប្រឫកប្រចប់និយាយភាសាផ្សេងៗខ្លួនរួមគ្នាប្រកាសព្រះនាមព្រះអង្គវិញ ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
សូមព្រះអង្គចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធមកញ៉ាំងតង្វាយនេះ សូមឲ្យសេចក្ដីស្រឡាញ់របស់ព្រះអង្គជ្រាបចូលក្នុងព្រះសហគមន៍
ដើម្បីឲ្យសេចក្ដីពិតនៃព្រះសង្គ្រោះបញ្ចេញពន្លឺចែងចាំងលើមនុស្សលោកទាំងមូល ។

ធម៌ប្រារព្ធ បុណ្យលើកតម្កើងព្រះវិញ្ញាណដ៏វិសុទ្ធយាងមក ទំព័រ ៣៤៥ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់ដ៏សប្បុរស !
យើងខ្ញុំទើបបានទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ។
សូមព្រះវិញ្ញាណដែលព្រះអង្គបានចាក់បង្ហូរនៅលើក្រុមគ្រីស្តទូត
ឆេះសន្ធោសន្ធៅក្នុងដួងចិត្តយើងខ្ញុំជានិច្ច ។

# អភិបូជានៅពេលថ្ងៃ

Ad Missam in die

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់ !

ព្រះអង្គប្រោសឲ្យយើងខ្ញុំប្រារព្ធពិធីបុណ្យដ៏ឱឡារិកនេះ និងប្រទានឲ្យព្រះសហគមន៍នៅគ្រប់ទីកន្លែងបានវិសុទ្ធ ។

សូមព្រះអង្គចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធមកលើផែនដីទាំងមូល ។

សូមឲ្យព្រះហឫទ័យប្រណីសន្ដោស ដែលបានណែនាំការប្រកាសដំណឹងល្អកាលពីដើម បន្តណែនាំយើងខ្ញុំជាអ្នកជឿសព្វថ្ងៃនេះផង ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !

សូមព្រះអង្គមេត្តាប្រទានព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅជាមួយយើងខ្ញុំ តាមព្រះបន្ទូលសន្យានៃព្រះបុត្រាព្រះអង្គ ។

ក្នុងអភិបូជានេះ សូមព្រះវិញ្ញាណបំភ្លឺចិត្តគំនិត និងណែនាំយើងខ្ញុំឲ្យស្គាល់សេចក្ដីពិតគ្រប់យ៉ាង ហើយយល់ពីគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ ។

ធម៌ប្រារព្ធ ៖ បុណ្យលើកតម្កើងព្រះវិញ្ញាណដ៏វិសុទ្ធយាងមក (De mysterio Pentecostes) ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណព្រះអម្ចាស់ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធបំផុត និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច !
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ព្រះអង្គបានប្រោសប្រទានព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយើងខ្ញុំ ដើម្បីឲ្យគម្រោងការដ៏អស្ចារ្យនៃបុណ្យចម្លងបានពេញលក្ខណៈ ។
កាលព្រះសហគមន៍ទើបកើតមក ព្រះវិញ្ញាណប្រោសឲ្យមនុស្សគ្រប់ជាតិសាសន៍ស្គាល់ព្រះអង្គជាព្រះដ៏ពិតប្រាកដតែមួយ ដើម្បីឲ្យគេប្រកាសជំនឿតែមួយតាមភាសារៀងៗខ្លួន ។

អាស្រ័យហេតុនេះហើយ បានជាមនុស្សទូទាំងសកលលោក
មានអំណរសប្បាយរីករាយក្នុងបុណ្យចម្លង
ហើយចូលរួមជាមួយអស់ទេវទូត និងឫទ្ធានុភាពនៃស្ថានបរមសុខ
ច្រៀងកោតសរសើរសិរីរុងរឿងរបស់ព្រះអង្គឥតឈប់ឈរ
ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ព្រះដ៏វិសុទ្ធ ព្រះដ៏វិសុទ្ធ...

បើលោកបូជាចារ្យជ្រើសរើសធម៌អរព្រះគុណដ៏វិសុទ្ធទី១ (Canon Romanus) បន្ទាប់មកលោកត្រូវអានពាក្យអធិដ្ឋានបុណ្យថ្ងៃទីហាសិប នៅទំព័រ ៥២៦ ។

## ពាក្យអរព្រះគុណ

ឱ ព្រះបិតាជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គថែរក្សាព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធ
ដែលព្រះអង្គបានចាក់បង្ហូរលើព្រះសហគមន៍ ។
សូមព្រះអង្គប្រោសឲ្យព្រះអំណោយទាននេះ ផ្តល់កម្លាំងដល់ព្រះសហគមន៍
និងបង្កើនផលផ្លែឲ្យមនុស្សលោកទទួលការសង្គ្រោះ ។

# ពាក្យអធិដ្ឋាន ក្នុងរដូវធម្មតា
# « ប្រចាំឆ្នាំ »

TEMPUS « PER ANNUM »

# ថ្ងៃអាទិត្យទី ១ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

HEBDOMADA I «PER ANNUM»

ថ្ងៃអាទិត្យទី១ ក្នុងរដូវធម្មតា ជាថ្ងៃបុណ្យព្រះយេស៊ូទទួលពិធីជ្រមុជទឹក នៅទំព័រ ១៦១ ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់អើយ !

សូមព្រះអង្គមេត្តាព្រះសណ្ដាប់ពាក្យអង្វររបស់ប្រជារាស្ត្រព្រះអង្គ ឲ្យយល់កាន់តែច្បាស់អំពីកិច្ចការដែលយើងខ្ញុំត្រូវប្រព្រឹត្ត និងប្រោសឲ្យយើងខ្ញុំមានកម្លាំងសម្រេចកិច្ចការទាំងនោះ

តាមព្រះហឫទ័យព្រះអង្គ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !

ព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយ

ដែលកើតមកពីញើសឈាមរបស់យើងខ្ញុំ ។

សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំបានវិសុទ្ធ និងប្រទាននូវអ្វីៗដែលយើងខ្ញុំបានសូមពីព្រះអង្គផង ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !

យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយ

និងព្រះលោហិតរបស់ព្រះគ្រីស្តឲ្យយើងខ្ញុំ ។

សូមព្រះអង្គប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកបំភ្លឺចិត្តគំនិតយើងខ្ញុំ

ឲ្យរស់នៅស្របតាមឋានៈរបស់ខ្លួនជាបុត្រធីតារបស់ព្រះអង្គ ។

# ថ្ងៃអាទិត្យទី ២ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA II «PER ANNUM»

### ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ
និងមានព្រះជន្មគង់នៅជានិច្ច !
ព្រះអង្គគ្រប់គ្រងលើអ្វីៗទាំងអស់
ដែលនៅលើមេឃ និងផែនដីទាំងមូល ។
សូមព្រះអង្គមេត្តាព្រះសណ្ដាប់ពាក្យអង្វរប្រជារាស្ត្រព្រះអង្គ និងផ្ដល់សុខសន្តិភាព
ដល់យើងខ្ញុំសព្វថ្ងៃនេះ ។

### ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំចូលរួមក្នុងអភិបូជាដោយសមរម្យ
ដ្បិតតាមរយៈសក្ការបូជានេះ
យើងខ្ញុំទទួលការសង្គ្រោះពីព្រះអង្គ ។

### ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់យើងខ្ញុំ !
សូមព្រះអង្គចាក់បង្ហូរព្រះវិញ្ញាណនៃសេចក្ដីស្រឡាញ់
ដើម្បីឲ្យយើងខ្ញុំមានចិត្តថ្លើមតែមួយ
ដោយសារព្រះកាយតែមួយរបស់ព្រះគ្រីស្ដ ។

# ថ្ងៃអាទិត្យទី ៣ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA III «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ
និងមានព្រះជន្មគង់នៅជានិច្ច ! ព្រះអង្គសព្វព្រះហឫទ័យត្រាស់ហៅយើងខ្ញុំឲ្យស្គាល់ដំណឹងល្អ
និងប្រោសឲ្យយើងខ្ញុំធ្វើជាប្រជារាស្ត្រផ្ទាល់របស់ព្រះអង្គ សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យទទួលព្រះបន្ទូលព្រះអង្គដោយចិត្តស្មោះជានិច្ច ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
យើងខ្ញុំសូមថ្វាយនំ និងស្រានេះ
ជានិមិត្តរូបនៃកិច្ចការរបស់មនុស្សលោកទាំងមូលសម្រាប់ចិញ្ចឹមជីវិត ។
សូមព្រះអង្គមេត្តាប្រោសឲ្យមនុស្សគ្រប់ជាតិសាសន៍
រួបរួមគ្នាជាធ្លុងតែមួយ និងរាប់គ្នាទុកជាបងប្អូនផង ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្តឲ្យយើងខ្ញុំទុកជាអាហារ ។
សូមព្រះអង្គមេត្តាប្រោសប្រណីឲ្យយើងខ្ញុំមានអំណរសប្បាយ
ដោយបានចូលរួមក្នុងព្រះរាជ្យព្រះអង្គ ។

# ថ្ងៃអាទិត្យទី ៤ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA IV «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គសព្វព្រះហឫទ័យចាត់ព្រះបុត្រាឲ្យយាងមករំដោះយើងខ្ញុំ
និងប្រទានសេចក្ដីសុខសាន្ដយ៉ាងបរិបូរណ៍ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ
ចេះគោរពស្រឡាញ់ព្រះអង្គអស់ពីដួងចិត្ត
និងប្រព្រឹត្តតាមដោយយកចិត្តទុកដាក់ជានិច្ច ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់ដ៏សប្បុរស !
ព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយពីយើងខ្ញុំជាបុត្រធីតារបស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាញ៉ាំងតង្វាយទាំងនេះ
ឲ្យទៅជាព្រះកាយ និងព្រះលោហិតរបស់ព្រះយេស៊ូគ្រីស្ដជាព្រះអម្ចាស់យើងខ្ញុំ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គបានប្រទានព្រះកាយ និងព្រះលោកហិតព្រះគ្រីស្ដ
ទុកជាអាហារសម្រាប់ចិញ្ចឹមជីវិតយើងខ្ញុំ ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿ និងប្រទានការសង្គ្រោះ
អស់កល្បជានិច្ចដល់យើងខ្ញុំ ។

# ថ្ងៃអាទិត្យទី ៥ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA V «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យត្រាស់ហៅយើងខ្ញុំ
ឲ្យរួមរស់ក្នុងព្រះសហគមន៍របស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាថែរក្សាការពារមហាគ្រួសាររបស់ព្រះអង្គ
តាមសេចក្ដីសង្ឃឹមរបស់យើងខ្ញុំផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ជាព្រះបិតាយើងខ្ញុំ !
ព្រះអង្គបានបង្កើតអ្វីៗទាំងអស់ដែលមានក្នុងពិភពលោក
ដើម្បីចិញ្ចឹមជីវិតយើងខ្ញុំ ។
សូមព្រះអង្គប្រោសឲ្យនំប៉័ង និងស្រានេះ បានទៅជាអាហារ
ដែលផ្ដល់ជីវិតអស់កល្បជានិច្ចដល់យើងខ្ញុំ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាជាអម្ចាស់ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រោសយើងខ្ញុំ
ឲ្យទទួលព្រះកាយព្រះគ្រីស្ដដែលជាប្រភពនៃជីវិត ។
សូមព្រះអង្គជួយឲ្យយើងខ្ញុំចេះស្រោចស្រង់មនុស្សដែលមានទុក្ខលំបាក
ដោយមិនប្រកាន់វណ្ណៈ ឬឋានៈអ្វីឡើយ ។

# ថ្ងៃអាទិត្យទី ៦ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA VI «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យគង់ក្នុងចិត្តមនុស្សសុចរិតទៀងត្រង់ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ
រស់នៅតាមរបៀបដែលគាប់ព្រះហឫទ័យព្រះអង្គ និងសូមយាងមកតាំងទីលំនៅ
ក្នុងដួងចិត្តរបស់យើងខ្ញុំជានិច្ច ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គតែងតែទទួលតង្វាយរបស់យើងខ្ញុំ
ដោយព្រះហឫទ័យអនុគ្រោះ ។
សូមព្រះអង្គមេត្តាជម្រះចិត្តគំនិតរបស់យើងខ្ញុំ
និងផ្ដល់កម្លាំងចិត្តថ្មីឲ្យយើងខ្ញុំប្រព្រឹត្តតាមព្រះហឫទ័យព្រះអង្គជានិច្ច ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គបានប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្ដឲ្យយើងខ្ញុំ
ទុកជាអាហារដែលផ្ដល់អំណរសប្បាយដ៏បរិបូណ៌ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំរស់នៅយ៉ាងសមរម្យ
ស្របតាមព្រះអំណោយទានរបស់ព្រះអង្គ ។

# ថ្ងៃអាទិត្យទី ៧ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA VII «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គមានធម៌មេត្តាករុណាដ៏លើសលប់ចំពោះមនុស្សគ្រប់ៗរូប ។
សូមព្រះអង្គប្រោសឲ្យពាក្យសម្ដី និងកិច្ចការដែលយើងខ្ញុំប្រព្រឹត្ត
បានគាប់តាមព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គជានិច្ច ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ដ៏វិសុទ្ធ !
ព្រះយេស៊ូជាព្រះបុត្រាព្រះអង្គបានបូជាព្រះជន្ម ដើម្បីសម្រុះសម្រួលមនុស្សដែលបាក់បែកគ្នាឲ្យចូលរួមជាធ្លុងតែមួយ ។
សូមព្រះអង្គមេត្តាទទួលតង្វាយរបស់យើងខ្ញុំ រួមជាមួយនឹងសក្ការបូជារបស់ព្រះគ្រីស្ដ
ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំបានទទួលការសង្គ្រោះពីព្រះយេស៊ូជាព្រះបុត្រាព្រះអង្គ ។
សូមព្រះអង្គប្រោសប្រណីឲ្យយើងខ្ញុំរស់នៅ
យ៉ាងជ្រៅក្នុងអាថ៌កំបាំងនៃការសង្គ្រោះនោះ ។

# ថ្ងៃអាទិត្យទី ៨ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA VIII «PER ANNUM»

### ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យមនុស្សលោករស់នៅក្នុងសេចក្ដីសុខសាន្តជានិច្ច ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំទៅជាបុត្រធីតាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ដោយមានអំណរសប្បាយបម្រើព្រះអង្គ អស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ។

### ពាក្យថ្វាយតង្វាយ

បពិត្រព្រះបិតាជាអម្ចាស់ !
យើងខ្ញុំគ្មានតង្វាយអ្វីយកមកថ្វាយព្រះអង្គទេ ក្រៅពីព្រះអំណោយទានដែលបានមកពីព្រះអង្គ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំទទួលអំណរសប្បាយក្នុងលោកនេះ
និងលោកខាងមុខរួមជាមួយព្រះអង្គផង ។

### ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គបានប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត
ដើម្បីជាអាហារចិញ្ចឹមជីវិតយើងខ្ញុំ ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យទទួលជីវិតអស់កល្បជានិច្ច
តាមរយៈអគ្គសញ្ញានេះ ។

# ថ្ងៃអាទិត្យទី ៩ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA IX «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាដ៏មានព្រះហឫទ័យដ៏សប្បុរស !
ព្រះអង្គចាត់ចែងអ្វីៗទាំងអស់តាមគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាកម្ចាត់ឧបទ្រពទាំងឡាយចេញពីយើងខ្ញុំ និងប្រទាននូវអ្វីៗដែល
នាំឲ្យយើងខ្ញុំបានប្រកបដោយសេចក្ដីសុខសាន្ត ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយ
ដែលយើងខ្ញុំលើកថ្វាយនៅលើតុសក្ការបូជានេះ ។
សូមព្រះអង្គមេត្តាបញ្ជូលយើងខ្ញុំរួមជាមួយសក្ការបូជារបស់ព្រះគ្រីស្ដ
និងជម្រះយើងខ្ញុំឲ្យបានរួចពីបាប ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គបានប្រទានព្រះកាយ និងព្រះលោហិតព្រះបុត្រាឲ្យយើងខ្ញុំ
ទុកជាអាហារដែលផ្ដល់ជីវិត ។
សូមព្រះអង្គចាត់ព្រះវិញ្ញាណដ៏វិសុទ្ធមកបំភ្លឺយើងខ្ញុំ
ឲ្យចេះផ្ដល់សក្ខីភាពថ្វាយព្រះអង្គ
ដោយមិនគ្រាន់តែពោលពាក្យសម្ដីប៉ុណ្ណោះទេ
គឺប្រព្រឹត្តតាមសេចក្ដីពិត ។

# ថ្ងៃអាទិត្យទី ១០ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA X «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់អើយ !
ព្រះអង្គជាដើមកំណើតនៃអំពើល្អគ្រប់យ៉ាង ហើយតែងតែព្រះសណ្ដាប់ពាក្យអង្វរ
របស់យើងខ្ញុំ
ដោយមិននឿយណាយឡើយ
សូមព្រះអង្គមេត្ដាបំភ្លឺចិត្ដគំនិតរបស់យើងខ្ញុំឲ្យស្គាល់នូវអ្វីៗដ៏សុចរិត និងប្រោសឲ្យ
យើងខ្ញុំចេះប្រព្រឹត្ដអំពើសុចរិតដូចព្រះអង្គ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
យើងខ្ញុំស្ម័គ្រចិត្តបម្រើព្រះអង្គ
សូមឲ្យតង្វាយរបស់យើងខ្ញុំដែលរួមជាមួយសក្ការបូជារបស់ព្រះគ្រីស្ដ
បានគាប់ព្រះហឫទ័យព្រះអង្គ ។
សូមព្រះអង្គមេត្ដាប្រោសឲ្យយើងខ្ញុំមានសេចក្ដីស្រឡាញ់ចំពោះព្រះអង្គ និងចំពោះ
អ្នកដទៃកាន់តែខ្លាំងឡើងៗ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ដ៏សប្បុរស !
ព្រះអង្គសព្វព្រះហឫទ័យប្រោសឲ្យយើងខ្ញុំ
បានជាសះស្បើយដោយសារអភិបូជានេះ ។
សូមព្រះអង្គមេត្ដារំដោះយើងខ្ញុំឲ្យរួចផុតពីអំពើបាបគ្រប់បែបយ៉ាង និងតម្រង់ជីវិត
របស់យើងខ្ញុំឲ្យប្រព្រឹត្ដតែអំពើល្អ ។

# ថ្ងៃអាទិត្យទី ១១ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XI «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់អើយ !
ព្រះអង្គពិតជាកម្លាំងការពារដល់អស់អ្នកទន់ខ្សោយ
ដែលផ្ញើជីវិតលើព្រះអង្គ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំមានចិត្តក្លាហាន
ប្រព្រឹត្តតែកិច្ចការណាដែលគាប់ព្រះហឫទ័យព្រះអង្គ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះបិតាជាអម្ចាស់ !
ព្រះអង្គចិញ្ចឹមយើងខ្ញុំដោយប្រទានម្ហូបអាហារ
និងប្រទានកម្លាំងខាងផ្លូវវិញ្ញាណតាមរយៈអគ្គសញ្ញា ។
សូមព្រះអង្គមេត្តាប្រោសឲ្យអាហារទាំងនេះ
គាំទ្រដំណើរជីវិតរបស់យើងខ្ញុំជានិច្ច ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់ដ៏សប្បុរស !
ព្រះអង្គប្រោសឲ្យយើងខ្ញុំទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត
ជាសញ្ញាសម្គាល់បញ្ជាក់ថា ព្រះសហគមន៍ជាធ្លុងតែមួយនឹងព្រះជាម្ចាស់ ។
សូមព្រះអង្គប្រោសប្រណីឲ្យយើងខ្ញុំធ្វើជាសាក្សីបង្ហាញថា
យើងខ្ញុំជាព្រះសហគមន៍តែមួយ ។

# ថ្ងៃអាទិត្យទី ១២ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XII «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គមិនដែលបោះបង់ចោលអស់អ្នក
ដែលពឹងផ្អែកលើសេចក្ដីស្រឡាញ់របស់ព្រះអង្គឡើយ ។
សូមព្រះអង្គណែនាំយើងខ្ញុំឲ្យបេះគោរព
និងកោតសរសើរព្រះនាមព្រះអង្គក្នុងជីវិតប្រចាំថ្ងៃរបស់យើងខ្ញុំ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
សូមព្រះអង្គមេត្តាទទួលតង្វាយពីយើងខ្ញុំ
ដែលរួមគ្នាជាព្រះសហគមន៍កោតសរសើរ និងលើកតម្កើងព្រះអង្គ ។
សូមព្រះអង្គជម្រះចិត្តគំនិតយើងខ្ញុំឲ្យបានគាប់ព្រះហឫទ័យព្រះអង្គផង ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គបានប្រទានព្រះកាយ និងព្រះលោហិតរបស់ព្រះបុត្រាឲ្យយើងខ្ញុំ
ទុកជាអាហារផ្ដល់កម្លាំងជារៀងរាល់ថ្ងៃ ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿរបស់យើងខ្ញុំ
ឲ្យភ្ជាប់ចិត្តនឹងព្រះអង្គជានិច្ច ដើម្បីទទួលការសង្គ្រោះ ។

# ថ្ងៃអាទិត្យទី ១៣ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XIII «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាដ៏សប្បុរស !
ព្រះអង្គសព្វព្រះហឫទ័យប្រោសឲ្យយើងខ្ញុំទៅជាបុត្រធីតានៃព្រះពន្លឺ ។
សូមព្រះអង្គមេត្តាការពារយើងខ្ញុំកុំឲ្យធ្លាក់ក្នុងភាពងងឹត តែប្រោសឲ្យយើងខ្ញុំរស់នៅក្នុងពន្លឺដ៏ត្រចះត្រចង់នៃសេចក្ដីពិតជានិច្ច ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះបិតាជាអម្ចាស់ !
ព្រះយេស៊ូសព្វព្រះហឫទ័យបូជាព្រះជន្ម ដើម្បីសម្ដែងធម៌មេត្តាករុណារបស់ព្រះអង្គចំពោះយើងខ្ញុំ ។ សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្ត និងកិច្ចការបម្រើរបស់យើងខ្ញុំ
រួមជាមួយសក្ការបូជារបស់ព្រះយេស៊ូគ្រីស្ដ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គសព្វព្រះហឫទ័យប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្ដឲ្យយើងខ្ញុំទុកជាអាហារដែលផ្ដល់ជីវិត ។ សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបង្កើតផលផ្លែនៃសេចក្ដីស្រឡាញ់
ដោយបេះគោរពបម្រើព្រះអង្គ និងបម្រើអ្នកដទៃយ៉ាងស្មោះ ។

# ថ្ងៃអាទិត្យទី ១៤ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XIV «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានព្រះហឫទ័យសប្បុរស !
ព្រះបុត្រាបានបន្ទាបព្រះអង្គ ដើម្បីលើកមនុស្សលោកឲ្យរួមរស់ជាមួយព្រះអង្គ ។
សូមព្រះអង្គមេត្តាប្រោសឲ្យអស់អ្នកដែលព្រះអង្គលោះចេញពីអំពើបាប បានពោរពេញដោយអំណរសប្បាយអស់កល្បជានិច្ច ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
យើងខ្ញុំសូមលើកតង្វាយថ្វាយទៅព្រះនាមព្រះអង្គ ។
សូមព្រះអង្គមេត្តាជម្រះចិត្តគំនិត និងតម្រង់អាកប្បកិរិយារបស់យើងខ្ញុំ
ឲ្យឆ្ពោះទៅរកជីវិតឯស្ថានបរមសុខ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គបានប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំ
ទុកជាអាហារប្រចាំជីវិត ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំទទួលការសង្គ្រោះ
ដែលជាព្រះអំណោយទានមកពីព្រះអង្គ
និងសូមឲ្យយើងខ្ញុំចេះកោតសរសើរព្រះអង្គជានិច្ចផង ។

# ថ្ងៃអាទិត្យទី ១៥ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XV «PER ANNUM»

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាអម្ចាស់ !
ព្រះអង្គតែងតែប្រទានពន្លឺនៃសេចក្ដីពិត
ឲ្យអស់អ្នកដែលឃ្លាតឆ្ងាយពីព្រះអង្គ
អាចវិលត្រឡប់មករកមាគ៌ារបស់ព្រះអង្គវិញបាន ។ សូមព្រះអង្គមេត្តាប្រោសឲ្យគ្រីស្ដបរិស័ទជ្រួតជ្រាបនូវព្រះបន្ទូលព្រះអង្គ
និងលះបង់អ្វីៗដែលមិនសមនឹងឋានៈរបស់ខ្លួនផង ។

ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
យើងខ្ញុំសូមថ្វាយកាយ វាចា ចិត្តរួមជាមួយនំប៉័ង និងស្រានេះ ។
សូមព្រះអង្គប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកញ៉ាំងចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យបានគាប់ព្រះហឫទ័យព្រះអង្គ ។

ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ដ៏វិសុទ្ធ !
ព្រះអង្គប្រទានព្រះបន្ទូលព្រះគ្រីស្ដ
ទុកជាអាហារប្រចាំជីវិតរបស់យើងខ្ញុំ ។
សូមព្រះអង្គប្រោសយើងខ្ញុំដែលទទួលព្រះកាយព្រះគ្រីស្ដនៅពេលនេះ បានទទួលផលនូវព្រះអំណោយទាននៃការសង្គ្រោះ
តាមគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គផង ។

# ថ្ងៃអាទិត្យទី ១៦ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XVI «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គសព្វព្រះហឫទ័យឲ្យប្រជារាស្ត្រព្រះអង្គ
មានសុភមង្គលដ៏ពេញលេញ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំមានជំនឿ សេចក្តីសង្ឃឹម
និងសេចក្តីស្រឡាញ់កាន់តែខ្លាំងឡើងៗ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាម្ចាស់ជាព្រះបិតា !
ព្រះយេស៊ូបានបូជាព្រះជន្មនៅលើឈើឆ្កាង
ទុកជាសក្ការបូជាដ៏ល្អឥតខ្ចោះសម្រាប់យើងខ្ញុំ ។
សូមព្រះអង្គមេត្តាទទួលកាយ វាចា ចិត្តដែលយើងខ្ញុំថ្វាយ
រួមជាមួយនឹងសក្ការបូជារបស់ព្រះបុត្រាព្រះអង្គ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់ជាព្រះបិតា !
ព្រះអង្គសព្វព្រះហឫទ័យគង់នៅជាមួយយើងខ្ញុំជានិច្ច ។
សូមព្រះអង្គប្រោសប្រណីដល់យើងខ្ញុំ
ដែលទទួលព្រះកាយព្រះគ្រីស្តនៅពេលនេះ
បានរស់នៅតាមរបៀបថ្មីស្របតាមព្រះអំណោយទានរបស់ព្រះអង្គ ។

# ថ្ងៃអាទិត្យទី ១៧ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XVII «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
មានតែព្រះអង្គទេដែលជាគ្រឹះដ៏រឹងមាំនៃពិភពទាំងមូល ហើយផ្តល់ឲ្យអ្វីៗទាំងអស់បានវិសុទ្ធ ។
ប្រសិនបើព្រះអង្គមិនជួយណែនាំទេ យើងខ្ញុំពុំអាចប្រព្រឹត្តកិច្ចការដ៏ល្អណាមួយបានឡើយ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំចេះប្រើសម្បត្តិក្នុងលោកនេះ ដោយភ្ជាប់ចិត្តនឹងសម្បត្តិឯស្ថានបរមសុខជានិច្ច ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
យើងខ្ញុំសូមថ្វាយតង្វាយទាំងនេះ
ដែលកើតមកពីធម៌មេត្តាករុណារបស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាប្រោសជីវិតប្រចាំថ្ងៃរបស់យើងខ្ញុំឲ្យបានវិសុទ្ធ
ដោយអគ្គសញ្ញាព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់ដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
យើងខ្ញុំទើបនឹងទទួលព្រះកាយព្រះគ្រីស្ត
ដែលរំឭកពីទុក្ខលំបាករបស់ព្រះបុត្រាព្រះអង្គ ។
សូមព្រះអង្គប្រោសឲ្យព្រះអំណោយទាន ដែលពោរពេញដោយសេចក្តីស្រឡាញ់នេះ ផ្តល់ការសង្គ្រោះដល់យើងខ្ញុំជានិច្ច ។

# ថ្ងៃអាទិត្យទី ១៨ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XVIII «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គតែងតែបង្ហាញធម៌មេត្តាករុណាដ៏លើសលប់
ដល់អស់អ្នកដែលទូលអង្វរព្រះអង្គដោយចិត្តស្មោះ ។
សូមព្រះអង្គមេត្តាថែរក្សាការពារ និងណែនាំយើងខ្ញុំ
ដោយប្រទានជីវិតថ្មីឲ្យយើងខ្ញុំតាមព្រះហឫទ័យរបស់ព្រះអង្គ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់ដ៏សប្បុរស !
យើងខ្ញុំសូមយកនំប៉័ង និងស្រានេះមកថ្វាយព្រះអង្គ ។
សូមព្រះអង្គមេត្តាទទួលសក្ការបូជានេះ និងប្រោសឲ្យយើងខ្ញុំទៅជាតង្វាយអស់កល្បជានិច្ចរួមជាមួយព្រះគ្រីស្ត ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គគង់នៅ និងការពារយើងខ្ញុំដែលកើតជាថ្មី
ដោយបានទទួលព្រះអំណោយទានពីស្ថានបរមសុខ ។
សូមព្រះអង្គមេត្តាថែទាំយើងខ្ញុំឥតឈប់ឈរ
ដើម្បីឲ្យយើងខ្ញុំសមនឹងទទួលការសង្គ្រោះអស់កល្បជានិច្ច ។

# ថ្ងៃអាទិត្យទី ១៩ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XIX «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វការ និងមានព្រះជន្មគង់នៅជានិច្ច !
ព្រះវិញ្ញាណដ៏វិសុទ្ធប្រោសឲ្យយើងខ្ញុំហ៊ានហៅព្រះអង្គថា «ព្រះបិតា»
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំដែលជាបុត្រធីតារបស់ព្រះអង្គ
ឲ្យទទួលជីវិតអស់កល្បជានិច្ចជាមត៌កតាមព្រះបន្ទូលសន្យា ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់ដ៏សប្បុរស !
យើងខ្ញុំសូមថ្វាយតង្វាយទាំងនេះ ដែលជាព្រះអំណោយទាន
មកពីព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាញ៉ាំងតង្វាយនេះ ឲ្យទៅជាព្រះកាយ
និងព្រះលោហិតព្រះគ្រីស្តសម្រាប់យើងខ្ញុំ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់ជាព្រះសង្គ្រោះ !
ព្រះអង្គបានប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំ ។
សូមសេចក្តីពិតរបស់ព្រះអង្គបំភ្លឺចិត្តគំនិតយើងខ្ញុំ
ឲ្យចេះស្រឡាញ់ព្រះអង្គអស់មួយជីវិត ។

# ថ្ងៃអាទិត្យទី ២០ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XX «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាដ៏មានធម៌មេត្តាករុណា !
ព្រះអង្គបានបម្រុងទុកនូវព្រះអំណោយទានផ្សេងៗ
ដែលភ្នែកមើលមិនឃើញ សម្រាប់អស់អ្នកដែលស្រឡាញ់ព្រះអង្គ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំស្រឡាញ់ព្រះអង្គលើសអ្វីៗទាំងអស់ ដើម្បីឲ្យព្រះបន្ទូលសន្យារបស់ព្រះអង្គកើតជារូបរាង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់ដ៏សប្បុរស !
ព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយរបស់យើងខ្ញុំ
ទុកជាការដោះដូរដ៏វិសេសវិសាល
គឺនៅពេលយើងខ្ញុំថ្វាយនូវអ្វីៗដែលព្រះអង្គបានប្រទានមកយើងខ្ញុំ
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំបានទទួលព្រះអង្គផ្ទាល់ផង ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះអង្គបានប្រោសឲ្យយើងខ្ញុំរួបរួមយ៉ាងជិតស្និតជាមួយព្រះគ្រីស្ត
ជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ។ សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំរស់នៅតាមគំរូព្រះបុត្រាក្នុងលោកនេះ
ដើម្បីទទួលសិរីរុងរឿងរួមជាមួយព្រះបុត្រានៅឯស្ថានបរមសុខ ។

# ថ្ងៃអាទិត្យទី ២១ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XXI «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាដ៏សប្បុរស !
មានតែព្រះអង្គទេ ដែលប្រោសឲ្យអស់អ្នកជឿមានក្ដីសង្ឃឹមលើព្រះអង្គ
និងប្រព្រឹត្តតាមព្រះបញ្ញាររបស់ព្រះអង្គដោយក្ដីស្រឡាញ់ ។
សូមព្រះអង្គមេត្តាប្រោសឲ្យប្រជារាស្ត្ររបស់ព្រះអង្គ ដែលរស់នៅក្នុងលោកដ៏មិនទៀងទាត់នេះ
មានអំណរសប្បាយដ៏ពិតប្រាកដ
ដោយជាប់ចិត្តនឹងសម្បត្តិនៃស្ថានបរមសុខ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់យើងខ្ញុំ !
ព្រះបុត្រាបានបូជាព្រះជន្មនៅលើឈើឆ្កាង
ដើម្បីប្រោសឲ្យយើងខ្ញុំជាបុត្រធីតារបស់ព្រះអង្គបានរួចពីបាប ។ សូមព្រះអង្គមេត្តាប្រោសឲ្យព្រះសហគមន៍រួបរួមគ្នាជាផ្លូងតែមួយ ព្រមទាំងប្រទាននូវសេចក្ដីសុខសាន្ត ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
សូមព្រះអង្គព្យាបាលយើងខ្ញុំដោយព្រះហឫទ័យមេត្តាករុណា
និងប្រោសយើងខ្ញុំឲ្យកាន់តែប្រសើរឡើងៗ ។
សូមព្រះអង្គមេត្តាគាំទ្រយើងខ្ញុំឲ្យប្រព្រឹត្តតែកិច្ចការ
ដែលគាប់ព្រះហឫទ័យព្រះអង្គ ។

# ថ្ងៃអាទិត្យទី ២២ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XXII «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអំណោយទានទាំងអស់សុទ្ធតែមកពីព្រះអង្គ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំស្រឡាញ់ព្រះនាមព្រះអង្គជានិច្ច
ហើយប្រោសឲ្យគ្រាប់ពូជដ៏ល្អលូតលាស់ក្នុងចិត្តរបស់យើងខ្ញុំផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់ដ៏វិសុទ្ធ !
ព្រះអង្គសព្វព្រះហឫទ័យប្រទានការសង្គ្រោះឲ្យយើងខ្ញុំ
តាមរយៈសក្ការបូជានេះ ។
សូមឲ្យអភិបូជាដែលជាគម្រោងការដ៏អស្ចារ្យ
ផ្តល់ផលផ្លែក្នុងជីវិតរបស់យើងខ្ញុំ ដោយឫទ្ធានុភាពរបស់ព្រះអង្គ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គបានចិញ្ចឹមជីវិតយើងខ្ញុំដោយប្រទានព្រះបន្ទូល និងព្រះកាយព្រះគ្រីស្តធ្វើជាអាហារ ។ សូមព្រះអង្គមេត្តាពង្រឹងសេចក្តីស្រឡាញ់របស់យើងខ្ញុំ
ឲ្យចេះគោរពបម្រើព្រះអង្គ ដោយបម្រើអ្នកដទៃដូចជាបងប្អូន ។

# ថ្ងៃអាទិត្យទី ២៣ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XXIII «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះអង្គចាត់ព្រះបុត្រាឲ្យយាងមកសង្គ្រោះមនុស្សលោក
និងប្រោសឲ្យយើងខ្ញុំជាបុត្រធីតាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ។ សូមព្រះអង្គមេត្តាប្រោសឲ្យអស់អ្នកជឿសង្ឃឹមលើព្រះអង្គ
មានសេរីភាពពិតប្រាកដ និងទទួលជីវិតអស់កល្បជានិច្ចជាមត៌ក ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះបិតាជាអម្ចាស់លើពិភពទាំងមូល !
ព្រះអង្គបានប្រោសយើងខ្ញុំឲ្យចេះអធិដ្ឋាន និងឲ្យចេះសម្រុះសម្រួលគ្នា ។
យើងខ្ញុំសូមថ្វាយនំបុ័ង និងស្រានេះ
ដើម្បីតបស្នងព្រះគុណព្រះអង្គ និងលើកតម្កើងព្រះអង្គ ។
សូមព្រះអង្គមេត្តាទទួលតង្វាយរបស់យើងខ្ញុំ និងប្រោសយើងខ្ញុំឲ្យរួមរស់ជាធ្លុងតែមួយ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់ដ៏វិសុទ្ធ !
ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត
ព្រមទាំងព្រះបន្ទូលដែលជាអាហារពីស្ថានបរមសុខ ។
សូមព្រះអង្គមេត្តាប្រទានព្រះអំណោយទានដែលមកពីព្រះបុត្រា
ឲ្យយើងខ្ញុំទទួលជីវិតអស់កល្បជានិច្ចរួមជាមួយព្រះបុត្រាព្រះអង្គផង ។

# ថ្ងៃអាទិត្យទី ២៤ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XXIV «PER ANNUM»

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាព្រះមហាក្សត្រ
និងជាព្រះបង្កើតអ្វីៗសព្វសារពើទាំងអស់ !
សូមព្រះអង្គបំភ្លឺយើងខ្ញុំឲ្យស្គាល់ព្រះហប្ញទ័យមេត្តាករុណារបស់ព្រះអង្គ
និងប្រោសយើងខ្ញុំឲ្យបេះបម្រើព្រះអង្គអស់ពីដួងចិត្ត ។

ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គទតមកយើងខ្ញុំដោយធម៌មេត្តាករុណា ។
សូមព្រះអង្គមេត្តាទទួលតង្វាយដែលយើងខ្ញុំលើកថ្វាយ
ដើម្បីកោតសរសើរព្រះនាមព្រះអង្គ ។
សូមព្រះអង្គប្រោសឲ្យតង្វាយនេះ
ផ្តល់ការសង្គ្រោះដល់មនុស្សលោកទាំងមូល ។

ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រទានព្រះកាយព្រះគ្រីស្តជាព្រះអំណោយទានពីស្ថានបរមសុខ ។
សូមឲ្យព្រះកាយគ្រប់គ្រងយើងខ្ញុំទាំងឆន្ទៈទាំងរូបកាយ
កុំឲ្យរស់នៅតាមបំណងប្រាថ្នារបស់ខ្លួនឡើយ
តែសូមឲ្យយើងខ្ញុំប្រព្រឹត្តតាមព្រះហប្ញទ័យព្រះអង្គវិញ ។

# ថ្ងៃអាទិត្យទី ២៥ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XXV «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះបុត្រាព្រះអង្គមានព្រះបន្ទូលថា ៖
«ត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នក (...)
ហើយត្រូវស្រឡាញ់បងប្អូនឯទៀតៗ» ។
សេចក្ដីស្រឡាញ់នេះ ជាគ្រឹះនៃវិន័យដ៏វិសុទ្ធរបស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំស្ដាប់បង្គាប់ព្រះអង្គ
ដើម្បីទទួលជីវិតអស់កល្បជានិច្ច ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
សូមព្រះអង្គទទួលតង្វាយពីប្រជារាស្ត្ររបស់ព្រះអង្គដោយអនុគ្រោះ ។
សូមព្រះអង្គប្រោសឲ្យពួកគេទទួលការសង្គ្រោះ
តាមគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ
តាមជំនឿ និងចិត្តភក្ដីរបស់ពួកគេដែរ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គចិញ្ចឹមយើងខ្ញុំដោយអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យទទួលការសង្គ្រោះ
ក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ និងក្នុងការរស់នៅប្រចាំថ្ងៃរបស់យើងខ្ញុំ ។

# ថ្ងៃអាទិត្យទី ២៦ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XXVI «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់ !
ព្រះអង្គសម្តែងឫទ្ធានុភាពដ៏អស្ចារ្យ
ដោយមានព្រះហឫទ័យទន់ភ្លន់ចំពោះអ្នកបាប
និងអាណិតអាសូរពួកគេ ។
សូមព្រះអង្គប្រោសប្រណីឲ្យយើងខ្ញុំស្វះស្វែងរកមតកនៃស្ថានបរមសុខ
តាមព្រះបន្ទូលសន្យារបស់ព្រះអង្គ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះបិតាដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
សូមព្រះអង្គទទួលតង្វាយពីយើងខ្ញុំដោយអនុគ្រោះ ។
សូមព្រះអង្គមេត្តាចាក់បង្ហូរព្រះពរគ្រប់បែបយ៉ាងមកយើងខ្ញុំ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់ដ៏សប្បុរស !
សូមព្រះអង្គប្រទានឲ្យគម្រោងការដ៏អស្ចារ្យនៃស្ថានបរមសុខ
ផ្តល់កម្លាំងឲ្យយើងខ្ញុំទាំងផ្លូវកាយ និងផ្លូវវិញ្ញាណ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំទទួលមតកយ៉ាងរុងរឿងរួមជាមួយព្រះគ្រីស្ត
នៅពេលដែលយើងខ្ញុំប្រកាសអំពីព្រះបុត្រាសោយទិវង្គត ។

# ថ្ងៃអាទិត្យទី ២៧ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XXVII «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គលើកលែងទោសឲ្យយើងខ្ញុំហួសពីការនឹកឃើញរបស់មនុស្ស ។
ព្រះអង្គផ្ដល់ព្រះអំណោយទានឲ្យយើងខ្ញុំ
ហួសពីពាក្យដែលយើងខ្ញុំទូលសូមទៅទៀត ។ សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ
រស់នៅគាប់ព្រះហឫទ័យព្រះអង្គផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គទទួលសក្ការបូជា
ដែលយើងខ្ញុំថ្វាយតាមព្រះបន្ទូលប្រៀនប្រដៅរបស់ព្រះអង្គ ។
ព្រះអង្គប្រោសឲ្យយើងខ្ញុំបានភ្ជាប់ចិត្តជាមួយព្រះអង្គ
ក្នុងគម្រោងការដ៏អាថ៌កំបាំង ។
សូមព្រះអង្គបង្ហើយកិច្ចការដែលព្រះអង្គសព្វព្រះហឫទ័យសង្គ្រោះយើងខ្ញុំ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គប្រទានព្រះកាយព្រះគ្រីស្ដ
ទុកជាអាហារចិញ្ចឹមជីវិត និងផ្ដល់កម្លាំងឲ្យយើងខ្ញុំ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំទៅជាព្រះកាយព្រះគ្រីស្ដក្នុងពិភពលោកនេះ ។

# ថ្ងៃអាទិត្យទី ២៨ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XXVIII «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់ដ៏សប្បុរស !
ព្រះអង្គគង់នៅខាងមុខ និងខាងក្រោយយើងខ្ញុំ
ហើយបំភ្លឺយើងខ្ញុំឲ្យសម្រេចចិត្តយ៉ាងត្រឹមត្រូវលើគ្រប់កិច្ចការ ។
សូមព្រះអង្គថែរក្សាការពារយើងខ្ញុំជារៀងរហូត ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ដ៏មានធម៌មេត្តាករុណា !
ព្រះអង្គទទួលពាក្យអង្វររបស់អ្នកជឿលើព្រះអង្គ រួមជាមួយតង្វាយដ៏សក្ការ ។
ដោយយើងខ្ញុំមានចិត្តគោរពបម្រើព្រះអង្គ
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
ឆ្លងទៅស្ថានបរមសុខប្រកបដោយសិរីរុងរឿង ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តជាព្រះបុត្រាព្រះអង្គ
ឲ្យយើងខ្ញុំទុកជាអាហារចិញ្ចឹមជីវិត ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំទៅជាបុត្រាធីតារបស់ព្រះអង្គ ។

# ថ្ងៃអាទិត្យទី ២៩ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XXIX «PER ANNUM»

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានព្រះជន្មគង់នៅជានិច្ច !
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានឆន្ទៈស្របនឹងព្រះហឫទ័យព្រះអង្គ
និងបម្រើព្រះអង្គជាព្រះដ៏មានឫទ្ធានុភាពដោយចិត្តស្មោះស្ម័គ្រ ។

ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គប្រោសឲ្យយើងខ្ញុំមានចិត្តស្មោះចំពោះព្រះអំណោយទានព្រះអង្គ ។
នៅពេលយើងខ្ញុំធ្វើពិធីរំឭកដល់គម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ
សូមព្រះអង្គប្រណីសន្ដោសឲ្យយើងខ្ញុំបានជាស្អាតបរិសុទ្ធ
តាមព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ ។

ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គបានប្រទានព្រះកាយព្រះគ្រីស្ត
ដែលជាទ្រព្យសម្បត្តិនៃស្ថានបរមសុខឲ្យយើងខ្ញុំ ។
សូមព្រះអង្គជួយឲ្យយើងខ្ញុំរស់នៅយ៉ាងសមរម្យក្នុងលោកនេះ
និងរៀបចំដួងចិត្តសម្រាប់ជីវិតអស់កល្បជានិច្ច ។

# ថ្ងៃអាទិត្យទី ៣០ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XXX «PER ANNUM»

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
សូមព្រះអង្គមេត្តាពង្រឹងជំនឿ សេចក្ដីសង្ឃឹម
និងសេចក្ដីស្រឡាញ់ដល់យើងខ្ញុំ
ឲ្យយកចិត្តទុកដាក់ប្រតិបត្តិនូវសេចក្ដីប្រៀនប្រដៅរបស់ព្រះអង្គ
ដើម្បីទទួលសេចក្ដីសុខសាន្តតាមព្រះបន្ទូលសន្យាព្រះអង្គ ។

ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
សូមព្រះអង្គទតមើល និងទទួលតង្វាយពីយើងខ្ញុំ
ដោយព្រះហឫទ័យសប្បុរស ។
ពេលយើងខ្ញុំបម្រើព្រះអង្គដោយថ្វាយអភិបូជា សូមព្រះអង្គណែនាំយើងខ្ញុំឲ្យឆ្ពោះទៅកាន់សិរីរុងរឿងរបស់ព្រះអង្គ ។

ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រទានអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត
មកបំពេញជីវិតរបស់យើងខ្ញុំឲ្យបានគ្រប់លក្ខណៈ ។
សូមព្រះអង្គប្រោសឲ្យសញ្ញាសម្គាល់នានា
ដែលយើងខ្ញុំប្រារព្ធក្នុងពិធីនេះ
កើតជារូបរាងពិតប្រាកដនៅថ្ងៃណាមួយ ។

# អាទិត្យទី ៣១ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XXXI «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាព និងធម៌មេត្តាករុណា !
ព្រះអង្គប្រទានព្រះអំណោយទានដល់អស់អ្នកជឿ
ឲ្យគោរពបម្រើ និងកោតសរសើរព្រះអង្គ ។
សូមព្រះអង្គមេត្តាការពារយើងខ្ញុំកុំឲ្យជំពប់ជើងដួល
នៅពេលយើងខ្ញុំរួតរះទៅទទួលជីវិតថ្មីដែលព្រះអង្គបានសន្យា ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
សូមព្រះអង្គប្រោសឲ្យតង្វាយដ៏សក្ការៈទាំងនេះ
ទៅជាយញ្ញបូជាដ៏ល្អឥតខ្ចោះថ្វាយព្រះអង្គ ។
សូមព្រះអង្គចាក់បង្ហូរធម៌មេត្តាករុណារបស់ព្រះអង្គមកយើងខ្ញុំផង ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ដ៏វិសុទ្ធបំផុត !
ព្រះអង្គសព្វព្រះហឫទ័យផ្តល់កម្លាំងមកយើងខ្ញុំតាមរយៈអគ្គសញ្ញានានា
ដើម្បីឲ្យរបៀបរស់នៅរបស់យើងខ្ញុំកាន់តែប្រសើរឡើងៗ ។
សូមព្រះកាយព្រះគ្រីស្តប្រោសឲ្យយើងខ្ញុំរៀបចំខ្លួន
ដើម្បីទទួលជីវិតថ្មីដែលព្រះអង្គបានសន្យា ។

# ថ្ងៃអាទិត្យទី ៣២ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XXXII «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គដកឧបសគ្គទាំងប៉ុន្មាន
ដែលរារាំងយើងខ្ញុំមិនឲ្យប្រព្រឹត្តតាមព្រះហឫទ័យព្រះអង្គ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំស្វែងរកទ្រព្យសម្បត្តិនៃស្ថានបរមសុខ
ទាំងមានសេរីភាពយ៉ាងពេញលេញខាងរូបកាយ និងឆន្ទៈ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គទតមើលយើងខ្ញុំដោយព្រះហឫទ័យស្រឡាញ់ ។
យើងខ្ញុំសូមថ្វាយតង្វាយទាំងនេះ ដើម្បីលើកតម្កើងព្រះបុត្រាដែលសោយទិវង្គត ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំគោរពបម្រើព្រះអង្គដោយចិត្តភក្តី ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គបានប្រទានអាហារដែលចិញ្ចឹមព្រលឹងយើងខ្ញុំ ។
យើងខ្ញុំសូមអរព្រះគុណព្រះអង្គ
និងទូលអង្វរព្រះអង្គអាណិតអាសូរយើងខ្ញុំ ។
សូមព្រះអង្គមេត្តាបង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធលើយើងខ្ញុំ
និងប្រោសយើងខ្ញុំឲ្យមានចិត្តស្មោះត្រង់ជានិច្ច ។

# ថ្ងៃអាទិត្យទី ៣៣ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XXXIII «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គសព្វព្រះហឫទ័យប្រទានសុភមង្គលដ៏ពិតប្រាកដឲ្យមនុស្សលោក
ដែលគោរពបម្រើព្រះអង្គដោយចិត្តភក្ដី ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានអំណរសប្បាយដ៏ពេញលេញ
និងមានចិត្តស្មោះត្រង់ជានិច្ចបម្រើព្រះអង្គដែលជាប្រភពនៃអ្វីៗដ៏ល្អគ្រប់យ៉ាង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ជាព្រះបិតា !
យើងខ្ញុំសូមលើកតង្វាយថ្វាយព្រះអង្គ
ជាព្រះដ៏មានឫទ្ធានុភាពសព្វប្រការ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំគោរពបម្រើព្រះអង្គដោយចិត្តភក្ដី
និងប្រទានឲ្យយើងខ្ញុំមានអំណរសប្បាយអស់កល្បជានិច្ច ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គបានប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្ដឲ្យយើងខ្ញុំ ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យរស់នៅ
តាមការប្រៀនប្រដៅរបស់ព្រះបុត្រា ។
រាល់ពេលយើងខ្ញុំនឹករឭកដល់ព្រះយេស៊ូសោយទិវង្គត
សូមព្រះអង្គបន្ថែមសេចក្ដីស្រឡាញ់មកយើងខ្ញុំផង ។

# ថ្ងៃអាទិត្យទី ៣៤ ក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

DOMINICA XXXIV «PER ANNUM»

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រទានកម្លាំងឲ្យអស់អ្នកជឿ
ប្រឹងប្រែងបំពេញគ្រប់កិច្ចការរបស់ព្រះអង្គ
ដើម្បីទទួលផលផ្លែយ៉ាងបរិបូណ៌ ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យជាសះស្បើយទាំងរូបកាយ និងឆន្ទៈ
តាមព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់ !
សូមព្រះអង្គទទួលតង្វាយដ៏សក្ការៈ
ដែលយើងខ្ញុំថ្វាយទៅព្រះនាមព្រះអង្គ
តាមការប្រៀនប្រដៅរបស់ព្រះអង្គ ។
សូមប្រោសឲ្យយើងខ្ញុំបានគាប់ព្រះហឫទ័យព្រះអង្គ
ដោយយកចិត្តទុកដាក់ប្រតិបត្តិតាមព្រះបន្ទូលជារៀងរាល់ថ្ងៃ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលប្រទានអំណរសប្បាយពេញលក្ខណៈ
ដោយប្រោសឲ្យយើងខ្ញុំបានទទួលព្រះកាយព្រះគ្រីស្ត ។
សូមព្រះអង្គមេត្តាថែរក្សាការពារយើងខ្ញុំកុំឲ្យឃ្លាតឆ្ងាយពីព្រះអង្គឡើយ ។

ថ្ងៃអាទិត្យទី១ក្រោយបុណ្យថ្ងៃទីហាសិប

# បុណ្យលើកតម្កើងព្រះត្រៃឯក

SANCTISSIMÆ TRINITATIS

(បុណ្យឱឡារិក)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ជាព្រះបិតាយើងខ្ញុំ !

ព្រះអង្គចាត់ព្រះបន្ទូលនៃសេចក្ដីពិត និងព្រះវិញ្ញាណដ៏វិសុទ្ធយាងមកក្នុងពិភពលោកនេះ ដើម្បីឲ្យមនុស្សជាតិយល់ពីគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ ។

នៅពេលយើងខ្ញុំបង្ហាញជំនឿរបស់ខ្លួន សូមព្រះអង្គប្រោសឲ្យយើងខ្ញុំលើកតម្កើងសិរីរុងរឿងនៃព្រះត្រៃឯក

និងក្រាបថ្វាយបង្គំព្រះដ៏មានឫទ្ធានុភាពសព្វប្រការដែលគង់នៅក្នុងអង្គតែមួយ ។

សូត្រធម៌ប្រកាសជំនឿ

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ជាព្រះបិតា !

យើងខ្ញុំជាអ្នកបម្រើ សូមថ្វាយនំ និងស្រានេះទៅព្រះនាមព្រះអង្គ

សូមព្រះអង្គញ៉ាំងតង្វាយនេះ ឲ្យបានវិសុទ្ធ ។

ដោយយើងខ្ញុំចូលរួមជាមួយសក្ការបូជានេះ សូមព្រះអង្គប្រោសយើងខ្ញុំឲ្យទៅជាតង្វាយអស់កល្បជានិច្ច ។

ធម៌ប្រារព្ធ ៖ ការអស្ចារ្យនៃព្រះត្រៃឯកដ៏វិសុទ្ធបំផុត ។

បៈ. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

បៈ. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

បៈ. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់ និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះជាម្ចាស់តែមួយព្រះអង្គ ។
ព្រះអង្គជាព្រះតែឯក ទោះបីព្រះអង្គមានលក្ខណៈផ្សេងពីគ្នាក៏ដោយ
ក៏ព្រះអង្គទាំងបីរួមគ្នាក្នុងសភាវៈតែមួយ ។
យើងខ្ញុំជឿថា ព្រះបិតា ព្រះបុត្រា
និងព្រះវិញ្ញាណដ៏វិសុទ្ធរួមគ្នាក្នុងសិរីរុងរឿងតែមួយ ។
ដូច្នេះ យើងខ្ញុំសូមលើកតម្កើងព្រះអង្គជាព្រះតែឯក
ដែលព្រះអង្គនីមួយៗមានអង្គប្លែកពីគ្នា សភាវៈតែមួយដូចគ្នា
និងភាពដ៏ឧត្តុងឧត្តមស្មើៗគ្នា ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយទេវទូត
អគ្គទេវទូត ខេរូប៊ីម និងពពួកសេរ៉ាភីម
កោតសរសើរព្រះអង្គរៀងរាល់ថ្ងៃ ដោយសូរសព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ លើពិភពលោកទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ
ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

### ពាក្យអរព្រះគុណ

បពិត្រព្រះបិតាជាព្រះអម្ចាស់យើងខ្ញុំ !
តាមរយៈព្រះកាយព្រះគ្រីស្ត
ព្រះអង្គប្រោសឲ្យយើងខ្ញុំមានសេចក្តីសុខ ខាងរូបកាយ និងវិញ្ញាណ ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យបានប្រកាសថា
ព្រះអង្គតែងឯកជាព្រះដ៏វិសុទ្ធអស់កល្បជានិច្ច និងជាអង្គតែមួយដែលមិនអាចបំបែកបាន ។

ថ្ងៃអាទិត្យក្រោយបុណ្យព្រះត្រៃឯកដ៏វិសុទ្ធបំផុត

# បុណ្យព្រះកាយ និងព្រះលោហិត ដ៏វិសុទ្ធបំផុតរបស់ព្រះគ្រីស្ត

SANCTISSIMI CORPORIS ET SANGUINIS CHRISTI

(បុណ្យឱឡារិក)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់ដ៏វិសុទ្ធ !
ព្រះអង្គប្រទានអគ្គសញ្ញានៃព្រះកាយព្រះគ្រីស្ត
ទុកជាការនឹករឭកអំពីទុក្ខលំបាករបស់ព្រះបុត្រាព្រះអង្គ ។ សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំ
ឲ្យយកចិត្តទុកដាក់គោរពអគ្គសញ្ញាដ៏ប្រសើរឧត្តមនេះ
ព្រមទាំងទទួលស្គាល់ផលផ្លែនៃការសង្គ្រោះរបស់ព្រះអង្គក្នុងជីវិតយើងខ្ញុំ ។

សូត្រធម៌ប្រកាសជំនឿ

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
សូមព្រះអង្គទទួលតង្វាយពីយើងខ្ញុំទុកជានិមិត្តរូប
នៃការរួបរួមគ្នា និងសេចក្តីសុខសាន្ត ។
សូមព្រះអង្គប្រទានព្រះអំណោយទានទាំងនេះ
ដល់ព្រះសហគមន៍របស់ព្រះអង្គផង ។

ធម៌ប្រារព្ធ ៖ ផលផ្លែនៃពិធីអរព្រះគុណដ៏វិសុទ្ធ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ជាព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាព្រះអម្ចាស់យើងខ្ញុំ ។

នៅពេលជប់លៀងចុងក្រោយបង្អស់រួមជាមួយក្រុមសាវ័ក
ព្រះគ្រីស្តដែលជាកូនចៀមឥតសៅហ្មង និងជាតង្វាយដ៏សមរម្យ
ទ្រង់បានបូជាព្រះជន្មដើម្បីអរព្រះគុណព្រះបិតា
ព្រះអង្គប្រព្រឹត្តដូច្នេះឲ្យមនុស្សគ្រប់ជំនាន់
នឹករឭកដល់ឈើឆ្កាង ដែលផ្តល់ការសង្គ្រោះ ។
ដោយសក្ការបូជាដ៏អស្ចារ្យនេះ ព្រះអង្គចិញ្ចឹមអស់អ្នកជឿ
ហើយប្រោសពួកគេឲ្យបានវិសុទ្ធ ដើម្បីឲ្យមនុស្សគ្រប់ជាតិសាសន៍
ដែលរស់ក្នុងពិភពលោកតែមួយ ទទួលពន្លឺដោយជំនឿតែមួយ
និងរួមគ្នាក្នុងសេចក្តីស្រឡាញ់តែមួយ ។

ពេលនេះ យើងខ្ញុំមកជិតតុសក្ការៈនៃអគ្គសញ្ញាដ៏អស្ចារ្យ
ព្រះអង្គបង្ហូរព្រះហឫទ័យថ្លាក់ថ្លម
ដើម្បីឲ្យថ្ងៃណាមួយ យើងខ្ញុំអាចឆ្លងចូលទៅឯស្ថានបរមសុខបាន ។

អាស្រ័យហេតុនេះ សត្វលោកទាំងអស់នៅលើផែនដី
និងនៅស្ថានបរមសុខ ច្រៀងបទថ្មីគោរពលើកតម្កើងព្រះអង្គ
ហើយយើងខ្ញុំរួមជាមួយអស់ទេវទូត ប្រកាសឡើងដោយឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ លើពិភពលោកទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ
ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

ឬ
ធម៌ប្រារព្ធទី១ និងទី២ នៃពិធីអរព្រះគុណដ៏វិសុទ្ធ តទៅទំព័រ ៥៣៦ ។

ពាក្យអរព្រះគុណ
ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំបានទទួលព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ត
ដែលនាំឲ្យយើងខ្ញុំចូលរួមក្នុងព្រះជន្មដែលព្រះជាម្ចាស់បម្រុងទុកជាមុន ។
សូមឲ្យអំណរសប្បាយដែលយើងខ្ញុំបានទទួលក្នុងអគ្គសញ្ញានេះ គង់វង្សអស់កល្ប
ជានិច្ច ។

ថ្ងៃសុក្រក្រោយថ្ងៃអាទិត្យទីពីរក្រោយបុណ្យព្រះវិញ្ញាណយាងមក

# ព្រះហឫទ័យមេត្តាករុណារបស់ព្រះយេស៊ូ

SACRATISSIMI CORDIS IESU

(បុណ្យឱឡារិក)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងនៃព្រះហឫទ័យរបស់ព្រះបុត្រា
និងនឹករឭកដល់សេចក្ដីស្រឡាញ់ដ៏អស្ចារ្យរបស់ព្រះអង្គសម្រាប់យើងខ្ញុំ ។ សូមព្រះ
អង្គប្រណីសន្ដោសយើងខ្ញុំដោយបង្ហូរព្រះអំណោយទាន
តាមមុខរបួសព្រះបេះដូងរបស់ព្រះអង្គ ។

សូត្រធម៌ប្រកាសជំនឿ

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
សូមព្រះអង្គទតមើលសេចក្ដីស្រឡាញ់ដ៏លើសលប់របស់ព្រះបុត្រា ។
សូមប្រោសឲ្យតង្វាយយើងខ្ញុំបានគាប់ព្រះហឫទ័យព្រះអង្គ
និងលើកលែងទោសរបស់យើងខ្ញុំ ។

ធម៌ប្រារព្ធ ៖ ព្រះគ្រីស្ដមានព្រះហឫទ័យមេត្តាករុណាដ៏ធំធេង ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ជាព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាព្រះអម្ចាស់យើងខ្ញុំ ។

ពេលគេលើកព្រះបុត្រាឡើងលើឈើឆ្កាង
ព្រះអង្គសព្វព្រះហឫទ័យបូជាព្រះជន្ម
ដោយសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅសម្រាប់យើងខ្ញុំ
ហើយព្រះលោហិត និងទឹកដែលហូរចេញពីមុខរបួសរបស់ព្រះអង្គ
ត្រឡប់ទៅជាប្រភពនៃអគ្គសញ្ញារបស់ព្រះសហគមន៍ ។
ព្រះបេះដូងដែលពោរពេញដោយសេចក្តីស្រឡាញ់បានទាក់ទាញមនុស្សទាំងអស់
ឲ្យមកទទួលទានទឹកនៃការសង្គ្រោះដោយអំណរសប្បាយ ។
អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយសន្តបុគ្គល
និងអស់ទេវទូតទាំងឡាយ កោតសរសើរព្រះអង្គឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !

### ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គបានប្រទានអគ្គសញ្ញានៃសេចក្តីស្រឡាញ់មកយើងខ្ញុំ ។
ដោយសារភ្លើងនៃសេចក្តីស្រឡាញ់របស់ព្រះអង្គ
សូមមេត្តាប្រោសយើងខ្ញុំឲ្យភ្ជាប់ចិត្តជាមួយព្រះបុត្រា
និងទទួលស្គាល់វត្តមានរបស់ព្រះបុត្រាក្នុងជីវិតអ្នកដទៃ ។

ថ្ងៃអាទិត្យចុងក្រោយក្នុងរដូវធម្មតា «ប្រចាំឆ្នាំ»

# ព្រះអម្ចាស់យេស៊ូគ្រីស្ត ជាព្រះមហាក្សត្រនៃពិភពលោក

DOMINICA NOSTRI IESU CHRISTI UNIVERSORUM REGIS

(បុណ្យឱឡារិក)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គសព្វព្រះហឫទ័យប្រោសអ្វីៗទាំងអស់ឲ្យប្រសើរឡើងវិញ
ឲ្យស្ថិតនៅក្រោមអំណាចព្រះបុត្រា
ដ៏ជាទីស្រឡាញ់របស់ព្រះអង្គជាព្រះមហាក្សត្រ ។
សូមព្រះអង្គប្រោសពិភពលោកទាំងមូលឲ្យរួចផុតពីទាសភាព
ដោយធ្វើជាអ្នកបម្រើដ៏ល្អរបស់ព្រះអង្គ
និងកោតសរសើរព្រះអង្គឥតឈប់ឈរ ។

សូត្រធម៌ប្រកាសជំនឿ

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់ដ៏សប្បុរស !
យើងខ្ញុំសូមយកនំ និងស្រាមកថ្វាយព្រះអង្គ
ទុកជានិមិត្តរូបនៃកិច្ចការរបស់យើងខ្ញុំ ។
សូមព្រះអង្គទទួលតង្វាយយើងខ្ញុំ
និងប្រោសឲ្យពិភពលោកទាំងមូលជានានឹងព្រះអង្គ ។
សូមឲ្យប្រជារាស្ត្រទាំងអស់រួបរួមគ្នាជាផ្លូងតែមួយក្នុងសេចក្តីសុខសាន្ត
ដែលជាព្រះអំណោយទានមកពីព្រះបុត្រាព្រះអង្គ ។

ធម៌ប្រារព្ធ ៖ ព្រះគ្រីស្តជាព្រះមហាក្សត្រនៃពិភពលោក ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធបំផុត !
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
រួមជាមួយព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ។

ព្រះបិតាបានអភិសេកព្រះបុត្រាព្រះអង្គ
គឺព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ ឲ្យទៅជាបូជាចារ្យអស់កល្បជានិច្ច
និងជាព្រះមហាក្សត្រត្រួតត្រាលើអ្វីៗទាំងអស់ ។
ព្រះគ្រីស្តបានបូជាព្រះជន្មនៅលើឈើឆ្កាងជាយញ្ញបូជាដ៏ល្អឥតខ្ចោះ
ដែលប្រទានសេចក្តីសុខសាន្តដល់យើងខ្ញុំ ។
ព្រះគ្រីស្តយាងមកសង្គ្រោះ និងរំដោះមនុស្សលោកឲ្យរួចពីបាប
ហើយប្រមូលសត្វលោក និងអ្វីៗទាំងអស់
ឲ្យស្ថិតនៅក្នុងព្រះរាជ្យរបស់ព្រះអង្គអស់កល្បជានិច្ចថ្វាយទៅព្រះបិតា ។
ព្រះរាជ្យនោះប្រកបដោយសេចក្តីពិត និងជីវិត
ព្រះរាជ្យនោះប្រកបដោយភាពដ៏វិសុទ្ធ និងការប្រណីសន្តោស
ព្រះរាជ្យនោះប្រកបដោយយុត្តិធម៌ សេចក្តីស្រឡាញ់ និងសេចក្តីសុខសាន្ត ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត និងសន្តបុគ្គលទាំងឡាយ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ លើពិភពលោកទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

### ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គប្រទានព្រះកាយព្រះគ្រីស្ត
ជាអាហារដែលផ្ដល់ជីវិតអស់កល្បជានិច្ចឲ្យយើងខ្ញុំ ។
សូមព្រះអង្គបំភ្លឺយើងខ្ញុំឲ្យប្រព្រឹត្តតាមព្រះបញ្ញារបស់ព្រះគ្រីស្ត
ដែលជាព្រះមហាក្សត្រនៃសកលលោក
តែសូមប្រោសឲ្យយើងខ្ញុំបានរួមរស់ជាមួយព្រះអង្គឯស្ថានបរមសុខផង ។

# ក្បួនពិធីអភិបូជា

## ORDO MISSÆ

# ពិធីប្រារព្ធ

Ritus initiales

១. នៅពេលគ្រីស្តបរិស័ទជួបជុំគ្នាហើយ លោកបូជាចារ្យ និងអស់អ្នកបម្រើពិធីបុណ្យដង្ហែទៅកាន់ទីសក្ការៈ ហើយទាំងអស់គ្នាច្រៀងបទចូល ។ ទៅដល់មុខតុសក្ការៈ លោកបូជាចារ្យ និងអ្នកបម្រើពិធីបុណ្យឱនកាយគោរព បន្ទាប់មក លោកបូជាចារ្យដើរទៅថើបតុសក្ការៈ (តាមកាលៈទេសៈ លោកអាចអុជកំញាន គោរពឈើឆ្កាង និងតុសក្ការៈ) ។ បន្ទាប់មក លោកបូជាចារ្យ និងអ្នកបម្រើ ពិធីបុណ្យទៅកន្លែងអង្គុយរៀងៗខ្លួន ។[១៩១]

ពេលច្រៀងចប់ លោកបូជាចារ្យរួមនឹងអង្គប្រជុំទាំងមូលឈរ [១៩២] គូសសញ្ញាឈើឆ្កាង ដោយពោលថា៖

**ក្នុងព្រះនាមព្រះបិតា និងព្រះបុត្រា ≅ និងព្រះវិញ្ញាណដ៏វិសុទ្ធ។**

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

២. បន្ទាប់មក លោកបូជាចារ្យលាតដៃ[១៩៣] ហើយគោរពអង្គប្រជុំ ទាំងពោលថា ៖
សូមព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត
និងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់
ហើយនឹងការរួមរស់ជាផ្លូងតែមួយដោយព្រះវិញ្ញាណដ៏វិសុទ្ធ គង់នៅជាមួយបងប្អូន ។

អង្គប្រជុំឆ្លើយ ៖ ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

---

[១៩១] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ ស្តីពីពិធីបុណ្យនៅកម្ពុជា និងឡាវ។ យើងអាចរៀបចំពិធីប្រារព្ធដូចតទៅ : នៅពេលគ្រីស្តបរិស័ទជួបជុំគ្នាហើយ លោកបូជាចារ្យ និងអស់អ្នកបម្រើពិធីបុណ្យលើកដៃប្រណម្យដង្ហែទៅកាន់ទីសក្ការៈ ហើយទាំងអស់គ្នាច្រៀងបទចូល។ ទៅដល់មុខតុសក្ការៈ អ្នកបម្រើពិធីបុណ្យអុជធូបជូនលោកបូជាចារ្យ។ លោកបូជាចារ្យដោតធូប ហើយក្រាបថ្វាយបង្គំ ចំណែកអ្នកបម្រើពិធីបុណ្យអង្គុយលើកែងជើងឱនកាយ សំពះគោរពតុសក្ការៈ និងព្រះឈើឆ្កាង (តាមកាលៈទេសៈ)។ បន្ទាប់មក លោកបូជាចារ្យឡើងទៅអង្គុយនៅទីសក្ការៈរួមជាមួយអ្នកបម្រើពិធីបុណ្យ។

[១៩២] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ ស្តីពីពិធីបុណ្យនៅកម្ពុជា និងឡាវ។ អង្គប្រជុំទាំងមូលអង្គុយបត់ជើងលើកន្ទេល។

[១៩៣] កាយវិការលាតដៃក្នុងក្បួនពិធីឡាតាំង អាចជំនួសដោយកាយវិការលើកដៃប្រណម្យ។

ឬ

សូមព្រះហឫទ័យប្រណីសន្តោស និងសេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់ជាព្រះបិតាយើងខ្ញុំ ហើយនឹងព្រះអម្ចាស់យេស៊ូគ្រីស្តគង់នៅជាមួយបងប្អូន ។

អង្គប្រជុំឆ្លើយ ៖ ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ឬ

សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

អង្គប្រជុំឆ្លើយ ៖ ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ជំនួសពាក្យ សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន លោកអភិបាលពោលថា ៖

សូមសេចក្តីសុខសាន្តគង់នៅជាមួយបងប្អូន ។

អង្គប្រជុំឆ្លើយ ៖ ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

៣. លោកបូជាចារ្យ ឬលោកឧបដ្ឋាក ឬអ្នកបម្រើពិធីបុណ្យអាចសង្ខេបខ្លឹមសារ នៃពិធីបុណ្យនៅថ្ងៃនេះជូនគ្រីស្តបរិស័ទ ។

# ពិធីសូមទទួលសារភាព[១៩៤]

Actus pænitentialis

៤. លោកបូជាចារ្យអញ្ជើញអង្គប្រជុំឲ្យទទួលសារភាព ៖

បងប្អូនជាទីស្រឡាញ់ !

ចូរយើងទទួលស្គាល់អំពើបាបរបស់ខ្លួន ដើម្បីថ្វាយអភិបូជាដោយសមរម្យ ។

អង្គប្រជុំស្ងៀមស្ងាត់បន្តិច ហើយសូត្រធម៌សូមទទួលសារភាពរួមជាមួយគ្នា[១៩៥]

ខ្ញុំសូមទទួលសារភាព ចំពោះព្រះដ៏មានឫទ្ធានុភាពសព្វប្រការ

ហើយចំពោះអស់បងប្អូនផងថា ខ្ញុំបានប្រព្រឹត្តអំពើបាបច្រើន

ដោយកាយវាចាចិត្ត និងដោយខានបំពេញកិច្ចការរបស់ខ្ញុំ

(គក់ទ្រូង)

ទោសខ្ញុំអើយ ទោសខ្ញុំអើយ ទោសខ្ញុំអើយធ្ងន់ណាស់ ។

ហេតុនេះ សូមព្រះនាងព្រហ្មចារិនីម៉ារី អស់ទេវទូត និងសន្តបុគ្គលទាំងឡាយ

ព្រមទាំងអស់បងប្អូន សូមជួយអង្វរព្រះជាអម្ចាស់ឲ្យខ្ញុំផង ។

លោកបូជាចារ្យ សូមព្រះជាម្ចាស់លើកលែងទោសឲ្យអង្គប្រជុំ ៖

សូមព្រះដ៏មានឫទ្ធានុភាពសព្វប្រការ

ទ្រង់ព្រះមេត្តាលើកលែងទោសឲ្យយើងខ្ញុំរួចពីបាប

ព្រមទាំងប្រទានជីវិតអស់កល្បជានិច្ចឲ្យយើងខ្ញុំ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

ឬ

៥. លោកបូជាចារ្យអញ្ជើញអង្គប្រជុំធ្វើពិធីសូមទទួលសារភាព ៖

បងប្អូនជាទីស្រឡាញ់ !

ចូរយើងទទួលស្គាល់អំពើបាបរបស់ខ្លួន ដើម្បីថ្វាយអភិបូជាដោយសមរម្យ ។

---

[១៩៤] នៅថ្ងៃអាទិត្យ ជាពិសេសរដូវបុណ្យចម្លង លោកបូជាចារ្យអាចធ្វើពិធីលើកលែងទោសដោយបាចទឹកព្រះពរដើម្បីនឹករឭកដល់អគ្គសញ្ញាជ្រមុជទឹក ។

[១៩៥] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ អង្គប្រជុំលុតជង្គង់អង្គុយលើកែងជើង ឱនកាយសំពះ ហើយស្ងៀមស្ងាត់បន្តិច ។

អង្គប្រជុំស្ងៀមស្ងាត់បន្តិច ហើយលោកបូជាចារ្យពោលថា ៖
ឱ ព្រះអម្ចាស់អើយ ! សូមអាណិតអាសូរយើងខ្ញុំ ។

អង្គប្រជុំឆ្លើយ ៖ ដ្បិតយើងខ្ញុំបានធ្វើខុសនឹងព្រះហឫទ័យព្រះអង្គ ។

លោកបូជាចារ្យ ៖
ឱ ព្រះអម្ចាស់អើយ ! សូមប្រោសប្រណីដល់យើងខ្ញុំ ។

អង្គប្រជុំឆ្លើយ ៖ ហើយសូមសង្គ្រោះយើងខ្ញុំផង ។

លោកបូជាចារ្យ សូមព្រះជាម្ចាស់លើកលែងទោសឲ្យអង្គប្រជុំ ៖
សូមព្រះដ៏មានឫទ្ធានុភាពសព្វប្រការ
ទ្រង់ព្រះមេត្តាលើកលែងទោសឲ្យយើងខ្ញុំរួចពីបាប
ព្រមទាំងប្រទានជីវិតអស់កល្បជានិច្ចឲ្យយើងខ្ញុំផង ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

ឬ

៦. លោកបូជាចារ្យអញ្ជើញអង្គប្រជុំ ធ្វើពិធីសូមទទួលសារភាព ៖
បងប្អូនជាទីស្រឡាញ់ !
ចូរយើងទទួលស្គាល់អំពើបាបរបស់ខ្លួន
ដើម្បីថ្វាយអភិបូជាដោយសមរម្យ ។

អង្គប្រជុំស្ងៀមស្ងាត់បន្តិច ហើយលោកបូជាចារ្យ ឬឧបដ្ឋាក ឬអ្នកបម្រើពិធីបុណ្យច្រៀង ឬពោលតាមពាក្យអង្វរខាងក្រោម ឬតាមឃ្លាផ្សេងទៀត ៖

ឱ ព្រះយេស៊ូជាអម្ចាស់អើយ !
ព្រះបិតាបានចាត់ព្រះអង្គឲ្យយាងមកព្យាបាលមនុស្សដែលបាក់ទឹកចិត្ត ។
ឱ ព្រះអម្ចាស់អើយ ! សូមអាណិតអាសូរ ។

អង្គប្រជុំឆ្លើយ ៖ ឱ ព្រះអម្ចាស់អើយ ! សូមអាណិតអាសូរ ។

លោកបូជាចារ្យ ៖
ឱ ព្រះយេស៊ូគ្រីស្តអើយ !
ព្រះអង្គយាងមកហៅរកអស់អ្នកបាប ។
ឱ ព្រះគ្រីស្តអើយ ! សូមអាណិតអាសូរ ។

អង្គប្រជុំឆ្លើយ ៖ ឱ ព្រះគ្រីស្តអើយ ! សូមអាណិតអាសូរ ។

លោកបូជាចារ្យ ៖
ឱ ព្រះយេស៊ូជាអម្ចាស់អើយ !
ព្រះអង្គគង់ខាងស្តាំព្រះបិតា សូមជួយអង្វរឲ្យយើងខ្ញុំ ។
ឱ ព្រះអម្ចាស់អើយ ! សូមអាណិតអាសូរ ។

អង្គប្រជុំឆ្លើយ ៖ ឱ ព្រះអម្ចាស់អើយ ! សូមអាណិតអាសូរ ។

លោកបូជាចារ្យ សូមព្រះជាម្ចាស់លើកលែងទោសឲ្យអង្គប្រជុំ ៖
សូមព្រះដ៏មានឫទ្ធានុភាពសព្វប្រការ
មេត្តាលើកលែងទោសឲ្យយើងខ្ញុំបានរួចពីបាប
ព្រមទាំងប្រទានជីវិតអស់កល្បជានិច្ចឲ្យយើងខ្ញុំផង ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

៧. បើសិនលោកបូជាចារ្យមិនបានជ្រើសរើសរបៀបលេខ ៦ទេ សូមសូត្រដូចខាងក្រោមនេះ ៖

| | | |
|---|---|---|
| ឱ ព្រះអម្ចាស់អើយ ! | សូមអាណិតអាសូរ | (អង្គប្រជុំឆ្លើយបន្ទរ) |
| ឱ ព្រះគ្រីស្តអើយ ! | សូមអាណិតអាសូរ | (អង្គប្រជុំឆ្លើយបន្ទរ) |
| ឱ ព្រះអម្ចាស់អើយ ! | សូមអាណិតអាសូរ | (អង្គប្រជុំឆ្លើយបន្ទរ) |

ឬ

| | |
|---|---|
| Kyrie, eleison | គីរីយេ. អេឡេអុីសុន |
| Christe, eleison | គ្រីស្តេ. អេឡេអុីសុន |
| Kyrie, eleison | គីរីយេ. អេឡេអុីសុន |

៨. រៀងរាល់ថ្ងៃអាទិត្យ និងបុណ្យសំខាន់ៗ សូមសូត្រ ឬច្រៀងធម៌លើកតម្កើងសិរីរុងរឿង លើកលែងតែក្នុងរដូវរង់ចាំ និងរដូវសែសិបថ្ងៃ ។

**ធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់**

សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត
ហើយសូមឲ្យមនុស្សលោកដ៏ជាទីស្រឡាញ់របស់ព្រះអង្គ បានសេចក្ដីសុខសាន្ដនៅលើផែនដី ។
យើងខ្ញុំសូមកោតសរសើរព្រះអង្គ លើកតម្កើងព្រះអង្គ
ក្រាបប្រណិប័តន៍ព្រះអង្គ លើកតម្កើងសិរីរុងរឿងព្រះអង្គ
អរព្រះគុណព្រះអង្គ ដែលប្រកបដោយសិរីរុងរឿងដ៏ធំទូលំទូលាយ ។
ឱ ព្រះយេស៊ូគ្រីស្ដជាអម្ចាស់ ជាព្រះបុត្រាតែមួយ !
ឱ ព្រះជាអម្ចាស់ ជាកូនចៀមរបស់ព្រះជាម្ចាស់ ជាព្រះបុត្រានៃព្រះបិតា!
ព្រះអង្គដែលដកបាបនៃពិភពលោក សូមអាណិតអាសូរយើងខ្ញុំ !
ព្រះអង្គដែលដកបាបនៃពិភពលោក សូមទទួលពាក្យអង្វរយើងខ្ញុំ !
ព្រះអង្គដែលគង់ខាងស្ដាំព្រះបិតា សូមអាណិតអាសូរយើងខ្ញុំ !
ឱ ព្រះយេស៊ូគ្រីស្ដអើយ !
មានតែព្រះអង្គទេ ជាព្រះដ៏វិសុទ្ធ ជាព្រះអម្ចាស់ ហើយជាព្រះដ៏ឧត្ដមបំផុត
ព្រះអង្គរួមជាមួយនឹងព្រះវិញ្ញាណដ៏វិសុទ្ធ ក្នុងសិរីរុងរឿងនៃព្រះបិតា ។
អាម៉ែន ។

៩. នៅពេលចប់ធម៌លើកតម្កើង លោកបូជាចារ្យលើកដៃសំពះ ហើយពោលថា៖

សូមបងប្អូនតាំងចិត្តអធិដ្ឋាន ។

អង្គប្រជុំនៅស្ងៀមស្ងាត់បន្ដិច រួចលោកបូជាចារ្យពោលពាក្យអធិដ្ឋានសរុប ក្នុងនាមបងប្អូនទាំងអស់ ។ លោកបញ្ចប់ពាក្យអធិដ្ឋានថា ៖

យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្ដ
ជាព្រះបុត្រាព្រះអង្គ និងជាព្រះអម្ចាស់ ដែលសោយរាជ្យរួមជាមួយព្រះអង្គ
និងព្រះវិញ្ញាណដ៏វិសុទ្ធអស់កល្បជាអង្វែងតរៀងទៅ ។

ប្រសិនបើ ពាក្យអធិដ្ឋានទៅកាន់ព្រះបិតា មានចែងអំពីព្រះគ្រីស្តនៅខាងចុងនោះ លោកបូជាចារ្យបញ្ចប់ ដោយពោលថា ៖

...ដែលសោយរាជ្យរួមជាមួយព្រះបិតា
និងព្រះវិញ្ញាណដ៏វិសុទ្ធ អស់កល្បជាអង្វែងតរៀងទៅ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

ប្រសិនបើ ពាក្យអធិដ្ឋានទៅកាន់ព្រះគ្រីស្ត លោកបូជាចារ្យបញ្ចប់ ដោយពោលថា ៖

យើងខ្ញុំសូមអង្វរព្រះអង្គដែលសោយរាជ្យរួមជាមួយព្រះបិតា
និងព្រះវិញ្ញាណដ៏វិសុទ្ធអស់កល្បជាអង្វែងតរៀងទៅ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

# ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់

Liturgia verbi

១០. គ្រីស្តបរិស័ទម្នាក់ ក្រោកឡើងទៅកាន់តុព្រះបន្ទូល ហើយអានអត្ថបទទីមួយ គ្រីស្តបរិស័ទឯទៀតៗស្តាប់ដោយយកចិត្តទុកដាក់ ។

អ្នកអានបញ្ចប់អត្ថបទដោយប្រកាសថា ៖

នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ។

អង្គប្រជុំឆ្លើយ ៖ សូមអរព្រះគុណព្រះជាម្ចាស់ ។

១១. គួរឲ្យអង្គប្រជុំស្មូតទំនុកតម្កើងឆ្លើយឆ្លងគ្នា ។

១២. បើសិនជាមានអត្ថបទទី២ អ្នកអានត្រូវឡើងទៅកាន់តុព្រះបន្ទូល ។

អ្នកអានបញ្ចប់អត្ថបទដោយប្រកាសថា ៖

នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ។

អង្គប្រជុំឆ្លើយ ៖ សូមអរព្រះគុណព្រះជាម្ចាស់ ។

១៣. បន្ទាប់មក អង្គប្រជុំច្រៀង អាលេលូយ៉ា ឬបទ្ទរមួយតាមរដូវបុណ្យ ។[១៩៦]

១៤. នៅពេលនេះ តាមកាលៈទេសៈ លោកបូជាចារ្យអាចដុតកំញាន ។ ក្រោយមក លោកឧបដ្ឋាក ឱនៅមុខលោកបូជាចារ្យអធិបតី សូមលោកប្រទានពរ ដោយពោលខ្សឹបៗថា ៖

សូមលោកប្រទានពរឲ្យខ្ញុំ ។

លោកបូជាចារ្យពោលថា ៖

សូមព្រះអម្ចាស់គង់នៅក្នុងចិត្ត និងនៅលើ បបូរមាត់អ្នក
ដើម្បីប្រកាសព្រះគម្ពីរដំណឹងល្អដោយសមរម្យ
ក្នុងព្រះនាមព្រះបិតា និងព្រះបុត្រា ≅ និងព្រះវិញ្ញាណដ៏វិសុទ្ធ ។

លោកឧបដ្ឋាកធ្វើសញ្ញាឈើឆ្កាងលើខ្លួន ទាំងឆ្លើយថា ៖

អាម៉ែន ។

បើគ្មានលោកឧបដ្ឋាក លោកបូជាចារ្យឱនកាយនៅមុខតុសក្ការៈ ដោយពោលខ្សឹបៗថា ៖

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
សូមព្រះអង្គមេត្តាជម្រះចិត្តគំនិត និងបបូរមាត់ខ្ញុំ
ដើម្បីប្រកាសព្រះគម្ពីរដំណឹងល្អរបស់ព្រះអង្គដោយសមរម្យ ។

១៥. លោកឧបដ្ឋាក ឬលោកបូជាចារ្យទៅកាន់តុព្រះបន្ទូល ។ តាមកាលៈទេសៈ អ្នកបម្រើពិធីបុណ្យអមដំណើរលោកដោយកាន់កំញាន និងទៀន ។ រួចលោកពោលថា ៖

សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

អង្គប្រជុំឆ្លើយ ៖ ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

លោកឧបដ្ឋាក ឬលោកបូជាចារ្យ ៖

សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត (ម៉ាថាយ-ម៉ាកុស-លូកា-យ៉ូហាន) ។

លោកបូជាចារ្យ គូសសញ្ញាឈើឆ្កាងលើព្រះគម្ពីរ លើថ្ងាស លើ បបូរមាត់ និងលើដើមទ្រូង គ្រីស្តបរិស័ទគូសសញ្ញាឈើឆ្កាង លើថ្ងាស លើ បបូរមាត់ និងលើដើមទ្រូងផងដែរ ។

អង្គប្រជុំឆ្លើយ ៖ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអម្ចាស់ ។

[១៩៦]. គ្រីស្តបរិស័ទលើកដៃប្រណម្យ ។

បន្ទាប់មក អ្នកបម្រើពិធីបុណ្យ លោកឧបដ្ឋាក ឬលោកបូជាចារ្យបក់កំញានលើព្រះគម្ពីរ ប្រសិនបើមានប្រើកំញាន និងប្រកាសព្រះបន្ទូលដំណឹង ។

១៦. ពេលបញ្ចប់ លោកឧបដ្ឋាក ឬលោកបូជាចារ្យប្រកាសថា ៖

នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

**អង្គប្រជុំឆ្លើយ ៖** សូមកោតសរសើរព្រះអម្ចាស់យេស៊ូគ្រីស្ត ។

ក្រោយពីអានចប់ លោកថើបព្រះគម្ពីរទាំងពោលខ្សឹបៗថា ៖

សូមឲ្យព្រះបន្ទូលដំណឹងល្អនេះ ជម្រះយើងខ្ញុំឲ្យបានរួចពីបាប ។

១៧. លោកបូជាចារ្យ បកស្រាយអត្ថន័យគម្ពីររាល់ថ្ងៃអាទិត្យ និងថ្ងៃបុណ្យសំខាន់ ។ ចំពោះ ថ្ងៃធម្មតា គួរធ្វើដូច្នេះដែរ ។

១៨. ពេលចប់ធម្មទេសនា តាមសេចក្ដីណែនាំអង្គប្រជុំប្រកាសជម៌ជឿរបស់មហាសន្និបាតក្រុងនីសេ/កុងស្តង់ទីណូប ដូចខាងក្រោមនេះ ៖

ខ្ញុំជឿលើព្រះជាម្ចាស់តែមួយព្រះអង្គ
ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ
ជាព្រះបង្កើតមេឃ និងដី ទាំងអ្វីៗដែលមើលឃើញ និងមើលមិនឃើញ ។
ខ្ញុំជឿលើព្រះអម្ចាស់យេស៊ូគ្រីស្តតែមួយ
ជាព្រះបុត្រាតែមួយនៃព្រះជាម្ចាស់
ហើយកើតពីព្រះបិតា មុនកាលសម័យទាំងអស់ ។
ព្រះអង្គជាព្រះជាម្ចាស់ចេញពីព្រះជាម្ចាស់ ជាព្រះពន្លឺចេញពីព្រះពន្លឺ
ជាព្រះជាម្ចាស់ដ៏ពិតប្រាកដ ចេញពីព្រះជាម្ចាស់ដ៏ពិតប្រាកដដែរ ។

ព្រះអង្គទទួលព្រះជន្មពីព្រះបិតា ហើយមិនកកើតដូចសត្វលោកឡើយ
ព្រះអង្គរួមសភាពជាមួយព្រះបិតា
ហើយអ្វីៗសព្វសារពើក៏កើតមក ដោយសារព្រះអង្គដែរ ។
ព្រះអង្គយាងមកពីស្ថានបរមសុខដើម្បីមនុស្សយើង និងដើម្បីសង្គ្រោះយើងខ្ញុំ ។
(អង្គប្រជុំឱនកាយបន្តិចរហូតដល់ "ព្រះអង្គទៅជាមនុស្ស")

ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ
ព្រះអង្គបានទទួលរូបកាយពីព្រះនាងព្រហ្មចារិនីម៉ារី ហើយព្រះអង្គទៅជាមនុស្ស ។
ព្រះអង្គត្រូវគេឆ្កាងនៅជំនាន់លោកប៉ុនពីឡាត
ដើម្បីជាប្រយោជន៍ដល់យើងខ្ញុំ ។
ព្រះអង្គសោយទិវង្គត ហើយព្រះសពព្រះអង្គត្រូវគេបញ្ចុះ ។
លុះដល់ថ្ងៃទីបី ព្រះអង្គមានព្រះជន្មរស់ឡើងវិញ ស្របតាមគម្ពីរ ។
ព្រះអង្គយាងឡើងស្ថានបរមសុខ ទៅគង់ខាងស្តាំព្រះបិតា ។

ព្រះអង្គនឹងយាងមកវិញយ៉ាងរុងរឿង
ដើម្បីវិនិច្ឆ័យមនុស្សទាំងរស់ ទាំងស្លាប់
ហើយព្រះរាជ្យព្រះអង្គ នឹងនៅស្ថិតស្ថេរឥតទីបញ្ចប់ឡើយ ។
ខ្ញុំជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ ជាព្រះអម្ចាស់ ដែលប្រទានជីវិត
ព្រះអង្គហូរចេញពីព្រះបិតា និងព្រះបុត្រា ។
ព្រះអង្គទទួលការក្រាបថ្វាយបង្គំ និងលើកតម្កើងសិរីរុងរឿង
ស្មើនឹងព្រះបិតា និងព្រះបុត្រា ។
ព្រះអង្គបានថ្លែងព្រះបន្ទូល តាមរយៈអស់លោកព្យាការី ។
ខ្ញុំជឿលើព្រះសហគមន៍តែមួយដ៏វិសុទ្ធ និងកាតូលិក
ដែលបន្តជំនឿពីក្រុមគ្រីស្តទូត ។

ខ្ញុំប្រកាសថា មានអគ្គសញ្ញាជ្រមុជទឹកតែមួយ
ដែលលើកលែងទោសឲ្យរួចពីបាប ។
ខ្ញុំរង់ចាំពេលដែលមនុស្សស្លាប់នឹងរស់ឡើងវិញ និងជីវិតនៅលោកខាងមុខផង ។
អាម៉ែន ។

១៩. យើងអាចសូត្រធម៌ជឿរបស់ក្រុមគ្រីស្តទូតនេះ ជំនួសធម៌ជឿរបស់មហាសន្និបាតក្រុងនីសេ/កុង ស្តង់ទីណូប ជាពិសេស នៅក្នុងរដូវសែសិបថ្ងៃ ឬរដូវបុណ្យចម្លង ។

ខ្ញុំជឿលើព្រះជាម្ចាស់ ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ
ជាព្រះបង្កើតមេឃ និងដី ។
ខ្ញុំជឿលើព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាតែមួយនៃព្រះបិតា
ហើយជាព្រះអម្ចាស់យើងខ្ញុំ ។
(អង្គប្រជុំឱនកាយបន្តិចរហូតដល់ "ព្រះនាងព្រហ្មចារិនីម៉ារី")

ព្រះអង្គមានកំណើតជាមនុស្ស ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ
ហើយទ្រង់បានប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី
ព្រះអង្គបានសោយទុក្ខលំបាកនៅជំនាន់ លោកប៉ុនពីឡាត ។

ព្រះអង្គត្រូវគេឆ្កាង សោយទិវង្គត
ហើយព្រះសពព្រះអង្គ ត្រូវគេបញ្ចុះក្នុងរូងថ្មមួយ ។
ព្រះអង្គបានយាងចុះទៅស្ថានក្រោម
លុះដល់ថ្ងៃទីបី ព្រះអង្គមានព្រះជន្មរស់ឡើងវិញ ពីចំណោមមនុស្សស្លាប់
ព្រះអង្គបានយាងឡើងស្ថានបរមសុខ
ទៅគង់ខាងស្តាំព្រះជាម្ចាស់ ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ។
ព្រះអង្គនឹងយាងមកវិញ ដើម្បីវិនិច្ឆ័យមនុស្សទាំងរស់ ទាំងស្លាប់ ។
ខ្ញុំជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ ខ្ញុំជឿលើព្រះសហគមន៍កាតូលិកដ៏វិសុទ្ធ
និងសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ ។

ខ្ញុំជឿថា មានការលើកលែងទោសមនុស្សឲ្យរួចពីបាប
ហើយរូបកាយមនុស្សនឹងរស់ឡើងវិញ
ព្រមទាំងមានជីវិតរស់នៅអស់កល្បជានិច្ចផង ។ អាម៉ែន ។

២០. ក្រោយមក មានពាក្យអង្វរសកលរបស់គ្រីស្តបរិស័ទ ។

# ពិធីអរព្រះគុណដ៏វិសុទ្ធ

Liturgia eucharistica

២១.ក្រោយពេលអង្វរសកលចប់ ច្រៀងចម្រៀងថ្វាយតង្វាយ អ្នកបម្រើពិធីបុណ្យយកកន្សែងព្រះកាយ កន្សែង ជម្រះពែងព្រះលោហិត ចានព្រះកាយ និងសៀវភៅក្បួនពិធីមកដាក់លើតុសក្ការៈ ។

២២. គួរឲ្យគ្រីស្តបរិស័ទចូលរួមហែតង្វាយ ដោយយកនំបុ័ង និងស្រាសម្រាប់ពិធីអរព្រះគុណដ៏វិសុទ្ធ ឬ អំណោយផ្សេងៗ សម្រាប់តម្រូវការរបស់ព្រះសហគមន៍ និងអ្នកក្រីក្រ ។[១៩៧]

២៣. លោកបូជាចារ្យឈរ [១៩៨] នៅខាងក្រោយតុសក្ការៈ លោកកាន់ចានព្រះកាយ ដែលមាននំបុ័ង ដោយដៃទាំងពីរលើកបន្តិច ទាំងពោលខ្សឹបៗថា ៖

បពិត្រព្រះជាអម្ចាស់នៃពិភពលោកទាំងមូល !

យើងខ្ញុំសូមសរសើរតម្កើងព្រះអង្គ

ដ្បិតយើងខ្ញុំទទួលនំបុ័ងនេះ ពីព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ។

យើងខ្ញុំសូមលើកនំបុ័ងនេះ ដែលជាផលផ្លែនៃទឹកដី

និងការងាររបស់មនុស្សលោក ថ្វាយទៅព្រះអង្គវិញ ។

សូមឲ្យនំបុ័ងនេះ ទៅជាអាហារដែលផ្តល់ជីវិតសម្រាប់យើងខ្ញុំ ។

លោកបូជាចារ្យ ដាក់ចានព្រះកាយដែលមាននំបុ័ងលើកន្សែងព្រះកាយ ។ ប្រសិនបើគ្មានចម្រៀងថ្វាយតង្វាយ លោកបូជាចារ្យពោលពាក្យខាងលើ ដោយសំឡេងខ្លាំងៗ ។

**អង្គប្រជុំឆ្លើយ ៖**

សូមសរសើរតម្កើងព្រះជាម្ចាស់ អស់កល្បជាអង្វែងតរៀងទៅ ។

២៤. លោកឧបដ្ឋាក ឬ លោកបូជាចារ្យ ចាក់ស្រា និងចាក់ទឹកបន្តិចចូលក្នុងពែងព្រះលោហិត ដោយពោលខ្សឹបៗថា ៖

ដូចទឹកលាយជាមួយស្រានេះ ដោយគម្រោងការដ៏អស្ចារ្យយ៉ាងណា

សូមប្រោសយើងខ្ញុំឲ្យចូលរួមក្នុងសភាពជាព្រះជាម្ចាស់របស់ព្រះគ្រីស្ត

ដែលបានបន្ទាបខ្លួនចូលរួមក្នុងសភាពជាមនុស្សយ៉ាងនោះដែរ ។

---

[១៩៧] នៅប្រទេសកម្ពុជា គ្រីស្តបរិស័ទដង្ហែតង្វាយរួមជាមួយនឹងធូបទៅកាន់តុសក្ការៈ ។

[១៩៨] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ១២៩១/៧៤ លោកបូជាចារ្យអាចអង្គុយនៅក្រោយតុសក្ការៈ ។

២៥. លោកបូជាចារ្យកាន់ពែងព្រះលោហិតដែលមានស្រា ដោយដៃទាំងពីរ ហើយលើកបន្តិចទាំងពោលខ្សឹបៗថា ៖

បពិត្រព្រះជាអម្ចាស់នៃពិភពលោកទាំងមូល !
យើងខ្ញុំសូមសរសើរតម្កើងព្រះអង្គ
ដ្បិតយើងខ្ញុំទទួលស្រាទំពាំងបាយជូរ
ពីព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ។
យើងខ្ញុំសូមលើកស្រានេះ ដែលជាផលផ្លែនៃដើមទំពាំងបាយជូរ
និងការងាររបស់មនុស្សលោក ថ្វាយទៅព្រះអង្គវិញ ។
សូមឲ្យស្រាតង្វាយនេះទៅជាភេសជ្ជៈ
ដែលផ្តល់ការសង្គ្រោះសម្រាប់យើងខ្ញុំ ។

អង្គប្រជុំឆ្លើយ ៖
សូមសរសើរតម្កើងព្រះជាម្ចាស់ អស់កល្បជាអង្វែងតរៀងទៅ ។

២៦. លោកបូជាចារ្យលំទោនកាយ ហើយពោលខ្សឹបៗថា ៖
ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គមេត្តាទទួលយើងខ្ញុំ ដែលមានចិត្តសុភាពរាបសា
និងសោកស្តាយដោយបានប្រព្រឹត្តអំពើបាប ។
សូមព្រះអង្គប្រោសឲ្យសក្ការបូជាដែលយើងខ្ញុំថ្វាយនៅថ្ងៃនេះ
បានគាប់ព្រះហឫទ័យព្រះជាអម្ចាស់ផង ។

២៧. ពេលបុណ្យឱឡារិក លោកបូជាចារ្យអាចថ្វាយកំញានដើម្បីគោរពតង្វាយ ឈើឆ្កាង និង តុសក្ការៈ ។ ក្រោយមក លោកឧបដ្ឋាក ឬអ្នកបម្រើពិធីបុណ្យ បក់ផ្សែងកំញានទៅរកលោកបូជាចារ្យ និងអង្គប្រជុំ ។[១៩៩]

[១៩៩] តាមវប្បធម៌ខ្មែរ គេប្រើធូប ។ គ្រីស្តបរិស័ទដង្ហែតង្វាយរួមជាមួយនឹងធូបទៅកាន់តុសក្ការៈ ។

២៨. លោកបូជាចារ្យឈរលាងដៃនៅចំហៀងតុសក្ការៈ[២០០] ទាំងពោលខ្សឹបៗថា ៖

ឱ ព្រះអម្ចាស់អើយ !

សូមលុបលាងកំហុសរបស់ខ្ញុំឲ្យបានស្អាតទាំងស្រុង

សូមជម្រះខ្ញុំឲ្យបានបរិសុទ្ធរួចពីបាប ។

២៩. បន្ទាប់មក លោកបូជាចារ្យត្រឡប់មកឈរនៅក្រោយតុសក្ការៈ បែរមុខទៅកាន់អង្គប្រជុំ ដោយលាតដៃ ហើយប្រណម្យដៃទាំងពោលថា ៖

សូមបងប្អូនតាំងចិត្តអធិដ្ឋាន ៖

សូមឲ្យសក្ការបូជារបស់ខ្ញុំ

និងរបស់បងប្អូនបានគាប់ព្រះហឫទ័យព្រះជាម្ចាស់

ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ។

អង្គប្រជុំឈរ[២០១] ហើយឆ្លើយ ៖

សូមព្រះអម្ចាស់ទទួលសក្ការបូជាពីដៃរបស់លោក

ទុកជាការលើកតម្កើងសិរីរុងរឿងព្រះនាមព្រះអង្គ និងជាប្រយោជន៍ដល់យើងខ្ញុំ

ព្រមទាំងព្រះសហគមន៍ទាំងមូលរបស់ព្រះអង្គផង ។

៣០. លោកបូជាចារ្យលាតដៃ ដោយពោលពាក្យអធិដ្ឋានថ្វាយតង្វាយ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

[២០០] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ១២៩១/៧៤ លោកបូជាចារ្យតែងតែអង្គុយនៅតុសក្ការៈ ដូច្នេះ អ្នកជំនួយពិធីបុណ្យលើកទឹក និងកន្សែងជូនលោកបូជាចារ្យ ។

[២០១] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ អង្គប្រជុំនៅតែអង្គុយ ។

# ធម៌អរព្រះគុណដ៏វិសុទ្ធ

PREX EUCHARISTICA

៣១. ពេលនេះ លោកបូជាចារ្យលាតដៃ ផ្ដើមសូត្រធម៌អរព្រះគុណដ៏វិសុទ្ធ ៖

សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

អង្គប្រជុំឆ្លើយ ៖ ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

លោកបូជាចារ្យលើកដៃពោលបន្តថា ៖

សូមលើកចិត្តថ្វាយព្រះអង្គ ។

អង្គប្រជុំឆ្លើយ ៖ យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

លោកបូជាចារ្យលាតដៃពោលបន្ត ៖

សូមអរព្រះគុណព្រះជាអម្ចាស់នៃយើងខ្ញុំ ។

អង្គប្រជុំឆ្លើយ ៖ ពិតជាការគួរណាស់ ហើយប្រពៃផង ។

លោកបូជាចារ្យលាតដៃអានធម៌ប្រារព្ធ ។

ពេលបញ្ចប់ធម៌ប្រារព្ធ លោកបូជាចារ្យលើកដៃសំពះ ច្រៀង ឬអានច្បាស់ៗរួមជាមួយអង្គប្រជុំ ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

៣២. គ្រប់ពេលថ្វាយអភិបូជា លោកបូជាចារ្យអាចច្រៀងធម៌អរព្រះគុណដ៏វិសុទ្ធ តាមរបៀបនៅទំព័រទី ៤០៧ ។ ក្នុងធម៌អរព្រះគុណដ៏វិសុទ្ធទី ១ លោកអាចរំលងពាក្យនៅក្នុងរង្វង់ក្រចក ។

# ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ

PRÆFATIO I DE ADVENTU

អបអរសាទរព្រះគ្រីស្តដែលបានយាងមក ហើយដែលនឹងយាងមកម្តងទៀត

De duobus adventibus Christi

៣៣. ធម៌ប្រារព្ធនេះ ប្រើក្នុងរដូវរង់ចាំ ចាប់ពីអាទិត្យទី១ រហូតដល់ថ្ងៃទី១៦ ខែធ្នូ និងអាចប្រើសម្រាប់អភិបូជាផ្សេងៗទៀតក្នុងរដូវនេះ ដែលគ្មានធម៌ប្រារព្ធ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់យើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ពេលព្រះអង្គយាងមកលើកទីមួយ
ទ្រង់បានទទួលយករូបកាយដ៏ទន់ខ្សោយរបស់មនុស្ស
និងបំពេញកិច្ចការដែលព្រះអង្គមានតាំងពីយូរអង្វែង
គឺបើកផ្លូវឲ្យយើងខ្ញុំទទួលការសង្គ្រោះអស់កល្បជានិច្ច ។

ពេលព្រះអង្គយាងមកលើកទីពីរ ទ្រង់នឹងពោរពេញដោយសិរីរុងរឿង
ហើយជាទីបញ្ចប់ យើងខ្ញុំនឹងទទួលមរតកយ៉ាងជាក់ស្ដែង
ដែលនៅពេលនេះ យើងខ្ញុំហ៊ានរង់ចាំក្នុងសេចក្ដីសង្ឃឹមតាមព្រះបន្ទូលសន្យា ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
កម្លាំងស័ក្ដិសិទ្ធិ និងអ្វីៗទាំងអស់ ដែលមានអំណាចនៅស្ថានបរមសុខ
លើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ២ ក្នុងរដូវរង់ចាំ

PRÆFATIO II DE ADVENTU

យើងខ្ញុំរង់ចាំព្រះគ្រីស្តយាងមក ដូចអ៊ីស្រាអែលពីដើម

De duplici exspectatione Christi

៣៤. ធម៌ប្រារព្ធនេះ ប្រើក្នុងរដូវរង់ចាំ ចាប់ពីថ្ងៃទី១៧ រហូតដល់ថ្ងៃទី២៤ ខែធ្នូ និងអាចប្រើសម្រាប់អភិបូជាផ្សេងៗទៀតក្នុងរដូវនេះ ដែលគ្មានធម៌ប្រារព្ធផ្ទាល់ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

គឺព្រះគ្រីស្តនេះហើយ ដែលអស់លោកព្យាការីបានថ្លែងទុកជាមុន
គឺព្រះគ្រីស្តនេះហើយ ដែលព្រះនាងព្រហ្មចារិនីម៉ារីជាមាតាបានរង់ចាំដោយចិត្តស្រឡាញ់

គឺព្រះគ្រីស្តនេះហើយ ដែលលោកយ៉ូហានបាទីស្តបានប្រកាសថា
ព្រះអង្គកំពុងយាងមក រួចលោកបង្ហាញឲ្យអ្នកស្រុកដឹងថា
ព្រះអង្គគង់នៅជាមួយពួកគេ
គឺព្រះគ្រីស្តនេះហើយ ដែលប្រទានឲ្យយើងខ្ញុំមានអំណរសប្បាយ
ដោយទ្រង់បានប្រសូតជាមនុស្សដូចយើងខ្ញុំ ។
ព្រះអង្គប្រទានឲ្យយើងខ្ញុំរង់ចាំដោយអធិដ្ឋាន
និងសប្បាយរីករាយដោយកោតសរសើរព្រះអង្គ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
កម្លាំងស័ក្តិសិទ្ធិ និងអ្វីៗទាំងអស់ ដែលមានអំណាចនៅស្ថានបរមសុខ
លើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ
ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ១ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត

PRÆFATIO I DE NATIVITATE DOMINI

ព្រះគ្រីស្តជាព្រះពន្លឺ

De Christo luce

៣៥. ធម៌ប្រារព្ធនេះ ប្រើក្នុងរដូវបុណ្យព្រះយេស៊ូប្រសូត និងក្នុងសប្ដាហ៍ក្រោយបុណ្យព្រះយេស៊ូប្រសូត ។ ក្នុងសប្ដាហ៍នេះ យើងអាចប្រើធម៌ប្រារព្ធនេះ ជំនួសធម៌ប្រារព្ធផ្សេងៗ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្ដជាអម្ចាស់យើងខ្ញុំ ។
ព្រះបន្ទូលដ៏អាថ៌កំបាំងបានទទួលរូបកាយជាមនុស្ស
ផ្ដល់ពន្លឺនៃសិរីរុងរឿងរបស់ព្រះអង្គមកបំភ្លឺចិត្តគំនិតយើងខ្ញុំ
ដើម្បីឲ្យយើងខ្ញុំស្គាល់ព្រះជាម្ចាស់ ក្នុងអង្គព្រះបុត្រាដែលយើងខ្ញុំមើលឃើញ
ហើយជាប់ចិត្តនឹងទ្រព្យសម្បត្តិសួគ៌ ដែលយើងខ្ញុំមើលមិនឃើញ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
កម្លាំងស័ក្តិសិទ្ធិ និងអ្វីៗទាំងអស់ ដែលមានអំណាចនៅស្ថានបរមសុខ
លើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ២ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត

PRÆFATIO II DE NATIVITATE DOMINI

ព្រះយេស៊ូប្រសូតមកឲ្យពិភពលោកបានល្អឥតខ្ចោះដូចដើមវិញ

De restauratione universa in Incarnatione

៣៦. ធម៌ប្រារព្ធនេះ ប្រើក្នុងរដូវបុណ្យព្រះយេស៊ូប្រសូត និងក្នុងសប្ដាហ៍ក្រោយបុណ្យព្រះយេស៊ូប្រសូត ។ ក្នុងសប្ដាហ៍នេះ យើងអាចប្រើធម៌ប្រារព្ធនេះ ជំនួសធម៌ប្រារព្ធផ្សេងៗ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្ដជាអម្ចាស់យើងខ្ញុំ ។

នៅថ្ងៃបុណ្យលើកតម្កើងគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ដនេះ
ថ្វីដ្បិតព្រះអង្គមានឋានៈជាព្រះជាម្ចាស់ដែលយើងខ្ញុំមើលមិនឃើញក្ដី
ក៏ទ្រង់ទទួលព្រះជន្មជាមនុស្សឲ្យយើងខ្ញុំមើលឃើញ
ហើយសូម្បីតែព្រះអង្គគង់នៅមុនកាលសម័យទាំងអស់ក៏ដោយ
ក៏ទ្រង់ចាប់ផ្ដើមរស់នៅក្នុងពេលវេលាដែរ ។

ដូច្នេះ បានជាព្រះអង្គអាចលើកអ្វីៗដែលវិនាសបាត់បង់
មកក្នុងព្រះឱរារបស់ព្រះអង្គ ព្រមទាំងស្ដារស្ថាព្រះហស្ដរបស់ព្រះអង្គ
ឲ្យទៅជាផ្លូវតែមួយ និងសង្គ្រោះមនុស្សលោកដែលកំពុងតែវង្វេង
ឲ្យត្រឡប់មកក្នុងព្រះរាជ្យនៃស្ថានបរមសុខវិញ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
សូមកោតសរសើរព្រះអង្គ ដោយច្រៀងអរសប្បាយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៣ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត

PRÆFATIO III DE NATIVITATE DOMINI

ព្រះបន្ទូលប្រសូតជាមនុស្ស ដើម្បីឲ្យមនុស្សលោកបានវិសុទ្ធ

De commercio in Incarnatione Verbi

៣៧. ធម៌ប្រារព្ធនេះ ប្រើក្នុងរដូវបុណ្យព្រះយេស៊ូប្រសូត និងក្នុងសប្ដាហ៍ ក្រោយបុណ្យព្រះយេស៊ូប្រសូត ។ ក្នុងសប្ដាហ៍នេះ យើងអាចប្រើ ធម៌ប្រារព្ធនេះជំនួសធម៌ប្រារព្ធផ្សេងៗ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្ដជាអម្ចាស់យើងខ្ញុំ ។
នៅថ្ងៃនេះ ទំនាក់ទំនងដ៏វិសុទ្ធរវាងព្រះគ្រីស្ដនឹងយើងខ្ញុំ
បានសម្ដែងយ៉ាងត្រចះត្រចង់ ។
ព្រះអង្គបានស្ដារជីវិតរបស់យើងខ្ញុំ ដោយយកភាពទន់ខ្សោយរបស់យើងខ្ញុំ
ដាក់ក្នុងព្រះបន្ទូលធ្វើឲ្យមនុស្សដែលតែងតែស្លាប់ មិនត្រឹមតែទទួលកិត្តិយសគ្មានទី
បញ្ចប់ប៉ុណ្ណោះទេ
តែដោយសម្ពន្ធមេត្រីដ៏អស្ចារ្យនេះ យើងខ្ញុំក៏មានជីវិតអស់កល្បជានិច្ចដែរ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយទេវទូតដ៏ច្រើនកុះករ កោតសរសើរព្រះអង្គ ទាំងប្រកាសដោយអំណរសប្បាយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធ ក្នុងបុណ្យព្រះយេស៊ូសម្ដែងព្រះអង្គ

PRÆFATIO DE EPIPHANIA DOMINI

ព្រះគ្រីស្ដជាពន្លឺបំភ្លឺមនុស្សលោក

De Christo lumine gentium

៣៨. ធម៌ប្រារព្ធនេះ និងធម៌ប្រារព្ធក្នុងបុណ្យព្រះយេស៊ូប្រសូត អាចប្រើបានដូចគ្នាក្នុងបុណ្យព្រះយេស៊ូសម្ដែងព្រះអង្គ ហើយអាចប្រើបានរហូតដល់ថ្ងៃសៅរ៍ មុនបុណ្យព្រះយេស៊ូទទួលពិធីជ្រមុជទឹក ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ថ្ងៃនេះ ព្រះបិតាបានសម្ដែងឲ្យយើងខ្ញុំ យល់ការអាថ៌កំបាំងនៃការសង្គ្រោះ
ដែលយើងខ្ញុំទទួលក្នុងអង្គព្រះគ្រីស្ដ ។

ដោយព្រះគ្រីស្តជាពន្លឺដែលបំភ្លឺមនុស្សគ្រប់ជាតិសាសន៍
ហើយបានចាប់កំណើតក្នុងសភាពជាមនុស្សដែលតែងតែស្លាប់
ព្រះបិតាប្រោសឲ្យយើងខ្ញុំកើតជាថ្មីក្នុងសិរីរុងរឿងរបស់ព្រះគ្រីស្ត
ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
កម្លាំងសក្តិសិទ្ធិ និងអ្វីៗទាំងអស់ ដែលមានអំណាចនៅស្ថានបរមសុខ
លើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ១ ក្នុងរដូវសែសិបថ្ងៃ

PRÆFATIO I DE QUADRAGESIMA

អត្ថន័យខាងផ្លូវវិញ្ញាណនៃរដូវសែសិបថ្ងៃ

De spiritali significatione Quadragesimæ

៣៩. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជានៃរដូវសែសិបថ្ងៃសម្រាប់ថ្ងៃអាទិត្យដែលគ្មានធម៌ប្រារព្ធផ្ទាល់ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្ដជាអម្ចាស់យើងខ្ញុំ ។

រៀងរាល់ឆ្នាំ ព្រះអង្គណែនាំប្រជារាស្ត្ររបស់ព្រះអង្គ
ឲ្យមានអំណរសប្បាយ និងចិត្តជ្រះថ្លារង់ចាំបុណ្យចម្លង
ដោយពួកគេព្យាយាមអធិដ្ឋាន ព្យាយាមស្រឡាញ់អ្នកដទៃ
និងចូលរួមក្នុងព្រឹត្តិការណ៍ដ៏អស្ចារ្យនៃការសង្គ្រោះ
ដែលប្រោសឲ្យពួកគេមានជីវិតថ្មី ពួកគេក៏ពោរពេញដោយព្រះហឫទ័យប្រណីស
ន្ដោសដ៏លើសលប់
ដែលព្រះអង្គប្រទានដល់បុត្រធីតា ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត កម្លាំងស័ក្ដិសិទ្ធិ និងអ្វីៗទាំងអស់ដែលមានអំណាចនៅស្ថានបរមសុខ លើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ២ ក្នុងរដូវសែសិបថ្ងៃ

PRÆFATIO II DE QUADRAGESIMA

ជីវិតថ្មីតាមផ្លូវវិញ្ញាណ

De spiritali pænitentia

៤0. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជានៃរដូវសែសិបថ្ងៃសម្រាប់ថ្ងៃអាទិត្យដែលគ្មានធម៌ប្រារព្ធផ្ទាល់ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ព្រះអង្គសព្វព្រះហឫទ័យប្រទានពេលវេលាដ៏ពិសិដ្ឋ
ដល់បុត្រធីតារបស់ព្រះអង្គ
ដើម្បីឲ្យពួកគេជម្រះចិត្តគំនិតបានស្អាតបរិសុទ្ធឡើងវិញ ។

ព្រះអង្គក៏សព្វព្រះហឫទ័យឲ្យពួកគេរំងាប់កិលេសតណ្ហា
ដើម្បីប្រើប្រាស់ទ្រព្យសម្បត្តិនៃពិភពលោកដ៏មិនទៀងទាត់នេះ
ដោយផ្ចង់ចិត្តនឹងសម្បត្តិសួគ៌ ដែលស្ថិតស្ថេរអស់កល្បជានិច្ច ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ សូមកោតសរសើរព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៣ ក្នុងរដូវសែសិបថ្ងៃ

PRÆFATIO III DE QUADRAGESIMA

ផលផ្លែនៃការតម

De fructibus abstinentiæ

៤១. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជា សម្រាប់ថ្ងៃធម្មតាក្នុងរដូវសែសិបថ្ងៃ និងថ្ងៃតមអាហារ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មគង់នៅអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ព្រះអង្គសព្វព្រះហឫទ័យឲ្យយើងខ្ញុំតម
ទុកជាកិច្ចអរព្រះគុណព្រះអង្គ
ដ្បិតការតមនេះ នាំឲ្យយើងខ្ញុំបោះបង់អំនួត
ចែករំលែកអាហារដល់អ្នកក្រីក្រ និងយកតម្រាប់តាមគំរូរបស់ព្រះអង្គ
ដែលមានព្រះហឫទ័យសប្បុរស ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូតដ៏ច្រើនឥតគណនា
សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៤ ក្នុងរដូវសែសិបថ្ងៃ

PRÆFATIO IV DE QUADRAGESIMA

ផលផ្លែនៃការតមអាហារ

De fructibus ieiunii

៤២. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជាសម្រាប់ថ្ងៃធម្មតាក្នុងរដូវសែសិបថ្ងៃ និងថ្ងៃតមអាហារ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មគង់នៅអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ពេលយើងខ្ញុំតមអាហារ ព្រះអង្គកាត់បន្ថយទម្លាប់អាក្រក់ក្នុងខ្លួនយើងខ្ញុំ
និងបង្វែរចិត្តគំនិតយើងខ្ញុំ ឆ្ពោះទៅរកព្រះអង្គវិញ
ហើយព្រះអង្គប្រទានឲ្យយើងខ្ញុំ ទាំងគុណធម៌ ទាំងរង្វាន់
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ក្នុងអង្គព្រះគ្រីស្ដនេះហើយ
បានជាទេវទូតទាំងឡាយគោរពកោតសរសើរព្រះអង្គ
ហើយអំណាចនានាភ័យញាប់ញ័រ នៅចំពោះព្រះភ័ក្រព្រះអង្គ ។
ផ្ទៃមេឃ និងឫទ្ធានុភាពនៃស្ថានបរមសុខរួមជាមួយពពួកសេរ៉ាភីម
ក្រាបថ្វាយបង្គំព្រះអង្គ ដោយមានអំណរសប្បាយយ៉ាងក្រៃលែង ។
យើងខ្ញុំសូមបន្ទាបខ្លួនចូលរួមកោតសរសើរព្រះអង្គ
ដោយប្រកាសថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ១
## លើកតម្កើងព្រះអម្ចាស់សោយទុក្ខលំបាក

PRÆFATIO I DE PASSIONE DOMINI

ឫទ្ធានុភាពនៃឈើឆ្កាង

De virtute Crucis

៤៣. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអាទិត្យទី៥ នៃរដូវសែសិបថ្ងៃ និងក្នុងអភិបូជាលើកតម្កើងការអាថ៌កំបាំងដ៏អស្ចារ្យនៃឈើឆ្កាង និងទុក្ខលំបាករបស់ព្រះអម្ចាស់ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។
ដោយសារព្រះបុត្រារងទុក្ខលំបាក ដើម្បីប្រទានការសង្គ្រោះពិភពលោកទាំងមូល
ប្រកាសអស់ពីដួងចិត្តនូវឫទ្ធានុភាពរបស់ព្រះអង្គ
ដ្បិតអំណាចដ៏អស្ចារ្យនៃឈើឆ្កាង បានសម្តែងការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ចំពោះពិភពលោក
និងឫទ្ធានុភាពរបស់ព្រះគ្រីស្ត ដែលជាប់នៅលើឈើឆ្កាង ។

បពិត្រព្រះអម្ចាស់ !
ហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយទេវទូត
និងសន្តបុគ្គលទាំងឡាយ សូមអរព្រះគុណព្រះអង្គ
ដោយប្រកាសទាំងអំណរសប្បាយក្រៃលែងថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ២
## លើកតម្កើងព្រះអម្ចាស់ដោយទុក្ខលំបាក

PRÆFATIO II DE PASSIONE DOMINI

ព្រះយេស៊ូឈ្នះសេចក្ដីស្លាប់

De victoria Passionis

៤៤. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជាថ្ងៃច័ន្ទ អង្គារ និងថ្ងៃពុធនៃសប្ដាហ៍ពិសិដ្ឋ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្ដជាអម្ចាស់យើងខ្ញុំ ។

ថ្ងៃដែលព្រះគ្រីស្ដបានរងទុក្ខលំបាក និងមានព្រះជន្មរស់ឡើងវិញ
ប្រកបដោយសិរីរុងរឿង មកជិតដល់ហើយ
គឺជាថ្ងៃដែលព្រះអង្គឈ្នះអំនួតរបស់មារសត្រូវ
និងជាថ្ងៃដែលយើងខ្ញុំ នឹករឭកដល់ព្រះគ្រីស្ដសង្គ្រោះយើងខ្ញុំ ។

តាមរយៈព្រះគ្រីស្តនេះហើយ
យើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូតដ៏ច្រើនកុះករ
លើកតម្កើងឫទ្ធានុភាពរបស់ព្រះអង្គ
និងសប្បាយរីករាយចំពោះព្រះភ័ក្ត្រព្រះអង្គជានិច្ច ។
យើងខ្ញុំសូមទូលអង្វរ និងច្រៀងកោតសរសើរព្រះអង្គ
ក្នុងអំណរសប្បាយយ៉ាងក្រៃលែង
ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ១ ក្នុងរដូវបុណ្យចម្លង

PRÆFATIO PASCHALIS I

អាថ៌កំបាំងដ៏អស្ចារ្យនៃបុណ្យចម្លង

De mysterio paschali

៤៥. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជានៃរដូវបុណ្យចម្លង ។ ក្នុងរាត្រីបុណ្យចម្លង សូមប្រើពាក្យ « នៅរាត្រីដ៏ពិសិដ្ឋនេះ» ។ ក្នុងថ្ងៃអាទិត្យបុណ្យចម្លង និងសប្ដាហ៍នៃបុណ្យចម្លង សូមប្រើពាក្យ« នៅថ្ងៃដ៏ពិសិដ្ឋនេះ» ។ សម្រាប់ថ្ងៃផ្សេងៗក្នុងរដូវបុណ្យចម្លង សូមប្រើពាក្យ «នៅពេលដ៏ពិសិដ្ឋនេះ» ។

បៈ. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

បៈ. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

បៈ. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ !

ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច

ពិតជាការគួរណាស់ហើយប្រពៃផង

ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន

ដែលយើងខ្ញុំអបអរសាទរព្រះអង្គគ្រប់ពេលវេលា

ជាពិសេស (នៅរាត្រីដ៏ពិសិដ្ឋនេះ/ នៅថ្ងៃដ៏ពិសិដ្ឋនេះ/ នៅពេលនេះ)

យើងខ្ញុំសូមប្រកាសយ៉ាងក្លៀវក្លាថា ព្រះគ្រីស្ដជាយញ្ញបូជានៃបុណ្យចម្លងសម្រាប់យើងខ្ញុំ ។

ព្រះយេស៊ូជាកូនចៀមដ៏ពិតប្រាកដ ដែលរំដោះបាបមនុស្សលោកីយ៍
ដោយព្រះអង្គសព្វព្រះហឫទ័យសោយទិវង្គត
នោះទ្រង់បានបំផ្លាញអំណាចនៃសេចក្ដីស្លាប់ ដោយព្រះអង្គមានព្រះជន្មរស់ឡើងវិញ នោះទ្រង់បានប្រទានជីវិតថ្មីឲ្យយើងខ្ញុំ ។

អាស្រ័យហេតុនេះហើយ បានជាមនុស្សទូទាំងសកលលោក
មានអំណរសប្បាយរីករាយក្នុងបុណ្យចម្លង
ហើយចូលរួមជាមួយអស់ទេវទូត និងឫទ្ធានុភាពនៃស្ថានបរមសុខ
ច្រៀងកោតសរសើរសិរីរុងរឿងរបស់ព្រះអង្គឥតឈប់ឈរ
ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ២ ក្នុងរដូវបុណ្យចម្លង

PRÆFATIO PASCHALIS II

ជីវិតថ្មីក្នុងអង្គព្រះគ្រីស្ត

De vita nova in Christo

៤៦. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងរដូវបុណ្យចម្លង ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ !

ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច

ពិតជាការគួរណាស់ហើយប្រពៃផង

ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន

ដែលយើងខ្ញុំអបអរសាទរព្រះអង្គគ្រប់ពេលវេលា

យើងខ្ញុំសូមប្រកាសយ៉ាងក្លៀវក្លាថា

ព្រះគ្រីស្តជាយញ្ញបូជានៃបុណ្យចម្លងសម្រាប់យើងខ្ញុំ ។

តាមរយៈព្រះគ្រីស្តនេះហើយ

បានជាបុត្រធីតានៃព្រះពន្លឺទទួលជីវិតអស់កល្បជានិច្ច

និងចូលក្នុងព្រះរាជ្យនៃស្ថានបរមសុខ ។

ដោយព្រះគ្រីស្តសោយទិវង្គត យើងខ្ញុំបានរួចពីអំណាចនៃសេចក្តីស្លាប់

ដោយព្រះគ្រីស្តមានព្រះជន្មរស់ឡើងវិញ យើងខ្ញុំក៏រស់ឡើងវិញដែរ ។

អាស្រ័យហេតុនេះហើយ បានជាមនុស្សទូទាំងសកលលោក
មានអំណរសប្បាយរីករាយក្នុងបុណ្យចម្លង
ហើយចូលរួមជាមួយអស់ទេវទូត និងឫទ្ធានុភាពនៃស្ថានបរមសុខ
ច្រៀងកោតសរសើរសិរីរុងរឿងរបស់ព្រះអង្គឥតឈប់ឈរ
ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៣ ក្នុងរដូវបុណ្យចម្លង

PRÆFATIO PASCHALIS III

ព្រះគ្រីស្តមានព្រះជន្មគង់នៅ និងទូលអង្វរព្រះបិតាឲ្យយើងខ្ញុំជានិច្ច

De Christo vivente et semper interpellante pro nobis

៤៧. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងរដូវបុណ្យចម្លង ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ !

ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច

ពិតជាការគួរណាស់ហើយប្រពៃផង

ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន

ដែលយើងខ្ញុំអបអរសាទរព្រះអង្គគ្រប់ពេលវេលា

ជាពិសេស នៅពេលនេះ យើងខ្ញុំសូមប្រកាសយ៉ាងក្លៀវក្លាថា

ព្រះគ្រីស្តជាយញ្ញបូជានៃបុណ្យចម្លងសម្រាប់យើងខ្ញុំ ។

ព្រះគ្រីស្តបូជាព្រះជន្មសម្រាប់យើងខ្ញុំឥតឈប់ឈរ

ទ្រង់ក៏នៅតែការពារយើងខ្ញុំ និងអង្វរព្រះបិតាឲ្យយើងខ្ញុំជានិច្ច ។

ព្រះគ្រីស្តជាយញ្ញបូជា តែព្រះអង្គមានជ័យជម្នះលើសេចក្តីស្លាប់

ព្រះគ្រីស្តត្រូវគេធ្វើគុត តែព្រះអង្គគង់នៅជារៀងរហូត ។

អាស្រ័យហេតុនេះហើយ បានជាមនុស្សទូទាំងសកលលោក
មានអំណរសប្បាយរីករាយក្នុងបុណ្យចម្លង
ហើយចូលរួមជាមួយអស់ទេវទូត និងឫទ្ធានុភាពនៃស្ថានបរមសុខ
ច្រៀងកោតសរសើរសិរីរុងរឿងរបស់ព្រះអង្គឥតឈប់ឈរ
ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះជាអម្ចាស់ លើពិភពលោកទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ
ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៤ ក្នុងរដូវបុណ្យចម្លង

PRÆFATIO PASCHALIS IV

ដោយព្រះគ្រីស្ដមានព្រះជន្មរស់ឡើងវិញ ទ្រង់ស្ដារពិភពលោកឡើងវិញ

De restauratione universi per mysterium paschale

៤៨. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងរដូវបុណ្យចម្លង ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ !
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំអបអរសាទរព្រះអង្គគ្រប់ពេលវេលា
ជាពិសេស នៅពេលនេះ យើងខ្ញុំសូមប្រកាសយ៉ាងក្លៀវក្លាថា
ព្រះគ្រីស្ដជាយញ្ញបូជានៃបុណ្យចម្លងសម្រាប់យើងខ្ញុំ ។

ព្រះគ្រីស្ដបានរំលាយពិភពលោកចាស់
ដើម្បីបង្កើតពិភពលោកថ្មី ហើយក្នុងអង្គព្រះគ្រីស្ដ
ព្រះអង្គស្ដារជីវិតរបស់យើងខ្ញុំឲ្យបានពេញលក្ខណៈវិញ ។

អាស្រ័យហេតុនេះហើយ បានជាមនុស្សទូទាំងសកលលោក
មានអំណរសប្បាយរីករាយក្នុងបុណ្យចម្លង
ហើយចូលរួមជាមួយអស់ទេវទូត និងឫទ្ធានុភាពនៃស្ថានបរមសុខ
ច្រៀងកោតសរសើរសិរីរុងរឿងរបស់ព្រះអង្គឥតឈប់ឈរ
ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៥ ក្នុងរដូវបុណ្យចម្លង

PRÆFATIO PASCHALIS V

ព្រះគ្រីស្តជាបូជាចារ្យ និងជាយញ្ញបូជា

De Christo sacerdote sacerdote et victima

៤៩. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងរដូវបុណ្យចម្លង ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ !

ពិតជាការគួរណាស់ហើយប្រពៃផង

ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន

ដែលយើងខ្ញុំអបអរសាទរព្រះអង្គគ្រប់ពេលវេលា

ជាពិសេស នៅពេលនេះ យើងខ្ញុំសូមប្រកាសយ៉ាងក្លៀវក្លាថា

ព្រះគ្រីស្តជាយញ្ញបូជានៃបុណ្យចម្លងសម្រាប់យើងខ្ញុំ ។

ពេលព្រះគ្រីស្តថ្វាយព្រះកាយព្រះអង្គ

ទ្រង់បានប្រោសឲ្យសក្ការបូជាទាំងប៉ុន្មាននៃសម្ពន្ធមេត្រីចាស់

បានល្អឥតខ្ចោះ ដោយលក្ខណៈពិតប្រាកដនៃឈើឆ្កាង ។

ព្រះអង្គថ្វាយព្រះជន្មទាំងស្រុងទៅព្រះបិតា ដើម្បីសង្គ្រោះយើងខ្ញុំ

នោះបញ្ជាក់ថា ព្រះអង្គពិតជាបូជាចារ្យ

ជាតុសក្ការៈ និងជាកូនចៀម ។

អាស្រ័យហេតុនេះហើយ បានជាមនុស្សទូទាំងសកលលោក
មានអំណរសប្បាយរីករាយក្នុងបុណ្យចម្លង
ហើយចូលរួមជាមួយអស់ទេវទូត និងឫទ្ធានុភាពនៃស្ថានបរមសុខ
ច្រៀងកោតសរសើរសិរីរុងរឿងរបស់ព្រះអង្គឥតឈប់ឈរ
ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ១
# បុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ

PRÆFATIO I DE ASCENSIONE DOMINI

គម្រោងការដ៏អស្ចារ្យរបស់ព្រះអម្ចាស់ យាងឡើងស្ថានបរមសុខ

De mysterio Ascensionis

៥០. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជា ថ្ងៃបុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ ។ ធម៌នេះ អាចបន្តប្រើរហូតដល់ថ្ងៃសៅរ៍មុនបុណ្យព្រះវិញ្ញាណយាងមក សម្រាប់អភិបូជាថ្ងៃធម្មតា ដែលគ្មានធម៌ប្រារព្ធផ្ទាល់ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។
ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។
ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ព្រះអម្ចាស់យេស៊ូ ជាព្រះមហាក្សត្រប្រកបដោយសិរីរុងរឿង
មានជ័យជម្នះលើអំពើបាប និងសេចក្តីស្លាប់
(នៅថ្ងៃនេះ) ព្រះអង្គយាងឡើងស្ថានបរមសុខដ៏ខ្ពង់ខ្ពស់បំផុត
ទាំងមានទេវទូតសម្លឹងមើលដោយស្ញប់ស្ញែង ។

ព្រះអង្គជាស្ពានដែលនាំឲ្យព្រះជាម្ចាស់ និងមនុស្សលោកមានទំនាក់ទំនងជាមួយគ្នា
ជាចៅក្រមនៃពិភពលោក និងជាព្រះអម្ចាស់លើអំណាចនានា ។
ព្រះអម្ចាស់យាងឡើងស្ថានបរមសុខមុនគេ
ដោយមិនបានឃ្លាតឆ្ងាយពីភាពទន់ទាបរបស់យើងខ្ញុំទេ
ប៉ុន្តែព្រះអង្គប្រោសយើងខ្ញុំដែលជាសរីរាង្គនៃព្រះកាយ
ឲ្យមានសេចក្ដីសង្ឃឹមថា នឹងឡើងតាមព្រះអង្គដែលជាព្រះសិរសា
ព្រមទាំងជាដើមកំណើតនៃអ្វីៗទាំងអស់ ។

អាស្រ័យហេតុនេះហើយ បានជាមនុស្សទូទាំងសកលលោក
មានអំណរសប្បាយរីករាយក្នុងបុណ្យចម្លង
ហើយចូលរួមជាមួយអស់ទេវទូត និងឫទ្ធានុភាពនៃស្ថានបរមសុខ
ច្រៀងកោតសរសើរសិរីរុងរឿងរបស់ព្រះអង្គឥតឈប់ឈរ
ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ២
# បុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ

PRÆFATIO II DE ASCENSIONE DOMINI

គម្រោងការដ៏អស្ចារ្យរបស់ព្រះអម្ចាស់ យាងឡើងស្ថានបរមសុខ

De mysterio Ascensionis

៥១. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជា ថ្ងៃបុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ ។ ធម៌នេះ អាចបន្តប្រើរហូតដល់ថ្ងៃសៅរ៍មុនបុណ្យព្រះវិញ្ញាណយាងមក សម្រាប់អភិបូជាថ្ងៃធម្មតា ដែលគ្មានធម៌ប្រារព្ធផ្ទាល់ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ក្រោយពេលព្រះគ្រីស្តមានព្រះជន្មរស់ឡើងវិញ
ទ្រង់បានបង្ហាញព្រះអង្គឲ្យសាវ័កទាំងអស់ឃើញយ៉ាងច្បាស់
រួចព្រះអង្គយាងឡើងស្ថានបរមសុខ
និងប្រទានឲ្យយើងខ្ញុំមានលក្ខណៈជាព្រះជាម្ចាស់រួមជាមួយព្រះអង្គ ។

អាស្រ័យហេតុនេះហើយ បានជាមនុស្សទូទាំងសកលលោក
មានអំណរសប្បាយរីករាយក្នុងបុណ្យចម្លង
ហើយចូលរួមជាមួយអស់ទេវទូត និងឫទ្ធានុភាពនៃស្ថានបរមសុខ
ច្រៀងកោតសរសើរសិរីរុងរឿងរបស់ព្រះអង្គឥតឈប់ឈរ
ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ១ ថ្ងៃអាទិត្យក្នុងរដូវធម្មតា

PRÆFATIO I DE DOMINICIS « PER ANNUM »

គម្រោងការដ៏អស្ចារ្យនៃបុណ្យចម្លង និងប្រជារាស្ត្ររបស់ព្រះជាម្ចាស់

De mysterio paschali et de populo Dei

៥២. ធម៌ប្រារព្ធនេះ ប្រើនៅថ្ងៃអាទិត្យក្នុងរដូវធម្មតា ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ព្រះគ្រីស្តបានបំពេញកិច្ចការដ៏ស្ញប់ស្ញែងក្រៃលែង
តាមគម្រោងការដ៏អស្ចារ្យនៃបុណ្យចម្លង
គឺព្រះអង្គត្រាស់ហៅយើងខ្ញុំ ឲ្យចេញពីអំព្រែកនៃអំពើបាប
និងសេចក្តីស្លាប់ ទៅកាន់សិរីរុងរឿង
ទៅជាពូជសាសន៍ដែលព្រះអង្គបានជ្រើសរើស
ទៅជាក្រុមបូជាចារ្យ ទៅជាជាតិសាសន៍ដ៏វិសុទ្ធ
ទៅជាប្រជារាស្ត្រដែលជាកម្មសិទ្ធិផ្ទាល់របស់ព្រះជាម្ចាស់ ។

យើងខ្ញុំសូមប្រកាសនៅគ្រប់ទិសទី
អំពីកិច្ចការដ៏មានឫទ្ធានុភាពរបស់ព្រះអង្គ
ដ្បិតទ្រង់បានត្រាស់ហៅយើងខ្ញុំឲ្យចេញពីសេចក្ដីងងឹត
ចូលក្នុងពន្លឺដ៏រុងរឿងរបស់ព្រះអង្គ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
កម្លាំងស័ក្ដិសិទ្ធិ និងអ្វីៗទាំងអស់ដែលមានអំណាចនៅស្ថានបរមសុខ
សូមរួមគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ២ ថ្ងៃអាទិត្យក្នុងរដូវធម្មតា

PRÆFATIO II DE DOMINICIS « PER ANNUM »

គម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះ

De mysterio salutis

៥៣. ធម៌ប្រារព្ធនេះ ប្រើនៅថ្ងៃអាទិត្យក្នុងរដូវធម្មតា ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ព្រះគ្រីស្តសម្តែងមេត្តាករុណាដល់យើងខ្ញុំដែលជាមនុស្សវង្វេង
ទ្រង់សព្វព្រះហឫទ័យបន្ទាបព្រះអង្គផ្ទាល់ ប្រសូតពីព្រះនាងព្រហ្មចារិនី ។
ដោយព្រះអង្គសោយទុក្ខលំបាកនៅលើឈើឆ្កាង
ទ្រង់បានរំដោះយើងខ្ញុំឲ្យរួចផុតពីសេចក្តីស្លាប់ជានិច្ចនិរន្តរ៍ ។
ដោយព្រះអង្គមានព្រះជន្មរស់ឡើងវិញ
ទ្រង់បានប្រទានជីវិតអស់កល្បជានិច្ចឲ្យយើងខ្ញុំ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត កម្លាំងស័ក្ដិសិទ្ធិ និងអ្វីៗទាំងអស់ដែលមានអំណាចនៅស្ថានបរមសុខ លើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៣ ថ្ងៃអាទិត្យក្នុងរដូវធម្មតា

PRÆFATIO III DE DOMINICIS « PER ANNUM »

ព្រះគ្រីស្តដែលជាមនុស្ស បានសង្គ្រោះមនុស្ស

De salvatione hominis per hominem

៥៤. ធម៌ប្រារព្ធនេះ ប្រើនៅថ្ងៃអាទិត្យក្នុងរដូវធម្មតា ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

យើងខ្ញុំដឹងថា សិរីរុងរឿងរបស់ព្រះអង្គទូលំទូលាយណាស់
ដោយលក្ខណៈជាព្រះជាម្ចាស់ ព្រះអង្គបានជួយរំដោះមនុស្សលោក ។
ព្រះអង្គជាឱសថព្យាបាលយើងខ្ញុំឲ្យរួចផុតពីសេចក្តីស្លាប់
ដូច្នេះមូលហេតុដែលនាំឲ្យយើងខ្ញុំវិនាសអន្តរាយ
ក៏ត្រឡប់ទៅជាមធ្យោបាយនៃការសង្គ្រោះវិញ
តាមរយៈព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ដោយសារព្រះគ្រីស្ដនេះហើយ
យើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូតដ៏ច្រើនកុះករ
លើកតម្កើងអានុភាពដ៏អស្ចារ្យរបស់ព្រះអង្គ
និងសប្បាយរីករាយចំពោះព្រះភ័ក្ត្រព្រះអង្គជានិច្ច ។
យើងខ្ញុំសូមទូលអង្វរ និងច្រៀងកោតសរសើរព្រះអង្គ
ក្នុងអំណរសប្បាយយ៉ាងក្រៃលែង
ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៤ ថ្ងៃអាទិត្យក្នុងរដូវធម្មតា

PRÆFATIO IV DE DOMINICIS « PER ANNUM »

ប្រវត្តិនៃការសង្គ្រោះ

De historia salutis

៥៥. ធម៌ប្រារព្ធនេះ ប្រើនៅថ្ងៃអាទិត្យក្នុងរដូវធម្មតា ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ដោយសារព្រះបុត្រាប្រសូតជាមនុស្ស
ព្រះអង្គបំបាត់ជីវិតចាស់របស់មនុស្ស ហើយបំពាក់ជីវិតថ្មីដល់ពួកគេ ។
ដោយសារព្រះអង្គរងទុក្ខលំបាក ទ្រង់បានលុបបាបរបស់យើងខ្ញុំចោល ។
ដោយសារព្រះអង្គមានព្រះជន្មរស់ឡើងវិញ
ទ្រង់បានបើកផ្លូវឲ្យមនុស្សចូលទៅកាន់ជីវិតអស់កល្បជានិច្ច ។
ដោយសារព្រះអង្គយាងឡើងទៅកាន់ព្រះបិតា
ទ្រង់បានបើកទ្វារនៃស្ថានបរមសុខ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត និងសន្តបុគ្គលទាំងឡាយ ច្រៀងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ដោយប្រកាសឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៥ ថ្ងៃអាទិត្យក្នុងរដូវធម្មតា

PRÆFATIO V DE DOMINICIS « PER ANNUM »

ព្រះជាម្ចាស់បង្កើតពិភពលោក

De creatione

៥៦. ធម៌ប្រារព្ធនេះ ប្រើនៅថ្ងៃអាទិត្យក្នុងរដូវធម្មតា ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ព្រះអង្គបានបង្កើតអ្វីៗសព្វសារពើទាំងអស់នៃពិភពលោក
ហើយទ្រង់បានរៀបចំឲ្យមានការផ្លាស់ប្តូរពេលវេលា និងរដូវកាល ។
ព្រះអង្គបង្កើតមនុស្សឲ្យធ្វើជាតំណាងមានលក្ខណៈដូចព្រះអង្គ
ដើម្បីទទួលខុសត្រូវលើអ្វីៗទាំងអស់ និងធ្វើជាម្ចាស់ក្នុងព្រះនាមព្រះអង្គ ។
យើងខ្ញុំសូមកោតសរសើរព្រះអង្គអស់កល្បជានិច្ច
ចំពោះកិច្ចការដ៏អស្ចារ្យដែលទ្រង់បានប្រព្រឹត្ត
តាមរយៈព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ទាំងមានអំណរសប្បាយរីករាយ
ដោយប្រកាសថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៦ ថ្ងៃអាទិត្យក្នុងរដូវធម្មតា

PRÆFATIO VI DE DOMINICIS « PER ANNUM »

ការធានាឲ្យចូលក្នុងបុណ្យចម្លងអស់កល្បជានិច្ច

De pignore æterni Paschatis

៥៧. ធម៌ប្រារព្ធនេះ ប្រើនៅថ្ងៃអាទិត្យក្នុងរដូវធម្មតា ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ដោយសារព្រះអង្គ យើងខ្ញុំមានជីវិត
មានចលនា និងមានសភាវៈជាមនុស្ស
ហើយក្នុងរូបកាយដែលព្រះអង្គប្រទានឲ្យយើងខ្ញុំនេះ
យើងខ្ញុំទទួលនូវព្រះហឫទ័យថ្នាក់ថ្នមរបស់ព្រះអង្គជារៀងរាល់ថ្ងៃ ។
លើសនេះទៅទៀត
ព្រះអង្គបានធានាប្រទានជីវិតអស់កល្បជានិច្ចដល់យើងខ្ញុំ ។

ដូច្នេះ យើងខ្ញុំសង្ឃឹមថា
បានចូលរួមក្នុងគម្រោងការដ៏អស្ចារ្យនៃបុណ្យចម្លងជារៀងរហូត
ដ្បិតយើងខ្ញុំបានទទួលផលផ្លែដំបូងនៃព្រះវិញ្ញាណ
គឺតាមរយៈព្រះវិញ្ញាណនេះហើយ
ដែលព្រះបិតាលើកព្រះយេស៊ូឡើងពីចំណោមមនុស្សស្លាប់ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
កោតសរសើរលើកតម្កើងព្រះអង្គ ទាំងមានអំណរសប្បាយរីករាយ
ដោយប្រកាសថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៧ ថ្ងៃអាទិត្យក្នុងរដូវធម្មតា

PRÆFATIO VII DE DOMINICIS « PER ANNUM »

ព្រះគ្រីស្តធ្វើតាមព្រះហឫទ័យព្រះបិតា ដើម្បីសង្គ្រោះមនុស្សលោក

De salute per obœdientiam Christi

៥៨. ធម៌ប្រារព្ធនេះ ប្រើនៅថ្ងៃអាទិត្យក្នុងរដូវធម្មតា ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ដោយព្រះបិតាស្រឡាញ់មនុស្សលោកខ្លាំងណាស់
ព្រះអង្គចាត់ព្រះបុត្រាមករំដោះយើងខ្ញុំ
ព្រះបុត្រារស់នៅដូចយើងខ្ញុំសព្វប្រការ
តែទ្រង់មិនបានប្រព្រឹត្តអំពើបាបសោះឡើយ
ដូច្នេះព្រះបិតាសព្វព្រះហឫទ័យនឹងយើងខ្ញុំ
ដូចព្រះអង្គសព្វព្រះហឫទ័យនឹងព្រះបុត្រាដែរ ។

យើងខ្ញុំបានបាត់បង់ព្រះអំណោយទាន
ដោយសារយើងខ្ញុំធ្វើខុសនឹងព្រះហឫទ័យព្រះអង្គ
ប៉ុន្តែព្រះអង្គប្រោសឲ្យយើងខ្ញុំ ទទួលព្រះអំណោយទាននោះសារជាថ្មី
ដោយសារព្រះបុត្រាធ្វើតាមព្រះបញ្ជារបស់ព្រះអង្គ ។

បពិត្រព្រះអម្ចាស់ !
ហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ សូមអរព្រះគុណព្រះអង្គ
ដោយប្រកាសទាំងអំណរសប្បាយយ៉ាងក្រៃលែងថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៨ ថ្ងៃអាទិត្យក្នុងរដូវធម្មតា

PRÆFATIO VIII DE DOMINICIS « PER ANNUM »

ព្រះត្រៃឯកបង្រួបបង្រួមព្រះសហគមន៍ឲ្យទៅជាធ្លុងតែមួយ

De Ecclesia adunata ex unitate Trinitatis

៥៩. ធម៌ប្រារព្ធនេះ ប្រើនៅថ្ងៃអាទិត្យក្នុងរដូវធម្មតា ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

នៅពេលបុត្រធីតារបស់ព្រះអង្គ បែកបាក់គ្នាព្រោះតែអំពើបាប
ព្រះអង្គបានប្រមូលពួកគេឲ្យត្រឡប់មកវិញ
តាមរយៈព្រះលោហិតរបស់ព្រះបុត្រា និងឫទ្ធានុភាពនៃព្រះវិញ្ញាណ ។
ព្រះអង្គបង្រួបបង្រួមពួកគេ ឲ្យទៅជាប្រជារាស្ត្រតែមួយក្នុងព្រះត្រៃឯក
ជាព្រះកាយព្រះគ្រីស្ត និងជាព្រះវិហារនៃព្រះវិញ្ញាណដ៏វិសុទ្ធ
គឺព្រះសហគមន៍
ដែលលើកតម្កើងព្រះប្រាជ្ញាញាណគ្រប់បែបយ៉ាងរបស់ព្រះអង្គ ។

អាស្រ័យហេតុនេះហើយ
បានជាយើងខ្ញុំសូមចូលរួមជាមួយទេវទូតដ៏ច្រើនកុះករ
កោតសរសើរព្រះអង្គ ទាំងប្រកាសដោយអំណរសប្បាយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ១
# បុណ្យព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត

PRÆFATIO I DE SS.MA EUCHARISTIA

ព្រះគ្រីស្តជាអគ្គសញ្ញា និងជាយញ្ញបូជា

De sacrificio et de saramento Christi

៦០. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជា សម្រាប់ថ្ងៃព្រហស្បតិ៍ពិសិដ្ឋ ។ ធម៌នេះ អាចប្រើក្នុងឱកាសគោរពព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ជាបុណ្យដ៏ឱឡារិក ឬជាបុណ្យរំឭក ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ព្រះគ្រីស្តជាបូជាចារ្យពិតប្រាកដ និងអស់កល្បជានិច្ច
ព្រះអង្គបង្កើតគំរូនៃយញ្ញបូជាគង់វង្សជារៀងរហូត ។

ព្រះអង្គបានថ្វាយព្រះជន្មមុនគេ ទុកជាយញ្ញបូជា
និងបង្គាប់ឲ្យយើងខ្ញុំថ្វាយសក្ការបូជានេះ
ដើម្បីនឹករំឭកដល់ព្រះអង្គ ។
ពេលយើងខ្ញុំពិសាព្រះកាយដែលព្រះអង្គបានបូជា
យើងខ្ញុំមានកម្លាំងរឹងមាំ
ពេលយើងខ្ញុំពិសាព្រះលោហិតដែលព្រះអង្គបានបង្ហូរ
យើងខ្ញុំបានស្អាតបរិសុទ្ធ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
កម្លាំងសក្តិសិទ្ធិ និងអ្វីៗទាំងអស់ ដែលមានអំណាចនៅស្ថានបរមសុខ
សូមរួមគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ២
# បុណ្យព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត

PRÆFATIO II DE SS.MA EUCHARISTIA

ផលផ្លែនៃពិធីអរព្រះគុណដ៏វិសុទ្ធ

De fructibus Sanctissimæ Eucharistiæ

៦១. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងឱកាសគោរពព្រះកាយ និងព្រះលោហិតព្រះគ្រីស្តជាបុណ្យដ៏ឱឡារិក ឬក្នុងអភិបូជាតាមសំណូមពរ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !<br>
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច<br>
ពិតជាការគួរណាស់ហើយប្រពៃផង<br>
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន<br>
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី<br>
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

នៅពេលជប់លៀងចុងក្រោយបង្អស់រួមជាមួយក្រុមសាវ័ក<br>
ព្រះគ្រីស្តដែលជាកូនចៀមឥតសៅហ្មង និងជាតង្វាយដ៏សមរម្យ<br>
ទ្រង់បានបូជាព្រះជន្ម ដើម្បីអរព្រះគុណព្រះបិតា<br>
ព្រះអង្គប្រព្រឹត្តដូច្នេះឲ្យមនុស្សគ្រប់ជំនាន់<br>
នឹករឭកដល់ឈើឆ្កាង ដែលផ្តល់ការសង្គ្រោះ ។

ដោយសក្ការបូជាដ៏អស្ចារ្យនេះ
ព្រះអង្គចិញ្ចឹមអស់អ្នកជឿ ហើយប្រោសពួកគេឲ្យបានវិសុទ្ធ
ដើម្បីឲ្យមនុស្សគ្រប់ជាតិសាសន៍ ដែលរស់ក្នុងពិភពលោកតែមួយ
ទទួលពន្លឺដោយជំនឿតែមួយ និងរួមគ្នាក្នុងសេចក្ដីស្រឡាញ់តែមួយ ។
ពេលនេះ យើងខ្ញុំមកជិតតុសក្ការៈនៃអគ្គសញ្ញាដ៏អស្ចារ្យ
ព្រះអង្គបង្ហូរព្រះហឫទ័យថ្នាក់ថ្នម
ដើម្បីឲ្យថ្ងៃណាមួយ យើងខ្ញុំអាចឆ្លងចូលនៅឯស្ថានបរមសុខបាន ។

អាស្រ័យហេតុនេះ សត្វលោកទាំងអស់នៅលើផែនដី
និងនៅស្ថានបរមសុខ ច្រៀងបទថ្មីគោរពលើកតម្កើងព្រះអង្គ
ហើយយើងខ្ញុំរួមជាមួយអស់ទេវទូត
ប្រកាសឡើងដោយឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ១ បុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារី

PRÆFATIO I DE BEATA MARIA VIRGINE

ព្រះនាងព្រហ្មចារិនីម៉ារីពោរពេញដោយសុភមង្គល ជាព្រះមាតារបស់ព្រះជាម្ចាស់

De Maternitate beatæ Mariæ Virginis

៦២. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងថ្ងៃបុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារីពោរពេញដោយសុភមង្គល ។ ពេលអានសូមកុំភ្លេចប្រាប់ឈ្មោះថ្ងៃបុណ្យក្នុងវង្វង់ក្រចក ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
ហើយនៅថ្ងៃដែលយើងខ្ញុំគោរពព្រះនាងព្រហ្មចារិនីម៉ារី (ក្នុងឱកាសបុណ្យ...)
យើងខ្ញុំសូមចូលរួមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ។
ព្រះវិញ្ញាណដ៏វិសុទ្ធគ្របបាំងឲ្យព្រះនាងមានគភ៌
និងរក្សាព្រហ្មចារិយ៍ជាដរាប ។
ព្រះនាងបានប្រសូតព្រះបុត្រាតែមួយ
ដែលជាពន្លឺស្ថិតស្ថេរអស់កល្បជានិច្ចនៅក្នុងពិភពលោក
គឺព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់យើងខ្ញុំ ។

ក្នុងអង្គព្រះគ្រីស្ដនេះហើយ
បានជាទេវទូតទាំងឡាយ គោរពកោតសរសើរព្រះអង្គ
ហើយអំណាចនានា ភ័យញាប់ញ័រនៅចំពោះព្រះភ័ក្ត្រព្រះអង្គ ។
ផ្ទៃមេឃ និងឫទ្ធានុភាពនៃស្ថានបរមសុខរួមជាមួយពពួកសេរ៉ាភីម
ក្រាបថ្វាយបង្គំព្រះអង្គ ដោយមានអំណរសប្បាយយ៉ាងក្រៃលែង ។
យើងខ្ញុំសូមបន្ទាបខ្លួនចូលរួមកោតសរសើរព្រះអង្គ
ដោយប្រកាសថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ២ បុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារី

PRÆFATIO II DE BEATA MARIA VIRGINE

ព្រះសហគមន៍លើកតម្កើងព្រះជាម្ចាស់ តាមពាក្យរបស់ព្រះនាងព្រហ្មចារិនីម៉ារី

Ecclesia, verbis Mariæ, laudes Deo persolvit

៦៣. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងថ្ងៃបុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារី ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតា !
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមកោតសរសើរឫទ្ធានុភាពរបស់ព្រះអង្គ
ក្នុងជីវិតរបស់សន្តបុគ្គលទាំងឡាយ ។

ជាពិសេស យើងខ្ញុំនឹករឭកដល់ព្រះនាងព្រហ្មចារិនីម៉ារី
ពោរពេញដោយសុភមង្គល
យើងខ្ញុំសូមប្រកាសពីព្រះហឫទ័យអាណិតអាសូររបស់ព្រះអង្គ
យើងខ្ញុំសូមកោតសរសើរ និងអរព្រះគុណព្រះអង្គ ។

ព្រះអង្គពិតជាបានប្រព្រឹត្តកិច្ចការប្រសើរអស្ចារ្យ
ដល់ទីដាច់ស្រយាលនៃផែនដី ហើយព្រះអង្គបានបន្ត
សម្ដែងធម៌មេត្តាករុណាដ៏លើសលប់ដល់មនុស្សគ្រប់ជំនាន់ ។

ព្រះអង្គទតឃើញព្រះនាងម៉ារី ដែលជាអ្នកបម្រើដ៏ទន់ទាប
ហើយតាមរយៈព្រះនាង ព្រះអង្គបានប្រទានព្រះសង្គ្រោះមនុស្សលោក
គឺព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាព្រះអង្គ និងជាព្រះអម្ចាស់យើងខ្ញុំ ។

ដោយសារព្រះគ្រីស្តនេះហើយ
បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូតដ៏ច្រើនកុះករ
លើកតម្កើងអានុភាពដ៏អស្ចារ្យរបស់ព្រះអង្គ
និងសប្បាយរីករាយចំពោះព្រះភ័ក្ត្រព្រះអង្គជានិច្ច ។
យើងខ្ញុំសូមទូលអង្វរ និងច្រៀងកោតសរសើរព្រះអង្គ
ក្នុងអំណរសប្បាយយ៉ាងក្រៃលែង
ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ១ បុណ្យគោរពគ្រីស្តទូត

PRÆFATIO I DE APOSTOLIS

គ្រីស្តទូតជាគង្វាលប្រជារាស្ត្ររបស់ព្រះជាម្ចាស់

De Apostolis pastoribus populi Dei

៦៤. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជានៃថ្ងៃបុណ្យគោរពគ្រីស្តទូត ជាពិសេស សន្តសិលា និងសន្តប៉ូល ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់យើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ព្រះអង្គពិតជាគង្វាលអស់កល្បជានិច្ច
ទ្រង់មិនដែលបោះបង់បោលហ្វូងចៀមរបស់ព្រះអង្គឡើយ
ផ្ទុយទៅវិញ ព្រះអង្គថែរក្សាការពារពួកគេ
តាមរយៈគ្រីស្តទូតទាំងឡាយ ។
ព្រះអង្គបានជ្រើសតាំងគង្វាលទាំងនោះ
ដើម្បីគ្រប់គ្រង និងណែនាំហ្វូងចៀមក្នុងនាមព្រះបុត្រារបស់ព្រះអង្គ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
កម្លាំងស័ក្ដិសិទ្ធិ និងអ្វីៗទាំងអស់ ដែលមានអំណាចនៅស្ថានបរមសុខ
សូមរួមគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ២ បុណ្យគោរពគ្រីស្តទូត

PRÆFATIO II DE APOSTOLIS

ក្រុមគ្រីស្តទូតជាគ្រឹះ និងជាសាក្សីរបស់ព្រះសហគមន៍

De apostolic fundamento et testimonio

៦៥. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជានៃថ្ងៃបុណ្យគោរពគ្រីស្តទូត និងអ្នកនិពន្ធគម្ពីរដំណឹងល្អ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច!
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ព្រះអង្គបានកសាងព្រះសហគមន៍ លើក្រុមគ្រីស្តទូតជាគ្រឹះយ៉ាងរឹងមាំ
ដើម្បីឲ្យព្រះសហគមន៍ទៅជាសញ្ញាសម្គាល់
បង្ហាញពីលក្ខណៈដ៏វិសុទ្ធរបស់ព្រះអង្គ ក្នុងពិភពលោកនេះ
ហើយប្រកាសដល់មនុស្សជាតិទាំងឡាយ អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ។

អាស្រ័យហេតុនេះហើយ
បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូតដ៏ច្រើនកុះករ
ច្រៀងកោតសរសើរព្រះអង្គអស់ពីដួងចិត្ត
នៅពេលនេះ និងរហូតតរៀងទៅ ដោយប្រកាសថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ១ បុណ្យគោរពសន្តបុគ្គលទាំងឡាយ

PRÆFATIO I DE SANCTIS

សិរីរុងរឿងនៃសន្តបុគ្គល

De Gloria Sanctorum

៦៦. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជានៅថ្ងៃ ៖

- បុណ្យគោរពសន្តបុគ្គលទាំងឡាយ (បុណ្យភ្ជុំ)[២០២] ។
- បុណ្យគោរពសន្តបុគ្គលជាឧបការីរបស់ភូមិភាគ ឬព្រះសហគមន៍នីមួយៗ ។
- បុណ្យឱឡារិក និងបុណ្យគោរពសន្តបុគ្គល ប្រសិនបើគ្មានធម៌ប្រារព្ធផ្ទាល់នៅថ្ងៃបុណ្យនោះ ។
- បុណ្យរំឭកសន្តបុគ្គល ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

---

[២០២] តាមសាសនៈក្រឹត្យលេខ ២៤០/៧០ ចុះនៅថ្ងៃទី ២ កុម្ភៈ ១៩៧០ បុណ្យគោរពសន្តបុគ្គលទាំងឡាយប្រារព្ធនៅថ្ងៃបុណ្យភ្ជុំ ។

សន្តបុគ្គលទាំងឡាយតែងតែលើកតម្កើងព្រះអង្គជានិច្ច
ហើយពេលព្រះអង្គបំពាក់ភួងជ័យឲ្យសន្តបុគ្គលទាំងឡាយ
ទុកជារង្វាន់ដល់អំពើល្អរបស់ពួកគាត់
ពេលនោះព្រះអង្គក៏បំពាក់ភួងជ័យលើព្រះអំណោយទានរបស់ព្រះអង្គដែរ ។

ព្រះអង្គប្រោសប្រទានរបៀបរស់នៅរបស់សន្តបុគ្គលធ្វើជាគំរូ
សហភាពជាមួយសន្តបុគ្គលធ្វើជាមហាគ្រួសារ
និងពាក្យអង្វររបស់ពួកគាត់ធ្វើជាទីពឹងរបស់យើងខ្ញុំ ។
ដូច្នេះសន្តបុគ្គលទាំងអស់នោះ ធ្វើជាសាក្សី
និងលើកទឹកចិត្តយើងខ្ញុំឲ្យរត់បានរហូតដល់គោលដៅ
ហើយទទួលភួងជ័យដែលមិនចេះរលួយរួមជាមួយពួកគាត់
តាមរយៈព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយទេវទូត
អគ្គទេវទូត និងសន្តបុគ្គលទាំងឡាយដ៏ច្រើនឥតគណនា
ច្រៀងលើកតម្កើងព្រះអង្គ ដោយប្រកាសឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ២ បុណ្យគោរពសន្តបុគ្គលទាំងឡាយ

PRÆFATIO II DE SANCTIS

## កិច្ចការរបស់សន្តបុគ្គល

De actione Sanctorum

៦៧. ធម៌ប្រារព្ធនេះ ប្រើក្នុងអភិបូជានៅថ្ងៃ ៖

- បុណ្យគោរពសន្តបុគ្គលទាំងឡាយ (បុណ្យភ្ជុំ)[២០៣] ។
- បុណ្យគោរពសន្តបុគ្គលជាឧបការីរបស់ភូមិភាគ ឬព្រះសហគមន៍នីមួយៗ ។
- បុណ្យឱឡារិក និងបុណ្យគោរពសន្តបុគ្គល ប្រសិនបើគ្មានធម៌ប្រារព្ធផ្ទាល់នៅថ្ងៃបុណ្យនោះ ។
- បុណ្យរំឭកសន្តបុគ្គល ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

[២០៣] តាមសាសនៈក្រឹត្យលេខ ២៤០/៧០ ចុះនៅថ្ងៃទី ២ កុម្ភៈ ១៩៧០ បុណ្យគោរពសន្តបុគ្គលទាំងឡាយប្រារព្ធនៅថ្ងៃបុណ្យភ្ជុំ ។

ព្រះអង្គប្រោសប្រទានឲ្យព្រះសហគមន៍
មានជីវិតរស់រវើក និងរឹងមាំជារៀងរហូត
ដោយសារសក្ខីភាពនៃជំនឿរបស់សន្ដបុគ្គលទាំងឡាយ
ដែលជាសញ្ញាសម្គាល់ដ៏ពិតប្រាកដ នៃសេចក្ដីស្រឡាញ់របស់ព្រះអង្គ ។
មិនតែប៉ុណ្ណោះ គំរូល្អរបស់សន្ដបុគ្គលទាំងឡាយ
ជំរុញយើងខ្ញុំឲ្យមានចិត្តក្លាហាន
ហើយពាក្យអង្វររបស់ពួកគាត់ គាំទ្រយើងខ្ញុំក្នុងគ្រប់កិច្ចការ
ដើម្បីឲ្យគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គបានកើតជារូបរាង ។

ឱ ព្រះអម្ចាស់អើយ !
ហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយទេវទូត
និងសន្ដបុគ្គលទាំងឡាយ សូមអរព្រះគុណព្រះអង្គ
ដោយប្រកាសទាំងអំណរសប្បាយក្រៃលែងថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ១ បុណ្យគោរពមរណសាក្សី

PRÆFATIO I DE SANCTIS MARTYRIBUS

មរណសាក្សីជាគំរូ និងជាសញ្ញាសម្គាល់

De signo et exemplo martyrii

៦៨. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងថ្ងៃបុណ្យឱឡារិក និងថ្ងៃបុណ្យគោរពមរណសាក្សី ។ ធម៌នេះ អាចប្រើក្នុងថ្ងៃបុណ្យរំឭកមរណសាក្សីផងដែរ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

សក្ខីភាពនៃជំនឿរបស់មរណសាក្សីឈ្មោះ...
ដែលបានបង្ហូរលោហិតដូចព្រះគ្រីស្ត
បង្ហាញឲ្យឃើញនូវស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះអង្គ
គឺព្រះអង្គសម្ដែងឫទ្ធានុភាពរបស់ព្រះអង្គ នៅក្នុងភាពទន់ខ្សោយរបស់យើងខ្ញុំ
ហើយព្រះអង្គប្រោសឲ្យមនុស្សទន់ខ្សោយ អាចផ្ដល់សក្ខីភាពពីព្រះអង្គបាន
តាមរយៈព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំនៅលើផែនដី
សូមចូលរួមជាមួយអំណាចនៃស្ថានបរមសុខ
ថ្វាយបង្គំឫទ្ធានុភាពដ៏អស្ចារ្យរបស់ព្រះអង្គឥតឈប់ឈរ
ដោយប្រកាសថា៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ២ បុណ្យគោរពមរណសាក្សី

PRÆFATIO II DE SANCTIS MARTYRIBUS

ការអស្ចារ្យរបស់ព្រះជាម្ចាស់ នៅក្នុងជ័យជម្នះរបស់មរណសាក្សី

De mirabilibus Dei in Martyrum victoria

៦៩. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងថ្ងៃបុណ្យឱឡារិក និងថ្ងៃបុណ្យគោរពមរណសាក្សី ។ ធម៌នេះ អាចប្រើក្នុងថ្ងៃបុណ្យរំឭកមរណសាក្សីផងដែរ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

យើងខ្ញុំសូមលើកតម្កើងព្រះអង្គ នៅពេលគោរពសន្តបុគ្គលទាំងឡាយ
ដោយពួកគាត់រងទុក្ខលំបាក ពួកគាត់បង្ហាញអំពីឫទ្ធានុភាពដ៏អស្ចារ្យរបស់ព្រះអង្គ
គឺព្រះអង្គមានព្រះហឫទ័យអាណិតអាសូរ
ប្រទានឲ្យពួកគាត់មានជំនឿក្លៀវក្លា ឲ្យពួកគាត់មានចិត្តរឹងប៉ឹងក្នុងការតស៊ូ
ឲ្យពួកគាត់មានជ័យជម្នះក្នុងការប្រកួត តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

អាស្រ័យហេតុនេះ សត្វលោកទាំងអស់នៅលើផែនដី
និងនៅស្ថានបរមសុខ ច្រៀងបទថ្មីគោរពលើកតម្កើងព្រះអង្គ
ហើយយើងខ្ញុំរួមជាមួយអស់ទេវទូតប្រកាសឡើង
ដោយឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធ បុណ្យគោរពសន្តបុគ្គលជាគង្វាល

PRÆFATIO DE SANCTIS PASTORIBUS

សន្តបុគ្គលជាគង្វាល នៅក្នុងព្រះសហគមន៍

De præsentia sanctorum Pastorum in Ecclesia

៧០. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងថ្ងៃបុណ្យឱឡារិក និងថ្ងៃបុណ្យគោរពសន្តបុគ្គលជាគង្វាល ។ ធម៌នេះ អាចប្រើក្នុងថ្ងៃបុណ្យរំឭកសន្តបុគ្គល ជាគង្វាលផងដែរ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។
នៅថ្ងៃបុណ្យគោរពសន្ត ឈ្មោះ...
ព្រះអង្គប្រោសឲ្យព្រះសហគមន៍មានអំណរសប្បាយ
ហើយព្រះអង្គពង្រឹងព្រះសហគមន៍ តាមគំរូនៃការរស់នៅរបស់គាត់
ព្រមទាំងណែនាំ និងថែរក្សាព្រះសហគមន៍
តាមពាក្យប្រៀនប្រដៅ និងតាមពាក្យអង្វររបស់គាត់ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ ច្រៀងបទលើកតម្កើងព្រះអង្គ
ដោយប្រកាសឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធ បុណ្យបព្វជិត បព្វជិតាជាព្រហ្មចារី

PRÆFATIO DE SANCTIS VIRGINIBUS ET RELIGIOSIS

ជីវិតរបស់បព្វជិត បព្វជិតា ជាទីសម្គាល់នៃឧបការគុណរបស់ព្រះជាម្ចាស់

De signo vitæ Deo consecratæ

៧១. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងថ្ងៃបុណ្យឱឡារិក និងថ្ងៃបុណ្យធំសម្រាប់បព្វជិតបព្វជិតា ជា ព្រហ្មចារី ។ ធម៌នេះ អាចប្រើក្នុងថ្ងៃបុណ្យរំឭក បព្វជិត បព្វជិតាផងដែរ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

យើងខ្ញុំសូមលើកតម្កើងឧបការគុណដ៏លើសលប់របស់ព្រះបិតា
ដែលណែនាំឲ្យសន្តបុគ្គលទាំងឡាយថ្វាយខ្លួនទៅព្រះគ្រីស្ត
ដើម្បីបម្រើព្រះរាជ្យនៃស្ថានបរមសុខ ។

ដោយឧបការគុណនេះ
ព្រះអង្គបានប្រោសឲ្យមនុស្សត្រឡប់ទៅរកភាពវិសុទ្ធដើមដំបូងវិញ
ហើយព្រះអង្គប្រោសឲ្យពួកគេមានពិសោធន៍នៅលើផែនដីនេះ
អំពីព្រះអំណោយទាននៅលោកខាងមុខ តាមព្រះបន្ទូលសន្យារបស់ព្រះអង្គ ។
អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ សូមកោតសរសើរព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ១ សម្រាប់ថ្ងៃធម្មតា

PRÆFATIO COMMUNIS I

អ្វីៗទាំងអស់ស្តារជាថ្មីក្នុងអង្គព្រះគ្រីស្ត

De universali restauratione in Christo

៧២. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជាដែលគ្មានធម៌ប្រារព្ធផ្ទាល់ និងអភិបូជាដែលគ្មានធម៌ប្រារព្ធតាមកាលកំណត់ក្នុងក្បួនពិធីបុណ្យផ្សេងៗ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ដោយសារព្រះគ្រីស្តនេះហើយ
ព្រះបិតាសព្វព្រះហឫទ័យស្តារអ្វីៗទាំងអស់ឲ្យបានថ្មីឡើងវិញ
ហើយប្រទានឲ្យយើងខ្ញុំ បានទទួលលក្ខណៈពេញលេញរបស់ព្រះគ្រីស្ត ។

ទោះបីព្រះអង្គមានឋានៈជាព្រះជាម្ចាស់ក៏ដោយ
ក៏ព្រះអង្គពុំបានក្ដោបក្ដាប់ឋានៈដែលស្មើនឹងព្រះជាម្ចាស់ដែរ
ផ្ទុយទៅវិញ ព្រះអង្គបានលះបង់អ្វីៗទាំងអស់ មកយកឋានៈជាទាសករ
ហើយព្រះលោហិតនៃព្រះឈើឆ្កាង
នាំឲ្យសត្វលោកទាំងឡាយបានសេចក្ដីសុខសាន្ត ។
ហេតុដូច្នេះ ព្រះជាម្ចាស់បានលើកតម្កើងព្រះអង្គឡើងយ៉ាងខ្ពង់ខ្ពស់បំផុត
ហើយព្រះអង្គបានទៅជាប្រភពនៃការសង្គ្រោះអស់កល្បជានិច្ច
ដល់អស់អ្នកដែលស្ដាប់បង្គាប់ព្រះអង្គ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
កម្លាំងសក្ដិសិទ្ធិ និងអ្វីៗទាំងអស់ ដែលមានអំណាចនៅស្ថានបរមសុខ
លើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ២ សម្រាប់ថ្ងៃធម្មតា

PRÆFATIO COMMUNIS II

ការសង្គ្រោះតាមរយៈព្រះគ្រីស្ត

De salute per Christum

៧៣. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជាដែលគ្មានធម៌ប្រារព្ធផ្ទាល់ និងអភិបូជាដែលគ្មានធម៌ប្រារព្ធតាមកាលកំណត់ក្នុងក្បួនពិធីបុណ្យផ្សេងៗ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មរស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ព្រះអង្គបានបង្កើតមនុស្សដោយព្រះហឫទ័យសប្បុរស
តែនៅពេលមនុស្សត្រូវផ្តន្ទាទោសតាមយុត្តិធម៌
ព្រះអង្គក៏បានសង្គ្រោះគេដោយព្រះហឫទ័យមេត្តាករុណា
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ក្នុងអង្គព្រះគ្រីស្តនេះហើយ   បានជាទេវទូតទាំងឡាយគោរពកោតសរសើរព្រះអង្គ
ហើយអំណាចនានាភ័យញាប់ញ័រ នៅចំពោះព្រះភ័ក្ត្រព្រះអង្គ ។
ផ្ទៃមេឃ និងឫទ្ធានុភាពនៃស្ថានបរមសុខរួមជាមួយពពួកសេរ៉ាភីម
ក្រាបថ្វាយបង្គំព្រះអង្គ ដោយមានអំណរសប្បាយយ៉ាងក្រៃលែង ។
យើងខ្ញុំសូមបន្ទាបខ្លួនចូលរួមកោតសរសើរព្រះអង្គ
ដោយប្រកាសថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៣ សម្រាប់ថ្ងៃធម្មតា

PRÆFATIO COMMUNIS III

លើកតម្កើងព្រះជាម្ចាស់ដែលបានបង្កើត និងស្ដារមនុស្សជាតិឡើងវិញ

Laudes Deo pro creatione et reformatione horminis

៧៤. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជាដែលគ្មានធម៌ប្រារព្ធផ្ទាល់ និងអភិបូជាដែលគ្មានធម៌ប្រារព្ធតាមកាលកំណត់ក្នុងក្បួនពិធីបុណ្យផ្សេងៗ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ព្រះបិតាបានបង្កើតមនុស្សជាតិ ហើយព្រះអង្គក៏ស្ដារគេឲ្យមានជីវិតថ្មីឡើងវិញ
ដោយព្រះហឫទ័យសប្បុរសដ៏លើសលប់
តាមរយៈព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ។

ដូច្នេះសត្វលោកតែងតែបម្រើព្រះអង្គ
អស់អ្នកដែលរួចពីបាបតែងតែកោតសរសើរព្រះអង្គ
ហើយសន្តបុគ្គលទាំងឡាយ ក៏តែងតែរួបរួមគ្នាអរព្រះគុណព្រះអង្គដែរ
ការទាំងនេះ គឺពិតជាត្រឹមត្រូវមែន ។
អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយទេវទូត
លើកតម្កើងព្រះអង្គទាំងអំណរសប្បាយ
ដោយប្រកាសថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៤ សម្រាប់ថ្ងៃធម្មតា

PRÆFATIO COMMUNIS IV

ការលើកតម្កើង ជាព្រះអំណោយទានរបស់ព្រះជាម្ចាស់

De laude, dono Dei

៧៥. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជាដែលគ្មានធម៌ប្រារព្ធផ្ទាល់ និងអភិបូជាដែលគ្មានធម៌ប្រារព្ធតាមកាលកំណត់ក្នុងក្បួនពិធីបុណ្យផ្សេងៗ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ទោះបីព្រះអង្គមិនត្រូវការឲ្យយើងខ្ញុំលើកតម្កើងទ្រង់ក៏ដោយ
ក៏ព្រះអង្គប្រទានព្រះអំណោយទានសម្រាប់យើងខ្ញុំអរព្រះគុណដែរ ។
ពាក្យលើកតម្កើងរបស់យើងខ្ញុំមិនបន្ថែមអ្វីសោះ
ចំពោះភាពដ៏ឧត្ដុងឧត្ដមរបស់ព្រះអង្គ
ប៉ុន្តែផ្ដល់ជាប្រយោជន៍ឲ្យយើងខ្ញុំទទួលការសង្គ្រោះ
តាមរយៈព្រះយេស៊ូគ្រីស្ដជាព្រះអម្ចាស់យើងខ្ញុំ ។

អាស្រ័យហេតុនេះហើយ
បានជាយើងខ្ញុំសូមចូលរួមជាមួយទេវទូតដ៏ច្រើនកុះករ
កោតសរសើរព្រះអង្គ ទាំងប្រកាសដោយអំណរសប្បាយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៥ សម្រាប់ថ្ងៃធម្មតា

PRÆFATIO COMMUNIS V

ការប្រកាសពីគម្រោងការដ៏អស្ចារ្យក្នុងអង្គព្រះគ្រីស្ត

Proclamatio mysterii Christi

៧៦. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជាដែលគ្មានធម៌ប្រារព្ធផ្ទាល់ និងអភិបូជាដែលគ្មានធម៌ប្រារព្ធតាមកាលកំណត់ក្នុងក្បួនពិធីបុណ្យផ្សេងៗ ។

បៈ សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

បៈ សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

បៈ សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ពេលយើងខ្ញុំនឹករឭកដល់ព្រះគ្រីស្តសោយទិវង្គត
យើងខ្ញុំពោរពេញដោយសេចក្តីស្រឡាញ់

ពេលយើងខ្ញុំប្រកាសថា ព្រះគ្រីស្តមានព្រះជន្មរស់ឡើងវិញ
យើងខ្ញុំពោរពេញដោយជំនឿដ៏រឹងមាំ
ពេលយើងខ្ញុំទន្ទឹងរង់ចាំព្រះអង្គយាងមកវិញប្រកបដោយសិរីរុងរឿង
យើងខ្ញុំពោរពេញដោយសេចក្តីសង្ឃឹមដ៏មោះមុត ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ កោតសរសើរព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៦ សម្រាប់ថ្ងៃធម្មតា

PRÆFATIO COMMUNIS VI

គម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះក្នុងអង្គព្រះគ្រីស្ត

De mysterio salutis in Christo

៧៧. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជាដែលគ្មានធម៌ប្រារព្ធផ្ទាល់ និងអភិបូជាដែលគ្មានធម៌ប្រារព្ធតាមកាលកំណត់ក្នុងក្បួនពិធីបុណ្យផ្សេងៗ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធបំផុត !
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
ដោយរួមជាមួយព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ។

ព្រះបិតាបានបង្កើតសត្វលោក និងអ្វីៗសព្វសារពើទាំងអស់
ដោយព្រះយេស៊ូគ្រីស្តជាព្រះបន្ទូលរបស់ព្រះអង្គ ។
ព្រះបិតាបាត់ឲ្យព្រះយេស៊ូគ្រីស្តយាងមកសង្គ្រោះ និងរំដោះយើងខ្ញុំ
គឺព្រះអង្គបានទទួលរូបកាយជាមនុស្ស ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ
ហើយទ្រង់ប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី ។

ដោយបំពេញបំណងរបស់ព្រះបិតា
និងប្រមូលប្រជារាស្ត្រមួយដ៏វិសុទ្ធថ្វាយព្រះអង្គ
ព្រះបុត្រាសព្វព្រះហឫទ័យត្រដាងព្រះហស្តរងទុក្ខលំបាក
ដើម្បីបំផ្លាញចំណងនៃសេចក្ដីស្លាប់ និងសម្ដែងអំពីជីវិតរស់ឡើងវិញ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ សូមប្រកាសលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ១ សម្រាប់មរណបុគ្គល

PRÆFATIO I DE DEFUNCTIS

សេចក្ដីសង្ឃឹមលើជីវិតរស់ឡើងវិញក្នុងអង្គព្រះគ្រីស្ត

De spe resurrectionis in Christo

៧៨. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជានឹករព្លកដល់មរណបុគ្គល ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

យើងខ្ញុំមានសេចក្ដីសង្ឃឹមថា
នឹងរស់ឡើងវិញប្រកបដោយសុភមង្គលក្នុងអង្គព្រះគ្រីស្ត
ទោះបី យើងខ្ញុំមានទុក្ខព្រួយអំពីសេចក្ដីស្លាប់ក៏ដោយ
ក៏ព្រះបន្ទូលសន្យាលើកទឹកចិត្តយើងខ្ញុំថា នឹងមានជីវិតអស់កល្បជានិច្ច ។

បពិត្រព្រះអម្ចាស់ !
យើងខ្ញុំជឿថា ជីវិតតែងតែប្រែប្រួល គឺមិនត្រូវដកហូតឡើយ ។
ទោះបី រូបកាយជាទីជម្រកនៅលើផែនដីនេះ
រលួយទៅជាធូលីក៏ដោយ ក៏យើងខ្ញុំនឹងមានទីជម្រកអស់កល្បជានិច្ច
ដែលព្រះអង្គបានរៀបចំជាស្រេចនៅស្ថានបរមសុខ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
កម្លាំងស័ក្ដិសិទ្ធិ និងអ្វីៗទាំងអស់ ដែលមានអំណាចនៅស្ថានបរមសុខ
លើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ២ សម្រាប់មរណបុគ្គល

PRÆFATIO II DE DEFUNCTIS

ព្រះគ្រីស្តសោយទិវង្គតដើម្បីឲ្យយើងខ្ញុំមានជីវិតរស់នៅ

Christus mortuus est pro vita nostra

៧៩. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជានឹករឭកដល់មរណបុគ្គល ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

មានតែព្រះបុត្រាមួយព្រះអង្គ ដែលសព្វព្រះហឫទ័យសោយទិវង្គត
ដើម្បីឲ្យយើងខ្ញុំអាចរួចផុតពីសេចក្តីស្លាប់
ហើយព្រះអង្គក៏សព្វព្រះហឫទ័យសោយទិវង្គត
ដើម្បីឲ្យយើងខ្ញុំរស់នៅជាមួយព្រះអង្គអស់កល្បជានិច្ច ។

អាស្រ័យហេតុនេះហើយ
បានជាយើងខ្ញុំសូមចូលរួមជាមួយទេវទូតដ៏ច្រើនកុះករ
កោតសរសើរព្រះអង្គ ទាំងប្រកាសដោយអំណរសប្បាយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៣ សម្រាប់មរណបុគ្គល

PRÆFATIO III DE DEFUNCTIS

ព្រះគ្រីស្តជាព្រះសង្គ្រោះ និងជាជីវិត

Christus, salus et vita

៨០. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជានឹករឭកដល់មរណបុគ្គល ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ព្រះអង្គជាព្រះសង្គ្រោះនៃពិភពលោក
ទ្រង់ជាជីវិតសម្រាប់មនុស្សជាតិ និងប្រោសអ្នកស្លាប់ឲ្យរស់ឡើងវិញ ។

ដោយសារព្រះគ្រីស្តនេះហើយ
បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូតដ៏ច្រើនកុះករ
លើកតម្កើងអានុភាពដ៏អស្ចារ្យរបស់ព្រះអង្គ
និងសប្បាយរីករាយចំពោះព្រះភ័ក្ត្រព្រះអង្គជានិច្ច ។
យើងខ្ញុំសូមទូលអង្វរ និងច្រៀងកោតសរសើរព្រះអង្គ
ក្នុងអំណរសប្បាយយ៉ាងក្រៃលែង
ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៤ សម្រាប់មរណបុគ្គល

PRÆFATIO IV DE DEFUNCTIS

ពីជីវិតលោកីយឆ្ពោះទៅកាន់សិរីរុងរឿងនៃស្ថានបរមសុខ

De vita terrena ad gloriam cælestem

៨១. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជានឹករឭកដល់មរណបុគ្គល ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ព្រះអង្គបានត្រាស់ហៅយើងខ្ញុំឲ្យកើតមក
និងគ្រប់គ្រងយើងខ្ញុំតាមព្រះហឫទ័យរបស់ព្រះអង្គ ។
ប៉ុន្តែព្រះអង្គបញ្ជាឲ្យយើងខ្ញុំត្រឡប់ទៅជាធូលីដីវិញ
ព្រោះតែអំពើបាបរបស់យើងខ្ញុំ ។
ដើម្បីសង្គ្រោះយើងខ្ញុំ ព្រះបុត្រាបានសោយទិវង្គត
ហើយដល់ពេលកំណត់ ព្រះអង្គនឹងលើកយើងខ្ញុំ
ឲ្យចូលក្នុងសិរីរុងរឿងរបស់ព្រះអង្គ ដែលមានព្រះជន្មរស់ឡើងវិញ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត និងសន្តបុគ្គលទាំងឡាយ ច្រៀងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ដោយប្រកាសឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌ប្រារព្ធទី ៥ សម្រាប់មរណបុគ្គល

PRÆFATIO V DE DEFUNCTIS

យើងខ្ញុំរស់ឡើងវិញដោយសារជ័យជម្នះរបស់ព្រះគ្រីស្ត

De resurrectione nostra per victoriam Christi

៨២. ធម៌ប្រារព្ធនេះ ប្រើនៅក្នុងអភិបូជានឹករឭកដល់មរណបុគ្គល ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ពេលជីវិតយើងខ្ញុំត្រូវវិនាស
ព្រះអង្គបានសង្គ្រោះយើងខ្ញុំដោយប្រណីសន្ដោស ។
ពេលយើងខ្ញុំជាប់ឃុំក្នុងសេចក្ដីស្លាប់ដោយសារបាប
នោះជ័យជម្នះរបស់ព្រះគ្រីស្តបានប្រោសលោះយើងខ្ញុំពីសេចក្ដីស្លាប់
ហើយទទួលជីវិតរួមជាមួយព្រះអង្គ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំនៅលើផែនដី
សូមចូលរួមជាមួយអំណាចនៃស្ថានបរមសុខ
ថ្វាយបង្គំឫទ្ធានុភាពដ៏អស្ចារ្យរបស់ព្រះអង្គ
ដោយប្រកាសឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

# ធម៌អរព្រះគុណដ៏វិសុទ្ធ

## PRECES EUCHARISTICÆ

# ធម៌អរព្រះគុណដ៏វិសុទ្ធ ទី ១

PREX EUCHARISTICA I

(តាមសាសនក្រឹត្យក្រុងរ៉ូម)

SEU CANON ROMANUS

៨៣. ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

ពេលនេះ លោកបូជាចារ្យសូត្រធម៌ប្រារព្ធស្របតាមពាក្យពន្យល់ក្នុងពិធី ។ ក្រោយសូត្រធម៌ប្រារព្ធចប់ លោកច្រៀង ឬអានរួមជាមួយគ្រីស្តបរិស័ទ ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

៨៤. លោកបូជាចារ្យលាតដៃ ដោយពោលថា ៖
ឱ ព្រះបិតាប្រកបដោយព្រះហឫទ័យសប្បុរសយ៉ាងក្រៃលែងអើយ !
យើងខ្ញុំសូមអង្វរព្រះអង្គតាមរយៈព្រះយេស៊ូគ្រីស្ត
ជាព្រះបុត្រាព្រះអង្គ និងជាអម្ចាស់យើងខ្ញុំ ។

លោកបូជាចារ្យប្រណម្យដៃ ។

សូមព្រះអង្គមេត្តាទទួល

លោកបូជាចារ្យធ្វើសញ្ញាឈើឆ្កាងលើនំ និងស្រាតង្វាយ ទាំងពោលថា ៖

ហើយប្រទានព្រះពរ ≅ លើអំណោយ តង្វាយ និងសក្ការបូជាដ៏វិសុទ្ធនេះ ។
យើងខ្ញុំសូមថ្វាយតង្វាយទាំងនេះ

លោកបូជាចារ្យលាតដៃ ហើយពោលបន្តថា ៖

ជាដំបូង ដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍កាតូលិក ។
សូមព្រះអង្គមេត្តាប្រទានសេចក្ដីសុខសាន្ត ដល់ព្រះសហគមន៍នៅលើផែនដីទាំងមូល ។
សូមព្រះអង្គថែរក្សាការពារ ណែនាំ
និងបង្រួបបង្រួមព្រះសហគមន៍ជាធ្លុងតែមួយ
រួមជាមួយអ្នកបម្រើរបស់ព្រះអង្គ សម្ដេចប៉ាបយើងខ្ញុំ (នាម...)
និងលោក (ឈ្មោះ...) ជាអភិបាលព្រះសហគមន៍យើងខ្ញុំ [២០៤]
ព្រមទាំងអស់លោកអភិបាល ដែលថែរក្សាសេចក្ដីពិត
និងជំនឿកាតូលិក ដែលបន្តមកពីក្រុមគ្រីស្ដទូត ។

៨៥. ធម៌អង្វរសម្រាប់មនុស្សទាំងឡាយ ។

សូមព្រះអម្ចាស់ប្រោសប្រណី ដល់អស់អ្នកបម្រើរបស់ព្រះអង្គ (ឈ្មោះ...)

លោកបូជាចារ្យប្រណម្យដៃ ហើយស្ញៀមស្ងាត់បន្តិចដោយនឹកដល់អ្នកនោះ ។ បន្ទាប់មក លោកលាតដៃ ហើយពោលបន្តថា ៖

និងអស់អ្នកដែលរួបរួមគ្នានៅទីនេះ មានតែព្រះអង្គទេដែលជ្រាបថា
បងប្អូនទាំងអស់នេះ មានជំនឿ និងចិត្តភក្ដីយ៉ាងណាចំពោះព្រះអង្គ ។
យើងខ្ញុំសូមថ្វាយអភិបូជានេះ សម្រាប់បងប្អូនទាំងនោះ
ហើយបងប្អូនក៏ថ្វាយអភិបូជាសម្រាប់ខ្លួនគេ និងញាតិមិត្តរបស់គេដែរ ។

[២០៤] ទីនេះ លោកអាចបន្ថែមឈ្មោះលោកអភិបាលឧបត្ថម្ភក ឬលោកអភិបាលជំនួយការផ្សេងៗ តាមពាក្យណែនាំនៃក្បួនពិធីបុណ្យលេខ ១៤៩ ។

បងប្អូនសង្ឃឹមថា ព្រះអង្គរំដោះពួកគេឲ្យរួចពីបាប
ឲ្យមានសុខភាពល្អ និងឲ្យបាកផុតពីអន្តរាយគ្រប់បែបយ៉ាង
ហេតុនេះ គេអាចបំពេញតាមពាក្យសន្យាចំពោះព្រះអង្គ
ជាព្រះជាម្ចាស់ដ៏ពិតប្រាកដ និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

៨៦. ពាក្យអង្វរបន្ត ៖
ដោយរួមជាមួយព្រះសហគមន៍ទាំងមូល យើងខ្ញុំទាំងអស់គ្នាសូមគោរព
ជាបឋម ព្រះនាងព្រហ្មចារិនីម៉ារី ពោរពេញដោយសិរីរុងរឿង
ជាព្រះមាតាព្រះជាម្ចាស់ និងព្រះអម្ចាស់យេស៊ូគ្រីស្តនៃយើងខ្ញុំ
† បន្ទាប់មក សន្តយ៉ូសែប ជាស្វាមីរបស់ព្រះនាងព្រហ្មចារិនី
គ្រីស្តទូត និងមរណសាក្សី
សន្តសិលា និងសន្តប៉ូល, សន្តអន់ដ្រេ
(សន្តយ៉ាកុប, សន្តយ៉ូហាន,
សន្តថូម៉ាស, សន្តភីលីព,
សន្តបារថូឡូមេ, សន្តម៉ាថាយ,
សន្តស៊ីម៉ូន និងសន្តយូដា,
សន្តលីណូ, សន្តក្លែ, សន្តក្លេម៉ង់
សន្តស៊ីស, សន្តក័រណើ, សន្តស៊ីព្រីយ៉ាំង,
សន្តឡូរ៉ង់, សន្តគ្រីសូកូន,
សន្តយ៉ូហាន និងសន្តប៉ូល,
សន្តកូស្មា និងសន្តដាមីយ៉ាំង) និងសន្តបុគ្គលទាំងឡាយ ។
ដោយពាក្យអង្វររបស់សន្តបុគ្គលទាំងអស់នោះ
សូមព្រះអង្គមេត្តាជួយ និងការពារយើងខ្ញុំគ្រប់ពេលវេលា និងគ្រប់ទិសទី
(ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)[២០៥]

[២០៥] ពាក្យនៅក្នុងរង្វង់ក្រចកអាចរំលងបាន ។

សូមជ្រើសរើសអត្ថបទខាងក្រោមនេះ ឲ្យត្រូវតាមរដូវបុណ្យ ឬតាមកាលៈទេសៈ ។

**ថ្ងៃអាទិត្យធម្មតាត្រូវអាន** [២០៦] **៖**

នៅថ្ងៃទីមួយនៃសប្ដាហ៍
យើងទាំងអស់គ្នារួមជាមួយព្រះសហគមន៍ទាំងមូល
លើកតម្កើងព្រះគ្រីស្ដដែលមានព្រះជន្មរស់ឡើងវិញ ។
យើងខ្ញុំទាំងអស់គ្នាសូមគោរព
ជាបឋម ព្រះនាងព្រហ្មចារិនីម៉ារី ពោរពេញដោយសិរីរុងរឿង
ជាព្រះមាតាព្រះយេស៊ូគ្រីស្ដជាព្រះជាម្ចាស់ និងជាព្រះអម្ចាស់យើងខ្ញុំ
បន្ទាប់មក សន្ដយ៉ូសែប ជាស្វាមីព្រះនាងព្រហ្មចារិនី
គ្រីស្ដទូត និងមរណសាក្សី
សន្ដសិលា និងសន្ដប៉ូល, សន្ដអន់ដ្រេ,
(សន្ដយ៉ាកុប, សន្ដយ៉ូហាន,
សន្ដថូម៉ាស, សន្ដភីលីព,
សន្ដបារថូឡូមេ, សន្ដម៉ាថាយ,
សន្ដស៊ីម៉ូន និងសន្ដយូដា,
សន្ដលីណូ, សន្ដក្លេ, សន្ដក្លេម៉ង់, សន្ដស៊ីស,
សន្ដក័រណី, សន្ដស៊ីព្រីយុាំង,
សន្ដឡូរ៉ង់, សន្ដគ្រីសូកូន,
សន្ដយ៉ូហាន និងសន្ដប៉ូល,
សន្ដកូស្មា និងសន្ដដាមីយុាំង) និងសន្ដបុគ្គលទាំងឡាយ ។
ដោយពាក្យអង្វររបស់សន្ដបុគ្គលទាំងអស់នោះ
សូមព្រះអង្គមេត្តាជួយការពារយើងខ្ញុំគ្រប់ពេលវេលា និងគ្រប់ទិសទី
(ដោយរួមជាមួយព្រះគ្រីស្ដ ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)[២០៧]

---

[២០៦] ធម៌នេះគ្មាននៅក្នុងក្បួនឡាតាំង ។

[២០៧] ពាក្យនៅក្នុងរង្វង់ក្រចកអាចរំលងបាន ។

**ពីថ្ងៃបុណ្យព្រះយេស៊ូប្រសូត រហូតដល់ថ្ងៃទី១ ខែមករា ត្រូវអាន ៖**

យើងខ្ញុំទាំងអស់គ្នារួមជាមួយព្រះសហគមន៍ទាំងមូល
អបអរសាទរថ្ងៃដ៏វិសុទ្ធបំផុត (ឬ យប់ដ៏វិសុទ្ធបំផុត)
ដែលព្រះនាងព្រហ្មចារិនីម៉ារីដ៏និមល បានប្រសូតព្រះសង្គ្រោះមនុស្សលោក ។
យើងខ្ញុំទាំងអស់គ្នាសូមគោរព
ជាបឋម ព្រះនាងព្រហ្មចារិនីម៉ារី ពោរពេញដោយសិរីរុងរឿង
ជាព្រះមាតាព្រះយេស៊ូគ្រីស្ដជាព្រះជាម្ចាស់ និងជាព្រះអម្ចាស់យើងខ្ញុំ †
បន្ទាប់មក សន្ដយ៉ូសែប ជាស្វាមីព្រះនាងព្រហ្មចារិនី
គ្រីស្ដទូត និងមរណសាក្សី
សន្ដសិលា និងសន្ដប៉ូល, សន្ដអន់ដ្រេ
(សន្ដយ៉ាកុប, សន្ដយ៉ូហាន
សន្ដថូម៉ាស, សន្ដភីលីព
សន្ដបារថូឡូមេ, សន្ដម៉ាថាយ
សន្ដស៊ីម៉ូន និងសន្ដយូដា
សន្ដលីណូ, សន្ដក្លេ, សន្ដក្លេម៉ង់
សន្ដស៊ីស, សន្ដក័រណេ, សន្ដស៊ីព្រីយ៉ាំង
សន្ដឡូរ៉ង់, សន្ដគ្រីសូកូន
សន្ដយ៉ូហាន និងសន្ដប៉ូល
សន្ដកូស្មា និងសន្ដដាមីយ៉ាំង)
និងសន្ដបុគ្គលទាំងឡាយ ។
ដោយពាក្យអង្វររបស់សន្ដបុគ្គលទាំងអស់នោះ
សូមព្រះអង្គមេត្ដាជួយការពារយើងខ្ញុំគ្រប់ពេលវេលា និងគ្រប់ទិសទី
(ដោយរួមជាមួយព្រះគ្រីស្ដ ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)

ថ្ងៃបុណ្យព្រះគ្រីស្តសម្តែងព្រះអង្គ ត្រូវអាន ៖

យើងខ្ញុំទាំងអស់គ្នា រួមជាមួយព្រះសហគមន៍ទាំងមូល
អបអរសាទរថ្ងៃដ៏វិសុទ្ធបំផុតនេះ ជាថ្ងៃដែលព្រះបុត្រាតែមួយ
រួមជាមួយព្រះបិតាក្នុងសិរីរុងរឿងអស់កល្បជានិច្ច
ទ្រង់បានសម្តែងព្រះអង្គក្នុងឋានៈជាមនុស្ស
មានសាច់ឈាមដ៏ពិតប្រាកដដូចយើងខ្ញុំបេះបិទ ។
យើងខ្ញុំទាំងអស់គ្នាសូមគោរព
ជាបឋម ព្រះនាងព្រហ្មចារិនីម៉ារី ពោរពេញដោយសិរីរុងរឿង
ជាព្រះមាតាព្រះយេស៊ូគ្រីស្តជាព្រះជាម្ចាស់ និងជាព្រះអម្ចាស់យើងខ្ញុំ
បន្ទាប់មក សន្តយ៉ូសែប ជាស្វាមីព្រះនាងព្រហ្មចារិនី
គ្រីស្តទូត និងមរណសាក្សី
សន្តសិលា និងសន្តប៉ូល, សន្តអន់ដ្រេ,
(សន្តយ៉ាកុប, សន្តយ៉ូហាន,
សន្តថូម៉ាស, សន្តភីលីព,
សន្តបារថូឡូមេ, សន្តម៉ាថាយ,
សន្តស៊ីម៉ូន និងសន្តយូដា,
សន្តលីណូ, សន្តក្លេ, សន្តក្លេម៉ង់,
សន្តស៊ីស, សន្តក័រណី, សន្តស៊ីព្រីយ៉ាំង,
សន្តឡូរ៉ង់, សន្តគ្រីសូកូន,
សន្តយ៉ូហាន និងសន្តប៉ូល,
សន្តកូស្មា និងសន្តដាមីយ៉ាំង) និងសន្តបុគ្គលទាំងឡាយ ។
ដោយពាក្យអង្វររបស់សន្តបុគ្គលទាំងអស់នោះ
សូមព្រះអង្គមេត្តាជួយការពារយើងខ្ញុំគ្រប់ពេលវេលា និងគ្រប់ទិសទី
(ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)

### ថ្ងៃបុណ្យព្រះយេស៊ូជប់លៀងសាវ័ក[២០៨] ត្រូវអាន ៖

យើងខ្ញុំទាំងអស់គ្នា រួមជាមួយព្រះសហគមន៍ទាំងមូល
អបអរសាទរថ្ងៃដ៏វិសុទ្ធបំផុត
ជាថ្ងៃដែលព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ
សព្វព្រះហឫទ័យឲ្យគេបញ្ជូនទៅសោយទុក្ខលំបាក ។
យើងខ្ញុំទាំងអស់គ្នាសូមគោរព
ជាបឋម ព្រះនាងព្រហ្មចារិនីម៉ារី ពោរពេញដោយសិរីរុងរឿង
ជាព្រះមាតាព្រះយេស៊ូគ្រីស្តជាព្រះជាម្ចាស់ និងជាព្រះអម្ចាស់យើងខ្ញុំ
បន្ទាប់មក សន្តយ៉ូសែប ជាស្វាមីព្រះនាងព្រហ្មចារិនី
គ្រីស្តទូត និងមរណសាក្សី
សន្តសិលា និងសន្តប៉ូល, សន្តអន់ដ្រេ,
(សន្តយ៉ាកុប, សន្តយ៉ូហាន,
សន្តថូម៉ាស, សន្តភីលីព,
សន្តបារថូឡូមេ, សន្តម៉ាថាយ,
សន្តស៊ីម៉ូន និងសន្តយូដា,
សន្តលីណូ, សន្តក្លេ, សន្តក្លេម៉ង់,
សន្តស៊ីល, សន្តក័រណី, សន្តស៊ីព្រីយ៉ាំង,
សន្តឡូរ៉ង់, សន្តគ្រីសូកូន,
សន្តយ៉ូហាន និងសន្តប៉ូល,
សន្តកូស្មា និងសន្តដាមីយ៉ាំង) និងសន្តបុគ្គលទាំងឡាយ ។
ដោយពាក្យអង្វររបស់សន្តបុគ្គលទាំងអស់នោះ
សូមព្រះអង្គមេត្តាជួយការពារយើងខ្ញុំគ្រប់ពេលវេលា និងគ្រប់ទិសទី
(ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)

[២០៨] ធម៌នេះមាននៅក្នុងក្បួនឡាតាំង (ត្រៃទិវា លេខ២០) ។

**ពីរាត្រីបុណ្យចម្លង រហូតដល់ថ្ងៃអាទិត្យទី២ នៃបុណ្យចម្លង ត្រូវអាន ៖**

យើងខ្ញុំទាំងអស់គ្នា រួមជាមួយព្រះសហគមន៍ទាំងមូល
អបអរសាទរថ្ងៃដ៏វិសុទ្ធបំផុត (ឬ យប់ដ៏វិសុទ្ធបំផុត)
ដែលព្រះអម្ចាស់យើងខ្ញុំ គឺព្រះយេស៊ូគ្រីស្តមានព្រះជន្មរស់ឡើងវិញ
ក្នុងរូបកាយជាមនុស្សពិតប្រាកដ ។
យើងខ្ញុំទាំងអស់គ្នាសូមគោរព
ជាបឋម ព្រះនាងព្រហ្មចារិនីម៉ារី ពោរពេញដោយសិរីរុងរឿង
ជាព្រះមាតាព្រះយេស៊ូគ្រីស្តជាព្រះជាម្ចាស់ និងជាព្រះអម្ចាស់យើងខ្ញុំ
បន្ទាប់មក សន្តយ៉ូសែប ជាស្វាមីព្រះនាងព្រហ្មចារិនី
គ្រីស្តទូត និងមរណសាក្សី
សន្តសិលា និងសន្តប៉ូល, សន្តអន់ដ្រេ,
(សន្តយ៉ាកុប, សន្តយ៉ូហាន,
សន្តថូម៉ាស, សន្តភីលីព,
សន្តបារថូឡូមេ, សន្តម៉ាថាយ,
សន្តស៊ីម៉ូន និងសន្តយូដា,
សន្តលីណូ, សន្តក្លេ, សន្តក្លេម៉ង់,
សន្តស៊ីល, សន្តក័រណើ, សន្តស៊ីព្រីយ៉ាំង,
សន្តឡូរ៉ង់, សន្តគ្រីសូកូន,
សន្តយ៉ូហាន និងសន្តប៉ូល,
សន្តកូស្មា និងសន្តដាមីយ៉ាំង)
និងសន្តបុគ្គលទាំងឡាយ ។
ដោយពាក្យអង្វររបស់សន្តបុគ្គលទាំងអស់នោះ
សូមព្រះអង្គមេត្តាជួយការពារយើងខ្ញុំគ្រប់ពេលវេលា និងគ្រប់ទិសទី
(ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)

## ថ្ងៃបុណ្យព្រះយេស៊ូយាងឡើងស្ថានបរមសុខ ត្រូវអាន ៖

យើងខ្ញុំទាំងអស់គ្នារួមជាមួយព្រះសហគមន៍ទាំងមូល
អបអរសាទរថ្ងៃដ៏វិសុទ្ធបំផុត
ជាថ្ងៃដែលព្រះបុត្រាតែមួយគត់របស់ព្រះអង្គ
គឺព្រះជាអម្ចាស់យើងខ្ញុំ ដែលភ្ជាប់នឹងភាពទន់ខ្សោយរបស់មនុស្សលោក
បានគង់នៅខាងស្ដាំព្រះបិតា ។
យើងខ្ញុំទាំងអស់គ្នាសូមគោរព
ជាបឋម ព្រះនាងព្រហ្មចារិនីម៉ារី ពោរពេញដោយសិរីរុងរឿង
ជាព្រះមាតាព្រះយេស៊ូគ្រីស្តជាព្រះជាម្ចាស់ និងជាព្រះអម្ចាស់យើងខ្ញុំ
បន្ទាប់មក សន្តយ៉ូសែប ជាស្វាមីព្រះនាងព្រហ្មចារិនី
គ្រីស្តទូត និងមរណសាក្សី
សន្តសិលា និងសន្តប៉ូល, សន្តអន់ដ្រេ,
(សន្តយ៉ាកុប, សន្តយ៉ូហាន,
សន្តថូម៉ាស, សន្តភីលីព,
សន្តបារថូឡូមេ, សន្តម៉ាថាយ,
សន្តស៊ីម៉ូន និងសន្តយូដា,
សន្តលីណូ, សន្តក្លេ, សន្តក្លេម៉ង,
សន្តស៊ីល, សន្តក័រណី, សន្តស៊ីព្រីយុាំង,
សន្តឡូរ៉ង, សន្តគ្រីសូកូន,
សន្តយ៉ូហាន និងសន្តប៉ូល,
សន្តកូស្មា និងសន្តដាមីយុាំង) និងសន្តបុគ្គលទាំងឡាយ ។
ដោយពាក្យអង្វររបស់សន្តបុគ្គលទាំងអស់នោះ
សូមព្រះអង្គមេត្តាជួយការពារយើងខ្ញុំគ្រប់ពេលវេលា និងគ្រប់ទិសទី
(ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)

## បុណ្យថ្ងៃទីហាសិប ត្រូវអាន ៖

យើងខ្ញុំទាំងអស់គ្នារួមជាមួយព្រះសហគមន៍ទាំងមូល
អបអរសាទរថ្ងៃដ៏វិសុទ្ធបំផុត
ជាថ្ងៃដែលព្រះវិញ្ញាណដ៏វិសុទ្ធយាងមកដូចជាអណ្ដាតភ្លើង
បែកចេញពីគ្នា ហើយគង់លើក្រុមគ្រីស្តទូត ។
យើងខ្ញុំទាំងអស់គ្នាសូមគោរព
ជាបឋម ព្រះនាងព្រហ្មចារិនីម៉ារី ពោរពេញដោយសិរីរុងរឿង
ជាព្រះមាតាព្រះយេស៊ូគ្រីស្តជាព្រះជាម្ចាស់ និងជាព្រះអម្ចាស់យើងខ្ញុំ
បន្ទាប់មក សន្តយ៉ូសែប ជាស្វាមីព្រះនាងព្រហ្មចារិនី
គ្រីស្តទូត និងមរណសាក្សី
សន្តសិលា និងសន្តប៉ូល, សន្តអន់ដ្រេ,
(សន្តយ៉ាកុប, សន្តយ៉ូហាន,
សន្តថូម៉ាស, សន្តភីលីព,
សន្តបារថូឡូមេ, សន្តម៉ាថាយ,
សន្តស៊ីម៉ូន និងសន្តយូដា,
សន្តលីណូ, សន្តក្លេ, សន្តក្លេម៉ង់,
សន្តស៊ីល, សន្តក័រណេ, សន្តស៊ីព្រីយ៉ាំង,
សន្តឡូរ៉ង់, សន្តគ្រីសូកូន,
សន្តយ៉ូហាន និងសន្តប៉ូល,
សន្តកូស្មា និងសន្តដាមីយ៉ាំង)
និងសន្តបុគ្គលទាំងឡាយ ។
ដោយពាក្យអង្វររបស់សន្តបុគ្គលទាំងអស់នោះ
សូមព្រះអង្គមេត្តាជួយការពារយើងខ្ញុំគ្រប់ពេលវេលា និងគ្រប់ទិសទី
(ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)

៨៧. លោកបូជាចារ្យលាតដៃ ដោយអានបន្តថា ៖

បពិត្រព្រះអម្ចាស់ !

សូមទទួលតង្វាយនេះ ពីយើងខ្ញុំជាអ្នកបម្រើ

និងពីគ្រួសារទាំងមូលរបស់ព្រះអង្គ ដោយអនុគ្រោះ ។

សូមប្រទានសេចក្តីសុខសាន្តរបស់ព្រះអង្គដល់យើងខ្ញុំជារៀងរាល់ថ្ងៃ ។

សូមរំដោះយើងខ្ញុំ ឲ្យរួចពីទោសអស់កល្បជានិច្ច

ហើយសូមទទួលយើងខ្ញុំចូលក្នុងចំណោមអស់អ្នក

ដែលព្រះអង្គបានជ្រើសរើស ។

លោកបូជាចារ្យលើកដៃប្រណម្យ

(ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)

## នៅថ្ងៃព្រះហស្បតិ៍ពិសិដ្ឋ[២០៩] ត្រូវអាន ៖

បពិត្រព្រះអម្ចាស់ !

សូមទទួលតង្វាយនេះ ពីគ្រួសារទាំងមូលរបស់ព្រះអង្គ

ដែលកំពុងនឹករឭកថ្ងៃព្រះយេស៊ូគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ

សព្វព្រះហឫទ័យប្រទានអគ្គសញ្ញាព្រះកាយ និងព្រះលោហិត

ដល់សាវ័ករបស់ព្រះអង្គ ទុកសម្រាប់ប្រព្រឹត្តតាម ។

សូមប្រទានសេចក្តីសុខសាន្តរបស់ព្រះអង្គដល់យើងខ្ញុំជារៀងរាល់ថ្ងៃ ។

សូមរំដោះយើងខ្ញុំ ឲ្យរួចពីទោសអស់កល្បជានិច្ច

ហើយសូមទទួលយើងខ្ញុំចូលក្នុងចំណោមអស់អ្នក

ដែលព្រះអង្គបានជ្រើសរើស ។

លោកបូជាចារ្យលើកដៃប្រណម្យ

(ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)

[២០៩] ធម៌នេះមាននៅក្នុងក្បួនឡាតាំង (ត្រៃទិវា លេខ២១) ។

**ពីរាត្រីបុណ្យចម្លង រហូតដល់ថ្ងៃអាទិត្យទី២ នៃបុណ្យចម្លង ត្រូវអាន ៖**

បពិត្រព្រះអម្ចាស់ !

សូមទទួលតង្វាយនេះ ពីយើងខ្ញុំជាអ្នកបម្រើ

និងពីគ្រួសារទាំងមូលរបស់ព្រះអង្គ ដោយអនុគ្រោះ ។

យើងខ្ញុំសូមថ្វាយសក្ការបូជានេះ

សម្រាប់អស់អ្នកដែលព្រះអង្គសព្វព្រះហឫទ័យឲ្យកើតជាថ្មី

ដោយទឹក និងដោយព្រះវិញ្ញាណដ៏វិសុទ្ធ

ព្រមទាំងលើកលែងទោសគេឲ្យរួចពីបាបផង ។

សូមប្រទានសេចក្តីសុខសាន្តរបស់ព្រះអង្គ ដល់យើងខ្ញុំជារៀងរាល់ថ្ងៃ ។

សូមរំដោះយើងខ្ញុំឲ្យរួចពីទោសអស់កល្បជានិច្ច

ហើយសូមទទួលយើងខ្ញុំចូលក្នុងចំណោមអស់អ្នកដែលព្រះអង្គបានជ្រើសរើស ។

លោកបូជាចារ្យលើកដៃប្រណម្យ

(ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)

៨៨. លោកបូជាចារ្យទ្រាប់ដៃទាំងពីរលើតង្វាយ ទាំងពោលថា ៖

ឱ ព្រះជាម្ចាស់អើយ !

សូមព្រះអង្គមេត្តាយល់ព្រមទទួលស្គាល់ និងប្រទានពរលើតង្វាយនេះ

ឲ្យបានវិសុទ្ធ និងជាទីគាប់ព្រះហឫទ័យព្រះអង្គ ។

សូមប្រោសឲ្យតង្វាយនេះ

បានទៅជាព្រះកាយ និងព្រះលោហិតព្រះអម្ចាស់យេស៊ូគ្រីស្ត

ជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ

ដើម្បីជាប្រយោជន៍ដល់យើងខ្ញុំ ។

លោកបូជាចារ្យលើកដៃប្រណម្យ

៨៩. លោកបូជាចារ្យពោលពាក្យនីមួយៗឲ្យបានច្បាស់ ត្រូវតាមអត្ថន័យនៃព្រះបន្ទូលនេះ ។

នៅថ្ងៃ មុនព្រះយេស៊ូសោយទុក្ខលំបាក

លោកបូជាចារ្យលើកនំប៉័ងឡើងបន្តិចពីតុសក្ការៈ ដោយពោលបន្តថា ៖

ព្រះអង្គយកនំប៉័ងមកកាន់ក្នុងព្រះហស្តដ៏វិសុទ្ធជាទីគោរព

លោកបូជាចារ្យ ងើបមុខឡើងបន្តិច

ព្រះអង្គងើបព្រះភ័ក្ត្រទតទៅលើមេឃ
ឆ្ពោះទៅកាន់ព្រះជាម្ចាស់
ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ
ព្រះអង្គអរព្រះគុណ និងសរសើរតម្កើង
ហើយកាច់ប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យ ឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។**

លោកបូជាចារ្យលើកព្រះកាយឡើងបង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់គោរព ។[២១០]

៩០. លោកបូជាចារ្យពោលបន្ត ៖

នៅពេលចុងក្រោយនៃពិធីជប់លៀង
ព្រះអង្គធ្វើតាមរបៀបដដែល

លោកបូជាចារ្យយកពែងមកកាន់ លើកបន្តិចពីតុសក្ការៈ ដោយពោលបន្ត៖

ព្រះអង្គកាន់ពែងដ៏ប្រសើរនេះ
ក្នុងព្រះហស្តដ៏វិសុទ្ធជាទីគោរព
អរព្រះគុណ និងសរសើរតម្កើងម្តងទៀត
ហើយប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា៖

[២១០] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ ស្តីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំ ជំនួសកាយវិការលុតជង្គង់ ។ គួរឱ្យគ្រីស្តបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយលោកបូជាចារ្យ ។

លោកបូជាចារ្យ ឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ**
**នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ព័ន្ធមេត្រីថ្មី**
**និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ**
**ដើម្បីលើកលែងទោសអ្នករាល់គ្នា**
**និងមនុស្សច្រើនឥតគណនាឲ្យរួចពីបាប ។**
**សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ ។**

លោកបូជាចារ្យលើកពែងព្រះលោហិតឡើងបង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់គោរព ។[២១១]

៩១. លោកបូជាចារ្យ ច្រៀង ឬពោលថា ៖
នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

អង្គប្រជុំឆ្លើយ ៖ ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

ឬ

ឱ ព្រះអម្ចាស់អើយ ! រៀងរាល់ពេលយើងខ្ញុំពិសានំប៉័ង និងពិសាពីពែងនេះ
យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

ឬ

ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !
ព្រះអង្គសោយទិវង្គតលើឈើឆ្កាង និងមានព្រះជន្មរស់ឡើងវិញ
ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។

---

[២១១] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ១២៩១/៧៤ ស្ដីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំ ជំនួសកាយវិការលុតជង្គង់ ។ គួរឱ្យគ្រីស្តបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយលោកបូជាចារ្យ ។

៩២. លោកបូជាចារ្យលាតដៃ ដោយពោលបន្ត ៖

បពិត្រព្រះអម្ចាស់ !

យើងខ្ញុំជាអ្នកបម្រើព្រះអង្គ រួមជាមួយប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គ
នាំគ្នានឹករឭកដល់ព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ និងជាព្រះអម្ចាស់យើងខ្ញុំ
គឺព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញពីស្ថានក្រោម
ហើយព្រះអង្គយាងឡើងស្ថានបរមសុខយ៉ាងរុងរឿង ។
ក្នុងចំណោមអ្វីៗដែលព្រះអង្គបានប្រទាន យើងខ្ញុំសូមថ្វាយព្រះអង្គនូវ
សក្ការបូជាដ៏បរិសុទ្ធ
សក្ការបូជាដ៏ពិសិដ្ឋ
សក្ការបូជាដ៏និម្មល ជាព្រះកាយដែលផ្តល់ជីវិតអស់កល្បជានិច្ច
និងព្រះលោហិត ដែលផ្តល់ការសង្គ្រោះជានិរន្តរ៍ ។

៩៣. កាលពីដើម ព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយរបស់លោកអាបែល
ជាមនុស្សសុចរិត និងយញ្ញបូជារបស់លោកអប្រាហាំ
ជាបុព្វបុរសយើងខ្ញុំ ព្រមទាំងយញ្ញបូជារបស់ស្តេចមែលគីសេដែក
ជាមហាបូជាចារ្យរបស់ព្រះអង្គយ៉ាងណា
សូមព្រះអង្គមេត្តាទទួលសក្ការបូជានេះ
ទុកជាយញ្ញបូជាដ៏ពិសិដ្ឋ និងជាសក្ការបូជាដ៏និម្មលយ៉ាងនោះផង ។

៩៤. លោកបូជាចារ្យឱនកាយបន្តិច ប្រណម្យដៃ ហើយពោលបន្ត ៖

ឱ ព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំសូមឱនកាយអង្វរព្រះអង្គ
សូមមេត្តាឲ្យទេវទូតដ៏ពិសិដ្ឋនាំយកសក្ការបូជានេះ
ទៅថ្វាយព្រះអង្គនៅលើតុសក្ការៈឯស្ថានបរមសុខ
នៅចំពោះព្រះភ័ក្ត្រនៃព្រះដ៏ខ្ពង់ខ្ពស់បំផុត ។

សូមឲ្យយើងខ្ញុំដែលទទួលព្រះកាយ
និងព្រះលោហិតដ៏វិសុទ្ធរបស់ព្រះបុត្រាពីតុសក្ការៈនេះ

លោកបូជាចារ្យឈរឡើង និងគូសសញ្ញាឈើឆ្កាងលើខ្លួន ហើយពោលថា ៖
បានពោរពេញដោយព្រះហឫទ័យប្រណីសន្ដោស និងព្រះពរយ៉ាងបរិបូរណ៍ ។

លោកបូជាចារ្យលើកដៃប្រណម្យ
(ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)

៩៥. ពាក្យអង្វរសម្រាប់មរណបុគ្គល លោកបូជាចារ្យលាតដៃ ហើយពោលថា ៖
សូមព្រះអម្ចាស់មេត្តានឹកដល់អ្នកបម្រើព្រះអង្គ នាម... និង នាម...
ដែលបានដៅដោយសញ្ញានៃជំនឿ
ពួកគាត់បានលាចាកលោកនេះមុនយើងខ្ញុំ
និងកំពុងសម្រាកយ៉ាងសុខសាន្ត ។

លោកបូជាចារ្យប្រណម្យដៃ ហើយអធិដ្ឋានយ៉ាងខ្លីសម្រាប់មរណបុគ្គលទាំងនោះ ។ បន្ទាប់មក លោកលាតដៃ ដោយពោលបន្តថា ៖
សូមព្រះអម្ចាស់មេត្តាប្រោសប្រទានបុគ្គលទាំងនោះ
និងអស់អ្នកដែលសម្រាកក្នុងអង្គព្រះគ្រីស្ត
បានត្រជាក់ត្រជំ ពោរពេញដោយពន្លឺ និងសេចក្ដីសុខសាន្ត ។

លោកបូជាចារ្យលើកដៃប្រណម្យ
(ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)

៩៦. លោកបូជាចារ្យ គក់ទ្រូង ហើយពោលបន្ត ៖
ទោះបីយើងខ្ញុំជាអ្នកបាបក៏ដោយ ក៏យើងខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គ

លោកបូជាចារ្យលាតដៃ ហើយពោលបន្តថា ៖
ដែលជឿសង្ឃឹមលើព្រះហឫទ័យមេត្តាករុណាដ៏លើសលប់របស់ព្រះអង្គដែរ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ
បានចូលរួមក្នុងសហភាពជាមួយគ្រីស្តទូត និងមរណសាក្សី

ជាមួយសន្តយ៉ូហានបាទីស្ត, សន្តស្តេផាន
សន្តម៉ាធីយ៉ា, សន្តបារណាបាស
(សន្តអ៊ីញ៉ាស, សន្តអឡិចសាំង
សន្តម៉ាសេឡាំង និងសិលា
សន្តីភេលីស៊ីតា និងពែពេទូអា
សន្តីអាហ្គាត, សន្តីលូស៊ី
សន្តីអាញ៉ែស, សន្តីសេស៊ីល
សន្តីអាណាស្តាស៊ី) និងសន្តបុគ្គលទាំងឡាយផង ។
យើងខ្ញុំសូមទទូចអង្វរព្រះអង្គ
សូមឲ្យយើងខ្ញុំបានចូលរួមក្នុងសហភាពរបស់ជនដ៏វិសុទ្ធទាំងនេះ ។
សូមព្រះអង្គកុំរាប់អំពើល្អរបស់យើងខ្ញុំឡើយ តែសូមលើកលែងទោសឲ្យយើងខ្ញុំវិញ

លោកបូជាចារ្យលើកដៃប្រណម្យ៖
ដោយសារព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។

៩៧. លោកបូជាចារ្យពោលបន្ត ៖
គឺដោយសារព្រះគ្រីស្តនេះហើយ បានជាព្រះអង្គនៅតែបង្កើតអ្វីៗដ៏ល្អទាំងអស់នេះ
ប្រោសឲ្យបានវិសុទ្ធ ឲ្យមានជីវិត និងប្រទានពរ ហើយប្រគល់ឲ្យយើងខ្ញុំ ។

៩៨. លោកបូជាចារ្យលើកបានព្រះកាយ និងពែងព្រះលោហិតក្នុងដៃទាំងពីរ ហើយពោលថា ៖
ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

(ពិធីទទួលព្រះកាយ និងព្រះលោហិត តទៅទំព័រ ៥៥៥)

# ធម៌អរព្រះគុណដ៏វិសុទ្ធទី ២

PREX EUCHARISTICA II

៩៩. ធម៌អរព្រះគុណដ៏វិសុទ្ធទី ២ នេះ មានធម៌ប្រារព្ធផ្ទាល់របស់ខ្លួន តែយើងអាចប្រើជាមួយធម៌ប្រារព្ធផ្សេងទៀត ជាពិសេស ធម៌ប្រារព្ធដែលរៀបរាប់អំពីប្រវត្តិនៃការសង្គ្រោះ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធបំផុត !
ពិតជាការគួរណាស់ហើយប្រពៃផង
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
ដោយរួមជាមួយព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ។
ព្រះបិតាបានបង្កើតសត្វលោក និងអ្វីៗសព្វសារពើទាំងអស់
ដោយព្រះយេស៊ូគ្រីស្តជាព្រះបន្ទូលរបស់ព្រះអង្គ ។
ព្រះបិតាចាត់ឲ្យព្រះយេស៊ូគ្រីស្តយាងមកសង្គ្រោះ និងរំដោះយើងខ្ញុំ
គឺព្រះអង្គបានទទួលរូបកាយជាមនុស្ស ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ
ហើយទ្រង់ប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី ។
ដោយបំពេញបំណងរបស់ព្រះបិតា
និងប្រមូលប្រជារាស្ត្រមួយដ៏វិសុទ្ធថ្វាយព្រះអង្គ
ព្រះបុត្រាសព្វព្រះហឫទ័យត្រដាងព្រះហស្តរងទុក្ខលំបាក
ដើម្បីបំផ្លាញចំណងនៃសេចក្ដីស្លាប់ និងសម្ដែងអំពីជីវិតរស់ឡើងវិញ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ រួមគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

១០០. លោកបូជាចារ្យលាតដៃ ដោយពោលបន្ត ៖
ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គពិតជាព្រះដ៏វិសុទ្ធ និងជាប្រភពនៃភាពដ៏វិសុទ្ធគ្រប់យ៉ាង ។

១០១. លោកបូជាចារ្យប្រណម្យដៃ ហើយទ្រាប់ដៃទាំងពីរលើតង្វាយ ។ បន្ទាប់មក លោកពោលថា៖
យើងខ្ញុំសូមទូលអង្វរព្រះអង្គ
សូមប្រោះព្រះវិញ្ញាណរបស់ព្រះអង្គដូចទឹកសន្សើម
មកញ៉ាំងតង្វាយទាំងនេះឲ្យបានវិសុទ្ធ គឺសូមឲ្យតង្វាយនេះ
លោកបូជាចារ្យប្រណម្យដៃ ហើយធ្វើសញ្ញាឈើឆ្កាងលើនំ និងស្រាតង្វាយ ទាំងពោលថា ៖
បានទៅជាព្រះកាយ ≅ និងព្រះលោហិតព្រះអម្ចាស់យេស៊ូគ្រីស្តសម្រាប់យើងខ្ញុំ ។
លោកបូជាចារ្យលើកដៃប្រណម្យ ។

១០២. លោកបូជាចារ្យពោលពាក្យនីមួយៗឲ្យបានច្បាស់ ត្រូវតាមអត្ថន័យនៃព្រះបន្ទូលនេះ ។
នៅគ្រាដែលព្រះយេស៊ូគ្រីស្តសព្វព្រះហឫទ័យ
ឲ្យគេបញ្ជូនព្រះអង្គទៅសោយទុក្ខលំបាក
លោកបូជាចារ្យ លើកនំតង្វាយឡើងបន្តិចពីតុសក្ការៈ ដោយពោលបន្ត ៖
ព្រះអង្គយកនំបុ័ងមកកាន់ អរព្រះគុណព្រះបិតា
ហើយកាច់ប្រទានឲ្យក្រុមសាវ័ក ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យ ឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។**

លោកបូជាចារ្យលើកព្រះកាយឡើងបង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់គោរព ។[២១២]

១០៣. លោកបូជាចារ្យពោលបន្ត ៖

នៅពេលចុងក្រោយនៃពិធីជប់លៀង ព្រះអង្គធ្វើតាមរបៀបដដែល

លោកបូជាចារ្យយកពែងមកកាន់ ឡើងបន្តិចពីតុសក្ការៈ ដោយពោលបន្ត ៖

ព្រះអង្គលើកពែងឡើង

អរព្រះគុណព្រះបិតា ហើយប្រទានឲ្យក្រុមសាវ័ក

ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យ ឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ**

**នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ព័ន្ធមេត្រីថ្មី**

**និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ**

**ដើម្បីលើកលែងទោសអ្នករាល់គ្នា**

**និងមនុស្សច្រើនឥតគណនាឲ្យរួចពីបាប ។**

**សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ ។**

លោកបូជាចារ្យលើកពែងព្រះលោហិតឡើង បង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់គោរព ។[២១៣]

---

[២១២] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ១២៩១/៧៤ ស្ដីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំជំនួសកាយវិការលុតជង្គង់ ។ គួរឱ្យគ្រីស្ដបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយលោកបូជាចារ្យ ។

[២១៣] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ ស្ដីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំជំនួសកាយវិការលុតជង្គង់ ។ គួរឱ្យគ្រីស្ដបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយលោកបូជាចារ្យ ។

១០៤. លោកបូជាចារ្យ ច្រៀង ឬពោលបន្ត ៖

នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

អង្គប្រជុំឆ្លើយ ៖ ឱ ព្រះអម្ចាស់អើយ !

យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ

ហើយយើងខ្ញុំសូមប្រកាស រហូតដល់ពេលព្រះអង្គយាងមក ។

ឬ

ឱ ព្រះអម្ចាស់អើយ !

រៀងរាល់ពេលយើងខ្ញុំពិសានំប៉័ង និងពិសាពីពែងនេះ

យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត

ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

ឬ

ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !

ព្រះអង្គសោយទិវង្គតលើឈើឆ្កាង និងមានព្រះជន្មរស់ឡើងវិញ

ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។

១០៥. លោកបូជាចារ្យលាតដៃ ដោយពោលបន្ត ៖

បពិត្រព្រះអម្ចាស់ !

ក្នុងពេលដែលយើងខ្ញុំនឹករឭក

ដល់ព្រះបុត្រាសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ

យើងខ្ញុំសូមថ្វាយព្រះកាយដែលផ្តល់ជីវិត និងព្រះលោហិតដែលផ្តល់ការសង្គ្រោះ

ព្រមទាំងអរព្រះគុណព្រះអង្គ ដ្បិតទ្រង់សព្វព្រះហឫទ័យឲ្យយើងខ្ញុំ

សមនឹងស្ថិតនៅចំពោះព្រះភ័ក្ត្រ និងបម្រើព្រះអង្គ ។

យើងខ្ញុំសូមលំទោនកាយទូលអង្វរ

សូមព្រះអង្គប្រោសប្រទានព្រះវិញ្ញាណដ៏វិសុទ្ធប្រមូលផ្តុំយើងខ្ញុំ

ដែលចូលរួមក្នុងព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ត

ឲ្យទៅជាធ្លុងតែមួយផង ។

បពិត្រព្រះអម្ចាស់ !
សូមព្រះអង្គនឹកដល់ព្រះសហគមន៍
ដែលមាននៅសព្វអន្លើក្នុងពិភពលោកទាំងមូល
សូមប្រោសឲ្យព្រះសហគមន៍ បានគ្រប់លក្ខណៈក្នុងសេចក្ដីស្រឡាញ់
រួមជាមួយសម្ដេចប៉ាបយើងខ្ញុំ ព្រះនាម...
លោក នាម... ជាអភិបាលព្រះសហគមន៍យើងខ្ញុំ[២១៤]
និងអស់លោកអ្នកដែលមានបន្ទុកដឹកនាំប្រជារាស្ត្រព្រះអង្គ ។

ក្នុងអភិបូជា នឹករឭកដល់មរណបុគ្គល លោកបូជាចារ្យអាចបន្ថែមពាក្យដូចខាងក្រោមនេះ ៖

**ឱ ព្រះបិតាយើងខ្ញុំអើយ !**
**សូមព្រះអង្គនឹកដល់** (ឈ្មោះ...) **ជាអ្នកបម្រើរបស់ព្រះអង្គ**
**ដែលព្រះអង្គត្រាស់ហៅឲ្យលាចាកលោកនេះ ទៅឯព្រះអង្គ** (នៅថ្ងៃនេះ)។
**សូមព្រះអង្គប្រោសប្រណី** (ឈ្មោះ...) **បានរួមស្លាប់ជាមួយព្រះបុត្រា ដែលសោយទិវង្គត សូមឲ្យគាត់បានរួមរស់ជាមួយព្រះបុត្រា**
**ដែលមានព្រះជន្មរស់ឡើងវិញផង។**

សូមព្រះអង្គនឹកដល់អស់បងប្អូនយើងខ្ញុំ
ដែលសម្រាន្តលក់ដោយមានចិត្តសង្ឃឹមនឹងរស់ឡើងវិញ
ព្រមទាំងបុគ្គលទាំងអស់ដែលបានលាចាកលោកនេះ
ក្នុងធម៌មេត្តាករុណារបស់ព្រះអង្គ ។
សូមព្រះអង្គប្រោសប្រទានឲ្យបុគ្គលទាំងនោះ បានចូលក្នុងពន្លឺនៃព្រះភ័ក្ត្រព្រះអង្គ ។

[២១៤] ទីនេះ លោកអាចបន្ថែមឈ្មោះលោកអភិបាលឧបត្ថម្ភក ឬលោកអភិបាលជំនួយការផ្សេងៗ តាមពាក្យណែនាំនៃក្បួនពិធីបុណ្យលេខ ១៤៩។

សូមព្រះអង្គអាណិតអាសូរយើងខ្ញុំទាំងអស់គ្នា
បានទទួលជីវិតអស់កល្បជានិច្ច រួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី
ដែលពោរពេញដោយសុភមង្គល ជាព្រះមាតារបស់ព្រះជាម្ចាស់
រួមជាមួយសន្តយ៉ូសែប ជាស្វាមីព្រះនាង
ជាមួយអស់គ្រីស្តទូត
និងអស់សន្តបុគ្គលនៅគ្រប់សម័យ
ដែលគាប់ព្រះហឫទ័យព្រះអង្គ ។
យើងខ្ញុំទាំងអស់គ្នាសូមកោតសរសើរ
និងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ។

លោកបូជាចារ្យលើកដៃប្រណម្យ ។

ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ ។

១០៦. លោកបូជាចារ្យលើកបានព្រះកាយ និងពែងព្រះលោហិតក្នុងដៃទាំងពីរ ហើយពោលថា៖

ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៥៥៥)

# ធម៌អរព្រះគុណដ៏វិសុទ្ធ ទី៣

PREX EUCHARISTICA III

១០៧. ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បន្ទាប់មក ត្រូវប្រើធម៌ប្រារព្ធណាមួយស្របតាមពាក្យណែនាំពិធី ហើយបន្តតាមរបៀបខាងក្រោមនេះ ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

១០៨. លោកបូជាចារ្យលាតដៃ ដោយពោលបន្ត ៖

ឱ ព្រះអម្ចាស់អើយ ! ព្រះអង្គពិតជាព្រះដ៏វិសុទ្ធមែន
ហើយអ្វីៗសព្វសារពើដែលព្រះអង្គបានបង្កើត សូមកោតសរសើរព្រះអង្គ ។
តាមរយៈព្រះអម្ចាស់យេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ
និងដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ
ទ្រង់ប្រទានឲ្យអ្វីៗសព្វសារពើមានជីវិត និងបានវិសុទ្ធ ។
ព្រះអង្គតែងតែប្រមូលផ្តុំប្រជារាស្ត្រសម្រាប់ព្រះអង្គ
ដើម្បីថ្វាយតង្វាយដ៏បរិសុទ្ធចំពោះព្រះនាមព្រះអង្គ ចាប់ពីថ្ងៃរះរហូតដល់ថ្ងៃលិច ។

១០៩. លោកបូជាចារ្យប្រណម្យដៃ ហើយទ្រាប់ដៃទាំងពីរលើតង្វាយ ដោយពោលថា ៖

ឱ ព្រះអម្ចាស់អើយ !

ហេតុនេះហើយ បានជាយើងខ្ញុំសូមលំទោនកាយទូលអង្វរព្រះអង្គ

សូមចាត់ព្រះវិញ្ញាណព្រះអង្គ មកប្រសិទ្ធពរលើតង្វាយ

ដែលយើងខ្ញុំលើកថ្វាយនេះ ឲ្យបានវិសុទ្ធ

លោកបូជាចារ្យប្រណម្យដៃ ហើយធ្វើសញ្ញាឈើឆ្កាងលើនំ និងស្រាតង្វាយទាំងពោលថា ៖

និងបានទៅជាព្រះកាយ ≅ និងព្រះលោហិតព្រះយេស៊ូគ្រីស្ត

ជាព្រះបុត្រាព្រះអង្គ និងជាព្រះអម្ចាស់យើងខ្ញុំ

លោកបូជាចារ្យលើកដៃប្រណម្យ ។

ដែលបានផ្ដាំឲ្យយើងខ្ញុំថ្វាយអភិបូជានេះ ។

១១០. លោកបូជាចារ្យពោលពាក្យនីមួយៗឲ្យបានច្បាស់ ត្រូវតាមអត្ថន័យនៃព្រះបន្ទូលនេះ ។

នៅរាត្រីដែលគេបញ្ជូនព្រះយេស៊ូ ទៅសោយទុក្ខលំបាក

លោកបូជាចារ្យលើកនំតង្វាយឡើងបន្តិចពីតុសក្ការៈ ដោយពោលបន្ត៖

ព្រះអង្គយកនំប៉័ងមកកាន់

អរព្រះគុណ និងលើកតម្កើងព្រះបិតា

ហើយកាច់ប្រទានឲ្យក្រុមសាវ័ក

ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យ ឱនកាយបន្តិច

## សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។

លោកបូជាចារ្យលើកព្រះកាយឡើង បង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់គោរព ។[២១៥]

[២១៥] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ១២៩១/៧៤ ស្ដីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំជំនួសកាយវិការលុតជង្គង់ ។ គួរឱ្យគ្រីស្តបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយលោកបូជាចារ្យ ។

១១១. លោកបូជាចារ្យពោលពាក្យនីមួយៗឲ្យបានច្បាស់ ត្រូវតាមអត្ថន័យនៃព្រះបន្ទូលនេះ ។
នៅពេលចុងក្រោយនៃពិធីជប់លៀង
ព្រះអង្គធ្វើតាមរបៀបដដែល

លោកបូជាចារ្យ យកពែងព្រះលោហិតមកកាន់ លើកបន្តិចពីតុសក្ការៈ ដោយពោលបន្ត ៖
ព្រះអង្គលើកពែងឡើង
អរព្រះគុណ និងលើកតម្កើងព្រះបិតា
ហើយប្រទានឲ្យក្រុមសាវ័ក ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យ ឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ**
**នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ព័ន្ធមេត្រីថ្មី**
**និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ**
**ដើម្បីលើកលែងទោសអ្នករាល់គ្នា**
**និងមនុស្សច្រើនឥតគណនាឲ្យរួចពីបាប ។**
**សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ ។**

លោកបូជាចារ្យលើកពែងព្រះលោហិតឡើង បង្ហាញអង្គប្រជុំរួចដាក់ចុះ ហើយលុតជង្គង់គោរព ។[២១៦]

១១២. លោកបូជាចារ្យ ច្រៀង ឬពោលបន្តថា ៖
នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

អង្គប្រជុំឆ្លើយ ៖ ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

---

[២១៦] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ ស្ដីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំជំនួសការលុតជង្គង់ ។ គួរឱ្យគ្រីស្តបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយលោកបូជាចារ្យ ។

ឬ

ឱ ព្រះអម្ចាស់អើយ !

វៀងរាល់ពេល យើងខ្ញុំពិសានំប៉័ង និងពិសាពីពែងនេះ

យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត

ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

ឬ

ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !

ព្រះអង្គសោយទិវង្គតលើឈើឆ្កាង និងមានព្រះជន្មរស់ឡើងវិញ

ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។

១១៣. លោកបូជាចារ្យលាតដៃ ដោយពោលបន្តថា ៖

ឱ ព្រះអម្ចាស់អើយ !

យើងខ្ញុំនឹករឭកដល់ព្រះបុត្រាព្រះអង្គ សោយទិវង្គតដើម្បីសង្គ្រោះយើងខ្ញុំ

ព្រះអង្គមានព្រះជន្មរស់ឡើងវិញដ៏អស្ចារ្យ និងយាងឡើងស្ថានបរមសុខ

ហើយយើងខ្ញុំក៏ទន្ទឹងរង់ចាំព្រះបុត្រាព្រះអង្គយាងមកវិញ ។

យើងខ្ញុំសូមថ្វាយសក្ការបូជាដ៏វិសុទ្ធដែលមានជីវិតនេះ

ដើម្បីអរព្រះគុណព្រះអង្គ ។

សូមព្រះអង្គមេត្តាទតមើលតង្វាយរបស់ព្រះសហគមន៍

ទុកជាសក្ការបូជារបស់ព្រះបុត្រា ។

សូមប្រោសឲ្យយើងខ្ញុំដែលទទួលកម្លាំងពីព្រះកាយ

និងព្រះលោហិតរបស់ព្រះបុត្រា ពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ

បានមូលផ្តុំគ្នាទៅជារូបកាយតែមួយ និងមានចិត្តថ្លើមតែមួយក្នុងអង្គព្រះគ្រីស្ត ។

សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ

បានទៅជាតង្វាយគង់វង្សអស់កល្បជានិច្ចចំពោះព្រះបិតា

ដូច្នេះ យើងខ្ញុំសមនឹងទទួលមត៌ក

រួមជាមួយអស់អ្នកដែលព្រះអង្គបានជ្រើសរើស

ជាបឋម រួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី
ដែលពោរពេញដោយសុភមង្គលដ៏លើសលប់
ជាព្រះមាតានៃព្រះជាម្ចាស់
ជាមួយសន្តយ៉ូសែបជាស្វាមីព្រះនាង
ជាមួយក្រុមគ្រីស្តទូត និងអស់មរណសាក្សី
(ជាមួយសន្ត...ឬសន្តី...ប្រចាំថ្ងៃ ឬឧបការី...)
ព្រមទាំងជាមួយសន្តបុគ្គលទាំងឡាយ
ដែលជួយអង្វរព្រះអង្គឲ្យយើងខ្ញុំឥតឈប់ឈរ ។

ឱ ព្រះអម្ចាស់អើយ !
សូមឲ្យសក្ការបូជានេះ ដែលផ្សះផ្សាយើងខ្ញុំបានជានាជាមួយព្រះអង្គ
សូមប្រោសឲ្យពិភពលោកទាំងមូល
បានប្រកបដោយសេចក្តីសុខសាន្ត និងទទួលការសង្គ្រោះ ។
សូមពង្រឹងព្រះសហគមន៍របស់ព្រះអង្គ
ដែលកំពុងធ្វើដំណើរនៅក្នុងលោកនេះ
ឲ្យមានជំនឿ និងសេចក្តីស្រឡាញ់
រួមជាមួយសម្តេចប៉ាបយើងខ្ញុំព្រះនាម... ជាអ្នកបម្រើព្រះអង្គ
លោកនាម... ជាអភិបាលព្រះសហគមន៍យើងខ្ញុំ[២១៧]
និងលោកអភិបាលព្រះសហគមន៍នានាក្នុងសកលលោក
អស់លោកបូជាចារ្យ អស់លោកឧបដ្ឋាក
និងប្រជារាស្ត្រទាំងមូលដែលជាកម្មសិទ្ធិរបស់ព្រះអង្គផង ។
សូមព្រះអង្គសណ្តាប់នូវពាក្យអង្វររបស់ក្រុមគ្រួសារនេះ
ដែលព្រះអង្គបានត្រាស់ហៅឲ្យជួបជុំនៅចំពោះព្រះភ័ក្ត្រព្រះអង្គ ។

[២១៧] ទីនេះ លោកអាចបន្ថែមឈ្មោះលោកអភិបាលឧបត្ថម្ភក ឬលោកអភិបាលជំនួយការផ្សេងៗ តាមពាក្យណែនាំនៃក្បួនពិធីបុណ្យ ។

**ពីរាត្រីបុណ្យចម្លងរហូតដល់ថ្ងៃអាទិត្យទី ២ នៃរដូវបុណ្យចម្លង ត្រូវបន្ថែម ៖**
**សូមព្រះអង្គប្រណីសន្តោសដល់អស់អ្នក ដែលព្រះអង្គបានប្រោសឲ្យកើតជាថ្មី**
**ដោយទឹក និងព្រះវិញ្ញាណដ៏វិសុទ្ធ ក្នុងឱកាសបុណ្យចម្លងនេះ**
**សូមប្រោសគេឲ្យរស់នៅតាមរបៀបថ្មីក្នុងអង្គព្រះគ្រីស្ត។**

បពិត្រព្រះបិតាដ៏មានព្រះហឫទ័យមេត្តាករុណាយ៉ាងក្រៃលែង !
សូមប្រោសឲ្យអស់បុត្រធីតាព្រះអង្គ
ដែលខ្វាត់ខ្វាយបានចូលរួមជាមួយព្រះអង្គផង ។
† សូមព្រះអង្គមេត្តាដល់អស់បងប្អូនយើងខ្ញុំ ដែលទទួលមរណភាព
និងដល់បុគ្គលទាំងអស់ដែលគាប់ព្រះហឫទ័យព្រះអង្គ ហើយបានលាចាកលោកនេះ
សូមទទួលបុគ្គលទាំងនោះ ចូលក្នុងព្រះរាជ្យរបស់ព្រះអង្គ ។
នៅទីនោះ យើងខ្ញុំសង្ឃឹមថា
នឹងបានពោរពេញទៅដោយសិរីរុងរឿងរបស់ព្រះអង្គជានិច្ចនិរន្តរ៍
ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ
លោកបូជាចារ្យលើកដៃប្រណម្យ
គឺដោយព្រះគ្រីស្តនេះហើយ
ដែលព្រះបិតាប្រទានអ្វីៗដ៏ល្អគ្រប់បែបយ៉ាងដល់ពិភពលោក ។ †

១១៤. លោកបូជាចារ្យលើកចានព្រះកាយ និងពែងព្រះលោហិតក្នុងដៃទាំងពីរ ហើយពោលថា៖
ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៥៥៥)

១១៥. ធម៌ខាងក្រោមនេះ អាចប្រើនៅពេលថ្វាយអភិបូជានឹករឭកដល់មរណបុគ្គល ។

†សូមព្រះបិតានឹករឭកដល់ (ឈ្មោះ...) ជាអ្នកបម្រើព្រះអង្គ
ដែលព្រះអង្គត្រាស់ហៅ (នៅថ្ងៃនេះ) ឲ្យលាចាកពីលោកនេះទៅឯព្រះអង្គ។
ដោយគាត់បានរួមស្លាប់ជាមួយព្រះបុត្រាដែលសោយទិវង្គត
សូមប្រោសឲ្យគាត់បានរួមជាមួយព្រះបុត្រា ដែលមានព្រះជន្មរស់ឡើងវិញ
ក្នុងពេលដែលព្រះគ្រីស្តដាស់អ្នកស្លាប់ឲ្យក្រោកពីដី
និងបំផ្លាស់បំប្រែរូបកាយដ៏ថោកទាបរបស់យើងខ្ញុំនេះ ឲ្យបានដូចព្រះកាយ
ប្រកបដោយសិរីរុងរឿងរបស់ព្រះអង្គ។

សូមព្រះអង្គមេត្តាដល់អស់បងប្អូនយើងខ្ញុំដែលទទួលមរណភាព
និងដល់បុគ្គលទាំងអស់ដែលគាប់ព្រះហឫទ័យព្រះអង្គ
ហើយបានលាចាកលោកនេះ សូមទទួលបុគ្គលទាំងនោះ
ចូលក្នុងព្រះរាជ្យរបស់ព្រះអង្គ។

នៅទីនោះ យើងខ្ញុំសង្ឃឹមថា
នឹងបានពោរពេញទៅដោយសិរីរុងរឿងរបស់ព្រះអង្គជានិច្ចនិរន្តរ៍។
នៅពេលព្រះអង្គជូតទឹកភ្នែកយើងខ្ញុំ
ពេលនោះ យើងខ្ញុំនឹងមើលឃើញព្រះភ័ក្ត្រព្រះជាម្ចាស់យ៉ាងជាក់ស្តែង
យើងខ្ញុំនឹងបានដូចព្រះអង្គជាអង្វែងតរៀងទៅ
ហើយយើងខ្ញុំលើកតម្កើងព្រះអង្គឥតឈប់ឈរ
រួមជាមួយព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ។

លោកបូជាចារ្យលើកដៃប្រណម្យ
គឺដោយសារព្រះគ្រីស្តនេះហើយ
ដែលព្រះបិតាប្រទានអ្វីៗដ៏ល្អគ្រប់បែបយ៉ាងដល់ពិភពលោក។ †

# ធម៌អរព្រះគុណដ៏វិសុទ្ធទី ៤

PREX EUCHARISTICA IV

១១៦. ពេលជ្រើសរើសធម៌អរព្រះគុណដ៏វិសុទ្ធទី៤ ត្រូវប្រើធម៌ប្រារព្ធខាងក្រោមនេះជាដាច់ខាត ព្រោះធម៌អរព្រះគុណដ៏វិសុទ្ធទាំងស្រុងនេះ ជាសេចក្ដីសង្ខេបអំពីប្រវត្តិនៃការសង្គ្រោះ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធបំផុត !
ពិតជាការគួរណាស់ ដែលយើងខ្ញុំអរព្រះគុណព្រះអង្គ
ហើយពិតជាការប្រពៃណាស់ ដែលយើងខ្ញុំលើកតម្កើងសិរីរុងរឿងព្រះអង្គ
ព្រោះព្រះអង្គជាព្រះជាម្ចាស់តែមួយគត់
ដែលមានព្រះជន្មរស់ និងជាព្រះដ៏ពិតប្រាកដ ។
ព្រះអង្គគង់នៅមុនកាលសម័យទាំងអស់ និងអស់កល្បជានិច្ច
ហើយគង់នៅក្នុងពន្លឺ ដែលគ្មាននរណាអាចចូលជិតបាន
មិនតែប៉ុណ្ណោះ ព្រះអង្គមានព្រះហឫទ័យសប្បុរសដ៏លើសលប់
និងជាប្រភពនៃជីវិតគ្រប់យ៉ាង ។

ព្រះអង្គបានបង្កើតពិភពលោក ដើម្បីឲ្យស្នាព្រះហស្ដរបស់ព្រះអង្គ
បានពោរពេញដោយព្រះពរ និងមានអំណរសប្បាយ
ដោយសារពន្លឺដ៏ត្រចះត្រចង់របស់ព្រះអង្គ ។

អាស្រ័យហេតុនេះហើយ បានជាទេវទូតដ៏ច្រើនឥតគណនា
ដែលគោរពបម្រើព្រះអង្គទាំងយប់ទាំងថ្ងៃ
ឈរនៅខាងមុខព្រះអង្គ សម្លឹងមើលរស្មីចែងចាំងនៃព្រះភ័ក្ត្រ
និងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គជានិរន្តរ៍ ។
ក្នុងនាមសត្វលោកទាំងអស់ យើងខ្ញុំត្រេកអរ
សូមលើកតម្កើងព្រះនាមព្រះអង្គរួមជាមួយទេវទូតទាំងឡាយ ដោយច្រៀងថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

១១៧. លោកបូជាចារ្យលាតដៃ ដោយពោលបន្តថា ៖

បពិត្រព្រះបិតាដ៏វិសុទ្ធ !
យើងខ្ញុំសូមប្រកាសថា ព្រះអង្គជាព្រះដ៏ប្រសើរឧត្តម
ព្រះអង្គបានបង្កើតអ្វីៗសព្វសារពើទាំងអស់
ដោយព្រះប្រាជ្ញាញាណ និងធម៌មេត្តាករុណា ។
ព្រះជាម្ចាស់បានបង្កើតមនុស្សជាតំណាងរបស់ព្រះអង្គ
ហើយទ្រង់ប្រទានពិភពលោកឲ្យមនុស្សថែរក្សា
ស្នាព្រះហស្ដរបស់ព្រះជាម្ចាស់ ដោយគោរពបម្រើព្រះអង្គជាព្រះអាទិករ ។
នៅពេលមនុស្សលោកបានផ្ដាច់ចំណងមេត្រីជាមួយព្រះអង្គ ដោយមិនស្ដាប់បង្គាប់
ព្រះអង្គ ទ្រង់មិនបណ្ដោយឲ្យមនុស្សលោក
ស្ថិតនៅក្រោមអំណាចនៃសេចក្ដីស្លាប់ឡើយ ។
ព្រះអង្គតែងតែមានព្រះហឫទ័យមេត្តាករុណាជួយមនុស្សទាំងអស់
ដើម្បីឲ្យអស់អ្នកដែលស្វែងរកបានជួបព្រះអង្គ ។

ជាច្រើនលើក ច្រើនគ្រា ព្រះអង្គប្រទានចំណងមេត្រីដល់មនុស្សលោក
ហើយតាមរយៈព្យាការីទាំងឡាយ
ព្រះអង្គអប់រំគេឲ្យមានសេចក្តីសង្ឃឹមថា ព្រះអង្គនឹងសង្គ្រោះគេ ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ព្រះអង្គស្រឡាញ់មនុស្សលោកយ៉ាងក្រៃលែង
ទ្រង់ចាត់ព្រះបុត្រាតែមួយរបស់ព្រះអង្គឲ្យយាងមកសង្គ្រោះយើងខ្ញុំ
តាមពេលកំណត់ដែលព្រះអង្គបាន សម្រេចមកហើយ ។

ព្រះបុត្រាទទួលរូបកាយជាមនុស្សមកពីព្រះវិញ្ញាណដ៏វិសុទ្ធ
ហើយទ្រង់បានប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី
ព្រះអង្គរស់នៅជាមនុស្សដូចយើងខ្ញុំក្នុងគ្រប់ប្រការ
តែមិនប្រព្រឹត្តអំពើបាបសោះឡើយ ។
ព្រះបុត្រានាំដំណឹងល្អប្រាប់ជនក្រីក្រថា គេនឹងទទួលការសង្គ្រោះ
ប្រាប់ជនជាប់ឃុំឃាំងថា គេនឹងមានសេរីភាព
ហើយប្រាប់ជនកើតទុក្ខថា គេនឹងបានអំណរសប្បាយវិញ ។

បពិត្រព្រះបិតា !
ដើម្បីបំពេញបំណងព្រះអង្គ ព្រះបុត្រាបានប្រគល់ខ្លួនឲ្យគេធ្វើគុត
ហើយដោយក្រោកឡើងពីចំណោមមនុស្សស្លាប់
ព្រះអង្គបំផ្លាញសេចក្តីស្លាប់ និងធ្វើឲ្យមានជីវិតឡើងវិញ ។

បពិត្រព្រះបិតាជាម្ចាស់ !
ព្រះបុត្រាចាត់ព្រះវិញ្ញាណដ៏វិសុទ្ធពីព្រះអង្គ
ដើម្បីប្រោសឲ្យយើងខ្ញុំលែងរស់សម្រាប់ខ្លួនឯងទៀតហើយ
គឺរស់សម្រាប់ព្រះបុត្រាដែលសោយទិវង្គត
និងមានព្រះជន្មរស់ឡើងវិញសម្រាប់យើង ។

ព្រះបុត្រាបានចាត់ព្រះវិញ្ញាណដ៏វិសុទ្ធ
ជាព្រះអំណោយទានដំបូងបង្អស់ដល់អស់អ្នកជឿ
គឺព្រះវិញ្ញាណដែលបំពេញកិច្ចការរបស់ព្រះបុត្រាក្នុងលោកនេះ
ឲ្យបានវិសុទ្ធជាស្ថាពរ ។

១១៨. លោកបូជាចារ្យប្រណម្យដៃ ហើយទ្រាប់ដៃទាំងពីរលើតង្វាយ ។ លោកពោលថា៖
ឱ ព្រះអម្ចាស់អើយ ! យើងខ្ញុំសូមអង្វរព្រះអង្គ
សូមឲ្យព្រះវិញ្ញាណដ៏វិសុទ្ធ មកញ៉ាំងតង្វាយទាំងនេះ ឲ្យបានវិសុទ្ធ

លោកបូជាចារ្យលើកដៃប្រណម្យ ហើយធ្វើសញ្ញាឈើឆ្កាងលើនំ និងស្រាតង្វាយ ទាំងពោលថា៖
ហើយបានទៅជាព្រះកាយ ≅ និងព្រះលោហិតព្រះយេស៊ូគ្រីស្ត
ជាព្រះអម្ចាស់យើងខ្ញុំ

លោកបូជាចារ្យលើកដៃប្រណម្យ ។
ក្នុងពិធីលើកតម្កើងគម្រោងការដ៏អស្ចារ្យនេះ
ដែលព្រះគ្រីស្តផ្ទាល់បានតាំងទុកជាចំណងមេត្រី អស់កល្បជានិច្ចសម្រាប់យើងខ្ញុំ ។

១១៩. លោកបូជាចារ្យពោលពាក្យនីមួយៗឲ្យបានច្បាស់ ត្រូវតាមអត្ថន័យ នៃព្រះបន្ទូល ។
បពិត្រព្រះបិតាដ៏វិសុទ្ធ !
ដល់ពេលកំណត់ ដែលព្រះបុត្រាបានទទួលសិរីរុងរឿងពីព្រះបិតា
ដោយទ្រង់ស្រឡាញ់សាវ័ករបស់ព្រះអង្គដែលរស់នៅក្នុងលោកនេះ
ព្រះអង្គក៏ស្រឡាញ់គេរហូតដល់ទីបំផុត ។

នៅពេលជប់លៀង

លោកបូជាចារ្យលើកនំតង្វាយឡើងបន្តិចពីតុសក្ការៈ ដោយពោលបន្ត៖
ព្រះអង្គយកនំប៉័ងមកកាន់
លើកតម្កើងព្រះបិតា ហើយកាច់ប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យ ឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ**
**ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។**

លោកបូជាចារ្យលើកព្រះកាយឡើងបង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់គោរព ។[២១៨]

១២០. លោកបូជាចារ្យអានបន្ត ៖

បន្ទាប់មក ព្រះអង្គធ្វើតាមរបៀបដដែល

លោកបូជាចារ្យយកពែងមកកាន់លើកបន្តិចពីតុសក្ការៈ ដោយពោលបន្ត ៖

ព្រះអង្គលើកពែងស្រាទំពាំងបាយជូរឡើង
អរព្រះគុណព្រះបិតា ហើយប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យ ឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ**
**នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ពន្ធមេត្រីថ្មី**
**និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ**
**ដើម្បីលើកលែងទោសអ្នករាល់គ្នា**
**និងមនុស្សច្រើនឥតគណនាឲ្យរួចពីបាប ។**
**សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ ។**

លោកបូជាចារ្យលើកពែងព្រះលោហិតឡើងបង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់គោរព ។[២១៩]

---

[២១៨] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យ ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ ស្ដីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំជំនួសកាយវិការលុតជង្គង់ ។ គួរឱ្យគ្រីស្ដបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយ លោកបូជាចារ្យ ។

[២១៩] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ ១២៩១/៧៤ ស្ដីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំជំនួសកាយវិការលុតជង្គង់ ។ គួរឱ្យគ្រីស្ដបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយ លោកបូជាចារ្យ ។

១២១. លោកបូជាចារ្យច្រៀង ឬពោលបន្ទថា ៖

នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

អង្គប្រជុំឆ្លើយ ៖

ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

ឬ

ឱ ព្រះអម្ចាស់អើយ !
រៀងរាល់ពេល យើងខ្ញុំពិសានំប៉័ង និងពិសាពីពែងនេះ
យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

ឬ

ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !
ព្រះអង្គសោយទិវង្គតលើឈើឆ្កាង និងមានព្រះជន្មរស់ឡើងវិញ
ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។

១២២. លោកបូជាចារ្យលាតដៃ ដោយពោលបន្ត ៖

ឱ ព្រះអម្ចាស់អើយ !
ហេតុនេះហើយ បានជាយើងខ្ញុំរួមគ្នានៅពេលនេះ
ធ្វើពិធីរំឭកដល់ព្រះបុត្រាសង្គ្រោះយើងខ្ញុំ
គឺយើងខ្ញុំនឹករឭកដល់ព្រះគ្រីស្តសោយទិវង្គត និងយាងចុះទៅស្ថានក្រោម
យើងខ្ញុំសូមប្រកាសថា ព្រះអង្គមានព្រះជន្មរស់ឡើងវិញ
ហើយយាងឡើងទៅគង់ខាងស្តាំព្រះបិតា ។
នៅពេលយើងខ្ញុំទន្ទឹងរង់ចាំ ព្រះអង្គយាងមកប្រកបដោយសិរីរុងរឿង
យើងខ្ញុំសូមថ្វាយទៅព្រះបិតានូវព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត
ទុកជាសក្ការបូជាដែលគាប់ព្រះហឫទ័យព្រះអង្គ
និងសង្គ្រោះពិភពលោកទាំងមូល ។

បពិត្រព្រះបិតាជាអម្ចាស់ !
សូមព្រះអង្គសព្វព្រះហឫទ័យទតមកសក្ការបូជា
ដែលព្រះអង្គផ្ទាល់បានប្រទានដល់ព្រះសហគមន៍ព្រះអង្គ ។
សូមព្រះអង្គមេត្តាប្រោសឲ្យបងប្អូន
ដែលហៀបនឹងទទួលចំណែកពីនំប៉័ងតែមួយ និងពីពែងតែមួយនេះ
រួបរួមគ្នាទៅជារូបកាយតែមួយដោយព្រះវិញ្ញាណដ៏វិសុទ្ធ
បានទៅជាសក្ការបូជាដ៏ល្អឥតខ្ចោះ ដ៏មានជីវិតក្នុងអង្គព្រះគ្រីស្ត
ដើម្បីលើកតម្កើងសិរីរុងរឿងព្រះអង្គ ។

បពិត្រព្រះបិតាជាអម្ចាស់ !
សូមព្រះអង្គប្រោសប្រណីដល់អស់បងប្អូន
ដែលយើងខ្ញុំនឹករឭកនៅពេលថ្វាយសក្ការបូជានេះ
ជាបឋម សម្ដេចប៉ាបយើងខ្ញុំព្រះនាម... ជាអ្នកបម្រើព្រះអង្គ
លោកនាម... ជាអភិបាលព្រះសហគមន៍យើងខ្ញុំ[២២០]
និងក្រុមលោកអភិបាលទាំងឡាយ
អស់លោកបូជាចារ្យ លោកឧបដ្ឋាក
អស់អ្នកដែលរួមថ្វាយអភិបូជានៅទីនេះ
និងប្រជារាស្ត្រព្រះអង្គទាំងមូល
ដែលស្វែងរកព្រះអង្គដោយចិត្តស្មោះត្រង់ ។

សូមព្រះអង្គនឹករឭកដល់អស់បងប្អូនយើងខ្ញុំ
ដែលទទួលមរណភាពក្នុងសេចក្ដីសុខសាន្តរបស់ព្រះគ្រីស្ត
និងដល់អស់មរណបុគ្គល
មានតែព្រះអង្គទេដែលស្គាល់ជំនឿរបស់អ្នកទាំងនោះ ។

[២២០] នៅទីនេះ អាចបន្ថែមឈ្មោះរបស់លោកអភិបាលឧបត្ថម្ភក ឬអភិបាលជំនួយការផ្សេងៗ តាមពាក្យណែនាំនៃក្បួនពិធីបុណ្យលេខ ១៤៩ ។

ឱ ព្រះបិតាដ៏មានព្រះហឫទ័យសន្ដោសមេត្តាអើយ !
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំទាំងអស់គ្នាដែលជាបុត្រធីតាព្រះអង្គ បានទទួលជីវិតបរមសុខទុកជាមរតករួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី ដែលពោរពេញដោយសុភមង្គល ជាព្រះមាតាព្រះជាម្ចាស់
ជាមួយសន្ដយ៉ូសែបជាស្វាមីព្រះនាង
ជាមួយក្រុមគ្រីស្ដទូត និងអស់សន្ដបុគ្គលនៅក្នុងព្រះរាជ្យព្រះអង្គ ។

នៅទីនោះ រួមជាមួយសត្វលោកទាំងឡាយ
ដែលរួចចាកពីការវិនាសអន្ដរាយរបស់អំពើបាប និងសេចក្ដីស្លាប់
យើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
តាមរយៈព្រះគ្រីស្ដជាព្រះអម្ចាស់យើងខ្ញុំ
គឺដោយព្រះគ្រីស្ដនេះហើយ
ដែលព្រះបិតាប្រទានអ្វីៗដ៏ល្អគ្រប់បែបយ៉ាងដល់ពិភពលោក ។

១២៣. លោកបូជាចារ្យលើកចានព្រះកាយ និងពែងព្រះលោហិតក្នុងដៃទាំងពីរ ហើយពោលថា៖
ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ដ ជាមួយព្រះគ្រីស្ដ និងក្នុងអង្គព្រះគ្រីស្ដ
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៥៥៥)

# ពិធីទទួលព្រះកាយ និងព្រះលោហិត

Ritus Communionis

១២៤. លោកបូជាចារ្យដាក់ចានព្រះកាយ និងពែងព្រះលោហិតលើតុសក្ការៈ ហើយលោកប្រណម្យដៃ ដោយពោលថា ៖

តាមដំបូន្មានរបស់ព្រះយេស៊ូជាព្រះសង្គ្រោះ
និងតាមការប្រៀនប្រដៅរបស់ព្រះអង្គ យើងខ្ញុំហ៊ានទូលថា ៖

លោកបូជាចារ្យលាតដៃ ហើយរួមជាមួយអង្គប្រជុំសូត្របន្តថា ៖

**ឱ ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ !**
**សូមសម្តែងព្រះបារមីឲ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ**
**សូមឲ្យព្រះរាជ្យព្រះអង្គបានមកដល់**
**សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គ បានសម្រេចនៅលើផែនដី**
**ដូចនៅស្ថានបរមសុខដែរ។**
**សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ។**
**សូមអត់ទោសឲ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោសឲ្យអស់អ្នក**
**ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ។**
**សូមកុំបណ្តោយឲ្យយើងខ្ញុំ ចាញ់ការល្បួងឡើយ។**
**តែសូមរំដោះយើងខ្ញុំ ឲ្យរួចពីមារកំណាច។**

១២៥. លោកបូជាចារ្យលាតដៃ ហើយពោលម្នាក់ឯងថា ៖

ឱ ព្រះអម្ចាស់អើយ !
សូមប្រោសយើងខ្ញុំឲ្យរួចពីសេចក្តីអាក្រក់គ្រប់យ៉ាង
សូមឲ្យយើងខ្ញុំបានប្រកបដោយសេចក្តីសុខសាន្តក្នុងពេលរស់នៅសព្វថ្ងៃ
ដោយសារធម៌មេត្តាករុណារបស់ព្រះអង្គ
សូមឲ្យយើងខ្ញុំរួចពីបាបជានិច្ច និងផុតពីទុក្ខលំបាកទាំងឡាយ ។
យើងខ្ញុំទន្ទឹងរង់ចាំសុភមង្គលតាមសេចក្តីសង្ឃឹមរបស់យើង
គឺជាថ្ងៃដែលព្រះយេស៊ូគ្រីស្តជាព្រះសង្គ្រោះទ្រង់យាងមក ។

លោកបូជាចារ្យលើកដៃប្រណម្យ

លោកបូជាចារ្យប្រណម្យដៃ ហើយអង្គប្រជុំប្រកាសដោយខ្លាំងៗថា ៖
ដ្បិតព្រះអង្គគ្រងរាជ្យ ទ្រង់មានឫទ្ធានុភាព
និងសិរីរុងរឿងអស់កល្បជាអង្វែងតរៀងទៅ ។

១២៦. លោកបូជាចារ្យលាតដៃ ហើយពោលច្បាស់ៗថា ៖
ឱ ព្រះអម្ចាស់យេស៊ូគ្រីស្ដអើយ !
ព្រះអង្គមានព្រះបន្ទូលទៅកាន់ក្រុមគ្រីស្ដទូតថា ៖
«ខ្ញុំទុកសេចក្ដីសុខសាន្ដឲ្យអ្នករាល់គ្នា
ខ្ញុំផ្ដល់សេចក្ដីសុខសាន្ដរបស់ខ្ញុំឲ្យអ្នករាល់គ្នា» ។
សូមព្រះអង្គកុំប្រកាន់ទោសរបស់យើងខ្ញុំឡើយ
តែសូមទ្រង់ឈ្វេងយល់ នូវជំនឿរបស់ព្រះសហគមន៍ព្រះអង្គវិញ ។
សូមព្រះអង្គសព្វព្រះហឫទ័យប្រទានឲ្យព្រះសហគមន៍
បានប្រកបដោយសេចក្ដីសុខសាន្ដ និងបានមូលផ្ដុំគ្នាជាធ្លុងតែមួយ ។

លោកបូជាចារ្យប្រណម្យដៃ ៖
ព្រះអង្គមានព្រះជន្មគង់នៅ និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

១២៧. លោកបូជាចារ្យបែរមុខមករកអង្គប្រជុំ ។ លោកលាតដៃ ហើយប្រណម្យដៃទាំងពោលថា៖
សូមឲ្យសេចក្ដីសុខសាន្ដរបស់ព្រះអម្ចាស់ គង់នៅជាមួយបងប្អូន ។

អង្គប្រជុំឆ្លើយ ៖ ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

១២៨. តាមកាលៈទេស លោកឧបដ្ឋាក ឬលោកបូជាចារ្យពោលថា ៖
សូមបងប្អូនជូនសេចក្ដីសុខសាន្ដ ចំពោះគ្នាទៅវិញទៅមក ។

ពេលនោះ អង្គប្រជុំធ្វើកាយវិការមួយតាមប្រពៃណីក្នុងស្រុក ជូនសេចក្ដីសុខសាន្ដ ការឯកភាព និងធម៌មេត្តាករុណាចំពោះគ្នាទៅវិញទៅមក ។ លោកបូជាចារ្យធ្វើកាយវិការជូនសេចក្ដីសុខសាន្ដទៅកាន់លោកឧបដ្ឋាក ឬអ្នកបម្រើពិធីបុណ្យ ។

១២៩. លោកបូជាចារ្យកាច់នំព្រះកាយពីលើចានព្រះកាយ យកបំណែកតូចមួយ ដាក់ក្នុងពែងព្រះលោហិត ទាំងពោលខ្សឹបៗថា ៖

សូមឲ្យព្រះកាយ និងព្រះលោហិតរបស់ព្រះយេស៊ូគ្រីស្ត
ជាអម្ចាស់យើងខ្ញុំ ដែលរួមគ្នាក្នុងពែងនេះ
ផ្តល់ជីវិតអស់កល្បជានិច្ច ដល់យើងខ្ញុំជាអ្នកទទួលព្រះកាយ ។

១៣០. ក្នុងពេលដដែលនោះ អង្គប្រជុំច្រៀង ឬសូត្រដូចខាងក្រោមនេះ ។

ឱ កូនចៀមរបស់ព្រះជាម្ចាស់ ដែលដកបាបនៃពិភពលោក
សូមអាណិតអាសូយើងខ្ញុំ ។

ឱ កូនចៀមរបស់ព្រះជាម្ចាស់ ដែលដកបាបនៃពិភពលោក
សូមអាណិតអាសូរយើងខ្ញុំ ។

ឱ កូនចៀមរបស់ព្រះជាម្ចាស់ ដែលដកបាបនៃពិភពលោក
សូមប្រទានសេចក្តីសុខសាន្តឲ្យយើងខ្ញុំ ។

គេអាចច្រៀងបទនេះច្រើនដង រហូតដល់លោកបូជាចារ្យកាច់នំព្រះកាយ ហើយសូមបញ្ចប់ចម្រៀងដោយឃ្លា "សូមប្រទានសេចក្តីសុខសាន្តឲ្យយើងខ្ញុំ" ។

១៣១. លោកបូជាចារ្យប្រណម្យដៃ ហើយពោលខ្សឹបៗថា ៖

ឱ ព្រះអម្ចាស់យេស៊ូគ្រីស្ត !
ជាព្រះបុត្រានៃព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ
ព្រះអង្គប្រទានជីវិតឲ្យពិភពលោកទាំងមូល
ដោយសោយទិវង្គត តាមព្រះហឫទ័យព្រះបិតា
និងដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ។
សូមរំដោះខ្ញុំឲ្យរួចផុតពីបាប និងសេចក្តីអាក្រក់ទាំងឡាយ
ដោយសារព្រះកាយ និងព្រះលោហិតដ៏វិសុទ្ធបំផុតរបស់ព្រះអង្គ ។
សូមឲ្យខ្ញុំប្រព្រឹត្តតាមឱវាទរបស់ព្រះអង្គជានិច្ច កុំឲ្យខ្ញុំឃ្លាតឆ្ងាយពីព្រះអង្គឡើយ ។

ឬ

បពិត្រព្រះអម្ចាស់យេស៊ូគ្រីស្ត !
សូមឲ្យខ្ញុំដែលទទួលព្រះកាយ និងព្រះលោហិតរបស់ព្រះអង្គ
មិនមានទោស និងមិនទទួលទណ្ឌកម្មឡើយ
ផ្ទុយទៅវិញ តាមព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ
សូមឲ្យព្រះកាយ និងព្រះលោហិតទៅជាឱសថការពារ
និងព្យាបាលវិញ្ញាណព្រមទាំងរូបកាយរបស់ខ្ញុំ ។

១៣២. លោកបូជាចារ្យលុតជង្គង់យកព្រះកាយ ហើយលើកបន្តិចពីលើចានព្រះកាយ ឬពែងព្រះលោហិត បង្ហាញអង្គប្រជុំ ព្រមទាំងពោលច្បាស់ៗថា ៖

នេះជាកូនចៀមរបស់ព្រះជាម្ចាស់
នេះជាព្រះអង្គដែលដកបាបនៃពិភពលោក ។
អ្នកណាដែលព្រះជាម្ចាស់បានត្រាស់ហៅ
ឲ្យមកចូលរួមក្នុងពិធីជប់លៀងរបស់កូនចៀម
អ្នកនោះពិតជាមានសុភមង្គលហើយ ។

លោកបូជាចារ្យ រួមជាមួយអង្គប្រជុំ ពោលបន្តថា ៖

ឱ ព្រះអម្ចាស់អើយ !
ខ្ញុំមិនសមនឹងទទួលព្រះអង្គក្នុងផ្ទះខ្ញុំទេ
តែសូមព្រះអង្គមានព្រះបន្ទូលតែមួយព្រះឱស្ឋមក
នោះព្រលឹងខ្ញុំនឹងជាសះស្បើយ ។

១៣៣. លោកបូជាចារ្យបែរមុខទៅរកតុសក្ការៈ ទាំងពោលខ្សឹបៗថា ៖

សូមព្រះកាយព្រះគ្រីស្តរក្សាខ្ញុំទុកក្នុងជីវិតអស់កល្បជានិច្ច ។

លោកបូជាចារ្យ ទទួលព្រះកាយព្រះគ្រីស្តដោយគោរព ។

បន្ទាប់មក លោកបូជាចារ្យកាន់ពែងព្រះលោហិត ពោលខ្សឹបៗថា ៖

សូមព្រះលោហិតព្រះគ្រីស្តរក្សាខ្ញុំទុកក្នុងជីវិតអស់កល្បជានិច្ច ។

លោកបូជាចារ្យ ទទួលព្រះលោហិតព្រះគ្រីស្តដោយគោរព ។

១៣៤. លោកបូជាចារ្យកាន់ចានព្រះកាយ ឬក្លង/ប្រអប់តម្កល់ព្រះកាយ រួចដើរទៅកាន់អ្នកទទួលព្រះកាយ ។ លោកលើកព្រះកាយឡើងបន្តិចនៅមុខអ្នកទទួលព្រះកាយម្នាក់ៗ ហើយពោលថា ៖

ព្រះកាយព្រះគ្រីស្ត ។

អ្នកទទួលព្រះកាយឆ្លើយថា ៖ អាម៉ែន ។

រួចទទួលព្រះកាយ ។

ប្រសិនបើលោកឧបដ្ឋាកចែកព្រះកាយ លោកត្រូវធ្វើតាមរបៀបនេះដែរ ។

១៣៥. បើមានការទទួលទាំងព្រះកាយ ទាំងព្រះលោហិត សូមធ្វើត្រឹមត្រូវតាមក្បួនពិធីរបស់ព្រះ សហគមន៍ ។

១៣៦. ពេលលោកបូជាចារ្យទទួលព្រះកាយ គ្រីស្តបរិស័ទចាប់ផ្តើមច្រៀង ចម្រៀងទទួលព្រះកាយ ។

១៣៧. ពេលគ្រីស្តបរិស័ទទទួលព្រះកាយចប់ លោកបូជាចារ្យ ឬលោកឧបដ្ឋាក ឬអ្នកបម្រើទីសក្ការៈ ប្រមូលកម្ទេចពីចានព្រះកាយចូលពែងព្រះលោហិត បន្ទាប់មក លោកចាក់ទឹកជម្រះពែងព្រះលោហិត ទាំងពោលខ្សឹបៗថា ៖

បពិត្រព្រះអម្ចាស់ !

សូមឲ្យយើងខ្ញុំទទួលដោយចិត្តបរិសុទ្ធ នូវអ្វីដែលយើងខ្ញុំបានទទួលតាមមាត់

សូមឲ្យព្រះអំណោយទាននាបច្ចុប្បន្ននេះ

ទៅជាឱសថផ្តល់ជីវិតអស់កល្បជានិច្ចដល់យើងខ្ញុំ ។

១៣៨. លោកបូជាចារ្យ អាចត្រឡប់ទៅអង្គុយនៅកន្លែងចាប់ផ្តើមពិធីវិញ ។ តាមកាលៈទេសៈ (ឧ.តាមពេលវេលាដែលមាន) អង្គប្រជុំអាចរក្សាភាពស្ងៀមស្ងាត់មួយរយៈខ្លី ឬសូត្រទំនុកតម្កើង ឬច្រៀងបទកោតសរសើរ ឬច្រៀងបទផ្សេងទៀត ។

១៣៩. រួចលោកបូជាចារ្យឈរនៅក្បែរអាសនៈ ឬតុសក្ការៈ[២២១] ហើយបែរមុខទៅរកអង្គប្រជុំ ។ លោកលើកដៃប្រណម្យទាំងពោលថា ៖

សូមបងប្អូនតាំងចិត្តអធិដ្ឋាន...

អង្គប្រជុំរួមជាមួយលោកបូជាចារ្យ អធិដ្ឋានដោយស្ងៀមស្ងាត់បន្តិច ប្រសិនបើមិនទាន់បានរក្សាភាពស្ងៀមស្ងាត់ ។ បន្ទាប់មក លោកលាតដៃពោលពាក្យអរព្រះគុណព្រះជាម្ចាស់ ។

ចុងបញ្ចប់អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

[២២១] នៅប្រទេសកម្ពុជា លោកអាចអង្គុយនៅកន្លែងចាប់ផ្តើមពិធី ឬនៅតុសក្ការៈ ។

# ពិធីបញ្ចប់

Ritus conclusionis

១៤០. បើមានព័ត៌មាន សូមប្រកាសនៅពេលនេះ ។

១៤១. លោកបូជាចារ្យ ចាត់គ្រីស្តបរិស័ទឲ្យទៅ លោកបែរមុខទៅរកអង្គប្រជុំ ហើយលាតដៃទាំងពោលថា ៖

សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

អង្គប្រជុំឆ្លើយ ៖ ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

លោកបូជាចារ្យប្រទានពរដល់អង្គប្រជុំ ដោយពោលថា ៖

សូមព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ ប្រទានព្រះពរដល់អស់បងប្អូន គឺព្រះបិតា និងព្រះបុត្រា ≃ និងព្រះវិញ្ញាណដ៏វិសុទ្ធ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

១៤២. មានថ្ងៃខ្លះ ឬឱកាសខ្លះជាបុណ្យពិសេស លោកបូជាចារ្យអាចបន្ថែមពាក្យអធិដ្ឋានមុន ពេលប្រទានពរបញ្ចប់ (សូមមើលទំព័រ...) ដើម្បីធ្វើឲ្យពិធីកាន់តែឱឡារិក ។

១៤៣. ពេលលោកអភិបាល ជាអធិបតីក្នុងពិធីបុណ្យឱឡារិក លោកពាក់មួកអភិបាល ហើយលាតដៃទាំងពោលថា ៖

សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

អង្គប្រជុំឆ្លើយ ៖ ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

លោកពោលបន្តថា ៖

សូមលើកតម្កើងព្រះនាមព្រះអម្ចាស់ ។

អង្គប្រជុំឆ្លើយ ៖ តាំងពីពេលនេះ រហូតតទៅ ។

លោកពោលបន្តទៀតថា ៖

យើងខ្ញុំទទួលការសង្គ្រោះ មកពីព្រះនាមព្រះអម្ចាស់ ។

អង្គប្រជុំឆ្លើយ ៖ ជាព្រះដែលបានបង្កើតមេឃ និងដី ។

ប្រសិនបើ  ក្នុងពិធីមានដំបងគង្វាល  លោកអភិបាលជាអធិបតី  កាន់ដំបងគង្វាលនោះ  ហើយពោលថា ៖

សូមព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ ប្រទានព្រះពរដល់អស់បងប្អូន ។

លោកធ្វើសញ្ញាឈើឆ្កាងបីដងលើអង្គប្រជុំ ទាំងពោលថា ៖

**គឺព្រះបិតា ≅ និងព្រះបុត្រា ≅ និងព្រះវិញ្ញាណ ≅ ដ៏វិសុទ្ធ។**

អង្គប្រជុំឆ្លើយ ៖  អាម៉ែន ។

១៤៤. លោកឧបដ្ឋាក ឬលោកបូជាចារ្យលើកដៃប្រណម្យនៅមុខអង្គប្រជុំ ទាំងពោលថា៖

អភិបូជាចប់ហើយ ព្រះជាម្ចាស់បាត់បងប្អូនឲ្យទៅ ។

ឬ

សូមអញ្ជើញទៅ និងប្រកាសដំណឹងល្អរបស់ព្រះអម្ចាស់ ។

ឬ

សូមអញ្ជើញឲ្យបានសុខសាន្ត  និងលើកតម្កើងសិរីរុងរឿងព្រះអម្ចាស់ក្នុងជីវិតរបស់បងប្អូន ។

ឬ

សូមអស់បងប្អូនអញ្ជើញឲ្យបានសុខសាន្ត ។

អង្គប្រជុំឆ្លើយ ៖  សូមអរព្រះគុណព្រះជាម្ចាស់ ។

១៤៥. ក្រោយមក  តាមទម្លាប់លោកបូជាចារ្យគោរពដោយថើបតុសក្ការៈ[២២២]  ដូចនៅពេលចាប់ផ្ដើមពិធី ។ ជាទីបញ្ចប់  បន្ទាប់ពីឱនកាយនៅមុខតុសក្ការៈ  លោកបូជាចារ្យ និងអ្នកបម្រើពិធីបុណ្យចេញទៅ ។

១៤៦. បើសិនជាមានពិធីផ្សេងៗបន្ត សូមកុំធ្វើតាមលេខ ១៤៤ ។

[២២២] យោងតាមសាសនក្រិត្យលេខ១២៩១/៧៤ ព្រះសហគមន៍កម្ពុជាបានទទួលការអនុញ្ញាតឱ្យលោកបូជាចារ្យក្រាបថ្វាយបង្គំជំនួសការថើបតុសក្ការៈ ។

# ធម៌អរព្រះគុណដ៏វិសុទ្ធ
# បន្ថែមខាងចុងសៀវភៅក្នុងពិធីអភិបូជា

APPENDIX
AD ORDINEM MISSÆ

# ធម៌អរព្រះគុណដ៏វិសុទ្ធ
# « ផ្សះផ្សាមនុស្សលោកទី ១ »
# នៅក្នុងពិធីមានលោកបូជាចារ្យច្រើននាក់ចូលរួម

De modo proferendi
Precem eucharisticam « de reconciliatione » I
quando in concelebratione adhibetur

ធម៌ប្រារព្ធ និងអត្ថបទ ចាប់ពីពាក្យ "ឱ ព្រះអម្ចាស់អើយ ! ព្រះអង្គពិតជាវិសុទ្ធមែន" រហូតដល់ "ព្រះអង្គជាព្រះដ៏វិសុទ្ធដែរ" ។ មានតែលោកបូជាចារ្យជាអធិបតីប៉ុណ្ណោះ ដែលពោលពាក្យនេះ ដោយលាតដៃទាំងពីរ ។

អត្ថបទចាប់ពីពាក្យ "សូមព្រះអង្គមេត្តាទទួលតង្វាយ" រហូតដល់ "យើងខ្ញុំក៏ជាបុត្រធីតារបស់ព្រះអង្គដែរ" ។ លោកបូជាចារ្យអានរួមជាមួយគ្នា ដោយទ្រាបដៃលើតង្វាយ ។

អត្ថបទចាប់ពីពាក្យ "បពិត្រព្រះបិតា កាលពីមុន" រហូតដល់ "ដោយសារព្រះលោហិតព្រះអង្គដែលត្រូវបង្ហូរលើឈើឆ្កាង" លោកបូជាចារ្យទាំងអស់អានរួមជាមួយគ្នា តាមរបៀបដូចតទៅនេះ ៖

ក. អត្ថបទចាប់ពីពាក្យ "បពិត្រព្រះបិតា កាលពីមុន" រហូតដល់ "ធ្វើពិធីបុណ្យចម្លងជាមួយក្រុមសាវ័ក" លោកបូជាចារ្យលើកដៃប្រណម្យ ។

ខ. ពេលសូត្រធម៌ប្រសិទ្ធព្រះកាយ និងព្រះលោហិត លោកបូជាចារ្យម្នាក់ៗទ្រាបដៃស្ដាំតម្រង់ទៅរកនំ និងស្រាតង្វាយតាមការគួរ ។ ពេលលោកបូជាចារ្យអធិបតីលើកនំព្រះកាយ និងពែងព្រះលោហិត លោកទាំងអស់សម្លឹងមើលព្រះកាយ និងព្រះលោហិត ហើយឱនកាយគោរព ។

គ. អត្ថបទចាប់ពីពាក្យ "បពិត្រព្រះអម្ចាស់ដែលមានព្រះហឫទ័យ" រហូតដល់ពាក្យ "មនុស្សលែងបាក់បែកគ្នាទៀតហើយ" លោកអធិបតីលាតដៃទាំងពីរ ។

អំពីពាក្យអង្វរផ្សេងៗ ៖ អត្ថបទចាប់ពីពាក្យ "បពិត្រព្រះអម្ចាស់ សូមព្រះអង្គប្រោសយើងខ្ញុំ" រហូតដល់ "ដែលមានព្រះជន្មរស់ឡើងវិញអស់កល្បជានិច្ច" លោកបូជាចារ្យអាចចែកគ្នាអានពាក្យអង្វរនេះ ។ លោកលាតដៃនៅពេលអាន ។

យើងអាចច្រៀងអត្ថបទខ្លះៗ ដូចជាធម៌ប្រសិទ្ធព្រះកាយ និងព្រះលោហិត ព្រមទាំងធម៌បន្ទាប់ លើកលែងតែធម៌អង្វរ ។ ធម៌បញ្ចប់ក៏យើងអាចច្រៀងបញ្ចប់បានដែរ ។

អំពីធម៌បញ្ចប់នៃធម៌អរព្រះគុណដ៏វិសុទ្ធ មានតែលោកបូជាចារ្យអធិបតី ឬក្រុមបូជាចារ្យអាចច្រៀងបាន ។

# ធម៌អរព្រះគុណដ៏វិសុទ្ធ

## « ផ្សះផ្សាមនុស្សលោក »

PRECES EUCHARISTICÆ
« DE RECONCILIATIONE »

គេអាចប្រើធម៌នេះ នៅក្នុងអភិបូជា ដែលបង្ហាញអំពីគម្រោងការដ៏អស្ចារ្យនៃ ការសម្រុះសម្រួល ជាពិសេស ក្នុងអភិបូជាសម្រាប់សេចក្ដីសុខសាន្ត សម្រាប់ផ្សះផ្សាមនុស្សលោក សម្រាប់រក្សាសន្តិភាព និងយុត្តិធម៌នៅពេលមានសង្គ្រាម ឬចលាចល ក្នុងសង្គម សម្រាប់លើកលែងទោសឲ្យរួចពីបាប សម្រាប់សូមសេចក្ដីស្រឡាញ់ ហើយដើម្បីលើកតម្កើងគម្រោងការដ៏អស្ចារ្យនៃព្រះឈើឆ្កាង ដើម្បីលើកតម្កើងព្រះកាយ ឬដើម្បីលើកតម្កើងព្រះលោហិតរបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត ព្រមទាំងអភិបូជាក្នុងរដូវសែសិបថ្ងៃ ។ ទោះបីធម៌អរព្រះគុណដ៏វិសុទ្ធទាំងអស់នោះមានធម៌ប្រារព្ធហើយ ក៏យើងអាចប្រើធម៌ប្រារព្ធផ្សេងៗទៀត ដែលទាក់ទងនឹងការលើកលែងទោស និង កែប្រែចិត្តគំនិតដូចជាធម៌ប្រារព្ធនៅក្នុងរដូវសែសិបថ្ងៃ ។

## ទី ១

១. ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ !
ជាព្រះបិតាដ៏វិសុទ្ធបំផុត ជាព្រះជាម្ចាស់ដែលមានឫទ្ធានុភាព និងព្រះជន្មគង់នៅ
ពិតជាការគួរណាស់ហើយប្រពៃផង
ដែលយើងខ្ញុំសូមថ្លែងអំណរព្រះគុណព្រះអង្គ គ្រប់ពេលវេលា ។

ព្រះអង្គតែងតែជំរុញយើងខ្ញុំ ឲ្យទទួលជីវិតពេញបរិបូណ៌
ហើយដោយសារព្រះហឫទ័យអាណិតអាសូរច្រើនពន់ប្រមាណ
ព្រះអង្គលើកលែងទោសឲ្យយើងខ្ញុំ ព្រមទាំងអញ្ជើញអ្នកបាប
ឲ្យជឿសង្ឃឹមតែលើព្រះអង្គ ដែលអត់ទោសជានិច្ច ។
ព្រះអង្គមិនដែលបែរព្រះភ័ក្ត្រចេញពីយើងខ្ញុំទេ
ទោះបីយើងខ្ញុំបានផ្ដាច់សម្ពន្ធមេត្រីជាមួយព្រះអង្គច្រើនដង
ក៏ព្រះអង្គនៅតែចងចំណងជាមួយមនុស្សលោក
ជាសម្ពន្ធមេត្រីដ៏រឹងមាំដែលគ្មានអ្វីអាចផ្ដាច់បាន
គឺដោយសារព្រះយេស៊ូជាព្រះបុត្រា និងជាព្រះសង្គ្រោះយើងខ្ញុំ ។
ឥឡូវនេះ ព្រះអង្គនៅតែផ្ដល់ឲ្យប្រជារាស្ត្រព្រះអង្គ
មានឱកាសទទួលការប្រណីសន្ដោស និងឲ្យគេជម្រះជម្រាជាមួយព្រះអង្គ ។
នៅពេលគេបែរមករកព្រះអង្គវិញ
ទ្រង់ប្រទានឲ្យគេមានសេចក្ដីសង្ឃឹមក្នុងអង្គព្រះគ្រីស្ត
និងឲ្យគេចង់បម្រើមនុស្សទាំងអស់
ដោយទុកចិត្តកាន់តែខ្លាំងទៅលើព្រះវិញ្ញាណដ៏វិសុទ្ធ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមស្ញើចសរសើរ
និងលើកតម្កើងឫទ្ធានុភាពនៃសេចក្ដីស្រឡាញ់របស់ព្រះអង្គ
ទាំងប្រកាសអំណរសប្បាយ ព្រោះយើងខ្ញុំបានទទួលការសង្គ្រោះ ។
យើងខ្ញុំសូមចូលរួមជាមួយសន្តបុគ្គលទាំងឡាយ ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

២. លោកបូជាចារ្យលាតដៃ ដោយពោលថា ៖
ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គពិតជាព្រះដ៏វិសុទ្ធមែន
តាំងពីដើមរៀងមក ព្រះអង្គតែងតែប្រព្រឹត្តការដ៏ល្អប្រសើរ
ដើម្បីឲ្យមនុស្សបានវិសុទ្ធដូចព្រះអង្គ ជាព្រះដ៏វិសុទ្ធដែរ ។

៣. លោកបូជាចារ្យប្រណម្យដៃ ហើយទ្រាប់ដៃទាំងពីរលើតង្វាយ ។ លោកពោលថា ៖
សូមព្រះអង្គមេត្តាទទួលតង្វាយប្រជារាស្ត្រព្រះអង្គ ដោយអនុគ្រោះ
សូមចាក់បង្ហូរព្រះវិញ្ញាណប្រកបដោយឫទ្ធានុភាព មកញ៉ាំងតង្វាយទាំងនេះ
លោកបូជាចារ្យប្រណម្យដៃ ហើយធ្វើសញ្ញាឈើឆ្កាងលើនំ និងស្រាតង្វាយ ទាំងពោលថា ៖
ឲ្យទៅជាព្រះកាយ ≃ និងព្រះលោហិតព្រះយេស៊ូគ្រីស្ត

លោកបូជាចារ្យប្រណម្យដៃ
ជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ
គឺក្នុងអង្គព្រះបុត្រានេះ យើងខ្ញុំក៏ជាបុត្រធីតារបស់ព្រះអង្គដែរ ។

បពិត្រព្រះបិតា !
កាលពីមុនយើងខ្ញុំឃ្លាតឆ្ងាយពីព្រះអង្គ
ពុំអាចវិលមករកព្រះអង្គវិញបានទេ ។
ពេលនោះ ព្រះអង្គស្រឡាញ់យើងខ្ញុំយ៉ាងខ្លាំងបំផុត
គឺព្រះយេស៊ូជាព្រះបុត្រាព្រះអង្គ ជាមនុស្សសុចរិតតែម្នាក់គត់
បានប្រគល់ខ្លួនរហូតដល់សោយទិវង្គតដោយមិនរួញរា
ឲ្យគេបោះដែកគោលភ្ជាប់លើឈើឆ្កាងដើម្បីសង្គ្រោះយើងខ្ញុំ ។
តែមុននឹងព្រះយេស៊ូត្រដាងព្រះហស្ត
ជាចំណងរវាងស្ថានបរមសុខ និងផែនដី
ដើម្បីធ្វើជាសញ្ញាសម្គាល់នៃសម្ពន្ធមេត្រីអស់កល្បជានិច្ច
ទ្រង់សព្វព្រះហឫទ័យ ធ្វើពិធីបុណ្យចម្លងរួមជាមួយក្រុមសាវ័ក ។

៤. លោកបូជាចារ្យ ពោលពាក្យនីមួយៗឲ្យបានច្បាស់ត្រូវតាមអត្ថន័យ នៃព្រះបន្ទូលនេះ ។
ពេលព្រះយេស៊ូជប់លៀង

លោកបូជាចារ្យលើកនំតង្វាយឡើងបន្តិចពីតុសក្ការៈ ដោយពោលបន្តថា៖
ព្រះអង្គយកនំប៉័ងមកកាន់
អរព្រះគុណ និងលើកតម្កើងព្រះបិតា
រួចកាច់នំប៉័ងប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យ ឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។**

លោកបូជាចារ្យ លើកព្រះកាយឡើងបង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់[២២៣] ។

៥. បន្ទាប់មក លោកបូជាចារ្យពោលបន្ត ៖
នៅពេលចុងក្រោយនៃពិធីជប់លៀងនេះ
ព្រះយេស៊ូជ្រាបថា ទ្រង់នឹងផ្សះផ្សាអ្វីៗទាំងអស់ឲ្យជានានឹងព្រះអង្គ
ដោយសារព្រះលោហិតព្រះអង្គ ដែលត្រូវបង្ហូរនៅលើឈើឆ្កាង

លោកបូជាចារ្យ លើកពែងព្រះលោហិតឡើងបន្តិចពីតុសក្ការៈ ដោយពោលបន្តថា ៖
ព្រះអង្គលើកពែងស្រាឡើង
អរព្រះគុណព្រះបិតាម្តងទៀត
ហើយប្រទានពែងស្រាឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

[២២៣] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ១២៩១/៧៤ ស្តីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំជំនួសកាយវិការលុតជង្គង់ គួរឱ្យគ្រីស្តបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយលោកបូជាចារ្យ ។

លោកបូជាចារ្យឱនកាយបន្តិច

## សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ
## នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ពន្ធមេត្រីថ្មី
## និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ
## ដើម្បីលើកលែងទោសអ្នករាល់គ្នា
## និងមនុស្សច្រើនឥតគណនាឲ្យបានរួចពីបាប ។
## សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ ។

លោកបូជាចារ្យ លើកពែងព្រះលោហិតឡើងបង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់[២២៤] ។

៦. លោកបូជាចារ្យច្រៀង ឬពោលបន្តថា ៖
នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

អង្គប្រជុំឆ្លើយ ៖
ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

ឬ
ឱ ព្រះអម្ចាស់អើយ !
រៀងរាល់ពេល យើងខ្ញុំពិសានំបុ័ង និងពិសាពីពែងនេះ
យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

---

[២២៤] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ១២៩១/៧៤ ស្ដីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំជំនួសកាយវិការលុតជង្គង់ គួរឱ្យគ្រីស្ដបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយលោកបូជាចារ្យ ។

ឬ

ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !
ព្រះអង្គសោយទិវង្គតលើឈើឆ្កាង និងមានព្រះជន្មរស់ឡើងវិញ
ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។

៧. លោកបូជាចារ្យលាតដៃ ដោយពោលបន្តថា ៖

បពិត្រព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្មោះត្រង់ជានិច្ច !
នៅពេលនេះ យើងខ្ញុំនាំគ្នានឹករឭកដល់ព្រះយេស៊ូគ្រីស្ត
ជាព្រះបុត្រារបស់ព្រះអង្គ ជាសក្ការបូជានៃបុណ្យចម្លង
និងជាសេចក្ដីសុខសាន្តជាស្ថាពររបស់យើងខ្ញុំ
យើងខ្ញុំក៏សូមលើកតម្កើងព្រះអង្គដែលសោយទិវង្គត
និងមានព្រះជន្មរស់ឡើងវិញពីចំណោមមនុស្សស្លាប់ ។

ពេលយើងខ្ញុំទន្ទឹងរង់ចាំថ្ងៃពោរពេញដោយអំណរ ដែលព្រះគ្រីស្តយាងមក
យើងខ្ញុំសូមថ្វាយសក្ការបូជាដែលធ្វើឲ្យមនុស្សលោក
និងព្រះជាម្ចាស់មានមេត្រីភាពឡើងវិញ ។

បពិត្រព្រះបិតាដ៏មានព្រះហឫទ័យសប្បុរសយ៉ាងលើសលប់ !
សូមព្រះអង្គមេត្តាទតមើលអស់អ្នក ដែលព្រះអង្គបានបង្រួបបង្រួម
តាមរយៈសក្ការបូជារបស់ព្រះបុត្រាព្រះអង្គ ។
ដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ
សូមប្រោសអ្នកទាំងនោះ ដែលទទួលចំណែកពីនំប៉័ងតែមួយ
និងពែងតែមួយឲ្យទៅជារូបកាយតែមួយក្នុងអង្គព្រះគ្រីស្ត
គឺក្នុងព្រះកាយព្រះគ្រីស្តនេះ មនុស្សលែងបាក់បែកគ្នាទៀតហើយ ។

បពិត្រព្រះជាអម្ចាស់ !
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យមានចិត្តថ្លើមតែមួយ
រួមជាមួយសម្ដេចប៉ាបយើងខ្ញុំព្រះនាម...
និងលោកនាម... ជាអភិបាលព្រះសហគមន៍យើងខ្ញុំ ។ [២២៥]
សូមជួយយើងខ្ញុំឲ្យរៀបចំផ្លូវទទួលព្រះរាជ្យព្រះអង្គ
រហូតដល់ពេលយើងខ្ញុំទៅជាសន្តបុគ្គលនៅចំពោះព្រះភ័ក្ត្រព្រះអង្គ
ក្នុងចំណោមសន្តបុគ្គលទាំងឡាយនៅឯស្ថានបរមសុខ
រួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី ដែលពោរពេញដោយសុភមង្គល
ជាមាតាព្រះជាម្ចាស់ អស់គ្រីស្ដទូត និងជនដ៏វិសុទ្ធទាំងឡាយ
ព្រមទាំងបងប្អូន ដែលបានទទួលមរណភាព ជាអស់អ្នកដែលយើងខ្ញុំ
សូមផ្ញើទៅលើព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ ។
ពេលនោះ ព្រះអង្គរំដោះយើងខ្ញុំឲ្យរួចផុតពីរបួសនៃសភាពរលួយ
ហើយបង្កើតយើងខ្ញុំឲ្យមានជីវិតថ្មីពេញលក្ខណៈ ។
យើងខ្ញុំនឹងច្រៀងដោយអំណរ និងអរព្រះគុណព្រះបិតា

លោកបូជាចារ្យប្រណម្យដៃ
រួមជាមួយព្រះគ្រីស្ត ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

៨. លោកបូជាចារ្យលើកចានព្រះកាយ និងពែងព្រះលោហិតក្នុងដៃទាំងពីរ ហើយពោលថា ៖
ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៥៥៥ )

---

[២២៥] នៅទីនេះ អាចបន្ថែមឈ្មោះរបស់លោកអភិបាលឧបត្ថម្ភក ឬអភិបាលជំនួយការផ្សេងៗ តាមពាក្យណែនាំនៃក្បួនពិធីបុណ្យ លេខ ១៤៩។

# ធម៌អរព្រះគុណដ៏វិសុទ្ធ
# « ផ្សះផ្សាមនុស្សលោកទី ២ »
# នៅក្នុងពិធីមានលោកបូជាចារ្យច្រើននាក់ចូលរួម

De modo proferendi
Precem eucharisticam « de reconciliatione » II
quando in concelebratione adhitetur

ធម៌ប្រារព្ធ និងអត្ថបទចាប់ពីពាក្យ "បពិត្រព្រះបិតា ប្រកបដោយឫទ្ធានុភាពសព្វប្រការ" រហូតដល់ "គឺព្រះបុត្រាដែលព្រះអង្គបញ្ជូនឲ្យគេធ្វើគុត ដើម្បីជាប្រយោជន៍ដល់យើងខ្ញុំ" ។ មានតែលោកបូជាចារ្យជាអធិបតីប៉ុណ្ណោះ ដែលពោលពាក្យនេះ ដោយលាតដៃទាំងពីរ ។

អត្ថបទចាប់ពីពាក្យ "ឥឡូវនេះ យើងខ្ញុំនាំគ្នាលើកតម្កើងព្រះគ្រីស្តដែលបានផ្សះផ្សា" រហូតដល់ "ដែលបានបង្គាប់ឲ្យយើងខ្ញុំធ្វើពិធីអរព្រះគុណ ចំពោះសេចក្តីពិតដែលព្រះអង្គបានសម្តែង" លោកបូជាចារ្យអានរួមជាមួយគ្នា ដោយទ្រាបដៃលើតង្វាយ ។

អត្ថបទចាប់ពីពាក្យ "មុនបូជាព្រះជន្មដើម្បីរំដោះយើងខ្ញុំ ព្រះយេស៊ូជប់លៀង" រហូតដល់ "ដែលផ្សះផ្សាយើងខ្ញុំ និងព្រះអង្គបានល្អឥតខ្ចោះ" លោកបូជាចារ្យទាំងអស់អានរួមជាមួយគ្នា តាមរបៀបដូចតទៅនេះ ៖

ក. អត្ថបទចាប់ពីពាក្យ "មុនបូជាព្រះជន្មដើម្បីរំដោះយើងខ្ញុំ ព្រះយេស៊ូជប់លៀង" រហូតដល់ "ហើយកាច់ប្រទានឲ្យក្រុមសាវ័ក ទាំងមានព្រះបន្ទូលថា" លោកបូជាចារ្យលើកដៃប្រណម្យ ។

ខ. ពេលសូត្រធម៌ប្រសិទ្ធព្រះកាយនិងព្រះលោហិត លោកបូជាចារ្យម្នាក់ៗទ្រាបដៃស្តាំតម្រង់ទៅរកនំ និងស្រាតង្វាយតាមការគួរ ។ ពេលលោកបូជាចារ្យអធិបតីលើកនំព្រះកាយ និងពែងព្រះលោហិត លោកទាំងអស់សម្លឹងមើលព្រះកាយ និងព្រះលោហិត ហើយឱនកាយគោរព ។

គ. អត្ថបទចាប់ពីពាក្យ "នៅពេលយើងខ្ញុំនឹករឭកដល់ព្រះបុត្រាព្រះអង្គសោយទិវង្គត" រហូតដល់ពាក្យ "ដែលផ្សះផ្សាយើងខ្ញុំ និងព្រះអង្គបានល្អឥតខ្ចោះ" លោកអធិបតីលាតដៃទាំងពីរ ។

អំពីពាក្យអង្វរផ្សេងៗ ៖ អត្ថបទចាប់ពីពាក្យ "យើងខ្ញុំសូមទូលអង្វរព្រះអង្គ" រហូតដល់ "ដែលពោរពេញដោយសេចក្តីសុខសាន្តដ៏ភ្លឺស្វាងរបស់ព្រះអង្គ" លោកបូជាចារ្យអាចចែកគ្នាអានពាក្យអង្វរនេះ លោកលាតដៃនៅពេលអាន ។

យើងអាចច្រៀងអត្ថបទខ្លះៗ ដូចជាធម៌ប្រសិទ្ធព្រះកាយ និងព្រះលោហិត ព្រមទាំងធម៌បន្ទាប់ លើកលែងតែធម៌អង្វរ ។ ធម៌បញ្ចប់ក៏យើងអាចច្រៀងបញ្ចប់បានដែរ ។

អំពីធម៌បញ្ចប់នៃធម៌អរព្រះគុណដ៏វិសុទ្ធ មានតែលោកបូជាចារ្យអធិបតី ឬក្រុមបូជាចារ្យអាចច្រៀងបាន ។

# ធម៌អរព្រះគុណដ៏វិសុទ្ធ
# « ផ្សះផ្សាមនុស្សលោក »

PREX EUCHARISTICA
« DE RECONCILIATIONE »

## ទី ២

១. ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ពិតជាការគួរណាស់ហើយប្រពៃផង
ដែលយើងខ្ញុំសូមថ្លែងអំណរព្រះគុណ និងលើកតម្កើងព្រះអង្គ
ដោយសារអ្វីៗទាំងអស់ ដែលព្រះអង្គប្រព្រឹត្តក្នុងពិភពលោកនេះ
តាមរយៈព្រះយេស៊ូគ្រីស្ត និងជាអម្ចាស់យើងខ្ញុំ ។

ទោះបីមនុស្សបាក់បែកគ្នា បែកហួរគ្នាក៏ដោយ
យើងខ្ញុំដឹងច្បាស់ថា តាមរយៈការពិសោធន៍ទាំងនេះ
ព្រះអង្គប្រែចិត្តគំនិតយើងខ្ញុំឲ្យប្រុងប្រៀបផ្សះផ្សាគ្នាវិញ ។
ប្រាកដមែន ព្រះវិញ្ញាណព្រះអង្គជម្រុញចិត្តមនុស្ស
ធ្វើឲ្យខ្មាំងសត្រូវនិយាយរកគ្នា ឲ្យអ្នកប្រឆាំងគ្នាចាប់ដៃគ្នា
ឲ្យប្រជាជនដែលទាស់ទែងគ្នា សុខចិត្តចាប់ផ្ដើមធ្វើដំណើរជាមួយគ្នាវិញ ។

បពិត្រព្រះអម្ចាស់ !
គឺឫទ្ធានុភាពរបស់ព្រះអង្គដែលណែនាំឲ្យមនុស្សសុខចិត្តស្រឡាញ់គ្នា
ជាជាងស្អប់គុំកួនគ្នា សុខចិត្តអត់ទោសឲ្យគ្នា ជាជាងសងសឹកគ្នា
សុខចិត្តរាប់អានគ្នា ជាជាងបាក់បែកគ្នា ។
ហេតុនេះហើយ បានជាយើងខ្ញុំសូមអរព្រះគុណ
និងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ឥតឈប់ឈរ
រួមជាមួយមហាជនដ៏ច្រើនកុះករនៅស្ថានបរមសុខ ដោយប្រកាសថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

២. លោកបូជាចារ្យលាតដៃ ដោយពោលថា ៖
បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំសូមលើកតម្កើងព្រះអង្គ តាមរយៈព្រះយេស៊ូគ្រីស្តជាព្រះបុត្រា
ដែលយាងមកក្នុងព្រះនាមព្រះអង្គ ។
ព្រះយេស៊ូពិតជាព្រះបន្ទូលដែលសង្គ្រោះមនុស្សលោក
ព្រះយេស៊ូពិតជាព្រះហស្តរបស់ព្រះបិតា ឈោងទៅរកអ្នកបាប ។
ព្រះយេស៊ូពិតជាមាគ៌ា ដែលប្រទានសេចក្តីសុខសាន្តរបស់ព្រះបិតាឲ្យយើងខ្ញុំ ។

បពិត្រព្រះអម្ចាស់ !
នៅពេលយើងខ្ញុំឃ្លាតឆ្ងាយពីព្រះអង្គ ព្រោះតែអំពើបាប
ទ្រង់បាននាំយើងខ្ញុំវិលមកវិញឲ្យផ្សះផ្សាជាមួយព្រះអង្គ
គឺដោយសារព្រះបុត្រា ដែលព្រះអង្គបានបញ្ជូនឲ្យគេធ្វើគុត
យើងខ្ញុំបានបែរមករកព្រះអង្គ ហើយអាចស្រឡាញ់គ្នាទៅវិញទៅមក ។

៣. លោកបូជាចារ្យប្រណម្យដៃ ហើយទ្រាបដៃទាំងពីរលើតង្វាយ ។ លោកពោលថា ៖

ឥឡូវនេះ យើងខ្ញុំនាំគ្នាលើកតម្កើងព្រះគ្រីស្ត
ដែលបានជប់ជុំជ្រះផ្សាយើងខ្ញុំជាមួយព្រះអង្គ
យើងខ្ញុំក៏សូមអង្វរព្រះអង្គ
សូមទ្រង់ព្រះមេត្តាប្រោសព្រះវិញ្ញាណរបស់ព្រះអង្គ
យាងមកញាំងតង្វាយទាំងនេះ ឲ្យបានវិសុទ្ធ

លោកបូជាចារ្យប្រណម្យដៃ ហើយធ្វើសញ្ញាឈើឆ្កាងលើនំ និងស្រាតង្វាយ ទាំងពោលថា៖

និងឲ្យទៅជាព្រះកាយ ≅ និងព្រះលោហិតព្រះបុត្រាព្រះអង្គ
ដែលបានបង្គាប់ឲ្យយើងខ្ញុំ ធ្វើពិធីលើកតម្កើងគម្រោងការដ៏អស្ចារ្យនេះ ។

លោកបូជាចារ្យប្រណម្យដៃ

៤. លោកបូជាចារ្យ ពោលពាក្យនីមួយៗឲ្យបានច្បាស់ត្រូវតាមអត្ថន័យ នៃព្រះបន្ទូលនេះ ។

មុនបូជាព្រះជន្មដើម្បីរំដោះយើងខ្ញុំ
ព្រះយេស៊ូជប់លៀង

លោកបូជាចារ្យលើកនំតង្វាយឡើងបន្តិចពីតុសក្ការៈ ដោយពោលបន្តថា៖

ព្រះអង្គយកនំប៉័ងមកកាន់
អរព្រះគុណព្រះបិតា
ហើយកាច់ប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យ ឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ**
**ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។**

លោកបូជាចារ្យ លើកព្រះកាយឡើងបង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់[២២៦] ។

---

[២២៦] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ១២៩១/៧៤ ស្ដីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំជំនួសកាយវិការលុតជង្គង់ គួរឱ្យគ្រីស្តបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយលោកបូជាចារ្យ ។

៥. បន្ទាប់មកលោកបូជាចារ្យពោលបន្ត ៖

នៅពេលយប់នោះ ព្រះអង្គធ្វើតាមរបៀបដដែល

លោកបូជាចារ្យ លើកពែងព្រះលោហិតឡើងបន្តិចពីតុសក្ការៈ ដោយពោលបន្តថា ៖

ព្រះអង្គយកពែងស្រាមកកាន់

អរព្រះគុណ និងលើកតម្កើងព្រះបិតា

ហើយប្រទានឲ្យក្រុមសាវ័ក ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ**

**នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ព័ន្ធមេត្រីថ្មី**

**និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ**

**ដើម្បីលើកលែងទោសអ្នករាល់គ្នា**

**និងមនុស្សច្រើនឥតគណនាឲ្យបានរួចពីបាប។**

**សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ។**

លោកបូជាចារ្យលើកពែងព្រះលោហិតឡើង បង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់[២២៧] ។

៦. លោកបូជាចារ្យច្រៀង ឬពោលបន្តថា ៖

នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

អង្គប្រជុំឆ្លើយ ៖

ឱ ព្រះអម្ចាស់អើយ !

យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ

ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

---

[២២៧] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ១៩៧៤ លេខ១២៩១/៧៤ ស្ដីពីពិធីបុណ្យនៅកម្ពុជា និងឡាវ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំជំនួសកាយវិការលុតជង្គង់ គួរឱ្យគ្រីស្តបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយលោកបូជាចារ្យ ។

ឬ

ឱ ព្រះអម្ចាស់អើយ ! រៀងរាល់ពេល យើងខ្ញុំពិសានំបុ័ង និងពិសាពីពែងនេះ
យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

ឬ

ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !
ព្រះអង្គសោយទិវង្គតលើឈើឆ្កាង និងមានព្រះជន្មរស់ឡើងវិញ
ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។

៧. លោកបូជាចារ្យលាតដៃ ដោយពោលបន្តថា ៖

នៅពេលយើងខ្ញុំនឹករឭកដល់ព្រះបុត្រាព្រះអង្គ
សោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
ធ្វើជាសញ្ញាបញ្ជាក់ពីសេចក្ដីស្រឡាញ់របស់ព្រះអង្គចំពោះយើងខ្ញុំ
យើងខ្ញុំសូមថ្វាយទៅព្រះអង្គនូវអ្វី ដែលព្រះអង្គបានប្រទានឲ្យយើងខ្ញុំ
គឺសក្ការបូជារបស់ព្រះគ្រីស្ដដែលផ្សះផ្សាយើងខ្ញុំនឹងព្រះអង្គ បានល្អឥតខ្ចោះ ។
បពិត្រព្រះបិតាដ៏វិសុទ្ធ !
យើងខ្ញុំសូមទូលអង្វរព្រះអង្គ សូមព្រះអង្គមេត្តាទទួលយើងខ្ញុំ
រួមជាមួយព្រះបុត្រាព្រះអង្គ ហើយក្នុងពិធីជប់លៀងដែលផ្ដល់ការសង្គ្រោះនេះ
សូមព្រះអង្គមេត្តាប្រទានព្រះវិញ្ញាណរបស់ព្រះបុត្រាឲ្យយើងខ្ញុំ
សូមព្រះវិញ្ញាណបំបាត់ហេតុទាំងឡាយ ដែលបណ្ដាលឲ្យយើងខ្ញុំបាក់បែកគ្នា ។
សូមព្រះវិញ្ញាណប្រោសឲ្យព្រះសហគមន៍ ទៅជាសញ្ញានៃការរួបរួមគ្នា
ហើយជាឧបករណ៍ ដែលនាំសេចក្ដីសុខសាន្តរបស់ព្រះអង្គដល់មនុស្សលោក ។
សូមឲ្យយើងខ្ញុំរួបរួមជាធ្លុងតែមួយ ជាមួយសម្ដេចប៉ាបយើងខ្ញុំព្រះនាម...
និងលោកនាម...ជាអភិបាលព្រះសហគមន៍យើងខ្ញុំ[២២៨]
ជាមួយលោកអភិបាលទាំងអស់
ព្រមទាំងជាមួយប្រជារាស្ដ្រទាំងមូលរបស់ព្រះអង្គផង ។

---

[២២៨] នៅទីនេះ អាចបន្ថែមឈ្មោះរបស់លោកអភិបាលឧបត្ថម្ភក ឬអភិបាលជំនួយការផ្សេងៗ តាមពាក្យណែនាំនៃក្បួនពិធីបុណ្យ លេខ ១៤៩។

នៅពេលនេះ ព្រះអង្គបានប្រមូលផ្តុំយើងខ្ញុំ
ឲ្យចូលរួមតុសក្ការៈរបស់ព្រះបុត្រាព្រះអង្គ
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ បានចូលរួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី
ពោរពេញដោយសិរីរុងរឿង ដែលពោរពេញដោយសុភមង្គល
ជាមាតាព្រះជាម្ចាស់ ជាមួយក្រុមគ្រីស្តទូត និងសន្តបុគ្គលទាំងអស់
ព្រមទាំងបងប្អូនយើងខ្ញុំ និងមនុស្សគ្រប់ជាតិសាសន៍ គ្រប់ភាសា
ដែលបានលាចាកលោកនេះ ក្នុងមេត្រីភាពរបស់ព្រះអង្គ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ បានចូលរួមជាមួយអស់អ្នកទាំងនោះ
ក្នុងពិធីជប់លៀងរួមគ្នាឥតឈប់ឈរ នៅឯផ្ទៃមេឃថ្មី និងផែនដីថ្មី
ដែលពោរពេញដោយសេចក្តីសុខសាន្តដ៏ភ្លឺស្វាងរបស់ព្រះអង្គ

លោកបូជាចារ្យប្រណម្យដៃ

ក្នុងអង្គព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់យើងខ្ញុំ ។

៨. លោកបូជាចារ្យលើកចានព្រះកាយ និងពែងព្រះលោហិតក្នុងដៃទាំងពីរ ហើយពោលថា ៖

ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៥៥៥)

# ធម៌អរព្រះគុណដ៏វិសុទ្ធ « ប្រើក្នុងឱកាសផ្សេងៗ » នៅក្នុងពិធីមានលោកបូជាចារ្យច្រើននាក់ចូលរួម

De modo proferendi Precem eucharisticam
qux in Missis pro variis necessitatibus adhiberi potest
quando in concelebratione adhibetur

ធម៌ប្រារព្ធ និងអត្ថបទចាប់ពីពាក្យ "ព្រះអង្គពិតជាព្រះដ៏វិសុទ្ធ" រហូតដល់ "ទ្រង់យកនំប៉័ងមកកាច់" ។ មានតែលោកបូជាចារ្យជាអធិបតីប៉ុណ្ណោះ ដែលពោលពាក្យនេះ ដោយលាតដៃទាំងពីរ ។

អត្ថបទចាប់ពីពាក្យ "ឱ ព្រះបិតាប្រកបដោយធម៌មេត្តាករុណា" រហូតដល់ "ព្រះអម្ចាស់យេស៊ូគ្រីស្ត សម្រាប់យើងខ្ញុំ" ។ លោកបូជាចារ្យអានរួមជាមួយគ្នា ដោយទ្រាបដៃលើតង្វាយ ។

អត្ថបទចាប់ពីពាក្យ "ពេលយប់ក្រោយបង្អស់មុនព្រះយេស៊ូសោយទិវង្គត" រហូតដល់ "គឺនៅក្នុងព្រះកាយ និងព្រះលោហិតព្រះអង្គ ដែលយើងខ្ញុំរួបរួមគ្នាជាផ្លូងតែមួយ" លោកបូជាចារ្យទាំងអស់អានរួមជាមួយគ្នា តាមរបៀបដូចតទៅនេះ ៖

ក. អត្ថបទចាប់ពីពាក្យ "មុនព្រះយេស៊ូសោយទិវង្គត" លោកបូជាចារ្យលើកដៃប្រណម្យ ។
ខ. ពេលសូត្រធម៌ប្រសិទ្ធព្រះកាយ និងព្រះលោហិត លោកបូជាចារ្យម្នាក់ៗទ្រាបដៃស្ដាំតម្រង់ទៅរកនំ និងស្រាតង្វាយតាមការគួរ ។ ពេលលោកបូជាចារ្យអធិបតីលើកនំព្រះកាយ និងពែងព្រះលោហិត លោកទាំងអស់សម្លឹងមើលព្រះកាយ និងព្រះលោហិត ហើយឱនកាយគោរព ។
គ. អត្ថបទចាប់ពីពាក្យ "បពិត្រព្រះបិតាដ៏វិសុទ្ធ" រហូតដល់ពាក្យ "សូមទ្រង់ទតមើលតង្វាយរបស់ព្រះសហគមន៍ព្រះអង្គដោយអនុគ្រោះ" ។ លោកអធិបតីលាតដៃទាំងពីរ ។

អំពីពាក្យអង្វរផ្សេងៗ ៖ អត្ថបទចាប់ពីពាក្យ "បពិត្រព្រះអម្ចាស់ ! សូមប្រោសឲ្យព្រះសហគមន៍របស់ព្រះអង្គមានកម្លាំងថ្មី" ឬ "សូមព្រះអង្គនឹកដល់អស់បងប្អូនយើងខ្ញុំ" ។ លោកបូជាចារ្យអាចចែកគ្នាអានពាក្យអង្វរនេះ ។ លោកលាតដៃនៅពេលអាន ។

យើងអាចច្រៀងអត្ថបទខ្លះៗដូចជា ធម៌ប្រសិទ្ធព្រះកាយ និងព្រះលោហិត ព្រមទាំងធម៌បន្ទាប់ លើកលែងតែធម៌អង្វរ ។ ធម៌បញ្ចប់ក៏យើងអាចច្រៀងបញ្ចប់បានដែរ ។

អំពីធម៌បញ្ចប់នៃធម៌អរព្រះគុណដ៏វិសុទ្ធ មានតែលោកបូជាចារ្យអធិបតី ឬក្រុមបូជាចារ្យអាចច្រៀងបាន ។

# ធម៌អរព្រះគុណដ៏វិសុទ្ធ
# ប្រើក្នុងឱកាសផ្សេងៗ

PREX EUCHARISTICA QUÆ IN MISSIS
PRO VARIIS NECESSITATIBUS ADHIBERI POTEST

## ទី ១

## ព្រះសហគមន៍កំពុងធ្វើដំណើរទៅរកឯកភាព

Ecclesia in viam unitatis progrediens

១. ធម៌អរព្រះគុណខាងក្រោមនេះ ប្រើក្នុងឱកាសដូចជា ៖
អភិបូជាសម្រាប់ព្រះសហគមន៍ អភិបូជាសម្រាប់សម្ដេចប៉ាប
អភិបូជាសម្រាប់លោកអភិបាល អភិបូជាសម្រាប់ជ្រើសរើសសម្ដេចប៉ាប ឬលោកអភិបាល
អភិបូជាសម្រាប់មហាសន្និបាត អភិបូជាសម្រាប់ក្រុមបូជាចារ្យ
អភិបូជាសម្រាប់លោកបូជាចារ្យផ្ទាល់ខ្លួន អភិបូជាសម្រាប់អ្នកបម្រើព្រះសហគមន៍
អភិបូជាសម្រាប់សំណាក់ធម៌ ឬសេចក្ដីត្រូវការផ្សេងៗរបស់ព្រះសហគមន៍ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏សប្បុរសយ៉ាងក្រៃលែង !
ពិតជាការគួរណាស់ ហើយប្រពៃផង ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គ
និងច្រៀងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដ្បិតតាមព្រះបន្ទូលដំណឹងល្អរបស់ព្រះបុត្រាព្រះអង្គ
ទ្រង់បានប្រមូលផ្ដុំមនុស្សគ្រប់ជាតិសាសន៍ គ្រប់ភាសា
គ្រប់អរិយធម៌ឲ្យទៅជាព្រះសហគមន៍តែមួយ ។

ព្រះអង្គបានប្រទានឲ្យព្រះសហគមន៍មានជីវិតរស់រវើក
ដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ហើយតាមរយៈព្រះសហគមន៍នេះ
ព្រះអង្គតែងតែប្រមែប្រមូលមនុស្សទាំងអស់ឲ្យទៅជាគ្រួសារតែមួយ ។
ព្រះសហគមន៍តែងតែបង្ហាញសម្ពន្ធមេត្រី នៃសេចក្ដីស្រឡាញ់របស់ព្រះអង្គ ។
ដូច្នេះជារៀងរហូត ព្រះសហគមន៍ផ្ដល់សេចក្ដីសង្ឃឹមនៃព្រះរាជ្យ
និងធ្វើជាសញ្ញាដ៏ភ្លឺស្វាងនៃព្រះហឫទ័យស្មោះត្រង់
ដែលព្រះអង្គបានសន្យាថា នឹងស្ថិតស្ថេរអស់កល្បជានិច្ច
តាមរយៈព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំនៅលើផែនដី
រួមជាមួយព្រះសហគមន៍ទាំងអស់ និងឫទ្ធានុភាពទាំងឡាយឯស្ថានបរមសុខ
សូមលើកតម្កើងព្រះអង្គឥតឈប់ឈរ ដោយសូរសព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

២. លោកបូជាចារ្យលាតដៃ ដោយពោលថា ៖
បពិត្រព្រះជាម្ចាស់ ! ព្រះអង្គពិតជាព្រះដ៏វិសុទ្ធ ហើយគួរកោតសរសើរ
ព្រះអង្គស្រឡាញ់មនុស្សលោក រួមដំណើរជាមួយយើងខ្ញុំជារៀងរាល់ថ្ងៃ ។
ព្រះបុត្រាប្រកបដោយព្រះពរគ្រប់បែបយ៉ាង
ព្រះអង្គគង់នៅកណ្ដាលចំណោមយើងខ្ញុំ
នៅពេលយើងខ្ញុំជួបជុំគ្នាក្នុងសេចក្ដីស្រឡាញ់របស់ព្រះអង្គ ។
ព្រះអង្គបកស្រាយព្រះគម្ពីរ និងកាច់នំបុ័ងប្រទានឲ្យយើងខ្ញុំ
ដូចព្រះអង្គបានប្រព្រឹត្តចំពោះក្រុមសាវ័កកាលពីដើម ។

៣. លោកបូជាចារ្យប្រណម្យដៃ ហើយទ្រាបដៃទាំងពីរលើតង្វាយ ។ លោកពោលថា ៖

ឱ ព្រះបិតាប្រកបដោយធម៌មេត្តាករុណា !
សូមព្រះអង្គបាត់ព្រះវិញ្ញាណរបស់ព្រះអង្គ
មកញ៉ាំងនំប៉័ង និងស្រាតង្វាយនេះឲ្យបានវិសុទ្ធ

លោកបូជាចារ្យប្រណម្យដៃ ហើយធ្វើសញ្ញាឈើឆ្កាងលើនំ និងស្រាតង្វាយ ទាំងពោលថា ៖

ទៅជាព្រះកាយ ≅ និងព្រះលោហិត

លោកបូជាចារ្យប្រណម្យដៃ

ព្រះអម្ចាស់យេស៊ូគ្រីស្តសម្រាប់យើងខ្ញុំ ។

៤. លោកបូជាចារ្យពោលពាក្យនីមួយៗ ឲ្យបានច្បាស់ត្រូវតាមអត្ថន័យនៃព្រះបន្ទូលនេះ ។

នៅយប់ មុនព្រះយេស៊ូសោយទុក្ខលំបាក
ព្រះអង្គធ្វើពិធីជប់លៀងចុងក្រោយបង្អស់

លោកបូជាចារ្យ លើកនំតង្វាយឡើងបន្តិចពីតុសក្ការៈ ដោយពោល បន្តថា ៖

ព្រះអង្គយកនំប៉័ងមកកាន់
លើកតម្កើងព្រះបិតា
ហើយកាច់ប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យ ឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។**

លោកបូជាចារ្យ លើកព្រះកាយឡើងបង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់[២២៩] ។

[២២៩] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ១២៩១/៧៤ ស្តីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំជំនួសកាយវិការលុតជង្គង់ គួរឱ្យគ្រីស្តបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយលោកបូជាចារ្យ ។

៥. បន្ទាប់មក លោកបូជាចារ្យពោលបន្ត ៖

នៅពេលចុងក្រោយនៃពិធីជប់លៀង
ព្រះអង្គធ្វើតាមរបៀបដដែល

លោកបូជាចារ្យ លើកពែងព្រះលោហិតឡើងបន្តិចពីតុសក្ការៈ ដោយពោលបន្តថា ៖

ព្រះអង្គលើកពែងស្រាឡើង
អរព្រះគុណព្រះបិតា ហើយប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ**
**នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ព័ន្ធមេត្រីថ្មី**
**និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ**
**ដើម្បីលើកលែងទោសអ្នករាល់គ្នា**
**និងមនុស្សច្រើនឥតគណនាឲ្យបានរួចពីបាប។**
**សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ។**

លោកបូជាចារ្យ លើកព្រះកាយឡើងបង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់[២៣០] ។

៦. លោកបូជាចារ្យច្រៀង ឬពោលបន្តថា ៖

នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

អង្គប្រជុំឆ្លើយ ៖ ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

---

[២៣០] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ១២៩១/៧៤ ស្ដីពីពិធីបុណ្យនៅកម្ពុជា និងឡាវ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំជំនួសកាយវិការលុតជង្គង់ គួរឱ្យគ្រីស្តបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយលោកបូជាចារ្យ ។

ឬ

ឱ ព្រះអម្ចាស់អើយ !

រៀងរាល់ពេល យើងខ្ញុំពិសានំបុ័ង និងពិសាពីពែងនេះ

យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត

ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

ឬ

ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !

ព្រះអង្គសោយទិវង្គតលើឈើឆ្កាង និងមានព្រះជន្មរស់ឡើងវិញ

ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។

៧. លោកបូជាចារ្យលាតដៃ ដោយពោលបន្តថា ៖

បពិត្រព្រះបិតាដ៏វិសុទ្ធ !

យើងខ្ញុំសូមនឹករឭកដល់ព្រះគ្រីស្តជាព្រះបុត្រាព្រះអង្គ និងជាព្រះសង្គ្រោះយើងខ្ញុំ ។

ក្រោយពេលព្រះបុត្រាឆ្លងកាត់ទុក្ខលំបាក និងសោយទិវង្គតនៅលើឈើឆ្កាង

ព្រះបិតាបានប្រោសព្រះបុត្រាឲ្យមានព្រះជន្មរស់ឡើងវិញ

ប្រកបដោយសិរីរុងរឿង និងគង់ខាងស្តាំព្រះអង្គ ។

យើងខ្ញុំសូមប្រកាសពីកិច្ចការនៃព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ

រហូតដល់ពេលព្រះគ្រីស្តយាងមកវិញ ហើយយើងខ្ញុំក៏សូមថ្វាយព្រះអង្គ

នូវនំបុ័ងដែលផ្តល់ជីវិត និងពែងនៃព្រះពរ ។

សូមទ្រង់ទតមើលតង្វាយរបស់ព្រះសហគមន៍ព្រះអង្គដោយអនុគ្រោះ

យើងខ្ញុំសូមបង្ហាញពីសក្ការបូជានៃបុណ្យចម្លងរបស់ព្រះគ្រីស្ត

ដែលយើងខ្ញុំបានទទួលបន្តពីជំនាន់មុនៗ ។

ដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណនៃសេចក្តីស្រឡាញ់

សូមរាប់បញ្ចូលយើងខ្ញុំទៅក្នុងចំណោមសិរីរាង្គរបស់ព្រះបុត្រាព្រះអង្គ

ចាប់ពីឥឡូវនេះ រហូតដល់ថ្ងៃយើងទទួលជីវិតអស់កល្បជានិច្ច

គឺនៅក្នុងព្រះកាយ និងព្រះលោហិតព្រះអង្គដែលយើងខ្ញុំរួបរួមគ្នាជាធ្លុងតែមួយ ។

បពិត្រព្រះអម្ចាស់ ! សូមប្រោសឲ្យព្រះសហគមន៍ព្រះអង្គ (នៅ...)
មានកម្លាំងថ្មី ដោយសារពន្លឺនៃព្រះបន្ទូលដំណឹងល្អ ។
សូមពង្រឹងចំណងមេត្រីរវាងគ្រីស្តបរិស័ទ និងអ្នកណែនាំប្រជារាស្ត្រព្រះអង្គ
រួមជាមួយសម្តេចប៉ាបយើងខ្ញុំ ព្រះនាម...
ជាមួយលោក នាម... ជាអភិបាលព្រះសហគមន៍យើងខ្ញុំ[២៣១]
និងជាមួយក្រុមអភិបាលទាំងមូល ដើម្បីឲ្យប្រជារាស្ត្ររបស់ព្រះអង្គ
ទៅជាពន្លឺក្នុងពិភពលោកដែលបាក់បែកគ្នា
ជាសញ្ញាសម្គាល់នៃឯកភាព និងការស្រុះស្រួលគ្នា ។
សូមព្រះអង្គនឹកដល់អស់បងប្អូនយើងខ្ញុំ (ឈ្មោះ... និងឈ្មោះ...)
ដែលសម្រាន្តលក់ក្នុងសេចក្តីសុខសាន្តរបស់ព្រះគ្រីស្ត ព្រមទាំងអស់មរណបុគ្គល
មានតែព្រះអង្គទេ ដែលស្គាល់ជំនឿរបស់អ្នកទាំងនោះ ។
សូមព្រះអង្គទទួលបុគ្គលទាំងនោះ ឲ្យគេមានអំណរសប្បាយ
ក្នុងពន្លឺនៃព្រះភ័ក្ត្រព្រះអង្គ ហើយនៅពេលគេរស់ឡើងវិញ
សូមប្រទានឲ្យគេមានជីវិតពេញបរិបូណ៌ ។
ពេលយើងខ្ញុំបញ្ចប់ដំណើរនៅនាលោកនេះ
សូមព្រះអង្គប្រោសប្រទានឲ្យយើងខ្ញុំ បានទទួលលំនៅស្ថានដ៏ស្ថិតស្ថេរ
និងរស់នៅជាមួយព្រះអង្គអស់កល្បជានិច្ច ។
យើងខ្ញុំទាំងអស់គ្នាសូមកោតសរសើរ និងលើកតម្កើងព្រះអង្គ
រួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី ដែលពោរពេញដោយសុភមង្គល
ជាមាតារបស់ព្រះជាម្ចាស់ ជាមួយអស់គ្រីស្តទូត និងមរណសាក្សី
(ជាមួយសន្ត...ដែលយើងខ្ញុំគោរពក្នុងថ្ងៃនោះ ឬជាឧបការី)
ព្រមទាំងសន្តបុគ្គលទាំងអស់

លោកបូជាចារ្យប្រណម្យដៃ

តាមរយៈព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ ។

[២៣១] នៅទីនេះ អាចបន្ថែមឈ្មោះរបស់លោកអភិបាលឧបត្ថម្ភក ឬអភិបាលជំនួយការផ្សេងៗ តាមពាក្យណែនាំនៃក្បួនពិធីបុណ្យ លេខ ១៤៩។

៨. លោកបូជាចារ្យ លើកបានព្រះកាយ និងពែងព្រះលោហិតក្នុងដៃទាំងពីរ ហើយពោលថា ៖

ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៥៥៥)

# ទី២

# ព្រះជាម្ចាស់ណែនាំព្រះសហគមន៍ តាមមាគ៌ានៃការសង្គ្រោះ

Deus Ecclesiam suam in viam salutis conducens

១. ធម៌អរព្រះគុណខាងក្រោមនេះ ប្រើក្នុងឱកាសដូចជា ៖
អភិបូជាសម្រាប់ព្រះសហគមន៍ អភិបូជាសម្រាប់ត្រាស់ហៅឲ្យទៅជាបូជាចារ្យ
អភិបូជាសម្រាប់គ្រហស្ថ អភិបូជាសម្រាប់គ្រួសារ អភិបូជាសម្រាប់ក្រុមបព្វជិតបព្វជិតា
អភិបូជាសម្រាប់ការត្រាស់ហៅឲ្យទៅជាបព្វជិតបព្វជិតា
អភិបូជាសម្រាប់សេចក្ដីស្រឡាញ់ អភិបូជាសម្រាប់ញាតិសន្ដាន និងមិត្តភក្ដិ
អភិបូជាសម្រាប់អរព្រះគុណព្រះជាម្ចាស់ ។

បៈ សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រៈ ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

បៈ សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រៈ យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

បៈ សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រៈ ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ព្រះអង្គជាព្រះបង្កើតពិភពលោក និងជាប្រភពនៃជីវិតទាំងអស់
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ព្រះអង្គមិនដែលបោះបង់អ្វីៗ
ដែលកើតពីព្រះប្រាជ្ញាញាណរបស់ព្រះអង្គឡើយ
ដ្បិតព្រះអង្គជាព្រះឧបការគុណ ដែលគង់នៅកណ្ដាលចំណោមយើងខ្ញុំ ។

កាលពីជំនាន់ដើម ព្រះអង្គដឹកដៃជនជាតិអ៊ីស្រាអែល
ជាប្រជារាស្ត្ររបស់ព្រះអង្គឲ្យឆ្លងកាត់វាលរហោស្ថាន
សព្វថ្ងៃ ព្រះអង្គនៅតែរួមដំណើរជាមួយព្រះសហគមន៍ក្នុងលោកនេះ
ដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ។
ព្រះបិតាណែនាំព្រះសហគមន៍ តាមរយៈព្រះគ្រីស្តជាព្រះអម្ចាស់យើងខ្ញុំ
ឲ្យឆ្លងកាត់សម័យកាលទាំងឡាយ
ទៅកាន់អំណរសប្បាយអស់កល្បជានិច្ចក្នុងព្រះរាជ្យព្រះអង្គ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយប្រកាសឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

២. លោកបូជាចារ្យលាតដៃ ដោយពោលថា ៖

ឱ ព្រះជាម្ចាស់អើយ ! ព្រះអង្គពិតជាព្រះដ៏វិសុទ្ធ

ព្រះអង្គស្រឡាញ់មនុស្សលោក ទ្រង់រួមដំណើរជាមួយយើងខ្ញុំជារៀងរាល់ថ្ងៃ ។
ព្រះបុត្រាប្រកបដោយព្រះពរគ្រប់បែបយ៉ាង
ព្រះអង្គគង់នៅកណ្តាលចំណោមយើងខ្ញុំ
នៅពេលយើងខ្ញុំជួបជុំគ្នាក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ ។
ព្រះអង្គបកស្រាយព្រះគម្ពីរ និងកាច់នំបុ័ងប្រទានឲ្យយើងខ្ញុំ
ដូចព្រះអង្គបានប្រព្រឹត្តចំពោះក្រុមសាវ័កកាលពីដើម ។

៣. លោកបូជាចារ្យប្រណម្យដៃ ហើយទ្រាបដៃទាំងពីរលើតង្វាយ ។ លោកពោលថា៖

ឱ ព្រះបិតាប្រកបដោយធម៌មេត្តាករុណា !
សូមព្រះអង្គចាត់ព្រះវិញ្ញាណរបស់ព្រះអង្គ
មកញ៉ាំងនំប៉័ង និងស្រាតង្វាយនេះឲ្យបានវិសុទ្ធ

លោកបូជាចារ្យប្រណម្យដៃ ហើយធ្វើសញ្ញាឈើឆ្កាងលើនំ និងស្រាតង្វាយទាំងពោលថា ៖

ទៅជាព្រះកាយ ≅ និងព្រះលោហិត

លោកបូជាចារ្យប្រណម្យដៃ

ព្រះអម្ចាស់យេស៊ូគ្រីស្តសម្រាប់យើងខ្ញុំ ។

៤. លោកបូជាចារ្យពោលពាក្យនីមួយៗ ឲ្យបានច្បាស់ត្រូវតាមអត្ថន័យ នៃព្រះបន្ទូលនេះ ។

នៅយប់ មុនព្រះយេស៊ូសោយទុក្ខលំបាក
ព្រះអង្គធ្វើពិធីជប់លៀងចុងក្រោយបង្អស់

លោកបូជាចារ្យ លើកនំតង្វាយឡើងបន្តិចពីតុសក្ការៈ ដោយពោលបន្តថា ៖

ព្រះអង្គយកនំប៉័ងមកកាន់
លើកតម្កើងព្រះបិតា
ហើយកាច់ប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យ ឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។**

លោកបូជាចារ្យលើកព្រះកាយឡើងបង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់[២៣២] ។

[២៣២] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ១៩៧៤ លេខ១២៩១/៧៤ ស្តីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំជំនួសកាយវិការលុតជង្គង់ គួរឱ្យគ្រីស្តបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយលោកបូជាចារ្យ ។

៥. បន្ទាប់មកលោកបូជាចារ្យពោលបន្ត ៖
នៅពេលចុងក្រោយនៃពិធីជប់លៀង
ព្រះអង្គធ្វើតាមរបៀបដដែល

លោកបូជាចារ្យ លើកពែងព្រះលោហិតឡើងបន្តិចពីតុសក្ការៈ ដោយពោលបន្តថា ៖
ព្រះអង្គលើកពែងស្រាឡើង
អរព្រះគុណព្រះបិតា ហើយប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ**
**នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ព័ន្ធមេត្រីថ្មី**
**និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ**
**ដើម្បីលើកលែងទោសអ្នករាល់គ្នា**
**និងមនុស្សច្រើនឥតគណនាឲ្យបានរួចពីបាប។**
**សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ។**

លោកបូជាចារ្យលើកពែងព្រះលោហិតឡើង បង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់[២៣៣] ។

៦. ក្រោយមកលោកបូជាចារ្យពោលបន្តថា ៖
នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

អង្គប្រជុំឆ្លើយ ៖ ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

[២៣៣] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ១២៩១/៧៤ ស្តីពីពិធីបុណ្យនៅកម្ពុជា និងឡាវ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំជំនួសកាយវិការលុតជង្គង់ គួរឱ្យគ្រីស្តបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយលោកបូជាចារ្យ ។

ឬ

ឱ ព្រះអម្ចាស់អើយ !

រៀងរាល់ពេល យើងខ្ញុំពិសានំប៉័ង និងពិសាពីពែងនេះ

យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត

ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

ឬ

ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !

ព្រះអង្គសោយទិវង្គតលើឈើឆ្កាង និងមានព្រះជន្មរស់ឡើងវិញ

ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។

៧. លោកបូជាចារ្យលាតដៃ ដោយពោលបន្តថា ៖

បពិត្រព្រះបិតាដ៏វិសុទ្ធ !

យើងខ្ញុំសូមនឹករឭកដល់ព្រះគ្រីស្តជាព្រះបុត្រាព្រះអង្គ និងជាព្រះសង្គ្រោះយើងខ្ញុំ ។

ក្រោយពេលព្រះបុត្រាឆ្លងកាត់ទុក្ខលំបាក និងសោយទិវង្គតនៅលើឈើឆ្កាង

ព្រះបិតាបានប្រោសព្រះបុត្រាឲ្យមានព្រះជន្មរស់ឡើងវិញ

ប្រកបដោយសិរីរុងរឿង និងគង់ខាងស្តាំព្រះអង្គ ។

យើងខ្ញុំសូមប្រកាសពីកិច្ចការនៃព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ

រហូតដល់ពេលព្រះគ្រីស្តយាងមកវិញ ហើយយើងខ្ញុំក៏សូមថ្វាយព្រះអង្គ

នូវនំប៉័ងដែលផ្តល់ជីវិត និងពែងនៃព្រះពរ ។

សូមព្រះអង្គទតមើលតង្វាយរបស់ព្រះសហគមន៍ព្រះអង្គដោយអនុគ្រោះ

យើងខ្ញុំសូមបង្ហាញពីសក្ការបូជានៃបុណ្យចម្លងរបស់ព្រះគ្រីស្ត

ដែលយើងខ្ញុំបានទទួលបន្តពីជំនាន់មុនៗ ។

ដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណនៃសេចក្តីស្រឡាញ់

សូមរាប់បញ្ចូលយើងខ្ញុំទៅក្នុងចំណោមសវីរាង្គរបស់ព្រះបុត្រាព្រះអង្គ

ចាប់ពីឥឡូវនេះ រហូតដល់ថ្ងៃយើងខ្ញុំទទួលជីវិតអស់កល្បជានិច្ច

គឺនៅក្នុងព្រះកាយ និងព្រះលោហិតព្រះអង្គដែលយើងខ្ញុំរួបរួមគ្នាជាធ្លុងតែមួយ ។

បពិត្រព្រះអម្ចាស់ !
ព្រះអង្គបានត្រាស់ហៅយើងខ្ញុំឲ្យរួមតុជាមួយព្រះអង្គ
សូមព្រះអង្គពង្រឹងឯកភាពឲ្យយើងខ្ញុំរួមជាធ្លុងតែមួយ
រួមជាមួយសម្ដេចប៉ាបយើងខ្ញុំ ព្រះនាម...
ជាមួយលោកនាម...ជាអភិបាលព្រះសហគមន៍យើងខ្ញុំ[២៣៤]
និងជាមួយក្រុមអភិបាលទាំងឡាយ
ជាមួយលោកបូជាចារ្យ និងលោកឧបដ្ឋាក
ព្រមទាំងប្រជារាស្ត្រទាំងអស់របស់ព្រះអង្គ ។
នៅពេលយើងខ្ញុំធ្វើដំណើរតាមមាគ៌ារបស់ព្រះអង្គ
ទាំងមានជំនឿ និងសេចក្ដីសង្ឃឹម
យើងខ្ញុំអាចនាំអំណរសប្បាយ និងការទុកចិត្តគ្នាចូលក្នុងពិភពលោកបាន ។
សូមព្រះអង្គនឹកដល់អស់បងប្អូនយើងខ្ញុំ (ឈ្មោះ...និងឈ្មោះ...)
ដែលសម្រាន្តលក់ក្នុងសេចក្ដីសុខសាន្តរបស់ព្រះគ្រីស្ត
ព្រមទាំងអស់មរណបុគ្គល
មានតែព្រះអង្គទេ ដែលស្គាល់ជំនឿរបស់អ្នកទាំងនោះ ។

សូមព្រះអង្គទទួលបុគ្គលទាំងនោះ ឲ្យគេមានអំណរសប្បាយក្នុងពន្លឺនៃព្រះភ័ក្ត្រព្រះអង្គ
ហើយនៅពេលគេរស់ឡើងវិញ
សូមប្រទានឲ្យគេមានជីវិតពេញបរិបូណ៌ ។
ពេលយើងខ្ញុំបញ្ចប់ដំណើរនៅលោកនេះ
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបានទទួលលំនៅស្ថានដ៏ស្ថិតស្ថេរ
និងរស់នៅជាមួយព្រះអង្គអស់កល្បជានិច្ច ។

[២៣៤] នៅទីនេះ អាចបន្ថែមឈ្មោះរបស់លោកអភិបាលឧបត្ថម្ភក ឬអភិបាលជំនួយការផ្សេងៗ តាមពាក្យណែនាំនៃក្បួនពិធីបុណ្យ លេខ ១៤៩។

យើងខ្ញុំទាំងអស់គ្នា សូមកោតសរសើរ និងលើកតម្កើងព្រះអង្គ
រួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី ដែលពោរពេញដោយសុភមង្គល
ជាមាតាព្រះជាម្ចាស់ ជាមួយអស់គ្រីស្តទូត និងមរណសាក្សី
(ជាមួយសន្ត... ដែលយើងខ្ញុំគោរពក្នុងថ្ងៃនោះ ឬជាឧបការី)
ព្រមទាំងសន្តបុគ្គលទាំងឡាយ

លោកបូជាចារ្យប្រណម្យដៃ
តាមរយៈព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ ។

៨. លោកបូជាចារ្យលើកបានព្រះកាយ និងពែងព្រះលោហិតក្នុងដៃទាំងពីរ ហើយពោលថា ៖
ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៥៥៥)

## ទី ៣

# ព្រះយេស៊ូជាមាគ៌ាទៅកាន់ព្រះបិតា

Iesus via ad Patrem

១. ធម៌អរព្រះគុណខាងក្រោមនេះ ប្រើក្នុងឱកាសដូចជា ៖
អភិបូជាសម្រាប់ការប្រកាសដំណឹងល្អ អភិបូជាសម្រាប់គ្រីស្តបរិស័ទដែលត្រូវគេបៀតបៀន
អភិបូជាសម្រាប់ប្រទេសមួយ ឬជនជាតិមួយ
អភិបូជាសម្រាប់មន្ត្រីរាជការទាំងអស់ អភិបូជាសម្រាប់រដ្ឋសភា
អភិបូជាសម្រាប់ឱកាសចូលឆ្នាំថ្មី និងអភិបូជាសម្រាប់វឌ្ឍនភាពរបស់ប្រជាជន ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ ជាព្រះអម្ចាស់នៃផ្ទៃមេឃ និងផែនដី !
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។
ព្រះអង្គបានបង្កើតពិភពលោកដោយព្រះបន្ទូលព្រះអង្គ
ហើយព្រះអង្គគ្រប់គ្រងអ្វីៗទាំងអស់ដោយសេចក្តីសុចរិត ។
ព្រះអង្គប្រោសប្រទានឲ្យព្រះបន្ទូលនេះប្រសូតជាមនុស្ស
ដើម្បីជាស្ពាននៃសម្ពន្ធមេត្រីថ្មីសម្រាប់យើងខ្ញុំ ។
ព្រះបុត្រាបានថ្លែងព្រះបន្ទូលក្នុងនាមព្រះបិតា
ហើយត្រាស់ហៅយើងខ្ញុំឲ្យដើរតាមព្រះអង្គ ។

ព្រះបុត្រាជាមាគ៌ាដែលនាំយើងខ្ញុំទៅកាន់ព្រះបិតា
ព្រះអង្គជាសេចក្ដីពិតដែលប្រទានសេរីភាព
ហើយជាជីវិតដែលផ្ដល់អំណរសប្បាយឲ្យយើងខ្ញុំ ។
តាមរយៈព្រះបុត្រា ព្រះបិតាបានបង្រួបបង្រួមមនុស្សលោក
ឲ្យទៅជាមហាគ្រួសារតែមួយ គឺមនុស្សដែលព្រះបិតាបានបង្កើត
ដើម្បីលើកតម្កើងសិរីរុងរឿងព្រះនាមព្រះអង្គ
ព្រះអង្គរំដោះគេដោយព្រះលោហិត ដែលព្រះបុត្រាបានបង្ហូរនៅលើឈើឆ្កាង
ហើយដៅសញ្ញាសម្គាល់លើគេដោយប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ចាប់ពីពេលនេះរហូតតរៀងទៅ
ដោយប្រកាសទាំងអំណរសប្បាយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

២. លោកបូជាចារ្យលាតដៃ ដោយពោលថា ៖
បពិត្រព្រះជាម្ចាស់ ! ព្រះអង្គពិតជាព្រះដ៏វិសុទ្ធ
យើងខ្ញុំសូមកោតសរសើរ ព្រះអង្គស្រឡាញ់មនុស្សលោកខ្លាំងណាស់
ដោយរួមដំណើរជាមួយយើងខ្ញុំជារៀងរាល់ថ្ងៃ ។
ព្រះបុត្រាប្រកបដោយព្រះពរគ្រប់បែបយ៉ាង ទ្រង់គង់នៅកណ្ដាលចំណោមយើងខ្ញុំ
នៅពេលយើងខ្ញុំជួបជុំគ្នាក្នុងសេចក្ដីស្រឡាញ់របស់ព្រះអង្គ ។
ព្រះអង្គបកស្រាយព្រះគម្ពីរ និងកាច់នំប៉័ងប្រទានឲ្យយើងខ្ញុំ
ដូចព្រះអង្គបានប្រព្រឹត្តចំពោះក្រុមសាវ័កកាលពីដើម ។

៣. លោកបូជាចារ្យប្រណម្យដៃ ហើយទ្រាប់ដៃទាំងពីរលើតង្វាយ ។ លោកពោលថា៖

ឱ ព្រះបិតាប្រកបដោយធម៌មេត្តាករុណា !
សូមព្រះអង្គបាត់ព្រះវិញ្ញាណរបស់ព្រះអង្គ
មកញ៉ាំងនំប៉័ង និងស្រាតង្វាយនេះឲ្យបានវិសុទ្ធ

លោកបូជាចារ្យប្រណម្យដៃ ហើយធ្វើសញ្ញាឈើឆ្កាងលើនំ និងស្រាតង្វាយទាំងពោលថា ៖

ទៅជាព្រះកាយ ✠ និងព្រះលោហិត

លោកបូជាចារ្យប្រណម្យដៃ

ព្រះអម្ចាស់យេស៊ូគ្រីស្តសម្រាប់យើងខ្ញុំ ។

៤. លោកបូជាចារ្យពោលពាក្យនីមួយៗ ឲ្យបានច្បាស់ត្រូវតាមអត្ថន័យនៃព្រះបន្ទូលនេះ ។

នៅយប់ មុនព្រះយេស៊ូសោយទុក្ខលំបាក
ព្រះអង្គធ្វើពិធីជប់លៀងចុងក្រោយបង្អស់

លោកបូជាចារ្យ លើកនំតង្វាយឡើងបន្តិចពីតុសក្ការៈ ដោយពោលបន្តថា ៖

ព្រះអង្គយកនំប៉័ងមកកាន់
លើកតម្កើងព្រះបិតា
ហើយកាច់ប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យ ឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ**
**ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។**

លោកបូជាចារ្យ លើកព្រះកាយឡើងបង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់[២៣៥] ។

---

[២៣៥] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ១២៩១/៧៤ ស្តីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំជំនួសកាយវិការលុតជង្គង់ គួរឱ្យគ្រីស្តបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយលោកបូជាចារ្យ ។

៥. បន្ទាប់មកលោកបូជាចារ្យពោលបន្ត ៖

នៅពេលចុងក្រោយនៃពិធីជប់លៀង ព្រះអង្គធ្វើតាមរបៀបដដែល

លោកបូជាចារ្យ លើកពែងព្រះលោហិតឡើងបន្តិចពីតុសក្ការៈ ដោយពោលបន្តថា ៖

ព្រះអង្គលើកពែងស្រាឡើង
អរព្រះគុណព្រះបិតា ហើយប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ**
**នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ព័ន្ធមេត្រីថ្មី**
**និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ**
**ដើម្បីលើកលែងទោសអ្នករាល់គ្នា**
**និងមនុស្សច្រើនឥតគណនាឲ្យបានរួចពីបាប។**
**សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ។**

លោកបូជាចារ្យលើកពែងព្រះលោហិតឡើងបង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់[២៣៦] ។

៦. ក្រោយមកលោកបូជាចារ្យពោលបន្តថា ៖

នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

អង្គប្រជុំឆ្លើយ ៖

ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

[២៣៦] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ១២៩១/៧៤ ស្ដីពីពិធីបុណ្យនៅកម្ពុជា និងឡាវ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំជំនួសកាយវិការលុតជង្គង់ គួរឱ្យគ្រីស្ដបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយលោកបូជាចារ្យ ។

ឬ

ឱ ព្រះអម្ចាស់អើយ !
រៀងរាល់ពេល យើងខ្ញុំពិសានំប៉័ង និងពិសាពីពែងនេះ
យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

ឬ

ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !
ព្រះអង្គសោយទិវង្គតលើឈើឆ្កាង និងមានព្រះជន្មរស់ឡើងវិញ
ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។

៧. លោកបូជាចារ្យលាតដៃ ដោយពោលបន្តថា ៖

បពិត្រព្រះបិតាដ៏វិសុទ្ធ !
យើងខ្ញុំសូមនឹករឭកដល់ព្រះគ្រីស្តជាព្រះបុត្រាព្រះអង្គ និងជាព្រះសង្គ្រោះយើងខ្ញុំ ។
ក្រោយពេលព្រះបុត្រាឆ្លងកាត់ទុក្ខលំបាក និងសោយទិវង្គតនៅលើឈើឆ្កាង
ព្រះបិតាបានប្រោសព្រះបុត្រាឲ្យមានព្រះជន្មរស់ឡើងវិញ
ប្រកបដោយសិរីរុងរឿង និងគង់ខាងស្តាំព្រះអង្គ ។
យើងខ្ញុំសូមប្រកាសពីកិច្ចការនៃព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ
រហូតដល់ពេលព្រះគ្រីស្តយាងមកវិញ ហើយយើងខ្ញុំក៏សូមថ្វាយព្រះអង្គ
នូវនំប៉័ងដែលផ្តល់ជីវិត និងពែងនៃព្រះពរ ។
សូមព្រះអង្គទតមើលតង្វាយរបស់ព្រះសហគមន៍ដោយអនុគ្រោះ
យើងខ្ញុំសូមបង្ហាញពីសក្ការបូជានៃបុណ្យចម្លងរបស់ព្រះគ្រីស្ត
ដែលយើងខ្ញុំបានទទួលបន្តពីជំនាន់មុនៗ ។
ដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណនៃសេចក្តីស្រឡាញ់
សូមរាប់បញ្ចូលយើងខ្ញុំទៅក្នុងចំណោមសិរីរាង្គរបស់ព្រះបុត្រាព្រះអង្គ
ចាប់ពីឥឡូវនេះ រហូតដល់ថ្ងៃយើងខ្ញុំទទួលជីវិតអស់កល្បជានិច្ច
គឺនៅក្នុងព្រះកាយ និងព្រះលោហិតព្រះគ្រីស្តដែលយើងខ្ញុំរួបរួមគ្នាជាធ្លុងតែមួយ ។

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
នៅពេលយើងខ្ញុំចូលរួមក្នុងគម្រោងការដ៏អាថ៌កំបាំងនេះ
សូមទ្រង់ប្រោសប្រទានជីវិតឲ្យយើងខ្ញុំ ដោយព្រះវិញ្ញាណរបស់ព្រះអង្គ
សូមឲ្យយើងខ្ញុំមានលក្ខណៈដូចព្រះបុត្រាព្រះអង្គ
សូមទ្រង់ពង្រឹងឯកភាពឲ្យយើងខ្ញុំរួមជាធ្លុងតែមួយ
រួមជាមួយសម្តេចប៉ាបយើងខ្ញុំ ព្រះនាម...
ជាមួយលោកនាម... ជាអភិបាលព្រះសហគមន៍យើងខ្ញុំ[២៣៧]
និងជាមួយក្រុមអភិបាលទាំងឡាយ ជាមួយលោកបូជាចារ្យ
និងលោកឧបដ្ឋាក ព្រមទាំងប្រជារាស្ត្រទាំងអស់របស់ព្រះអង្គ ។
សូមព្រះបិតាប្រទានពន្លឺនៃជំនឿ បំភ្លឺដល់គ្រីស្តបរិស័ទទាំងឡាយ
ឲ្យថ្វាយខ្លួនដើម្បីបម្រើព្រះបន្ទូលដំណឹងល្អជានិច្ច
ដោយយល់ពីទីសម្គាល់នៃសម័យកាល ។
សូមឲ្យយើងខ្ញុំយកចិត្តទុកដាក់ ចំពោះសេចក្តីត្រូវការរបស់មនុស្សគ្រប់ៗរូប
ដោយចែករំលែកសេចក្តីទុក្ខព្រួយ និងការឈឺចាប់
អំណរសប្បាយ និងសេចក្តីសង្ឃឹម
សូមឲ្យយើងខ្ញុំនាំដំណឹងល្អនៃការសង្គ្រោះដល់បងប្អូនទាំងនោះ
ហើយរួមគ្នាទៅមុខតាមមាគ៌ានៃព្រះរាជ្យរបស់ព្រះអង្គ ។
សូមព្រះអង្គនឹកដល់អស់បងប្អូនយើងខ្ញុំ (ឈ្មោះ...និងឈ្មោះ...)
ដែលសម្រាន្តលក់ក្នុងសេចក្តីសុខសាន្តរបស់ព្រះគ្រីស្ត
ព្រមទាំងមរណបុគ្គលទាំងឡាយ
មានតែព្រះអង្គទេ ដែលស្គាល់ជំនឿរបស់អ្នកទាំងនោះ ។
សូមព្រះអង្គទទួលបុគ្គលទាំងនោះ ឲ្យគេមានអំណរសប្បាយ
ក្នុងពន្លឺនៃព្រះភ័ក្ត្រព្រះអង្គ ហើយនៅពេលគេរស់ឡើងវិញ
សូមប្រទានឲ្យគេមានជីវិតពេញបរិបូណ៌ ។

[២៣៧] នៅទីនេះ អាចបន្ថែមឈ្មោះរបស់លោកអភិបាលឧបត្ថម្ភក ឬអភិបាលជំនួយការផ្សេងៗ តាមពាក្យណែនាំនៃក្បួនពិធីបុណ្យ លេខ ១៤៩។

ពេលយើងខ្ញុំបញ្ចប់ដំណើរនៅលោកនេះ
សូមព្រះអង្គប្រោសប្រទានឲ្យយើងខ្ញុំ បានទទួលលំនៅស្ថានដ៏ស្ថិតស្ថេរ
និងរស់នៅជាមួយព្រះអង្គអស់កល្បជានិច្ច ។
យើងខ្ញុំទាំងអស់គ្នាសូមកោតសរសើរ និងលើកតម្កើងព្រះអង្គ
រួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី ដែលពោរពេញដោយសុភមង្គល
ជាមាតាព្រះជាម្ចាស់ ជាមួយអស់គ្រីស្តទូត និងមរណសាក្សី
(ជាមួយសន្ត...ដែលយើងខ្ញុំគោរពក្នុងថ្ងៃនោះ ឬជាឧបការី)
ព្រមទាំងសន្តបុគ្គលទាំងឡាយ

លោកបូជាចារ្យប្រណម្យដៃ
តាមរយៈព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ ។

៨. លោកបូជាចារ្យលើកបានព្រះកាយ និងពែងព្រះលោហិតក្នុងដៃទាំងពីរ ហើយពោលថា ៖
ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៥៥៥)

# ទី៤

# ព្រះយេស៊ូយាងទៅគ្រប់ទីកន្លែងទាំងប្រព្រឹត្តអំពើល្អ

Iesus pertransiens benefaciendo

១. ធម៌អរព្រះគុណខាងក្រោមនេះ ប្រើក្នុងឱកាសដូចជា ៖
អភិបូជាសម្រាប់ជនភៀសខ្លួន អភិបូជាពេលទុរ្ភិក្ស
អភិបូជាសម្រាប់អ្នកសង្កត់សង្កិនយើងខ្ញុំ
អភិបូជាសម្រាប់អ្នកជាប់ជាឈ្លើយ អភិបូជាសម្រាប់អ្នកជាប់ឃុំឃាំង
អភិបូជាសម្រាប់អ្នកជំងឺ អភិបូជាសម្រាប់អ្នកដែលហៀបនឹងស្លាប់
អភិបូជាសូមសេចក្តីសុខសាន្តក្នុងពេលទទួលមរណភាព
និងអភិបូជាសម្រាប់សេចក្តីត្រូវការណាមួយ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាជាព្រះជាម្ចាស់ ដ៏មានព្រះហឫទ័យមេត្តាករុណា និងស្មោះត្រង់ !
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ព្រះអង្គបានប្រទានព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ
មកជាព្រះអម្ចាស់ និងជាព្រះប្រោសលោះយើងខ្ញុំ ។
ព្រះអង្គតែងតែបង្ហាញធម៌មេត្តាករុណាដល់អ្នកតូចតាច
និងអ្នកក្រីក្រ អ្នកជំងឺ និងអ្នកបាប
ហើយព្រះអង្គជិតស្និទ្ធជាមួយអ្នកដែលត្រូវគេជិះជាន់ និងអ្នកដែលមានទុក្ខព្រួយ ។

ព្រះបុត្រាបានប្រកាសដល់ពិភពលោក
តាមព្រះបន្ទូល និងកិច្ចការរបស់ព្រះអង្គថា
ព្រះជាម្ចាស់ជាព្រះបិតារបស់យើងខ្ញុំ
ហើយព្រះបិតាសព្វព្រះហឫទ័យថែទាំបុត្រធីតាទាំងអស់របស់ព្រះអង្គ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ សូមលើកតម្កើង និងអរព្រះគុណព្រះនាមព្រះអង្គ
ទាំងច្រៀងបទកោតសរសើរសិរីរុងរឿងរបស់ព្រះអង្គ ដោយឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

២. លោកបូជាចារ្យលាតដៃ ដោយពោលថា ៖
ឱ ព្រះជាម្ចាស់ !
ព្រះអង្គពិតជាព្រះដ៏វិសុទ្ធ
ព្រះអង្គស្រឡាញ់មនុស្សលោកគ្រប់ជាតិសាសន៍
ហើយរួមដំណើរជាមួយយើងខ្ញុំជារៀងរាល់ថ្ងៃ ។
ព្រះបុត្រាប្រកបដោយព្រះពរគ្រប់បែបយ៉ាង
ព្រះអង្គគង់នៅកណ្តាលចំណោមយើងខ្ញុំ
នៅពេលយើងខ្ញុំជួបជុំគ្នា ក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ ។
ទ្រង់បកស្រាយព្រះគម្ពីរ និងកាច់នំប៉័ងប្រទានឲ្យយើងខ្ញុំ
ដូចព្រះអង្គបានប្រព្រឹត្តចំពោះក្រុមសាវ័កកាលពីដើម ។

៣. លោកបូជាចារ្យប្រណម្យដៃ ហើយទ្រាបដៃទាំងពីរលើតង្វាយ ។ លោកពោលថា៖

ឱ ព្រះបិតាប្រកបដោយធម៌មេត្តាករុណា !
សូមព្រះអង្គចាត់ព្រះវិញ្ញាណរបស់ព្រះអង្គ
មកញ៉ាំងនំបុ័ង និងស្រាតង្វាយនេះឲ្យបានវិសុទ្ធ

លោកបូជាចារ្យប្រណម្យដៃ ហើយធ្វើសញ្ញាឈើឆ្កាងលើនំ និងស្រាតង្វាយទាំងពោលថា ៖

ទៅជាព្រះកាយ ≅ និងព្រះលោហិត

លោកបូជាចារ្យប្រណម្យដៃ

ព្រះអម្ចាស់យេស៊ូគ្រីស្តសម្រាប់យើងខ្ញុំ ។

៤. លោកបូជាចារ្យពោលពាក្យនីមួយៗ ឲ្យបានច្បាស់ត្រូវតាមអត្ថន័យ នៃព្រះបន្ទូលនេះ ។

នៅយប់ មុនព្រះយេស៊ូសោយទុក្ខលំបាក
ព្រះអង្គធ្វើពិធីជប់លៀងចុងក្រោយបង្អស់

លោកបូជាចារ្យ លើកនំតង្វាយឡើងបន្តិចពីតុសក្ការៈ ដោយពោល បន្តថា ៖

ព្រះអង្គយកនំបុ័ងមកកាន់
លើកតម្កើងព្រះបិតា
ហើយកាច់ប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យ ឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ**
**ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា។**

លោកបូជាចារ្យ លើកព្រះកាយឡើងបង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់[២៣៨] ។

---

[២៣៨] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ១៩៧៤ លេខ១២៩១/៧៤ ស្តីពីពិធីបុណ្យនៅកម្ពុជា និងឡាវ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំជំនួសកាយវិការលុតជង្គង់ គួរឱ្យគ្រីស្តបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយលោកបូជាចារ្យ ។

៥. បន្ទាប់មកលោកបូជាចារ្យពោលបន្ត ៖

នៅពេលចុងក្រោយនៃពិធីជប់លៀង ព្រះអង្គធ្វើតាមរបៀបដដែល

លោកបូជាចារ្យលើកពែងព្រះលោហិតឡើងបន្តិចពីតុសក្ការៈ ដោយពោលបន្តថា ៖

ព្រះអង្គលើកពែងស្រាឡើង
អរព្រះគុណព្រះបិតា ហើយប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

លោកបូជាចារ្យឱនកាយបន្តិច

**សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ**
**នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ព័ន្ធមេត្រីថ្មី**
**និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ**
**ដើម្បីលើកលែងទោសអ្នករាល់គ្នា**
**និងមនុស្សច្រើនឥតគណនាឲ្យបានរួចពីបាប។**
**សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ។**

លោកបូជាចារ្យ លើកពែងព្រះលោហិតឡើងបង្ហាញអង្គប្រជុំ រួចដាក់ចុះ ហើយលុតជង្គង់[២៣៩] ។

៦. ក្រោយមកលោកបូជាចារ្យពោលបន្តថា ៖

នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

អង្គប្រជុំឆ្លើយ ៖

ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

---

[២៣៩] យោងតាមសាសនក្រឹត្យអនុញ្ញាតពីក្រសួងពិធីបុណ្យចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៤ លេខ១២៩១/៧៤ ស្ដីពីពិធីបុណ្យនៅកម្ពុជា និងឡាវ ។ លោកបូជាចារ្យឱនកាយក្រាបថ្វាយបង្គំជំនួសកាយវិការលុតជង្គង់ គួរឱ្យគ្រីស្តបរិស័ទក្រាបថ្វាយបង្គំដល់កន្ទេលរួមជាមួយលោកបូជាចារ្យ ។

ឬ

ឱ ព្រះអម្ចាស់អើយ !
រៀងរាល់ពេល យើងខ្ញុំពិសានំប៉័ង និងពិសាពីពែងនេះ
យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

ឬ

ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !
ព្រះអង្គសោយទិវង្គតលើឈើឆ្កាង និងមានព្រះជន្មរស់ឡើងវិញ
ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។

៧. លោកបូជាចារ្យលាតដៃ ដោយពោលបន្តថា ៖

បពិត្រព្រះបិតាដ៏វិសុទ្ធ !
យើងខ្ញុំសូមនឹករឭកដល់ព្រះគ្រីស្តជាព្រះបុត្រាព្រះអង្គ និងជាព្រះសង្គ្រោះយើងខ្ញុំ ។
ក្រោយពេលព្រះបុត្រាឆ្លងកាត់ទុក្ខលំបាក និងសោយទិវង្គតនៅលើឈើឆ្កាង
ព្រះបិតាបានប្រោសព្រះបុត្រាឲ្យមានព្រះជន្មរស់ឡើងវិញ
ប្រកបដោយសិរីរុងរឿង និងគង់ខាងស្ដាំព្រះអង្គ ។
យើងខ្ញុំសូមប្រកាសពីកិច្ចការ នៃព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ
រហូតដល់ពេលព្រះគ្រីស្តយាងមកវិញ
ហើយយើងខ្ញុំក៏សូមថ្វាយព្រះអង្គនូវនំប៉័ងដែលផ្ដល់ជីវិត និងពែងនៃព្រះពរ ។
សូមទ្រង់ទតមើលតង្វាយរបស់ព្រះសហគមន៍ព្រះអង្គដោយអនុគ្រោះ
យើងខ្ញុំសូមបង្ហាញពីសក្ការបូជានៃបុណ្យចម្លងរបស់ព្រះគ្រីស្ត
ដែលយើងខ្ញុំបានទទួលបន្តពីជំនាន់មុនៗ ។
ដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណនៃសេចក្តីស្រឡាញ់
សូមរាប់បញ្ចូលយើងខ្ញុំទៅក្នុងចំណោមសិរីរាង្គរបស់ព្រះបុត្រាព្រះអង្គ
ចាប់ពីឥឡូវនេះ រហូតដល់ថ្ងៃយើងខ្ញុំទទួលជីវិតអស់កល្បជានិច្ច
គឺនៅក្នុងព្រះកាយ និងព្រះលោហិតព្រះគ្រីស្តដែលយើងខ្ញុំរួបរួមគ្នាជាធ្លុងតែមួយ ។
ឱ ព្រះអម្ចាស់អើយ !

សូមឲ្យព្រះសហគមន៍របស់ព្រះអង្គមានជំនឿ និងសេចក្ដីស្រឡាញ់ឥតខ្ចោះ
រួមជាមួយសម្ដេចប៉ាបយើងខ្ញុំ ព្រះនាម...
ជាមួយលោក នាម... ជាអភិបាលព្រះសហគមន៍យើងខ្ញុំ [២៤០]
និងជាមួយលោកអភិបាលទាំងឡាយ
ជាមួយលោកបូជាចារ្យ និងលោកឧបដ្ឋាក
ព្រមទាំងប្រជារាស្ត្រទាំងអស់
ដែលព្រះអង្គបានលោះធ្វើជាកម្មសិទ្ធិរបស់ព្រះអង្គ ។
សូមទ្រង់បើកភ្នែកយើងខ្ញុំ ឲ្យស្គាល់ពីសេចក្ដីត្រូវការរបស់បងប្អូនយើងខ្ញុំ
សូមបំភ្លឺចិត្តគំនិតយើងខ្ញុំឲ្យពោលពាក្យ និងប្រព្រឹត្តកិច្ចការ
ដើម្បីលើកទឹកចិត្តអស់អ្នកដែលនឿយហត់ និងមានបន្ទុកធ្ងន់ ។
សូមប្រោសឲ្យយើងខ្ញុំបម្រើបងប្អូនទាំងនោះ ដោយចិត្តស្មោះត្រង់
តាមគំរូ និងសេចក្ដីប្រៀនប្រដៅរបស់ព្រះគ្រីស្ត ។
សូមឲ្យព្រះសហគមន៍របស់ព្រះអង្គផ្ដល់សក្ខីភាពដ៏រស់រវើក
អំពីសេចក្ដីពិត និងសេរីភាព
អំពីសន្តិភាព និងយុត្តិធម៌
ដើម្បីឲ្យមនុស្សគ្រប់ៗរូបភ្ញាក់រលឹកក្នុងសេចក្ដីសង្ឃឹមថ្មី ។
សូមព្រះអង្គនឹកដល់អស់បងប្អូនយើងខ្ញុំ (ឈ្មោះ...និងឈ្មោះ...)
ដែលសម្រាន្តលក់ក្នុងសេចក្ដីសុខសាន្តរបស់ព្រះគ្រីស្ត
ព្រមទាំងមរណបុគ្គលទាំងឡាយ
មានតែព្រះអង្គទេ ដែលស្គាល់ជំនឿរបស់អ្នកទាំងនោះ ។
សូមព្រះអង្គទទួលបុគ្គលទាំងនោះ ឲ្យគេមានអំណរសប្បាយ
ក្នុងពន្លឺនៃព្រះភ័ក្ត្រព្រះអង្គ ហើយនៅពេលគេរស់ឡើងវិញ
សូមប្រទានឲ្យគេមានជីវិតពេញបរិបូណ៌ ។
ពេលយើងខ្ញុំបញ្ចប់ដំណើរនៅនាលោកនេះ
សូមព្រះអង្គប្រោសប្រទានឲ្យយើងខ្ញុំ បានទទួលលំនៅស្ថានដ៏ស្ថិតស្ថេរ

[២៤០] នៅទីនេះ អាចបន្ថែមឈ្មោះរបស់លោកអភិបាលឧបត្ថម្ភក ឬអភិបាលជំនួយការផ្សេងៗ តាមពាក្យណែនាំនៃក្បួនពិធីបុណ្យ លេខ ១៤៩។

និងរស់នៅជាមួយព្រះអង្គអស់កល្បជានិច្ច ។
យើងខ្ញុំទាំងអស់គ្នាសូមកោតសរសើរ និងលើកតម្កើងព្រះអង្គ
រួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី ដែលពោរពេញដោយសុភមង្គល
ជាមាតាព្រះជាម្ចាស់ ជាមួយអស់គ្រីស្តទូត និងមរណសាក្សី
(ជាមួយសន្ត...ដែលយើងខ្ញុំគោរពក្នុងថ្ងៃនោះ ឬជាឧបការី)
ព្រមទាំងសន្តបុគ្គលទាំងឡាយ

លោកបូជាចារ្យប្រណម្យដៃ
តាមរយៈព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ ។

៨. លោកបូជាចារ្យលើកបានព្រះកាយ និងពែងព្រះលោហិតក្នុងដៃទាំងពីរ ហើយពោលថា ៖
ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៥៥៥)

# ពិធីបុណ្យគោរពសន្តបុគ្គលទាំងឡាយ

PROPRIUM DE SANCTIS

១. ក្នុងក្បួនពិធីបុណ្យគោរពសន្តបុគ្គលមានបីប្រភេទៈ បុណ្យឱឡារិក បុណ្យធម្មតា និងបុណ្យរំឭក ។ នៅថ្ងៃណាដែលគ្មានបញ្ជាក់ពីបុណ្យប្រភេទណាមួយទេនោះ យើងចាត់ទុកថ្ងៃនោះ ជាបុណ្យរំឭកដែលយើងជ្រើសរើសធ្វើ ឬមិនធ្វើក៏បាន ។

២. ក្នុងសៀវភៅនេះ មានពាក្យអធិដ្ឋានសម្រាប់បុណ្យឱឡារិក និងបុណ្យធម្មតា ។

៣. ទាក់ទងនឹងបុណ្យរំឭកមានពាក្យអធិដ្ឋានដូចតទៅ ៖

ក. បុណ្យរំឭកខ្លះត្រូវប្រើពាក្យអធិដ្ឋានរបស់បុណ្យនោះដែលមានជាស្រាប់ ។

ខ. បុណ្យរំឭកដែលគ្មានពាក្យអធិដ្ឋានជាស្រាប់ សូមជ្រើសរើសពាក្យអធិដ្ឋានរួមតាមមុខងារ (ឧ. មរណសាក្សី គ្រូបាធ្យាយ បព្វជិត បព្វជិតា...) ឬពាក្យអធិដ្ឋានពិសេសតាមសេចក្តីត្រូវការរបស់ព្រះសហគមន៍នីមួយៗ ។

គ. ក្នុងករណីសន្តបុគ្គលណាម្នាក់ ជាមរណសាក្សីផង និងជាអភិបាលព្រះសហគមន៍ផង នោះព្រះសហគមន៍អាចជ្រើសរើសពាក្យអធិដ្ឋានទាក់ទងនឹងបុណ្យរំឭកមរណសាក្សី ឬបុណ្យគោរពលោកអភិបាលព្រះសហគមន៍ ឬបុណ្យទាំងពីរបញ្ចូលគ្នា ។

ឃ. ពេលថ្វាយអភិបូជាគោរពសន្តបុគ្គលណាម្នាក់ ព្រះសហគមន៍អាចជ្រើសរើសពាក្យអធិដ្ឋានគោរពសន្តបុគ្គលរួមតាមមុខងារ ឬពាក្យអធិដ្ឋានគោរពសន្តបុគ្គលទាំងឡាយ ដើម្បីបង្ហាញពីភាពជាសន្តបុគ្គលក្នុងការរស់នៅប្រចាំថ្ងៃរបស់គាត់ ។

ង. ប្រសិនបើមិនមានពាក្យថ្វាយតង្វាយ និងពាក្យអរព្រះគុណជាស្រាប់ទេ សូមជ្រើសរើសពាក្យទាំងនោះពីក្នុងក្បួនពាក្យអធិដ្ឋានរួមតាមមុខងារ ឬពីក្នុងក្បួនពាក្យអធិដ្ឋានតាមរដូវនីមួយៗនៃប្រតិទិន ។

៤. ពាក្យអធិដ្ឋានគោរពសន្តបុគ្គលដែលមានក្នុងក្បួននេះ អាចប្រើដើម្បីថ្វាយអភិបូជាតាមប្រាថ្នា (votive masses) លើកលែងតែពាក្យអធិដ្ឋានក្នុងអភិបូជាលើកតម្កើងព្រឹត្តិការណ៍ដ៏អស្ចារ្យរបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត និងព្រះនាងព្រហ្មចារិនីម៉ារី (តាមសេចក្តីណែនាំក្បួនពិធីរបស់ក្រុងរ៉ូមលេខ ៣៧៥) និងពាក្យអធិដ្ឋានគោរពសន្តបុគ្គលខ្លះដែលមានជាស្រាប់ក្នុងក្បួនអភិបូជាតាមប្រាថ្នា ។

ប្រសិនបើប្រើពាក្យអធិដ្ឋានគោរពសន្តបុគ្គលដើម្បីថ្វាយអភិបូជាតាមប្រាថ្នា គួរតែកែឃ្លាស្តីអំពីពេលវេលាដូចតទៅ "នៅពេលដែលយើងរំឭកដល់..." ។

# ខែ មករា

## ថ្ងៃទី ២ មករា

# សន្តបាស៊ីល និងសន្តក្រេគ័រ
# ជាជនដ៏ប្រសើរឧត្តម នៅណាស៊ីយ៉ាង
# ជាអភិបាល និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**Ss. Basilii Magni et Gregorii Nazianzeni,**
**episcoporum et Ecclesiæ doctorum**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់ !

ព្រះអង្គសព្វព្រះហឫទ័យបំភ្លឺព្រះសហគមន៍ ដោយសារការប្រៀនប្រដៅ និងការរស់នៅរបស់សន្តបាស៊ីល និងសន្តក្រេគ័រ ។

សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យយកចិត្តទុកដាក់

ស្វែងរកសេចក្ដីពិត និងសេចក្ដីស្រឡាញ់

ដើម្បីឲ្យយើងខ្ញុំប្រព្រឹត្តនូវអ្វីៗទាំងអស់ដោយចិត្តសុភាពរាបសារ ។

ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ !

សូមព្រះអង្គទទួលសក្ការបូជាដែលយើងខ្ញុំថ្វាយ

ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ

ក្នុងឱកាសយើងខ្ញុំគោរពសន្តបាស៊ីល និងសន្តក្រេគ័រ ។

សូមទ្រង់ប្រោសឲ្យតង្វាយនេះ ក្លាយទៅជាមធ្យោបាយ

នាំឲ្យយើងខ្ញុំទទួលការសង្គ្រោះអស់កល្បជានិច្ច ។

ពាក្យអរព្រះគុណ

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គបានប្រោសឲ្យយើងខ្ញុំចូលរួមក្នុងពិធីជប់លៀងនៃស្ថានបរមសុខ ។
ក្នុងឱកាសបុណ្យគោរពសន្តបាស៊ីល និងសន្តក្រេគ័រ
សូមព្រះអង្គដែលគង់នៅឯស្ថានដ៏ខ្ពង់ខ្ពស់
ពង្រឹង និងប្រទានកម្លាំងមកយើងខ្ញុំឲ្យរស់នៅតាមជំនឿ និងដើរតាមមាគ៌ានៃការសង្គ្រោះ ដែលព្រះអង្គត្រួសត្រាយសម្រាប់យើងខ្ញុំ ។

# ថ្ងៃទី ៣ មករា

# ព្រះនាមដ៏វិសុទ្ធរបស់ព្រះយេស៊ូ

**Sanctissimi Nominis Iesu**

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ជាព្រះបិតា !
ព្រះអង្គសព្វព្រះហឫទ័យសង្គ្រោះមនុស្សលោក
តាមរយៈព្រះបន្ទូលព្រះអង្គប្រសូតជាមនុស្ស ។
សូមព្រះអង្គប្រណីសន្ដោសឲ្យមនុស្សលោកទទួលស្គាល់ និងអង្វរព្រះនាមនៃព្រះបុត្រាតែមួយរបស់ព្រះអង្គ ។

ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
សូមព្រះអង្គមេត្តាទទួលតង្វាយរបស់យើងខ្ញុំដោយអនុគ្រោះ ។
ព្រះអង្គប្រទានព្រះនាមដ៏វិសុទ្ធថ្វាយព្រះគ្រីស្ត
ដែលបានដាក់ខ្លួនធ្វើតាមព្រះបញ្ជា រហូតដល់សោយទិវង្គតលើឈើឆ្កាង ។
សូមប្រោសឲ្យយើងខ្ញុំទទួលកម្លាំង និងការសង្គ្រោះដែលមកពីព្រះនាមព្រះអង្គ ។

ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គបានទទួល
តង្វាយដែលយើងខ្ញុំថ្វាយ
ដើម្បីលើកតម្កើងព្រះនាមព្រះគ្រីស្ត
ហើយព្រះអង្គបានប្រទានព្រះកាយព្រះគ្រីស្តឲ្យយើងខ្ញុំវិញ ។
សូមព្រះអង្គប្រោសប្រណីឲ្យយើងខ្ញុំត្រេកអរ
ដោយយើងខ្ញុំមានឈ្មោះកត់ទុកនៅស្ថានបរមសុខ ។

## ថ្ងៃទី ៧ មករា

# សន្ត រ៉ៃម៉ុង នៅពេញ៉ាហ្វ័រ ជាបូជាចារ្យ

**S. Raimumdi de Penyafort, presbyteri**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់គង្វាលមួយរូប (Latin p. 933) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ !
ព្រះអង្គបានប្រោសឲ្យសន្តរ៉ៃម៉ុង
មានចិត្តមេត្តាករុណាអាណិតអាសូរដល់អ្នកបាប និងអ្នកជាប់ជាឈ្លើយ ។
តាមរយៈពាក្យទូលអង្វររបស់សន្តរ៉ៃម៉ុង
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យរួចផុតពីទាសភាពនៃអំពើបាប
និងមានសេរីភាពដើម្បីប្រព្រឹត្តតាមព្រះហប្ញទ័យព្រះអង្គ ។

# ថ្ងៃទី ១៣ មករា

# សន្តហ៊ីឡែរ ជាអភិបាល និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Hilarii, episcopi et Ecclesiæ doctoris**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល (Latin p. 929) ឬពាក្យអធិដ្ឋានរួមសម្រាប់គ្រូបាធ្យាយនៃព្រះសហគមន៍ (Latin p. 943) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គបានប្រោសសន្តហ៊ីឡែរ ឲ្យស្គាល់យ៉ាងច្បាស់ថា
ព្រះបុត្រាពិតជាព្រះជាម្ចាស់មែន ។
ព្រះអង្គក៏បានប្រោសលោកឲ្យប្រកាសជំនឿនេះ ដោយមិនរង្គោះរង្គើឡើយ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ ចេះប្រកាសជំនឿដ៏ពិតប្រាកដនៅពេលនេះផង ។

# ថ្ងៃទី ១៧ មករា

# សន្តអន់ទាន់ ជាចៅអធិការ

**S. Antonii, abbatis**

(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាម្ចាស់ !
ព្រះអង្គប្រោសឲ្យសន្តអន់ទាន់ សម្រេចចិត្តលះបង់អ្វីៗទាំងអស់
ទៅរស់នៅជាឥសីក្នុងវាលរហោស្ថាន ។
លោកមានបំណងចង់គោរពបម្រើតែព្រះអង្គគត់ដោយចិត្តស្មោះ
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំសុខចិត្តលះបង់ខ្លួនយើងខ្ញុំដែរ និងស្រឡាញ់ព្រះអង្គលើសអ្វីៗទាំងអស់ ដូចសន្តអន់ទាន់ផង ។

### ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គទទួលតង្វាយដែលយើងខ្ញុំថ្វាយទៅព្រះអង្គ
នៅថ្ងៃគោរពសន្តអន់ទាន់ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំផ្ចង់ចិត្តតែលើព្រះអង្គ កុំឲ្យជំពាក់ចិត្តនឹងសម្បត្តិ
ដ៏មិនទៀងទាត់នៃលោកនេះឡើយ ។

### ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់យើងខ្ញុំ !
ព្រះអង្គបានប្រទានព្រះកាយ និងព្រះលោហិតរបស់ព្រះបុត្រាព្រះអង្គ
ឲ្យយើងខ្ញុំទទួលទានទុកជាអាហារដែលផ្តល់កម្លាំង ។
សូមព្រះអង្គពង្រឹងជំនឿ និងសេចក្តីក្លាហានរបស់យើងខ្ញុំ
ឲ្យបានដូចសន្តអន់ទាន់ដែលឈ្នះការល្បួងគ្រប់យ៉ាងរបស់មារផង ។

## ថ្ងៃទី ២០ មករា

# សន្តហ្វាប៊ីយ៉ាំង ជាសម្តេចប៉ាប និងជាមរណសាក្សី

**S. Fabiani, papæ et martyris**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីមួយរូប (Latin p. 915) ឬពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់សម្តេចប៉ាប (Latin p. 927) ។

### ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាម្ចាស់ !
ព្រះអង្គពិតជាសិរីរុងរឿងរបស់អស់អ្នកដែលបម្រើព្រះអង្គជាបូជាចារ្យ ។ ព្រះអង្គ
បានប្រោសឲ្យសន្តហ្វាប៊ីយ៉ាំងមានចិត្តក្លាហាន
រហូតដល់សុខចិត្តលះបង់ជីវិតព្រោះតែព្រះអង្គ ។ សូមព្រះអង្គប្រោសឲ្យយើងខ្ញុំរួម
គ្នាជាធ្លុងតែមួយក្នុងជំនឿ
និងបម្រើព្រះអង្គអស់ពីដួងចិត្ត ។

# ថ្ងៃទី ២០ មករា
# សន្តសេបាស្យាំង ជាមរណសាក្សី
**S. Sebastiani, martyris**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីមួយរូប (Latin p. 915) ។

## ពាក្យអធិដ្ឋានសរុប
បពិត្រព្រះអម្ចាស់ !
ព្រះអង្គបានប្រោសឲ្យសន្តសេបាស្យាំង មានចិត្តក្លាហានគោរពបម្រើព្រះអង្គ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំប្រព្រឹត្តតាមគំរូរបស់សន្តសេបាស្យាំង
ដោយសុខចិត្តធ្វើតាមព្រះបញ្ជារបស់ព្រះអង្គ ជាជាងធ្វើតាមបង្គាប់របស់មនុស្សលោក ។

# ថ្ងៃទី ២១ មករា
# សន្តីអាញេស ជាព្រហ្មចារិនី និងជាមរណសាក្សី
**S. Agnetis, virginis et martyris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីព្រហ្មចារិនី (Latin p. 924) ឬ ពាក្យអធិដ្ឋានរួមសម្រាប់ព្រហ្មចារិនី ៖ សម្រាប់ព្រហ្មចារិនីមួយរូប (Latin p. 947) ។

## ពាក្យអធិដ្ឋានសរុប
បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ហើយមានព្រះជន្មគង់នៅជានិច្ច !
ព្រះអង្គតែងតែគាំទ្រមនុស្សទន់ខ្សោយឲ្យមានកម្លាំង
ហ៊ានប្រឈមមុខនឹងអ្នកមានអំណាច ។
នៅថ្ងៃនេះ យើងខ្ញុំប្រារព្ធបុណ្យកំណើតនៅស្ថានបរមសុខរបស់សន្តីអាញេស
ដែលបានបូជាជីវិតថ្វាយព្រះអង្គ ។
សូមព្រះអង្គពង្រឹងជំនឿរបស់យើងខ្ញុំឲ្យបានដូចសន្តីអាញេស ។

# ថ្ងៃទី ២២ មករា

# សន្តវ៉ាំងសង់ ជាឧបដ្ឋាក និងជាមរណសាក្សី

**S. Vincentii, diaconi et martyris**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីមួយរូប (Latin p. 915) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គបានប្រោសឲ្យសន្តវ៉ាំងសង់
មានជ័យជម្នះលើអ្នកប្រហារជីវិតលោក ។
សូមមេត្តាប្រទានព្រះវិញ្ញាណព្រះអង្គឲ្យយើងខ្ញុំ
សូមពង្រឹងជំនឿ និងសេចក្ដីស្រឡាញ់របស់យើងខ្ញុំជានិច្ច ។

# ថ្ងៃទី ២៤ មករា

# សន្តហ្វ្រង់ស័រ នៅសាល ជាអភិបាល និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Francisci de Sales, episcopi et Ecclesiæ doctoris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាលមួយរូប (Latin p. 929) ឬពាក្យអធិដ្ឋានរួមសម្រាប់គ្រូបាធ្យាយនៃព្រះសហគមន៍ (Latin p. 943) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យប្រោសឲ្យសន្តហ្វ្រង់ស័រ
យកចិត្តទុកដាក់បម្រើមនុស្សទាំងអស់ក្នុងគ្រប់ប្រការ ។ សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ មានចិត្តស្រឡាញ់ថ្នាក់ថ្នមអ្នកដទៃយ៉ាងខ្លាំង
និងបម្រើគេជារៀងរាល់ថ្ងៃដូចសន្តហ្វ្រង់ស័រ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ !
យើងខ្ញុំសូមថ្វាយ កាយ វាចាចិត្តរបស់យើងខ្ញុំចំពោះព្រះអង្គ ។
សូមព្រះវិញ្ញាណប្រោសឲ្យយើងខ្ញុំមានចិត្តស្លូតបូត
និងមានចិត្តឆេះឆួលស្រឡាញ់ព្រះអង្គ លើសអ្វីៗទាំងអស់ដូចសន្តហ្វ្រង់ស័រ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គបានប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំ ។
សូមព្រះអង្គប្រទានឲ្យយើងខ្ញុំដែលកំពុងរស់នៅលើផែនដីនេះ
មានចិត្តខន្តី ស្លូតបូត និងប្រព្រឹត្តតាមសន្តហ្វ្រង់ស័រដោយសេចក្តីស្រឡាញ់
ដើម្បីទទួលសិរីរុងរឿងឯស្ថានបរមសុខ ។

# ថ្ងៃទី ២៥ មករា

# សន្តប៉ូល ជាគ្រីស្តទូត ប្រែចិត្តគំនិតជឿលើព្រះយេស៊ូ

**IN CONVERSIONE S. PAULI, APOSTOLI**

(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់!
នៅថ្ងៃនេះ យើងខ្ញុំសូមប្រារព្ធបុណ្យសន្តប៉ូលកែប្រែចិត្តគំនិត ។
ព្រះអង្គបានប្រៀនប្រដៅមនុស្សគ្រប់ជាតិសាសន៍
តាមរយៈគ្រីស្តទូតប៉ូលប្រកាសដំណឹងល្អ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំហ៊ានធ្វើជាសាក្សី
បញ្ជាក់ពីសេចក្តីពិតរបស់ព្រះអង្គចំពោះមនុស្សលោក ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ !
ក្នុងអភិបូជានេះ យើងខ្ញុំនាំគ្នាលើកតម្កើងព្រះបុត្រាព្រះអង្គ
ដែលទ្រង់បានប្រោសឲ្យគ្រីស្តទូតប៉ូលមានជំនឿបំភ្លឺមនុស្សលោក ។
សូមព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺឲ្យយើងខ្ញុំមានជំនឿដូចសន្តប៉ូល
ដែលបង្ហាញសិរីរុងរឿងរបស់ព្រះអង្គ ។

ធម៌ប្រារព្ធទី ១ បុណ្យគោរពគ្រីស្តទូត ទំព័រ ៤៧៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គបានប្រទានព្រះកាយ និងព្រះលោហិតព្រះបុត្រាឲ្យយើងខ្ញុំ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំមានចិត្តឆេះឆួលស្រឡាញ់ព្រះអង្គ
ដោយរស់នៅដូចសន្តប៉ូលដែលយកចិត្តទុកដាក់
ប្រមែប្រមូលព្រះសហគមន៍នានាឲ្យទៅជាផ្លូងតែមួយ ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក ទំព័រ... ។

# ថ្ងៃទី ២៦ មករា

# សន្តធីម៉ូថេ និងសន្តទីតុស ជាអភិបាល

**Ss. Timothei et Titi, episcoporum**

(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាម្ចាស់ !
ព្រះអង្គបានប្រទានឲ្យសន្តធីម៉ូថេ និងសន្តទីតុស
មានគុណធម៌ដ៏ប្រសើរដូចគ្រីស្តទូតឯទៀតៗ ។ តាមរយៈពាក្យទូលអង្វររបស់សន្តទាំងពីរ
សូមព្រះអង្គប្រោសយើងខ្ញុំដែលកំពុងរស់នៅក្នុងលោកនេះ
ឲ្យមានចិត្តសុចរិត និងស្មោះស្ម័គ្រចំពោះព្រះជាម្ចាស់
ព្រមទាំងទន្ទឹងរង់ចាំសុភមង្គលឯស្ថានបរមសុខ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ !
ក្នុងឱកាសដែលយើងខ្ញុំប្រារព្ធបុណ្យសន្តធីម៉ូថេ និងសន្តទីតុស
សូមព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយរួមជាមួយយើងខ្ញុំ
ដែលជាប្រជារាស្ត្ររបស់ព្រះអង្គ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គបានប្រទានព្រះកាយព្រះគ្រីស្តទុកជាអាហារចិញ្ចឹមជំនឿ
ដែលយើងខ្ញុំបានទទួលមកពីការប្រកាសដំណឹងល្អរបស់គ្រីស្តទូត ។ សូមព្រះអង្គប្រោសយើងខ្ញុំឲ្យបន្តបេសកកម្មជាគ្រីស្តទូត
ក្នុងជីវិតយើងខ្ញុំដូចសន្តធីម៉ូថេ និងសន្តទីតុស ។

# ថ្ងៃទី ២៧ មករា
# សន្តីអង់ហ្សែល ម៉េរីស៊ី ជាព្រហ្មចារិនី

**S. Angelæ Merici, virginis**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់ព្រហ្មចារិនី ៖ សម្រាប់ព្រហ្មចារិនីមួយរូប (Latin p. 947) ឬពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់អ្នកអប់រំ (Latin p. 965) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ !

ព្រះអង្គសព្វព្រះហឫទ័យត្រាស់ហៅសន្តីអង់ហ្សែលជាព្រហ្មចារិនី
ដែលអង្វរព្រះជាម្ចាស់ឥតឈប់ឈរឲ្យយើងខ្ញុំ ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿរបស់យើងខ្ញុំ
ឲ្យបានធ្វើសាក្សីអំពីជំនឿរបស់ខ្លួនគ្រប់ពេលវេលា ដោយសេចក្តីស្រឡាញ់
និងមានការប្រុងប្រយ័ត្នដូចសន្តីអង់ហ្សែល ។

# ថ្ងៃទី ២៨ មករា

# សន្តថូម៉ាស នៅអគីណូ ជាបូជាចារ្យ និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Thomæ de Aquino, presbyteri et Ecclesiæ doctoris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់គ្រូបាធ្យាយនៃព្រះសហគមន៍ (Latin p. 943) ឬពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់គង្វាលមួយរូប (Latin p. 933) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាម្ចាស់ !

ព្រះអង្គបានប្រោសឲ្យសន្តថូម៉ាស មានចិត្តក្លៀវក្លាស្វែងរកភាពដ៏វិសុទ្ធ
និងយកចិត្តទុកដាក់ពន្យល់លទ្ធិគ្រីស្តសាសនាដល់មនុស្សលោក ។
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំ
ឲ្យយល់ពីការប្រៀនប្រដៅរបស់សន្តថូម៉ាស និងធ្វើតាមគំរូរស់នៅរបស់លោក ។

# ថ្ងៃទី ៣១ មករា

# សន្តយ៉ូហានបូស្កូ ជាបូជាចារ្យ

**S. Ioannis Bosco, presbyteri**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់គង្វាលមួយរូប (Latin p. 933) ឬពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់អ្នកអប់រំ (Latin p. 965) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ជាព្រះបិតា !

ព្រះអង្គបានប្រោសឲ្យសន្តយ៉ូហានបូស្កូ ជាបូជាចារ្យ យកចិត្តទុកដាក់ថែរក្សា
និងអប់រំយុវជន ដូចឪពុកបង្កើតអប់រំ និងថែរក្សាកូនរបស់ខ្លួន ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យមានចិត្តឆេះឆួលស្រឡាញ់អ្នកដទៃ
ដើម្បីណែនាំបងប្អូនឲ្យស្គាល់ និងបម្រើព្រះអង្គតែមួយគត់ដូចសន្តយ៉ូហានបូស្កូ ។

# ខែ កុម្ភៈ

## ថ្ងៃទី ២ កុម្ភៈ

# បុណ្យថ្វាយព្រះឱរសយេស៊ូនៅក្នុងព្រះវិហារ

**IN PRÆSENTATIONE DOMINI**

(បុណ្យ)

## ពិធីប្រទានពរលើទៀន និងក្បួនហែរ

**De benediction et processione candelarum**

១. គ្រីស្តបរិស័ទកាន់ទៀនជួបជុំគ្នានៅកន្លែងមួយខាងក្រៅព្រះវិហារ ។

២. លោកបូជាចារ្យពាក់អាវវែងពណ៌ស សម្រាប់ដង្ហែព្រះកាយព្រះគ្រីស្ត និងអ្នកបម្រើពិធីបុណ្យ ចូលរួមជាមួយអង្គប្រជុំ ។

៣. នៅពេលអុជទៀន អង្គប្រជុំចាប់ផ្ដើមច្រៀងបន្ទរមួយដូចខាងក្រោម ៖




៤. បន្ទាប់ពីបទចម្រៀង បូជាចារ្យពោលថា ៖ ក្នុងព្រះនាមព្រះបិតា និងព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។ លោកបូជាចារ្យស្វាគមន៍អង្គប្រជុំ ហើយពន្យល់ពីអត្ថន័យពិធីបុណ្យលោកអាចពោលពាក្យដូចតទៅ ៖

បងប្អូនជាទីស្រឡាញ់ !

បុណ្យព្រះអម្ចាស់យេស៊ូប្រសូតបានកន្លងផុតទៅសែសិបថ្ងៃហើយ ។
ថ្ងៃនេះប្រសើរណាស់ ដ្បិតព្រះនាងម៉ារី និងលោកយ៉ូសែប
បានយកព្រះឱរសយេស៊ូថ្វាយព្រះជាម្ចាស់ក្នុងព្រះវិហារក្រុងយេរូសាឡឹម ។
តាមរូបភាពខាងក្រៅព្រះអម្ចាស់យាងមកបំពេញធម្មវិន័យ ប៉ុន្តែលើសពីនេះទៅទៀត ព្រះអង្គយាងមកដើម្បីទាក់ទងជាមួយអស់អ្នកជឿ
ដែលជាប្រជារាស្ត្រដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ។

ពេលនោះ ព្រះវិញ្ញាណដ៏វិសុទ្ធបានជំរុញឲ្យលោកតាស៊ីម៉ូន និងលោកយាយហាណ្ណាមកព្រះវិហារ ។
ព្រះវិញ្ញាណក៏បានបំភ្លឺពួកគាត់ឲ្យទទួលព្រះអម្ចាស់ និងប្រកាសជំនឿលើព្រះអង្គដោយត្រេកអរសប្បាយ ។
ដូច្នេះ ពេលនេះសូមព្រះវិញ្ញាណដ៏វិសុទ្ធបង្រួបបង្រួមយើងខ្ញុំ
ឲ្យបន្តដំណើរចូលក្នុងដំណាក់របស់ព្រះជាម្ចាស់ដើម្បីជួបនឹងព្រះគ្រីស្ត ។
នៅទីនោះ ក្នុងពិធីកាច់នំប៉័ង យើងអាចជួប និងទទួលព្រះអង្គ
រហូតដល់ពេលព្រះអង្គយាងមកវិញប្រកបដោយសិរីរុងរឿង ។

៥. បន្ទាប់ពីប្រកាសហើយ លោកបូជាចារ្យលាតដៃធ្វើព្រះពរលើទៀន ទាំងពោលថា ៖

សូមបងប្អូនតាំងចិត្តអធិដ្ឋាន

ឱ ព្រះជាម្ចាស់ ជាប្រភពនិងប្រភពដើមនៃពន្លឺទាំងអស់អើយ!
ថ្ងៃនេះ ព្រះអង្គបានបំភ្លឺមនុស្សគ្រប់ជាតិសាសន៍ឲ្យស្គាល់ព្រះអង្គ
តាមរយៈលោកតាស៊ីម៉ូនជាមនុស្សសុចរិត ។
សូមព្រះអង្គប្រទានព្រះពរ ✠ លើទៀន
ដែលយើងខ្ញុំនឹងប្រើដើម្បីលើកតម្កើងព្រះនាមព្រះអង្គ ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យរស់នៅក្នុងគុណធម៌
និងស្វែងរកពន្លឺរបស់ព្រះអង្គដែលមិនចេះរលត់ ។

អង្គប្រជុំឆ្លើយ ៖ អាម៉ែន ។

លោកយកទឹកព្រះពរមកប្រោះលើទៀនដោយស្ងៀមស្ងាត់ ហើយដុតកំញានរៀបចំហែចូលក្នុងព្រះវិហារ ។

៦. ក្រោយពេលលោកបូជាចារ្យបានទទួលទៀនដែលកំពុងឆេះពីលោកឧបដ្ឋាក ឬអ្នកបម្រើពិធីបុណ្យ ពិធីហែចូលក្នុងព្រះវិហារចាប់ផ្ដើម ។ លោកឧបដ្ឋាកប្រកាសថា ៖

ចូរយើងទៅជួបព្រះអម្ចាស់ដោយសេចក្ដីសុខសាន្ត ។

ឬ

ចូរយើងទៅមុខដោយសេចក្ដីសុខសាន្ត ។

អង្គប្រជុំឆ្លើយទាំងអស់គ្នា ៖ ក្នុងព្រះនាមព្រះគ្រីស្ត ។ អាម៉ែន ។

៧. អង្គប្រជុំកាន់ទៀនកំពុងឆេះ ។ ពេលហែចូលគួរឲ្យយើងសូត្រទំនុកតម្កើង ឬច្រៀងបទមួយស្រង់ពីព្រះគម្ពីរ លូកា ២.២៩-៣២ ។

បន្ទរ ៖

នេះជាពន្លឺដែលនាំឲ្យមនុស្សគ្រប់ជាតិសាសន៍ស្គាល់ព្រះអង្គ
និងជាសិរីរុងរឿងរបស់អ៊ីស្រាអែលជាប្រជារាស្ត្រព្រះអង្គ ។

ឱ ព្រះអម្ចាស់អើយ !
ឥឡូវនេះ សូមឲ្យទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ
លាចាកលោកនេះទៅដោយសុខសាន្ត ស្របតាមព្រះបន្ទូលសន្យារបស់ព្រះអង្គ ។

បន្ទរ ៖

នេះជាពន្លឺដែលនាំឲ្យមនុស្សគ្រប់ជាតិសាសន៍ស្គាល់ព្រះអង្គ...
ភ្នែកទូលបង្គំបានឃើញការសង្គ្រោះរបស់ព្រះអង្គហើយ ។

បន្ទរ ៖

នេះជាពន្លឺដែលនាំឲ្យមនុស្សគ្រប់ជាតិសាសន៍ស្គាល់ព្រះអង្គ...
និងជាពន្លឺដែលព្រះអង្គបានប្រទានឲ្យប្រជាជាតិទាំងអស់ ។

បន្ទរ ៖

នេះជាពន្លឺដែលនាំឲ្យមនុស្សគ្រប់ជាតិសាសន៍ស្គាល់ព្រះអង្គ...

៨. ពេលក្បួនដង្ហែដល់ក្នុងព្រះវិហារ អង្គប្រជុំច្រៀងបទចូល ។ ពេលលោកបូជាចារ្យទៅដល់ទីសក្ការៈ លោកគោរពតុសក្ការបូជា ហើយលោកបក់កំញាន បើសិនជាអាចធ្វើបាន ។ បន្ទាប់មក លោកដើរទៅអាសនៈដោះអាវដង្ហែចេញ និងពាក់អាវអភិបូជាវិញ ។ បន្ទាប់ពីសូមធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ លោកពោលពាក្យអធិដ្ឋានសរុប និងបន្តអភិបូជាតាមធម្មតា ។

# អភិបូជា

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ ហើយមានព្រះជន្មគង់នៅជានិច្ច !
ព្រះអង្គស្រឡាញ់មនុស្សលោកខ្លាំងណាស់
រហូតដល់ចាត់ព្រះបុត្រាតែមួយរបស់ព្រះអង្គមកប្រសូត្រជាមនុស្ស ។
នៅថ្ងៃនេះ យើងខ្ញុំនាំគ្នានឹករឭកដល់ព្រះបុត្រា ដែលនាងម៉ារី
និងលោកយ៉ូសែបយកទៅថ្វាយព្រះអម្ចាស់ ក្នុងព្រះវិហារក្រុងយេរូសាឡឹម ។
ដោយព្រះហឫទ័យប្រណីសន្ដោស
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យថ្វាយខ្លួនទៅព្រះអង្គដោយចិត្តបរិសុទ្ធផង ។

ប្រសិនបើបុណ្យនេះ ប្រារព្ធចំនឹងថ្ងៃអាទិត្យ សូមសូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គសព្វព្រះហឫទ័យឲ្យព្រះបុត្រាតែមួយ ដែលជាកូនចៀមដ៏ល្អឥតខ្ចោះ
ទៅជាតង្វាយរបស់ព្រះសហគមន៍ ដើម្បីឲ្យពិភពលោកមានជីវិត ។
យើងខ្ញុំសូមអង្វរព្រះអង្គមេត្តាទទួលតង្វាយ
ដែលព្រះសហគមន៍មានអំណរសប្បាយថ្វាយទៅព្រះអង្គ ។

ធម៌ប្រារព្ធ ៖ អាចកំបាំងដ៏អស្ចារ្យនៃការថ្វាយព្រះឱរសយេស៊ូនៅក្នុងព្រះវិហារ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ និងគង់នៅអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ថ្ងៃនេះ នាងម៉ារី និងលោកយ៉ូសែប បានថ្វាយព្រះបុត្រា
ដែលមានព្រះជន្មគង់ជាមួយព្រះអង្គ នៅក្នុងព្រះវិហារក្រុងយេរូសាឡឹម
ហើយព្រះវិញ្ញាណដ៏វិសុទ្ធបានប្រកាសថា ព្រះយេស៊ូជាសិរីរុងរឿងរបស់អ៊ីស្រាអែល
និងជាពន្លឺដែលបំភ្លឺមនុស្សលោក ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំមានអំណរសប្បាយ
ចូលរួមជាមួយអស់ទេវទូត និងសន្តបុគ្គលទាំងឡាយ
ទទួលព្រះសង្គ្រោះ និងលើកតម្កើងព្រះអង្គ
ដោយប្រកាសថា៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !

### ពាក្យអរព្រះគុណ
បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គបានប្រទានព្រះកាយព្រះគ្រីស្តឲ្យយើងខ្ញុំ
និងប្រោសឲ្យយើងខ្ញុំមានលក្ខណៈពេញលេញ ។
ព្រះអង្គបាត់ព្រះយេស៊ូជាព្រះគ្រីស្តឲ្យយាងមកក្នុងលោកនេះ
ដើម្បីបំពេញសេចក្តីសង្ឃឹមរបស់លោកស៊ីម្ញ៉ូន
និងសេចក្តីសង្ឃឹមរបស់មនុស្សលោក ។
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យជួបព្រះអម្ចាស់
និងទទួលជីវិតអស់កល្បជានិច្ច ។

# ថ្ងៃទី ៣ កុម្ភៈ

# សន្តប្លែស ជាអភិបាល និងជាមរណសាក្សី

**S. Blasii, episcopi et martyris**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីមួយរូប (Latin p. 915) ឬពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល (Latin p. 929) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គតែងតែស្ដាប់ពាក្យអង្វររបស់ប្រជារាស្ត្រព្រះអង្គ
ដោយប្រោសឲ្យគេរស់នៅតាមគំរូសន្តប្លែសដែលបានបូជាជីវិត ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំរស់នៅដោយសេចក្ដីសុខសាន្ត និងមានអំណរសប្បាយក្នុងលោកនេះ
ព្រមទាំងមានជីវិតអស់កល្បជានិច្ចនៅលោកខាងមុខ ។

# សន្តអង់ហ្សែរ ជាអភិបាលព្រះសហគមន៍

**S. Ansgarii, episcopi**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់សាសនទូត (Latin p. 938) ឬសម្រាប់អភិបាល (Latin p. 929) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាម្ចាស់ !
ព្រះអង្គសព្វព្រះហឫទ័យចាត់សន្តអង់ហ្សែរ
ជាអភិបាលឲ្យមកបំភ្លឺមនុស្សជាច្រើន ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំដើរក្នុងពន្លឺនៃសេចក្ដីពិតរបស់ព្រះអង្គ
តាមរយៈពាក្យទូលអង្វររបស់សន្តអង់ហ្សែរផង ។

## ថ្ងៃទី ៥ កុម្ភៈ

# សន្តីអាហ្កាថ ជាព្រហ្មចារិនី និងជាមរណសាក្សី

**S. Agathæ, virginis et martyris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីជាព្រហ្មចារិនី (Latin p. 924) ឬ ពាក្យអធិដ្ឋានរួមសម្រាប់ព្រហ្មចារិនី ៖ សម្រាប់ព្រហ្មចារិនីមួយរូប (Latin p. 947) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់យើងខ្ញុំ !

ព្រះអង្គប្រោសឲ្យសន្តីអាហ្កាថ ថ្វាយខ្លួនទាំងស្រុងទៅព្រះអង្គជាព្រហ្មចារិនី

និងមានចិត្តក្លាហានហ៊ានបូជាជីវិត ។

សូមព្រះអង្គមេត្តាស្តាប់ពាក្យអង្វររបស់សន្តីអាហ្កាថ សម្រាប់យើងខ្ញុំផង ។

## ថ្ងៃទី ៦ កុម្ភៈ

# សន្តប៉ូល មីគី និងសហជីវិន ជាមរណសាក្សី

**Ss. Pauli Miki et sociorum, martyrum**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សី (Latin p. 909) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាម្ចាស់ !

ព្រះអង្គពិតជាកម្លាំង និងជាសេចក្តីក្លាហាននៃសន្តបុគ្គលទាំងឡាយ ។

ព្រះអង្គសព្វព្រះហឫទ័យត្រាស់ហៅសន្តប៉ូល មីគី

និងសហជីវិនរបស់លោកឲ្យទទួលជីវិតដ៏ពេញលេញតាមរយៈឈើឆ្កាង ។

សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យមានចិត្តក្លាហាន

ប្រកាសជំនឿរហូតដល់ហ៊ានបូជាជីវិត ។

# ថ្ងៃទី ៨ កុម្ភៈ

# សន្តយេរ៉ូម អេមីលីយ៉ាំង

**S. Hieronymi Emiliani**

ពាក្យអធិដ្ឋានរួមសម្រាប់សន្ត: សន្តី ៖ សម្រាប់អ្នកអប់រំ (Latin p.965) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ជាព្រះបិតាដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះអង្គប្រោសឲ្យសន្តយេរ៉ូម អេមីលីយ៉ាំង
ថែទាំ និងការពារកូនកំព្រាដូចឪពុកបង្កើត ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំទទួលព្រះវិញ្ញាណ
ដែលធ្វើឲ្យយើងខ្ញុំទៅជាបុត្រធីតាដ៏ពិតប្រាកដរបស់ព្រះអង្គ ។

# សន្តីយ៉ូសែហ្វីន បាគីតា ជាព្រហ្មចារិនី

**S. Iosephinæ Bakhita, virginis**

ពាក្យអធិដ្ឋានរួមសម្រាប់ព្រហ្មចារិនី ៖ សម្រាប់ព្រហ្មចារិនីមួយរូប (Latin p. 947) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាម្ចាស់ !
ព្រះអង្គបានណែនាំសន្តីយ៉ូសែហ្វីន បាគីតា
ចេញពីទាសករឲ្យមានកិត្តិយសទៅជាបុត្រីរបស់ព្រះអង្គ
និងថ្វាយខ្លួនជាព្រហ្មចារិនីដែលជាភរិយារបស់ព្រះគ្រីស្ត ។ សូមព្រះអង្គប្រោស
យើងខ្ញុំឲ្យចេះស្រឡាញ់ព្រះអម្ចាស់យេស៊ូ
ដែលសោយទិវង្គតនៅលើឈើឆ្កាង និងមានចិត្តមេត្តាករុណាចំពោះអ្នកដទៃ
តាមគំរូរបស់សន្តីយ៉ូសែហ្វីន បាគីតា ។

# ថ្ងៃទី ១០ កុម្ភៈ

# សន្តី ស្កូឡាស្ទីក ជាព្រហ្មចារិនី

**S. Scholasticæ, virginis**

(បុណ្យរំឮក)

ពាក្យអធិដ្ឋានរួមសម្រាប់ព្រហ្មចារិនី ៖ សម្រាប់ព្រហ្មចារិនីមួយរូប (Latin p. 947) ឬពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់ដូនជីសម្ងាត់ ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ !
ថ្ងៃនេះ យើងខ្ញុំសូមរំឭកដល់ សន្តីស្កូឡាស្ទីក ជាទីគាប់ព្រះហឫទ័យព្រះអង្គ ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យចេះបម្រើព្រះអង្គដោយចិត្តស្មោះ
តាមគំរូរបស់ សន្តីស្កូឡាស្ទីក និងឲ្យយើងខ្ញុំមានអំណរសប្បាយ
ទទួលសេចក្តីស្រឡាញ់ដែលមកពីព្រះអង្គ ។

# ថ្ងៃទី ១១ កុម្ភៈ

# ព្រះនាងម៉ារីនៅលួរដ៍

**Beatæ Mariæ Virginis de Lourdes**

ពាក្យអធិដ្ឋានរួមសម្រាប់ព្រះនាងព្រហ្មចារិនីម៉ារីពោរពេញដោយសុភមង្គល (Latin p. 897) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាម្ចាស់ដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះអង្គតែងតែយាងមកជួយការពារយើងខ្ញុំជាអ្នកទន់ខ្សោយ ។ នៅពេលយើងខ្ញុំរំឭកដល់ព្រះមាតាដ៏និមលរបស់ព្រះជាម្ចាស់
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យក្រោកចេញពីអំពើបាបនានា
តាមពាក្យអង្វររបស់ព្រះមាតាផង ។

## ថ្ងៃទី ១៤ កុម្ភៈ

# សន្តស៊ីរីល ជាបព្វជិត និងសន្តម៉េតូដ ជាអភិបាលព្រះសហគមន៍

**S. Cyrilli, monachi, et Methodii, episcop**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាអម្ចាស់ ! ព្រះអង្គបំភ្លឺជនជាតិស្លាវច្រើននាក់ឲ្យស្គាល់ព្រះអង្គ តាមរយៈសន្តស៊ីរីល និងសន្តម៉េតូដ ជាបងប្អូន ។
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យយល់ពីអត្ថន័យនៃព្រះបន្ទូល និងមានជំនឿពិតប្រាកដ ព្រមទាំងរួបរួមគ្នាជាផ្លូងតែមួយ ។

ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ ! ថ្ងៃនេះ យើងខ្ញុំនឹករឭកដល់សន្តស៊ីរីល និងសន្តមេតូដ
សូមព្រះអង្គទតមើលតង្វាយដែលយើងខ្ញុំថ្វាយចំពោះព្រះអង្គ
ជាព្រះដ៏មានឫទ្ធានុភាពសព្វប្រការ ។
សូមព្រះអង្គប្រោសតង្វាយនេះ ឲ្យទៅជាសញ្ញាសម្គាល់នៃមនុស្សលោកថ្មី
ដែលស្រុះស្រួលជាមួយព្រះអង្គក្នុងសេចក្ដីស្រឡាញ់ ។

ពាក្យអរព្រះគុណ

បពិត្រព្រះជាម្ចាស់ ជាព្រះបិតានៃមនុស្សគ្រប់ជាតិសាសន៍ !
ព្រះអង្គប្រោសឲ្យយើងខ្ញុំចូលរួមក្នុងព្រះកាយព្រះគ្រីស្តតែមួយ និងក្នុងព្រះវិញ្ញាណតែមួយ ព្រមទាំងចូលរួមក្នុងពិធីជប់លៀង
អស់កល្បជានិច្ចទុកជាមរតក ។
នៅថ្ងៃនេះ យើងខ្ញុំគោរពសន្តស៊ីរីល និងសន្តមេតូដ
សូមព្រះអង្គមេត្តាថែរក្សាយើងខ្ញុំជាបុត្រធីតារបស់ព្រះអង្គ
ឲ្យមានជំនឿតែមួយ មានចិត្តថ្លើមតែមួយ
ដើម្បីកសាងព្រះរាជ្យប្រកបដោយយុត្តិធម៌ និងសេចក្ដីសុខសាន្ត ។

## ថ្ងៃទី ១៧ កុម្ភៈ

# សន្តទាំង ៧ ជាអ្នកបង្កើតក្រុមគ្រួសារបម្រើព្រះនាងម៉ារី

**Ss. septem Fundatorum Ordinis Servorum B. M. V.**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់បព្វជិត (Latin p. 961) ។

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់យើងខ្ញុំ ! ព្រះអង្គប្រោសឲ្យសន្តទាំងប្រាំពីរនាក់
ជាប់ចិត្តស្រឡាញ់ព្រះមាតានៃព្រះជាម្ចាស់យ៉ាងខ្លាំង ។
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យមានចិត្តគោរពប្រណិប័តន៍ព្រះមាតា
ព្រមទាំងណែនាំប្រជារាស្ត្រជាច្រើនថ្វាយទៅព្រះអង្គ តាមគំរូសន្តទាំងប្រាំពីរនាក់ ។

## ថ្ងៃទី ២១ កុម្ភៈ

# សន្តសិលា ដាមីយ៉ាំង ជាអភិបាល និងជាគ្រូបាធ្យាយ នៃព្រះសហគមន៍

**S. Petri Damiani, episcopi et Ecclesiæ doctoris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់គ្រូបាធ្យាយនៃព្រះសហគមន៍ (Latin p. 943) ឬពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល (Latin p. 929) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គប្រោសសន្តសិលា ដាមីយ៉ាំងឲ្យលះបង់អ្វីៗទាំងអស់ថ្វាយទៅព្រះគ្រីស្ត
និងបម្រើព្រះសហគមន៍របស់ព្រះអង្គដោយអស់ពីចិត្ត ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យស្តាប់តាមការបង្រៀន និងរស់នៅ
តាមគំរូរបស់សន្តសិលា ដាមីយ៉ាំង ដើម្បីទទួលនូវអំណរសប្បាយមកពីព្រះអង្គ
ដែលជាពន្លឺអស់កល្បជានិច្ច ។

## ថ្ងៃទី ២២ កុម្ភៈ

# អាសនៈ សន្តសិលា ជាគ្រីស្តទូត

**CATHEDRÆ S. PETRI, APOSTOLI**

(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គសព្វព្រះហឫទ័យតែងតាំងព្រះសហគមន៍
ឲ្យស្ថិតនៅលើថ្មគ្រឹះដ៏រឹងមាំ គឺលើជំនឿរបស់សន្តសិលា ។
សូមព្រះអង្គប្រោសប្រណីយើងខ្ញុំឲ្យរួចផុតពីអន្តរាយគ្រប់បែបយ៉ាង
ដែលរារាំងព្រះសហគមន៍សព្វថ្ងៃនេះ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គតែងតែស្តាប់ពាក្យអង្វរ និងទទួលតង្វាយពីយើងខ្ញុំដោយអនុគ្រោះ ។
សូមព្រះអង្គប្រោសឲ្យព្រះសហគមន៍មានជំនឿពេញលក្ខណៈ
តាមការណែនាំរបស់គ្រីស្តទូតសិលាជាគង្វាល
និងឲ្យយើងខ្ញុំទទួលជីវិតអស់កល្បជានិច្ចទុកជាមរតក ។

ធម៌ប្រារព្ធទី ១ បុណ្យគោរពគ្រីស្តទូត ទំព័រ ៤៧៦ ។

## ពាក្យអរព្រះគុណ

ឱ ព្រះបិតាជាអម្ចាស់ !
នៅថ្ងៃនេះ យើងខ្ញុំគោរពសន្តសិលាជាគ្រីស្តទូត យើងខ្ញុំសូមអរព្រះគុណព្រះអង្គ
ដែលចិញ្ចឹមយើងខ្ញុំដោយប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ។
សូមព្រះអង្គប្រោសលោះយើងខ្ញុំឲ្យរួមរស់ជាមួយគ្នាជាផ្លូវតែមួយ
ប្រកបដោយសេចក្តីសុខសាន្ត ។

យើងអាចប្រើពាក្យប្រទានពរក្នុងពិធីឱឡារិកនៅ ទំព័រ ៥៦០ ។

# ថ្ងៃទី ២៣ កុម្ភៈ

# សន្តប៉ូលីកាព ជាអភិបាល និងជាមរណសាក្សី

**S. Polycarpi, episcopi et martyris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីមួយរូប (Latin p. 915) ឬពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល (Latin p. 929) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដែលបង្កើតអ្វីៗទាំងអស់ !

ព្រះអង្គប្រោសឲ្យសន្តប៉ូលីកាព មានកិត្តិយសចូលរួមក្នុងក្រុមមរណសាក្សី ។ សូមព្រះអង្គប្រោសយើងខ្ញុំឲ្យចូលរួមក្នុងទុក្ខលំបាករបស់ព្រះគ្រីស្ត ដើម្បីឲ្យយើងខ្ញុំរស់ឡើងវិញក្នុងជីវិតអស់កល្បជានិច្ច ។

# ខែ មីនា

## ថ្ងៃទី ៤ មីនា

# សន្តកាស៊ីមៀរ

**S. Casimiri**

ពាក្យអធិដ្ឋានរួមសម្រាប់សន្ត: សន្តី ៖ សម្រាប់សន្ត:មួយរូប (Latin p. 956) ។

### ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គបំភ្លឺចិត្តគំនិតសន្តកាស៊ីមៀរឲ្យយល់ថា
អស់អ្នកបម្រើព្រះអង្គ គឺជាអ្នកគ្រងរាជ្យរួមជាមួយព្រះអង្គ ។
សូមទ្រង់ប្រោសឲ្យយើងខ្ញុំបម្រើព្រះអង្គ ដោយយុត្តិធម៌ និងចិត្តបរិសុទ្ធ ។

## ថ្ងៃទី ៧ មីនា

# សន្តីប៉ែរពេទុយ និងសន្តីហ្វេលីស៊ីតេ ជាមរណសាក្សី

**Ss. Perpetuæ et Felicitalis, martyrum**

(បុណ្យរំឭក)

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់ !
សេចក្ដីស្រឡាញ់របស់ព្រះអង្គបានជំរុញឲ្យសន្តីប៉ែរពេទុយ និងសន្តីហ្វេលីស៊ីតេ
ហ៊ានពុះពារទារុណកម្មគ្រប់យ៉ាង រហូតដល់បូជាជីវិតថ្វាយព្រះអង្គ ។
តាមរយ:សន្តីប៉ែរពេទុយ និងហ្វេលីស៊ីតេ
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យចេះស្រឡាញ់ព្រះអង្គកាន់តែខ្លាំងឡើងៗ ។

ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់យើងខ្ញុំ !

នៅថ្ងៃនេះ យើងខ្ញុំសូមថ្វាយតង្វាយទាំងមានអំណរសប្បាយដោយដឹងថា សន្តប៉ែរពេទុយ និងសន្តីហ្វេលីស៊ីតេ ចូលស្ថានបរមសុខរួមជាមួយព្រះអង្គ ។ យើងខ្ញុំសូមប្រកាសនូវស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះអង្គ និងត្រេកអរសប្បាយ ដែលមានសន្តីប៉ែរពេទុយ និងសន្តីហ្វេលីស៊ីតេ ជួយអង្វរព្រះអង្គឲ្យយើងខ្ញុំ ។

ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !

ព្រះអង្គប្រោសឲ្យយើងខ្ញុំមានអំណរសប្បាយទទួលព្រះកាយព្រះគ្រីស្ត នៅថ្ងៃគោរពសន្តីប៉ែរពេទុយ និងសន្តីហ្វេលីស៊ីតេ ។ យើងខ្ញុំសូមទូលអង្វរព្រះអង្គប្រោសប្រទានចិត្តសុភាពរាបសារ ឲ្យយកចិត្តទុកដាក់បម្រើព្រះអង្គ និងស្គាល់ពីព្រះអំណោយទានរបស់ព្រះអង្គ ។

## ថ្ងៃទី ៨ មីនា

# សន្តយ៉ូហាន ជាបព្វជិតដែលគោរពព្រះជាម្ចាស់

**S. Ioannis a Deo, religiosi**

ពាក្យអធិដ្ឋានរួមសម្រាប់សន្ត: សន្តី ៖ សម្រាប់បព្វជិត (Latin p. 961) ឬពាក្យអធិដ្ឋានរួមសម្រាប់អ្នកដែលបំពេញកិច្ចការនៃធម៌មេត្តាករុណា (Latin p. 963) ។

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !

ព្រះអង្គប្រោសឲ្យសន្តយ៉ូហាន មានចិត្តអាណិតអាសូរអ្នកជំងឺពន់ពេក ។ សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំស្ម័គ្រចិត្តបម្រើបងប្អូនដោយចិត្តស្រឡាញ់ ដូច្នេះ យើងខ្ញុំសង្ឃឹមថា ព្រះអង្គនឹងជ្រើសរើសយើងខ្ញុំឲ្យចូល ក្នុងព្រះរាជ្យព្រះអង្គនៅថ្ងៃណាមួយ ។

# ថ្ងៃទី ៩ មីនា

# សន្តីហ្វ្រង់ស៊ីស្កា ជាបព្វជិតា និងជាអ្នកក្រុងរ៉ូម

**S. Franciscæ Romanæ, religiosæ**

ពាក្យអធិដ្ឋានរួមសម្រាប់សន្ត: សន្តី ៖ សម្រាប់សន្តី (Latin p. 966) ឬ សម្រាប់បព្វជិតា (Latin p. 961) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រោសឲ្យសន្តីហ្វ្រង់ស៊ីស្កា ជាអ្នកក្រុងរ៉ូម
ធ្វើជាគំរូដល់អស់អ្នកដែលមានគ្រួសារ និងក្រុមគ្រួសារបព្វជិតា ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យយកចិត្តទុកដាក់បម្រើព្រះអង្គ
ក្នុងគ្រប់កាលៈទេសៈដើម្បីគាប់ព្រះហឫទ័យព្រះអង្គ
និងប្រព្រឹត្តតាមដូចសន្តីហ្វ្រង់ស៊ីស្កា ។

# ថ្ងៃទី ១៧ មីនា

# សន្តប៉ាទ្រីក ជាអភិបាលព្រះសហគមន៍

**S. Patricii, episcopi**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់សាសនទូត (Latin p. 938) ឬសម្រាប់អភិបាល (Latin p. 929) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតានៃមនុស្សលោកទាំងឡាយ !
ព្រះអង្គសព្វព្រះហឫទ័យជ្រើសរើស សន្តប៉ាទ្រីក ឲ្យប្រកាសដំណឹងល្អ
ដើម្បីឲ្យប្រជាជនទាំងឡាយនៅប្រទេសអៀរឡង់ស្គាល់ព្រះអង្គ ។
តាមរយៈពាក្យអង្វររបស់សន្តប៉ាទ្រីក សូមព្រះអង្គប្រោសយើងខ្ញុំជាគ្រីស្តបរិស័ទ
ឲ្យយកចិត្តទុកដាក់ខិតខំណែនាំមនុស្សគ្រប់ៗរូប
ស្គាល់ពីធម៌មេត្តាករុណាដ៏អស្ចារ្យរបស់ព្រះអង្គ ។

# ថ្ងៃទី ១៨ មីនា

# សន្តស៊ីរីល ជាអភិបាលនៅក្រុងយេរូសាឡឹម និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Cyrilli Hierosolymitani, episcopi et Ecclesiæ doctoris**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល (Latin p. 929) ឬពាក្យអធិដ្ឋានរួមសម្រាប់គ្រូបាធ្យាយនៃព្រះសហគមន៍ ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាម្ចាស់ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យសន្តស៊ីរីល នៅក្រុងយេរូសាឡឹម
ណែនាំព្រះសហគមន៍ឲ្យរិះគិតយ៉ាងជ្រៅ
អំពីគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះរបស់ព្រះអង្គ ។
តាមរយៈពាក្យអង្វររបស់សន្តស៊ីរីល
សូមប្រោសយើងខ្ញុំឲ្យស្គាល់ព្រះអង្គកាន់តែច្បាស់ឡើងៗ និងរួមរស់ជាមួយព្រះអង្គគ្រប់ពេលវេលាផង ។

# ថ្ងៃទី ១៩ មីនា

# សន្តយ៉ូសែប ជាស្វាមីព្រះនាងព្រហ្មចារិនីម៉ារី

**S. IOSEPH SPONSI BEATÆ MARIÆ VIRGINIS**

(បុណ្យឱឡារិក)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !

ព្រះអង្គបានប្រោសឲ្យសន្តយ៉ូសែប ទទួលបន្ទុកថែទាំព្រះយេស៊ូជាព្រះសង្គ្រោះ ។

តាមរយៈពាក្យទូលអង្វររបស់សន្តយ៉ូសែប

សូមមេត្តាប្រោសឲ្យព្រះសហគមន៍បានទទួលការសង្គ្រោះពីព្រះអង្គ

ហើយបង្ហាញដល់មនុស្សលោកសព្វថ្ងៃនេះ ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !

ព្រះអង្គប្រោសសន្តយូសែបឲ្យថ្វាយខ្លួនដោយចិត្តស្មោះ ដើម្បីបម្រើព្រះបុត្រាព្រះអង្គ ។

សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យប្រាថ្នាបម្រើព្រះអង្គដោយចិត្តស្មោះ ។

ធម៌ប្រារព្ធ ៖ បេសកកម្មរបស់សន្តយូសែប ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណព្រះអម្ចាស់ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មគង់នៅអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គ
ក្នុងឱកាសបុណ្យសន្តយ៉ូសែបយ៉ាងឱឡារិក ។
ព្រះអង្គបំភ្លឺសន្តយ៉ូសែបដែលជាបុរសដ៏សុចរិត
ឲ្យធ្វើជាស្វាមីរបស់ព្រះនាងព្រហ្មចារិនីម៉ារី ជាព្រះមាតារបស់ព្រះជាម្ចាស់ ។
សន្តយ៉ូសែបពិតជាអ្នកបម្រើដ៏ស្មោះត្រង់ និងឈ្លាសវៃ
ដែលទទួលបន្ទុកធ្វើជាឪពុកថែរក្សាការពារព្រះបុត្រាព្រះអង្គ គឺព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ
ដែលចាប់កំណើតដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយដោយប្រកាសថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !

### ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គបានចិញ្ចឹមក្រុមគ្រួសាររបស់ព្រះអង្គ
ដោយប្រទានអាហារដ៏វិសុទ្ធពីតុសក្ការបូជា ។
សូមព្រះអង្គថែរក្សាការពារមហាគ្រួសាររបស់ព្រះអង្គគ្រប់ពេលវេលា
និងពង្រឹងព្រះសហគមន៍តាមរយៈព្រះអំណោយទានព្រះអង្គ
ដែលយើងខ្ញុំទទួលដោយចិត្តរីករាយនៅថ្ងៃគោរពសន្តយ៉ូសែប ។

## ថ្ងៃទី ២៣ មីនា

# សន្តទូរី ប៊ីយូ ជាអភិបាលព្រះសគមន៍ម៉ូហ្គ្រូវេយ៉ូ

**S. Turibii de Mogrovejo, episcopi**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល (Latin p. 929) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតានៃមនុស្សគ្រប់ជាតិសាសន៍ !
ព្រះអង្គប្រោសឲ្យសន្តទូរី ប៊ីយូ ខិតខំប្រកាសដំណឹងល្អ
ដោយស្រឡាញ់យុត្តិធម៌ និងសេចក្តីពិត ។
សូមព្រះអង្គមេត្តាពង្រឹងជំនឿព្រះសហគមន៍របស់ព្រះអង្គ
បានរីកចម្រើនឡើង និងប្រោសឲ្យយើងខ្ញុំរស់នៅជាមនុស្សសុចរិត ។

# ថ្ងៃទី ២៥ មីនា

# បុណ្យទេវទូតជូនដំណឹង

**IN ANNUNTIATIONE DOMINI**

(បុណ្យឱឡារិក)

ប្រសិនបើបុណ្យ "ទេវទូតជូនដំណឹង" ចំនឹងថ្ងៃសប្ដាហ៍ពិសិដ្ឋ សូមប្រារព្ធបុណ្យនេះ នៅថ្ងៃចន្ទ ក្រោយថ្ងៃអាទិត្យទី ២ នៃបុណ្យចម្លង ។

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាអម្ចាស់ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យព្រះបន្ទូលព្រះអង្គ
ទទួលរូបកាយពីព្រះនាងព្រហ្មចារិនីម៉ារី ហើយទៅជាមនុស្ស ។
យើងខ្ញុំប្រកាសថា ព្រះបុត្រាពិតជាព្រះអម្ចាស់ផង ពិតជាមនុស្សផង
ហើយព្រះអង្គយាងមករំដោះ និងសង្គ្រោះយើងខ្ញុំ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំដែលជឿសង្ឃឹមលើព្រះអង្គ រស់នៅតាមឋានៈ ជាបុត្រធីតារបស់ព្រះអង្គជានិច្ច ។

សូត្រធម៌ប្រកាសជំនឿ ។ ដល់ពាក្យ ព្រះអង្គបានទទួលរូបកាយពីព្រះនាងព្រហ្មចារិនីម៉ារី ហើយព្រះអង្គទៅជាមនុស្ស អង្គប្រជុំឱនកាយគោរព ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
នៅថ្ងៃនេះ យើងខ្ញុំមានអំណរសប្បាយនឹករឭក
ដល់ថ្ងៃទេវទូតជូនដំណឹងឲ្យព្រះនាងម៉ារី អំពីកំណើតព្រះអម្ចាស់យេស៊ូ ។
ព្រឹត្តិការណ៍ទេវទូតជូនដំណឹងនេះ បានបង្ហាញអំពីដើមកំណើតនៃព្រះសហគមន៍ដែរ ។
សូមព្រះអង្គទទួលតង្វាយពីព្រះសហគមន៍ដោយអនុគ្រោះផង ។

ធម៌ប្រារព្ធ ៖ ព្រឹត្តិការណ៍ដ៏អស្ចារ្យអំពីកំណើតព្រះអម្ចាស់យេស៊ូ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណព្រះអម្ចាស់ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មគង់នៅអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ព្រះនាងព្រហ្មចារិនីម៉ារី បានទទួលដំណឹងពីទេវទូតដោយជឿជាក់ថា
ព្រះគ្រីស្តនឹងប្រសូតជាមនុស្សដើម្បីសង្គ្រោះពិភពលោក ។
ព្រះនាងមានផ្ទៃដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ
តាមព្រះបន្ទូលសន្យារបស់ព្រះអង្គមកប្រជារាស្ត្រអ៊ីស្រាអែល ។ សេចក្តីសង្ឃឹមនៃ
ប្រជាជាតិទាំងអស់បានកើតជារូបរាងហើយ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយពពួកទេវទូត
ដែលស្ថិតនៅចំពោះព្រះភ័ក្ត្រព្រះអង្គ
ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយប្រកាសថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !

## ពាក្យអរព្រះគុណ

ឱ ព្រះបិតាជាអម្ចាស់យើងខ្ញុំ !

យើងខ្ញុំសូមប្រកាសថា ព្រះយេស៊ូប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី

គឺព្រះអង្គពិតជាព្រះជាម្ចាស់ផង និងជាមនុស្សផង ។

តាមរយៈព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ

សូមព្រះអង្គប្រទានជីវិតអស់កល្បជានិច្ចដល់យើងខ្ញុំ ។

# ខែ មេសា

## ថ្ងៃទី ២ មេសា

# សន្តហ្វ្រង់ស្វ័រ មកពីភូមិប៉ូឡា ជាឥសី

**S. Francisci de Paola, eremitæ**

ពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់បព្វជិត (Latin p. 961) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានធម៌មេត្តាករុណា !
ព្រះអង្គសព្វព្រះហឫទ័យលើកទឹកចិត្តអ្នកទន់ទាប
ដោយប្រោសឲ្យសន្ត ហ្វ្រង់ស្វ័រ ទទួលសិរីរុងរឿងនៅស្ថានបរមសុខ ។
តាមរយៈពាក្យទូលអង្វររបស់លោក
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំមានអំណរសប្បាយទទួលរង្វាន់
តាមព្រះបន្ទូលសន្យារបស់ព្រះអង្គចំពោះអ្នកតូចតាច ។

## ថ្ងៃទី ៤ មេសា

# សន្តអ៊ីស៊ីដ័រ ជាអភិបាល និងគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Isidori, episcopi et Ecclesiæ doctoris**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល (Latin p. 929) ឬពាក្យអធិដ្ឋានរួមសម្រាប់គ្រូបាធ្យាយនៃព្រះសហគមន៍ (Latin p. 943) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គប្រោសឲ្យសន្តអ៊ីស៊ីដ័រ ជាអភិបាលព្រះសហគមន៍ក្រុងសេវីល
មានចំណេះវិជ្ជាជ្រៅជ្រះអាចណែនាំ និងការពារព្រះសហកមន៍ក្នុងសម័យរបស់លោក ។
តាមរយៈពាក្យទូលអង្វររបស់សន្តអ៊ីស៊ីដ័រ
សូមព្រះអង្គមេត្តាបំភ្លឺ និងណែនាំព្រះសហគមន៍របស់ព្រះអង្គសព្វថ្ងៃនេះផង ។

# ថ្ងៃទី ៥ មេសា
# សន្តវ៉ាំងសង់ ហ្វេរីយេ ជាបូជាចារ្យ
**S. Vincentii Ferrer, presbyteri**

ពាក្យអធិដ្ឋានរួមសម្រប់គង្វាល ៖ សម្រាប់សាសនទូត (Latin p. 938) ។

ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់ !

ព្រះអង្គបានជ្រើសរើស សន្តវ៉ាំសង់ ហ្វេរីយេ ជាបូជាចារ្យ

ដែលប្រកាសពីព្រះបន្ទូលព្រះអង្គដើម្បីដាស់តឿនគ្រីស្តបរិស័ទ

ឲ្យត្រៀមខ្លួនជានិច្ចទទួលព្រះបុត្រាព្រះអង្គយាងមកវិនិច្ឆ័យមនុស្សលោក ។

សូមព្រះអង្គប្រោសយើងខ្ញុំឲ្យកែប្រែចិត្តគំនិត

ដោយនឹកគិតដល់ព្រះបុត្រាដែលយាងមកវិញ

គឺព្រះយេស៊ូដែលសោយរាជ្យរួមជាមួយព្រះអង្គ

និងព្រះវិញ្ញាណដ៏វិសុទ្ធអស់កល្បជាអង្វែងតរៀងទៅ ។

# ថ្ងៃទី ៧ មេសា
# សន្តយ៉ូហាន បាទីស្ត ដឺឡាសាល ជាបូជាចារ្យ
**S. Ioannis Baptistæ de la Salle, presbyteri**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់គង្វាលមួយរូប (Latin p. 933) ឬពាក្យអធិដ្ឋាន រួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់អ្នកអប់រំ (Latin p. 965) ។

ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់យើងខ្ញុំ !

ព្រះអង្គសព្វព្រះហឫទ័យជ្រើសរើសសន្ត យ៉ូហានបាទីស្ត ដឺឡាសាល

ដើម្បីអប់រំកូនក្មេង និងយុវជនតាមមាគ៌ារបស់ព្រះគ្រីស្ត ។

សូមព្រះអង្គបំភ្លឺគ្រីស្តបរិស័ទឲ្យស្ម័គ្រចិត្តជួយអប់រំយុវជន

ខាងចំណេះដឹងទូទៅ និងខាងជំនឿផង ។

# ថ្ងៃទី ១១ មេសា

# សន្ត ស្តានីស្លាស ជាអភិបាលព្រះសហគមន៍ និងជាមរណសាក្សី

**S. Stanislai, episcopi et martyris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីមួយរូប (Latin p. 915) ឬ នៅក្នុង រដូវបុណ្យចម្លង (Latin p. 921) ឬពាក្យអធិដ្ឋានរួមសម្រាប់គង្វាល៖ សម្រាប់អភិបាល (Latin p. 929) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គប្រោសឲ្យសន្ត ស្តានីស្លាស មានសេចក្តីក្លាហាន
រហូតដល់បូជាជីវិតដើម្បីលើកតម្កើងព្រះអង្គ ។ សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំមានចិត្តក្លាហានដូចសន្ត ស្តានីស្លាស
កាន់ជំនឿយ៉ាងខ្ជាប់ខ្ជួនរហូតដល់អវសាននៃជីវិត ។

# ថ្ងៃទី ១៣ មេសា

# សន្តម៉ាតាំងទី១ សម្តេចបាប និងមរណសាក្សី

**S. Martini I, papæ et martyris**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី៖ សម្រាប់មរណសាក្សីមួយរូប (Latin p. 915) ឬនៅក្នុង រដូវបុណ្យចម្លង (Latin p.921) ឬពាក្យអធិដ្ឋានរួមសម្រាប់គង្វាល៖ សម្រាប់សម្តេចបាប (Latin p. 927) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គប្រោសឲ្យសម្តេចប៉ាប ម៉ាតាំងទី១
មានចិត្តពុះពាររាល់ការគំរាមកំហែងរបស់ព្រះចៅអធិរាជ ។
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យបេះតស៊ូក្នុងជំនឿដ៏ពិតប្រាកដ ដោយមានចិត្តស្មោះត្រង់ជានិច្ច ។

# ថ្ងៃទី ២១ មេសា

# សន្ដអង់សែលម៍ ជាអភិបាល និងគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Anselmi, episcopi et Ecclesiæ doctoris**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល (Latin p. 929) ឬពាក្យអធិដ្ឋានរួមសម្រាប់គ្រូបាធ្យាយនៃព្រះសហគមន៍ (Latin p. 943) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាអម្ចាស់ !
ព្រះអង្គប្រទានពន្លឺឲ្យសន្ដ អង់សែលម៍ មានប្រាជ្ញាឈ្លាសវៃ យល់ដឹងពីជំនឿ ហើយបង្រៀនបងប្អូនឯទៀតៗឲ្យយកចិត្តទុកដាក់ស្វែងរកព្រះអង្គ ។
សូមប្រោសឲ្យជំនឿរបស់យើងខ្ញុំលើព្រះអង្គ ជួយឲ្យយើងខ្ញុំស្គាល់ព្រះអង្គ និងដោយសារក្រឹត្យវិន័យរបស់ព្រះអង្គ សូមឲ្យយើងខ្ញុំមានអំណរសប្បាយក្នុងជីវិត ។

# ថ្ងៃទី ២៣ មេសា

# សន្ដហ្សក ជាមរណសាក្សី

**S. Georgii, martyris**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី៖ សម្រាប់មរណសាក្សីមួយរូប នៅក្នុងរដូវបុណ្យចម្លង (Latin p. 921) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គប្រោសសន្ដហ្សក ដែលជួបប្រទះការលំបាកក្នុងជីវិតឲ្យទទួលស្គាល់ថា លោកចូលរួមក្នុងទុក្ខលំបាករបស់ព្រះអម្ចាស់ដែលជាប់នៅលើឈើឆ្កាង ។
ក្នុងពេលយើងខ្ញុំអស់កម្លាំង និងមានភាពទុនខ្សោយក្នុងជីវិត សូមព្រះអង្គលើកទឹកចិត្តដល់យើងខ្ញុំផង ។

# សន្តអាដាលប៊ឺត ជាអភិបាល និងជាមរណសាក្សី

**S. Adalberti, episcopi et martyris**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីមួយរូប នៅក្នុងរដូវបុណ្យចម្លង (Latin p. 921) ឬពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល (Latin p. 929) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាម្ចាស់ !
ព្រះអង្គប្រោសឲ្យសន្តអាដាលប៊ឺត ជាអភិបាល
មានចិត្តស្រឡាញ់ឆេះឆួលដល់អ្នកដទៃរហូតដល់បូជាជីវិត ដើម្បីឲ្យពួកគេក្លាយជាគ្រីស្តបរិស័ទ ។
សូមព្រះអង្គប្រោសយើងខ្ញុំដែលជាកូនចៀមរបស់ព្រះអង្គ
បេះស្តាប់បង្គាប់អ្នកគង្វាល ព្រមទាំងប្រោសឲ្យព្រះសហគមន៍
យកចិត្តទុកដាក់ថែរក្សាកូនចៀមដូច សន្ត អាដាលប៊ឺតដែរ ។

# ទី ២៤ មេសា

# សន្តហ្វី ដែលនៅភូមិស៊ីកម៉ារិនហ្កែន ជាបូជាចារ្យ និងជាមរណសាក្សី

**S. Fidelis de Sigmaringen, presbyteri et martyris**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីមួយរូប នៅក្នុងរដូវបុណ្យចម្លង (Latin p.921) ឬពាក្យអធិដ្ឋានរួមសម្រាប់អ្នកគង្វាល៖ សម្រាប់អ្នកគង្វាលមួយរូប (Latin p.933) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យសន្ត ហ្វី ដែលប្រកាសដំណឹងល្អរហូតដល់បូជាជីវិត
ដើម្បីឲ្យអ្នកដទៃបានស្គាល់ព្រះគ្រីស្ត ។
តាមរយៈពាក្យទូលអង្វររបស់លោក សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានចិត្តស្រលាញ់
និងមានជំនឿយ៉ាងមាំមួនលើព្រះអង្គ ដែលមានព្រះជន្មរស់ឡើងវិញផង ។

# ថ្ងៃទី ២៥ មេសា

# សន្តម៉ាកុស អ្នកនិពន្ធព្រះគម្ពីរដំណឹងល្អ

**S. MARCI, EVENGELISTÆ**

(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គសព្វព្រះហឫទ័យឲ្យសន្តម៉ាកុសនិពន្ធគម្ពីរមួយក័ណ្ឌ និងប្រកាសដំណឹងល្អ ។
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យយកចិត្តទុកដាក់ដើរតាមព្រះគ្រីស្ត
ដែលជាព្រះបុត្រាព្រះអង្គ និងជាព្រះអម្ចាស់យើងខ្ញុំ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
សូមព្រះអង្គមេត្តាទទួលសក្ការបូជា
ដែលយើងខ្ញុំលើកថ្វាយទៅព្រះអង្គក្នុងថ្ងៃគោរពសន្តម៉ាកុស ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យយកចិត្តទុកដាក់ប្រកាសដំណឹងល្អ
ដោយបានលះបង់ខ្លួនឯងចោល លីឈើឆ្កាងរួមជាមួយព្រះយេស៊ូគ្រីស្ត
ជាព្រះបុត្រាព្រះអង្គ និងជាព្រះអម្ចាស់យើងខ្ញុំ ។

ធម៌ប្រារព្ធទី ២ បុណ្យគោរពគ្រីស្តទូត ទំព័រ ៤៧៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំមានកម្លាំង
ដើម្បីប្រកាសដំណឹងល្អដល់មនុស្សគ្រប់ជាតិសាសន៍ ។
សូមព្រះអង្គប្រទាននូវសេចក្តីក្លាហានឲ្យយើងខ្ញុំ
បានបន្តជំនឿដល់អ្នកដទៃដូចសន្តម៉ាកុស ។

## ថ្ងៃទី ២៨ មេសា

# សន្តសិលា សាណែល ជាបូជាចារ្យ និងជាមរណសាក្សី

**S. Petri Chanel, presbyteri et martyris**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីមួយរូប នៅក្នុងរដូវបុណ្យចម្លង (Latin p. 921) ឬពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់សាសនទូត (Latin p. 938) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យសន្តសិលា សាណែល ទទួលសិរីរុងរឿងជាមរណសាក្សី
ដើម្បីឲ្យព្រះសហគមន៍រីកចម្រើនឡើង ។
ក្នុងរដូវបុណ្យចម្លងនេះ សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំ
ឲ្យបានធ្វើជាសាក្សីដ៏ពិតប្រាកដអំពីជីវិតថ្មី
ដែលព្រះគ្រីស្តបានប្រទានឲ្យយើងខ្ញុំ ។

# សន្តល្វីស ម៉ារី ហ្គ្រីញៀន ជាបូជាចារ្យ

**S. Ludovici Mariæ Grignion de Montfort, presbyteri**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់គង្វាលមួយរូប (Latin p. 933) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យប្រោសឲ្យសន្តល្វីស ជាបូជាចារ្យ
ព្រមទាំងទទួលសិរីរុងរឿងជាមរណសាក្សី លោកជាបរមគ្រូរបស់យើងខ្ញុំដោយសេចក្តីស្រឡាញ់ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានជំនឿមាំមួនដូចសន្តល្វីស ហើយសុខចិត្តដើរតាមព្រះយេស៊ូគ្រីស្តជានិច្ច ។

## ថ្ងៃទី ២៩ មេសា

# សន្តីកាតារីន ជាព្រហ្មចារិនី និងជាគ្រូបាធ្យាយនៃព្រះសហគមន៍ នៅទីក្រុងស៊ីយែន

**S. Catharinæ Senensis, virginis et Ecclesiæ doctoris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រោសឲ្យសន្តីកាតារីនស្រឡាញ់ព្រះអង្គយ៉ាងខ្លាំងបំផុត ដោយនាងនឹកសញ្ជឹងគិតអំពីព្រះយេស៊ូរងទុក្ខលំបាក ហើយព្រះអង្គក៏ត្រាស់ហៅនាងឲ្យបម្រើព្រះសហគមន៍ផងដែរ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំស្រឡាញ់ព្រះអង្គ ដោយរួមស្លាប់ជាមួយព្រះគ្រីស្ត និងពោរពេញក្នុងអំណរសប្បាយក្នុងសិរីរុងរឿងរបស់ព្រះអង្គ ។

ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
សូមព្រះអង្គមេត្តាទទួលសក្ការបូជា ដែលយើងខ្ញុំលើកថ្វាយព្រះអង្គនៅថ្ងៃនេះ ។
ក្នុងឱកាសយើងខ្ញុំនឹករឭកដល់សន្តីកាតារីន
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យយកចិត្តទុកដាក់អរព្រះគុណព្រះអង្គ គ្រប់ពេលវេលាតាមសេចក្ដីបង្រៀនរបស់សន្តីកាតារីនផង ។

ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !
យើងខ្ញុំទើបនឹងទទួលអាហារពីតុនៃស្ថានបរមសុខ
សូមព្រះអង្គប្រោសឲ្យអាហារដែលបានចិញ្ចឹមសន្តីកាតារីន
ផ្ដល់ជីវិតអស់កល្បជានិច្ចដល់យើងខ្ញុំ ។

# ថ្ងៃទី ៣០ មេសា

# សន្តពីយូស ទី៥ ជាសម្តេចប៉ាប

**S. Pii V, papæ**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់សម្តេចប៉ាប (Latin p. 927) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រោសឲ្យសន្តពីយូស ទី៥ ជាសម្តេចប៉ាប
ណែនាំព្រះសហគមន៍ និងថែរក្សាជំនឿឲ្យរឹងមាំ
ដោយយកចិត្តទុកដាក់រៀបចំសក្ការបូជាឲ្យកាន់តែប្រសើរឡើងៗ ។
តាមរយៈពាក្យទូលអង្វររបស់លោក សូមព្រះអង្គប្រោសយើងខ្ញុំ
ឲ្យចូលរួមក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ
ដោយមានជំនឿរស់រវើក និងមានចិត្តមេត្តាករុណាប្រកបដោយជលផ្លែ ។

# ឧសភា

## ថ្ងៃទី ១ ឧសភា

# សន្តយ៉ូសែប ជាពលករ

**S. Ioseph opificis**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់ដែលបង្កើតពិភពលោកទាំងមូល !
ព្រះអង្គសព្វព្រះហឫទ័យឲ្យមនុស្សគ្រប់ជាតិសាសន៍
បំពេញកិច្ចការរៀងៗខ្លួនដើម្បីបន្តព្រះរាជកិច្ចរបស់ព្រះអង្គ ។
តាមគំរូរបស់សន្តយ៉ូសែប
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំធ្វើកិច្ចការថ្វាយព្រះអង្គ
ដើម្បីទទួលរង្វាន់តាមព្រះបន្ទូលសន្យា ។

ពាក្យថ្វាយតង្វាយ

បពិត្រព្រះបិតាជាអម្ចាស់ !
អ្វីៗទាំងអស់ដែលមានក្នុងពិភពលោកសុទ្ធតែមកពីព្រះអង្គ ។
នៅថ្ងៃនេះ យើងខ្ញុំនឹករឭកដល់សន្តយ៉ូសែបជាពលករ
សូមព្រះអង្គទទួលតង្វាយពីយើងខ្ញុំទុកជានិមិត្តរូបនៃការងាររបស់មនុស្សលោក
ហើយសូមប្រោសឲ្យតង្វាយនេះ ទៅជាព្រះកាយព្រះគ្រីស្តការពារយើងខ្ញុំ ។

ធម៌ប្រារព្ធ ៖ បេសកកម្មរបស់សន្តយ៉ូសែប ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !

ព្រះអង្គមានឫទ្ធានុភាពសព្វប្រការ និងមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

នៅថ្ងៃនឹករឭកដល់សន្តយ៉ូសែប
យើងខ្ញុំសូមលើកតម្កើងសិរីរុងរឿង និងអរព្រះគុណព្រះអង្គ ។
ព្រះអង្គបំភ្លឺសន្តយ៉ូសែបដែលជាបុរសដ៏សុចរិត
ឲ្យធ្វើជាស្វាមីរបស់ព្រះនាងព្រហ្មចារិនីម៉ារី ជាព្រះមាតារបស់ព្រះជាម្ចាស់ ។
សន្តយ៉ូសែបពិតជាអ្នកបម្រើដ៏ស្មោះត្រង់ និងឈ្លាសវៃ
ដែលទទួលបន្ទុកធ្វើជាឪពុកថែរក្សាការពារព្រះបុត្រាព្រះអង្គ គឺព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ
ដែលចាប់កំណើតដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយដោយប្រកាសថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !

### ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គបានចិញ្ចឹមជីវិតយើងខ្ញុំដោយព្រះកាយព្រះគ្រីស្ត ។
តាមគំរូរបស់សន្តយ៉ូសែប
សូមទ្រង់ប្រោសយើងខ្ញុំឲ្យចូលរួមក្នុងគ្រប់កិច្ចការ
ដែលបង្ហាញពីសេចក្តីស្រឡាញ់របស់ព្រះអង្គ និងប្រទានផលផ្លែនៃសេចក្តីសុខសាន្តអស់កល្បជានិច្ចឲ្យយើងខ្ញុំ ។

## ថ្ងៃទី ២ ឧសភា

# សន្តអាថាណាស ជាអភិបាល និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Athanasii, episcopi et Ecclesiæ doctoris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គបានជ្រើសរើសសន្តអាថាណាស ជាអភិបាល
ឲ្យធ្វើជាជនដ៏ឆ្នើមខាងជំនឿ ដោយប្រកាសថា
ព្រះបុត្រាព្រះអង្គពិតជាព្រះជាម្ចាស់ ។
តាមការប្រៀនប្រដៅរបស់សន្តអាថាណាស
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំស្គាល់ និងស្រឡាញ់ព្រះអង្គកាន់តែខ្លាំងឡើងៗ ។

ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គតែងតែទតមើលតង្វាយដែលយើងខ្ញុំថ្វាយទៅព្រះអង្គជានិច្ច ។
នៅថ្ងៃនេះ យើងខ្ញុំនឹករឭកដល់សន្តអាថាណាស
សូមព្រះអង្គប្រោសឲ្យតង្វាយនេះ ទៅជាសាក្សីនៃសេចក្តីពិត
និងនាំការសង្គ្រោះដល់អស់អ្នកដែលកាន់តាមជំនឿឥតសៅហ្មង ។

ពាក្យអរព្រះគុណ

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំប្រកាសរួមជាមួយសន្តអាថាណាស ថា
ព្រះយេស៊ូពិតជាព្រះបុត្រាតែមួយគត់របស់ព្រះបិតា ។
តាមរយៈព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត
សូមព្រះអង្គការពារ និងប្រទានជីវិតអស់កល្បជានិច្ចឲ្យយើងខ្ញុំ ។

## ថ្ងៃទី ៣ ឧសភា

# សន្តភីលីព និងសន្តយ៉ាកុប ជាគ្រីស្តទូត

**SS. PHILIPPI ET IACOBI, APOSTOLORUM**

(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

### ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានធម៌មេត្តាករុណា !
នៅថ្ងៃបុណ្យគោរពសន្តភីលីព និងសន្តយ៉ាកុប ជាគ្រីស្តទូត
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យមានជំនឿកាន់តែមាំមួន ។
តាមរយៈពាក្យទូលអង្វររបស់សន្តទាំងពីរ
សូមឲ្យយើងខ្ញុំសុខចិត្តរួមស្លាប់រួមរស់ជាមួយព្រះបុត្រាតែមួយរបស់ព្រះអង្គ
ដើម្បីឃើញព្រះភក្រព្រះអង្គនៅថ្ងៃណាមួយផង ។

### ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
នៅថ្ងៃបុណ្យគោរពសន្តភីលីព និងសន្តយ៉ាកុប
សូមព្រះអង្គទទួលតង្វាយដែលយើងខ្ញុំថ្វាយដោយអនុគ្រោះ ។
សូមព្រះអង្គប្រទានជំនឿដ៏បរិសុទ្ធ និងឥតសៅហ្មងដល់យើងខ្ញុំ ។

ធម៌ប្រារព្ធ បុណ្យគោរពគ្រីស្តទូត ទំព័រ ៤៧៦ ។

### ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គតែងតែជម្រះចិត្តគំនិតរបស់យើងខ្ញុំ
ដោយប្រទានព្រះអំណោយទាន គឺព្រះកាយព្រះគ្រីស្ត ។
រួមជាមួយសន្តភីលីព និងសន្តយ៉ាកុប សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
ឃើញព្រះបិតានៅក្នុងអង្គព្រះបុត្រា ដើម្បីទទួលជីវិតអស់កល្បជានិច្ច ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក ទំព័រ ៥៦០ ។

# ថ្ងៃទី ១២ ឧសភា

# សន្តណេរ៉េ និងសន្តអាគីឡេ ជាមរណសាក្សី

**Ss. Nerei et Achillei, martyrum**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីជាច្រើននាក់ (Latin p. 909) ឬ ពាក្យអធិដ្ឋានក្នុងរដូវបុណ្យចម្លង (Latin p. 918) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គប្រោសឲ្យសន្តណេរ៉េ និងសន្តអាគីឡេ
មានសេចក្តីក្លាហានដ៏មហិមា ហ៊ានប្រកាសជំនឿលើព្រះអង្គ ។
នៅចំពោះព្រះភក្ត្រព្រះអង្គ សូមប្រោសឲ្យយើងខ្ញុំជឿជាក់ថា
មរណសាក្សីទាំងពីរកំពុងអង្វរព្រះអង្គសម្រាប់យើងខ្ញុំ ។

# សន្តប៉ង់ក្រាស ជាមរណសាក្សី

**S. Pancratii, martyris**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីមួយរូប (Latin p. 915) ឬពាក្យអធិដ្ឋានក្នុងរដូវបុណ្យចម្លង (Latin p. 921) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យព្រះសហគមន៍ត្រេកអរសប្បាយ
និងទុកចិត្តលើពាក្យទូលអង្វររបស់សន្តប៉ង់ក្រាស ជាមរណសាក្សី ។
តាមរយៈពាក្យទូលអង្វររបស់លោក
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានចិត្តស៊ូទ្រាំ
ក្នុងភក្តិភាពចំពោះព្រះអង្គ និងមានចិត្តនឹងនរជានិច្ច ។

# ថ្ងៃទី ១៣ ឧសភា

# ព្រះនាងម៉ារីជាព្រហ្មចារិនី នៅហ្វាទីម៉ា

**Beatæ Mariæ Virginis de Fatima**

ពាក្យអធិដ្ឋានរួមរបស់ព្រះនាងព្រហ្មចារិនីម៉ារីពោរពេញដោយសុភមង្គល (Latin p. 897) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ !
ព្រះអង្គបានជ្រើសរើសព្រះមាតារបស់ព្រះបុត្រា
ឲ្យធ្វើជាមាតារបស់យើងខ្ញុំដែរ ។
តាមការណែនាំរបស់ព្រះមាតានៅហ្វាទីម៉ា
សូមប្រោសយើងខ្ញុំឲ្យយកចិត្តទុកដាក់ផ្ដន្ទាខ្លួន
និងទូលអង្វរព្រះអង្គដើម្បីសង្គ្រោះមនុស្សលោក ។
សូមប្រោសឲ្យយើងខ្ញុំរៀបចំផ្លូវថ្វាយព្រះរាជ្យព្រះអង្គ ។

# ថ្ងៃទី ១៤ ឧសភា
# សន្តម៉ាធីយ៉ាស ជាគ្រីស្តទូត
**S. MATTHIÆ, APOSTOLI**

(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប
បពិត្រព្រះបិតាជាអម្ចាស់ !
ព្រះអង្គបានជ្រើសរើសឲ្យសន្តម៉ាធីយ៉ាស ចូលរួមក្នុងចំណោមក្រុមគ្រីស្តទូត ។
តាមរយៈពាក្យទូលអង្វររបស់លោក
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានអំណរសប្បាយ
ដោយដឹងថា ព្រះអង្គស្រឡាញ់យើងខ្ញុំយ៉ាងខ្លាំង
និងរាប់បញ្ចូលយើងខ្ញុំ នៅក្នុងចំណោមអស់អ្នកដែលព្រះអង្គបានជ្រើសរើស ។

## ពាក្យថ្វាយតង្វាយ
ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គតែងតែទទួលតង្វាយពីព្រះសហគមន៍ដោយព្រហ្មហឫទ័យអនុគ្រោះ ។
នៅថ្ងៃបុណ្យគោរពសន្តម៉ាធីយ៉ាស ជាគ្រីស្តទូត
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបានប្រកាសដំណឹងល្អ
និងមានជំនឿរឹងមាំដោយឫទ្ធានុភាពរបស់ព្រះអង្គ ។

ធម៌ប្រារព្ធ បុណ្យគោរពគ្រីស្តទូត ទំព័រ ៤៧៦ ។

## ពាក្យអរព្រះគុណ
ឱ ព្រះជាអម្ចាស់ជាព្រះបិតា !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គ
ដែលប្រទានព្រះអំណោយទានផ្សេងៗមកព្រះសហគមន៍ ។
តាមរយៈពាក្យអង្វររបស់សន្តម៉ាធីយ៉ាស
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យចូលរួមជាមួយអស់សន្តបុគ្គលទាំងឡាយ ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក ទំព័រ ៥៦០ ។

## ថ្ងៃទី ១៨ ឧសភា

# សន្តយ៉ូហានទី ១ ជាសម្តេចប៉ាប និងមរណសាក្សី

**S. Ioannis I, papæ et martyris**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីមួយរូប (Latin p. 927) ឬនៅក្នុងរដូវបុណ្យចម្លង (Latin p. 921) ឬពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់សម្តេចប៉ាប (Latin p. 927) ។

### ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាអម្ចាស់ !
ព្រះអង្គប្រទានរង្វាន់ដល់អ្នកជឿសង្ឃឹមលើព្រះអង្គ
ហើយនៅថ្ងៃនេះ ព្រះអង្គប្រោសសន្តយ៉ូហានទី១ ជាសម្តេចប៉ាប
ឲ្យទៅជាមរណសាក្សី ។
សូមព្រះអង្គមេត្តាស្តាប់ពាក្យអង្វររបស់យើងខ្ញុំ
និងប្រោសឲ្យយើងខ្ញុំរស់នៅតាមជំនឿដ៏មាំមួនរបស់សន្តយ៉ូហានទី១ ផង ។

## ថ្ងៃទី ២០ ឧសភា

# សន្តប៊ែរណាដាំង នៅស៊ីយែន ជាបូជាចារ្យ

**S. Bernardini Senensis, presbyteri**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់សាសនទូត (Latin p. 938) ឬពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់បព្វជិត (Latin p. 961) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់ !
ព្រះអង្គប្រោសឲ្យសន្តប៊ែរណាដាំង ជាបូជាចារ្យ នៅស៊ីយែន
មានចិត្តស្រឡាញ់ព្រះនាមព្រះយេស៊ូយ៉ាងខ្លាំងបំផុត ។
តាមរយៈពាក្យទូលអង្វររបស់លោក សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
មានចិត្តឆេះឆួលទទួលសេចក្តីស្រឡាញ់របស់ព្រះអង្គ ។

# ថ្ងៃទី ២១ ឧសភា

# សន្តគ្រីស្តូហ្វ័រ ម៉ាហ្គាលែន ជាបូជាចារ្យ និងសហការី ជាមរណសាក្សី នៅប្រទេស ម៉ិចសិក

**Ss. Christophori Magallanes, presbyteri, et sociorum, martyrum**
**Martyres in Mexico**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីច្រើននាក់ (Latin p. 909) ឬ នៅក្នុងរដូវបុណ្យចម្លង (Latin p. 918) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ និងគង់នៅអស់កល្បជានិច្ច !
ព្រះអង្គប្រោសឲ្យសន្តគ្រីស្តូហ្វ័រ ជាបូជាចារ្យ និងសហការីរបស់លោក
ដែលមានជំនឿលើព្រះគ្រីស្តជាព្រះមហាក្សត្រ ទៅជាមរណសាក្សី ។
តាមរយៈពាក្យទូលអង្វររបស់អស់លោក
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបានប្រកាសជំនឿដ៏ពិតប្រាកដ
និងគោរពវិន័យនៃសេចក្តីស្រឡាញ់របស់ព្រះអង្គដោយខ្ជាប់ខ្ជួន ។

# ថ្ងៃទី ២២ ឧសភា

# សន្តីរីតា នៅកាស៊ីយ៉ា ជាបព្វជិតា

**S. Ritæ de Cascia, religiosæ**

ពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់បព្វជិតា (Latin p. 961) ។

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យសន្តី រីតា មានប្រាជ្ញាឈ្លាសវៃ
និងមានកម្លាំងមាំមួនមកពីព្រះឈើឆ្កាង ។
តាមរយៈពាក្យទូលអង្វររបស់នាង សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
ដែលជួបការលំបាកទាំងផ្លូវកាយ ទាំងផ្លូវចិត្ត
បានចូលរួមយ៉ាងជ្រៅជាមួយព្រះគ្រីស្ត ក្នុងគម្រោងការដ៏អស្ចារ្យនៃបុណ្យចម្លង ។

# ថ្ងៃទី ២៥ ឧសភា

# សន្តបេ៊ែត៍ ជាទីគោរព ជាបូជាចារ្យ និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Bedæ Venerabilis, presbyteri et Ecclesiæ doctoris**

ពាក្យអធិដ្ឋានរួមសម្រាប់គ្រូបាធ្យាយនៃព្រះសហគមន៍ (Latin p. 943) ឬពាក្យអធិដ្ឋានរួមសម្រាប់សន្ត: សន្តី ៖ សម្រាប់ចៅអធិការ/បព្វជិត (Latin p. 959) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គបានប្រទានពន្លឺឲ្យព្រះសហគមន៍
តាមរយ:ចំណេះដឹងរបស់សន្តបេ៊ែត៍ ជាបូជាចារ្យ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គ
បានពោរពេញដោយពន្លឺ និងប្រព្រឹត្តតែអំពើល្អ
តាមរយ:ប្រាជ្ញាឈ្លាសវៃរបស់សន្តបេ៊ែត៍ផង ។

# សន្តហ្គ្រេហ្គ័រ ទី៧ ជាសម្តេចប៉ាប

**S. Gregorii VII, papæ**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់សម្តេចប៉ាប (Latin p. 927) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គប្រទានឲ្យព្រះសហគមន៍មានសេចក្តីក្លាហាន និងមានចិត្តឆេះឆួលស្វែងរកយុត្តិធម៌តាមគំរូសន្តហ្គ្រេហ្គ័រ ទី៧ ជាសម្តេចប៉ាប ។
សូមព្រះអង្គប្រោសឲ្យព្រះសហគមន៍រួចផុតពីមារកំណាច
និងសម្តែងមេត្តាករុណាគ្រប់ពេលវេលាផង ។

# ថ្ងៃទី ២៥ ឧសភា

# សន្តីម៉ារី ម៉ាដាឡា នៃគ្រួសារប៉ាស៊ី ជាព្រហ្មចារិនី

**S. Mariæ Magdalenæ de'Pazzi, virginis**

ពាក្យអធិដ្ឋានរួមសម្រាប់ព្រហ្មចារិនី ៖ សម្រាប់ព្រហ្មចារិនីមួយរូប (Latin p. 947) ឬពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់បព្វជិតា (Latin p. 961) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាអម្ចាស់ !
ព្រះអង្គសព្វព្រះហឫទ័យប្រទានព្រះអំណោយទានឲ្យសន្តីម៉ារីម៉ាដាឡា
ជាព្រហ្មចារិនី នៃគ្រួសារប៉ាស៊ី មានចិត្តឆេះឆួលស្រឡាញ់ព្រះអង្គ ។
នៅថ្ងៃនេះ សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានចិត្តបរិសុទ្ធ
និងចិត្តមេត្តាករុណាដូចសន្តីម៉ារីម៉ាដាឡាផង ។

# ថ្ងៃទី ២៦ ឧសភា

# សន្តហ្វីលីព នេរី ជាបូជាចារ្យ

**S. Philippi Neri, presbyteri**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ !
ព្រះអង្គសព្វព្រះហឫទ័យប្រទានសិរីរុងរឿង
ដល់អស់អ្នកស្រឡាញ់ព្រះអង្គដោយចិត្តស្មោះ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ
មានចិត្តឆេះឆួលស្រឡាញ់ព្រះអង្គ ដូចសន្តហ្វីលីព នេរីដែរ ។

### ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !

យើងខ្ញុំសូមថ្វាយសក្ការបូជានេះ ដើម្បីកោតសរសើរព្រះអង្គ ។

សូមព្រះអង្គប្រោសឲ្យយើងខ្ញុំខិតខំប្រព្រឹត្តគ្រប់កិច្ចការ

ដើម្បីលើកតម្កើងព្រះនាមព្រះអង្គ និងបម្រើអ្នកដ៏ទៃ

ដោយមានអំណរសប្បាយឥតឈប់ឈរ ដូចសន្តហ្វីលីព នេរី ។

### ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !

ព្រះអង្គបានប្រទានអាហារដែលចុះពីស្ថានបរមសុខឲ្យយើងខ្ញុំ ។ តាមគំរូរបស់សន្ត ហ្វីលីព សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ

ស្វែងរកអាហារដែលផ្តល់ជីវិតអស់កល្បជានិច្ច ។

# ថ្ងៃទី ២៧ ឧសភា

# សន្តអូគូស្តាំង នៅកាន់បេរី ជាអភិបាលព្រះសហគមន៍

**S. Augustini Cantuariensis, episcopi**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល៖ សម្រាប់សាសនទូត (Latin p. 938) ឬសម្រាប់អភិបាល (Latin p. 929) ។

### ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាម្ចាស់ !

ព្រះអង្គសព្វព្រះហឫទ័យឲ្យប្រជាជាតិអង់គ្លេស

ទទួលដំណឹងល្អតាមរយៈសន្តអូគូស្តាំង នៅកាន់បេរី ។

សូមព្រះអង្គប្រោសឲ្យយើងខ្ញុំជាព្រះសហគមន៍ បានទទួលផលផ្លែដ៏បរិបូណ៌

ដែលកើតចេញពីការងាររបស់សន្តអូគូស្តាំងផង ។

# ថ្ងៃទី ៣១ ឧសភា
# ការសួរសុខទុក្ខរបស់ព្រះនាងព្រហ្មចារិនីម៉ារី
## IN VISITATIONE BEATÆ MARIÆ VIRGINIS
(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Gloria in excelsis)

### ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ និងគង់នៅអស់កល្បជានិច្ច !
ព្រះអង្គសព្វព្រះហឫទ័យបំភ្លឺចិត្តគំនិតនាងម៉ារី
ជាព្រះមាតានៃព្រះបុត្រាព្រះអង្គ ឲ្យទៅសួរសុខទុក្ខនាងអេលីសាបែត ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំសុខចិត្តធ្វើតាមការបំភ្លឺរបស់ព្រះវិញ្ញាណ
ដោយលើកតម្កើងព្រះអង្គគ្រប់ពេលវេលារួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី ។

### ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គគាប់ព្រះហឫទ័យនឹងព្រះមាតានៃព្រះបុត្រាតែមួយគត់របស់ព្រះអង្គ
ដែលមានចិត្តមេត្តាករុណាទៅសួរសុខទុក្ខនាងអេលីសាបែត ។
សូមព្រះអង្គមេត្តាទទួលសក្ការបូជាដែលយើងខ្ញុំថ្វាយនៅថ្ងៃនេះ ដោយអនុគ្រោះ ។

ធម៌ប្រារព្ធទី ២ បុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារី ទំព័រ ៤៧២ ។

### ពាក្យអរព្រះគុណ

បពិត្រព្រះជាម្ចាស់ !
យើងខ្ញុំជាព្រះសហគមន៍ សូមលើកតម្កើងព្រះអង្គ
ដ្បិតព្រះអង្គបានបង្កើតស្នាព្រះហស្តដ៏អស្ចារ្យសម្រាប់អស់អ្នកជឿ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានអំណរសប្បាយ
ដោយទទួលព្រះគ្រីស្តក្នុងអគ្គសញ្ញានេះ ដូចសន្តយ៉ូហានបាទីស្ត
ត្រេកអរសប្បាយក្នុងផ្ទៃដោយបានជួបព្រះគ្រីស្ត ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក ទំព័រ ៥៦០ ។

# បុណ្យគោរពព្រះបេះដូងដ៏និម្មល
# របស់ព្រះនាងព្រហ្មចារិនីម៉ារី

Sabbato post dominicam secundam post Pentecosten
**Immaculati Cordis beatæ Mariæ Virginis**
(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គបានរៀបចំដំណាក់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ
នៅក្នុងដួងចិត្តព្រះនាងព្រហ្មចារិនីម៉ារី ។
តាមរយៈពាក្យទូលអង្វររបស់ព្រះនាង
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំទៅជាព្រះដំណាក់របស់ព្រះអង្គផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
សូមព្រះអង្គទតមើលតង្វាយដែលយើងខ្ញុំថ្វាយទៅព្រះអង្គដោយអនុគ្រោះ ក្នុងឱកាសយើងខ្ញុំគោរពព្រះនាងម៉ារីជាមាតារបស់ព្រះជាម្ចាស់ ។
សូមព្រះអង្គគាប់ព្រះហឫទ័យនឹងតង្វាយរបស់យើងខ្ញុំ
ទាំងប្រទានកម្លាំង និងលើកលែងទោសឲ្យយើងខ្ញុំផង ។

ធម៌ប្រារព្ធទី ១ បុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារី ទំព័រ ៤៧២ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គសព្វព្រះហឫទ័យប្រោសលោះយើងខ្ញុំដោយព្រះកាយព្រះគ្រីស្ត ។
នៅថ្ងៃយើងខ្ញុំគោរពព្រះនាងម៉ារី ជាព្រះមាតាព្រះបុត្រាព្រះអង្គ
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបានពោរពេញ
ដោយព្រះហឫទ័យប្រណីសណ្ដោសរបស់ព្រះអង្គ និងភ្ជាប់ចិត្តជាមួយការសង្គ្រោះពីព្រះអង្គជានិច្ចផង ។

# ខែ មិថុនា

## ថ្ងៃទី ១ មិថុនា

## សន្តយូស្តាំង ជាមរណសាក្សី

**S. Iustini, martyris**

(បុណ្យរំឭក)

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាម្ចាស់ !
ព្រះអង្គបានអប់រំសន្តយូស្តាំង ជាមរណសាក្សីឲ្យមានចំណេះដឹងខ្ពស់
ដោយយល់ថា ទុក្ខលំបាករបស់ព្រះគ្រីស្តនៅលើឈើឆ្កាង
ប្រសើរជាងចំណេះដឹងតាមរបៀបលោកីយ៍ ។
តាមរយៈពាក្យទូលអង្វររបស់សន្តយូស្តាំង
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានជំនឿពិតប្រាកដលើព្រះអង្គ
ដោយប្រានបោលនូវអប្បិយជំនឿ និងលិទ្ធិខុសឆ្គងទាំងឡាយ ។

### ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ
ចូលរួមក្នុងសក្ការបូជារបស់ព្រះយេស៊ូគ្រីស្តដូចសន្តយូស្តាំង
ដែលបានបូជាជីវិតដើម្បីការពារជំនឿជាគ្រីស្តបរិស័ទ ។

### ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គបានប្រទានអាហារនៃស្ថានបរមសុខឲ្យយើងខ្ញុំទទួលទាន ។
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យយកគំរូតាមសន្តយូស្តាំង ជាមរណសាក្សី
ដោយបេះអរព្រះគុណព្រះអង្គគ្រប់ពេលវេលា
ចំពោះអំណោយទានផ្សេងៗដែលយើងខ្ញុំបានទទួលពីព្រះអង្គ ។

## ថ្ងៃទី ២ មិថុនា

# សន្តម៉ាសេឡាំង និងសន្តសិលា ជាមរណសាក្សី

**Ss. Marcellini et Petri, martyrum**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី៖ សម្រាប់មរណសាក្សីជាច្រើន (Latin p. 909) ឬនៅក្នុងរដូវបុណ្យចម្លង (Latin p. 918) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គប្រោសសន្តម៉ាសេឡាំង និងសន្តសិលា ឲ្យមានចិត្តក្លាហាន
រហូតដល់បូជាជីវិតថ្វាយព្រះអង្គ និងធ្វើជាគំរូសម្រាប់យើងខ្ញុំ ។
តាមរយៈពាក្យទូលអង្វររបស់លោកទាំងពីរ
សូមព្រះអង្គប្រទានឲ្យយើងខ្ញុំមានជំនឿមាំមួន និងហ៊ានធ្វើសក្ខីភាពអំពីព្រះអង្គ ។

## ថ្ងៃទី ៣ មិថុនា

# សន្តឆាល ល្វង់ហ្គា និងសហជីវិន ជាមរណសាក្សី នៅយូហ្គាន់ដា

**Ss. Caroli Lwanga et sociorum, martyrum**
**Martyres in Uganda**

(បុណ្យរំឭក)

### ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រោសឲ្យឈាមរបស់មរណសាក្សី
ត្រឡប់ទៅជាគ្រាប់ពូជ ដែលបង្កើតគ្រីស្តបរិស័ទថ្មីៗជាច្រើន ។
សូមព្រះអង្គប្រទានព្រះពរដល់ព្រះសហគមន៍
ដែលស្រោចស្រពដោយឈាមរបស់សន្តឆាល ល្វង់ហ្គា និងសហជីវិន
បានបង្កើតជាផលផ្លែដ៏បរិបូរណ៍ ។

ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ ! ព្រះអង្គបានប្រោសឲ្យមរណសាក្សីនៅប្រទេសយូហ្គាន់ដា ហ៊ានបូជាជីវិតជាជាងប្រព្រឹត្តអំពើបាប ។

សូមព្រះអង្គមេត្តាទទួលតង្វាយយើងខ្ញុំពីតុសក្ការបូជានេះ

និងប្រោសយើងខ្ញុំឲ្យជាប់ចិត្តបម្រើព្រះអង្គតែមួយគត់ ។

ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ ! ក្នុងឱកាសនឹករំឭកពីជ័យជម្នះរបស់មរណសាក្សីនេះ

ព្រះអង្គបានប្រទានព្រះកាយព្រះគ្រីស្តឲ្យយើងខ្ញុំ ។

ព្រះកាយព្រះគ្រីស្តបានផ្តល់កម្លាំងឲ្យមរណសាក្សី

អាចស៊ូទ្រាំទទួលទារុណកម្មយ៉ាងធ្ងន់ធ្ងរ ។

សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានជំនឿរឹងមាំ

និងចិត្តមេត្តាករុណា ហ៊ានជម្នះរាល់ឧបសគ្គ ។

## ថ្ងៃទី ៥ មិថុនា

# សន្តបូនីហ្វាស ជាអភិបាលព្រះសហគមន៍ និងជាមរណសាក្សី

**S. Bonifatii, episcopi et martyris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី៖ សម្រាប់មរណសាក្សីមួយរូប (Latin p. 915) ឬនៅក្នុង រ ដូវបុណ្យចម្លង (Latin p.921) ឬពាក្យអធិដ្ឋានរួមសម្រាប់គង្វាល៖ សម្រាប់សាសនទូត (Latin p.938) ។

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់អើយ !

ព្រះអង្គបានប្រោសឲ្យសន្តបូនីហ្វាស សុខចិត្តបង្ហូរឈាមទៅជាមរណសាក្សី ។

សូមព្រះអង្គប្រោសយើងខ្ញុំឲ្យយកគំរូតាមសន្តបូនីហ្វាស

ដែលបានប្រើ បប្ញូរមាត់របស់គាត់បង្រៀនដល់ប្រជាជាតិអាល្លឺម៉ង់

អំពីសេចក្តីពិត ព្រមទាំងប្រកាសជំនឿតាមរយៈកិច្ចការរបស់គាត់ ។

## ថ្ងៃទី ៦ មិថុនា

# សន្តណ័រប៊ែរ ជាអភិបាលព្រះសហគមន៍

**S. Norberti, episcopi**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល (Latin p. 929) ឬពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់បព្វជិត (Latin p. 961) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គសព្វព្រហឫទ័យឲ្យសន្តណ័រប៊ែរ ឧស្សាហ៍អធិដ្ឋាន
និងយកចិត្តទុកដាក់ណែនាំព្រះសហគមន៍ ស្របតាមដំបូន្មានរបស់ព្រះគ្រីស្ត ។
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យមានគង្វាលដូចសន្តណ័រប៊ែរ
ដើម្បីណែនាំព្រះសហគមន៍សព្វថ្ងៃនេះផង ។

## ថ្ងៃទី ៩ មិថុនា

# សន្តអេប្រែម ជាឧបដ្ឋាក និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Ephræ, diaconi et Ecclesiæ doctoris**

ពាក្យអធិដ្ឋានរួមសម្រាប់គ្រូបាធ្យាយនៃព្រះសហគមន៍ (Latin p. 943) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកបំភ្លឺសន្តអេប្រែម ជាឧបដ្ឋាក
ឲ្យនិពន្ធបទចម្រៀងជាច្រើន
ដើម្បីកោតសរសើរពីគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ ។
សូមព្រះអង្គប្រទានកម្លាំងមកយើងខ្ញុំឲ្យបម្រើព្រះអង្គតែមួយគត់ ។

# ថ្ងៃទី ១១ មិថុនា
# សន្តបារណាបាស ជាគ្រីស្តទូត

**S. Barnabæ, apostoli**

(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យញែកសន្តបារណាបាស
ទៅជាមនុស្សម្នាក់ពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ និងជំនឿ
ចេញទៅប្រកាសដំណឹងល្អដល់ប្រជាជាតិនានា ។ សូមព្រះអង្គមេត្តាប្រោសឲ្យអស់អ្នកជឿ
បានប្រកាសព្រះបន្ទូលព្រះអង្គ និងប្រព្រឹត្តតាមផង ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គប្រោសឲ្យសន្តបារណាបាស ពោរពេញដោយសេចក្ដីស្រឡាញ់
បាននាំពន្លឺនៃដំណឹងល្អចេញទៅប្រកាសដល់ប្រជាជាតិនានា ។
សូមព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយទាំងនេះ
និងប្រោសឲ្យយើងខ្ញុំមានចិត្តឆេះឆួលស្រឡាញ់ព្រះអង្គ ដូចសន្តបារណាបាស ។

ធម៌ប្រារព្ធ បុណ្យគោរពគ្រីស្តទូត ទំព័រ ៤៧៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ !
នៅថ្ងៃគោរពសន្តបារណាបាស ជាគ្រីស្តទូត
យើងខ្ញុំបានទទួលព្រះគ្រីស្តតាមរយៈអគ្គសញ្ញាព្រះកាយ ។
សូមឲ្យយើងខ្ញុំមានចិត្តសង្ឃឹមថា
នៅថ្ងៃណាមួយ ព្រះអង្គនឹងបើកបង្ហាញឲ្យយើងខ្ញុំឃើញព្រះអង្គផ្ទាល់នឹងភ្នែក ។

# ថ្ងៃទី ១៣ មិថុនា

# សន្តអន់តន នៅប៉ាឌូ ជាបូជាចារ្យ និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Antonii de Padova, presbyteri et Ecclesiae doctoris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់គង្វាលមួយរូប (Latin p. 927) ឬពាក្យអធិដ្ឋាន រួមសម្រាប់គ្រូបាធ្យាយនៃព្រះសហគមន៍ (Latin p. 943) ឬពាក្យអធិដ្ឋានរួមសម្រាប់សន្ត: សន្តី៖ សម្រាប់បព្វជិត (Latin p. 961) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ និងមានព្រះជន្មគង់នៅជានិច្ច !
ព្រះអង្គប្រោសឲ្យសន្តអន់តន នៅប៉ាឌូ ពូកែទាំងបកស្រាយព្រះគម្ពីរ ទាំងទូលអង្វរព្រះអង្គសម្រាប់អ្នកតូចតាច ។
នៅថ្ងៃយើងខ្ញុំគោរពសន្តអន់តន សូមព្រះអង្គប្រោសយើងខ្ញុំ
ឲ្យយកចិត្តទុកដាក់នឹងការណែនាំរបស់ព្រះសហគមន៍
និងសូមជួយការពារយើងខ្ញុំឲ្យរួចពីឧបទ្រពនានា ។

# ថ្ងៃទី ១៩ មិថុនា

# សន្តរ៉ូមូអាល ជាចៅអធិការ

**S. Romualdi, abbatis**

ពាក្យអធិដ្ឋានរួមសម្រាប់សន្ត: សន្តី ៖ សម្រាប់ចៅអធិការ ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ ! ព្រះអង្គសព្វព្រះហឫទ័យប្រោសសន្តរ៉ូមូអាល
ធ្វើជាគំរូ ដើម្បីឲ្យព្រះសហគមន៍កែសម្រួលរបៀបរស់នៅតាមបែបតាបស ។
តាមរយៈពាក្យទូលអង្វររបស់លោក សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
ជាគ្រីស្តបរិស័ទដើរតាមព្រះគ្រីស្ត ដោយលះបង់ខ្លួនឯង
ដើម្បីទទួលកេរមរតកឯស្ថានបរមសុខផង ។

# ថ្ងៃទី ២១ មិថុនា

# សន្តលូអ៊ីស ហ្គូនហ្សាក ជាបព្វជិត

**S. Aloisii Gonzaga, religiosi**

(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គប្រទានព្រះអំណោយទានពិសេសឲ្យសន្តលូអ៊ីស ហ្គូនហ្សាក
រស់នៅក្នុងភាពបរិសុទ្ធ ដោយមានចិត្តសោកស្ដាយចំពោះអំពើបាប ។
តាមរយៈពាក្យទូលអង្វររបស់សន្តលូអ៊ីស
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំដែលបានឃ្លាតឆ្ងាយពីគំរូរបស់លោក
ព្យាយាមកែប្រែចិត្តគំនិត និងផ្ដន្ទាខ្លួន ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
សូមឲ្យយើងខ្ញុំត្រាប់តាមគំរូរបស់សន្តលូអ៊ីស
ដោយខិតខំចូលរួមក្នុងពិធីជប់លៀងឯស្ថានបរមសុខទាំងស្លៀកពាក់ស្អាតបាត ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំដែលរួមគ្នាថ្វាយអភិបូជានេះ
ទទួលព្រះអំណោយរបស់ព្រះអង្គទុកជាកម្មសិទ្ធិ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គបានប្រទានអាហាររបស់ទេវទូតមកចិញ្ចឹមយើងខ្ញុំ
ដើម្បីបម្រើព្រះអង្គដោយចិត្តបរិសុទ្ធ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ
ចេះអរព្រះគុណព្រះអង្គគ្រប់ពេលវេលា តាមគំរូសន្តលូអ៊ីសផង ។

## ថ្ងៃទី ២២ មិថុនា

# សន្តប៉ូឡាំង នៅណុល ជាអភិបាលព្រះសហគមន៍

**S. Paulini Nolani, episcopi**

សូមយកពាក្យអធិដ្ឋានរួមតាមមុខងារជាគង្វាល ៖ សម្រាប់អភិបាល (Latin p. 929) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ !

ព្រះអង្គបានប្រោសឲ្យសន្តប៉ូឡាំង នៅណុល ជាអភិបាលព្រះសហគមន៍
យកចិត្តទុកដាក់ណែនាំព្រះសហគមន៍ និងស្រឡាញ់ជនក្រីក្រ ។
នៅថ្ងៃដែលយើងខ្ញុំគោរពសន្តប៉ូឡាំង សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
មានចិត្តស្រឡាញ់ជនកំសត់ទុគ៌ត តាមគំរូរបស់លោក ។

# សន្តយ៉ូហាន ហ្វីសែរ ជាអភិបាល និងសន្តថូម៉ាស ម៉ូរ ជាមរណសាក្សី

**Ss. Ioannis Fisher, episcopi, et Thomæ More, martyrum**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី៖ សម្រាប់មរណសាក្សីជាច្រើន (Latin p. 909) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាអម្ចាស់ !

ព្រះអង្គប្រោសឲ្យសន្តយ៉ូហាន ហ្វីសែរ និងសន្តថូម៉ាស ម៉ូរ ជាមរណសាក្សី
ហ៊ានប្រកាសជំនឿដ៏ពិតប្រាកដរហូតដល់បូជាជីវិត ។
តាមរយៈពាក្យទូលអង្វររបស់សន្តបុគ្គលទាំងពីរ
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យមានកម្លាំង បើកមាត់ប្រកាសជំនឿ
និងផ្ដល់សក្ខីភាពតាមការរស់នៅជារៀងរាល់ថ្ងៃផង ។

# ថ្ងៃទី ២៤ មិថុនា

# កំណើតសន្តយ៉ូហាន បាទីស្ត

**IN NATIVITATE S. IOANNIS BAPTISTÆ**

(បុណ្យឱឡារិក)

## អភិបូជានៅពេលល្ងាច

Ad Missam in Vigilia

អភិបូជានេះ ប្រារព្ធនៅពេលល្ងាច ថ្ងៃទី២៣ មិថុនា មុន ឬ ក្រោយអធិដ្ឋានពេលល្ងាច ។

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

### ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
សូមឲ្យមហាគ្រួសាររបស់ព្រះអង្គដើរតាមមាគ៌ានៃការសង្គ្រោះ
ឆ្ពោះទៅរកព្រះគ្រីស្តដោយយកចិត្តទុកដាក់ស្ដាប់
តាមការប្រៀនប្រដៅរបស់សន្តយ៉ូហាន ដែលជាអ្នករៀបចំផ្លូវថ្វាយព្រះអង្គ ។

សូត្រធម៌ប្រកាសជំនឿ

### ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយដែលប្រជារាស្ត្រលើកថ្វាយ
នៅថ្ងៃគោរពសន្តយ៉ូហានបាទីស្ត ។
តាមរយៈអភិបូជានេះ សូមប្រោសឲ្យយើងខ្ញុំជាប់ចិត្តបម្រើព្រះអង្គជានិច្ច ។

ធម៌ប្រារព្ធផ្ទាល់ ប្រើនៅក្នុងអភិបូជា ទំព័រ ៦៧៨ ។

### ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ ! ព្រះអង្គប្រោសឲ្យសន្តយ៉ូហានបាទីស្តប្រកាសថា
ព្រះបុត្រាព្រះអង្គជាកូនចៀមដែលរំដោះបាបរបស់យើងខ្ញុំ ។
សូមឲ្យសន្តយ៉ូហានបាទីស្តអង្វរព្រះអង្គសម្រាប់យើងខ្ញុំ
ដែលទើបបានទទួលព្រះកាយព្រះគ្រីស្តក្នុងសក្ការបូជានេះ ។

# អភិបូជានៅពេលថ្ងៃ

Ad Missam in die

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គបានចាត់សន្តយ៉ូហាន បាទីស្ត
មកដើម្បីរៀបចំប្រជារាស្ត្រមួយថ្វាយព្រះគ្រីស្ត ។
សូមព្រះអង្គប្រទានព្រះវិញ្ញាណដ៏វិសុទ្ធឲ្យអស់អ្នកជឿមានអំណរសប្បាយ និងមានចិត្តដើរតាមមាគ៌ានៃការសង្គ្រោះក្នុងសេចក្តីសុខសាន្ត ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យសន្តយ៉ូហានបាទីស្ត
ប្រកាសដំណឹងល្អអំពីព្រះសង្គ្រោះដែលយាងមក
និងបង្ហាញឲ្យគេដឹងថា ព្រះយេស៊ូពិតជាព្រះសង្គ្រោះពិភពលោក ។
នៅថ្ងៃយើងខ្ញុំគោរពសន្តយ៉ូហាន សូមព្រះអង្គមេត្តាទទួលតង្វាយ
ដែលយើងខ្ញុំលើកថ្វាយដោយអនុគ្រោះ ។

ធម៌ប្រារព្ធ ៖ បេសកកម្មរបស់អ្នករៀបចំផ្លូវថ្វាយព្រះគ្រីស្ត ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏មានឫទ្ធានុភាព និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះយេស៊ូគ្រីស្ដជាអម្ចាស់យើងខ្ញុំ ។

ព្រះជាម្ចាស់បានចាត់លោកយ៉ូហានបាទីស្ដ មកដើម្បីរៀបចំផ្លូវថ្វាយព្រះគ្រីស្ដ ។
ព្រះអង្គបានញែកលោកពីក្នុងចំណោមមនុស្សទាំងឡាយ
ដើម្បីបំពេញបេសកកម្មដ៏ពិសេសបំផុត
យើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ។
លោកបានបម្រះដោយអរសប្បាយក្នុងផ្ទៃម្ដាយ
នៅពេលជួបព្រះសង្គ្រោះដែលនឹងប្រសូតជាមនុស្ស
កំណើតរបស់លោកធ្វើឲ្យមនុស្សលោកមានអំណរសប្បាយ ។
លោកជាព្យាការីតែម្នាក់គត់ដែលបានបង្ហាញឲ្យគេស្គាល់
កូនចៀមជាព្រះសង្គ្រោះមនុស្សលោក ។
នៅពេលលោកជ្រមុជព្រះយេស៊ូដែលជាម្ចាស់នៃអគ្គសញ្ញាជ្រមុជទឹក
លោកបានធ្វើឲ្យទឹកទន្លេយ័រដាន់ប្រែជាទឹកដ៏វិសុទ្ធ ។
លោកបានទទួលកិត្តិយសផ្ដល់សក្ខីភាពដ៏ប្រសើរជាងគេ
ដោយបង្ហូរឈាមរហូតដល់បូជាជីវិត ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
កម្លាំងសក្ដិសិទ្ធិ និងអ្វីៗទាំងអស់ ដែលមានអំណាចនៅស្ថានបរមសុខ
សូមរួមគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !

ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យយើងខ្ញុំរីករាយ
ដោយចូលរួមក្នុងពិធីជប់លៀងរបស់កូនចៀម ដែលយាងមកពីស្ថានបរមសុខ ។
នៅថ្ងៃគោរពសន្តយ៉ូហានបាទីស្ត ទទួលជីវិតក្នុងលោកនេះ
សូមព្រះអង្គប្រោសឲ្យព្រះសហគមន៍ទទួលស្គាល់ថា
ព្រះគ្រីស្តយាងមកប្រទានជីវិតជារៀងរហូតដល់អ្នកជឿ
ដូចសន្តយ៉ូហានបានប្រកាសទុកជាមុន ។

## ថ្ងៃទី ២៧ មិថុនា

# សន្តស៊ីរីល នៅក្រុងអាឡិចសង់ឌ្រី
# ជាអភិបាលព្រះសហគមន៍ និងជាគ្រូបាធ្យាយ

**S. Cyrilli Alexandrini, episcopi et Ecclesiæ doctoris**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល (Latin p. 929) ឬពាក្យអធិដ្ឋានរួមសម្រាប់គ្រូបាធ្យាយនៃព្រះសហគមន៍ (Latin p. 943) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាម្ចាស់ !
ព្រះអង្គប្រោសឲ្យសន្តស៊ីរីល ជាអភិបាល នៅក្រុងអាឡិចសង់ឌ្រី
មានចិត្តក្លាហានថែរក្សា និងការពារព្រះសហគមន៍ដែលជឿថា
ព្រះនាងព្រហ្មចារិនីម៉ារី ពិតជាមាតារបស់ព្រះជាម្ចាស់ ។
សូមព្រះអង្គពង្រឹងជំនឿយើងខ្ញុំដែលគោរពព្រះនាងម៉ារី
ជាមាតារបស់ព្រះជាម្ចាស់ ។ សូមព្រះអង្គសង្គ្រោះយើងខ្ញុំតាមរយៈព្រះយេស៊ូគ្រីស្ត
ជាព្រះបុត្រាព្រះអង្គដែលបានប្រសូតជាមនុស្ស ។

# ថ្ងៃទី ២៨ មិថុនា
# សន្តអ៊ីរេណេ ជាអភិបាល និងជាមរណសាក្សី

**S. Irenæi, episcopi et martyris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាអម្ចាស់ !
ព្រះអង្គត្រាស់ហៅសន្តអ៊ីរេណេ ជាអភិបាលឲ្យពង្រឹងលទ្ធិដ៏ពិតប្រាកដ
និងសន្តិភាពក្នុងព្រះសហគមន៍ ។
តាមរយៈពាក្យទូលអង្វររបស់លោក
សូមព្រះអង្គប្រោសឲ្យជំនឿ និងសេចក្ដីស្រឡាញ់របស់យើងខ្ញុំរស់រវើកឡើងវិញ
ហើយឲ្យយើងខ្ញុំយកចិត្តទុកដាក់បង្រួបបង្រួមអស់អ្នកដែលបែកបាក់គ្នា ។

ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
នៅថ្ងៃគោរពសន្តអ៊ីរេណេចូលស្ថានបរមសុខ
យើងខ្ញុំមានអំណរសប្បាយថ្វាយសក្ការបូជានេះ
ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានចិត្តស្រឡាញ់សេចក្ដីពិត
ដើម្បីរក្សាការពារជំនឿព្រះសហគមន៍ និងរួបរួមគ្នាជាធ្លុងតែមួយ ។

ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គបានប្រោសឲ្យសន្តអ៊ីរេណេ រក្សាការពារជំនឿរហូតដល់បូជាជីវិត ។
តាមរយៈអភិបូជានេះ សូមព្រះអង្គប្រោសប្រណីឲ្យយើងខ្ញុំ
មានជំនឿកាន់តែរីកចម្រើនឡើង ហើយប្រព្រឹត្តតាមជំនឿនោះ
ដើម្បីទទួលការសង្គ្រោះពីព្រះអង្គ ។

# ថ្ងៃទី ២៩ មិថុនា

# សន្តសិលា និងសន្តប៉ូល ជាគ្រីស្តទូត

**SS. PETRI ET PAULI, APOSTOLORUM**

( បុណ្យឱឡារិក )

## អភិបូជានៅពេលល្ងាច

Ad Missam in Vigilia

អភិបូជានេះ ប្រារព្ធនៅពេលល្ងាចថ្ងៃទី២៨ មិថុនា ។

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រទានពរឲ្យសន្តសិលា និងសន្តប៉ូល ជាគ្រីស្តទូត
ទៅជាគ្រឹះដ៏រឹងមាំរបស់ព្រះសហគមន៍ ។
តាមរយ:ពាក្យទូលអង្វររបស់លោកទាំងពីរ
សូមព្រះអង្គសង្គ្រោះយើងខ្ញុំអស់កល្បជានិច្ច ។

សូត្រធម៌ប្រកាសជំនឿ ។

### ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
សូមព្រះអង្គទទួលតង្វាយដែលយើងខ្ញុំថ្វាយនៅលើតុសក្ការបូជា
ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
សម្រាប់ថ្ងៃបុណ្យដ៏ឱឡារិករបស់សន្តសិលា និងសន្តប៉ូល ។
ពេលណាយើងខ្ញុំមិនពឹងលើបុណ្យកុសល
ពេលនោះយើងខ្ញុំកាន់តែមានអំណរសប្បាយ ព្រោះព្រះអង្គសង្គ្រោះយើងខ្ញុំដោយព្រះហឫទ័យសប្បុរស ។

ធម៌ប្រារព្ធផ្ទាល់នេះ ដូចនៅក្នុងអភិបូជាបន្ទាប់ ទំព័រ ៦៧៦ ។

ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់ជាព្រះបិតា !
ព្រះអង្គបានចិញ្ចឹមជីវិតយើងខ្ញុំដោយអគ្គសញ្ញាដ៏អស្ចារ្យមកពីស្ថានបរមសុខ ។
សូមព្រះអង្គពង្រឹងជំនឿរបស់អស់អ្នកជឿលើព្រះអង្គ និងបំភ្លឺគេឲ្យរស់នៅតាមការប្រៀនប្រដៅរបស់គ្រីស្តទូតផង ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក ទំព័រ ៥៦០ ។

# អភិបូជានៅពេលថ្ងៃ

Ad Missam in die

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាម្ចាស់ !
ព្រះអង្គប្រោសឲ្យយើងខ្ញុំមានអំណរសប្បាយយ៉ាងក្រៃលែង
នៅថ្ងៃបុណ្យដ៏ឱឡារិករបស់សន្តសិលា និងសន្តប៉ូល ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំរស់នៅតាមការប្រៀនប្រដៅ
របស់គ្រីស្តទូតទាំងពីរ ដែលជាជំនឿដើមដំបូងរបស់ព្រះសហគមន៍ ។

សូត្រធម៌ប្រកាសជំនឿ ។

ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
សូមព្រះអង្គមេត្តាទទួលពាក្យទូលអង្វររបស់គ្រីស្តទូតទាំងពីរ
រួមជាមួយតង្វាយដែលយើងខ្ញុំថ្វាយចំពោះព្រះនាមព្រះអង្គ ។
សូមប្រោសឲ្យយើងខ្ញុំជាប់ចិត្តគោរពបម្រើព្រះអង្គក្នុងសក្ការបូជានេះ ។

ធម៌ប្រារព្ធ ៖ អំពីបេសកកម្មទាំងពីររបស់សន្តសិលា និងសន្តប៉ូល ក្នុងព្រះសហគមន៍ ។

បៈ សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រៈ ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

បៈ សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រៈ យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

បៈ សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រៈ ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏មានឫទ្ធានុភាព និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។
ព្រះអង្គសព្វព្រះហឫទ័យប្រទានអំណរសប្បាយឲ្យយើងខ្ញុំ
តាមរយៈកិច្ចការរបស់សន្តសិលា និងសន្តប៉ូល៖
សន្តសិលាជាអ្នកប្រកាសជំនឿលើព្រះគ្រីស្តមុនគេបង្អស់ ហើយសន្តប៉ូលជាគ្រូពូកែ
ខាងបកស្រាយព្រះបន្ទូល ។
សន្តសិលាជាអ្នកប្រមូលប្រជារាស្ត្រអ៊ីស្រាអែលដែលនៅសេសសល់
ឲ្យទៅជាព្រះសហគមន៍ដើមដំបូង
រីឯសន្តប៉ូលជាគ្រូបាធ្យាយបង្រៀន និងណែនាំសាសន៍ដទៃ
ដែលព្រះអង្គបានត្រាស់ហៅ ។
សន្តទាំងពីរមានវិធីធ្វើខុសគ្នា
តែលោកទាំងពីរបានខិតខំប្រមែប្រមូលមនុស្សលោក
ឲ្យទៅជាគ្រួសារតែមួយក្នុងអង្គព្រះគ្រីស្ត ។
ដូច្នេះ សន្តទាំងពីរបានទទួលមកុដជាមរណសាក្សី
និងទទួលការគោរពរួមជាមួយគ្នាទូទាំងសកលលោក ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ លើកតម្កើងព្រះអង្គ
ដោយប្រកាសឥតឈប់ឈរថា៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !

ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គបានប្រទានកម្លាំងថ្មីឲ្យយើងខ្ញុំក្នុងអភិបូជានេះ ។
សូមមេត្តាប្រោសឲ្យយើងខ្ញុំចេះរស់នៅជាព្រះសហគមន៍
ដោយព្យាយាមកាច់នំប៉័ង ព្យាយាមស្តាប់ការប្រៀនប្រដៅរបស់ក្រុមគ្រីស្តទូត ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានចិត្តថ្លើមតែមួយ ហើយជាប់ចិត្តនឹងសេចក្តីស្រឡាញ់របស់ព្រះអង្គ ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក ទំព័រ ៥៦០ ។

## ថ្ងៃទី ៣០ មិថុនា

# មរណសាក្សីដើមដំបូងនៅព្រះសហគមន៍ក្រុងរ៉ូម

**Ss. Protomartyrum sanctæ Romanæ Ecclesiæ**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី៖ សម្រាប់មរណសាក្សីច្រើននាក់ Latin p. 909) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ជាព្រះបិតា !
ព្រះអង្គបានទទួលឈាមដែលមរណសាក្សីដើមដំបូង
របស់ព្រះសហគមន៍ក្រុងរ៉ូម ថ្វាយទៅព្រះអង្គទុកជាតង្វាយដ៏សក្ការៈ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានចិត្តក្លាហាន មាំមួន តាមគំរូរបស់មរណសាក្សី ។
សូមប្រោសឲ្យយើងខ្ញុំមានអំណរសប្បាយនឹងជ័យជម្នះនៃសេចក្តីស្រឡាញ់ ។

# ខែ កក្កដា

## ថ្ងៃទី ៣ កក្កដា

## សន្តថូម៉ាស ជាគ្រីស្តទូត

**S. THOMÆ, APOSTOLI**

(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

### ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំមានមោទនភាពនឹងប្រារព្ធបុណ្យគោរពសន្តថូម៉ាស ជាគ្រីស្តទូត ។
តាមរយៈពាក្យទូលអង្វររបស់លោក
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានជំនឿរឹងមាំ និងទទួលជីវិតរួមជាមួយព្រះយេស៊ូ
ដែលសន្តថូម៉ាសបានទទួលស្គាល់ថា ជាព្រះអម្ចាស់ ។

### ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
នៅថ្ងៃនេះ យើងខ្ញុំគោរពគ្រីស្តទូត ថូម៉ាស
ដែលលោកបានប្រកាសថា ព្រះគ្រីស្តជាព្រះអម្ចាស់
និងជាព្រះរបស់យើងខ្ញុំមែន ។
យើងខ្ញុំសូមថ្វាយសក្ការបូជាដើម្បីលើកតម្កើង និងបម្រើព្រះអង្គតាមកាតព្វកិច្ចរបស់យើងខ្ញុំ
សូមព្រះអង្គរក្សាព្រះអំណោយទានរបស់ព្រះអង្គ
ទុកសម្រាប់យើងខ្ញុំផង ។

ធម៌ប្រារព្ធ បុណ្យគោរពគ្រីស្តទូត ទំព័រ ៤៧៦-៤៧៨ ។

ពាក្យអរព្រះគុណ

ឱ ព្រះជាម្ចាស់ជាព្រះបិតា !
ក្នុងអភិបូជានេះ យើងខ្ញុំពិតជាបានទទួលព្រះកាយ
ព្រះបុត្រាតែមួយរបស់ព្រះអង្គ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំទទួលស្គាល់ព្រះយេស៊ូរួមជាមួយគ្រីស្តទូត ថូម៉ាស
ដោយជឿថា ព្រះអង្គពិតជាព្រះអម្ចាស់ និងជាព្រះរបស់យើងខ្ញុំមែន
ហើយសូមឲ្យយើងខ្ញុំប្រកាសអំពីព្រះអង្គ
តាមរយៈកិច្ចការ និងរបៀបដែលយើងខ្ញុំរស់នៅ ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក (ទំព័ ៥៦០) ។

# ថ្ងៃទី ៤ កក្កដា

# សន្តីអេលីសាបិត នៅព័រទុយហ្គាល

**S. Elisabeth Lusitaniæ**

ពាក្យអធិដ្ឋានរួមសម្រាប់សន្ត: សន្តីៈ សម្រាប់អ្នកប្រព្រឹត្តកិច្ចការនៃធម៌មេត្តាករុណា Latin p. 963) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ជាព្រះបិតា !
ព្រះអង្គជាប្រភពនៃសេចក្តីស្រឡាញ់គ្រប់យ៉ាង ហើយព្រះអង្គសព្វព្រះហឫទ័យនឹង
អ្នកដែលកសាងសន្តិភាព ។ យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ដែលប្រោសឲ្យសន្តីអេ
លីសាបិត
សម្រុះសម្រួលមនុស្សដែលបែកបាក់គ្នាឲ្យជានានឹងគ្នា ។ សូមព្រះអង្គប្រោសឲ្យ
យើងខ្ញុំដែលជាបុត្រធីតារបស់ព្រះអង្គ
ចេះយកចិត្តទុកដាក់កសាងសន្តិភាពជានិច្ច ។

## ថ្ងៃទី ៥ កក្កដា

# សន្តអន់ទន ម៉ារីសាក្ការីយ៉ា ជាបូជាចារ្យ

**S. Antonii Mariæ Zaccaria, presbyteri**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល៖ សម្រាប់គង្វាលមួយរូប Latin p. 927) ឬពាក្យអធិដ្ឋានរួមសម្រាប់សន្ត: សន្តី ៖ សម្រាប់អ្នកអប់រំ Latin p. 965) ឬសម្រាប់បព្វជិត Latin p. 961) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យយើងខ្ញុំស្គាល់ព្រះគ្រីស្តយ៉ាងច្បាស់ ដូចសន្តអន់ទនម៉ារី សាក្ការីយ៉ា ដែលបានគោរព និងទទួលព្រះកាយព្រះគ្រីស្ត
ព្រមទាំងស្រឡាញ់ព្រះឈើឆ្កាង តាមសេចក្តីបង្រៀនរបស់គ្រីស្តទូតប៉ូល ។
សូមព្រះអង្គណែនាំឲ្យយើងខ្ញុំបម្រើព្រះសហគមន៍
ដោយយកចិត្តទុកដាក់ប្រកាសដល់មនុស្សតូចតាចថា ព្រះអង្គសង្គ្រោះគេ ។

## ថ្ងៃទី ៦ កក្កដា

# សន្តីម៉ារី កូរែទី ជាព្រហ្មចារិនី និងមរណសាក្សី

**S. Mariæ Goretti, virginis et martyris**

ពាក្យអធិដ្ឋានរួមតាមមុខងារជាមរណសាក្សី ៖ សម្រាប់មរណសាក្សីជាព្រហ្មចារី Latin p. 924) ឬពាក្យអធិដ្ឋានរួមតាមមុខងារជាព្រហ្មចារិនី៖ សម្រាប់ព្រហ្មចារីមួយរូប Latin p. 947) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គបានបង្កើតមនុស្សឲ្យមានចិត្តស្មោះត្រង់
ហើយព្រះអង្គគាប់ព្រះហឫទ័យនឹងសេចក្តីស្រឡាញ់ដ៏បរិសុទ្ធ ។
ព្រះអង្គបានប្រោសឲ្យសន្តីម៉ារី កូរែទី ជាអ្នកបម្រើព្រះអង្គ
ហ៊ានបូជាជីវិតទាំងនៅវ័យក្មេង ។
តាមរយៈពាក្យទូលអង្វររបស់នាង
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ មានចិត្តតស៊ូធ្វើតាមបង្គាប់របស់ព្រះអង្គផង ។

## ថ្ងៃទី ៩ កក្កដា

# សន្តអូហ្គូស្ទីន ហ្សាវរុង ជាបូជាចារ្យ ព្រមទាំងសហជីវិន ជាមរណសាក្សី

**Ss. Augustini Zhao Rong, presbyteri, et sociorum, martyrum**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីច្រើននាក់ Latin p. 909) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យពង្រឹងព្រះសហគមន៍
តាមរយៈសក្ខីភាពជាមរណសាក្សីរបស់សន្តអូហ្គូស្ទីន ហ្សាវរុង និងសហជីវិន ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបំពេញបេសកកម្មថ្វាយព្រះអង្គ
ដោយមានចិត្តស្មោះត្រង់ ទាំងមានអំណរសប្បាយ និងសេរីភាព
ហើយធ្វើជាសាក្សីនៃសេចក្ដីពិតចំពោះមុខពិភពលោក ។

## ថ្ងៃទី ១១ កក្កដា

# សន្តបេណេឌិកតូ ជាចៅអធិការ

**S. Benedicti, abbatis**

(បុណ្យរំឭក)

### ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រោសឲ្យសន្តបេណេឌិកតូ ជាចៅអធិការ
និងជាគ្រូដ៏ប្រសើរណែនាំក្រុមបព្វជិតឲ្យបម្រើព្រះអង្គតែមួយគត់ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំចេះយកចិត្តទុកដាក់
ប្រព្រឹត្តតាមវិន័យរបស់ព្រះអង្គដោយចិត្តស្មោះ និងស្រឡាញ់ព្រះអង្គលើសអ្វីៗទាំងអស់ ។

### ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
សូមព្រះអង្គទតមើលតង្វាយយើងខ្ញុំដោយព្រះហឫទ័យសប្បុរស
នៅពេលដែលយើងខ្ញុំគោរពសន្តបេណេឌិកតូ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំស្វែងរកព្រះអង្គគ្រប់ពេលវេលា ហើយនៅពេលយើងខ្ញុំបម្រើព្រះអង្គ
សូមឲ្យយើងខ្ញុំរួមគ្នាជាផ្លូងតែមួយ និងទទួលសេចក្ដីសុខសាន្ត ។

### ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ ! ព្រះអង្គសព្វព្រះហឫទ័យប្រទានព្រះកាយព្រះគ្រីស្ត
ដែលផ្ដល់ជីវិតអស់កល្បជានិច្ចដល់យើងខ្ញុំ ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យយកចិត្តទុកដាក់
ស្ដាប់ការប្រៀនប្រដៅរបស់សន្តបេណេឌិកតូ
ដើម្បីបម្រើព្រះអង្គដោយចិត្តស្មោះ និងព្យាយាមអធិដ្ឋាន
ព្រមទាំងស្រឡាញ់អ្នកដទៃទុកជាបងប្អូន ។

## ថ្ងៃទី ១៣ កក្កដា

# សន្តហង់រី

**S. Henrici**

ពាក្យអធិដ្ឋានរួមសម្រាប់សន្ត សន្តី ៖ សម្រាប់សន្តមួយរូប Latin p. 956) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាអម្ចាស់ !
ព្រះអង្គប្រោសប្រទានឲ្យសន្តហង់រី ជាមហាក្សត្រមានប្រាជ្ញាវាងវៃ
ត្រួតត្រារាជាណាចក្ររបស់លោកនៅលើផែនដីនេះ
ហើយក៏លើកលោកឲ្យចូលក្នុងព្រះរាជ្យនៃស្ថានបរមសុខដែរ ។
តាមរយៈពាក្យទូលអង្វររបស់លោក សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
យកចិត្តទុកដាក់បម្រើព្រះអង្គដោយចិត្តស្មោះ ក្នុងលោកដ៏មិនទៀងទាត់នេះ ។

# ថ្ងៃទី ១៤ កក្កដា

# សន្តកាមីល នៅភូមិលេលីស៍ ជាបូជាចារ្យ

**S. Camilli de Lellis presbyteri**

ពាក្យអធិដ្ឋានរួមសម្រាប់សន្តបុគ្គល៖ សម្រាប់អ្នកប្រព្រឹត្តកិច្ចការនៃធម៌មេត្តាករុណា Latin p. 963) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រោសប្រទានឲ្យសន្តកាមីល ជាបូជាចារ្យ
មានចិត្តស្រឡាញ់អាណិតអាសូរអ្នកជំងឺយ៉ាងខ្លាំង ។
សូមព្រះអង្គប្រទានព្រះវិញ្ញាណនៃសេចក្ដីស្រឡាញ់ផ្ទាល់របស់ព្រះអង្គឲ្យយើងខ្ញុំ
សូមប្រោសយើងខ្ញុំឲ្យយកចិត្តទុកដាក់បម្រើព្រះអង្គ និងបម្រើបងប្អូនឯទៀតៗ
ធ្វើដូច្នេះ បន្ទាប់ពីបញ្ចប់ជីវិតក្នុងលោកនេះ
យើងខ្ញុំសង្ឃឹមថា នឹងជួបព្រះអង្គដោយសេចក្ដីសុខសាន្ត ។

# ថ្ងៃទី ១៥ កក្កដា

# សន្តបូណាវិនទួរ ជាអភិបាល និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Bonaventuræ, episcopi et Ecclesiæ**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល Latin p. 929) ឬពាក្យអធិដ្ឋានរួមសម្រាប់គ្រូបាធ្យាយនៃព្រះសហគមន៍ Latin p. 943) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
នៅថ្ងៃនេះ យើងខ្ញុំសូមនឹករឭកដល់ថ្ងៃកំណើតនៅស្ថានបរមសុខ
របស់សន្តបូណាវិនទួរ ជាអភិបាលព្រះសហគមន៍ ។
សូមឲ្យគុណប្រយោជន៍នៃទេវវិទ្យាដ៏ជ្រាលជ្រៅដែលលោកបានបង្រៀន
បំភ្លឺយើងខ្ញុំឲ្យមានជំនឿមាំមួន និងជំរុញយើងខ្ញុំឲ្យស្រឡាញ់អ្នកដទៃយ៉ាងខ្លាំង ។

## ថ្ងៃទី ១៦ កក្កដា

# ព្រះនាងម៉ារី នៅលើភ្នំការមែល

**Beatæ Mariæ Virginis de Monte Carmelo**

ពាក្យអធិដ្ឋានរួមសម្រាប់ព្រះនាងព្រហ្មចារិនីម៉ារី (Latin p. 897) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់អើយ !

សូមឲ្យពាក្យអង្វររបស់ព្រះនាងម៉ារី ផ្តល់កម្លាំងមកយើងខ្ញុំ

និងគាំពារយើងខ្ញុំឲ្យធ្វើដំណើរឡើងទៅកំពូលភ្នំ គឺព្រះយេស៊ូគ្រីស្ត ។

## ថ្ងៃទី ២០ កក្កដា

# សន្តអាប៉ូលីណែរ ជាអភិបាល និងជាមរណសាក្សី

**S. Apollinaris, episcopi et martyris**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី៖ សម្រាប់មរណសាក្សីមួយរូប (Latin p. 915) ឬពាក្យអធិដ្ឋានរួមសម្រាប់គង្វាល៖ សម្រាប់អភិបាល (Latin p. 929) ។

### ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាអម្ចាស់ !

ព្រះអង្គសព្វព្រះហឫទ័យឲ្យសន្តអាប៉ូលីណែរ

ធ្វើជាគ្រូដ៏ល្អ និងសុខចិត្តបូជាជីវិត

ដើម្បីបង្ហាញមាគ៌ានៃការសង្គ្រោះអស់កល្បជានិច្ចដល់អស់អ្នកជឿ ។

តាមរយៈពាក្យទូលអង្វររបស់លោក

សូមព្រះអង្គប្រោសយើងខ្ញុំឲ្យគោរពវិន័យរបស់ព្រះអង្គយ៉ាងខ្ជាប់ខ្ជួន

ដើម្បីទទួលភ្នួងជ័យរួមជាមួយលោកផង ។

# ថ្ងៃទី ២១ កក្កដា

# សន្តឡូរង់ នៅទីក្រុងប្រិនឌីស៊ី ជាបូជាចារ្យ និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Laurentii de Brindisi, presbyteri et Ecclesiæ doctoris**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល៖ សម្រាប់គង្វាលមួយរូប（Latin p. 927）ឬពាក្យអធិដ្ឋានរួមសម្រាប់គ្រូបាធ្យាយនៃព្រះសហគមន៍（Latin p. 943）ឬពាក្យអធិដ្ឋានរួមសម្រាប់សន្ត: សន្តី៖ សម្រាប់បព្វជិត（Latin p. 961）។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យសន្តឡូរង់ នៅក្រុងប្រិនឌីស៊ី ជាបូជាចារ្យ
មានប្រាជ្ញាឈ្លាសវៃក្នុងការផ្តល់ប្រឹក្សា និងមានចិត្តតស៊ូ
លើកតម្កើងព្រះនាមព្រះអង្គដែលសង្គ្រោះមនុស្សលោក ។
តាមរយ:ពាក្យទូលអង្វររបស់លោក
សូមព្រះអង្គប្រទានព្រះវិញ្ញាណដល់យើងខ្ញុំ
ឲ្យប្រព្រឹត្តកិច្ចការស្របតាមព្រះហឫទ័យព្រះអង្គ ។

# ថ្ងៃទី ២២ កក្កដា
# សន្តីម៉ារី ម៉ាដាឡា

**S. Mariæ Magdalenæ**

(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះបុត្រារបស់ព្រះអង្គបានប្រគល់បេសកកម្មឲ្យនាងម៉ារី ម៉ាដាឡា
ប្រកាសមុនគេបង្អស់ដោយអំណរសប្បាយថា
ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ។
តាមរយៈគំរូ និងពាក្យទូលអង្វររបស់នាង សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
យកចិត្តទុកដាក់ប្រកាសអំពីព្រះគ្រីស្តដែលមានព្រះជន្មគង់នៅ
និងសូមឲ្យយើងខ្ញុំបានឃើញព្រះគ្រីស្តសោយរាជ្យ ក្នុងសិរីរុងរឿងរបស់ព្រះបិតា ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យសន្តីម៉ារី ម៉ាដាឡា យកចិត្តទុកដាក់បម្រើ
ព្រះបុត្រាតែមួយរបស់ព្រះអង្គដោយសេចក្តីស្រឡាញ់ ។
តាមរយៈពាក្យទូលអង្វររបស់សន្តី ម៉ារី ម៉ាដាឡា
សូមព្រះអង្គមេត្តាទទួលតង្វាយរបស់យើងខ្ញុំដោយអនុគ្រោះ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គ
ដែលប្រោសឲ្យយើងខ្ញុំបានចូលរួមក្នុងអភិបូជានេះ ។
សូមឲ្យសេចក្តីស្រឡាញ់របស់ព្រះអង្គជ្រួតជ្រាបក្នុងដួងចិត្តយើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំ
រស់នៅតាមគំរូរបស់សន្តីម៉ារី ម៉ាដាឡា
ដែលស្រឡាញ់ព្រះគ្រីស្តជាព្រះគ្រូរបស់នាង ។

## ថ្ងៃទី ២៣ កក្កដា

# សន្តីប្រ៊ីហ្សីត ជាបព្វជិតា

**S. Birgittæ, religiosæ**

ពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់សន្តី (Latin p. 966) ឬ សម្រាប់បព្វជិត (Latin p. 961) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គបានប្រោសឲ្យសន្តីប្រ៊ីហ្សីត ជាភរិយា និងជាបព្វជិតា
សញ្ជឹងគិតពីទុក្ខលំបាករបស់ព្រះបុត្រាព្រះអង្គ
ហើយយល់ដឹងពីព្រះប្រាជ្ញាញាណនៃឈើឆ្កាង ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំយកចិត្តទុកដាក់នឹងការត្រាស់ហៅ ហើយស្វែងរកព្រះអង្គគ្រប់ពេលវេលា ។

## ថ្ងៃទី ២៤ កក្កដា

# សន្តសាបែល ម៉ាកឃ្លូវ ជាបូជាចារ្យ

**S. Sarbellii Makhluf, presbyteri**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់គង្វាលមួយរូប (Latin p. 933) ឬពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់បព្វជិតនៅអារាម (Latin p. 959) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គបានត្រាស់ហៅសន្តសាបែល ម៉ាកឃ្លូវ ជាបូជាចារ្យ
ឲ្យតស៊ូម្នាក់ឯងនៅវាលរហោស្ថាន ដោយអធិដ្ឋានតាមបង្គាប់របស់ព្រះអង្គ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំចេះស៊ូទ្រាំរងទុក្ខលំបាកតាមគំរូរបស់ព្រះគ្រីស្ត ដើម្បីទទួលព្រះរាជ្យព្រះជាម្ចាស់ទុកជាមរតក ។

# ថ្ងៃទី ២៥ កក្កដា

# សន្ដយ៉ាកុប ជាគ្រីស្ដទូត

**S. IACOBI, APOSTOLI**

( បុណ្យ )

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គប្រោសប្រទានឲ្យសន្ដយ៉ាកុប ជាសាវ័ករបស់ព្រះគ្រីស្ដ
បូជាជីវិតមុនគេបង្អស់ ។
ឈាមរបស់លោកជាផលផ្លែដំបូងដែលក្រុមគ្រីស្ដទូតថ្វាយទៅព្រះអង្គ ។
ដោយពឹងលើជំនឿរបស់សន្ដយ៉ាកុប
យើងខ្ញុំសូមព្រះអង្គពង្រឹង និងការពារព្រះសហគមន៍ជានិច្ច ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
នៅថ្ងៃនេះ យើងខ្ញុំសូមគោរពសន្ដយ៉ាកុប
ដែលបានទទួលពែងនៃទុក្ខលំបាករបស់ព្រះគ្រីស្ដ មុនគេក្នុងចំណោមគ្រីស្ដទូត ។
សូមព្រះអង្គជម្រះយើងខ្ញុំក្នុងព្រះលោហិតរបស់ព្រះបុត្រា
ដើម្បីយើងខ្ញុំថ្វាយសក្ការបូជាឲ្យបានគាប់ព្រះហឫទ័យព្រះអង្គ ។

ធម៌ប្រារព្ធ បុណ្យគោរពគ្រីស្ដទូត ទំព័រ ៤៧៦ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !
នៅថ្ងៃបុណ្យគោរពសន្ដយ៉ាកុប ជាគ្រីស្ដទូត
និងតាមរយៈពាក្យទូលអង្វររបស់លោក សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
មានអំណរសប្បាយដោយបានទទួលព្រះកាយព្រះគ្រីស្ដ ។

# ថ្ងៃទី ២៦ កក្កដា
# សន្តីហាណ្ណា និងសន្តយ៉ូហាគីម ជាមាតាបិតារបស់ព្រះនាងម៉ារី

**Ss. Ioachim et Annæ, parentum beatæ Mariæ Virginis**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ជាព្រះនៃបុព្វបុរសយើងខ្ញុំ !
ព្រះអង្គប្រោសឲ្យសន្តីហាណ្ណា និងសន្តយ៉ូហាគីម
បង្កើតបុត្រីដែលនឹងទៅជាព្រះមាតានៃព្រះបុត្រាព្រះអង្គ ។
តាមពាក្យអង្វររបស់លោកទាំងពីរ សូមប្រោសឲ្យប្រជារាស្ត្ររបស់ព្រះអង្គ
ទទួលការសង្គ្រោះតាមព្រះបន្ទូលសន្យា ។

ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយរបស់យើងខ្ញុំ
ដែលលើកថ្វាយដើម្បីអរព្រះគុណព្រះអង្គ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំទទួលព្រះពរ
ដែលព្រះអង្គបានសន្យាចំពោះលោកអាប្រាហាំ និងពូជពង្សរបស់លោក ។

ពាក្យអរព្រះគុណ

ឱ ព្រះជាម្ចាស់អើយ !
តាមគម្រោងការដ៏អស្ចារ្យ
ព្រះអង្គសព្វព្រះហឫទ័យឲ្យព្រះបុត្រាតែមួយរបស់ព្រះអង្គ
ប្រសូតក្នុងចំណោមមនុស្សលោក ដើម្បីឲ្យមនុស្សលោកកើតជាថ្មីពីព្រះអង្គ ។
សូមព្រះអង្គមេត្តាប្រោសឲ្យអស់អ្នកដែលទទួលព្រះកាយព្រះគ្រីស្ត
បានទៅជាបុត្រធីតារបស់ព្រះអង្គ ។

# ថ្ងៃទី ២៩ កក្កដា

# សន្តីម៉ាថា

**S. Marthæ**

(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ និងមានព្រះជន្មគង់នៅជានិច្ច ! ព្រះបុត្រាគាប់ព្រះហឫទ័យនឹងសន្តីម៉ាថា ដែលទទួលព្រះអង្គឲ្យស្នាក់នៅផ្ទះរបស់នាងទុកជាភ្ញៀវកិត្តិយស ។

តាមរយៈពាក្យទូលអង្វររបស់នាង សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ

យកចិត្តទុកដាក់បម្រើព្រះគ្រីស្ត ដោយបម្រើបងប្អូនយ៉ាងស្មោះអស់ពីចិត្ត ។

យើងខ្ញុំសង្ឃឹមថា នៅថ្ងៃណាមួយ

ព្រះអង្គទទួលយើងខ្ញុំឲ្យស្នាក់នៅឯស្ថានបរមសុខដែរ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !

នៅថ្ងៃគោរពសន្តីម៉ាថា យើងខ្ញុំសូមលើកតម្កើងការដ៏អស្ចារ្យរបស់ព្រះអង្គ

ដែលប្រោសឲ្យសន្តីម៉ាថា បម្រើព្រះយេស៊ូដោយសេចក្ដីស្រឡាញ់ ។

សូមព្រះអង្គប្រោសឲ្យកិច្ចការបម្រើរបស់យើងខ្ញុំ បានគាប់ព្រះហឫទ័យព្រះអង្គផង ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !

ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្តឲ្យយើងខ្ញុំ ។

សូមព្រះអង្គបង្វែរចិត្តគំនិតយើងខ្ញុំ

កុំឲ្យឈ្លក់វង្វេងនឹងសម្បត្តិលោកីយដែលមិនទៀងទាត់នេះ ។

សូមព្រះអង្គប្រោសឲ្យយើងខ្ញុំស្រឡាញ់ព្រះអង្គកាន់តែខ្លាំងឡើងៗ

ដោយចិត្តស្មោះតាមគំរូរបស់សន្តីម៉ាថា ព្រមទាំងមានអំណរសប្បាយ

ដោយសង្ឃឹមថា នឹងជួបព្រះភ័ក្ត្រព្រះអង្គនៅស្ថានបរមសុខ ។

## ថ្ងៃទី ៣០ កក្កដា

# សន្តសិលា គ្រីសូឡូក ជាអភិបាល និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Petri Chrysologi, episcopi et Ecclesiæ doctoris**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល (Latin p. 929) ឬពាក្យអធិដ្ឋានរួមសម្រាប់គ្រូបាធ្យាយនៃព្រះសហគមន៍ (Latin p. 943) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យសន្តសិលា គ្រីសូឡូក ជាអភិបាល
មានថ្វីមាត់ប្រកាសពីព្រះបន្ទូលដែលកើតជាមនុស្ស ។
តាមរយៈពាក្យទូលអង្វររបស់លោក
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំទុកគម្រោងការដ៏អស្ចារ្យ
នៃការសង្គ្រោះរបស់ព្រះអង្គនៅក្នុងចិត្ត
និងឲ្យយើងខ្ញុំបង្ហាញការសង្គ្រោះនោះ
តាមរយៈកិច្ចការដែលយើងខ្ញុំប្រព្រឹត្ត ។

# ថ្ងៃទី ៣១ កក្កដា
# សន្តអ៊ីញ៉ាស នៅឡយ៉ូឡា ជាបូជាចារ្យ

**S. Ignatii de Loyola, presbyteri**

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !

ព្រះអង្គបានជ្រើសរើសសន្តអ៊ីញ៉ាស នៅឡយ៉ូឡា ពីក្នុងព្រះសហគមន៍

ឲ្យលើកតម្កើងសិរីរុងរឿងដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះនាមព្រះអង្គ ។

សូមព្រះអង្គប្រោសយើងខ្ញុំឲ្យយកតម្រាប់តាមលោក និងពុះពារតយុទ្ធនៅលើពិភពលោកនេះ

ព្រមទាំងទទួលភ្នួងជ័យនៃស្ថានបរមសុខរួមជាមួយលោកផង ។

ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាម្ចាស់ជាព្រះបិតា !

នៅថ្ងៃគោរពសន្តអ៊ីញ៉ាស សូមព្រះអង្គគាប់ព្រះហឫទ័យនឹងតង្វាយ

ដែលយើងខ្ញុំលើកថ្វាយ ។

សូមឲ្យសក្ការបូជាដែលជាប្រភពនៃភាពដ៏វិសុទ្ធ

ប្រោសយើងខ្ញុំឲ្យទៅជាជនដ៏វិសុទ្ធក្នុងសេចក្ដីពិត ។

ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !

នៅថ្ងៃគោរពសន្តអ៊ីញ៉ាស យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ។

សូមឲ្យសក្ការបូជានេះ ប្រោសឲ្យយើងខ្ញុំ

លើកតម្កើងព្រះអង្គជាព្រះដ៏ឧត្តុង្គឧត្ដមដោយគ្មានទីបញ្ចប់ ។

# ខែ សីហា

## ថ្ងៃទី ១ សីហា

# សន្តអាលហ្វុងស៊ូ ម៉ារី នៅលីកូរី ជាអភិបាល និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Alfonsi Mariæ de' Liguori, episcopi et Ecclesiæ et Ecclesiæ doctoris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល (Latin p. 929) ឬពាក្យអធិដ្ឋានរួមសម្រាប់គ្រូបាធ្យាយនៃព្រះសហគមន៍ (Latin p. 943) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គតែងតែបង្ហាញគំរូថ្មីៗខាងគុណធម៌ ពីក្នុងព្រះសហគមន៍របស់ព្រះអង្គ ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យយកតម្រាប់តាមសន្តអាលហ្វុងស៊ូ ជាអភិបាល
ដែលលោកព្យាយាមនាំមនុស្សទាំងឡាយឲ្យទទួលរង្វាន់
រួមជាមួយលោកនៅស្ថានបរមសុខ ។

### ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះវិញ្ញាណបានធ្វើឲ្យដួងចិត្តយើងខ្ញុំ ឆេះឆួលដោយភ្លើងមកពីស្ថានបរមសុខ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំចូលរួមក្នុងសក្ការបូជានេះ
ដោយថ្វាយខ្លួនទាំងស្រុងរួមជាមួយព្រះគ្រីស្ត តាមគំរូរបស់សន្តអាលហ្វុងស៊ូ ។

### ពាក្យអរព្រះគុណ

បពិត្រព្រះជាម្ចាស់ ! យើងខ្ញុំសូមអរព្រះគុណព្រះអង្គ
ដែលប្រោសឲ្យសន្តអាលហ្វុងស៊ូ ទៅជាអ្នកបម្រើដ៏ស្មោះត្រង់ ជាស់តឿន
និងពន្យល់គ្រីស្តបរិស័ទ អំពីការអាថ៌កំបាំងដ៏អស្ចារ្យនៃព្រះកាយព្រះគ្រីស្ត ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំឧស្សាហ៍ទទួលព្រះកាយព្រះគ្រីស្ត
និងកោតសរសើរព្រះអង្គឥតឈប់ឈរ ។

## ថ្ងៃទី ២ សីហា

# សន្តអឺសែប នៅវែរសេលី ជាអភិបាលព្រះសហគមន៍

**S. Eusebii Vercellensis, episcopi**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល (Latin p. 929) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាអម្ចាស់ !

ព្រះអង្គប្រោសឲ្យសន្តអឺសែប មានចិត្តនឹងនរអះអាងថា

ព្រះបុត្រាពិតជាព្រះជាម្ចាស់មែន ។

សូមព្រះអង្គប្រោសឲ្យយើងខ្ញុំរក្សាជំនឿ តាមការប្រៀនប្រដៅរបស់សន្តអឺសែប

និងចូលរួមក្នុងព្រះជន្មផ្ទាល់របស់ព្រះបុត្រាព្រះអង្គ ។

# សន្តសិលា ហ្សូលីយ៉ាំង អេម៉ារ ជាបូជាចារ្យ

**S. Petri Iuliani Eymard, presbyteri**

ពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់បព្វជិត (Latin p. 961) ឬពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់គង្វាលមួយរូប (Latin p. 933) ។

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !

ព្រះអង្គប្រទានឲ្យសន្តសិលា ហ្សូលីយ៉ាំង អេម៉ារ

ស្រឡាញ់អស់ពីចិត្តនូវព្រះកាយ និងព្រះលោហិតរបស់ព្រះបុត្រាព្រះអង្គ ។

លោកបានទទួលអំណរសប្បាយក្នុងពិធីជប់លៀងរបស់ព្រះអម្ចាស់យ៉ាងណា

សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានអំណរសប្បាយយ៉ាងនោះដែរ ។

# ថ្ងៃទី ៤ សីហា
# សន្តយ៉ូហាន ម៉ារី វិយ៉ាណេ ជាបូជាចារ្យ

**S. Ioannis Mariæ Vianney, presbyteri**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់គង្វាលមួយរូប (Latin p. 933) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ និងព្រះហឫទ័យសប្បុរស !
ព្រះអង្គប្រោសឲ្យសន្តយ៉ូហាន ម៉ារីវិយ៉ាណេ ជាបូជាចារ្យ
ខ្នះខ្នែងក្នុងការបម្រើព្រះសហគមន៍ ។
តាមគំរូ និងពាក្យទូលអង្វររបស់លោក សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
បេះប្រមូលបងប្អូនជាច្រើនថ្វាយព្រះគ្រីស្ត ដោយបង្ហាញធម៌មេត្តាករុណា
ហើយសូមឲ្យយើងខ្ញុំទទួលសិរីរុងរឿងអស់កល្បជានិច្ចរួមជាមួយពួកគេផង ។

# ថ្ងៃទី ៥ សីហា
# បុណ្យរំឭកថ្ងៃឆ្លងព្រះវិហារបាស៊ីលីកា សន្តីម៉ារី

**In Dedicatione basilicæ S. Mariæ**

ពាក្យអធិដ្ឋានរួមសម្រាប់ព្រះនាងព្រហ្មចារិនីម៉ារីពោរពេញដោយសុភមង្គល (Latin p. 897) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់អើយ !
សូមព្រះអង្គលើកលែងទោសឲ្យយើងខ្ញុំជាអ្នកបម្រើព្រះអង្គ
ដែលបានធ្វើខុសនឹងព្រះហឫទ័យព្រះអង្គតាមរយៈកិច្ចការរបស់ខ្លួន ។
តាមរយៈពាក្យទូលអង្វររបស់ព្រះមាតានៃព្រះបុត្រាព្រះអង្គ និងជាមាតានៃព្រះអម្ចាស់យើងខ្ញុំ សូមព្រះអង្គសង្គ្រោះយើងខ្ញុំផង ។

# ថ្ងៃទី ៦ សីហា

# ព្រះអម្ចាស់សម្ដែងរូបកាយដ៏អស្ចារ្យ

**IN TRANSFIGURATIONE DOMINI**

(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គចាត់ព្រះបុត្រាតែមួយឲ្យយាងមក
សម្ដែងរូបកាយដ៏អស្ចារ្យពោរពេញដោយសិរីរុងរឿង
និងបានអះអាងពីគម្រោងការដ៏អស្ចារ្យនៃជំនឿ
ហើយបញ្ជាក់ជាមុនថា យើងខ្ញុំជាបុត្រធីតារបស់ព្រះអង្គ
តាមរយៈសក្ខីភាពរបស់គ្រូបាធ្យាយនៃព្រះសហគមន៍ ។
សូមព្រះអង្គប្រោសយើងខ្ញុំដែលជាអ្នកបម្រើរបស់ព្រះអង្គ
ឲ្យយកចិត្តទុកដាក់ស្ដាប់ព្រះសូរសៀងនៃព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ
និងទទួលជីវិតអស់កល្បជានិច្ចជាមរតករួមជាមួយព្រះអង្គ ។

នៅពេលប្រារព្ធបុណ្យនេះ ចំនៅថ្ងៃអាទិត្យ គួរសូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
សូមព្រះអង្គញ៉ាំងតង្វាយនេះឲ្យបានវិសុទ្ធ
ក្នុងឱកាសលើកតម្កើងព្រះបុត្រាតែមួយរបស់ព្រះអង្គ សម្ដែងរូបកាយដ៏អស្ចារ្យ
ពោរពេញដោយសិរីរុងរឿង ។
សូមឲ្យរស្មីពណ្ណរាយនៃព្រះបុត្រា
ជម្រះគ្រប់ភាពសៅហ្មងនៃអំពើបាបរបស់យើងខ្ញុំផង ។

ធម៌ប្រារព្ធ៖ ព្រះអម្ចាស់សម្ដែងរូបកាយដ៏អស្ចារ្យពោរពេញដោយសិរីរុងរឿង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ជាព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។
ព្រះបុត្រាបង្ហាញឲ្យសាក្សីដែលព្រះអង្គជ្រើសរើស
ឃើញសិរីរុងរឿងក្នុងរូបកាយរបស់ព្រះអង្គ
គឺជារូបកាយដែលព្រះអង្គប្រទានឲ្យមនុស្សលោក ។
ព្រះអង្គបានលុបបំបាត់ភាពអាម៉ាស់នៃឈើឆ្កាងពីក្នុងចិត្តសាវ័ក
ដោយបង្ហាញថា រូបកាយរបស់ព្រះអង្គជាព្រះសិរសានៃព្រះសហគមន៍
បានពោរពេញដោយសិរីរុងរឿងយ៉ាងណា
រូបកាយរបស់អ្នកជឿនឹងពោរពេញដោយសិរីរុងរឿងយ៉ាងនោះដែរ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំដែលរស់នៅលើផែនដីនេះ
សូមចូលរួមជាមួយអំណាចនៃស្ថានបរមសុខ
លើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយប្រកាសឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ លើពិភពលោកទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យព្រះបុត្រាព្រះអង្គ
សម្ដែងរូបកាយដ៏អស្ចារ្យពោរពេញដោយសិរីរុងរឿង ។
សូមឲ្យអាហារនៃស្ថានបរមសុខដែលព្រះអង្គប្រទានមកយើងខ្ញុំ
ផ្លាស់ប្រែយើងខ្ញុំឲ្យមានលក្ខណៈដូចព្រះបុត្រាព្រះអង្គ ។

## ថ្ងៃទី ៧ សីហា

# សន្តស៊ីស្ត ទី២ ជាសម្ដេចប៉ាប និងសហការី ជាមរណសាក្សី

**Ss. Xysti II, papæ, et sociorum, martyrum**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីជាច្រើន (Latin p. 909) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គប្រោសឲ្យសន្តស៊ីស្ត និងសហការីបានបូជាជីវិត
ដើម្បីជាប្រយោជន៍ដល់ព្រះបន្ទូលព្រះអង្គ និងធ្វើជាសាក្សីថ្វាយព្រះគ្រីស្ត ។
ដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានជំនឿដោយចិត្តសុភាពរាបសា និងបានប្រកាស
ជំនឿដោយចិត្តក្លាហាន ។

# សន្តកាយេតាំង ជាបូជាចារ្យ

**S. Caietani, presbyteri**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់គង្វាលមួយរូប (Latin p. 933) ឬពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់បព្វជិត (Latin p. 961) ។

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ ! ព្រះអង្គបំភ្លឺចិត្តគំនិតសន្តកាយេតាំង ជាបូជាចារ្យ
ឲ្យរស់នៅតាមរបៀបគ្រីស្តទូតពីដើម ។
តាមគំរូ និងពាក្យទូលអង្វររបស់លោក
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ ផ្ញើជីវិតទាំងស្រុងលើព្រះអង្គគ្រប់ពេលវេលា
និងយកចិត្តទុកដាក់ស្វែងរកព្រះរាជ្យព្រះអង្គ ដោយមិនឿយណាយឡើយ ។

## ថ្ងៃទី ៨ សីហា

# សន្តដូមីនិក ជាបូជាចារ្យ

**S. Dominici, presbyteri**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ !
ព្រះអង្គបាត់ឲ្យសន្តដូមីនិក មកជួយព្រះសហគមន៍តាមរយៈការប្រៀនប្រដៅ
និងការប្រព្រឹត្តអំពើល្អរបស់លោក ។
សូមព្រះអង្គប្រោសឲ្យលោកដែលជាវាគ្មិនប្រកាសសេចក្តីពិត
ទៅជាអ្នកជួយអង្វរព្រះអង្គដោយឥតឈប់ឈរសម្រាប់យើងខ្ញុំ ។

ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ ! តាមរយៈពាក្យទូលអង្វររបស់សន្តដូមីនិក
ព្រះអង្គតែងតែសណ្តាប់ពាក្យអធិដ្ឋានរបស់យើងខ្ញុំ ។
តាមរយៈអានុភាពនៃសក្ការបូជានេះ សូមព្រះអង្គប្រោសប្រណីផ្តល់កម្លាំង
និងការពារអស់អ្នកដែលតស៊ូដើម្បីជំនឿ ។

### ពាក្យអរព្រះគុណ

បពិត្រព្រះជាម្ចាស់ជាព្រះបិតា !
នៅថ្ងៃគោរពសន្តជូមីនិក យើងខ្ញុំសូមអរព្រះគុណព្រះអង្គអស់ពីដួងចិត្ត
ដ្បិតព្រះអង្គប្រទានព្រះកាយព្រះគ្រីស្តមកចិញ្ចឹមយើងខ្ញុំ ។
ព្រះអង្គចាត់សន្តជូមីនិក មកជួយព្រះសហគមន៍ឲ្យមានដំណើរការល្អ
តាមរយៈការប្រៀនប្រដៅរបស់លោក ។
សូមឲ្យព្រះសហគមន៍បន្តរីកចម្រើន តាមពាក្យទូលអង្វររបស់លោក ។

## ថ្ងៃទី ៩ សីហា

# សន្តីតេរេសា បេណេឌិក នៃព្រះឈើឆ្កាង ជាព្រហ្មចារិនី និងជាមរណសាក្សី

**S. Teresiæ Benedictæ a Cruce, virginis et martyris**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់ព្រហ្មចារិនីជាមរសាក្សី (Latin p. 924) ឬពាក្យអធិដ្ឋានរួមសម្រាប់ព្រហ្មចារិនី ៖ សម្រាប់ព្រហ្មចារិនីមួយរូប (Latin p. 947) ។

### ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ជាព្រះបិតាយើងខ្ញុំ !
ព្រះអង្គបំភ្លឺសន្តីតេរេសបេណេឌិក នៃព្រះឈើឆ្កាង ជាមរណសាក្សី
ឲ្យស្គាល់ព្រះបុត្រាព្រះអង្គដែលរងទុក្ខលំបាកនៅលើឈើឆ្កាង
និងឲ្យគ្រាប់តាមទ្រង់រហូតបូជាជីវិត ។
តាមរយៈពាក្យទូលអង្វររបស់នាង
សូមព្រះអង្គប្រោសឲ្យមនុស្សជាតិទាំងអស់ ទទួលស្គាល់ព្រះគ្រីស្តជាព្រះសង្គ្រោះ
និងឆ្ពោះទៅកាន់ព្រះបិតាអស់កល្បជានិច្ចតាមរយៈព្រះបុត្រា ។

# ថ្ងៃទី ១០ សីហា

# សន្តឡូរង់ ជាឧបដ្ឋាក និងជាមរណសាក្សី

**S. LAURENTII, DIACONI ET MARTYRIS**

(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យសន្តឡូរង់ស្រឡាញ់ព្រះអង្គយ៉ាងខ្លាំង
និងបម្រើព្រះសហគមន៍ដោយចិត្តស្មោះត្រង់
ព្រមទាំងទទួលសិរីរុងរឿងក្នុងនាមជាមរណសាក្សី ។
សូមប្រោសឲ្យយើងខ្ញុំចេះស្រឡាញ់អ្វីៗដែលលោកបានស្រឡាញ់
និងប្រព្រឹត្តតាមការប្រៀនប្រដៅរបស់លោក ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
នៅថ្ងៃដែលយើងខ្ញុំគោរពសន្តឡូរង់
សូមព្រះអង្គមេត្តាទទួលតង្វាយរបស់យើងខ្ញុំដោយអនុគ្រោះ ។
សូមប្រោសឲ្យព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ត
នាំការសង្គ្រោះដល់យើងខ្ញុំ ។

ធម៌ប្រារព្ធ បុណ្យគោរពមរណសាក្សី ទំព័រ ៤៨៤-៤៨៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ ! យើងខ្ញុំសូមអរព្រះគុណព្រះអង្គ
ដែលបានប្រទានព្រះអំណោយទានដ៏សក្ការៈ មកចិញ្ចឹមជីវិតយើងខ្ញុំ ។
នៅថ្ងៃគោរពសន្តឡូរង់នេះ យើងខ្ញុំសូមអង្វរព្រះអង្គ
សូមប្រោសឲ្យការគោរពដឹងគុណដែលជាកាតព្វកិច្ចបម្រើរបស់យើងខ្ញុំ
នាំឲ្យយើងខ្ញុំសក្តិសមនឹងទទួលការសង្គ្រោះពីព្រះអង្គ ។

# ថ្ងៃទី ១១ សីហា
# សន្តីក្លារ៉ា ជាព្រហ្មចារិនី
**S. Claræ, virginis**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់ព្រហ្មចារិនី ៖ សម្រាប់ព្រហ្មចារិនីមួយរូប (Latin p. 946) ឬពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់បព្វជិតា (Latin p. 960) ។

## ពាក្យអធិដ្ឋានសរុប
ឱ ព្រះជាម្ចាស់អើយ !

ព្រះអង្គណែនាំសន្តីក្លារ៉ា ឲ្យមានចិត្តស្រឡាញ់ភាពក្រីក្រយ៉ាងខ្លាំង ។

សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំដើរតាមព្រះគ្រីស្ត ដោយដាក់ចិត្តជាជនក្រីក្រដូចសន្តីក្លារ៉ា ។

តាមរយៈពាក្យទូលអង្វររបស់នាង សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ

សម្លឹងមើលសិរីរុងរឿងរបស់ព្រះអង្គ នៅស្ថានបរមសុខរួមជាមួយនាងផង ។

# ថ្ងៃទី ១២ សីហា
# សន្តីយ៉ូហាណា ហ្វ្រង់ស័រ ដឺហ្សង់តាល ជាបព្វជិតា
**S. Ioannæ Franciscæ de Chantal, religiosæ**

ពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់បព្វជិតា (Latin p. 961) ។

## ពាក្យអធិដ្ឋានសរុប
ឱ ព្រះជាម្ចាស់អើយ !

ព្រះអង្គប្រោសឲ្យសន្តីយ៉ូហាណា ហ្វ្រង់ស័រ ដឺហ្សង់តាល

បានពោរពេញដោយព្រះអំណោយទានដ៏ប្រសើរ ក្នុងដំណាក់កាលផ្សេងៗនៃជីវិត ។

តាមរយៈពាក្យទូលអង្វររបស់នាង សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ

មានចិត្តស្មោះត្រង់នឹងការត្រាស់ហៅ ហើយធ្វើជាពន្លឺបំភ្លឺដល់អ្នកដទៃ ។

## ថ្ងៃទី ១៣ សីហា

# សន្តប៉ុងស្យាង ជាសម្តេចប៉ាប
# សន្តហ៊ីប៉ូលីត ជាបូជាចារ្យ និងជាមរណសាក្សី

**Ss. Pontani, papæ, et Hippolyti, presbyteri, martyrum**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីជាច្រើន (Latin p. 909) ឬពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់គង្វាលជាច្រើន (Latin p. 927) ។

### ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រោសប្រទានឲ្យសន្តប៉ុងស្យាង និងហ៊ីប៉ូលីត
រងទុក្ខលំបាកយ៉ាងយូរមុនទៅជាមរណសាក្សី ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំមានចិត្តជឿយ៉ាងមាំមួន និងស្រឡាញ់ព្រះអង្គយ៉ាងខ្លាំង ។

# ថ្ងៃទី ១៤ សីហា
# សន្តម៉ាកស៊ីមីលីយាង កូលបេ
# ជាបូជាចារ្យ និងជាមរណសាក្សី

**S. Maximili Mariæ Kolbe, presbyteri et martyris**

(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យសន្តម៉ាកស៊ីមីលីយាង កុលបេ
មានចិត្តឆេះឆួលស្រឡាញ់ព្រះនាងព្រហ្មចារិនីម៉ារី
និងស្ម័គ្រចិត្តស៊ូប្តូរជីវិតសម្រាប់អ្នកដទៃ ។
តាមរយៈពាក្យទូលអង្វររបស់លោក
សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតយើងខ្ញុំ ឲ្យយកចិត្តទុកដាក់បម្រើព្រះអង្គ
និងមនុស្សឯទៀតៗ ដូចព្រះបុត្រាដែលសព្វព្រះហឫទ័យបូជាព្រះជន្ម ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
យើងខ្ញុំសូមថ្វាយតង្វាយទៅព្រះអង្គ សូមទ្រង់មេត្តាបំភ្លឺចិត្តគំនិតយើងខ្ញុំ
ឲ្យសុខចិត្តបូជាជីវិតថ្វាយព្រះអង្គ តាមគំរូរបស់សន្តម៉ាកស៊ីមីលីយាង ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !
ពេលព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំ
សូមប្រោសឲ្យយើងខ្ញុំមានចិត្តឆេះឆួលស្រឡាញ់អ្នកដទៃ
ដូចសន្តម៉ាកស៊ីមីលីយាង ។

# ថ្ងៃទី ១៥ សីហា
# បុណ្យព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ
**IN ASSUMPTIONE BEATÆ MARIÆ VIRGINIS**
(បុណ្យឱឡារិក)

## អភិបូជានៅពេលល្ងាច
Ad Missam in Vigilia

អភិបូជានេះ ប្រារព្ធនៅពេលល្ងាចថ្ងៃទី១៤ សីហា ។

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

### ពាក្យអធិដ្ឋានសរុប
ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យទតមើលភាពទន់ទាបរបស់ព្រះនាងព្រហ្មចារិនីម៉ារី
និងប្រណីសន្ដោសលើកព្រះនាងឡើង ។
ព្រះអង្គប្រោសព្រះនាងឲ្យប្រសូតព្រះបុត្រាតែមួយរបស់ព្រះអង្គទៅជាមនុស្ស
បានជានៅថ្ងៃនេះ ព្រះនាងទទួលភួងជ័យ
ពោរពេញដោយសិរីរុងរឿងដ៏លើសលប់ ។
តាមរយៈពាក្យទូលអង្វររបស់ព្រះនាង សូមព្រះអង្គមេត្ដាសង្គ្រោះយើងខ្ញុំ
និងលើកយើងខ្ញុំឡើងទៅឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

សូត្រធម៌ប្រកាសជំនឿ ។

### ពាក្យថ្វាយតង្វាយ
ឱ ព្រះជាអម្ចាស់អើយ !
សូមព្រះអង្គទទួលតង្វាយដែលសម្រុះសម្រួលយើងខ្ញុំជាមួយព្រះអង្គ ។ នៅថ្ងៃយើងខ្ញុំប្រារព្ធបុណ្យព្រះនាងម៉ារីឡើងស្ថានបរមសុខ
សូមព្រះអង្គមេត្ដាលើកលែងទោសឲ្យយើងខ្ញុំ
និងប្រោសយើងខ្ញុំឲ្យអរព្រះគុណព្រះអង្គដោយឥតឈប់ឈរ ។

ពាក្យអរព្រះគុណ
បពិត្រព្រះបិតាជាអម្ចាស់យើងខ្ញុំ !
ព្រះអង្គប្រទានឲ្យយើងខ្ញុំបានចូលរួមក្នុងពិធីជប់លៀងនៃស្ថានបរមសុខ ។
នៅថ្ងៃដែលយើងខ្ញុំគោរពព្រះមាតាព្រះជាម្ចាស់យាងឡើងស្ថានបរមសុខ
សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំឲ្យរួចពីអន្តរាយគ្រប់បែបយ៉ាង ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក

# អភិបូជានៅពេលថ្ងៃ

Ad Missam in die

ពាក្យអធិដ្ឋានសរុប
បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គសព្វព្រះហឫទ័យលើកព្រះនាងព្រហ្មចារិនីម៉ារីដ៏និមល
ជាព្រះមាតានៃព្រះបុត្រាព្រះអង្គឡើងស្ថានបរមសុខ ទាំងរូបកាយ ទាំងវិញ្ញាណ
គឺព្រះអង្គប្រោសឲ្យព្រះនាងមានកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ យកចិត្តទុកដាក់នឹងសម្បត្តិសួគ៌
សូមឲ្យយើងខ្ញុំអាចទទួលសិរីរុងរឿងរួមជាមួយព្រះនាងផង ។

ពាក្យថ្វាយតង្វាយ
ឱ ព្រះជាអម្ចាស់អើយ !
សូមព្រះអង្គទទួលតង្វាយរបស់យើងខ្ញុំទុកជាកិច្ចអរព្រះគុណព្រះអង្គ ។
តាមរយៈពាក្យទូលអង្វររបស់ព្រះនាងព្រហ្មចារិនីម៉ារី
ដែលព្រះអង្គលើកឡើងទៅឯស្ថានបរមសុខ
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានចិត្តឆេះឆួលដោយសេចក្ដីស្រឡាញ់
និងទន្ទឹងរង់ចាំព្រះអង្គឥតឈប់ឈរ ។

ធម៌ប្រារព្ធ ៖ ព្រះនាងម៉ារីយាងឡើងស្ថានបរមសុខពោរពេញដោយសិរីរុងរឿង ។

ប.  សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ.  ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប.  សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ.  យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប.  សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ.  ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ជាព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។
ថ្ងៃនេះ ព្រះអង្គបានលើកព្រះនាងព្រហ្មចារិនី
ជាមាតាព្រះជាម្ចាស់ឡើងស្ថានបរមសុខ ។
ព្រឹត្តិការណ៍នេះ ជាការចាប់ផ្តើម និងជារូបភាពព្រះសហគមន៍
ដែលកំពុងដើរឆ្ពោះទៅកាន់ភាពពេញលក្ខណៈ ។
ព្រឹត្តិការណ៍នេះ ជាប្រភពនៃសេចក្តីសង្ឃឹមដ៏ពិតប្រាកដ
ហើយជាទីពឹងសម្រាប់ប្រជាជនដែលកំពុងតែដើរឆ្ពោះទៅរកព្រះអង្គ ។
ព្រះអង្គមិនសព្វព្រះហឫទ័យឲ្យរូបកាយរបស់ព្រះនាងរលួយក្នុងផ្នូរឡើយ
ដ្បិតរូបកាយរបស់ព្រះនាងនេះហើយ ដែលបានបង្កើតរូបកាយជាមនុស្ស
ដល់ព្រះបុត្រាព្រះអង្គដែលជាប្រភពនៃជីវិតគ្រប់យ៉ាង ។

អាស្រ័យហេតុនេះហើយ បានយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ សូមកោតសរសើរព្រះអង្គ
ដោយប្រកាសទាំងអំណរសប្បាយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !

ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គបានប្រទានព្រះកាយព្រះគ្រីស្តឲ្យយើងខ្ញុំ ។
តាមរយៈពាក្យទូលអង្វររបស់ព្រះនាងព្រហ្មចារិនីម៉ារី
ដែលព្រះអង្គបានលើកឡើងស្ថានបរមសុខ
សូមព្រះអង្គមេត្តាប្រទានឲ្យយើងខ្ញុំបានទទួលសិរីរុងរឿងឯស្ថានបរមសុខផង ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក

## ថ្ងៃទី ១៦ សីហា

# សន្តស្ទេផាន នៅប្រទេសហុងគ្រី

**S. Stephani Hungariæ**

ពាក្យអធិដ្ឋានរួមសម្រាប់សន្ត: សន្តី ៖ សម្រាប់សន្ត:មួយរូប (Latin p. 956) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គប្រោសឲ្យសន្តស្ទេផាន ដែលជាមហាក្សត្រនៅប្រទេសហុងគ្រី
ជួយព្រះសហគមន៍ឲ្យរីកចម្រើនឡើងនៅលើផែនដី ។
សូមព្រះអង្គមេត្តាសណ្ដាប់ពាក្យអង្វររបស់សន្តស្ទេផាន
ដើម្បីជាប្រយោជន៍ដល់យើងខ្ញុំបានចូលរួមក្នុងស្ថានបរមសុខផង ។

# ថ្ងៃទី ១៩ សីហា

# សន្តយ៉ូហានអឺដ ជាបូជាចារ្យ

**S. Ioannis Eudes, presbyteri**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់គង្វាលមួយរូប (Latin p. 933) ឬពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តីៈ សម្រាប់បព្វជិត (Latin p. 961) ។

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គបានជ្រើសរើសសន្តយ៉ូហាន អឺដ ជាបូជាចារ្យ ឲ្យទៅប្រកាស
ពីព្រះហឫទ័យមេត្តាករុណាដ៏លើសលប់របស់ព្រះគ្រីស្ត ចំពោះមនុស្សលោក ។
តាមគំរូ និងការប្រៀនប្រដៅរបស់លោក សូមព្រះអង្គប្រោសឲ្យយើងខ្ញុំស្គាល់
និងស្រឡាញ់ព្រះអង្គកាន់តែខ្លាំងឡើងៗ ព្រមទាំងរស់នៅតាមពន្លឺនៃដំណឹងល្អផង ។

# ថ្ងៃទី ២០ សីហា

# សន្តប៊ែរណា ជាចៅអធិការ និងគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Bernardi, abbatis et Ecclesiæ doctoris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យសន្តប៊ែរណា
មានចិត្តឆេះឆួលស្រឡាញ់ព្រះដំណាក់ព្រះអង្គ និងធ្វើជាពន្លឺបំភ្លឺព្រះសហគមន៍ ។
តាមរយៈពាក្យទូលអង្វររបស់លោក
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ មានចិត្តស្រឡាញ់ព្រះអង្គយ៉ាងខ្លាំង
និងប្រព្រឹត្តអ្វីៗទាំងអស់ក្នុងឋានៈជាបុត្រធីតាពោរពេញដោយពន្លឺ ។

ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
ថ្ងៃនេះ យើងខ្ញុំនឹករឭកដល់សន្តប៉ែរណា
ជាជនមានទេពកោសល្យ ទាំងពាក្យសម្ដី ទាំងកិច្ចការ
ហើយលោកខិតខំធ្វើឲ្យព្រះសហគមន៍បានស្រុះស្រួលគ្នា ។
សូមព្រះអង្គមេត្តាទទួលតង្វាយពីយើងខ្ញុំ និងប្រោសឲ្យព្រះសហគមន៍
បានប្រកបដោយសេចក្ដីសុខសាន្ត និងរួមគ្នាជាធ្លុងតែមួយ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
នៅថ្ងៃគោរពសន្តប៉ែរណា សូមព្រះអង្គប្រោសឲ្យព្រះកាយព្រះគ្រីស្ត
ដែលយើងខ្ញុំទើបនឹងទទួលបានទៅជាប្រយោជន៍សម្រាប់យើងខ្ញុំ ។
តាមគំរូរបស់លោកដែលផ្ដល់កម្លាំងដល់យើងខ្ញុំ
និងតាមការប្រៀនប្រដៅរបស់លោក ដែលនាំឲ្យយើងខ្ញុំមានការចេះដឹង
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យមានចិត្តស្រឡាញ់ព្រះបន្ទូល
ដែលបានចាប់កំណើតជាមនុស្ស ។

# ថ្ងៃទី ២១ សីហា
# សន្តពីយូស ទី១០ ជាសម្តេចប៉ាប
**S. Pii X, papæ**
(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់សម្តេចប៉ាប (Latin p. 927) ។

## ពាក្យអធិដ្ឋានសរុប
ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យប្រោសឲ្យសន្តពីយូស ទី១០
ពោរពេញដោយព្រះប្រាជ្ញាញាណ និងមានចិត្តក្លាហាន
ដើម្បីការពារ និងស្តារឡើងវិញនូវជំនឿរបស់ព្រះសហគមន៍កាតូលិក ។
តាមគំរូ និងការប្រៀនប្រដៅរបស់លោក
សូមព្រះអង្គប្រទានជីវិតអស់កល្បជានិច្ចដល់យើងខ្ញុំទុកជារង្វាន់ ។

## ពាក្យថ្វាយតង្វាយ
ឱ ព្រះជាអម្ចាស់អើយ !
សូមព្រះអង្គមេត្តាទទួលតង្វាយរបស់យើងខ្ញុំ ដោយអនុគ្រោះ ។
តាមការប្រៀនប្រដៅរបស់សន្តពីយូស ជាសម្តេចប៉ាប
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំចូលរួមដោយស្មោះអស់ពីចិត្តក្នុងអភិបូជានេះ ព្រម
ទាំងទទួលព្រះកាយព្រះគ្រីស្តដោយមានជំនឿមាំមួនផង ។

## ពាក្យអរព្រះគុណ
ឱ ព្រះអម្ចាស់ជាព្រះបិតាយើងខ្ញុំ !
ក្នុងថ្ងៃគោរពសន្តពីយូស ជាសម្តេចប៉ាប យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ។
ដោយអានុភាពនៃព្រះកាយដែលយើងខ្ញុំទទួលពីតុសក្ការបូជានេះ
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានជំនឿមាំមួន
និងរួបរួមគ្នាក្នុងសេចក្តីស្រឡាញ់តែមួយ ។

# ថ្ងៃទី ២២ សីហា
# ព្រះនាងម៉ារី ជាព្រះមហាក្សត្រីយានី

**Beatæ Mariæ Virginis Reginæ**

(បុណ្យរំឭក)

### ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាម្ចាស់ !
ព្រះអង្គសព្វព្រះហឫទ័យប្រោសឲ្យព្រះមាតានៃព្រះបុត្រា
ទៅជាមាតា និងមហាក្សត្រីយ៍របស់យើងខ្ញុំដែរ ។
តាមរយៈពាក្យទូលអង្វររបស់ព្រះនាង
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំទទួលសិរីរុងរឿងឯស្ថានបរមសុខ
ដែលទ្រង់បានសន្យាប្រទានដល់បុត្រធីតារបស់ព្រះអង្គ ។

### ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
យើងខ្ញុំសូមលើកតង្វាយថ្វាយទៅព្រះអង្គ នៅថ្ងៃដែលយើងខ្ញុំនឹករឭកដល់ព្រះនាងព្រហ្មចារិនីម៉ារី ។
សូមព្រះអង្គមេត្តាសង្គ្រោះយើងខ្ញុំ តាមរយៈព្រះគ្រីស្តដែលកើតជាមនុស្ស
និងបូជាព្រះជន្មនៅលើឈើឆ្កាងទុកជាតង្វាយដ៏ឥតសៅហ្មង ។

ធម៌ប្រារព្ធទី ១ បុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារី ទំព័រ ៤៧២-៤៧៤ ។

### ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !
នៅថ្ងៃដែលយើងខ្ញុំនឹករឭកព្រះនាងព្រហ្មចារិនីម៉ារី
ព្រះអង្គបានប្រទានព្រះកាយព្រះគ្រីស្តជាអាហារពីស្ថានបរមសុខឲ្យយើងខ្ញុំ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំសមនឹងចូលរួម
ក្នុងពិធីជប់លៀងអស់កល្បជានិច្ចរបស់ព្រះអង្គ ។

# ថ្ងៃទី ២៣ សីហា

# សន្តីរ៉ូស នៅក្រុងលីម៉ា ជាព្រហ្មចារិនី

**S. Rosæ de Lima, virginis**

ពាក្យអធិដ្ឋានរួមសម្រាប់ព្រហ្មចារិនី ៖ សម្រាប់ព្រហ្មចារិនីមួយរូប (Latin p. 947) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យសន្តីរ៉ូស នៅក្រុងលីម៉ា មានចិត្តឆេះឆួលស្រឡាញ់ព្រះអង្គ
ដោយថ្វាយខ្លួនទៅព្រះអង្គតែមួយគត់
លះបង់ប្រយោជន៍ខ្លួនឯង និងផ្ដន្ទាខ្លួន ដោយបំពេញទុក្ករកិរិយា ។
តាមរយៈពាក្យទូលអង្វររបស់នាង
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំដើរតាមមាគ៌ាឆ្ពោះទៅកាន់ជីវិត និងទទួលអំណរ
សប្បាយនៅឯស្ថានបរមសុខផង ។

# ថ្ងៃទី ២៤ សីហា

# សន្តបារថូឡូមេ ជាគ្រីស្តទូត

**S. BARTHOLOMÆI, APOSTOLI**

(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់អើយ !
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានជំនឿរឹងមាំ ដូចគ្រីស្តទូត បារថូឡូមេ
ដែលជាប់ចិត្តយ៉ាងខ្លាំងនឹងព្រះបុត្រាព្រះអង្គ ។
តាមរយៈពាក្យទូលអង្វររបស់លោក សូមព្រះអង្គមេត្តាប្រោសឲ្យព្រះសហគមន៍
ទៅជាអគ្គសញ្ញានៃការសង្គ្រោះសម្រាប់មនុស្សគ្រប់ជាតិសាសន៍ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ !
យើងខ្ញុំសូមថ្វាយសក្ការបូជានេះ ដើម្បីលើកតម្កើងព្រះអង្គ
នៅថ្ងៃបុណ្យគោរពសន្តបារថូឡូមេ ជាគ្រីស្តទូត ។
តាមរយៈពាក្យអង្វររបស់លោក សូមព្រះអង្គមេត្តាសង្គ្រោះយើងខ្ញុំផង ។

ធម៌ប្រារព្ធ បុណ្យគោរពគ្រីស្តទូត ទំព័រ ៤៧៦-៤៧៨ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !
នៅថ្ងៃបុណ្យគោរពសន្តបារថូឡូមេ ជាគ្រីស្តទូត
យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ដែលបានប្រទានព្រះកាយព្រះគ្រីស្ត
មកសង្គ្រោះយើងខ្ញុំអស់កល្បជានិច្ច ។
សូមឲ្យព្រះកាយព្រះគ្រីស្តជួយយើងខ្ញុំទាំងនៅក្នុងពេលឥឡូវនេះ និងនៅពេលខាងមុខផង ។

# សន្តលូអ៊ីស ជាមហាក្សត្រប្រទេសបារាំង

**S. Ludovici**

ពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់សន្តៈមួយរូប (Latin p. 956) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ជាព្រះបិតា !
ព្រះអង្គត្រាស់ហៅសន្តលូអ៊ីស ដែលជាស្ដេចនៅលើផែនដីឲ្យទទួលសិរីរុងរឿង
ក្នុងព្រះរាជ្យនៃស្ថានបរមសុខ ។
តាមរយៈពាក្យទូលអង្វររបស់សន្តលូអ៊ីស
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងលោកនេះ និងស្វះស្វែង
រកព្រះរាជ្យអស់កល្បជានិច្ចរបស់ព្រះអង្គ ។

# សន្តយ៉ូសែប ជាបូជាចារ្យ នៅកាឡាសង់

**S. Iosephi de Calasanz, presbyteri**

ពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់អ្នកអប់រំ (Latin p. 965) ឬពាក្យអធិដ្ឋានរួម
សម្រាប់គង្វាល ៖ សម្រាប់គង្វាលមួយរូប (Latin p. 933) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យសន្តយ៉ូសែប ជាបូជាចារ្យ នៅកាឡាសង់
មានចិត្តមេត្តាករុណា និងធ្វើការដោយមិនហត់នឿយ
ក្នុងការអប់រំក្មេងៗ និងជួយគេឲ្យរស់នៅប្រកបដោយគុណធម៌ ។
សូមព្រះអង្គប្រោសយើងខ្ញុំដែលគោរពលោក
ទុកជាគ្រូប្រកបដោយប្រាជ្ញាឈ្លាសវៃ ឲ្យប្រព្រឹត្តតាមគំរូរបស់លោក
ដែលជាសហការីមួយរូបបម្រើសេចក្ដីពិតរបស់ព្រះអង្គ ។

# ថ្ងៃទី ២៧ សីហា
# សន្ដីម៉ូនិក
**S. Monicæ**

ពាក្យអធិដ្ឋានរួមសម្រាប់សន្ត: សន្ដី ៖ សម្រាប់សន្ដី (Latin p. 966) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ !

ព្រះអង្គតែងតែលួងលោមចិត្តអស់អ្នកដែលយំសោកសង្រេង ។

ព្រះអង្គសព្វព្រះហឫទ័យទទួលដំណក់ទឹកភ្នែក និងពាក្យអង្វររបស់សន្ដីម៉ូនិក

ដែលទូលអង្វរព្រះជាម្ចាស់សូមឲ្យអូគូស្ដាំងជាកូនប្រែចិត្តគំនិត ។

តាមរយៈពាក្យទូលអង្វររបស់អ្នកទាំងពីរ

សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ ដែលមានចិត្តសោកស្ដាយយ៉ាងខ្លាំង

ចំពោះអំពើបាបរបស់ខ្លួន បានទទួលការលើកលែងទោស

តាមព្រះហឫទ័យប្រណីសន្ដោសពីព្រះអង្គ ។

# ថ្ងៃទី ២៨ សីហា

# សន្តអូគូស្តាំង ជាអភិបាល និងគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Augustini, episcopi et Ecclesiæ doctoris**

(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់អើយ !
សូមព្រះអង្គប្រទានកម្លាំងថ្មីដល់ព្រះសហគមន៍
ដូចព្រះអង្គប្រទានកម្លាំងឲ្យសន្តអូគូស្តាំង ជាអភិបាលដែរ ។
សូមទ្រង់ប្រោសឲ្យយើងខ្ញុំស្រេកឃ្លានព្រះអង្គ
ដែលជាប្រភពតែមួយនៃប្រាជ្ញាដ៏ពិតប្រាកដ និងស្វែងរកព្រះអង្គ
ដែលជាម្ចាស់នៃសេចក្តីស្រឡាញ់មកពីស្ថានបរមសុខ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
យើងខ្ញុំសូមថ្វាយសក្ការបូជាដែលរំឭកពីការសង្គ្រោះរបស់ព្រះអង្គចំពោះយើងខ្ញុំ ។
យើងខ្ញុំទូលអង្វរព្រះអង្គ សូមឲ្យអគ្គសញ្ញានៃព្រះហឫទ័យ
ពោរពេញដោយសេចក្តីស្រឡាញ់ និងសប្បុរសធម៌របស់ព្រះអង្គ
ទៅជាទីសម្គាល់នៃការរួបរួមគ្នាជាធ្លុងតែមួយ និងជាសម្ពន្ធមេត្រីនៃធម៌មេត្តាករុណា ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យញែកយើងខ្ញុំឲ្យទៅជាជនដ៏វិសុទ្ធ ដោយសារយើងខ្ញុំបាន
ចូលរួមតុជប់លៀងជាមួយព្រះគ្រីស្ត
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំដែលបានទទួលព្រះកាយព្រះគ្រីស្ត
ទៅជាសរីរាង្គនៃព្រះកាយព្រះអង្គផង ។

# ថ្ងៃទី ២៩ សីហា
# ទុក្ខលំបាករបស់សន្តយ៉ូហានបាទីស្ត

**In Passione S. Ioannis Baptistæ**

(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យចាត់សន្តយ៉ូហាន បាទីស្ត
មកផែនដីនេះមុនព្រះបុត្រាព្រះអង្គ ទាំងនៅពេលលោកកើត
ទាំងនៅពេលលោកទទួលមរណភាព ។
សន្តយ៉ូហានបានបូជាជីវិតជាមរណសាក្សីដើម្បីសេចក្ដីពិត និងយុត្តិធម៌យ៉ាងណា
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានចិត្តពុះពារប្រកាសជំនឿ
តាមសេចក្ដីប្រៀនប្រដៅរបស់ព្រះអង្គយ៉ាងនោះដែរ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះបិតាជាអម្ចាស់ !
នៅថ្ងៃបុណ្យគោរពសន្តយ៉ូហាន បាទីស្ត
យើងខ្ញុំសូមលើកសក្ការបូជានេះ ថ្វាយទៅព្រះអង្គ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំតម្រង់ផ្លូវថ្វាយព្រះអង្គ
ដូចសន្តយ៉ូហាន បាទីស្ត ដែលជាសំឡេងស្រែកនៅវាលរហោស្ថាន
បានផ្សាភ្ជាប់សេចក្ដីប្រៀនប្រដៅរបស់លោកដោយបង្ហូរឈាម ។

ធម៌ប្រារព្ធ ៖ បេសកកម្មរបស់អ្នកដែលមកផែនដីនេះមុនព្រះបុត្រា ។

បៈ សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រៈ ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

បៈ សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រៈ យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

បៈ សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រៈ ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !

ជាព្រះអម្ចាស់ដ៏មានឫទ្ធានុភាព និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ព្រះជាម្ចាស់បានចាត់លោកយ៉ូហានបាទីស្តមកផែនដីនេះមុនព្រះបុត្រាព្រះអង្គ ។
ព្រះអង្គបានញែកលោកពីក្នុងចំណោមមនុស្សទាំងឡាយ
ដើម្បីបំពេញបេសកកម្មដ៏ពិសេសបំផុត
យើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ។
លោកបានបម្រះដោយអរសប្បាយក្នុងផ្ទៃម្តាយ
នៅពេលជួបព្រះសង្គ្រោះដែលនឹងប្រសូតជាមនុស្ស
កំណើតរបស់លោកធ្វើឲ្យមនុស្សលោកមានអំណរសប្បាយ ។
លោកជាព្យាការីតែម្នាក់គត់ដែលបានបង្ហាញឲ្យគេស្គាល់
កូនចៀមជាព្រះសង្គ្រោះមនុស្សលោក ។
នៅពេលលោកជ្រមុជព្រះយេស៊ូដែលជាម្ចាស់នៃអគ្គសញ្ញាជ្រមុជទឹក
លោកបានធ្វើឲ្យទឹកទន្លេយ័រដាន់ប្រែជាទឹកដ៏វិសុទ្ធ ។
លោកបានទទួលកិត្តិយសផ្តល់សក្ខីភាពដ៏ប្រសើរជាងគេ
ដោយបង្ហូរឈាមរហូតដល់បូជាជីវិត ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
កម្លាំងសក្តិសិទ្ធិ និងអ្វីៗទាំងអស់ ដែលមានអំណាចនៅស្ថានបរមសុខ
រួមគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយច្រៀងឥតឈប់ឈរថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !

នៅថ្ងៃប្រារព្ធបុណ្យកំណើតនៅស្ថានបរមសុខរបស់សន្តយ៉ូហាន បាទីស្ត

សូមព្រះអង្គប្រោសឲ្យយើងខ្ញុំគោរព និងកោតសរសើរព្រះកាយព្រះគ្រីស្ត

ដែលយើងខ្ញុំទើបបានទទួល ទុកជាអគ្គសញ្ញានៃការសង្គ្រោះ ។

ជាងនេះទៅទៀត សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានអំណរសប្បាយ

ដោយសារព្រះកាយព្រះគ្រីស្តមានជលផ្លែពិតប្រាកដក្នុងជីវិតយើងខ្ញុំ ។

# ខែ កញ្ញា

## ថ្ងៃទី ៣ កញ្ញា

# សន្ត ហ្រ្គេហ្គ័រដ៏ប្រសើរឧត្តម ជាសម្តេចប៉ាប និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Gregorii Magni, papæ et Ecclesiæ doctoris**

(បុណ្យរំឭក)

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គតែងតែថែរក្សាប្រជារាស្ត្រព្រះអង្គដោយព្រះហឫទ័យស្លូតបូត
និងគ្រប់គ្រងគេដោយព្រះហឫទ័យស្រឡាញ់ ។
តាមរយៈពាក្យទូលអង្វររបស់សន្តហ្រ្គេហ្គ័រ ជាសម្តេចប៉ាប
សូមព្រះអង្គប្រទានប្រាជ្ញាញាណដល់អស់អ្នកដែលដឹកនាំព្រះសហគមន៍ ។
សូមប្រោសឲ្យហ្វូងចៀមដ៏វិសុទ្ធរបស់ព្រះអង្គរីកចម្រើនឡើង
ដែលជាអំណរសប្បាយអស់កល្បជានិច្ចរបស់គង្វាល ។

### ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គមេត្តាស្តាប់ពាក្យទូលអង្វររបស់យើងខ្ញុំ ។
នៅថ្ងៃគោរពសន្តហ្រ្គេហ្គ័រ យើងខ្ញុំសូមថ្វាយសក្ការបូជានេះ
ដើម្បីជាប្រយោជន៍ដល់យើងខ្ញុំ និងតាមរយៈតង្វាយនេះ
សូមព្រះអង្គលើកលែងទោសឲ្យមនុស្សលោកបានរួចពីបាប ។

### ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំសូមអរព្រះគុណព្រះអង្គ នៅថ្ងៃបុណ្យគោរពសន្តហ្រ្គេហ្គ័រ ។
តាមរយៈព្រះគ្រីស្តជាបរមគ្រូ សូមព្រះអង្គបង្រៀនអស់អ្នក
ដែលទ្រង់បានចិញ្ចឹមដោយព្រះកាយព្រះគ្រីស្តជាអាហារផ្តល់ជីវិត ។
សូមប្រោសឲ្យគេបានស្គាល់សេចក្តីពិត និងសម្តែងធម៌មេត្តាករុណាក្នុងគ្រប់កិច្ចការ ។

## ថ្ងៃទី ៥ កញ្ញា

# សន្តីតេរេសា នៅកុលកាតា ជាព្រហ្មចារិនី និងជាអ្នកបង្កើតក្រុមគ្រួសារសាសនទូតមេត្តាករុណា

**Sanctae Teresiae de Kolcatta Virgis et Fundatricis**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ជាព្រះបិតា !
ព្រះអង្គបានត្រាស់ហៅសន្តីតេរេសា ជាព្រហ្មចារិនី
ឲ្យឆ្លើយតបនឹងព្រះបុត្រារបស់ព្រះអង្គ
ដែលស្រេកឃ្លានសេចក្តីស្រឡាញ់នៅលើឈើឆ្កាង ដោយមានធម៌មេត្តាចំពោះអ្នកក្រីក្របំផុតក្នុងចំណោមប្រជាជនក្រីក្រ ។
តាមពាក្យទូលអង្វររបស់នាង សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ
បេះបម្រើព្រះគ្រីស្តនៅក្នុងចំណោមបងប្អូនដែលរងទុក្ខវេទនាផង ។

ពាក្យថ្វាយតង្វាយ

ឱ ព្រះជាម្ចាស់អើយ !
សូមព្រះអង្គមេត្តាទទួលការបម្រើរបស់យើងខ្ញុំដោយអនុគ្រោះ ។
នៅថ្ងៃបុណ្យគោរពសន្តីតេរេសាយ៉ាងឱឡារិក
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំចូលរួមក្នុងគម្រោងដ៏អស្ចារ្យនេះ
ដែលនាំឲ្យយើងខ្ញុំមានចិត្តឆេះឆួលដោយធម៌មេត្តាករុណា
និងយកចិត្តទុកដាក់ខ្នះខ្នែងចំពោះការសង្គ្រោះមនុស្សលោក ។

ធម៌ប្រារព្ធ ៖ សាសនទូតនៃធម៌មេត្តាករុណា

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប.  សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ.  ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ព្រះអង្គសព្វព្រះហឫទ័យឲ្យសន្តីតេរេសា ចូលរួមជាមួយព្រះបុត្រារបស់ព្រះអង្គ
ដែលសោយទិវង្គតនៅលើឈើឆ្កាងដោយស្រេកឃ្លាន
ហើយធ្វើឲ្យនាងទៅជាបេសកជននៃធម៌មេត្តាករុណា ។
ព្រះអង្គរៀបចំឲ្យអ្នកម្ដាយតេរេសា បង្ហាញពន្លឺនៃធម៌មេត្តាករុណារបស់ព្រះអង្គ
ដោយយកចិត្តទុកដាក់បម្រើអ្នកក្រីក្រដែលសង្គមបានបោះបង់ចោល ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយទេវទូត
និងអគ្គទេវទូត ព្រមទាំងសន្តបុគ្គលដ៏ច្រើនកុះករ
ច្រៀងលើកតម្កើងព្រះអង្គឥតឈប់ឈរ ដោយប្រកាសថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ លើពិភពលោកទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ
ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់ជាព្រះបិតាអើយ !
សូមឲ្យព្រះកាយព្រះគ្រីស្តដែលយើងខ្ញុំទើបទទួល ប្រោសឲ្យយើងខ្ញុំមានចិត្តឆេះឆួលដោយធម៌មេត្តាករុណា ដូចសន្តិតេរេសា
ដែលបម្រើព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គនៅក្នុងអ្នកក្រីក្រ
ទាំងមានចិត្តពោរពេញដោយអំណរសប្បាយ ។

# ថ្ងៃទី ៨ កញ្ញា

# ថ្ងៃកំណើតព្រះនាងព្រហ្មចារិនីម៉ារី

**IN NATIVITATE BEATÆ MARIÆ VIRGINIS**

(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គតែងតែប្រទានព្រះអំណោយទានពីស្ថានបរមសុខមកអ្នកបម្រើព្រះអង្គ
សូមឲ្យអស់អ្នកដែលបានទទួលការសង្គ្រោះ តាមរយៈកំណើតបុត្រាព្រះនាងម៉ារី
បានប្រកបដោយសេចក្ដីសុខសាន្ត នៅថ្ងៃបុណ្យកំណើតព្រះនាងផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
នៅថ្ងៃបុណ្យគោរពកំណើតព្រះនាងព្រហ្មចារិនីម៉ារី
យើងខ្ញុំសូមថ្វាយតង្វាយនេះទៅព្រះអង្គដោយអំណរសប្បាយ ។
យើងខ្ញុំទូលអង្វរព្រះអង្គ សូមឲ្យព្រះបុត្រាដែលសព្វព្រះហឫទ័យ
ទទួលរូបកាយជាមនុស្សពីព្រះនាងម៉ារី ផ្ដល់កម្លាំងមកយើងខ្ញុំ ។

ធម៌ប្រារព្ធទី ១ បុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារី ទំព័រ ៤៧២-៤៧៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គតែងតែប្រោសឲ្យព្រះសហគមន៍ត្រេកអរសប្បាយ
ដោយប្រទានកម្លាំងតាមរយៈព្រះកាយព្រះគ្រីស្ដជាអាហារ ។
សូមព្រះអង្គប្រោសឲ្យព្រះសហគមន៍សប្បាយរីករាយ
ដោយសារបុណ្យកំណើតព្រះនាងព្រហ្មចារិនីម៉ារីដែលជាសេចក្ដីសង្ឃឹម
និងជាថ្ងៃដែលព្រះអង្គសង្គ្រោះពិភពលោកបានចាប់ផ្ដើមហើយ ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក

# ថ្ងៃទី ៩ កញ្ញា

# សន្តសិលា ក្លាវេ ជាបូជាចារ្យ

**S. Petri Claver, presbyteri**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់គង្វាលមួយរូប (Latin p. 933) ឬពាក្យអធិដ្ឋាន រួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់អ្នកប្រព្រឹត្តកិច្ចការនៃធម៌មេត្តាករុណា (Latin p. 963) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !

ព្រះអង្គប្រោសឲ្យសន្តសិលា ក្លាវេ ធ្វើជាអ្នកបម្រើទាសករ

ហើយប្រទានកម្លាំងឲ្យលោកមានចិត្តសប្បុរសដ៏អស្ចារ្យ

និងអត់ធ្មត់ដើម្បីជួយពួកគេ ។

តាមរយៈពាក្យទូលអង្វររបស់លោក សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ

បម្រើព្រះគ្រីស្តដោយស្រឡាញ់អ្នកជិតខាងយ៉ាងពិតប្រាកដ ។

# ថ្ងៃទី ១២ កញ្ញា
# ព្រះនាមដ៏វិសុទ្ធរបស់នាងម៉ារី

**Sanctissimi Nominis Mariæ**

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំសូមទូលអង្វរព្រះអង្គ សូមមេត្តាប្រទានឲ្យអស់អ្នក
ដែលលើកតម្កើងនាមរបស់ព្រះនាងព្រហ្មចារិនីម៉ារី
បានគាប់ព្រះហឫទ័យព្រះអង្គដូចព្រះនាងដែរ ។

ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
តាមរយៈពាក្យទូលអង្វររបស់ព្រះនាងព្រហ្មចារិនីម៉ារី
សូមព្រះអង្គទតមើលតង្វាយរបស់យើងខ្ញុំដោយអនុគ្រោះ ។
សូមប្រោសឲ្យយើងខ្ញុំបានគាប់ព្រះហឫទ័យព្រះអង្គ
ក្នុងពេលយើងខ្ញុំគោរពសរសើរនាមរបស់ព្រះនាង ។

ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យប្រទានពរដល់យើងខ្ញុំ
តាមរយៈពាក្យទូលអង្វររបស់ព្រះនាងម៉ារីជាមាតារបស់ព្រះជាម្ចាស់ ។
នៅថ្ងៃយើងខ្ញុំគោរពនាមដ៏វិសុទ្ធរបស់ព្រះនាងម៉ារី
សូមព្រះអង្គប្រោសឲ្យព្រះនាងជួយយើងខ្ញុំក្នុងគ្រប់សេចក្ដីត្រូវការ ។

# ថ្ងៃទី ១៣ កញ្ញា

# សន្តយ៉ូហាន គ្រីសូស្តូម ជាអភិបាល និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Ioannis Chrysostomi, episcopi et Ecclesiæ doctoris**

(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !

ព្រះអង្គជាកម្លាំងដល់អស់អ្នកដែលផ្ញើជីវិតលើព្រះអង្គ ។ ព្រះអង្គសព្វព្រះហឫទ័យឲ្យសន្តយ៉ូហាន គ្រីសូស្តូម មានឈ្មោះល្បី
ដោយសារសំនួនវោហារដ៏អស្ចារ្យ និងបទពិសោធន៍នៃទុក្ខលំបាក ។
តាមរយៈការប្រៀនប្រដៅរបស់លោក សូមព្រះអង្គប្រោសប្រទានកម្លាំង
ឲ្យយើងខ្ញុំធ្វើតាមគំរូរបស់លោក ដែលមានចិត្តអត់ធ្មត់មិនព្រមចុះចាញ់ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាម្ចាស់អើយ !

ក្នុងឱកាសបុណ្យរំឭកសន្តយ៉ូហាន គ្រីសូស្តូម
សូមព្រះអង្គគាប់ព្រះហឫទ័យទទួលតង្វាយរបស់យើងខ្ញុំ ។
សូមប្រោសឲ្យយើងខ្ញុំថ្វាយខ្លួនទាំងស្រុងដោយកោតសរសើរព្រះអង្គ
តាមការប្រៀនប្រដៅរបស់លោក ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាម្ចាស់ដ៏សប្បុរស !

យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ដែលប្រទានព្រះកាយព្រះគ្រីស្តឲ្យយើងខ្ញុំ
នៅថ្ងៃគោរពសន្តយ៉ូហាន គ្រីសូស្តូម ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំដឹងថា យើងខ្ញុំស្ថិតនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ
និងឲ្យយើងខ្ញុំមានចិត្តស្មោះត្រង់ប្រកាសថា ព្រះអង្គជាសេចក្តីពិត ។

# ថ្ងៃទី ១៤ កញ្ញា

# បុណ្យលើកតម្កើងព្រះឈើឆ្កាង

**IN EXALTATIONE SANCTÆ CRUCIS**

(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យព្រះបុត្រាតែមួយរបស់ព្រះអង្គ
បូជាព្រះជន្មនៅលើឈើឆ្កាងដើម្បីសង្គ្រោះមនុស្សគ្រប់ជាតិសាសន៍ ។
ដូចយើងខ្ញុំបានយល់ពីគម្រោងការដ៏អស្ចារ្យនេះ នៅលើផែនដីយ៉ាងណា
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំទទួលការសង្គ្រោះក្នុងស្ថានបរមសុខយ៉ាងនោះដែរ ។

នៅពេលប្រារព្ធបុណ្យនេះ ចំនៅថ្ងៃអាទិត្យ សូមសូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
តង្វាយនៅលើតុសក្ការបូជានេះ ជាសញ្ញាសម្គាល់នៃព្រះកាយ
ដែលព្រះបុត្រាបានបូជានៅលើឈើឆ្កាង ។
សូមឲ្យតង្វាយនេះ ដែលបានដកបាបនៃពិភពលោក
លាងជម្រះចិត្តគំនិតយើងខ្ញុំឲ្យរួចពីបាបដែរ ។

ធម៌ប្រារព្ធ ៖ ជ័យជម្នះនៃព្រះឈើឆ្កាងប្រកបដោយសិរីរុងរឿង ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏មានឫទ្ធានុភាព និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។
យើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ និងអរព្រះគុណព្រះអង្គ
ដែលសព្វព្រះហឫទ័យសង្គ្រោះមនុស្សលោកដោយសារឈើឆ្កាង ។
ព្រះឈើឆ្កាងឈ្នះសេចក្ដីស្លាប់ និងប្រោសឲ្យជីវិតរស់រវើកឡើងវិញ ។
មារបានឈ្នះមនុស្សនៅលើដើមឈើមួយក្នុងសួនឧទ្យានស្រុកអេដែន
តែជាទីបំផុតព្រះគ្រីស្តឈ្នះមារនៅលើឈើឆ្កាង ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ លើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយប្រកាសថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !

ឬអាចប្រើ ធម៌ប្រារព្ធទី ១ លើកតម្កើងព្រះអម្ចាស់សោយទុក្ខលំបាក ទំព័រ ៤៣៤-៤៣៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់យេស៊ូគ្រីស្ត !
ព្រះអង្គបានប្រទានព្រះកាយ និងព្រះលោហិតឲ្យយើងខ្ញុំក្នុងពិធីជប់លៀងនេះ ។
សូមព្រះអង្គប្រទានជីវិតប្រកបដោយសិរីរុងរឿងដល់អស់អ្នក
ដែលបានទទួលការសង្គ្រោះ ដោយសារព្រះឈើឆ្កាងជាប្រភពនៃជីវិត ។

# ថ្ងៃទី ១៥ កញ្ញា

# ព្រះនាងព្រហ្មចារិនីម៉ារី រងទុក្ខលំបាក

**Beatae Mariae Virginis Perdolentis**

(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !

ព្រះអង្គសព្វព្រះហឫទ័យឲ្យព្រះមាតាឈរក្បែរឈើឆ្កាងរួមទុក្ខជាមួយព្រះបុត្រា ។

សូមព្រះអង្គមេត្តាប្រោសឲ្យព្រះសហគមន៍

ចូលរួមជាមួយព្រះនាងព្រហ្មចារិនីម៉ារីក្នុងទុក្ខលំបាករបស់ព្រះគ្រីស្ត

ដើម្បីឲ្យមានជីវិតរស់ឡើងវិញរួមជាមួយព្រះអង្គផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាម្ចាស់ដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !

នៅពេលព្រះនាងព្រហ្មចារិនីម៉ារីឈរនៅក្បែរឈើឆ្កាង

ព្រះអង្គសព្វព្រះហឫទ័យប្រទានព្រះនាង

ធ្វើជាមាតាដ៏ជាទីស្រឡាញ់របស់យើងខ្ញុំ ។

សូមព្រះអង្គមេត្តាទទួលពាក្យទូលអង្វរ និងតង្វាយដែលយើងខ្ញុំលើកថ្វាយ

ដើម្បីកោតសរសើរព្រះនាមព្រះអង្គ ។

ធម៌ប្រារព្ធទី ១ បុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារី ទំព័រ ៤៧២-៤៧៤

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !

យើងខ្ញុំបានទទួលព្រះកាយព្រះគ្រីស្ត ជាអគ្គសញ្ញានៃការសង្គ្រោះអស់កល្បជានិច្ច ។

នៅថ្ងៃយើងខ្ញុំគោរពព្រះនាងព្រហ្មចារិនីម៉ារី រួមទុក្ខលំបាកជាមួយព្រះបុត្រា

សូមព្រះអង្គមេត្តាជួយឲ្យយើងខ្ញុំចូលរួមទុក្ខលំបាករបស់ព្រះគ្រីស្ត

ដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍ ។

# ថ្ងៃទី ១៦ កញ្ញា
# សន្តគ័រណេី ជាសម្តេចប៉ាប សន្តស៊ីព្រីយ៉ាំង ជាអភិបាលព្រះសហគមន៍ និងជាមរណសាក្សី

**Ss. Cornelii, papæ, et Cypriani, episcopi, martyrum**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីជាច្រើន (Latin p. 909) ។ ឬ ពាក្យអិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល (Latin p. 927) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !

ព្រះអង្គបានប្រោសឲ្យសន្តគ័រណេី និងសន្តស៊ីព្រីយ៉ាំង ទៅជាគង្វាលដ៏វៀសវៃ

និងជាមរណសាក្សីប្រកបដោយសេចក្តីក្លាហាន ។

តាមរយៈពាក្យទូលអង្វររបស់លោកទាំងពីរ

សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានជំនឿរឹងមាំ និងឥតប្រែប្រួល

ហើយព្យាយាមអស់ពីកម្លាំងកាយចិត្ត ដើម្បីឲ្យព្រះសហគមន៍ទៅជាផ្លូវតែមួយ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !

សូមព្រះអង្គមេត្តាទទួលតង្វាយយើងខ្ញុំ

នៅថ្ងៃរំឭកទុក្ខលំបាករបស់សន្តគ័រណេី និងសន្តស៊ីព្រីយ៉ាំង ជាមរណសាក្សី ។

សូមឲ្យអំណោយទានរបស់ព្រះអង្គដែលប្រោសឲ្យលោកទាំងពីរ

មានចិត្តក្លាហាននៅពេលត្រូវគេបៀតបៀន ជំរុញឲ្យយើងខ្ញុំបេះតស៊ូក្នុងគ្រប់ការលំបាក ។

ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !

ព្រះអង្គប្រទានព្រះកាយព្រះគ្រីស្តឲ្យយើងខ្ញុំនៅក្នុងអភិបូជានេះ

សូមព្រះអង្គពង្រឹងជំនឿយើងខ្ញុំឲ្យរឹងមាំ

តាមគំរូរបស់សន្តគ័រណី និងសន្តស៊ីព្រីយ៉ាំងជាមរណសាក្សី ។

សូមព្រះកាយព្រះគ្រីស្តប្រោសយើងខ្ញុំឲ្យមានកម្លាំងផ្តល់សក្ខីភាពថា ដំណឹងល្អជាសេចក្តីពិត ។

## ថ្ងៃទី ១៧ កញ្ញា

# សន្តរ៉ូប៊ែរ បេឡាម៉ាំង ជាអភិបាល និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Roberti Bellarmino, episcopi et Ecclesiæ doctoris**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល (Latin p. 929) ឬ ពាក្យអធិដ្ឋានរួមសម្រាប់គ្រូបាធ្យាយនៃព្រះសហគមន៍ (Latin p. 943) ។

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់ជាព្រះបិតា !

ព្រះអង្គប្រោសឲ្យសន្តរ៉ូប៊ែរ បេឡាម៉ាំង ជាអភិបាល

មានចំណេះវិជ្ជាដ៏ខ្ពង់ខ្ពស់ និងគុណសម្បត្តិ

ដើម្បីការពារជំនឿព្រះសហគមន៍របស់ព្រះអង្គ ។

តាមរយៈពាក្យទូលអង្វររបស់លោក

ហើយដោយពឹងទៅលើជំនឿត្រឹមត្រូវដដែល

សូមប្រោសឲ្យប្រជារាស្ត្ររបស់ព្រះអង្គមានអំណរសប្បាយជានិច្ច ។

## ថ្ងៃទី ១៩ កញ្ញា

# សន្តហ្យង់វីយេ ជាអភិបាល និងជាមរណសាក្សី

**S. Ianuarii, episcopi et martyris**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីមួយរូប (Latin p. 915) ឬ ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល (Latin p. 929) ។

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យយើងខ្ញុំប្រារព្ធបុណ្យរំឭក
ដើម្បីគោរពសន្តហ្យង់វីយេ ជាមរណសាក្សី ។
សូមព្រះអង្គប្រទានឲ្យយើងខ្ញុំចូលរួមអរសប្បាយជាមួយលោក
ក្នុងជីវិតប្រកបដោយសុភមង្គលអស់កល្បជានិច្ច ។

# ថ្ងៃទី ២០ កញ្ញា

# សន្តអន់ដ្រេ គីម ថេហ្គុន ជាបូជាចារ្យ និងសន្តប៉ូល ជុង ហាសាង ព្រមទាំងសហជីវិន ជាមរណសាក្សីនៅប្រទេសកូរ៉េ

**Ss. Andreæ Kim Tae-gŏn, presbyteri,
et Pauli Chŏng Ha-sang, et sociorum, martyrum**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ជាព្រះបិតា !
ព្រះអង្គសព្វព្រះហឫទ័យឲ្យចំនួនបុត្រធីតាកើនឡើងក្នុងពិភពលោកទាំងមូល ។
ព្រះអង្គបានប្រោសឲ្យឈាមរបស់មរណសាក្សី សន្តអន់ដ្រេគីម និងសហជីវិន
ទៅជាគ្រាប់ពូជបង្កើតអ្នកជឿ ។
សូមឲ្យអស់លោកជួយការពារយើងខ្ញុំ និងសូមឲ្យគំរូល្អរបស់អស់លោក
ផ្ដល់ផលប្រយោជន៍សម្រាប់យើងខ្ញុំ ។

ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
សូមព្រះអង្គទតមើលតង្វាយរបស់យើងខ្ញុំដោយអនុគ្រោះ ។
តាមរយៈពាក្យទូលអង្វររបស់មរណសាក្សី សូមប្រោសឲ្យយើងខ្ញុំទៅជាសក្ការបូជា
ដែលគាប់ព្រះហឫទ័យព្រះអង្គដើម្បីសង្គ្រោះមនុស្សលោក ។

ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ ! នៅថ្ងៃយើងខ្ញុំរំឭកមរណសាក្សី
ព្រះអង្គប្រទានអាហាររបស់អ្នកក្លាហានមកចិញ្ចឹមយើងខ្ញុំ ។
ដោយយើងខ្ញុំមានចិត្តស្មោះត្រង់ជាប់ជាមួយព្រះគ្រីស្ត យើងខ្ញុំសូមឱនកាយទូល
អង្វរព្រះអង្គ សូមឲ្យយើងខ្ញុំចេះបំពេញគ្រប់កិច្ចការ
ក្នុងព្រះសហគមន៍សម្រាប់ការសង្គ្រោះដល់មនុស្សទាំងឡាយ ។

# ថ្ងៃទី ២១ កញ្ញា

# សន្តម៉ាថាយ ជាគ្រីស្តទូត និងអ្នកនិពន្ធគម្ពីរដំណឹងល្អ

**APOSTOLI ET EVANGELISTÆ**

(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់ដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !
ព្រះអង្គសព្វព្រះហឫទ័យជ្រើសរើសសន្តម៉ាថាយ
ជាអ្នកទារពន្ធម្នាក់ឲ្យទៅជាគ្រីស្តទូត ។
ដោយពឹងលើគំរូ និងពាក្យទូលអង្វររបស់លោក យើងខ្ញុំសូមអង្វរព្រះអង្គ
មេត្តាការពារយើងខ្ញុំឲ្យជាប់ចិត្តដើរតាមព្រះអង្គជានិច្ច ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ ! នៅថ្ងៃរំឭកសន្តម៉ាថាយ
សូមព្រះអង្គមេត្តាទទួលសក្ការបូជា និងពាក្យអង្វររបស់យើងខ្ញុំ ។
យើងខ្ញុំសូមឱនកាយទូលអង្វរព្រះអង្គ
សូមទ្រង់ទតមើលព្រះសហគមន៍ដែលមានជំនឿរឹងមាំ
តាមរយៈការប្រៀនប្រដៅរបស់គ្រីស្តទូត ។

ធម៌ប្រារព្ធ បុណ្យគោរពគ្រីស្តទូត ទំព័រ ៤៨៤-៤៨៦ ។

## ពាក្យអរព្រះគុណ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គប្រទានឲ្យគ្រីស្តទូតម៉ាថាយ ទទួលអំណរនៅពេលលោកស្វាគមន៍
ព្រះសង្គ្រោះទុកជាភ្ញៀវនៅក្នុងផ្ទះ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំកើតជាថ្មីដោយសារអាហារមកពីព្រះគ្រីស្ត
ដែលយាងមកមិនមែនសម្រាប់មនុស្សសុចរិតនោះទេ
តែទ្រង់យាងមករកមនុស្សបាបដើម្បីប្រទានការសង្គ្រោះ ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក

# ថ្ងៃទី ២៣ កញ្ញា

# សន្តពីយ៉ូ ជាបូជាចារ្យ នៅក្រុងពៀត្រេលជីណា

**S. Pii de Pietrelcina, Presbyteri**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់គង្វាលមួយរូប (Latin p. 933) ឬ ពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់បព្វជិត (Latin p. 961) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅជានិច្ច !
ព្រះអង្គប្រោសឲ្យសន្តពីយ៉ូ ជាបូជាចារ្យ
ចូលរួមក្នុងទុក្ខលំបាករបស់ព្រះបុត្រានៅលើឈើឆ្កាង ។ ព្រះអង្គបានបង្ហាញការអស្ចារ្យនៃធម៌មេត្តាករុណារបស់ព្រះអង្គ
ឲ្យមនុស្សលោកស្គាល់ ក្នុងគ្រប់កិច្ចការបម្រើរបស់សន្តពីយ៉ូ ។
តាមរយៈពាក្យទូលអង្វររបស់លោក សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
ចូលរួមក្នុងទុក្ខលំបាករបស់ព្រះគ្រីស្ត ដើម្បីទទួលសិរីរុងរឿងរួមជាមួយព្រះអង្គ
ដែលមានព្រះជន្មរស់ឡើងវិញ ។

(នេះជាពាក្យអធិដ្ឋានបន្ថែមនៅក្នុងក្បួនពិធីបុណ្យ ជាឡាតាំង SUPPLEMENTUM P. 1276) ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គមេត្តាទទួលតង្វាយដែលយើងខ្ញុំលើកថ្វាយនៅថ្ងៃនឹករំឭកសន្តពីយ៉ូ ។
នៅក្នុងសក្ការបូជានេះ សូមប្រោសឲ្យយើងខ្ញុំបានគាប់ព្រះហឫទ័យព្រះអង្គ
និងទទួលការសង្គ្រោះពីព្រះអង្គផង ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាម្ចាស់ ! យើងខ្ញុំសូមអរព្រះគុណព្រះអង្គ
ដែលបានប្រទានព្រះកាយព្រះគ្រីស្តមកចិញ្ចឹមយើងខ្ញុំ ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យដើរតាមគំរូរបស់សន្តពីយ៉ូ
ដោយបម្រើអ្នកដទៃអស់ពីកម្លាំងកាយចិត្ត ។

# ថ្ងៃទី ២៦ កញ្ញា

# សន្តកូស្មា និងសន្តដាមុីយ៉ាំង ជាមរណសាក្សី

**Ss. Cosmæ et Damiani, martyrum**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីជាច្រើន (Latin p. 909) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាអម្ចាស់អើយ !
ដោយព្រះហឫទ័យប្រណីសន្ដោសដ៏លើសលប់
ព្រះអង្គបានប្រទានសិរីរុងរឿងអស់កល្បជានិច្ចដល់សន្តកូស្មា និងដាមុីយ៉ាំង
ហើយព្រះអង្គក៏ជួយយើងខ្ញុំដោយឥតឈប់ឈរដែរ ។
នៅថ្ងៃនឹករឭកសន្តទាំងពីរ សូមព្រះអង្គប្រោសឲ្យយើងខ្ញុំកោតសរសើរព្រះអង្គ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំសូមគោរពជនសុចរិតទាំងពីររបស់ព្រះអង្គ
ដែលបានបូជាជីវិតដ៏ថ្លៃថ្លាទៅជាមរណសាក្សី ។
ព្រះអង្គប្រោសឲ្យយើងខ្ញុំថ្វាយសក្ការបូជានេះ
ដែលជាប្រភពបូជាជីវិតរបស់មរណសាក្សីទាំងឡាយ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
នៅថ្ងៃនឹករឭកសន្តកូស្មា និងសន្តដាមុីយ៉ាំង ជាមរណសាក្សី
សូមព្រះអង្គរក្សាព្រះអំណោយទានរបស់ព្រះអង្គទុកក្នុងដួងចិត្តយើងខ្ញុំជានិច្ច
ហើយសូមឲ្យអ្វីៗដែលយើងខ្ញុំបានទទួលពីព្រះអង្គ
ប្រោសឲ្យយើងខ្ញុំបានជាសះស្បើយ ព្រមទាំងទទួលការសង្គ្រោះ
និងសេចក្ដីសុខសាន្ត ។

# ថ្ងៃទី ២៧ កញ្ញា
# សន្តវ៉ាំងសង់ ដឺប៉ូល ជាបូជាចារ្យ
**S. Vincentii de Paul, presbyteri**

(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យសន្តវ៉ាំងសង់ ដឺប៉ូល ជាបូជាចារ្យ មានគុណធម៌ជាគ្រីស្តទូត
ដោយជួយសង្គ្រោះជនក្រីក្រ និងអប់រំបព្វជិតឯទៀតៗ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំមានចិត្តឆេះឆួលដូចលោក
និងសូមឲ្យយើងខ្ញុំស្រឡាញ់នូវអ្វីៗដែលលោកបានស្រឡាញ់ ហើយឲ្យយើងខ្ញុំ
ប្រព្រឹត្តតាមការប្រៀនប្រដៅរបស់លោក ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាម្ចាស់ជាព្រះបិតា !
ព្រះអង្គបានប្រោសសន្តវ៉ាំងសង់ឲ្យរស់នៅស្របតាមសក្ការបូជា
ដែលលោកបានថ្វាយ ។
ដោយឫទ្ធានុភាពនៃសក្ការបូជានេះ សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
ទៅជាតង្វាយដែលគាប់ព្រះហឫទ័យព្រះអង្គ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គប្រទានព្រះកាយព្រះគ្រីស្តឲ្យព្រះសហគមន៍មានកម្លាំងកាន់តែខ្លាំងក្លា ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំយកចិត្តទុកដាក់ប្រកាសដំណឹងល្អដល់អ្នកក្រីក្រ
តាមគំរូរបស់សន្តវ៉ាំងសង់ ដឺប៉ូល ដែលលោកប្រព្រឹត្តតាមព្រះបុត្រាព្រះអង្គ ។
សូមឲ្យពាក្យទូលអង្វររបស់លោក គាំទ្រការរស់នៅរបស់យើងខ្ញុំផង ។

# ថ្ងៃទី ២៨ កញ្ញា

# សន្តវិនហ្សេសឡាយ ជាមរណសាក្សី

**S. Venceslai, martyris**

តាមក្បួនពិធីគោរពមរណសាក្សី ៖ សម្រាប់មរណសាក្សីមួយរូប (Latin p. 915) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គបានបង្រៀនសន្តវិនហ្សេសឡាយ ជាមរណសាក្សី
ឲ្យលោកចាត់ទុកព្រះរាជ្យនៃស្ថានបរមសុខសំខាន់ជាង ការគ្រងរាជ្យនៅលើផែនដីនេះ ។
តាមរយៈពាក្យទូលអង្វររបស់លោក សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
សុខចិត្តលះបង់បោលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីភ្ជាប់ចិត្តនឹងព្រះអង្គជានិច្ច ។

# សន្តឡូរ៉ង់ រូអ៊ីស និងសហការី ជាមរណសាក្សី

**Ss. Laurentii Ruiz et sociorum, martyrum**

តាមក្បួនពិធីគោរពមរណសាក្សី ៖ សម្រាប់មរណសាក្សីជាច្រើន (Latin p. 909) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាជាអម្ចាស់ !
ព្រះអង្គប្រោសសន្តឡូរ៉ង់ រូអ៊ីស និងសហការីរបស់លោក
ឲ្យស៊ូទ្រាំរហូតដល់បូជាជីវិត ជាមរណសាក្សី ។
សូមប្រោសយើងខ្ញុំឲ្យចេះស៊ូទ្រាំដោយបម្រើព្រះអង្គ និងបម្រើអ្នកជិតខាង
ទាំងដឹងថា អស់អ្នកដែលត្រូវគេបៀតបៀនព្រោះតែសេចក្ដីសុចរិត
មានសុភមង្គលក្នុងព្រះរាជ្យព្រះអង្គ ។

# ថ្ងៃទី ២៩ កញ្ញា

# សន្តមីកាអែល កាព្រីអែល និងរ៉ាហ្វាអែល ជាអគ្គទេវទូត

**SS. MICHAELIS, GABRIELIS ET RAPHAELIS, ARCHANGELORUM**

(បុណ្យរំឭក)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គរៀបចំឲ្យទេវទូត និងមនុស្សលោកបំពេញមុខងារបម្រើ
ដោយមានរបៀបរៀបរយដ៏អស្ចារ្យ ។
សូមព្រះអង្គបាត់អ្នកបម្រើរបស់ព្រះអង្គនៅស្ថានបរមសុខ
ឲ្យឃ្លាំមើលយើងខ្ញុំទាំងយប់ទាំងថ្ងៃ
ដើម្បីការពារជីវិតយើងខ្ញុំនៅលើផែនដីនេះផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
យើងខ្ញុំសូមថ្វាយសក្ការបូជានេះ ដើម្បីកោតសរសើរព្រះអង្គ ។
នៅពេលទេវទូតទាំងឡាយនាំយកសក្ការបូជានេះ
ថ្វាយព្រះអង្គជាព្រះដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គមេត្តាទទួលដោយអនុគ្រោះ
និងប្រទានការសង្គ្រោះដល់យើងខ្ញុំផង ។

ធម៌ប្រារព្ធ ៖ ព្រះជាម្ចាស់បានលើកតម្កើងសិរីរុងរឿងតាមរយៈទេវទូត ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏មានឫទ្ធានុភាព និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។
យើងខ្ញុំសូមកោតសរសើរព្រះអង្គឥតឈប់ឈរ រួមជាមួយអគ្គទេវទូត
និងអស់ទេវទូតរបស់ព្រះអង្គ ។
ការគោរពរបស់យើងខ្ញុំចំពោះអស់ទេវទូតដែលគាប់ព្រះហឫទ័យព្រះអង្គ
បានត្រឡប់ទៅជាការកោតសរសើរសិរីរុងរឿងរបស់ព្រះអង្គ ។
តាមរយៈសេចក្ដីថ្លៃថ្នូដ៏អស្ចារ្យ និងភាពត្រចះត្រចង់របស់ទេវទូត
ព្រះអង្គបង្ហាញភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះអង្គ
ដើម្បីឲ្យយើងខ្ញុំលើកតម្កើងទ្រង់លើសពីអ្វីៗទាំងអស់
តាមរយៈព្រះគ្រីស្ដជាអម្ចាស់យើងខ្ញុំ ។

ដោយសារព្រះគ្រីស្ដនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយ
អស់ទេវទូតដ៏ច្រើនកុះករ មានអំណរសប្បាយរីករាយ
កោតសរសើរអានុភាពដ៏អស្ចារ្យរបស់ព្រះអង្គ ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !

### ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំមានកម្លាំងថ្មី ដោយបានទទួលទានអាហារមកពីស្ថានបរមសុខ ។
យើងខ្ញុំសូមឱនកាយទូលអង្វរព្រះអង្គ សូមមេត្តាបាត់ទេវទូតមកការពារយើងខ្ញុំ
និងនាំយើងខ្ញុំឲ្យធ្វើដំណើរទៅមុខ តាមផ្លូវនៃការសង្គ្រោះដោយចិត្តក្លាហាន ។

# ថ្ងៃទី ៣០ កញ្ញា
# សន្តយេរ៉ូម ជាបូជាចារ្យ
# និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Hieronymi, presbyteri et Ecclesiæ doctoris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !

ព្រះអង្គប្រោសប្រទានឲ្យសន្តយេរ៉ូម ជាបូជាចារ្យ

រស់នៅតាមព្រះបន្ទូល និងស្រឡាញ់ព្រះគម្ពីរដោយចិត្តសុភាពរាបសា ។

សូមឲ្យបុត្រធីតារបស់ព្រះអង្គ ទទួលផលផ្លែពីព្រះបន្ទូលព្រះអង្គ

និងយល់ច្បាស់ថា ព្រះបន្ទូលជាប្រភពនៃជីវិត ។

ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !

យើងខ្ញុំនឹកសញ្ជឹងគិតពីព្រះបន្ទូលព្រះអង្គ តាមគំរូរបស់សន្តយេរ៉ូម ។

សូមព្រះអង្គប្រោសឲ្យយើងខ្ញុំស្រេកឃ្លានចង់នៅក្បែរព្រះអង្គ

ដើម្បីលើកសក្ការបូជានៃការសង្គ្រោះ ថ្វាយទៅព្រះអង្គជាព្រះដ៏ឧត្តុង្គឧត្តម ។

ពាក្យអរព្រះគុណ

បពិត្រព្រះជាអម្ចាស់ !

នៅថ្ងៃគោរពសន្តយេរ៉ូម យើងខ្ញុំមានអំណរសប្បាយ

ដោយបានទទួលព្រះអំណោយទានដ៏វិសុទ្ធរបស់ព្រះអង្គ ។

សូមព្រះអង្គប្រោសឲ្យអស់អ្នកដែលផ្ញើជីវិតលើព្រះអង្គ

រំភើបចិត្តនឹងសក្ការបូជានេះ ហើយយកចិត្តទុកដាក់ស្តាប់

ការប្រៀនប្រដៅរបស់ព្រះអង្គ ។

សូមឲ្យគេស្គាល់ផ្លូវ និងធ្វើដំណើរទៅមុខដើម្បីទទួលជីវិតអស់កល្បជានិច្ច ។

# បុណ្យភ្ជុំ

នៅក្នុងខែកញ្ញា ឬ ខែតុលា

ថ្ងៃទី ១

# បុណ្យគោរពសន្តបុគ្គលទាំងឡាយ

**OMNIUM SANCTORUM**

(បុណ្យឱឡារិក)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ និងមានព្រះជន្មគង់នៅជានិច្ច!
នៅថ្ងៃនេះ យើងខ្ញុំសូមគោរពដល់គុណធម៌របស់សន្តបុគ្គលទាំងឡាយ
ដែលជាព្រះអំណោយទានរបស់ព្រះអង្គ ។
តាមរយៈពាក្យទូលអង្វររបស់សន្តបុគ្គលទាំងឡាយ
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបានរួចពីបាប និងបានគាប់ព្រះហឫទ័យព្រះអង្គ ។

**✠ អត្ថបទទី ១ សូមថ្លែងព្រះគម្ពីរវិវរណៈ ៧,២-៤,៩-១៤**

ខ្ញុំយ៉ូហាន ឃើញទេវទូតមួយអង្គឡើងពីទិសខាងកើតមក ទាំងកាន់ត្រារបស់ព្រះដ៏មានព្រះជន្មគង់នៅផង ។ ទេវទូតនោះ បន្លឺសំឡេងយ៉ាងខ្លាំងៗទៅកាន់ទេវទូតទាំងបួន ដែលបានទទួលអំណាចធ្វើទុក្ខទោសផែនដី និងសមុទ្រថា៖ "សូមកុំអាលធ្វើទុក្ខទោសផែនដី សមុទ្រ ឬដើមឈើណាឡើយ! ចាំយើងបោះត្រាសម្គាល់លើថ្ងាសពួកអ្នកបម្រើរបស់ព្រះជាម្ចាស់នៃយើង ហើយសិន" ។ ពេលនោះ ខ្ញុំក៏ឮថា អស់អ្នកដែលត្រូវគេបោះត្រាសម្គាល់មានចំនួនមួយសែន បួនម៉ឺនបួនពាន់នាក់ មកពីកុលសម្ព័ន្ធទាំងប៉ុន្មានរបស់ជនជាតិអ៊ីស្រាអែល ។ ក្រោយមក ខ្ញុំមើល មហាជនដ៏ច្រើនកុះករ គ្មាននរណាអាចរាប់ចំនួនបានឡើយ អ្នកទាំងនោះមកពីគ្រប់ជាតិសាសន៍ គ្រប់កុលសម្ព័ន្ធ និងគ្រប់ភាសា ។ ពួកគេពាក់អាវសវែង ឈរនៅមុខបល្ល័ង្ក និងនៅមុខកូនចៀមទាំងកាន់ធាងទន្សែនៅដៃផង ។ គេនាំគ្នាបន្លឺសំឡេងឡើងយ៉ាងខ្លាំងៗថា៖ "មានតែព្រះនៃយើងដែលគង់នៅលើបល្ល័ង្ក ជុំវិញពួកព្រឹទ្ធាចារ្យ និងជុំវិញសត្វមានជីវិត ទាំងបួន នាំគ្នាក្រាបនៅមុខបល្ល័ង្កទាំងឱនមុខដល់ដីថ្វាយបង្គំព្រះជាម្ចាស់ ហើយពោលថា៖

"អាម៉ែន ! សូមកោតសរសើរ សូមលើកតម្កើងសិរីរុងរឿងព្រះប្រាជ្ញាញាណសូមអរព្រះគុណ សូមលើកតម្កើងព្រះកិត្តិនាម ឫទ្ធានុភាព និងមហិទ្ធិឫទ្ធិរបស់ព្រះនៃយើងអស់កល្បជាអង្វែង តរៀងទៅ ! អាម៉ែន !។ ព្រឹទ្ធាចារ្យម្នាក់មានប្រសាសន៍សួរខ្ញុំថា៖ "តើអស់អ្នកដែលពាក់ អាវសវែងនោះ ជានរណា? ហើយគេមកពីណា? ។ ខ្ញុំក៏ជម្រាប់លោកថា៖ "លោកម្ចាស់ខ្ញុំ អើយ ! លោកទេតើដែលជ្រាប" ។ លោកក៏ប្រាប់ខ្ញុំថា៖ "ពួកគេសុទ្ធតែជាអ្នកដែលបានឆ្លងកាត់ ទុក្ខវេទនាដ៏ខ្លាំងនោះ ។ គេបានបោកអាវរបស់ខ្លួនឲ្យបានស្អាតក្នុងព្រះលោហិតរបស់កូនចៀម" ។

**ទំនុកតម្កើងលេខ ២៤ (២៣)** **បទពាក្យ ៧**

| | |
|---|---|
| ១. អ្វីៗដែលនៅលើផែនដី | កើតមកច្រើនក្រៃមីរដេរដាស |
| សុទ្ធជាកម្មសិទ្ធព្រះអម្ចាស់ | ជាស្នាព្រះហស្តនៃព្រះអង្គ ។ |
| ២. គឺព្រះអង្គហើយដែលបាក់គ្រឹះ | គ្រប់ទីគ្រប់ទិសគ្រប់ជ្រោយជ្រុង |
| ធ្វើឲ្យផែនដីនៅរឹងប៉ឹង | ធំធេងល្វើយល្វឹងលើសមុទ្រ ។ |
| ៣. តើនរណាអាចឡើងលើភ្នំ | វិហារឧត្តមដ៏វិសុទ្ធ |
| ដែលជាទីស្ថានតែមួយគត់ | ល្អល្អះបំផុតសែនសុខសាន្ត ។ |
| ៤. គឺមានតែអ្នកត្រឹមត្រូវល្អ | ទឹកចិត្តស្មោះសរបរិសុទ្ធថ្កាន |
| មិនបណ្ដោយខ្លួនស្បថបំពាន | នោះទើបអាចបានឡើងទីខ្ពស់ ។ |
| ៥. ព្រះជាអម្ចាស់ប្រទានពរ | ជោគជ័យបវរសព្វទាំងអស់ |
| ហើយព្រះអង្គបានជួយសង្គ្រោះ | ទាំងប្រោសឲ្យរស់មានជីវិត ។ |
| ៦. អ្នកទាំងនេះហើយគឺប្រជា | ស្វះស្វែងម្នីម្នាចូលមកជិត |
| ជាអ្នកស្វែងរកព្រះម្ចាស់ពិត | ព្រះភ័ក្ត្រល្អល្អិតព្រះយ៉ាកុប ។ |

**✠ អត្ថបទទី ២ សូមថ្លែងលិខិតទី១ របស់លោកយ៉ូហាន ៣,១-៣**

បងប្អូនជាទីស្រឡាញ់ សូមគិតមើល៍ ព្រះបិតាមានព្រះហឫទ័យស្រឡាញ់យើងខ្លាំងដល់កំរិតណា គឺព្រះអង្គស្រឡាញ់យើងរហូតដល់ទៅហៅយើងថា ជាបុត្រធីតារបស់ព្រះអង្គ ហើយយើង ពិតជាបុត្រធីតារបស់ព្រះអង្គមែន! ។ ហេតុនេះហើយ បានជាមនុស្សលោកមិនស្គាល់យើង មកពីគេមិនស្គាល់ព្រះអង្គ ។ កូនចៅជាទីស្រឡាញ់អើយ! ពេលនេះ យើងទាំងអស់គ្នា ជា បុត្រធីតារបស់ព្រះជាម្ចាស់ ហើយដែលយើងនឹងទៅជាយ៉ាងណាៗនោះ ព្រះអង្គពុំទាន់សម្តែង ឲ្យយើងដឹងនៅឡើយទេ ។ ប៉ុន្តែ នៅពេលព្រះគ្រីស្តយាងមកដល់ យើងនឹងបានដូចព្រះអង្គដែរ ដ្បិតព្រះអង្គមានភាពយ៉ាងណា យើងនឹងឃើញព្រះអង្គយ៉ាងនោះ ។ អ្នកណាមានសេចក្តីសង្ឃឹម លើព្រះអង្គបែបនេះ អ្នកនោះបានជម្រះខ្លួនឲ្យបរិសុទ្ធដូចព្រះអង្គទ្រង់បរិសុទ្ធដែរ ។

✠ **ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ**

**អាលេលូយ៉ា ! អាលេលូយ៉ា !**

ព្រះអម្ចាស់មានព្រះបន្ទូលថា ៖ «អស់អ្នកដែលនឿយហត់ និងមានបន្ទុកធ្ងន់អើយ ! ចូរមករកខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាសម្រាក» ។ **អាលេលូយ៉ា !**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមលោកម៉ាថាយ** ៥,១-១២

ព្រះយេស៊ូទតឃើញមហាជនដែលដើរតាមព្រះអង្គ ! ទ្រង់យាងឡើងទៅលើភ្នំ រួចព្រះអង្គគង់នៅទីនោះ ។ សាវ័កនាំគ្នាចូលមកគាល់ព្រះអង្គ ព្រះអង្គក៏មានព្រះបន្ទូលបង្រៀនគេថា៖ «អ្នកណាដាក់ចិត្តជាអ្នកក្រខ្សត់ អ្នកនោះមានសុភមង្គលហើយ ដ្បិតពួកគេបានទទួលព្រះរាជ្យនៃស្ថានបរមសុខ ! អ្នកណាសោកសៅ អ្នកនោះមានសុភមង្គលហើយ ដ្បិតព្រះជាម្ចាស់នឹងសម្រាលទុក្ខពួកគេ ! អ្នកណាស្រេកឃ្លានសេចក្ដីសុចរិត អ្នកនោះមានសុភមង្គលហើយ ដ្បិតព្រះ ជាម្ចាស់នឹងប្រទានឲ្យពួកគេបានឆ្អែត ! អ្នកណាមានចិត្តមេត្តាករុណា អ្នកនោះមានសុភមង្គលហើយ ដ្បិតព្រះជាម្ចាស់នឹងសម្ដែងព្រះហឫទ័យមេត្តាករុណាដល់ពួកគេវិញ! អ្នកណាមានចិត្តបរិសុទ្ធ អ្នកនោះមានសុភមង្គលហើយ ដ្បិតពួកគេនឹងមានឈ្មោះជាបុត្ររបស់ព្រះជាម្ចាស់! អ្នកណាត្រូវគេបៀតបៀនព្រោះតែបានធ្វើតាមសេចក្ដីសុចរិត អ្នកនោះមានសុភមង្គលហើយ ដ្បិតគេបានទទួលក្នុងព្រះរាជ្យនៃស្ថានបរមសុខ! ប្រសិនបើមានគេត្មះតិះដៀលបៀតបៀន និងមានគេនិយាយអាក្រក់គ្រប់យ៉ាងបង្ខូចឈ្មោះអ្នករាល់គ្នាព្រោះតែខ្ញុំ នោះអ្នករាល់គ្នាមានសុភមង្គលហើយ !។ ចូរអរសប្បាយរីករាយឡើង ព្រោះអ្នករាល់គ្នានឹងទទួលរង្វាន់យ៉ាងធំនៅស្ថានបរមសុខ ដ្បិតពួកព្យាការីដែលរស់នៅមុនអ្នករាល់គ្នា ក៏ត្រូវគេបៀតបៀនដូច្នោះដែរ» ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !

សូមឲ្យតង្វាយដែលយើងខ្ញុំលើកថ្វាយ នៅថ្ងៃគោរពសន្តបុគ្គលទាំងឡាយ
បានគាប់ព្រះហឫទ័យព្រះអង្គ ។
យើងខ្ញុំជឿថា សន្តបុគ្គលទទួលជីវិតអស់កល្បជានិច្ចយ៉ាងណា
សូមឲ្យយើងខ្ញុំដឹងច្បាស់ថា សន្តបុគ្គលទាំងនោះជួយយើងខ្ញុំ
ឲ្យទទួលការសង្គ្រោះយ៉ាងនោះដែរ ។

ធម៌ប្រារព្ធ ៖ សិរីរុងរឿងនៃក្រុងយេរូសាឡឹមជាមាតារបស់យើង ។

បៈ   សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រៈ   ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

បៈ   សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រៈ   យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

បៈ   សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រៈ   ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏មានឫទ្ធានុភាព និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។
ថ្ងៃនេះ ព្រះអង្គប្រទានឲ្យយើងខ្ញុំប្រារព្ធពិធីបុណ្យប្រចាំក្រុងរបស់ព្រះអង្គ
គឺជាក្រុងយេរូសាឡឹមនៅស្ថានបរមសុខដែលជាមាតារបស់យើងខ្ញុំ ។
នៅក្រុងនេះ បងប្អូនយើងខ្ញុំច្រើនឥតគណនាពាក់មកុដ
ច្រៀងកោតសរសើរព្រះអង្គអស់កល្បជានិច្ច ។
យើងខ្ញុំស្រេកឃ្លានចង់ធ្វើបូជនីយចរទៅកាន់ក្រុងនោះដោយជំនឿ
និងមានអំណរសប្បាយក្នុងសិរីរុងរឿងដែលព្រះអង្គបានប្រទាន
ឲ្យអស់សមាជិកព្រះសហគមន៍ដែលព្រះអង្គជ្រើសរើស ។
តាមរយៈអស់សន្តបុគ្គល ព្រះអង្គប្រទានទាំងកម្លាំង
ទាំងគំរូល្អនៅក្នុងភាពទន់ខ្សោយរបស់យើងខ្ញុំ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយទេវទូតជាច្រើន
ព្រមទាំងសន្តបុគ្គលទាំងឡាយ លើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយសូរសព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !

ពាក្យអរព្រះគុណ

ឱ ព្រះជាម្ចាស់អើយ !
យើងខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ ជាព្រះដ៏វិសុទ្ធតែមួយព្រះអង្គគត់
ដែលបង្ហាញការអស្ចារ្យតាមរយៈសន្តបុគ្គលទាំងឡាយ ។
សូមព្រះអង្គសព្វព្រះហឫទ័យប្រទានភាពដ៏វិសុទ្ធ
ប្រកបដោយសេចក្ដីស្រឡាញ់មកយើងខ្ញុំ
និងប្រោសឲ្យយើងខ្ញុំចេញពីតុនៃបូជនីយសក្ការ
ឆ្ពោះទៅកាន់ពិធីជប់លៀងឯស្ថានបរមសុខដែលជាមាតុភូមិរបស់យើងខ្ញុំ ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក (Latin p. 614) ។

អភិបូជាតាមប្រាថ្នាសម្រាប់សន្តបុគ្គលទាំងឡាយ សូមមើលក្នុងក្បួនពិធី cf. infra, p. 1187 ។

# បុណ្យឧទ្ទិសដល់មរណបុគ្គលទាំងឡាយ

**IN COMMEMORATIONE OMNIUM FIDELIUM DEFUNCTORUM**

មានប្រជុំគ្នាច្រើនចូលរួមក្នុងប្រារព្ធពិធីនេះ អាចប្រើតាមចិត្តប្រាថ្នា ។ ទោះបីជា ថ្ងៃទី២ វិច្ឆិកា ចំនឹងថ្ងៃអាទិត្យ គឺត្រូវធ្វើពិធីអភិបូជាសម្រាប់អស់អ្នកជឿដែលបានលាចាកលោកទៅហើយ ។

## ថ្ងៃទី ២

ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ជាព្រះបិតា !
សូមព្រះអង្គស្ដាប់ពាក្យទូលអង្វររបស់យើងខ្ញុំដោយអនុគ្រោះ ។
ជំនឿរបស់យើងខ្ញុំលើព្រះបុត្រា
ដែលព្រះបិតាលើកឡើងពីចំណោមមនុស្សស្លាប់ កាន់តែចម្រើនឡើងយ៉ាងណា
សូមឲ្យសេចក្ដីសង្ឃឹមរបស់យើងខ្ញុំលើអ្នកបម្រើរបស់ព្រះអង្គ
ដែលបានលាចាកលោកនេះទៅហើយ នឹងរស់ឡើងវិញកាន់តែរឹងមាំយ៉ាងនោះដែរ ។

✠ **អត្ថបទទី ១ សូមថ្លែងព្រះគម្ពីររបស់ព្យាការីអេសាយ** ២៥,៦-៩

ព្រះអម្ចាស់នៃពិភពទាំងមូល នឹងជប់លៀងប្រជាជនទាំងអស់នៅលើភ្នំស៊ីយ៉ូន គឺមានម្ហូបដ៏ឆ្ងាញ់ពិសា និងស្រាទំពាំងបាយជូរដ៏មានឱជារសបំផុត មានសាច់ចំឡុក និងស្រាទំពាំងបាយជូរ ដែលគេសម្រាំងយ៉ាងល្អ ។ នៅលើភ្នំនោះ ព្រះអង្គនឹងដកសម្លៀកបំពាក់កាន់ទុក្ខចេញពី ប្រជាជនទាំងប៉ុន្មាន ហើយដកទុក្ខព្រួយចេញពីប្រជាជាតិទាំងអស់ដែរ ។ ព្រះអង្គនឹងបំបាត់ សេចក្ដីស្លាប់រហូតតទៅ ព្រះជាអម្ចាស់នឹងជូតទឹកភ្នែកចេញពីមុខរបស់មនុស្សទាំងអស់ ហើយ ព្រះអង្គក៏ដកការអាម៉ាស់នៃប្រជារាស្ត្ររបស់ព្រះអង្គចេញពីទឹកដីទាំងមូលដែរ ។ នេះជាព្រះ បន្ទូលរបស់ព្រះអង្គ ហើយព្រះអង្គសង្គ្រោះយើង យើងបានផ្ញើជីវិតលើព្រះអម្ចាស់មែន! ចូរយើងសប្បាយរីករាយ និងមានអំណរឡើង ដ្បិតព្រះអង្គជាព្រះសង្គ្រោះរបស់យើង ! ។

## ទំនុកតម្កើងលេខ ៣១ (៣០) — បទកាកគតិ

២. ឱ ព្រះអម្ចាស់ ខ្ញុំសូមប្រកាស សូមជ្រកក្រោមម្លប់ ជារៀងរហូត
ឥតមានឈរឈប់ ទាំងថ្ងៃទាំងយប់ សូមរំដោះផង ។

៦. ខ្ញុំសូមប្រគល់ វិញ្ញាណនិមល ថ្វាយអង្គក្សត្រា ទៅក្នុងព្រះហស្ត
ព្រះម្ចាស់ហើយណា ព្រោះព្រះអង្គជា ព្រះទុកចិត្តបាន ។

៨. ចិត្តខ្ញុំស្រស់ថ្លា អរឥតឧបមា រីករាយសប្បាយ ដោយសារព្រះអង្គ
ទ្រង់មានព្រះទ័យ ករុណាប្រណី ពេលខ្ញុំវេទនា ។

៩. ទ្រង់មិនបណ្ដោយ ឲ្យរូបខ្ញុំធ្លោយ គ្រាំគ្រាខ្លោចផ្សា ធ្លាក់ទៅក្នុងដៃ
របស់បច្ចា សូមទ្រង់ករុណា មេត្តាប្រណី ។

១៦. អាយុជីវិត របស់ខ្ញុំស្ថិត ដោយក្ដីសុខដុម នៅក្នុងព្រះហស្ត
ព្រះម្ចាស់ឧត្ដម សូមរំដោះខ្ញុំ ផុតពីដៃខ្មាំង ។

១៧. សូមបែរព្រះភ័ក្ត្រ ទតមកមើលអ្នក បម្រើព្រះអង្គ មេត្តាសង្គ្រោះ
ទូលបង្គំផង ដោយហឫទ័យទ្រង់ ប្រណីករុណា ។

២៣. ពេលខ្ញុំខ្វល់ចិត្ត វិលវល់គំនិត ជួបទុក្ខគ្រោះភ័យ ខ្ញុំនឹកស្មានថា
ទ្រង់លែងប្រណី តែពេលខ្ញុំស្ដី ទ្រង់ស្ដាប់ពាក្យខ្ញុំ ។

✠ **អត្ថបទទី២ សូមថ្លែងលិខិតរបស់លោកប៉ូលផ្ញើជូនគ្រីស្តបរិស័ទនៅក្រុងរ៉ូម** ១៤,៧...១២
បងប្អូនជាទីស្រឡាញ់!
ក្នុងចំណោមបងប្អូន គ្មាននរណាម្នាក់រស់ ឬស្លាប់សម្រាប់ខ្លួនឯងឡើយ ។ ដ្បិតបើយើងរស់ យើងរស់សម្រាប់ព្រះអម្ចាស់ ហើយបើយើងស្លាប់ ក៏ស្លាប់សម្រាប់ព្រះអម្ចាស់ដែរ ។ ទោះបីយើងរស់ក្តី ស្លាប់ក្តី យើងថ្វាយខ្លួនទៅព្រះអម្ចាស់ជានិច្ច ដ្បិតព្រះគ្រីស្តបានសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញដើម្បីធ្វើជាព្រះអម្ចាស់ ទាំងលើមនុស្សស្លាប់ ទាំងលើមនុស្សរស់ ។ រីឯអ្នក ហេតុដូចម្តេច បានជាអ្នកថ្កោលទោសបងប្អូនរបស់អ្នក? ហេតុដូចម្តេច បានជាអ្នកមើលងាយបងប្អូនរបស់អ្នក? ។ យើងទាំងអស់គ្នានឹងទៅឈរនៅមុខតុលាការរបស់ព្រះជាម្ចាស់ ដ្បិតមានចែងទុកមកថា៖ ព្រះអម្ចាស់មានព្រះបន្ទូលថា *"ពិតដូចយើងមានជីវិតរស់យ៉ាងណា មនុស្សទាំងអស់ពិតជាលុតជង្គង់ថ្វាយបង្គំយើង ហើយប្រកាសទទួលស្គាល់ព្រះជាម្ចាស់យ៉ាងនោះដែរ"* ។ ដូច្នេះ យើងត្រូវរៀបរាប់ទូលព្រះជាម្ចាស់នូវអំពើដែលខ្លួនយើងម្នាក់ៗ បានប្រព្រឹត្ត ។

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ**
**អាលេលូយ៉ា** ! **អាលេលូយ៉ា** ! ចូរប្រុងស្មារតី និងទូលអង្វរគ្រប់ពេលវេលា
ដើម្បីឲ្យអ្នករាល់គ្នាអាចឈរនៅមុខបុត្រមនុស្ស ។ **អាលេលូយ៉ា** !

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមលោកលូកា** ១២,៣៥-៤៥
ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ក្រុមសាវ័កថា៖ «ចូរប្រុងប្រៀបខ្លួន ហើយទុកឲ្យចង្កៀងរបស់អ្នករាល់គ្នានៅឆេះ ។ ចូរប្រព្រឹត្តឲ្យបានដូចពួកអ្នកបម្រើដែលរង់ចាំម្ចាស់វិលត្រឡប់មកពីជប់លៀងវិញ គឺនៅពេលមកដល់លោកគោះទ្វារ អ្នកបម្រើទៅបើកជូនភ្លាម ។ ពេលម្ចាស់ត្រឡប់មកដល់ឃើញអ្នកបម្រើណានៅរង់ចាំលោក អ្នកបម្រើនោះ មានសុភមង្គលហើយ ។ ខ្ញុំ សុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា លោកនឹងឲ្យអ្នកបម្រើអង្គុយបរិភោគ ហើយលោករៀបចំខ្លួនបម្រើគេវិញ ។ បើលោកវិលមកវិញនៅពាក់កណ្តាលអធ្រាត្រ ឬជិតភ្លឺ ហើយឃើញអ្នកបម្រើទាំងនោះ នៅរង់ចាំដូច្នេះ ពួកគេប្រាកដជាមានសុភមង្គល ។ អ្នករាល់គ្នាដឹងហើយថា បើម្ចាស់ផ្ទះដឹងថាចោរចូលមកប្លន់ថ្មើរណា គាត់នឹងមិនបណ្តោយឲ្យវាចូលមកក្នុងផ្ទះគាត់បាន ឡើយ ។ រីឯអ្នករាល់គ្នាវិញ ចូរត្រៀមខ្លួនជានិច្ច ដ្បិតបុត្រមនុស្សនឹងមកដល់នៅវេលាដែលអ្នក រាល់គ្នាពុំបានគិត» ។

ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
សូមព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយដែលយើងខ្ញុំថ្វាយ
សម្រាប់អស់អ្នកបម្រើរបស់ព្រះអង្គដែលសម្រាកក្នុងព្រះគ្រីស្ត ។
សូមព្រះអង្គប្រោសអ្នកទាំងនោះ ឲ្យបានរួចពីចំណងនៃសេចក្ដីស្លាប់
ដោយសារសក្ការបូជាតែមួយនេះ
សូមឲ្យអ្នកទាំងនោះសមនឹងទទួលជីវិតអស់កល្បជានិច្ច ។

ធម៌ប្រារព្ធ សម្រាប់មរណបុគ្គល ៖ ព្រះគ្រីស្តជាព្រះសង្គ្រោះ និងជាជីវិត ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ជាព្រះអម្ចាស់ដ៏មានឫទ្ធានុភាព ហើយមានព្រះជន្មគង់នៅអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ព្រះអង្គជាព្រះសង្គ្រោះនៃពិភពលោក
ទ្រង់ជាជីវិតសម្រាប់មនុស្សជាតិ និងប្រោសអ្នកស្លាប់ឲ្យរស់ឡើងវិញ ។

ដោយសារព្រះគ្រីស្តនេះហើយ
បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូតដ៏ច្រើនកុះករ
លើកតម្កើងអានុភាពដ៏អស្ចារ្យរបស់ព្រះអង្គ
និងសប្បាយរីករាយចំពោះព្រះភ័ក្ត្រព្រះអង្គជានិច្ច ។
យើងខ្ញុំសូមទូលអង្វរ និងច្រៀងកោតសរសើរព្រះអង្គ
ក្នុងអំណរសប្បាយយ៉ាងក្រៃលែង ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !
ព្រះអង្គជាព្រះអម្ចាស់ លើពិភពលោកទាំងមូល
មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។
ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
តាមរយៈព្រះអំណោយទាននៃសក្ការបូជាដែលយើងខ្ញុំបានទទួល
សូមព្រះអង្គប្រទានព្រះហឫទ័យមេត្តាករុណា
ដល់អស់អ្នកបម្រើរបស់ព្រះអង្គ ដែលបានលាចាកលោកនេះហើយ ។
សូមឲ្យអស់អ្នកដែលព្រះអង្គសព្វព្រះហឫទ័យប្រទានអគ្គសញ្ញាជ្រមុជទឹក
បានទទួលជីវិតពោរពេញដោយអំណរសប្បាយអស់កល្បជានិច្ច ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក (Latin p. 614-615) ។

# ខែ តុលា

## ថ្ងៃទី ១ តុលា

# សន្តីតេរេសា នៃព្រះកុមារយេស៊ូ ជាព្រហ្មចារិនី និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Teresæ a Iesu Infante, virginis et Ecclesiæ doctoris**

(បុណ្យរំឭក)

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ ! ព្រះអង្គសព្វព្រះហឫទ័យបើកទ្វារព្រះរាជ្យរបស់ព្រះអង្គ
ឲ្យអស់អ្នកបន្ទាបខ្លួន និងអ្នកតូចតាច ។
ព្រះអង្គក៏ណែនាំយើងខ្ញុំឲ្យប្រព្រឹត្តតាមរបៀបរស់នៅរបស់សន្តីតេរេសា
ដែលយកចិត្តទុកដាក់ចំពោះកិច្ចការដ៏តូចតាចប្រចាំថ្ងៃដែរ ។
សូមព្រះអង្គបង្ហាញឲ្យយើងខ្ញុំឃើញសិរីរុងរឿងរបស់ព្រះអង្គ តាមរយៈពាក្យទូល
អង្វររបស់នាងផង ។

### ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ!
យើងខ្ញុំសូមប្រកាសពីស្នាព្រះហស្តដ៏អស្ចារ្យ
ដែលព្រះអង្គបានបង្ហាញតាមរយៈការរស់នៅរបស់សន្តីតេរេសា ។
ព្រះអង្គគាប់ព្រះហឫទ័យនឹងគុណធម៌របស់សន្តីតេរេសាយ៉ាងណា
សូមព្រះអង្គទតមើលកិច្ចការបម្រើរបស់យើងខ្ញុំដោយអនុគ្រោះយ៉ាងនោះផង ។

### ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គប្រោសឲ្យព្រះកាយព្រះគ្រីស្តដែលយើងខ្ញុំទទួល
បានទៅជាកម្លាំងនៃសេចក្តីស្រឡាញ់ដែលឆេះឆួលក្នុងដួងចិត្តយើងខ្ញុំ
គឺកម្លាំងនៃសេចក្តីស្រឡាញ់នេះហើយ ដែលប្រោសឲ្យសន្តីតេរេសា
ថ្វាយខ្លួនទាំងស្រុងទៅព្រះអង្គ ព្រមទាំងចង់ឲ្យមនុស្សទាំងអស់
បានទទួលព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ ។

# ថ្ងៃទី ២ តុលា

# ទេវទូតអ្នកការពារដ៏វិសុទ្ធ

**Ss. Angelorum Custodum**

(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គដែលមានឧបការគុណហួសពីការស្មាន
សព្វព្រះហឫទ័យចាត់ទេវទូតដ៏វិសុទ្ធមកការពារយើងខ្ញុំ ។
ពេលព្រះអង្គសណ្ដាប់ឮសម្រែកទូលអង្វររបស់យើងខ្ញុំ
សូមទ្រង់មេត្តាការពារយើងខ្ញុំគ្រប់ពេលវេលា តាមរយៈទេវទូតរបស់ព្រះអង្គ
និងប្រោសឲ្យយើងខ្ញុំមានអំណរសប្បាយអស់កល្បជានិច្ច
រួមជាមួយទេវទូតដ៏វិសុទ្ធទាំងឡាយ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយដែលយើងខ្ញុំលើកថ្វាយព្រះអង្គ
នៅថ្ងៃគោរពទេវទូតដ៏វិសុទ្ធទាំងឡាយ ។
ដោយមានទេវទូតរបស់ព្រះអង្គការពារ
សូមប្រោសឲ្យយើងខ្ញុំបានរួចផុតពីគ្រោះកាចនៅពេលនេះ និងទទួលអំណរសប្បាយ
ក្នុងជីវិតអស់កល្បជានិច្ច ។

ធម៌ប្រារព្ធ ៖ លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់តាមរយៈទេវទូតទាំងឡាយ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ជាព្រះអម្ចាស់ដ៏មានឫទ្ធានុភាព ហើយមានព្រះជន្មគង់នៅអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
យើងខ្ញុំសូមលើកតម្កើងព្រះអង្គឥតឈប់ឈរ រួមជាមួយអគ្គទេវទូត
និងអស់ទេវទូតរបស់ព្រះអង្គ ។
ពេលយើងខ្ញុំគោរពកោតសរសើរទេវទូតដ៏វិសុទ្ធ
ដែលគាប់ព្រះហឫទ័យព្រះអង្គ នោះពាក្យកោតសរសើររបស់យើងខ្ញុំ
ត្រឡប់ទៅជាពាក្យកោតសរសើរសិរីរុងរឿងដ៏លើសលប់របស់ព្រះអង្គ ។
កិត្តិយសដ៏ខ្ពង់ខ្ពស់ និងរុងរឿងរបស់ទេវទូតបានបង្ហាញថា
ព្រះជាម្ចាស់អស្ចារ្យណាស់ ពិភពទាំងមូលលើកតម្កើងព្រះអង្គលើសអ្វីៗទាំងអស់
តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។

ដោយព្រះគ្រីស្តនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយ
ទេវទូតដ៏ច្រើនកុះករ ទាំងមានអំណរសប្បាយរីករាយ
កោតសរសើរអានុភាពដ៏អស្ចារ្យរបស់ព្រះអង្គ ដោយសូរស័ព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !

### ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យប្រទានព្រះកាយព្រះគ្រីស្ត
មកចិញ្ចឹមយើងខ្ញុំឲ្យមានជីវិតអស់កល្បជានិច្ច ។
សូមព្រះអង្គមេត្តាដឹកនាំយើងខ្ញុំឆ្ពោះទៅកាន់មាគ៌ានៃការសង្គ្រោះ និងសេចក្តីសុខ
សាន្ត តាមរយៈកិច្ចការរបស់ទេវទូតទាំងឡាយ ។

# ថ្ងៃទី ៤ តុលា

# សន្តប្រ្វង់ស្វ័រ នៅក្រុងអាស៊ីស៊ី

**S. Francisci Assisiensis**

(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យប្រោសឲ្យសន្តប្រ្វង់ស្វ័រ
រស់នៅដូចព្រះគ្រីស្តជាអ្នកទន់ទាប និងជាអ្នកក្រីក្រ ។
នៅពេលយើងខ្ញុំធ្វើដំណើរតាមគន្លងរបស់សន្តប្រ្វង់ស្វ័រ
យើងខ្ញុំក៏ធ្វើដំណើរតាមព្រះបុត្រាដែរ ។
តាមរយៈអំណរសប្បាយនឹងធម៌មេត្តាករុណា
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបានចូលរួមជាមួយព្រះបិតាផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
នៅពេលយើងខ្ញុំលើកតង្វាយទាំងនេះ ថ្វាយព្រះអង្គ
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបានចូលរួម
ក្នុងពិធីប្រារព្ធការអាថ៌កំបាំងនៃព្រះឈើឆ្កាងដោយសមរម្យ
តាមគំរូរបស់សន្តប្រ្វង់ស្វ័រដែលមានចិត្តឆេះឆួលជាប់ជាមួយព្រះឈើឆ្កាង ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យប្រទានអំណោយទានដ៏ពិសិដ្ឋដល់យើងខ្ញុំ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំយកតម្រាប់តាមសន្តប្រ្វង់ស្វ័រ
ដែលមានចិត្តមេត្តាករុណា និងយកចិត្តទុកដាក់ប្រកាសដំណឹងល្អដូចគ្រីស្តទូត ។
សូមប្រោសឲ្យយើងខ្ញុំមានបទពិសោធន៍
អំពីឥទ្ធិពលនៃសេចក្តីស្រឡាញ់របស់ព្រះអង្គ
ហើយសូមឲ្យសេចក្តីស្រឡាញ់នេះ ផ្តល់ការសង្គ្រោះដល់មនុស្សទាំងអស់ ។

# ថ្ងៃទី ៦ តុលា
# សន្តប្រ៊ុយណូ ជាបូជាចារ្យ
**S. Brunonis, presbyteri**

ពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់បព្វជិត (Latin p. 959) ឬពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់គង្វាលមួយរូប (Latin p. 933) ។

## ពាក្យអធិដ្ឋានសរុប
ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គបានត្រាស់ហៅសន្តប្រ៊ុយណូឲ្យថ្វាយខ្លួនទាំងស្រុង
ដោយរស់នៅជាតាបសដើម្បីបម្រើព្រះអង្គ ។
តាមរយៈពាក្យទូលអង្វររបស់លោក សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
ជានិច្ចកាលសម្លឹងឆ្ពោះទៅរកព្រះអង្គតែមួយគត់
ក្នុងចំណោមអ្វីៗដែលតែងតែប្រែប្រួលនៅក្នុងលោកនេះ ។

# ថ្ងៃទី ៧ តុលា
# ព្រះនាងព្រហ្មចារិនីម៉ារី តាមមាលា (សូត្រផ្គាំ)
**Beatæ Mariæ Virginis a Rosario**

(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប
ឱ ព្រះអម្ចាស់យើងខ្ញុំអើយ !
សូមព្រះអង្គប្រទានព្រះអំណោយទានដ៏ថ្លៃថ្លារបស់ព្រះអង្គឲ្យយើងខ្ញុំ
ដោយទេវទូតផ្ដល់ដំណឹងមកថា ព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ
ទ្រង់យាងមកប្រសូតជាមនុស្ស ។
តាមរយៈពាក្យទូលអង្វររបស់ព្រះនាងព្រហ្មចារិនីម៉ារី
ដោយសារព្រះបុត្រារងទុក្ខលំបាក និងសុគតលើឈើឆ្កាង
សូមព្រះអង្គនាំយើងខ្ញុំចូលទៅក្នុងសិរីរុងរឿងរួមជាមួយព្រះគ្រីស្ត
ដែលមានព្រះជន្មរស់ឡើងវិញ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !

សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំមានភាពសមរម្យ  រួមជាមួយតង្វាយដែលយើងខ្ញុំលើកថ្វាយទៅព្រះអង្គ

ដើម្បីគោរពការអាចកំបាំងដ៏អស្ចារ្យរបស់ព្រះបុត្រាតែមួយរបស់ព្រះអង្គ

ហើយសមនឹងទទួលព្រះបន្ទូលសន្យារបស់ព្រះអង្គផង ។

ធម៌ប្រារព្ធទី ១ បុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារី (នៅថ្ងៃបុណ្យ) ទំព័រ ៤៧២ ឬធម៌ប្រារព្ធទី ២ ទំព័រ ៤៧៤ ។

## ពាក្យអរព្រះគុណ

ឱ ព្រះបិតាជាអម្ចាស់យើងខ្ញុំ !

នៅក្នុងអភិបូជានេះ ព្រះអង្គប្រោសឲ្យយើងខ្ញុំប្រកាសពីព្រះបុត្រារបស់ព្រះអង្គដែលសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ ។

ព្រះអង្គប្រោសយើងខ្ញុំឲ្យចូលរួមក្នុងទុក្ខលំបាករបស់ព្រះបុត្រាព្រះអង្គយ៉ាងណា

សូមព្រះអង្គសព្វព្រះហឫទ័យឲ្យយើងខ្ញុំចូលរួមក្នុងសិរីរុងរឿង

របស់ព្រះបុត្រាព្រះអង្គយ៉ាងនោះដែរ ។

## ថ្ងៃទី ៩ តុលា

# សន្តដឺនីស ជាអភិបាល និងសហជីវិន ជាមរណសាក្សី

**Ss. Dionysii, episcopi, et sociorum, martyrum**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីជាច្រើន (Latin p. 909) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គបានចាត់សន្តដឺនីស និងសហជីវិនរបស់លោក
ឲ្យទៅប្រកាសដំណឹងល្អដល់ប្រជាជាតិទាំងឡាយ
ហើយព្រះអង្គប្រទានកម្លាំងដល់អស់លោកដើម្បីបំពេញបេសកកម្ម ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំធ្វើតម្រាប់តាមអស់លោក
ដោយមិនជាប់ចិត្តនឹងទ្រព្យសម្បត្តិក្នុងលោកនេះ ហើយព្យាយាមពុះពារឧបសគ្គទាំងឡាយ ។

# សន្តយ៉ូហាន លេអូណាឌី ជាបូជាចារ្យ

**S. Ioannis Leonardi, presbyteri**

ពាក្យអធិដ្ឋានរួមសម្រាប់អ្នកគង្វាល ៖ សម្រាប់សាសនទូត (Latin p. 938) ឬពាក្យអធិដ្ឋានរួមសម្រាប់សន្ត: សន្តី ៖ សម្រាប់អ្នកដែលប្រព្រឹត្តកិច្ចការធម៌មេត្តាករុណា (Latin p. 963) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់ជាព្រះបិតា !
ព្រះអង្គប្រទានអំណោយទានគ្រប់យ៉ាងដល់សន្តយ៉ូហាន លេអូណាឌីជាបូជាចារ្យ
ដើម្បីប្រកាសដំណឹងល្អដល់មនុស្សគ្រប់ជាតិសាសន៍ ។
តាមរយៈពាក្យទូលអង្វររបស់លោក សូមព្រះអង្គប្រោសឲ្យព្រះសហគមន៍
មានជំនឿពិតប្រាកដលើព្រះអង្គ និងរីកចម្រើនឡើងនៅគ្រប់ទីកន្លែង ។

# ថ្ងៃទី ១១ តុលា
# សន្តយ៉ូហាន ទី២៣ ជាសម្ដេចប៉ាប
**S. John XXIII, papæ**
(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់អ្នកគង្វាល ៖ សម្រាប់សម្ដេចប៉ាប ៖ (Latin p. 927) ។

## ពាក្យអធិដ្ឋានសរុប
ឱ ព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ
និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច !
ព្រះអង្គសព្វព្រះហឫទ័យប្រោសឲ្យសម្ដេចប៉ាប យ៉ូហាន
ពោរពេញដោយសុភមង្គល មានជីវិតយ៉ាងត្រចះត្រចង់
តាមគំរូរបស់ព្រះគ្រីស្ដដែលជាគង្វាលដ៏ល្អ នៅលើពិភពលោកទាំងមូល ។
តាមរយៈពាក្យទូលអង្វររបស់លោក សូមព្រះអង្គប្រោសឲ្យយើងខ្ញុំអាចបង្ហាញ
ធម៌មេត្តាករុណាដ៏បរិបូរណ៍របស់ព្រះអង្គដល់មនុស្សលោក ។

## ពាក្យថ្វាយតង្វាយ
ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គទទួលតង្វាយ និងពាក្យទូលអង្វររបស់ព្រះសហគមន៍ដោយអនុគ្រោះ ។
សូមឲ្យយើងខ្ញុំឆ្លងផុតពីលោកនេះ ទៅចូលរួមក្នុងសិរីរុងរឿងនៃស្ថានបរមសុខ
ដោយជាប់ចិត្តជាមួយព្រះអង្គ ។

## ពាក្យអរព្រះគុណ
ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំសូមឱនកាយទូលអង្វរព្រះអង្គជាព្រះដ៏ខ្ពង់ខ្ពស់បំផុត ។
ព្រះអង្គប្រទានព្រះកាយ និងព្រះលោហិតព្រះបុត្រាព្រះអង្គ
មកចិញ្ចឹមយើងខ្ញុំយ៉ាងណា សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
បានចូលរួមចំណែកក្នុងទេវភាពរបស់ព្រះអង្គយ៉ាងនោះដែរ ។

ថ្ងៃទី ១៤ តុលា

# សន្តកាលីទូស ជាសម្តេចប៉ាប និងជាមរណសាក្សី

**S. Callisti I, papæ et martyris**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីមួយរូប ៖ (Latin p. 915) ឬ ពាក្យអធិដ្ឋានរួមសម្រាប់អ្នកគង្វាល ៖ សម្រាប់សម្តេចប៉ាប (Latin p. 927) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !

ព្រះអង្គសព្វព្រះហឫទ័យឲ្យសន្តកាលីទូស ជាសម្តេចប៉ាបបម្រើព្រះសហគមន៍
និងយកចិត្តទុកដាក់ដល់ការបញ្ចុះសពរបស់គ្រីស្តបរិស័ទ ។
ដោយសារសក្ខីភាពនៃជំនឿរបស់លោក សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានកម្លាំង
បានរួចផុតពីចំណងនៃភាពរលួយ និងទទួលមរតកដែលមិនចេះរលួយ ។

# ថ្ងៃទី ១៥ តុលា

# សន្ដីតេរេសានៃព្រះយេស៊ូ ជាព្រហ្មចារិនី នៅក្រុងអាវីឡា និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Teresiæ a Iesu, virginis et Ecclesiæ doctoris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់ជាព្រះបិតា !

ព្រះអង្គសព្វព្រះហឫទ័យប្រទានព្រះវិញ្ញាណឲ្យសន្ដីតេរេសានៃព្រះយេស៊ូ

បង្ហាញផ្លូវឲ្យព្រះសហគមន៍រស់នៅតាមរបៀបល្អឥតខ្ចោះ ។

ដោយសារផលផ្លែនៃការបង្រៀនរបស់សន្ដីតេរេសា សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ

មានកម្លាំង និងឆេះឆួលទៅដោយភាពវិសុទ្ធដ៏ពិតប្រាកដជានិច្ច ។

ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !

ព្រះអង្គគាប់ព្រះហឫទ័យនឹងសន្ដីតេរេសា

ដែលបានបម្រើព្រះអង្គដោយចិត្តភក្ដី ។

សូមព្រះអង្គជាព្រះដ៏ខ្ពង់ខ្ពស់បំផុត

សព្វព្រះហឫទ័យទទួលតង្វាយយើងខ្ញុំដោយអនុគ្រោះ ។

ពាក្យអរព្រះគុណ

ឱ ព្រះបិតាជាអម្ចាស់យើងខ្ញុំ !

ព្រះអង្គប្រទាននំបុ័ងនៃស្ថានបរមសុខមកចិញ្ចឹមយើងខ្ញុំ

ដែលជាព្រះសហគមន៍ស្ដាប់បង្គាប់ព្រះអង្គ ។

សូមព្រះអង្គប្រោសឲ្យយើងខ្ញុំរស់នៅតាមគំរូសន្ដីតេរេសា

និងមានអំណរសប្បាយច្រៀងលើកតម្កើងព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គអស់

កល្បជានិច្ច ។

# ថ្ងៃទី ១៦ តុលា

# សន្តីហេដវីគ ជាបព្វជិតា

**S. Hedvigis, religiosæ**

ពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់បព្វជិតា (Latin p. 961) ឬសម្រាប់ សន្តី ៖ (Latin p. 966) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ការរស់នៅដ៏អស្ចារ្យរបស់សន្តីហេដវីគ
ជាគំរូឲ្យយើងខ្ញុំចេះបន្ទាបខ្លួន សម្រាប់មនុស្សទាំងអស់យ៉ាងណា
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបានទទួលអំណោយពីស្ថានបរមសុខ
តាមពាក្យទូលអង្វររបស់នាងយ៉ាងនោះដែរ ។

# សន្តីម៉ាការីត ម៉ារី អាឡាកុក ជាព្រហ្មចារិនី

**S. Margaritæ Mariæ Alacoque, virginis**

ពាក្យអធិដ្ឋានរួមសម្រាប់ព្រហ្មចារិនី ៖ សម្រាប់ព្រហ្មចារិនីមួយរូប ៖ (Latin p. 947) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គមានព្រះហឫទ័យមេត្តាករុណាដ៏លើសលប់ចំពោះមនុស្សលោក ។
សូមព្រះអង្គចាក់បង្ហូរព្រះវិញ្ញាណលើយើងខ្ញុំ ដូចព្រះអង្គបានបង្ហូរលើសន្តីម៉ាការីត
ដើម្បីឲ្យយើងខ្ញុំស្គាល់សេចក្ដីស្រឡាញ់ដ៏ធំធេងរបស់ព្រះគ្រីស្ត
ហើយសូមឲ្យយើងខ្ញុំបានពោរពេញដោយភាពដ៏វិសុទ្ធរបស់ព្រះអង្គ ។

# ថ្ងៃទី ១៧ តុលា
# សន្តអ៊ីញ៉ាស នៅក្រុងអន់ទីយ៉ូក ជាអភិបាល និងជាមរណសាក្សី

**S. Ignatii Antiocheni, episcopi et martyris**

(បុណ្យរំឭក)

### ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ និងមានព្រះជន្មគង់នៅជានិច្ច !
ព្រះអង្គប្រោសប្រទានឲ្យព្រះសហគមន៍ជាព្រះកាយព្រះគ្រីស្ត
មានកិត្តិយសដោយសារសក្ខីភាពរបស់មរណសាក្សីដ៏វិសុទ្ធ ។
នៅថ្ងៃនេះ យើងខ្ញុំប្រារព្ធបុណ្យសន្តអ៊ីញ៉ាស
ដែលបានទទួលសិរីរុងរឿងអស់កល្បជានិច្ច ដោយសាររងទុក្ខលំបាក ។
តាមរយៈការរងទុក្ខលំបាកនេះ សូមព្រះអង្គការពារយើងខ្ញុំអស់មួយជីវិតផង ។

### ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
ព្រះអង្គគាប់ព្រះហឫទ័យនឹងសន្តអ៊ីញ៉ាស
ដែលរងទុក្ខលំបាក និងបូជាជីវិតជាមរណសាក្សី ។
លោកជាគ្រាប់ស្រូវរបស់ព្រះគ្រីស្ត ដែលបានទៅជានំប៉័ងឥតសៅហ្មង ។
សូមព្រះអង្គសព្វព្រះហឫទ័យទទួលសក្ការបូជា
ពីចិត្តស្មោះត្រង់របស់យើងខ្ញុំដោយអនុគ្រោះ ។

### ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ព្រះអង្គបានប្រទាននំប៉័ងជាអាហារនៃស្ថានបរមសុខឲ្យយើងខ្ញុំ ។
នៅថ្ងៃបុណ្យរំឭកសន្តអ៊ីញ៉ាស សូមព្រះអង្គផ្តល់កម្លាំងឲ្យយើងខ្ញុំ
ទៅជាគ្រីស្តបរិស័ទ ដោយសារជំនឿ និងជីវិតរស់នៅប្រចាំថ្ងៃ ។

# ថ្ងៃទី ១៨ តុលា

# សន្តលូកា អ្នកនិពន្ធគម្ពីរដំណឹងល្អ

**S. LUCÆ EVANGELISTÆ**

(បុណ្យរំឭក)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាអម្ចាស់ !
ព្រះអង្គសព្វព្រះហឫទ័យជ្រើសរើស សន្តលូកា ឲ្យប្រៀនប្រដៅ
និងនិពន្ធពីអាថ៌កំបាំងនៃសេចក្តីស្រឡាញ់របស់ព្រះអង្គចំពោះអ្នកក្រីក្រ ។
សូមព្រះអង្គប្រោសឲ្យអស់អ្នកជឿមានកិត្តិយសក្នុងព្រះនាមព្រះអង្គ
បេះស៊ូទ្រាំដោយមានចិត្តតែមួយ និងវិញ្ញាណតែមួយ ។
សូមព្រះអង្គប្រណីសន្ដោសឲ្យប្រជាជាតិទាំងឡាយ បានទទួលការសង្គ្រោះពីព្រះអង្គ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គផ្តល់ព្រះអំណោយទានឲ្យយើងខ្ញុំមានសេរីភាពបម្រើព្រះអង្គអស់ពីចិត្ត ។
នៅថ្ងៃបុណ្យរំឭកសន្តលូកា សូមព្រះអង្គប្រទានឲ្យយើងខ្ញុំមានសេចក្តីសុខសាន្ត
និងទទួលសិរីរុងរឿងរបស់ព្រះអង្គ តាមរយៈតង្វាយដែលយើងខ្ញុំលើកថ្វាយព្រះអង្គ ។

ធម៌ប្រារព្ធទី២ បុណ្យគោរពគ្រីស្តទូត ទំព័រ ៤៧៦ ។

## ពាក្យអរព្រះគុណ

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
សូមឲ្យព្រះកាយព្រះគ្រីស្តដែលយើងខ្ញុំបានទទួលពីតុសក្ការបូជា
ប្រោសឲ្យយើងខ្ញុំទៅជាជនដ៏វិសុទ្ធ ។
សូមព្រះអង្គផ្តល់កម្លាំងដល់យើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំមានជំនឿរឹងមាំ
តាមរយៈព្រះបន្ទូលដំណឹងល្អដែលសន្តលូកាបានប្រកាស ។

## ថ្ងៃទី ១៩ តុលា

# សន្តយ៉ូហាន ដឺ ប្រេប៊ឺហ្វ និងសន្តអ៊ីសាក យ៉ូក ជាបូជាចារ្យ និងសហជីវិន ជាមរណសាក្សី

**Ss. Ioannis de Brébeuf et Isaac Jogues, presbyterorum, et sociorum, martyrum**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី៖ សម្រាប់សាសនទូតមរណសាក្សី៖ (Latin p. 922) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យបង្ហាញសេចក្ដីសង្ឃឹមលើព្រះរាជ្យព្រះអង្គ
តាមរយៈកិច្ចការដ៏លំបាករបស់សន្តយ៉ូហាន ដឺប្រេប៊ឺហ្វ និងសន្តអ៊ីសាក យ៉ូក
ព្រមទាំងសហការី និងតាមរយៈការបង្ហូរឈាមរបស់អស់លោក ។
សូមព្រះអង្គប្រទានឲ្យគ្រីស្តបរិស័ទមានជំនឿរឹងមាំពីមួយថ្ងៃទៅមួយថ្ងៃ
តាមរយៈពាក្យទូលអង្វររបស់អស់លោក ។

# សន្តប៉ូល នៃព្រះឈើឆ្កាង ជាបូជាចារ្យ

**S. Pauli a Cruce, presbyteri**

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យសន្តប៉ូល ជាបូជាចារ្យ
ស្រឡាញ់ព្រះឈើឆ្កាងតែមួយគត់ ។
សូមព្រះអង្គប្រោសប្រណីឲ្យយើងខ្ញុំម្នាក់ៗ
មានកម្លាំងលីឈើឆ្កាងរបស់ខ្លួន ដោយសេចក្ដីក្លាហាន តាមគំរូរបស់លោក ។

ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
នៅថ្ងៃរំឮកសន្តប៉ូលនៃព្រះឈើឆ្កាង
សូមព្រះអង្គទតមើលតង្វាយដែលយើងខ្ញុំលើកថ្វាយទៅព្រះអង្គ ។
សូមព្រះអង្គប្រោសយើងខ្ញុំដែលប្រារព្ធការអាថ៌កំបាំង
នៃទុក្ខលំបាករបស់ព្រះយេស៊ូ ឲ្យយកតម្រាប់តាមសន្តប៉ូលផង ។

ពាក្យអរព្រះគុណ

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យយើងខ្ញុំស្គាល់
គម្រោងការដ៏អស្ចារ្យនៃព្រះឈើឆ្កាងនៅក្នុងជីវិតសន្តប៉ូល ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបានទទួលកម្លាំងពីសក្ការបូជានេះ
ដោយជាប់ចិត្តជាមួយព្រះគ្រីស្ត និងបម្រើព្រះសហគមន៍
ដើម្បីឲ្យមនុស្សទាំងអស់ទទួលការសង្គ្រោះពីព្រះអង្គ ។

## ថ្ងៃទី ២២ តុលា

# សន្តយ៉ូហាន ប៉ូល ទី២ ជាសម្ដេចប៉ាប

**S. Ioannis Paul II, Papæ**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់សម្ដេចប៉ាប ៖ (Latin p. 927) ។

ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គសព្វព្រះហឫទ័យប្រោសឲ្យសន្តយ៉ូហាន ប៉ូល ទីពីរ ធ្វើជាសម្ដេចប៉ាប
ណែនាំព្រះសហគមន៍នៅទូទាំងសកលលោក ។
តាមការប្រៀនប្រដៅរបស់លោក សូមបើកចិត្តយើងខ្ញុំ
ឲ្យទទួលការប្រណីសន្ដោសពីព្រះគ្រីស្ត ជាព្រះសង្គ្រោះតែមួយរបស់មនុស្សលោក ។

ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យគោរពព្រះអំណោយទានរបស់ព្រះអង្គអស់ពីចិត្ត ។
តាមរយៈព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គ
សូមប្រោសឲ្យអគ្គសញ្ញាព្រះកាយព្រះគ្រីស្ដលាងជម្រះយើងខ្ញុំជាអ្នកបម្រើ
បានស្អាតបរិសុទ្ធ ។

ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ដោយបានទទួលព្រះកាយព្រះគ្រីស្ដដែលមកពីស្ថានបរមសុខ
សូមឲ្យយើងខ្ញុំយកចិត្តទុកដាក់នឹងព្រះអំណោយទានផ្សេងៗនៅពេលនេះ
ហើយរៀបចំខ្លួនដើម្បីទទួលព្រះអំណោយទានអស់កល្បជានិច្ច ។

## ថ្ងៃទី ២៣ តុលា

# សន្តយ៉ូហាន នៅកាពីស្រ្តាណូ ជាបូជាចារ្យ

**S. Ioannis de Capestrano, presbyteri**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់សាសនទូត ៖ (Latin p. 938) ឬ ពាក្យអធិដ្ឋានរួមសម្រាប់សន្ត: សន្តី ៖ សម្រាប់បព្វជិត (Latin p. 961) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គបានជ្រើសរើស សន្តយ៉ូហាន នៅកាពីស្រ្តាណូ
ឲ្យជួយសម្រាលទុក្ខប្រជារាស្ត្ររបស់ព្រះអង្គដែលកើតទុក្ខព្រួយ ។
សូមព្រះអង្គការពារព្រះសហគមន៍របស់ព្រះអង្គ
និងថែរក្សាឲ្យបានប្រកបដោយសេចក្តីសុខសាន្តជារៀងរហូត ។

## ថ្ងៃទី ២៤ តុលា

# សន្តអន់តូនី ម៉ារីក្លារេ ជាអភិបាលព្រះសហគមន៍

**S. Antonii Mariæ Claret, episcopi**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់សាសនទូត ៖ (Latin p. 938) ឬ សម្រាប់អភិបាល (Latin p. 929) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យផ្តល់កម្លាំងឲ្យសន្តអន់តូនី ម៉ារីក្លារេ ជាអភិបាល
ដើម្បីប្រកាសព្រះបន្ទូលដំណឹងល្អដល់ប្រជារាស្ត្រព្រះអង្គ
ដោយលោកស្រឡាញ់អ្នកតូចតាច និងមានចិត្តអត់ធ្មត់ ។
តាមរយៈពាក្យទូលអង្វររបស់លោក សូមព្រះអង្គប្រោសយើងខ្ញុំ
ឲ្យបេះស្វែងរកអ្វីៗដែលជារបស់ព្រះអង្គ និងសូមឲ្យយើងខ្ញុំជាប់ចិត្តជាមួយព្រះអង្គ
ដើម្បីជាប្រយោជន៍ដល់បងប្អូនជាច្រើន បានទៅជាបុត្រធីតារួមជាមួយព្រះគ្រីស្ត ។

# ថ្ងៃទី ២៨ តុលា

# សន្តស៊ីម៉ូន និងសន្តយូដា ជាគ្រីស្តទូត

**SS. SIMONIS ET IUDÆ, APOSTOLORUM**

(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គបានប្រោសយើងខ្ញុំឲ្យស្គាល់ព្រះនាមព្រះអង្គ
តាមរយៈការប្រកាសដំណឹងល្អរបស់គ្រីស្តទូត ។
សូមព្រះអង្គសព្វព្រះហឫទ័យប្រោសឲ្យព្រះសហគមន៍
បានរីកចម្រើនឡើងជារៀងរហូត ដោយមានអ្នកជឿកាន់តែកើនឡើងៗ
តាមរយៈពាក្យទូលអង្វររបស់គ្រីស្តទូតផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះជាអម្ចាស់អើយ !
សូមព្រះអង្គទទួលពាក្យអង្វររបស់យើងខ្ញុំ
នៅថ្ងៃគោរពសន្តស៊ីម៉ូន និងសន្តយូដា ជាគ្រីស្តទូតដ៏វិសុទ្ធ ។
សូមព្រះអង្គមេត្តាណែនាំយើងខ្ញុំឲ្យថ្វាយសក្ការបូជានេះ ដោយសមរម្យ ។

ធម៌ប្រារព្ធ បុណ្យគោរពគ្រីស្តទូត ទំព័រ ៤៧៦-៤៧៨ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ ! ព្រះអង្គបានប្រទានព្រះកាយព្រះគ្រីស្តឲ្យយើងខ្ញុំ ។
យើងខ្ញុំឱនកាយអង្វរព្រះអង្គ សូមប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកបំភ្លឺចិត្តគំនិតយើងខ្ញុំ ។
នៅពេលយើងខ្ញុំគោរពគ្រីស្តទូតស៊ីម៉ូន និងយូដា ដែលរងទុក្ខលំបាក
និងទទួលសិរីរុងរឿង សូមព្រះអង្គថែរក្សាយើងខ្ញុំ
ក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គផង ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក (Latin p. 613-614) ។

# ខែ វិច្ឆិកា

## ថ្ងៃទី ១ វិច្ឆិកា

# បុណ្យគោរពសន្តបុគ្គលទាំងឡាយ

**OMNIUM SANCTORUM**

(បុណ្យឱឡារិក)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ
និងមានព្រះជន្មគង់នៅជានិច្ច !
នៅថ្ងៃនេះ យើងខ្ញុំសូមគោរពដល់គុណធម៌របស់សន្តបុគ្គលទាំងឡាយ
ដែលជាព្រះអំណោយទានរបស់ព្រះអង្គ ។
តាមរយៈពាក្យទូលអង្វររបស់សន្តបុគ្គលទាំងឡាយ
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបានរួចពីបាប និងបានគាប់ព្រះហឫទ័យព្រះអង្គ ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
សូមឲ្យតង្វាយដែលយើងខ្ញុំលើកថ្វាយ
នៅថ្ងៃគោរពសន្តបុគ្គលទាំងឡាយ បានគាប់ព្រះហឫទ័យព្រះអង្គ ។
យើងខ្ញុំជឿថា សន្តបុគ្គលទទួលជីវិតអស់កល្បជានិច្ចយ៉ាងណា
សូមឲ្យយើងខ្ញុំដឹងច្បាស់ថា សន្តបុគ្គលទាំងនោះជួយយើងខ្ញុំ
ឲ្យទទួលការសង្គ្រោះយ៉ាងនោះដែរ ។

ធម៌ប្រារព្ធ ៖ សិរីរុងរឿងនៃក្រុងយេរូសាឡឹមជាមាតារបស់យើង ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

ប. សូមអរព្រះគុណព្រះអម្ចាស់ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាម្ចាស់ដ៏មានឫទ្ធានុភាព និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។
ថ្ងៃនេះ ព្រះអង្គប្រទានឲ្យយើងខ្ញុំប្រារព្ធពិធីបុណ្យប្រចាំក្រុងរបស់ព្រះអង្គ
គឺជាក្រុងយេរូសាឡឹមនៅស្ថានបរមសុខដែលជាមាតារបស់យើងខ្ញុំ ។
នៅក្រុងនេះ បងប្អូនយើងខ្ញុំច្រើនឥតគណនាពាក់មកុដ
ច្រៀងកោតសរសើរព្រះអង្គអស់កល្បជានិច្ច ។
យើងខ្ញុំស្រេកឃ្លានចង់ធ្វើបូជនីយចរទៅកាន់ក្រុងនោះដោយជំនឿ
និងមានអំណរសប្បាយក្នុងសិរីរុងរឿងដែលព្រះអង្គបានប្រទាន
ឲ្យអស់សមាជិកព្រះសហគមន៍ដែលព្រះអង្គជ្រើសរើស ។
តាមរយៈអស់សន្តបុគ្គល ព្រះអង្គប្រទានទាំងកម្លាំង
ទាំងគំរូល្អនៅក្នុងភាពទន់ខ្សោយរបស់យើងខ្ញុំ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយទេវទូតជាច្រើន
ព្រមទាំងសន្តបុគ្គលទាំងឡាយ លើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយសូរសព្ទតែមួយថា ៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !

ពាក្យអរព្រះគុណ

ឱ ព្រះជាម្ចាស់អើយ !
យើងខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ ជាព្រះដ៏វិសុទ្ធតែមួយព្រះអង្គគត់
ដែលបង្ហាញការអស្ចារ្យតាមរយៈសន្តបុគ្គលទាំងឡាយ ។
សូមព្រះអង្គសព្វព្រះហឫទ័យប្រទានភាពដ៏វិសុទ្ធ
ប្រកបដោយសេចក្ដីស្រឡាញ់មកយើងខ្ញុំ
និងប្រោសឲ្យយើងខ្ញុំចេញពីតុនៃបូជនីយសក៌
ឆ្ពោះទៅកាន់ពិធីជប់លៀងឯស្ថានបរមសុខដែលជាមាតុភូមិរបស់យើងខ្ញុំ ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក (Latin p. 614) ។

អភិបូជាតាមប្រាថ្នាសម្រាប់សន្តបុគ្គលទាំងឡាយ សូមមើលក្នុងក្បួនពិធី cf. infra, p. 1187 ។

# ថ្ងៃទី ២ វិច្ឆិកា

# បុណ្យឧទ្ទិសដល់មរណបុគ្គលទាំងឡាយ

**IN COMMENORATIONE OMNIUM FIDELIUM DEFUNCTORUM**

មានប្រជុំគ្នាច្រើនចូលរួមក្នុងប្រារព្ធពិធីនេះ អាចប្រើតាមចិត្តប្រាថ្នា ។ ទោះបីជា ថ្ងៃទី២ វិច្ឆិកា ចំនឹងថ្ងៃអាទិត្យ គឺត្រូវធ្វើពិធីអភិបូជាសម្រាប់អស់អ្នកជឿដែលបានលាចាកលោកទៅហើយ ។

១

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់ជាព្រះបិតា !
សូមព្រះអង្គស្ដាប់ពាក្យទូលអង្វររបស់យើងខ្ញុំដោយអនុគ្រោះ ។
ជំនឿរបស់យើងខ្ញុំលើព្រះបុត្រាដែលព្រះបិតាលើកឡើងពីចំណោមមនុស្សស្លាប់
កាន់តែចម្រើនឡើងយ៉ាងណា សូមឲ្យសេចក្ដីសង្ឃឹមរបស់យើងខ្ញុំ
លើអ្នកបម្រើរបស់ព្រះអង្គដែលបានលាចាកលោកនេះទៅហើយ នឹងរស់ឡើងវិញ
កាន់តែរឹងមាំយ៉ាងនោះដែរ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាអម្ចាស់ !
សូមព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយដែលយើងខ្ញុំថ្វាយ
សម្រាប់អស់អ្នកបម្រើរបស់ព្រះអង្គដែលសម្រាកក្នុងព្រះគ្រីស្ត ។
សូមព្រះអង្គប្រោសអ្នកទាំងនោះ ឲ្យបានរួចពីចំណងនៃសេចក្ដីស្លាប់
ដោយសារសក្ការបូជាតែមួយនេះ
សូមឲ្យអ្នកទាំងនោះសមនឹងទទួលជីវិតអស់កល្បជានិច្ច ។

ធម៌ប្រារព្ធ សម្រាប់មរណបុគ្គល ទំទំព័រ ៥០៤-៥១២ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
តាមរយៈព្រះអំណោយទាននៃសក្ការបូជាដែលយើងខ្ញុំបានទទួល
សូមព្រះអង្គប្រទានព្រះហឫទ័យមេត្តាករុណាដល់អស់អ្នកបម្រើរបស់ព្រះអង្គ
ដែលបានលាចាកលោកនេះហើយ ។
សូមឲ្យអស់អ្នកដែលព្រះអង្គសព្វព្រះហឫទ័យប្រទានអគ្គសញ្ញាជ្រមុជទឹក
បានទទួលជីវិតពោរពេញដោយអំណរសប្បាយអស់កល្បជានិច្ច ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក (Latin p. 615) ។

### ២

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គជាសិរីរុងរឿងរបស់អស់អ្នកជឿ និងជាជីវិតរបស់មនុស្សសុចរិត ។
ព្រះបុត្រាព្រះអង្គបានសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
ប្រកបដោយសិរីរុងរឿង ព្រមទាំងសង្គ្រោះយើងខ្ញុំទាំងអស់គ្នា ។
សូមព្រះអង្គទតមើលអ្នកបម្រើរបស់ព្រះអង្គដែលបានលាចាកលោកនេះ
ដោយប្រកាសអំពីការអាថ៌កំបាំងដ៏អស្ចារ្យដែលអ្នកទាំងនោះនឹងរស់ឡើងវិញ
សូមប្រោសឲ្យគេសមនឹងទទួលអំណរសប្បាយអស់កល្បជានិច្ចផង ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាព និងពោរពេញដោយធម៌មេត្តាករុណា !
តាមរយៈតង្វាយនៃសក្ការបូជានេះ សូមព្រះអង្គលាងជម្រះអ្នកបម្រើរបស់ព្រះអង្គ
ដែលលាចាកលោកនេះឲ្យរួចពីបាប ក្នុងព្រះលោហិតព្រះគ្រីស្តផង
ព្រោះព្រះអង្គសព្វព្រះហឫទ័យលើកលែងទោសឥតឈប់ឈរ
ឲ្យអស់អ្នកដែលព្រះអង្គបានជម្រះក្នុងអគ្គសញ្ញាជ្រមុជទឹក ។

ធម៌ប្រារព្ធ សម្រាប់មរណបុគ្គល ទំព័រ ៥០៤-៥១២ ។

### ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យយើងខ្ញុំទទួលព្រះកាយព្រះគ្រីស្ត
ដែលបានបូជាព្រះជន្មសម្រាប់យើងខ្ញុំ
ហើយមានព្រះជន្មរស់ឡើងវិញប្រកបដោយសិរីរុងរឿង ។
យើងខ្ញុំសូមឱនកាយអង្វរព្រះអង្គ សម្រាប់អស់អ្នកបម្រើរបស់ព្រះអង្គ
ដែលលាចាកលោកនេះទៅហើយ សូមព្រះអង្គប្រោសឲ្យអស់អ្នកទាំងនោះ
បានជ្រះស្អាតពីបាប តាមរយៈគម្រោងការដ៏អស្ចារ្យនៃបុណ្យចម្លង
និងសូមប្រោសឲ្យគេទទួលសិរីរុងរឿងនៃជីវិតរស់ឡើងវិញផង ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក (Latin p. 615) ។

៣

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះបិតាជាម្ចាស់អើយ !
ព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គឲ្យឈ្នះសេចក្តីស្លាប់
ហើយឆ្លងទៅកាន់ព្រះរាជ្យនៃស្ថានបរមសុខ ។
ដោយព្រះអង្គបានឈ្នះសេចក្តីស្លាប់
សូមទ្រង់ប្រោសឲ្យអ្នកបម្រើរបស់ព្រះអង្គ ដែលបានលាចាកលោកនេះ
បានយល់ព្រះភក្ត្រព្រះអង្គ ដែលជាប្រភពនៃជីវិត និងជាព្រះសង្គ្រោះ ។

### ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ !
ព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយនៃសក្ការបូជាពីយើងខ្ញុំ
សម្រាប់អ្នកបម្រើរបស់ព្រះអង្គ ដែលបានសម្រាន្តក្នុងអង្គព្រះគ្រីស្ត ។
តាមរយៈសក្ការបូជាតែមួយនេះ សូមព្រះអង្គប្រោសអ្នកទាំងនោះ
ឲ្យរួចពីចំណងនៃសេចក្តីស្លាប់ ហើយប្រោសគេឲ្យសមនឹង
ទទួលជីវិតអស់កល្បជានិច្ច ។

ធម៌ប្រារព្ធ សម្រាប់មរណបុគ្គល ទំព័រ ៥០៤-៥១២ ។

ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !

តាមរយៈព្រះអំណោយទាននៃសក្ការបូជាដែលយើងខ្ញុំបានទទួល

សូមព្រះអង្គប្រោសឲ្យអ្នកបម្រើព្រះអង្គ ដែលបានលាចាកលោកនេះ

បានទទួលធម៌មេត្តាករុណារបស់ព្រះអង្គ ។

សូមប្រោសឲ្យអស់អ្នកដែលទទួលព្រះអំណោយទាននៃអគ្គសញ្ញាជ្រមុជទឹក

បានពោរពេញដោយអំណរសប្បាយអស់កល្បជានិច្ចផង ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក (Latin p. 615) ។

## ថ្ងៃទី ៣ វិច្ឆិកា

# សន្តម៉ាតាំង ដេប៉ូរេស ជាបព្វជិត

**S. Martini de Porres, religiosi**

ពាក្យអធិដ្ឋានរួមសម្រាប់សន្តបុគ្គល ៖ សម្រាប់បព្វជិត ៖ (Latin p. 961) ។

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !

ព្រះអង្គសព្វព្រះហឫទ័យណែនាំសន្តម៉ាតាំង ឲ្យដើរតាមរបៀបដាក់ខ្លួន

ឆ្ពោះទៅទទួលសិរីរុងរឿងនៅស្ថានបរមសុខ ។

សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ

ធ្វើតាមគំរូរបស់លោកក្នុងជីវិតសព្វថ្ងៃនេះ ហើយសូមឲ្យយើងខ្ញុំសមនឹងទទួល

អំណរសប្បាយ

រួមជាមួយលោកឯស្ថានបរមសុខ ។

# ថ្ងៃទី ៤ វិច្ឆិកា

# សន្តហ្សាល បូរ៉ូមេ ជាអភិបាល

**S. Caroli Borromeo, episcopi**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល ៖ (Latin p. 929) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គរក្សាទុកក្នុងចំណោមប្រជារាស្ត្ររបស់ព្រះអង្គ
នូវវិញ្ញាណដែលព្រះអង្គបំពេញឲ្យសន្តហ្សាល បូរ៉ូមេ ជាអភិបាល
ដើម្បីឲ្យព្រះសហគមន៍មានកម្លាំងថ្មីជារៀងរហូត ។
សូមព្រះអង្គប្រោសឲ្យព្រះសហគមន៍មានលក្ខណៈដូចព្រះគ្រីស្ត ដើម្បីបង្ហាញព្រះភក្ត្រព្រះអង្គឲ្យមនុស្សលោកស្គាល់ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ ! នៅថ្ងៃបុណ្យរំឭកសន្តហ្សាល
សូមព្រះអង្គទតមើលតង្វាយនៅលើតុសក្ការបូជាដោយអនុគ្រោះ ។
តាមរយៈសក្ការបូជា ព្រះអង្គសព្វព្រះហឫទ័យប្រោសឲ្យសន្តហ្សាល
ទៅជាគង្វាលដែលយកចិត្តទុកដាក់បម្រើព្រះសហគមន៍
ដោយមានគុណធម៌ដ៏ល្អប្រសើរ ។
សូមព្រះអង្គប្រោសឲ្យព្រះសហគមន៍ទទួលបាន
ផលផ្លែសម្បូរហូរហៀរក្នុងកិច្ចការប្រចាំថ្ងៃ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ ! យើងខ្ញុំទូលអង្វរព្រះអង្គ
សូមឲ្យព្រះកាយ និងព្រះលោហិតដែលយើងខ្ញុំបានទទួលក្នុងអភិបូជានេះ
ប្រោសឲ្យយើងខ្ញុំមានការប្ដេជ្ញាចិត្តដូចសន្តហ្សាល
ដែលបម្រើព្រះសហគមន៍ដោយមានចិត្តស្មោះត្រង់
និងពោរពេញដោយធម៌មេត្តាករុណាផង ។

# ថ្ងៃទី ៩ វិច្ឆិកា

# បុណ្យរំឭកថ្ងៃឆ្លងព្រះវិហារបាស៊ីលីកា ឡាតេរ៉ង់

**IN DEDICATIONE BASILICÆ LATERANENSIS**

(បុណ្យ)

នៅក្នុងបុណ្យរំឭកថ្ងៃឆ្លងព្រះវិហារបាស៊ីលីកានេះ ត្រូវថ្វាយអភិបូជា តាមក្បួនពិធីសម្រាប់បុណ្យរំឭកឆ្លងព្រះវិហារ (Latin p. 891) ។

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គបានជ្រើសរើសថ្មដែលមានជីវិត
ដើម្បីរៀបចំព្រះដំណាក់អស់កល្បជានិច្ចសម្រាប់ព្រះរាជ្យព្រះអង្គ ។
សូមព្រះអង្គបង្កើនព្រះហឫទ័យប្រណីសន្ដោសដល់ព្រះសហគមន៍
ដើម្បីឲ្យអស់អ្នកជឿលើព្រះអង្គ មានចំនួនកើនឡើង
និងអាចកសាងក្រុងយេរូសាឡឹមនៅស្ថានបរមសុខ ។

សូត្រធម៌ប្រកាសជំនឿ នៅពេលបុណ្យនេះត្រូវចំថ្ងៃអាទិត្យ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយ
ដែលយើងខ្ញុំលើកថ្វាយដោយអនុគ្រោះ ។
សូមឲ្យអស់អ្នកដែលទូលអង្វរព្រះអង្គ
អាចទទួលកម្លាំងពីអគ្គសញ្ញានេះ ហើយសូមព្រះអង្គតបឆ្លើយនឹងពាក្យអង្វររបស់គេផង ។

ធម៌ប្រារព្ធ ៖ គម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់សម្រាប់ព្រះសហគមន៍ដែលជាកូនក្រមុំរបស់ព្រះគ្រីស្ត និងជាព្រះដំណាក់នៃព្រះវិញ្ញាណ ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។
ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។
ប. សូមអរព្រះគុណព្រះអម្ចាស់ ។
គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ព្រះអង្គជាព្រះជាម្ចាស់ដ៏មានឫទ្ធានុភាព និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ដោយព្រះហឫទ័យសប្បុរស ព្រះអង្គគង់នៅក្នុងព្រះវិហារនេះ
ហើយព្រះអង្គគាំទ្រយើងខ្ញុំឲ្យទៅជាព្រះដំណាក់នៃព្រះវិញ្ញាណដ៏វិសុទ្ធ
និងឲ្យមានជីវិតដែលបង្ហាញអំពីសិរីរុងរឿងរបស់ព្រះអង្គ ។
ព្រះអង្គបានបន្សុទ្ធព្រះសហគមន៍ដែលជាភរិយារបស់ព្រះគ្រីស្ត
ហើយរៀងរាល់ឆ្នាំ ព្រះអង្គធ្វើឲ្យអាគារដែលមើលឃើញនឹងភ្នែក
ទៅជាសញ្ញាសម្គាល់នៃព្រះសហគមន៍ ។
សូមប្រោសព្រះសហគមន៍ឲ្យមានអំណរសប្បាយ
និងមានមុខងារជាម្ដាយដែលមានកូនច្រើនឥតគណនា នៅក្នុងសិរីរុងរឿងនៃស្ថាន
បរមសុខ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយប្រកាសឥតឈប់ឈរថា៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !

ពាក្យអរព្រះគុណ

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យព្រះសហគមន៍នៅលើផែនដីនេះ
ជាសញ្ញាសំគាល់នៃក្រុងយេរូសាឡឹមនៅស្ថានបរមសុខ ។
ដោយយើងខ្ញុំបានទទួលព្រះកាយព្រះគ្រីស្ត សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
ទៅជាព្រះដំណាក់នៃការប្រណីសន្ដោសរបស់ព្រះអង្គ
ហើយសូមឲ្យយើងខ្ញុំបានចូលទៅរស់នៅក្នុងកន្លែង
ដែលពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក (Latin p. 614-615) ។

## ថ្ងៃទី ១០ វិច្ឆិកា

# សន្ដឡេអូ ជាជនដ៏ប្រសើរឧត្ដម ជាសម្ដេចប៉ាប និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Leonis Magni, papæ et Ecclesiæ doctoris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គមិនដែលបណ្ដោយឲ្យអំណាចរបស់មារឈ្នះព្រះសហគមន៍ឡើយ ។
ដោយគ្រីស្តទូតជាគ្រឹះដ៏រឹងមាំ
និងតាមរយៈពាក្យទូលអង្វររបស់ សម្ដេចប៉ាប ឡេអូ
សូមព្រះអង្គប្រោសឲ្យព្រះសហគមន៍ ស្ថិតនៅយ៉ាងមាំក្នុងសេចក្ដីពិតរបស់ព្រះអង្គ
និងបានប្រកបដោយសេចក្ដីសុខសាន្តអស់កល្បជានិច្ច ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ !
តាមរយៈតង្វាយដែលយើងខ្ញុំលើកថ្វាយនៅថ្ងៃនេះ
សូមព្រះអង្គប្រទានពន្លឺដល់ព្រះសហគមន៍
ដើម្បីឲ្យហ្វូងចៀមរបស់ព្រះអង្គចម្រើនឡើងគ្រប់ទីកន្លែង ។
នៅក្រោមការណែនាំរបស់ព្រះអង្គ សូមឲ្យគង្វាលទាំងឡាយបេះអរព្រះគុណព្រះអង្គ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គណែនាំព្រះសហគមន៍ ដែលទ្រង់បានចិញ្ចឹមដោយអាហារដ៏ពិសិដ្ឋនេះ ។
សូមឲ្យព្រះសហគមន៍មានសេរីភាពកាន់តែប្រសើរទៅៗ
និងខិតខំព្យាយាមដើរនៅក្នុងជំនឿតែមួយ ។

# ថ្ងៃទី ១១ វិច្ឆិកា
# សន្តម៉ាតាំង ជាអភិបាល នៅក្រុងទួរ

**S. Martini Turonensis, episcopi**

(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
សន្តម៉ាតាំង ជាអភិបាលបានលើកតម្កើងព្រះអង្គ
ទាំងពេលលោកមានជីវិតរស់នៅ ទាំងពេលលោកទទួលមរណភាព ។
យើងខ្ញុំសូមទូលអង្វរព្រះអង្គ សូមទ្រង់បង្ហូរព្រះហឫទ័យប្រណីសន្ដោសដ៏អស្ចារ្យរបស់ព្រះអង្គ
ជ្រាបចូលក្នុងដួងចិត្តយើងខ្ញុំ និងសូមកុំឲ្យការរស់នៅ ឬ សេចក្ដីស្លាប់
នាំយើងខ្ញុំឲ្យឃ្លាតឆ្ងាយពីសេចក្ដីស្រឡាញ់របស់ព្រះអង្គ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
សូមព្រះអង្គបន្សុទ្ធតង្វាយដែលយើងខ្ញុំលើកថ្វាយ
ដោយមានអំណរសប្បាយ នៅថ្ងៃគោរពសន្តម៉ាតាំង ។
សូមប្រោសឲ្យជីវិតរបស់យើងខ្ញុំបែរឆ្ពោះទៅរកព្រះអង្គជានិច្ច
ទាំងនៅពេលមានទុក្ខព្រួយ ទាំងនៅពេលមានសេចក្ដីសុខ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គស្ដារយើងខ្ញុំឲ្យមានកម្លាំងឡើងវិញ ដោយសារអគ្គសញ្ញាដែលបង្រួបបង្រួមជាធ្លុងតែមួយ ។
សូមឲ្យយើងខ្ញុំរួមចិត្តគំនិតជាមួយព្រះអង្គនៅក្នុងគ្រប់កិច្ចការ ។
សន្តម៉ាតាំង បានបន្ទាបខ្លួនចំពោះព្រះអង្គយ៉ាងណា
សូមឲ្យយើងខ្ញុំលើកតម្កើងព្រះអង្គ
ដោយដាក់ខ្លួនជាកម្មសិទ្ធិរបស់ព្រះអង្គយ៉ាងនោះដែរ ។

# ថ្ងៃទី ១២ វិច្ឆិកា

# សន្តយ៉ូសាផាត ជាអភិបាលព្រះសហគមន៍ និងជាមរណសាក្សី

**S. Iosaphat, episcopi et martyris**

(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !

តាមរយៈពាក្យទូលអង្វររបស់សន្តយ៉ូសាផាត សូមព្រះអង្គពង្រឹងជំនឿរបស់ព្រះសហគមន៍ ។

ព្រះវិញ្ញាណព្រះអង្គបានបំភ្លឺសន្តយ៉ូសាផាត ឲ្យហ៊ានបូជាជីវិតសម្រាប់កូនចៀម ។

សូមព្រះអង្គប្រទានឲ្យយើងខ្ញុំមានកម្លាំងដោយសារព្រះវិញ្ញាណនោះ

និងមិនខ្លាចហ៊ានបូជាជីវិតសម្រាប់អ្នកដទៃ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាម្ចាស់ដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង !

សូមព្រះអង្គចាក់បង្ហូរព្រះពរមកលើតង្វាយទាំងនេះ ។

សន្តយ៉ូសាផាតបានប្រកាសជំនឿដោយបូជាជីវិតរបស់លោក

សូមព្រះអង្គប្រទានជំនឿនោះមកយើងខ្ញុំផង ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !

សូមព្រះអង្គប្រទានព្រះវិញ្ញាណនៃសេចក្តីសុខសាន្ត និងភាពរឹងប៉ឹង

ពីតុសក្ការបូជានៃស្ថានបរមសុខនេះ មកយើងខ្ញុំ ។

សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ ហ៊ានលះបង់ជីវិតធ្វើការដើម្បីកិត្តិយស

និងការរួបរួមរបស់ព្រះសហគមន៍ជាធ្លុងតែមួយ តាមគំរូរបស់សន្តយ៉ូសាផាត ។

# ថ្ងៃទី ១៥ វិច្ឆិកា

# សន្តអាល់ប៊ែរ ជាជនដ៏ប្រសើរឧត្តម ជាអភិបាល និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Alberti Magni, episcopi et Ecclesiæ doctoris**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល ៖ (Latin p. 929) ឬពាក្យអធិដ្ឋានរួមសម្រាប់គ្រូបាធ្យាយនៃព្រះសហគមន៍ (Latin p. 943) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !

ព្រះអង្គបានប្រោសឲ្យសន្តអាល់ប៊ែរ ជាអភិបាលទៅជាជនដ៏ប្រសើរឧត្តម

ដោយសារលោកផ្សារភ្ជាប់ទស្សនៈរបស់មនុស្សជាមួយនឹងជំនឿលើព្រះអង្គ ។

សូមព្រះអង្គប្រោសឲ្យយើងខ្ញុំជំពាក់ចិត្តនឹងសេចក្ដីពិតដែលលោកបានបង្រៀន

ហើយតាមរយៈការរីកចម្រើនខាងចំណេះវិជ្ជា

សូមប្រោសឲ្យយើងខ្ញុំស្គាល់ និងស្រឡាញ់ព្រះអង្គកាន់តែខ្លាំងឡើង ។

# ថ្ងៃទី ១៦ វិច្ឆិកា

# សន្តីម៉ាការីតា នៅស្កុតឡែន

**S. Margaritæ Scotiæ**

ពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី៖ សម្រាប់អ្នកដែលប្រព្រឹត្តកិច្ចការធម៌មេត្តាករុណា (Latin p. 963) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !

ព្រះអង្គប្រោសឲ្យសន្តីម៉ាការីតា នៅស្កុតឡែន

មានចិត្តស្រឡាញ់ដ៏លើសលប់ចំពោះជនក្រីក្រ ។

តាមរយៈគំរូ និងពាក្យទូលអង្វររបស់នាង សូមព្រះអង្គប្រោស

ឲ្យយើងខ្ញុំចេះបង្ហាញអំពីព្រះហឫទ័យដ៏សប្បុរសរបស់ព្រះអង្គ

ក្នុងចំណោមមនុស្សជាតិទាំងឡាយ ។

# ថ្ងៃទី ១៦ វិច្ឆិកា
# សន្តីហ្សេទ្រូដ ជាព្រហ្មចារិនី
**S. Gertrudis, virginis**

ពាក្យអធិដ្ឋានរួមសម្រាប់ព្រហ្មចារិនី ៖ សម្រាប់ព្រហ្មចារិនីមួយរូប (Latin p. 946) ។ ឬ ពាក្យអធិដ្ឋានរួមសម្រាប់សន្ដ: សន្ដី ៖ សម្រាបជូនជី (Latin p. 960) ។

## ពាក្យអធិដ្ឋានសរុប
បពិត្រព្រះជាម្ចាស់ !
ព្រះអង្គបានរៀបចំលំនៅដ្ឋានដែលគាប់ព្រះហឫទ័យព្រះអង្គ
ក្នុងដួងចិត្តសន្តីហ្សេទ្រូដ ជាព្រហ្មចារិនី ។
តាមរយៈពាក្យទូលអង្វររបស់នាង សូមព្រះអង្គប្រទានពន្លឺ
ដើម្បីលុបបំបាត់ភាពងងឹតចេញពីចិត្តរបស់យើងខ្ញុំ ។
សូមប្រោសឲ្យយើងខ្ញុំមានអំណរសប្បាយរីករាយ
ដោយជឿជាក់ថា ព្រះអង្គគង់នៅជាមួយ និងបំពេញកិច្ចការក្នុងចិត្តយើងខ្ញុំ ។

# ថ្ងៃទី ១៧ វិច្ឆិកា
# សន្តីអេលីសាបែត នៅហុងគ្រី ជាបព្វជិតា
**S. Elisabeth Hungariæ, religiosæ**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់សន្ដ: សន្ដី៖ សម្រាប់អ្នកដែលប្រព្រឹត្តកិច្ចការធម៌មេត្តាករុណា (Latin p. 963) ។

## ពាក្យអធិដ្ឋានសរុប
ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យសន្តីអេលីសាបែត នៅហុងគ្រី
ទទួលស្គាល់ និងគោរពតម្កើងវត្តមានព្រះគ្រីស្តនៅក្នុងជនក្រីក្រ ។
តាមរយៈពាក្យទូលអង្វររបស់នាង
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំចេះបម្រើអ្នកក្រក្សត់ និងអ្នកកើតទុក្ខព្រួយ
ដោយសេចក្ដីស្រឡាញ់ដែលគ្មានទីបញ្ចប់ ។

# ថ្ងៃទី ១៨ វិច្ឆិកា
# បុណ្យរំឭកថ្ងៃឆ្លងព្រះវិហារបាស៊ីលីកា សន្តសិលា និងសន្តប៉ូល ជាគ្រីស្តទូត

**In Dedicatione basilicarum Ss. Petri et Pauli, apostolorum**

(បុណ្យ)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គតែងតែការពារព្រះសហគមន៍របស់ព្រះអង្គ
ដោយមានក្រុមគ្រីស្តទូតជាកំផែងដ៏រឹងមាំ ។
លោកទាំងពីរបានផ្តល់ចំណេះដឹងដើមដំបូងអំពីព្រះជាម្ចាស់ដល់ព្រះសហគមន៍
តាមរយៈលោកទាំងពីរ សូមព្រះអង្គប្រោសឲ្យព្រះសហគមន៍
កាន់តែទទួលការប្រណីសន្តោស ចាប់ពីពេលនេះ
រហូតដល់អវសាន្តនៃពិភពលោក ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ !
សូមព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយនេះពីយើងខ្ញុំដោយអនុគ្រោះ ។
តាមរយៈបេសកកម្មរបស់គ្រីស្តទូតសិលានិងប៉ូល យើងខ្ញុំបានទទួលសេចក្តីពិត ។
សូមព្រះអង្គឲ្យសេចក្តីពិតនេះ ស្ថិតស្ថេរ និងបរិសុទ្ធក្នុងដួងចិត្តយើងខ្ញុំ ។

ធម៌ប្រារព្ធ បុណ្យគោរពគ្រីស្តទូត ទំព័រ ៤៧៦-៤៧៨ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គបានប្រទាននំបុ័ងពីស្ថានបរមសុខមកចិញ្ចឹមប្រជារាស្ត្ររបស់ព្រះអង្គ ។
នៅថ្ងៃបុណ្យរំឭកគ្រីស្តទូតសិលា និងប៉ូល
សូមប្រោសឲ្យយើងខ្ញុំមានអំណរសប្បាយ ដោយសារឧបការីទាំងពីរ
ដែលជាព្រះអំណោយទានរបស់ព្រះអង្គបានដឹកនាំយើងខ្ញុំ ។

## ថ្ងៃទី ២១ វិច្ឆិកា

# បុណ្យថ្វាយទារិកាព្រហ្មចារិនីម៉ារីនៅក្នុងព្រះវិហារ

**In Praesentatione beatae Mariae Virginis**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់ព្រះនាងព្រហ្មចារិនីម៉ារីពោរពេញដោយសុភមង្គល (Latin p. 897) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !
នៅថ្ងៃនេះ យើងខ្ញុំនឹករឭកដល់ទារិកាព្រហ្មចារិនីម៉ារី
ដែលឪពុកម្ដាយយកទៅថ្វាយព្រះអង្គនៅក្នុងព្រះវិហារ ។
តាមរយៈពាក្យទូលអង្វររបស់ព្រះនាង សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
សមនឹងទទួលការប្រណីសន្ដោសដ៏ពេញលេញពីព្រះអង្គ ។

## ថ្ងៃទី ២២ វិច្ឆិកា

# សន្ដីសេស៊ីល ជាព្រហ្មចារិនី និងជាមរណសាក្សី

**S. Cæciliæ, virginis et martyris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីព្រហ្មចារិនី (Latin p. 924) ឬ
ពាក្យអធិដ្ឋានរួមសម្រាប់ព្រហ្មចារិនី ៖ សម្រាប់ព្រហ្មចារិនីមួយរូប (Latin p. 947) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
រៀងរាល់ឆ្នាំ ព្រះអង្គប្រោសឲ្យយើងខ្ញុំមានអំណរសប្បាយ
នៅថ្ងៃបុណ្យគោរពសន្ដីសេស៊ីល ជាអ្នកបម្រើរបស់ព្រះអង្គ ។
សូមព្រះអង្គមេត្តាប្រទានឲ្យយើងខ្ញុំចេះយកតម្រាប់តាមគំរូរបស់នាង
និងហ៊ានប្រកាសពីកិច្ចការដ៏អស្ចារ្យដែលព្រះគ្រីស្ដជាព្រះបុត្រា
បានប្រព្រឹត្តតាមរយៈអ្នកបម្រើរបស់ព្រះអង្គ ។

## ថ្ងៃទី ២៣ វិច្ឆិកា

# សន្តក្លេម៉ង់ ទី១ ជាសម្តេចប៉ាប និងជាមរណសាក្សី

**S. Clementis I, papæ et martyris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីមួយរូប (Latin p. 915) ឬពាក្យអធិដ្ឋានរួមសម្រាប់អ្នកគង្វាល ៖ សម្រាប់សម្តេចប៉ាប (Latin p. 927) ។

### ពាក្យអធិដ្ឋានសរុប

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គប្រោសឲ្យសន្តបុគ្គលទាំងឡាយមានគុណធម៌យ៉ាងអស្ចារ្យ ។
រៀងរាល់ឆ្នាំ សូមព្រះអង្គប្រោសប្រទានឲ្យយើងខ្ញុំត្រេកអរសប្បាយ
នៅថ្ងៃបុណ្យរំឭកសន្តក្លេម៉ង់ ដែលជាមរណសាក្សី
និងជាមហាបូជាចារ្យរបស់ព្រះបុត្រាព្រះអង្គ ។
តាមលក្ខណៈជាមរណសាក្សី លោកបានបង្ហាញពី
គម្រោងការដ៏អាថ៌កំបាំងរបស់ព្រះអង្គ ហើយតាមរយៈការរស់នៅរបស់លោក
លោកបញ្ជាក់នូវអ្វីៗដែលលោកបានប្រកាសតាមពាក្យសម្ដីរបស់ខ្លួន ។

# សន្តកូឡុមបង់ ជាចៅអធិការ

**S. Columbani, abbatis**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់សាសនទូត (Latin p. 938) ឬពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់ចៅអធិការ (Latin p. 958) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យសន្តកូឡុមបង់ យកចិត្តទុកដាក់ទាំងប្រកាសដំណឹងល្អ
ទាំងស្រឡាញ់ជីវិតរស់នៅជាបព្វជិតក្នុងអារាម ។
តាមរយៈគំរូ និងពាក្យទូលអង្វររបស់លោក សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
ខិតខំប្រឹងប្រែងដើម្បីស្វែងរកព្រះអង្គច្រើនជាងអ្វីៗទាំងអស់ និងដើម្បីនាំអស់អ្នក
ជឿឲ្យមានចំនួនកាន់តែកើនឡើង ។

# ថ្ងៃទី ២៤ វិច្ឆិកា

# សន្តអន់ត្រេ យុងឡាក់ ជាបូជាចារ្យ និងសហជីវិន ជាមរណសាក្សី

**Ss. Andreæ Dũng Lạc, presbyteri, et sociorum, martyrum**

(បុណ្យរំឭក)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គជាប្រភព និងជាឫសគល់នៃភាពជាឪពុកចំពោះមនុស្សលោក ។
ព្រះអង្គប្រោសឲ្យសន្តអន់ត្រេ យុងឡាក់ និងសហជីវិន ជាមរណសាក្សី
មានចិត្តស្រឡាញ់ឈើឆ្កាងរហូតដល់បូជាជីវិត ។
តាមរយៈពាក្យទូលអង្វររបស់អស់លោក សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
ចេះប្រកាសអំពីព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គក្នុងចំណោមបងប្អូនយើងខ្ញុំ
ដើម្បីឲ្យយើងខ្ញុំសមជាបុត្រធីតារបស់ព្រះអង្គ ទាំងឈ្មោះ ទាំងសេចក្ដីពិត ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះបិតាដ៏វិសុទ្ធបំផុត !
នៅថ្ងៃគោរពមរណសាក្សីដ៏វិសុទ្ធដែលរងទុក្ខលំបាក
សូមព្រះអង្គមេត្តាទទួលតង្វាយដែលយើងខ្ញុំថ្វាយទៅព្រះអង្គដោយអនុគ្រោះ ។
នៅពេលយើងខ្ញុំជួបទុក្ខលំបាក
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានចិត្តស្មោះត្រង់ចំពោះព្រះអង្គជានិច្ច
ហើយសូមឲ្យយើងខ្ញុំចេះថ្វាយខ្លួនទាំងស្រុងជាសក្ការបូជា
ដែលគាប់ព្រះហឫទ័យព្រះអង្គ ។

ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គប្រទានឲ្យយើងខ្ញុំមានកម្លាំងជាថ្មី តាមរយៈព្រះកាយព្រះគ្រីស្ត ។
នៅថ្ងៃរំឭកមរណសាក្សីដ៏វិសុទ្ធ យើងខ្ញុំឱនកាយទូលអង្វរព្រះអង្គ
សូមឲ្យយើងខ្ញុំស្ថិតនៅក្នុងសេចក្ដីស្រឡាញ់របស់ព្រះអង្គ
និងមានចិត្តអត់ធ្មត់តស៊ូ ដើម្បីសមនឹងទទួលរង្វាន់អស់កល្បជានិច្ច ។

# ថ្ងៃទី ២៥ វិច្ឆិកា

# សន្តីកាតេរីន នៅអាឡិចសង់ឌ្រី ជាព្រហ្មចារិនី និងជាមរណសាក្សី

**S. Catharinae Alexandrinae, virginis et martyris**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់ព្រហ្មចារិនីជាមរណសាក្សី (Latin p. 924) ឬ ពាក្យអធិដ្ឋានរួមសម្រាប់ព្រហ្មចារិនី ៖ សម្រាប់ព្រហ្មចារិនីមួយរូប (Latin p. 947) ។

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
ព្រះអង្គសព្វព្រះហឫទ័យឲ្យប្រជារាស្ត្ររបស់ព្រះអង្គ ទទួលសន្តីកាតេរីន
នៅអាឡិចសង់ឌ្រី ជាព្រហ្មចារិនី និងជាមរណសាក្សីដែលមិនចេះចុះចាញ់ ។
តាមរយៈពាក្យទូលអង្វររបស់នាង
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំមានជំនឿរឹងមាំ និងឥតងាករេ
ព្រមទាំងលះបង់ប្រយោជន៍ផ្ទាល់ខ្លួន
ដើម្បីបង្រួបបង្រួមព្រះសហគមន៍ជាធ្លុងតែមួយ ។

# ថ្ងៃទី ៣០ វិច្ឆិកា

# សន្តអន់ឌ្រេ ជាគ្រីស្តទូត

**S. ANDREÆ, APOSTOLI**

(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំសូមឱនកាយថ្វាយបង្គំព្រះអង្គជាព្រះដ៏ខ្ពង់ខ្ពស់បំផុត
ព្រះអង្គប្រោសឲ្យគ្រីស្តទូតអន់ឌ្រេពោរពេញដោយសុភមង្គល ធ្វើជាគង្វាល
និងជាអ្នកប្រកាសដំណឹងល្អដល់ព្រះសហគមន៍ព្រះអង្គ ។
សូមព្រះអង្គមេត្តាទទួលពាក្យទូលអង្វររបស់លោកសម្រាប់យើងខ្ញុំ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
នៅថ្ងៃបុណ្យគោរពសន្តអន់ឌ្រេ សូមព្រះអង្គមេត្តាទទួលតង្វាយ
ដែលយើងខ្ញុំលើកថ្វាយ ដោយអនុគ្រោះ ។
សូមឲ្យតង្វាយនេះ បានគាប់ព្រះហឫទ័យព្រះអង្គ និងផ្តល់ជីវិតដល់យើងខ្ញុំ ។

ធម៌ប្រារព្ធ បុណ្យគោរពគ្រីស្តទូត ទំព័រ ៤៧៦-៤៧៨ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គប្រទានព្រះកាយព្រះគ្រីស្តឲ្យយើងខ្ញុំមានកម្លាំងរឹងមាំ ។
តាមគំរូរបស់គ្រីស្តទូត អន់ឌ្រេ ពោរពេញដោយសុភមង្គល
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំទទួលព្រះគ្រីស្តដែលសោយទិវង្គត
មកគង់ក្នុងដួងចិត្តយើងខ្ញុំ ។ សូមឲ្យយើងខ្ញុំសមនឹងរស់នៅជាមួយព្រះគ្រីស្តក្នុងសិរីរុងរឿង ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក (Latin p. 614-615) ។

# ខែ ធ្នូ

## ថ្ងៃទី ៣ ធ្នូ

# សន្តហ្វ្រង់ស័រសាវីយេ៉ ជាបូជាចារ្យ

**S. Francisci Xavier, presbyteri**

(បុណ្យរំឭក)

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !

តាមរយៈការប្រៀនប្រដៅរបស់សន្តហ្វ្រង់ស័រសាវីយេ៉

សូមព្រះអង្គប្រោសឲ្យមនុស្សជាច្រើនបានបែរទៅរកព្រះអង្គ ដោយមានចិត្តឆេះឆួលខ្នះខ្នែងដើម្បីជំនឿ ។ សូមប្រោសឲ្យព្រះសហគមន៍មានអំណរសប្បាយនៅគ្រប់ទីកន្លែង

ដោយមានកូនចៅដ៏ច្រើនកុះករ ។

### ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !

សូមព្រះអង្គមេត្តាទទួលតង្វាយដែលយើងខ្ញុំលើកថ្វាយ

នៅថ្ងៃបុណ្យរំឭកសន្តហ្វ្រង់ស័រសាវីយេ៉ ដោយអនុគ្រោះ ។

ព្រះអង្គបានប្រោសលោកឲ្យធ្វើដំណើរទៅទីឆ្ងាយដាច់ស្រយាល

ក្នុងគោលបំណងសង្គ្រោះមនុស្សលោក ។

សូមព្រះអង្គប្រោសឲ្យយើងខ្ញុំអាចធ្វើជាសាក្សីអំពីព្រះបន្ទូលដំណឹងល្អ

និងរួសរាន់ធ្វើដំណើរឆ្ពោះទៅរកព្រះអង្គរួមជាមួយអស់បងប្អូនយើងខ្ញុំ ។

ពាក្យអរព្រះគុណ

ឱ ព្រះជាម្ចាស់អើយ !
សូមឲ្យសក្ការបូជារបស់ព្រះអង្គជំរុញយើងខ្ញុំ
ឲ្យមានចិត្តឆេះឆួលដោយធម៌មេត្តាករុណា
ដូចសន្តប្រាំងស័រសាវីយេ៉ មានចិត្តឆេះឆួលដើម្បីសង្គ្រោះមនុស្សលោក ។
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យខិតខំបំពេញមុខងាររបស់ខ្លួន
និងទទួលរង្វាន់ដែលព្រះអង្គសន្យាប្រទានឲ្យអស់អ្នកធ្វើការបានល្អ
ក្នុងស្រែរបស់ព្រះអង្គ ។

## ថ្ងៃទី ៤ ធ្នូ

# សន្តយ៉ូហាន នៅដាម៉ាសហ្សែន ជាបូជាចារ្យ និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Ioannis Damasceni, presbyteri et Ecclesiæ doctoris**

ពាក្យអធិដ្ឋានរួមសម្រាប់អ្នកគង្វាល ៖ សម្រាប់គង្វាលមួយរូប (Latin p. 933) ឬ ពាក្យអធិដ្ឋានរួមសម្រាប់គ្រូបាធ្យានៃព្រះសហគមន៍ (Latin p. 943) ។

ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំទូលអង្វរព្រះអង្គ សូមជួយឧបត្ថម្ភយើងខ្ញុំ
តាមពាក្យអធិដ្ឋានរបស់សន្តយ៉ូហាន ជាបូជាចារ្យនៅដាម៉ាសហ្សែន
ដែលប៉ិនប្រសប់បង្រៀន ដើម្បីឲ្យជំនឿដ៏ពិតប្រាកដ ទៅជាពន្លឺ
និងជាកម្លាំងរបស់យើងខ្ញុំ ។

# ថ្ងៃទី ៦ ធ្នូ
# សន្តនីកូឡា ជាអភិបាល

**S. Nicolai, episcopi**

ពាក្យអធិដ្ឋានរួមសម្រាប់អ្នកគង្វាល ៖ សម្រាប់អភិបាល（Latin p. 929）។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ !

យើងខ្ញុំឱនកាយទូលអង្វរព្រះអង្គ សូមឲ្យព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គ
ដែលជាមាគ៌ានៃការសង្គ្រោះបើកចំហរនៅចំពោះមុខយើងខ្ញុំ ។
សូមព្រះអង្គជួយការពារយើងខ្ញុំឲ្យរួចផុតពីអន្តរាយគ្រប់បែបយ៉ាង
តាមរយៈពាក្យទូលអង្វររបស់សន្តនីកូឡា ជាអភិបាល ។

# ថ្ងៃទី ៧ ធ្នូ
# សន្តអំប្រូស ជាអភិបាល និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Ambrosii, episcopi et Ecclesiæ doctoris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យសន្តអំប្រូស ជាអភិបាល
ទៅជាគ្រូបង្រៀននៃជំនឿរបស់ព្រះសហគមន៍ និងជាគំរូនៃសេចក្ដីក្លាហានរបស់គ្រីស្ដទូត ។
សូមព្រះអង្គបង្កើតបុត្រនៅក្នុងព្រះសហគមន៍តាមព្រះហឫទ័យព្រះអង្គ ដើម្បីឲ្យគេគ្រប់គ្រងព្រះសហគមន៍ ដោយមានសេចក្ដីក្លាហាន និងប្រាជ្ញាវាងវៃ ។

ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
នៅពេលយើងខ្ញុំលើកតម្កើងគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ
សូមព្រះវិញ្ញាណបំពេញឲ្យយើងខ្ញុំមានពន្លឺនៃជំនឿ ដែលបំភ្លឺសន្តអំប្រូស
ដើម្បីឲ្យសិរីរុងរឿងរបស់ព្រះអង្គលាតសន្ធឹងនៅគ្រប់ទីកន្លែង ។

ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ដោយសារឫទ្ធានុភាពរបស់ព្រះកាយព្រះគ្រីស្ដ ព្រះអង្គប្រទានឲ្យយើងខ្ញុំមានកម្លាំង
សូមទ្រង់មេត្តាណែនាំយើងខ្ញុំឲ្យទទួលផលផ្លែល្អ ដែលមកពីការប្រៀនប្រដៅរបស់សន្តអំប្រូស ។
សូមឲ្យយើងខ្ញុំរួសរាន់ធ្វើដំណើរតាមមាគ៌ារបស់ព្រះអង្គដោយមិនភ័យខ្លាច ហើយរៀបចំខ្លួនដើម្បីទទួលអាហារដ៏ឈ្ងុយឆ្ងាញ់
ក្នុងពិធីជប់លៀងអស់កល្បជានិច្ចរបស់ព្រះអង្គ ។

# ថ្ងៃទី ៨ ធ្នូ

# បុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារី មិនជំពាក់បាប

**IN CONCEPTIONE IMMACULATA BEATÆ MARIÆ VIRGINIS**

(បុណ្យឱឡារិក)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
ដោយសារព្រះនាងព្រហ្មចារិនីម៉ារីមិនដែលជំពាក់បាប
ព្រះអង្គរៀបចំឲ្យនាងធ្វើជាលំនៅស្ថានដ៏សមរម្យសម្រាប់ព្រះបុត្រាព្រះអង្គ ។
ដោយសារព្រះបុត្រាសោយទិវង្គត ទ្រង់បានការពារនាង
ឲ្យរួចផុតពីភាពសៅហ្មងទាំងឡាយ តាមការគ្រោងទុករបស់ព្រះអង្គ ។
តាមរយៈពាក្យទូលអង្វររបស់ព្រះនាង សូមព្រះអង្គមេត្តាលាងជម្រះចិត្តគំនិតយើងខ្ញុំ និងគង់ជាមួយយើងខ្ញុំ ។

សូត្រធម៌ប្រកាសជំនឿ ។

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
នៅថ្ងៃបុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារីមិនជំពាក់បាប
សូមព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយ ដែលយើងខ្ញុំលើកថ្វាយដោយអនុគ្រោះ ។
យើងខ្ញុំសូមប្រកាសថា ព្រះអង្គសព្វព្រះហឫទ័យប្រោសនាងម៉ារី
មិនឲ្យជំពាក់បាបអ្វីទាំងអស់ ។
តាមរយៈពាក្យទូលអង្វររបស់នាង សូមព្រះអង្គប្រោសយើងខ្ញុំឲ្យរួចផុតពីបាបគ្រប់បែបយ៉ាង ។

ធម៌ប្រារព្ធ ៖ គម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ចំពោះនាងម៉ារី និងព្រះសហគមន៍ ។

បៈ សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

បៈ សូមលើកចិត្តថ្វាយព្រះអង្គ ។

គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។

បៈ សូមអរព្រះគុណព្រះអម្ចាស់ ។

គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។

បពិត្រអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !

ជាព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច

ពិតជាការគួរណាស់ហើយប្រពៃផង ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។

ព្រះអង្គការពារព្រះនាងព្រហ្មចារិនីម៉ារីពីភាពសៅហ្មងនៃបាបដើមដំបូង ។ ព្រះនាងពោរពេញដោយព្រះហឫទ័យប្រណីសន្ដោសពីព្រះអង្គ ។ ព្រះអង្គរៀបចំឲ្យព្រះនាងធ្វើជាព្រះមាតាដ៏ជាទីគោរពរបស់ព្រះបុត្រាព្រះអង្គ និងបង្ហាញពីព្រះសហគមន៍ដើមដំបូងដែលជាកូនក្រមុំស្រស់ស្អាតដ៏បរិសុទ្ធ ។ ព្រះនាងជាព្រហ្មចារិនីដ៏បរិសុទ្ធ បានបង្កើតព្រះបុត្រាជាកូនចៀមដ៏ស្លូតត្រង់ ដែលយាងមករំដោះបាបយើងរាល់គ្នា ។ ព្រះអង្គប្រោសឲ្យព្រះនាងនាំមុខមនុស្សទាំងអស់ ហើយឲ្យនាងធ្វើជាអ្នកជួយអង្វរព្រះហឫទ័យប្រណីសន្ដោស សម្រាប់ប្រជារាស្ត្រព្រះអង្គ និងជាគំរូនៃភាពដ៏វិសុទ្ធ ។ អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត ច្រៀងកោតសរសើរព្រះអង្គ ដោយអំណរសប្បាយ ទាំងប្រកាសថា៖

ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !

ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតាយើងខ្ញុំ !
ព្រះអង្គបានការពារព្រះនាងម៉ារីមិនឲ្យជំពាក់បាប ។
តាមរយៈអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត សូមព្រះអង្គមេត្តាព្យាបាលរបួសនៃទោស
របស់យើងខ្ញុំផង ។

នៅក្នុងពិធីបញ្ចប់ លោកបូជាចារ្យអាចប្រើពាក្យប្រទានពរឱឡារិក（Latin p. 612-613）។

## ថ្ងៃទី ៩ ធ្នូ

# សន្តយ៉ូហាន ឌីអេហ្គូ គូអូត្លាតូអាស៊ីន

**S. Ioannis Didaci Cuauhtlatoatzin**

ពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់សន្តៈមួយរូប （Latin p. 956）។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យសន្តយ៉ូហាន ឌីអេហ្គូ បង្ហាញសេចក្តីស្រឡាញ់
របស់ព្រះនាងព្រហ្មចារិនីម៉ារីដ៏វិសុទ្ធចំពោះប្រជារាស្ត្ររបស់ព្រះអង្គ ។
តាមរយៈពាក្យទូលអង្វររបស់លោក
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំធ្វើតាមព្រះហឫទ័យព្រះអង្គ
ដោយអនុវត្តតាមពាក្យទូន្មានដែលព្រះមាតាប្រទាននៅហ្គ័រដាឡុពេ ។

# ថ្ងៃទី ១១ ធ្នូ
# សន្តដាម៉ាស ទី១ ជាសម្តេចប៉ាប
**S. Damasi I, paæ**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់សម្តេចប៉ាប (Latin p. 927) ។

## ពាក្យអធិដ្ឋានសរុប
ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំលើកតម្កើងគុណធម៌របស់មរណសាក្សី
ដូចសន្តដាម៉ាសជាសម្តេចប៉ាបកោតសរសើរ និងស្រឡាញ់មរណសាក្សីដែរ ។

# ថ្ងៃទី ១២ ធ្នូ
# ព្រះនាងព្រហ្មចារិនីម៉ារី នៅហ្គ័រដាឡូពេ

**Beatæ Mariæ Virginis de Guadalupe**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់ព្រះនាងព្រហ្មចារិនីម៉ារី (Latin p. 897) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានធម៌មេត្តាករុណា !
ព្រះអង្គសព្វព្រះហឫទ័យឲ្យព្រះមាតាដ៏វិសុទ្ធរបស់ព្រះបុត្រា
ថែរក្សាការពារប្រជារាស្ត្រព្រះអង្គនៅព្រះសហគមន៍ហ្គ័រដាឡូពេ ។
សូមព្រះអង្គប្រោសឲ្យអស់អ្នកដែលទូលអង្វរព្រះនាងព្រហ្មចារិនីម៉ារី
នៅហ្គ័រដាឡូពេ ស្វែងរកភាពរីកចម្រើនរបស់មនុស្សលោក
តាមផ្លូវយុត្តិធម៌ និងសុខសន្តិភាពដោយមានជំនឿរឹងមាំ ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយដែលយើងខ្ញុំលើកថ្វាយទៅព្រះអង្គ
នៅថ្ងៃបុណ្យគោរពព្រះនាងម៉ារីនៅហ្គ័រដាឡូពេ ដោយអនុគ្រោះ ។
សូមប្រោសឲ្យសក្ការបូជានេះ ផ្តល់កម្លាំងឲ្យយើងខ្ញុំបំពេញតាមវិន័យរបស់ព្រះអង្គ
ក្នុងឋានៈជាបុត្រធីតាដ៏ពិតប្រាកដរបស់ព្រះនាងព្រហ្មចារិនីម៉ារី ។

## ពាក្យអរព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា !
សូមឲ្យព្រះកាយ និងព្រះលោហិតព្រះបុត្រាព្រះអង្គ
ដែលយើងខ្ញុំទើបបានទទួលពីសក្ការបូជានេះ
សម្រុះសម្រួលយើងខ្ញុំក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ ។
សូមឲ្យយើងខ្ញុំដែលទទួលអំណរសប្បាយពីព្រះនាងម៉ារីនៅហ្គ័រដាឡូពេ
បេះរស់នៅជាផ្លូវតែមួយប្រកបដោយសេចក្តីសុខសាន្តនៅលោកនេះ
រហូតដល់ថ្ងៃព្រះអម្ចាស់យាងមកវិញក្នុងសិរីរុងរឿង ។

# ថ្ងៃទី ១៣ ធ្នូ

# សន្ដីលូស៊ី ជាព្រហ្មចារិនី និងជាមរណសាក្សី

**S. Luciæ, virginis et martyris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់ព្រហ្មចារិនីជាមរណសាក្សី (Latin p. 1276) ឬ ពាក្យអធិដ្ឋានរួមសម្រាប់ព្រហ្មចារិនី ៖ សម្រាប់ព្រហ្មចារិនីមួយរូប (Latin p. 1276) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !

សូមឲ្យពាក្យទូលអង្វររបស់សន្ដីលូស៊ី ជាព្រហ្មចារិនី និងជាមរណសាក្សី នាំឲ្យយើងខ្ញុំមានចិត្តគំនិតថ្មី ។

សូមប្រោសឲ្យយើងខ្ញុំអាចប្រារព្ធបុណ្យកំណើតរបស់សន្ដីលូស៊ី នៅស្ថានបរមសុខ នាពេលឥឡូវនេះ និងឲ្យយើងខ្ញុំសម្លឹងឆ្ពោះទៅកាន់អ្វីៗដែលអស់កល្បជានិច្ច ។

# ថ្ងៃទី ១៤ ធ្នូ
# សន្តយ៉ូហាន នៃព្រះឈើឆ្កាង ជាបូជាចារ្យ និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Ioannis a Cruce, presbyteri et Ecclesiæ doctoris**

(បុណ្យរំឭក)

ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យសន្តយ៉ូហាន ជាបូជាចារ្យ
ថ្វាយខ្លួនទាំងស្រុង និងស្រឡាញ់ព្រះឈើឆ្កាង ។
ដោយយើងខ្ញុំយកតម្រាប់តាមលោកគ្រប់ពេលវេលា សូមព្រះអង្គប្រោសឲ្យយើងខ្ញុំយកចិត្តទុកដាក់អធិដ្ឋានឥតឈប់ឈរ
ក្នុងសិរីរុងរឿងរបស់ព្រះអង្គ ។

ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
សូមព្រះអង្គមេត្តាទតមើលតង្វាយដែលយើងខ្ញុំលើកថ្វាយព្រះអង្គ
នៅថ្ងៃគោរពសន្តយ៉ូហាន នៃព្រះឈើឆ្កាង ។
សូមប្រោសឲ្យយើងខ្ញុំដែលប្រារព្ធពិធីលើកតម្កើង
គម្រោងការដ៏អាថ៌កំបាំងនៃទុក្ខលំបាករបស់ព្រះអម្ចាស់ ហ៊ានធ្វើតាមអ្វីៗដែលយើងខ្ញុំកំពុងប្រព្រឹត្ត ។

ពាក្យអរព្រះគុណ

ឱ ព្រះជាម្ចាស់អើយ !

ព្រះអង្គប្រោសឲ្យសន្តយ៉ូហាន យល់ពីគម្រោងការដ៏អាថ៌កំបាំងនៃព្រះឈើឆ្កាង ។ សូមព្រះអង្គប្រោសឲ្យយើងខ្ញុំដែលទទួលកម្លាំងពីសក្ការបូជានេះ ជាប់ចិត្តជាមួយព្រះគ្រីស្តដោយស្មោះ និងបំពេញភារកិច្ចក្នុងព្រះសហគមន៍ សម្រាប់ការសង្គ្រោះមនុស្សទាំងអស់ ។

# ថ្ងៃទី ១៦ ធ្នូ
# ជនដ៏មានសុភមង្គលទាំង ៧ នៅប្រទេសថៃ ជាមរណសាក្សី

(បុណ្យរំពុក)

នៅប្រទេសថៃសម័យនោះ គ្រីស្តបរិស័ទរងការបៀតបៀនយ៉ាងខ្លាំងពីអាជ្ញាធរ ។ គេហាមលោកគ្រូភីលីព ស៊ីផន អាយុ៣៣ឆ្នាំ មិនឲ្យអប់រំជំនឿជាដាច់ខាត ព្រមទាំងបង្ខំគាត់ឲ្យបោះបង់ជំនឿបោលទៀតផង ។ ប៉ុន្តែ គាត់មិនព្រមធ្វើតាមគេទេ ដូច្នេះហើយ គេក៏សម្លាប់គាត់នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៤០ ។ នៅភូមិមួយទៀត ប៉ូលីសចាប់ដូចជី ២នាក់ គឺបងស្រី អាញ៉ែសនិងបងស្រី លូស៊ី ឲ្យបោះបង់បោលព្រះជាម្ចាស់ តែគាត់មិនព្រមធ្វើតាមទេ ។ ប៉ូលីសខឹងណាស់ក៏នាំបងស្រី ២នាក់ ទៅសម្លាប់នៅឯដីព្រះពរ (ដីរបស់ព្រះសហគមន៍សម្រាប់កប់សពគ្រីស្តបរិស័ទ) ។ ពេលនោះ បងប្អូន ៦ ទៀតៗក៏សុខចិត្តលះបង់ជីវិតរួមជាមួយបងស្រីដែរ ។ ប៉ូលីសបាញ់ប្រហែល ២០គ្រាប់ រួចគេក៏ត្រឡប់ទៅវិញភ្លាម ។ ភ្លាមនោះ អ្នកភូមិក៏ទៅជួយជីករណ្តៅសម្រាប់កប់សពទាំង ៧នាក់នោះ ។

ឈ្មោះជនដ៏មានសុភមង្គលទាំង៧នាក់ មាន ៖

*លោកគ្រូភីលីព **ស៊ីផន** អាយុ ៣៣ឆ្នាំ*

*បងស្រីអាញ៉ែស **ភីឡា** អាយុ ៣១ឆ្នាំ*

*បងស្រីលូស៊ី **ខាំបាង** អាយុ ២៣ឆ្នាំ*

*អាកាថា **ភុត្តា** អាយុ ៥៩ឆ្នាំ*

***សេស៊ីលីយ៉ា** អាយុ ១៦ឆ្នាំ*

*ប៊ីប៊ែនណា **ខាំផៃ** អាយុ ១៥ឆ្នាំ*

*ម៉ារី **ផន** អាយុ ១៤ឆ្នាំ ។*

# ថ្ងៃទី ២១ ធ្នូ
# សន្តសិលាកានីស្ស ជាបូជាចារ្យ និងជាគ្រូបាធ្យាយនៃព្រះសហគមន៍

**S. Petri Canisii, presbyteri et Ecclesiæ doctoris**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល៖ សម្រាប់គង្វាលមួយរូប (Latin p. 927) ឬពាក្យអធិដ្ឋានរួមសម្រាប់គ្រូបាធ្យាយនៃព្រះសហគមន៍ (Latin p. 943) ។

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !

ព្រះអង្គប្រោសឲ្យសន្តសិលា កានីស្ស ជាបូជាចារ្យ មានគុណធម៌រឹងមាំ

និងចំណេះវិជ្ជាខ្ពង់ខ្ពស់ ដើម្បីការពារជំនឿរបស់ព្រះសហគមន៍កាតូលិក ។

តាមរយៈពាក្យទូលអង្វររបស់លោក សូមព្រះអង្គប្រោសឲ្យអស់អ្នកដែលស្វែងរកសេចក្ដីពិត

មានអំណរសប្បាយដោយបានជួបព្រះអង្គដែលជាព្រះជាម្ចាស់របស់ពួកគេ និងប្រោសឲ្យអស់អ្នកជឿខិតខំតស៊ូប្រកាសអំពីព្រះអង្គ ។

# ថ្ងៃទី ២៣ ធ្នូ
# សន្តយ៉ូហាន នៅកេទី ជាបូជាចារ្យ

**S. Ioannis de Kety, presbyteri**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់គង្វាលមួយរូប (Latin p. 927) ឬពាក្យអធិដ្ឋានរួមសម្រាប់សន្តៈ សន្តី ៖ សម្រាប់អ្នកប្រព្រឹត្តកិច្ចការមេត្តាករុណា (Latin p. 943) ។

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
តាមគំរូរបស់សន្តយ៉ូហាន ជាបូជាចារ្យនៅកេទី សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបានរីកចម្រើនឡើងខាងចំណេះដឹងអំពីអ្វីៗដ៏វិសុទ្ធ ។ ដោយយើងខ្ញុំបង្ហាញចិត្តមេត្តាករុណាដល់មនុស្សទាំងអស់
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបានទទួលការលើកលែងទោស
នៅចំពោះព្រះភក្ត្រព្រះអង្គផង ។

# ថ្ងៃទី ២៦ ធ្នូ
# សន្តស្តេផាន ជាមរណសាក្សីទីមួយ

**S. STEPHANI, PROTOMARTYRIS**

(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

បពិត្រព្រះអម្ចាស់ !
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំធ្វើតាមអ្វីៗដែលយើងខ្ញុំគោរពបូជា
និងចេះរៀនស្រឡាញ់ខ្មាំងសត្រូវរបស់យើងខ្ញុំ
ដើម្បីឲ្យយើងខ្ញុំប្រារព្ធបុណ្យកំណើតនៅស្ថានបរមសុខរបស់លោកស្តេផាន
ដែលដឹងអំពីរបៀបអធិដ្ឋានសម្រាប់អស់អ្នកដែលបៀតបៀនលោក ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយ
ដែលយើងខ្ញុំលើកថ្វាយនៅថ្ងៃនេះ ដោយអនុគ្រោះ ។
នៅថ្ងៃបុណ្យរំឭកសន្តស្តេផាន ជាមរណសាក្សី
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យព្រះយេស៊ូប្រសូត ទំព័រ ៤១៨-៤២២ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
ព្រះបិតាបានសង្គ្រោះយើងខ្ញុំតាមរយៈព្រះបុត្រាដែលប្រសូតជាមនុស្ស
ហើយព្រះអង្គប្រទានឲ្យយើងខ្ញុំមានអំណរសប្បាយ
នៅថ្ងៃបុណ្យសន្តស្តេផាន ជាមរណសាក្សី ។
យើងខ្ញុំសូមអរព្រះគុណព្រះអង្គ
ដែលមានព្រះហឫទ័យមេត្តាករុណាដ៏លើសលប់ចំពោះយើងខ្ញុំ ។

# ថ្ងៃទី ២៧ ធ្នូ
# សន្តយ៉ូហាន ជាគ្រីស្តទូត និងជាអ្នកនិពន្ធគម្ពីរ
**S. IOANNIS, APOSTOLI ET EVANGELISTÆ**

(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប
ឱ ព្រះជាម្ចាស់អើយ !

ព្រះអង្គសព្វព្រះហឫទ័យបង្ហាញការអាថ៌កំបាំងនៃព្រះបន្ទូលព្រះអង្គ

ឲ្យមនុស្សលោកតាមរយៈគ្រីស្តទូតយ៉ូហាន ។

សូមព្រះអង្គមេត្តាបំភ្លឺយើងខ្ញុំឲ្យយល់កាន់តែច្បាស់នូវព្រះបន្ទូល

ដែលលោកយ៉ូហានបានប្រកាសតាមរបៀបដ៏អស្ចារ្យឲ្យយើងខ្ញុំឮ ។

## ពាក្យថ្វាយតង្វាយ
ឱ ព្រះអម្ចាស់អើយ !

សូមព្រះអង្គមេត្តាញ៉ាំងតង្វាយដែលយើងខ្ញុំថ្វាយទៅព្រះអង្គឲ្យបានវិសុទ្ធ ។

សូមប្រទានឲ្យយើងខ្ញុំនូវប្រាជ្ញាញាណឈ្វេងយល់

អំពីការលាក់កំបាំងនៃព្រះបន្ទូលអស់កល្បជានិច្ច តាមរយៈពិធីជប់លៀងនៅថ្ងៃនេះ

ដូចព្រះអង្គបានផ្តល់ឲ្យគ្រីស្តទូតយ៉ូហាន តាមរយៈប្រភពតែមួយដែរ ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យព្រះយេស៊ូប្រសូត ទំព័រ ៤១៨-៤២២ ។

## ពាក្យអរព្រះគុណ
បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !

ព្រះអង្គបានជ្រើសរើសគ្រីស្តទូតយ៉ូហាន ឲ្យប្រកាសអំពីព្រះបន្ទូលដែលកើតជាមនុស្ស ។

តាមរយៈអភិបូជាដែលយើងខ្ញុំប្រារព្ធ សូមព្រះអង្គប្រោសឲ្យព្រះបន្ទូលនេះ គង់សណ្ឋិត

ក្នុងចំណោមយើងខ្ញុំគ្រប់ពេលវេលា ។

# ថ្ងៃទី ២៨ ធ្នូ
# ក្មេងដ៏ស្លូតត្រង់ ជាមរណសាក្សី
**SS. INNOCENTIUM, MARTYRUM**

(បុណ្យ)

សូត្រធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (Glória in excélsis)

## ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
នៅថ្ងៃនេះ ក្មេងស្លូតត្រង់ទាំងប៉ុន្មានបានប្រកាសអំពីព្រះជាម្ចាស់
មិនមែនដោយពាក្យសម្ដីទេ គឺដោយបូជាជីវិត ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំហ៊ានបើកមាត់ប្រកាសជំនឿ
តាមរយៈពាក្យសម្ដី និងរបៀបរស់នៅរបស់យើងខ្ញុំផង ។

## ពាក្យថ្វាយតង្វាយ

ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គមេត្តាទទួលតង្វាយពីយើងខ្ញុំដែលជាអ្នកបម្រើ ដោយអនុគ្រោះ ។
តាមរយៈគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ សូមទ្រង់លាងជម្រះចិត្តគំនិតយើងខ្ញុំ
និងផ្ដល់ការសង្គ្រោះដល់មនុស្សលោកផង ។

ធម៌ប្រារព្ធ ក្នុងរដូវបុណ្យព្រះយេស៊ូប្រសូត ទំព័រ ៤១៨-៤២២ ។

## ពាក្យអរព្រះគុណ

ឱ ព្រះអម្ចាស់អើយ !
នៅថ្ងៃគោរពបុណ្យក្មេងស្លូតត្រង់
ដែលមិនទាន់ចេះប្រកាសអំពីព្រះបុត្រារបស់ព្រះអង្គដោយពាក្យសម្ដី
ព្រះអង្គសព្វព្រះហឫទ័យបំពាក់ភួងជ័យឲ្យពួកគេ ដោយសារព្រះបន្ទូលបានប្រសូត ។
សូមព្រះអង្គផ្ដល់អំណោយទានផ្សេងៗ និងប្រទានការសង្គ្រោះយ៉ាងបរិបូណ៌
ដល់អស់អ្នកជឿ ដូចក្មេងទាំងនោះដែរ ។

## ថ្ងៃទី ២៩ ធ្នូ

# សន្តថូម៉ាស បេកេត ជាអភិបាល និងជាមរណសាក្សី

**S. Thomæ Becket, episcopi et martyris**

ពាក្យអធិដ្ឋានរួមសម្រាប់មរណសាក្សី ៖ សម្រាប់មរណសាក្សីមួយរូប (Latin p. 915) ឬពាក្យអធិដ្ឋានរួមសម្រាប់គង្វាល ៖ សម្រាប់អភិបាល (Latin p. 929) ។

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះជាម្ចាស់អើយ !
ព្រះអង្គប្រោសឲ្យសន្តថូម៉ាស បេកេត ជាមរណសាក្សី
មានសេចក្ដីក្លាហានហ៊ានបូជាជីវិតដើម្បីយុត្តិធម៌ ។
តាមរយៈពាក្យទូលអង្វររបស់លោក សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ
ចេះលះបង់ជីវិតរបស់ខ្លួនសម្រាប់ព្រះគ្រីស្ត នៅនាលោកនេះ
និងឲ្យយើងខ្ញុំទទួលជីវិតអស់កល្បជានិច្ចនៅស្ថានបរមសុខ ។

## ថ្ងៃទី ៣១ ធ្នូ

# សន្តស៊ីលវេស្ទ្រី ទី១ ជាសម្ដេចប៉ាប

**S. Silvestri I, papæ**

ពាក្យអធិដ្ឋានរួមសម្រាប់គង្វាល៖ សម្រាប់សម្ដេចប៉ាប (Latin p. 927)

### ពាក្យអធិដ្ឋានសរុប

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គយាងមកជួយប្រជារាស្ត្ររបស់ព្រះអង្គ
តាមរយៈពាក្យទូលអង្វររបស់សន្តស៊ីលវេស្ទ្រី ជាសម្ដេចប៉ាប ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំធ្វើដំណើរក្នុងលោកនេះ ដោយមានអំណរសប្បាយ
នៅក្រោមការណែនាំរបស់ព្រះអង្គឆ្ពោះទៅកាន់ជីវិតអស់កល្បជានិច្ច ។

# មាតិកា

ទំព័រ


**ធម្មនុញ្ញព្រះសហគមន៍ក្បួនពិធីអភិបូជាក្រុងរ៉ូមតាមក្រឹត្យអនុញ្ញាតរបស់មហាសន្និបាតវ៉ាទីកង់ទី២**

CONSTITUTIO APOSTOLICA MISSALE ROMANUM EX DECRETO CONCILII CECUMENICI VATICANI II INSTURATUM PROMULGATUR

**ខ្ញុំប៉ូលជាអភិបាលព្រះសហគមន៍** ........ ៧

**សេចក្ដីណែនាំរបស់មហាសន្និបាតវ៉ាទីកង់ទី២ ស្ដីពីក្បួនពិធីអភិបូជាក្រុងរ៉ូម**

INSTITUTIO GENERALIS MISSALIS ROMANI

**សេចក្ដីផ្ដើម- PROŒMIUM** ........ ១៧

សក្ខីភាពអំពីជំនឿដែលមិនចេះប្រែប្រួល-Testimonium fidei immutatæ ........ ១៧

សាក្សីអំពីការបញ្ជូនបន្តដែលឥតចេះប្រែប្រួល-Tradio non intermissa declaratur ........ ១៩

ការរៀបចំកែសម្រួលឲ្យស្របតាមស្ថានភាពថ្មី-Ad novas rerum condiciones accommodatio......២១

**ជំពូកទី ១**

Caput I

**សារៈសំខាន់ និងមុខងារកំពូលនៃពិធីអរព្រះគុណដ៏វិសុទ្ធ**........ ២៤

**ជំពូកទី ២**

Caput II

**រចនាសម្ព័ន្ធនៃអភិបូជា និងផ្នែកផ្សេងជាគោលការណ៍សំខាន់ៗ** ........ ២៧

I. រចនាសម្ព័ន្ធទូទៅនៃពិធីអភិបូជា........ ២៧

II. គោលការណ៍សំខាន់ៗពីភាពខុសគ្នានៃពិធីអភិបូជា........ ២៧

អានអត្ថបទព្រះគម្ពីរ និងសេចក្ដីអត្ថាធិប្បាយ ........ ២៧

ពាក្យអធិដ្ឋាន និងផ្នែកផ្សេងទៀតដែលលោកបូជាចារ្យត្រូវប្រព្រឹត្ត ........ ២៨

ក្បួនផ្សេងៗក្នុងការប្រារព្ធអភិបូជា ........ ២៩

របៀបនៃការប្រកាសអត្ថបទផ្សេងៗ ........ ២៩

សារៈសំខាន់នៃការច្រៀង ........ ៣០

អាកប្បកិរិយា និងឥរិយាបថ........ ៣១

ភាពស្ងៀមស្ងាត់ ........ ៣២

III. ផ្នែកនីមួយៗនៃពិធីអភិបូជា........ ៣៤

ក. ពិធីប្រារព្ធ ........ ៣៤

ក្បួនដង្ហែរចូលព្រះវិហារ........ ៣៤

គោរពតុសក្ការបូជា និងជំរាបសួស្វាគមន៍អង្គប្រជុំចូលរួម........ ៣៤

ពិធីសូមទទួលសារភាព ........ ៣៥

ពាក្យអង្វព្រះយេស៊ូជាអម្ចាស់៖ ឱ ព្រះអម្ចាស់អើយ ! សូមអាណិតអាសូរ ........ ៣៥
ធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ........ ៣៥
ពាក្យអធិដ្ឋានសរុប ........ ៣៥
ខ. ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់ ........ ៣៦
ភាពស្ងៀមស្ងាត់ជាសក្ការបូជា ........ ៣៦
អានអត្ថបទព្រះគម្ពីរ ........ ៣៦
ស្មូតបន្ទរទំនុកតម្កើង ........ ៣៧
ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ ........ ៣៨
ធម្មទេសនា ........ ៣៨
ការប្រកាសជំនឿ ........ ៣៩
ពាក្យអង្វរសកល ........ ៣៩
គ. ពិធីអរព្រះគុណដ៏វិសុទ្ធ ........ ៤០
ការរៀបចំនំប៉័ង និងស្រាតង្វាយ ........ ៤០
ពាក្យថ្វាយតង្វាយ ........ ៤១
ធម៌អរព្រះគុណដ៏វិសុទ្ធ ........ ៤១
ពិធីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ........ ៤២
ពាក្យអធិដ្ឋានរបស់ព្រះអម្ចាស់ (ធម៌ ឱ ព្រះបិតា) ........ ៤៣
ពិធីជូនសេចក្ដីសុខសាន្ត ........ ៤៣
ពិធីកាច់នំតង្វាយ ........ ៤៣
ទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ........ ៤៤
ឃ. ពិធីបញ្ចប់ ........ ៤៥

## ជំពូកទី ៣

Caput III

**ភារកិច្ចរបស់អ្នកបម្រើពិធីបុណ្យក្នុងអភិបូជា** ........ ៤៦
I. ភារកិច្ចនៃអគ្គសញ្ញាតែងតាំងជាអ្នកបម្រើ ........ ៤៦
II. បេសសកកម្មរបស់អ្នកបម្រើពិធីបុណ្យ ........ ៤៧
ការចាត់តាំងអ្នកបម្រើតុសក្ការបូជា និងអ្នកប្រកាសព្រះបន្ទូល ........ ៤៧
មុខងារផ្សេងៗនៃពិធីបុណ្យ ........ ៤៨
III. ការចាត់ចែងមុខងារនៃពិធីបុណ្យ និងការរៀបចំប្រារព្ធពិធី ........ ៤៩

## ជំពូកទី ៤

Caput IV

**របៀបផ្សេង ៗនៃការប្រារព្ធពិធីអភិបូជា** ........ ៥០
I. ពិធីអភិបូជាដោយមានគ្រីស្តបរិស័ទចូលរួម ........ ៥០
សម្ភារៈដែលត្រូវរៀបចំមុន ........ ៥១
ក. ពិធីអភិបូជាដោយគ្មានលោកឧបដ្ឋាក ........ ៥២

ពិធីប្រារព្ធ ..... ៥២
ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់ ..... ៥៣
ពិធីអរព្រះគុណដ៏វិសុទ្ធ ..... ៥៥
ពិធីបញ្ចប់ ..... ៦០
ខ. ពិធីអភិបូជាដោយមានលោកឧបដ្ឋាក ..... ៦០
ពិធីប្រារព្ធ ..... ៦១
ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់ ..... ៦១
ពិធីអរព្រះគុណដ៏វិសុទ្ធ ..... ៦២
ពិធីបញ្ចប់ ..... ៦៣
គ. មុខងាររបស់អ្នកបម្រើតុសក្ការបូជា ..... ៦៣
ពិធីប្រារព្ធ ..... ៦៤
ពិធីអរព្រះគុណដ៏វិសុទ្ធ ..... ៦៤
ឃ. មុខងាររបស់អ្នកប្រកាសព្រះបន្ទូល ..... ៦៥
ពិធីប្រារព្ធ ..... ៦៥
ពិធីលើកតម្កើងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ..... ៦៥
II. ពិធីអភិបូជាដោយមានលោកបូជាចារ្យចូលរួមច្រើននាក់ ..... ៦៥
ពិធីប្រារព្ធ ..... ៦៨
ពិធីលើកតម្កើងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ..... ៦៨
ពិធីអរព្រះគុណដ៏វិសុទ្ធ ..... ៦៨
របៀបពោលធម៌អរព្រះគុណដ៏វិសុទ្ធ ..... ៦៨
ធម៌អរព្រះគុណដ៏វិសុទ្ធ ទី១ ធម៌អរព្រះគុណដ៏វិសុទ្ធបុរាណពីក្រុងរ៉ូម ..... ៦៩
ធម៌អរព្រះគុណដ៏វិសុទ្ធ ទី២ ..... ៧០
ធម៌អរព្រះគុណដ៏វិសុទ្ធ ទី៣ ..... ៧១
ធម៌អរព្រះគុណដ៏វិសុទ្ធ ទី៤ ..... ៧១
ពិធីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ..... ៧២
ពិធីបញ្ចប់ ..... ៧៤
III. ពិធីអភិបូជាដែលមានលោកបូជាចារ្យតែម្នាក់ និងអ្នកបម្រើម្នាក់ ..... ៧៥
ពិធីប្រារព្ធ ..... ៧៥
ពិធីលើកតម្កើងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ..... ៧៥
ពិធីអរព្រះគុណព្រះជាម្ចាស់ ..... ៧៦
ពិធីបញ្ចប់ ..... ៧៧
IV. ក្បួនចាប់ទូទៅមួយចំនួនពីរបៀបថ្វាយអភិបូជា ..... ៧៧
គោរពតុសក្ការបូជា និងព្រះគម្ពីរដំណឹងល្អ ..... ៧៧
ការលុតជង្គង់ និងឱនកាយ ..... ៧៧
ការអុជធូប ឬដុតកំញាន ..... ៧៨
ពិធីជម្រះឲ្យបានស្អាតបរិសុទ្ធ ..... ៧៩
ពិធីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ..... ៨០

## ជំពូកទី ៥

Caput V


**ការរៀបចំព្រះវិហារ និងគ្រឿងសង្ហារិមសម្រាប់ពិធីអភិបូជា** ........ ៨២

I. គោលការណ៍ទូទៅ........ ៨២

II. ការរៀបចំទីសក្ការបូជាសម្រាប់អភិបូជា ........ ៨៣

តុសក្ការបូជា និងគ្រឿងដ៏សក្ការៈសម្រាប់តុសក្ការបូជា........ ៨៣

តុព្រះបន្ទូល ........ ៨៥

កៅអីសម្រាប់លោកបូជាចារ្យធ្វើជាអធិបតី និងកៅអីផ្សេង ........ ៨៦

III. របៀបរៀបចំព្រះវិហារ ........ ៨៦

កន្លែងសម្រាប់គ្រីស្តបរិស័ទ........ ៨៦

កន្លែងសម្រាប់ក្រុមចម្រៀង និងឧបករណ៍តន្ត្រី........ ៨៧

ព្រះពន្លា ជាកន្លែងទុកព្រះកាយព្រះគ្រីស្ត ........ ៨៧

រូបភាពដ៏សក្ការៈ ........ ៨៨


## ជំពូកទី ៦

Caput VI


**លក្ខណៈផ្សេងៗនៃពិធីអភិបូជា** ........ ៨៩

I. នំ និងស្រាតង្វាយសម្រាប់អភិបូជា........ ៨៩

II. គ្រឿងសង្ហារិមដ៏សក្ការៈ ........ ៨៩

III. សម្ភារៈប្រើប្រាស់លើតុសក្ការបូជា ........ ៩០

III. សម្លៀកបំពាក់ពិសិដ្ឋ ........ ៩១

V. សម្ភារផ្សេងៗដែលត្រូវការនៅក្នុងព្រះវិហារ........ ៩៣


## ជំពូកទី ៧

Caput VII


**ជម្រើសនៃអភិបូជា និងផ្នែកនីមួយៗ** ........ ៩៤

I. ការជ្រើសរើសនៃពិធីអភិបូជា........ ៩៤

II. ជម្រើសនៃអត្ថបទផ្សេងៗសម្រាប់ពិធីអភិបូជា ........ ៩៥

ការអានអត្ថបទព្រះគម្ពីរ ........ ៩៥

ពាក្យអធិដ្ឋាន........ ៩៧

ធម៌អរព្រះគុណដ៏វិសុទ្ធ ........ ៩៧

បទចម្រៀង........ ៩៨

## ជំពូកទី ៨

Caput VIII

**ពិធីអភិបូជាតាមកាលៈទេសៈ និងអភិបូជាអង្វរព្រះជាម្ចាស់សម្រាប់អ្នកដែលបានលាចាកលោកនេះទៅហើយ** ........ ៩៩

I. ពិធីអភិបូជាតាមសេចក្ដីត្រូវការផ្សេងៗ ........ ៩៩

II. ពិធីអភិបូជាអង្វរព្រះជាម្ចាស់ឲ្យវិញ្ញាណក្ខន្ធមនុស្សស្លាប់ទៅហើយ ........ ១០០

## ជំពូកទី ៩

Caput IX

**ការកែសម្រួលស្ថិតនៅក្រោមអំណាចលោកអភិបាល ឬក្រុមលោកអភិបាលប្រចាំភូមិភាគ** ... ១០២

## ពាក្យអធិដ្ឋានតាមរដូវផ្សេងៗ

PROPRIUM DE TEMPORE

**រដូវរង់ចាំ-Tempu Adventus**

អាទិត្យទី១ ក្នុងរដូវរង់ចាំ-DOMINICA I ADVENTUS ........ ១១០

អាទិត្យទី២ ក្នុងរដូវរង់ចាំ-DOMINICA II ADVENTUS ........ ១១៧

អាទិត្យទី៣ ក្នុងរដូវរង់ចាំ-DOMINICA III ADVENTUS ........ ១២៤

អាទិត្យទី៤ ក្នុងរដូវរង់ចាំ-DOMINICA IV ADVENTUS ........ ១៣០

អាទិត្យចុងក្រោយនៃរដូវរង់ចាំ ពីថ្ងៃទី១៧ ដល់ ថ្ងៃទី២៤ធ្នូ-Feriæ a die 17 ad diem 24 decembris ........ ១៣១

**រដូវបុណ្យព្រះយេស៊ូប្រសូត-Tempus Nativtatis**

បុណ្យព្រះយេស៊ូប្រសូត-In Nativitate Domini ........ ១៤០

បុណ្យលើកតម្កើងព្រះរាជវង្ស-S. Farmiliæ Iesu, Mariæ et Ioseph ........ ១៤៥

ថ្ងៃទី៥ ក្នុងសប្ដាហ៍បុណ្យព្រះយេស៊ូប្រសូត-Dies infra octavam ........ ១៤៧

បុណ្យគោរពព្រះនាងម៉ារីជាព្រះមាតារបស់ព្រះជាម្ចាស់-Sollemnitas sanctæ Dei Genetricis Mariæ ........ ១៥០

ថ្ងៃអាទិត្យទី ២ ក្រោយបុណ្យព្រះយេស៊ូប្រសូត-Dominica II post Nativitatem ........ ១៥១

បុណ្យព្រះយេស៊ូសម្ដែងព្រះអង្គ-In Epiphania Domini ........ ១៥២

សប្ដាហ៍ក្នុងរដូវបុណ្យព្រះយេស៊ូប្រសូត-In feriis temporis Nativitatis ........ ១៥៥

បុណ្យព្រះអម្ចាស់យេស៊ូទទួលពិធីជ្រមុជទឹក-In Baptismate Domini ........ ១៦១

**ពាក្យអធិដ្ឋានក្នុងរដូវសែសិបថ្ងៃ-Tempus Quadragesimæ**

ថ្ងៃពុធ ផេះ-Feria IV Cinerum ........ ១៦៦

ថ្ងៃអាទិត្យទី ១ ក្នុងរដូវសែសិបថ្ងៃ-Dominica et hebdomada I ........ ១៧១

ថ្ងៃអាទិត្យទី ២ ក្នុងរដូវសែសិបថ្ងៃ-Dominica et hebdomada II ........ ១៧៩

ថ្ងៃអាទិត្យទី ៣ ក្នុងរដូវសែសិបថ្ងៃ-Dominica et hebdomada III ........ ១៨៧

ថ្ងៃអាទិត្យទី ៤ ក្នុងរដូវសែសិបថ្ងៃ-Dominica et hebdomada IV ........ ១៩៥

ថ្ងៃអាទិត្យទី ៥ ក្នុងរដូវសែសិបថ្ងៃ-Dominica et hebdomada V ........ ២០៣

## សប្ដាហ៍ពិសិដ្ឋ-Hebdomada sancta


ថ្ងៃអាទិត្យបុណ្យហែស្លឹក លើកតម្កើងព្រះអម្ចាស់រងទុក្ខលំបាក-Dominica in Palmis de Passione Domini .....២១៤
ថ្ងៃចន្ទ ក្នុងសប្ដាហ៍ពិសិដ្ឋ-Feriæ.....២២០
ថ្ងៃអង្គារ ក្នុងសប្ដាហ៍ពិសិដ្ឋ FERIA III HEBDOMADÆ SANCTÆ.....២២១
ថ្ងៃពុធ ក្នុងសប្ដាហ៍ពិសិដ្ឋ FERIA IV HEBDOMADÆ SANCTÆ.....២២២
ថ្ងៃព្រហស្បតិ៍ ក្នុងសប្ដាហ៍ពិសិដ្ឋ-Feria V, ad Missam Chrismatis.....២២៣


## ត្រៃទិវានៃបុណ្យចម្លង-Sacrum Triduum Paschale


ថ្ងៃព្រហស្បតិ៍ពិសិដ្ឋ ព្រះអម្ចាស់ជប់លៀង - Feria V, Ad Missam vespertinam in Cena Domini.....២៣៦
ថ្ងៃសុក្រពិសិដ្ឋ (ព្រះយេស៊ូសោយទិវង្គត) - Feria VI in Passione Domini.....២៤៥
ភាគទី មួយ ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់ LITURGIA VERBI.....២៤៦
ភាគទី ពីរ ពិធីថ្វាយបង្គំព្រះឈើឆ្កាង ADORATIO SANCTÆ CRUCIS.....២៥៣
បង្ហាញព្រះឈើឆ្កាង OSTENSIO SANCTÆ CRUCIS
ភាគទី បី ពិធីទទួលព្រះកាយព្រះគ្រីស្ដ SACRA COMMUNIO.....២៥៤
ថ្វាយបង្គំព្រះឈើឆ្កាង
ថ្ងៃសៅរ៍ពិសិដ្ឋ-Sabbato Sancto.....២៥៨
ថ្ងៃអាទិត្យបុណ្យចម្លង ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ-Dominica Paschæ in Resurrectione Domini
រាត្រីបុណ្យចម្លង ព្រះយេស៊ូមានជ័យជម្នះលើសេចក្ដីស្លាប់-Vigilia paschalis, in nocte sancta.....២៦០
អភិបូជានៅពេលថ្ងៃ-Ad Missam in.....២៨៨


## រដូវបុណ្យចម្លង - Tempus Paschale


ថ្ងៃអាទិត្យទី ១ នៃបុណ្យចម្លង-Dies infra Octavam Paschæ.....២៩១
ថ្ងៃអាទិត្យទី ២ ក្នុងរដូវបុណ្យចម្លង-Dominica et hebdomada II.....២៩៧
ថ្ងៃអាទិត្យទី ៣ ក្នុងរដូវបុណ្យចម្លង-Dominica et hebdomada III.....៣០៤
ថ្ងៃអាទិត្យទី ៤ ក្នុងរដូវបុណ្យចម្លង-Dominica et hebdomada IV.....៣១១
ថ្ងៃអាទិត្យទី ៥ ក្នុងរដូវបុណ្យចម្លង-Dominica et hebdomada V.....៣១៨
ថ្ងៃអាទិត្យទី ៦ ក្នុងរដូវបុណ្យចម្លង-Dominica et hebdomada VI.....៣២៥
បុណ្យលើកតម្កើងព្រះជាម្ចាស់លើកព្រះយេស៊ូឡើងស្ថានបរមសុខ-In Ascensione Domini.....៣៣៣
ថ្ងៃអាទិត្យទី ៧ ក្នុងរដូវបុណ្យចម្លង-Dominica et hebdomada VII.....៣៣៦
បុណ្យលើកតម្កើងព្រះវិញ្ញាណយាងមក-Dominica Pentecostes.....៣៤៣


## រដូវធម្មតា « ប្រចាំឆ្នាំ » - Tempus « per annum »


ក្រោយថ្ងៃបុណ្យទីហាសិបមានបុណ្យយ៉ាងឱឡារិកក្នុងរដូវធម្មតា
Sollemnitates Domini «per annum » occurrentes
ពាក្យអធិដ្ឋាន ក្នុងរដូវធម្មតា « ប្រចាំឆ្នាំ ».....៣៤៩
បុណ្យលើកតម្កើងព្រះត្រៃឯក-Sanctissimæ Trinitatis.....៣៨៥
បុណ្យលើកតម្កើងព្រះកាយ និងព្រះលោហិតព្រះយេស៊ូគ្រីស្ដ-Ss. mi Corporis et Sanguinis Christi.....៣៨៨
ព្រះហឫទ័យមេត្តាករុណារបស់ព្រះយេស៊ូ-Sacratissimi Cordis Iesu.....៣៩១
ព្រះគ្រីស្ដជាព្រះមហាក្សត្រនៃពិភពលោក-Domini nostril Iesu Christi universorum Regis.....៣៩៣

# ក្បួនពិធីអភិបូជា
ORDO MISSÆ

**ក្បួនពិធីអភិបូជា-Ordo Missæ**


ពិធីប្រារព្ធ Ritus initiales ........ ៣៩៩
ធម៌អរព្រះគុណដ៏វិសុទ្ធ- Preces eucharistica ........ ៤១៣
ធម៌ប្រារព្ធទី ១ ក្នុងរដូវរង់ចាំ PRÆFATIO I DE ADVENTU ........ ៤១៤
ធម៌ប្រារព្ធទី ២ ក្នុងរដូវរង់ចាំ PRÆFATIO I DE ADVENTU ........ ៤១៦
ធម៌ប្រារព្ធទី ១ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត ........ ៤១៨
ធម៌ប្រារព្ធទី ២ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត ........ ៤២០
ធម៌ប្រារព្ធទី ៣ ក្នុងរដូវបុណ្យព្រះអម្ចាស់យេស៊ូប្រសូត ........ ៤២២
ធម៌ប្រារព្ធ ក្នុងបុណ្យព្រះយេស៊ូសម្ដែងព្រះអង្គ ........ ៤២៤
ធម៌ប្រារព្ធទី ១ ក្នុងរដូវសែសិបថ្ងៃ PRÆFATIO I DE QUADRAGESIMA ........ ៤២៦
ធម៌ប្រារព្ធទី ២ ក្នុងរដូវសែសិបថ្ងៃ PRÆFATIO II DE QUADRAGESIMA ........ ៤២៨
ធម៌ប្រារព្ធទី ៣ ក្នុងរដូវសែសិបថ្ងៃ PRÆFATIO III DE QUADRAGESIMA ........ ៤៣០
ធម៌ប្រារព្ធទី ៤ ក្នុងរដូវសែសិបថ្ងៃ PRÆFATIO IV DE QUADRAGESIMA ........ ៤៣២
ធម៌ប្រារព្ធទី ១ លើកតម្កើងព្រះអម្ចាស់សោយទុក្ខលំបាក ........ ៤៣៤
ធម៌ប្រារព្ធទី ២ លើកតម្កើងព្រះអម្ចាស់សោយទុក្ខលំបាក ........ ៤៣៦
ធម៌ប្រារព្ធទី ១ ក្នុងរដូវបុណ្យចម្លង PRÆFATIO PASCHALIS I ........ ៤៣៨
ធម៌ប្រារព្ធទី ២ ក្នុងរដូវបុណ្យចម្លង PRÆFATIO PASCHALIS II ........ ៤៤០
ធម៌ប្រារព្ធទី ៣ ក្នុងរដូវបុណ្យចម្លង PRÆFATIO PASCHALIS III ........ ៤៤២
ធម៌ប្រារព្ធទី ៤ ក្នុងរដូវបុណ្យចម្លង PRÆFATIO PASCHALIS IV ........ ៤៤៤
ធម៌ប្រារព្ធទី ១ បុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ PRÆFATIO I DE ASCENSIONE DOMINI ........ ៤៤៨
ធម៌ប្រារព្ធទី ២ បុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ ........ ៤៤៨, ៤៥០
ធម៌ប្រារព្ធទី ១ ថ្ងៃអាទិត្យក្នុងរដូវធម្មតា PRÆFATIO I DE DOMINICIS « PER ANNUM » ........ ៤៥២
ធម៌ប្រារព្ធទី ២ ថ្ងៃអាទិត្យក្នុងរដូវធម្មតា PRÆFATIO II DE DOMINICIS « PER ANNUM » ........ ៤៥៤
ធម៌ប្រារព្ធទី ៣ ថ្ងៃអាទិត្យក្នុងរដូវធម្មតា PRÆFATIO III DE DOMINICIS « PER ANNUM » ........ ៤៥៦
ធម៌ប្រារព្ធទី ៤ ថ្ងៃអាទិត្យក្នុងរដូវធម្មតា PRÆFATIO IV DE DOMINICIS « PER ANNUM » ........ ៤៦៨
ធម៌ប្រារព្ធទី ៥ ថ្ងៃអាទិត្យក្នុងរដូវធម្មតា PRÆFATIO V DE DOMINICIS « PER ANNUM » ........ ៤៦០
ធម៌ប្រារព្ធទី ៦ ថ្ងៃអាទិត្យក្នុងរដូវធម្មតា PRÆFATIO VI DE DOMINICIS « PER ANNUM » ........ ៤៦២
ធម៌ប្រារព្ធទី ៧ ថ្ងៃអាទិត្យក្នុងរដូវធម្មតា PRÆFATIO VII DE DOMINICIS « PER ANNUM » ........ ៤៦៤
ធម៌ប្រារព្ធទី ៨ ថ្ងៃអាទិត្យក្នុងរដូវធម្មតា PRÆFATIO VIII DE DOMINICIS « PER ANNUM » ........ ៤៦៦
ធម៌ប្រារព្ធទី ១ បុណ្យព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ........ ៤៦៨
ធម៌ប្រារព្ធទី ២ បុណ្យព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ........ ៤៧០
ធម៌ប្រារព្ធទី ១ បុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារី ........ ៤៧២
ធម៌ប្រារព្ធទី ២ បុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារី ........ ៤៧៤
ធម៌ប្រារព្ធទី ១ បុណ្យគោរពគ្រីស្តទូត PRÆFATIO I DE APOSTOLIS ........ ៤៧៦
ធម៌ប្រារព្ធទី ២ បុណ្យគោរពគ្រីស្តទូត PRÆFATIO II DE APOSTOLIS ........ ៤៧៨

ធម៌ប្រារព្ធទី ១ បុណ្យគោរពសន្តបុគ្គលទាំងឡាយ PRÆFATIO I DE SANCTIS ........ ៤៨០
ធម៌ប្រារព្ធទី ២ បុណ្យគោរពសន្តបុគ្គលទាំងឡាយ PRÆFATIO II DE SANCTIS ........ ៤៨២
ធម៌ប្រារព្ធទី ១ បុណ្យគោរពមរណសាក្សី PRÆFATIO I DE SANCTIS MARTYRIBUS ........ ៤៨៤
ធម៌ប្រារព្ធទី ២ បុណ្យគោរពមរណសាក្សី PRÆFATIO II DE SANCTIS MARTYRIBUS ........ ៤៨៦
ធម៌ប្រារព្ធ បុណ្យគោរពសន្តបុគ្គលជាគង្វាល PRÆFATIO DE SANCTIS PASTORIBUS ........ ៤៨៨
ធម៌ប្រារព្ធ បុណ្យបញ្ញជិត បញ្ញជិតាជាព្រហ្មចារី ........ ៤៩០
ធម៌ប្រារព្ធទី ១ សម្រាប់ថ្ងៃធម្មតា PRÆFATIO COMMUNIS I ........ ៤៩២
ធម៌ប្រារព្ធទី ២ សម្រាប់ថ្ងៃធម្មតា PRÆFATIO COMMUNIS II ........ ៤៩៤
ធម៌ប្រារព្ធទី ៣ សម្រាប់ថ្ងៃធម្មតា PRÆFATIO COMMUNIS III ........ ៤៩៦
ធម៌ប្រារព្ធទី ៤ សម្រាប់ថ្ងៃធម្មតា PRÆFATIO COMMUNIS IV ........ ៤៩៨
ធម៌ប្រារព្ធទី ៥ សម្រាប់ថ្ងៃធម្មតា PRÆFATIO COMMUNIS V ........ ៥០០
ធម៌ប្រារព្ធទី ៦ សម្រាប់ថ្ងៃធម្មតា PRÆFATIO COMMUNIS VI ........ ៥០២
ធម៌ប្រារព្ធទី ១ សម្រាប់មរណបុគ្គល PRÆFATIO I DE DEFUNCTIS ........ ៥០៤
ធម៌ប្រារព្ធទី ២ សម្រាប់មរណបុគ្គល PRÆFATIO II DE DEFUNCTIS ........ ៥០៦
ធម៌ប្រារព្ធទី ៣ សម្រាប់មរណបុគ្គល PRÆFATIO III DE DEFUNCTIS ........ ៥០៨
ធម៌ប្រារព្ធទី ៤ សម្រាប់មរណបុគ្គល PRÆFATIO IV DE DEFUNCTIS ........ ៥១០
ធម៌ប្រារព្ធទី ៥ សម្រាប់មរណបុគ្គល PRÆFATIO V DE DEFUNCTIS ........ ៥១២

**ធម៌អរព្រះគុណដ៏វិសុទ្ធ PRECES EUCHARISTICÆ**

ធម៌អរព្រះគុណដ៏វិសុទ្ធទី ១- Prex eucharistica I seu Canon romanus ........ ៥១៧
ធម៌អរព្រះគុណដ៏វិសុទ្ធទី ២- Prex eucharistica II ........ ៥៣៤
ធម៌អរព្រះគុណដ៏វិសុទ្ធទី ៣- Prex eucharistica III ........ ៥៤០
ធម៌អរព្រះគុណដ៏វិសុទ្ធទី ៤- Prex eucharistica IV ........ ៥៤៧
ពិធីទទួលព្រះកាយ និងព្រះលោហិត - Ritus Communionis ........ ៥៥៥
ពិធីបញ្ចប់ - Ritus Conclusionis ........ ៥៦០
ធម៌អរព្រះគុណដ៏វិសុទ្ធ បន្ថែមខាងចុងសៀវភៅក្បួនពិធីអភិបូជា - Appendix ad Ordinem Missæ........
ធម៌អរព្រះគុណដ៏វិសុទ្ធ “ផ្សះផ្សាមនុស្សលោក” ទី ១ - Prex eucharistica « de reconciliatione », I ........ ៥៦៥
ធម៌អរព្រះគុណដ៏វិសុទ្ធ “ផ្សះផ្សាមនុស្សលោក” ទី ២ - Prex eucharistica « de reconciliatione », II ...... ៥៧២
ធម៌អរព្រះគុណដ៏វិសុទ្ធប្រើក្នុងឱកាសផ្សេងៗ - Prex eucharistica quæ in Missis pro variis necessitatibus adhiberi potest ..
ធម៌អរព្រះគុណដ៏វិសុទ្ធ “ប្រើក្នុងឱកាសផ្សេងៗ” ទី១ - Forma I ........ ៥៧៩
ធម៌អរព្រះគុណដ៏វិសុទ្ធ “ប្រើក្នុងឱកាសផ្សេងៗ” ទី២ - Forma II ........ ៥៨៧
ធម៌អរព្រះគុណដ៏វិសុទ្ធ “ប្រើក្នុងឱកាសផ្សេងៗ” ទី៣ - Forma III ........ ៥៩៤
ធម៌អរព្រះគុណដ៏វិសុទ្ធ “ប្រើក្នុងឱកាសផ្សេងៗ” ទី៤ - Forma IV ........ ៦០១

# ពាក្យអធិដ្ឋានសម្រាប់សន្ត សន្តីទាំងឡាយ

PROPRIUM DE SANCTIS


ខែ មករា ..... ៦១១

ខែ កុម្ភៈ ..... ៦២៣

ខែ មីនា..... ៦៣៦

ខែ មេសា ..... ៦៤៦

ខែឧសភា ..... ៦៥៥

ខែ មិថុនា ..... ៦៦៩

ខែ កក្កដា ..... ៦៨៦

ខែ សីហា ..... ៧០១

ខែ កញ្ញា ..... ៧២៩

ខែ តុលា ..... ៧៦១

ខែ វិច្ឆិកា..... ៧៧៩

ខែ ធ្នូ ..... ៨០១